# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ១៣

បាលីប្រែ ២០

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

# និង

# បបញ្ចសូទនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# មជ្ឈិមនិកាយ មូលបណ្ណាសក

# បឋមភាគ

# ១៣

# បាលីប្រែ ២០



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ១៣

# សុត្តន្តបិដក

# មជ្ឈិមនិកាយ មូលបណ្ណាសក

*សូមនមស្ការ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ*

## មូលបរិយាយវគ្គ

## មូលបរិយាយសូត្រទី ១

[១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគទ្រង់គង់ក្រោមម្លប់សាលរាជព្រឹក្ស[១] ក្នុងសុភគវ័ន ( ព្រៃជាទីត្រេកអរនៃជនច្រើន ) ជិតក្រុងឧក្កដ្ឋា ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ដូច្នេះ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងបរិយាយ ដែលជាឫសគល់នៃធម៌ទាំងពួង ប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះ ចូរយកចិត្តទុកដាក់ដោយប្រពៃ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[២] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្តាប់ មិនបានឃើញ នូវព្រះអរិយៈទាំងឡាយ

---

១- សូមមើលអដ្ឋកថាខាងក្រោម ។

( មានព្រះពុទ្ធជាដើម ) មិនឈ្លាសក្នុងអរិយធម៌[១] មិនបានទូន្មានខ្លួន ក្នុងអរិយធម៌ គឺមិនមានអរិយធម៌ មិនឃើញនូវពួកសប្បុរស មានព្រះពុទ្ធជាដើម មិនឈ្លាសក្នុងសប្បុរសធម៌ មិនបានទូន្មានខ្លួនក្នុងសប្បុរសធម៌ រមែងសម្គាល់នូវផែនដីថា ជាផែនដីពិត លុះសម្គាល់នូវផែនដីថា ជាផែនដីពិតហើយ ក៏រប់អាននូវផែនដី រប់អានក្នុងផែនដី រប់អានថា ផែនដីពិត រប់អានថា ផែនដីជារបស់អញ ត្រេកអរនឹងផែនដី ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរនៃផែនដីនោះមិនបាន ។ បុថុជ្ជនតែងសម្គាល់នូវទឹកថា ជាទឹកពិត លុះសម្គាល់នូវទឹកថា ជាទឹកពិតហើយ ក៏រប់អាននូវទឹក រប់អានក្នុងទឹក រប់អានថាទឹកពិត រប់អានថាទឹកជារបស់អញ ត្រេកអរនឹងទឹក ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរទឹកនោះមិនបាន ។ បុថុជ្ជនសម្គាល់នូវភ្លើងថា ជាភ្លើងពិត លុះសម្គាល់នូវភ្លើងថា ជាភ្លើងពិតហើយ ក៏រប់អាននូវភ្លើង រប់អានក្នុងភ្លើង រប់អានថាភ្លើងពិត រប់អានថាភ្លើងជារបស់អញ ត្រេកអរនឹងភ្លើង ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរភ្លើងនោះមិនបាន ។ បុថុជ្ជនសម្គាល់នូវខ្យល់ ថាជាខ្យល់ពិត លុះសម្គាល់នូវខ្យល់ថាជាខ្យល់ពិតហើយ ក៏រប់អាននូវខ្យល់ រប់អានក្នុងខ្យល់ រប់អានថាខ្យល់ពិត រប់អានថាខ្យល់ជារបស់អញ ត្រេកអរនឹងខ្យល់ ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគត

---

១- សូមមើលអដ្ឋកថាខាងក្រោម ។

ពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរខ្យល់នោះមិនបាន ។ បុថុជ្ជន សម្គាល់នូវពួកសត្វថា ជាសត្វពិត លុះសម្គាល់នូវពួកសត្វថា ជាសត្វពិតហើយ ក៏រមែងប្រកាន់នូវពួកសត្វ ប្រកាន់ក្នុងពួកសត្វ ប្រកាន់ថាសត្វពិត ប្រកាន់ថា ពួកសត្វជារបស់អញ ត្រេកអរនឹងពួកសត្វ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរសត្វនោះមិនបាន ។ បុថុជ្ជនសម្គាល់នូវពួកទេវតាថាជាទេវតាពិត លុះសម្គាល់នូវពួកទេវតាថាជា ទេវតាពិតហើយ ក៏រមែងប្រកាន់នូវពួកទេវតា ប្រកាន់ក្នុងពួកទេវតា ប្រកាន់ថា ទេវតាពិត ប្រកាន់ថាពួកទេវតាជារបស់អញ ត្រេកអរនឹងពួកទេវតា ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរទេវតានោះមិនបាន ។ បុថុជ្ជនសម្គាល់នូវមារថា ជាមារពិត លុះសម្គាល់នូវមារថាជាមារពិតហើយ ក៏រមែងប្រកាន់នូវមារ ប្រកាន់ក្នុងមារ ប្រកាន់ថាមារពិត ប្រកាន់ថាមារជារបស់អញ ត្រេកអរនឹងមារ ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរ មារនោះមិនបាន ។ បុថុជ្ជនសម្គាល់នូវព្រហ្មថាជាព្រហ្មពិត លុះសម្គាល់នូវព្រហ្មថាព្រហ្មពិតហើយ ក៏រមែងប្រកាន់នូវព្រហ្ម ប្រកាន់ក្នុងព្រហ្ម ប្រកាន់ថា ព្រហ្មពិត ប្រកាន់ថាព្រហ្មជារបស់អញ ត្រេកអរនឹងព្រហ្ម ។ ដំណើរនោះ ព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរ ព្រហ្មនោះមិនបាន ។ បុថុជ្ជនសម្គាល់នូវពួកអាភស្សរព្រហ្មថា ជាអាភស្សរព្រហ្មពិត លុះសម្គាល់នូវពួកអាភស្សរព្រហ្ម ថាជាអាភស្សរព្រហ្មពិត

ហើយ ក៏រាប់អាននូវពួកអកនិដ្ឋព្រហ្ម រាប់អានក្នុងពួកអកនិដ្ឋព្រហ្ម រាប់-អានថា ពួកអកនិដ្ឋព្រហ្មពិត រាប់អានថាពួកអកនិដ្ឋព្រហ្មជារបស់អញ ត្រេកអរ នឹងពួកអកនិដ្ឋព្រហ្ម ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគត ពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរអកនិដ្ឋព្រហ្មមិនបាន ។ បុថុជ្ជនសម្គាល់នូវពួកសុភកិណ្ហព្រហ្ម ថាជាសុភកិណ្ហព្រហ្មពិត លុះសម្គាល់ នូវពួកសុភកិណ្ហព្រហ្ម ថាជាសុភកិណ្ហព្រហ្មពិតហើយ ក៏រាប់អាននូវពួក សុភកិណ្ហព្រហ្ម រាប់អានក្នុងពួកសុភកិណ្ហព្រហ្ម រាប់អានថា ពួកសុភកិណ្ហ-ព្រហ្មពិត រាប់អានថាពួកសុភកិណ្ហព្រហ្មជារបស់អញ ត្រេកអរនឹងពួកសុភ-កិណ្ហព្រហ្ម ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរសុភកិណ្ហព្រហ្មមិនបាន ។ បុថុជ្ជនសម្គាល់នូវពួកវេហប្ផ-លព្រហ្ម ថាជាវេហប្ផលព្រហ្មពិត លុះសម្គាល់នូវពួកវេហប្ផលព្រហ្ម ថាជា វេហប្ផលព្រហ្មពិតហើយ ក៏រាប់អាននូវពួកវេហប្ផលព្រហ្ម រាប់អានក្នុងពួក វេហប្ផលព្រហ្ម រាប់អានថា វេហប្ផលព្រហ្មពិត រាប់អានថាវេហប្ផលព្រហ្ម ជារបស់អញ ត្រេកអរនឹងពួកវេហប្ផលព្រហ្ម ។ ដំណើរនោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរវេហប្ផលព្រហ្មនោះ មិនបាន ។ បុថុជ្ជនសម្គាល់នូវអសញ្ញិសត្វថា ជាអសញ្ញិសត្វពិត លុះ សម្គាល់នូវអសញ្ញិសត្វថាជាអសញ្ញិសត្វពិតហើយ ក៏រាប់អាននូវអសញ្ញិសត្វ រាប់អានក្នុងអសញ្ញិសត្វ រាប់អានថា អសញ្ញិសត្វពិត រាប់អានថា អសញ្ញិ-សត្វជារបស់អញ ត្រេកអរនឹងអសញ្ញិសត្វ ។ ដំណើរនោះព្រោះហេតុអ្វី ។

តថាគតពោលថា ព្រោះបុថុជ្ជននោះកំណត់នូវដំណើរអសញ្ញិសត្វមិនបាន ។ បុថុជ្ជនសម្គាល់នូវអាកាសានញ្ចាយតនព្រហ្មថា ជាអាកាសានញ្ចាយតនព្រហ្មពិត លុះសម្គាល់នូវអាកាសានញ្ចាយតនព្រហ្មថា ជាអាកាសានញ្ចាយតនព្រហ្មពិតហើយ រមែងសំគាល់នូវអាកាសានញ្ចាយតនព្រហ្ម រមែងសំគាល់ក្នុងអាកាសានញ្ចាយតនព្រហ្ម រមែងសំគាល់ថា អាកាសានញ្ចាយតនព្រហ្មពិត រមែងសំគាល់ថា អាកាសានញ្ចាយតនព្រហ្មជារបស់អញ ត្រេកអរនឹងអាកាសានញ្ចាយតនព្រហ្ម ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះកំណត់នូវដំណើរអាកាសានញ្ចាយតនព្រហ្មនោះមិនបាន ។ បុថុជ្ជនសម្គាល់នូវវិញ្ញាណញ្ចាយតនព្រហ្ម ថាជាវិញ្ញាណញ្ចាយតនព្រហ្មពិត លុះសម្គាល់នូវវិញ្ញាណញ្ចាយតនព្រហ្មថាជាវិញ្ញាណញ្ចាយតនព្រហ្មពិតហើយ ក៏រមែងសំគាល់នូវវិញ្ញាណញ្ចាយតនព្រហ្ម រមែងសំគាល់ក្នុងវិញ្ញាណញ្ចាយតនព្រហ្ម រមែងសំគាល់ថា ជាវិញ្ញាណញ្ចាយតនព្រហ្មពិត រមែងសំគាល់ថាវិញ្ញាណញ្ចាយតនព្រហ្មជារបស់អញ ត្រេកអរនឹងវិញ្ញាណញ្ចាយតនព្រហ្ម ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះកំណត់នូវដំណើរវិញ្ញាណញ្ចាយតនព្រហ្មមិនបាន ។ បុថុជ្ជនសម្គាល់នូវអាកិញ្ចញ្ញាយតនព្រហ្ម ថាជាអាកិញ្ចញ្ញាយតនព្រហ្មពិត លុះសម្គាល់នូវអាកិញ្ចញ្ញាយតនព្រហ្ម ថាជាអាកិញ្ចញ្ញាយតនព្រហ្មពិតហើយ ក៏រមែងសំគាល់នូវអាកិញ្ចញ្ញាយតនព្រហ្ម រមែងសំគាល់ក្នុងអាកិញ្ចញ្ញាយតនព្រហ្ម រមែងសំគាល់ថាអាកិញ្ចញ្ញាយតនព្រហ្មពិត រមែងសំគាល់ថា អាកិញ្ចញ្ញាយតនព្រហ្មជារបស់អញ ត្រេកអរនឹងអាកិញ្ចញ្ញាយតនព្រហ្ម ។ ដំណើរនោះ

ព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវអាកិញ្ចញ្ញា-យតនព្រហ្មមិនបាន។ បុថុជ្ជនសម្គាល់នូវនេវសញ្ញានាសញ្ញាយតនព្រហ្ម ថាជានេវសញ្ញានាសញ្ញាយតនព្រហ្មពិត លុះសម្គាល់នូវនេវសញ្ញានាសញ្ញាយតន-ព្រហ្មពិតហើយ ក៏រាប់អាននូវនេវសញ្ញានាសញ្ញាយតនព្រហ្ម រាប់អានក្នុងនេវសញ្ញានាសញ្ញាយតនព្រហ្ម រាប់អានថា នេវសញ្ញានាសញ្ញាយតនព្រហ្មពិត រាប់អានថា នេវសញ្ញានាសញ្ញាយតនព្រហ្មជារបស់អញ ត្រេកអរទីងនេវសញ្ញានាសញ្ញាយតនព្រហ្ម ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវនេវសញ្ញានាសញ្ញាយតនព្រហ្មនោះមិនបាន ។ បុថុជ្ជនសម្គាល់នូវរូបាយតនៈ ថាជារូបាយតនពិត លុះសម្គាល់នូវរូបាយតនថាជារូបាយតនៈពិតហើយ ក៏រាប់អាននូវរូបាយតនៈ រាប់អានក្នុងរូបាយតនៈ រាប់អានថារូបាយតនៈពិត រាប់អានថារូបាយតនៈជារបស់អញ ត្រេកអរទីងរូបាយតនៈ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើររូបាយតនៈនោះមិនបាន ។ បុថុជ្ជនសម្គាល់នូវសទ្ទាយតនៈថា ជាសទ្ទាយតនៈពិត លុះសម្គាល់នូវសទ្ទាយតនៈថាជាសទ្ទាយតនៈពិតហើយ ក៏រាប់អានថាសទ្ទាយតនៈ រាប់អានក្នុងសទ្ទាយ-តនៈ រាប់អានថាសទ្ទាយតនៈពិត រាប់អានថាសទ្ទាយតនៈ ជារបស់អញ ត្រេកអរទីងសទ្ទាយតនៈ ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរសទ្ទាយតនៈនោះមិនបាន ។ បុថុជ្ជនសម្គាល់នូវមុតៈ[១] ថាជាមុតៈពិត លុះសម្គាល់នូវមុតៈ ថាជាមុតៈពិតហើយ

១- មុត សព្ទ ក្នុងទីនេះ ជាឈ្មោះអាយតនៈទាំង ៣ គឺគន្ធៈ រស ផោដ្ឋព្វៈ ។

ក៏រប់អាននូវមុតៈ រប់អានក្នុងមុតៈ រប់អានថាមុតៈពិត រប់អានថាមុតៈជារបស់អញ ត្រេកអរនឹងមុតៈ ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរមុតៈនោះមិនបាន ។ បុថុជ្ជនសម្គាល់នូវវិញ្ញាតៈ[១] ថាជាវិញ្ញាតៈពិត លុះសម្គាល់នូវវិញ្ញាតៈ ថាជាវិញ្ញាតៈពិតហើយ ក៏រប់អាននូវវិញ្ញាតៈ រប់អានក្នុងវិញ្ញាតៈ រប់អានថាវិញ្ញាតៈពិត រប់អានថាវិញ្ញាតៈជារបស់អញ ត្រេកអរនឹងវិញ្ញាតៈ ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរវិញ្ញាតៈនោះមិនបាន ។ បុថុជ្ជនសម្គាល់នូវរបស់ដូចគ្នា[២] ថាជារបស់ដូចគ្នាពិត លុះសម្គាល់នូវរបស់ដូចគ្នា ថាជារបស់ដូចគ្នាពិតហើយ ក៏រប់អាននូវរបស់ដូចគ្នា រប់អានក្នុងរបស់ដូចគ្នា រប់អានថារបស់ដូចគ្នាពិត រប់អានថារបស់ដូចគ្នាជារបស់អញ ត្រេកអរនឹងរបស់ដូចគ្នា ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើររបស់ដូចគ្នាមិនបាន ។ បុថុជ្ជនសម្គាល់នូវរបស់ផ្សេងគ្នា[៣] ថាជារបស់ផ្សេងគ្នាពិត លុះសម្គាល់នូវរបស់ផ្សេងគ្នា ថាជារបស់ផ្សេងគ្នាពិតហើយ ក៏រប់អាននូវរបស់ផ្សេងគ្នា រប់អានក្នុងរបស់ផ្សេងគ្នា រប់អានថា របស់ផ្សេងគ្នាពិត រប់អានថា របស់ផ្សេងគ្នាជារបស់អញ ត្រេកអរនឹងរបស់ផ្សេងគ្នា ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើររបស់ផ្សេងគ្នានោះមិនបាន បុថុជ្ជនសម្គាល់នូវវត្ថុទាំងពួង[៤] ថាជាវត្ថុទាំងពួងពិត គឺសំម្តែងនូវទិដ្ឋិដែលមានសភាពប្រហែលគ្នា លុះសម្គាល់នូវវត្ថុទាំងពួងថាជា

---

១-២-៣-៤ សូមមើលអដ្ឋកថាខាងក្រោម ។

វត្ថុទាំងពួងពិតហើយ ក៏រាប់អាននូវវត្ថុទាំងពួង រាប់អានក្នុងវត្ថុទាំងពួង រាប់អានថាវត្ថុទាំងពួងពិត រាប់អានថាវត្ថុទាំងពួងជារបស់អញ ត្រេកអរនឹងវត្ថុទាំងពួង ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះកំណត់នូវដំណើរវត្ថុទាំងពួងនោះមិនបាន ។ បុថុជ្ជនសម្គាល់នូវនិព្វាន[១] ថាជានិព្វានពិត លុះសម្គាល់នូវនិព្វានថាជានិព្វានពិតហើយ ក៏រាប់អាននូវនិព្វាន រាប់អានក្នុងនិព្វាន រាប់អានថា និព្វានពិត រាប់អានថានិព្វានជារបស់អញ ត្រេកអរនឹងនិព្វាន ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរនិព្វាននោះមិនបាន ។

## នយភូមិបរិច្ឆេទទី ១ ដោយអំណាចបុថុជ្ជន ចប់

[៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាសេក្ខបុគ្គល មិនទាន់បានសម្រេចអរហត្ត កំពុងប្រាថ្នានូវធម៌ដ៏ក្សេមចាកយោគៈ ( អរហត្តដ៏ប្រសើរ ) ។ ភិក្ខុនោះឯងដឹងច្បាស់នូវផែនដី ថាជាផែនដីពិត លុះដឹងច្បាស់នូវផែនដី ថាជាផែនដីពិតហើយ ក៏មិនរាប់អាននូវផែនដី មិនរាប់អានក្នុងផែនដី មិនរាប់អានថាជាផែនដីពិត មិនរាប់អានថាផែនដីជារបស់អញ មិនត្រេកអរនឹងផែនដី ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះភិក្ខុជាសេក្ខៈនោះ គប្បីកំណត់នូវដំណើរនៃផែនដីនោះបាន ។បេ។ ភិក្ខុជាសេក្ខបុគ្គលដឹងច្បាស់នូវទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា មារ ព្រហ្ម ពួកអាភស្សរព្រហ្ម ពួកសុភកិណ្ហព្រហ្ម ពួកវេហប្ផលព្រហ្ម អសញ្ញិសត្វ អាកាសានញ្ចាយតនព្រហ្ម វិញ្ញាណញ្ចាយតនព្រហ្ម អាកិញ្ចញ្ញាយតនព្រហ្ម នេវសញ្ញានាសញ្ញាយតន-

---

១- សូមមើលអដ្ឋកថាខាងក្រោម ។

ព្រហ្ម រូបាយតនៈ សទ្ទាយតនៈ មុតៈ វិញ្ញាតៈ របស់ដូចគ្នា របស់ផ្សេងគ្នា វត្ថុទាំងពួង និងនិព្វានថា ជានិព្វានពិត លុះដឹងច្បាស់នូវនិព្វានថា ជានិព្វានពិតហើយ ក៏មិនរាប់អាននូវនិព្វាន មិនរាប់អានក្នុងនិព្វាន មិនរាប់អានថានិព្វានពិត មិនរាប់អានថានិព្វានជារបស់អញ មិនត្រេកអរនឹងនិព្វាន ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះភិក្ខុជាសេក្ខបុគ្គលនោះ គប្បីកំណត់នូវដំណើរនៃផែនដីជាដើមនោះបាន ។

**នយភូមិបរិច្ឆេទទី ២ ដោយអំណាចសេក្ខបុគ្គល ចប់**

[ ៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ប្រព្រឹត្តគ្រប់គ្រាន់ហើយ មានសោឡសកិច្ចបានធ្វើសម្រេចហើយ មានភារៈ[១] ដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនបានសម្រេចតាមលំដាប់ហើយ មានភវសំយោជនៈអស់រលីងហើយ មានចិត្តរួចស្រឡះ ព្រោះដឹងដោយប្រពៃហើយ ភិក្ខុជាអរហន្តខីណាស្រពនោះ ដឹងច្បាស់នូវផែនដីថា ជាផែនដីពិត លុះបានដឹងច្បាស់នូវផែនដីថា ជាផែនដីពិតហើយ ក៏មិនរាប់អាននូវផែនដី មិនរាប់អានក្នុងផែនដី មិនរាប់អានថាផែនដីពិត មិនរាប់អានថាផែនដីជារបស់អញ មិនត្រេកអរនឹងផែនដី ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះភិក្ខុជាអរហន្តខីណាស្រពនោះ កំណត់នូវដំណើរនៃផែនដីនោះបាន ។បេ។ ភិក្ខុជាអរហន្តខីណាស្រព ដឹងច្បាស់នូវទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា មារ ព្រហ្ម ពួកអាភស្សរព្រហ្ម ពួកសុភកិណ្ហព្រហ្ម ពួកវេហប្ផលព្រហ្ម អសញ្ញីសត្វ អាកាសានញ្ចាយតនព្រហ្ម វិញ្ញាណញ្ចា-

១- សូមមើលអដ្ឋកថាខាងក្រោម ។

យតនព្រហ្ម អាកិញ្ចញ្ញាយតនព្រហ្ម នេវសញ្ញានាសញ្ញាយតនព្រហ្ម រូបា-យតនៈ សទ្ទាយតនៈ មុតៈ វិញ្ញាតៈ របស់ដូចគ្នា របស់ផ្សេងគ្នា វត្ថុទាំងពួង និងនិព្វានថា ជានិព្វានពិត លុះដឹងច្បាស់នូវនិព្វានថា ជានិព្វានពិតហើយ ក៏មិនរាប់អាននូវនិព្វាន មិនរាប់អានក្នុងនិព្វាន មិនរាប់អានថានិព្វានពិត មិនរាប់អានថា និព្វានជារបស់អញ មិនត្រេកអរនឹងនិព្វាន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះភិក្ខុជាអរហន្តខីណាស្រពនោះ កំណត់នូវដំណើរនៃទឹកជាដើមនោះបាន ។

## នយភូមិបរិច្ឆេទទី ៣ ដោយអំណាចនៃព្រះខីណាស្រព ចប់

[ ៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអរហន្តខីណាស្រព មានព្រហ្ម-ចរិយធម៌ប្រព្រឹត្តគ្រប់គ្រាន់ហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចតាមលំដាប់ហើយ មានកិលេសសំយោជនៈអស់រលីងហើយ មានចិត្តរួចស្រឡះ ព្រោះដឹងដោយប្រពៃហើយ ភិក្ខុនោះឯងដឹងច្បាស់នូវផែនដី ថាជាផែនដីពិត លុះដឹងច្បាស់នូវផែនដី ថាជាផែនដីពិតហើយ ក៏មិនរាប់អាននូវផែនដី មិនរាប់អានក្នុងផែនដី មិនរាប់អានថា ផែនដីពិត មិនរាប់អានថា ផែនដីជារបស់អញ មិនត្រេកអរនឹងផែនដី ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះភិក្ខុនោះជាវីតរាគបុគ្គលជ្រះរាគៈហើយ ។បេ។ ភិក្ខុជាអរហន្តខីណាស្រព ដឹងច្បាស់នូវទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា មារ ព្រហ្ម ពួកអាភស្សរព្រហ្ម ពួកសុភកិណ្ហព្រហ្ម ពួកវេហប្ផលព្រហ្ម អសញ្ញិសត្វ អាកាសានញ្ចាយតនព្រហ្ម វិញ្ញាណញ្ចា-

យតនព្រហ្ម អាកិញ្ចញ្ញាយតនព្រហ្ម នេវសញ្ញានាសញ្ញាយតនព្រហ្ម រូបា- យតនៈ សទ្ទាយតនៈ មុតៈ វិញ្ញាតៈ របស់ដូចគ្នា របស់ផ្សេងគ្នា វត្ថុទាំងពួង និងនិព្វាន ថាជានិព្វានពិត លុះដឹងច្បាស់នូវនិព្វាន ថាជានិព្វានពិតហើយ ក៏មិនរាប់អាននូវនិព្វាន មិនរាប់អានក្នុងនិព្វាន មិនរាប់អានថា និព្វានពិត មិនរាប់អានថា និព្វានជារបស់អញ មិនត្រេកអរនឹងនិព្វាន ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះភិក្ខុនោះជាវីតរាគបុគ្គល ដ្បិតអស់រាគៈហើយ ។

**នយភូមិបរិច្ឆេទទី ៤ ដោយអំណាចនៃព្រះខីណាស្រព ចប់**

[ ៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ប្រព្រឹត្តគ្រប់គ្រាន់ហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចតាមលំដាប់ហើយ មានភវសំយោជនៈអស់រលីងហើយ មានចិត្តរួចស្រឡះ ព្រោះដឹងដោយប្រពៃហើយ ភិក្ខុនោះដឹងច្បាស់នូវផែនដី ថាជាផែនដីពិត លុះដឹងច្បាស់នូវផែនដីថាជាផែនដីពិតហើយ ក៏មិនរាប់អាននូវផែនដី មិនរាប់អានក្នុងផែនដី មិនរាប់អានថា ផែនដីពិត មិនរាប់អានថា ផែនដីជារបស់អញ មិនត្រេកអរនឹងផែនដី ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះភិក្ខុនោះជាវីតទោសបុគ្គល ដ្បិតអស់ទោសៈហើយ ។បេ។ ភិក្ខុជាអរហន្តខីណាស្រព ដឹងច្បាស់នូវទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា មារ ព្រហ្ម ពួកអាភស្សរព្រហ្ម ពួកសុភកិណ្ហព្រហ្ម ពួកវេហប្ផលព្រហ្ម អសញ្ញិសត្វ អាកាសានញ្ចាយតនព្រហ្ម វិញ្ញាណញ្ចាយតនព្រហ្ម អាកិញ្ចញ្ញាយតនព្រហ្ម នេវសញ្ញានាសញ្ញាយតនព្រហ្ម

រូបាយតនៈ សុទ្ធាយតនៈ មុតៈ វិញ្ញាតៈ របស់ដូចគ្នា របស់ផ្សេងគ្នា វត្ថុទាំងពួង និងនិព្វាន ថាជានិព្វានពិត លុះដឹងច្បាស់នូវនិព្វាន ថាជានិព្វានពិតហើយ ក៏មិនរាប់អាននូវនិព្វាន មិនរាប់អានក្នុងនិព្វាន មិនរាប់អានថា និព្វានពិត មិនរាប់អានថា និព្វានជារបស់អញ មិនត្រេកអរនឹងនិព្វាន ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះភិក្ខុនោះជាវីតទោសបុគ្គល ផុតអស់ទោសៈហើយ ។

**នយភូមិបរិច្ឆេទទី ៥ ដោយអំណាចនៃព្រះខីណាស្រព ចប់**

[ ៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ប្រព្រឹត្តគ្រប់គ្រាន់ហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនបានសម្រេចតាមលំដាប់ហើយ មានភវសំយោជនៈអស់រលីងហើយ មានចិត្តរួចស្រឡះ ព្រោះដឹងដោយប្រពៃហើយ ភិក្ខុជាអរហន្តខីណាស្រពនោះឯង ដឹងនូវផែនដីថា ជាផែនដីពិត លុះដឹងច្បាស់នូវផែនដីថា ជាផែនដីពិតហើយ ក៏មិនរាប់អាននូវផែនដី មិនរាប់អានក្នុងផែនដី មិនរាប់អានថា ផែនដីពិត មិនរាប់អានថា ផែនដីជារបស់អញ មិនត្រេកអរនឹងផែនដី ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះភិក្ខុនោះជាវីតមោហបុគ្គល ផុតអស់មោហៈហើយ ។បេ។ ភិក្ខុជាអរហន្តខីណាស្រពនោះឯង ដឹងច្បាស់នូវទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា មារ ព្រហ្ម ពួកអាភស្សរព្រហ្ម ពួកសុភកិណ្ហព្រហ្ម ពួកវេហប្ផលព្រហ្ម អសញ្ញិសត្វ អាកាសានញ្ចាយតនព្រហ្ម វិញ្ញាណញ្ចាយតនព្រហ្ម អាកិញ្ចញ្ញាយតនព្រហ្ម នេវសញ្ញានាសញ្ញាយតនព្រហ្ម រូបាយតនៈ សុទ្ធាយតនៈ មុតៈ វិញ្ញាតៈ

របស់ដូចគ្នា របស់ផ្សេងគ្នា វត្ថុទាំងពួង និងនិព្វានថា ជានិព្វានពិត លុះដឹងច្បាស់នូវនិព្វាន ថាជានិព្វានពិតហើយ ក៏មិនរាប់អាននូវនិព្វាន មិនរាប់អានក្នុងនិព្វាន មិនរាប់អានថានិព្វានពិត មិនរាប់អានថា និព្វានជារបស់អញ មិនត្រេកអរនឹងនិព្វាន ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះភិក្ខុនោះជាវីតមោហបុគ្គល ជ្រិតអស់មោហៈហើយ ។

## នយភូមិបរិច្ឆេទទី ៦ ដោយអំណាចនៃព្រះខីណាស្រព ចប់

[ ៨ ] ម្នាលភិក្ខុទាំងឡាយ ចំណែកព្រះតថាគត អរហន្តសម្មាសម្ពុទ្ធរមែងជ្រាបច្បាស់នូវផែនដីថា ជាផែនដីពិត លុះជ្រាបច្បាស់នូវផែនដីថាជាផែនដីពិតហើយ ក៏មិនរាប់អាននូវផែនដី មិនរាប់អានក្នុងផែនដី មិនរាប់អានថា ផែនដីពិត មិនរាប់អានថាផែនដីជារបស់អញ មិនត្រេកអរនឹងផែនដី ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះព្រះតថាគតទ្រង់កំណត់នូវដំណើរនៃផែនដីនោះបាន ។បេ។ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ នូវទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា មារ ព្រហ្ម ពួកអាភស្សរព្រហ្ម ពួកសុភកិណ្ហព្រហ្ម ពួកវេហប្ផលព្រហ្ម អសញ្ញិសត្វ អាកាសានញ្ចាយតនព្រហ្ម វិញ្ញាណញ្ចាយតនព្រហ្ម អាកិញ្ចញ្ញាយតនព្រហ្ម នេវសញ្ញានាសញ្ញាយតនព្រហ្ម រូបាយតនៈ សទ្ទាយតនៈ មុតៈ វិញ្ញាតៈ របស់ដូចគ្នា របស់ផ្សេងគ្នា វត្ថុទាំងពួង និងនិព្វានថា ជានិព្វានពិត លុះទ្រង់ជ្រាបនូវនិព្វានថាជានិព្វានពិតហើយ ក៏មិនរាប់អាននូវនិព្វាន មិនរាប់អានក្នុងនិព្វាន មិនរាប់អានថាជានិព្វានពិត មិនរាប់អានថានិព្វានជារបស់អញ មិន

ត្រេកអរនឹងនិព្វាន ។ ដំណើរនោះព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះព្រះតថាគត ទ្រង់កំណត់នូវដំណើរនៃទឹកជាដើមនោះបាន ។

**នយភូមិបរិច្ឆេទទី ៧ ដោយអំណាចនៃព្រះសាស្តា ចប់**

[ ៩ ] ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបនូវផែនដីថាជាផែនដីពិត លុះទ្រង់ជ្រាបនូវផែនដីថាជាផែនដីពិតហើយ ក៏មិនរាប់អាននូវផែនដី មិនរាប់អានក្នុងផែនដី មិនរាប់អានថាជាផែនដីពិត មិនរាប់អានថាផែនដីជារបស់អញ មិនត្រេកអរនឹងផែនដី ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះព្រះតថាគត ទ្រង់ជ្រាបច្បាស់ថា សេចក្តីប្រាថ្នាដែលមានហើយ ( អំពីមុន ) ជាឫសគល់នៃសេចក្តីទុក្ខ ទាំងជ្រាបច្បាស់ថា ជាតិជរា មរណៈ របស់សត្វដែលកើតអំពីកម្មភព គឺកុសលាកុសលចេតនា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ តថាគតពោលថា ព្រះតថាគត បានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ព្រោះអស់តណ្ហា ព្រោះប្រាសចាកតណ្ហា ព្រោះរលត់តណ្ហា ព្រោះលះបោលនូវតណ្ហា ព្រោះរលាស់ចោលនូវតណ្ហា ដោយប្រការទាំងពួង ។បេ។ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាប់ច្បាស់នូវទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា មារ ព្រហ្ម ពួកអាភស្សរព្រហ្ម ពួកសុភកិណ្ហព្រហ្ម វេហប្ផលព្រហ្ម អសញ្ញិសត្វ អាកាសានញ្ចាយតនព្រហ្ម វិញ្ញាណញ្ចាយតនព្រហ្ម អាកិញ្ចញ្ញាយតនព្រហ្ម នេវសញ្ញានាសញ្ញាយតនព្រហ្ម រូបាយតនៈ សទ្ទាយតនៈ មុតៈ វិញ្ញាតៈ របស់ដូចគ្នា របស់ផ្សេងគ្នា វត្ថុទាំងពួង និងនិព្វានថាជានិព្វានពិត

លុះទ្រង់ជ្រាបច្បាស់នូវនិព្វានថា ជានិព្វានពិតហើយ ក៏មិនរាប់អាននូវនិព្វាន មិនរាប់អានក្នុងនិព្វាន មិនរាប់អានថាជានិព្វានពិត មិនរាប់អានថា និព្វានជារបស់អញ មិនត្រេកអរនឹងនិព្វាន ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាប់ច្បាស់ថា សេចក្តីប្រាថ្នាដែលមានហើយ ( អំពីមុន ) ជាឫសគល់នៃសេចក្តីទុក្ខ ទាំងជ្រាបច្បាស់ថា ជាតិជរា មរណៈ របស់សត្វដែលកើតអំពីកម្មភព គឺកុសលាកុសលចេតនា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ តថាគតពោលថា ព្រះតថាគតបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ព្រោះអស់តណ្ហា ព្រោះប្រាសចាកតណ្ហា ព្រោះរលត់តណ្ហា ព្រោះលះចោលនូវតណ្ហា ព្រោះរលាស់ចោលនូវតណ្ហា ដោយប្រការទាំងពួង ។

**នយភូមិបរិច្ឆេទទី ៨ ដោយអំណាចនៃព្រះសាស្តា ចប់**

លុះព្រះមានព្រះភាគទ្រង់សម្តែងសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះក៏គ្មានចិត្តត្រេកអររីករាយ ចំពោះភាសិតនៃព្រះមានព្រះភាគឡើយ ។

**មូលបរិយាយសូត្រទី ១ ចប់**

# អដ្ឋកថា

# មូលបរិយាយសូត្រ

### ឯវម្មេសុតំ ។បេ។ សព្វធម្មបរិយាយំ

## បទនមស្ការព្រះរតនត្រ័យ

ខ្ញុំព្រះអង្គ សូមវន្ទាព្រះសម្ពុទ្ធ ទ្រង់មានងងឹត គឺមោហៈកម្ចាត់បង់ហើយដោយពន្លឺ គឺបញ្ញា រួចផុតហើយអំពីគតិទាំងពួង មានព្រះហឫទ័យត្រជាក់ដោយព្រះករុណា ជាគ្រូនៃសត្វលោកផង មនុស្ស និងទេវតាផង ។ ព្រះពុទ្ធអង្គទ្រង់ចូលដល់នូវធម៌ដែលប្រាសចាកមន្ទិលណា ទើបទ្រង់ធ្វើឲ្យកើត និងធ្វើឲ្យជាក់ច្បាស់នូវភាពជាព្រះពុទ្ធ ខ្ញុំព្រះអង្គសូមវន្ទាព្រះធម៌ដ៏ឧត្តមនោះ ។ ខ្ញុំព្រះអង្គសូមវន្ទាព្រះអរិយសង្ឃ គឺប្រជុំព្រះអរិយបុគ្គលទាំង ៨ ដែលជាពុទ្ធឱរស កើតអំពីព្រះឱរៈនៃព្រះសុគត ទ្រង់កម្ចាត់មារ និងសេនាបានហើយ ។

បុណ្យដែលសម្រេចដោយការវន្ទា ព្រះរតនត្រ័យរបស់ខ្ញុំ ដែលជាអ្នកមានចិត្តជ្រះថ្លានេះ ដោយអានុភាពនៃបុណ្យនោះ សូមឲ្យខ្ញុំជាបុគ្គលមានអន្តរាយកម្ចាត់ចេញបានដោយល្អហើយ អដ្ឋកថាឯណា ដែលព្រះអរហន្តដ៏ជំនាញ ៥០០ អង្គសង្គាយនា គឺចងក្រងទុកអំពីខាងដើម និងដែលព្រះសង្គីតិកាចារ្យទាំងឡាយសង្គាយនាបន្ថែមក្នុងកាលខាងក្រោយក្តី ដើម្បីប្រកាស គឺអធិប្បាយ អត្ថនៃព្រះសូត្រ មជ្ឈិមនិកាយ ក្នុងគម្ពីរនេះដែលកំណត់អត្ថដោយព្រះសូត្រខ្នាតកណ្តាល ដែលព្រះពុទ្ធអង្គ និងសាវកពណ៌នាទុក កម្ចាត់-

បង់បាននូវលទ្ធិដទៃស្រេចហើយ ព្រះមហិន្ទមហាថេរៈ ដែលជាអ្នកឈ្លាស បាននាំមកកាន់កោះសីហឡស្ថាបនា គឺចារឹកទុកជាសីហឡភាសា ដើម្បីប្រយោជន៍ដល់អ្នកកោះ ខ្ញុំនឹងនាំសីហឡភាសាចេញហើយ លើកឡើងកាន់ភាសាដែលជាទីត្រេកអរនៃចិត្ត ដែលសមគួរជាបែបផែនបាន ប្រាសចាកទោស គឺមគធភាសា ។ មួយផ្នែកទៀត ប្រកាស គឺអធិប្បាយអត្ថ មិនឲ្យជំទាស់មតិនៃព្រះថេរៈមហាវិហារ ដែលជាប្រទីបនៃថេរវង្ស មានការវិនិច្ឆ័យល្អិតល្អ ដោយវៀរពាក្យដែលត្រួតគ្នាដដែលៗ ចេញខ្លះ ដើម្បីការត្រេកអរនៃសាធុជន និងដើម្បីការតាំងនៅនៃព្រះធម៌ ។

ចំណែកធម៌ គឺ សីលកថា ធុតធម្ម គឺធុតង្គ កម្មដ្ឋានគ្រប់យ៉ាង ឈានសមាបត្តិយ៉ាងពិស្តារ ព្រមទាំងចរិយាវិធាន គឺចរិតរបស់បុគ្គល អភិញ្ញាទាំងពួង ការវិនិច្ឆ័យបញ្ញាទាំងមូល ខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ អរិយសច្ច ៤ ការសម្តែងបច្ចយាការ គឺបដិច្ចសមុប្បាទ មាននយ័បរិសុទ្ធល្អិតល្អ ល្មមជាបែបកាន់យកបាន និងវិបស្សនាភាវនាទាំងពួង ទាំងអស់នេះ ខ្ញុំបានពោលទុកហើយក្នុងវិសុទ្ធិមគ្គដ៏បរិសុទ្ធ ហេតុនោះ ខ្ញុំមិនពោលគោលធម៌ទាំងពួងនោះឲ្យក្រៃលែងឡើងក្នុងទីនេះទៀតឡើយ ។

វិសុទ្ធិមគ្គនោះ ខ្ញុំរចនាដោយគិតថា វិសុទ្ធិមគ្គនឹងតាំងនៅត្រង់កណ្តាលនៃនិកាយទាំង ៤ ហើយប្រកាសអត្ថតាមដែលលោកភាសិតទុក ក្នុងនិកាយទាំង ៤ នោះបាន ដូច្នោះ ហេតុនោះ សូមអ្នកទាំងឡាយកាន់យកវិសុទ្ធិមគ្គនោះ ព្រមទាំងអដ្ឋកថានេះ ជ្រាបអត្ថនៃមជ្ឈិមសង្គីតិ គឺមជ្ឈិមនិកាយទាំង ៣

បណ្ណាសកៈចុះ ។

សីលកថា ធុតង្គធម៌ កម្មដ្ឋាន សេចក្តីពិស្តាររបស់ឈាន និងសមាបត្តិ ដែលប្រកបដោយវិធី គឺការអនុលោមតាមចរិត ៦ អភិញ្ញាទាំងពួង ពាក្យវិនិច្ឆ័យដែលសង្គ្រោះទុកដោយបញ្ញា ខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ អរិយសច្ចៈ ៤ បច្ចយាការទេសនា ដែលមិនក្រៅគន្លងព្រះបាលី មានន័យដែលឈ្មោះថា មជ្ឈិមសង្គីតិ ក្នុងពាក្យថា មជ្ឈិមសង្គីតិយានោះ ពោលដោយបណ្ណាសកៈ បានដល់ការរួបរួមបណ្ណាសកៈ ៣ ពួក គឺមូលបណ្ណាសកៈ មជ្ឈិមបណ្ណាសកៈ និងឧបរិបណ្ណាសកៈ ពោលដោយវគ្គ បានដល់ ការរួបរួមវគ្គ មាន ១៥ វគ្គ ព្រោះបែងចែកបណ្ណាសកៈ ១ ជា ៥ ពោលដោយសូត្រ មាន ១៥២ សូត្រ ពោលដោយបទ មាន ៨០៥២៣ ព្រោះហេតុនោះ ទើបបុរាណាចារ្យពោលទុកថា លោកពោលកំណត់បទទុក ៨០៥២៣ បទយ៉ាងនេះ ។

តែពោលដោយអក្ខរៈ មាន ៧៤០០៥៣ អក្ខរៈ ពោលដោយភាណវារ មាន ៨០ ភាណវារ និងកន្លះភាណវារ មាន ២៣ បទ ។ ពោលដោយអនុសន្ធិ ដោយសង្ខេប មាន ៣ អនុសន្ធិ គឺបុច្ឆាអនុសន្ធិ អជ្ឈាសយានុសន្ធិ និងយថានុសន្ធិ តែបើពោលដោយពិស្តារក្នុងរឿងនេះ មាន ៣៩០០ អនុសន្ធិ ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលទុកថា លោកប្រកាសន័យអនុសន្ធិ របស់មជ្ឈិមបណ្ណាសកៈទាំងនោះទុក ៣៩០០ អនុសន្ធិ ។

ក្នុងបណ្ណាសកៈទាំងនោះ មូលបណ្ណាសកៈ ជាបណ្ណាសកៈដើម ក្នុងវគ្គទាំងឡាយ មូលបរិយាយវគ្គ ជាវគ្គដើម និងក្នុងសូត្រទាំងឡាយ មូលបរិ-

យាយសូត្រជាសូត្រដើម ។

[ ១ ] ពាក្យនិទានថា **ឯវម្មេ សុតំ** ជាពាក្យដែលព្រះអានន្ទ ពោលទុកក្នុងបឋមសង្គីតិកាល ខាងដើមមូលបរិយាយសូត្រនោះ ។ បឋមមហាសង្គីតិនេះ លោកពោលទុកពិស្តារហើយ ក្នុងខាងដើមនៃអដ្ឋកថាទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ។ ព្រោះដូច្នោះ បឋមមហាសង្គីតិនោះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលដោយពិស្តារហើយ ក្នុងអដ្ឋកថាទីឃនិកាយនោះឯង ។

បទថា **ឯវម្មេ សុតំ** ជាដើមនេះ ជាពាក្យផ្តើម ។ បណ្តាបទទាំងនោះ បទថា **ឯវំ** ជានិបាត ។ បទថា **មេ** ជាដើម ជានាមបទ ។ ក្នុងបទថា **ឧក្កដ្ឋាយំ វិហរតិ** នេះ បណ្ឌិតគប្បីជ្រាបការចែកបទ ដោយន័យនេះមុនថា បទថា **វិ** ជាឧបសគ្គ ។ បទថា **ហរតិ** ជាអាខ្យាត តែដោយអត្ថ **ឯវំ** សព្ទមានអត្ថចែកចេញបានច្រើនយ៉ាង គឺឧបមា ឧបទេស ( ការណែនាំ ) សម្បហំសនៈ ( ការលើកតម្កើង ) គរហណៈ ( ការតិះដៀល ) វចនសម្បដិគ្គហៈ ( ការទទួលពាក្យ ) អាការនិទស្សនៈ ( ការចង្អុលបង្ហាញ ) អវធារណៈ ( ការហាមសេចក្តីដទៃ ) ។

ពិតហើយ **ឯវំ** សព្ទនេះ មកក្នុងអត្ថថា ឧបមា ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ** កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើនយ៉ាងនោះ ដូច្នេះ ។

មកក្នុងអត្ថថា ការណែនាំ ដូចក្នុងប្រយោគជាដើមថា **ឯវន្តេ អភិ-**

**ក្កមិតព្វំ ឯវន្តេ បដិក្កមិតព្វំ** អ្នកត្រូវឈានដើរទៅមុខយ៉ាងនេះ អ្នកត្រូវថយក្រោយយ៉ាងនេះ ដូច្នេះ ។

មកក្នុងអត្ថថា លើកតម្កើង ដូចក្នុងប្រយោគជាដើមថា **ឯវមេតំ ភគវា ឯវមេតំ សុគតំ** បពិត្រព្រះដ៏មានព្រះភាគ ហេតុនុ៎ះយ៉ាងនេះហើយ បពិត្រព្រះសុគត ហេតុនុ៎ះយ៉ាងនេះហើយ ដូច្នេះ ។

មកក្នុងអត្ថថា តិះដៀល ដូចក្នុងប្រយោគជាដើមថា **ឯវមេវំ បណាយំ វសលី យស្មឹ វា តស្មឹ វា តស្ស មុណ្ឌកស្ស សមណស្ស វណ្ណំ ភាសតិ** មេចង្រៃនេះ ធ្លាប់តែអឺចឹងៗ ហ៊ានពោលសរសើរសមណៈត្រងោលក្នុងទីផ្តេសផ្តាស ដូច្នេះ ។

មកក្នុងអត្ថថា ការទទួលពាក្យ ដូចក្នុងប្រយោគជាដើមថា **ឯវំ ភន្តេតិ ខោតេ ភិក្ខូ ភគវតោ បច្ចស្សោសុំ** ភិក្ខុទទួលពាក្យនៃព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ ដូច្នេះ ។

មកក្នុងអត្ថថា អាការ ដូចក្នុងប្រយោគជាដើមថា **ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ ជានាមិ** ខ្ញុំបានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយក៏យ៉ាងនោះដែរ ដូច្នេះ ។

មកក្នុងអត្ថថា ការចង្អុលបង្ហាញ ដូចក្នុងប្រយោគជាដើមថា **ឯហិ ត្វំ មាណវក យេន សមណោ អានន្ទោ ។បេ។ អនុកម្បំ ឧបាទាយ** ម្នាលមាណព ឯងចូរមកនេះ ឯងចូរទៅរកព្រះសមណៈឈ្មោះអានន្ទ លុះចូលទៅដល់ហើយ ចូរសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅ

មកបានរហ័សរហួន មានកម្លាំងនៅជាសុខសប្បាយ នឹងព្រះសមណៈឈ្មោះអានន្ទ តាមពាក្យរបស់អញថា សុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ផ្តាំឲ្យសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន និងកម្លាំង និងអាការនៅជាសុខសប្បាយ ចំពោះព្រះអានន្ទដ៏ចម្រើន រួចហើយឯងចូរនិមន្តថា សូមលោកម្ចាស់អានន្ទ អាស្រ័យនូវសេចក្តីអនុគ្រោះ និមន្តមកកាន់ទីលំនៅរបស់សុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ឲ្យទាន ដូច្នេះ ។

មកក្នុងអត្ថថា ការហាមសេចក្តីដទៃ ដូចក្នុងប្រយោគជាដើមថា **តំ កឹ មញ្ញថ កាឡាមា ឥមេ ធម្មា ។បេ។ ឯវំ នោ ឯត្ថ ហោតិ** ម្នាលកាឡាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្តេច ធម៌នេះជាកុសល ឬជាអកុសល ។ ជាអកុសលព្រះអង្គ ។ ជាធម៌ប្រកបដោយទោស ឬមិនប្រកបដោយទោសទេ ។ ជាធម៌ប្រកបដោយទោសព្រះអង្គ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬអ្នកប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀលព្រះអង្គ ។ ធម៌ទាំងនេះ ដែលបុគ្គលសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ឬមិនប្រព្រឹត្តទៅទេ ឬក៏ក្នុងដំណើរនោះដូចម្តេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះ ដែលបុគ្គលសមាទានបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ យើងខ្ញុំក៏យល់ក្នុងដំណើរនោះដូច្នោះដែរ ដូច្នេះ ។

**ឯវំ** សព្ទនេះ ក្នុងទីនេះ បណ្ឌិតគប្បីជ្រាបថា ប្រើក្នុងអត្ថថា អាការការចង្អុលបង្ហាញ ការហាមសេចក្តីដទៃ ក្នុង ៣ យ៉ាងនោះ ព្រះអានន្ទ

សម្តែងសេចក្តីនេះដោយ **ឯវំ** សុតំ ដែលមានអាការជាអត្ថថា បុគ្គលណាមួយអាចនឹងជ្រាបព្រះតម្រាស់ របស់ព្រះមានព្រះភាគអង្គនោះ ដែលល្អិតសុខុមដោយន័យផ្សេងៗ កើតឡើងដោយអធ្យាស្រ័យដ៏វិសាល ទូលំទូលាយដោយអត្ថ និងព្យញ្ជនៈ មានបាដិហារិយ៍ច្រើនយ៉ាង ជ្រាលជ្រៅដោយធម៌ ដោយអត្ថ ដោយទេសនា និងដោយបដិវេធ មកកាន់សោតប្បសាទរបស់សត្វទាំងពួង ដោយសមគួរដល់ភាសារបស់ខ្លួន ដោយប្រការទាំងពួងផង ឲ្យកើតការចង់ស្តាប់ ដោយពេញកម្លាំងផង ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ គឺខ្ញុំបានស្តាប់មកហើយដោយអាការម្យ៉ាង ។ ព្រះអានន្ទត្ថេរកាលនឹងបង្ហាញដោយអត្ថថា ខ្ញុំមិនមែនសយម្ភូ សូត្រនេះខ្ញុំមិនបានធ្វើឲ្យជាក់ច្បាស់ ទើបសម្តែងសូត្រទាំងមូល ដែលនឹងត្រូវពោលក្នុងឥឡូវនេះថា ខ្ញុំបានស្តាប់យ៉ាងនេះ គឺខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ ព្រះអានន្ទត្ថេរ កាលសម្តែងកម្លាំង គឺការចងចាំរបស់ខ្លួន ដែលសមគួរដល់ភាវៈ ដែលព្រះមានព្រះភាគទ្រង់សរសើរយ៉ាងនេះថា **ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ពហុស្សុតានំ យទិទំ អានន្ទោ ។បេ។** ម្នាលភិក្ខុទាំងឡាយបណ្តាពួកភិក្ខុអ្នកចេះដឹងច្រើន ដែលជាសាវករបស់តថាគត ស្រេចនឹងអានន្ទប្រសើរជាងគេ ពួកភិក្ខុអ្នកមានស្មារតីស្រេចនឹងអានន្ទ ពួកភិក្ខុអ្នកមានគតិ ស្រេចនឹងអានន្ទ ពួកភិក្ខុអ្នកមានប្រាជ្ញាស្រេចនឹងអានន្ទ ពួកភិក្ខុជាឧបដ្ឋាក ក៏ស្រេចនឹងអានន្ទដែរ ។ ព្រះធម្មសេនាបតី ក៏សរសើរយ៉ាងនេះថា **អាយស្មា អានន្ទោ អត្ថកុសលោ ធម្មកុសលោ ព្យញ្ជនកុសលោ និរុត្តិកុសលោ បុព្វាបរកុសលោ** អានន្ទ

ឈ្លាសក្នុងអត្ថ ១ ឈ្លាសក្នុងធម៌ ១ ឈ្លាសក្នុងអក្ខរប្បភេទ ១ ឈ្លាសក្នុងភាសា ១ ឈ្លាសទាំងដើម ទាំងចុង ១ ញុំាងសត្វទាំងឡាយឲ្យកើតការចង់ស្ដាប់ ។ ដោយអត្ថថា ការហាមសេចក្ដីដទៃ ខ្ញុំបានស្ដាប់មកប៉ុណ្ណោះ ហើយសូត្រនោះឯង មិនលើស មិនខ្វះ ដោយអត្ថ ឬព្យញ្ជនៈ គប្បីឃើញថា យ៉ាងនេះប៉ុណ្ណោះ មិនគប្បីឃើញដទៃ ក្រៅអំពីនេះ ដូច្នេះ ។

**មេ** សព្ទ ប្រាកដក្នុងអត្ថ ៣ យ៉ាង ។ ពិតហើយ **មេ** សព្ទនោះ មានអត្ថថា **មយា** ( គឺខ្ញុំ ) ក្នុងប្រយោគជាដើមថា **គាថាភិគីតម្មេអភោជនេយ្យំ** ភោជនដែលតថាគតពោលហើយដោយគាថា ( ច្រៀង ) ជាវត្ថុមិនគួរដល់ការបរិភោគទេ ។

មានអត្ថថា **មយ្ហំ** ( ដល់ខ្ញុំ ) ដូចក្នុងប្រយោគជាដើមថា **សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះមានព្រះភាគ សម្ដែងធម៌ដោយសង្ខេបដល់ខ្ញុំ ។

មានអត្ថថា **មម** ( របស់ខ្ញុំ ) ក្នុងប្រយោគជាដើមថា **ធម្មទាយាទា មេ ភិក្ខវេ ភវថ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមត៌កចុះ ។

ឯក្នុងពាក្យនេះ **មេ** សព្ទ ប្រើក្នុងអត្ថ ២ យ៉ាងថា ខ្ញុំបានស្ដាប់មក និងថា ការស្ដាប់របស់ខ្ញុំ ដូច្នេះ ។

**សុត** សព្ទ ក្នុងពាក្យថា **សុតំ** នេះ មានឧបសគ្គ និងមិនមានឧបសគ្គ មានអត្ថច្រើនយ៉ាង គឺគមន គឺការទៅ វិស្សុត គឺ ការប្រាកដ កិលិន្ន គឺ

ជោកជាំដោយតម្រេក ឧបចិត គឺការសន្សំអនុយោគ គឺការប្រកបរឿយៗ សោតវិញ្ញេយ្យ គឺ ការដឹងតាមត្រចៀក សោតទ្វារានុសារវិញ្ញាណ គឺ ដឹងតាមក្រសែនៃត្រចៀក ។

ពិតហើយ **សុត** សព្ទនោះ មានអត្ថថា ទៅ ដូចក្នុងប្រយោគជាដើមថា **សេនាយ បសុតោ** ទៅហើយដោយសេនា ។

មានអត្ថថា មានធម៌ដែលខ្លួនត្រងត្រាប់ស្តាប់ហើយ យ៉ាងជាក់ច្បាស់ ( ប្រាកដ ) ដូចក្នុងប្រយោគជាដើមថា **សុតធម្មស្ស បស្សតោ** បុគ្គលមានធម៌ស្តាប់ហើយ បានឃើញច្បាស់ ។

មានអត្ថថា ជោកជាំ របស់បុគ្គលដែលជោកជាំដោយតម្រេក ដូចក្នុងប្រយោគជាដើមថា **អវស្សុតា អវស្សុតស្ស** ( សុន្ទរីនន្ទាជាម្ចាស់ ) មានតម្រេកមិនគួរនឹងត្រេកអរឲ្យបុរសបុគ្គលដែលមានតម្រេក ... ដូច្នេះ ។

មានអត្ថថា សន្សំ ដូចក្នុងប្រយោគជាដើមថា **តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ** បុណ្យឈ្មោះថា បានសន្សំទុក មិនមែនតិចឡើយ ។

មានអត្ថថា ប្រកបរឿយៗ ក្នុងឈានរឿយៗ ដូចក្នុងប្រយោគជាដើមថា **យេ ឈានប្បសុតា ធីរា** អ្នកប្រាជ្ញពួកណា ជាអ្នកប្រកបរឿយៗ ក្នុងឈាន ។

មានអត្ថថា ដឹងតាមត្រចៀក ដូចក្នុងប្រយោគជាដើមថា **ទិដ្ឋំ សុតំ មុតំ** ឃើញហើយ ស្តាប់ហើយ ជ្រាបហើយ ។

មានអត្ថថា ដឹងតាមក្រសែនៃសោតទ្វារ ដូចក្នុងប្រយោគជាដើមថា

**សុតធរោ សុតសន្និចយោ** ( ភិក្ខុក្នុងសាសនានេះ ) ជាអ្នកទ្រទ្រង់នូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ ។ តែក្នុងទីនេះ **សុត** សព្ទនោះ សំដៅយកអត្ថថា ចងចាំ ឬទ្រទ្រង់នូវការចាំតាមគន្លងនៃសោតទ្វារ ។ ពិតហើយ កាលមេ សព្ទ មានអត្ថដូចគ្នានឹង **មយា** រមែងប្រកបសេចក្ដីបានថា ខ្ញុំបានស្ដាប់មក គឺចាំតាមគន្លងនៃសោតទ្វារយ៉ាងនេះ មានអត្ថដូចគ្នានឹង **មម** រមែងប្រកបសេចក្ដីបានថា ការស្ដាប់របស់ខ្ញុំ គឺការចាំតាមគន្លងនៃសោតទ្វាររបស់ខ្ញុំយ៉ាងនេះ ។

ក្នុងបទទាំង ៣ ដូចពោលមកនេះ បទថា **ឯវំ** ជាការសម្ដែងកិច្ចនៃវិញ្ញាណ មានសោតវិញ្ញាណជាដើម ។ បទថា **មេ** ជាការសម្ដែងដល់បុគ្គលដែលមានការដល់ព្រមដោយវិញ្ញាណដូចពោលហើយ ។ បទថា **សុតំ** ជាការសម្ដែងការកាន់យកដែលមិនខុស មិនលើស មិនខ្វះ ព្រោះឃាត់ការមិនស្ដាប់ ។

ម្យ៉ាងទៀតបទថា **ឯវំ** ជាការប្រកាសការប្រព្រឹត្តទៅក្នុងអារម្មណ៍នៃវិញ្ញាណវិថី ដែលប្រព្រឹត្តទៅតាមគន្លងនៃសោតទ្វារនោះដោយប្រការផ្សេងៗ ។ បទថា **មេ** ជាការប្រកាសខ្លួន ។ បទថា **សុតំ** ជាការប្រកាសធម៌ ។ ពិតហើយ ក្នុងបទថា **ឯវំមេ សុតំ** នេះមានសេចក្ដីសង្ខេបដូចតទៅនេះថា ខ្ញុំមិនធ្វើកិច្ចដទៃនៃវិញ្ញាណវិថី ដែលប្រព្រឹត្តទៅហើយក្នុងអារម្មណ៍ដោយប្រការផ្សេងៗ តែខ្ញុំធ្វើកិច្ចនេះ ធម៌នេះខ្ញុំស្ដាប់ហើយ ។

ម្យ៉ាងទៀត បទថា **ឯវំ** ជាការប្រកាសពាក្យដែលគប្បីថ្លែងលម្អិត ។

បទថា **មេ** ជាការប្រកាសបុគ្គល ។ បទថា **សុតំ** ជាការប្រកាសកិច្ចនៃបុគ្គល ។ មានពាក្យអធិប្បាយទុកដូច្នេះថា ព្រះសូត្រដែលខ្ញុំនឹងសម្តែង ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។

ម្យ៉ាងទៀត បទថា **ឯវំ** ជាការខែលម្អិតអាការផ្សេងៗ របស់ចិត្តសន្តាន ដែលមានការកាន់យកអត្ថ និងព្យញ្ជនៈផ្សេងៗ ដោយការប្រព្រឹត្តទៅដោយប្រការផ្សេងៗ គ្នា ។

ពិតហើយ សព្ទថា **ឯវំ** នេះ ជាការបញ្ញត្តអាការ សព្ទថា **មេ** ជាការសម្តែងកត្តា គឺអ្នកធ្វើ ។ សព្ទថា **សុតំ** ជាការសម្តែងវិស័យ ។ ដោយការអធិប្បាយត្រឹមប៉ុណ្ណេះ ឈ្មោះថា ធ្វើការសន្និដ្ឋានបានថា ដោយចិត្តសន្តានដែលប្រព្រឹត្តទៅដោយអាការផ្សេងៗ គ្នា ព្រះថេរៈដែលប្រកបដោយចិត្តសន្តាននោះ ទើបជាកត្តា និងទទួលអារម្មណ៍បាន ។

ម្យ៉ាងទៀត សព្ទថា **ឯវំ** ជាការសម្តែងកិច្ចនៃបុគ្គល ។ សព្ទថា **សុតំ** ជាការសម្តែងកិច្ចនៃវិញ្ញាណ ។ សព្ទថា **មេ** ជាការសម្តែងដល់បុគ្គលដែលប្រកបដោយកិច្ចទាំង ២ ។ ក្នុងបទថា **ឯវម្មេ សុតំ** នេះ មានសេចក្តីសង្ខេបថា ខ្ញុំបានស្តាប់មកដោយវោហារ នៃចំណែកកិច្ចដែលបានមកដោយអំណាចនៃវិញ្ញាណ ដោយបុគ្គលដែលដល់ព្រមដោយចំណែកកិច្ច និងវិញ្ញាណកិច្ច ។

បណ្តាបទទាំងនោះ បទថា **ឯវំ** ជាអវិជ្ជមានបញ្ញត្តិ ដោយអត្ថថាជាក់ច្បាស់ និងបទថា **មេ** ជាអវិជ្ជមានបញ្ញត្តិ ដោយបរមត្ថ ក្នុងសេចក្តីនេះ មានពាក្យពិសេសតទៅទៀត គឺពាក្យដែលព្រះថេរៈគប្បីបានការថ្លែង

លម្អិតថា **ឯវំ** ឬ **មេ** មានដោយបរមត្ថ ។ បទថា **សុតំ** ជាវិជ្ជមានបញ្ញត្តិ ។ អធិប្បាយថា ក្នុងបទថា **សុតំ** នេះ អារម្មណ៍ដែលបានតាមសោតៈនេះ មានដោយបរមត្ថ ដូច្នេះ ។

ម្យ៉ាងទៀត បទថា **ឯវំ** និង **មេ** ចាត់ជាឧបាទាយបញ្ញត្តិ ព្រោះព្រះថេរៈពោលសំដៅយកធម៌ដែលប៉ះខ្ទប់សោតៈ និងខន្ធដែលជាប់ទាក់ទងក្នុងសន្តានរបស់ខ្លួននោះ ។ បទថា **សុតំ** ជាឧបនិធាបញ្ញត្តិ ព្រោះព្រះថេរៈពោលអាស្រ័យដល់វត្ថុដែលឃើញហើយជាដើម ។

ម្យ៉ាងទៀត ក្នុងសេចក្តីនេះ ព្រះថេរៈសម្តែងការមិនល្ងង់ខ្លៅ ដោយពាក្យថា **ឯវំ** អធិប្បាយថា បុគ្គលល្ងង់ខ្លៅ មិនអាចចាក់ធ្លុះដោយប្រការផ្សេងៗ បានឡើយ ។ ដោយបទថា **សុតំ** ព្រះថេរៈសម្តែងការមិនវង្វេង គឺមិនភ្លេចភ្លាំងព្រះពុទ្ធវចនៈដែលបានស្តាប់មកហើយ អធិប្បាយថា សុតៈដែលបុគ្គលណាវង្វេងហើយ បុគ្គលនោះ រមែងនឹកមិនចេញថា អញបានស្តាប់មកហើយដោយកាលដទៃ ការសម្រេចនៃបញ្ញារបស់ព្រះថេរៈនោះ រមែងមានព្រោះការមិនល្ងង់ខ្លៅ ឯការសម្រេចនៃសតិ រមែងមានព្រោះការមិនវង្វេង ។ បណ្តាអត្ថ ២ យ៉ាងនោះ សមត្ថភាពក្នុងការចងចាំព្យញ្ជនៈ មានដោយសតិមានបញ្ញាជាអ្នកនាំ សមត្ថភាពក្នុងការយល់អត្ថ មានដោយបញ្ញា មានសតិជាអ្នកនាំ ការសម្រេចភាពជានាយឃ្លាំងនៃធម៌ ដោយអាចក្នុងការរក្សាឃ្លាំងធម៌ដែលដល់ព្រមដោយអត្ថ និងព្យញ្ជនៈ មានព្រោះប្រកប ដោយសមត្ថភាពទាំង ២ យ៉ាងនោះ ។

ន័យម្យ៉ាងទៀត ដោយបទថា **ឯវំ** ព្រះថេរៈសម្តែងការធ្វើទុកក្នុងចិត្ត ដោយឧបាយប្រាជ្ញា ព្រោះបុគ្គលដែលធ្វើទុកក្នុងចិត្តដោយអយោនិសោមនសិការ មិនមានការចាក់ធ្លុះប្រការផ្សេងៗ ។ ដោយបទថា **សុតំ** លោកសម្តែងការមិនរាយមាយ ព្រោះបុគ្គលដែលមានចិត្តរាយមាយ មិនមែនជាការស្តាប់ ។ ពិតហើយ បុគ្គលដែលមានចិត្តរាយមាយ សូម្បីត្រូវប្រាប់ដល់គុណសម្បត្តិគ្រប់យ៉ាង ក៏គង់ពោលថា ខ្ញុំស្តាប់មិនច្បាស់លាស់ សូមលោកពោលម្តងទៀត ។ ក្នុងសេចក្តីនេះ ព្រោះការស្តាប់ដោយការធ្វើទុកក្នុងចិត្តដោយឧបាយ បុគ្គលរមែងញ៉ាំងការតាំងខ្លួនទុកដោយប្រពៃ និងភាពជាអ្នកមានបុណ្យធ្វើទុកក្នុងកាលមុនឲ្យសម្រេចបាន ព្រោះបុគ្គលមិនបានតាំងខ្លួនទុកដោយប្រពៃ និងមិនបានធ្វើបុណ្យទុកក្នុងកាលមុន មិនមានការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញានោះ ព្រោះការមិនរាយមាយ ទើបបុគ្គលញ៉ាំងការស្តាប់ព្រះសទ្ធម្ម និងការចូលទៅសេពគប់សប្បុរសឲ្យសម្រេច ។ ពិតហើយ បុគ្គលដែលមានចិត្តរាយមាយ មិនអាចស្តាប់ធម៌បានឡើយ ហើយការស្តាប់រមែងមិនកើតមានដល់បុគ្គល ដែលមិនចូលទៅសេពគប់សប្បុរស ។

ម្យ៉ាងទៀត ព្រោះហេតុដែលលោកពោកទុកថា បទថា **ឯវំ** ជាបទសម្តែងអាការផ្សេងៗ នៃចិត្តសន្តាន ដែលមានការទទួលយកអត្ថ និងព្យញ្ជនៈប្រព្រឹត្តទៅដោយប្រការផ្សេងៗគ្នា ។ អាការដែលល្អយ៉ាងនេះ រមែងមានដល់បុគ្គលដែលមិនតម្កល់ខ្លួនទុកប្រពៃ ឬមិនបានធ្វើបុណ្យទុកក្នុងកាលមុន ។ ដូច្នោះ លោកសម្តែងការដល់ព្រមនៃចក្រទាំង ២ ខាងចុងរបស់ខ្លួន ដោយ

អាការដ៏ចម្រើននេះ ដោយបទថា **ឯវំ** លោកសម្តែងការដល់ព្រមនៃចក្រទាំង ២ ខាងដើមរបស់ខ្លួន ដោយបទថា **សុតំ** ។ ពិតហើយ ការស្តាប់ ( ធម៌ ) មិនកើតមានដល់បុគ្គលដែលនៅក្នុងប្រទេសមិនសមគួរ ឬបុគ្គលវៀរចាកការសេពគប់សប្បុរស ។ ការបរិសុទ្ធនៃអាសវក្កិលេស រមែងមិនសម្រេចដល់បុគ្គលនោះ ព្រោះការសម្រេចនៃចក្រទាំង ២ ខាងចុង ការបរិសុទ្ធនៃបយោគសម្បត្តិ រមែងមានព្រោះការសម្រេចនៃចក្រទាំង ២ ខាងដើមដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ការសម្រេចនៃការឈ្លាសក្នុងអធិគម គឺ បដិវេធ រមែងមានដល់បុគ្គលនោះ ព្រោះការបរិសុទ្ធនៃអាសវក្កិលេស ការសម្រេចនៃការឈ្លាសក្នុងអាគម គឺ បរិយត្តិ រមែងមានព្រោះការបរិសុទ្ធិនៃបយោគសម្បត្តិ គឺសេចក្តីព្យាយាម ព្រះថេរៈកាលរៀបរៀងនិទានវចនៈទុកក្នុងឋានៈដែលសមគួរ ពាក្យរបស់លោកដែលដល់ព្រមដោយអាគម និងអធិគម ដែលមានអាសវក្កិលេស បរិសុទ្ធដោយបយោគសម្បត្តិ រមែងគួរជាព្រះតម្រាស់របស់ព្រះមានព្រះភាគ ដូចពន្លឺប្រាក់ ពន្លឺមាស ដែលផ្សាយចេញអំពីព្រះអាទិត្យកំពុងរះឡើង និងដូចការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ជាអ្នកនាំនូវកុសលកម្ម ទើបពោលពាក្យជាដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។

ន័យម្យ៉ាងទៀត ដោយបទថា **ឯវំ** នេះ ព្រះថេរៈសម្តែងការៈ គឺការដល់ព្រមនៃអត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទារបស់ខ្លួន ដោយពាក្យដែលសម្តែងដល់បដិវេធមានប្រការផ្សេងៗ ដោយពាក្យថា **សុតំ** នេះ លោក

សម្តែងការៈ គឺការដល់ព្រមនៃធម្មប្បដិសម្ភិទា និងនិរុត្តិប្បដិសម្ភិទា ដោយពាក្យសម្តែងដល់ការចាក់ធ្លុះប្រភេទនៃធម៌ដែលត្រូវស្តាប់ ។

ម្យ៉ាងទៀត ព្រះថេរៈ កាលពោលពាក្យដែលសម្តែងការធ្វើទុកក្នុងចិត្តដោយឧបាយនេះថា **ឯវំ** ដូច្នេះ ទើបសម្តែងថា ធម៌ទាំងនេះ ក៏ខ្ញុំតាមសម្លឹងដោយចិត្ត ចាក់ធ្លុះដោយល្អ ដោយទិដ្ឋិហើយ កាលនឹងពោលពាក្យដែលសម្តែងការតាមប្រកបការស្តាប់នេះថា **សុតំ** ដូច្នេះ ទើបសម្តែងថា ធម៌ដ៏ច្រើនដែលខ្ញុំស្តាប់មកហើយ ទ្រទ្រង់ទុកហើយ ស្វាធ្យាយហើយ ដូច្នេះ ។

ព្រះថេរៈ កាលសម្តែងការបរិបូណ៌នៃអត្ថ និងព្យញ្ជនៈ ដោយពាក្យទាំង ២ នេះ ទើបញ៉ាំងការអើពើឲ្យកើតឡើងក្នុងការស្តាប់ ។ ពិតហើយ បុគ្គលកាលមិនស្តាប់ធម៌ដែលបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ដោយអើពើ រមែងឆ្ងាយចាកប្រយោជន៍ដ៏ធំក្រៃលែង ព្រោះដូច្នោះ គួរធ្វើការអើពើឲ្យកើតហើយស្តាប់ធម៌ដោយគោរពចុះ ។

ដោយពាក្យទាំងអស់នេះ គឺបទថា **ឯវម្មេ សុតំ** គឺព្រះអានន្ទ កាលមិនទុកធម៌ដែលព្រះតថាគតទ្រង់ប្រកាស ឲ្យឆ្ងាយអំពីខ្លួន ឈ្មោះថា កន្លងនូវភូមិនៃអសប្បុរស ប្តេជ្ញាភាពជាសាវក ឈ្មោះថា ឈានចុះកាន់ភូមិនៃសប្បុរស ។

ម្យ៉ាងទៀត ដោយបទទាំងអស់នេះថា **ឯវម្មេ សុតំ** ជាដើម ឈ្មោះថា ព្រះថេរៈញ៉ាំងចិត្តឲ្យចេញចាកអសទ្ធម្ម ឲ្យតាំងនៅក្នុងសទ្ធម្ម ។ ព្រះថេរៈ កាលសម្តែងថា ព្រះតម្រាស់របស់ព្រះមានព្រះភាគអង្គនោះ ខ្ញុំស្តាប់មកទាំង

អស់ហើយនោះឯង ឈ្មោះថា រមែងចេញមុខ អាងដល់ព្រះសាស្តា ចុះ ស៊ប់ក្នុងព្រះតម្រាស់ព្រះជិនស្រី ប្រតិស្ឋានទេតិធម៌ ។

ន័យម្យ៉ាងទៀត ដោយបទថា **ឯវម្មេ សុតំ** ព្រះថេរៈញ៉ាំងភាពជាអ្នកមិនមានសទ្ធាក្នុងធម៌នេះរបស់ទេវតា និងមនុស្សទាំងពួងឲ្យអស់ទៅ ឲ្យកើតការដល់ព្រមនៃសទ្ធា មិនអាងថា សូត្រនោះលោកឲ្យកើតឯង បើកផ្ទារការស្តាប់មកអំពីមុនថា សូត្រនេះ ខ្ញុំបានទទួលមកចំពោះព្រះភក្ត្រព្រះមានព្រះភាគអង្គនោះ ទ្រង់អង់អាចដោយវេសារជ្ជធម៌ ៤ ទ្រទ្រង់ទុកនូវញាណដែលជាកម្លាំង ១០ ទ្រង់តាំងនៅក្នុងឋានៈ ជាអ្នកអាចហ៊ាន បន្លឺសីហនាទបាន ប្រសើរឧត្តមជាងសត្វគ្រប់ជំពូក ជាធំដោយធម៌ ជាព្រះធម្មរាជា ជាព្រះធម្មាធិបតី ជាប្រទីបដោយធម៌ ជាទីពឹងដោយធម៌ ជាស្តេចចក្រពត្តិដ៏ប្រសើរដោយសទ្ធម្ម ទ្រង់ត្រាស់ដឹងឯងដោយប្រពៃ ដោយឥតសង្ស័យ ឬសន្ទិះក្នុងអត្ថ ក្នុងធម៌ ក្នុងបទ ឬក្នុងព្យញ្ជនៈ ក្នុងសូត្រនេះឯង ។ ព្រោះហេតុនោះ ទើបលោកពោលពាក្យនេះទុកថា

ព្រះសាវ័ករបស់ព្រះគោតម ពោលយ៉ាងនេះថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ញ៉ាំងអសទ្ធាឲ្យវិនាស ញ៉ាំងសទ្ធាក្នុងសាសនាឲ្យចម្រើន ដូច្នេះ ។

បទថា **ឯកំ** ជាបទសម្តែងលម្អិតដល់ចំនួនរាប់ ។ បទថា **សមយំ** ជាបទសម្តែងវេលាដែលកំណត់ទុកហើយ ។ ពីរបទថា **ឯកំ សមយំ** ជាបទសម្តែងវេលាដែលមិនកំណត់ ពិតប្រាកដ ។

**សមយ** សព្ទ ក្នុងបទថា **ឯកំ សមយំ** នោះ រមែងប្រាកដក្នុងអត្ថថា

**សមវាយ** គឺការដល់ព្រម ខណៈ កាល សមូហៈ គឺការប្រជុំ ហេតុ ទិដ្ឋិ បដិលាភ គឺការបាន បហាន គឺការលះ និងបដិវេធ គឺការចាក់ធ្លុះ ។

ពិតហើយ **សមយ** សព្ទនោះ មានការដល់ព្រមជាអត្ថ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **អប្បេវនាម ស្វេបិ ឧបសង្កមេយ្យាម កាលញ្ច សមយញ្ច ឧបាទាយ** បើដូច្នោះ ចាំយើងពិចារណានូវកាល និងសម័យសិន ហើយសឹមទៅក្នុងថ្ងៃស្អែក ។

មានខណៈជាអត្ថ ដូចក្នុងប្រយោគជាដើមថា **អយំ ភិក្ខវេ ឯកោវ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ** ម្នាលភិក្ខុទាំងឡាយ នេះជាខណៈ និងសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យតែមួយ ដូច្នេះ ។

មានកាលជាអត្ថ ដូចក្នុងប្រយោគជាដើមថា **ឧណ្ហសមយោ បរិឡាហសមយោ** សម័យក្តៅ សម័យស្អុះស្អាប់ ដូច្នេះ ។

មានការប្រជុំជាអត្ថ ដូចក្នុងប្រយោគជាដើមថា **មហាសមយោ បវនស្មឹ** ថ្ងៃនេះជាថ្ងៃប្រជុំធំ ក្នុងដងព្រៃធំ ។

មានហេតុជាអត្ថ ដូចក្នុងប្រយោគជាដើមថា **សមយោបិ ខោ តេ ភទ្ទាលិ ។បេ។ សមយោ អប្បដិវិទ្ធោ អហោសិ** ។ ម្នាលភទ្ទាលិ អ្នកមិនបានដឹងហេតុថា ព្រះមានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី តែព្រះមានព្រះភាគ គង់ដឹងអាត្មាអញថា ភិក្ខុឈ្មោះភទ្ទាលិ មិនបានបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តាដូច្នេះឡើយ ម្នាលភទ្ទាលិ នេះឯងជាហេតុ ដែលអ្នកមិនបានដឹង ។

មានទិដ្ឋិជាអត្ថ ដូចក្នុងប្រយោគជាដើមថា **តេន ខោ បន សមយេន ឧគ្គាហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ សមយប្បវាទកេ តិណ្ឌុកាចីរេ ឯកសាលកេ មល្លិកាយ អារាមេ បដិវសតិ** សម័យនោះ ឯង បរិព្វាជកឈ្មោះឧគ្គាហមានះ ជាសមណមុណ្ឌិកាបុត្រ អាស្រ័យនៅក្នុង អារាមរបស់ព្រះនាងមល្លិកាទេវី ដែលមានសាលាមួយ មានជួរដើមទន្លាប់ ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សានូវទិដ្ឋិ ( លទ្ធិ ) ។

មានការបានចំពោះជាអត្ថ ដូចក្នុងប្រយោគជាដើមថា

**ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយិកោ**
**អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ ។**

បណ្ឌិត ជាអ្នកមិនប្រមាទ តែងបានចំពោះប្រយោជន៍ទាំងពីរ គឺ ប្រយោជន៍ណា ក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ណាដែលមានក្នុង បរលោកក្តី ធីរជន ឈ្មោះថា បណ្ឌិត ព្រោះការបានចំពោះ នូវប្រយោជន៍ទាំងពីរនោះ ។

មានការលះបង់ជាអត្ថ ដូចក្នុងប្រយោគជាដើមថា **សម្មា មានាភិ-សមយាអន្តមកាសិ ទុក្ខស្ស** ធ្វើនូវទីបំផុតកងទុក្ខ ដោយហេតុដែលបាន លះបង់នូវមានះចោលដោយប្រពៃ ។

មានការចាក់ដោតជាអត្ថ ដូចក្នុងប្រយោគជាដើមថា **ទុក្ខស្ស បីឡនដ្ឋោ សង្ខតដ្ឋោ សន្តាបដ្ឋោ វិបរិណាមដ្ឋោ អភិសមយដ្ឋោ** ទុក្ខមានអត្ថថា បៀតបៀន មានបច្ច័យតាក់តែង ធ្វើឲ្យក្តៅក្រហាយ ប្រែប្រួល និងគួរចាក់ដោត ។

តែក្នុងទីនេះ **សមយ** សព្ទនោះ មានកាលជាអត្ថ ព្រោះហេតុនោះ ទើបព្រះថេរៈសម្ដែងថា ក្នុងសម័យមួយ បណ្ដាសម័យដែលញែកកាលចេញ ជាឆ្នាំ រដូវ ខែ កន្លះខែ ពេលយប់ ពេលថ្ងៃ ពេលព្រឹក ពេលថ្ងៃត្រង់ ពេលល្ងាច បឋមយាម មជ្ឈិមយាម បច្ឆិមយាម និងមួយសន្ទុះជាដើម ។

ក្នុងសេចក្ដីនោះ សូត្រណាដែលព្រះមានព្រះភាគត្រាស់ទុកក្នុងឆ្នាំ រដូវ ខែ បក្ខ ចំណែករាត្រី ចំណែកថ្ងៃណាមួយ ក្នុងបណ្ដាសម័យ មានឆ្នាំជាដើម នោះ សូត្រទាំងអស់នោះ ព្រះថេរៈចេះចាំល្អ គឺកំណត់ទុកដោយល្អ ដោយបញ្ញាក៏ពិត ទោះយ៉ាងនោះ ព្រោះហេតុដែលលោកពោលយ៉ាងនេះថា ខ្ញុំបាន ស្ដាប់មកហើយយ៉ាងនេះ ក្នុងឆ្នាំនោះ រដូវនោះ ខែនោះ បក្ខនោះ រត្តិភាគ នោះ ទិវាភាគនោះ បុគ្គលណាមួយ មិនអាចទ្រទ្រង់ចាំបានងាយ មិនអាច នឹងសម្ដែងឯង ឬឲ្យអ្នកដទៃសម្ដែងបាន នឹងត្រូវនិយាយគ្នាច្រើន ដូច្នោះ ទើបព្រះថេរៈសង្ខេបអត្ថនោះទុកដោយបទមួយប៉ុណ្ណោះ ហើយពោលថា **ឯកំ សមយំ** ដូច្នេះ ។

ម្យ៉ាងទៀត សម័យនៃព្រះមានព្រះភាគនេះ បែកប្រភេទ កាលវេលា ចេញសន្ធឹកសន្ធាប់ ដែលប្រាកដច្បាស់ពន់ពេក ក្នុងពួកទេវតា និងមនុស្ស ជាដើមយ៉ាងនេះ គឺសម័យទ្រង់ចុះកាន់គភ៌ សម័យប្រសូត សម័យកើតការ សង្វេគ សម័យទ្រង់ចេញបួស សម័យទ្រង់ធ្វើទុក្ករកិរិយា សម័យឈ្នះមារ សម័យត្រាស់ដឹង សម័យនៅជាសុខក្នុងបច្ចុប្បន្ន សម័យទេសនា សម័យ ទ្រង់បរិនិព្វាន ព្រះថេរៈសម្ដែងថា សម័យមួយ ពោល គឺសម័យទេសនា

ក្នុងបណ្ដាសម័យទាំងឡាយនោះ ។

ម្យ៉ាងទៀត ព្រះថេរៈសំដៅយកសម័យនៃកិច្ចដែលប្រកបដោយករុណា ក្នុងបណ្ដាសម័យនៃកិច្ចដែលប្រកបដោយញាណ និងករុណា សម័យនៃការបដិបត្តិដើម្បីជាប្រយោជន៍អ្នកដទៃ ក្នុងបណ្ដាសម័យនៃការបដិបត្តិដើម្បីប្រយោជន៍ខ្លួន និងអ្នកដទៃ សម័យនៃធម្មីកថា ក្នុងបណ្ដាសម័យនៃករណីទាំង ២ នៃបុគ្គលប្រជុំគ្នា សម័យនៃទេសនា ក្នុងបណ្ដាសម័យនៃទេសនា និងការបដិបត្តិ សម័យណាមួយ ក្នុងបណ្ដាសម័យទាំងឡាយនោះ ទើបពោលថា **ឯកំ សមយំ** ដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ក្នុងទីនេះ លោកមិនធ្វើដូចក្នុងអភិធម្ម លោកធ្វើការសម្ដែងលម្អិតដោយសត្តមីវិភត្តិថា **យស្មឹ សមយេ កាមាវចរំ** និង **យស្មឹ សមយេ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ** ក្នុងសុត្តបទដទៃចាកគម្ពីរនេះ ហើយក្នុងវិន័យលោកសម្ដែងខែដោយតតិយាវិភត្តិថា **តេន សមយេន ពុទ្ធោ ភគវា** តែធ្វើការសម្ដែងលម្អិតដោយទុតិយាវិភត្តិថា **ឯកំ សមយំ** ឆ្លើយថា ព្រោះក្នុងទីនោះ មានអត្ថយ៉ាងនោះ តែក្នុងទីនេះ មានអត្ថយ៉ាងនេះ ( មានអត្ថមួយផ្សេងទៀត ) ។ ពិតហើយ ក្នុងបណ្ដាអភិធម្មជាដើមនោះ និងក្នុងសុត្តបទដទៃក្រៅអំពីនេះ **សមយ** សព្ទ មានអត្ថក្នុងអធិករណៈ ( សត្តមីវិភត្តិ ) និងមានអត្ថការលក្ខណៈដោយភាវៈ ។ ព្រោះថា **សមយ** ជាអធិករណៈ មានកាលជាអត្ថ និងមានសមូហៈជាអត្ថ លោកកំណត់ថា ជាភាវៈនៃធម៌ទាំងឡាយ មានផស្សៈជាដើម ដែលលោកពោលទុកហើយក្នុងទីនោះៗ ដោយ

ការៈនៃសម័យ ពោលគឺខណៈ ការរួបរួម និងហេតុ ។ ព្រោះដូច្នោះ ដើម្បីឲ្យអត្ថភ្លឺច្បាស់ ទើបលោកសម្ដែងលម្អិតជាសត្តមីវិភត្តិក្នុងបទនោះ ។ ពិតហើយ សម័យនៃការបញ្ញត្តសិក្ខាបទនោះ ព្រះសារីបុត្រជាដើម ក៏ដឹងបានលំបាក ។

ព្រះមានព្រះភាគ កាលទ្រង់បញ្ញត្តសិក្ខាបទដោយសម័យនោះ ដែលជាហេតុ និងជាករណៈ កាលទ្រង់សម្លឹងដល់ហេតុនៃការបញ្ញត្តសិក្ខាបទ ទ្រង់ប្រថាប់នៅក្នុងទីនោះៗ ព្រោះដូច្នោះ ដើម្បីនឹងឲ្យអត្ថនោះភ្លឺច្បាស់ ទើបលោកធ្វើការសម្ដែងលម្អិត ជាតតិយាវិភត្តិក្នុងបទនោះ ។

តែក្នុងទីនេះ និងក្នុងទីដទៃ ដែលមានអត្ថយ៉ាងនេះ **សមយ** សព្ទ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ ពិតហើយ ក្នុងសម័យណា ព្រះមានព្រះភាគទ្រង់សម្ដែងព្រះសូត្រនេះ ឬសូត្រដទៃ ក្នុងសម័យនោះ ព្រះអង្គទ្រង់ប្រថាប់នៅដោយធម៌ ជាគ្រឿងនៅ គឺករុណា ដោយចំណែកមួយ ។ ព្រោះដូច្នោះ ដើម្បីឲ្យអត្ថនោះភ្លឺច្បាស់ ទើបលោកធ្វើការសម្ដែងលម្អិតជាទុតិយាវិភត្តិក្នុងបទនេះ ។ ហេតុនោះ ទើបលោកពោលពាក្យនេះទុកថា

សម្លឹងដល់អត្ថនោះៗ ហើយ លោកពោល **សមយ** សព្ទទុកក្នុងទីដទៃដោយសត្តមីវិភត្តិ និងតតិយាវិភត្តិ តែក្នុងទីនេះ លោកពោល **សមយ** សព្ទនោះទុកដោយទុតិយាវិភត្តិ ។

ឯបុរាណាចារ្យទាំងឡាយ ពណ៌នាទុកថា **សមយ** សព្ទនោះ មានប្រភេទដែលពោលញែកបានដូច្នេះថា **តស្មឹ សមយេ តេន សមយេន** ក្ដី **តំ**

**សមយំ** ក្តី តែពោលដោយអត្ថ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ក្នុងទីទាំងពួង ដូច្នេះ ។ ព្រោះដូច្នោះ កាលលោកពោលថា **ឯកំ សមយំ** គប្បីជ្រាបថា **ឯកស្មឹ សមយេ** ដូច្នេះ ។

បទថា **ភគវា** ជាពាក្យពោលដោយសេចក្តីគោរព ។ ព្រោះមនុស្ស ទាំងឡាយហៅគ្រូក្នុងលោកថា **ភគវា** ឯព្រះមានព្រះភាគអង្គនេះ ឈ្មោះថា ជាគ្រូរបស់សត្វគ្រប់ជំពូក ព្រោះជាបុគ្គលប្រសើរដោយព្រះពុទ្ធគុណគ្រប់អន្លើ ព្រោះដូច្នោះ គប្បីជ្រាបគ្រូថា **ភគវា** ដូច្នេះ ។

សូម្បីបុរាណាចារ្យទាំងឡាយ ក៏បានពោលទុកថា ពាក្យថា **ភគវា** ជា ពាក្យប្រសើរ ពាក្យថា **ភគវា** ជាពាក្យឧត្តម ព្រោះហេតុនោះ ទើបលោក ហៅបុគ្គលប្រកបដោយសេចក្តីគោរពរាប់អានថា **ភគវា** ដូច្នេះ ។

ម្យ៉ាងទៀត លោកពោលទុកថា

> **ភគវា** ព្រោះមានព្រះភាគ្យ គឺបារមីធម៌ ។ ព្រោះកាច់បំបាក់បង់នូវកងកិលេស ព្រោះប្រកបដោយបុញ្ញសិរី ព្រោះសោយព្រហ្មវិហារធម៌ និងព្រោះខ្ជាក់ចោលនូវការវិលវល់ស្លាប់កើតក្នុងភពទាំង ៣ ។

គប្បីជ្រាបអត្ថនៃបទថា **ភគវា** នេះ ដោយអំណាចគាថានេះ ដោយ ពិស្តារ ។ ពិតហើយ សព្វថា **ភគវា** នោះ លោកពោលទុកហើយ ក្នុង ពុទ្ធានុស្សតិ ក្នុងវិសុទ្ធិមគ្គ ។

ក្នុងអធិការនេះ ដោយពាក្យអធិប្បាយប្រមាណប៉ុណ្ណោះ ព្រះថេរៈកាល

សម្តែងធម៌តាមដែលខ្លួនបានស្តាប់មក ដោយពាក្យថា **ឯវម្មេ សុតំ** ឈ្មោះថា ធ្វើសរីរៈ គឺព្រះធម៌របស់ព្រះមានព្រះភាគឲ្យប្រចក្ស ។ ព្រោះហេតុនោះ ព្រះថេរៈរមែងញ៉ាំងជនដែលកើតការនឿយណាយ ព្រោះមិនឃើញព្រះសាស្តា ឲ្យត្រេកអរក្នុងចិត្តថា បាវចនៈដែលឥតសាស្តារមែងមិនមាន នេះជាសាស្តារបស់យើងទាំងឡាយ ។ ព្រះថេរៈ កាលសម្តែងភាពដែលព្រះមានព្រះភាគមិនមានក្នុងសម័យនោះ ដោយពាក្យថា **ឯកំ សមយំ ភគវា** ញ៉ាំងការរលត់នៃរូបកាយឲ្យស្ទុះទៅ ។ ព្រោះហេតុនោះ ព្រះថេរៈរមែងញ៉ាំងជនដែលស្រវឹងក្នុងជីវិតឲ្យសង្វេគថា ព្រះមានព្រះភាគអង្គនោះ ទ្រង់សម្តែងអរិយធម៌មានឈ្មោះយ៉ាងនេះ ទ្រទ្រង់ទុកនូវកម្លាំង ១០ មានព្រះវរកាយស្មើដោយដុំពេជ្រ ទ្រង់បរិនិព្វានហើយ ដោយប្រយោជន៍អ្វីដទៃ ដែលពួកអ្នកគប្បីញ៉ាំងការសង្ឃឹមក្នុងជីវិតឲ្យកើតឡើង និងញ៉ាំងការឧស្សាហ៍របស់ជននោះឲ្យកើតឡើងក្នុងព្រះសទ្ធម្ម ។

ម្យ៉ាងទៀត ព្រះថេរៈកាលពោលថា **ឯវំ** រមែងសម្តែងលម្អិតដល់សម្បត្តិគឺទេសនា កាលពោលថា **មេ សុតំ** រមែងសម្តែងលម្អិតដល់សាវកសម្បត្តិ ។ កាលពោលថា **ឯកំ សមយំ** រមែងសម្តែងលម្អិតដល់កាលសម្បត្តិ ។ កាលពោលថា **ភគវា** រមែងសម្តែងលម្អិតដល់ទេសកសម្បត្តិ ។

## ការមកនៃឈ្មោះ ឯករឧក្កដ្ឋា

បទថា **ឧក្កា** ក្នុងបទថា **ឧក្កដ្ឋាយំ វិហរតិ** នេះ សំដៅយកប្រទីបក្រុងនោះគេហៅថា **ឧក្កដ្ឋា** ព្រោះអ្នកក្រុងនាំគ្នាចូលគប់ភ្លើង សាងនគរក្នុង

ពេលយប់ ដោយបំណងថា ថ្ងៃមង្គល ខណៈល្អ ឫក្សល្អ កុំកន្លងបង់ទៅឡើយ ។ លោកពោលអធិប្បាយទុកថា ព្រោះក្រុងនោះ អ្នកស្រុកអុជប្រទីបមានជ័ង បំភ្លឺឲ្យកសាង ។ ជិតក្រុងឈ្មោះ **ឧក្កដ្ឋា** នោះ ។ បទថា **ឧក្កដ្ឋាយំ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា ជិត ។ បទថា **វិហរតិ** នេះ ជាការសម្ដែងដល់ការព្រមព្រៀងនៃការនៅ ក្នុងបណ្ដាការនៅដោយការផ្លាស់ប្ដូរឥរិយាបថ ការនៅដូចពួកទេវតា ការនៅដូចពួកព្រហ្ម ការនៅដូចព្រះអរិយៈឯណានីមួយ ដោយមិនផ្សេងគ្នា ។ តែក្នុងទីនេះ ជាការសម្ដែងការប្រកបដោយឥរិយាបថឯណាមួយ បណ្ដាឥរិយាបថ គឺ ឈរ ដើរ អង្គុយ និងដេក ។

ព្រោះហេតុនោះ ព្រះមានព្រះភាគប្រថាប់ឈរក្ដី យាងក្ដី គង់ក្ដី ផ្ទំក្ដី គប្បីជ្រាបថា ប្រថាប់ទាំងអស់ ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះ ទ្រង់សម្រាកដើម្បីបំបាត់ការហត់នឿយចាកឥរិយាបថមួយ ដោយឥរិយាបថមួយ ទ្រង់រមែងបរិហារ គឺទ្រទ្រង់អត្តភាពឲ្យប្រព្រឹត្តទៅ មិនឲ្យទ្រុឌទ្រោម ។ ព្រោះដូច្នោះ ទើបលោកពោលថា ប្រថាប់ដូច្នេះ ។

## ការមកនៃឈ្មោះ ព្រៃសុភគវ័ន

ក្នុងបទថា **សុភគវនេ** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ។ ព្រៃឈ្មោះថា **សុភគ** ព្រោះដល់នូវការស្អាត អធិប្បាយថា ព្រោះល្អត្រកាល និងព្រោះមានវត្ថុដែលគប្បីបំណងល្អ ។ ព្រោះការស្អាតរបស់ព្រៃនោះ ទើបមនុស្សទាំងឡាយ កាន់យកបាយ និងទឹកជាដើម ទៅបរិភោគកម្សាន្តសប្បាយ

នៅក្នុងព្រៃនោះរៀងរាល់ថ្ងៃ និងបទស្រន់វត្ថុដែលគេប្រាថ្នាល្អៗ ក្នុងទីនោះថា យើងខ្ញុំទាំងឡាយ សូមបានកូនប្រុស កូនស្រីចុះ និងវត្ថុដែលគប្បីប្រាថ្នានោះ ពួកគេក៏បានសមដូចប្រាថ្នានោះឯង ។ ព្រៃនោះ ឈ្មោះថា **សុភគ** ព្រោះស្រស់ស្អាត និងព្រោះមានវត្ថុដែលគប្បីប្រាថ្នាល្អ ដូចពណ៌នាមកនេះ ។ម្យ៉ាងទៀត **សុភគ** ព្រោះមនុស្សចំណែកច្រើនជាប់ចិត្ត ។ ឈ្មោះថា **វន** ( ព្រៃ ) ព្រោះអត្ថថា សត្វទាំងឡាយពេញចិត្ត គឺធ្វើឲ្យសត្វទាំងឡាយ ស្រឡាញ់ដោយគុណសម្បត្តិរបស់ព្រៃនោះឯង អធិប្បាយថា ឲ្យកើតការគួរស្រឡាញ់ក្នុងខ្លួនឯង ដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា **វន** ព្រោះហៅរក អធិប្បាយថា ដូចហៅហ្វូងសត្វដោយសំឡេងហៅរបស់បក្សី មានបក្សីកោកិលា ( តាវៅ ) ជាដើម ដែលត្រេកអរ នឹងក្លិនផ្កាច្រើនពណ៌ និងដោយមែក ទង ប្រគាប ស្លឹកចាស់ ស្លឹកខ្ចីរបស់ដើមឈើដែលកម្រើក ព្រោះត្រូវខ្យល់ត្រសៀកៗថា មកចុះ មកស៊ី មកប្រើប្រាស់ជាមួយគ្នាចុះ ។ ព្រៃនោះផង ដល់នូវការស្អាតផង ដូច្នោះ ទើបឈ្មោះថា **សុភគវន** ។ ក្នុងព្រៃ **សុភគវន** នោះ ។ បណ្ដាព្រៃមាន ២ ប្រភេទ គឺព្រៃដាំ និងព្រៃកើតឯង ក្នុងព្រៃ ២ ប្រភេទនោះ ព្រៃដាំ បានដល់ ព្រៃវេឡុវន និងព្រៃជេតវនជាដើម ព្រៃកើតឯង បានដល់ ព្រៃអន្ធវន ព្រៃមហាវន និងព្រៃអញ្ជនវនជាដើម ។ ព្រៃសុភគវននេះ គប្បីជ្រាបថា ជាព្រៃកើតឯង ។

សូម្បីដើមរាំងក្នុង ក្នុងបទថា **សាលរាជមូលេ** លោកក៏ហៅថា ដើម

សាលៈ សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រៃមហាសាលវន មិនឆ្ងាយអំពីស្រុក ឬនិគម ព្រៃមហាសាលវននោះ ក៏ដេរដាសទៅដោយដើមល្ហុងខ្វង និងត្រាស់ថា រវាងដើមរាំងទាំងគូ ។ សូម្បីដើមឈើដែលធំបំផុត ក៏លោកហៅថា ដើមឈើម្ចាស់ព្រៃ សមដូចពាក្យដែលលោកពោលថា

**តវេវ តេវ វិជិតេ        តវេវុយ្យានភូមិយា**
**ឧជុវំសា មហាសាលា   នីលោភាសា មនោរមា ។**

បពិត្រព្រះសម្មតិទេព ត្រង់ទីឧទ្យានរបស់ព្រះអង្គ ក្នុងដែនរបស់ព្រះអង្គហ្នឹងឯងមានពួកឈើធំ មានដើមត្រង់ មានពន្លឺខៀវ ជាទីត្រេកអរនៃចិត្ត ។

សូម្បីដើមឈើណាមួយ ក៏ហៅថា ដើមឈើម្ចាស់ព្រៃបាន សមដូចព្រះមានព្រះភាគត្រាស់ថា **អថ ខោ តំ ភិក្ខវេ មាលុវាពីជំ អញ្ញតរស្មឹ សាលមូលេ និបតេយ្យ** ម្នាលភិក្ខុទាំងឡាយ ពូជជ្រៃនោះ ក៏ជ្រុះចុះទៀបគល់រាំងក្នុងមួយដើម ដូច្នេះជាដើម តែក្នុងទីនេះ លោកបំណងយកដើមឈើធំបំផុត ឈ្មោះថា ដើមឈើម្ចាស់ព្រៃ ។

ចំណែកពាក្យសព្ទនៃបទថា **សាលរាជមូលេ** នោះ រមែងញ៉ាំងដើមឈើនោះឲ្យសម្រេចជាដើមឈើធំបំផុត ដូចប្រយោគជាដើមថា **សុបតិដ្ឋស្ស ខោ បន ព្រាហ្មណា ធម្មិក និគ្រោធរាជស្ស ...** ម្នាលព្រាហ្មណធម្មិកៈ សុបតិដ្ឋនិគ្រោធរាជ ... ។

ក្នុងបទថា **សាលរាជមូលេ** នោះ បែកចេញជាសមាស ២ យ៉ាង ( ឆដ្ឋីតប្បុរិសសមាសថា ) **សាលានំ រាជា** ( ស្តេចនៃដើមឈើទាំង-ឡាយ ) ព្រោះហេតុនោះ ទើបឈ្មោះថា **សាលរាជា** ខ្វះ និងជា ( វិសេសនបុព្វបទ កម្មធារយសមាសថា ) **សាលោ ច សោ ជេដ្ឋកដ្ឋេន រាជា** ច ដើមសាលៈនោះផង ជាស្តេច ព្រោះអត្ថថា ធំបំផុតផង ព្រោះហេតុនោះ ទើបឈ្មោះថា **សាលរាជា** ។ បទថា **មូលំ** ប្រែថា ជិត ។ ព្រោះថា **មូល** សព្ទនេះ ប្រើក្នុងអត្ថថា ជិតគល់ ក្នុងប្រយោគជាដើមថា **មូលានិ ឧទ្ធរេយ្យ អន្តមសោ ឧសីរនាឡិមត្តានិបិ** ក៏រមើងឫសគល់ ដោយហោចទៅ សូម្បីប៉ុនចម្រៀកស្បូវភ្លាំង ( ក៏មិនឲ្យសល់ ) ។ **មូល** សព្ទ ប្រើក្នុងហេតុដែលមិនទូទៅ ក្នុងប្រយោគជាដើមថា **លោភោ អកុ-សលមូលំ** លោភៈជាឫសគល់នៃអកុសល ។ ម្យ៉ាងទៀត **មូល** សព្ទ ប្រើក្នុងអត្ថថា ជិត ដូចក្នុងប្រយោគជាដើមថា **យាវ ច មជ្ឈន្ហិកេ កាលេ ឆាយា ផរតិ និវាតេ បណ្ណានិ បតន្តិ ឯត្តាវតា រុក្ខមូលំ** ក្នុងពេលថ្ងៃត្រង់ស្រមោលដើមឈើផ្សាយទៅត្រឹមណា ក្នុងពេលស្ងប់ខ្យល់ ស្លឹកឈើជ្រុះត្រឹមណា ទីដែលស្រមោលផ្សាយទៅ និងទីដែលស្លឹកឈើជ្រុះនោះ ហៅថា ទីជិតគល់ឈើ ។ តែក្នុងទីនេះ **មូល** សព្ទ លោកបំណងយកអត្ថថា **សមីប** គឺជិត ព្រោះដូច្នោះ គប្បីជ្រាបអត្ថក្នុងពាក្យថា **សាលរាជមូលេ** នេះ យ៉ាងនេះថា ក្នុងទីជិតនៃដើមរាំងធំ ។

ក្នុងសេចក្តីនោះ គប្បីមានពាក្យសួរថា បើព្រះមានព្រះភាគ ប្រថាប់នៅ

ក្នុងក្រុងឧក្កដ្ឋាមុនសោត ក៏មិនគួរពោលថា ក្បែរដើមរាំងធំ ក្នុងព្រៃសុភគវន បើប្រថាប់នៅទៀបដើមរាំងធំ ក្នុងព្រៃសុភគវននោះសោត ក៏មិនគួរពោលថា ក្នុងក្រុងឧក្កដ្ឋា ព្រោះថា ព្រះអង្គមិនអាចគង់នៅម្តងក្នុងទី ២ កន្លែងបានឡើយ ឆ្លើយថា សេចក្តីនោះ មិនគប្បីឃើញយ៉ាងនោះ ខ្ញុំបានពោលទុកហើយមិនមែនឬថា សត្តមីវិភត្តិ ចុះក្នុងអត្ថថា ជិត ។ ព្រោះដូច្នោះ ហ្វូងគោកាលត្រាច់ទៅក្បែរស្ទឹងគង្គា និងយមុនាជាដើម រមែងត្រូវហៅថា ត្រាច់ទៅក្បែរស្ទឹងគង្គា ជិតស្ទឹងយមុនា យ៉ាងណា សូម្បីក្នុងទីនេះក៏ដូច្នោះ គឺព្រះមានព្រះភាគ គង់នៅក្នុងព្រៃសុភគវន ជិតក្រុងឧក្កដ្ឋា ក្នុងទីជិតដើមរាំងធំ លោកក៏ហៅថា គង់នៅទៀបដើមរាំងធំ ក្នុងព្រៃសុភគវន ក្បែរក្រុងឧក្កដ្ឋា ដូច្នេះ ។ បទថា **ឧក្កដ្ឋា** ជាពាក្យមានអត្ថ សំដៅដល់គោចរគាម ។ បទថា **សុភគវនំ** ជាពាក្យមានអត្ថចង្អុលដល់ទីនៅ ដែលសមគួរដល់ បព្វជិត ។ ក្នុង ២ ពាក្យនោះ ព្រះអានន្ទសម្តែងការអនុគ្រោះចំពោះគ្រហស្ថ របស់ព្រះមានព្រះភាគ ដោយការប្រារព្ធដល់ក្រុងឧក្កដ្ឋា សម្តែងការដែលទ្រង់ធ្វើសេចក្តីអនុគ្រោះ ចំពោះបព្វជិត ដោយការប្រារព្ធដល់ព្រៃសុភគវន ។

ម្យ៉ាងទៀត ព្រះអានន្ទសម្តែងការវៀរអត្តកិលមថានុយោគ ដោយទ្រង់ទទួលបច្ច័យដោយពាក្យដើម គឺ **ឧក្កដ្ឋា** សម្តែងការវៀរកាមសុខល្លិកានុ-យោគ ដោយទ្រង់លះវត្ថុកាម ដោយពាក្យក្រោយ គឺ **សុភគវនំ** នោះ ។ លោកសម្តែងវីរិយៈ ក្នុងការទ្រង់សម្តែងព្រះធម៌ដោយពាក្យដើម សម្តែងព្រះអជ្ឈាស្រ័យដែលបង្អោនទៅក្នុងវិវេក ដោយពាក្យក្រោយ ។ សម្តែងការចូល

ដល់ព្រះករុណាគុណ ដោយពាក្យដើម សម្តែងការចូលដល់ព្រះបញ្ញាគុណ ដោយពាក្យក្រោយ ។ សម្តែងការដែលព្រះអង្គមានព្រះអធ្យាស្រ័យបង្អោន ទៅក្នុងការញុំាងប្រយោជន៍ និងសេចក្តីសុខ ឲ្យសម្រេចដល់សត្វទាំងឡាយ ដោយពាក្យដើម សម្តែងភាពជាបុគ្គលមិនសង្ឃឹមផលតបស្នង ក្នុងការធ្វើប្រយោជន៍ និងសេចក្តីសុខដល់អ្នកដទៃ ដោយពាក្យក្រោយ ។ សម្តែងការគង់នៅយ៉ាងសុខសាន្ត លះបង់សេចក្តីសុខដែលប្រពៃរបស់ធម៌ជាគ្រឿងចំណាំដោយពាក្យដើម សម្តែងការប្រថាប់នៅជាសុខសាន្ត មានការព្យាយាមប្រកបក្នុងឧត្តរិមនុស្សធម្ម ជាគ្រឿងសម្គាល់ដោយពាក្យក្រោយ ។ សម្តែងភាពជាអ្នកមានឧបការៈច្រើនដល់មនុស្សទាំងឡាយ ដោយពាក្យដើម សម្តែងភាពជាអ្នកមានឧបការៈច្រើន ដល់ទេវតាទាំងឡាយ ដោយពាក្យក្រោយ ។ សម្តែងភាពដែលព្រះអង្គកើតឡើងក្នុងលោក ហើយជាអ្នកចម្រើនព្រមក្នុងលោក ដោយពាក្យដើម សម្តែងភាពជាអ្នកមិនជាប់ក្នុងលោក ដោយពាក្យក្រោយ ។ ព្រះអានន្ទសម្តែងការញុំាងប្រយោជន៍ ដែលជាហេតុឲ្យព្រះមានព្រះភាគទ្រង់កើតឡើងនោះ ឲ្យសម្រេចដោយពាក្យដើម ព្រោះព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ បុគ្គលឯក គឺនរណា គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ។ សម្តែងការគង់នៅ ដែលសមគួរដល់ទីកន្លែងដែលព្រះដ៏មាន

ព្រះភាគទ្រង់កើតឡើង ដោយពាក្យក្រោយ ។

គប្បីជ្រាបការប្រកបអត្ថក្នុងបទថា **យទត្ថំ ភគវា ឧប្បន្នោ តទនុ្វ-បរិហារំ** នោះ មានន័យជាដើមថា ព្រះមានព្រះភាគ ទ្រង់កើតឡើង ដែលជាលោកិយ និងលោកុត្តរ គឺជំបូង ប្រសូតត្រង់លុម្ពិនីវន លើកទី ២ ត្រាស់ដឹងត្រង់មណ្ឌលពោធិព្រឹក្ស ព្រោះហេតុនោះ ទើបព្រះអានន្ទត្ថេរសម្តែងទីគង់នៅ សម្រាប់ព្រះមានព្រះភាគនោះ ក្នុងព្រៃទាំងអស់ ។

បទថា **តត្រ** ជាបទសម្តែងដល់ទីកន្លែង និងពេលវេលា ។ អធិប្បាយថា ព្រះមានព្រះភាគគង់នៅក្នុងសម័យណា ព្រះអានន្ទត្ថេរសម្តែងទីកន្លែង និងពេលវេលានោះថា ក្នុងសម័យនោះ និងគង់នៅក្នុងទីជិតដើមរាំងធំណា ក្នុងទីជិតដើមរាំងធំនោះ ។ ន័យម្យ៉ាងទៀត ទ្រង់សម្តែងក្នុងស្ថានទី និងពេលវេលាដែលគួរសម្តែង ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់មិនសម្តែងធម៌ក្នុងទីកន្លែង ឬពេលវេលា ដែលមិនសមគួរ ក្នុងសេចក្តីនេះ មានពាក្យជាដើមថា ម្នាលពាហិយៈ ឈប់សិន កាលនេះ ជាកាលមិនសមគួរ ដូច្នោះ ជាគ្រឿងសាធកៈ ។ សព្ទថា **ខោ** ជានិបាត ចុះក្នុងអត្ថ បទបូរណមត្ថ គឺគ្រឿងធ្វើបទឲ្យពេញប៉ុណ្ណោះខ្លះ ក្នុងអត្ថ អវធារណៈ គឺហាមសេចក្តីដទៃខ្លះ ក្នុងអត្ថ អាទិកាល គឺកាលជាខាងដើមខ្លះ ។ បទថា **ភគវា** ជាបទសម្តែងដល់ព្រះមានព្រះភាគ ទ្រង់ជាគ្រូរបស់សត្វលោក ។

បទថា **ភិក្ខុ** ជាបទពោលដល់បុគ្គលដែលគួរបានស្តាប់ទេសនា ។ ម្យ៉ាងទៀត ក្នុងបទថា **ភិក្ខុ** នេះ គប្បីជ្រាបអត្ថនៃពាក្យ ដោយន័យជាដើម

ថា ឈ្មោះថា **ភិក្ខុ** ព្រោះអត្ថថា ជាអ្នកសូម គឺឈ្មោះថា **ភិក្ខុ** ព្រោះអត្ថថា ចូលដល់ការត្រាច់ទៅដើម្បីភិក្ខា ។

បទថា **អាមន្តេសិ** ប្រែថា ហៅ គឺបានពោល ក្នុងទីនេះ មានអត្ថយ៉ាងនេះថា ដាស់តឿនឲ្យរឭក ចំណែកក្នុងទីដទៃ រមែងចុះក្នុងអត្ថថា **ញាបន** គឺឲ្យជ្រាបក៏មាន ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតដាស់តឿនអ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតប្រកាសឲ្យអ្នកទាំងឡាយដឹងដូច្នេះ ។ ក្នុងអត្ថថា ហៅ ក៏មាន សមដូចព្រះតម្រាស់ថា ម្នាលភិក្ខុ អ្នកចូរមក ចូរទៅហៅសារីបុត្រមកតាមពាក្យរបស់តថាគត ។

បទថា **ភិក្ខវោ** ជាបទសម្ដែងអាការហៅមក ។ ពិតហើយ ពាក្យនោះព្រះមានព្រះភាគត្រាស់ទុក ព្រោះសម្រេចមកអំពីការប្រកបគុណ គឺភាពជាអ្នកមានប្រក្រតីសូម ( របស់ភិក្ខុនោះ ) ។ ឯអ្នកសព្ទសាស្ត្រទាំងឡាយសម្គាល់ថា ភិក្ខុដែលប្រកបដោយគុណ គឺភាពជាអ្នកសូមជាប្រក្រតីខ្លះ ឈ្មោះថា ជាអ្នកប្រកបដោយគុណ មានភាពជាអ្នកសូមជាធម្មតាជាដើមខ្លះ ជាអ្នកប្រកបដោយគុណ គឺភាពជាអ្នកមានប្រក្រតី ធ្វើពាក្យអនុមោទនាថា សាធុក្នុងការសូមខ្លះ ។ ដោយពាក្យដែលសម្រេចមកអំពីការប្រកបដោយគុណ ដូចភាពជាបុគ្គលមានប្រក្រតីសូមជាដើម របស់ភិក្ខុទាំងនោះ ទុំះឈ្មោះថា ព្រះមានព្រះភាគប្រកាសចរិយាវត្ត ( របស់ភិក្ខុទាំងនោះ ) ដែលមនុស្សជាន់ខ្ពស់ និងមនុស្សជាន់ទាបសេពហើយ ( ជាការ ) ហាមប្រាមភាពជាបុគ្គល

វាយមាយ និងការរួញរា ( របស់ពួកលោក ) ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងនោះ ឲ្យបែរមុខមករកព្រះអង្គ ដោយព្រះតម្រាស់ដែលមានការទតមើលដោយព្រះហឫទ័យដ៏ត្រជាក់ស្រទន់ ប្រកបដោយក្រសែនៃករុណា ជាប្រធាន ទ្រង់ឲ្យភិក្ខុទាំងនោះមានបំណងនឹងស្ដាប់ ដោយព្រះតម្រាស់ដែលសម្ដែងភាពដែលព្រះអង្គបំណងនឹងត្រាស់ប្រៀនប្រដៅនោះឯង ហើយទ្រង់ប្រកបភិក្ខុទាំងនោះទុកក្នុងការតាំងចិត្តស្ដាប់ដោយល្អ ដោយព្រះតម្រាស់ដែលទ្រង់បំណងនឹងដាស់តឿនឲ្យរឭកនោះឯង ។ ព្រោះគុណសម្បត្តិនៃគោល គឺពាក្យប្រៀនប្រដៅ ទាក់ទងនឹងការតាំងចិត្តស្ដាប់ដោយល្អ ។ បើមានពាក្យសួរជ្រៀតចូលមកថា ព្រោះហេតុអ្វី កាលទេវតា និងមនុស្សដទៃមាន ទើបត្រាស់ហៅភិក្ខុទាំងឡាយនោះមក ឆ្លើយថា ព្រោះភិក្ខុទាំងឡាយ ជាបុគ្គលចម្រើនបំផុត ប្រសើរបំផុត នៅជិត និងនៅព្រមព្រៀងគ្នាសព្វវេលា អធិប្បាយថា ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ ទូទៅដល់បរិសទ្យគ្រប់ពួក ហើយភិក្ខុទាំងឡាយ ឈ្មោះថា ចម្រើនបំផុតក្នុងបរិសទ្យ ព្រោះជាអ្នកកើតឡើងមុនបរិសទ្យដទៃ ឈ្មោះថា ប្រសើរបំផុត ព្រោះបំណងយកបព្វជិតជាប្រធាន ប្រព្រឹត្តតាមព្រះសាស្ដា និងទទួលយកពាក្យប្រៀនប្រដៅទាំងអស់ ឈ្មោះថា នៅជិត ព្រោះកាលអង្គុយនៅក្នុងទីនោះ ឈ្មោះថា នៅក្នុងសម្នាក់របស់ព្រះសាស្ដា ឈ្មោះថា ព្រមព្រៀងគ្នាសព្វកាល ព្រោះត្រាច់ទៅជិតសម្នាក់ព្រះសាស្ដា ។

ម្យ៉ាងទៀត ភិក្ខុទាំងនោះ ឈ្មោះថា ជាភាជនៈនៃព្រះធម្មទេសនា ព្រោះ

ឲ្យកើតការបដិបត្តិ តាមដែលព្រះមានព្រះភាគទ្រង់ប្រៀនប្រដៅ និងព្រោះជាបុគ្គលពិសេស ។ ម្យ៉ាងទៀត ទេសនាដែលព្រះមានព្រះភាគ ទ្រង់សម្តែងចំពោះ សំដៅចំពោះភិក្ខុពួកខ្លះប៉ុណ្ណោះ ព្រោះដូច្នោះ ទើបព្រះអង្គទ្រង់ហៅភិក្ខុទាំងនោះមក ដោយអាការយ៉ាងនេះ ។ ក្នុងសេចក្តីនោះ គប្បីមានពាក្យសួរជ្រៀតចូលមកថា ដើម្បីប្រយោជន៍ដូចម្តេច ទើបព្រះមានព្រះភាគកាលទ្រង់សម្តែងធម៌ ទ្រង់ហៅភិក្ខុទាំងឡាយមកមុន ទ្រង់មិនសម្តែងធម៌តែម្តងទៅ ឆ្លើយថា ដើម្បីឲ្យកើតសតិ ព្រោះថា ភិក្ខុទាំងឡាយកំពុងអង្គុយគិតរឿងដទៃខ្លះ អង្គុយដោយចិត្តអណ្តែតអណ្តូងខ្លះ អង្គុយពិចារណាធម៌ខ្លះ អង្គុយមនសិការកម្មដ្ឋានខ្លះ កាលព្រះមានព្រះភាគ មិនត្រាស់ហៅភិក្ខុទាំងនោះ ( ជាមុន ) ហើយសម្តែងធម៌ ភិក្ខុទាំងនោះមិនអាចកំណត់បានថា ព្រះធម្មទេសនានេះ មានអ្វីជាហេតុ ជាបច្ច័យ ព្រះអង្គទ្រង់សម្តែងធម៌ ព្រោះឧបទ្ទវហេតុអ្វី គប្បីទទួលយកខុស ឬទទួលយកមិនបានសោះតែម្តង ហេតុនោះ ដើម្បីជាការដាស់នូវស្មារតីភិក្ខុទាំងនោះ ទើបព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយជាមុន ហើយសម្តែងធម៌ក្នុងកាលជាក្រោយ ។

បទថា **ភទន្តេ** នោះ ជាពាក្យសម្តែងការគោរព ឬជាការថ្វាយពាក្យតបដល់ព្រះសាស្តា ។ ម្យ៉ាងទៀត ក្នុងរឿងនេះ ព្រះមានព្រះភាគកាលត្រាស់ថា **ភិក្ខវោ** ឈ្មោះថា ត្រាស់ហៅភិក្ខុទាំងនោះមក ភិក្ខុទាំងនោះកាលទូលថា **ភទន្តេ** ឈ្មោះថា ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ប្រទានពាក្យហៅចំពោះថា **ភិក្ខវោ** ភិក្ខុទាំង-

ឡាយឆ្លើយតបថា **ភទន្តេ** ។ បទថា **តេ ភិក្ខូ** សំដៅយកពួកភិក្ខុដែលព្រះមានព្រះភាគត្រាស់ហៅមក ។

បទថា **ភគវតោ បច្ចស្សោសុំ** សេចក្ដីថា ( ភិក្ខុទាំងនោះ ) ទូលស្នងព្រះពុទ្ធដីកា អធិប្បាយថា បែរមុខមកស្ដាប់ គឺបង្អោនទទួល បានដល់ ទូលទទួល ។ បទថា **ភគវា ឯតទវោច** សេចក្ដីថា ព្រះមានព្រះភាគបានត្រាស់សូត្រទាំងអស់នោះ គឺដែលគប្បីត្រាស់ក្នុងឥឡូវនេះ ។

និទានវចនៈណា ដែលប្រដាប់ដោយកាលៈ ទេសៈ អ្នកសម្ដែងរឿងរ៉ាវបរិសទ្យ និងប្រទេស ដូចកំពង់ទឹកដែលមានភូមិភាគសស្អាត ដេរដាសដោយគ្រាប់ខ្សាច់ពណ៌ស ដេរដាសទៅដោយកែវមុក្ដា មានជណ្ដើរ ដែលរចនាដោយផ្ទាំងសិលា ដែលដុសខាត់ មិនមានមន្ទិល ដើម្បីងាយចំពោះការចុះកាន់ស្រះបោក្ខរណី ដែលចម្រុះទៅដោយផ្កាឈូកខៀវ មានទឹកស្អាត មានរសល្អ ដូចជណ្ដើរដែលមានកាំល្អិត ទន់ សម្រេចដោយភ្លុកដំរី ល្អរុងរឿងកើតអំពីរស្មីរបស់កម្រងកែវមណី ដោតដោយល្អសមាស ដើម្បីងាយស្រួលចំពោះការឈានឡើងកាន់មហាប្រាសាទដ៏ប្រសើរ មានជញ្ជាំង រចនាទុកបានសមសួន ការពារដោយវេទិកាដ៏វិចិត្រ មានអង្គ អាចកម្រើកបាន ហាក់ដូចជាមានបំណងនឹងឲ្យខ្ពស់ រហូតទើសទីគោចររបស់ផ្កាយ ដូចមហាទ្វារដែលមានសន្ទុះធំ បិទបាំងទុកល្អហើយ រុងរឿងដោយគំនរមាស មណី មុក្ដា និងកែវពពាលជាដើម ដើម្បីងាយស្រួលចំពោះការចូលទៅកាន់គេហាសនៈ ដែលរំលេចឥស្សរិយសម្បត្តិដ៏ឱឡារិក ជាទីត្រាច់ចរទៅដោយបុគ្គលដែលនិយាយ

សើចលេង ដោយសំឡេងដ៏ពីរោះ ផ្សារភ្ជាប់ជាមួយសំឡេងប៉ះខ្ទប់របស់កង ដៃមាស ដែលព្យួរទុកជារបៀប ដែលព្រះអានន្ទពោលទុកហើយ ការនិទានវចនៈនោះ ចប់បរិបូណ៌ហើយដោយប្រការដូច្នេះ ។

## ហេតុកើតព្រះសូត្រ ៤ យ៉ាង

ឥឡូវនេះ ដល់លំដាប់ឱកាសដែលនឹងពណ៌នាព្រះសូត្រ ដែលព្រះមានព្រះភាគទ្រង់លើកសម្តែងដោយន័យថា **សព្វធម្មមូលបរិយាយំ** ដូច្នេះ ។ ការពណ៌នាព្រះសូត្រនេះ កាលពិចារណាហេតុដែលទ្រង់លើកព្រះសូត្រឡើងសម្តែងហើយ ទើបពោល រមែងជាក់ច្បាស់ ដូច្នោះ ខ្ញុំនឹងពិចារណាហេតុដែលទ្រង់លើកព្រះសូត្រនេះសម្តែងមុន អធិប្បាយថា ហេតុដែលទ្រង់លើកព្រះសូត្រឡើងសម្តែង មាន ៤ ប្រការ គឺ **អត្តជ្ឈាសយ** ប្រព្រឹត្តទៅតាមអធ្យាស្រ័យរបស់ព្រះអង្គ ១ **បរជ្ឈាសយ** ប្រព្រឹត្តទៅតាមអធ្យាស្រ័យរបស់អ្នកដទៃ ១ **បុច្ឆាវសិក** ប្រព្រឹត្តទៅដោយអំណាចការសួរ ១ **អត្ថុប្បត្តិក** ប្រព្រឹត្តទៅដោយហេតុដែលកើតឡើង ១ ។

បណ្តាហេតុ ៤ ប្រការនោះ ព្រះសូត្រពួកណា ដែលបុគ្គលដទៃមិនបានទូលអារាធនា ព្រះមានព្រះភាគ ត្រាស់ទេសនាដោយព្រះអធ្យាស្រ័យរបស់ព្រះអង្គតែមួយព្រះអង្គឯង មានអាកង្ខេយ្យសូត្រ វត្ថសូត្រ មហាសតិប្បដ្ឋានសូត្រ មហាសឡាយតនវិភង្គសូត្រ អរិយវង្សសូត្រ ចំណែកនៃសម្មប្បធានសូត្រ ចំណែកនៃឥទ្ធិបាទសូត្រ ឥន្ទ្រិយ ពល ពោជ្ឈង្គ និងមគ្គជាដើម ព្រះសូត្រទាំងនោះ ឈ្មោះថា មានហេតុដែលទ្រង់លើកឡើងសម្តែង ប្រព្រឹត្ត

ទៅតាមអធ្យាស្រ័យរបស់ព្រះអង្គ ។

ម្យ៉ាងទៀត ព្រះសូត្រពួកណា ដែលព្រះមានព្រះភាគទ្រង់សម្លឹងមើល អធ្យាស្រ័យ ការគាប់ចិត្ត ការពេញចិត្ត អភិនីហារ និងការៈដែលត្រាស់ដឹង បានរបស់ជនដទៃ យ៉ាងនេះថា ធម៌បន្ទំវិមុត្តិរបស់រាហុលចាស់ក្លាហើយ បើ ដូច្នោះ តថាគតគប្បីដឹកនាំរាហុល ក្នុងអាសវក្ខយធម៌ឲ្យខ្ពស់ឡើង ដូច្នេះ ( ជាដើម ) ហើយទើបត្រាស់ដោយអំណាចអធ្យាស្រ័យរបស់អ្នកដទៃ ( នោះ ) ដូចជា ចូឡរាហុលោវាទសូត្រ មហារាហុលោវាទសូត្រ ធម្មចក្កប្បវត្តន-សូត្រ ធាតុវិភង្គសូត្រជាដើម ព្រះសូត្រទាំងនោះ ឈ្មោះថា មានហេតុ គឺទ្រង់លើកឡើងសម្តែង ប្រព្រឹត្តទៅតាមអធ្យាស្រ័យរបស់អ្នកដទៃ ។

ម្យ៉ាងទៀត ព្រះសូត្រពួកណា ដែលពួកសត្វទាំងឡាយ គឺបរិសទ្យ ៤ វណ្ណៈ ៤ នាគ ទ្រុឌ គន្ធព្វ អសុរ យក្ខ ទេវមហារាជ ទេវតាជាន់តាវត្តិង្ស មហាព្រហ្មជាដើម នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរបញ្ហា ដោយន័យជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា ពោជ្ឈង្គ ពោជ្ឈង្គ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា នីវរណៈ នីវរណៈ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ឧបាទានក្ខន្ធទាំង ៥ នេះ ដូចម្តេច ក្នុងលោក នេះ អ្វីជាទ្រព្យដ៏ប្រសើរបំផុតរបស់បុរស កាលត្រូវសួរយ៉ាងនេះហើយ ព្រះ មានព្រះភាគបានត្រាស់ទេសនា មានពោជ្ឈង្គសំយុត្តជាដើម ឬព្រះសូត្រដទៃ ពួកណា មានទេវតាសំយុត្ត មារសំយុត្ត ព្រហ្មសំយុត្ត សក្កប្បញ្ហសូត្រ ចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សាមញ្ញផលសូត្រ អាឡវកសូត្រ

សូចិលោមសូត្រ ខរលោមសូត្រជាដើម ព្រះសូត្រទាំងនេះ ឈ្មោះថា មានហេតុដែលទ្រង់លើកឡើងសម្ដែងប្រព្រឹត្តទៅដោយអំណាចការសួរ ។

ម្យ៉ាងទៀត ព្រះសូត្រទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់អាស្រ័យហេតុការណ៍កើតឡើង ត្រាស់ទេសនា ដូចជា ធម្មទាយាទសូត្រ ចូឡសីហនាទសូត្រ ចន្ទូបមសូត្រ បុត្តមំសូបមសូត្រ ទារុក្ខន្ធូបមសូត្រ អគ្គិក្ខន្ធូបមសូត្រ ផេណបិណ្ឌូបមសូត្រ បារិច្ឆត្តកូបមសូត្រ ព្រះសូត្រទាំងនេះ ឈ្មោះថា មានហេតុដែលទ្រង់លើកឡើងសម្ដែង ប្រព្រឹត្តទៅដោយហេតុដែលកើតឡើង ។ ក្នុងបណ្ដាហេតុដែលកើតឡើងសម្ដែង ៤ ប្រការ ដូចពណ៌នាមកនេះ មូលបរិយាយសូត្រនេះ មានហេតុដែលទ្រង់លើកឡើងសម្ដែងប្រព្រឹត្តទៅដោយហេតុដែលកើតឡើង ( អត្ថុប្បត្តិហេតុ ) ។ ព្រោះថា មូលបរិយាយសូត្រនេះ ព្រះមានព្រះភាគទ្រង់លើកឡើងសម្ដែង ព្រោះហេតុដែលកើតឡើង ព្រោះហេតុដែលកើតឡើងដូចម្ដេច ព្រោះមានះដែលកើតឡើងអាស្រ័យបរិយត្តិ ។

បានឮមកថា ព្រាហ្មណ៍ ៥០០ នាក់ រៀនចប់ត្រៃវេទ ក្រោយមក បានស្ដាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ កាលឃើញទោសក្នុងកាមទាំងឡាយ ឃើញអានិសង្សក្នុងការចេញបួស ទើបចេញបួសក្នុងសម្នាក់ព្រះមានព្រះភាគ មិនយូរប៉ុន្មាន ក៏រៀនយកព្រះពុទ្ធវចនៈទាំងអស់ ព្រោះអាស្រ័យការសិក្សារៀនសូត្រ ទើបកើតមានះឡើងថា ពួកយើងចេះព្រះពុទ្ធវចនៈ ដែលព្រះមានព្រះភាគត្រាស់យ៉ាងឆាប់រហ័ស ព្រោះថា ព្រះមានព្រះភាគ មិនត្រាស់

រឿងណាមួយក្រៅអំពីលិង្គ ៣ បទ ៤ និងវិភត្តិ ៧ កាលព្រះអង្គត្រាស់យ៉ាងនេះ ឈ្មោះថា បទដែលជាកំណួច ( ដែលមិនយល់ ) សម្រាប់ពួកយើងមិនមាន ដូច្នេះ ។ ភិក្ខុទាំងនោះ មិនមានការគោរពក្នុងព្រះមានព្រះភាគ ចាប់តាំងអំពីពេលនោះ ក៏មិនទៅឧបដ្ឋាកព្រះមានព្រះភាគខ្លះ មិនទៅស្តាប់ជាប្រចាំខ្លះ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបវារចិត្តរបស់ភិក្ខុទាំងនោះ ទ្រង់ព្រះតម្រិះថា ភិក្ខុទាំងនេះមិនទាន់ដកសសរខឿន គឺមានះ ក៏មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវមគ្គ ឬផល ទ្រង់ធ្វើមានះដែលកើតឡើង ព្រោះអាស្រ័យការរៀនសុត្តៈនៃភិក្ខុទាំងនោះ ឲ្យជាអត្ថុប្បត្តិហេតុ ទើបផ្តើមការសម្តែងធម៌ថា ព្រះមានព្រះភាគ ជាបុគ្គលឈ្លាសក្នុងការសម្តែងមូលបរិយាយសូត្រនៃធម៌ទាំងពួង ដើម្បីបំបាក់បង់នូវមានះ ( របស់ភិក្ខុទាំងនោះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សព្វធម្មមូលបរិយាយំ** ប្រែថា ព្រះសូត្រពោលដោយហេតុដែលជាមូលដ្ឋាននៃធម៌ទាំងពួង ។ បទថា **សព្វេសំ** ប្រែថា មិនមានចំណែកសេសសល់ ។ ពិតហើយ សព្ទថា **សព្វ** នេះ ចង្អុលដល់ការមិនមានចំណែកសល់ ។ សព្ទថា **សព្វ** នោះ រមែងសម្តែងដល់វត្ថុដែលទាក់ទងគ្នាមិនមានសេសសល់ ដូចក្នុងប្រយោគជាដើមថា រូបទាំងពួងមិនទៀង វេទនាទាំងពួងមិនទៀង ក្នុងបណ្តាធម៌ដែលទាក់ទងក្នុងកាយរបស់ខ្លួនទាំងអស់ ដូច្នេះ ។

ចំណែកសព្ទថា **ធម្ម** នេះ រមែងប្រាកដក្នុងសព្ទជាដើមថា បរិយត្តិ សច្ចៈ សមាធិ បញ្ញា ធម្មតា សភាវៈ សុញ្ញតា បុញ្ញ អាបត្តិ និងញេយ្យ ។

ពិតហើយ សព្ទថា **ធម្ម** រមែងប្រាកដក្នុងអត្ថថា **បរិយត្តិ** ដូចក្នុងប្រយោគជាដើមថា **ឥធ ភិក្ខុ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ** ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌ គឺសុត្តៈ គេយ្យៈ ដូច្នេះ ... ។

ប្រាកដក្នុងអត្ថថា **សច្ច** ដូចក្នុងប្រយោគជាដើមថា **ទិដ្ឋធម្មោ បត្តធម្មោ វិទិតធម្មោ** ឃើញអរិយសច្ចធម៌ច្បាស់ហើយ បានដល់អរិយសច្ចធម៌ហើយ បានដឹងច្បាស់អរិយសច្ចធម៌ហើយ ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **សមាធិ** ដូចក្នុងប្រយោគជាដើមថា **ឯវំធម្មា តេ ភគវន្តោ** ព្រះមានព្រះភាគទាំងឡាយ មានធម៌យ៉ាងនេះ ។

ប្រាកដក្នុងអត្ថថា **បញ្ញា** ដូចក្នុងប្រយោគជាដើមថា **យស្សេតេ ចតុរោ ធម្មា វានរិន្ទ យថា តវ សច្ចំ ធម្មោ ។បេ។** បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៤ ដូចអ្នក គឺសេចក្ដីទៀងទាត់ ១ ធម៌គឺប្រាជ្ញាជាគ្រឿងពិចារណា ១ ព្យាយាមមិនដាច់ ១ ការលះ ១ បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **ធម្មតា** ដូចក្នុងប្រយោគជាដើមថា **ជាតិធម្មា ជរាធម្មា** មានការកើតឡើងជាធម្មតា មានការចាស់ជាធម្មតា ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **សភាវ** ដូចក្នុងប្រយោគជាដើមថា **កុសលាធម្មា** ធម៌ជាកុសល ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **សុញ្ញតា** ដូចក្នុងប្រយោគជាដើមថា **តស្មឹ ខោ បន សមយេ ធម្មា ហោន្តិ** ពួកធម៌ កើតមានក្នុងសម័យនោះ ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **បុញ្ញ** គឺបុណ្យ ដូចក្នុងប្រយោគជាដើមថា **ធម្មោ-សុចិណ្ណោ សុខមាវហាតិ** ធម៌ ( បុណ្យ ) ដែលបុគ្គលសន្សំល្អ ហើយ រមែងនាំមកនូវសេចក្ដីសុខ ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **អាបត្តិ** ដូចក្នុងប្រយោគជាដើមថា **ទ្វេ អនិយតា ធម្មា** ធម៌ ( អាបត្តិ ) ទាំងឡាយជាអនិយតមាន ២ ប្រការ ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **ញេយ្យ** ដូចក្នុងប្រយោគជាដើមថា **សព្វេ ធម្មា សព្វាការេន ពុទ្ធស្ស ភគវតោ ញាណមុខេ អាបាថ មាគច្ឆន្តិ** ធម៌ ( ការត្រាស់ដឹង ) ទាំងពួង មកកាន់គន្លងក្នុងព្រះញាណរបស់ព្រះមានព្រះភាគ ដោយអាការទាំងពួង ដូច្នេះ ។

តែក្នុងទីនេះ **ធម្ម** សព្ទនេះ រមែងប្រព្រឹត្តទៅក្នុងអត្ថថា សភាវៈ ។ ក្នុងពាក្យថា **ធម្ម** នោះ មានអត្ថវចនៈដូច្នេះថា សភាវៈពួកណា រមែងទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ហេតុនោះ សភាវៈទាំងនោះ ឈ្មោះថា **ធម្ម** ។

**មូល** សព្ទ លោកពោលទុកពិស្ដារហើយ ។ តែក្នុងទីនេះ **មូល** សព្ទ គប្បីជ្រាបថា ចុះក្នុងអត្ថថា ហេតុដែលមិនទូទៅ ។

**បរិយាយ** សព្ទ មានអត្ថ ៣ យ៉ាង គឺទេសនា ១ ការណៈ គឺហេតុ ១ វារៈ ១ ។

**បរិយាយ** សព្ទ ចុះក្នុងអត្ថថា **ទេសនា** ដូចក្នុងប្រយោគជាដើមថា **មធុបិណ្ឌិកបរិយាយាត្វេវ នំ ធារេហិ** ចូរអ្នកចាំទុកនូវសេចក្ដីនោះថា ធម្មបរិយាយនេះ ឈ្មោះថា មធុបិណ្ឌិកបរិយាយដូច្នេះចុះ ដូច្នេះ ។

**បរិយាយ** សព្ទ ចុះក្នុងអត្ថថា **ការណ** គឺហេតុ ដូចក្នុងប្រយោគជាដើមថា **អត្ថិខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អកិរិយវាទោ សមណោ គោតមោ** ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើ ដែលគេថានោះត្រូវហើយ ដូច្នេះ ។

ចុះក្នុងអត្ថថា **វារ** ដូចក្នុងប្រយោគជាដើមថា **កស្ស នុ ខោ អានន្ទ អជ្ជ បរិយាយោ ភិក្ខុនិយោ ឱវទិតុំ** ម្នាលអានន្ទ ថ្ងៃនេះជាវេន ( វារៈ ) ភិក្ខុណាហ្ន៎ ដែលត្រូវឲ្យឱវាទពួកភិក្ខុនី ដូច្នេះ ។

តែក្នុងទីនេះ ( បរិយាយសព្ទនោះ ) រមែងចុះក្នុងអត្ថថា ការណៈខ្លះ ទេសនាខ្លះ ។ ព្រោះដូច្នោះ **បរិយាយ** សព្ទ ក្នុងពាក្យនេះថា **សព្វធម្ម-មូលបរិយាយំ** ដូច្នេះ គប្បីជ្រាបយ៉ាងនេះថា ការណៈ ដែលតែងស្គាល់ថាហេតុ ដែលមិនទូទៅដល់ធម៌ទាំងពួង ឬទេសនា គឺការណៈ ( ហេតុ ) នៃធម៌ទាំងពួង ដូច្នេះ ។

ម្យ៉ាងទៀត សភាវធម៌ទាំងឡាយដែលកើតក្នុងភូមិ ៤ មិនគប្បីយល់ថា ឈ្មោះថា ធម៌ទាំងពួង ព្រោះហេតុដែលព្រះសូត្រនោះ មានអត្ថ ដែលត្រូវណែនាំ តែសភាវធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ប៉ុណ្ណោះ ដែលទាក់ទងក្នុងសក្កាយទិដ្ឋិ គប្បីយល់ថា ធម៌ទាំងពួង ដោយមិនមានចំណែកសេសសល់ ក្នុងពាក្យនេះ មានអធិប្បាយដូចពោលមកនេះឯង ។

**វោ** សព្ទ ក្នុងបទថា **វោ** នេះ រមែងប្រើក្នុងបឋមាវិភត្តិ ទុតិយាវិភត្តិ

តតិយាវិភត្តិ ចតុត្ថីវិភត្តិ ឆដ្ឋីវិភត្តិ និងបទបូរណៈ គឺធ្វើបទឲ្យពេញ ។ អធិប្បាយថា **វា** សព្ទ ប្រើក្នុងបឋមាវិភត្តិ ដូចក្នុងប្រយោគជាដើមថា **កច្ចិ បន វោ អនុរុទ្ធា សមគ្គា សម្មោទមានា** ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយព្រមព្រៀង ស្រុះស្រួល មិនទាស់ទែងគ្នា ដូច្នេះ ។

ប្រើក្នុងទុតិយាវិភត្តិ ដូចក្នុងប្រយោគជាដើមថា **គច្ឆថ ភិក្ខវេ បណាមេមិ វោ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទៅ តថាគតបណ្តេញអ្នកទាំងឡាយ ដូច្នេះ ។

ប្រើក្នុងតតិយាវិភត្តិ ដូចក្នុងប្រយោគជាដើមថា **ន វោ មម សន្តិកេ វត្ថព្វំ** អ្នកទាំងឡាយមិនគួរនៅក្នុងសម្នាក់តថាគតទេ ដូច្នេះ ។

ប្រើក្នុងចតុត្ថីវិភត្តិ ដូចក្នុងប្រយោគជាដើមថា **វនបត្ថបរិយាយំ វោ ភិក្ខវេ ទេសិស្សាមិ** ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវហេតុនៃការនៅក្នុងព្រៃដល់អ្នកទាំងឡាយ ដូច្នេះ ។

ប្រើក្នុងឆដ្ឋីវិភត្តិ ដូចក្នុងប្រយោគជាដើមថា **សព្វេសំ វោ សារីបុត្ត សុភាសិតំ** ម្នាលសារីបុត្ត បើដោយបរិយាយ អ្នកទាំងអស់គ្នាសុទ្ធតែនិយាយត្រូវហើយ ដូច្នេះ ។

ប្រើក្នុងអត្ថថា គ្រាន់តែធ្វើបទឲ្យពេញ ដូចក្នុងប្រយោគជាដើមថា **យេ ហិ វោ អរិយា បរិសុទ្ធកាយកម្មន្តា** ព្រះអរិយៈទាំងឡាយណា ដែលមានកាយកម្មបរិសុទ្ធ ដូច្នេះ ។ តែក្នុងទីនេះ **វោ** សព្ទនេះ គប្បីជ្រាបការប្រើក្នុងចតុត្ថីវិភត្តិ ។

បទថា **ភិក្ខវេ** ជាការត្រាស់ហៅភិក្ខុដែលនៅចំពោះព្រះភក្ត្រដដែលទៀត ដោយការឲ្យទទួលស្តាប់ ។ បទថា **ទេសិស្សាមិ** ជាការជាស់តឿនឲ្យដឹងថា នឹងសម្តែងធម៌ ។ អធិប្បាយទុកដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងមូលហេតុនៃធម៌ទាំងពួងដល់អ្នកទាំងឡាយ តថាគតនឹងសម្តែងទេសនាដែលជាតួហេតុដោយន័យទី ២ ដល់ពួកអ្នក ដូច្នេះ ។ ពីរបទថា **តំ សុណាថ** សេចក្តីថា អ្នកទាំងឡាយចូរស្តាប់អត្ថនោះ គឺហេតុនោះ បានដល់ទេសនានោះ ដែលតថាគតនឹងពោល ។ ពីរបទថា **សាធុកំ សាធុ** ក្នុងបទថា **សាធុកំ មនសិករោថ** ដូច្នេះ ក៏មានអត្ថដូចគ្នា ។

ម្យ៉ាងទៀត **សាធុ** សព្ទនេះ ប្រើក្នុងបទទាំងឡាយថា អាយាចន គឺអង្វរ សម្បដិច្ឆន្ន គឺទទួល សម្បហំសន គឺការត្រេកអរ សុន្ទរ គឺល្អ និងទឡ្ហីកម្ម គឺធ្វើឲ្យមាំ អធិប្បាយថា **សាធុ** សព្ទ ប្រើក្នុងអត្ថថា អង្វរ ដូចក្នុងប្រយោគជាដើមថា **សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះមានព្រះភាគសម្តែងធម៌ដោយសង្ខេប ប្រោសខ្ញុំព្រះអង្គ ដូច្នេះ ។

ប្រើក្នុងអត្ថថា ទទួល ដូចក្នុងប្រយោគជាដើមថា **សាធុ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា** ភិក្ខុនោះត្រេកអររីករាយនឹងសុភាសិតរបស់ព្រះមានព្រះភាគថា ពីរោះហើយព្រះអង្គដូច្នេះ ។

ប្រើក្នុងអត្ថថា ត្រេកអរ ដូចក្នុងប្រយោគជាដើមថា **សាធុ សាធុ សារីបុត្តា** ប្រពៃណាស់ ប្រពៃណាស់ សារីបុត្រ ដូច្នេះ ។

ប្រើក្នុងអត្ថថា ល្អ ដូចក្នុងប្រយោគជាដើមថា **សាធុ ធម្មរុចី រាជា សាធុ បញ្ញាណវា នរោ សាធុ មិត្តានមទ្ទុព្ភោ បាបស្សាករណំ សុខំ** ព្រះរាជាជាអ្នកគាប់ចិត្តដោយធម៌ទើបល្អ ជនមានប្រាជ្ញាទើបល្អ ការមិនប្រទូស្តមិត្តទើបល្អ កិរិយាមិនធ្វើបាបទើបសុខ ដូច្នេះ ។

**សាធុ** សព្ទក៏ដូចគ្នា ប្រើក្នុងអត្ថថា ធ្វើឲ្យមាំ លោកពោលទុកថា ប្រើក្នុងអត្ថថា បង្គាប់ក៏មាន ដូចក្នុងប្រយោគជាដើមថា **តេនហិ ព្រាហ្មណ សាធុកំ សុណាហិ** ម្នាលព្រាហ្មណ៍ បើដូច្នោះ ចូរអ្នកស្តាប់ឲ្យល្អ ដូច្នេះ ។

សូម្បីក្នុងព្រះសូត្រនេះ ក៏គប្បីយល់អត្ថដូចគ្នានេះ ប្រើក្នុងការធ្វើឲ្យមាំផង ក្នុងការបង្គាប់នេះឯងផង ទោះប្រើក្នុងអត្ថថា ល្អ ក៏គួរ ។

ពិតហើយ ដោយ **ធុក** សព្ទ មានអត្ថថា ធ្វើឲ្យមាំ ព្រះមានព្រះភាគទ្រង់សម្តែងពាក្យនេះថា អ្នកទាំងឡាយ ចូររៀនឲ្យល្អ ចូរស្តាប់ធម៌នេះឲ្យមាំ ។ ដោយអត្ថថា បង្គាប់ ទ្រង់សម្តែងពាក្យនេះថា អ្នកទាំងឡាយ ចូរស្តាប់តាមអាណត្តិរបស់តថាគត ។ មានអត្ថថា ល្អ ទ្រង់សម្តែងពាក្យនេះថា អ្នកទាំងឡាយ ចូរស្តាប់ធម៌នេះឲ្យល្អ ឲ្យប្រពៃ ។

បទថា **មនសិករោថ** សេចក្តីថា បង្អោនចិត្ត គឺដាក់ចិត្ត អធិប្បាយថា មានចិត្តមិនរាយមាយ ពិចារណា គឺធ្វើទុកក្នុងចិត្តដូច្នេះ ។

ឥឡូវនេះ បទថា **តំ សុណាថ** នេះ ក្នុងអធិការនេះ ជាការហាមនូវការរាយមាយនៃសោតិន្ទ្រិយ បទថា **សាធុកំ មនសិករោថ** ជាការហាមនូវការរាយមាយនៃមនិន្ទ្រិយ ដោយការប្រកបធ្វើឲ្យមាំក្នុងចិត្ត ។

ម្យ៉ាងទៀត ក្នុង ២ ពាក្យនេះ ពាក្យដំបូងហាមការប្រកាន់ខុសដោយព្យញ្ជនៈ ពាក្យក្រោយ ហាមការប្រកាន់ខុសដោយអត្ថ ។ ដូចក្នុងប្រយោគជាដើមថា លោកប្រកបការស្តាប់ធម៌ដោយពាក្យដំបូង ប្រកបការចងចាំ និងការពិចារណាធម៌ ដែលបានស្តាប់ហើយដោយពាក្យក្រោយ ។ ម្យ៉ាងទៀត លោកសម្តែងថា ព្រះធម៌នេះ ដល់ព្រមដោយព្យញ្ជនៈដោយពាក្យដំបូង ព្រោះដូច្នោះ ទើបជាវត្ថុគួរស្តាប់ ហើយលោកសម្តែងថា ព្រះធម៌នេះ ដល់ព្រមដោយអត្ថ ដោយពាក្យក្រោយ ព្រោះដូច្នោះ ទើបជាវត្ថុដែលគួរដាក់ចិត្ត ។

ម្យ៉ាងទៀត ព្រោះយកបទថា **សាធុកំ** ប្រកបចូលជាមួយគ្នាទាំង ២ បទ បណ្ឌិតគប្បីជ្រាបការប្រកបយ៉ាងនេះថា ព្រោះហេតុដែលព្រះធម៌នេះ ជាធម៌ដែលជ្រាលជ្រៅ និងជាទេសនាដែលជ្រាលជ្រៅ ដូច្នោះ អ្នកទាំងឡាយ ចូរស្តាប់ឲ្យល្អ ។ ព្រោះព្រះធម៌នេះ មានអត្ថជ្រាលជ្រៅ និងមានបដិវេធក៏ជ្រាលជ្រៅ ដូច្នោះ អ្នកទាំងឡាយចូរដាក់ចិត្តទុកឲ្យល្អ ដូច្នេះ ។

បទថា **ភាសិស្សាមិ** ប្រែថា តថាគតនឹងសម្តែង គឺនឹងសម្តែងទេសនាដែលប្រកាសទុកក្នុងពាក្យនេះថា អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះ ដោយមិនសង្ខេបនោះឯង ។ មួយប្រការទៀត មានអធិប្បាយទុកថា តថាគតនឹងពោលរឿងនោះដោយពិស្តារ ដូច្នេះ ។ ពិតហើយ បទទាំងនេះ ប្រារព្ធអត្ថដោយសង្ខេបផង ពិស្តារផង ។ សមដូចព្រះវង្គីសត្ថេរពោលទុកថា តែងសម្តែងធម៌ដល់ភិក្ខុទាំងឡាយ សម្តែងដោយសង្ខេបខ្លះ សម្តែងដោយពិស្តារខ្លះ មិនមានសំឡេងគឹកកងដូចជាសត្វសាលិកា បញ្ចេញនូវប្រាជ្ញាដ៏វិសេស

ដូច្នេះ ។ កាលត្រាស់យ៉ាងនេះហើយ ភិក្ខុទាំងនោះឯងកើតឧស្សាហ៍ ស្តាប់ព្រះពុទ្ធតម្រាស់ អធិប្បាយថា ទទួលយក គឺកាន់យកព្រះតម្រាស់របស់ព្រះសាស្តាថា ព្រះករុណាព្រះអង្គ ។

[ ២ ] លំដាប់នោះ ព្រះមានព្រះភាគបានត្រាស់ពាក្យនេះ គឺបានត្រាស់ព្រះសូត្រទាំងអស់នោះ គឺដែលនឹងត្រូវពោលតទៅនេះ មានបទថា **ឥធ ភិក្ខវេ** ដូច្នេះជាដើម ។ បទថា **ឥធ** ក្នុងពាក្យថា **ឥធ ភិក្ខវេ** នេះ ជានិបាតប្រើក្នុងការអះអាងដល់ស្ថានទី ក្នុងទីខ្លះព្រះអង្គត្រាស់សំដៅយក លោក សមដូចព្រះធម្មសង្គាហកាចារ្យពោលថា **ឥធ តថាគតោ លោកេ ឧប្បជ្ជតិ** ព្រះតថាគតទ្រង់រមែងកើតឡើងក្នុងលោកនេះ ដូច្នេះ ។ ក្នុងទីខ្លះ លោកពោលសំដៅយកសាសនា ។ សមដូចព្រះមានព្រះភាគត្រាស់ថា **ឥធេវ ភិក្ខវេ សមណោ ឥធ ទុតិយោ សមណោ** ម្នាលភិក្ខុទាំងឡាយ សមណៈ ( ទី ១ ) មានតែក្នុងសាសនានេះ សមណៈទី ២ ក៏មានតែក្នុងសាសនានេះ ដូច្នេះ ។ ក្នុងទីខ្លះ លោកពោលសំដៅយក ឱកាស ដូចលោកពោលទុកថា **ឥធេវ តិដ្ឋមានស្ស ។បេ។** ហៃសម្លាញ់រួមទុក្ខ កាលខ្ញុំកើតជាទេវតា តាំងនៅក្នុងឱកាសនេះឯង ហើយខ្ញុំបានអាយុបន្ថែមទៀត សូមអ្នកជ្រាប ដូច្នេះ ។

ក្នុងទីខ្លះ លោកពោលសំដៅយកត្រឹមតែធ្វើបទឲ្យពេញប៉ុណ្ណោះ ។ សមដូចព្រះមានព្រះភាគត្រាស់ថា **ឥធាហំ ភិក្ខវេ ភុត្តាវី អស្សំ បវារិតោ** ម្នាលភិក្ខុទាំងឡាយ តថាគតបរិភោគស្រេចហើយ ហាមភត្តហើយ ដូច្នេះ ។ តែក្នុងទីនេះ គប្បីជ្រាបថា លោកសំដៅយក លោក ដូច្នេះ ។

បទថា **ឥធ ភិក្ខវេ** សេចក្តីថា ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយមកទៀត ដើម្បីទ្រង់សម្តែងទេសនាតាមដែលទ្រង់បានប្តេជ្ញា ។ ដោយបទទាំង ២ លោកពោលអធិប្បាយទុកថា ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ដូច្នេះ ។

ក្នុងបទថា **អស្សុតវា បុថុជ្ជនោ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បុថុជ្ជនឈ្មោះថា **ញេយ្យ** ព្រោះមិនមានអាគម ឈ្មោះថា **អស្សុតវា** ព្រោះមិនមានអធិគម អធិប្បាយថា បុថុជ្ជនណា ឈ្មោះថា មិនមានអាគម ដែលកម្ចាត់ការមិនដឹង ព្រោះមិនដឹងហេតុដែលវៀរចាកការរៀន ការសាកសួរ និងការវិនិច្ឆ័យក្នុងខន្ធ ធាតុ អាយតនៈ សច្ចៈ បច្ចយាការ និងសតិប្បដ្ឋានជាដើម ឈ្មោះថា មិនមានអធិគម ព្រោះមិនបានសម្រេចធម៌ ដែលគប្បីសម្រេចដោយការបដិបត្តិ ទើបបុថុជ្ជននោះ ឈ្មោះថា **ញេយ្យ** ព្រោះមិនមានអាគម ឈ្មោះថា **អស្សុតវា** ព្រោះមិនមានអធិគម ។

ជននេះ ឈ្មោះថា បុថុជ្ជន ព្រោះហេតុទាំងឡាយ មានការញុំាងកិលេសក្រាស់ឲ្យកើតជាដើម ម្យ៉ាងទៀត ជននេះ ឈ្មោះថា ក្រាស់ ( បុថុ ) ព្រោះឈមចុះខាងក្នុងកិលេសដែលក្រាស់ ។

ពិតហើយ ជននោះ ឈ្មោះថា បុថុជ្ជន ព្រោះហេតុទាំងឡាយ មានញុំាងកិលេសជាដើម ដែលក្រាស់មានប្រការផ្សេងៗ ឲ្យកើត ។ សមដូចព្រះធម្មសង្គាហកាចារ្យពោលទុកថា ជនទាំងឡាយ ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា ញុំាងកិលេសក្រាស់ឲ្យកើត ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា ត្រូវសក្កាយទិដ្ឋិ

បៀតបៀនច្រើន ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា ត្រូវទទឹងមើលសាស្ដាឿយៗ ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា មិនទាន់រួចផុតអំពីគតិទាំងពួងដែលក្រាស់ ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា តាក់តែងគ្រឿងតាក់តែងផ្សេងៗ ដ៏ច្រើន ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា ត្រូវឱឃៈផ្សេងៗ ដ៏ច្រើនបន្សាត់នាំទៅ ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា ដុតពោលដោយការដុតពោលផ្សេងៗ ដ៏ច្រើន ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា ក្ដៅក្រហាយដោយការក្ដៅក្រហាយផ្សេងៗ ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា ត្រេកត្រអាល ជាប់ចិត្ត ងប់ជ្រប់ លិចចុះ ជាប់ស្អិត ជាប់ជំពាក់ ពាក់ព័ន្ធក្នុងកាមគុណ ៥ ដ៏ច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា ត្រូវនីវរណៈ ៥ រួបរឹតទុក ហ៊ុមព័ទ្ធ បិទបាំង គ្របសង្កត់ទុកដ៏ច្រើន ម្យ៉ាងទៀត ឈ្មោះថា បុថុជ្ជន ព្រោះនៅក្នុងពពួកជនដែលមានធម្មចរិយាថោកទាប ជាអ្នកបែរមុខចេញពីអរិយធម៌ បែរខ្នងដាក់អរិយធម៌ដោយច្រើន គឺរាប់មិនអស់ ម្យ៉ាងទៀត ឈ្មោះថា បុថុជ្ជន ព្រោះអត្ថថា ជននេះដល់នូវការរាប់ថា បែកចេញដោយឡែក គឺមិនជាប់ទាក់ទងនឹងព្រះអរិយៈដែលប្រកបដោយគុណ មានសីល និងសុតៈជាដើម ។ ពីរបទថា **អស្សុតវា បុថុជ្ជនោ** មានន័យដូចពោលមកនេះ ។

ក្នុងបណ្ដាបុថុជ្ជន ២ ពួក ដែលព្រះពុទ្ធជាផៅពង្សនៃព្រះអាទិត្យបានត្រាស់ទុក គឺអន្ធបុថុជ្ជន ១ ពួក កល្យាណបុថុជ្ជន ១ ពួក គប្បីជ្រាបថាលោកពោលសំដៅដល់អន្ធបុថុជ្ជន ។

បទថា **អរិយ** ក្នុងបទជាដើមថា **អរិយានំ អទស្សាវី** លោកពោលសំដៅ

យកព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវកពុទ្ធ ព្រោះជាអ្នកឆ្ងាយចាកកិលេស មិនឈានទៅក្នុងផ្លូវវិនាស ឈានទៅក្នុងផ្លូវចម្រើន ដែលសត្វលោក ព្រមទាំងទេវលោកគប្បីធ្វើដំណើរតាម ។

ម្យ៉ាងទៀត ព្រះអរិយៈក្នុងទីនេះ គឺព្រះសម្ពុទ្ធនោះឯង សមដូចព្រះសម្ពុទ្ធត្រាស់ថា **សទេវកេ លោកេ សមារកេ ។បេ។** ព្រះតថាគត ជាអរិយបុគ្គលក្នុងលោក ព្រមទាំងទេវលោក ។បេ។

ម្យ៉ាងទៀត ព្រះបច្ចេកពុទ្ធ និងសាវករបស់តថាគត គប្បីជ្រាបថា សប្បុរស ក្នុងពាក្យថា **សប្បុរិសា** នេះ ។ ពិតហើយ ព្រះបច្ចេកពុទ្ធជាដើមនោះ ឈ្មោះថា សោភណបុរស ព្រោះប្រកបដោយគុណដែលជាលោកុត្តរ ព្រោះហេតុនោះ ទើបឈ្មោះថា សប្បុរស ។ ម្យ៉ាងទៀត សប្បុរសទាំងអស់នោះ លោកពោលចែកជា ២ ពួក ។ ពិតហើយ ព្រះពុទ្ធទាំងឡាយក្តី ព្រះបច្ចេកពុទ្ធ និងពុទ្ធសាវកក្តី ជាអរិយៈផង ជាសប្បុរសផង សមដូចពាក្យដែលលោកពោលថា

បុគ្គលណា ជាកតញ្ញូកតវេទី មានប្រាជ្ញា មានមិត្តល្អ មានការសេពគប់មាំ ធ្វើនូវកិច្ចដោយគោរព ចំពោះបុគ្គលអ្នកដល់នូវសេចក្តីទុក្ខ បណ្ឌិតទាំងឡាយ ពោលនូវបុគ្គលបែបនោះថា ជាសប្បុរស ដូច្នេះ ។

ពិតហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះថា **កល្យាណមិត្តោ ទឡ្ហ-ភត្តិ ច ហោតិ** ដូច្នេះ លោកពោលយកពុទ្ធសាវក ដោយពាក្យថា កតញ្ញុតាជាដើម លោកពោលសំដៅយកព្រះបច្ចេកពុទ្ធ និងព្រះពុទ្ធ ដូច្នេះឯង ។

ឥឡូវនេះ បុគ្គលណា មានប្រក្រតីមិនឃើញព្រះអរិយៈទាំងនោះ និង មិនត្រេកអរក្នុងការឃើញ បុគ្គលនោះ គប្បីជ្រាបថា មានប្រក្រតីមិនឃើញ ព្រះអរិយៈទាំងឡាយ ដូច្នេះ ។ ការឃើញនោះចែកចេញជា ២ គឺមិនឃើញ ដោយភ្នែក ១ មិនឃើញដោយញាណ ១ ។ ក្នុង ២ យ៉ាងនោះ ការមិន ឃើញដោយញាណ លោកបំណងយកក្នុងទីនេះ ។

ពិតហើយ ព្រះអរិយៈទាំងឡាយ សូម្បីបុគ្គលឃើញដោយមំសចក្ខុ ឬ ទិព្វចក្ខុ ក៏មិនឈ្មោះថា បានឃើញ ព្រោះចក្ខុទាំងនោះ ទទួលយកត្រឹមតែ ឧបាទាយរូប មិនមែនទាញយកភាពជាព្រះអរិយៈជាអារម្មណ៍ឡើយ ម្យ៉ាង ទៀត ទោះឆ្កែស្រុក ចចកជាដើម រមែងឃើញព្រះអរិយៈទាំងឡាយដោយ ចក្ខុ តែឆ្កែស្រុកជាដើមនោះ មិនឈ្មោះថា បានឃើញព្រះអរិយៈឡើយ ។ ក្នុងសេចក្ដីនេះ មានរឿងជាឧទាហរណ៍ ។

បានឮមកថា ឧបដ្ឋាករបស់ព្រះថេរៈដែលជាខីណាសវៈ នៅក្នុងចិត្ត-លតាបពិត បួសឯចាស់ ថ្ងៃមួយ ត្រាច់ទៅបិណ្ឌបាតជាមួយព្រះថេរៈ ទទួល យកបាត្រ និងចីវររបស់ព្រះថេរៈ ដើរតាមក្រោយមក សួរព្រះថេរៈថា បពិត្រ លោកម្ចាស់ បុគ្គលដូចម្ដេច ឈ្មោះថា ព្រះអរិយៈ ព្រះថេរៈឆ្លើយថា បុគ្គល ខ្លះ ក្នុងលោកនេះ ជាមនុស្សចាស់ ទទួលយកបាត្រ និងចីវររបស់ព្រះថេរៈ ធ្វើវត្តបដិបត្តិ សូម្បីត្រាច់ទៅជាមួយព្រះអរិយៈ ក៏មិនស្គាល់ព្រះអរិយៈ ព្រះ អរិយៈទាំងឡាយ ដឹងបានលំបាកយ៉ាងនេះ ដូច្នេះ ។ កាលព្រះថេរៈពោល យ៉ាងនេះ ឧបដ្ឋាកនោះ ក៏នៅតែមិនដឹង ។

ព្រោះហេតុនោះ ការឃើញដោយចក្ខុ មិនឈ្មោះថា ឃើញ ការឃើញដោយញាណប៉ុណ្ណោះ ឈ្មោះថា ឃើញ សមដូចព្រះពុទ្ធអង្គត្រាស់ថា ម្នាលវក្កលិ ប្រយោជន៍អ្វីដោយកាយដែលជារបស់ស្អុយនេះ ដែលអ្នកឃើញហើយ ម្នាលវក្កលិ ប្រយោជន៍អ្វីដោយកាយស្អុយ ដែលអ្នកឃើញហើយនេះ ម្នាលវក្កលិ បុគ្គលណាមួយឃើញធម៌ បុគ្គលនោះ ឈ្មោះថា ឃើញតថាគត ដូច្នេះ ។

ព្រោះដូច្នោះ បុគ្គលសូម្បីឃើញ ( នូវព្រះអរិយៈ ) ដោយចក្ខុ តែមិនឃើញអនិច្ចលក្ខណៈជាដើម ដែលព្រះអរិយៈទាំងឡាយឃើញហើយដោយញាណ និងមិនសម្រេចធម៌ដែលព្រះអរិយៈសម្រេចហើយ គប្បីជ្រាបថា មិនឃើញព្រះអរិយៈទាំងឡាយ ព្រោះធម៌ដែលធ្វើឲ្យជាព្រះអរិយៈ និងភាពជាព្រះអរិយៈ បុគ្គលនោះមិនទាន់ឃើញ ដូច្នេះ ។

ពីរបទថា **អរិយធម្មស្ស អកោវិទោ** សេចក្តីថា មិនឈ្លាសក្នុងអរិយធម៌ ដែលចែកជាសតិប្បដ្ឋានជាដើម ។

ឈ្មោះថា វិន័យ មាន ២ យ៉ាង ក្នុងមួយៗ មាន ៥ ប្រភេទ ព្រោះការមិនមានវិន័យទាំង ២ នោះ លោកហៅថា **អវិនីត** ក្នុងពាក្យថា **អរិយធម្មេ អវិនីតោ** នេះ ។

## វិន័យ ២ យ៉ាង

ពិតហើយ វិន័យនេះ មាន ២ យ៉ាង គឺសំវរវិន័យ ១ បហានវិន័យ ១ ។ វិន័យ ១ ក្នុងវិន័យទាំង ២ នេះ ចែកចេញជា ៥ ។ ពិតហើយ សូម្បី

សំវរវិន័យ មាន ៥ គឺសីលសំវរៈ សតិសំវរៈ ញាណសំវរៈ ខន្តិសំវរៈ និងវីរិយសំវរៈ ។ សូម្បីបហានសំវរៈ មាន ៥ យ៉ាងដូចគ្នា គឺតទង្គប្បហាន វិក្ខម្ភនប្បហាន សមុច្ឆេទប្បហាន បដិបស្សទ្ធិប្បហាន និងនិស្សរណប្បហាន។

សំវរវិន័យ ៥ យ៉ាងនោះ សំវរៈដែលត្រាស់ថា ភិក្ខុចូលដល់ដោយបាតិមោក្ខសំវរៈ នេះហៅថា សីលសំវរៈ ។

សំវរៈដែលត្រាស់ទុកថា ភិក្ខុរមែងរក្សាចក្ខុន្ទ្រិយ គឺដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ នេះហៅថា សតិសំវរៈ ។

សំវរៈដែលត្រាស់ថា ម្នាលអជិតៈ សតិជាគ្រឿងទប់ខ្សែតណ្ហាទាំង-ឡាយនោះ ដែលមាននៅក្នុងលោក តថាគតពោលថា សតិជាគ្រឿងរាំងខ្សែតណ្ហាទាំងឡាយ បុគ្គលគប្បីបិទខ្សែតណ្ហាទាំងនោះដោយបញ្ញា ។

សំវរៈដែលត្រាស់ទុកថា ភិក្ខុរមែងអត់ធន់ចំពោះត្រជាក់ និងក្ដៅ នេះហៅថា ខន្តិសំវរៈ ។

សំវរៈដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទទួលទុកនូវកាមវិតក្កដែលកើតហើយ នេះហៅថា វីរិយសំវរៈ ។

ម្យ៉ាងទៀត សំវរៈទាំងអស់នេះ លោកហៅថា សំវរៈ ព្រោះជាគ្រឿងរារាំងកាយទុច្ចរិត និងវចីទុច្ចរិតជាដើម ដែលខ្លួនត្រូវសង្រួមតាមកិច្ចរបស់ខ្លួន និងហៅថា វិន័យ ព្រោះជាគ្រឿងកម្ចាត់កាយទុច្ចរិត និងវចីទុច្ចរិតជាដើម ដែលខ្លួនត្រូវកម្ចាត់តាមកិច្ចរបស់ខ្លួន ។ សំវរវិន័យគប្បីជ្រាបថា បែកចេញជា ៥ ដូចអធិប្បាយមកនេះឯង ។

# បហាន ៥

ម្យ៉ាងទៀត ការលះអង្គនោះៗ រមែងមានដោយវិបស្សនាញាណនោះៗ ព្រោះជាបដិបក្ខនឹងវិបស្សនាញាណ មាននាមរូបបរិច្ឆេទញ្ញាណជាដើម ដូចការកម្ចាត់ងងឹត រមែងមានព្រោះពន្លឺនៃប្រទីប ដូច្នោះ គឺលះសក្កាយទិដ្ឋិ ដោយការកំណត់នាមរូប លះទិដ្ឋិដែលមិនមានហេតុ និងមានហេតុមិនស្មើគ្នា ដោយការកំណត់បច្ច័យ លះសេចក្ដីសង្ស័យ ដោយការឆ្លងសេចក្ដីសង្ស័យ ដែលជាចំណែកខាងក្រោយ នៃការកំណត់បច្ច័យនោះឯង លះការប្រកាន់ថា អញ របស់អញ ដោយការពិចារណាកលាប: គឺក្រុម ឬកង លះសញ្ញាក្នុងធម៌ ដែលមិនមែនផ្លូវ ថាជាផ្លូវ ដោយការកំណត់មគ្គ និងអមគ្គ លះឧច្ឆេទ-ទិដ្ឋិ ដោយការឃើញការកើតឡើង លះសស្សតទិដ្ឋិដោយការពិចារណាឃើញការវិនាស លះការសម្គាល់ថា មិនគួរខ្លាចក្នុងវត្ថុដែលគួរខ្លាច ដោយការពិចារណាឃើញភ័យ លះការសម្គាល់ថា ពេញចិត្ត ដោយការពិចារណាឃើញទោស លះអភិរតិសញ្ញា ដោយនិព្វិទានុបស្សនា លះភាពជាបុគ្គលដែលចង់រួចផុតដោយញាណ គឺភាពជាអ្នកប្រាថ្នានឹងរួចផុត លះការមិនសម្លឹងដោយឧបេក្ខាញាណ លះបដិលោមក្នុងធម្មដ្ឋិតិ និងក្នុងព្រះនិព្វានដោយអនុលោ-មញ្ញាណ លះការប្រកាន់និមិត្តក្នុងសង្ខារដោយគោត្រភូញាណ នេះឈ្មោះថា តទង្គប្បហាន ។

ម្យ៉ាងទៀត ការលះនីវរណធម៌ជាដើមនោះ ដោយសមាធិ ចែកចេញជាឧបចារសមាធិ ព្រោះហាមការប្រព្រឹត្តទៅ ( នៃនីវរណ: ) ដូចការសង្កត់ចកលើផ្ទៃទឹក ដោយប្រើថ្នាំងសង្កត់ ដូច្នោះ នេះឈ្មោះថា វិក្ខម្ភនបហាន ។

ឯការលះគំនរកិលេស ក្នុងសន្តានរបស់ខ្លួន ដែលទាក់ទងក្នុងសមុទយៈ ដែលព្រះមានព្រះភាគត្រាស់ទុកដោយន័យជាដើមថា ព្រះយោគាវចរលះបង់ទិដ្ឋិទាំងឡាយ មួយអន្លើដោយកងកិលេសនោះ មិនឲ្យប្រព្រឹត្តទៅបានទៀត ដាច់ខាតដោយមគ្គនោះ ព្រោះចម្រើនអរិយមគ្គ ៤ បានហើយ នេះឈ្មោះថា សមុច្ឆេទប្បហាន ។

ម្យ៉ាងទៀត កិលេសទាំងឡាយ ស្ងប់រម្ងាប់ទៅក្នុងខណៈនៃផល នេះឈ្មោះថា បដិបស្សទ្ធិប្បហាន ។ ព្រះនិព្វាន ឈ្មោះថា លះគ្រឿងតាក់តែងទាំងពួងបាន ព្រោះរលាស់ចោលគ្រឿងតាក់តែងទាំងពួងហើយ នេះឈ្មោះថា និស្សរណប្បហាន ។

ម្យ៉ាងទៀត ព្រោះការលះទាំងអស់នោះ ឈ្មោះថា បហាន ដោយអត្ថថា លះបង់ ឈ្មោះថា វិន័យ ដោយអត្ថថា កម្ចាត់ ដូច្នោះ ទើបលោកហៅថា បហានវិន័យ ។ ម្យ៉ាងទៀត ព្រោះការលះកិលេសនោះផង ព្រោះធ្វើឲ្យកើតមានការកម្ចាត់កិលេសនោះផង ការលះទាំងអស់នោះ លោកហៅថា បហាន-វិន័យ ។ សូម្បីបហានវិន័យ គប្បីជ្រាបថា ចែកចេញជា ៥ ប្រការ ដោយប្រការដូច្នេះ ។

វិន័យនេះដោយសង្ខេបមាន ២ និងដោយបំបែកមាន ១០ ដូចពណ៌នាមក ដូច្នេះ ព្រោះហេតុដែលបុថុជ្ជនអ្នកមិនបានស្តាប់នោះ មិនមានវិន័យទាំង ២ យ៉ាងនោះ ដូច្នោះ ទើបបុថុជ្ជននេះ ព្រះមានព្រះភាគត្រាស់ហៅថា **អវិនីត** ( អ្នកមិនមានវិន័យ ) ព្រោះខ្វះសំវរៈ និងព្រោះលះបហាតព្វធម៌មិនបាន ។

ក្នុងបទថា **សប្បុរិសានំ អទស្សាវី** ( មិនឃើញសប្បុរស ) **សប្បុរិសធម្មស្ស អកោវិទោ** ( មិនឈ្លាសក្នុងធម៌របស់សប្បុរស ) **សប្បុរិសធម្មេ អវិនីតោ** ( មិនបានទូន្មានខ្លួនក្នុងធម៌របស់សប្បុរស ) នេះ ក៏មានន័យដូចគ្នា ។

ពាក្យនេះ ដោយអត្ថមិនផ្សេងគ្នាឡើយ សមដូចលោកពោលទុកថា ព្រះអរិយៈ គឺសប្បុរស សប្បុរស គឺព្រះអរិយៈ ធម៌របស់ព្រះអរិយៈ គឺធម៌របស់សប្បុរស ធម៌របស់សប្បុរស គឺធម៌របស់ព្រះអរិយៈ វិន័យរបស់ព្រះអរិយៈ គឺវិន័យរបស់សប្បុរស វិន័យរបស់សប្បុរស គឺវិន័យរបស់ព្រះអរិយៈ សព្ទថា **អរិយេ** ឬ **សប្បុរិសេ** ក្តី **អរិយធម្មេ** ឬ **សប្បុរិសធម្មេ** ក្តី **អរិយវិនយេ** ឬ **សប្បុរិសវិនយេ** ក្តី ទាំងអស់នោះសុទ្ធតែដូចគ្នា មានអត្ថតែមួយដូចគ្នា ស្មើគ្នា មានតម្លៃប៉ុនគ្នា កំណើតដូចគ្នាទាំងអស់ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងសព្វធម្មមូលបរិយាយសូត្រដល់ពួកអ្នក តែទ្រង់មិនសម្តែងសូត្រនោះ ទ្រង់បែរជាសម្តែងដល់បុថុជ្ជនយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះមិនបានស្តាប់ មិនឃើញព្រះអរិយៈទាំងឡាយ ដូច្នេះ ឆ្លើយថា ដើម្បីនឹងធ្វើឲ្យជាក់ច្បាស់នូវអត្ថនោះ ដោយធម្មទេសនាដែលជាបុគ្គលាធិដ្ឋាន ដូច្នេះ ។

ពិតហើយ ការទេសនារបស់ព្រះមានព្រះភាគ លំដាប់ដំបូងមាន ៤ ប្រការ ដោយអំណាចធម៌ និងបុគ្គលនោះឯង គឺព្រះធម្មទេសនាដែលលើកព្រះធម៌ជា

ទីតាំង ( ធម្មាធិដ្ឋាន ) បុគ្គលទេសនា ដែលលើកព្រះធម៌ជាទីតាំង ( ធម្មា-ធិដ្ឋាន ) បុគ្គលទេសនាដែលលើកបុគ្គលជាទីតាំង ( បុគ្គលាធិដ្ឋាន ) និង ព្រះធម្មទេសនា លើកបុគ្គលជាទីតាំង ( បុគ្គលាធិដ្ឋាន ) ។

បណ្តាទេសនា ៤ ប្រការនោះ ទេសនាបែបនេះថា ម្នាលភិក្ខុទាំងឡាយ វេទនាមាន ៣ វេទនា ៣ តើដូចម្តេច វេទនា ៣ គឺសុខវេទនា ១ ទុក្ខ-វេទនា ១ អទុក្ខមសុខវេទនា ១ ម្នាលភិក្ខុទាំងឡាយ វេទនាមាន ៣ នេះឯង គប្បីជ្រាបថា ឈ្មោះថា ធម្មទេសនាដែលជាធម្មាធិដ្ឋាន ។

ទេសនាបែបនេះថា ម្នាលភិក្ខុទាំងឡាយ បុរសនេះមានធាតុ ៦ មានផស្សាយតនៈ ៦ មានមនោបវិចារៈ ១៨ មានអធិដ្ឋានធម៌ ៤ គប្បីជ្រាបថា ឈ្មោះថា បុគ្គលទេសនា ជាធម្មាធិដ្ឋាន ។

ទេសនាបែបនេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ មាននៅក្នុងលោក បុគ្គល ៣ ពួក តើដូចម្តេច គឺបុគ្គលខ្វាក់ ១ បុគ្គលមានភ្នែកម្ខាង ១ បុគ្គលមានភ្នែកទាំងពីរខាង ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្វាក់ តើដូចម្តេច គប្បីជ្រាបថា ឈ្មោះថា បុគ្គលទេសនាដែលជាបុគ្គលាធិដ្ឋាន ។

ទេសនាបែបនេះថា ម្នាលភិក្ខុទាំងឡាយ ចុះទុគ្គតិភ័យ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាដូច្នេះថា កាយទុច្ចរិតមានផលអាក្រក់ ក្នុងលោកខាងមុខ ។បេ។ ត្រឡប់រក្សាខ្លួនឲ្យស្អាតវិញ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុគ្គតិភ័យ គប្បីជ្រាបថា ឈ្មោះថា ធម្មទេសនាដែលជាបុគ្គលាធិដ្ឋាន ។

គប្បីជ្រាបអធិប្បាយថា ក្នុងទីនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងបុថុជ្ជន ពង្រីកអត្ថនៃទេសនាដែលជាបុគ្គលាធិដ្ឋានឲ្យជាក់ច្បាស់ ទើបទ្រង់សម្តែងបង្ហាញដល់បុថុជ្ជនយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ មិនបានស្តាប់ មិនបានឃើញព្រះអរិយៈទាំងឡាយ ព្រោះហេតុដែលបុថុជ្ជន មិនបានកំណត់ដឹងខន្ធ និងសេចក្តីសម្គាល់ ដែលជាឫសគល់របស់ធម៌ទាំងពួង ដែលទ្រង់បំណងយកក្នុងទីនេះ ក៏មានការមិនកំណត់ដឹងជាឫសគល់ ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងបុថុជ្ជនយ៉ាងនេះហើយ ឥឡូវនេះកាលទ្រង់សម្តែងសេចក្តីសម្គាល់ក្នុងវត្ថុទាំងឡាយ មានបឋវី គឺដីជាដើមដែលឲ្យកើតធម៌ ដែលទាក់ទងក្នុងសក្កាយទិដ្ឋិទាំងអស់របស់បុថុជ្ជននោះ ទើបត្រាស់ពាក្យជាដើមថា **បឋវឹ បឋវិតោ** ដូច្នេះ ។

## អធិប្បាយ បឋវី ៤ ប្រការ

ក្នុងបទថា **បឋវឹ បឋវិតោ** នោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា បឋវីមាន ៤ យ៉ាង គឺ **លក្ខណាបឋវី ១ សសម្ភារបឋវី ១ អារម្មណាបឋវី ១** និង **សម្មតិបឋវី ១** ។

ក្នុងបឋវី ៤ យ៉ាងនោះ បឋវីធាតុដែលលោកពោលក្នុងប្រយោគជាដើមថា ម្នាលអ្នកមានអាយុ បឋវីធាតុខាងក្នុង តើដូចម្តេច ធម្មជាតណាជាខាងក្នុង អាស្រ័យនូវខ្លួន រឹង កក ឈ្មោះថា លក្ខណាបឋវី ។

បឋវីធាតុដែលលោកពោលទុកក្នុងប្រយោគជាដើមថា ភិក្ខុជីកឯងក្តី ឲ្យអ្នកដទៃជីកក្តី នូវផែនដី ដូច្នេះ ឈ្មោះថា សសម្ភារបឋវី ។

ម្យ៉ាងទៀត បឋវីធាតុ គឺកោដ្ឋាស ២០ មានសក់ជាដើម និងវត្ថុខាង

ក្រៅ មានដែក និងលោហៈជាដើម ព្រមទាំងគុណសម្បត្តិ មានពណ៌ជាដើម ហៅថា សសម្ភារបឋវី ។

ឯបឋវីធាតុ មកក្នុងប្រយោគជាដើមថា បុគ្គលមួយពួក ដឹងច្បាស់នូវបឋវីកសិណ ហៅថា **អារម្មណបឋវី** ជួនកាល ហៅថា **និមិត្តបឋវី** ។

បឋវីធាតុដែលហៅថា បុគ្គលបានឈានមានបឋវីកសិណជាអារម្មណ៍ កើតក្នុងទេវលោក រមែងបានឈ្មោះថា បឋវីទេវតា ដោយអំណាចបឋវីកសិណ ជាហេតុឲ្យមក ( កើត ) នេះ គប្បីជ្រាបថា សម្មតិបឋវី ។

ក្នុងអធិការនេះ រមែងបានបឋវីកសិណទាំងអស់នោះ ។ បុថុជ្ជននេះ រមែងសម្គាល់បឋវីឯណាមួយ ក្នុងបណ្ដាបឋវីទាំងនោះ ថាជាបឋវី រមែងសម្គាល់នូវបឋវីថាជាបឋវីពិត រមែងដឹងដោយចំណែកនៃបឋវី កាលកាន់យកតាមលោកវោហារហើយ រមែងសំដៅយកដោយសញ្ញាវិបល្លាស ថាជាបឋវី កាលលែងចោលនូវចំណែកនៃបឋវីមិនបានយ៉ាងនេះ រមែងសម្គាល់យកចំណែកនៃបឋវីនោះ ដោយន័យជាដើមថា សត្វ ឬថារបស់សត្វ ។ ព្រោះហេតុអ្វី ទើបមិនគួរពោលថា **ឯវំ សញ្ជានាតិ** ។ ព្រោះថា បុថុជ្ជនដូចជាមនុស្សឆ្កួត ។ រមែងប្រកាន់វត្ថុណាមួយ ដោយអាការឯណាមួយ ។

ម្យ៉ាងទៀត ដោយហេតុផ្សេងៗ មានភាពជាបុគ្គលមិនឃើញព្រះអរិយៈទាំងឡាយជាដើមនុ៎ះឯង ចាត់ជាគោលក្នុងការកត់សម្គាល់នេះ ដែលព្រះមានព្រះភាគកាលត្រាស់ថា **អបរិញ្ញាតំ តស្ស** ខាងមុខក៏ឈ្មោះថា ត្រាស់ហើយ ។

បទថា **បឋវឹ បឋវិតោ សញ្ញត្វា** សេចក្តីថា បុថុជ្ជននោះសម្គាល់ផែនដីនោះដោយសញ្ញាវិបរិតយ៉ាងនេះហើយ តមក រមែងសម្គាល់ គឺកំណត់ឲ្យផ្សេងចេញទៅ បានដល់ ប្រកាន់ដោយអាការផ្សេងៗ គឺដោយប្រការដទៃដោយកិលេសជាគ្រឿងយឹតយូរ គឺ តណ្ហា មានះ និងទិដ្ឋិ ដ៏មានកម្លាំងដែលលោកពោលដោយនាម រួមជា **មញ្ញនា** ក្នុងទីនេះ តាមបាលីថា ចំណែកនៃកិលេសជាគ្រឿងយឹតយូរ មានសញ្ញាជាដើមហេតុ ដូច្នេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **បឋវឹ មញ្ញតិ** ដូច្នេះ ។

ដើម្បីទ្រង់សម្តែងការសម្គាល់ទាំងនោះ របស់បុគ្គលដែលសម្គាល់យ៉ាងនេះ ដោយន័យដែលពិស្តារ ទើបព្រះមានព្រះភាគត្រាស់បឋវីខាងក្នុង ២០ ប្រភេទ ដោយន័យជាដើមថា **កេសា លោមា** ត្រាស់បឋវីក្នុងគម្ពីរវិភង្គយ៉ាងនេះថា បណ្តាធាតុ ២ នោះ បឋវីធាតុខាងក្រៅ តើដូចម្តេច ធម្មជាតណាជាខាងក្រៅ រឹង កក មានអាការរឹង មានសភាពរឹង ជាខាងក្រៅ ដែលវិញ្ញាណមិនចូលទៅកាន់យកបានទេ គឺ ដែក លោហៈ សំណប៉ាហាំង សំណកក់ ប្រាក់ កែវមុក្តា កែវមណី កែវពៃទូរ្យ ស័ង្ខ ថ្ម កែវពពាល ប្រាក់ មាស កែវក្រហម កែវពព្រុស ស្មៅ កំណាត់ឈើ ដុំក្រួស ខ្សាច់ អំបែង ផែនដី ថ្ម ភ្នំ និងត្រាស់និមិត្តផែនដី ក្នុងវត្ថុ អារម្មណ៍ខាងក្នុងលោកសំដៅយកបឋវីនោះៗ ពោលប្រកបសេចក្តីនោះ ។

បទថា **បឋវឹ មញ្ញតិ** សេចក្តីថា បុថុជ្ជនរមែងសម្គាល់ថា អញជាដីជាដីជារបស់អញ ថាអ្នកដទៃជាដី ថាដីរបស់អ្នកដទៃ ដូច្នេះ ដោយការ

សម្គាល់ ៣ យ៉ាង ។

ម្យ៉ាងទៀត រមែងសម្គាល់បឋវី ( ផែនដី ) ខាងក្នុង ដោយការសម្គាល់ដោយអំណាចតណ្ហា មានះ និងទិដ្ឋិ ។

សម្គាល់ដូចម្តេច ពិតហើយ បុថុជ្ជននេះ ញ៉ាំងឆន្ទរាគៈឲ្យកើតក្នុងសក់ជាដើម គឺត្រេកអរ រីករាយ ភ្លើតភ្លើន រវើងក្នុងសក់ រោម ក្រចក ធ្មេញ ស្បែក ឬវត្ថុដែលជាទីតាំងនៃតម្រេកណាមួយ បុថុជ្ជនរមែងសម្គាល់បឋវីខាងក្នុង ដោយការសម្គាល់ដែលកើតអំពីអំណាចនៃតណ្ហាយ៉ាងនេះ ។

ឬកើតការជាប់ជំពាក់ក្នុងសក់ជាដើមនោះ ដោយន័យជាដើមថា សក់របស់អញគប្បីដូច្នេះរហូតទៅ ចូររោមរបស់អញ គប្បីដូច្នេះរហូតទៅ ឬតាំងចិត្តទុកដើម្បីបានវត្ថុដែលខ្លួនមិនទាន់បាន ដោយន័យជាដើមថា ដោយសីល ឬព្រហ្មចរិយៈនេះ អញនឹងមានសក់ខ្មៅរលោង ទន់ល្អ ដូច្នេះ ។ បុថុជ្ជនរមែងសម្គាល់បឋវីខាងក្នុង ដោយការសម្គាល់ដោយតណ្ហា ដូចអធិប្បាយមកនេះ ។

ម្យ៉ាងទៀត បុថុជ្ជនអាស្រ័យសម្បត្តិ គឺការដល់ព្រម ឬវិបត្តិរបស់សក់ជាដើមនៃខ្លួន ហើយញ៉ាំងមានះឲ្យកើតឡើងថា អញល្អជាង អញស្មើនឹងគេ ឬអញអាក្រក់ជាង ដូចពោលមកនេះ ឈ្មោះថា សម្គាល់បឋវីខាងក្នុង ដោយការសម្គាល់ដែលកើតអំពីអំណាចមានះ ។ ម្យ៉ាងទៀត រមែងប្រកាន់មាំក្នុងសក់ ថាជាជីវៈ ដោយន័យដែលមកហើយថា ជីវៈនោះ សរីរៈនោះ ដូច្នេះ ។ ក្នុងរោមជាដើមក៏ន័យនេះ ។ បុថុជ្ជនរមែងសម្គាល់បឋវីខាងក្នុង ដោយការ

សម្គាល់ដែលកើតមកអំពីអំណាចទិដ្ឋិដូចពោលមកនេះ ។

ម្យ៉ាងទៀត បុថុជ្ជនរមែងប្រកាន់មាំនូវបឋវី មានសក់ជាដើម ដោយន័យជាសូត្រចំពោះព្រឹត្តិកម្មនេះថា ម្នាលអាវុសោ បឋវីធាតុខាងក្នុងឯណា និងបឋវីធាតុខាងក្រៅឯណា បឋវីធាតុទាំង ២ នោះ ឈ្មោះថា បឋវីធាតុដូចគ្នា ទុំះមិនមែនរបស់អញ ថារបស់អញ អញជារបស់ទុំះ ទុំះជាអត្តារបស់អញ ឈ្មោះថា រមែងសម្គាល់បឋវីខាងក្នុង ដោយការសម្គាល់ដែលកើតមកអំពីអំណាចទិដ្ឋិយ៉ាងនេះ ។ បុថុជ្ជនរមែងសម្គាល់បឋវីខាងក្នុង ដោយការសម្គាល់ ៣ យ៉ាង ដូចពណ៌នាមកនេះ ។ គប្បីជ្រាបថា រមែងសម្គាល់បឋវីខាងក្រៅដូចបឋវីខាងក្នុងដែរ ។

សេចក្តីនេះដូចម្តេច ពិតហើយ បុថុជ្ជននេះ ញុំាំងឆន្ទរាគៈឲ្យកើតឡើងក្នុងដែក និងលោហៈជាដើម ត្រេកអរ រីករាយ វង្វេងក្នុងដែក និងលោហៈជាដើម រមែងហួងហែងរក្សា គ្រប់គ្រងនូវដែកជាដើមទុក ដោយន័យជាដើមថា ដែករបស់អញ លោហៈរបស់អញ ឈ្មោះថា សម្គាល់បឋវីខាងក្រៅដោយការសម្គាល់ដោយអំណាចតណ្ហា ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត បុថុជ្ជន រមែងហួងហែងក្នុងបឋវីខាងក្រៅនេះថា ចូរដែក និងលោហៈជាដើមរបស់អញ គប្បីមានយ៉ាងនេះរហូតទៅ ឬតាំងចិត្តទុក ដើម្បីបានវត្ថុដែលមិនទាន់បានថា ដោយសីល និងដោយព្រហ្មចរិយៈនេះ អញនឹងជាអ្នកមានឧបករណ៍ មានដែក និងលោហៈជាដើម ដែលដល់ព្រមហើយយ៉ាងនេះ បុថុជ្ជន ឈ្មោះថា សម្គាល់បឋវីខាងក្រៅ ដោយការសម្គាល់ដែលកើតមក

អំពីអំណាចនៃតណ្ហា ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត បុថុជ្ជនអាស្រ័យសម្បត្តិ ឬវិបត្តិនៃដែក និងលោហៈជាដើមរបស់ខ្លួនហើយ កើតមានះឡើងថា ដោយឧបករណ៍នេះ ទើបអញល្អជាងគេ ស្មើគេ ឬអាក្រក់ជាងគេ បុថុជ្ជនឈ្មោះថា រមែងសម្គាល់បឋវីខាងក្រៅ ដោយការសម្គាល់ដែលកើតមកអំពីអំណាចមានះយ៉ាងនេះ ។

បុថុជ្ជន ជាបុគ្គលមានការសម្គាល់ក្នុងដែកថា ជីវៈ រមែងប្រកាន់មាំថា នេះជាជីវៈ ន័យក្នុងលោហៈជាដើមក៏ដូច្នេះ ។ បុថុជ្ជន ឈ្មោះថា រមែងសម្គាល់បឋវីខាងក្រៅ ដោយការសម្គាល់ដែលកើតមកអំពីអំណាចទិដ្ឋិ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ពិចារណាឃើញបឋវីកសិណ ដោយជាអត្តា គឺរមែងប្រកាន់មាំនូវនិមិត្តបឋវីថា អត្តា ដោយន័យដែលលោកពោលទុកក្នុងគម្ពីរបដិសម្ភិទាមគ្គនោះឯងថា បុថុជ្ជន រមែងពិចារណាឃើញអត្តទាំង ២ គឺបឋវីកសិណ និងអត្តាវយវៈថា បឋវីកសិណយ៉ាងណា អញក៏យ៉ាងនោះ អញយ៉ាងណា បឋវីកសិណក៏យ៉ាងនោះ ដូច្នេះ ឈ្មោះថា រមែងសម្គាល់បឋវីខាងក្រៅ ដោយការសម្គាល់ដែលកើតមកអំពីអំណាចទិដ្ឋិ ដោយប្រការដូច្នេះ ។

បុថុជ្ជនរមែងសម្គាល់បឋវីខាងក្រៅ ដោយការសម្គាល់ ៣ យ៉ាង ដូចអធិប្បាយមកនេះ ។

ក្នុងបទថា **បឋវឹ មញ្ញតិ** នេះ គប្បីជ្រាបការសម្គាល់ទាំង ៣ ដូច

ពណ៌នាមកនេះ ។ តអំពីនេះទៅ ខ្ញុំនឹងពោលដោយសង្ខេបប៉ុណ្ណោះ ។ បទថា **បឋវិយា** ក្នុងបទថា **បឋវិយា មញ្ញតិ** នេះ ជាសត្តមីវិភត្តិ ព្រោះដូច្នោះមានអធិប្បាយដូច្នេះថា បុថុជ្ជនរមែងសម្គាល់ថា អញមាននៅក្នុងបឋវី រមែងសម្គាល់ថា ការកង្វល់របស់អញ មាននៅក្នុងបឋវី រមែងសម្គាល់ថា បុគ្គលដទៃមាននៅក្នុងបឋវី រមែងសម្គាល់ថា ការកង្វល់របស់បុគ្គលដទៃក្នុងបឋវីមាន ដូច្នេះ ម្យ៉ាងទៀត អត្ថរបស់សត្តមីវិភត្តិនោះឯណា ដែលលោកពោលទុកថា បុថុជ្ជនរមែងពិចារណាឃើញអត្តាក្នុងរូបដូចម្ដេច គឺបុថុជ្ជនពួកខ្លះក្នុងលោកនេះ រមែងពិចារណាឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាអត្តា បុថុជ្ជននោះ រមែងពិចារណាឃើញអត្តាក្នុងរូបយ៉ាងនេះថា នេះឯងជាអត្តារបស់អញ អត្តារបស់អញនេះឯង មាននៅក្នុងរូបនេះ ដូច្នេះ ដោយន័យនោះឯង ទើបបុថុជ្ជនកាន់យកវេទនាធម៌ជាដើម តអំពីនេះ ក៏កំណត់យកបឋវីប្រភេទណាមួយ ក្នុងបណ្ដាបឋវីទាំងខាងក្នុង និងខាងក្រៅ ដោយភាពជាឱកាសនៃអត្តានោះ សម្គាល់ថា អត្តារបស់អញនេះឯង មាននៅក្នុងបឋវីនេះ ដូច្នេះ ឈ្មោះថា រមែងសម្គាល់ក្នុងបឋវី ។ នេះឈ្មោះថា ការសម្គាល់ដោយអំណាចនៃទិដ្ឋិរបស់បុថុជ្ជន ។

កាលបុថុជ្ជននោះ ញុំាងសេចក្ដីស្នេហាក្នុងអត្តា និងមានះ ដែលមានអត្តាជាទីតាំងឲ្យកើតឡើងក្នុងរូបនោះឯង គប្បីជ្រាបថា ជាការសម្គាល់ដោយអំណាចនៃតណ្ហា និងមានះ ។

តែក្នុងកាលណា បុថុជ្ជន សម្គាល់ដោយន័យនោះឯងថា អត្តានៃអ្នក

ដទៃនោះឯង មាននៅក្នុងបឋវី ក្នុងកាលនោះ ការសម្គាល់ដែលកើតមក អំពីអំណាចនៃទិដ្ឋិនោះឯង រមែងពាល់ត្រូវ ។ ឯការសម្គាល់ក្រៅអំពីនេះ លោកក៏បំណាងយកដែរ ។

បទថា **បឋវិតោ** ក្នុងបទថា **បឋវិតោ មញ្ញតិ** ជាបញ្ចមីវិភត្តិ ។

ព្រោះដូច្នោះ បុថុជ្ជន កាលសម្គាល់ការកើតឡើង ឬការប្រាសទៅរបស់បឋវី មានប្រភេទតាមដែលពោលហើយនៃខ្លួនក្ដី នៃបុគ្គលដទៃក្ដី ព្រមទាំងទ្រព្យសម្បត្តិ ឬសម្គាល់ថា អត្តាដទៃអំពីបឋវី គប្បីជ្រាបថា ឈ្មោះថា សម្គាល់ចាកបឋវី ដែលជាការសម្គាល់ដោយអំណាចនៃទិដ្ឋិរបស់បុថុជ្ជននោះ។ កាលបុថុជ្ជននោះ ញុំាំងសេចក្ដីស្នេហា និងមានះឲ្យកើតក្នុងវត្ថុដែលសម្គាល់ដោយអំណាចទិដ្ឋិនោះឯង គប្បីជ្រាបថា ជាការសម្គាល់ដោយតណ្ហា និងមានះ ។ អាចារ្យពួកខ្លះពោលថា បុថុជ្ជនចម្រើនបឋវីកសិណ ដែលជាបរិត្តារម្មណ៍ហើយ បន្ទំអំពីនោះ ប្រកាន់យកអត្តា ដែលមិនមានប្រមាណដទៃ ហើយសម្គាល់ថា អត្តារបស់អញ ( មាន ) សូម្បីខាងក្រៅអំពីបឋវី ដូច្នេះ ឈ្មោះថា រមែងសម្គាល់ក្រៅពីបឋវី ។ ការសម្គាល់ឯណាមួយ ដែលប្រព្រឹត្តទៅដោយន័យនេះថា បុថុជ្ជនរមែងប្រកាន់មហាបឋវីតែម្យ៉ាង ។

ក្នុងបទនេះថា **បឋវឹ មេតិ មញ្ញតិ** មានវិនិច្ឆ័យដូចតទៅនេះ ការសម្គាល់ដែលប្រព្រឹត្តទៅដោយន័យនេះថា រមែងហួងហែងមហាបឋវី ដោយអំណាចតណ្ហាតែមួយចំណែក គប្បីជ្រាបថា បានដល់ ការសម្គាល់ដោយអំណាចតណ្ហាតែម្យ៉ាងដូចគ្នា ។ ការសម្គាល់ដោយអំណាចតណ្ហានេះ គួរ

ប្រកបចូលក្នុងបឋវីទាំងឡាយខាងក្នុង និងខាងក្រៅទាំងអស់ មានប្រភេទតាមដែលពោលទុកហើយ យ៉ាងនេះថា សក់របស់អញ រោមរបស់អញ ដែករបស់អញ ដូច្នេះ ។

បទថា **បឋវឹ អភិនន្ទតិ** សេចក្ដីថា បុថុជ្ជន រមែងត្រេកអរ អធិប្បាយថា ត្រេកអរ ជាប់ចិត្តក្នុងបឋវី មានប្រការតាមដែលពោលហើយនោះឯង ដោយកិលេស មានតណ្ហាជាដើម ។

បើមានពាក្យសួរថា កាលអត្ថនេះសម្រេចហើយ ដោយពីរបទនេះឯងថា **បឋវឹ មញ្ញតិ** ព្រោះហេតុអ្វី ទើបពោលបែបនេះ ។

ឆ្លើយថា ពាក្យនេះ បុរាណាចារ្យទាំងឡាយ មិនបានលើកមកអធិប្បាយ មតិនេះជាចំណែកផ្ទាល់ខ្លួនរបស់ខ្ញុំ ចាកលីលានៃការសម្ដែង ឬចាកការឃើញទោស ព្រោះលោកដល់ព្រមដោយលីលានៃការសម្ដែងដ៏វិចិត្រ ដោយន័យផ្សេងៗ ព្រោះចាក់ធ្លុះធម្មធាតុឯណា ធម្មធាតុនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ដឹងដោយល្អហើយ ព្រោះដូច្នោះ កាលលោកសម្ដែងការកើតឡើងនៃកិលេស ដោយអំណាចការសម្គាល់ខាងដើមហើយ ឥឡូវនេះ កាលសម្ដែងដោយអំណាចការត្រេកអរជាដើម ទើបពោលពាក្យនេះទុក ព្រោះលីលានៃការសម្ដែងខ្លះ ។

ម្យ៉ាងទៀត បុថុជ្ជនណា សម្គាល់បឋវី សម្គាល់ក្នុងបឋវី សម្គាល់ចាកបឋវី សម្គាល់ថា បឋវីរបស់អញ បុថុជ្ជននេះ ព្រោះហេតុដែលខ្លួនមិនអាចលះតណ្ហា ឬទិដ្ឋិដែលអាស្រ័យបឋវីបាន ដូច្នោះ ទើបត្រេកអរក្នុងបឋវី

ដោយចំណែកមួយ ។ មួយវិញទៀត បុថុជ្ជនណា ត្រេកអរក្នុងបឋវី បុថុជ្ជននោះ រមែងត្រេកអរក្នុងទុក្ខ ហើយទុក្ខជាទោស ព្រោះដូច្នោះ ទើបលោកពោលពាក្យនេះទុក ព្រោះការឃើញទោស ។ សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលណា ត្រេកអរក្នុងបឋវីធាតុ បុគ្គលនោះ ត្រេកអរក្នុងទុក្ខ បុគ្គលណា ត្រេកអរក្នុងទុក្ខ បុគ្គលនោះ រមែងមិនរួចផុតទៅអំពីទុក្ខ ដូច្នេះ ។

ព្រះមានព្រះភាគ កាលត្រាស់ការសម្គាល់ និងការត្រេកអរដែលមានបឋវីជាទីតាំងយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់នាំហេតុ ដែលជាហេតុសម្គាល់ និងត្រេកអររបស់បុថុជ្ជននោះ ទើបត្រាស់ថា តថាគតពោលថា ដំណើរនុ៎ះ ព្រោះហេតុអ្វី ការមិនដឹងដោយជុំវិញ ជាហេតុនៃដំណើរនុ៎ះ ដូច្នេះ ។

សេចក្តីនោះ មានអត្ថដូចតទៅនេះ បើមានពាក្យសួរជ្រៀតចូលមកថា បុថុជ្ជននោះ សម្គាល់បឋវីនោះ ព្រោះហេតុអ្វី គឺព្រោះហេតុអ្វី ទើបសម្គាល់ការត្រេកអរក្នុងបឋវីនោះដូច្នេះសោត គប្បីឆ្លើយថា ( ព្រោះព្រះមានព្រះភាគត្រាស់ថា ) តថាគតពោលថា សេចក្តីនុ៎ះ បុថុជ្ជននោះមិនបានកំណត់ដឹងហើយ មានអធិប្បាយថា ព្រោះហេតុនោះ បុថុជ្ជននោះមិនបានកំណត់ដឹងហើយ ពិតហើយ បុថុជ្ជនណា រមែងកំណត់ដឹងនូវបឋវី បុថុជ្ជននោះ រមែងកំណត់ដឹងដោយបរិញ្ញា ៣ គឺញាតបរិញ្ញា ១ តីរណបរិញ្ញា ១ បហានបរិញ្ញា ១ ។

ក្នុងបរិញ្ញា ៣ នោះ ញាតបរិញ្ញាដូចម្ដេច គឺបុថុជ្ជនរមែងដឹងបឋវីធាតុថា បឋវីធាតុនេះ ប្រព្រឹត្តទៅខាងក្នុង បឋវីធាតុនេះ ប្រព្រឹត្តទៅខាងក្រៅ នេះជាលក្ខណៈនៃបឋវីធាតុនោះ នេះជាកិច្ច ជាបច្ចុប្បដ្ឋាន និងជាបទដ្ឋាន របស់បឋវីធាតុនោះ ដូចពោលមកនេះ ហៅថា **ញាតបរិញ្ញា** ។

តីរណបរិញ្ញាដូចម្ដេច គឺបុថុជ្ជនពិចារណាបឋវីធាតុ ធ្វើឲ្យជាវត្ថុដែលខ្លួនដឹងហើយយ៉ាងនេះ ដោយអាការ ៤០ ថា មិនទៀង ជាទុក្ខ ជារោគជាដើម ដូចពោលមកនេះ ហៅថា **តីរណបរិញ្ញា** ។

បហានបរិញ្ញាដូចម្ដេច គឺបុគ្គលពិចារណាឃើញយ៉ាងនេះហើយ រមែងលះឆន្ទរាគៈក្នុងបឋវីធាតុដោយអរហត្តមគ្គ ដូចពោលមកនេះ ហៅថា **បហានបរិញ្ញា** ។

ម្យ៉ាងទៀត ការកំណត់នាម និងរូប ឈ្មោះថា **ញាតបរិញ្ញា** ។ ការកំណត់ដឹង មានការពិចារណាកលាបៈជាខាងដើម និងអនុលោមញ្ញាណជាទីបំផុត ឈ្មោះថា **តីរណបរិញ្ញា** ។ ញាណក្នុងអរិយមគ្គ ឈ្មោះថា **បហានបរិញ្ញា** ។

បុថុជ្ជនណា រមែងកំណត់ដឹងបឋវី បុថុជ្ជននោះ រមែងកំណត់ដឹងដោយបរិញ្ញា ៣ នេះ ។ បរិញ្ញាទាំងនោះ មិនមានដល់បុថុជ្ជននោះ ព្រោះដូច្នោះ បុថុជ្ជននោះ ឈ្មោះថា រមែងសម្គាល់ រមែងត្រេកអរក្នុងបឋវី ព្រោះមិនកំណត់ដឹង ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន ក្នុងលោកនេះ ជាអ្នកមិនបានស្ដាប់ ។បេ។ រមែងសម្គាល់នូវបឋវី ថា

ជាបឋវីពិត រមែងសម្គាល់នូវបឋវី ថាជាបឋវីពិត ហើយក៏រាប់អាននូវបឋវី រាប់អានក្នុងបឋវី រាប់អានថាបឋវីពិត រាប់អានថាបឋវីជារបស់អញ ត្រេកអរនឹងបឋវី ដំណើរនោះ ព្រោះហេតុអ្វី តថាគតពោលថា ព្រោះបុថុជ្ជននោះកំណត់នូវដំណើរនៃបឋវីនោះមិនបាន ។

**បឋវីវារៈ ចប់**

# អធិប្បាយ អាបោធាតុជាដើម

ក្នុងបទនេះថា **អាបំ អាបតោ** គប្បីជ្រាបអាបោ ៤ យ៉ាង គឺលក្ខណ-អាបោ សសម្ភារអាបោ អារម្មណអាបោ និងសម្មតិអាបោ ។ បណ្ដាអាបោ ៤ យ៉ាងនោះ អាបោដែលពោលក្នុងប្រយោគជាដើមថា បណ្ដាធាតុ ២ នោះ អាបោធាតុខាងក្នុង តើដូចម្ដេច ។ ធម្មជាតណាជាខាងក្នុង អាស្រ័យនូវខ្លួន ជាទឹក ដល់នូវភាពជាទឹក មានសភាពស្អិត ដល់នូវភាពស្អិត មានសភាពជាទីជាប់នៅនៃរូបជាខាងក្នុង ដែលវិញ្ញាណចូលទៅកាន់យក ... ឈ្មោះថា លក្ខណអាបោ ។ អាបោពោលទុកក្នុងប្រយោគជាដើមថា បុគ្គលរៀនយកអាបោកសិណ រមែងកាន់យកនិមិត្តក្នុងអាបោ ដូច្នេះ ឈ្មោះថា សសម្ភារអាបោ ។ ពាក្យដ៏សេសទាំងអស់ មានន័យដូចលោកពោលទុកក្នុងបឋវីនោះឯង ។ តែបើពោលដោយន័យ ក្នុងការប្រកបសេចក្ដីសុទ្ធៗ អាបោធាតុដែលប្រព្រឹត្តខាងក្នុង ១២ យ៉ាង ដែលលោកពោលទុកដោយន័យថា ប្រមាត់ ស្លេស្ម ដូច្នេះជាដើម គប្បីជ្រាបថា ជាអាបោធាតុខាងក្នុង

និងអាបោធាតុ ដែលលោកពោលយ៉ាងនេះថា បណ្ដាធាតុ ២ នោះ អាបោធាតុខាងក្រៅ តើដូចម្ដេច ធម្មជាតណាជាខាងក្រៅ ជាទឹក ដល់នូវភាពជាទឹក មានសភាពស្អិត ដល់នូវភាពស្អិត មានភាពជាទីជាប់នៅនៃរូបជារូបខាងក្រៅ ដែលវិញ្ញាណមិនចូលទៅកាន់យក គឺរសគល់ រសដើម រសសម្បក រសស្លឹក រសផ្កា រសផ្លែ ទឹកដោះស្រស់ ទឹកដោះជូរ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ទឹកដែលឋិតនៅលើផែនដីក្ដី ទឹកដែលឋិតនៅឰដ៏អាកាសក្ដី គប្បីជ្រាបថា ជាអាបោធាតុខាងក្រៅ ។ អាបោធាតុនោះ ឈ្មោះថា **និមិត្តអាបោ** ក្នុងពួក ៣ នៃអជ្ឈត្តារម្មណ៍ ។

ក្នុងបទថា **តេជំ តេជតោ** នេះ គប្បីជ្រាបសេចក្ដីពិស្ដារដោយន័យដែលពោលហើយ ក្នុងវារៈនៃតេជោនោះឯង តែក្នុងសេចក្ដីនេះ កាលពោលដោយន័យនៃការពង្រីកសេចក្ដី តេជោធាតុ ៤ យ៉ាង ដែលលោកពោលយ៉ាងនេះថា តេជោធាតុដែលជាហេតុឲ្យរាងកាយកក់ក្ដៅ ទ្រុឌទ្រោម ក្រវល់ក្រវាយ និងដែលជាហេតុដុតអាហារឲ្យរលួយ គប្បីជ្រាបថា តេជោធាតុខាងក្នុង និងតេជោធាតុដែលលោកពោលទុកយ៉ាងនេះថា បណ្ដាធាតុ ២ នោះ តេជោធាតុខាងក្រៅ តើដូចម្ដេច ធម្មជាតណាជាខាងក្រៅ ជាសភាពក្ដៅ ដល់នូវសភាពក្ដៅ ជាចំហាយ ដល់នូវសភាពចំហាយ ជាធម្មជាតអប់កម្ដៅ ដល់នូវសភាពអប់កម្ដៅជាខាងក្រៅ ដែលវិញ្ញាណមិនចូលទៅកាន់យក គឺភ្លើងឧស ភ្លើងកំទេច ភ្លើងស្មៅ ភ្លើងអាចម៍គោ ភ្លើងអង្កាម ភ្លើងសំរាម ភ្លើងរន្ទះ ភ្លើងកម្ដៅ កម្ដៅព្រះអាទិត្យ កម្ដៅគំនរឧស កម្ដៅគំនរស្មៅ កម្ដៅ

គំនរស្រូវ កម្ពោគំនរផេះ ... គប្បីជ្រាបថា ជាតេជោធាតុខាងក្រៅ ។

ក្នុងន័យនៃការអធិប្បាយនៃពាក្យនេះថា **វាយំ វាយតោ** មានអធិប្បាយដូចតទៅនេះ វាយោធាតុដែលលោកពោលយ៉ាងនេះថា ខ្យល់បក់ពីក្រោមឡើងលើ ខ្យល់បក់ពីលើទៅក្រោម ខ្យល់ដេកនៅខាងក្នុងផ្ទៃ ( ខ្យល់ខាងក្រៅពោះវៀន ) ខ្យល់ដេកនៅក្នុងក្រពះ ( ខ្យល់ខាងក្នុងពោះវៀន ) ខ្យល់បក់ផ្សព្វផ្សាយសព្វអវយវៈតូចធំ ខ្យល់ពិសដូចសស្ត្រា ខ្យល់ដូចជាកាំបិតកោរ ខ្យល់អាចពន្លះនូវហឫទ័យ ខ្យល់ដកដង្ហើមចូល ខ្យល់ដកដង្ហើមចេញ ... គប្បីជ្រាបថា ជាវាយោធាតុខាងក្នុង ។ ខ្យល់ដែលលោកពោលទុកយ៉ាងនេះថា បណ្តាវាយោធាតុ ២ យ៉ាងនោះ វាយោធាតុខាងក្រៅ តើដូចម្តេច ធម្មជាតិណាជាខាងក្រៅ ជាសភាពបក់ផាត់ ដល់នូវសភាពបក់ផាត់ មានភាពធ្វើរូបឲ្យរឹងប៉ឹងជាខាងក្រៅ ដែលវិញ្ញាណមិនចូលទៅកាន់យក គឺខ្យល់បក់មកអំពីទិសខាងកើត ខ្យល់បក់មកអំពីទិសខាងលិច ខ្យល់បក់មកអំពីទិសខាងជើង ខ្យល់បក់មកអំពីទិសខាងត្បូង ខ្យល់ប្រកបដោយធូលី ខ្យល់មិនមានធូលី ខ្យល់ត្រជាក់ ខ្យល់ក្តៅ ខ្យល់តិច ខ្យល់ខ្លាំង ខ្យល់ខ្មៅ ខ្យល់កំបុតត្បូង ខ្យល់ដែលតាំងឡើងអំពីស្លាបសត្វ ខ្យល់ដែលតាំងឡើងអំពីគ្រុឌ ខ្យល់ដែលតាំងឡើងអំពីស្លឹកត្នោតជាដើម ខ្យល់ដែលតាំងឡើងអំពីផ្លិត ... គប្បីជ្រាបថា ជាវាយោធាតុខាងក្រៅ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

ហារន័យដែលឈ្មោះថាលក្ខណៈនេះ ក្នុងនេត្តិបករណ៍យ៉ាងនេះថា កាល

ពោលដល់ធម៌មួយហើយ ដោយធម៌មួយនោះ ក៏ឈ្មោះថា ពោលដល់ធម៌គ្រប់យ៉ាង មានលក្ខណៈតែមួយដូចគ្នា លក្ខណហារន័យលោកពោលទុកយ៉ាងនេះ ដូច្នេះ ឈ្មោះថា លោកពោលទុកដោយពាក្យមានប្រមាណប៉ុណ្ណេះ ដោយអំណាចនៃហារន័យនោះ ព្រោះកាលកាន់យកមហាភូតរូបទាំង ៤ ក៏រមែងឈ្មោះថា កាន់យកឧបាទាយរូបទុកផងដែរ ព្រោះឧបាទាយរូបមិនកន្លងផុតលក្ខណរូបទៅបានឡើយ មហាភូតរូប និងឧបាទាយរូបណា ឧបាទាយរូបនោះ ជារូបក្ខន្ធ ដូច្នេះ ព្រះមានព្រះភាគកាលត្រាស់ថា បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្តាប់ រមែងសម្គាល់នូវបឋវី អាបោ តេជោ វាយោ ក៏ឈ្មោះថា ទ្រង់ត្រាស់ថា បុថុជ្ជននោះ រមែងពិចារណាឃើញរូបថា ជាអត្តាផងដែរ ។

កាលត្រាស់ថា បុថុជ្ជនរមែងសម្គាល់ក្នុងបឋវី អាបោ តេជោ វាយោ ក៏ដូចជាទ្រង់បានត្រាស់ថា រមែងពិចារណាឃើញអត្តាក្នុងរូប ដូច្នេះ ។ កាលត្រាស់ថា រមែងសម្គាល់ចាកបឋវី អាបោ តេជោ វាយោ ក៏ដូចជាត្រាស់ថា រមែងពិចារណាឃើញអត្តា ដែលមានរូប និងរូបក្នុងអត្តា ព្រោះសម្រេចសេចក្តីថា អត្តាដទៃអំពីរូប ដូច្នេះ ។

គប្បីជ្រាបការសម្គាល់ដោយអំណាចនៃសក្កាយទិដ្ឋិ ដែលមានរូបជាទីតាំង ៤ ប្រការដូចពោលមកនេះ ។

ក្នុងសេចក្តីនេះ គប្បីជ្រាបការផ្សេងគ្នានេះថា បណ្តាទិដ្ឋិ ៤ ប្រការនោះ ជាឧច្ឆេទទិដ្ឋិ ១ ជាសស្សតទិដ្ឋិ ៣ ដូច្នេះ ទើបទិដ្ឋិមាន ២ យ៉ាង ។ ព្រះ

មានព្រះភាគកាលត្រាស់ការសម្គាល់ ដែលមានសង្ខារជាទីតាំង ដោយមានរូបជាប្រធានយ៉ាងនេះហើយ ឥឡូវនេះ សត្វទាំងឡាយពួកណា ត្រូវបញ្ញត្តឡើងព្រោះអាស្រ័យសង្ខារទាំងឡាយ ព្រោះបុថុជ្ជនធ្វើការសម្គាល់ក្នុងសត្វទាំងឡាយនោះ ដូច្នោះ កាលចង្អុលបង្ហាញសត្វទាំងនោះ ទើបត្រាស់ថា ឈ្មោះថា សម្គាល់នូវពួកសត្វ ( ភូត ) ថាជាសត្វពិត ។

ក្នុងពាក្យនោះ **ភូត** សព្ទនេះ ប្រើក្នុងអត្ថជាដើមថា ខន្ធ ៥ អមនុស្ស ធាតុ មានពិត ព្រះខីណាស្រព សត្វ និងដើមឈើ ។

ពិតហើយ **ភូត** សព្ទនេះ ប្រើក្នុងអត្ថថា ខន្ធ ៥ ដូចក្នុងប្រយោគជាដើមថា **ភូតមិទន្តិ ភិក្ខវេ សមនុបស្សថ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញនូវខន្ធបញ្ចកៈនេះ ដែលកើតឡើងហើយឬទេ ។

ប្រើក្នុងអត្ថថា **អមនុស្ស** ដូចក្នុងប្រយោគជាដើមថា **យានីធ ភូតានិ សមាគតានិ** ពួកភូតណា ដែលមកជួបជុំក្នុងទីនេះ ដូច្នេះ ។

ប្រើក្នុងអត្ថថា **ធាតុ ៤** ដូចក្នុងប្រយោគនេះថា **ចត្តារោ ខោ ភិក្ខុ មហាភូតា ហេតុ** ម្នាលភិក្ខុ មហាភូតទាំង ៤ ជាហេតុ មហាភូតទាំង ៤ ជាបច្ច័យ ដូច្នេះជាដើម ។

ប្រើក្នុងអត្ថថា **មានពិត** ដូចក្នុងប្រយោគជាដើម **ភូតស្មឹ បាចិត្តិយំ** ភិក្ខុណាមួយ ប្រាប់ឧត្តរិមនុស្សធម្មដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយៈ ព្រោះឧត្តរិមនុស្សធម្មនោះ ភិក្ខុមានពិតមែន ។

ប្រើក្នុងអត្ថថា **ព្រះខីណាស្រព** ដូចក្នុងប្រយោគជាដើមថា **យោ ច កាលឃសោ ភូតោ** បុគ្គលណា ជាអ្នកទំពាស៊ីនូវពេលវេលា ដូច្នេះ ។

ប្រើក្នុងអត្ថថា **សត្វ** ដូចក្នុងប្រយោគជាដើមថា **សព្វេវ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ** សត្វទាំងឡាយនេះឯង តែងលះបង់រាងកាយទុកក្នុងលោក ដូច្នេះ ។

ប្រើក្នុងអត្ថថា **ដើមឈើ** ដូចក្នុងប្រយោគជាដើមថា **ភូតគាមបាតព្យតាយ** ភិក្ខុធ្វើភូតគាម មានឈើ និងស្មៅជាដើមឲ្យវិនាស ត្រូវអាបត្តិបាចិត្តិយៈ ដូច្នេះ ។

តែក្នុងទីនេះ **ភូត** សព្ទនេះ រមែងប្រើក្នុងសត្វទាំងឡាយ ។ ឯ **ភូត** សព្ទ មិនប្រព្រឹត្តទៅផ្សេងគ្នាឡើយ ព្រោះថា សត្វទាំងឡាយទាបជាងជាន់ចាតុម្មហារាជ លោកបំណងយកថា **ភូត** ក្នុងទីនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភូតេ ភូតតោ សញ្ជានាតិ** ជាដើម មានន័យដូចពោលហើយនោះឯង ។

ក្នុងពាក្យជាដើមថា **ភូតេ មញ្ញតិ** គប្បីប្រកបការសម្គាល់ ៣ យ៉ាង ។

ការសម្គាល់ ៣ យ៉ាង តើដូចម្តេច ពិតហើយ បុថុជ្ជននេះ ប្រកាន់យកភូតទាំងឡាយថា ស្អាត មានសេចក្តីសុខ ដោយន័យដែលពោលមកហើយថា បុគ្គលនោះ រមែងឃើញនូវគហបតី ឬគហបតីបុត្រដែលស្កប់ស្កល់មូលមិត្របម្រើដោយកាមគុណទាំង ៥ ដូច្នេះ រមែងតម្រេក គឺរមែងត្រេកអរក្នុងភូតទាំងនោះ ព្រោះឃើញ និងរមែងត្រេកត្រអាល ព្រោះបានឮ

បានហិតក្លិន បានលិទ្ធរស បានពាល់ត្រូវ និងបានជ្រាប បុថុជ្ជនរមែងសម្គាល់ក្នុងភូតទាំងឡាយ គឺការសម្គាល់ដោយអំណាចនៃតណ្ហា ដូចពណ៌នាមកដូច្នេះ ។

រមែងតាំងចិត្តទុកដើម្បីបានវត្ថុដែលខ្លួនមិនទាន់បាន ដោយន័យជាដើមថា ធ្វើម្តេចហ្ន៎ អាត្មាអញគប្បីចូលដល់ភាពជាសម្លាញ់នៃខត្តិយមហាសាលទាំង-ឡាយ ។ បុថុជ្ជនរមែងសម្គាល់ក្នុងភូតទាំងឡាយ ដោយអំណាចនៃតណ្ហា ដោយប្រការដូច្នេះ ។

តែព្រោះអាស្រ័យសម្បត្តិ និងវិបត្តិរបស់ខ្លួន និងរបស់ភូតទាំងឡាយ បុថុជ្ជនរមែងប្រកាន់ថា អញល្អជាងគេ បុថុជ្ជនរមែងសម្គាល់ភូតប្រភេទណាមួយ ក្នុងភូតទាំងឡាយថា អាក្រក់ជាងខ្លួន ឬរមែងសម្គាល់ខ្លួនថា អាក្រក់ជាងភូតប្រភេទណាមួយ រមែងសម្គាល់ភូតប្រភេទណាមួយ ថាល្អជាងខ្លួន ( ឬសម្គាល់ខ្លួនថា ល្អជាងភូតប្រភេទណាមួយ ) សម្គាល់ខ្លួនថា ស្មើគ្នានឹងភូត ឬសម្គាល់ភូតថា ស្មើគ្នានឹងខ្លួន ។ សមដូចលោកពោលទុកថា បុគ្គលពួកខ្លះក្នុងលោកនេះ កាលមុនប្រកាន់ថា ខ្លួនស្មើនឹងអ្នកដទៃដោយជាតិ ។បេ។ ឬដោយវត្ថុឯណានីមួយ ក្រោយមក ត្រឡប់ជាសម្គាល់ខ្លួនថា ប្រសើរជាងគេ ត្រឡប់សម្គាល់អ្នកដទៃថា ថោកទាបជាងខ្លួន មានះបែបនេះ លោកហៅថា មានាតិមានះ ។ បុថុជ្ជន រមែងសម្គាល់ក្នុងភូតទាំងឡាយ គឺការសម្គាល់ដោយអំណាចនៃមានះ ដូចពណ៌នាមកដូច្នេះ ។

បុថុជ្ជនសម្គាល់ថា ភូតទាំងឡាយទៀង ស្ថិតស្ថេរ ពិតប្រាកដ មាន

ធម្មតា មិនប្រែប្រួល ឬសម្គាល់ថា សត្វទាំងពួង ប្រាណទាំងពួង ភូតទាំងពួង ជីវៈទាំងពួង មិនមានអំណាច មិនមានកម្លាំង មិនមានសេចក្ដីព្យាយាម ដែលបង្អោនទៅកាន់ការៈ គឺជួបនូវគ្រោះអាក្រក់ គ្រោះល្អ រមែងសោយសុខទុក្ខ ក្នុងអភិជាតិ ៦ នោះឯង ឈ្មោះថា រមែងសម្គាល់ដោយការសម្គាល់ ដោយអំណាចនៃទិដ្ឋិ ។ បុថុជ្ជនរមែងសម្គាល់ក្នុងភូតទាំងឡាយ ដោយការសម្គាល់ ៣ យ៉ាង ដោយប្រការដូច្នេះ ។

បុថុជ្ជន រមែងសម្គាល់ក្នុងភូតទាំងឡាយដូចម្ដេច គឺសង្ឃឹមការកើតឡើងនៃខ្លួន ឬការកើតសេចក្ដីសុខដល់ខ្លួន ក្នុងភូតទាំងឡាយនោះៗ បុថុជ្ជនរមែងសម្គាល់ក្នុងភូតទាំងឡាយ ដោយការសម្គាល់ ដោយអំណាចនៃតណ្ហា ដូចពណ៌នាមកនេះ ។ ឬកាលសង្ឃឹមការកើតឡើងក្នុងភូតទាំងឡាយ ទើបឲ្យទាន សមាទានសីល ធ្វើនូវឧបោសថកម្ម បុថុជ្ជនរមែងសម្គាល់ក្នុងភូតទាំងឡាយ ដោយអំណាចនៃតណ្ហា ដោយប្រការដូច្នេះ ។

បុថុជ្ជនទាញយកភូតទាំងឡាយ ដោយការប្រកាន់រួមគ្នា រមែងសម្គាល់ភូតទាំងឡាយពួកខ្លះ ក្នុងបណ្ដាភូតទាំងនោះថា ល្អជាង ឬសម្គាល់សត្វ ពួកខ្លះថា ស្មើគ្នា ឬអាក្រក់ជាង បុថុជ្ជនរមែងសម្គាល់ក្នុងភូតទាំងឡាយ ដោយអំណាចនៃមានះ ដោយប្រការដូចពោលមកនេះ ។

ម្យ៉ាងទៀត បុថុជ្ជនរមែងសម្គាល់ភូតពួកខ្លះថា ទៀង ស្ថិតស្ថេរ រមែងសម្គាល់ភូតពួកខ្លះថា មិនទៀង មិនស្ថិតស្ថេរ ឬរមែងសម្គាល់ថា សូម្បីអញ រមែងជាភូតប្រភេទណាមួយ ក្នុងបណ្ដាភូតទាំងឡាយដូច្នេះ ឈ្មោះថា

សម្គាល់ក្នុងភូតទាំងឡាយ ដោយអំណាចនៃទិដ្ឋិ ដោយប្រការដូច្នេះឯង ។

ក្នុងបទថា **ភូតោ មញ្ញតិ** មានវិនិច្ឆ័យដូចតទៅនេះ បុថុជ្ជនកាលសម្គាល់ការកើតឡើងនៃខ្លួន ឬបុគ្គលដទៃ ព្រមទាំងទ្រព្យ អំពីភូតប្រភេទណាមួយ គប្បីជ្រាបថា រមែងសម្គាល់ចាកភូតដូច្នេះ ។ នេះជាការសម្គាល់ដោយអំណាចទិដ្ឋិរបស់បុថុជ្ជននោះ ។ កាលបុថុជ្ជននោះ ញុំាងសេចក្តីស្នេហា និងមានះឲ្យកើតឡើងក្នុងវត្ថុ ដែលសម្គាល់ដោយអំណាចនៃទិដ្ឋិនោះឯង គប្បីជ្រាបថា ជាការសម្គាល់ដោយអំណាចនៃតណ្ហា និងមានះផងដែរ ។

ក្នុងបទថា **ភូតេ មេតិ មញ្ញតិ** នេះ រមែងបានទូវការសម្គាល់ដោយអំណាចនៃតណ្ហាណាមួយ ដូច្នេះ ។ ការសម្គាល់ដោយអំណាចនៃតណ្ហានេះ គប្បីជ្រាបថា រមែងប្រព្រឹត្តទៅដោយការប្រកាន់ ថាជារបស់អញ ដោយន័យជាដើមថា បុត្ររបស់អញ ធីតារបស់អញ ពពែ និងចៀមរបស់អញ មាន់ និងជ្រូករបស់អញ ដំរី គោ ទន្សាយ និងត្មារបស់អញ ដូច្នេះ ។

បទថា **ភូតេ អភិនន្ទតិ** មានន័យដូចពោលហើយយ៉ាងនេះឯង ។

ក្នុងបទថា **អបរិញ្ញាតំ តស្ស** នេះ មានវិនិច្ឆ័យដូច្នេះ ការបញ្ញត្តភូតទាំងឡាយ ព្រោះអាស្រ័យសង្ខារទាំងឡាយណា ព្រោះមិនកំណត់ដឹងសង្ខារទាំងឡាយនោះ ភូតទាំងឡាយគប្បីជ្រាបថា ឈ្មោះថា បុថុជ្ជនមិនកំណត់ដឹង ដូច្នេះ ។ ឯការប្រកបសេចក្តី គប្បីធ្វើទុកដោយន័យ ដូចពោលហើយនោះឯង ។

ព្រះមានព្រះភាគ កាលសម្តែងទីតាំងនៃការសម្គាល់ ដោយអំណាចនៃ

សង្ខារ និងដោយអំណាចនៃសត្វ ដោយសង្ខេបយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្ដែងទីតាំងនោះដោយពិស្ដារ ដោយប្រភេទជាដើមថា ភូមិវិសេស ទើបត្រាស់ថា **ទេវេ ទេវតោ** ដូច្នេះជាដើម ។

ក្នុងពាក្យនោះ មានរូបវិគ្គហៈដូច្នេះថា ឈ្មោះថា **ទេវា** ព្រោះអត្ថថា រមែងលេង អធិប្បាយថា សុខស្រួល និងរុងរឿងដោយកាមគុណ ៥ ឬ ដោយឫទ្ធិរបស់ខ្លួន ។ ទេពទាំងនោះ មាន ៣ ពួក គឺសម្មតិទេព ឧបបត្តិ-ទេព និងវិសុទ្ធិទេព ។ ព្រះរាជា ព្រះមហេសី និងព្រះរាជកុមារ ឈ្មោះថា **សម្មតិទេវា** ទេពដែលខ្ពស់ជាងនោះ តាំងអំពីទេវតាជាន់ចាតុម្មហារាជ ឈ្មោះថា **ឧបបត្តិទេវា** ។ ព្រះអរហន្តខីណាស្រពទាំងឡាយ ឈ្មោះថា **វិសុទ្ធិទេវា** ។ តែក្នុងទីនេះ គប្បីឃើញថា លោកបំណងយកឧបបត្តិទេព ។ ឧបបត្តិទេព ទាំងនោះ នឹងឃើញថា មិនប្លែកគ្នាឡើយ គឺវៀរមារ មួយអន្លើដោយបរិស័ទ ក្នុងទេវលោក ជាន់បរនិម្មិតវសវត្តីចេញ ទេវតាកាមាវចរដ៏សេស ៦ ជាន់ លោកបំណងយកថា ជា **ទេវ** ក្នុងទីនេះ ។ ពណ៌នាអត្ថទាំងអស់ ក្នុង សេចក្ដីនោះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងភូតវារៈនោះឯង ។

ក្នុងបទថា **បជាបតឹ** នេះ មារគប្បីជ្រាបថាជា បជាបតិ ។ តែអាចារ្យ ពួកខ្លះពោលថា ពាក្យថា បជាបតិនេះ ជាឈ្មោះរបស់ទេវមហារាជជាដើម ដែលជាធំជាងទេវតានោះៗ ។ ពាក្យនោះលោកបដិសេធទុកក្នុងមហាអដ្ឋកថា ថាមិនត្រឹមត្រូវ ព្រោះមហារាជជាដើមនោះ លោកកាន់យកដោយ **ទេវ** សព្ទ នោះឯង ។ ឯមារនោះឯង លោកបំណងយកថា ជាបជាបតិក្នុងទីនេះ ដោយ

ភាពជាធំជាងបជា ពោល គឺពួកសត្វ ។

សួរថា មារនោះ រមែងនៅក្នុងទីណា ឆ្លើយថា រមែងនៅក្នុងទេវលោក ជាន់បរនិម្មិតវសវត្តី ។

ពិតហើយ មារវសវត្តីគ្រងរាជ្យនៅក្នុងទេវលោកនោះ ។ អាចារ្យពួកខ្លះពោលថា មារប្រថាប់គ្រប់គ្រងភាពជាធំក្នុងបរិស័ទរបស់ខ្លួន ក្នុងមួយចំណែករបស់ទេវលោកនោះ ដូចរាជឱរសរបស់ព្រះរាជាដ៏រុងរឿង ប្រថាប់នៅក្នុងចុងដែននៃរាជាណាចក្រ ដូច្នោះ ។ ក្នុងសេចក្តីនេះ គប្បីជ្រាបថា លោកចាត់យកបរិស័ទមារចូលដោយ **មារ** សព្ទនោះឯង ។ ឯក្នុងពាក្យនេះក្នុងន័យនៃការពង្រីកសេចក្តី មានអធិប្បាយដូច្នេះថា បុថុជ្ជនបានឃើញក្តីបានឮក្តី នូវបជាបតិដែលមានពណ៌សម្បុរល្អ មានអាយុវែង មានសេចក្តីសុខច្រើន រមែងជាប់ជំពាក់ក្នុងរាជសម្បត្តិ ដោយអំណាចនៃតណ្ហា ឬតាំងចិត្តដើម្បីនឹងបានវត្ថុដែលខ្លួនមិនទាន់បាន ដោយន័យជាដើមថា ធ្វើម្តេចហ្ន៎ អញគប្បីចូលដល់ភាពជាសម្មាញ់នៃបជាបតី ឈ្មោះថា រមែងសម្គាល់បជាបតីដោយអំណាចនៃតណ្ហា តែកាលបុថុជ្ជនដល់នូវភាពជាបជាបតីហើយ ញុំាងមានះឲ្យកើតឡើងថា អញជាធំ ជាអធិបតីជាងបជាទាំងឡាយ គប្បីជ្រាបថា ឈ្មោះថា រមែងសម្គាល់បជាបតី គឺការសម្គាល់ដោយអំណាចនៃមានះ ។

តែកាលបុថុជ្ជនសម្គាល់ថា បជាបតិទៀង ស្ថិតស្ថេរ ឬដាច់សូន្យ វិនាស ឬមិនមានអំណាច មិនមានកម្លាំង មិនមានសេចក្តីព្យាយាម បង្អោនទៅកាន់ការជួបជោគល្អ ជោគកាច រមែងសោយសុខទុក្ខក្នុងអភិជាតិ ៦ នោះឯង

គប្បីជ្រាបថា ឈ្មោះថា សម្គាល់បជាបតិដោយអំណាចនៃទិដ្ឋិ ។

តែក្នុងពាក្យថា បជាបតិនេះ ការសម្គាល់ដោយអំណាចនៃទិដ្ឋិប្រភេទណាមួយនោះឯង រមែងត្រូវ ។ គប្បីជ្រាបការប្រព្រឹត្តទៅនៃការសម្គាល់នោះយ៉ាងនេះ ។ បុគ្គលខ្លះក្នុងលោកនេះ រមែងសម្គាល់ថា ធម៌ណា មានក្នុងបជាបតិ ធម៌ទាំងអស់នោះ ទៀង ស្ថិតស្ថេរ ជាថាវរៈ មិនមានការប្រែប្រួលជាធម្មតា ។ ប្រការមួយទៀត រមែងសម្គាល់ថា បាបរមែងមិនមានក្នុងបជាបតិ កម្មដ៏លាមកទាំងឡាយ រមែងមិនមានក្នុងបជាបតិនោះ ។

ក្នុងបទថា **បជាបតិំ** នេះ រមែងបាននូវការសម្គាល់ទាំង ៣ ។

សម្គាល់ដូចម្តេច គឺបុគ្គលពួកខ្លះក្នុងលោកនេះ រមែងសម្គាល់កាលដែលខ្លួន ឬអ្នកដទៃ ព្រមទាំងទ្រព្យសកើតឡើង អំពីបជាបតិ នេះហៅថាសម្គាល់ដោយអំណាចនៃទិដ្ឋិរបស់បុគ្គលនោះ ។

កាលបុគ្គលនោះញុំាងសេចក្តីស្នេហា និងមានះឲ្យកើតឡើងក្នុងវត្ថុដែលសម្គាល់ដោយអំណាចនៃទិដ្ឋិនោះឯង គប្បីជ្រាបថា ជាការសម្គាល់ដោយអំណាចនៃតណ្ហា និងមានះ ។

ក្នុងបទថា **បជាបតី មេ** នេះ រមែងបាននូវការសម្គាល់ ដោយអំណាចនៃតណ្ហាប្រភេទណាមួយនោះឯង ។ ការសម្គាល់ដោយអំណាចនៃតណ្ហានេះគប្បីជ្រាបថា រមែងប្រព្រឹត្តទៅដល់បុគ្គលដែលប្រកាន់ថា របស់អញ ដោយន័យជាដើមថា បជាបតិជាគ្រូរបស់អញ ជាម្ចាស់របស់អញ ដូច្នេះ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

ក្នុងបទថា **ព្រហ្មំ ព្រហ្មតោ** មានវិនិច្ឆ័យដូច្នេះ ឈ្មោះថា ព្រហ្ម ព្រោះអត្ថថា ចម្រើនហើយដោយគុណវិសេសនោះៗ ។

ម្យ៉ាងទៀត ទេវមហាព្រហ្មក្តី ព្រះតថាគតក្តី ព្រាហ្មណ៍ក្តី មាតាបិតាក្តី វត្ថុដែលប្រសើរបំផុតក្តី លោកហៅថា ព្រហ្ម ។

ពិតហើយ មហាព្រហ្ម លោកហៅថា ព្រហ្ម ដូចក្នុងប្រយោគជាដើមថា **សហស្សោ ព្រហ្មា ទ្វិសហស្សោ ព្រហ្មា** សហស្សព្រហ្ម ទ្វិសហស្សព្រហ្ម ជាដើម ។

ព្រះតថាគត លោកក៏ហៅថា ព្រហ្ម ដូចក្នុងប្រយោគនេះថា **ព្រហ្មាតិ ខោ ភិក្ខវេ តថាគតស្សេតំ អធិវចនំ** ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រហ្ម នេះ ជាឈ្មោះរបស់តថាគតនោះឯង ។

ព្រាហ្មណ៍ លោកក៏ហៅថា ព្រហ្ម ដូចក្នុងប្រយោគនេះថា

**តមោនុទោ ពុទ្ធោ សមន្តចក្ខុ លោកន្តគូ សព្វភវាតិវត្តោ**
**អនាសវោ សព្វទុក្ខប្បហីនោ សច្ចវ្ហយោ ព្រហ្មុបាសិតោ មេ ។**

ព្រះពុទ្ធ ទ្រង់បន្ទោបង់ងងឹត មានសមន្តចក្ខុ ទ្រង់ដល់ទីបំផុតលោក ប្រព្រឹត្តកន្លងហើយនូវភពទាំងពួង មិនមានអាសវៈ ទ្រង់លះបង់ទុក្ខទាំងពួងហើយ មានព្រះនាមដ៏ទៀងទាត់ ជាបុគ្គលដែលព្រហ្មបម្រើហើយ បានចូលទៅគាល់ព្រះមានព្រះភាគហើយ ដូច្នេះ ។

មាតា បិតា លោកហៅថា ព្រហ្ម ដូចក្នុងប្រយោគនេះថា **ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ** មាតា បិតា បណ្ឌិតហៅថា ព្រហ្មផង

បុញ្ញចារ្យផង ។ វត្ថុដែលប្រសើរបំផុត លោកហៅថា **ព្រហ្ម** ដូចក្នុងប្រយោគនេះថា **ព្រហ្មចក្កំ បវត្តេតិ** ព្រះមានព្រះភាគ ទ្រង់ញ៉ាំងចក្រដ៏ប្រសើរបំផុតឲ្យប្រព្រឹត្តទៅ ដូច្នេះ ។

តែក្នុងទីនេះ លោកបំណងយកព្រហ្មដែលកើតឡើងដើមកប្ប ។ ម្យ៉ាងទៀត ព្រហ្មបុរោហិត និងព្រហ្មបារិសជ្ជ គប្បីជ្រាបថា លោកកាន់យកដោយ **ព្រហ្ម** សព្ទនេះឯង ។ តែការពណ៌នាអត្ថក្នុងសេចក្តីនេះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងបឋវីវារៈនោះឯង ។

ក្នុងវារៈពោលអំពីអាភស្សរព្រហ្ម គប្បីជ្រាបវិនិច្ឆ័យដូច្នេះ រស្មីផ្សាយចេញអំពីរាងកាយរបស់ព្រហ្មទាំងនោះ ហាក់ដូចជាដាច់ធ្លាក់ទៅ ដូចគ្នានឹងអណ្តាតភ្លើងដែលដាច់ធ្លាក់ទៅអំពីគប់ភ្លើង ដូច្នេះ ព្រោះហេតុនោះ ទើបព្រហ្មទាំងនោះ ឈ្មោះថា អាភស្សរា ។ ដោយការកំណត់អាភស្សរព្រហ្មទាំងនោះ ទើបលោកកំណត់យកភូមិរបស់ទុតិយជ្ឈានទាំងអស់ផងដែរ ។ ព្រហ្មដែលស្ថិតនៅក្នុងជាន់តែមួយទាំងអស់នោះឯង គប្បីជ្រាបថា បានដល់ បរិត្តាភាព្រហ្ម អប្បមាណាភាព្រហ្ម និងអាភស្សរាព្រហ្ម ។

ក្នុងវារៈពោលអំពីសុភកិណ្ហព្រហ្ម គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ព្រហ្ម ឈ្មោះថា **សុភកិណ្ហា** ព្រោះអត្ថថា ធ្លៀលធ្លាត់ទៅដោយពណ៌ ស្រស់ស្អាតល្អ គឺដោយរស្មីកាយដ៏សោភា ទើបល្អដូចមាស ភ្លឺព្រោងព្រាយ ដូចគេរក្សាទុកក្នុងប្រអប់មាសដ៏ក្រាស់ ។ ដោយការកំណត់យកសុភកិណ្ហព្រហ្មទាំងនោះ ឈ្មោះថា លោកកំណត់យកភូមិរបស់តតិយជ្ឈានទាំងអស់ផងដែរ ។ ព្រហ្ម

ដែលស្ថិតនៅក្នុងជាន់តែមួយទាំងអស់នោះឯង គប្បីជ្រាបថា បានដល់ បរិត្ត-សុភព្រហ្ម អប្បមាណសុភព្រហ្ម សុភកិណ្ហព្រហ្ម ។

ក្នុងវារៈពោលអំពីវេហប្ផលព្រហ្ម គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ព្រហ្មដែលឈ្មោះថា **វេហប្ផលា** ព្រោះអត្ថថា មានផលដ៏បរិបូណ៌ លោកពោលថា បានដល់ ព្រហ្មជាន់ចតុត្ថជ្ឈាន ។ ឯការអធិប្បាយពង្រីកសេចក្តីប្រកបក្នុងវារៈទាំង ៣ នេះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងកុសលវារៈនោះឯង ។

ក្នុងវារៈពោលអំពីអភិភូ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ដែលឈ្មោះថា **អភិភូ** ព្រោះអត្ថថា គ្របសង្កត់ ។ សួរថា គ្របសង្កត់នូវអ្វី ឆ្លើយថា គ្របសង្កត់នូវអរូបក្ខន្ធ ៤ ។ ពាក្យថា **អភិភូ** នោះ ជាឈ្មោះរបស់អសញ្ញីភព ។ ពួកទេវៈ គឺព្រហ្មអសញ្ញីសត្វ ស្ថិតនៅក្នុងជាន់តែមួយនឹងវេហប្ផលាព្រហ្ម ( តែញែក ) ស្ថិតនៅក្នុងឱកាសមួយដោយឡែក លោកកើតឡើងដោយឥរិយាបថណា លោកស្ថិតនៅដោយឥរិយាបថនោះឯង ដរាបដល់អាយុក្ខ័យ ដូចគ្នានឹងរូបចិត្រកម្ម ក្នុងទីនេះ លោកសំដៅដល់ វេហប្ផលព្រហ្ម និងអសញ្ញីសត្វទាំងអស់នោះ ដោយពាក្យថា **អភិភូ** ។ អាចារ្យពួកខ្លះសរសើរព្រហ្មដែលជាធំក្នុងជាន់នោះៗ ( ថាអភិភូ ) ដោយន័យជាដើមយ៉ាងនេះថា សហស្ស-ព្រហ្ម[១] ឈ្មោះថា **អភិភូ** ។ តែគប្បីជ្រាបថា ពាក្យរបស់អាចារ្យពួកនោះមិនត្រឹមត្រូវ ព្រោះព្រហ្មជាធំនោះ លោកប្រារព្ធកាន់យកដោយសព្ទថា ព្រហ្មហើយនោះឯង ដូច្នេះ ។

---

១- ព្រហ្មដែលមានរស្មីផ្សាយទៅបាន ១០០០ ចក្រវាល ។

ម្យ៉ាងទៀត ក្នុងវារៈនេះ គប្បីជ្រាបអត្ថនៃការអធិប្បាយពង្រីកសេចក្តីថា បុថុជ្ជនបានស្តាប់ហើយថា ព្រហ្មអភិភូ មានពណ៌សម្បុរល្អ មានអាយុវែង ដូច្នេះ ហើយកើតសេចក្តីត្រេកអរពេញចិត្តក្នុងព្រហ្មអភិភូនោះ ឈ្មោះថា រមែងសម្គាល់ព្រហ្មអភិភូ ដោយការសម្គាល់ដោយអំណាចតណ្ហា ឬទោះតាំងចិត្ត ( ប្រាថ្នា ) ដើម្បីឲ្យបាន ( កើតក្នុងព្រហ្មអភិភូ ) ដែលខ្លួនមិនទាន់បាន ដោយន័យជាដើមថា ធ្វើម្តេចហ្ន៎ អញគប្បីចូលដល់ភាពជាសម្មាញ់នៃព្រហ្មអភិភូ ឈ្មោះថា រមែងសម្គាល់នូវព្រហ្មអភិភូ ដោយអំណាចតណ្ហា ម្យ៉ាងទៀត កាលសម្គាល់ខ្លួនថា អាក្រក់ជាង ( ព្រហ្មអភិភូ ) ឬសម្គាល់ថា ព្រហ្មអភិភូល្អជាងខ្លួន ឈ្មោះថា រមែងសម្គាល់ព្រហ្មអភិភូដោយអំណាចមានះ កាលប្រកាន់ដោយន័យជាដើមថា ព្រហ្មអភិភូទៀង ស្ថិតស្ថេរ ឈ្មោះថា រមែងសម្គាល់ព្រហ្មអភិភូដោយអំណាចទិដ្ឋិ ។ ពាក្យដ៏សេសមានន័យដូចពោលហើយ ក្នុងបឋវីវារៈនោះឯង ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងទេវលោក ដោយលំដាប់យ៉ាងនេះ កាលទ្រង់សម្តែងអសញ្ញីភព ដោយពាក្យថា **អភិភូ** ឥឡូវនេះ ព្រោះកថាពោលដោយវេហប្ផលា និងទេវតា គឺព្រះអនាគាមី និងព្រះខីណាស្រពជាន់សុទ្ធាវាស ដែលតាំងនៅក្នុងចំណែកវេហប្ផលា ឬព្រោះហេតុដែលទេវតាទាំងនោះ មានអាយុ តាំងនៅ ២០០០-៣០០០ កប្ប រមែងមាន ព្រោះក្នុងវេលាដែលព្រះពុទ្ធទ្រង់កើតឡើងប៉ុណ្ណោះ បើព្រះពុទ្ធទាំងឡាយមិនកើតឡើងរហូតមួយអសង្ខេយ្យកប្ប ក្នុងកាលនោះ ភូមិនោះទទេ ភពជាន់សុទ្ធាវាស រមែង

មានចំពោះកាលព្រះពុទ្ធទាំងឡាយកើតឡើងប៉ុណ្ណោះ ដូចទីប្រថាប់ទុកសម្រាប់ព្រះរាជា ដូច្នោះ ដោយហេតុនោះឯង ទើបភូមិនោះលោកមិនបានចាត់ជាវិញ្ញាណដ្ឋិតិ ទាំងមិនបានចាត់ជាសត្តាវាស តែការសម្គាល់ទាំងនេះមានគ្រប់កាល ដូច្នោះ កាលទ្រង់សម្ដែងភូមិនៃការសម្គាល់ទាំងនោះ ដែលមានទៅគ្រប់កាល ទើបព្រះមានព្រះភាគ លះសុទ្ធាវាស ហើយត្រាស់ពាក្យជាដើមថា **អាកាសានញ្ចាយតនំ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាកាសានញ្ចាយតនំ** បានដល់ ខន្ធ ៤ ដែលជាកុសលវិបាក និងកិរិយាដែលប្រព្រឹត្តទៅក្នុងអាកាសានញ្ចាយតនភូមិនោះ ។ ខន្ធទាំងឡាយនោះ គប្បីឃើញថា កើតឡើងក្នុងភូមិនោះឯង ព្រោះកថានេះ ជាការពោលដល់កំណត់កត ។ ក្នុងវិញ្ញាណញ្ចាយតនៈជាដើម ក៏មានន័យដូច្នេះ ក្នុងបណ្ដាវារៈ ៤ នោះឯង ការពង្រីកសេចក្ដី គប្បីជ្រាបដោយន័យដែលពោលទុកក្នុងអភិភូវារៈ និងការសម្គាល់ដោយអំណាចនៃមានះ ក្នុងសេចក្ដីនេះ រមែងប្រើបាន ដោយន័យដែលពោលទុកហើយ ក្នុងបជាបតិវារៈ ។

## អត្ថរបស់ ទិដ្ឋ សព្វជាដើម

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងទីតាំងនៃការសម្គាល់ ដោយប្រភេទមានការប្លែកគ្នារវាងភូមិជាដើមនោះ ដោយពិស្ដារយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសង្គ្រោះសម្ដែងប្រភេទនៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលទាក់ទងក្នុងសក្កាយទិដ្ឋិ ដែលជាទីតាំងនៃការសម្គាល់ទាំងអស់ ដោយហេតុ ៤ យ៉ាង មានរូបារម្មណ៍ដែលឃើញជាដើម ទើបត្រាស់ពាក្យជាដើមថា **ទិដ្ឋំ**

**ទិដ្ឋតោ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទិដ្ឋំ** សំដៅដល់វត្ថុដែលមើលឃើញដោយមំសចក្ខុះ ទិព្វចក្ខុះ ។ បទថា **ទិដ្ឋំ** នោះ ជាឈ្មោះរបស់រូបាយតនៈ ។ បណ្ដាបទទាំងនោះ បទថា **ទិដ្ឋំ មញ្ញតិ** សេចក្ដីថា បុថុជ្ជនរមែងសម្គាល់ដោយការសម្គាល់ទាំង ៣ ។

សួរថា សម្គាល់ដូចម្ដេច ឆ្លើយថា បុថុជ្ជនកាលមើលរូបាយតនៈដោយសុភសញ្ញា និងសុខសញ្ញា ឈ្មោះថា រមែងញុំាងឆន្ទរាគៈឲ្យកើតក្នុងរូបាយតនៈនោះ គឺរមែងត្រេកអរ រីករាយនូវរូបាយតនៈនោះ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សត្វត្រេកអរ ជាប់ជំពាក់ សញ្ជប់ជ្រប់ស៊ប់នៅក្នុងរូបស្រីហើយ សត្វពួកនោះឈ្មោះថា លុះក្នុងអំណាចនៃរូបស្រី រមែងសោកស្ដាយ អស់កាលយូរអង្វែងដូច្នេះ ។ បុថុជ្ជន ឈ្មោះថា រមែងសម្គាល់រូបារម្មណ៍ ដែលខ្លួនឃើញហើយដោយការសម្គាល់ដោយអំណាចនៃតណ្ហាយ៉ាងនេះ ឬបុថុជ្ជនគប្បីហួងហែងក្នុងរូបយ៉ាងនេះថា សូមរូបរបស់អញគប្បីដូច្នេះសព្វកាល ឬបុថុជ្ជនកាលសង្ឃឹមរូបសម្បត្តិ រមែងឲ្យទាន សេចក្ដីពិស្ដារដូចពោលមកដូច្នេះ ។ បុថុជ្ជនរមែងសម្គាល់រូបារម្មណ៍ ដែលខ្លួនឃើញហើយ ដោយការសម្គាល់ដោយអំណាចនៃតណ្ហាយ៉ាងនេះ ។

ម្យ៉ាងទៀត បុថុជ្ជនអាស្រ័យរូបសម្បត្តិ និងរូបវិបត្តិរបស់ខ្លួន និងរបស់បុគ្គលដទៃ រមែងញុំាងមានះឲ្យកើត គឺរមែងសម្គាល់រូបារម្មណ៍ដែលខ្លួនឃើញ

ដោយការសម្គាល់ ដោយអំណាចនៃមានះយ៉ាងនេះថា អញល្អជាងបុគ្គលនេះ អញស្មើនឹងបុគ្គលនេះ ឬអញអន់ជាងបុគ្គលនេះ ដូច្នេះ ។

ម្យ៉ាងទៀត បុថុជ្ជនរមែងសម្គាល់រូបាយតនៈថា ទៀង ស្ថិតស្ថេរ ពិតប្រាកដ រមែងសម្គាល់ថា ជាអត្តា ទាក់ទងក្នុងអត្តា រមែងសម្គាល់ក្នុងរូបាយតនៈដែលជាមង្គល ថាជាអពមង្គល បុថុជ្ជនរមែងសម្គាល់រូបាយតនៈដែលខ្ញុំនឃើញ ដោយការសម្គាល់ដោយអំណាចនៃទិដ្ឋិ ដោយប្រការដូច្នេះ ។

បុថុជ្ជន ឈ្មោះថា រមែងសម្គាល់រូបាយតនៈដែលខ្ញុំនឃើញ ដោយការសម្គាល់ទាំង ៣ ដោយប្រការដូច្នេះ ។

សួរថា រមែងសម្គាល់រូបាយតនៈដែលខ្ញុំនឃើញហើយដូចម្តេច ឆ្លើយថា បុថុជ្ជនកាល សម្គាល់ដោយន័យពិចារណាឃើញអត្តាក្នុងរូប ឈ្មោះថា សម្គាល់ក្នុងរូបាយតនៈដែលខ្ញុំនឃើញ ។ សូម្បីសម្គាល់ថា រាគៈជាដើម រមែងកើតមាន ក្នុងរូប ដូចគ្នានឹងទឹកដោះ កើតមានក្នុងកន្សោមដោះ ដូច្នោះ ឈ្មោះថា រមែងសម្គាល់ក្នុងរូបាយតនៈដែលខ្ញុំនឃើញ ។ នេះឈ្មោះថា ការសម្គាល់ដោយអំណាចនៃទិដ្ឋិរបស់បុថុជ្ជននោះ ។

ម្យ៉ាងទៀត កាលបុថុជ្ជននោះញ៉ាំងសេចក្តីស្នេហា និងមានះឲ្យកើតឡើងក្នុងវត្ថុដែលសម្គាល់ដោយអំណាចនៃទិដ្ឋិនោះឯង គប្បីជ្រាបថា ជាការសម្គាល់ដោយអំណាចនៃតណ្ហា និងមានះផងដែរ ។ បុថុជ្ជន ឈ្មោះថា សម្គាល់ក្នុងរូបាយតនៈដែលខ្ញុំនឃើញ ដោយប្រការដូច្នេះ ។ ពាក្យដ៏សេសគប្បីជ្រាបតាមន័យ ដែលពោលមកហើយក្នុងបឋវីវារៈ ។

បទថា **សុតំ** សំដៅដល់បានឮដោយមំសសោតខ្លះ ទិព្វសោតខ្លះ ។ បទថា **សុតំ** នោះ ជាឈ្មោះរបស់សទ្ទាយតនៈ ។

បទថា **មុតំ** បានដល់ ជ្រាប និងដឹងហើយទទួលយក អធិប្បាយថា ចូលទៅប៉ះពាល់ ។ លោកពោលអធិប្បាយទុកថា ដឹងច្បាស់ ព្រោះការប៉ះគ្នានៃឥន្ទ្រិយ និងអារម្មណ៍ទាំងឡាយ ។

បទថា **មុតំ** នោះ ជាឈ្មោះរបស់គន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈ ។

បទថា **វិញ្ញាតំ** ប្រែថា ដឹងតាមផ្លូវចិត្ត ។ បទថា **វិញ្ញាតំ** ជាឈ្មោះរបស់អាយតនៈ ៧ ដ៏សេស ។ ម្យ៉ាងទៀត ជាឈ្មោះនៃធម្មារម្មណ៍ក៏បាន តែក្នុងទីនេះបានចំពោះអារម្មណ៍ ដែលទាក់ទងក្នុងកាយរបស់ខ្លួន គឺសក្កាយទិដ្ឋិ ។

ក្នុងសេចក្តីនេះ គប្បីជ្រាបសេចក្តីពិស្តារ ដោយន័យដែលពោលហើយក្នុងទិដ្ឋវារៈ ។

## អធិប្បាយ ឯកត្តំ នានត្តំ

ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រភេទនៃសក្កាយទិដ្ឋិទាំងអស់ដោយអារម្មណ៍ ៤ ប្រការ មានរូបារម្មណ៍ដែលខ្លួនឃើញហើយជាដើមយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងប្រភេទនៃសក្កាយទិដ្ឋិនោះឯងចេញជា ២ ប្រការ គឺដោយវារៈរបស់លោកដែលជាអ្នកចូលសមាបត្តិ ១ របស់លោកដែលមិនបានចូលសមាបត្តិ ១ ទើបត្រាស់បទជាដើមថា **ឯកត្តំ នានត្តំ** ដូច្នេះ ។

បទថា **ឯកត្តំ** នេះ ព្រះអង្គទ្រង់សម្តែងវាទៈរបស់អ្នកចូលសមាបត្តិ ។

បទថា **នានត្តំ** នេះ ទ្រង់សម្តែងវាទៈរបស់បុគ្គលអ្នកចូលសមាបត្តិ ។

ក្នុង ២ បទនោះ មានអត្ថចំពោះពាក្យដូច្នេះ ភាវៈតែ ១ ឈ្មោះថា **ឯកត្តំ** ភាវៈដែលផ្សេងគ្នា ឈ្មោះថា **នានត្តំ** ។

ឯការពង្រីកសេចក្តីក្នុងបទនេះ បណ្ឌិតគប្បីចែកវាទៈរបស់បុគ្គលដែលចូលសមាបត្តិដោយខន្ធ ៤ និងរបស់បុគ្គលដែលមិនបានចូលសមាបត្តិដោយខន្ធ ៥ ហើយពិចារណាជ្រាបតាមសមគួរ ដោយសាសនន័យជាដើមថា បុថុជ្ជនរមែងពិចារណាឃើញរូបថា ជាអត្តា និងដោយន័យនៃអដ្ឋកថាដែលលោកពោលទុកក្នុងបឋវីវាទៈជាដើម ។ ឯអាចារ្យពួកខ្លះ រមែងពោលឯកត្តន័យ ដោយបទនេះថា **ឯកត្តំ** ពោលន័យដែលផ្សេងគ្នា ដោយបទនេះថា **នានត្តំ** ដូច្នេះ ។ អាចារ្យពួកដទៃពោលការប្រកាន់មាំដោយអំណាចទិដ្ឋិយ៉ាងនេះថា អត្តារមែងមានសញ្ញាដូចគ្នា មិនសាបសូន្យ កាលស្លាប់ហើយ អត្តារមែងមានសញ្ញាផ្សេងគ្នា ។ ពាក្យទាំងអស់នោះ មិនត្រឹមត្រូវឡើយ ព្រោះលោកមិនបានបំណងយកក្នុងទីនេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសក្កាយទិដ្ឋិទាំងអស់ជា ២ យ៉ាង យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងសក្កាយទិដ្ឋិនោះឯងឲ្យតែមួយ ទើបត្រាស់ពាក្យជាដើមថា **សព្វំ សព្វតោ** ដូច្នេះ ។

ឯន័យពង្រីកក្នុងសេចក្តីនេះ បណ្ឌិតគប្បីជ្រាបដូច្នេះ បុថុជ្ជនកាលពេញចិត្តក្នុងវត្ថុទាំងពួង ឈ្មោះថា រមែងសម្គាល់វត្ថុទាំងពួង ដោយអំណាចនៃ

តណ្ហា កាលសម្គាល់វត្ថុដែលខ្លួនសាងឡើង ដោយន័យជាដើមថា សត្វទាំងនេះ អញសាងឡើង ដូច្នេះ គប្បីជ្រាបថា ឈ្មោះថា រមែងសម្គាល់វត្ថុទាំងពួងដោយអំណាចនៃមានះ កាលសម្គាល់ដោយន័យជាដើមថា វត្ថុទាំងពួងមានកម្មដែលខ្លួនធ្វើទុកក្នុងកាលមុនជាហេតុ វត្ថុទាំងពួង មានការសាងឡើងដោយព្រះឦស្វរៈជាហេតុ វត្ថុទាំងពួង មិនមានហេតុ មិនមានបច្ច័យ វត្ថុទាំងពួងមាន វត្ថុទាំងពួងមិនមាន ដូច្នេះ ឈ្មោះថា សម្គាល់វត្ថុទាំងពួងដោយអំណាចនៃទិដ្ឋិ ។

សួរថា បុថុជ្ជនរមែងសម្គាល់ក្នុងវត្ថុទាំងពួងដូចម្តេច ឆ្លើយថា បុគ្គលពួកខ្លះក្នុងលោកនេះ មានការឃើញយ៉ាងនេះថា អត្តារបស់អញនេះធំ បុគ្គលនោះកំណត់លោកសន្និវាសទាំងអស់ ដោយជាឱកាសនៃអត្តានោះ រមែងសម្គាល់ថា អត្តារបស់អញនេះឯង មាននៅក្នុងលោកសន្និវាសទាំងពួង ។ នេះឈ្មោះថា ការសម្គាល់ដោយអំណាចនៃទិដ្ឋិរបស់បុគ្គលនោះ ។

កាលបុគ្គលនោះ ញុំាងសេចក្តីស្នេហាក្នុងអត្តានោះឯង ញុំាងមានះដែលមានអត្តានោះជាទីតាំងឲ្យកើតឡើងនៅក្នុងខ្លួន គប្បីជ្រាបថា ការសម្គាល់ដោយអំណាចតណ្ហា និងមានះ ( ក៏កើតឡើងដែរ ) ។ ពាក្យដ៏សេសគប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងបបរិវារៈនោះឯង ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសក្កាយទិដ្ឋិទាំងអស់ឲ្យតែមួយយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងសក្កាយទិដ្ឋិនោះឲ្យតែមួយ ដោយន័យដទៃទៀត ទើបត្រាស់បទជាដើមថា **ឯកត្តំ ឯកត្តតោ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និព្វានំ** សេចក្ដីថា គប្បីជ្រាបបរមនិព្វានក្នុងបច្ចុប្បន្ន ដែលមកហើយដោយចំណែក ៥ ដោយន័យជាដើមថា នែអ្នកដ៏ចម្រើន កាលណាបើខ្លួននេះឆ្អែតស្កប់ស្កល់ ឲ្យគេបម្រើដោយកាមគុណ ៥ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះឯង ទើបខ្លួននេះ ឈ្មោះថា ជាអត្តភាពដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន ។

ក្នុងសេចក្ដីនេះ បុថុជ្ជនកាលត្រេកអរក្នុងនិព្វាន គប្បីជ្រាបថា ឈ្មោះថា រមែងសម្គាល់ដោយអំណាចនៃតណ្ហា ។ បុថុជ្ជនកាលញុំាងមានះឲ្យកើតឡើងថា អញរមែងសម្រេចនិព្វាន គប្បីជ្រាបថា ឈ្មោះថា រមែងសម្គាល់ដោយអំណាចនៃមានះ ។ កាលប្រកាន់អស្សាទ ( ការពេញចិត្ត ) ដែលមិនមែននិព្វាន ថាជានិព្វាន និងប្រកាន់និព្វានថា ជាអស្សាទ គប្បីជ្រាបថា ឈ្មោះថា រមែងសម្គាល់ដោយអំណាចនៃទិដ្ឋិ ។

ឯបុថុជ្ជន កាលប្រកាន់អត្តាផ្សេងអំពីនិព្វាន សម្គាល់ថា អត្តារបស់អញនេះឯង រមែងមានក្នុងនិព្វាន នេះឈ្មោះថា រមែងសម្គាល់ក្នុងនិព្វាន ។ នេះជាការសម្គាល់ដោយអំណាចនៃទិដ្ឋិរបស់បុថុជ្ជននោះ ។

កាលបុថុជ្ជននោះ កើតសេចក្ដីស្នេហាក្នុងអត្តានោះឯង ហើយកើតមានះដែលមានអត្តានោះជាទីតាំង គប្បីជ្រាបថា សម្គាល់ដោយអំណាចនៃតណ្ហា និងមានះ ។

ក្នុងការសម្គាល់ក្រៅពីនិព្វានក៏មានន័យដូច្នេះ ។ ពិតហើយ ក្នុងសេចក្ដីនោះ បុថុជ្ជនកាលប្រកាន់អត្តាថាដទៃអំពីនិព្វាន សម្គាល់ថា នេះនិព្វាន នេះ

អត្តា អត្តារបស់អញនេះដទៃអំពីនិព្វាន នេះឈ្មោះថា រមែងសម្គាល់ក្រៅពីនិព្វាន នេះជាការសម្គាល់ដោយអំណាចទិដ្ឋិរបស់បុថុជ្ជននោះ ។

កាលបុថុជ្ជនកើតសេចក្តីស្នេហាក្នុងអត្តានោះឯង និងកើតមានះដែលមានអត្តានោះជាទីតាំង តណ្ហា និងមានះ ក៏គប្បីជ្រាបថា ( កើតឡើងផងដែរ ) តែកាលសម្គាល់ថា ឱ និព្វានរបស់អញ សុខពិត គប្បីជ្រាបថា ឈ្មោះថាសម្គាល់និព្វាន ថាជារបស់អញ ដូច្នេះ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។ ក្នុងសេចក្តីនេះ មានពាក្យប្រព័ន្ធដូចតទៅនេះ

កាយរបស់ខ្លួននេះដូចម្តេច កាលបុថុជ្ជនមិនដឹងកាយរបស់ខ្លួននោះតាមសេចក្តីពិត ការសម្គាល់ខុសគ្រប់យ៉ាង រមែងកើតឡើងក្នុងកាយរបស់ខ្លួន កាយរបស់ខ្លួននេះគួរខ្ពើម មានការបែកធ្លាយទៅជាធម្មតា ជាអណ្តូងកើតនៃទុក្ខ មិនមែនជាអ្នកនាំ ។ បុគ្គលពាល កាលប្រកាន់កាយនោះ ថាជាសត្រូវ ( ចំពោះសេចក្តីពិត ) ឈ្មោះថា រមែងប្រកាន់ដោយការសម្គាល់ខុស កាលបុថុជ្ជនពិចារណាឃើញកាយរបស់ខ្លួន ដោយភាពជារបស់ស្អាត និងដោយភាពជាសុខ រមែងសម្គាល់ខុសដោយអំណាចនៃតណ្ហា ដូចការសម្គាល់ខុសក្នុងភ្លើងរបស់សត្វមមាច ដូច្នោះ កាលបុថុជ្ជនប្រកាន់និច្ចសញ្ញា ឃើញសម្បត្តិនៃកាយរបស់ខ្លួននោះ បុគ្គលនោះ រមែងមានការសម្គាល់ខុសដោយអំណាចមានះ ដូចក្អែឃើញលាមកហើយ កើតសុកសញ្ញាក្នុងលាមកនោះ កាលបុថុជ្ជនពិចារណាឃើញកាយរបស់ខ្លួននោះ ថាជាអត្តា ជាប់ក្នុងអត្តា មិនយល់តាមសេចក្តីពិត រមែងមានការសម្គាល់ខុសដោយទិដ្ឋិ ដូចបុគ្គលសម្គាល់រូប

ក្នុងកញ្ចក់ ដូច្នោះ ពាក្យថា ការសម្គាល់នេះ ជាពាក្យដែលល្អិត ជាគ្រឿងចងរបស់មារ ជាចំណងធួរ តែស្រាយបានលំបាក ព្រោះជាគ្រឿងចង ដែលចងបុថុជ្ជនទុក បុថុជ្ជន ទោះព្យាយាមរើបម្រះ ដោយវិធីផ្សេងៗ ជាច្រើន ក៏មិនកន្ទងផុតកាយរបស់ខ្លួនទៅបាន រមែងត្រូវកាយរបស់ខ្លួននោះចងរឹតទុកយ៉ាងណែន ដូចឆ្កែត្រូវលាមដោយប្រវាក់ទុកត្រង់បង្គោលដ៏មាំ ដែលគេបោះទុកយ៉ាងល្អ បុគ្គលដែលវង្វេង ងប់ជ្រប់ក្នុងកាយរបស់ខ្លួន រមែងក្តៅក្រហាយជានិច្ច ដោយជាតិ ជរា និងទុក្ខ មានរោគជាដើម ដូចត្រីជាប់សន្ទូច ដូច្នោះ ។

ដូច្នោះហើយ ទើបខ្ញុំសូមពោលនឹងលោកដ៏ចម្រើនទាំងឡាយ លោកទាំង-ឡាយពិចារណាកាយរបស់ខ្លួន ដែលស្អាតឲ្យឃើញថា មិនគួរពេញចិត្ត មិនស្អាត មានការបែកធ្លាយទៅជាធម្មតា មិនមែនអត្តា ព្រោះកាយរបស់ខ្លួននេះមានសភាពយ៉ាងនេះ អ្នកប្រាជ្ញពិចារណាឃើញកាយនេះយ៉ាងនេះ លះការសម្គាល់ខុសទាំងអស់ចេញបាន រមែងរួចផុតចាកទុក្ខទាំងពួង ដូច្នេះ ។

**ពោលដោយន័យទី ១ ប្រការទី ២៤**

**ដោយអំណាចបុថុជ្ជន ចប់**

## អធិប្បាយ សេក្ខបុគ្គល

[ ៣ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងការប្រព្រឹត្តទៅរបស់បុថុជ្ជនដែលមានធម៌ គឺសក្កាយទិដ្ឋិទាំងអស់ឲ្យជាមូល ក្នុងវត្ថុជាតុ មានបឋវីជាដើម ដូចពណ៌នាមកនេះ ឥឡូវ កាលសម្តែងការប្រព្រឹត្តទៅរបស់ព្រះសេក្ខបុគ្គល ក្នុងវត្ថុជាតុទាំងនោះដូចគ្នា ទើបត្រាស់បទជាដើមថា **យោបិ សោ ភិក្ខវេ**

**ភិក្ខុ សេខោ** ដូច្នេះ បណ្ដាបទទាំងនោះ បទថា **យោ** ជាបទផ្ដើម ។ បទថា **សោ** ជាបទសម្ដែងលម្អិត ។ **បិ** អក្ខរៈ មានការប្រមូលមកជាអត្ថ ដូចក្នុងប្រយោគថា ធម៌នេះមិនទៀង ដូច្នេះ ។

ដោយ **បិ** សព្ទនោះ រមែងប្រមូលមកនូវបុគ្គលដោយការស្មើគ្នា តាមអារម្មណ៍ មិនប្រមូលមកដោយការស្មើគ្នានៃបុគ្គលឡើយ តែដោយកំណត់យ៉ាងទាប បានដល់ បុគ្គលដែលមានទិដ្ឋិវិបត្តិ ក្នុងទីនេះសំដៅយកបុគ្គលដែលសម្បូរដោយទិដ្ឋិ ការស្មើគ្នានៃបុគ្គលទាំង ២ នោះមិនមាន តែអារម្មណ៍របស់បុគ្គលពួកទី ១ ( ដែលមានទិដ្ឋិវិបត្តិ ) យ៉ាងណា អារម្មណ៍របស់បុគ្គលពួកទី ២ ( ដែលសម្បូរដោយទិដ្ឋិ ) ក៏ដូច្នោះដូចគ្នា ។ ដោយហេតុនោះទើបលោកពោលថា រមែងប្រមូលមកនូវបុគ្គល ដោយការស្មើគ្នានៃអារម្មណ៍ មិនប្រមូលមកដោយការស្មើគ្នានៃបុគ្គលឡើយ ។

គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់សម្ដែងព្រះសេក្ខបុគ្គល ដែលគប្បីពោលក្នុងឥឡូវនេះ ដោយបទទាំងអស់នេះថា **យោបិ សោ** ។ បទថា **ភិក្ខវេ ភិក្ខុ** នេះ មានន័យដូចពោលហើយនោះឯង ។

បទថា **សេខោ** សេចក្ដីថា ឈ្មោះថា សេក្ខៈ ព្រោះអត្ថដូចម្ដេច ឆ្លើយថា ឈ្មោះថា សេក្ខៈ ព្រោះបានសេក្ខធម៌ ។ សមដូចព្រះតម្រាស់ដែលត្រាស់ទុកថា ភិក្ខុនោះក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យគេតែងនិយាយថា **សេក្ខ សេក្ខ** ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ដែលឈ្មោះថា **សេក្ខ** នោះ ដោយហេតុប៉ុន្មានយ៉ាង ម្នាលភិក្ខុ ភិក្ខុក្នុង

សាសនានេះ ប្រកបដោយសេក្ខសម្មាទិដ្ឋិ ។បេ។ ប្រកបដោយសេក្ខសម្មាសមាធិ ម្នាលភិក្ខុ ដែលឈ្មោះថា សេក្ខៈ ដោយហេតុប៉ុណ្ណេះឯង ។

ម្យ៉ាងទៀត បុគ្គលឈ្មោះថា **សេក្ខ** ព្រោះអត្ថថា កំពុងសិក្សានៅឡើយ ដូច្នេះក៏មាន ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា ភិក្ខុសិក្សាយ៉ាងនេះឯង ដូច្នោះ ទើបលោកហៅថា **សេក្ខ** សួរថា ព្រះសេក្ខបុគ្គលរមែងសិក្សាអ្វី ឆ្លើយថា រមែងសិក្សាអធិសីលសិក្ខាខ្លះ អធិចិត្តសិក្ខាខ្លះ អធិប្បញ្ញាសិក្ខាខ្លះ ភិក្ខុរមែងសិក្សាយ៉ាងនេះឯង ព្រោះហេតុនោះ ទើបលោកហៅថា **សេក្ខ** ។

បុគ្គលណា ជាកល្យាណបុថុជ្ជន ជាអ្នកធ្វើឲ្យបរិបូណ៌ដោយអនុលោមប្បដិបទា មានសីលបរិបូណ៌ មានទ្វាររក្សាហើយក្នុងឥន្ទ្រិយទាំងឡាយ ស្គាល់ប្រមាណក្នុងការបរិភោគភោជន តាមប្រកបសេចក្តីព្យាយាមរបស់បុគ្គលអ្នកភ្ញាក់រឭក តាមប្រកបភាវនានុយោគនូវពោធិបក្ខិយធម៌ អស់បឋមយាមនៃរាត្រីនិងបច្ឆិមយាម ដោយគិតថា អញនឹងសម្រេចសាមញ្ញផលឯណាមួយ ក្នុងថ្ងៃនេះ ឬថ្ងៃស្អែក បុគ្គលនោះ លោកហៅថា សេក្ខៈ ព្រោះកំពុងសិក្សា ។

តែក្នុងអត្ថនេះ បុគ្គលដែលសម្រេចបដិវេធប៉ុណ្ណោះ លោកបំណងយកថាជាសេក្ខៈ មិនមែនសំដៅយកបុថុជ្ជនឡើយ ។

**មានស** ដែលបុគ្គលនោះមិនទាន់សម្រេចហើយ ដូច្នោះ បុគ្គលនោះឈ្មោះថា ជាអ្នកមានមានសៈមិនទាន់បានសម្រេច ។ រាគៈក្តី ចិត្តក្តី ព្រះអរហត្តក្តី ឈ្មោះថា **មានស** ។

ពិតហើយ រាគៈ ឈ្មោះថា **មានស** ដូចក្នុងប្រយោគនេះថា **អន្ត-លិក្ខចរោ ចាសោ យ្វាយញ្ចរតិ មានសោ** អន្ទាក់ គឺរាគៈណា ដែលត្រាច់ទៅលើអាកាស ដូច្នេះ ។

ចិត្តឈ្មោះថា **មានស** ដូចក្នុងប្រយោគជាដើមថា **ចិត្តំ មនោ មានសំ** ចិត្ត មនោ មានសៈ ។

ព្រះអរហត្ត ឈ្មោះថា **មានស** ដូចក្នុងប្រយោគថា **អប្បត្តមានសោ សេខោ កាលំ កយិរា ជនេសុតា** បពិត្រព្រះមានព្រះភាគ អ្នកល្បីក្នុងប្រជុំជន សាវករបស់ព្រះអង្គជាសេក្ខបុគ្គល មានបំណងមិនទាន់សម្រេចនៅត្រេកអរក្នុងសាសនា គប្បីធ្វើមរណកាលដូចម្តេចបាន ដូច្នេះ ។

ព្រះអរហត្តប៉ុណ្ណោះ លោកបំណងយកថា **មានស** ក្នុងទីនេះ ដោយហេតុនោះ ទើបមានពាក្យអធិប្បាយដែលពោលទុកថា បុគ្គលមានព្រះអរហត្តមិនទាន់សម្រេចហើយ ។ បទថា **អនុត្តរំ** ប្រែថា ប្រសើរបំផុត អធិប្បាយថា មិនមានធម៌ណាប្រៀបបាន ព្រះអរហត្តប៉ុណ្ណោះ លោកបំណងយកថា ធម៌ដែលជាដែនក្សេមចាកយោគៈ ព្រោះសំដៅយកអត្ថថា ក្សេមចាកយោគៈ ៤ គឺយោគៈ ៤ មិនប្រទូស្តហើយ ។

បទថា **បត្ថយមានោ** មានវិនិច្ឆ័យថា សេចក្តីប្រាថ្នាមាន ២ យ៉ាង គឺសេចក្តីប្រាថ្នាដោយអំណាចតណ្ហា និងសេចក្តីប្រាថ្នាដោយអំណាចឆន្ទៈ ។ សេចក្តីប្រាថ្នាដោយអំណាចតណ្ហា រមែងមាន ដូចក្នុងប្រយោគថា **បត្ថយ-មានស ហិ ជប្បិតានិ សំវេធិតំ វាបិ បកប្បិតេសុ** ការជាប់ចិត្តទាំងឡាយ

នៃបុគ្គលកាលប្រាថ្នាក្តី ការញាប់ញ័រក្នុងធម៌ទាំងឡាយ ដែលខ្ជួនកំណត់ហើយក្តី ដូច្នេះ ។

ភាពជាបុគ្គលបំណងនឹងធ្វើ គឺការប្រាថ្នាដោយអំណាចកុសលច្ឆន្ទៈ រមែងបានក្នុងប្រយោគថា **ជិន្ទំ ចាបិមតោ សោតំ ។បេ។ ខេមំ បត្តេថ ភិក្ខវោ** បានកាត់កម្ចាត់ខ្សែរបស់មារ ហើយធ្វើឲ្យប្រាសចាកដើមបបុស គឺមានះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាអ្នកច្រើនដោយសេចក្តីរីករាយ ចូរប្រាថ្នានូវព្រះនិព្វានជាទីក្សេម ដូច្នេះ ។ សេចក្តីប្រាថ្នាដោយអំណាចធន្ទៈនេះប៉ុណ្ណោះ លោកបំណងយកក្នុងទីនេះ ។

បទថា **តេន បត្ថយមានោ** សេចក្តីថា បុគ្គលដែលមានបំណងធ្វើ គឺប្រាថ្នានឹងសម្រេចធម៌ដែលជាដែនក្សេមចាកយោគៈនោះ គប្បីជ្រាបថា បុគ្គលបង្អោនទៅ ឱនទៅ ទេរទៅ ( ដើម្បីសម្រេចធម៌ជាដែនក្សេមចាកយោគៈ )។

បទថា **វិហរតិ** សេចក្តីថា បំបាត់ទុក្ខដែលកើតឡើងក្នុងឥរិយាបថដទៃដោយឥរិយាបថម៉្យាងទៀត រក្សារាងកាយមិនឲ្យទ្រុឌទ្រោម ។ ម៉្យាងទៀតគប្បីឃើញអត្ថក្នុងសេចក្តីនេះ ដោយនិទ្ទេសន័យជាដើមថា បុគ្គលដែលបង្អោនចិត្តទៅដោយការពិចារណាថា សង្ខារទាំងឡាយទាំងពួងមិនទៀង ដូច្នេះឈ្មោះថា រមែងនៅដោយសទ្ធា ។

បទថា **បឋវី បឋវិតោ អភិជានាតិ** សេចក្តីថា រមែងដឹងច្បាស់បឋវីថាជាបឋវី គឺរមែងមិនដឹងដោយសញ្ញាដែលផុយគ្នាចាកអាការទាំងពួង ដូចបុថុជ្ជន ម៉្យាងទៀត រមែងដឹងដោយញាណដ៏វិសេសក្រៃលែង ។

ក្នុងបទថា **បឋវី** មានពាក្យដែលលោកពោលអធិប្បាយថា បុគ្គលកាលលែងភាពជាបឋវីបានយ៉ាងនេះ ក៏រមែងដឹងច្បាស់ភាពជាបឋវីនោះយ៉ាងនេះថា មិនទៀងខ្លះ ជាទុក្ខខ្លះ ជាអនត្តាខ្លះ និងមានពាក្យដែលលោកពោលអធិប្បាយទុកថា សេក្ខបុគ្គល កាលជ្រាបបឋវីយ៉ាងនេះហើយ រមែងមិនសម្គាល់បឋវី ។ ឯសេក្ខបុគ្គលនឹងពោលថា មានការសម្គាល់ក៏មិនមែន នឹងពោលថា មិនមានការសម្គាល់ក៏មិនមែន ។ ក្នុងអត្ថនេះ គប្បីជ្រាបថា លោកពោលចោលបទនេះ ។

កាលមានបុគ្គលពោលថា ក្នុងបទនេះមានអធិប្បាយដូចម្តេច ឆ្លើយថា លំដាប់ដំបូង ព្រះមានព្រះភាគត្រាស់ដល់បុថុជ្ជនថា សម្គាល់ខុសក្នុងបឋវី ព្រោះការសម្គាល់ខុសគ្រប់យ៉ាង បុថុជ្ជនមិនទាន់លះបាន ព្រះខីណាស្រព រមែងមិនសម្គាល់ខុស ព្រោះលោកលះការសម្គាល់ខុសគ្រប់យ៉ាងបានហើយ ការសម្គាល់ដោយអំណាចទិដ្ឋិ ព្រះសេក្ខបុគ្គលលះបាន សូម្បីការសម្គាល់ដទៃៗ ក៏ដល់នូវការស្រោលស្តើង ដោយហេតុនោះ ព្រះសេក្ខៈនោះ បុគ្គលណាម្នាក់ មិនគួរពោលថា រមែងសម្គាល់ខុស ដូចបុថុជ្ជន ទាំងមិនគួរពោលថា រមែងមិនសម្គាល់ខុសដូចព្រះខីណាស្រព ។

បទថា **បរិញ្ញេយ្យំ តស្ស** សេចក្តីថា ទីតាំងនៃសេចក្តីសម្គាល់ខុសនោះ ដែលព្រះសេក្ខៈគប្បីកំណត់ដឹងបានដោយបរិញ្ញាទាំង ៣ ព្រោះលោកឈមចុះកាន់ភាពជាបុគ្គលទៀងហើយ និងព្រោះមានការត្រាស់ដឹង ជាទីទៅខាងមុខ ទីតាំងនៃការសម្គាល់ខុស ដែលមិនទាន់គួរកំណត់ដឹង មិនមែនលោកមិនត្រូវ

កំណត់ដឹងដូចបុថុជ្ជនឡើយ ទាំងមិនមែនលោកបានកំណត់ដឹងអស់ហើយ ដូចជាព្រះខីណាស្រពនោះឡើយ ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានន័យដូចពោលហើយដូចគ្នា ។

**ពោលអំពីន័យទី ២**

**អធិប្បាយ សេក្ខបុគ្គល ចប់**

# អធិប្បាយ អរិយបុគ្គល

[ ៤ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងការប្រព្រឹត្តទៅរបស់ព្រះសេក្ខៈ ក្នុងវត្ថុជាតុ មានបឋវីជាដើម ដូចពណ៌នាយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងការប្រព្រឹត្តទៅរបស់ព្រះខីណាស្រព ទើបត្រាស់បទជាដើមថា **យោបិ សោ ភិក្ខវេ ភិក្ខុ អរហំ** ដូច្នេះ ។

បណ្តាបទទាំងនោះ **បិ** សព្ទ ក្នុងបទថា **យោបិ** មានការប្រមូលមកជាអត្ថ ។ ដោយ **បិ** សព្ទនោះ ព្រះមានព្រះភាគទ្រង់សម្តែងថា ក្នុងទីនេះរមែងបានការស្មើគ្នាដោយចំណែកទាំង ២ ។ អធិប្បាយថា ព្រះសេក្ខៈ ឈ្មោះថាជាអ្នកស្មើដោយព្រះខីណាស្រព ព្រោះភាពជាព្រះអរិយបុគ្គល ដោយហេតុនោះ ទើបលោកបាននូវភាពស្មើគ្នាដោយបុគ្គល ។ ចំណែកភាពជាអ្នកស្មើគ្នាដោយអារម្មណ៍ ក៏មានន័យដូចពោលហើយដូចគ្នា ។

បទថា **អរហំ** សេចក្តីថា បុគ្គលមានកិលេសនៅឆ្ងាយ អធិប្បាយថា បុគ្គលមានកិលេសឆ្ងាយ គឺមានកិលេសដែលលោកលះបានហើយ ។ សម

ដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា **អរហន្ត** តើដោយប្រការដូចម្តេច អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង ធ្វើសត្វឲ្យកើតក្នុងភពថ្មីទៀត ជាធម៌ប្រព្រឹត្តទៅមួយអន្លើដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុងខាងមុខ ជាកិលេសឆ្ងាយអំពីភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា **អរហន្ត** ដោយប្រការដូច្នេះឯង ។

បទថា **ខីណាសវោ** មានវិនិច្ឆ័យដូច្នេះ អាសវៈមាន ៤ គឺកាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ អាសវៈទាំង ៤ នេះ របស់ព្រះអរហន្តអស់ហើយ គឺលោកលះបាន ដកឡើងបាន ស្ងប់រម្ងាប់ ជារបស់មិនគួរកើតឡើងទៀត ដែលលោកដុតហើយដោយភ្លើង គឺញាណ ដោយហេតុនោះ ទើបព្រះអរហន្តនោះ លោកហៅថា **ព្រះខីណាស្រព** ។

បទថា **វុសិតវា** សេចក្តីថា ព្រះអរហន្តនោះនៅហើយ គឺនៅចប់ហើយក្នុងធម៌ជាគ្រឿងនៅរបស់គ្រូខ្លះ ក្នុងធម៌ជាគ្រឿងនៅ គឺអរិយមគ្គខ្លះ ក្នុងធម៌ជាគ្រឿងនៅរបស់ព្រះអរិយៈ ១០ ប្រការខ្លះ ព្រះអរហន្តនោះនៅហើយ គឺនៅចប់ហើយ បានដល់ មានធម៌ជាគ្រឿងនៅចប់ហើយ មានចរណៈដែលប្រព្រឹត្តហើយ ដូច្នោះ ទើបឈ្មោះថា នៅចប់ហើយ ។

បទថា **កតករណីយោ** សេចក្តីថា ព្រះសេក្ខៈទាំង ៧ រហូតដល់កល្យាណបុថុជ្ជន ឈ្មោះថា រមែងធ្វើកិច្ចដែលគួរធ្វើដោយមគ្គ ៤ កិច្ចដែលគប្បីធ្វើគ្រប់យ៉ាង ព្រះខីណាស្រពធ្វើហើយ ធ្វើស្រេចអស់ហើយ កិច្ចដែល

គប្បីធ្វើដ៏ក្រៃលែងរបស់ព្រះខីណាស្រពនោះ ដើម្បីការសម្រេចការអស់ទៅនៃទុក្ខ រមែងមិនមាន ដូច្នោះ ទើបព្រះអរហន្តនោះ ឈ្មោះថា មានកិច្ចដែលត្រូវធ្វើស្រេចហើយ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា កាលភិក្ខុនោះមានចិត្តរួចដោយប្រពៃ មានចិត្តស្ងប់រម្ងាប់ហើយ ការសន្សំកុសលឬអកុសល ដែលធ្វើរួចហើយ មិនមានទេ កិច្ចដែលត្រូវធ្វើក៏មិនមាន ។

ក្នុងបទថា **ឱហិតភារោ** មានវិនិច្ឆ័យដូច្នេះ ភារៈមាន ៣ គឺខន្ធភារៈ កិលេសភារៈ អភិសង្ខារភារៈ ភារៈ ៣ នេះ ព្រះអរហន្តនោះដាក់ចុះហើយ លើកចុះហើយ ដាក់ហើយ ធ្វើឲ្យធ្លាក់ទៅហើយ ដោយហេតុនេះ ទើបព្រះអរហន្តនោះ លោកហៅថា មានភារៈដាក់ចុះហើយ ។

បទថា **អនុបត្តសទត្ថោ** សេចក្តីថា បុគ្គលតាមសម្រេចប្រយោជន៍ខ្លួនហើយ អធិប្បាយថា តាមសម្រេចនូវប្រយោជន៍ដែលជារបស់ខ្លួន ។ **ក** អក្ខរៈ ផ្លាស់ជា **ទ** អក្ខរៈ ។ អរហត្តគប្បីជ្រាបថា ប្រយោជន៍របស់ខ្លួន ។ ពិតហើយ អរហត្តនោះ លោកហៅថា ប្រយោជន៍របស់ខ្លួន គឺប្រយោជន៍ខ្លួន ព្រោះអត្ថថា ទាក់ទងនឹងខ្លួន ព្រោះអត្ថថា មិនលះបង់ខ្លួន និងព្រោះអត្ថថា ជាប្រយោជន៍យ៉ាងក្រៃលែងរបស់ខ្លួន ។

បទថា **បរិក្ខីណភវសំយោជនោ** មានវិនិច្ឆ័យថា ក្នុងសំយោជនៈ ១០ គឺកាមរាគៈ បដិឃៈ មានះ ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ភវរាគៈ ឥស្សា មច្ឆរិយៈ និងអវិជ្ជា ហៅថា សំយោជនៈជាគ្រឿងចងសត្វទុកក្នុងភព ព្រោះសំយោជនៈទាំងនេះ រមែងចង គឺតាមចងសត្វទាំងឡាយទុកក្នុងភព ម្យ៉ាង

ទៀត រមែងក្ជាប់កពទុកដោយកព សំយោជនៈជាគ្រឿងចងសត្វទុកក្នុងកព ទាំងនេះ របស់ព្រះអរហន្តអស់ហើយដោយជុំវិញ លោកលះបានហើយ លោកដុតបំផ្លាញហើយ ដោយភ្លើង គឺញាណ ដោយហេតុនោះ ព្រះខីណាស្រព នោះ លោកហៅថា បុគ្គលមានសំយោជនៈជាគ្រឿងចងសត្វទុកក្នុងកពអស់ដោយជុំវិញហើយ ។

បទថា **សម្មទញ្ញា** ក្នុងបទថា **សម្មទញ្ញា វិមុត្តោ** នេះ សេចក្ដីថា ព្រោះដឹងដោយប្រពៃ ។ លោកពោលអធិប្បាយទុកដូចម្ដេច លោកពោលអធិប្បាយទុកថា ព្រោះដឹង គឺជ្រាប បានដល់ ពិចារណា ត្រួតពិនិត្យមើល បើកផ្សារ ធ្វើឲ្យជាក់ច្បាស់នូវអត្ថនៃខន្ធ ថាជាខន្ធ អត្ថនៃអាយតនៈ ថាជាអាយតនៈ អត្ថនៃធាតុ ថាជាធាតុ អត្ថនៃទុក្ខ ថាជាការបៀតបៀន អត្ថនៃសមុទយៈ ថាជាប្រកពកើតទុក្ខ អត្ថនៃនិរោធ ថាជាការស្ងប់ អត្ថនៃមគ្គ ថាជាទស្សនៈ មានប្រភេទយ៉ាងនេះថា សង្ខារទាំងពួងមិនទៀង ដូច្នេះ ដោយប្រពៃ គឺតាមសេចក្ដីពិត ។

បទថា **វិមុត្តោ** មានវិនិច្ឆ័យដូច្នេះ **វិមុត្តិ** មាន ២ យ៉ាង គឺការរួចផុតនៃចិត្ត ១ ព្រះនិព្វាន ១ ព្រះអរហន្ត ឈ្មោះថា រួចផុតហើយ ដោយការរួចផុតនៃចិត្ត ព្រោះភាពដែលចិត្តរបស់លោករួចផុតហើយ ចាកកិលេសទាំងពួង ឈ្មោះថា រួចផុតហើយក្នុងព្រះនិព្វាន ព្រោះលោកមានចិត្តបង្អោនទៅកាន់ព្រះនិព្វាន ដោយហេតុនោះ ទើបព្រះអរហន្ត លោកហៅថា រួចផុតហើយ ព្រោះដឹងដោយប្រពៃ ។

បទថា **បរិញ្ញាតំ តស្ស** សេចក្ដីថា ទីតាំងនៃការសម្គាល់ខុសនោះ ព្រះអរហន្តកំណត់ដឹងហើយ ដោយបរិញ្ញាទាំង ៣ ដូច្នោះ ទើបព្រះអរហន្ត នោះមិនសម្គាល់ទីតាំងនោះ ម្យ៉ាងទៀត អធិប្បាយថា ព្រះអរហន្តមិន សម្គាល់ដោយការប្រកាន់ខុសនោះ ។ ពាក្យដ៏សេសមានន័យដូចពោលហើយ នោះឯង ។

[ ៥ ] ឯ ៣ វារៈជាដើមថា **១យា រាគស្ស** ដូច្នេះ លោកពោល ទុកហើយក្នុងនិទ្ទេសវារៈ វារៈទាំងនោះ ក៏គួរឲ្យពិស្ដារ ក្នុងវារៈពោលដោយ បឋវីជាដើម ។ បរិញ្ញាវារៈនេះ ក៏គួរឲ្យពិស្ដារក្នុងនិទ្ទេសវារៈ ។ បណ្ឌិត កាលឲ្យនូវការពិស្ដារ គប្បីប្រកបបទថា **បរិញ្ញាតំ តស្ស** ដោយគ្រប់ៗ បទ ហើយគប្បីប្រកបសេចក្ដីទៀតថា **១យា រាគស្ស វីតរាគត្តា** ដូច្នេះ ក្នុង បទក្រៅអំពីនោះក៏ន័យនេះ ។ ទេសនាលោកសង្ខេបទុកថា ពាក្យដែល ពោលហើយ ក្នុងបទមួយ ក៏ឈ្មោះថា ពោលហើយគ្រប់ៗ បទ ។

ក្នុងបទថា **១យា រាគស្ស វីតរាគត្តា** នេះ សេចក្ដីថា ព្រោះហេតុ ដែលអ្នកបួសក្រៅសាសនា ជាអ្នកប្រាសចាកតម្រេកក្នុងកាម តែមិនមែន ព្រោះអស់រាគៈ ឯព្រះអរហន្ត ឈ្មោះថា ជាអ្នកប្រាសចាកតម្រេកក្នុងកាម ព្រោះការអស់រាគៈ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **១យា រាគស្ស វីតរាគត្តា** ដូច្នេះ ។ ក្នុងទោសៈ និងមោហៈ ក៏ន័យនេះ ។ ដូចជា កាល ព្រះមានព្រះភាគត្រាស់ថា តថាគតពោលថា **បរិញ្ញាតំ តស្ស** ដូច្នេះ រមែង បានសេចក្ដីថា ព្រះអរហន្តនោះ រមែងមិនសម្គាល់វត្ថុនោះ ឬការសម្គាល់នោះ

ព្រោះលោកបានកំណត់ដឹងហើយ យ៉ាងណា សូម្បីក្នុងទីនេះក៏ដូច្នោះ ។ ព្រះអរហន្តនោះ បណ្ឌិតគប្បីឃើញថា រមែងមិនសម្គាល់វត្ថុនោះ ឬរមែងមិនសម្គាល់ការសម្គាល់ខុសនោះ ព្រោះលោកអស់រាគៈហើយ ។

ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា **បរិញ្ញាតំ តស្ស** នេះ លោកពោលទុកដើម្បីសម្ដែងការបរិបូណ៌នៃមគ្គភាវនា ។ ពាក្យក្រៅអំពីនេះ គប្បីឃើញថា លោកពោលទុកដើម្បីសម្ដែងការបរិបូណ៌នៃការធ្វើឲ្យជាក់ច្បាស់នៃផល ។

ម្យ៉ាងទៀត ព្រះអរហន្តរមែងមិនសម្គាល់ដោយហេតុ ២ ប្រការ ព្រោះភាពដែលវត្ថុលោកកំណត់បានហើយ និងព្រោះអកុសលមូល លោកដកឡើងបានហើយ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យសម្ដែងការកំណត់ដឹងវត្ថុរបស់ព្រះអរហន្តនោះ ដោយពាក្យនៃបរិញ្ញា និងសម្ដែងការដកឡើងនូវអកុ-សលមូល ដោយពាក្យក្រៅអំពីនេះ ដូច្នេះឯង ។

ក្នុងបណ្ដាពាក្យទាំងនោះ គប្បីជ្រាបការប្លែកគ្នាក្នុង ៣ ពាក្យ ខាងចុងដូច្នេះ ព្រះអរហន្តនោះ លោកឃើញទោសក្នុងតម្រេក ក្នុងពាក្យទាំង ៣ នោះហើយ ពិចារណាឃើញទុក្ខ ជាអ្នករួចផុតហើយ ដោយអប្បណិហិតវិមោក្ខ រមែងមានរាគៈប្រាសទៅ ព្រោះការអស់ទៅនៃរាគៈ ។ លោកឃើញទោសក្នុងទោសៈ ពិចារណាឃើញដោយភាពជារបស់មិនទៀង ជាអ្នករួចផុតហើយ ដោយអនិមិត្តវិមោក្ខ រមែងជាអ្នកមានទោសៈប្រាសទៅ ព្រោះការអស់ទោសៈ ។ លោកឃើញទោសក្នុងមោហៈ ពិចារណាដោយភាពជាអនត្តា រួចផុតហើយដោយសុញ្ញតវិមោក្ខ រមែងជាអ្នកប្រាសចាកមោហៈ ព្រោះអស់

មោហៈ ។ បើមានពាក្យសួរថា បើដូច្នោះ បុគ្គលម្នាក់ រមែងរួចផុតដោយវិមោក្ខ ៣ ( ក្នុងគ្រាតែមួយ ) មិនបាន ព្រោះដូច្នោះ មិនគួរពោល ២ វារៈទុក គប្បីឆ្លើយថា សេចក្ដីនេះមិនដូច្នោះឡើយ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនបានកំណត់ពិតប្រាកដ ។

សេចក្ដីពិត ព្រះមានព្រះភាគ ត្រាស់ដោយមិនពិតប្រាកដថា **យោបិ សោ ភិក្ខវេ ភិក្ខុ អរហំ** ដូច្នេះ តែមិនត្រាស់ទុកថា រមែងជាអ្នករួចផុតដោយអប្បណិហិតវិមោក្ខ ឬរួចផុតដោយវិមោក្ខក្រៅអំពីនេះដូច្នេះឡើយ ។ ហេតុនោះ វត្ថុណារមែងសមគួរដល់ព្រះអរហន្ត វត្ថុទាំងអស់នោះ គួរពោលពិតដូច្នេះ ។

ម្យ៉ាងទៀត កាលពោលដោយមិនប្លែកគ្នា ព្រះអរហន្តគ្រប់អង្គ កាលកិលេស មានរាគៈជាដើមអស់ទៅ លោកក៏ហៅថា ជាអ្នកមានរាគៈទៅប្រាស ព្រោះរាគៈអស់ទៅ ព្រោះលោកកំណត់ដឹងនូវវិបរិណាមទុក្ខ ។ លោកហៅថា បុគ្គលប្រាសចាកទោសៈ ព្រោះទោសៈអស់ទៅ ព្រោះលោកកំណត់ដឹងទុក្ខក្នុងទុក្ខ ឈ្មោះថា ជាអ្នកប្រាសចាកមោហៈ ព្រោះមោហៈអស់ទៅ ព្រោះលោកកំណត់ដឹងសង្ខារទុក្ខ ។

ម្យ៉ាងទៀត លោកឈ្មោះថា ប្រាសចាករាគៈ ព្រោះរាគៈអស់ទៅ ព្រោះលោកកំណត់ដឹងឥដ្ឋារម្មណ៍ ឈ្មោះថា ប្រាសចាកទោសៈ ព្រោះទោសៈអស់ទៅ ព្រោះលោកកំណត់ដឹងអនិដ្ឋារម្មណ៍ ឈ្មោះថា ប្រាសចាកមោហៈ ព្រោះមោហៈអស់ទៅ ព្រោះលោកកំណត់ដឹងមជ្ឈត្តារម្មណ៍ ។

ម្យ៉ាងទៀត លោកឈ្មោះថា ប្រាសចាករាគៈ ព្រោះរាគៈអស់ទៅ ព្រោះលោកកំណត់ដឹងនូវឥដ្ឋារម្មណ៍ ឈ្មោះថា ប្រាសចាកទោសៈ ព្រោះទោសៈអស់ទៅ ដោយលោកកំណត់ដឹងអនិដ្ឋារម្មណ៍ ឈ្មោះថា ប្រាសចាកមោហៈ ព្រោះមោហៈអស់ទៅ ដោយលោកកំណត់ដឹងនូវមជ្ឈត្តារម្មណ៍ ។ ម្យ៉ាងទៀត លោកឈ្មោះថា ប្រាសចាករាគៈ ព្រោះរាគៈអស់ទៅ ព្រោះលោកដករាគានុស័យក្នុងសុខវេទនាចេញបាន ឈ្មោះថា ប្រាសចាកទោសៈ និងប្រាសចាកមោហៈ លោកដកបដិឃានុស័យ និងមោហានុស័យ ក្នុងទុក្ខវេទនា និងឧបេក្ខាវេទនាចេញបានដូច្នេះឯង ដូច្នោះ ព្រះមានព្រះភាគកាលទ្រង់សម្ដែងការផ្សេងគ្នានោះ ទើបត្រាស់ថា **ខយា រាគស្ស វីតរាគត្តា ។បេ។ ខយា មោហស្ស វីតមោហត្តា** ដូច្នេះ ។

**ពោលដោយន័យទី ៣-៤-៥-៦**

**ដោយអំណាចអរិយបុគ្គល ចប់**

## អធិប្បាយ ពាក្យថា តថាគត

[ ៨ ] ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការប្រព្រឹត្តទៅរបស់ព្រះខីណាស្រព ក្នុងវត្ថុធាតុទាំងឡាយ មានបឋវីជាដើមយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងការប្រព្រឹត្តទៅរបស់ព្រះអង្គឯង ទើបត្រាស់បទថា **តថាគតោបិ ភិក្ខវេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **តថាគតោ** មានវិនិច្ឆ័យដូច្នេះ ព្រះមានព្រះភាគ

លោកហៅថា តថាគត ដោយហេតុ ៨ យ៉ាង គឺហៅថា **តថាគត** ព្រោះអត្ថថា ទ្រង់មកហើយយ៉ាងនោះ ១ ហៅថា **តថាគត** ព្រោះអត្ថថា ទ្រង់ទៅហើយយ៉ាងនោះ ១ ហៅថា **តថាគត** ព្រោះអត្ថថា ទ្រង់មកកាន់លក្ខណៈដ៏ពិត ១ ហៅថា **តថាគត** ព្រោះអត្ថថា ត្រាស់ដឹងព្រមចំពោះនូវធម៌ដែលពិតតាមសេចក្តីពិត ១ ហៅថា **តថាគត** ព្រោះទ្រង់ឃើញពិត ១ ហៅថា **តថាគត** ព្រោះត្រាស់វាចាពិត ១ ហៅថា **តថាគត** ព្រោះទ្រង់ធ្វើពិត ១ ហៅថា **តថាគត** ព្រោះអត្ថថា គ្របសង្កត់ ១ ។

សួរថា ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះអត្ថថា ទ្រង់មកហើយយ៉ាងនោះដូចម្តេច ។

ឆ្លើយថា ព្រះសម្មាសម្ពុទ្ធអង្គមុនៗ ទ្រង់ដល់នូវការខ្នះខ្នែង ទ្រង់មកដើម្បីប្រយោជន៍ដល់សត្វលោកទាំងពួង ដោយប្រការណា ដូចជា ព្រះមានព្រះភាគទ្រង់ព្រះនាមថា **វិបស្សី** ១ ទ្រង់ព្រះនាមថា **សិខី** ១ ទ្រង់ព្រះនាមថា **វេស្សភូ** ១ ទ្រង់ព្រះនាមថា **កកុសន្ធៈ** ១ ទ្រង់ព្រះនាមថា **កោនាគមនៈ** ១ ទ្រង់ព្រះនាមថា **កស្សបៈ** ១ ទ្រង់មកដើម្បីប្រយោជន៍ដល់សត្វលោកយ៉ាងណា ព្រះមានព្រះភាគរបស់យើងនេះ ក៏ទ្រង់មកដើម្បីជាប្រយោជន៍ដល់សត្វលោក ដូច្នោះដូចគ្នា ។

សេចក្តីនេះ លោកអធិប្បាយទុកដូចម្តេច ។ លោកពោលអធិប្បាយថា ព្រះមានព្រះភាគទាំងនោះ ទ្រង់មកដោយអភិនីហារណា ព្រះមានព្រះភាគនៃយើងទាំងឡាយ ក៏ទ្រង់មកដោយអភិនីហារនោះដូចគ្នា ។

ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ព្រះនាមថា វិបស្សី ។បេ។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា កស្សបៈ ទ្រង់បំពេញទានបារមី សីលបារមី នេក្ខម្ម-បារមី បញ្ញាបារមី វិរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី ឧបេក្ខាបារមី ទ្រង់បានបំពេញបារមី ៣០ គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ ទាំងទ្រង់បានបំពេញមហាបរិច្ចាគទាំង ៥ នេះ គឺទ្រង់បរិច្ចាគអវយវៈ កែវភ្នែក រាជទ្រព្យ រាជសម្បត្តិ ឱរស និងមហេសី ទ្រង់បំពេញបុព្វបយោគ បុព្វចរិយា ការបង្រៀនធម៌ និងញាតត្ថចរិយាជាដើម រហូតដល់ទីបំផុតដោយពុទ្ធចរិយា យ៉ាងណា ព្រះមានព្រះភាគនៃយើង ក៏ទ្រង់មកយ៉ាងនោះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា វិបស្សី ។បេ។ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា កស្សបៈ ទ្រង់បំពេញ គឺចម្រើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គមានអង្គ ៨ យ៉ាងណា សូម្បីព្រះមានព្រះភាគនៃយើង ក៏ទ្រង់មកយ៉ាងនោះ ព្រះមានព្រះភាគទ្រង់មកហើយដោយប្រការនោះ យ៉ាងនេះ ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា **ព្រះតថាគត** ។

ព្រះមុនីទាំងឡាយ មានវិបស្សីសម្ពុទ្ធជាដើមយាងមកដល់ភាពជាព្រះ-សព្វញ្ញុក្នុងលោកនេះដោយប្រការណា ព្រះសក្យមុនី ក៏យាងមកដោយប្រការនោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគមានចក្ខុ ទ្រង់ព្រះនាមថា ព្រះ**តថាគត** ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់មកហើយដោយប្រការនោះ ដូចពណ៌នាមកយ៉ាងនេះ ដូច្នោះ ទើបទ្រង់ព្រះនាមថា **ព្រះតថាគត** ។

សួរថា ព្រះមានព្រះភាគ ទ្រង់ឈ្មោះថា **តថាគត** ព្រោះយាងទៅហើយយ៉ាងនោះដូចម្ដេច ឆ្លើយថា ព្រះមានព្រះភាគ ព្រះនាមថា វិបស្សី ។បេ។ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា កស្សបៈ ប្រសូតភ្លាម ទ្រង់យាងទៅបានយ៉ាងណា ព្រះមានព្រះភាគនៃយើង ក៏ទ្រង់យាងទៅបាន ដូច្នោះ ។

ព្រះមានព្រះភាគនៃយើង ទ្រង់យាងទៅបានដូចម្ដេច ទ្រង់យាងទៅបានយ៉ាងនេះ គឺប្រសូតភ្លាមទ្រង់ប្រថាប់ឈរលើផ្ទៃប្រឹថពី ដោយព្រះបាទដ៏រាបស្មើ បែរព្រះភក្ត្រទៅទិសឧត្តរ បោះជំហានយាងទៅបាន ៧ ជំហាន ដូចព្រះអង្គបានត្រាស់ថា ម្នាលអានន្ទ ពោធិសត្វប្រសូតមកភ្លាម ទ្រង់ប្រតិស្ឋានលើផែនដី ដោយព្រះបាទដ៏ស្មើ បែរព្រះភក្ត្រទៅទិសខាងជើង ទ្រង់យាងដោយព្រះបាទបាន ៧ ជំហាន កាលទេវតាកំពុងបាំងស្វេតច្ឆត្រថ្វាយ ទ្រង់ក្រឡេកមើលគ្រប់ទិសទាំងអស់ ទើបបញ្ចេញអាសភិវាចាថា អាត្មាអញ ជាកំពូលរបស់លោក អាត្មាអញ ជាបុគ្គលចម្បងជាងលោក អាត្មាអញ ជាបុគ្គលប្រសើរជាងលោក ជាតិនេះ ជាជាតិទីបំផុត ឥឡូវនេះ មិនមានភពថ្មីទៀតឡើយ ដូច្នេះ ។

ការយាងទៅរបស់ព្រះអង្គនោះ ដូច្នោះ មិនខុសអំពីនោះ ព្រោះជាបុព្វ-និមិត្តនៃការសម្រេចគុណវិសេសជាច្រើន ។

ការដែលទ្រង់ប្រសូតភ្លាម ប្រថាប់ឈរលើផ្ទៃប្រឹថពី ដោយព្រះបាទ

ដ៏រាបស្មើ នេះជាបុព្វនិមិត្តនៃការបានឥទ្ធិបាទ ៤ ។

ការដែលព្រះអង្គបែរព្រះភក្ត្រទៅទិសឧត្តរនោះ ជាបុព្វនិមិត្តនៃការដែលព្រះអង្គជាអ្នកធ្វងផុតលោកទាំងពួង ។

ការឈានព្រះបាទយាងបាន ៧ ជំហាន ជាបុព្វនិមិត្តនៃការបានរតនៈ គឺពោជ្ឈង្គ ៧ ប្រការ ។

ការលើកឡើងនូវផ្ចិតដែលពោលក្នុងបទថា ផ្ចិតមានដងជាវិការនៃមាសផ្សាយទៅ ដូច្នេះ ជាបុព្វនិមិត្តនៃការញាំញីពួកតិរ្ថិយទាំងឡាយ ។

ការដែលទ្រង់បាំងស្វេតច្ឆត្រ ជាបុព្វនិមិត្តនៃការបានស្វេតច្ឆត្រដ៏ប្រសើរវិសេស ប្រាសចាកមន្ទិល គឺការរួចផុត ដោយអំណាចភាពជាព្រះអរហន្ត ។

ការដែលទ្រង់ពិនិត្យមើលទៅសព្វទិសនោះ ជាបុព្វនិមិត្តនៃការបាននូវញាណដ៏ប្រសើរ គឺសព្វញ្ញុតញ្ញាណ ការដែលទ្រង់បន្លឺអាសភិវាចា ជាបុព្វ-និមិត្តនៃការប្រកាសធម្មចក្រដ៏ប្រសើរ មិនមានបុគ្គលណាជំទាស់រារាំងបាន ។

ព្រះមានព្រះភាគ ទ្រង់ទៅដោយប្រការនោះ ការយាងទៅរបស់ព្រះអង្គយ៉ាងនោះ មិនខុសអំពីនោះ ព្រោះជាបុព្វនិមិត្តនៃការបានសម្រេចគុណវិសេសជាច្រើន ដោយហេតុនោះ ទើបបុរាណាចារ្យពោលថា

ព្រះគោតមនោះ លុះប្រសូតហើយភ្លាមប៉ុណ្ណោះ ក៏ជាន់ផ្ទៃពសុធាដោយព្រះបាទដ៏រាបស្មើ ហើយទ្រង់យាងទៅបាន ៧ ជំហាន ដូចគោមេហ្វូងដើរនាំមុខហ្វូងគោទៅ ដូច្នោះ ពួកទេវតាទាំងឡាយ ក៏បានតម្កោះស្វេតច្ឆត្របាំងថ្វាយព្រះគោតមនោះ កាលយាងទៅបាន ៧ ជំហានហើយ ទ្រង់សម្លឹងមើល

គ្រប់ទិសដោយជុំវិញ បានបន្លឺព្រះសូរសៀង ដែលប្រកបដោយអង្គ ៨ ដូចស្តេចរាជសីហ៍ ឈរលើកំពូលភ្នំ បន្លឺសីហនាទ ដូច្នោះ ។

ព្រះមានព្រះភាគ យាងទៅហើយដោយប្រការនោះ ដូចពណ៌នាមកយ៉ាងនេះ ដូច្នោះ ទើបព្រះអង្គព្រះនាមថា **តថាគត** ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា វិបស្សី ។បេ។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា កស្សបៈ យ៉ាងណា ព្រះមានព្រះភាគនៃយើងនេះក៏យ៉ាងនោះដូចគ្នា ។ គឺព្រះអង្គទ្រង់លះកាមច្ឆន្ទៈ ដោយនេក្ខម្មៈ យាងទៅហើយ ទ្រង់លះព្យាបាទ ដោយមិនព្យាបាទ ទ្រង់លះថីនមិទ្ធៈ ដោយអាលោកសញ្ញា ទ្រង់លះឧទ្ធច្ចកុក្កុច្ចៈ ដោយការមិនរាយមាយ ទ្រង់លះវិចិកិច្ឆាដោយការកំណត់ធម៌ យាងទៅហើយ ទ្រង់ទម្លាយអវិជ្ជាដោយញាណ យាងទៅហើយ ទ្រង់បន្ទោបង់ការមិនត្រេកអរ ដោយបាមោជ្ជ ទ្រង់ដកគ្រឿងរាំង គឺនីវរណៈដោយបឋមជ្ឈាន ញុំាងឯងឹត គឺវិតក្ក វិចារៈ ឲ្យស្ងប់រម្ងាប់ដោយទុតិយជ្ឈាន ទ្រង់ខ្ជាក់ចោលនូវបីតិដោយតតិយជ្ឈាន ទ្រង់លះសុខ និងទុក្ខដោយចតុត្ថជ្ឈាន ទ្រង់កន្លងផុតរូបសញ្ញា បដិឃសញ្ញា និងនានត្តសញ្ញាដោយអាកាសានញ្ចាយតនសមាបត្តិ ទ្រង់កន្លងផុតអាកាសានញ្ចាយតនសញ្ញាដោយវិញ្ញាណញ្ចាយតនសមាបត្តិ ទ្រង់កន្លងផុតវិញ្ញាណញ្ចាយតនសញ្ញាដោយអាកិញ្ចញ្ញាយតនសមាបត្តិ ទ្រង់កន្លងផុតអាកិញ្ចញ្ញាយតនសញ្ញាដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ យាងទៅហើយ ទ្រង់លះនិច្ចសញ្ញាដោយអនិច្ចានុបស្សនាញាណ ទ្រង់លះសុខសញ្ញា ដោយទុក្ខានុបស្សនាញាណ

ទ្រង់លះអត្តសញ្ញា ដោយអនត្តានុបស្សនាញាណ ទ្រង់លះការត្រេកអរ ដោយនិព្វិទានុបស្សនាញាណ ទ្រង់លះរាគៈ ដោយវិរាគានុបស្សនាញាណ ទ្រង់លះសមុទយៈ ដោយនិរោធានុបស្សនាញាណ ទ្រង់លះការប្រកាន់មាំ ដោយបដិនិស្សគ្គានុបស្សនាញាណ ទ្រង់លះឃនសញ្ញា ដោយខយានុបស្សនាញាណ ទ្រង់លះការប្រមូលមក ដោយវយានុបស្សនាញាណ ទ្រង់លះធុវសញ្ញា ដោយវិបរិណាមានុបស្សនាញាណ ទ្រង់លះនិមិត្តសញ្ញា ដោយអនិមិត្តានុបស្សនាញាណ ទ្រង់លះការប្រាថ្នា ដោយអប្បណិហិតានុបស្សនាញាណ ទ្រង់លះអភិនិវេសដោយសុញ្ញតានុបស្សនាញាណ ទ្រង់លះការប្រកាន់ថាជាសារៈ ដោយអធិប្បញ្ញាធម្មវិបស្សនាញាណ ទ្រង់លះការប្រកាន់មាំ ព្រោះការវង្វេង ដោយយថាភូតញ្ញាណទស្សនញ្ញាណ ទ្រង់លះការប្រកាន់ដោយអាល័យ ដោយអាទីនវានុបស្សនាញាណ ទ្រង់លះការមិនពិចារណា ដោយបដិសង្ខានុបស្សនាញាណ ទ្រង់លះការប្រកាន់មាំក្នុងសំយោជនៈ ដោយវិវដ្ដានុបស្សនាញាណ ទ្រង់កាច់បំបាក់កិលេសក្នុងបច្ចុប្បន្ន ដោយសោតាបត្តិមគ្គ ទ្រង់លះកិលេសយ៉ាងគ្រោតគ្រាត ដោយសកទាគាមិមគ្គ ទ្រង់ដកកិលេសដែលនៅសេសសល់បន្តិចបន្តួច ដោយអនាគាមិមគ្គ ទ្រង់កាត់ផ្តាច់កិលេសគ្រប់យ៉ាង ដោយអរហត្តមគ្គ យាងទៅហើយ ។ ព្រះមានព្រះភាគយាងទៅហើយយ៉ាងនោះ ដោយអាការដូចពណ៌នាមកយ៉ាងនេះ ដូច្នោះ ទើបទ្រង់ព្រះនាមថា **តថាគត** ។

សួរថា ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់យាងមក

កាន់លក្ខណៈដែលពិតយ៉ាងនោះដូចម្ដេច ឆ្លើយថា ព្រះមានព្រះភាគ ទ្រង់យាងមកហើយ គឺដល់ដោយមិនខុស បានដល់ សម្រេចដោយលំដាប់នូវលក្ខណៈនៃបឋវីធាតុ ថាជាការរឹងមាំយ៉ាងត្រឹមត្រូវ មិនខុសនូវលក្ខណៈនៃអាបោធាតុ ថាជាគ្រឿងហូរ លក្ខណៈនៃតេជោធាតុ ថាជារបស់ក្ដៅ លក្ខណៈនៃវាយោធាតុ ថាកម្រើក លក្ខណៈអាកាសធាតុ ថាពាល់ត្រូវមិនបាន លក្ខណៈនៃវិញ្ញាណ ថាជាគ្រឿងដឹង លក្ខណៈនៃរូប ថាបែកធ្លាយទៅ លក្ខណៈនៃវេទនា ថាសោយអារម្មណ៍ លក្ខណៈនៃសញ្ញា ថាចាំបាន លក្ខណៈនៃសង្ខារថា ជាគ្រឿងតាក់តែង លក្ខណៈនៃវិញ្ញាណថា ដឹងច្បាស់ លក្ខណៈនៃវិតក្កថា លើកចិត្តឡើងកាន់អារម្មណ៍ លក្ខណៈនៃវិចារៈ ថាឈ្លេចឈ្លីអារម្មណ៍ លក្ខណៈបីតិ ថាផ្សាយជ្រួតជ្រាបទៅ លក្ខណៈនៃ សុខថាត្រេកអរ លក្ខណៈនៃចិត្តេកគ្គតា ថាមិនរាយមាយ លក្ខណៈនៃផស្សៈ ថាពាល់ត្រូវ លក្ខណៈនៃសទ្ធិន្ទ្រិយ ថាបង្អោនចិត្តជឿ លក្ខណៈនៃវីរិយិន្ទ្រិយថាផ្គងចិត្ត លក្ខណៈនៃសតិន្ទ្រិយ ថាប្រាកដច្បាស់ លក្ខណៈនៃសមាធិន្ទ្រិយថាជាសភាពនៃចិត្តដែលមិនរាយមាយ លក្ខណៈនៃបញ្ញិន្ទ្រិយ ថាដឹងច្បាស់ លក្ខណៈនៃសទ្ធាពល ថាចិត្តមិនញាប់ញ័រ ព្រោះវត្ថុមិនគួរជឿ លក្ខណៈនៃវីរិយពល ថាចិត្តមិនញាប់ញ័រ ព្រោះខ្ជិលច្រអូស លក្ខណៈនៃសតិពល ថាចិត្តមិនញាប់ញ័រ ព្រោះមិនមានស្មារតី លក្ខណៈនៃសមាធិពល ថាចិត្តមិនញាប់ញ័រព្រោះឧទ្ធច្ចៈ លក្ខណៈនៃបញ្ញាពល ថាចិត្តមិនញាប់ញ័រព្រោះអវិជ្ជា លក្ខណៈនៃសតិសម្ពោជ្ឈង្គ ថាប្រាកដច្បាស់ លក្ខណៈនៃធម្មវិចយ-

សម្ពោជ្ឈង្គ ថាការពិចារណា លក្ខណៈនៃវីរិយសម្ពោជ្ឈង្គ ថាផ្គងចិត្ត លក្ខណៈនៃបីតិសម្ពោជ្ឈង្គ ថាការផ្សាយចិត្តទៅ លក្ខណៈនៃបស្សទ្ធិសម្ពោជ្ឈង្គ ថាការស្ងប់ចិត្ត លក្ខណៈនៃសមាធិសម្ពោជ្ឈង្គ ថាការមិនរាយមាយរបស់ចិត្ត លក្ខណៈនៃឧបេក្ខាសម្ពោជ្ឈង្គ ថាការពិចារណា លក្ខណៈនៃសម្មាទិដ្ឋិ ថាការឃើញត្រូវ លក្ខណៈនៃសម្មាសង្កប្ប ថាការលើកចិត្តឡើង លក្ខណៈរបស់សម្មាវាចា ថាការកំណត់ចិត្ត លក្ខណៈនៃសម្មាកម្មន្តៈ ថាព្យាយាមប្រឹងប្រែង លក្ខណៈនៃសម្មាអាជីវៈ ថាការផូរផង់នៃចិត្ត លក្ខណៈនៃសម្មាវាយាមៈ ថាការផ្គងចិត្ត លក្ខណៈនៃសម្មាសតិ ថាការប្រាកដច្បាស់ លក្ខណៈនៃសម្មាសមាធិ ថាការដែលចិត្តមិនរាយមាយ លក្ខណៈនៃអវិជ្ជា ថាការមិនដឹង លក្ខណៈនៃសង្ខារ ថាចេតនា លក្ខណៈនៃវិញ្ញាណ ថាដឹងច្បាស់ លក្ខណៈនៃនាម ថាបង្អោនចិត្តទៅ លក្ខណៈនៃរូប ថាទ្រុឌទ្រោមទៅ លក្ខណៈនៃអាយតនៈ ៦ ថាជាប្រកពកើត លក្ខណៈនៃផស្សៈ ថាពាល់ត្រូវ លក្ខណៈនៃវេទនា ថាសោយអារម្មណ៍ លក្ខណៈនៃតណ្ហា ថាជាហេតុនៃទុក្ខ លក្ខណៈនៃឧបាទាន ថាការប្រកាន់ លក្ខណៈនៃភព ថាការប្រមូលទុក លក្ខណៈនៃជាតិ ថាការកើត លក្ខណៈនៃជរា ថាការចាស់ លក្ខណៈនៃមរណៈ ថាចុតិ លក្ខណៈនៃធាតុ ថាសោះសូន្យ លក្ខណៈនៃអាយតនៈ ថាជាប្រកពកើត លក្ខណៈនៃសតិប្បដ្ឋាន ថាប្រាកដច្បាស់ លក្ខណៈនៃសម្មប្បធាន ថាព្យាយាម លក្ខណៈនៃឥទ្ធិបាទ ថាសម្រេច លក្ខណៈនៃឥន្ទ្រិយ ថាជាធំ លក្ខណៈនៃពល ថាមិនញាប់ញ័រ លក្ខណៈនៃពោជ្ឈង្គ ថា

ជាធម៌នាំសត្វចេញចាកទុក្ខ លក្ខណៈនៃមគ្គ ថាជាហេតុឲ្យដល់នូវការរំលត់ទុក្ខ លក្ខណៈនៃសច្ចៈ ថាពិត លក្ខណៈនៃសមថៈ ថាមិនរាយមាយ លក្ខណៈនៃវិបស្សនា ថាពិចារណាឃើញ លក្ខណៈនៃសមថៈ និងវិបស្សនា ថាមានកិច្ចដូចគ្នា លក្ខណៈនៃវត្ថុដែលជាគូគ្នា ថាមិនលះគ្នា លក្ខណៈនៃសីលវិសុទ្ធិ ថាជាការសង្រួមរក្សា លក្ខណៈនៃចិត្តវិសុទ្ធិ ថាមិនរាយមាយ លក្ខណៈនៃទិដ្ឋិវិសុទ្ធិ ថាឃើញត្រូវ លក្ខណៈនៃញាណក្នុងធម៌ជាទីអស់ទៅ ថាសមុច្ឆេទ លក្ខណៈនៃញាណក្នុងធម៌ដែលមិនទាន់កើតឡើង ថាស្ងប់ លក្ខណៈនៃឆន្ទៈ ថាមូលហេតុ លក្ខណៈនៃមនសិការ ថាព្យាយាម ប្រឹងប្រែង លក្ខណៈនៃផស្សៈ ថាជាទីរួម លក្ខណៈនៃវេទនា ថាជាទីប្រជុំ លក្ខណៈនៃសមាធិ ថាធម៌ដែលជាប្រធាន លក្ខណៈនៃសតិ ថាភាពជាធំ លក្ខណៈនៃបញ្ញា ថាខ្ពស់ជាងធម៌ទាំងពួង លក្ខណៈនៃវិមុត្តិ ថាជាខ្លឹម លក្ខណៈនៃនិព្វានដែលឈមចុះកាន់អមតៈ ថាជាទីបំផុត ព្រះមានព្រះភាគទ្រង់មកដល់ គឺដល់ បានដល់ត្រាស់ដឹងនូវលក្ខណៈតាមសេចក្ដីពិតយ៉ាងនេះ យ៉ាងពិតប្រាកដ គឺមិនខុស ដូច្នោះ ទើបទ្រង់ព្រះនាមថា **តថាគត ។**

ព្រះមានព្រះភាគ ទ្រង់យាងមកដល់លក្ខណៈដែលពិតយ៉ាងនេះ ដូច្នោះ ទើបទ្រង់ព្រះនាមថា **តថាគត ។**

សួរថា ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះត្រាស់ដឹងព្រមចំពោះនូវធម៌ដែលពិតតាមសេចក្ដីពិតដូចម្ដេច ឆ្លើយថា ឈ្មោះថា ធម៌ដែលពិត បានដល់ អរិយសច្ច ៤ ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំង-

ឡាយ ធម្មជាត ៤ យ៉ាងនេះ ជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ធម្មជាត ៤ គឺអ្វីខ្លះ ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះជាទុក្ខ នុ៎ះជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ដូច្នេះជាដើម ។ សេចក្ដីពិស្ដារ ( អ្នកសិក្សាគប្បីពិនិត្យមើលខ្លួនឯង ) ។

ព្រះមានព្រះភាគត្រាស់ដឹងព្រមចំពោះនូវអរិយសច្ចទាំង ៤ នោះ ព្រោះហេតុនោះ ទើបបានទទួលព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងព្រមចំពោះនូវអរិយសច្ចទាំងឡាយដែលពិត ។

ពិតហើយ **គត** សព្ទ ក្នុងបទថា **តថាគតោ** នេះ មានអត្ថថា ត្រាស់ដឹងព្រមចំពោះ ។

ម្យ៉ាងទៀត សភាវៈដែលជរា និងមរណៈកើតមានព្រោះជាតិជាបច្ច័យ ជាសភាវៈដែលពិត មិនប្រែប្រួល មិនដទៃឡើយ ។បេ។ សភាវៈដែលសង្ខារទាំងឡាយកើតមាន ព្រោះមានអវិជ្ជាជាបច្ច័យ ជាសភាវៈដែលពិត មិនប្រែប្រួល មិនទៅជាដទៃឡើយ ។

ម្យ៉ាងទៀត សភាវៈដែលអវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ សង្ខារទាំងឡាយជាបច្ច័យនៃវិញ្ញាណ ។បេ។ សភាវៈដែលជាតិជាបច្ច័យនៃជរា និងមរណៈ ជាសភាវៈដែលពិត មិនប្រែប្រួល មិនជាដទៃឡើយ ។

ព្រះមានព្រះភាគ ត្រាស់ដឹងព្រមចំពោះនូវសភាវៈទាំងអស់នោះ ព្រោះហេតុនោះ ទើបបានទទួលព្រះនាមថា **តថាគត** ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងព្រមចំពោះ

នូវធម៌ដែលពិតតាមសេចក្ដីពិត ដោយប្រការដូចពណ៌នាមក ដូច្នេះ ។

សួរថា ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់មានប្រក្រតីឃើញអារម្មណ៍ដែលពិតដូចម្ដេច ឆ្លើយថា អារម្មណ៍ណាដែលឈ្មោះថា រូបារម្មណ៍ ដែលមកប្រាកដក្នុងចក្ខុទ្វាររបស់សត្វទាំងឡាយ មិនមានប្រមាណ មានទាំងក្នុងលោក និងទាំងទេវលោក ។បេ។ ក្នុងពួកសត្វ ព្រមទាំងទេវលោក និងមនុស្ស ក្នុងលោកធាតុមិនមានប្រមាណ អារម្មណ៍នោះព្រះមានព្រះភាគទ្រង់ដឹង គឺទ្រង់ឃើញ ដោយអាការទាំងអស់ ។

អារម្មណ៍នោះ ព្រះមានព្រះភាគ ទ្រង់ដឹង និងទ្រង់ឃើញយ៉ាងនេះ ចែកចេញទៅតាមឈ្មោះជាអនេក តាមវារៈ ១៣ វារៈ តាមន័យ ៥២ ន័យ ដោយន័យជាដើមថា រូប គឺរូបាយតនៈនោះដូចម្ដេច ។ រូបណាដែលអាស្រ័យមហាភូតរូប ៤ ជារូបដែលមានវណ្ណៈ គឺពណ៌ មើលឃើញបាន ពាល់ត្រូវបាន ជារូបពណ៌ខៀវ ជារូបពណ៌លឿង ដោយអំណាចជារូបដែលគួរប្រាថ្នា និងមិនគួរប្រាថ្នាជាដើម ដោយអំណាចដែលនឹងបានក្នុងរូបដែលបានឃើញ សំឡេងដែលបានឮ ក្លិន រស ផោដ្ឋព្វៈដែលបានជ្រាប និងធម្មារម្មណ៍ដែលបានដឹងច្បាស់ រមែងជារបស់ពិតនោះឯង មិនប្រែប្រួល ។ ក្នុងបណ្ដាអារម្មណ៍ មានសំឡេងជាដើម ដែលមកប្រាកដក្នុងសោតទ្វារជាដើម ក៏ន័យនេះ ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណាដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដែលពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និង

មនុស្សដ៏សេស ឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ត្រាច់រង្គាត់រកអារម្មណ៍នោះ តថាគតបានដឹងជាក់ស្តែងហើយដោយសារចិត្ត ព្រោះហេតុនោះ បានជាគេហៅថា តថាគត ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់មានប្រក្រតីឃើញអារម្មណ៍ដែលពិត ដោយប្រការដូចពណ៌នាមក ដូច្នេះ ។

ក្នុងបទថា **តថាគតោ** នេះ អ្នកសិក្សាគប្បីជ្រាបការប្រើបទថា **តថាគតោ** ចុះក្នុងអត្ថថា បុគ្គលមានប្រក្រតីឃើញអារម្មណ៍ដែលពិត ។

សួរថា ព្រះមានព្រះភាគ ព្រះនាមថា តថាគត ព្រោះទ្រង់មានប្រក្រតីត្រាស់វាទៈដែលពិតដូចម្តេច ឆ្លើយថា ការដែលព្រះមានព្រះភាគប្រថាប់គង់លើអបរាជិតបល្ល័ង្ក ខាងក្រោមមណ្ឌលពោធិព្រឹក្ស ទ្រង់ផ្ចាញ់មារទាំង ៣ ហើយត្រាស់ដឹងព្រមចំពោះនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្តី ការដែលព្រះមានព្រះភាគទ្រង់រំលត់ខន្ធបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុក្នុងចន្លោះដើមរាំងទាំងគូនាកណ្តាលរាត្រីក្តី អស់រយៈពេល ៤៥ ឆ្នាំ ក្នុងចន្លោះនេះ គឺក្នុងរយៈពេលបឋមពោធិកាលក្តី មជ្ឈិមពោធិកាលក្តី បច្ឆិមពោធិកាលក្តី ព្រះពុទ្ធវចនៈណាដែលព្រះមានព្រះភាគត្រាស់ទុក ជាសុត្តៈ គេយ្យៈ ។បេ។ វេទល្លក្តី ព្រះពុទ្ធវចនៈទាំងអស់នោះ វិញ្ញូជនពោលតិះដៀលមិនបាន ទាំងដោយអត្ថ និងព្យញ្ជនៈ មិនខ្វះ មិនលើស បរិបូណ៌ដោយអាការគ្រប់យ៉ាង ញាំញីនូវការស្រវឹងដោយរាគៈ ដោយទោសៈ និងមោហៈ ខុសក្លាំងក្លាត់ក្នុងព្រះពុទ្ធវចនៈសូម្បីមួយចម្រៀករោមទ្រាយក៏មិនមានក្តី ទាំងអស់នោះជារបស់

ពិត មិនប្រែប្រួល បីដូចប្រថាប់ត្រាដោយព្រះរាជលញ្ចករតែមួយ ប្រៀបបីដូចវាល់ដោយនាឡិតែមួយ បីដូចថ្លឹងដោយជញ្ជីងតែមួយ ដូច្នោះ ។

ព្រោះហេតុនោះ ទើបបុរាណាចារ្យពោលថា ការដែលព្រះតថាគតត្រាស់ដឹងព្រមចំពោះនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងកណ្តាលរាត្រីក្តី ការដែលព្រះតថាគតបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងកណ្តាលរាត្រីក្តី ការដែលព្រះតថាគតត្រាស់សន្ទនា ចន្លុះបង្ហាញក្នុងរវាងនេះក្តី ទាំងអស់នោះជារបស់ពិត មិនជាដទៃឡើយ ព្រោះដូច្នោះ ទើបបានទទួលព្រះនាមថាតថាគត ។

ពិតហើយ **គត** សព្ទ ក្នុងបទថា **តថាគតោ** នេះ មានអត្ថស្មើគ្នានឹង **គទ** ( បន្ទឹវាចា ឬនិយាយ ) ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់មានប្រក្រតីត្រាស់វាទៈដែលពិត ដោយប្រការដូចពណ៌នាមក ដូច្នេះ ។

ម្យ៉ាងទៀត ការពោល ឈ្មោះថា **អាគទ** អធិប្បាយថា បានដល់ពាក្យពោល ។ ការត្រាស់របស់ព្រះតថាគតនោះពិត គឺមិនវិបរិត ព្រោះហេតុនោះ ទើបបានទទួលព្រះនាមថា **តថាគត** ព្រោះផ្លាស់ **ទ** អក្ខរៈជា **ត** អក្ខរៈ អ្នកសិក្សាគប្បីជ្រាបបទសម្រេចរូបក្នុងអត្ថនេះ ដូចពណ៌នាមកដូច្នេះ ។

សួរថា ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់ជាអ្នកមានប្រក្រតីធ្វើពិតដូចម្តេច ឆ្លើយថា កាយកម្មរបស់ព្រះមានព្រះភាគ រមែងស្របតាមវចីកម្ម ទាំងវចីកម្មក៏ស្របតាមកាយកម្ម ព្រោះហេតុនោះ ព្រះមាន

ព្រះភាគ មានប្រក្រតីត្រាស់យ៉ាងណា ទ្រង់មានប្រក្រតីធ្វើយ៉ាងនោះ មានប្រក្រតីធ្វើយ៉ាងណា ក៏ទ្រង់មានប្រក្រតីត្រាស់យ៉ាងនោះ អធិប្បាយថា វចីកម្មរបស់ព្រះមានព្រះភាគនោះ មានសភាពដូច្នេះ យ៉ាងណា សូម្បីកាយកម្មក៏ប្រព្រឹត្តទៅយ៉ាងនោះ ហេតុនោះ ទើបទ្រង់ព្រះនាមថា **តថាគត** ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ហេតុនោះ ទើបបានជាគេហៅថា **តថាគត** ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះជាអ្នកមានប្រក្រតីធ្វើពិតដូចពណ៌នាមក ដូច្នេះ ។

សួរថា ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះអត្ថថា គ្របសង្កត់ដូចម្តេច ឆ្លើយថា ព្រះមានព្រះភាគ ទ្រង់គ្របសង្កត់ខាងលើ តាំងអំពីភវគ្គព្រហ្មចុះមក ខាងក្រោមតាំងអំពីអវិចីមហានរកឡើងទៅ ទទឹងវ័មែងគ្របសង្កត់សព្វសត្វក្នុងលោកធាតុ មិនមានប្រមាណដោយសីលខ្វះ សមាធិខ្វះ បញ្ញាខ្វះ វិមុត្តិខ្វះ វិមុត្តិញាណទស្សនៈខ្វះ ការថ្លឹង ឬការកំណត់វាស់នូវគុណ មានសីលជាដើមនៃព្រះមានព្រះភាគអង្គនោះ មិនមាន ព្រះអង្គមានព្រះគុណដែលមិនមានបុគ្គលណាម្នាក់អាចថ្លឹងបាន មិនអាចប្រមាណបាន មិនមានបុគ្គលណាក្រៃលែងជាង ជាព្រះរាជានៃព្រះរាជា ជាទេវតានៃទេវតា ជាសក្កៈលើសក្កៈទាំងឡាយ ជាព្រហ្មលើព្រហ្មទាំងឡាយ ព្រោះហេតុនោះ ទើប

ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នកគ្របសង្កត់ អង់អាច ជាអ្នកឃើញពិត មានអំណាចគ្របសង្កត់លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសបាន ហេតុនោះ បានជាគេហៅថា តថាគត ។ ក្នុងបទថា តថាគតនោះ គប្បីជ្រាបបទសម្រេចរូបយ៉ាងនេះ ។

វត្ថុដូចគ្នានឹងឱសថ ឈ្មោះថា **អគទ** ។ ឱសថនោះ គឺអ្វី គឺការទេសនាវិលាស ( តាមឧបនិស្ស័យរបស់អ្នកស្តាប់ ) និងការធ្វើឲ្យចម្រើននៃបុណ្យ ។ ព្រោះឱសថនោះ ទើបព្រះមានព្រះភាគ ជាពេទ្យដ៏មានអានុភាពច្រើន ទ្រង់គ្របសង្កត់នូវបុគ្គលដែលកាន់លទ្ធិដទៃទាំងអស់ និងលោក ព្រមទាំងទេវលោក ដូចគ្នានឹងបង្ក្រាបពស់ ( ពិស ) ដោយទិព្វឱសថ ដូច្នោះ ។ ឱសថក្នុងការគ្របសង្កត់លោកទាំងអស់ របស់ព្រះមានព្រះភាគអង្គនោះ ដែលសម្រេចមកអំពីការទេសនាវិលាស និងសម្រេចមកអំពីបុណ្យជារបស់ពិត មិនប្រែប្រួល ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់បានទទួលព្រះនាមថា តថាគត ។ ព្រោះផ្លាស់ **ទ** អក្ខរៈ ជា **ត** អក្ខរៈ ដោយប្រការដូចពោលមកនេះ ។ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះអត្ថថា គ្របសង្កត់ដូចពណ៌នាមក ដូច្នេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះអត្ថថា ទ្រង់ចូលដល់ដោយសេចក្តីពិតខ្លះ ទ្រង់ចូលដល់សេចក្តីពិតខ្លះ ។ បទថា **គតោ** ដោយអត្ថថា ដល់ហើយ ផុតហើយ សម្រេចហើយ ដើរទៅដល់

ហើយ ។ ក្នុងពាក្យទាំងនោះ គប្បីជ្រាបអធិប្បាយដូច្នេះ ព្រះមានព្រះភាគ ទ្រង់ដល់ហើយ គឺស្ទង់ដល់ហើយនូវលោកទាំងអស់ ដោយសេចក្ដីពិត គឺ តីរណប្បរិញ្ញា ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **តថាគត** ។

ព្រះមានព្រះភាគ ទ្រង់ដល់ហើយ គឺផុតហើយ នូវហេតុកើតរបស់លោក ដោយសេចក្ដីពិត គឺបហានប្បរិញ្ញា ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា តថាគត ។

ព្រះមានព្រះភាគ ទ្រង់ដល់ហើយ គឺសម្រេចហើយនូវការរលត់របស់ លោកដោយសេចក្ដីពិត គឺការធ្វើឲ្យជាក់ច្បាស់ ព្រោះហេតុនោះ ទើបទ្រង់ ព្រះនាមថា **តថាគត** ។

ព្រះមានព្រះភាគ ទ្រង់ដល់ហើយ គឺយាងទៅដល់ហើយ នូវសេចក្ដីពិត គឺបដិបទាដែលជាហេតុ ឲ្យដល់នូវការរំលត់លោក ព្រោះហេតុនោះ ទើប ទ្រង់ព្រះនាមថា **តថាគត** ។

ព្រោះហេតុនោះ ពាក្យណាដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុ ទាំងឡាយ លោក ( គឺទុក្ខសច្ច ) តថាគតបានត្រាស់ដឹងហើយ តថាគតផុត ចាកលោក ( គឺទុក្ខសច្ច ) ហើយ ម្នាលភិក្ខុទាំងឡាយ លោកសមុទយៈ តថាគតបានត្រាស់ដឹងហើយ លោកសមុទយៈ តថាគតបានលះបង់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធ តថាគតបានត្រាស់ដឹងហើយ លោកនិរោធ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធគាមិនី- បដិបទា តថាគតបានត្រាស់ដឹងហើយ លោកនិរោធគាមិនីបដិបទា តថាគត

បានចម្រើនហើយ ព្រោះដូច្នោះ ទើបបានទទួលព្រះនាមថា **តថាគត** អត្ថនៃពាក្យនោះ អ្នកសិក្សាគប្បីជ្រាបយ៉ាងនេះ ។

ពាក្យដូចពោលមកនេះ ក៏ត្រឹមតែមុខកថាក្នុងការសម្តែងដល់ភាវៈដែលព្រះតថាគត ជាអ្នកចូលដល់សេចក្តីពិតប៉ុណ្ណោះ ព្រះតថាគតប៉ុណ្ណោះ គប្បីពណ៌នាភាវៈដែលព្រះតថាគត ជាអ្នកចូលដល់សេចក្តីពិតបាន ដោយអាការគ្រប់យ៉ាង ។

ចំណែកក្នុង ២ បទថា **អរហំ សម្មាសម្ពុទ្ធោ** គប្បីជ្រាបអធិប្បាយដូច្នេះ លំដាប់ដំបូង ព្រះមានព្រះភាគគប្បីជ្រាបថា ជាព្រះអរហន្តដោយហេតុទាំងនេះ គឺព្រោះទ្រង់ឆ្ងាយ ១ ព្រោះទ្រង់កម្ចាត់សត្រូវទាំងឡាយ ១ ព្រោះទ្រង់កាច់បំបាក់នូវកាំ ( នៃសង្សារចក្រ ) ទាំងឡាយ ១ ព្រោះជាបុគ្គលគួរដល់បច្ច័យជាដើម ១ ព្រោះមិនធ្វើបាបក្នុងទីកំបាំង ១ ។

ឯឈ្មោះថា **សម្មាសម្ពុទ្ធ** ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង សេចក្តីសង្ខេបក្នុងទីនេះមានប្រមាណប៉ុណ្ណោះ ។ តែបទទាំង ២ នេះ ព្រះពុទ្ធឃោសាចារ្យ បានអធិប្បាយទុកហើយដោយពិស្តារក្នុងកិរិយាពណ៌នាពុទ្ធានុស្សតិ ក្នុងវិសុទ្ធិមគ្គឯណោះ ។

ក្នុងបទថា **បរិញ្ញាតន្តំ តថាគតស្ស** នេះ គប្បីជ្រាបអធិប្បាយថា វត្ថុ ( ដែលជាទីតាំង ) នៃការសម្គាល់ គឺប្រកាន់នោះ ព្រះតថាគតកំណត់ដឹងហើយ ដូច្នេះក៏បាន ។ វត្ថុនោះ ឈ្មោះថា តថាគតកំណត់ដឹងហើយ គឺមានភាវៈដែលទ្រង់ដឹងដោយប្រពៃហើយ មានទីបំផុត ដែលទ្រង់ដឹងដោយប្រពៃ

ហើយ អធិប្បាយថា ទ្រង់ដឹងដោយមិនមានអ្វីសេសសល់ ។

ពិតហើយ ព្រះពុទ្ធទាំងឡាយ មួយអន្លើដោយសាវក មិនមានការផ្សេងគ្នាក្នុងការលះកិលេស ដោយមគ្គនោះៗ ក៏ពិត ទោះយ៉ាងនោះ ក៏មានការផ្សេងគ្នាក្នុងបរិញ្ញា គឺការកំណត់ដឹង ព្រោះថា ពួកសាវកពិចារណាធាតុ ៤ ត្រឹមតែចំណែកខ្លះប៉ុណ្ណោះ ក៏សម្រេចនិព្វានបាន តែសម្រាប់ព្រះពុទ្ធទាំងឡាយ សង្ខារសូម្បីមានប្រមាណតិច ដែលមិនបានឃើញ មិនបានត្រិះរិះ មិនបានពិចារណា មិនបានធ្វើឲ្យជាក់ច្បាស់ដោយព្រះញាណ រមែងមិនមាន ។

ចំណែកវារៈពោលដោយនិព្វាន គឺវារៈជាដើមថា **នន្ទិ** ជាឫសគល់នៃទុក្ខនេះ ដែលព្រះពុទ្ធត្រាស់ទុក្ខហើយ វារៈនោះ គួរពង្រីកសេចក្តីឲ្យពិស្តារក្នុងវារៈពោលដោយបឋវីធាតុជាដើម ។ វារៈនេះជាវារៈពោលដោយវត្ថុដែលទ្រង់កំណត់ដឹង និងកាលពង្រីកឲ្យពិស្តារចេញទៅ វារៈឈ្មោះថា **បរិញ្ញាតន្តំ តថាគតស្ស** គួរប្រកបចូលជាមួយគ្រប់បទ ( ទាំង ) ពាក្យថា **នន្ទិ** ជាឫសគល់នៃទុក្ខជាដើម ក៏គួរប្រកបចូលមកទៀត ។ ឯទេសនា ព្រះមានព្រះភាគ ទ្រង់សង្ខេបទុកដោយទ្រង់សម្គាល់ថា វត្ថុ ( ដែលជាទីតាំងនៃការសម្គាល់ ) ក៏លោកពោលទុកគ្រប់បទនោះឯង ។

## អធិប្បាយ ពាក្យថា នន្ទិ ទុក្ខស្ស មូលំ

[ ៩ ] ម្យ៉ាងទៀត ក្នុងបទថា **នន្ទិ ទុក្ខស្ស មូលំ** ជាដើម គប្បីជ្រាបអធិប្បាយដូចតទៅនេះថា

បទថា **នន្ទិ** បានដល់ តណ្ហាដែលកើតដំបូង ។ បទថា **ទុក្ខំ** បានដល់

បញ្ចក្ខន្ធ ។ បទថា **មូលំ** បានដល់ ឫសគល់ ។ បទថា **ឥតិ វិទិត្វា** សេចក្ដីថា ព្រោះទ្រង់ជ្រាបទន្ទិក្នុងភពដំបូងយ៉ាងនេះថា ជាឫសគល់នៃទុក្ខនេះ បទថា **ភវា** បានដល់ កម្មភព ។ បទថា **ជាតិ** បានដល់ វិបាកក្ខន្ធ ។ ពិតហើយ វិបាកក្ខន្ធទាំងនោះ ព្រោះហេតុដែលកើតដូច្នោះ ទើបត្រាស់ហៅថា **ជាតិ** ។ ម្យ៉ាងទៀត ទេសនានេះ ព្រះមានព្រះភាគសម្ដែងទុកដោយលើកដល់ជាតិជាមាតិកា ។ កាលបើដូច្នេះ ទើបគួរប្រកបចូលជាមួយពាក្យថា **ឥតិ វិទិត្វា** ។ ក្នុងពាក្យនេះ មានអធិប្បាយដូច្នេះថា ព្រោះទ្រង់ជ្រាបយ៉ាងនេះថា កម្មភព គឺចេតនា មាន ទើបមានឧបបត្តិភព ។ បទថា **ភូតស្ស** ប្រែថា នៃសត្វ ។ បទថា **ជរាមរណំ** ប្រែថា ជរា និងមរណៈ ។ មានពាក្យអធិប្បាយយ៉ាងនេះថា ព្រោះទ្រង់ជ្រាបយ៉ាងនេះថា ជរា និងមរណៈរមែងមានដល់ខន្ធនៃសត្វដែលកើតមកហើយ ព្រោះឧបបត្តិភពនោះ ។

ព្រះមានព្រះភាគប្រថាប់គង់ លើអបរាជិតបល្ល័ង្ក ទៀបគល់ពោធិព្រឹក្ស ទ្រង់ពិចារណាបដិច្ចសមុប្បាទណា ទើបបានសម្រេចព្រះសព្វញ្ញុតញ្ញាណ ព្រោះទ្រង់ចាក់ធ្លុះនូវបដិច្ចសមុប្បាទនោះ កាលទ្រង់សម្ដែងហេតុនៃការមិនមាននៃការសម្គាល់ខុសទាំងឡាយ ទើបទ្រង់សម្ដែងបដិច្ចសមុប្បាទនេះឯង ដែលមានសង្ខេប ៤ សន្ធិ ៣ អទ្ធា ៣ និងអាការ ២០ ។

សួរថា បដិច្ចសមុប្បាទទាំងអស់នោះ ព្រះមានព្រះភាគទ្រង់សម្ដែងហើយ ដោយពាក្យមានប្រមាណប៉ុណ្ណោះដូចម្ដេច ឆ្លើយថា ក្នុងបទថា **នន្ទិ ទុក្ខស្ស មូលំ** នេះ មានអធិប្បាយថា សព្វថា **នន្ទិ** នេះ ជាសង្ខេបទី ១

**ឧក្ខ** ជាសង្ខេបទី ២ ព្រោះព្រះបាលីថា **ឧក្ខស្ស** ភពជាសង្ខេបទី ៣ ព្រោះព្រះបាលីថា **ភវា ជាតិ** ជាតិ ជរា និងមរណៈជាសង្ខេបទី ៤ គប្បីជ្រាបសង្ខេប ៤ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ដូចពណ៌នាមក ដូច្នេះ ។ បទថា **សង្ខេប** អធិប្បាយថា បានដល់ ចំណែកទាំងឡាយ ។

ចន្លោះតណ្ហា និងទុក្ខ ជាសន្ធិទី ១ ចន្លោះទុក្ខ និងភព ជាសន្ធិទី ២ ចន្លោះភព និងជាតិ ជាសន្ធិទី ៣ គប្បីជ្រាបសន្ធិ ៣ សង្ខេប ៤ ដែលដូចគ្នានឹងចន្លោះនៃម្រាមដៃទាំង ៤ ដូចពណ៌នាមក ដូច្នេះ ។

ក្នុងបដិច្ចសមុប្បាទនោះ ទន្ទិជាអតីតអទ្ធា ជាតិ ជរា និងមរណៈជាអនាគតអទ្ធា ទុក្ខ និងភព ជាបច្ចុប្បន្នអទ្ធា គប្បីជ្រាបអទ្ធា ៣ ដូចពណ៌នាមក ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងអតីតអទ្ធា ក្នុងបណ្ដាអាការ ៥ ដោយបទថា **ឆន្ទិ** ទើបតណ្ហាមកហើយ ១ សូម្បីតណ្ហានោះមិនទាន់មក ( អាការ ៤ ) គឺអវិជ្ជា សង្ខារ ឧបាទាន និងភព ក៏សង្គ្រោះចូលមកនោះឯង ដោយលក្ខណៈដែលជាបច្ច័យ ។ ម្យ៉ាងទៀត ដោយពាក្យថា **ជាតិ ជរា** និង **មរណៈ** ព្រោះហេតុដែលអធិប្បាយទុកថា ខន្ធទាំងឡាយណា មានជាតិ ជរា និងមរណៈ ខន្ធទាំងនោះ ព្រះមានព្រះភាគបានត្រាស់ទុកហើយ ក្នុងអនាគតអទ្ធា ទើបជាការរួមយកវិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា ចូលជាមួយគ្នាដែរ ។

ក្នុងកម្មភព ដែលជាភពដំបូង មានធម៌ ៥ ប្រការ គឺមោហៈ គឺអវិជ្ជា

ការប្រមូលមក គឺសង្ខារ ការប្រាថ្នា គឺតណ្ហា ការចូលទៅប្រកាន់ គឺឧបាទាន ចេតនា គឺភព ជាបច្ច័យនៃបដិសន្ធិក្នុងបច្ចុប្បន្នអទ្ធា ក្នុងកម្មភពដែលជាភពដំបូង ។

ក្នុងបច្ចុប្បន្នអទ្ធា មានធម៌ ៥ គឺបដិសន្ធិ គឺវិញ្ញាណ វត្ថុដែលឈានចុះ គឺនាមរូប បសាទរូប គឺអាយតនៈ អាការដែលពាល់ត្រូវ គឺផស្សៈ អាការដែលសោយអារម្មណ៍ គឺវេទនា ជាបច្ច័យរបស់កម្មដែលធ្វើទុកមុន ក្នុងឧបបត្តិភព ក្នុងបច្ចុប្បន្នអទ្ធា ។

តែក្នុងបច្ចុប្បន្នអទ្ធា អាយតនៈទាំងឡាយចម្រើនបានល្អហើយ ទើបមានធម៌ ៥ មោហៈ គឺអវិជ្ជា ការប្រមូលមក គឺសង្ខារ ការប្រាថ្នា គឺតណ្ហា ការចូលទៅប្រកាន់ គឺឧបាទាន ចេតនា គឺកម្មភព ជាបច្ច័យរបស់បដិសន្ធិក្នុងអនាគតអទ្ធា ព្រោះកម្មភពក្នុងបច្ចុប្បន្នអទ្ធា ។

ក្នុងអនាគតអទ្ធា មាន ៥ ប្រការ បដិសន្ធិ គឺវិញ្ញាណ វត្ថុដែលឈានចុះ គឺនាមរូប បសាទរូប គឺអាយតនៈ អាការដែលពាល់ត្រូវ គឺផស្សៈ អាការដែលសោយអារម្មណ៍ គឺវេទនា ជាបច្ច័យនៃកម្មដែលធ្វើទុកហើយ ក្នុងបច្ចុប្បន្នអទ្ធា ព្រោះឧបបត្តិភព ក្នុងអនាគតអទ្ធា ។

គប្បីជ្រាបអាការ ២០ ក្នុងបដិច្ចសមុប្បាទនេះ ដែលមានលក្ខណៈដូចសម្ដែងទុកហើយយ៉ាងនេះ ដោយប្រការដូច្នេះឯង ។

បដិច្ចសមុប្បាទដែលមានសង្ខេប ៤ មានសន្ធិ ៣ មានអទ្ធា ៣ និងមានអាការ ២០ ទាំងអស់គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់សម្ដែងហើយ

ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណោះថា ព្រោះជ្រាបយ៉ាងនេះថា **នន្ទិ** ជាឫសគល់នៃទុក្ខ ទើបជ្រាបតទៅថា ព្រោះភព ទើបមានជាតិ សត្វដែលកើតមកហើយ រមែងមានជរា និងមរណៈ ដោយប្រការដូចពណ៌នាមក ដូច្នេះ ។

ឥឡូវនេះ ខ្ញុំនឹងធ្វើការពណ៌នាទៅតាមលំដាប់បទ ក្នុងបទថា **តស្មា តិហ ភិក្ខវេ ។បេ។ អភិសម្ពុទ្ធោតិ វទាមិ** ហើយសរុបដោយបទយោជនា ។

បទថា **តស្មា តិហ** អធិប្បាយថា បានដល់ **តស្មា** ដែលប្រែថា ព្រោះហេតុនោះឯង ។ **តិ** អក្ខរៈ និង **ហ** អក្ខរៈ ជានិបាត ។ ពាក្យថា **សព្វសោ** នោះ ជាពាក្យពោលមិនមានចំណែកសល់ ។ បទថា **តណ្ហានំ** បានដល់ តណ្ហាទាំងអស់ ដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា **នន្ទិ** បទថា **ខយា** ប្រែថា ព្រោះការអស់ទៅជាសមុច្ឆេទដោយលោកុត្តរមគ្គ ។ ពាក្យថា **វិរាគ** ជាដើម ជាវេវចនៈនៃពាក្យថា **ខយ** គឺការអស់ទៅ ។ អធិប្បាយថា តណ្ហាពួកណាអស់ទៅហើយ តណ្ហាទាំងនោះ រមែងប្រាសទៅខ្លះ រលត់ហើយខ្លះ លះបង់ហើយខ្លះ រលាស់ចោលខ្លះ ។ ម្យ៉ាងទៀត ពាក្យថា **ខយា** នេះ ជាពាក្យប្រើទូទៅដល់កិច្ចរបស់មគ្គទាំង ៤ ។ ព្រោះហេតុនោះ ទើបគួរអធិប្បាយប្រកបសេចក្តីថា ព្រោះខ្ជាក់ចោលបានដោយមគ្គទី ១ មគ្គទី ២ ព្រោះលះបង់បានដោយមគ្គទី ៣ ព្រោះរលាស់ចោលជាសមុច្ឆេទដោយមគ្គទី ៤ ។

ម្យ៉ាងទៀត គប្បីធ្វើអធិប្បាយប្រកបសេចក្តីក្នុងព្រះតម្រាស់ក្នុងទីនេះយ៉ាងនេះថា បុថុជ្ជន សម្គាល់នូវបឋវីធាតុ ថាជាបឋវីធាតុ ដោយតណ្ហាពួកណា

ព្រោះការអស់ទៅនៃតណ្ហាទាំងនោះ បុថុជ្ជនសម្គាល់នូវបឋវីធាតុដោយតណ្ហា ណា ព្រោះខ្វាក់ចេញបាននូវតណ្ហាទាំងនោះ បុថុជ្ជនសម្គាល់ក្នុងបឋវីធាតុ ដោយតណ្ហាពួកណា ព្រោះរំលត់តណ្ហាទាំងនោះចេញបាន បុថុជ្ជនគប្បី សម្គាល់ចាកបឋវីធាតុ ដោយតណ្ហាពួកណា ព្រោះលះបង់នូវតណ្ហាទាំងនោះ ចេញបាន បុថុជ្ជនសម្គាល់ថា បឋវីធាតុរបស់អញ ដោយតណ្ហាពួកណា ព្រោះលះបង់តណ្ហាទាំងនោះចេញបាន ម្យ៉ាងទៀត បុថុជ្ជនសម្គាល់បឋវីធាតុ ដោយតណ្ហាពួកណា ព្រោះការអស់ទៅនៃតណ្ហាទាំងនោះ ។បេ។ បុថុជ្ជនគប្បី ត្រេកអរក្នុងបឋវីធាតុ ដោយតណ្ហាពួកណា ព្រោះលះបង់តណ្ហាទាំងនោះ ចេញបាន ។ សេចក្តីទាំង ២ នេះ មិនមានអ្វីដែលជំទាស់គ្នា ។

បទថា **អនុត្តរំ** គឺវៀរចាកបុគ្គលដែលក្រៃលែងជាង បានដល់ ប្រសើរ ជាងបុគ្គលដទៃទាំងអស់ ។

## អត្ថរបស់ ពោធិ សព្ទ

បទថា **សម្មាសម្ពោធឹ** ប្រែថា ការត្រាស់ដោយប្រពៃ និងដោយព្រះអង្គ ឯង ។ ម្យ៉ាងទៀត ដោយអត្ថថា ការត្រាស់ដឹងដែលបណ្ឌិតសរសើរ និង ប្រពៃ ។ បទថា **ពោធិ** បានដល់ ដើមឈើខ្លះ មគ្គខ្លះ សព្វញ្ញុតញ្ញាណខ្លះ និព្វានខ្លះ ។ អធិប្បាយថា ដើមឈើ ហៅថា ពោធិ ដូចក្នុងអាគតដ្ឋានថា **ពោធិរុក្ខមូលេ បឋមាភិសម្ពុទ្ធោ** ប្រែថា បានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅ ក្រោមម្លប់ពោធិព្រឹក្ស និងបទថា **អន្តរា ច ពោធឹ អន្តរា ច គយំ** ប្រែថា ក្នុងចន្លោះនៃគយាសីសប្រទេសផង ក្នុងចន្លោះពោធិព្រឹក្សផង ។ មគ្គ លោក

ហៅថា **ពោធិ** ដូចក្នុងអាគតដ្ឋានថា **ចតូសុ មគ្គេសុ ញាណំ** ប្រែថា ញាណក្នុងមគ្គទាំង ៤ លោកហៅថា **ពោធិ** ដូចក្នុងអាគតដ្ឋានថា **បប្បោតិ ពោធឹ វរភូរិ មេធសោ** ប្រែថា តថាគតនោះ មានប្រាជ្ញាដ៏ប្រសើរ ប្រៀបដោយផែនដី និងបានដល់ពោធិញ្ញាណដ៏ខ្ពង់ខ្ពស់ មានចំណែកដ៏ប្រសើរក្នុងផ្លូវប្រាជ្ញា ។ និព្វានលោកហៅថា **ពោធិ** ដូចក្នុងអាគតដ្ឋានថា **បត្វាន ពោធឹ អមតំ អសង្ខតំ** ប្រែថា ព្រះមានព្រះភាគ ទ្រង់សម្រេចពោធិ ដែលជាអមតៈ មិនមានបច្ច័យតាក់តែង ។ តែក្នុងទីនេះ បំណងយកអរហត្ត-មគ្គញ្ញាណនៃព្រះមានព្រះភាគ ។ អាចារ្យពួកខ្លះ ពោលថា បំណងយកសព្វញ្ញុតញ្ញាណដូច្នេះក៏មាន ។

សួរថា អរហត្តមគ្គនៃសាវ័កទាំងឡាយ ចាត់ជាពោធិញ្ញាណដ៏កំពូលឬទេ ឆ្លើយថា មិនរាប់ចូលទេ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះឲ្យសម្រេចគុណមិនបានគ្រប់យ៉ាង ។

ពិតហើយ បណ្តាសាវ័កទាំងនោះ អរហត្តមគ្គនៃបុគ្គលខ្លះ ឲ្យបានចំពោះអរហត្តផលប៉ុណ្ណោះ ។ របស់អង្គខ្លះឲ្យវិជ្ជា ៣ របស់អង្គខ្លះឲ្យអភិញ្ញា ៦ របស់អង្គខ្លះឲ្យបដិសម្ភិទា ៤ របស់អង្គខ្លះឲ្យសម្រេចត្រឹមសាវកបារមី-ញាណ ។ របស់ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏ឲ្យចំពោះបច្ចេកពោធិញ្ញាណប៉ុណ្ណោះ ឯអរហត្តមគ្គនៃព្រះពុទ្ធទាំងឡាយ ឲ្យគុណសម្បត្តិគ្រប់យ៉ាង ដូចការអភិសេកក្នុងរាជសម្បត្តិរបស់ព្រះរាជា រមែងឲ្យភាពជាធំក្នុងលោកទាំងអស់ ព្រោះដូច្នោះ ទើបពោធិញ្ញាណរបស់បុគ្គលដទៃ មិនរាប់ថា ជាកំពូល

( ដូចសព្វញ្ញុតញ្ញាណ ) ។

បទថា **អភិសម្ពុទ្ធោ** ដោយអត្ថថា ដឹងក្រៃលែងហើយ គឺចាក់ធ្លុះហើយ អធិប្បាយថា ដល់ហើយ គឺសម្រេចហើយ ។ បទថា **ឥតិ វទាមិ** សេចក្តីថា តថាគតរមែងពោល គឺត្រាស់សម្តែង បញ្ញត្ត តែងតាំង បើកផ្ចារ បែកធ្វើឲ្យងាយ ដោយប្រការដូច្នេះ ។ ក្នុងពាក្យនោះ មានអធិប្បាយពង្រីកសេចក្តីដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគត ។បេ។ រមែងមិនសម្គាល់បឋវីធាតុ ។បេ។ រមែងមិនត្រេកអរក្នុងបឋវីធាតុ សេចក្តីនុ៎ះព្រោះហេតុអ្វី ព្រោះតថាគតដឹងយ៉ាងនេះថា នន្ទិជាឫសគល់នៃទុក្ខ ព្រោះភព ទើបមានជាតិ សត្វដែលកើតមកហើយមានជរា និងមរណៈ ។

**ឥតិ** អក្ខរៈ ក្នុងបទថា **ឥតិ វិទិត្វា** ដែលមកក្នុងបទថា **នន្ទិ ទុក្ខស្ស–មូលំ ។បេ។ ជរា មរណាន្តិ ឥតិ វិទិត្វា** នោះ មានអត្ថថា ការណៈ គឺជាហេតុ ព្រោះហេតុនោះ ទើបមានអធិប្បាយថា ព្រោះដឹងច្បាស់ គឺព្រោះចាក់ធ្លុះនូវបដិច្ចសមុប្បាទនេះ ។

គប្បីជ្រាបបន្ថែមតិចតួចទៀត ។ ព្រោះព្រះតថាគត ទ្រង់ដឹងច្បាស់នូវបដិច្ចសមុប្បាទនេះយ៉ាងនេះ ទើបទ្រង់លះតណ្ហាដែលត្រាស់ថា នន្ទិនោះបានគ្រប់ប្រការ និងព្រោះតណ្ហាទាំងនោះអស់ទៅទាំងអស់ ទើបព្រះតថាគតបានត្រាស់ដឹងព្រមចំពោះ នូវអនុត្តរសម្មាសម្ពោធិញ្ញាណ ព្រោះដូច្នោះ ទើបតថាគតពោលថា ព្រះតថាគតមិនសម្គាល់ក្នុងបឋវីធាតុ ។បេ។ មិនត្រេកអរក្នុងបឋវីធាតុ អធិប្បាយថា ព្រោះត្រាស់ដឹងព្រមចំពោះយ៉ាងនេះ ទើបតថាគត

ពោលថា ព្រះតថាគតមិនសម្គាល់ មិនត្រេកអរក្នុងបឋវីធាតុ ។

ម្យ៉ាងទៀត ព្រោះព្រះតថាគត ទ្រង់ដឹងច្បាស់នូវបដិច្ចសមុប្បាទ ដោយន័យជាដើមថា នន្ទិ ជាឫសគល់របស់ទុក្ខ ទើបទ្រង់ដល់នូវការអស់ទៅនៃតណ្ហា ដោយប្រការទាំងពួងដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ ទើបតថាគតពោលថា តថាគតបានត្រាស់ដឹងព្រមចំពោះ ។បេ។ ព្រោះការអស់ទៅនៃតណ្ហាដោយប្រការទាំងពួង ព្រោះបានត្រាស់ដឹងព្រមយ៉ាងនេះ ទើបព្រះ-តថាគតមិនសម្គាល់បឋវីធាតុ ។បេ។ មិនត្រេកអរ ។ ក្នុងទីណាមួយ ព្រះមានព្រះភាគទ្រង់មិនបានត្រាស់ **យស្មា** ( ព្រោះហេតុណា ) ត្រាស់តែ **តស្មា** ( ព្រោះហេតុនោះ ) ក្នុងទីនោះ ត្រូវនាំយក **យស្មា** មកប្រកបចូលផង ។ វិធីនេះជាវិធីយុត្តិក្នុងផ្លូវសាសនា ។ ក្នុងគ្រប់បទក៏មានន័យយ៉ាងនេះដូចគ្នា ។

## ភិក្ខុមិនត្រេកអរនឹងភាសិតរបស់ព្រះតថាគត

បទថា **ឥទមវោច ភគវា** សេចក្តីថា ព្រះមានព្រះភាគកាលទ្រង់សម្តែងព្រះសព្វញ្ញុតញ្ញាណដ៏ជ្រាលជ្រៅក្រៃលែង មានការចាក់ធ្លុះដល់ មិនគប្បីបានដោយបញ្ញារបស់អ្នកដទៃ ទើបទ្រង់ប្រដាប់ដោយវារៈរបស់បុថុជ្ជនមួយវារៈ ដោយវារៈរបស់ព្រះសេក្ខបុគ្គលមួយវារៈ ដោយវារៈរបស់ព្រះខីណាស្រព ៤ វារៈ ដោយវារៈរបស់ព្រះតថាគត ២ វារៈ រួមជាប្រដាប់ដោយវារៈធំ ៨ វារៈ ហើយវារៈធំ ១ ទ្រង់ប្រដាប់ដោយវារៈក្នុងចន្លោះ គឺវារៈបន្ទាប់បន្សំ ២៤ វារៈ មានវារៈពោលដោយបឋវីធាតុជាដើម ហើយបានត្រាស់ព្រះសូត្រទាំងអស់

ដែលផ្តើមតាំងអំពីវគ្គបញ្ចប់ ពាក្យផ្តើមខាងដើម រហូតដល់ពាក្យថា **យាវ អភិសម្ពុទ្ធោតិ វទាមិ** ដោយបរិយត្តិចំនួន ២ ភាណវារ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះដែលប្រកបដោយន័យដ៏វិចិត្រ និងទេសនាវិលាស ដោយព្រះសូរសៀង ដូចសំឡេងនៃព្រហ្ម ពីរោះដូចសំឡេងនៃការវិក ហាក់ដូចទ្រង់បានស្រោចនូវហទយៈនៃជនដោយទឹកអម្រឹត ព្រោះពីរោះត្រចៀកយ៉ាងនេះ ( ភិក្ខុទាំងនោះក៏មិនបានត្រេកអរព្រះភាសិត ) ។

បទថា **ន តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ** សេចក្តីថា ភិក្ខុទាំង ៥០០ អង្គនោះ មិនបានអនុមោទនាព្រះតម្រាស់របស់ព្រះមានព្រះភាគឡើយ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនយល់ ។ បានឮថា ភិក្ខុទាំងនោះ មិនយល់អត្ថរបស់សូត្រនេះ ដូច្នោះ ទើបមិនត្រេកអរ ។ ពិតហើយ ក្នុងសម័យនោះ ព្រះសូត្រនោះ សូម្បីប្រកបដោយន័យដ៏វិចិត្រ និងជាទេសនាវិលាសយ៉ាងនេះ សម្រាប់ភិក្ខុទាំងនោះ បានត្រឹមតែដូចគេយកសំពត់ក្រាស់ចងមាត់ ហើយយកគ្រឿងបរិភោគដែលពេញចិត្តមកដាក់ត្រង់ចំពោះមុខ មិនអាចបរិភោគបាន ដូច្នោះ ។

សួរថា ព្រះមានព្រះភាគ ទ្រង់បំពេញបារមីមកអស់ ៤ អសង្ខេយ្យ ហើយសម្រេចសព្វញ្ញុតញ្ញាណដើម្បីទូន្មានអ្នកដទៃឲ្យយល់ធម៌ ដែលព្រះអង្គទ្រង់សម្តែងមិនមែនឬ ហេតុដូចម្តេច ទើបទ្រង់សម្តែងធម៌ដល់ភិក្ខុទាំងនោះ ដោយភិក្ខុទាំងនោះមិនយល់ទៅវិញ ឆ្លើយថា ចម្លើយនេះ លោកបានពោលហើយ ក្នុងការពិចារណាបទផ្តើម របស់សូត្រនោះថា ព្រះមានព្រះភាគ ទ្រង់

ផ្តើមទេសនាយ៉ាងនេះថា **សព្វធម្មមូលបរិយាយំ** ដើម្បីកាច់បំបាក់នូវមានះរបស់ភិក្ខុទាំងនោះ ដូច្នោះ ទើបក្នុងទីនេះ មិនមានអ្វីដែលត្រូវពោលដដែលទៀត ។

កាលបានស្តាប់សូត្រនេះ ដែលព្រះមានព្រះភាគទ្រង់សម្តែងដើម្បីបំបាក់បង់នូវមានះយ៉ាងនេះហើយ ទើបភិក្ខុទាំងនោះគិតគ្នាថា បានឮថា បុថុជ្ជនមានទិដ្ឋិជាគន្លងដើរទៅ រមែងសម្គាល់នូវបឋវីនោះឯង ឯព្រះសេក្ខៈ និងព្រះអរហន្ត ព្រះតថាគតរមែងជ្រាបយ៉ាងច្បាស់ថា វត្ថុនេះ គឺអ្វី វត្ថុនេះ ដូចម្តេចដូច្នេះ ជាអ្នកអស់មានះ ដូចអាសិរពិសដែលត្រូវដកចង្កូមហើយ ដូច្នោះដោយរឭកបានថា កាលមុនពួកយើងរមែងដឹងនូវទៅដល់ព្រះតម្រាស់ណាមួយដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយ យ៉ាងរួសរាន់នោះឯង តែឥឡូវនេះបែរជាមិនដឹង មិនឃើញទីបំផុត ឬអាថ៌កំបាំងនៃមូលបរិយាយសូត្រនេះឡើយ គួរអស្ចារ្យហ្ន៎ ព្រះពុទ្ធទាំងឡាយ ទ្រង់មានបញ្ញា មិនមានបុគ្គលណាមួយប្រមាណបាន ដូច្នេះហើយ បាននាំគ្នាទៅកាន់ទីគាល់ព្រះសម្ពុទ្ធ និងទៅស្តាប់ធម៌ដោយគោរព ។

សម័យនោះឯង ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងធម្មសភាសន្ទនាគ្នាដល់រឿងនេះថា គួរអស្ចារ្យពិត អានុភាពរបស់ព្រះពុទ្ធទាំងឡាយ ព្រាហ្មណ៍បណ្ឌិត ទាំងនោះស្រវឹងហើយក្នុងមានះ គង់ធ្វើឲ្យអស់មានះបានដោយមូលបរិយាយទេសនារបស់ព្រះមានព្រះភាគ ។ ឥឡូវនេះ ភិក្ខុទាំងនោះ កំពុងជជែកគ្នាមិនទាន់ចប់ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីព្រះ

គន្ធកុដិ ទៅប្រថាប់លើបវរពុទ្ធាសនៈដែលគេក្រាលទុកក្នុងធម្មសភា ដោយបាដិហារ្យដែលសមគួរក្នុងខណៈនោះ ហើយបានត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសន្ទនាគ្នាដោយរឿងអ្វី ។ ភិក្ខុទាំងនោះបានទូលសេចក្ដីនុ៎ះដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគបានត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏បានធ្វើភិក្ខុទាំងនេះ ដែលក្អេងក្អាងដោយមានះ ឲ្យអស់មានះហើយដូចគ្នា ។ បន្ទាប់អំពីនោះ ព្រោះកើតរឿងនេះជាហេតុ ទើបព្រះមានព្រះភាគទ្រង់នាំអតីតនិទាន នេះមកពោលថា

ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយ ព្រាហ្មណ៍ទិសាបាមោក្ខម្នាក់ អាស្រ័យនៅក្នុងក្រុងពារាណសី រៀនចប់ត្រៃវេទ ព្រមទាំងនិឃណ្ឌុ-សាស្ត្រ និងកេដុភសាស្ត្រ និងអក្ខរប្បភេទសម័យ មានគម្ពីរឥតិហាសជាគម្រប់ ៥ ជាអ្នកជំនាញក្នុងគម្ពីរវេយ្យាករណ៍ និងមហាបុរិសលក្ខណៈ ក្នុងគម្ពីរលោកាយតៈ ។ ព្រាហ្មណ៍នោះ បានបង្រៀនមន្តដល់មាណព ៥០០ នាក់ ។ ពួកមាណពដែលជាអ្នកឈ្លាស រៀនបានច្រើន ចាំរហ័ស និងស្ទាត់ជំនាញ មន្តដែលមាណពទាំងនោះរៀនហើយ មិនភ្លេចភ្លាំងឡើយ ។ សូម្បីព្រាហ្មណ៍នោះក៏មិនបានហួងហែងវិជ្ជា ហាក់ដូចជាចាក់ទឹកចូលទៅក្នុងក្អមឲ្យមាណពទាំងនោះរៀនសិប្បៈរហូតអស់ ហើយបានពោលនឹងមាណពទាំងនោះដូច្នេះថា សិប្បៈនេះមានប្រមាណប៉ុណ្ណោះ ជាប្រយោជន៍ទាំងក្នុងបច្ចុប្បន្ន និងចំណែកខាងមុខ ។ មាណពទាំងនោះក៏កើតមានះឡើងថា អាចារ្យរបស់ពួក

យើងដឹងវត្ថុណា ពួកយើងក៏ដឹងវត្ថុនោះ ឥឡូវនេះ ពួកយើងក៏ជាអាចារ្យបាន ហើយ តាំងអំពីនោះមក ក៏ផ្តាច់ការគោរព បោះបង់ចោលវត្តក្នុងអាចារ្យ ។ អាចារ្យជ្រាបហើយ គិតថា អញនឹងធ្វើការញាំញីមានះរបស់មាណពទាំងនេះ ថ្ងៃមួយ អាចារ្យបានហៅមាណពទាំងនោះមកកាន់ទីទំនុកបម្រុង ហើយពោល ថា នែបាទាំងឡាយ ខ្ញុំនឹងសួរបញ្ហាពួកបា ពួកបាអាចពោលដោះស្រាយបាន ឬទេ មាណពទាំងនោះក៏នាំគ្នាប្រញាប់ឆ្លើយទាំងស្រវឹងក្នុងការសិក្សាថា សួរ មកចុះលោកអាចារ្យ សួរមកចុះលោកអាចារ្យ ។ ទើបអាចារ្យពោលថា

កាលរមែងស៊ីនូវសត្វទាំងអស់ ព្រមទាំងខ្លួនឯង ចំណែកសត្វពួកណាជា អ្នកស៊ីនូវកាល សត្វនោះឈ្មោះថា ដុតនូវតណ្ហា ដែលជាធម្មជាតិដុតសត្វ ។

ហើយពោលតទៅថា បាទាំងឡាយ ចូរពួកបាពោលដោះស្រាយបញ្ហា នេះចុះ ។

មាណពទាំងនោះគិតហើយ តែមិនដឹង ទើបនាំគ្នាទៅស្ងៀម ។ ទើប អាចារ្យពោលថា ណ្ហើយចុះ បាទាំងឡាយ ថ្ងៃនេះទៅវិញសិនចុះ ស្អែកនេះ សឹមមកដោះស្រាយ ដូច្នេះហើយ បញ្ជូនមាណពនោះត្រឡប់ទៅ ។ មាណព ទាំងនោះរួមគ្នាជាក្រុម ១០ នាក់ខ្លះ ២០ នាក់ខ្លះ ពិចារណាប្រស្នា ក៏នៅតែ មិនឃើញខាងដើម មិនឃើញខាងចុងនៃប្រស្នានោះ ទើបពួកមាណពទាំង នោះ នាំគ្នាមកប្រាប់អាចារ្យថា ពួកខ្ញុំមិនយល់អត្ថនៃបញ្ហានេះឡើយ ដើម្បី សង្កត់សង្កិនមាណពទាំងនោះ ទើបអាចារ្យពោលគាថានេះថា

ក្បាលនរជនទាំងឡាយដ៏ច្រើន ក្បាលទាំងនោះមានរោមផង ធំផង គ្រប

នៅលើក បណ្ដាមនុស្សទាំងអម្បាលនោះ គង់មានមនុស្សណាមួយ ដែលមានប្រាជ្ញាមិនខាន ។

គាថានេះ មានអធិប្បាយថា ក្បាលរបស់បុគ្គលជាច្រើនប្រាកដ គឺមានក្បាលទាំងអស់នោះក៏មានសក់ ក្បាលទាំងអស់ធំតាំងនៅលើក តែកាលគិតមិនដល់ ដូចគ្នានឹងផ្លែត្នោត ដូច្នោះ ក្បាលទាំងនោះ និងក្បាលទាំងនេះ មិនមានការប្លែកផ្សេងគ្នា ។ តែក្នុងទីនេះអាចារ្យពោលថា **កោចិនេវ កណ្ណវា** ដូច្នេះ សំដៅយកខ្លួនឯង ។ បទថា **កណ្ណវា** ប្រែថា អ្នកមានបញ្ញា ។ បុគ្គលណាហ្ន៎ ជាអ្នកមិនមានវន្ទត្រចៀក ។

មាណពទាំងនោះបានស្ដាប់គាថានោះហើយ ជាអ្នកអៀនអន់ សំយុង-កឱនមុខ អង្គុយយកម្រាមដៃគូរផែនដី ។ លំដាប់នោះ អាចារ្យឃើញថា មាណពទាំងនោះមានការខ្មាស ទើបពោលថា នែបាទាំងឡាយ ពួកបា ចូររៀនយកប្រស្នាចុះ ដូច្នេះហើយ បានស្រាយប្រស្នាឲ្យមាណពទាំងនោះស្ដាប់ ។

បទថា **កាលោ** បានដល់ កាល គឺបុរេភត្តក្តី បច្ឆាភត្តក្តីជាដើម ។ បទថា **ភូតានិ** នោះ ជាឈ្មោះហៅសត្វ ។ កាលមិនបានទំពាស៊ីសាច់ និងស្បែករបស់សត្វទាំងឡាយឡើយ ដែលពិត វាធ្វើឲ្យអាយុ ពណ៌សម្បុរ និងពលៈរបស់សត្វទាំងនោះឲ្យអស់ទៅ ញ៉ាំញីនូវភាពជាកំលោះ ភាពជាក្រមុំ ធ្វើភាពជាបុគ្គលមិនមានរោគឲ្យវិនាសទៅ ទើបហៅថា ស៊ី គឺទំពាស៊ី ។

បទថា **សព្វានេវ សហត្តនា** សេចក្តីថា កាលតែងទំពាស៊ីយ៉ាងនោះ រមែងមិនវៀរបុគ្គលណាមួយ រមែងស៊ីទាំងអស់នោះឯង មិនមែនស៊ីតែសត្វ

ទាំងឡាយប៉ុណ្ណោះទេ តែដែលពិតនោះ រមែងស៊ីខ្លួនឯងទៅព្រមទាំងខ្លួនឯងនោះឯង បុរេភត្តកខ្លួន មិនមកជាបច្ឆាភត្តឡើយ ។ ក្នុងបច្ឆាភត្តជាដើមក៏មានន័យនេះ ។

បទថា **យោ ច កាលឃសោ ភូតោ** នោះ ជាឈ្មោះហៅព្រះខីណាស្រព ព្រះខីណាស្រពនោះ ហៅថា ជាអ្នកស៊ីកាល ព្រោះលោកជាអ្នកស៊ីបដិសន្ធិកាលក្នុងកពតទៅ រហូតអស់ ហើយតាំងនៅ ។

បទថា **សភូតបចនឹ បចិ** សេចក្តីថា តណ្ហានេះ រមែងដុតសត្វទាំងឡាយក្នុងអបាយទាំងឡាយ ព្រះខីណាស្រពនោះដុតតណ្ហានោះដោយភ្លើង គឺញាណ បានដល់ ធ្វើឲ្យជាផេះទៅហើយ ។ ព្រោះហេតុនោះ ទើបលោកពោលថា **ភូតបចនឹ បចិ** ប្រែថា ដុតតណ្ហាដែលដុតសត្វ ។ ក្នុងបទថា **បចនឹ** បាលីជា **បជ្ជនឹ** ក៏មាន ដោយអត្ថថា ឲ្យកើត គឺឲ្យកើតឡើង ។

លំដាប់នោះ មាណពទាំងនោះឃើញអត្ថរបស់ប្រស្នាប្រាកដច្បាស់តាមពាក្យស្រាយរបស់អាចារ្យ ដូចបុគ្គលឃើញទីរាប និងទីមិនរាបស្មើក្នុងពេលយប់ ដោយពន្លឺប្រទីប ១០០០ ទើបគិតថា ឥឡូវនេះ ពួកយើងនឹងនៅរួមជាមួយអាចារ្យរហូតអស់ជីវិត ដែលឈ្មោះថា អាចារ្យហើយ ជាធំក្រៃលែង តែពួកយើងកើតការប្រកាន់ខ្លួនថា បានសិក្សាមកច្រើន ទើបមិនដឹងអត្ថរបស់គាថាត្រឹម ៤ បាទ កាលលះបង់មានះបានហើយ វិលត្រឡប់មកធ្វើវត្តបដិបត្តិដល់អាចារ្យដូចសព្វដងហើយ បានជាអ្នកមានស្ថានសួគ៌ជាទីទៅខាងមុខ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ តថាគតបានជាអាចារ្យ ភិក្ខុទាំង

នេះបានជាមាណព សូម្បីក្នុងកាលមុន តថាគតក៏បានធ្វើភិក្ខុទាំងនេះ ដែលមានមានះ និងអន្ទោល ទៅយ៉ាងនេះឲ្យអស់មានះ ដោយប្រការដូច្នេះ ។

ភិក្ខុទាំងនោះបានស្តាប់ជាតកនោះហើយ គិតបានថា កាលមុនពួកយើងក៏ត្រូវមានះគ្របសង្កត់ហើយ ទើបលះបង់មានះចេញឲ្យក្រៃលែងឡើងទៅទៀត បានជាអ្នកមានមុខទៅរកកម្មដ្ឋាន ដែលជាឧបការៈដល់ខ្លួន ។ ក្រោយមកព្រះមានព្រះភាគ កាលយាងចារិកទៅក្នុងជនបទ ដល់ក្រុងវេសាលី ហើយប្រថាប់នៅត្រង់គោតមកចេតិយ ទ្រង់ជ្រាបថា ភិក្ខុ ៥០០ នេះមានញាណចាស់ក្លាហើយ ទើបត្រាស់គោតមកសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងធម៌ ដើម្បីឲ្យចេះដឹង មិនមែនដើម្បីមិនឲ្យចេះដឹងទេ ម្នាលភិក្ខុទាំង-ឡាយ តថាគតសម្តែងធម៌សមតាមហេតុ មិនមែនមិនសមតាមហេតុទេ ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងធម៌ប្រកបដោយសេចក្តីអស្ចារ្យ មិនមែនមិនប្រកបដោយសេចក្តីអស្ចារ្យទេ ។បេ។ អ្នកទាំងឡាយ គួរធ្វើតាមឱវាទ គួរធ្វើតាមអនុសាសនី ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អ្នកទាំងឡាយ គួរត្រេកអរ គួរពេញចិត្ត គួររីករាយ ( ចំពោះគុណព្រះរតនត្រ័យ ) ថា ព្រះដ៏មានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយដោយប្រពៃ ព្រះសង្ឃប្រតិបត្តិដោយប្រពៃ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។ ក៏កាលដែលព្រះដ៏មានព្រះភាគ សម្តែងនូវវេយ្យាករណ៍នេះចប់ហើយ លោកធាតុទាំង ១ ពាន់

ក៏កក្រើករញ្ជួយ ។

ភិក្ខុ ៥០០ អង្គនោះ បានស្តាប់ព្រះសូត្រនេះហើយ បានជាព្រះអរហន្ត ព្រមដោយបដិសម្ភិទាទាំងឡាយ ក្នុងវេលាចប់ព្រះសូត្រនោះឯង ទេសនានេះ ចប់ហើយដោយអាការយ៉ាងនេះ ៕ល៕

## មូលបរិយាយសូត្រ ចប់

## សូត្រទី ១ ចប់

# សុត្តន្តបិដក

## សព្វាសវសំវរសូត្រទី ២

[ ១០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ដូច្នេះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវហេតុនៃសេចក្តីសង្រួមក្នុងអាសវៈទាំងពួង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរប្រុងស្តាប់នូវហេតុនោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃ តថាគតនឹងសម្តែង ។ ពួកភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ១១ ] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការអស់ទៅនៃអាសវធម៌[១] ទាំងឡាយ របស់បុគ្គលអ្នកដឹងអ្នកឃើញ មិនមែនពោលនូវការអស់ទៅ នៃអាសវៈទាំងឡាយ របស់បុគ្គលអ្នកមិនដឹង មិនឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដឹងអ្វី ឃើញអ្វី ទើបអស់ទៅនៃអាសវធម៌ទាំងឡាយ ។ បុគ្គលឃើញនូវយោនិសោមនសិការ និងអយោនិសោមនសិការ[២] ( ទើបអស់ទៅនៃអាសវធម៌ទាំងឡាយ ) ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តដោយខុសទំនង អាសវៈ

---

១- អាសវធម៌ ប្រែថា សភាវៈដែលត្រាំ ឬហូរទៅអំពីភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត ហៅថា អាសវៈ ( មើលអដ្ឋកថាខាងក្រោម ) ។ ២- មើលអដ្ឋកថាខាងក្រោម ។

ទាំងឡាយ ដែលមិនទាន់កើតឡើង រមែងកើតឡើងបានផង អាសវៈទាំង-ឡាយដែលកើតឡើងហើយ រឹងរឹតតែចម្រើនឡើងផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តដោយត្រូវទំនង អាសវៈទាំងឡាយដែលមិនទាន់ កើតឡើង រមែងកើតឡើងមិនបានផង អាសវៈទាំងឡាយដែលកើតឡើង ហើយ រមែងសាបសូន្យទៅវិញផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលត្រូវ លះបង់អាសវៈដោយការឃើញ គឺសោតាបត្តិមគ្គក៏មាន ត្រូវលះបង់អាសវៈ ដោយសេចក្តីសង្រួមឥន្ទ្រិយក៏មាន ត្រូវលះបង់អាសវៈដោយការសេពក៏មាន ត្រូវលះបង់អាសវៈដោយការអត់ធន់ក៏មាន ត្រូវលះបង់អាសវៈដោយការវៀរ ក៏មាន ត្រូវលះបង់អាសវៈដោយការបន្ទោបង់ក៏មាន ត្រូវលះបង់អាសវៈ ដោយការចម្រើនក៏មាន ។

[ ១២ ] ម្នាលភិក្ខុទាំងឡាយ អាសវៈដែលភិក្ខុត្រូវលះបង់ដោយការ ឃើញ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិន បានចេះដឹង មិនបានឃើញនូវព្រះអរិយៈទាំងឡាយ ( មានព្រះពុទ្ធជាដើម ) មិនឈ្លាសក្នុងអរិយធម៌ មិនបានទូន្មានខ្លួន ក្នុងអរិយធម៌ មិនបានឃើញនូវ សប្បុរសទាំងឡាយ ( មានព្រះពុទ្ធជាដើម ) មិនឈ្លាសក្នុងសប្បុរិសធម៌ មិនបានទូន្មានខ្លួនក្នុងសប្បុរិសធម៌ រមែងមិនដឹងច្បាស់ក្នុងធម៌ដែលគួរធ្វើទុក ក្នុងចិត្ត មិនដឹងច្បាស់ក្នុងធម៌ ដែលមិនគួរធ្វើទុកក្នុងចិត្ត ។ កាលបើបុថុជ្ជន នោះ មិនដឹងច្បាស់នូវធម៌ដែលគួរធ្វើទុកក្នុងចិត្ត មិនដឹងច្បាស់នូវធម៌ដែល មិនគួរធ្វើទុកក្នុងចិត្ត ធម៌ណាដែលមិនគួរធ្វើទុកក្នុងចិត្ត ក៏ត្រឡប់ជាធ្វើទុកក្នុង

ចិត្តនូវធម៌ទាំងនោះវិញ ធម៌ណាដែលគួរធ្វើទុកក្នុងចិត្ត ក៏ត្រឡប់ជាមិនធ្វើទុកក្នុងចិត្តនូវធម៌ទាំងនោះវិញ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដូចម្តេចដែលមិនគួរធ្វើទុកក្នុងចិត្ត តែបុថុជ្ជនធ្វើទុកក្នុងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុថុជ្ជនធ្វើទុកក្នុងចិត្ត នូវធម៌ គឺអយោនិសោមនសិការណាហើយ កាមាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងផង កាមាសវៈដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនឡើងផង ភវាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងផង ភវាសវៈដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនឡើងផង អវិជ្ជាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងផង អវិជ្ជាសវៈដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនឡើងផង ធម៌ទាំងនេះឯង ដែលមិនគួរធ្វើទុកក្នុងចិត្ត តែបុថុជ្ជនតែងធ្វើទុកក្នុងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដូចម្តេច ដែលគួរធ្វើទុកក្នុងចិត្ត តែបុថុជ្ជនមិនបានធ្វើទុកក្នុងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលបុថុជ្ជនធ្វើទុកក្នុងចិត្ត នូវធម៌ គឺយោនិសោមនសិការណាហើយ កាមាសវៈដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងមិនបានផង កាមាសវៈដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង ភវាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងមិនបានផង ភវាសវៈដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង អវិជ្ជាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងមិនបានផង អវិជ្ជាសវៈដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង ធម៌ទាំងនេះឯង ដែលគួរធ្វើទុកក្នុងចិត្ត តែបុថុជ្ជនតែងមិនបានធ្វើទុកក្នុងចិត្ត ។ ព្រោះតែបុថុជ្ជននោះ ធ្វើទុកក្នុងចិត្តនូវធម៌ដែល

មិនគួរធ្វើទុកក្នុងចិត្ត មិនធ្វើទុកក្នុងចិត្តនូវធម៌ដែលគួរធ្វើទុកក្នុងចិត្ត ( យ៉ាងនេះហើយ ) បានជាអាសវៈទាំងឡាយ ដែលមិនទាន់កើតឡើង ក៏កើតឡើងផង អាសវៈទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនឡើង ។ បុថុជ្ជននោះ ធ្វើទុកក្នុងចិត្តដោយឧបាយខុសទំនងយ៉ាងនេះថា អំពីអតីតកាល អាត្មាអញបានកើតដែរឬ អំពីអតីតកាលអាត្មាអញមិនបានកើតទេ ( មួយយ៉ាងទៀត ) អំពីអតីតកាល អាត្មាអញមានជាតិជាអ្វី ឬអំពីអតីតកាល អាត្មាអញ មានសណ្ឋានទ្រង់ទ្រាយដូចម្តេច អំពីអតីតកាល អាត្មាអញកើតជាជាតិអ្វី ឬមួយអាត្មាអញមានសណ្ឋានទ្រង់ទ្រាយដូចម្តេច ក្នុងអនាគតកាល អាត្មាអញ នឹងកើតទៀតដែរឬ ក្នុងអនាគតកាល អាត្មាអញនឹងមិនកើតទៀតទេ ( មួយយ៉ាងទៀត ) ក្នុងអនាគតកាល អាត្មាអញនឹងកើតជាជាតិអ្វី ឬក្នុងអនាគតកាល អាត្មាអញនឹងមានសណ្ឋានទ្រង់ទ្រាយដូចម្តេច ក្នុងអនាគតកាល អាត្មាអញនឹងមានជាតិជាអ្វី ឬមានសណ្ឋានទ្រង់ទ្រាយដូចម្តេច ( មួយយ៉ាងទៀត ) បុថុជ្ជននោះប្រារព្ធនូវបច្ចុប្បន្នកាល ក្នុងកាលឥឡូវនេះ ហើយមានសេចក្តីសង្ស័យក្នុងខ្លួនថា ឥឡូវនេះ អាត្មាអញមាន ឬមិនមានទេ ឬឥឡូវនេះ អាត្មាអញមានជាតិជាអ្វី មានសណ្ឋានទ្រង់ទ្រាយដូចម្តេច តើសត្វនេះមកអំពីណាហ្ន៎ សត្វនោះនឹងទៅកាន់ទីណាវិញហ្ន៎ ។ កាលបុថុជ្ជននោះធ្វើទុកក្នុងចិត្តដោយឧបាយខុសទំនងយ៉ាងនេះហើយ បណ្តាទិដ្ឋិទាំង ៦ ទិដ្ឋិណាមួយ គង់កើតឡើងបាន ។ ទិដ្ឋិកើតឡើងដល់បុថុជ្ជននោះ ព្រោះប្រកាន់សេចក្តីទៀងទាត់ ពិតថេរថា ខ្លួនរបស់អាត្មាអញមាន ១ ។ ទិដ្ឋិកើតឡើង

ដល់បុថុជ្ជននោះ ព្រោះប្រកាន់សេចក្តីទៀងទាត់ ឋិតថេរថា ខ្លួនរបស់អាត្មាអញមិនមាន ១ ។ ទិដ្ឋិកើតឡើងដល់បុថុជ្ជននោះ ព្រោះប្រកាន់សេចក្តីទៀងទាត់ ឋិតថេរថា អាត្មាអញដឹងច្បាស់នូវខ្លួនដោយសភាវៈថាជាខ្លួនពិត ១ ។ ទិដ្ឋិកើតឡើងដល់បុថុជ្ជននោះ ព្រោះប្រកាន់សេចក្តីទៀងទាត់ ឋិតថេរថា អាត្មាអញដឹងច្បាស់នូវសភាវៈមិនមែនខ្លួន ដោយសភាវៈថា ជាខ្លួនពិត ១ ។ ទិដ្ឋិកើតឡើងដល់បុថុជ្ជននោះ ព្រោះប្រកាន់សេចក្តីទៀងទាត់ ឋិតថេរថា អាត្មាអញដឹងច្បាស់នូវខ្លួនឯង ដោយសភាវៈថា មិនមែនខ្លួនពិត[១] ១ ។ ពុំនោះសោត បុថុជ្ជននោះ មានសេចក្តីយល់ឃើញយ៉ាងនេះថា ខ្លួនរបស់អាត្មាអញដែលត្រូវទទួល រមែងទទួលនូវផលកម្មល្អ និងអាក្រក់ក្នុងកំណើតនោះៗ តែខ្លួនរបស់អាត្មាអញនោះជាសភាវៈ ទៀងទាត់ ប្រាកដ ឋិតថេរជាសភាវៈមិនប្រែប្រួល តាំងនៅមាំដូចជាសស្សតិវត្ថុ ( ព្រះអាទិត្យ និងព្រះចន្ទជាដើម ) ដូច្នោះឯង ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ដំណើរគឺទិដ្ឋិ ញាតស្បាត គឺទិដ្ឋិ ផ្លូវឆ្ងាយដាច់ស្រយាល គឺទិដ្ឋិ ចម្រូង គឺទិដ្ឋិ សេចក្តីញាប់ញ័រ គឺទិដ្ឋិ ចំណង គឺទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនដែលជាប់ដោយចំណង គឺទិដ្ឋិ ជាអ្នកមិនចេះដឹង តថាគតហៅថា ជាអ្នកមិនបានរួចស្រឡះចាកជាតិទុក្ខ ជរាទុក្ខ មរណទុក្ខ សោកទុក្ខ បរិទេវទុក្ខ ទុក្ខទុក្ខ ទោមនស្សទុក្ខ និងឧបាយាសទុក្ខ ទាំងមិនរួចចាកទុក្ខ ( ក្នុងវដ្តៈទាំងអស់ ) ។ ម្នាលភិក្ខុទាំងឡាយ ឯអរិយសាវ័កដែលជាអ្នកបានចេះដឹង

---

១- សូមមើលអដ្ឋកថាខាងក្រោម ។

បានឃើញនូវព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ឈ្លាសក្នុងអរិយធម៌ បានទូន្មានខ្លួនល្អក្នុងអរិយធម៌ បានឃើញនូវសប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ឈ្លាសក្នុងសប្បុរិសធម៌ បានទូន្មានខ្លួនល្អ ក្នុងសប្បុរិសធម៌ រមែងដឹងច្បាស់នូវធម៌ដែលគួរធ្វើទុកក្នុងចិត្តហើយ ដឹងច្បាស់នូវធម៌ដែលមិនគួរធ្វើទុកក្នុងចិត្ត ។ កាលអរិយសាវកនោះដឹងច្បាស់នូវធម៌ដែលគួរធ្វើទុកក្នុងចិត្ត ដឹងច្បាស់នូវធម៌ដែលមិនគួរធ្វើទុកក្នុងចិត្តហើយ ធម៌ទាំងឡាយណាដែលមិនគួរធ្វើទុកក្នុងចិត្ត ក៏មិនធ្វើទុកក្នុងចិត្តនូវធម៌ទាំងនោះឡើយ ។ ធម៌ទាំងឡាយណា ដែលគួរធ្វើទុកក្នុងចិត្ត ក៏ធ្វើទុកក្នុងចិត្តនូវធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំង-ឡាយ ធម៌ទាំងឡាយដូចម្តេច ដែលមិនគួរធ្វើទុកក្នុងចិត្ត ហើយអរិយសាវកមិនធ្វើទុកក្នុងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលអរិយសាវកធ្វើទុកក្នុងចិត្តនូវធម៌ គឺអយោនិសោមនសិការហើយ កាមាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងផង កាមាសវៈដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនផង ភវាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងផង ភវាសវៈដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនឡើងផង អវិជ្ជាសវៈ ដែលមិនទាន់កើតឡើង រមែងកើតឡើងផង អវិជ្ជាសវៈដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនឡើងផង ធម៌ទាំងនេះឯងដែលមិនគួរធ្វើទុកក្នុងចិត្ត ហើយអរិយសាវកមិនធ្វើទុកក្នុងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដូចម្តេច ដែលគួរធ្វើទុកក្នុងចិត្ត ហើយអរិយសាវកធ្វើទុកក្នុងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាលអរិយសាវកធ្វើទុកក្នុងចិត្តនូវធម៌ គឺយោនិសោមនសិការហើយ កាមាសវៈដែលមិនទាន់កើត

ឡើង រមែងកើតឡើងមិនបានផង កាមាសវៈដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង ។ ភវាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើងមិនបានផង ភវាសវៈដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង អវិជ្ជាសវៈ ដែលមិនទាន់កើតឡើង រមែងកើតឡើងមិនបានផង អវិជ្ជាសវៈដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង ធម៌ទាំងនេះឯងរមែងគួរធ្វើទុកក្នុងចិត្ត ហើយអរិយសាវកធ្វើទុកក្នុងចិត្ត ។ ព្រោះតែអរិយសាវកនោះមិនធ្វើទុកក្នុងចិត្តនូវធម៌ ដែលមិនគួរធ្វើទុកក្នុងចិត្ត ធ្វើទុកក្នុងចិត្តនូវធម៌ដែលគួរធ្វើទុកក្នុងចិត្ត ( យ៉ាងនេះហើយ ) បានជាអាសវៈទាំងឡាយដែលមិនទាន់កើតឡើង ក៏កើតឡើងមិនបានផង អាសវៈទាំងឡាយដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង ។ អរិយសាវកនោះធ្វើទុកក្នុងចិត្តដោយឧបាយថា នេះកងទុក្ខ ធ្វើទុកក្នុងចិត្តដោយឧបាយថា នេះតណ្ហាជាដែនឲ្យកើតកងទុក្ខ ធ្វើទុកក្នុងចិត្តដោយឧបាយថា នេះនិព្វានធម៌ជាទីរំលត់នូវកងទុក្ខ ធ្វើទុកក្នុងចិត្តដោយឧបាយថា នេះសេចក្តីប្រតិបត្តិ ដើម្បីដល់នូវព្រះនិព្វាន ជាទីរំលត់នូវកងទុក្ខ ។ កាលអរិយសាវកនោះ ធ្វើទុកក្នុងចិត្តដោយឧបាយយ៉ាងនេះហើយ សំយោជនៈទាំងឡាយ ៣ គឺសក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាស នឹងសាបសូន្យទៅ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងនេះឯងដែលតថាគតពោលថា ត្រូវលះដោយការឃើញ គឺសោតាបត្តិ-មគ្គ ។

[១៣] ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្តេច ដែលបុគ្គល

ត្រូវលះបង់ដោយការសង្រួម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយហើយ សង្រួមដោយការសង្រួមនូវចក្ខុន្ទ្រិយគ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមិនសង្រួមចក្ខុន្ទ្រិយសំវរៈ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយណា គប្បីកើតឡើងបាន តែកាលបើភិក្ខុនោះសង្រួមចក្ខុន្ទ្រិយសំវរៈយ៉ាងនេះវិញ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយនោះ រមែងមិនមានឡើយ ។ ភិក្ខុពិចារណាដោយឧបាយហើយ សង្រួមសោតិន្ទ្រិយសំវរៈគ្រប់ឥរិយាបថទាំង ៤ ។បេ។ ពិចារណាដោយឧបាយហើយ សង្រួមនូវឃានិន្ទ្រិយសំវរៈ គ្រប់ឥរិយាបថទាំង ៤ ។បេ។ ពិចារណាដោយឧបាយហើយ សង្រួមនូវជិវ្ហិន្ទ្រិយសំវរៈ គ្រប់ឥរិយាបថទាំង ៤ ។បេ។ ពិចារណាដោយឧបាយហើយ សង្រួមនូវកាយន្ទ្រិយសំវរៈ គ្រប់ឥរិយាបថទាំង ៤ ។បេ។ ពិចារណាដោយឧបាយហើយ សង្រួមនូវមនិន្ទ្រិយសំវរៈ គ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមិនសង្រួមនូវមនិន្ទ្រិយសំវរៈ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយណា គប្បីកើតឡើងបាន តែកាលបើភិក្ខុនោះសង្រួមនូវមនិន្ទ្រិយសំវរៈយ៉ាងនេះវិញ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយនោះ រមែងមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ មិនសង្រួមនូវសំវរៈ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយណា គប្បីកើតឡើងបាន កាលបើភិក្ខុនោះសង្រួម សំវរៈយ៉ាងនេះវិញ អាសវៈទាំងឡាយ ដែលជា

គ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយនោះ រមែងមិនមានឡើយ ។ ម្នាល ភិក្ខុទាំងឡាយ អាសវៈទាំងនេះដែលតថាគតពោលថា ត្រូវលះបង់ដោយការ សង្រួម ។

[ ១៤ ] ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្តេច ដែលបុគ្គល ត្រូវលះបង់ដោយការសេព ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយហើយ អាស្រ័យ សេព គឺប្រើប្រាស់នូវសំពត់ចីវរ គ្រាន់តែដើម្បីការពារនូវត្រជាក់ ដើម្បីការពារនូវកម្តៅ ដើម្បីការពារនូវ សម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ គ្រាន់ តែដើម្បីបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្តីខ្មាសឲ្យកម្រើក ។ ពិចារណា ដោយឧបាយហើយ អាស្រ័យ សេព គឺបរិភោគនូវចង្ហាន់បិណ្ឌបាត ដើម្បី លេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីឲ្យកើតបុរិសមានះ ស្រវឹងដូចអ្នកប្រដាល់ ក៏ទេ ដើម្បីប្រដាប់តាក់តែងរាងកាយដូចស្រ្តីក្នុងបុរីក៏ទេ ដើម្បីធ្វើឲ្យផូរផង់ ពណ៌សម្បុរដូចអ្នករបាំក៏ទេ បរិភោគគ្រាន់តែឲ្យតាំងនៅនៃកាយនេះ ដើម្បី ញុំាងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់បង់នូវសេចក្តីលំបាក ដើម្បី អនុគ្រោះដល់ព្រហ្មចរិយធម៌ អាត្មាអញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តី ស្រេកឃ្លានដែលមានហើយផង នឹងញុំាងវេទនាថ្មី គឺការឆ្អែតហួសប្រមាណ មិនឲ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តី មិនមានទោស មានមិនប្រអូសកាយ មិនប្រអូសចិត្តជាដើមក្តី កិរិយានៅ សប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អាត្មាអញ ដោយបានបរិភោគ

នូវបច្ឆ្នាន់បិណ្ឌបាតនេះ ។ ពិចារណាដោយឧបាយហើយ អាស្រ័យ សេព គឺប្រើប្រាស់នូវទីសេនាសនៈ គ្រាន់តែដើម្បីការពារនូវត្រជាក់ ដើម្បីការពារនូវកម្តៅ ដើម្បីការពារនូវសម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ គ្រាន់តែដើម្បីបន្ទោបង់នូវក្រវល់ក្រវាយ ដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងព្រះកម្មដ្ឋាន ។ ពិចារណាដោយឧបាយហើយ អាស្រ័យ សេព គឺបរិភោគនូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ គ្រាន់តែដើម្បីការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមិនអាស្រ័យ សេព នូវបច្ច័យណាមួយដោយឧបាយ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយណា គប្បីកើតឡើងបាន តែកាលបើភិក្ខុនោះអាស្រ័យ សេព នូវបច្ច័យណាមួយដោយឧបាយយ៉ាងនេះវិញ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយនោះ រមែងមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងនេះឯង ដែលតថាគតពោលថា ត្រូវលះបង់ដោយការសេព ។

[ ១៥ ] ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្តេច ដែលបុគ្គលត្រូវលះបង់ដោយការអត់ធន់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយហើយ អត់ធន់ចំពោះត្រជាក់ ក្តៅ ឃ្លាន ស្រេក ជាអ្នកអត់ទ្រាំនូវសម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ និងគន្លងពាក្យដែលគេនិយាយមិនពីរោះ គ្រោះ ខ្ជិខ្ជា និងទុក្ខ-

វេទនាដែលកើតឡើង ប្រព្រឹត្តទៅក្នុងសរីរកាយដ៏ក្លា អាក្រក់ ខ្លោចផ្សា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត នឹងនាំឲ្យខូចជីវិត ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមិនអត់ទ្រាំនូវហេតុណាមួយហើយ អាសវៈទាំងឡាយ ដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយ គប្បីកើតឡើងបាន តែកាលបើភិក្ខុនោះអត់ធន់ទ្រាំនូវហេតុណាមួយបានយ៉ាងនេះវិញ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយនោះ រមែងមិនមានឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ អាសវៈទាំងនេះឯងដែលតថាគតពោលថា ត្រូវលះបង់ដោយការអត់ធន់ ។

[ ១៦ ] ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្តេចដែលបុគ្គលត្រូវលះបង់ដោយការវៀរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចា-រណាដោយឧបាយហើយ វៀរនូវដំរីកាច វៀរសេះកាច វៀរគោកាច វៀរឆ្កែកាច វៀរសត្វពស់ ដង្គត់ឈើ ចម្រូងបន្លា អណ្តូង ជ្រោះ រណ្តៅទឹកស្អុយ និងប្រឡាយទឹកស្អុយ ។ មួយវិញទៀត ភិក្ខុអង្គុយលើអាសនៈមិនសមគួរមានសភាពយ៉ាងណា ត្រាច់ទៅក្នុងទីមិនគួរមានសភាពយ៉ាងណា សេពគប់នូវបាបមិត្តមានសភាពយ៉ាងណា ពួកសព្រហ្មចារីភិក្ខុ ជាអ្នកប្រាជ្ញគប្បីជឿ ( ថាភិក្ខុនោះជាអ្នកប្រព្រឹត្តទៅ ) ក្នុងទីដ៏លាមកទាំងឡាយ ។ ភិក្ខុនោះ ពិចារណាដោយឧបាយហើយ វៀរនូវអាសនៈដែលមិនសមគួរនោះផង នូវទីគោចរដែលមិនសមគួរនោះផង នូវពួកបាបមិត្តនោះផង ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមិនវៀរនូវហេតុដែលគួរវៀរណាមួយ អាសវៈទាំង-

ឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយ គប្បីកើតឡើងបាន តែកាល បើភិក្ខុនោះ វៀរនូវហេតុដែលគួរវៀរណាមួយយ៉ាងនេះវិញ អាសវៈទាំង-ឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយនោះ រមែងមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងនេះឯង ដែលតថាគតពោលថា ត្រូវលះបង់ដោយការវៀរ ។

[ ១៧ ] ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្តេច ដែលបុគ្គលត្រូវលះបង់ដោយការបន្ទោបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយហើយ អត់ធន់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស បំផ្លាញ នូវកាមវិតក្កដែលកើតឡើងហើយ នូវព្យាបាទវិតក្កដែលកើតឡើងហើយ ។បេ។ នូវវិហិង្សាវិតក្កដែលកើតឡើងហើយ ។បេ។ អត់ធន់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស បំផ្លាញនូវពួកអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមិនបន្ទោបង់ នូវវិតក្កណាមួយហើយ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយ គប្បីកើតឡើងបាន តែកាលបើភិក្ខុនោះបន្ទោបង់ នូវវិតក្កណាមួយយ៉ាងនេះវិញ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយនោះ រមែងមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងនេះឯងដែលតថាគតពោលថា ត្រូវលះបង់ដោយការបន្ទោបង់ ។

[ ១៨ ] ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្តេច ដែលបុគ្គលត្រូវលះបង់ដោយការចម្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

ពិចារណាដោយឧបាយហើយ ចម្រើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់[1] ដែលអាស្រ័យនូវធម៌ជាគ្រឿងប្រាសចាករាគៈ ដែលអាស្រ័យនូវធម៌ជាទីរលត់ទុក្ខ ដែលជាធម៌បង្អោនទៅដើម្បីលះកិលេស ពិចារណាដោយឧបាយហើយ ទើបចម្រើននូវធម្មវិចយសម្ពោជ្ឈង្គ ។បេ។ ចម្រើននូវវីរិយសម្ពោជ្ឈង្គ ។បេ។ ចម្រើននូវបីតិសម្ពោជ្ឈង្គ ។បេ។ ចម្រើននូវបស្សទ្ធិសម្ពោជ្ឈង្គ ។បេ។ ចម្រើននូវសមាធិសម្ពោជ្ឈង្គ ។បេ។ ចម្រើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ ដែលអាស្រ័យនូវធម៌ជាទីប្រាសចាករាគៈ ដែលអាស្រ័យនូវធម៌ជាទីរលត់ទុក្ខ ដែលជាធម៌បង្អោនទៅដើម្បីលះកិលេស ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមិនចម្រើននូវសម្ពោជ្ឈង្គណាមួយហើយ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយ គប្បីកើតឡើងបាន តែកាលបើភិក្ខុនោះចម្រើននូវសម្ពោជ្ឈង្គណាមួយយ៉ាងនេះវិញ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយនោះ រមែងមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយនេះឯង ដែលតថាគតពោលថា ត្រូវលះបង់ដោយការចម្រើន ។

[ ១៩ ] ម្នាលភិក្ខុទាំងឡាយ វេលាណាដែលភិក្ខុត្រូវលះបង់ អាសវៈទាំងឡាយណា ដោយការឃើញ គឺសោតាបត្តិមគ្គ អាសវៈទាំងនោះ ក៏ឈ្មោះថា ភិក្ខុបានលះបង់ដោយការឃើញហើយ ។ អាសវៈទាំងឡាយណា

---

១- ការស្ងប់ស្ងាត់ មាន ៥ ប្រការ មានតទង្គវិវេកជាដើម អធិប្បាយដូចបបហាន ៥ ប្រការ ក្នុងមូលបរិយាយសូត្រនោះដែរ ។

ដែលភិក្ខុត្រូវលះបង់ដោយការសង្រួម អាសវៈទាំងនោះ ក៏ឈ្មោះថា ភិក្ខុបានលះបង់ដោយការសង្រួមហើយ ។ អាសវៈទាំងឡាយណា ដែលភិក្ខុត្រូវលះបង់ដោយការសេព ( នូវបច្ច័យ ) អាសវៈទាំងនោះ ក៏ឈ្មោះថា ភិក្ខុបានលះបង់ដោយការសេពហើយ ។ អាសវៈទាំងឡាយណា ដែលភិក្ខុត្រូវលះបង់ដោយការអត់ធន់ ( នូវត្រជាក់ និងក្តៅជាដើម ) អាសវៈទាំងនោះ ក៏ឈ្មោះថា ភិក្ខុបានលះបង់ដោយការអត់ធន់ហើយ ។ អាសវៈទាំងឡាយណា ដែលភិក្ខុត្រូវលះបង់ដោយការវៀរ ( ចាកទីអន្តរាយមិនសមគួរជាដើម ) អាសវៈទាំងនោះ ក៏ឈ្មោះថា ភិក្ខុបានលះបង់ដោយវៀរហើយ ។ អាសវៈទាំងឡាយណា ដែលភិក្ខុត្រូវលះបង់ដោយការបន្ទោបង់ ( នូវកាមវិតក្កជាដើម ) អាសវៈទាំងនោះ ក៏ឈ្មោះថា ភិក្ខុបានលះបង់ដោយការបន្ទោបង់ហើយ ។ អាសវៈទាំងឡាយណា ដែលភិក្ខុត្រូវលះបង់ដោយការចម្រើន ( សម្ពោជ្ឈង្គទាំង ៧ ) អាសវៈទាំងនោះ ក៏ឈ្មោះថា ភិក្ខុបានលះបង់ដោយការចម្រើនហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគត ហៅថា ជាអ្នកសង្រួម ដោយការសង្រួមក្នុងអាសវៈទាំងអស់ ហើយជាអ្នកផ្តាច់ផ្តិលនូវតណ្ហា ញុំាងសំយោជនៈឲ្យប្រែប្រួល គឺធ្វើមិនឲ្យមានមន្ទិល ធ្វើនូវទីបំផុតកងទុក្ខ ដោយហេតុដែលបានលះបង់នូវមានះចោលដោយប្រពៃ ។ លុះព្រះមានព្រះភាគ ទ្រង់បានសំដែងសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតនៃព្រះមានព្រះភាគ ។

**សព្វាសវសំវរសូត្រទី ២ ចប់**

# អដ្ឋកថា

## សព្វាសវសំវរសូត្រ

### អធិប្បាយ ពីមកនៃពាក្យថា សាវត្ថី និងជេតវន

[ ១០ ] សព្វាសវសំវរសូត្រ មានពាក្យផ្តើមថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។បេ។ ក្រុងសាវត្ថី ។

ក្នុងសព្វាសវសំវរសូត្រនេះ មានអដ្ឋកថាពោលតាមលំដាប់បទដូចតទៅនេះ អ្នកអក្ខរសាស្ត្រពិចារណាទុកយ៉ាងនេះជាបឋម បទថា **សាវត្ថី** គឺព្រះនគរ ដែលជាលំនៅរបស់ឥសី ឈ្មោះ **សវត្ថ** ដូចបទថា **កាកន្ទី មាកន្ទី** ដូច្នោះ ។ ឯអដ្ឋកថាចារ្យទាំងឡាយពោលទុកថា វត្ថុជាគ្រឿងឧបភោគ និងបរិភោគរបស់មនុស្សគ្រប់យ៉ាង មាននៅក្នុងនគរនេះ ដូច្នោះ ទើបនគរនេះឈ្មោះថា **សាវត្ថី** ។ ក្នុងកាលកាន់យកពាក្យថា **សត្ថ** មកសង្គ្រោះទុកផងទើបឈ្មោះថា **សាវត្ថី** ព្រោះអាស្រ័យហេតុដែលត្រូវសួរថា មានរបស់អ្វីខ្លះក៏ឆ្លើយថា មានសព្វបែបយ៉ាង ។

គ្រឿងឧបភោគបរិភោគគ្រប់យ៉ាង មកប្រជុំគ្នាក្នុងនគរសាវត្ថីសព្វវេលាដូច្នោះ លោកសំដៅយកការសម្បូរដោយគ្រឿងឧបភោគ បរិភោគគ្រប់យ៉ាងទើបហៅថានគរនោះថា **សាវត្ថី** ។ នេះជានគររបស់អ្នកកោសល គួរសរសើរគួររីករាយ គួរត្រេកអរ អឺងកងទៅដោយសំឡេង ១០ ប្រការ ជាក្រុងសម្បូរបាយ សម្បូរទឹក ។ ជាក្រុងដល់នូវការចម្រើនបរិបូណ៌ មាំទាំ ទូលំទូលាយគួរសរសើរ និងឧត្តម សម្បូរដូចទេវបុរី ឈ្មោះអាលកមន្ទា ។ ក្នុងក្រុងសាវត្ថី

នោះ ។

ក្នុងបទថា **ជេតវនេ** អធិប្បាយថា ព្រះរាជកុមារឈ្មោះថា **ជេត** ព្រោះទ្រង់ច្បាំងឈ្នះសត្រូវរបស់ព្រះអង្គ ឬព្រោះប្រសូតក្នុងពេលដែលព្រះបិតាមានជ័យជម្នះចំពោះសត្រូវរបស់ព្រះអង្គ ។ ម្យ៉ាងទៀត ទ្រង់ព្រះនាមថា **ជេត** ព្រោះព្រះនាមយ៉ាងនេះ ព្រះជនក ព្រះជននី ទ្រង់តាំងឲ្យ ដើម្បីជាសិរីមង្គល ព្រះរាជឧទ្យានរបស់ព្រះរាជកុមារជេត ឈ្មោះថា **ជេតវន** ។ ព្រោះឧទ្យានជេតវននោះ ដែលព្រះរាជកុមារឈ្មោះថា **ជេត** នោះ ទ្រង់ដាំថែទាំ ទំនុកបម្រុង ឲ្យចម្រើនដុះដាលផង ព្រះអង្គក៏ទ្រង់ជាម្ចាស់នៃឧទ្យាននោះផង ដូច្នោះទើបហៅថា **ជេតវន** ។ ក្នុងវត្តជេតវននោះ ។ ក្នុងបទថា **អនាថ-បិណ្ឌិកស្ស អារាមេ** នេះ មានអធិប្បាយថា គហបតីនោះឈ្មោះថា **សុទត្ត** ដោយឈ្មោះដែលមាតាបិតាតាំងឲ្យ តែដែលបានឈ្មោះថា **អនាថបិណ្ឌិក** ព្រោះបានឲ្យអាហារដល់ជនអនាថាទាំងឡាយជាប្រចាំ ព្រោះជាអ្នកស្តុកស្តម្ភដោយសម្បត្តិគ្រប់យ៉ាង និងព្រោះប្រាសចាកសេចក្តីកំណាញ់ផង ដល់ព្រមដោយគុណ មានករុណាជាដើមផង ។ សត្វទាំងឡាយដោយចំពោះ គឺបព្វជិតរមែងត្រេកអរ ក្នុងឧទ្យាននេះ ដូច្នោះ ទើបឈ្មោះថា **អារាម** ។ អធិប្បាយថា សត្វទាំងឡាយ មកអំពីទីផ្សេងៗ គ្នា រមែងត្រេកអរ រីករាយសប្បាយ ព្រោះឧទ្យាននោះ មានលម្អទៅដោយផ្កាឈើ ផ្លែឈើជាដើម សម្បូរទៅដោយអង្គប្រកបនៃសេនាសនៈ ៥ ប្រការ មានមិនឆ្ងាយមិនជិតពីគោចរគាមជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា **អារាម** ព្រោះទាក់ទាញសត្វ

ដែលទៅដល់ទីនោះទុកខាងក្នុងបរិវេណនៃខ្លួននោះឯង ហើយឲ្យត្រេកអរទៅដោយសម្បត្តិ មានប្រការដូចពោលហើយ ។ សេចក្តីពិត អារាមនោះ អនាថបិណ្ឌិកគហបតីបានវេរប្រគេនសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយបរិច្ចាគទ្រព្យអស់ ៥៤ កោដិ គឺបរិច្ចាគទិញដីអំពីដៃនៃព្រះរាជកុមារឈ្មោះជេត ដោយការយកប្រាក់ ១៨ កោដិក្រាលពេញបរិវេណ បរិច្ចាគតម្លៃកសាងសេនាសនៈផ្សេងៗ ១៨ កោដិ បរិច្ចាគតម្លៃធ្វើការឆ្លងព្រះវិហារ ១៨ កោដិទៀត ដូច្នោះ ទើបបានឈ្មោះថា ជាអារាមរបស់អនាថបិណ្ឌិក ។ ព្រះមានព្រះភាគ គង់ក្នុងអារាមរបស់អនាថបិណ្ឌិកគហបតីនោះ ។ បទថា **ជេតវនេ** ក្នុងបទថា **ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ** នោះ ជាពាក្យប្រារព្ធដល់ម្ចាស់ដើម ។ បទថា **អនាថបិណ្ឌិកស្ស អារាមេ** ជាពាក្យប្រារព្ធដល់ម្ចាស់ក្រោយ ។

សួរថា មានប្រយោជន៍អ្វី ក្នុងការប្រារព្ធដល់ម្ចាស់ទ្រព្យទាំងពីរនោះ ឆ្លើយថា មានប្រយោជន៍ គឺធ្វើឲ្យត្រេកអររបស់បុគ្គលអ្នកត្រូវការបុណ្យ ។

ពិតហើយ ក្នុងពាក្យនោះ ព្រះអានន្ទកាលសម្តែងថា បុគ្គលត្រូវការបុណ្យទាំងឡាយ រមែងធ្វើបុណ្យ ព្រោះកិត្តិសព្ទរបស់លោកទាំងពីរនោះថា ព្រះរាជកុមារព្រះនាមថាជេតនោះ ទ្រង់បរិច្ចាគទ្រព្យ ១៨ កោដិ ដែលព្រះអង្គបានមកដោយការលក់ទីកន្លែង ដើម្បីកសាងខ្លោងទ្វារ និងប្រាសាទ ហើយទ្រង់បរិច្ចាគដើមឈើ ដែលមានតម្លៃច្រើនកោដិ ឯអនាថបិណ្ឌិកគហបតីបានបរិច្ចាគទ្រព្យ ៥៤ កោដិ ដូច្នេះហើយ ដឹកនាំបុគ្គលដែលត្រូវការបុណ្យដទៃ

ឲ្យរាប់អានជនទាំងពីរនោះជាគ្រូ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់សូត្រនេះថា **សព្វា-សវសំវរបរិយាយំ វោ ភិក្ខវេ** ដូច្នេះ ។ ឆ្លើយថា ដើម្បីទ្រង់សម្ដែងដល់បដិបទា ដើម្បីការអស់អាសវៈ ។ ផ្ដើមតាំងអំពីការជម្រះឧបក្កិលេសដល់ភិក្ខុទាំងនោះ ។ បណ្ដាបទទាំងនោះ បទថា **សព្វាសវសំវរបរិយាយំ** សេចក្ដីថា ជាហេតុសង្រួម គឺជាហេតុឲ្យរាំងប្រយ័ត្នក្នុងអាសវៈគ្រប់យ៉ាង ។ អធិប្បាយថា ជាហេតុឲ្យអាសវៈទាំងនេះ ដែលភិក្ខុសង្រួមបិទបាំងហើយ រមែងដល់នូវការអស់ទៅ ពោលគឺ ការរលត់ទៅដោយមិនកើតឡើង គឺ ភិក្ខុរមែងលះបង់បាន បានដល់ រមែងមិនប្រព្រឹត្តទៅ ។

[ ១១ ] ក្នុងបទថា **អាសវានំ** នោះ ឈ្មោះថា **អាសវ** ព្រោះអត្ថថា ហូរទៅ លោកអធិប្បាយថា អាសវៈទាំងនោះ រមែងហូរទៅ គឺហូរចេញតាមចក្ខុ ។បេ។ តាមចិត្ត ដូច្នេះ ។ ម្យ៉ាងទៀត អាសវៈទាំងនោះកាលពោលដោយធម៌ រមែងហូរទៅរហូតដល់គោត្រភូ កាលពោលដោយឱកាសលោក រមែងហូរទៅដល់ភវគ្គព្រហ្ម ។ ព្រោះហេតុនោះ ទើបឈ្មោះថា **អាសវ** អធិប្បាយថា អាសវៈទាំងនោះ ធ្វើធម៌នោះ និងឱកាសនោះទុកខាងក្នុង ( អំណាច ) ហើយប្រព្រឹត្តទៅ ។

ពិតហើយ **អា** អក្ខរៈនេះ មានអត្ថថា ធ្វើទុកក្នុងខាងក្នុង ។ ដែលឈ្មោះថា **អាសវ** ព្រោះដូចជារបស់ត្រាំ មានទឹកស្រវឹងជាដើម ដោយអត្ថថា ត្រាំនៅយូរដូច្នេះខ្លះ ។ សេចក្ដីពិត ក្នុងផ្លូវលោក មានទឹកស្រវឹងដែល

ត្រាំទុកយូរ គេក៏ហៅថា **អាសវ** ដូច្នេះ ។ បើទឹកស្រវឹងជាដើម ហៅថាអាសវៈបាន ព្រោះអត្ថថា ត្រាំទុកយូរសោត កិលេសទាំងនេះក៏គួរតែដូច្នោះដូចគ្នា ។ សមដូចព្រះតម្រាស់ដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ចំណុចខាងដើមរបស់អវិជ្ជាមិនប្រាកដ គឺមិនប្រាកដថា ក្នុងកាលមុនអំពីនេះ មិនមានអវិជ្ជា ដូច្នេះ ។ ម្យ៉ាងទៀត ដែលឈ្មោះថា **អាសវ** ព្រោះអត្ថថា ហូរទៅ គឺហូរចេញទៅកាន់សង្សារទុក្ខតទៅដូច្នេះខ្លះ ។ ពាក្យអធិប្បាយពាក្យមុនៗ ក្នុងរូបវិគ្គហៈទាំងនេះ រមែងប្រើក្នុងទីដែលកិលេសទាំងឡាយមកដោយឈ្មោះថា **អាសវ** ឯពាក្យអធិប្បាយក្រោយ ប្រើក្នុងកម្មក៏បាន ។ មិនមែនត្រឹមតែកម្មកិលេស តែម្យ៉ាងប៉ុណ្ណោះដែលជាអាសវៈនោះ ដោយពិតសូម្បីឧបទ្រវជាច្រើន ក៏ឈ្មោះថា **អាសវ** បានដូចគ្នា ។ សេចក្តីពិតក្នុងព្រះសូត្រទាំងឡាយ កិលេសទាំងឡាយដែលជាមូលហេតុ ឲ្យបង្កការជម្លោះវិវាទ ក៏មកដោយឈ្មោះថា **អាសវ** ។ ក្នុងបទនេះថា ម្នាលចុន្ទ តថាគតមិនសម្តែងធម៌ដើម្បីរារាំងនូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នតែមួយយ៉ាងដល់ពួកអ្នកទេ ដូច្នេះ ។ កម្មដែលប្រព្រឹត្តទៅក្នុងភូមិ ៣ និងពួកអកុសលធម៌ដ៏សេសទាំងឡាយ ក៏ឈ្មោះថា **អាសវ** ក្នុងពាក្យនេះថា

តថាគត គប្បីកើតជាទេវតា ឬកើតជាគន្ធព្វ ត្រាច់ទៅតាមអាកាស ព្រោះអាសវៈណាក្តី គប្បីដល់នូវភាពនៃខ្លួនជាយក្ខ និងជួបប្រទះនូវភាពនៃខ្លួនជាមនុស្ស ព្រោះអាសវៈណាក្តី អាសវៈទាំងអស់នោះ របស់តថាគតអស់ហើយ បានកម្ចាត់បង់ហើយ ធ្វើឲ្យរបួតចំណាងហើយ ដូច្នេះ ។

ការចូលទៅប្រទូស្តអ្នកដទៃ ការក្តៅក្រហាយ ការសម្លាប់ ការចាប់ចង ជាដើម និងឧបទ្រវច្រើនប្រការ ដែលជាហេតុឲ្យសត្វសោយទុក្ខក្នុងអបាយ ក៏ឈ្មោះថា **អាសវ** ដូចក្នុងប្រយោគនេះថា តថាគតមិនសម្តែងធម៌ ដើម្បីរារាំងនូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នផង ដើម្បីកម្ចាត់បង់នូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខផង ដូច្នេះ ។ ក្នុងទីណាអាសវៈទាំងនេះ មកដោយប្រការណា ក្នុងទីនោះក៏គប្បីជ្រាបដោយប្រការនោះ ។ ក្នុងព្រះវិន័យ អាសវៈ ទាំងឡាយនេះ មានមកហើយ ២ យ៉ាង ដូចក្នុងប្រយោគថា ( តថាគតនឹងសម្តែងធម៌ ) ដើម្បីរារាំងអាសវ-ធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកម្ចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១ ដូច្នេះ ។ ក្នុងសឡាយតនវគ្គ មានមកហើយ ៣ យ៉ាង ដូចក្នុងប្រយោគថា អ្នកមានអាយុ អាសវៈទាំងនេះមាន ៣ យ៉ាង គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ដូច្នេះ ក្នុងសុត្តន្តបិដកក្រៅនេះ និងព្រះអភិធម្មបិដក អាសវៈទាំង ៣ នោះឯង រួមជាមួយទិដ្ឋាសវៈចូលមកហើយជា ៤ យ៉ាង ។ ពោលដោយបរិយាយ អាសវៈទាំងឡាយចែកជា ៥ យ៉ាង គឺភិក្ខុទាំងឡាយ អាសវៈដែលជាហេតុញ៉ាំងសត្វឲ្យចូលដល់នរកក៏មាន អាសវៈដែលជាហេតុឲ្យសត្វទៅកាន់កំណើតសត្វតិរច្ឆាន ក៏មាន អាសវៈដែលជាហេតុឲ្យសត្វទៅកាន់បេតវិស័យក៏មាន អាសវៈដែលជាហេតុឲ្យសត្វទៅកាន់មនុស្សលោកក៏មាន និងអាសវៈដែលជាហេតុ ញ៉ាំងសត្វឲ្យទៅកាន់ទេវលោកក៏មាន ។ ក្នុងឆក្កនិបាត អាសវៈមាន ៦ យ៉ាង ដោយន័យជាដើមថា ម្នាលភិក្ខុទាំង-

ឡាយ អាសវៈដែលត្រូវលះដោយសំវរៈ ក៏មាន ។ ឯក្នុងសូត្រនេះ អាសវៈ ៦ នោះឯង ព្រមដោយអាសវៈដែលត្រូវលះដោយទស្សនៈមានមក គឺបន្ថែមមកទៀតជា ៧ អត្ថ និងប្រភេទនៃអាសវៈ ក្នុងបទថា អាសវៈមានប្រមាណប៉ុណ្ណេះ ។

ឯក្នុងបទថា **សំវរ** មានវិនិច្ឆ័យដូចតទៅនេះ ដែលឈ្មោះថា **សំវរ** ព្រោះអត្ថថា សង្រួម អធិប្បាយថា បិទ គឺហាម បានដល់ មិនឲ្យប្រព្រឹត្តទៅ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ កាលដែលសិងសម្ងំក្នុងវេលាថ្ងៃ ត្រូវបិទទ្វារហើយសឹមសិងសម្ងំចុះ ដូច្នេះ ។ អាចារ្យពោលសំវរៈដោយអត្ថថា បិទ ក្នុងពាក្យជាដើមថា តថាគតពោលថា សតិ ជាគ្រឿងរាំងខ្សែតណ្ហាទាំងឡាយ បុគ្គលគប្បីបិទខ្សែតណ្ហាទាំងនោះដោយបញ្ញា ដូច្នេះ ។

សំវរៈនោះមាន ៥ យ៉ាង គឺ **សីលសំវរ សតិសំវរ ញាណសំវរ ខន្តិសំវរ វីរិយសំវរ** ។ បណ្តាសំវរៈទាំងនោះ សំវរៈដែលត្រាស់ទុកថា ភិក្ខុប្រកបដោយបាតិមោក្ខសំវរៈនេះ ឈ្មោះថា **សីលសំវរ** ។ សេចក្តីពិតបាតិមោក្ខសីល លោកពោលថា ជាសំវរៈក្នុងទីនេះ ។ សំវរៈក្នុងពាក្យជាដើមថា ភិក្ខុរមែងដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឈ្មោះថា **សតិសំវរ** សតិ លោកពោលថា ជាសំវរៈក្នុងទីនេះ ។

សំវរៈដែលត្រាស់ថា តថាគតពោលថា បុគ្គលគប្បីបិទខ្សែតណ្ហាទាំងនោះដោយបញ្ញា នេះឈ្មោះថា **ញាណសំវរ** ។ ក្នុងទីនេះ លោកពោល

ញាណថា **សំវរ** ដោយអត្ថថា បិទទុកបាន ដោយបទថា **បិធិយ្យរេ** ។ ខន្តិសំវរៈ និងវីរិយសំវរៈ មកក្នុងសូត្រនេះដោយ ន័យជាដើមថា ភិក្ខុជាអ្នកអត់ធន់ចំពោះរងា ។បេ។ រមែងមិនឲ្យវិតក្កកើតឡើងគ្របសង្កត់បាន ដូច្នេះ ។ គប្បីជ្រាបថា ខន្តិ និងវីរិយៈ ឈ្មោះថា **សំវរ** ព្រោះលោក សង្គ្រោះដោយនិទ្ទេសនេះថា **សព្វាសវសំវរប្បរិយាយំ** នេះ ។

ម្យ៉ាងទៀត សំវរៈទាំង ៥ នេះ ក៏មកក្នុងសូត្រនេះដូចគ្នា បណ្ដាសំវរៈទាំង ៥ យ៉ាងនោះ ខន្តិសំវរៈ និងវីរិយសំវរៈលោកពោលទុកមុនហើយនោះឯង ។ សំវរៈដែលត្រាស់ថា ភិក្ខុនោះពិចារណាដោយឧបាយហើយ វៀរនូវអាសនៈដែលមិនសមគួរនោះផង នូវទីគោចរដែលមិនសមគួរនោះផង នេះ ឈ្មោះថា **សីលសំវរ** ក្នុងទីនេះ ។ សំវរៈដែលត្រាស់ថា ភិក្ខុពិចារណាដោយឧបាយហើយ សង្រួមដោយការសង្រួមនូវចក្ខុន្ទ្រិយ ដូច្នេះ នេះឈ្មោះថា **សតិសំវរ** ។ ការពិចារណាដោយញាណក្នុងធម៌ទាំងពួង ឈ្មោះថា **ញាណសំវរ** ។ ឯការឃើញ ការសេព ការចម្រើន ក៏ឈ្មោះថា **ញាណ-សំវរ** ដោយសព្វដែលលោកមិនបានកាន់យក ។ ដែលឈ្មោះថា **បរិយាយ** ព្រោះជាហេតុ គឺគ្រឿងកំណត់នៃធម៌ទាំងឡាយ អធិប្បាយថា ធម៌ទាំង-ឡាយរមែងដល់នូវការកើតឡើង ឬរលត់ទៅ ។ ពាក្យណាដែលគួរពោលក្នុងពាក្យថា **សព្វាសវសំវរប្បរិយាយំ** ពាក្យនោះ លោកពោលអធិប្បាយទុកដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ជានតោ អហំ** ជាដើមដូច

តទៅនេះ បទថា **ជានតោ** គឺកំពុងដឹង ។ បទថា **បស្សតោ** គឺឃើញ ។ ទាំង ២ បទនេះ មានអត្ថដូចគ្នា ខុសគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ។ កាលបើដូច្នោះ ព្រះមានព្រះភាគសម្តែងដល់បុគ្គល ដោយសំដៅដល់លក្ខណៈរបស់ញាណ ដោយបទថា **ជានតោ** ។ សេចក្តីពិត ញាណមានការដឹងជាលក្ខណៈ ទ្រង់សម្តែងបុគ្គល ដោយសំដៅដល់អំណាចនៃញាណ ដោយបទថា **បស្សតោ** ។ សេចក្តីពិត ញាណមានអំណាចក្នុងការឃើញ ។ បុគ្គលដែលដល់ព្រមដោយញាណ រមែងឃើញធម៌ដែលព្រះពុទ្ធទ្រង់បើកផ្ចារទុកដោយញាណនោះឯង ប្រៀបដូចបុគ្គលដែលមានភ្នែកល្អ ឃើញរូបដោយចក្ខុដូច្នោះ ។ មួយវិញទៀត ដើម្បីឲ្យយោនិសោមនសិការកើតឡើង អយោនិសោមនសិការមិនកើតឡើងដល់អ្នកឃើញ ដូចជាមិនកើតឡើងដល់បុគ្គលដឹង ដូច្នោះ សារៈសំខាន់ក្នុងពាក្យទាំង ២ នេះ មានប្រមាណប៉ុណ្ណោះ ។ ឯអាចារ្យពួកខ្លះពោលពិស្តារទុកច្រើនពេក ។ សេចក្តីនោះ មិនសមគួរក្នុងអត្ថនេះ ។

បទថា **អាសវានំ ខយំ** សេចក្តីថា ការលះអាសវៈ គឺការកើតឡើងនៃការអស់ទៅ ដោយមិនមានសេសសល់ បានដល់ អាការ គឺការអស់ទៅដោយអត្ថថា ការៈ គឺការមិនមាននៃអាសវៈទាំងឡាយ ។ **ខយ** សព្ទនេះឯងមានអត្ថថា អស់អាសវៈ ទាំងក្នុងសូត្រនេះ និងក្នុងប្រយោគជាដើមថា **អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ** ។ ឯក្នុងសូត្រដទៃ មគ្គ ផល និព្វាន លោកហៅថា ជាធម៌អស់ទៅនៃអាសវៈ ។ ពិតហើយ **មគ្គ** លោក

ហៅថា ធម៌ជាទីអស់អាសវៈ ដូចក្នុងប្រយោគជាដើមថា ញាណជាបឋម ក្នុងកិរិយាអស់ទៅ កើតឡើងដល់សេក្ខបុគ្គល អ្នកកំពុងសិក្សា អ្នករឭករឿយៗ នូវផ្លូវត្រង់ លំដាប់ពីនោះមក អរហត្តក៏កើតឡើង ដូច្នេះ ។

ផល លោកពោលថា ធម៌ជាទីអស់អាសវៈ ដូចក្នុងប្រយោគជាដើមថា បុគ្គលជាសមណៈបាន ព្រោះការអស់ទៅនៃអាសវៈ ។ និព្វាន លោកពោលថា ធម៌ជាទីអស់ទៅនៃអាសវៈ ដូចក្នុងប្រយោគជាដើមថា

កាលបុគ្គលគយឃ្នាំមើលទោសរបស់បុគ្គលដទៃជាប្រក្រតី មានការសម្គាល់ក្នុងហេតុ ក្នុងការពោលទោស ( អ្នកដទៃ ) ជានិច្ចជាប្រក្រតី អាសវៈទាំងឡាយរបស់បុគ្គលនោះ តែងចម្រើន បុគ្គលនោះ ឈ្មោះថា ឋិតនៅឆ្ងាយអំពីធម៌ជាគ្រឿងអស់អាសវៈ ដូច្នេះ ។

បទថា **នោ អជានតោ ន អបស្សតោ** សេចក្តីថា បុគ្គលណាមិនដឹង មិនឃើញ តថាគតមិនពោលការអស់ទៅនៃអាសវៈរបស់បុគ្គលនោះ ។ ជនពួកណាពោលដល់ការបរិសុទ្ធ ដោយសំសារៈជាដើមនៃបុគ្គលដែលមិនដឹង មិនឃើញ ជនទាំងនោះ ឈ្មោះថា ជំទាស់ហើយ ដោយបទថា **នោ ជានតោ នោ បស្សតោ** នេះ ។ម្យ៉ាងទៀត ដោយ ២ បទដំបូង ( **ជានតោ បស្សតោ** ) ព្រះមានព្រះភាគ ក៏បានត្រាស់ឧបាយទុកហើយ ដោយ ២ បទក្រោយនេះ ( **នោ អជានតោ អបស្សតោ** ) ព្រះមានព្រះភាគ ក៏បានត្រាស់ការបដិសេធឧបាយទុកហើយ ព្រោះដូច្នោះ ក្នុងទីនេះ **ញាណ** ឈ្មោះថា ព្រះមានព្រះភាគ ទ្រង់សម្តែងថាជាធម៌ គឺគ្រឿងរាំងអាសវៈទាំងឡាយ

ដោយសង្ខេប ។

ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់មានបំណងសម្តែងធម៌ ដែលកាលភិក្ខុដឹង ទើបមានការអស់ទៅនៃអាសវៈទាំងឡាយ ទើបទ្រង់ផ្តើមពាក្យបុច្ឆាថា **កិញ្ច ភិក្ខវេ ជានតោ** ដូច្នេះ ។ ក្នុងបទថា **កិញ្ច ភិក្ខវេ ជានតោ** នោះ ការដឹងមានច្រើនយ៉ាង សេចក្តីពិត ភិក្ខុអង្គខ្លះមានជាតិជាអ្នកឈ្លាស រមែងចេះធ្វើក្រស់ អង្គខ្លះរមែងដឹងវិធីធ្វើចីវរជាដើមណាមួយ កាលភិក្ខុនោះតាំងនៅក្នុងការបំពេញវត្ត ធ្វើកម្មដូច្នេះ ការដឹងនោះមិនគួរនឹងពោលថា ជាបទដ្ឋានរបស់មគ្គ និងផល ។ ឯភិក្ខុណាបួសក្នុងសាសនាហើយ ដឹងវិធីធ្វើវេជ្ជកម្មជាដើម កាលភិក្ខុដឹងយ៉ាងនេះ អាសវៈទាំងឡាយរមែងចម្រើនឡើងនោះឯង ព្រោះដូច្នោះ កាលភិក្ខុឃើញធម៌ណា ទើបការអស់អាសវៈកើតមាន កាលទ្រង់សម្តែងធម៌នោះឯង ទើបព្រះមានព្រះភាគត្រាស់ថា **យោនិសោ ច មនសិការំ អយោនិសោ ច មនសិការំ** ដូច្នេះ ។

យោនិសោមនសិការ និងអយោនិសោមនសិការទាំង ២ យ៉ាងនោះ ដែលឈ្មោះថា យោនិសោមនសិការ បានដល់ ការធ្វើទុកក្នុងចិត្តដោយត្រូវឧបាយ ការធ្វើទុកក្នុងចិត្តដោយត្រូវផ្លូវ ការនឹក ការបង្អោននឹក ការចងចិត្ត ការដាក់ចិត្ត ការធ្វើទុកក្នុងចិត្តនូវចិត្តក្នុងអនិច្ចលក្ខណៈជាដើម ដោយន័យជាដើមថា មិនទៀង ឬដោយសច្ចានុលោមិកញ្ញាណ នេះហៅថា យោនិសោ-មនសិការ ។ ដែលឈ្មោះថា អយោនិសោមនសិការ បានដល់ ការធ្វើទុកក្នុងចិត្តដោយមិនត្រូវឧបាយ បានដល់ ធ្វើទុកក្នុងចិត្តដោយមិនត្រូវផ្លូវ គឺធ្វើ

ទុកក្នុងចិត្តមិនជាឧបាយ ដោយខុសផ្លូវ ក្នុងវត្ថុមិនទៀង ថាទៀង ក្នុងវត្ថុដែលជាទុក្ខ ថាសុខ ក្នុងវត្ថុដែលមិនមែនអត្តា ថាជាអត្តា ឬការនឹក ការបង្អោនទឹក ការបងចិត្ត ការដាក់ចិត្ត ការធ្វើទុកក្នុងចិត្តនូវចិត្ត ដោយការផ្ទុយគ្នានឹងសច្ចៈ នេះហៅថា អយោនិសោមនសិការ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដល់ភិក្ខុដែលដឹង ដើម្បីញុំាងយោនិសោមនសិការឲ្យកើតឡើង និងដល់ភិក្ខុដែលឃើញ ដោយប្រការដែលអយោនិសោមនសិការមិនកើតឡើង ដូចពណ៌នាមក ដូច្នេះ ។

ឥឡូវនេះ កាលទ្រង់សម្ដែងយុត្តិនៃអត្ថនេះ ទើបព្រះមានព្រះភាគត្រាស់ថា **អយោនិសោ ភិក្ខវេ ។បេ។ បហិយ្យន្តិ ។**

សួរថា ដោយបទថា **អយោនិសោ ភិក្ខវេ ។បេ។ បហិយ្យន្តិ** នោះលោកពោលអធិប្បាយទុកដូចម្ដេច ។

ឆ្លើយថា លោកពោលអធិប្បាយថា ព្រោះអាសវៈទាំងឡាយតែងកើតឡើងដល់ភិក្ខុដែលដាក់ចិត្ត ដោយមិនជាឧបាយ កាលភិក្ខុដាក់ចិត្តដោយឧបាយ លោករមែងលះអាសវៈទាំងឡាយបាន ព្រោះដូច្នោះ បណ្ឌិតគប្បីយល់ថា ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដល់ភិក្ខុដែលដឹង ដើម្បីញុំាងយោនិសោមនសិការឲ្យកើតឡើង និងដល់ភិក្ខុដែលឃើញ ដោយប្រការដែលអយោនិសោមនសិការមិនកើតឡើង ដូចពណ៌នាមកនេះ ។ ក្នុងសេចក្ដីនេះ មានការពិចារណាដោយសង្ខេបប្រមាណប៉ុណ្ណេះ ។ ឯសេចក្ដីពិស្ដារមានដូចតទៅនេះ ។ ព្រះសូត្រទាំងមូលខាងមុខ មានអត្ថទាក់ទងគ្នា

ដោយពីរបទនេះ គឺ **យោនិសោ អយោនិសោ** មុន ។ សេចក្តីពិត ព្រះសូត្រទាំងអស់ខាងមុខ លោកពោលដោយអំណាចវដ្ដ: និងវិវដ្ដ: ។ វដ្ដ:មានការមិនដាក់ចិត្តដោយឧបាយជាឫសគល់ ។ វិវដ្ដ:មានការដាក់ចិត្ត ដោយឧបាយជាឫសគល់ ។ សេចក្តីនេះដូចម្តេច អធិប្បាយថា ការដាក់ចិត្តដោយមិនជាឧបាយ កាលចម្រើនឡើង រមែងឲ្យធម៌ ២ យ៉ាង គឺអវិជ្ជា និងភវតណ្ហាបរិបូណ៌ ។ កាលមានអវិជ្ជា ទើបសង្ខារទាំងឡាយមាន ព្រោះអវិជ្ជាជាបច្ច័យ ។បេ។ ទើបកងទុក្ខមានការកើតឡើង ។ កាលមានតណ្ហា ឧបាទានក៏កើតមាន ព្រោះមានតណ្ហាជាបច្ច័យ ។បេ។ ទើបកងទុក្ខមានការកើតឡើង ។ ដូច្នោះ បុគ្គលច្រើនដោយការមិនដាក់ចិត្ត ដោយឧបាយប្រាជ្ញាយ៉ាងនេះ រមែងវិលវល់ ស្លាប់កើតក្នុងភព កំណើត គតិ ឋិតិ និងសត្តាវាសរឿយៗ ទៅ ប្រៀបដូចទូកដែលត្រូវខ្យល់បក់ធ្វើឲ្យឃ្លោង និងប្រៀបដូចហ្វូងគោដែលធ្លាក់ចុះទៅក្នុងស្ទឹងដែលកំពុងហូរខ្លាំង និងដូចគោបម្រើដែលគេទឹម ដូច្នោះ ។ វដ្ដ:មានការមិនដាក់ចិត្តដោយឧបាយជាឫសគល់ ដូចពោលមកប៉ុណ្ណេះ ។

ឯការដាក់ចិត្តដោយឧបាយ កាលចម្រើនឡើង រមែងធ្វើមគ្គមានអង្គ ៨ មានសម្មាទិដ្ឋិជាដើមឲ្យបរិបូណ៌ ដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ការបរិបូណ៌ដោយយោនិសោមនសិការ នេះជាប្រធាន នេះជាបុព្វនិមិត្ត ប្រព្រឹត្តទៅដើម្បីញ៉ាំងអរិយមគ្គប្រកបដោយអង្គ ៨ ឲ្យកើតឡើងដល់ភិក្ខុ ដោយប្រការយ៉ាងនេះដែរ ដូច្នេះ ។ ដោយបទថា **យា ច សម្មាទិដ្ឋិ សា វិជ្ជា** នេះ បណ្ឌិតគប្បីជ្រាបវិវដ្ដ: ដែលមានការដាក់ចិត្តដោយឧបាយជាឫសគល់

យ៉ាងនេះថា ព្រោះអវិជ្ជាកើតឡើង និងអវិជ្ជារលត់ទៅ ទើបការរលត់នៃសង្ខារមានដល់ភិក្ខុនោះ ។បេ។ ការរលត់នៃកងទុក្ខទាំងឡាយនេះ រមែងមានដោយប្រការយ៉ាងនេះ ។ ព្រះសូត្រទាំងមូលខាងមុខ មានការទាក់ទងគ្នាដោយបទទាំង ២ នេះ ដូចពោលមកនេះ ។ ក្នុងសូត្រនេះដែលទាក់ទងគ្នាយ៉ាងនេះ ព្រោះសម្ដែងការលះអាសវៈបានមុនហើយ នឹងពោលការកើតឡើងតាមក្រោយមិនសមគួរ ទាក់ទងនឹងអាសវៈដែលលះបានហើយ រមែងមិនកើតឡើងទៀត តែដែលត្រឹមត្រូវ គឺពោលការលះអាសវៈទាំងឡាយដែលកើតឡើងហើយ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **អយោនិសោ ភិក្ខវេ មនសិការោតោ** ជាដើម ដោយសង្ខេបឧទ្ទេស ។ បណ្ដាបទទាំងនោះ បទថា **អយោនិសោ មនសិការោតោ** សេចក្ដីថា បុគ្គលញ៉ាំងការដាក់ចិត្តដោយមិនជាឧបាយ មានប្រការដូចពោលហើយឲ្យកើតឡើង ។ តែក្នុងបទថា **ឧប្បន្នា ចេវ អាសវា ឧប្បជ្ជន្តិ** នេះ សេចក្ដីថា កាលភិក្ខុបានបច្ច័យមានចីវរជាដើម ដែលខ្លួនមិនធ្លាប់បានអំពីមុន ឬបានវត្ថុដែលគួរពេញចិត្តឯណានីមួយរបស់ឧបដ្ឋាក សទ្ធិវិហារិក និងអន្តេវាសិកហើយ មិនដាក់ចិត្តដោយឧបាយនូវបច្ច័យ ឬវត្ថុនោះថា ស្អាត ជាសុខ ឬកាលភិក្ខុមិនដាក់ចិត្តដោយឧបាយនូវអារម្មណ៍ដទៃៗ ដែលខ្លួនមិនធ្លាប់បានសោយមកអំពីមុនដោយប្រការណាមួយ អាសវៈពួកណារមែងកើតឡើង ។ អាសវៈទាំងនោះដែលមិនទាន់កើតឡើង គប្បីជ្រាបថា រមែងកើតឡើង ដូច្នេះ ។ សេចក្ដីពិត អាសវៈទាំងឡាយដែលឈ្មោះថា មិនកើតឡើងក្នុងសង្សារវដ្ដ ដែល

មានទីបំផុតខាងដើម ដែលមិនមានបុគ្គលណាដឹងហើយ ដោយប្រការដទៃ រមែងមិនមាន ។ អាសវៈទាំងឡាយរបស់ភិក្ខុណា ក្នុងកាលមុនមិនកើតឡើងក្នុងវត្ត ឬក្នុងអារម្មណ៍ដែលខ្លួនមិនធ្លាប់បានសោយមកអំពីមុន ដោយសេចក្ដីបរិសុទ្ធតាមប្រក្រតី ឬដោយអំណាចការ **ឧទ្ទេស បរិបុច្ឆា បរិយត្តិ នវកម្ម** និង **យោនិសោមនសិការ** ឯណានីមួយហើយ រមែងកើតឡើងដោយឆាប់រួសរាន់ ដោយបច្ច័យដូច្នោះ ក្នុងកាលជាខាងក្រោយ អាសវៈទាំងឡាយរបស់ភិក្ខុនោះ គប្បីជ្រាបថា មិនធ្លាប់កើតឡើងហើយ រមែងកើតឡើង ដូច្នេះ ។ ឯអាសវៈទាំងឡាយដែលកំពុងកើតឡើងរឿយៗ ក្នុងវត្ថុ និងក្នុងអារម្មណ៍ទាំងនោះឯង លោកហៅថា កើតឡើងហើយ រមែងចម្រើន ដែលឈ្មោះថា ការចម្រើននៃអាសវៈទាំងឡាយដែលកើតឡើងដំបូង ដោយប្រការដទៃអំពីនេះ មិនមានឡើយ ។

ក្នុងបទថា **យោនិសោ ច ខោ ភិក្ខវេ** នេះ សេចក្ដីថា អាសវៈទាំង-ឡាយនៃភិក្ខុណា រមែងមិនកើតឡើង ដោយសេចក្ដីបរិសុទ្ធតាមប្រក្រតី ឬដោយហេតុ មានឧទ្ទេស និងបរិបុច្ឆាជាដើម ដូចមិនកើតឡើងដល់ព្រះមហាកស្សប និងនាងភទ្ទកាបិលានី ភិក្ខុនោះរមែងដឹងច្បាស់ថា អាសវៈទាំងឡាយរបស់អញមិនទាន់ដល់នូវការដកដោយមគ្គឬហ្ន៎ កុំដូច្នោះឡើយ អញនឹងបដិបត្តិដើម្បីដកអាសវៈទាំងនោះ ។ បន្ទាប់អំពីនោះ លោករមែងដកអាសវៈទាំងអស់នោះដោយមគ្គភាវនា អាសវៈទាំងឡាយនោះរបស់លោក លោកពោលថា ដែលមិនទាន់កើត រមែងមិនកើតឡើង ។ ឯភិក្ខុណាមានសតិនៅ

ឆ្ងាយ អាសវៈទាំងឡាយ រមែងកើតឡើងដោយឆាប់រួសរាន់ ព្រោះការមិនមានស្មារតី បន្ទាប់អំពីនោះ ភិក្ខុនោះក៏ដល់នូវការសង្វេគ ផ្តើមតាំងសេចក្តីព្យាយាមដោយឧបាយ រមែងដកអាសវៈទាំងនោះបាន អាសវៈដែលកើតឡើងដល់ភិក្ខុនោះ ហៅថា លោករមែងលះបាន ដូចព្រះមហាតិស្សត្ថេរដែលនៅត្រង់មណ្ឌលារាម ។

បានឮថា លោករៀនឧទ្ទេសក្នុងវិហារនោះឯង គ្រានោះ កិលេសក៏កើតឡើងដល់លោក ដែលត្រាច់បិណ្ឌបាតក្នុងភូមិ ព្រោះអារម្មណ៍ដែលជាវិសភាគគ្នា ។ លោកសង្កត់អារម្មណ៍នោះដោយវិបស្សនា ហើយត្រឡប់ទៅវិហារ ។ អារម្មណ៍នោះបានប្រាកដដល់លោកក្នុងកាលយល់សប្តិ ។ លោកកើតសង្វេគឡើងថា កិលេសនេះចម្រើនឡើងហើយ រមែងជាគ្រឿងធ្វើអញឲ្យធ្លាក់ទៅក្នុងអបាយ ដូច្នេះហើយ ថ្វាយបង្គំលាអាចារ្យ ហើយចេញអំពីវិហារ ទៅរៀនអសុភកម្មដ្ឋាន ដែលជាបដិបក្ខចំពោះរាគៈ ក្នុងសម្នាក់របស់ព្រះមហាសង្ឃរក្ខិតត្ថេរ ចូលទៅកាន់ចន្លោះគុម្ពឈើ លាតសំពត់បង្សុកូលទ្រាប់អង្គុយកាត់បង់នូវរាគៈ ដែលប្រកបដោយកាមគុណ ៥ ដោយអនាគាមិមគ្គ ក្រោកឡើងហើយ ថ្វាយបង្គំអាចារ្យ ក្នុងថ្ងៃស្អែកឡើង បានសម្រេចឧទ្ទេសមគ្គ ។ អាសវៈទាំងឡាយពួកណាកំពុងប្រព្រឹត្តទៅមិនទាន់កើតឡើង ឈ្មោះថា ការលះអាសវៈទាំងឡាយនោះ ដោយបដិបទា រមែងមិនមាន ។

ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់កាន់យកបទនេះថា **ឧប្បន្នា ច អាសវា បហិយ្យន្តិ** ដូច្នេះហើយ ទ្រង់ពង្រីកទេសនាឲ្យពិស្តារ ដើម្បីទ្រង់ចង្អុលបង្ហាញ

ហេតុនៃការលះនូវអាសវៈដែលលះបានដទៃដោយប្រការផ្សេងៗ ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ បុគ្គលត្រូវលះបង់អាសវៈដោយការឃើញ គឺសោតាបត្តិមគ្គក៏មានដូច្នេះ សមដូចព្រះអដ្ឋជាព្រះធម្មរាជា អ្នកឈ្លាសក្នុងប្រភេទនៃទេសនា ។ បណ្តាបទទាំងនោះ បទថា **ទស្សនា បហាតព្វា** សេចក្តីថា គប្បីលះដោយទស្សនៈ ក្នុងគ្រប់បទក៏ន័យនេះ ។

## អាសវៈលះបានដោយទស្សនៈ

[ ១២ ] ឥឡូវនេះ ព្រះមានព្រះភាគ មានបំណងនឹងធ្វើឲ្យជាក់ច្បាស់នូវបទទាំងនោះដោយលំដាប់ ទើបទ្រង់តាំងបញ្ហាថា ម្នាលភិក្ខុទាំងឡាយ អាសវៈដែលភិក្ខុត្រូវលះបង់ដោយឃើញ តើដូចម្តេច ដូច្នេះហើយ ទ្រង់ផ្តើមទេសនាដែលជាបុគ្គលាធិដ្ឋានថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះជាអ្នកមិនបានចេះដឹង ដោយន័យដូចពោលហើយ ក្នុងអដ្ឋកថាមូលបរិយាយសូត្រ ។ បណ្តាបទទាំងនោះ បទថា **មនសិករណីយេ ធម្មេ នប្បជានាតិ** សេចក្តីថា រមែងមិនដឹងធម៌ដែលគួរបង្អោនទឹក គឺដែលគួរនាំមកពិចារណា ។ បទថា **អមនសិករណីយេ** សេចក្តីថា រមែងមិនស្គាល់ធម៌ដែលផ្ទុយគ្នា ។ ក្នុងបទដ៏សេសក៏ន័យនេះ ។ ព្រោះការកំណត់ដោយធម៌ថា ធម៌ទាំងនេះគួរដាក់ចិត្ត ធម៌ទាំងនេះមិនគួរដាក់ចិត្ត ដូច្នេះ មិនមាន តែការកំណត់ដោយអាការមាន គឺធម៌ទាំងឡាយដែលភិក្ខុដាក់ចិត្ត ដោយអាការណា ទើបជាបទដ្ឋាននៃការកើតឡើងនៃអកុសលធម៌ ភិក្ខុមិនគួរធ្វើការដាក់ចិត្តក្នុងធម៌ទាំងនោះដោយអាការនោះ ធម៌ទាំងឡាយដែលភិក្ខុដាក់ចិត្ត ដោយអាការណា

ទើបជាបទដ្ឋាននៃ ការកើតឡើងនៃកុសលធម៌ ធម៌ទាំងនេះ ភិក្ខុគួរដាក់ចិត្ត ដោយអាការនោះ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់បទជាដើមថា **យស្ស ភិក្ខវេ ធម្មេ មនសិករោតោ អនុប្បន្នោ វា កាមាសវោ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យស្ស** សេចក្ដីថា អាសវៈពួកណារបស់ បុថុជ្ជនដែលមិនបានស្ដាប់ហើយនោះ ។ បទថា **មនសិករោតោ** សេចក្ដីថា អ្នករឭក គឺនាំមកពិចារណា ។ **វា** សព្ទ ក្នុងបទថា **ឧប្បន្នោ វា កាមសវោ** នេះ មានសមុច្ចយជាអត្ថ មិនមែនមានវិកប្បជាអត្ថឡើយ ដូច្នោះ គប្បី ឃើញអត្ថក្នុងទីនេះថា កាមាសវៈដែលមិនទាន់កើត រមែងកើតឡើង កាមា-សវៈដែលកើតឡើងហើយ រមែងចម្រើន ។

ដូចព្រះតម្រាស់ថា **យាវតា ភិក្ខវេ សត្តា អបាទា វា ។បេ។ តថាគតោ តេសំ អគ្គមក្ខាយតិ** ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលជាសត្វមិនមានជើងក្ដី ។បេ។ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធប្រាកដ ជាប្រសើរជាងពួកសត្វទាំងនោះ ដូច្នេះ ។ ដូចព្រះតម្រាស់ថា ដើម្បីការស្ថិត នៅនៃសត្វទាំងឡាយ ដែលកើតមកហើយខ្លះ ដើម្បីអនុគ្រោះសត្វដែលជា សម្ភវេសីខ្លះ សេចក្ដីថា **ភូត** និង **សម្ភវេសី** ។ ដូចព្រះតម្រាស់ថា អំពី ភ្លើងខ្លះ អំពីទឹកខ្លះ អំពីការដាច់ការសាមគ្គីខ្លះ សេចក្ដីថា ( ម្នាលអានន្ទ ក្រុងបាដលិបុត្រ មុខជានឹងមានសេចក្ដីអន្តរាយ ) អំពីភ្លើង ១ អំពីទឹក ១ អំពីការបែកបាកគ្នានឹងគ្នា ១ ដូច្នេះ ។ ក្នុងបទនេះថា **យស្ស ភិក្ខវេ ធម្មេ មនសិករោតោ អនុប្បន្នោ វា កាមាសវោ** ក៏គប្បីឃើញអត្ថយ៉ាងនេះថា

**អនុប្បន្នោ ច កាមាសវោ ឧប្បជ្ជតិ ឧប្បន្នោ ច កាមាសវោ បវឌ្ឍតិ** ( ប្រែថា កាមាសវៈដែលមិនទាន់កើត រមែងកើតឡើងផង និងកាមាសវៈដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនឡើងផង ) ។ ក្នុងបទដ៏សេស ក៏យ៉ាងនេះដូចគ្នា ។ បណ្ដាអាសវៈទាំងនោះ តម្រេកដែលប្រកបដោយកាមគុណ ៥ ឈ្មោះថា **កាមាសវ** តម្រេកដោយអំណាចការពេញចិត្តក្នុងរូបភព និងការពេញចិត្តក្នុងឈាន ដែលប្រកបដោយសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ឈ្មោះថា **ភវាសវ** ។ សូម្បីទិដ្ឋាសវៈ រមែងសង្គ្រោះចូលក្នុងភវាសវៈដូចគ្នា ដោយអាការយ៉ាងនេះ ។ ការមិនដឹងក្នុងសច្ចៈទាំង ៤ ឈ្មោះថា **អវិជ្ជាសវ** ។ បណ្ដាអាសវៈទាំងនោះ កាមាសវៈដែលមិនទាន់កើតឡើង និងដែលកើតឡើងហើយ រមែងចម្រើនដល់បុគ្គលដែលត្រេកអរ គឺដាក់ចិត្តក្នុងកាមគុណ ។ ភវាសវៈដែលមិនទាន់កើតឡើង រមែងកើតឡើង និងដែលកើតឡើងហើយ រមែងចម្រើនដល់បុគ្គលដែលត្រេកអរ ពេញចិត្ត គឺដាក់ចិត្តក្នុងមហគ្គតធម៌ ។ អវិជ្ជាសវៈ ដែលមិនទាន់កើតរមែងកើត ដែលកើតហើយ ក៏រមែងចម្រើនដល់បុគ្គលដែលដាក់ចិត្តក្នុងធម៌ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយធម៌ជាបទដ្ឋាននៃវិបល្លាស ៤ គប្បីជ្រាបអត្ថដូចពោលមកនេះ ។ ធម៌ចំណែកសគួរឲ្យពិស្ដារ ដោយភាពជាបដិបក្ខនឹងធម៌តាមន័យដែលពោលហើយ ។

សួរថា ព្រោះហេតុអ្វី ទើបក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់អាសវៈ ៣ យ៉ាងប៉ុណ្ណោះ ឆ្លើយថា ព្រោះជាសត្រូវចំពោះវិមោក្ខ ។

ពិតហើយ កាមាសវៈ ជាបដិបក្ខចំពោះអប្បណិហិតវិមោក្ខ ។ ភវាសវៈ

និងអវិជ្ជាសវៈក្រៅអំពីនេះ ជាបដិបក្ខចំពោះអនិមិត្តវិមោក្ខ និងសុញ្ញតវិមោក្ខ ដូច្នោះ គប្បីជ្រាបថា ព្រះមានព្រះភាគ កាលទ្រង់សម្ដែងអត្ថនេះថា ពួកជនដែលឲ្យអាសវៈទាំង ៣ នេះកើតឡើង រមែងជាបុគ្គលដែលមានចំណែកនៃវិមោក្ខទាំង ៣ នោះ ជនដែលមិនឲ្យអាសវៈនេះកើតឡើង រមែងជាបុគ្គលមានចំណែកនៃវិមោក្ខទាំង ៣ នេះ ទើបត្រាស់វិមោក្ខ ៣ ទុកប៉ុណ្ណោះ ។ ពាក្យនេះថា ម្យ៉ាងទៀត **ឱដ្ឋាសវ** ឈ្មោះថា ព្រះអង្គបានត្រាស់ហើយ ក្នុងអាសវកថានេះដូចគ្នា ដូច្នេះ ក៏ឈ្មោះថាពណ៌នាហើយ ។ បទថា **តស្ស អមនសិការណីយានំ ធម្មានំ មនសិការា** សេចក្ដីថា ព្រោះហេតុនៃការដាក់ចិត្ត អធិប្បាយថា ព្រោះហេតុដែលដាក់ចិត្តនូវធម៌ទាំងនោះ ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះ ។ ពាក្យថា អាសវៈទាំងឡាយ ដែលមិនទាន់កើតឡើង រមែងកើតឡើងផង អាសវៈទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនឡើងផង ដូច្នេះ នេះជាពាក្យពោលត្រួត ដោយមិនបែកផ្សេងគ្នានៃអាសវៈទាំងឡាយ ដែលពោលហើយខាងដើម ។

បុថុជ្ជននេះ ជាអ្នកមិនបានស្ដាប់ ដែលព្រះមានព្រះភាគត្រាស់ទុកហើយ ដើម្បីទ្រង់ចង្អុលបង្ហាញអាសវៈ ដែលគប្បីលះដោយទេសនា ដែលជាបុគ្គលាធិដ្ឋាន ព្រោះបុថុជ្ជននោះ ជាទីតាំងនៃអាសវៈទាំងឡាយ មានកាមាសវៈជាដើម ដែលមានការមិនដាក់ចិត្តដោយឧបាយនៃប្រាជ្ញា ជាបច្ច័យដែលត្រាស់ដោយភាពជាសាមញ្ញធម្មតាយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុមិនដាក់ចិត្តដោយឧបាយប្រាជ្ញា អាសវៈទាំងឡាយដែលមិនទាន់កើត

រមែងកើតឡើង ដូច្នោះ កាលទ្រង់សម្តែងអាសវៈនោះ ដោយបុគ្គលនោះឯង ដោយពាក្យមានប្រមាណប៉ុណ្ណោះហើយ ឥឡូវនេះ កាលទ្រង់សម្តែងអាសវៈដែលគប្បីលះដោយទស្សនៈ ទើបត្រាស់ពាក្យជាដើមថា **សោ ឯវំ អយោនិសោ មនសិករោតិ អហោសឹ នុ ខោ អហំ** ដូច្នេះ ក្នុងសូត្រនេះ កាលទ្រង់សម្តែងទិដ្ឋាសវៈ ដោយលើកវិចិកិច្ឆាឡើងជាប្រធាន ទើបព្រះមានព្រះភាគទ្រង់ផ្តើមទេសនានេះ ។ អត្ថនៃពាក្យនោះថា អាសវៈ ដោយន័យដែលត្រាស់ហើយយ៉ាងនេះ រមែងកើតឡើងដល់បុគ្គលណា បុគ្គលនោះឈ្មោះថាជា **បុថុជ្ជន បុថុជ្ជន** នេះ ព្រះអង្គត្រាស់ដោយន័យជាដើមថា **អស្សុត្វា** ដូច្នេះ បុថុជ្ជននោះ រមែងដាក់ចិត្តដោយមិនជាឧបាយ គឺដោយមិនត្រូវឧបាយ បានដល់ មិនត្រូវផ្លូវ ។

សួរថា ដាក់ចិត្តដូចម្តេច ឆ្លើយថា គឺរមែងដាក់ចិត្តថា អញបានមានហើយឬហ្ន៎ ។បេ។ សត្វនឹងទៅកាន់ទីណា ដូច្នេះ ។

សួរថា លោកអធិប្បាយដូចម្តេច ឆ្លើយថា លោកអធិប្បាយថា បុគ្គលនោះរមែងដាក់ចិត្ត ដោយមិនជាឧបាយ ដោយប្រការដែលបុគ្គលនោះមានវិចិកិច្ឆាទាំង ១៦ យ៉ាង ដែលព្រះមានព្រះភាគត្រាស់ទុកដោយន័យថា **អហំ អហោសឹ នុ ខោ** ដូច្នេះកើតឡើង ។ បណ្តាកង្ខាទាំងនោះ សេចក្តីសង្ស័យថា **អហោសឹ នុ ខោ ន នុ ខោ** ( អញបានមានហើយឬហ្ន៎ ឬមិនបានមានហើយ ) សេចក្តីថា បុថុជ្ជនសង្ស័យការមាន និងការមិនមាននៃអត្តាក្នុងអតីត ព្រោះអាស្រ័យអាការ គឺសស្សតទិដ្ឋិ និងអាការដែលកើតឡើង

រឿយៗ បទថា **កឹ ការណំ** ( ហេតុអ្វី ) មិនចាំបាច់ត្រូវពោល ព្រោះពាលបុថុជ្ជន មានព្រឹត្តិកម្មប្រទូស្តដូចមនុស្សឆ្កួត ។ ម្យ៉ាងទៀត អយោនិសោមនសិការនោះឯង ជាហេតុក្នុងរឿងនេះ ។

សួរថា អ្វីជាហេតុនៃអយោនិសោមនសិការយ៉ាងនេះ ឆ្លើយថា ភាពជាបុថុជ្ជននោះឯង ឬ កិច្ច មានការមិនឃើញព្រះអរិយៈទាំងឡាយជាដើមជាហេតុ ។

សួរថា សូម្បីបុថុជ្ជន រមែងដាក់ចិត្តដោយឧបាយនៃប្រាជ្ញាមិនមែនឬ ឬបុគ្គលណាពោលយ៉ាងនេះថា បុថុជ្ជនមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ភាពជាបុថុជ្ជនមិនជាហេតុសំខាន់ក្នុងសេចក្តីនេះ កម្ម គឺការស្តាប់ធម៌ និងការមានកល្យាណមិត្តជាដើមឯណោះទេ ជាហេតុសំខាន់ក្នុងរឿងនេះ សេចក្តីពិតតាមប្រក្រតីរបស់ខ្លួន សត្វ មានត្រី និងម្រឹគជាដើម មិនមានក្លិនក្រអូប តែក្លាយជាសត្វមានក្លិនក្រអូបបាន ព្រោះមានគ្រឿងតាក់តែងជាបច្ច័យ ។

បទថា **កឹ នុ ខោ អហោសឹ** សេចក្តីថា បុថុជ្ជនអាស្រ័យជាតិ ភេទ និងការឧប្បត្តិក ទើបសង្ស័យថា អញបានជាក្សត្រហើយឬហ្ន៎ បានជាព្រាហ្មណ៍ វេស្សៈ សូទ្រៈ គ្រហស្ថ បព្វជិត ទេវតា មនុស្សឯណាមួយហើយឬហ្ន៎ ។

បទថា **កថំ នុខោ** សេចក្តីថា បុថុជ្ជនបានអាស្រ័យអាការនៃទ្រង់ទ្រាយ ទើបសង្ស័យថា អញបានជាបុគ្គលខ្ពស់ហើយឬហ្ន៎ បានជាមនុស្សទាប មនុស្សស មនុស្សខ្មៅ មនុស្សត្រូវខ្នាត មនុស្សដែលមិនត្រូវខ្នាតហើយឬហ្ន៎ ។ ឯ

អាចារ្យពួកខ្លះរមែងពោលថា បុថុជ្ជនអាស្រ័យការនិម្មិតនៃព្រះឦស្វរជាដើម ហើយសង្ស័យក្នុងហេតុថា អញបានមានហើយ ព្រោះហេតុអ្វីហ្ន៎ ។

បទថា **កឹ ហុត្វា កឹ អហោសឹ** សេចក្ដីថា បុថុជ្ជនអាស្រ័យជាតិ គឺកំណើតជាដើម រមែងសង្ស័យការបន្ដនៃខ្លួនថា អញជាក្សត្រហើយ ទើបបានមកកើតជាព្រាហ្មណ៍ឬហ្ន៎ ។បេ។ ជាទេវតាហើយ ទើបបានមកជាមនុស្សឬហ្ន៎ ដូច្នេះ ។ បទថា **អទ្ធានំ** ក្នុងគ្រប់ៗ បទ ជាពាក្យដែលប្រាប់ដល់កាលវេលា ។

បទថា **ភវិស្សាមិ នុខោ ន នុខោ** សេចក្ដីថា រមែងសង្ស័យភាពដែលខ្លួននឹងមានទៅខាងមុខ ឬមិនមានក្នុងអនាគត ព្រោះអាស្រ័យអាការនៃសស្សតទិដ្ឋិ និងអាការឧច្ឆេទទិដ្ឋិ ។ ពាក្យដ៏សេសក្នុងសូត្រនេះ មានន័យដូចពោលហើយដូចគ្នា ។

បទថា **ឯតរហិ វា បច្ចុប្បន្នំ អទ្ធានំ** សេចក្ដីថា ឬប្រកាន់បច្ចុប្បន្នកាលទាំងអស់ មានបដិសន្ធិជាដើម មានចុតិជាទីបំផុត ក្នុងបច្ចុប្បន្ន ។

បទថា **អជ្ឈត្តំ កថំកថី ហោតិ** សេចក្ដីថា បុថុជ្ជនរមែងជាអ្នកមានសេចក្ដីសង្ស័យក្នុងខន្ធទាំងឡាយរបស់ខ្លួន សង្ស័យដូចម្ដេច សង្ស័យភាពដែលខ្លួនកំពុងមានថា អញកំពុងមានឬហ្ន៎ ។

សួរថា សេចក្ដីនេះត្រឹមត្រូវហើយឬ ឆ្លើយថា ក្នុងពាក្យថា ត្រូវ ឬមិនត្រូវនេះ ចាំបាច់គិតធ្វើអ្វី អើ ក្នុងរឿងនេះ មានរឿងដូចតទៅនេះ ជាឧទាហរណ៍ ។ បានឮថា កូនរបស់ម្ដាយមីងកោរក្បាល ឯកូនរបស់អ៊ំស្រី

មិនបានកោរក្បាល កូនរបស់អំស្រើនោះដេកលក់ ញាតិទាំងឡាយលួចកោរក្បាល ។ កូនអំស្រើនោះលុះភ្ញាក់ឡើង ក៏គិតថា អញជាកូនរបស់ម្តាយមីងឬហ្ន៎ ។ ការសង្ស័យថា អញមាន ឬមិនមានហ្ន៎ ក៏យ៉ាងនេះឯង ។

បទថា **នោ នុ ខោស្មិ** បានដល់ បុថុជ្ជនរមែងសង្ស័យការដែលខ្លួនមិនមាន ក្នុងសេចក្តីនោះ មានរឿងដូចតទៅនេះជាឧទាហរណ៍ ។ បានឮថា អ្នកចាប់ត្រីម្នាក់ ឃើញជើងរបស់ខ្លួនដែលត្រជាក់ ព្រោះត្រាំនៅក្នុងទឹកយូរ ថាជាត្រី ទើបបានវាយ ។ បុគ្គលម្នាក់ទៀត នៅចាំស្រែក្បែរព្រៃខ្មោច មានចិត្តខ្លាច ទើបដេកបញ្ឈរជង្គង់ ។ កាលភ្ញាក់ឡើង គិតថា ជើងរបស់ខ្លួនជាយក្ខពីរនាក់ ទើបបានវាយ ។ បុគ្គលរមែងមានសេចក្តីសង្ស័យថា អញមាន ឬមិនមាន ដូច្នេះ ។

បទថា **កឹ នុខោ** បានដល់ បុគ្គលជាក្សត្រ តែសង្ស័យភាពជាក្សត្រនៃខ្លួន ។ ក្នុងបទដ៏សេសក៏ន័យនេះ ។ ឯអ្នកកើតជាទេវតា ឈ្មោះថា មិនដឹងភាពជាទេវតារមែងមិនមាន សូម្បីទេវតានោះ ក៏រមែងមានសេចក្តីសង្ស័យភាពជាទេវតានោះ ដោយន័យជាដើមថា អញមានរូប ឬមិនមានរូបហ្ន៎ ។

បើមានពាក្យសួរថា ក្សត្រជាដើម មិនដឹងភាពជាក្សត្រជាដើម ព្រោះហេតុអ្វី គប្បីឆ្លើយថា ការកើតឡើងក្នុងត្រកូលនោះៗ នៃក្សត្រជាដើមទាំងនោះ មិនប្រចក្ស ។ សូម្បីគ្រហស្ថទាំងឡាយ មានបោត្ថលិតព្រាហ្មណ៍ជាដើម ក៏មានការសម្គាល់ខ្លួនឯងថា ជាបព្វជិត សូម្បីបព្វជិតក៏មានការសម្គាល់ខ្លួនឯងថា ជាគ្រហស្ថ ដោយន័យជាដើមថា កម្មរបស់អញកម្រើកហើយហ្ន៎ ។

ម្យ៉ាងទៀត សូម្បីមនុស្សទាំងឡាយ រមែងមានសេចក្ដីសម្គាល់ក្នុងខ្លួនថា ជាសម្មតិទេព ដូចព្រះរាជា ។

បទថា **កថំ នុ ខោស្មិ** នេះ មានន័យដូចពោលហើយនោះឯង ។ ក្នុងបទថា **កថំ នុ ខោស្មិ** នេះ អធិប្បាយថា បុថុជ្ជន កាលប្រកាន់ថា ខាងក្នុងមានតែជីវៈសុទ្ធៗ ដូច្នេះហើយ អាស្រ័យអាការនៃទ្រង់ទ្រាយរបស់ជីវៈនោះ សង្ស័យថា អញជាបុគ្គលខ្ពស់ឬហ្ន៎ ឬថា អញមានរូបរាងតឿ ៤ ចំណែក ៦ ចំណែក ៨ ចំណែក ១៦ ចំណែកជាដើម ប្រការណាមួយ ដូច្នេះ គប្បីជ្រាបថា សង្ស័យថា អញដូចម្ដេចហ្ន៎ ។ ដែលឈ្មោះថា បុគ្គលមិនដឹងសរីរសណ្ឋានដែលជាបច្ចុប្បន្នមិនមានឡើយ ។

បទថា **កុតោ អាគតោ សោ កុហឹ គាមី ភវិស្សតិ** បានដល់ សង្ស័យទីមក និងទីទៅរបស់អត្តភាព ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងវិចិកិច្ឆា ១៦ យ៉ាង ដូចពណ៌នាមកដូច្នេះហើយ ឥឡូវនេះ ដើម្បីសម្ដែងទិដ្ឋាសវៈណា ដោយមាតិកា គឺវិចិកិច្ឆានេះ ព្រះអង្គទ្រង់បានផ្ដើមទេសនានេះ កាលទ្រង់នឹងសម្ដែងទិដ្ឋាសវៈនោះ ទើបត្រាស់បទជាដើមថា **តស្ស ឯវំ អយោនិសោ មនសិករោតោ ឆន្នំ ទិដ្ឋីនំ** ដូច្នេះ ដោយពាក្យអធិប្បាយទុកថា វិចិកិច្ឆានេះរមែងកើតឡើងដល់បុគ្គលនោះដោយប្រការណា បណ្ដាទិដ្ឋិ ៦ ណាមួយ រមែងកើតឡើងដល់បុគ្គលនោះឯង បុគ្គលមិនដាក់ចិត្តដោយឧបាយប្រាជ្ញា មានសេចក្ដីសង្ស័យដោយប្រការនោះ ព្រោះអយោនិសោមនសិការ ដល់នូវការមានកម្លាំង ។

វា សព្វ ក្នុងបទទាំងអស់នោះ ជាវិកប្បត្ថ ។ អធិប្បាយថា ទិដ្ឋិរមែងកើតឡើងយ៉ាងនេះខ្លះ យ៉ាងនេះខ្លះ ។ សស្សតទិដ្ឋិ ក្នុងបទថា អត្តារបស់អញកំពុងមាននេះ រមែងប្រកាន់ថា អត្តារបស់ខ្លួនមាន សព្វៗ កាល ។

បទថា **សច្ចតោ ថេតតោ** សេចក្តីថា ដោយមែន និងដោយពិត ។ អធិប្បាយថា ដោយការប្រកាន់យ៉ាងមាំដោយល្អថា នេះប៉ុណ្ណោះពិត ឯទិដ្ឋិថា អត្តារបស់អញមិនមាន ឈ្មោះថា ឧច្ឆេទទិដ្ឋិ ព្រោះប្រកាន់ថា សត្វដែលមាននៅដាច់សូន្យក្នុងភពនោះៗ ។

ម្យ៉ាងទៀត ទិដ្ឋិដំបូង ឈ្មោះថា **សស្សតទិដ្ឋិ** ព្រោះប្រកាន់ថា មាននៅក្នុងកាលទាំង ៣ ទិដ្ឋិដែលប្រកាន់ថា វត្ថុដែលជាបច្ចុប្បន្នប៉ុណ្ណោះមាន ឈ្មោះថា **ឧច្ឆេទទិដ្ឋិ** ។ ម្យ៉ាងទៀត ទិដ្ឋិខាងក្រោយ ឈ្មោះថា ឧច្ឆេទទិដ្ឋិ ព្រោះប្រកាន់ក្នុងអតីត និងអនាគតថា មិនមាន ដូចទិដ្ឋិរបស់បុគ្គលដែលប្រកាន់ដោយទិដ្ឋិថា ការបូជាទាំងឡាយ មានផេះជាទីបំផុត ដូច្នោះ ឯទិដ្ឋិដែលប្រកាន់ក្នុងអតីត ប៉ុណ្ណោះថា មិនមាន ឈ្មោះថា សស្សតទិដ្ឋិ ដូចទិដ្ឋិរបស់សត្វដែលកើតឡើងរឿយៗ ប៉ុណ្ណោះ ។

បទថា **អត្តនា វ អត្តានំ សញ្ជានាមិ** សេចក្តីថា កាលបុថុជ្ជនប្រកាន់ខន្ធទាំងឡាយ ដោយមានសញ្ញាខន្ធជាប្រធានថា នុ៎ះអត្តា ហើយសម្គាល់នូវខន្ធដ៏សេសដោយបញ្ញា រមែងមានការយល់ថា អាត្មាអញសម្គាល់អត្តានេះដោយអត្តានេះ ។

បទថា **អត្តានា វ អត្តានំ** សេចក្តីថា កាលបុថុជ្ជនសម្គាល់សញ្ញាខន្ធ

នោះថាជាអត្តា និងប្រកាន់ខន្ធ ៤ ក្រៅអំពីនេះ ថាជាអនត្តា ហើយសម្គាល់ខន្ធ ៤ នោះដោយសញ្ញា រមែងមានការយល់យ៉ាងនេះថា ( សម្គាល់អនត្តាដោយអត្តា ) ។

បទថា **អនត្តនា វ អត្តានំ** សេចក្តីថា កាលបុថុជ្ជនប្រកាន់សញ្ញាខន្ធថា អនត្តា និងប្រកាន់ខន្ធ ៤ ក្រៅអំពីនេះ ថាអត្តា ហើយសម្គាល់ខន្ធទាំង ៤ នោះដោយសញ្ញា រមែងមានការយល់យ៉ាងនេះថា ( សម្គាល់អត្តា ដោយអនត្តា ) ។ ទិដ្ឋិគ្រប់យ៉ាងដូចពោលមកនេះ ចាត់ជាសស្សតទិដ្ឋិ និងឧច្ឆេទ-ទិដ្ឋិទាំងអស់ ។

អាការទាំងឡាយ មានបទថា **វទោ វេទេយ្យោ** ជាអាការរបស់ការប្រកាន់មាំ ដោយសស្សតទិដ្ឋិនោះឯង ។ ក្នុង ២ ពាក្យនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ដែលឈ្មោះថា **វទោ** ព្រោះអត្ថថា អ្នកនិយាយ អធិប្បាយថា អ្នកធ្វើវចីកម្ម ។ ដែលឈ្មោះថា **វេទេយ្យោ** ព្រោះអត្ថថា ដឹង អធិប្បាយថា ដឹងផង សោយផង ។

សួរថា សោយនូវអ្វី ឆ្លើយថា សោយផលរបស់កម្មល្អ និងកម្មអាក្រក់ក្នុងភពនោះៗ ។

បទថា **តត្រ តត្រ** សេចក្តីថា ក្នុងកំណើត គតិ ឋិតិ និវាស និងនិកាយ ឬក្នុងអារម្មណ៍នោះៗ ។ បទថា **និច្ចោ** គឺវៀរចាកការកើតឡើង និងការវិនាសទៅ ។ បទថា **ធុវោ** គឺមាំទាំ បានដល់ ជាសារៈ ។ បទថា **សស្សតោ** គឺមានសព្វកាលទាំងពួង ។ បទថា **អវិបរិណាមធម្មោ** សេចក្តីថា មានការ

មិនលះភាពជាប្រក្រតីរបស់ខ្លួនជាធម្មតា គឺរមែងមិនដល់នូវភាពជាប្រការផ្សេងៗ ដូចបង្គោលដូច្នោះ ។

បទថា **សស្សតិសមំ** សេចក្តីថា ព្រះចន្ទ ព្រះអាទិត្យ សមុទ្រ មហាប្រឹថពី និងភ្នំ លោកហៅថា **សស្សតិ** គឺរបស់ទៀង តាមវោហាររបស់សត្វលោក ។ ស្មើគ្នានឹងវត្ថុទៀងទាំងឡាយ ឈ្មោះថា **សស្សតិសមាស ។** ទិដ្ឋិយ៉ាងនេះ រមែងមានដល់បុគ្គលដែលប្រកាន់ថា វត្ថុដែលទៀងទាំងឡាយរមែងតាំងនៅដរាបណា អត្តានេះ ក៏នឹងតាំងនៅយ៉ាងនោះដរាបនោះ ។

បទថា **ឥទំ** ក្នុងបទថា **ឥទំ វុច្ចតិ ភិក្ខវេ ទិដ្ឋិគតំ** ដូច្នេះជាដើម ជាពាក្យបង្អួលបង្ហាញពាក្យដែលគប្បីពោលក្នុងពេលនេះយ៉ាងជាក់ច្បាស់ ។ បទថា **ឥទំ** នេះ លោកពោលទុកដោយការទាក់ទងនឹងទិដ្ឋិគតៈ មិនមែនពោលទុកដោយទាក់ទងនឹងទិដ្ឋិឡើយ ។ ក្នុងទីនេះទិដ្ឋិនោះឯង ឈ្មោះទិដ្ឋិគតៈ ដូចគូថគតៈ ។ម្យ៉ាងទៀត ការប្រព្រឹត្តទៅក្នុងទិដ្ឋិ ឈ្មោះទិដ្ឋិគតៈ ។ ទស្សនៈនេះ ព្រោះហេតុដែលឈមចុះខាងក្នុងនៃទិដ្ឋិ ៦២ ដូច្នោះ ទើបឈ្មោះថាទិដ្ឋិគតៈ ។ ម្យ៉ាងទៀត ការទៅរបស់ទិដ្ឋិក៏ឈ្មោះថា **ទិដ្ឋិគត ។** ពាក្យថា **អត្ថិមេ អត្តា** ជាដើមនេះ ត្រឹមតែជាគ្រឿងទៅនៃទិដ្ឋិ ។ អធិប្បាយថា អត្តាឬបុគ្គលណាម្នាក់ដែលទៀង មិនមានក្នុងទីនេះ ។ ម្យ៉ាងទៀត ទិដ្ឋិនោះឈ្មោះថា **ព្រៃស្តុក** ព្រោះអត្ថថា កាប់ក្ការបានលំបាក ឈ្មោះថា **កន្តារ** ព្រោះអត្ថថា ឆ្លងបានលំបាក និងព្រោះអត្ថថា មានភ័យចំពោះមុខ ដូចជា ទុព្ភិក្ខកន្តារនិងវាឡកន្តារ គឺកន្តារព្រោះសត្វកាចជាដើម ដូច្នោះ ។ ទិដ្ឋិនោះ ឈ្មោះថា

ជាសត្រូវ ព្រោះអត្ថថា ជាគ្រឿងចាក់ដោត ឬព្រោះអត្ថថា ជាគ្រឿងធ្វើសម្មាទិដ្ឋិឲ្យអស់ទៅ ។ ដែលឈ្មោះថា បម្រះនទៀលទៅផ្សេងៗ ព្រោះអត្ថថា យ្វេងយ្វោងខុសប្រក្រតី ព្រោះគ្រាខ្លះ ប្រកាន់ដោយសស្សតទិដ្ឋិ គ្រាខ្លះ ប្រកាន់ដោយឧច្ឆេទទិដ្ឋិ ។ ឈ្មោះថា **សំយោជន** ព្រោះអត្ថថា ជាគ្រឿងចង ដោយហេតុនោះ ទើបលោកពោលថា **ទិដ្ឋិគតហានំ ។បេ។ ទិដ្ឋិសំយោជនំ** ដូច្នេះ ។ ឥឡូវនេះ កាលសម្តែងអត្ថ គឺការចងនោះឯងនៃសំយោជនៈ ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា **ទិដ្ឋិសំយោជនសំយុត្តោ** ដូច្នេះ ។ សេចក្តីនោះមានអត្ថសង្ខេបតទៅនេះថា បុថុជ្ជនដែលប្រកបដោយទិដ្ឋិសំយោជនៈនេះ រមែងមិនផុតអំពីជាតិជាដើមនេះឡើយ ។ ម្យ៉ាងទៀត មិនចាំបាច់និយាយច្រើន បុគ្គលរមែងមិនផុតទៅអំពីវដ្តទុក្ខទាំងអស់បានឡើយ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងទិដ្ឋាសវៈដែលមាន ៦ ប្រភេទ ដូចពណ៌នាមកដូច្នេះហើយ ព្រោះសីលព្វតបរាមាស ទ្រង់សម្តែង ដោយអំណាចកាមាសវៈជាដើមនោះឯង សេចក្តីពិត សមណព្រាហ្មណ៍ទាំងឡាយខាងក្រៅព្រះពុទ្ធសាសនានេះ ត្រូវអវិជ្ជាគ្របសង្កត់ រមែងនាំគ្នាប្រកាន់សីលនិងវត្ត ដើម្បីសេចក្តីសុខក្នុងកាម និងដើម្បីសេចក្តីសុខក្នុងភព និងការបរិសុទ្ធក្នុងភព ដូច្នោះ កាលទ្រង់មិនសម្តែងសីលព្វតបរាមាសនោះដដែលទៀត ឬទ្រង់មិនសម្តែងសីលព្វតបរាមាសនោះម្តងទៀត ព្រោះសីលព្វតបរាមាសនោះព្រះអង្គទ្រង់កាន់យកដោយសព្វថា ទិដ្ឋិហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែង

បុគ្គលអ្នកលះអាសវៈ ដែលគប្បីលះដោយទស្សនៈនោះ ហើយសម្តែងវិធីលះអាសវៈទាំងនោះ ឬដើម្បីទ្រង់សម្តែងការកើតឡើងនៃអាសវៈទាំងនោះនៃបុថុជ្ជន ដែលមិនបានដាក់ចិត្តដោយឧបាយ ហើយទើបទ្រង់សម្តែងវិធីលះនៃបុគ្គលដែលផ្ទុយគ្នានោះ ឥឡូវនេះ ទើបត្រាស់ថា **សុតវា ច ខោ ភិក្ខវេ** ដូច្នេះជាដើម ។ អត្ថរបស់ពាក្យនោះ បណ្ឌិតគប្បីជ្រាបដោយន័យនៃពាក្យដែលទ្រង់សម្តែងហើយខាងដើម រហូតដល់បាលីបទេសថា **សោ ឥទំ ទុក្ខំ** ដូច្នេះ និងដោយបុគ្គលដែលផ្ទុយគ្នានឹងបុគ្គលដែលពោលមកហើយ ។ បុគ្គលនេះគប្បីជ្រាបថា ជាអរិយសាវកអ្នកបានស្តាប់ ជាអ្នកឈ្លាសក្នុងអរិយធម៌ និងបានទូន្មានដោយល្អក្នុងអរិយធម៌ ដោយបចូនីកន័យ គឺដោយភាពជាសត្រូវចំពោះបុគ្គលដែលមិនដឹង និងមិនបានទូន្មានក្នុងអរិយធម៌ ដោយអាការទាំងពួង ។ ម្យ៉ាងទៀត បុគ្គលនេះគប្បីជ្រាបថា ជាអរិយសាវកដោយអត្ថដែលសមគួរដល់ហេតុនោះ តាំងអំពីវិបស្សនាដ៏កំពូល រហូតដល់គោត្រភូ ។

ក្នុងបទថា **សោ ឥទំ ទុក្ខន្តិ យោនិសោ មនសិករោតិ** ដូច្នេះជាដើមនេះ មានការពង្រីកអត្ថឲ្យជាក់ច្បាស់ដូច្នេះ អរិយសាវកដែលចម្រើនកម្មដ្ឋានក្នុងសច្ចៈ ៤ នោះ ដំបូង ផ្តើមរៀនកម្មដ្ឋានប្រកបដោយសច្ចៈ ៤ ក្នុងសម្នាក់របស់អាចារ្យយ៉ាងនេះថា ខន្ធដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា ជាទុក្ខ ព្រោះទោស គឺតណ្ហា តណ្ហា ឈ្មោះថា ជាប្រភពកើតនៃទុក្ខ ការមិនប្រព្រឹត្តទៅនៃទុក្ខ និងទុក្ខសមុទយៈទាំង ២ ឈ្មោះថា និរោធ ផ្លូវឲ្យដល់នូវការរំលត់ ឈ្មោះថា មគ្គ ដូច្នេះហើយ ដោយសម័យតមក លោក

ឈានឡើងកាន់ផ្លូវនៃវិបស្សនា រមែងដាក់ចិត្តដល់ខន្ធដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ នោះ ដោយឧបាយថា វត្ថុនេះជាទុក្ខ គឺរមែងរំពឹង និងពិចារណាឃើញច្បាស់ដោយឧបាយ គឺដោយត្រូវផ្លូវ ។ ក្នុងទីនេះ ព្រះមានព្រះភាគត្រាស់វិបស្សនា ដោយលើកមនសិការជាសំខាន់នោះឯង រហូតដល់សោតាបត្តិមគ្គ ។ ព្រះយោគាវចររមែងដាក់ចិត្តដោយឧបាយថា តណ្ហានេះ ជាសមុដ្ឋាន គឺជាហេតុឲ្យកើតទុក្ខនោះឯង តណ្ហានេះ ឈ្មោះថា **សមុទយ** ។ ព្រះយោគាវចររមែងដាក់ចិត្តដោយឧបាយថា ព្រោះទុក្ខនេះផង សមុទយៈនេះផង កាលមកដល់ឋានៈនេះហើយ រមែងរលត់ទៅ គឺមិនប្រព្រឹត្តទៅដូច្នោះ ទើបឋានៈនេះ ឈ្មោះថា និព្វាន នេះឈ្មោះថា ទុក្ខនិរោធ ។ ព្រះយោគាវចររមែងដាក់ចិត្តដោយឧបាយដល់មគ្គមានអង្គ ៨ ដែលជាហេតុឲ្យដល់និរោធថា នេះ គឺបដិបទាឲ្យដល់នូវការរំលត់ទុក្ខ គឺរមែងពិចារណា និងរមែងឃើញច្បាស់ដោយឧបាយ គឺដោយត្រូវទំនង ។ ក្នុងសេចក្ដីនោះ មានឧបាយកំណត់ដូច្នេះថា

ឈ្មោះថា ការប្រកាន់មាំ រមែងមានក្នុងវដ្ដៈ មិនមានក្នុងវិវដ្ដៈឡើយ ។ ដូច្នោះ ព្រះយោគាវចរកំណត់ភូតរូប ៤ ក្នុងសន្តតិរបស់ខ្លួន ដោយន័យជាដើមថា **បឋវីធាតុ អាបោធាតុ** នេះ មាននៅក្នុងកាយនេះ ដូច្នេះ កំណត់ឧបាទាយរូបតាមទំនងនៃភូតរូបនោះ ហើយកំណត់ថា នេះជារូបក្ខន្ធ ដូច្នេះ កាលកំណត់រូបក្ខន្ធនោះ ក៏រមែងកំណត់ធម៌ គឺចិត្ត និងចេតសិក ដែលមានរូបក្ខន្ធនោះជាអារម្មណ៍កើតឡើងហើយថា ធម៌ ៤ ប្រការនេះ ជាអរូបក្ខន្ធ

បន្ទាប់អំពីនោះ រមែងកំណត់ថា ខន្ធ ៤ បញ្ចក្ខន្ធទាំងនេះជាទុក្ខ បញ្ចក្ខន្ធទាំងនោះ ដោយសង្ខេបមាន ២ ចំណែកប៉ុណ្ណោះ គឺនាម និងរូប ហើយនាមរូបនេះ មានហេតុ-បច្ច័យកើតឡើង ព្រះយោគាវចររមែងកំណត់ហេតុ-បច្ច័យរបស់នាមរូបនោះ មានអវិជ្ជា ភព តណ្ហា កម្ម និងអាហារជាដើមថា នេះជាបច្ច័យ ។ បន្ទាប់អំពីនោះ ព្រះយោគាវចរកំណត់កិច្ច និងលក្ខណៈរបស់ខ្លួនតាមសេចក្តីពិតនៃបច្ច័យ និងធម៌ដែលអាស្រ័យកើតឡើងទាំងនោះ ហើយលើកឡើងកាន់អនិច្ចលក្ខណៈថា ធម៌ទាំងនេះមិនមាន តែក៏កើតមានឡើង លើកឡើងកាន់ទុក្ខលក្ខណៈថា ធម៌ទាំងនេះជាទុក្ខ ព្រោះត្រូវការកើតឡើង និងការវិនាសទៅបៀតបៀន ។ លើកឡើងកាន់អនត្តលក្ខណៈថា ធម៌ទាំងនេះឈ្មោះថា ជាអនត្តា ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ។ ព្រះយោគាវចរកាលលើកធម៌ទាំងនេះឡើងកាន់ត្រៃលក្ខណ៍យ៉ាងនេះហើយ ឲ្យវិបស្សនាប្រព្រឹត្តទៅដោយលំដាប់ រមែងសម្រេចសោតាបត្តិមគ្គបាន ។ ក្នុងខណៈនោះលោករមែងចាក់ធ្លុះសច្ចៈទាំង ៤ ដោយការចាក់ធ្លុះដោយញាណ ១ ដួងប៉ុណ្ណោះ រមែងត្រាស់ដឹងដោយការត្រាស់ដឹងដោយញាណ ១ ដួង រមែងចាក់ធ្លុះនូវទុក្ខ ដោយការកំណត់ដឹង រមែងចាក់ធ្លុះនូវសមុទយៈ ដោយការលះ រមែងចាក់ធ្លុះនូវនិរោធ ដោយការធ្វើឲ្យជាក់ច្បាស់ រមែងចាក់ធ្លុះនូវមគ្គ ដោយការចម្រើន ។ម្យ៉ាងទៀត លោករមែងត្រាស់ដឹងនូវទុក្ខ ដោយការកំណត់ដឹង ។បេ។ រមែងត្រាស់ដឹងមគ្គដោយការចម្រើន មិនមែនត្រាស់ដឹងសច្ចៈមួយទៀត ដោយញាណមួយទៀតឡើយ ។ សេចក្តីពិត ព្រះយោគាវចរ

នេះ រមែងចាក់ធ្លុះ និងរមែងត្រាស់ដឹងនិរោធសច្ច ដោយភាពជាអារម្មណ៍ និងសច្ចៈដ៏សេសដោយភាពជាកិច្ច ដោយញាណ ១ ដូចប៉ុណ្ណោះ ។ ក្នុងសម័យនោះ លោករមែងមិនមានការគិតយ៉ាងនេះថា អាត្មាអញរមែងកំណត់ដឹងទុក្ខ ដូច្នេះឬ ។បេ។ ឬគិតយ៉ាងនេះថា អាត្មាអញ ញ៉ាំងមគ្គឲ្យចម្រើនដូច្នេះ ។ ម្យ៉ាងទៀត ការធ្វើឲ្យជាក់ច្បាស់នូវនិរោធដោយអំណាចនៃបដិវេធរមែងធ្វើឲ្យជាអារម្មណ៍នោះឯង ញាណនោះ ឈ្មោះថា រមែងធ្វើកិច្ចដែលកំណត់ដឹងនូវទុក្ខខ្លះ ធ្វើកិច្ចលះសមុទយៈខ្លះ និងធ្វើកិច្ចចម្រើនមគ្គខ្លះ ។ កាលលោកដាក់ចិត្តដោយឧបាយប្រាជ្ញាយ៉ាងនេះ លោករមែងលះសំយោជនៈ ៣ បាន គឺសក្កាយទិដ្ឋិមានវត្ថុ ២០ វិចិកិច្ឆាមានវត្ថុ ៨ សីលព្វតបរាមាសព្រោះស្ទាបអង្អែលសីល និងវត្តថា ការបរិសុទ្ធមាន ព្រោះសីល ការបរិសុទ្ធមាន ព្រោះវត្ត ។ បណ្ដាអាសវៈទាំង ៤ នោះ សក្កាយទិដ្ឋិ សីលព្វតបរាមាស លោកសង្គ្រោះដោយទិដ្ឋាសវៈ គឺអាសវៈផង សំយោជនៈផង វិចិកិច្ឆាជាសំយោជនៈតែម្យ៉ាង មិនជាអាសវៈ ។ តែឈ្មោះថា ជាអាសវៈ ព្រោះទាក់ទងក្នុងបាលីថា **ទស្សនា បហាតព្វា អាសវា** ដូច្នេះ ហេតុនោះទើបធម៌ទាំងនេះ ហៅថា បហាតព្វធម៌ ។ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសក្កាយទិដ្ឋិជាដើមនេះថា ជាអាសវៈ ដែលឈ្មោះថា ទស្សនបហាតព្វធម៌ ទើបបានត្រាស់ទុក ។ ម្យ៉ាងទៀត សក្កាយទិដ្ឋិនេះ លោកចែកទុកដោយសរុបយ៉ាងនេះថា បណ្ដាទិដ្ឋិ ៦ យ៉ាង ទិដ្ឋិណាមួយកើតឡើង ដូច្នេះ ព្រះមានព្រះភាគទ្រង់សំដៅយកសក្កាយទិដ្ឋិនោះ ទើបត្រាស់ថា **ឥមេ វុច្ចន្តិ ភិក្ខវេ**

ដូច្នេះ ។ ព្រោះសក្កាយទិដ្ឋិនោះ ព្រះយោគាវចររមែងលះបានព្រមគ្នានឹងវិចិកិច្ឆា និងសីលព្វតបរាមាសដែលកើតរួមគ្នា និងមានអត្ថដូចគ្នា ដោយការលះ ។ សេចក្តីពិត កាលព្រះយោគាវចរលះទិដ្ឋាសវៈបានហើយ កាមាសវៈក្តី អវិជ្ជាសវៈក្តី ក្នុងចិត្តដែលជាទិដ្ឋិសម្បយុត្ត ៤ ដួង ដែលកើតរួមនឹងទិដ្ឋាសវៈនោះ ព្រះយោគាវចររមែងលះបានដូចគ្នា ។ ឯភវាសវៈដែលកើតឡើងបាន ដោយអំណាចនៃការសម្រេចការប្រាថ្នារបស់នាគ និងគ្រុឌជាដើម ក្នុងចិត្តដែលជាទិដ្ឋិវិប្បយុត្ត ៤ ដួង ឈ្មោះថា ធម៌ ដែលមានអត្ថតែមួយដូចគ្នា ដោយការលះអាសវៈដ៏សេសទាំង ៣ គឺអវិជ្ជាសវៈដែលសម្បយុត្តដោយភវាសវៈក្តី អវិជ្ជាសវៈដែលជាតួធ្វើឲ្យកើតអកុសលកម្ម មានបាណាតិបាតជាដើម ក្នុងទោមនស្សចិត្ត ២ ដួងក្តី អវិជ្ជាសវៈដែលសម្បយុត្តដោយវិចិកិច្ឆាចិត្តដូចគ្នាក្តី ព្រះយោគាវចររមែងលះបាន ដោយប្រការទាំងពួង ។ ព្រោះដូច្នោះ ទើបលោកធ្វើនិទ្ទេសជាពហុវចនៈទុកដូច្នេះឯង ក្នុងទីនេះ អត្ថ គប្បីជ្រាបដូចពោលមកនេះ ។ ពាក្យអធិប្បាយរបស់បុរាណាចារ្យ ដូច្នេះ ។

បទថា **ទស្សនា បហាតព្វា** សេចក្តីថា សោតាបត្តិមគ្គ ឈ្មោះថា ទស្សនៈ អធិប្បាយថា អាសវៈទាំងនោះ ទស្សនៈនោះគប្បីលះ ។

សួរថា ព្រោះហេតុអ្វី ទើបសោតាបត្តិមគ្គ ឈ្មោះថា ទស្សនៈ ឆ្លើយថា ព្រោះឃើញព្រះនិព្វានដំបូង ។ សួរថា គោត្រភូញាណរមែងឃើញព្រះនិព្វានមុនសោតាបត្តិមគ្គ មិនមែនឬ ឆ្លើយថា គោត្រភូញាណមិនឃើញក៏មិនមែន តែគោត្រភូញាណនោះ កាលឃើញហើយ ធ្វើកិច្ចដែលគួរធ្វើមិន

បាន ព្រោះលះសំយោជនៈមិនបាន ដូច្នោះ ទើបមិនគួរពោលថា ឃើញ ដូច្នេះ ។ ក្នុងរឿងនេះ មានបុរសអ្នកស្រុកបានឃើញព្រះរាជាក្នុងទីកន្លែងមួយ ហើយក៏ពោលថា មិនបានគាល់ព្រះរាជា ព្រោះមិនបានចូលគាល់ដើម្បីឲ្យសម្រេចកិច្ចក្នុងការថ្វាយគ្រឿងបណ្ណាការ ជាឧទាហរណ៍ ។

## អាសវៈលះបានដោយសំវរៈ

[ ១៣ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងអាសវៈ ដែលគប្បីលះបានដោយទស្សនៈយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងអាសវៈដែលព្រះយោគាវចរ គប្បីលះដោយសំវរៈ ដែលទ្រង់សម្តែងលម្អិតទុកក្នុងលំដាប់តទៅ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយដូចម្តេច ដែលបុគ្គលត្រូវលះបង់ដោយការសង្រួម ដូច្នេះ ។ ក្នុងបទទាំងពួង គប្បីជ្រាបការសម្ពន្ធគ្នាយ៉ាងនេះ ។ ខាងមុខអំពីនេះ ខ្ញុំនឹងពណ៌នាត្រឹមតែអត្ថប៉ុណ្ណោះ ។

សួរថា ឈ្មោះថា អាសវៈដែលព្រះយោគាវចរគប្បីលះមិនបានដោយកិច្ច ២ យ៉ាង គឺដោយទស្សនៈ និងដោយភាវនាមិនមាន មិនមែនឬ កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់សម្តែងអាសវៈ ដែលព្រះយោគាវចរគប្បីលះដោយកិច្ច មានសំវរៈជាដើម មួយផ្នែកទៅវិញ ។

ឆ្លើយថា ព្រោះអាសវៈទាំងឡាយ ដែលព្រះយោគាវចរសង្កត់ទុកបានដោយចំណែកខាងដើម ដោយកិច្ច មានការសង្រួមជាដើម រមែងដល់នូវការកើតកន្ទ្រាក់ដោយមគ្គ ៤ ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការលះអាសវៈទាំងនេះក្នុងចំណែកខាងដើមនៃមគ្គទាំងនោះ ដោយការសង្កត់សង្កិន

ទុក ដោយអាការ ៥ យ៉ាង ទើបត្រាស់យ៉ាងនេះ ។ ដូច្នោះ សោតាបត្តិមគ្គដំបូង ដែលព្រះអង្គត្រាស់ទុកហើយនេះ និងមគ្គ ៣ ដែលព្រះអង្គត្រាស់ដោយឈ្មោះថា ភាវនា ក្នុងបទនេះ ។ កថាពោលដោយអាសវៈដែលគប្បីលះបង់ដោយសំវរៈជាដើមនេះ បណ្ឌិតគប្បីជ្រាបថា ជាបុព្វភាគបដិបទានៃសោតាបត្តិមគ្គ និងនៃមគ្គទាំង ៣ នោះ ។

បណ្តាបទទាំងនោះ បទថា **ឥធ** គឺក្នុងសាសនានេះ ។ បទថា **បដិសង្ខា** ប្រែថា ពិចារណាហើយ ។ **សង្ខា** សព្ទ ក្នុងបទថា **បដិសង្ខា** នោះ រមែងប្រើក្នុងញាណ កោដ្ឋាស បញ្ញត្តិ និងការរាប់ ។ អធិប្បាយថា **សង្ខា** សព្ទប្រើក្នុងញាណ ដូចក្នុងប្រយោគជាដើមថា **សង្ខាយេកំ បដិសេវតិ** ទ្រង់ជ្រាបហើយ ទើបសេពរបស់ខ្លះ ។ ប្រើក្នុងកោដ្ឋាស ដូចក្នុងប្រយោគជាដើមថា **បបញ្ចសញ្ញាសង្ខា សមុទាចរន្តិ** ម្នាលភិក្ខុ ចំណែកនៃបបញ្ចសញ្ញារមែងប្រព្រឹត្តទៅតាមបុរស ព្រោះមានសភាវៈណាជាហេតុ ។ ប្រើក្នុងបញ្ញត្តិដូចក្នុងប្រយោគជាដើមថា **តេសំ តេសំ ធម្មានំ សង្ខា សមញ្ញា** បញ្ញត្តិជាឈ្មោះនៃធម៌ទាំងឡាយនោះ ។ ប្រើក្នុងការរាប់ ដូចក្នុងប្រយោគជាដើមថា **ន សុករំ សង្ខាតុំ** ការរាប់មិនមែនធ្វើបានដោយងាយឡើយ ។ ឯក្នុងទីនេះគប្បីឃើញអត្ថថា ប្រើក្នុង ញាណ ។

សេចក្តីពិត បទថា **បដិសង្ខា យោនិសោ** សេចក្តីថា ពិចារណា គឺដឹងបានដល់ ឃើញចំពោះដោយឧបាយ គឺដោយត្រូវផ្លូវ ។ ក្នុងទីនេះ ការពិចារណាទោសក្នុងអសំវរៈ គប្បីជ្រាបថា ការពិចារណាដោយឧបាយ ។ ការ

ពិចារណាទោសក្នុងអសំវរៈនេះ គប្បីជ្រាបដោយន័យនៃអាទិត្តបរិយាយសូត្រ ជាដើមថា ម្នាលភិក្ខុទាំងឡាយ ចក្ខុន្ទ្រិយដែលបុគ្គលអាលដោយបន្ទះដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះរុងរោចន៍សន្ធោសន្ធៅប្រសើរជាង ការកាន់យកនិមិត្ត ដោយអនុព្យញ្ជនៈ ក្នុងរូបដែលបុគ្គលគប្បីដឹងដោយចក្ខុ មិនប្រសើរទេ ។

ក្នុងបទថា **ចក្ខុន្ទ្រិយសំវរសំវុតោ វិហរតិ** នេះ អធិប្បាយថា ឥន្ទ្រិយ គឺចក្ខុ ឈ្មោះថា **ចក្ខុន្ទ្រិយ** ដែលឈ្មោះថា **សំវរ** ព្រោះរាំង អធិប្បាយថា ព្រោះបិទ គឺរាំងទុកបាន ។ ពាក្យថា **សំវរ** នេះ ជាឈ្មោះ របស់សតិ ។ ការសង្រួមក្នុងឥន្ទ្រិយ គឺចក្ខុ ឈ្មោះថា ការសង្រួមចក្ខុន្ទ្រិយ ដូចក្នុងប្រយោគជាដើមថា ក្អែកត្រង់កំពង់ទឹក អណ្តើកក្នុងអណ្តូងទឹក ក្របី នៅក្នុងព្រៃ ។

ក្នុងបទថា **ចក្ខុន្ទ្រិយសំវរសំវុតោ វិហរតិ** នោះ ការសង្រួម ឬការមិន សង្រួមក្នុងចក្ខុន្ទ្រិយ រមែងមិនមានក៏ពិត សូម្បីយ៉ាងនោះ សតិ ឬការវង្វេង ភ្លេច រមែងមិនកើតឡើងព្រោះអាស្រ័យចក្ខុបសាទ ។ ម្យ៉ាងទៀត ក្នុងកាល ណា រូបារម្មណ៍មកកាន់គន្លងចក្ខុ ក្នុងកាលនោះ កាលភវង្គចិត្តកើតឡើង ២ ខណៈហើយរលត់ទៅ កិរិយាមនោធាតុកើតឡើង ឲ្យអាវជ្ជនកិច្ចសម្រេច ហើយរលត់ទៅ បន្ទាប់អំពីនោះ ចក្ខុវិញ្ញាណកើតឡើង ឲ្យទស្សនកិច្ចសម្រេច ហើយរលត់ទៅ បន្ទាប់អំពីនោះ វិបាកមនោធាតុកើតឡើងឲ្យសម្បដិច្ឆន្នកិច្ច សម្រេចហើយរលត់ទៅ បន្ទាប់អំពីនោះ កិរិយាមនោវិញ្ញាណធាតុកើតឡើង ឲ្យសន្តីរណកិច្ចសម្រេចហើយរលត់ទៅ បន្ទាប់អំពីនោះ អហេតុកកិរិយាមនោ-

វិញ្ញាណធាតុកើតឡើង ឲ្យវោដ្ឋព្វនកិច្ចសម្រេចហើយរលត់ទៅ ។ ក្នុងលំដាប់នោះ ជវនចិត្តរមែងស្ទុះទៅ ។ ម្យ៉ាងទៀត ក្នុងបទថា **ចក្ខុន្ទ្រិយសំវរសំវុតោ វិហរតិ** នោះ ការសង្រួម ឬការមិនសង្រួម រមែងមិនមានក្នុងសម័យនៃភវង្គចិត្ត ទាំងក្នុងសម័យនៃអាវជ្ជនចិត្តជាដើម សម័យណាមួយ ការសង្រួម ឬការមិនសង្រួមរមែងមិនមានដូចគ្នា ។ តែក្នុងខណៈនៃជវនចិត្ត បើទោស គឺគ្រឿងទ្រុស្តសីល ភាពជាអ្នកមិនមានស្មារតី ការមិនដឹង ការមិនអត់ធន់ ឬការខ្ជិលច្រអូសកើតឡើងសោត នេះជាការមិនសង្រួម ។ ការមិនសង្រួមនោះសូម្បីយ៉ាងនេះ លោកក៏ហៅថា ការមិនសង្រួមក្នុងចក្ខុន្ទ្រិយ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះកាលមានការមិនសង្រួមក្នុងចក្ខុន្ទ្រិយនោះ ។ ទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្ត មានអាវជ្ជនចិត្តក្តី ឈ្មោះថា ព្រះយោគាវចរមិនគ្រប់គ្រងហើយ ។

ប្រៀបដូចអ្វី ប្រៀបដូចទ្វារទាំង ៤ ក្នុងព្រះនគរ ដែលបុគ្គលមិនគ្រប់គ្រងហើយខាងក្នុងផ្ទះ ខ្លោងទ្វារ និងបន្ទប់ជាដើម ដែលបុគ្គលគ្រប់គ្រងល្អហើយក៏ពិត សូម្បីយ៉ាងនោះ ទ្រព្យគ្រប់យ៉ាងក្នុងព្រះនគរ ឈ្មោះថា មិនបានរក្សា មិនបានគ្រប់គ្រងឡើយ ព្រោះចោរទាំងឡាយ ចូលទៅតាមទ្វារព្រះនគរ លួចវត្ថុដែលខ្លួនប្រាថ្នាបាន យ៉ាងណា កាលទោស គឺគ្រឿងទ្រុស្តសីលកើតឡើងក្នុងជវនចិត្ត កាលមានការមិនសង្រួមក្នុងជវនចិត្តនោះ ទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្ត មានអាវជ្ជនចិត្តជាដើមក្តី ក៏ឈ្មោះថា ភិក្ខុមិនគ្រប់គ្រងដូច្នោះនោះឯង ។

តែកាលសីលជាដើមកើតឡើងក្នុងជវនចិត្តនោះ ទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្ត មានអាវជ្ជនចិត្តជាដើមក្តី ឈ្មោះថា ភិក្ខុគ្រប់គ្រងល្អហើយ ប្រៀបដូចអ្វី ប្រៀបដូចទ្វារព្រះនគរ ដែលបុគ្គលគ្រប់គ្រងល្អហើយ ខាងក្នុងផ្ទះជាដើម ដែលបុគ្គលរក្សាមិនល្អក៏ពិត តែទ្រព្យគ្រប់យ៉ាងក្នុងនគរ ឈ្មោះថា បុគ្គលរក្សាល្អហើយ ព្រោះកាលបិទទ្វារនគរហើយ ចោរទាំងឡាយ ក៏ចូលទៅមិនបាន យ៉ាងណា កាលសីលជាដើមកើតឡើងក្នុងជវនចិត្ត ទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្ត មានអាវជ្ជនចិត្តជាដើមក្តី ឈ្មោះថា ភិក្ខុរក្សាល្អហើយដូច្នោះដូចគ្នា ។ ព្រោះដូច្នោះ សំវរៈដែលកើតឡើងក្នុងខណៈនៃជវនចិត្ត លោកហៅថា ការសង្រួមក្នុងចក្ខុន្ទ្រិយ ។ ក្នុងទីនេះ សតិសំវរៈនេះ គប្បីជ្រាបថា ព្រះអង្គទ្រង់បំណាងយកហើយ ។ បុគ្គលសង្រួមហើយដោយការសង្រួមចក្ខុន្ទ្រិយ ឈ្មោះថា **ចក្ខុន្ទ្រិយសំវរសំវុតោ** បុគ្គលចូលដល់ហើយដោយការសង្រួមចក្ខុន្ទ្រិយ ។ ពិតហើយ ពាក្យណាដែលលោកពោលទុកក្នុងវិភង្គនៃបទថា **ចាតិមោក្ខ-សំវរសំវុតោ** នេះថា ភិក្ខុដែលចូលដល់ ។បេ។ ប្រកបដោយការសង្រួមបាតិមោក្ខនេះ ពាក្យនោះបណ្ឌិតគប្បីសង្គ្រោះយកពាក្យតែមួយដូចគ្នា ហើយជ្រាបដោយអត្ថយ៉ាងនេះថា ភិក្ខុដែលសង្រួមដោយចក្ខុន្ទ្រិយ ។ម្យ៉ាងទៀត ដែលឈ្មោះថាបុគ្គលសង្រួមហើយ ព្រោះអត្ថថា សង្រួមប្រយ័ត្ន អធិប្បាយថា រារាំង គឺបិទ ។ ភិក្ខុដែលសង្រួមប្រយ័ត្នក្នុងចក្ខុន្ទ្រិយ គឺបុគ្គលមានចក្ខុន្ទ្រិយ រាំងរក្សាហើយ អធិប្បាយថា ការពារ បិទសន្ទះទ្វារ គឺសតិដែលសន្មតថា ការសង្រួមតាមចក្ខុន្ទ្រិយក្នុងចក្ខុទ្វារ ដូចបុគ្គលបិទសន្ទះទ្វារ

ត្រង់ទ្វារផ្ទះ ដូច្នោះ ។ ក្នុងសេចក្តីនេះ អត្ថនេះប៉ុណ្ណោះល្អជាង ។ ពិតហើយ អត្ថនេះឯង រមែងប្រាកដក្នុង ២ បទនេះថា បុគ្គលមិនសង្រួមប្រយ័ត្នក្នុងចក្ខុន្ទ្រិយ និងបុគ្គលសង្រួមប្រយ័ត្នក្នុងចក្ខុន្ទ្រិយ ដូច្នេះ ។

បទថា **វិហរតិ** សេចក្តីថា បុគ្គលសង្រួមតាមចក្ខុន្ទ្រិយយ៉ាងនេះ ដោយការនៅដោយឥរិយាបថណាមួយ ។

ក្នុងបទថា **យញ្ហិស្ស** ជាដើម គប្បីជ្រាបអត្ថយ៉ាងនេះថា កាលភិក្ខុនោះមិនសង្រួមប្រយ័ត្នក្នុងចក្ខុន្ទ្រិយណា គឺមិនរាំង មិនបិទ ការរាំងប្រយ័ត្នតាមចក្ខុន្ទ្រិយ ម្យ៉ាងទៀត អាទេស **យេ** អក្ខរៈ ជា **យំ** ក៏បាន ឯ **ហិ** អក្ខរៈ ជាបទបូរណៈ សេចក្តីថា **យេ អស្ស** ។

បទថា **ឧប្បជ្ជេយ្យុំ** ប្រែថា គប្បីកើតឡើង ។

បទថា **អាសវា វិឃាតបរិឡាហា** បានដល់ អាសវៈ ៤ និងការក្តៅក្រហាយព្រោះកិលេស ឬការក្តៅក្រហាយព្រោះវិបាក ដែលធ្វើការចង្អៀតចង្អល់ដទៃ ។ សេចក្តីពិត កាមាសវៈរមែងកើតឡើងដល់ភិក្ខុដែលពេញចិត្តត្រេកអរនូវឥដ្ឋារម្មណ៍ដែលមកប្រាកដក្នុងចក្ខុទ្វារ ដោយអំណាចការពេញចិត្តក្នុងកាម ភវាសវៈរមែងកើតឡើងដល់ភិក្ខុដែលត្រេកអរ ដោយការប្រាថ្នាក្នុងភពថា អញនឹងបានសម្បត្តិដូច្នេះ ក្នុងសុគតិភពដទៃ ទិដ្ឋាសវៈរមែងកើតឡើងដល់ភិក្ខុដែលប្រកាន់ថា ជាសត្វ ឬរបស់សត្វ ការមិនដឹងដែលកើតព្រមជាមួយអាសវៈទាំងអស់នោះឯង ឈ្មោះថា អវិជ្ជាសវៈ អាសវៈ ៤ រមែងកើតឡើងដូចពោលមកនេះ ។ កិលេសទាំងឡាយដទៃ ដែលសម្បយុត្តដោយ

អាសវៈទាំងនោះ ការក្តៅក្រហាយ ដែលធ្វើការចង្អៀតចង្អល់ ឬវិបាកក្នុងភព តទៅរបស់កិលេសទាំងនោះពួកណា ពិតហើយ កិលេសជាដើមនោះៗ លោក ពោលថា គប្បីកើតឡើងដល់ភិក្ខុដែលមិនសង្រួមដូចគ្នា ។

បទថា **ឯវំស តេ** សេចក្តីថា ដោយឧបាយនេះ អាសវៈទាំងនោះឯង មិនមានដល់ភិក្ខុនោះ ដែលសង្រួមយ៉ាងនេះឡើយ អធិប្បាយថា មិនមែន មានដោយប្រការដទៃ ។

ក្នុងបទជាដើមថា **បដិសង្ខា យោនិសោ សោតិន្ទ្រិយ សំវរសំវុតោ** ក៏ មានន័យនេះ ។ បទថា **ឥមេ វុច្ចន្តិ អាសវា សំវរា បហាតព្វា** សេចក្តី ថា អាសវៈទាំងនោះ ព្រោះចែកក្នុងទ្វារទាំង ៦ មួយទ្វារ ៤ ទើបរួមជា អាសវៈ ២៤ តថាគតពោលថា ព្រះយោគាវចរគួរលះបង់ដោយសំវរៈ ។ ក្នុងទីនេះ សតិសំវរៈនោះឯង គប្បីជ្រាបថា សំវរៈក្នុងគ្រប់ៗ បទនោះឯង ។

## អាសវៈលះបានដោយការពិចារណា

[ ១៤ ] ពាក្យដែលគប្បីពោលក្នុងបទថា **បដិសង្ខា យោនិសោ ចីវរំ** ជាដើម ទាំងអស់ លោកពោលទុកហើយក្នុងសីលកថា ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គនោះឯង ។

បទថា **យញ្ហិស្ស** សេចក្តីថា អាសវៈ និងការក្តៅក្រហាយដែលធ្វើការ ចង្អៀតចង្អល់ចិត្ត គប្បីកើតឡើងដល់ភិក្ខុ ដែលមិនពិចារណា ហើយសេព បច្ច័យ ឬបណ្តាចីវរ បិណ្ឌបាតជាដើមណាមួយ ។

បទថា **អបដិសេវតោ** សេចក្តីថា បុគ្គលមិនពិចារណាដោយឧបាយ

ហើយសេពយ៉ាងនេះ ៗ ពាក្យដ៏សេសមានន័យ ដូចពោលហើយនោះឯង ៗ ក្នុងទីនេះ គប្បីជ្រាបការកើតឡើងនៃកាមាសវៈនៃភិក្ខុដែលប្រាថ្នាចីវរជាដើម ដែលខ្លួនមិនបាន ឬដែលត្រេកអរក្នុងចីវរជាដើម ដែលខ្លួនបានហើយតែម្យ៉ាង គប្បីជ្រាបការកើតឡើងនៃភវាសវៈរបស់ភិក្ខុ ដែលត្រេកអរដោយការប្រាថ្នាក្នុងភពថា អញនឹងបានសម្បត្តិដូច្នេះ ក្នុងសម្បត្តិភព គឺសុគតិភពខាងមុខ គប្បីជ្រាបការកើតឡើងនៃទិដ្ឋាសវៈរបស់ភិក្ខុ ដែលតាំងការសម្គាល់ក្នុងខ្លួនថា អញនឹងបានដូច្នេះ ឬវត្ថុនេះនឹងជារបស់អញដូច្នេះ ៗ អវិជ្ជាសវៈកើតព្រមជាមួយអាសវៈទាំងពួង គប្បីជ្រាបការកើតឡើងនៃអាសវៈទាំង ៤ យ៉ាង ដូចពោលមកនេះឯង ៗ ឯការក្ដៅក្រហាយព្រោះវិបាក គប្បីជ្រាបដោយការកើតឡើងនៃវេទនាថ្មី ៗ បទថា **ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា បដិសេវនា បហាតព្វា** សេចក្ដីថា អាសវៈទាំងនេះ មាន ១៦ យ៉ាង ព្រោះចែកអាសវៈក្នុងបច្ច័យនីមួយៗ មានចីវរប្បច្ច័យជាដើម បច្ច័យមួយមាន ៤ អាសវៈ ៗ អាសវៈទាំងនេះយើងពោលថា ព្រះយោគាវចរគប្បីលះបានដោយការពិចារណា ហើយសេព ពោល គឺការសង្រួមដោយញាណនេះ ដូច្នេះឯង ៗ

## អាសវៈលះបានដោយការអត់ធន់

[ ១៥ ] បទថា **បដិសង្ខា យោនិសោ ខមោ ហោតិ សីតស្ស** សេចក្ដីថា ភិក្ខុពិចារណាដោយឧបាយត្រូវផ្លូវហើយ រមែងជាបុគ្គលអត់ធន់ចំពោះរងា គឺរមែងអត់ធន់នូវការរងា មិនញាប់ញ័រព្រោះការរងា សូម្បីតិច

តួប ដូចបុរសមិនមានសេចក្តីក្លាហាននោះឡើយ លោកមិនព្រមលះបង់ចោលកម្មដ្ឋាន ។ ម្យ៉ាងទៀត លោកត្រូវងាប៉ះពាល់ ក៏មិនញាប់ញ័រ រមែងដាក់ចិត្តចំពោះកម្មដ្ឋាន ដូចព្រះលោមសនាគត្ថេរដូច្នោះ ។ បានឮថា ព្រះថេរៈនៅក្នុងកុដិ បំពេញសេចក្តីព្យាយាម ក្នុងគុហាបិយង្គុ នាចេតិយបព៌ត ពិចារណាលោកន្តរិយនរក ដែលតាំងនៅក្នុងចន្លោះចក្រវាល ក្នុងសម័យសន្សើមធ្លាក់ មិនលះបង់កម្មដ្ឋានឡើយ ឲ្យវេលាកន្លងទៅក្នុងទីវាល ។ សូម្បីក្នុងរដូវក្តៅជាដើម ក៏គប្បីជ្រាបការអធិប្បាយពង្រីកសេចក្តីយ៉ាងនេះ ការពិត ភិក្ខុណា រមែងអត់ធន់នូវការក្តៅ ដែលមានប្រមាណក្រៃលែងបាន ភិក្ខុនោះ បណ្ឌិតគប្បីជ្រាបថា ជាអ្នកអត់ធន់ចំពោះការក្តៅបាន ដូចព្រះថេរៈនោះឯង ។ បានឮថា ក្នុងវេលាក្រោយភត្ត ក្នុងគិម្ហន្តរដូវ ព្រះថេរៈអង្គុយនៅខាងក្រៅទីចង្ក្រម កាលលោកដាក់ចិត្តដល់កម្មដ្ឋាន ញើសក៏ហូរចេញអំពីក្លៀក ។ ពេលនោះ ទើបអន្តេវាសិកនិមន្តលោកថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់គង់ក្នុងទីនេះចុះ ឱកាសនេះត្រជាក់សប្បាយ ។ ព្រះថេរៈពោលថា ខ្ញុំមិនអង្គុយក្នុងទីនោះទេ ព្រោះខ្លាចក្តៅ ដូច្នេះហើយ អង្គុយពិចា-រណាអវិចីមហានរក ។ ក្នុងទីនេះការក្តៅព្រោះភ្លើង គប្បីជ្រាបថា ឈ្មោះថា **ឧណ្ហំ** ក្នុងរឿងនោះ លោកពោលទុកដោយអំណាចការក្តៅដែលកើតអំពីព្រះអាទិត្យ ។ ភិក្ខុណាកាលមិនបានភត្ត ឬទឹកផឹកត្រឹម ២-៣ ពេល ហើយពិចារណាការកើតឡើងក្នុងបេតវិស័យរបស់ខ្លួនក្នុងសង្សារវដ្ដ ដែលមិនមានទីបំផុតខាងដើម ហើយមិនញាប់ញ័រ មិនលះបង់កម្មដ្ឋាន ទោះត្រូវសម្ពស្ស

នៃរបោមមូស និងកម្តៅថ្ងៃ សូម្បីមានប្រមាណក្រៃលែងពាល់ត្រូវ ក៏ពិចា-
រណាការចូលដល់កំណើតសត្វតិរច្ឆាន មិនញាប់ញ័រ មិនលះបង់កម្មដ្ឋាន
ឡើយ និងសូម្បីត្រូវសម្ផស្សនៃសត្វលូនវារពាល់ត្រូវ ក៏ពិចារណាអត្តភាព
ក្នុងកាលមុន ដែលបម្រះនទៀល ច្រើនវារៈត្រង់មាត់របស់រាជសីហ៍ និងខ្លា
ធំជាដើមក្នុងសង្សារវដ្ត ដែលមិនមានខាងដើមហើយ មិនញាប់ញ័រ មិន
លះបង់កម្មដ្ឋាន ដូចព្រះបធានិយត្ថេរ ភិក្ខុនោះគប្បីជ្រាបថា ជាអ្នកអត់ធន់
ចំពោះការឃ្លាន ។បេ។ សម្ផស្សនៃសត្វលូនវារជាដើម ។ បានឮថា ពស់
ពិសមួយក្បាល បានចឹកព្រះថេរៈដែលកំពុងស្តាប់អរិយវង្សសូត្រ ក្នុងកុដិ
ដែលធ្វើសេចក្តីព្យាយាម ឈ្មោះកណិការក្នុងមហាវិហារ ឈ្មោះខណ្ឌវេល ។
ព្រះថេរៈសូម្បីដឹងហើយ មានចិត្តជ្រះថ្លា អង្គុយស្តាប់ធម៌តាមប្រក្រតី ។
កម្លាំងពិសបានឡើងខ្លាំងឡើងតាមលំដាប់ ។ ព្រះថេរៈបានពិចារណាដល់
សីល តាំងអំពីមណ្ឌលឧបសម្បទា ហើយកើតបីតិឡើងថា អាត្មាអញមាន
សីលបរិសុទ្ធហ្ន៎ ។ ព្រមគ្នានឹងការកើតនៃបីតិ ពិសបានវិលត្រឡប់ចូលទៅ
កាន់ផែនដី ព្រះថេរៈបានឯកគ្គតាចិត្តក្នុងទីនោះឯង ចម្រើនវិបស្សនា ហើយ
សម្រេចអរហត្ត ។ ភិក្ខុណាបានស្តាប់ពាក្យគ្រោតគ្រាត និងពាក្យពោល
ដែលសហគតៈដោយអនិដ្ឋមវត្ថុ ដែលមកអំពីទីឆ្ងាយ ព្រោះជាពាក្យដែល
គ្រោតគ្រាត ហើយពិចារណានូវគុណរបស់ខន្តិ មិនញាប់ញ័រដោយអំណាច
ការជេរ ដូចព្រះទីឃភាណកអភយត្ថេរ ភិក្ខុនេះ បណ្ឌិតគប្បីជ្រាបថា ជាអ្នក
អត់ធន់ចំពោះពាក្យគ្រោតគ្រាត ដែលមកអំពីឆ្ងាយបាន ។ បានឮថា ព្រះ

ថេរៈពោលមហាអរិយវង្សប្បដិបទា ដើម្បីភាពជាអ្នកត្រេកអរក្នុងការសន្តោស ដោយបច្ច័យ ។ ពួកអ្នកស្រុកទាំងឡាយនាំគ្នាមក ។ ទើបសក្ការៈធំកើតមាន ដល់ព្រះថេរៈ ។ ព្រះមហាថេរៈរូបខ្លះ អត់ធន់នឹងសក្ការៈនោះមិនបាន ទើប ជេរដោយន័យជាដើមថា ទីឃភាណកៈញុំាងការរីកវរឡើងអស់រាត្រី ដោយ ពោលថា អញនឹងពោលអរិយវង្ស ព្រះថេរៈទាំង ២ រូប ពេលដើរផ្លូវ ត្រឡប់ទៅកាន់វិហាររៀងៗ ខ្លួន ហើយបានដើររួមផ្លូវតែមួយអស់ផ្លូវប្រមាណ មួយគាវុត ព្រះថេរៈនោះបានជេរព្រះទីឃភាណកត្ថេរគ្រប់ៗ គាវុត ហើយ ព្រះទីឃភាណកត្ថេរឈរនៅក្នុងទីផ្លូវរបស់វិហារទាំង ២ ដែលបែកគ្នា ថ្វាយ បង្គំព្រះថេរៈនោះ ហើយពោលថា លោកម្ចាស់ដ៏ចម្រើន នេះជាផ្លូវរបស់ លោកម្ចាស់ ។ ព្រះថេរៈនោះដើរចេញទៅ ធ្វើហាក់ដូចមិនបានឮ ឯព្រះទីឃ-ភាណកត្ថេរទៅដល់វិហារ លាងជើងហើយអង្គុយចុះ ទើបអន្តេវាសិកបាន ពោលនឹងលោកថា លោកម្ចាស់ដ៏ចម្រើន មានរឿងអ្វី ហេតុអ្វី ទើបលោក ម្ចាស់មិនពោលពាក្យណាមួយនឹងព្រះថេរៈនោះ ដែលជេរបរិភាសលោកម្ចាស់ គ្រប់ៗ គាវុត ព្រះថេរៈឆ្លើយថា អាវុសោ ការអត់ធន់ជាកិច្ចរបស់ខ្ញុំ ការមិន អត់ធន់មិនជាកិច្ចរបស់ខ្ញុំឡើយ ខ្ញុំមិនធ្លាប់ឃើញការឃ្លាតចាកកម្មដ្ឋានរបស់ខ្ញុំ សូម្បីព្រោះការលើកជើងម្ខាង ក្នុងទីនេះគួរជ្រាបថា ពាក្យនោះឯង ឈ្មោះថា ត្រឹមត្រូវតាមទំនងគន្ថធម៌ ។

សេចក្តីទុក្ខតាមកាយ ឈ្មោះថា ជាទុក្ខ ព្រោះអត្ថថា ជាហេតុឲ្យដល់ ទុក្ខ ឈ្មោះថា ក្រាស់ ព្រោះអត្ថថា ក្រាស់ឃ្មឹក ឈ្មោះថា រឹង ព្រោះអត្ថថា

គ្រោតគ្រាត ឈ្មោះថា ក្លា ព្រោះអត្ថថា មុត ឈ្មោះថា មិនត្រេកអរ ព្រោះវៀរចាកការត្រេកអរ ឈ្មោះថា មិនគួរពេញចិត្ត ព្រោះអត្ថថា មិនជាទីចម្រើនចិត្ត ឈ្មោះថា ជាគ្រឿងធក់ទាញជីវិតបាន ភិក្ខុណាអត់ធន់វេទនានោះបាន គឺមិនញាប់ញ័រ បានដល់ តាំងនៅតាមប្រក្រតី ដូចព្រះបធានិយត្ថេរ ដែលនៅត្រង់ចិត្តលតាបព៌ត ភិក្ខុនេះ គប្បីជ្រាបថា ជាអ្នកមានប្រក្រតីអត់ធន់ចំពោះវត្ថុផ្សេងៗ ដែលកើតឡើង ។បេ។

បានឮថា កាលព្រះថេរៈឈរបំពេញព្យាយាមអស់រាត្រី ខ្យល់ក្នុងពោះក៏កើតឡើង ។ លោកមិនអាចអត់ធន់ក្នុងខ្យល់នោះបាន ទើបប្រែទៅ ប្រែមក ។ ព្រះថេរៈដែលសមាទានបិណ្ឌបាតជាវត្តមួយរូប ឈរនៅក្បែរទីចង្ក្រមទើបពោលនឹងលោកថា អាវុសោ ធម្មតាបព្វជិត ជាអ្នកមានប្រក្រតីអត់ធន់ដូច្នេះ ។ ព្រះថេរៈនោះទទួលថា សាធុ លោកម្ចាស់ដ៏ចម្រើន ដូច្នេះហើយបានដេកស្ងៀម មិនកម្រើក ។ ខ្យល់បានចាក់ដោតពោះដូងទៅរហូតដល់ផ្ចិត ។ ព្រះថេរៈសង្កត់វេទនា ចម្រើនវិបស្សនា ត្រឹមមួយស្របក់ ក៏បានជាព្រះ-អនាគាមី ហើយក៏អស់ជីវិតដូច្នេះឯង ។

បទថា **យញ្ហស្ស** សេចក្តីថា អាសវៈទាំងឡាយរមែងកើតដល់ភិក្ខុនោះដែលអត់ធន់ចំពោះរោគជាដើមណាមួយមិនបាន ។ បទថា **អនធិវាសយតោ** សេចក្តីថា បុគ្គលអត់ធន់ទុក្ខមិនបាន គឺអត់ធន់មិនបាន ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។ ក្នុងរឿងនេះគប្បីជ្រាបការកើតឡើងនៃអាសវៈយ៉ាងនេះ ។ កាមាសវៈរមែងកើតឡើងដល់ភិក្ខុដែលត្រូវរោគពាល់ត្រូវហើយ

ប្រាថ្នាភាពកក់ក្ដៅ ។ ក្នុងបទទាំងពួងក៏ន័យនេះ ។ អធិប្បាយថា ភវាសវៈ រមែងមានដល់ភិក្ខុដែលប្រាថ្នាភពថា ការរេងា ឬការកក់ក្ដៅរបស់អញក្នុងសម្បត្តិភព មិនមានដូច្នេះ ការប្រកាន់ថា ការរេងា ការកក់ក្ដៅ រមែងមានដល់អញដូច្នេះ ឈ្មោះថា **ទិដ្ឋាសវ** អាសវៈដែលសម្បយុត្តដោយអាសវៈទាំងពួង ឈ្មោះថា **អវិជ្ជាសវ** ។ បទថា **ឥមេ វុច្ចន្តិ ។បេ។ អធិវាសនា បហាតព្វា** សេចក្ដីថា អាសវៈទាំងនេះមានច្រើន ព្រោះចែក ១ ជា ៤ ដោយអំណាចនៃធម៌ មានរេងាជាដើមតែម្យ៉ាង ព្រះមានព្រះភាគត្រាស់ថា គួរលះចេញដោយការអត់ធន់ ពោល គឺខន្តិសំវរៈ ។ ក្នុងទីនេះ ព្រោះខន្តិនេះរមែងអត់ធន់ក្នុងធម៌ មានរេងាជាដើមបាន គឺលើកឲ្យនៅខាងលើខួនទោះឯងបានដល់ មិនមែនអត់ធន់មិនបាន ហើយលះបង់ចោល ដូច្នោះ ខន្តិនេះគប្បីជ្រាបថា **អធិវាសនា** ។

## អាសវៈលះបានដោយការវៀរ

[ ១៦ ] បទថា **បដិសង្ខា យោនិសោ ចណ្ឌំ ហត្ថឹ បរិវជ្ជេតិ** សេចក្ដីថា ភិក្ខុមិនគប្បីឈរនៅក្នុងទីជិតដំរីកាច ដោយគិតថា អញជាសមណៈដូច្នេះ ព្រោះថា ការស្លាប់ក្ដី សេចក្ដីទុក្ខទៀបនឹងស្លាប់ ដែលមានដំរីនោះជាហេតុ គប្បីមាន ។ ភិក្ខុពិចារណាដោយឧបាយ គឺដោយត្រូវទំនងយ៉ាងនេះហើយ រមែងវៀរ គឺថយចេញអំពីដំរីកាច ក្នុងបទទាំងពួងក៏ន័យនេះ ។

បទថា **ចណ្ឌំ** គឺសត្វដែលកាច អធិប្បាយថា កាចសាហាវ ។

បទថា **ខាណុំ** បានដល់ ដង្គត់ដើមគគីរជាដើម ។

បទថា **កណ្ដកដ្ឋានំ** សេចក្ដីថា ទីកន្លែងមានបន្លា អធិប្បាយថា ឱកាសដែលមានបន្លាជាច្រើន ។

បទថា **សោត្ថំ** បានដល់ ទីកន្លែងដែលមានប្រាំងចោទ ( អណ្ដូង ) ។

បទថា **បបាតំ** បានដល់ ទីកន្លែងមានប្រាំងតែម្ខាង ( ជ្រោះ ) ។

បទថា **ចន្ទនិកំ** បានដល់ ទីកន្លែងដែលចោលរបស់ស្មោកគ្រោក មានទឹកសំណល់ជាដើម ( រណ្ដៅជ្រាំ ) ។

បទថា **ឱឡិគល្លំ** បានដល់ ឱកាសដែលជាទីប្រជុំនៃភក់ជាដើមទាំងនោះ ស្ថានទីនោះ ជាទីស្ថានទីដែលក្រាលដោយរបស់មិនស្អាត មានប្រមាណដល់ក្បាលជង្គង់ ។ ស្ថានទីទាំង ២ កន្លែងនោះ ជាទីកន្លែងអាក្រក់ ដូចមានអមនុស្ស ដូច្នោះ គួរវៀរទីកន្លែងនោះចេញ ។ អាសនៈដែលមិនសមគួរ ឈ្មោះថា **អនាសន** ។

ក្នុងបទថា **អនាសនេ** នេះ ដោយអត្ថ អាសនៈនោះ គប្បីជ្រាបថា បានដល់ អាសនៈដែលលាក់នៅក្នុងទីកំបាំង មានទព្វសម្ភារៈដែលមិនពិតប្រាកដ ។ ទីត្រាច់ទៅដែលមិនសមគួរ ឈ្មោះថា **អគោចរ** ក្នុងបទថា **អគោចរេ** នេះ ។ ទីអគោចរនោះមាន ៥ យ៉ាង ដោយបែកប្រភេទជាផ្ទះស្រីពេស្យាជាដើម ។

បទថា **បាបកេ មិត្តេ** បានដល់ មិត្តបដិរូប ឬមិត្តអាក្រក់ គឺអ្នកទ្រុស្តសីល ។ បទថា **ភជន្តំ** ប្រែថា សេព ។

បទថា **វិញ្ញូ សព្រហ្មចារី** សេចក្ដីថា សព្រហ្មចារីទាំងឡាយដែលជា

បណ្ឌិត គឺសម្បូរដោយការដឹង ។ ពាក្យនេះជាឈ្មោះរបស់ភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុទាំងនោះរមែងប្រព្រឹត្តធម៌ ដែលស្មើដោយព្រហ្មនេះ ដោយគិតថា យើងជាអ្នកមានកម្មរួមគ្នា និងរៀនឧទ្ទេសរួមគ្នា និងមានសិក្ខាស្មើគ្នា ដូច្នេះ ទើបភិក្ខុទាំងនោះ លោកហៅថា **សព្រហ្មចារី** ។

បទថា **ឧាបកេសុ ឋានេសុ** សេចក្តីថា ក្នុងទីទាំងឡាយដ៏លាមក ។

បទថា **ឱកប្បេយ្យំ** សេចក្តីថា គប្បីជឿបាន គឺគប្បីបង្អោនចិត្តជឿថា លោកមានអាយុនេះបានធ្វើ ឬនឹងធ្វើពិត ដូច្នេះ ។

បទថា **យញ្ញិស្ស** សេចក្តីថា កាលភិក្ខុនោះមិនវៀរបណ្តាអន្តរាយ មានដំរីជាដើមណាមួយ ។ ពាក្យដ៏សេសមានន័យដូចពោលនោះឯង ។ ក្នុងទីនេះ គប្បីជ្រាបការកើតឡើងនៃអាសវៈយ៉ាងនេះ ។ កាមាសវៈ រមែងកើតឡើងដល់ភិក្ខុដែលជួបនូវសេចក្តីទុក្ខ មានដំរីជាដើមជាហេតុ ហើយប្រាថ្នាសេចក្តីសុខ ។ ភវាសវៈរមែងកើតមានដល់ភិក្ខុ ដែលប្រាថ្នាភពថា ទុក្ខដូច្នេះរបស់អញមិនមានក្នុងសម្បត្តិភព គឺក្នុងសុគតិភព ។ ការប្រកាន់ថា ដំរីនឹងជាន់អញ សេះនឹងជាន់អញ ដូច្នេះ ឈ្មោះថា **ទិដ្ឋាសវ** ។ អាសវៈដែលសម្បយុត្តដោយអកុសលធម៌គ្រប់យ៉ាង ឈ្មោះថា **អវិជ្ជាសវ** ។

បទថា **ឥមេ វុច្ចន្តិ ។បេ។ បរិវជ្ជនា បហាតព្វា** សេចក្តីថា អាសវៈមានច្រើនយ៉ាង ព្រោះចែកអាសវៈទាំងនេះចេញ ១ ជា ៤ យ៉ាង ដោយអំណាចអន្តរាយ មានដំរីជាដើម គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ថា យោគាវចរគប្បីលះបង់ដោយការវៀរ ពោល គឺសីលសំវរៈនេះ ។

# អាសវៈលះបានដោយការបន្ទោបង់

[ ១៧ ] បទថា **បដិសង្ខា យោនិសោ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ** សេចក្ដីថា ព្រះយោគាវចរពិចារណាឃើញទោស ក្នុងកាមវិតក្កដោយឧបាយ ដោយន័យជាដើមថា វិតក្កនេះជាអកុសលព្រោះហេតុនេះ វិតក្កនេះមានទោសព្រោះហេតុនេះ ហើយវិតក្កនោះឯង រមែងប្រព្រឹត្តទៅដើម្បីការបៀតបៀនខ្លួនឯង ដូច្នេះហើយ រារាំងទុកមិនបាននូវកាមវិតក្កដែលកើតឡើងបានដល់ កើតឡើងហើយក្នុងអារម្មណ៍នោះ អធិប្បាយថា លើកចិត្តឡើងហើយ ឲ្យវិតក្កឈប់មិនបាន ឬមិនឲ្យកាមវិតក្កឈប់នៅខាងក្នុងបាន ។

សួរថា ភិក្ខុកាលរារាំងមិនបាន នឹងធ្វើដូចម្ដេច ឆ្លើយថា រមែងលះ គឺលះវិតក្កនោះចេញ ។ សួរថា ភិក្ខុលះវិតក្កដូចបុគ្គលយកល្អីដាក់សំរាមចោលឬ ឆ្លើយថា មិនមែនដូច្នោះទេ ។

ម្យ៉ាងទៀត ភិក្ខុរមែងបន្ទោបង់ គឺដក បានដល់ ចាក់ទម្លុះ ដោយអត្ថថា នាំចេញទៅនូវកាមវិតក្កនោះ ។

សួរថា ចាក់ធ្លុះដូចបុគ្គលយកជន្ទួញចាក់គោឬ ឆ្លើយថា មិនមែនដូច្នោះឡើយ ដោយពិត គឺធ្វើកាមវិតក្កនោះឲ្យទន់ខ្សោយទៅ គឺធ្វើកាមវិតក្កនោះឲ្យប្រាសចាកទៅ បានដល់ ធ្វើកាមវិតក្កនោះមិនឲ្យសល់នៅខាងក្នុងរបស់ភិក្ខុនោះ ដោយហោចសូម្បីក្នុងភវង្គចិត្ត ។

សួរថា ភិក្ខុធ្វើវិតក្កឲ្យជាយ៉ាងនោះបានដូចម្ដេច ឆ្លើយថា រមែងញ៉ាំងកាមវិតក្កនោះឲ្យដល់នូវការមិនមាន គឺរមែងឲ្យដល់នូវការមិនមាន សូម្បីតិចតួច អធិប្បាយថា រមែងធ្វើដោយប្រការដែលវិតក្ក គឺលោកសង្កត់សង្កិនទុក

បានយ៉ាងល្អដោយវិក្ខម្ភនប្បហាន ។ ក្នុងព្យាបាទវិតក្ក និងវិហិង្សាវិតក្ក ក៏ន័យនេះដូចគ្នា ។ ក្នុងវិភង្គលោកពោលទុកថា ក្នុងបទថា **កាមវិតក្កោ** នេះ វិតក្កដែល បដិសំយុត្តដោយកាម គឺការត្រិះរិះខុស ឈ្មោះកាមវិតក្កក្នុងទីដទៃៗ ក៏ន័យនេះ ។

បទថា **ឧប្បន្នុប្បន្នេ** សេចក្តីថា កើតហើយ គឺឧប្បត្តិកហើយ អធិប្បាយថា គ្រាន់តែកើតឡើងហើយប៉ុណ្ណោះ ។ ម្យ៉ាងទៀត ភិក្ខុបន្ទោបង់នូវអកុសលវិតក្កទាំងឡាយដែលកើតឡើងម្តងបានហើយ ក្នុងវារៈទី ២ សូម្បីលោកមិនបានសម្លឹង លោកក៏រមែងបន្ទោបង់អកុសលវិតក្កទាំងឡាយ ដែលកើតឡើងហើយ សូម្បី ៧ ដងបាននោះឯង ។

បទថា **បាបកេ អកុសលេ** សេចក្តីថា ដែលឈ្មោះថា **បាប** ព្រោះអត្ថថា លាមក ដែលឈ្មោះថា **អកុសល** ព្រោះអត្ថថា ជាកម្មដែលធ្វើដោយការមិនឈ្លាស ។

បទថា **ធម្មេ** បានដល់ កាមវិតក្កជាដើមនោះឯង ម្យ៉ាងទៀត បានដល់មហាវិតក្ក ៩ យ៉ាងទាំងអស់ បណ្តាមហាវិតក្ក ៩ យ៉ាងនោះ ៣ យ៉ាងបានពោលហើយ ។ វិតក្កដ៏សេស ៦ ទៀត បានដល់ វិតក្កដល់ញាតិ វិតក្កដល់ជនបទ វិតក្កដល់ទេវតា វិតក្កដែលប្រកបដោយភាពជាអ្នកអាណិតអាសូរចំពោះអ្នកដទៃ វិតក្កដែលបដិសំយុត្តដោយលាភសក្ការៈ និងកិត្តិយស និងវិតក្កដែលបដិសំយុត្តដោយវត្ថុដទៃ ។

បទថា **យញ្ចាស្ស** សេចក្តីថា អាសវៈ និងការក្តៅក្រហាយ ព្រោះការ

បង្អៀតបង្អល់ចិត្ត គប្បីកើតឡើងដល់ភិក្ខុដែលបន្ទោបង់មិនបានទូវវិតក្កឯណាមួយ ក្នុងបណ្តាវិតក្កទាំងនោះ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

ក្នុងទីនេះ កាមាសវៈនោះឯង គឺកាមវិតក្ក អាសវៈដែលប្លែកចេញទៅអំពីកាមវិតក្កនោះ ឈ្មោះថា **ភវាសវ** ។ អាសវៈដែលសម្បយុត្តដោយភវាសវៈនោះឯង ឈ្មោះថា **ទិដ្ឋាសវ** ។ ការមិនដឹងក្នុងវិតក្កទាំងឡាយឈ្មោះថា **អវិជ្ជាសវ** ។ គប្បីជ្រាបការកើតឡើងនៃអាសវៈទាំងនេះ ដោយប្រការដូចពណ៌នាមកនេះ ។ បទថា **ឥមេ វុច្ចន្តិ ។បេ។ វិនោទនា បហាតព្វា** សេចក្តីថា អាសវៈមានប្រការដូចពោលហើយ ដោយអំណាចកាមវិតក្កជាដើមទាំងនេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ថា ភិក្ខុគប្បីលះដោយការបន្ទោបង់ ពោល គឺវិរិយសំវរៈដែលសហគតៈដោយការពិចារណាទោសក្នុងវិតក្កនោះៗ ។

## អាសវៈលះបានដោយការចម្រើន

[ ១៨ ] បទថា **បដិសង្ខា យោនិសោ សតិសម្ពោជ្ឈង្គំ ភាវេតិ** សេចក្តីថា ភិក្ខុពិចារណាឃើញទោសនៃការមិនអប់រំ និងអានិសង្សនៃការអប់រំដោយឧបាយ គឺដោយត្រូវផ្លូវ ហើយគួរចម្រើនសតិសម្ពោជ្ឈង្គ ។ ក្នុងបទទាំងពួងក៏ន័យនេះ ។ ក្នុងអធិការនៃពោជ្ឈង្គនេះ ពោជ្ឈង្គដែលជាលោកុត្តរប៉ុណ្ណោះដែលកើតឡើង ព្រោះបានសម្រេចមគ្គ ៣ ខាងដើម ព្រះមានព្រះភាគទ្រង់បំណងយកហើយក្នុងទីនេះ ដោយពិត សូម្បីយ៉ាងនោះ

ដើម្បីការមិនវង្វេងក្នុងពោជ្ឈង្គទាំងឡាយរបស់ពួកភិក្ខុ ដែលធ្វើសេចក្ដីព្យាយាមដំបូង ខ្ញុំនឹងពណ៌នាដោយន័យនៃពោជ្ឈង្គទាំងនោះ ដោយលាយឡំគ្នាទាំងខាងលោកិយផង ខាងលោកុត្តរផង ។ តែក្នុងទីនេះ ខ្ញុំនឹងលះបង់ន័យដែលជាលោកិយចេញ កាន់យកន័យខាងលោកុត្តរប៉ុណ្ណោះ ។ ក្នុងអធិការនៃពោជ្ឈង្គនេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យបទខាងដើមទាំង ៧ ដែលលោកពោលទុកដោយន័យជាដើមថា **សតិសម្ពោជ្ឈង្គំ** ជាមុន ដោយអត្ថ និងដោយលក្ខណៈជាដើម ដោយលំដាប់ និងដោយមិនសង្ខេបពេក ។ ក្នុងពោជ្ឈង្គ ៧ នោះ គប្បីជ្រាបវិនិច្ឆ័យក្នុងសតិពោជ្ឈង្គមុន ។ ដែលឈ្មោះថាសតិ ព្រោះអត្ថថា ជាគ្រឿងរឭក ។ ឯសតិនេះ មានការប្រាកដជាលក្ខណៈឬមានការរឭកជាលក្ខណៈ ។ សមដូចពាក្យដែលលោកពោលទុកថា មហាបពិត្រ នាយឃ្លាំងរបស់ព្រះរាជា រមែងក្រាបទូលដល់ទ្រព្យសម្បត្តិរបស់ព្រះរាជាថា បពិត្រមហារាជ ប្រាក់មានប៉ុណ្ណោះ មាសមានប៉ុណ្ណោះ សម្បត្តិមានប៉ុណ្ណោះ ដូច្នេះ យ៉ាងណា មហាបពិត្រ សតិ ក៏ដូច្នោះដូចគ្នា កាលកើតឡើង រមែងរឭកធម៌ទាំងឡាយដែលជាកុសល អកុសល មានទោស មិនមានទោស ថោកទាប ប្រណីត ខ្មៅ ស និងមានចំណែកជាបដិបក្ខគ្នា ។ សេចក្ដីពិស្ដារថា សតិប្បដ្ឋានមាន ៤ នេះ ។ សតិនោះមានការរឭកជាកិច្ច ។ លក្ខណៈនៃសតិនោះ ព្រះថេរៈពោលទុកដោយកិច្ចពិត ។ម្យ៉ាងទៀត សតិនោះមានការមិនវង្វេងជាកិច្ច ។ មានការបែរមុខចំពោះអារម្មណ៍ជាគ្រឿងប្រាកដ ។ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺសតិ ឈ្មោះថា **សតិសម្ពោជ្ឈង្គ** ។

ក្នុងបទថា **ពោជ្ឈង្គោ** នោះ មានវិគ្គហៈថា អង្គនៃការត្រាស់ដឹង ឬនៃធម៌ជាគ្រឿងត្រាស់ដឹង ដូច្នោះ ទើបឈ្មោះថា **ពោជ្ឈង្គ** ។ លោកពោលអធិប្បាយដូចម្តេច លោកអធិប្បាយថា សាមគ្គីធម៌ គឺសតិ ធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិ ឧបេក្ខា ដែលជាបដិបក្ខចំពោះ ឧបទ្រវដ៏ច្រើន មានការរួញរា ការឈប់ ការប្រមូលមក កាមសុខល្លិកានុយោគ អត្តកិលមថានុយោគ ការប្រកាន់មាំថាដាច់សូន្យ និងទៀងពិត ដែលកើតឡើងក្នុងខណៈនៃមគ្គទាំងចំណែកលោកិយ និងលោកុត្តរ ដែលជាហេតុត្រាស់ដឹងនៃព្រះអរិយសាវក លោកហៅថា **ពោធិ** ព្រោះធ្វើអធិប្បាយដូចពោលមកនេះ ។

បទថា **ពុជ្ឈតិ** សេចក្តីថា រមែងភ្ញាក់ចាកការលក់ ដោយអំណាចកិលេសដែលដេកត្រាំ អធិប្បាយថា រមែងចាក់ធ្លុះអរិយសច្ច ៤ ឬធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននោះឯង ។ ដូចព្រះមានព្រះភាគត្រាស់ថា ចម្រើនពោជ្ឈង្គ ៧ ហើយរមែងត្រាស់ដឹងចំពោះនូវបញ្ញាជាគ្រឿងត្រាស់ដឹងដ៏កំពូល ។ ដែលឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃបញ្ញាជាគ្រឿងត្រាស់ដឹង ពោល គឺធម្មសាមគ្គីនោះឯង ប្រៀបដូចអង្គឈាន និងអង្គមគ្គជាដើម ដូច្នោះ ។

អរិយសាវកនេះ រមែងត្រាស់ដឹងដោយធម្មសាមគ្គីនេះ មានប្រការដូចពោលហើយ ព្រោះធ្វើអធិប្បាយដូចពោលមកនេះ អរិយសាវកនោះ ទើបលោកហៅថា **ពោធិ** ( អ្នកត្រាស់ដឹង ) ដែលឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គប្រកបរបស់ព្រះអរិយសាវក ដែលត្រាស់ដឹងនោះ ដូចអង្គប្រកបនៃសេនា

និងអង្គប្រកបនៃរថ ដូច្នោះ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា ម្យ៉ាងទៀត ដែលឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គប្រកបនៃបុគ្គលដែលត្រាស់ដឹង ម្យ៉ាងទៀត គប្បីជ្រាបអត្ថដោយន័យនៃបដិសម្ភិទាមគ្គជាដើមថា

សួរថា ក្នុងបទថា **ពោជ្ឈង្គា** នេះ ដែលឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថដូចម្ដេច ឆ្លើយថា ដែលឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា រមែងប្រព្រឹត្តទៅដើម្បីការត្រាស់ដឹង ដែលឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា រមែងត្រាស់ដឹង ដែលឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា រមែងត្រាស់ដឹងតាម ដែលឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា រមែងត្រាស់ដឹងចំពោះ ដែលឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា ដឹងព្រម ។

គប្បីជ្រាបវិនិច្ឆ័យដោយអត្ថ និងដោយលក្ខណៈជាដើមរបស់ពោជ្ឈង្គដំបូងជាមុនយ៉ាងនេះថា ពោជ្ឈង្គដ៏ប្រសើរ គឺល្អ ឈ្មោះថា សម្ពោជ្ឈង្គ កាលបើដូច្នេះ សម្ពោជ្ឈង្គ គឺសតិ ឈ្មោះថា **សតិសម្ពោជ្ឈង្គ** ។ នូវសតិ-សម្ពោជ្ឈង្គនោះ ។

គប្បីជ្រាបវិនិច្ឆ័យនេះ ក្នុងពោជ្ឈង្គទី ២ ជាដើមដូច្នេះ ដែលឈ្មោះថា **ធម្មវិចយ** ព្រោះអត្ថថា ជ្រើសរើសសច្ចៈទាំង ៤ ប្រការ ។ ធម្មវិចយនោះ មានការជ្រើសរើសជាលក្ខណៈ មានការឲ្យពន្លឺជាកិច្ច មានការមិនវង្វេងជាគ្រឿងប្រាកដ ។

ដែលឈ្មោះថា **វិរិយ** ព្រោះជាសភាវៈដែលក្លៀវក្លា និងព្រោះឲ្យធម៌ប្រព្រឹត្តទៅដោយត្រូវវិធី ។ វិរិយៈនោះ មានការផ្គងចិត្តជាលក្ខណៈ មានការ

ឧបត្ថម្ភចិត្តជាកិច្ច មានការមិនរួញរាក្នុងចិត្តជាគ្រឿងប្រាកដ ។

ដែលឈ្មោះថា **បីតិ** ព្រោះអត្ថថា ឆ្អែត ។ បីតិនោះមានការផ្សាយទៅជាលក្ខណៈ ឬមានការត្រេកអរជាលក្ខណៈ មានការឆ្អែតនៃកាយ និងចិត្តជាកិច្ច មានការអណ្តែតឡើងនៃកាយ និងចិត្តជាគ្រឿងប្រាកដ ។

ដែលឈ្មោះថា **បស្សទ្ធិ** ព្រោះស្ងប់សេចក្តីក្រវល់ក្រវាយផ្លូវកាយ និងចិត្ត បស្សទ្ធិនោះ មានការចូលទៅស្ងប់ជាលក្ខណៈ មានការញាំញីការក្រវល់ក្រវាយផ្លូវកាយ និងចិត្តជាកិច្ច មានការត្រជាក់ដែលកើតអំពីការមិនក្តៅក្រហាយនៃកាយ និងចិត្តជាអាការប្រាកដ ។

ដែលឈ្មោះថា **សមាធិ** ព្រោះតាំងមាំ ។ សមាធិនោះ មានការមិនរាយមាយជាលក្ខណៈ ឬមានការមិនរេទៅក្នុងអារម្មណ៍ជាលក្ខណៈ មានការប្រមូលមកនូវចិត្ត និងចេតសិកជាកិច្ច មានការតាំងមាំនៃចិត្តជាគ្រឿងប្រាកដ។

ដែលឈ្មោះថា **ឧបេក្ខា** ព្រោះព្រងើយ ។ ឧបេក្ខានោះ មានការពិចារណាជាលក្ខណៈ ឬមានការប្រព្រឹត្តទៅដោយស្មើជាលក្ខណៈ មានការឃាត់ការចុះ និងការឡើងនៃចិត្តជាកិច្ច ឬមានការកាត់ផ្តាច់ការធ្លាក់ទៅជាចំណែកខាងណាមួយជាកិច្ច មានការដាក់ខ្លួនជាកណ្តាលជាគ្រឿងប្រាកដ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។ គប្បីជ្រាបវិនិច្ឆ័យនៃបទដ៏សេស ទាំងដោយអត្ថ និងដោយលក្ខណៈជាដើមយ៉ាងនេះឯង ។

ក្នុងបទថា **កមតោ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ សតិសម្ពោជ្ឈង្គព្រះមានព្រះភាគត្រាស់ជាមុន ព្រោះសតិសម្ពោជ្ឈង្គនោះ ជាឧបការៈដល់

ពោជ្ឈង្គដ៏សេសទាំងអស់ ដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលថា សតិជាគ្រឿងសម្រេចប្រយោជន៍គ្រប់យ៉ាង ដូច្នោះ ។ ខាងមុខ អំពីនោះ ប្រយោជន៍ក្នុងការពោលពោជ្ឈង្គដ៏សេសទុកមុន ទុកក្រោយ បាន ពោលហើយ ក្នុងសុត្តៈនោះឯង ដោយន័យជាដើមថា ភិក្ខុ មានសតិយ៉ាងនេះ ជ្រើសរើសធម៌នោះដោយបញ្ញា ដូច្នេះ ។ ក្នុងទីនេះគប្បីជ្រាបវិនិច្ឆ័យដោយ លំដាប់ដូចពោលមកនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អនូនាធិកតោ** ដូច្នេះ សួរថា ព្រោះហេតុ អ្វី ទើបព្រះមានព្រះភាគត្រាស់ពោជ្ឈង្គត្រឹម ៧ ប្រការប៉ុណ្ណោះ មិនលើស មិនខ្វះ ឆ្លើយថា ព្រោះជាបដិបក្ខចំពោះការរួញរា និងការរាយមាយ និង ប្រយោជន៍ដល់ពោជ្ឈង្គគ្រប់ប្រការ អធិប្បាយថា ក្នុងអធិការនៃពោជ្ឈង្គនេះ ពោជ្ឈង្គ ៣ ជាបដិបក្ខចំពោះការរួញរា ដូចព្រះមានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ បើចិត្តរួញរាក្នុងសម័យណា សម័យនោះ ជាកាល គួរនឹងចម្រើនធម្មវិចយសម្ពោជ្ឈង្គ ជាកាលគួរនឹងចម្រើនវីរិយសម្ពោជ្ឈង្គ ជា កាលគួរនឹងចម្រើនបីតិសម្ពោជ្ឈង្គ ដូច្នេះ ។

ពោជ្ឈង្គ ៣ ជាបដិបក្ខចំពោះការរាយមាយ ដូចព្រះមានព្រះភាគត្រាស់ ថា ម្នាលភិក្ខុទាំងឡាយ បើចិត្តរាយមាយក្នុងសម័យណា សម័យនោះ ជា កាលគួរនឹងចម្រើនបស្សទ្ធិសម្ពោជ្ឈង្គជាកាលគួរនឹងចម្រើនសមាធិសម្ពោជ្ឈង្គ ជាកាលគួរនឹងចម្រើនឧបេក្ខាសម្ពោជ្ឈង្គ ដូច្នេះ ។ ក្នុងបណ្តាពោជ្ឈង្គទាំងនេះ សតិសម្ពោជ្ឈង្គជាឯក គឺកំពូលក្នុងការឲ្យសម្រេចប្រយោជន៍ដល់ពោជ្ឈង្គទាំង

អស់ ដូចព្រះមានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ តថាគតពោលសតិថាមានប្រយោជន៍ដល់ពោជ្ឈង្គគ្រប់ប្រការដូច្នេះ ។ បាលីថា **សព្វត្ថកំ** ដូច្នេះក៏មាន ។ បាលីទាំង ២ នោះដោយអត្ថ គឺបានដល់ ពោជ្ឈង្គគ្រប់ប្រការ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពោជ្ឈង្គនេះដោយមិនខ្វះមិនលើសយ៉ាងនេះថា ព្រះមានព្រះភាគត្រាស់ពោជ្ឈង្គត្រឹម ៧ ប៉ុណ្ណោះ មិនលើសមិនខ្វះ ព្រោះពោជ្ឈង្គ ៣ ជាបដិបក្ខចំពោះការរួញរាពោជ្ឈង្គ ៣ ជាបដិបក្ខចំពោះការរាយមាយ និងព្រោះសតិជាប្រយោជន៍ដល់ពោជ្ឈង្គគ្រប់ប្រការយ៉ាងនេះ ។

បណ្ឌិត កាលជ្រាបអត្ថវណ្ណនានៃបទទាំង ៧ ដែលពោលដោយន័យជាដើមថា **សតិសម្ពោជ្ឈង្គំ** យ៉ាងនេះមុនហើយ ឥឡូវនេះ គប្បីជ្រាបអត្ថវណ្ណនាយ៉ាងនេះ ក្នុងប្រយោគជាដើមថា **ភាវេតិ វិវេកនិស្សិតំ** ដូច្នេះតទៅ

បទថា **ភាវេតិ** សេចក្តីថា រមែងឲ្យចម្រើន អធិប្បាយថា រមែងឲ្យកើតឡើង គឺឲ្យកើតឡើងចំពោះក្នុងចិត្តសន្តានរបស់ខ្លួនរឿយៗ ។

បទថា **វិវេកនិស្សិតំ** គឺអាស្រ័យវិវេក ។ ការស្ងាត់ ឈ្មោះថា **វិវេក** ។ វិវេកនោះ មាន ៥ យ៉ាង គឺ **តទង្គវិវេក វិក្ខម្ភនវិវេក សមុច្ឆេទវិវេក បដិបស្សទ្ធិវិវេក** និង **និស្សរណវិវេក** កាលដែលវិវេកនោះផ្សេងៗ គ្នា គប្បីជ្រាបដោយន័យដែលលោកពោលទុកក្នុងពាក្យនេះថា **អរិយធម្មេ អវិនីតោ** ដូច្នេះ ។ សេចក្តីពិត វិវេកនោះឯង ព្រះមានព្រះភាគត្រាស់ថា វិន័យ ក្នុងបទថា **អរិយធម្មេ អវិនីតោ** នោះ ។ ក្នុងវិវេកទាំង ៥ យ៉ាងដូចពោលមក

នេះ គប្បីជ្រាបដូច្នេះថា

បទថា **វិវេកនិស្សិតំ** សេចក្តីថា ចម្រើនសតិសម្ពោជ្ឈង្គ អាស្រ័យតទង្គវិវេក អាស្រ័យសមុច្ឆេទវិវេក អាស្រ័យនិស្សរណវិវេក ។ ពិតហើយ ព្រះយោគាវចរដែលតាមប្រកបការចម្រើនពោជ្ឈង្គនេះ ក្នុងខណៈនៃវិបស្សនា រមែងចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យតទង្គវិវេកដោយកិច្ច ដែលអាស្រ័យនិស្សរណវិវេកដោយអធ្យាស្រ័យ តែក្នុងកាលនៃមគ្គ រមែងចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យសមុច្ឆេទវិវេកដោយកិច្ច និងអាស្រ័យនិស្សរណវិវេកដោយ អារម្មណ៍ ។ អាចារ្យពួកខ្លះពោលថា អាស្រ័យវិវេកទាំង ៤ យ៉ាងដូច្នេះក៏មាន ។ ព្រោះថា អាចារ្យទាំងនោះមិនលើកពោជ្ឈង្គឡើងមកចំពោះក្នុងខណៈនៃវិបស្សនាដែលមានកម្លាំង និងក្នុងខណៈនៃមគ្គ និងផលតែម្យ៉ាងប៉ុណ្ណោះ តែក្នុងកសិណជ្ឈាន អានាបានស្សតិកម្មដ្ឋាន និងក្នុងព្រហ្មវិហារជ្ឈានដែលជាបាទរបស់វិបស្សនា ក៏លើកឡើងមកផង សូម្បីព្រះអដ្ឋកថាចារ្យទាំងឡាយក៏មិនបានជំទាស់ ព្រោះដូច្នោះ តាមមតិរបស់អាចារ្យទាំងនោះ ក៏គួរពោលថា ព្រះយោគាវចរ រមែងចម្រើនសតិសម្ពោជ្ឈង្គដែលអាស្រ័យវិក្ខម្ភនវិវេកដោយកិច្ចតែម្យ៉ាង ក្នុងខណៈដែលប្រព្រឹត្តទៅនៃឈានទាំងនោះ ។ លោកពោលថា ក្នុងខណៈនៃវិបស្សនា ព្រះយោគាវចររមែងចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនិស្សរណវិវេក ដោយអធ្យាស្រ័យដូច្នេះ យ៉ាងណា ព្រះយោគាវចររមែងចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យបដិបស្សទ្ធិវិវេក ក៏ដូច្នោះ ។ ក្នុងសតិសម្ពោជ្ឈង្គដែលអាស្រ័យវិរាគៈជាដើម

ក៏ន័យនេះ ។ ការពិត ធម៌ មានវិរាគៈជាដើម ក៏មានវិវេកជាអត្ថទាំងអស់ ។ ក្នុងធម៌ទាំងឡាយ មានវិរាគៈជាដើមនេះ វោស្សគ្គតែមួយចែកចេញជា ២ យ៉ាង គឺបរិច្ចាគវោស្សគ្គ ១ បក្ខន្ទនវោស្សគ្គ ១ ។ បណ្ដាវោស្សគ្គ គឺការលះបង់ទាំង ២ យ៉ាងនោះ ការលះកិលេសដោយអំណាចតទង្គប្បហាន ក្នុងខណៈនៃវិបស្សនា និងដោយសមុច្ឆេទប្បហាន ក្នុងខណៈនៃមគ្គ ឈ្មោះថា ការលះដោយបរិច្ចាគ ។ ឯការស្ទុះទៅកាន់ព្រះនិព្វាន ដោយការបង្អោនទៅកាន់ព្រះនិព្វាននោះ ក្នុងខណៈនៃវិបស្សនា ឈ្មោះថា ការលះដោយការស្ទុះទៅ តែក្នុងខណៈនៃមគ្គ ការស្ទុះទៅកាន់ព្រះនិព្វាន មានដោយអំណាចនៃការធ្វើឲ្យជាអារម្មណ៍ ។ សូម្បីវោស្សគ្គទាំងគូនោះ រមែងសមក្នុងន័យរបស់អដ្ឋកថា ដែលលាយឡំដោយលោកិយ និងលោកុត្តរនោះ ។ ពិតហើយ សតិសម្ពោជ្ឈង្គនេះ រមែងលះកិលេស និងរមែងស្ទុះទៅកាន់ព្រះនិព្វាន ដោយប្រការតាមដែលពោលហើយ ដោយពាក្យទាំងនេះថា **វោស្សគ្គ-បរិណាមី** នេះ មានពាក្យអធិប្បាយដែលលោកពោលថា កំពុងបង្អោនទៅ និងបង្អោនទៅហើយ គឺចាស់ក្លា និងចាស់ក្លាហើយ ដើម្បីការលះបង់ដូច្នេះ ។ អធិប្បាយថា ភិក្ខុនេះជាអ្នកប្រកបរឿយៗ នូវការចម្រើនពោជ្ឈង្គ រមែងចម្រើនសតិសម្ពោជ្ឈង្គនោះ ដោយសតិសម្ពោជ្ឈង្គចាស់ក្លា និងចាស់ក្លាហើយ ដើម្បីការលះបង់ដោយការលះកិលេស និងដើម្បីការលះបង់ដោយការស្ទុះទៅកាន់ព្រះនិព្វាន ។ ក្នុងពោជ្ឈង្គដ៏សេសក៏ន័យនេះ ។

តែក្នុងទីនេះ និព្វាននោះឯង លោកពោលថា **វិវេក** ព្រោះស្ងាត់ចាក

សង្ខតធម៌ទាំងពួង លោកពោលថា **វិរាគ** ព្រោះការៈនៃសង្ខតធម៌ទាំងអស់ ប្រាសចាកតម្រេកហើយ ហើយលោកពោលថា **និរោធ** ព្រោះការៈ គឺការរំលត់នៃសង្ខតធម៌ទាំងឡាយ ។ មគ្គនោះឯងមានប្រក្រតីបង្អោនទៅដើម្បីការលះបង់ ដូច្នោះ ព្រះយោគាវចរ រមែងចម្រើនសតិសម្ពោជ្ឈង្គដែលអាស្រ័យវិវេក ព្រោះធ្វើវិវេកឲ្យជាអារម្មណ៍ ហើយប្រព្រឹត្តទៅ ។ ព្រះយោគាវចរ រមែងចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនិរោធក៏យ៉ាងនោះ ។ ព្រះ-យោគាវចររមែងចម្រើនសតិសម្ពោជ្ឈង្គដែលចាស់ក្លាហើយ គឺចាស់ក្លាដោយជុំវិញ ដោយការៈ គឺការលះ និងដោយការៈ គឺការស្ទុះទៅកាន់ព្រះនិព្វានដោយការដកកិលេសបានជាសមុច្ឆេទ ព្រោះកើតឡើងក្នុងខណៈនៃអរិយមគ្គនោះឯង គប្បីឃើញអត្ថដូចពោលមកនេះ ។ ក្នុងពោជ្ឈង្គដ៏សេសក៏ន័យនេះ ។

បទថា **យញ្ហិស្ស** សេចក្តីថា អាសវៈទាំងឡាយ និងការក្តៅក្រហាយដែលធ្វើការចង្អៀតចង្អល់ចិត្តទាំងឡាយ រមែងមានដល់ភិក្ខុដែលមិនចម្រើនក្នុងបណ្តាពោជ្ឈង្គទាំងឡាយនោះណាមួយ ។ ពាក្យដ៏សេស មានន័យដូចពោលហើយ ដូច្នេះ ។ ក្នុងការកើតឡើងនៃអាសវៈក្នុងសូត្រនេះ គប្បីជ្រាបដូច្នេះ អាសវៈទាំង ៣ គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈពួកណាគប្បីកើតឡើង ព្រោះភិក្ខុមិនបានអប់រំពោជ្ឈង្គ ដែលសម្បយុត្តដោយមគ្គខាងចុងទាំងនេះ អាសវៈទាំងនោះ រមែងមិនមានដល់ភិក្ខុនោះ ដែលចម្រើនពោជ្ឈង្គទាំងនោះ ដូច្នេះ ។ បទថា **ឥមេ វុច្ចន្តិ ។បេ។ ភាវនា បហាតព្វា** សេចក្តីថា អាសវៈទាំង ៣ នេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ថា ភិក្ខុគប្បីលះ

ដោយការចម្រើនពោជ្ឈង្គដែលសម្បយុត្តដោយមគ្គ ៣ នេះ ។

[ ១៩ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សរសើរភិក្ខុដែលលះអាសវៈបានដោយអាការ ៧ នេះ និងកាលទ្រង់សម្តែងអានិសង្សក្នុងការលះអាសវៈនៃភិក្ខុនោះ និងកាលឲ្យកើតការខ្វល់ខ្វាយដល់សត្វទាំងឡាយ ដោយការលះអាសវៈដោយហេតុទាំងនេះឯង ទើបត្រាស់ថា **យតោ ខោ ភិក្ខវេ ។បេ។ អន្តមកាសិ ទុក្ខស្ស** ដូច្នេះ ។

បណ្តាបទទាំងនោះ **តោ** អក្ខរៈ ក្នុងបទថា **យតោ ខោ** ប្រើក្នុងឆដ្ឋីវិភត្តិ អធិប្បាយថា ស្មើគ្នានឹង **យស្ស ខោ** ( របស់កាលណា ) ដូច្នេះ ឯព្រះបុរាណាចារ្យទាំងឡាយ រមែងពណ៌នាថា ស្មើគ្នានឹង **យម្ហិ កាលេ** ( ក្នុងកាលណា ) ដូច្នេះ ។ បទថា **យេ អាសវា ទស្សនា បហាតព្វា** សេចក្តីថា អាសវៈទាំងឡាយណា ដែលភិក្ខុលះបានហើយដោយទស្សនៈ អាសវៈទាំងឡាយនោះ ឈ្មោះថា ភិក្ខុនោះ លះបានហើយដោយទស្សនៈនោះឯង ហើយលោករមែងមានការសម្គាល់ក្នុងអាសវៈ ដែលមិនទាន់លះបាននោះឯងថា ខ្ញុំលះបានហើយក៏ទេ ។ ក្នុងបទទាំងពួងមានសេចក្តីពិស្តារយ៉ាងនេះ ។

បទថា **សព្វាសវសំវរសំវុតោ** សេចក្តីថា ជាបុគ្គលបិទហើយ ដោយការបិទអាសវៈគ្រប់យ៉ាង ។ម្យ៉ាងទៀត ជាបុគ្គលបិទហើយ ដោយគ្រឿងបិទនូវអាសវៈគ្រប់យ៉ាង ។

បទថា **អច្ឆេច្ឆិ តណ្ហំ** សេចក្តីថា កាត់ហើយ ឬដកឡើងបានហើយនូវ

តណ្ហាទាំងអស់គ្រប់យ៉ាង ។

បទថា **វិវត្តយិ សំយោជនំ** សេចក្តីថា រមែងវិលត្រឡប់នូវសំយោជនៈទាំង ១០ គឺធ្វើឲ្យអស់មន្ទិល ។

បទថា **សម្មា** គឺដោយហេតុ បានដល់ ដោយកាល ។

បទថា **មានាភិសមយា** សេចក្តីថា ព្រោះសម្រេចការឃើញ និងព្រោះសម្រេចដោយការលះមានះ ។ សេចក្តីពិតអរហត្តមគ្គ រមែងឃើញច្បាស់នូវមានះ ដោយអំណាចកិច្ច ។ នេះជាការសម្រេចការឃើញរបស់ភិក្ខុនោះ ។ អរហត្តមគ្គដែលភិក្ខុឃើញហើយដោយទស្សនៈនោះ ក៏លោករមែងលះបានក្នុងខណៈនោះឯង ដូចការត្រឡប់បានជីវិតរបស់សត្វដែលត្រូវពស់ចឹកដូច្នោះ នេះជាការសម្រេចដោយការលះរបស់ភិក្ខុនោះ ។

បទថា **អន្តមកាសិ ទុក្ខស្ស** សេចក្តីថា ទីបំផុត ៤ យ៉ាង ទីបំផុត គឺព្រំដែនដែលមាននៅទីបំផុត ដែលព្រះមានព្រះភាគត្រាស់ថា ចុងវត្តពន្ធចង្កេះចាស់ហើយ ឬត្រួយរបស់ពណ៌ខៀវក្រៀមស្វិតហើយ និងទីបំផុតដែលថោកទាប ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះជាទីបំផុតនៃជីវិត ហើយទីបំផុត គឺចំណែកដែលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា សក្កាយ ( ទិដ្ឋិ ) ក៏ជាទីបំផុតមួយ និងទីបំផុតរបស់ការរាប់ ដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា នេះជាទីបំផុតនៃទុក្ខ ព្រោះរាប់បច្ច័យគ្រប់យ៉ាង ក្នុងបណ្តាទីបំផុតទាំង ៤ យ៉ាងនោះ ភិក្ខុបានធ្វើទីបំផុត ប្រការទី ៤ នោះនៃវដ្តទុក្ខទាំងពួងបាន ព្រោះមានះដែលខ្លួនឃើញ លះបានដោយអរហត្ត-

មគ្គយ៉ាងនេះ អធិប្បាយថា លោកបានធ្វើការកាត់ផ្តាច់ គឺធ្វើឲ្យអស់ទៅ បានដល់ ធ្វើទុក្ខឲ្យសល់នៅត្រឹមតែរាងកាយជាតិចុងក្រោយ ។ បទថា **អត្តមនា តេ ភិក្ខូ** សេចក្តីថា ភិក្ខុទាំងនោះមានចិត្តជារបស់ខ្លួន គឺមានចិត្តត្រេកអរ ឬជាអ្នកមានចិត្តដែលសម្បយុត្តដោយបីតិ និងសោមនស្ស ។

បទថា **ភគវតោ ភាសិតំ អភិនន្ទុំ** សេចក្តីថា ភិក្ខុទាំងឡាយទទួលដោយសិរសា គឺត្បូង ហើយសរសើរព្រះពុទ្ធភាសិត គឺព្រះតម្រាស់ដែលត្រាស់ល្អហើយ បានដល់ ដែលទ្រង់ប្រាស្រ័យហើយ មានការធ្វើទីបំផុតទុក្ខជាបរិយោសានថា ព្រះមានព្រះភាគត្រាស់នូវពាក្យនេះយ៉ាងនេះ ព្រះសុគតត្រាស់ពាក្យនេះ ដូច្នេះ ។

ពាក្យដ៏សេសឯណាដែលខ្ញុំមិនបានពោលទុកក្នុងទីនេះ ខ្ញុំមិនពោលពាក្យនោះដដែលទៀតឡើយ ព្រោះពោលទុកមុនហើយ និងព្រោះយល់បានងាយហើយ ព្រោះដូច្នោះ អ្នកសិក្សាគប្បីពិចារណាពាក្យទាំងអស់ តាមលំដាប់បទដោយទំនងនៃពាក្យដែលពោលហើយហោង ។៚

**សព្វាសវសំវរសូត្រ ចប់**

**សូត្រទី ២ ចប់**

# សុត្តន្តបិដក

## ធម្មទាយាទសូត្រទី ៣

[ ២០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ២១ ] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកធម៌ របស់តថាគតជាមត៌ក កុំយកអាមិស[១] ជាមត៌កឡើយ តថាគតមានសេចក្តីអនុគ្រោះចំពោះអ្នកទាំងឡាយដូច្នេះថា ធ្វើម្តេចហ្ន៎ពួកសាវ័ករបស់តថាគត គួរយកធម៌ជាមត៌ក កុំយកអាមិសជាមត៌កឡើយ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ យកអាមិសជាមត៌ក មិនយកធម៌របស់តថាគតជាមត៌កហើយ គង់មានអ្នកផងតិះដៀលអ្នកទាំងឡាយ ដោយហេតុនេះថា ពួកសាវ័ករបស់ព្រះសាស្តា សុទ្ធតែយកអាមិសជាមត៌ក មិនយកធម៌ជាមត៌កទេ ។ ទាំងតថាគតក៏ត្រូវអ្នកផងតិះដៀលដោយហេតុនោះថា ពួកសាវ័ករបស់ព្រះសាស្តា សុទ្ធតែយកអាមិសជាមត៌ក មិនយកធម៌ជាមត៌កឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយយកធម៌របស់តថាគតជាមត៌ក មិនយកអាមិសជាមត៌កទេ គឺឥតមានអ្នកផងតិះដៀលអ្នកទាំង-ឡាយ ដោយហេតុនោះថា ពួកសាវ័ករបស់ព្រះសាស្តាសុទ្ធតែយកធម៌ជាមត៌ក

---

១- សូមមើលអដ្ឋកថាខាងក្រោម ។

មិនមែនយកអាមិសជាមត៌កទេ ។ ទាំងតថាគត ក៏ឥតមានអ្នកផងតិះដៀល ដោយហេតុនោះថា ពួកសាវ័ករបស់ព្រះសាស្តា សុទ្ធតែយកធម៌ជាមត៌ក មិនមែនយកអាមិសជាមត៌កទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងកាលឥឡូវនេះ អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមត៌ក កុំយកអាមិសជាមត៌កឡើយ តថាគតមានសេចក្តីអនុគ្រោះចំពោះអ្នកទាំងឡាយថា ធ្វើម្តេចហ្ន៎ ពួកសាវ័ករបស់តថាគត គួរយកធម៌ជាមត៌ក កុំយកអាមិសជាមត៌កឡើយ ។

[ ២២ ] ម្នាលភិក្ខុទាំងឡាយ ក្នុងទីនេះ តថាគតបរិភោគស្រេច ឃាត់លែងទទួលទៀត គ្រប់គ្រាន់បរិបូណ៌ ឆ្អែតស្កប់ស្កល់ គួរតាមប្រមាណហើយ ឯបិណ្ឌបាតរបស់តថាគតនៅសល់ច្រើន ជារបស់គួរចាក់ចោលជាធម្មតា ។ គ្រានោះ មានភិក្ខុ ២ រូបមកដល់ កំពុងមានសេចក្តីស្រេកឃ្លានគ្របសង្កត់ជាខ្លាំង តថាគតក៏ពោលទៅនឹងភិក្ខុទាំងពីររូបនោះយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតបរិភោគស្រេច ឃាត់លែងទទួលទៀត គ្រប់គ្រាន់បរិបូណ៌ ឆ្អែតស្កប់ស្កល់ គួរតាមប្រមាណហើយ ឯបិណ្ឌបាតរបស់តថាគតនេះ នៅសល់ច្រើន ជារបស់គួរចាក់ចោលជាធម្មតា បើអ្នកទាំង-ឡាយចង់ឆាន់ ចូរឆាន់ចុះ បើអ្នកទាំងឡាយមិនឆាន់ទេ តថាគតនឹងចាក់ចោលក្នុងទីដែលគ្មានស្មៅស្រស់ ឬនឹងចាក់ចោលក្នុងទឹកដែលគ្មានសត្វឥឡូវនេះ ។ បណ្តាភិក្ខុទាំង ២ រូបនោះ ភិក្ខុ ១ រូបគិតថា ព្រះមានព្រះភាគទ្រង់សោយស្រេច ឃាត់លែងទទួលទៀត គ្រប់គ្រាន់បរិបូណ៌ ឆ្អែតស្កប់ស្កល់ គួរតាម

ប្រមាណហើយ បិណ្ឌបាតនេះរបស់ព្រះមានព្រះភាគ នៅសល់ច្រើន ជារបស់គួរចាក់ចោលជាធម្មតា បើពួកយើងនឹងមិនឆាន់ ព្រះមានព្រះភាគនឹងចាក់ចោលឥឡូវនេះ ក្នុងទីដែលគ្មានស្មៅស្រស់ ឬនឹងចាក់ចោលក្នុងទឹកដែលគ្មានសត្វ នេះជាព្រះពុទ្ធដីកាដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមត៌ក កុំយកអាមិសជាមត៌កឡើយ ឯបិណ្ឌបាតនេះក៏ជាអាមិសមួយដែរ បើដូច្នោះមានតែអាត្មាអញកុំបរិភោគបិណ្ឌបាតនេះឡើយ នឹងទ្រាំអត់សេចក្តីស្រេកឃ្លាននេះឲ្យអស់មួយយប់មួយថ្ងៃទៅចុះ ។ ភិក្ខុនោះ ក៏មិនឆាន់បិណ្ឌបាតនោះឡើយ ហើយទ្រាំអត់សេចក្តីស្រេកឃ្លាននោះ អស់មួយយប់ មួយថ្ងៃយ៉ាងនេះ ។ គ្រានោះ ភិក្ខុទី ២ គិតយ៉ាងនេះថា ព្រះមានព្រះភាគ ទ្រង់សោយស្រេចឃាត់លែងទទួលទៀត គ្រប់គ្រាន់បរិបូណ៌ទៀត ឆ្អែតស្កប់ស្កល់ គួរតាមប្រមាណហើយ ឯបិណ្ឌបាតនេះរបស់ព្រះមានព្រះភាគ ក៏នៅច្រើន ជារបស់គួរចាក់ចោលជាធម្មតា បើពួកយើងមិនឆាន់ទេ ព្រះមានព្រះភាគនឹងទ្រង់ចាក់ចោលឥឡូវនេះ ក្នុងទីដែលគ្មានស្មៅស្រស់ ឬនឹងចាក់ចោលក្នុងទឹកដែលគ្មានសត្វ បើដូច្នោះ មានតែអាត្មាអញ គួរឆាន់ចង្ហាន់បិណ្ឌបាតនេះ ឲ្យបាត់សេចក្តីស្រេកឃ្លាន នឹងបានប្រព្រឹត្តទៅអស់មួយយប់មួយថ្ងៃនេះឯង ។ ភិក្ខុនោះក៏ឆាន់ចង្ហាន់បិណ្ឌបាតនោះ បានបន្ទោបង់សេចក្តីស្រេកឃ្លាន បាត់អស់កម្លាំង ប្រព្រឹត្តទៅអស់មួយយប់មួយថ្ងៃនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឆាន់ចង្ហាន់បិណ្ឌបាតនោះ បានបន្ទោបង់សេចក្តីស្រេកឃ្លាន បាត់អស់

កម្លាំង ប្រព្រឹត្តទៅអស់មួយយប់មួយថ្ងៃនោះឯង ក៏មិនជាអ្វី ។ ឯភិក្ខុទី ១ នោះឯង គួរជាទីបូជាដោយវិសេសផង ជាទីសរសើររបស់តថាគតផង ។ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ការមិនឆាន់ចង្ហាន់បិណ្ឌបាតនោះ អាចធ្វើឲ្យភិក្ខុនោះ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច ដើម្បីសេចក្តីសន្តោស ដើម្បីមានចិត្តជូរផង់ ដើម្បីជាមនុស្សដែលគេចិញ្ចឹមងាយ ដើម្បីប្រារព្ធនូវព្យាយាមអស់កាលដ៏យូរអង្វែងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងធម្មវិន័យនេះ អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមត៌ក កុំយកអាមិសជាមត៌កឡើយ តថាគតមានសេចក្តីអនុគ្រោះចំពោះអ្នកទាំង-ឡាយដូច្នេះថា ធ្វើម្តេចហ្ន៎ ពួកសាវករបស់តថាគតគួរជាអ្នកយកធម៌ជាមត៌ក កុំយកអាមិសជាមត៌កឡើយ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះ លុះព្រះសុគតមានពុទ្ធដីកានេះ ចប់ហើយ ក៏ទ្រង់ស្តេចក្រោកចាកអាសនៈ ទ្រង់ពុទ្ធដំណើរទៅកាន់វិហារ ។

[ ២៣ ] កាលដែលព្រះមានព្រះភាគ ទ្រង់ព្រះពុទ្ធដំណើរទៅមិនយូរប៉ុន្មាន ព្រះសារីបុត្រដ៏មានអាយុ ក៏ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ។ ភិក្ខុទាំងនោះទទួលថេរវាចាព្រះសារីបុត្រដ៏មានអាយុថា ម្នាលអាវុសោ ។ ព្រះសារីបុត្រដ៏មានអាយុ បានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ ចុះព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ ពួកសាវកមិនហាត់ធ្វើនូវវិវេក គឺសេចក្តីស្ងប់ស្ងាត់ ដោយហេតុប៉ុន្មានយ៉ាងមួយទៀត ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ ពួកសាវកហាត់ធ្វើ

នូវវិវេកដោយហេតុប៉ុន្មានយ៉ាង ។ ពួកភិក្ខុតបថា ម្នាលអាវុសោ យើងខ្ញុំទាំងឡាយមកពីចម្ងាយ មានប្រាថ្នាដើម្បីដឹងនូវអត្ថនៃភាសិតនុ៎ះ ក្នុងសំណាក់ព្រះសារីបុត្រដ៏មានអាយុ ឯអត្ថនៃភាសិតនុ៎ះ ប្រាកដច្បាស់ចំពោះព្រះសារីបុត្រដ៏មានអាយុហើយ ពួកភិក្ខុអ្នកស្តាប់ ( នូវភាសិត ) របស់ព្រះសារីបុត្រដ៏មានអាយុរួចហើយ នឹងចងចាំទុក ព្រះសារីបុត្រដ៏មានអាយុឆ្លើយថា ម្នាលអាវុសោទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យមែនទែន ខ្ញុំនឹងសម្តែងឲ្យស្តាប់ ។ ភិក្ខុទាំងនោះក៏ទទួលថេរវាចារបស់ព្រះសារីបុត្រដ៏មានអាយុថា ព្រះករុណា អាវុសោ ។

[ ២៤ ] ព្រះសារីបុត្រដ៏មានអាយុ បានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ ពួកសាវ័កមិនហាត់ធ្វើនូវវិវេក ដោយហេតុប៉ុន្មានយ៉ាង ម្នាលអាវុសោទាំងឡាយ ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ ពួកសាវ័កក្នុងសាសនានេះ មិនហាត់ធ្វើនូវវិវេក មិនលះបង់នូវពួកធម៌ដែលព្រះសាស្តាទ្រង់ត្រាស់ឲ្យលះបង់ បែរទៅជាអ្នកប្រព្រឹត្តល្មោភច្រើន ជាអ្នកកាន់សាសនាធូរៗ នាំអាទិ៍ឲ្យប្រព្រឹត្តទន់ទាប ជាអ្នកដាក់ធុរៈក្នុងវិវេក គឺមិនបំពេញកិច្ចក្នុងព្រះនិព្វាន ។ ម្នាលអាវុសោទាំងឡាយ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុជាថេរៈនឹងមានគេតិះដៀលដោយហេតុ ៣ យ៉ាង ។ គឺភិក្ខុជាថេរៈទាំងឡាយ នឹងមានគេតិះដៀលដោយហេតុទី ១ នេះថា ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ តែមានពួកសាវ័កមិនហាត់ធ្វើនូវវិវេក ។ ភិក្ខុជាថេរៈទាំងឡាយ នឹងមានគេតិះដៀល

ដោយហេតុទី ២ នេះថា ពួកសាវកមិនលះបង់នូវពួកធម៌ដែលព្រះសាស្តាទ្រង់សំដែងប្រាប់ឲ្យលះបង់ ។ ភិក្ខុជាថេរៈទាំងឡាយ នឹងមានគេតិះដៀល ដោយហេតុទី ៣ នេះថា ពួកសាវកជាអ្នកប្រព្រឹត្តល្មោភច្រើន ជាអ្នកកាន់ ( សាសនា ) ធូរៗ នាំអាទិ៍ឲ្យប្រព្រឹត្តទន់ទាប ជាអ្នកដាក់ធុរៈក្នុងវិវេក ។ ម្នាលអាវុសោទាំងឡាយ ពួកភិក្ខុជាថេរៈ រមែងមានគេតិះដៀល ដោយហេតុទាំង ៣ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ បណ្តាភិក្ខុទាំងនោះ ពួកមជ្ឈិមភិក្ខុ ។បេ។ ពួកនវកភិក្ខុ រមែងមានគេតិះដៀល ដោយហេតុទាំង ៣ យ៉ាងនេះឯង ។ ពួកនវកភិក្ខុនឹងមានគេតិះដៀល ដោយហេតុទី ១ នេះថា ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ តែពួកសាវកមិនហាត់ធ្វើនូវវិវេក ។ ពួកនវកភិក្ខុ នឹងមានគេតិះដៀល ដោយហេតុទី ២ នេះថា ពួកសាវកមិនលះបង់នូវពួកធម៌ ដែលព្រះសាស្តាទ្រង់សំដែងប្រាប់ឲ្យលះបង់ ។ ពួកនវកភិក្ខុនឹងមានគេតិះដៀលដោយហេតុទី ៣ នេះថា ពួកភិក្ខុជាអ្នកប្រព្រឹត្តល្មោភច្រើន ជាអ្នកកាន់ ( សាសនា ) ធូរៗ នាំអាទិ៍ឲ្យប្រព្រឹត្តទន់ទាប ជាអ្នកដាក់ធុរៈក្នុងវិវេក ។ ម្នាលអាវុសោទាំងឡាយ ពួកនវកភិក្ខុរមែងមានគេតិះដៀល ដោយហេតុទាំង ៣ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ តែពួកសាវកមិនហាត់ធ្វើនូវវិវេក ដោយហេតុទាំង ៣ យ៉ាងប៉ុណ្ណេះឯង ។

[ ២៥ ] ម្នាលអាវុសោទាំងឡាយ ចុះព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ ទាំងពួកសាវកក៏សិក្សាតាមនូវវិវេក ដោយហេតុមានប៉ុន្មានយ៉ាង

ម្នាលអាវុសោទាំងឡាយ ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ ពួកសាវកក៏សិក្សាតាមនូវវិវេកផង លះបង់នូវពួកធម៌ដែលព្រះជាគ្រូទ្រង់សម្តែងប្រាប់ឲ្យលះបង់ផង មិនជាអ្នកប្រព្រឹត្តល្មោភច្រើនផង មិនកាន់ ( សាសនា ) ធូរផង ដាក់ធុរៈក្នុងការប្រព្រឹត្តទន់ទាបផង ជាប្រធានក្នុងវិវេកធម៌ គឺព្រះនិព្វានផង ។ ម្នាលអាវុសោ បណ្តាភិក្ខុទាំងនោះ ថេរភិក្ខុទាំងឡាយ រមែងមានអ្នកផងសរសើរដោយហេតុ ៣ យ៉ាង ។ គឺពួកភិក្ខុជាថេរៈ រមែងមានអ្នកផងសរសើរដោយហេតុទី ១ នេះថា ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ ទាំងពួកសាវកក៏សិក្សាតាមនូវវិវេក ។ ពួកភិក្ខុជាថេរៈ រមែងមានអ្នកផងសរសើរ ដោយហេតុទី ២ នេះថា ពួកសាវកជាអ្នកលះបង់នូវពួកធម៌ ដែលព្រះសាស្តាទ្រង់សម្តែងប្រាប់ឲ្យលះបង់ ។ ពួកភិក្ខុជាថេរៈ រមែងមានអ្នកផងសរសើរដោយហេតុទី ៣ នេះថា ពួកសាវកមិនប្រព្រឹត្តល្មោភច្រើនផង មិនកាន់ ( សាសនា ) ធូរផង មិនដាក់ធុរៈក្នុងការប្រព្រឹត្តទន់ទាបផង ជាប្រធានក្នុងវិវេកធម៌ គឺព្រះនិព្វានផង ។ ម្នាលអាវុសោទាំង-ឡាយ ពួកភិក្ខុជាថេរៈ រមែងមានអ្នកផងសរសើរដោយហេតុទាំង ៣ នេះឯង ។ ម្នាលអាវុសោទាំងឡាយ បណ្តាភិក្ខុទាំងនោះ ពួកមជ្ឈិមភិក្ខុ ( ភិក្ខុកណ្តាល ) ។បេ។ ពួកនវកភិក្ខុ ( ភិក្ខុថ្មី ) រមែងមានអ្នកផងសរសើរដោយហេតុ ៣ យ៉ាង ។ គឺពួកនវកភិក្ខុរមែងមានអ្នកផងសរសើរដោយហេតុទី ១ នេះថា ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ មានពួកសាវកសិក្សាតាមនូវវិវេក ។ ពួកនវកភិក្ខុរមែងមានអ្នកផងសរសើរ ដោយ

ហេតុទី ២ នេះថា ពួកសាវ័កជាអ្នកលះបង់នូវពួកធម៌ ដែលព្រះសាស្តាទ្រង់សម្តែងប្រាប់ឲ្យលះបង់ ។ ពួកនវកភិក្ខុរមែងមានអ្នកផងសរសើរដោយហេតុទី ៣ នេះថា ពួកសាវ័កមិនប្រព្រឹត្តល្មោភច្រើនផង មិនកាន់ ( សាសនា ) ធូរៗ ផង ដាក់ធុរៈក្នុងការប្រព្រឹត្តទន់ទាបផង ជាប្រធានក្នុងវិវេកធម៌ គឺព្រះនិព្វានផង ។ ម្នាលអាវុសោទាំងឡាយ ពួកនវកភិក្ខុរមែងមានអ្នកផងសរសើរ ដោយហេតុទាំង ៣ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយ រមែងមានពួកសាវ័កជាអ្នកសិក្សាតាមនូវវិវេក ដោយហេតុទាំង ៣ យ៉ាងប៉ុណ្ណោះឯង ។

[២៦] ម្នាលអាវុសោទាំងឡាយ បណ្តាធម៌ទាំងនោះ លោភៈជាបាបធម៌ ១ ទោសៈជាបាបធម៌ ១ មជ្ឈិមាបដិទា គឺសេចក្តីប្រតិបត្តិយ៉ាងកណ្តាល ប្រព្រឹត្តទៅដើម្បីលះបង់នូវលោភៈផង ដើម្បីលះបង់នូវទោសៈផង ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ គឺឃើញនូវសច្ចៈទាំង ៤ ផង ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតញាណ គឺដឹងនូវសច្ចៈទាំង ៤ ផង ប្រព្រឹត្តដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីព្រះនិព្វាន ។ ម្នាលអាវុសោទាំងឡាយ ក៏មជ្ឈិមាបដិទានោះ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីព្រះនិព្វាន តើដូចម្តេច ។ ( មជ្ឈិមាបដិបទានោះ ) គឺអរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង ឯអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ គឺសេចក្តីឃើញត្រូវ ១

សេចក្តីត្រិះរិះត្រូវ ១ សម្តីត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្តីព្យាយាមត្រូវ ១ ការរឭកត្រូវ ១ ការតម្កល់ចិត្តត្រូវ ១ ម្នាលអាវុសោទាំងឡាយ មជ្ឈិមាបដិបទានេះឯង ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីព្រះនិព្វាន ។ ម្នាលអាវុសោទាំងឡាយ បណ្តាធម៌ទាំងនោះ សេចក្តីក្រោធជាបាបធម៌ ១ ការចងនូវសេចក្តីក្រោធទុកជាបាបធម៌ ១ ... ។ លុបគុណគេជាបាបធម៌ ១ វាយឫកស្មើជាបាបធម៌ ១ ... ។ សេចក្តីឈ្នានីសជាបាបធម៌ ១ សេចក្តីកំណាញ់ជាបាបធម៌ ១ ... ។ ការបិទបាំងទោសខ្លួនជាបាបធម៌ ១ សេចក្តីអួតអាងជាបាបធម៌ ១ ... ។ សេចក្តីរឹងត្អឹងជាបាបធម៌ ១ ប្រឡងវាសនាជាបាបធម៌ ១ ... ។ មានះជាបាបធម៌ ១ អតិមានះជាបាបធម៌ ១ ... ។ សេចក្តីស្រវឹងជាបាបធម៌ ១ សេចក្តីធ្វេសប្រហែសជាបាបធម៌ ១ សេចក្តីប្រតិបត្តិយ៉ាងកណ្តាល ប្រព្រឹត្តទៅដើម្បីលះបង់នូវសេចក្តីស្រវឹងផង ដើម្បីលះបង់នូវសេចក្តីធ្វេសប្រហែសផង ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីព្រះនិព្វាន ។ ម្នាលអាវុសោទាំងឡាយ សេចក្តីប្រតិបត្តិយ៉ាងកណ្តាលនោះ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បី

ព្រះនិព្វាន តើដូចម្តេច ។ ( សេចក្តីប្រតិបត្តិយ៉ាងកណ្តាលនោះ ) គឺអរិយ-មគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង ឯអរិយមគ្គប្រកបដោយអង្គ ៨ ប្រការនោះ គឺសេចក្តីឃើញត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ សម្តីត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្តីព្យាយាមត្រូវ ១ ការរឭកត្រូវ ១ ការតម្កល់ចិត្តត្រូវ ១ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីប្រតិបត្តិយ៉ាងកណ្តាលនេះឯង ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីព្រះនិព្វាន ។ ព្រះសារីបុត្រដ៏មានអាយុ បានសម្តែងនូវសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះ ក៏មានចិត្តត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះសារីបុត្រដ៏មានអាយុ ។

## ធម្មទាយាទសូត្រទី ៣ ចប់

# អដ្ឋកថា

## ធម្មទាយាទសូត្រ

### ហេតុកើតព្រះសូត្រ

[ ២០ ] ធម្មទាយាទសូត្រនេះ មានពាក្យផ្ដើមថា **ធម្មទាយាទា មេ ភិក្ខវេ ភវថ** **ឯវម្មេ សុតំ** ។ ព្រោះធម្មទាយាទសូត្រនោះ ទ្រង់លើកឡើងសម្ដែងតាមដែលមានរឿងកើតឡើង ដូច្នោះ ខ្ញុំនឹងសម្ដែងហេតុដែលនាំឲ្យកើតព្រះសូត្រនោះហើយ ទើបធ្វើការបរិយាយ ពង្រីកព្រះសូត្រនោះទៅតាមលំដាប់បទ ។

សួរថា ធម្មទាយាទសូត្រនេះ ព្រះមានព្រះភាគទ្រង់លើកឡើងសម្ដែង ព្រោះមានរឿងអ្វីកើតឡើង ឆ្លើយថា រឿងលាភសក្ការៈ ។

បានឮមកថា លាភសក្ការៈកើតឡើងដល់ព្រះមានព្រះភាគ ព្រោះទ្រង់បានសន្សំទានបារមីឲ្យបរិបូណ៌ហើយ អស់ ៤ អសង្ខេយ្យ ជាការពិត ព្រោះព្រះបារមីគ្រប់ប្រការ ហាក់ដូចជាមកប្រជុំគ្នាថា នឹងឲ្យផលក្នុងអត្តភាពមួយនេះឯង ដូច្នេះហើយ ឲ្យកើតជាក្រសែទឹកធំ គឺលាភសក្ការៈ ដូចមហាមេឃដែលសហការគ្នាជាគូៗ តាំងខ្លួនឡើងគ្រប់ទិស ហើយធ្លាក់ចុះមក ឲ្យកើតជាអន្លង់ទឹកធំ ដូច្នេះ ។

ប្រជាជនមានវណ្ណៈផ្សេងៗ មានក្សត្រ និងព្រាហ្មណ៍ជាដើម មានដៃកាន់បាយ ទឹក យាន សំពត់ កម្រងផ្កា គ្រឿងក្រអូប និងគ្រឿងលាបជាដើម មកអំពីទីនោះៗ ហើយនាំគ្នាសួររកព្រះមានព្រះភាគថា ព្រះពុទ្ធអង្គគង់នៅទីណា ព្រះមានព្រះភាគប្រថាប់នៅទីណា ព្រះទេវទេព ព្រះនរៈដ៏អង់អាច

ព្រះបុរសសីហរាជ ប្រថាប់នៅទីណា ប្រជាជនទាំងនោះ ប្រើរទេះទាំង-ឡាយ ១០០ រទេះ ដឹកបច្ច័យមក កាលមិនទាន់បានឱកាសចូលគាល់ ក៏ចតរទេះតម្រៀបជាប់គ្នាដោយជុំវិញ មានផ្ទៃដីរាប់គាវុត ដូចជា **អគ្គិកាវិទ្ធ-ព្រាហ្មណ៍** ជាគំរូជាដើម ។ បើពោលឲ្យល្អិត អ្នកសិក្សាគប្បីជ្រាបបានតាមន័យដែលមកហើយក្នុងខន្ធកៈ និងក្នុងសូត្រនោះ ។

ព្រះមានព្រះភាគ មានលាភសក្ការៈកើតឡើងច្រើនយ៉ាងណា ភិក្ខុសង្ឃក៏មានដូច្នោះដូចគ្នា ។ សេចក្តីនេះសមដោយពាក្យអះអាង ដែលព្រះអានន្ទពោលទុកដូច្នេះថា សម័យនោះឯង ព្រះមានព្រះភាគ គេធ្វើសក្ការៈ គោរពរាប់អាន បូជា កោតក្រែង បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាប្រក្រតី សូម្បីភិក្ខុសង្ឃ ក៏គេធ្វើសក្ការៈ ។បេ។ ដែរ ។

ព្រះមានព្រះភាគ ទ្រង់ក៏បានត្រាស់ទុកដូចគ្នាថា ម្នាលចុន្ទ ពួក ឬគណៈដែលឧប្បត្តិកឡើងក្នុងលោក ឥឡូវនេះ មានចំនួនប៉ុនណា ពួក ឬគណៈដទៃ សូម្បីតែមួយក្រុម តថាគតក៏មើលមិនឃើញឡើយ ដែលនឹងបានទទួលលាភដ៏លើស និងយសដ៏លើស ដូចគ្នានឹងពួកភិក្ខុនេះឡើយ លាភសក្ការៈនោះ ដែលកើតឡើងដល់ព្រះមានព្រះភាគ និងភិក្ខុសង្ឃ រួមគ្នាហើយ ជារបស់ប្រមាណមិនបាន ដូចទឹកស្ទឹងធំ ២ ខ្សែ ដែលហូរមករួមគ្នាតែមួយ ក៏ជារបស់ប្រមាណមិនបាន ដូច្នោះ ។

ភិក្ខុទាំងឡាយបានក្លាយ ជាអ្នកជូន់ក្នុងបច្ច័យ ជាប់ក្នុងបច្ច័យ ងប់ជ្រប់

ក្នុងបច្ច័យតាមលំដាប់ សូម្បីក្នុងវេលាក្រោយកត្ត កាលមហាជននាំទេយ្យធម៌ មានប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើមមកប្រគេន ភិក្ខុទាំងនោះ កាលវាយ ជូនហើយ ក៏លាន់សំឡេងអឺងកងថា ឲ្យដល់អាចារ្យរបស់អាត្មាផង ឲ្យដល់ ឧបជ្ឈាយ៍របស់អាត្មាផង ការប្រព្រឹត្តរបស់ភិក្ខុទាំងនោះ ក៏បានប្រាកដលេចឮ ដល់ព្រះមានព្រះភាគ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់កើតធម្មសង្វេគថា សេចក្តីនេះ មិនសមគួរឡើយ ហើយទ្រង់តម្រិះថា តថាគតមិនអាចនឹងបញ្ញត្ត សិក្ខាបទហាមថា បច្ច័យជារបស់មិនសមគួរ ទាក់ទងនឹងការបំពេញសមណ-ធម៌របស់កុលបុត្រទាំងឡាយ ត្រូវអាស្រ័យបច្ច័យ តែណ្ហើយចុះ តថាគត នឹងសម្តែងធម្មទាយាទបដិបទា ( មតិកធម៌ ) ក៏អាចចាត់ថា ជាការបញ្ញត្ត សិក្ខាបទនៃកុលបុត្រទាំងឡាយ ដែលប្រាថ្នាចំពោះសិក្ខា និងដូចជាកញ្ចក់ សម្រាប់ឆ្លុះមើលបានជុំវិញខ្លួន ដែលបិទភ្ជាប់ទុកត្រង់ទ្វារក្រុង ។

អធិប្បាយថា មហាជនក្នុងវណ្ណៈទាំង ៤ ឃើញស្រមោលរបស់ខ្លួនក្នុង កញ្ចក់សម្រាប់ឆ្លុះមើលបានជុំវិញខ្លួន ដែលតាំងទុកត្រង់ទ្វារក្រុង រមែងកម្ចាត់ ទោស ហើយត្រឡប់ក្លាយជាអ្នកមិនមានទោស គឺមន្ទិល យ៉ាងណា កុល-បុត្រទាំងឡាយ ដែលប្រាថ្នាចំពោះសិក្ខា ក៏ដូច្នោះដូចគ្នា បំណងនឹងប្រដាប់ តាក់តែងដោយគ្រឿងប្រដាប់ គឺសេចក្តីព្យាយាម មកបង្អោនទឹកដល់ធម្ម-ទេសនា ដែលឧបមាដោយកញ្ចក់ឆ្លុះមើលបានជុំវិញខ្លួន ហើយនាំគ្នាវៀរ អាមិសទាយាទបដិបទា បែរមកបំពេញធម្មទាយាទបដិបទា ក៏នឹងអាចធ្វើជាតិ ជរា មរណៈឲ្យអស់ទៅបានឆាប់រួសរាន់នោះឯង ព្រះមានព្រះភាគបានត្រាស់

សូត្រនេះទុក ក៏ព្រោះមានរឿងយ៉ាងនេះកើតឡើង ។

[ ២១ ] ក្នុងព្រះសូត្រនោះ ព្រះតម្រាស់ដែលត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយ ចូរយកធម៌របស់តថាគតជាមត៌ក កុំយកអាមិសជាមត៌កឡើយ ដូច្នេះ ។ មានពាក្យអធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ ជាទាយាទនៃធម៌របស់តថាគតចុះ កុំជាទាយាទនៃអាមិសឡើយ គឺធម៌របស់តថាគតឯណា ចូរអ្នកទាំងឡាយ ជាអ្នកទទួលនូវធម៌នេះចុះ ឯតថាគតមានអាមិសណា ចូរអ្នកទាំងឡាយ កុំទទួលនូវអាមិសនោះឡើយ ។

ក្នុងព្រះតម្រាស់នោះ ធម៌មាន ២ យ៉ាង គឺនិប្បរិយាយធម៌ ១ បរិយាយធម៌ ១ ឯអាមិសក៏មាន ២ យ៉ាង គឺនិប្បរិយាយអាមិស ១ បរិយាយអាមិស ១ ។

ធម៌ក្តី អាមិសនោះក្តី មានអធិប្បាយដូចម្តេច ។

មានអធិប្បាយថា លោកុត្តរធម៌ទាំង ៩ ដែលចែកប្រភេទជាមគ្គ ៤ ផល ៤ និព្វាន ១ ឈ្មោះថា និប្បរិយាយធម៌ គឺធម៌ដែលអ្នកបដិបត្តិឲ្យកើតឡើងនោះឯង មិនមែនជាធម៌ដោយបរិយាយ គឺ ដោយអម ដោយហេតុ ឬដោយលេសណាមួយឡើយ ។ ឯកុសលដែលអាស្រ័យវិវដ្ដៈ គឺ និព្វាននេះដូចជាបុគ្គលពួកខ្លះក្នុងលោកនេះ ប្រាថ្នានូវវិវដ្ដៈ ទើបឲ្យទាន សមាទានសីល រក្សាឧបោសថ ធ្វើការបូជាព្រះរតនត្រ័យ ដោយសក្ការៈទាំងឡាយ មានគ្រឿងក្រអូប និងផ្កាកម្រងជាដើម ស្តាប់ធម៌ និងសម្តែងធម៌ ធ្វើឈាន និងសមាបត្តិឲ្យកើតឡើង បុគ្គលនោះធ្វើយ៉ាងនេះ រមែងបាននិប្បរិយាយធម៌ គឺ

អមតនិព្វានដោយលំដាប់ ។ ធម៌ដូចពោលមកនេះឯង ឈ្មោះថា **ធម្មបរិយាយ** ។ បច្ច័យ ៤ មានចីវរជាដើម ក៏ទំនងនេះ ឈ្មោះថា **អាមិសនិប្បរិយាយ** ដោយពិត មិនមែនជាអាមិសព្រោះបរិយាយដទៃឡើយ ឬព្រោះកិលេសដទៃឡើយ ឯកុសលដែលនាំទៅកាន់វដ្ដៈនេះ ដូចជាបុគ្គលពួកខ្លះក្នុងលោកនេះ ប្រាថ្នាវដ្ដៈ ប្រាថ្នាភពដែលមានសម្បត្តិ ទើបឲ្យទាន ។បេ។ ធ្វើសមាបត្តិឲ្យកើតឡើង បុគ្គលនោះធ្វើយ៉ាងនេះ រមែងបានទេវសម្បត្តិ មនុស្សសម្បត្តិដោយលំដាប់ កុសលដូចពោលមកនេះ ឈ្មោះថា អាមិសបរិយាយ ។

ក្នុងរឿងធម៌ និងអាមិសនោះ សូម្បីធម្មនិប្បរិយាយ ក៏ឈ្មោះថា ជាធម៌របស់ព្រះមានព្រះភាគ ទាក់ទងនឹងធម៌នោះ ព្រះមានព្រះភាគត្រាស់ប្រៀនប្រដៅទុក ទើបភិក្ខុទាំងឡាយ បានសម្រេចមគ្គផល និងនិព្វាន សេចក្ដីនេះសមដូចពាក្យសួរដែលពោលទុកដូច្នេះថា ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ជាអ្នកបង្កើតផ្លូវដែលមិនទាន់កើតឡើង ជាអ្នករៀបចំផ្លូវ ដែលគេមិនទាន់រៀបចំ ជាអ្នកប្រាប់ផ្លូវ ដែលគេមិនដែលប្រាប់ ជាអ្នកស្គាល់ផ្លូវ ដឹងផ្លូវ ឈ្លាសវៃក្នុងផ្លូវ ពួកសាវកក្នុងកាលឥឡូវនេះ គ្រាន់តែជាអ្នកដើរតាមផ្លូវ ប្រកបតាមជាខាងក្រោយ ដូច្នេះ ។ នឹងថា ម្នាលអាវុសោ ព្រោះថា ព្រះមានព្រះភាគនោះ ទ្រង់តែងជ្រាបនូវហេតុដែលគួរជ្រាប ទ្រង់ឃើញនូវហេតុដែលគួរឃើញ ព្រះតថាគតនោះ មានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌មិនវិបរិតកើតហើយ ព្រះអង្គជាបុរសដ៏ប្រសើរ ព្រះអង្គជាអ្នកពោលនូវធម៌ ។

ធម្មបរិយាយ ក៏ឈ្មោះថា ជារបស់ព្រះមានព្រះភាគដោយពិត ព្រោះព្រះមានព្រះភាគប្រៀនប្រដៅ ទើបសាវកទាំងឡាយដឹងយ៉ាងនេះថា បុគ្គលប្រាថ្នាវិវដ្តៈហើយឲ្យទាន ។បេ។ ធ្វើសមាបត្តិឲ្យកើត បាននិព្វានដែលជាអមតៈដោយលំដាប់ ។ ឯអាមិសនិប្បរិយាយ ក៏ឈ្មោះថា ជារបស់ព្រះមានព្រះភាគដូចគ្នា ព្រោះព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកនោះឯង ទើបភិក្ខុបានចីវរដែលប្រណីត ព្រោះទ្រង់ប្រារព្ធរឿងពេទ្យជីវកជាគំរូ ព្រះមានព្រះភាគក៏ត្រាស់ទុកជាគោលដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវគហបតិចីវរ ភិក្ខុណាប្រាថ្នា ( បង្សុកូល ) ភិក្ខុនោះ ចូរទ្រទ្រង់សំពត់បង្សុកូលចុះ ភិក្ខុណាប្រាថ្នា ( គហបតិចីវរ ) ភិក្ខុនោះ ចូរត្រេកអរនឹងគហបតិចីវរចុះ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត តថាគតពោលសរសើរសេចក្តីសន្តោស ដោយបច្ច័យណាមួយ ( តាមមានតាមបាន ) ។

ម្យ៉ាងទៀត ក្នុងកាលមុន ភិក្ខុទាំងឡាយមិនទាន់បានបិណ្ឌបាតប្រណីត ទើបសរសើរដុំបាយដែលស្វែងរកដោយកម្លាំងស្នែង ដោយការត្រាច់ទៅតាមលំដាប់ច្រកប៉ុណ្ណោះ ព្រោះព្រះមានព្រះភាគ កាលគង់នៅក្នុងក្រុងរាជគ្រឹះទ្រង់បានអនុញ្ញាតទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសង្ឃភត្ត ឧទ្ទេសភត្ត និមន្តនភត្ត សលាកភត្ត បក្ខិកភត្ត ឧបោសថិកភត្ត បាដិបទិកភត្ត ភិក្ខុទាំងនោះ បានភោជនប្រណីត សេនាសនៈក៏ទំនងដូចគ្នា ក្នុងកាលមុន ភិក្ខុទាំងឡាយ បានអាស្រ័យតាមទីផ្សេងៗ មានតាមញកភ្នំដែលមិនបានរៀបចំ និងតាមគល់ឈើ ព្រោះព្រះមានព្រះភាគទ្រង់អនុញ្ញាត

ទុកឯងយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសេនាសនៈ ៥ យ៉ាង ទើបភិក្ខុទាំងនោះបានសេនាសនៈទាំងនេះ គឺ វិហារ អឌ្ឍយោគ ផ្ទះ ឬប្រាសាទមានកំពូល និងគុហា ។

ម្យ៉ាងទៀត ក្នុងកាលមុន ភិក្ខុទាំងឡាយបានសម៉ាគ្រាំដោយទឹកនោមធ្វើជាថ្នាំ ព្រោះព្រះមានព្រះភាគ ទ្រង់អនុញ្ញាតទុកដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតភេសជ្ជៈ ៥ យ៉ាង គឺសប្បិ នវនីត ប្រេង ទឹកឃ្មុំ ទឹកអំពៅ ទើបភិក្ខុទាំងនោះបានភេសជ្ជៈច្រើនប្រភេទ ។

សូម្បីអាមិសបរិយាយ ក៏ឈ្មោះថា ជារបស់ព្រះមានព្រះភាគដូចគ្នា ព្រោះព្រះមានព្រះភាគត្រាស់ប្រៀនប្រដៅទុក ទើបសាវកទាំងឡាយដឹងយ៉ាងនេះថា បុគ្គលប្រាថ្នាកពដែលមានសម្បត្តិ ឲ្យទាន សមាទានសីល ។បេ។ ធ្វើសមាបត្តិឲ្យកើតហើយ រមែងបានអាមិសបរិយាយ គឺទិព្វសម្បត្តិ មនុស្សសម្បត្តិដោយលំដាប់ ។

ព្រោះធម្មនិប្បរិយាយផង ធម្មបរិយាយផង អាមិសនិប្បរិយាយផង អាមិសបរិយាយផង ឈ្មោះថា ជារបស់ព្រះមានព្រះភាគទាំងអស់ ដូច្នោះ កាលទ្រង់សម្តែងការៈដែលព្រះអង្គទ្រង់ជាម្ចាស់របស់ក្នុងធម៌ និងអាមិសនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរយកធម៌របស់តថាគតជាមត៌ក កុំយកអាមិសជាមត៌កឡើយ អធិប្បាយថា ធម៌ទាំង ២ យ៉ាងដែលជារបស់តថាគតឯណា ចូរអ្នកទាំងឡាយជាទាយាទនៃធម៌ទាំងនោះចុះ ឯអាមិសនោះក៏ជារបស់តថាគតដូចគ្នា ចូរអ្នកកុំជាទាយាទនៃ

អាមិសនោះឡើយ គឺចូរអ្នកទាំងឡាយជាម្ចាស់របស់តែចំពោះចំណែកនៃធម៌ប៉ុណ្ណោះចុះ កុំជាម្ចាស់ចំណែកនៃអាមិសឡើយ ព្រោះថា ភិក្ខុណាបួសក្នុងសាសនារបស់ព្រះជិនស្រី មានបច្ច័យជាទីបំផុត គឺឃើញដល់បច្ច័យ៤ ដែលជាហេតុឲ្យកើតតណ្ហា ដាក់ចោលនូវធុរៈក្នុងការបដិបត្តិធម៌សមគួរដល់ធម៌ ភិក្ខុរូបនេះ ឈ្មោះថា **អាមិសទាយាទ** អ្នកទាំងឡាយ កុំជាបុគ្គលយ៉ាងនោះឡើយ ឯភិក្ខុណាអាស្រ័យគុណធម៌ មានភាពជាអ្នកប្រាថ្នាតិចជាដើម ក្នុងបច្ច័យដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកឲ្យ ពិចារណាយ៉ាងល្អិតល្អន់ជាមុន ហើយសឹមសេព គឺបរិភោគ ជាអ្នកមានបដិបទាដ៏កំពូល ឃើញឯងតាំងនៅក្នុងអរិយវង្ស ៤ ភិក្ខុរូបនេះ ឈ្មោះថា **ធម្មទាយាទ** អ្នកទាំងឡាយចូរជាបុគ្គលដូច្នោះចុះ ។

ឥឡូវនេះ ជនពួកណា មានការគិតដូច្នេះថា ក្នុងអនាគតកាល នឹងមានឬមិនមានហ្ន៎ ព្រះមានព្រះភាគទ្រង់បំណងឲ្យសាវកទាំងឡាយបានលាភ ទើបត្រាស់យ៉ាងនេះ ដើម្បីទ្រង់សម្តែងដល់ជនទាំងនោះថា ព្រះតថាគតបំណងនឹងឲ្យសាវកទាំងឡាយបានលាភដែលប្រណីតក្រៃលែងជាងនេះ ទើបពោលយ៉ាងនេះ ទើបព្រះមានព្រះភាគត្រាស់ថា **អត្ថិ មេ តុម្ហេសុ ។បេ។ នោ អាមិស-ទាយាទា** ដូច្នេះ ( តថាគតមានសេចក្តីអនុគ្រោះចំពោះអ្នកទាំងឡាយ ។បេ។ កុំយកអាមិសជាមត៌ក ) ។

ព្រះពុទ្ធតម្រាស់នេះ មានអធិប្បាយដូច្នេះថា តថាគតមានការអនុគ្រោះអាណិតអាសូរ បំណងល្អ ឲ្យនូវប្រយោជន៍ដល់អ្នកទាំងឡាយថា ដោយ

ហេតុដូចម្តេចហ្ន៎ ដោយឧបាយដូចម្តេចហ្ន៎ ទើបសាវកទាំងឡាយ ជាធម្ម-ទាយាទ ជាម្ចាស់របស់ចំណែកនៃធម៌ មិនជាអាមិសទាយាទ ។

ម្យ៉ាងទៀត លោកបរិយាយទុកដូច្នេះថា បានឮថា ព្រះមានព្រះភាគទ្រង់ឃើញអ្នកបួសច្រើនរយជំពូក មានភិក្ខុ ភិក្ខុនី និងសិក្ខមានាជាដើម ក្នុងអតីតកាល គឺក្នុងសាសនារបស់ព្រះពុទ្ធអង្គមុន មានបដិបទាប្រាកដ មកដោយន័យថា សង្ឃាដីរបស់កបិលភិក្ខុក៏ត្រូវភ្លើងឆេះដូច្នេះជាដើម ហើយអ្នកបួសក្នុងសាសនារបស់ព្រះអង្គ ដូចទេវទត្តជាដើម ដែលជាអ្នកឃើញដល់អាមិស ធ្លាក់ចូលទៅក្នុងអាមិស ស្លាប់ហើយពេញក្នុងអបាយភូមិ តែទ្រង់ឃើញសាវក អ្នកជូន់ក្នុងធម៌ មានព្រះសារីបុត្រ ព្រះមហាមោគ្គល្លាន និងព្រះមហាកស្សបជាដើម ត្រឡប់បានសម្រេចគុណ មានអភិញ្ញា និងបដិ-សម្ភិទាជាដើម ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់ប្រាថ្នាឲ្យសាវកទាំងនោះរួចផុតដោយមិនមានសេសសល់អំពីអបាយភូមិ និងបានសម្រេចគុណធម៌ទាំងឡាយ ទើបត្រាស់ថា **អត្ថិ មេ តុម្ហេសុ អនុកម្បា កិន្តិ មេ សាវកា ធម្ម-ទាយាទា ភវេយ្យុំ នោ អាមិសទាយាទា** តថាគតមានសេចក្តីអនុគ្រោះចំពោះអ្នកទាំងឡាយថា ធ្វើដូចម្តេចហ្ន៎ ពួកសាវករបស់តថាគត គួរយកធម៌ជាមត៌ក កុំយកអាមិសជាមត៌កឡើយ ដូច្នេះ ។

ភិក្ខុអ្នកឃើញដល់បច្ច័យ រមែងអស់តេជះ អាប់អន់ពន្លឺ ក្នុងចន្លោះបរិសុទ្ធ ៤ ដូចគ្នានឹងកហាបណៈដែលប្រើការមិនកើត រងើកដែលរលត់ហើយ ដូច្នេះ ឯភិក្ខុមានចិត្តវិលត្រឡប់អំពីបច្ច័យនោះ ជាអ្នកជូន់ក្នុងធម៌

ប្រព្រឹត្តគ្របសង្កត់អាមិសជានិច្ច រមែងមានតេជះ ដូចគ្មានពឹងរាជសីហ៍ដូច្នោះ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះថា **អត្ថិ មេ ។បេ។ នោ អាមិសទាយាទា** ដូច្នេះ ។

កាលទ្រង់ចង្អុលបង្ហាញ ឲ្យយល់ក្នុងព្រះពុទ្ធតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរយកធម៌របស់តថាគតជាមត៌កចុះ កុំយកអាមិសជាមត៌កឡើយ តថាគតប្រាថ្នាឲ្យពួកសាវ័កបានលាភដែលប្រណីតជាងត្រាស់ទុកហើយដោយសេចក្ដីអនុគ្រោះ មិនមែនមិនត្រូវការឲ្យព្រះសាវ័កបានលាភឡើយយ៉ាងនេះហើយ កាលទ្រង់សម្ដែងទោសក្នុងការមិនព្រមធ្វើតាមឱវាទនេះ ក្នុងឥឡូវនេះ ទើបត្រាស់ថា **តុម្ហេ ច មេ ភិក្ខវេ ។បេ។ នោ ធម្មទាយាទា** ដូច្នេះ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ ។បេ។ មិនយកធម៌ជាមត៌ក ។

បណ្ដាបទទាំងនោះ បទថា **តុម្ហេបិ តេន អាទិស្សា ភវេយ្យាថ** សេចក្ដីថា សូម្បីពួកអ្នកក៏គប្បីត្រូវរង្កៀសដោយភាពជាអាមិសទាយាទនោះ មិនត្រូវរង្កៀសដោយធម្មទាយាទឡើយ ។ មានពាក្យអធិប្បាយថា អ្នកទាំងឡាយគប្បីត្រូវគេមើលងាយ គឺត្រូវធ្វើ បានដល់ កំណត់ទុកដោយឡែក ដោយអត្ថថា ត្រូវវិញ្ញូជនតិះដៀល ។

សួរថា តិះដៀលដូចម្ដេច ឆ្លើយថា តិះដៀលថា ពួកសាវ័ករបស់ព្រះ-សាស្ដា ជាអាមិសទាយាទ មិនជាធម្មទាយាទឡើយ ។

បទថា **អហម្បិ តេន អាទិស្សោ ភវេយ្យំ** សេចក្ដីថា សូម្បីតថាគត

ក៏ត្រូវគេតិះដៀលបាន ព្រោះធ្វើឲ្យអ្នកទាំងឡាយជាអាមិសទាយាទនោះ មិនមែនតិះដៀលដោយអ្នកទាំងឡាយជាធម្មទាយាទឡើយ ។

សួរថា ត្រូវតិះដៀលដូចម្ដេច ឆ្លើយថា ត្រូវតិះដៀលថា ពួកសាវករបស់ព្រះសាស្ដា រស់នៅដោយអាមិសទាយាទ មិនរស់នៅដោយធម្មទាយាទឡើយ ។

ពាក្យតិះដៀលនេះ ព្រះមានព្រះភាគត្រាស់ទុកដើម្បីធ្វើឲ្យភិក្ខុទាំងឡាយនោះក្លាយជាបុគ្គលទន់ភ្លន់ក្រៃលែងនោះឯង ។

ក្នុងព្រះពុទ្ធតម្រាស់នេះ មានអធិប្បាយដូច្នេះថា ម្នាលភិក្ខុទាំងឡាយអ្នកទាំងឡាយ កុំលិចចុះក្នុងអាមិស ត្រាច់ទៅឡើយ ព្រោះការលិចចុះក្នុងអាមិសរបស់ពួកអ្នក វិញ្ញូជនទាំងឡាយ ក៏នឹងនាំគ្នាតិះដៀលតថាគតថា ព្រះមានព្រះភាគ ទ្រង់ជាព្រះសព្វញ្ញូ ហេតុអ្វី ទើបមិនអាចធ្វើពួកសាវករបស់ព្រះអង្គឲ្យជាធម្មទាយាទ កុំឲ្យជាអាមិសទាយាទហ្ន៎ ប្រៀបដូចពួកអ្នកស្រុកឃើញមារយាទមិនសមគួរ រមែងតិះដៀលដល់អាចារ្យ និងឧបជ្ឈាយ៍ថា លោកទាំងនេះ ជាសទ្ធិវិហារិករបស់អ្នកណា ជាអន្តេវាសិករបស់អ្នកណា ម្យ៉ាងទៀត ប្រៀបដូចអ្នកក្នុងត្រកូលឃើញក្មេងប្រុស ឬក្មេងស្រីដែលមានត្រកូលជាមនុស្សមិនល្អ មានការប្រព្រឹត្តបោះបង់មារយាទ រមែងតិះដៀលដល់ឪពុកម្ដាយថា ពួកក្មេងនេះ ជាកូនប្រុសកូនស្រីរបស់អ្នកណា យ៉ាងណាវិញ្ញូជនទាំងឡាយ ក៏នឹងតិះដៀលតថាគតដូចគ្នា គឺតិះដៀលថា ព្រះមានព្រះភាគ ទ្រង់ជាសព្វញ្ញូ ហេតុអ្វី ទើបមិនអាចធ្វើពួកសាវករបស់ព្រះអង្គ

ឲ្យជាធម្មទាយាទ កុំឲ្យជាអាមិសទាយាទឡើយ ។

កាលទ្រង់សម្តែងទោស ក្នុងការមិនព្រមធ្វើតាមព្រះពុទ្ធោវាទយ៉ាងនេះហើយ កាលទ្រង់សម្តែងអានិសង្សក្នុងការព្រមធ្វើតាម ទើបព្រះមានព្រះភាគត្រាស់ថា **តុម្ហេ ច មេ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អហម្បិ តេន អាទិស្សោ ច ភវេយ្យំ** សេចក្តីថា ឧបមាដូចពួកអ្នកស្រុកឃើញពួកភិក្ខុកំលោះ ប្រព្រឹត្តវត្តបរិបូណ៌ដល់ព្រមដោយឧទ្ទេស និងបរិបុច្ឆា មានអាកប្បកិរិយាសមរម្យ ដូចគ្នានឹងព្រះថេរៈដែលមានវស្សា ១០០ ទើបសួរថា លោកម្ចាស់ទាំងនោះ ជាសទ្ធិវិហារិករបស់អ្នកណា ជាអន្តេវាសិករបស់អ្នកណា កាលមានបុគ្គលប្រាប់ថារបស់អាចារ្យ និងឧបជ្ឈាយ៍រូបនោះ ក៏នាំគ្នាសរសើរថា ព្រះថេរៈប្រហែលជាអាចក្នុងការដាស់តឿនប្រៀនប្រដៅ អាចារ្យ និងឧបជ្ឈាយ៍រមែងមិនត្រូវនិន្ទា មិនត្រូវតិះដៀល យ៉ាងណា សូម្បីតថាគតក៏ដូច្នោះក៏ដូចគ្នា គឺព្រោះអ្នកទាំងឡាយជាធម្មទាយាទនោះ មិនមែនដោយភាពដែលអ្នកទាំងឡាយ ជាអាមិសទាយាទឡើយ អ្នកស្រុកក៏នឹងនាំគ្នាសួរថា សាវ័ករបស់អ្នកណាហ្ន៎ បដិបត្តិនាលកបដិបទា បដិបត្តិតុវដកបដិបទា បដិបត្តិចន្ទូបមបដិបទា បដិបត្តិរថវិនីតបដិបទា បដិបត្តិមហាគោសិង្គសាលបដិបទា បដិបត្តិមហាសុញ្ញតាបដិបទា ជាបន្ទាល់ក្នុងអរិយវង្ស មានការសន្តោសក្នុងបច្ច័យ ៤ និងមានការនាជាទីត្រេកអរ មានចិត្តចៀសចេញឆ្ងាយចាកតម្រេកក្នុងបច្ច័យ ហើយទៅ ប្រៀបដូចព្រះចន្ទដែលប្រាសចាកពពក កាលមានមនុស្សប្រាប់ថា សាវ័ក

របស់ព្រះសមណគោតម ក៏នាំគ្នាសរសើរថា ព្រះមានព្រះភាគ ទ្រង់ជាសព្វញ្ញូពិតហ្ន៎ ទ្រង់មានសមត្ថភាពពិតហ្ន៎ ដែលទ្រង់ទូន្មានពួកសាវកឲ្យលះបង់អាមិសទាយាទបដិបទា ហើយបែរមកបំពេញបដិបទារបស់បុគ្គលជាធម្មទាយាទ ព្រះអង្គរមែងមិនត្រូវវិញ្ញូជនទាំងឡាយតិះដៀលយ៉ាងនេះឯង អ្នកសិក្សាជ្រាបពាក្យអធិប្បាយ ក្នុងបទនេះយ៉ាងនេះ ន័យល្អិតល្អន់ដ៏សេស គប្បីជ្រាបដោយន័យដែលផ្ទុយគ្នា នឹងន័យដែលពោលហើយក្នុងកណ្ហបក្ខ ( ចំណែកមិនល្អ ) ។

កាលទ្រង់សម្ដែងអានិសង្ស ក្នុងការព្រមធ្វើតាមព្រះឱវាទនេះយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ប្រគល់ព្រះឱវាទនោះ ទើបព្រះមានព្រះភាគត្រាស់ថា **តស្មាតិហ មេ ភិក្ខវេ ។បេ។ នោ អាមិសទាយាទា** ដូច្នេះ ។

[ ២២ ] ព្រះមានព្រះភាគ កាលទ្រង់ប្រគល់ព្រះពុទ្ធោវាទនេះ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សរសើរពួកភិក្ខុដែលបំពេញបដិបទារបស់បុគ្គលជាធម្មទាយាទនោះ ទើបមានព្រះពុទ្ធតម្រាស់ជាដើមថា **ឥធាហំ ភិក្ខវេ** ដូច្នេះ ។

ពិតហើយ ភិក្ខុទាំងឡាយ លុះបានស្ដាប់ព្រះតម្រាស់របស់ព្រះសាស្ដាហើយ រមែងនាំគ្នាបដិបត្តិដើម្បីភាពជាយ៉ាងនោះៗ ឯង ។

បណ្ដាបទទាំងនោះ បទថា **ឥធ** នេះ ជានិបាត ។

បទថា **ភុត្តាវី** ប្រែថា សោយស្រេចហើយ អធិប្បាយថា ទ្រង់ធ្វើភត្តកិច្ចហើយ ។

បទថា **បវារិតោ** ប្រែថា ព្រះមានព្រះភាគ ទ្រង់ហាមភត្តហើយដោយបវារណា ( ការហាម ) កាលគ្រប់គ្រាន់ដល់សេចក្ដីត្រូវការហើយ អធិប្បាយ

ថា ដោយហេតុល្មមដល់សេចក្ដីត្រូវការហើយ ទើបទ្រង់ហាមភោជន ឬទ្រង់ឆ្អែតហើយ ។

អធិប្បាយថា បវារណា ( ការព្រមឲ្យដាស់តឿន ការព្រមឲ្យសូម ការហាម ) មាន ៤ យ៉ាង គឺបវារណារបស់ភិក្ខុដែលចាំវស្សាហើយ ១ បវារណាដោយបច្ច័យ ១ បវារណាទាំងដែលមានរបស់នៅព្រម ១ បវារណាដើម្បីល្មមដល់សេចក្ដីត្រូវការហើយ ១ ។

ក្នុងបណ្ដាបវារណា ៤ នោះ បវារណាដែលមានពាក្យយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយដែលនៅចាំវស្សារួចហើយ បវារណាដោយស្ថាន ៣ យ៉ាង ដូច្នេះ ឈ្មោះថា **វស្សំ វុដ្ឋបវារណា** ។

បវារណា ដែលមានពាក្យយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចង់បវារណាព្រះសង្ឃ ដោយថ្នាំសម្រាប់កែរោគកំណត់ ៤ ខែ និងបវារណាមួយទៀតថា វៀរលែងតែគេបានបវារណាថែមទៀត វៀរលែងតែគេបានបវារណាជានិច្ច ឈ្មោះថា **បច្ចយបវារណា** ។

បវារណាដែលមានពាក្យយ៉ាងនេះថា ដែលឈ្មោះថា ហាមភោជន គឺភិក្ខុកំពុងឆាន់ ១ គេយកភោជនមកប្រគេនទៀត ១ គេនៅក្នុងហត្ថបាស ១ គេបង្អោនភោជនមកចំពោះ ១ ភិក្ខុហាមភោជន ១ នេះឈ្មោះថា **អនតិរិត្តបវារណា** ។

បវារណាយ៉ាងនេះ គឺ ( បោក្ខរសាតិព្រាហ្មណ៍ ) បានអង្គាសព្រះមានព្រះភាគ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯង ឲ្យឆ្អែត

ស្តាប់ស្គាល់ ឈ្មោះថា **យាវទត្ថបវារណា** ។

បវារណាដើម្បីល្មមដល់សេចក្ដីត្រូវការនេះ លោកបំណងយកហើយក្នុងទីនេះ ដោយហេតុនោះ ទើបបានពោលថា

បទថា **បវារិតោ** ប្រែថា ព្រះមានព្រះភាគ ទ្រង់ហាមកត្តហើយដោយការបវារណា កាលល្មមដល់សេចក្ដីត្រូវការហើយ ។

បទថា **បរិបុណ្ណោ** សេចក្ដីថា ទ្រង់បរិបូណ៌ហើយដោយភោជន ។

បទថា **បរិយោសិតោ** ប្រែថា មានភោជនដែលព្រះអង្គឲ្យដល់ទីបំផុតហើយ គឺឆាន់ស្រេចហើយ ។ ក្នុងបទថា **បរិយោសិតោ** នេះ គប្បីឃើញថាលោកលុបបទក្រោយ គឺ **ភោជនោ** ចេញ អធិប្បាយថា តថាគតគប្បីឆាន់ប៉ុនណា ក៏ឆាន់ប៉ុណ្ណោះ កិរិយា គឺការឆាន់របស់តថាគត ចប់សព្វគ្រប់ហើយ ។

បទថា **សុហិតោ** ប្រែថា ទ្រង់ឆ្អែតហើយ មា៉្យងទៀត ដោយអត្ថថាទ្រង់សុខសម្រាន្តហើយ ព្រោះមិនមានទុក្ខ គឺសេចក្ដីស្រេកឃ្លាន ។

បទថា **យាវទត្ថោ** សេចក្ដីថា សេចក្ដីត្រូវការដោយភោជនរបស់តថាគតមានប៉ុនណា សេចក្ដីត្រូវការទាំងអស់នោះ តថាគតបានសម្រេច គឺដល់ទីបំផុតហើយ ។

ក្នុងពាក្យទាំងនេះ គឺ **ភុត្តាវី បវារិតោ បរិបុណ្ណោ បរិយោសិតោ សុហិតោ យាវទត្ថោ** ៣ ពាក្យខាងក្រោយ មានអត្ថស្មើគ្នានឹង ៣ ពាក្យខាងដើម អធិប្បាយថា ភិក្ខុមានភោជនដែលខ្លួនឲ្យដល់ទីបំផុតហើយ ឈ្មោះថា មានភោជនដែលខ្លួនឆាន់ហើយ ភិក្ខុដែលឆ្អែតហើយ ឈ្មោះថា ហាមកត្ត

ហើយ ដោយការហាម ការល្មមដល់សេចក្តីត្រូវការហើយ ភិក្ខុដែលគ្រប់គ្រាន់ដល់សេចក្តីត្រូវការហើយ ឈ្មោះថា បរិបូណ៌ហើយ ម្យ៉ាងទៀត ៣ ពាក្យដំបូង មានអត្ថស្មើគ្នានឹង ៣ ពាក្យខាងក្រោយ អធិប្បាយថា ព្រោះភិក្ខុឆាន់ស្រេច ដូច្នោះ ទើបឈ្មោះថា មានភោជនដែលខ្លួនឲ្យដល់ទីបំផុតហើយ ព្រោះភិក្ខុហាមភត្តហើយ ដូច្នោះ ទើបឈ្មោះថា ឆ្អែតហើយ ព្រោះហេតុដែលភិក្ខុបរិបូណ៌ហើយ ដូច្នោះ ទើបឈ្មោះថា ល្មមដល់សេចក្តីត្រូវការដោយហេតុដូចពោលមកនេះ អ្នកសិក្សាគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់កំណត់អត្ថរបស់ពាក្យគ្រប់ពាក្យនោះ ហើយទើបត្រាស់ ។ បទថា **សិយា** ប្រើក្នុងអត្ថថា ជាចំណែកមួយ និងក្នុងអត្ថថា នឹកដោយក ។

ប្រើក្នុងអត្ថថា ជាចំណែកមួយ ដូចក្នុងប្រយោគជាដើមថា **បឋវីធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា** បឋវីធាតុខាងក្នុងក៏មាន ខាងក្រៅក៏មាន ។

ប្រើក្នុងអត្ថថា គិតដោយក គឺដូចក្នុងប្រយោគជាដើមថា **សិយា អញ្ញ-តរស្ស ភិក្ខុនោ អាបត្តិ សិយា វីតិក្កមោ** គង់មានភិក្ខុអង្គណាត្រូវអាបត្តិជាការប្រព្រឹត្តល្មើស ។ ក្នុងពាក្យនេះ ប្រើបានក្នុងអត្ថទាំង ២ ។

បិណ្ឌបាតច្រើនពេកនោះឯង ឈ្មោះថា ជារបស់សល់ជាធម្មតា និងធម្មតាក៏ត្រូវចោលទៅ ។ អធិប្បាយថា ជារបស់សេសសល់ផង ជារបស់ត្រូវចោលផង ទើបមិនចាំបាច់ធ្វើអ្វីដទៃ ។

បទនិបាតថា **អថ** គឺ **តម្ហិ** យោគជា **កាលេ** ប្រែថា ក្នុងកាលនោះ ។

បទថា **ជិឃច្ឆាទុព្វល្យបរេតា** សេចក្តីថា ដែលការឃ្លាន និងការ

ខ្សោយកម្លាំងគ្របសង្កត់ហើយ គឺប្រទូស្តហើយ បានដល់ ជាប់តាមហើយ ។

ក្នុងបណ្តាភិក្ខុទាំងនោះ ភិក្ខុពួកខ្លះ សូម្បីត្រូវឃ្លានគ្របសង្កត់មក ៨ ថ្ងៃខ្លះ ១០ ថ្ងៃខ្លះ ក៏មិនខ្សោយកម្លាំង គង់អាចសង្កត់ទុកបាន តែភិក្ខុ ២ រូបនេះ មិនដូច្នោះឡើយ ដើម្បីសម្តែងហេតុផលដូចពោលមកនេះ ទើបព្រះមានព្រះភាគត្រាស់ទុកទាំង ២ យ៉ាង ទាំងការឃ្លាន និងការខ្សោយកម្លាំង ។

បទថា **ត្យាហំ** កាត់បទជា **តេ អហំ** ប្រែថា តថាគត និងភិក្ខុ ២ រូបនោះ ។

ពីរបទថា **សចេ អាកង្ខថ** សេចក្តីថា បើអ្នកទាំងឡាយប្រាថ្នាសោត ។

បទថា **អបហរិតេ** ប្រែថា ប្រាសចាករបស់ខៀវស្រស់ដែលដុះឡើងហើយ អធិប្បាយថា ក្នុងទីដែលមិនមានស្មៅ ដែលធម្មតាត្រូវងាប់ទៅ ព្រោះត្រូវដុំបាយដែលធ្លាក់ទៅសង្កត់ ក្នុងទីដែលត្រូវចោលបិណ្ឌបាតទាំងរទេះ ក៏ស្មៅទាំងឡាយមិនងាប់ ទីនោះមិនមានស្មៅក៏ដោយ មានស្មៅច្រើនក៏ដោយ ឈ្មោះថា ព្រះមានព្រះភាគ ទ្រង់កំណត់ដល់ហើយដោយបទថា **អបហរិតេ** នោះ ។ បទថា **អបហរិតេ** នោះ ព្រះមានព្រះភាគត្រាស់ទុកដើម្បីមិនឲ្យភិក្ខុល្មើសក្នុងភូតគាមសិក្ខាបទ ។

បទថា **អប្បាណកេ** ប្រែថា មិនមានសត្វតូច គឺក្នុងទឹកច្រើន ដែលប្រាសចាកសត្វល្អិតដែលត្រូវស្លាប់ ព្រោះត្រូវដុំបាយដែលធ្លាក់ចូលទៅ ការពិត កាលទឹកតិច ដោយការចាក់បាយចូលទៅប៉ុណ្ណោះ ពួកសត្វតូចៗ នឹងស្លាប់ តែក្នុងទីទាំងឡាយ មានស្រះធំជាដើម ពួកសត្វតូចៗ មិនស្លាប់ឡើយ

ដើម្បីអនុរក្សសត្វមានជីវិតដូចពោលមកនេះឯង ទើបព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះ ។ បទថា **ឱបិលាបេស្សាមិ** ប្រែថា ចាក់ចោល សេចក្តីថា នឹងឲ្យលិចចុះ ។

បទថា **ឥតរេកស្ស** សេចក្តីថា ក្នុងបណ្តាភិក្ខុ ២ រូបនោះ មួយរូបមានការគិតយ៉ាងនេះថា ... តែព្រះមានព្រះភាគ ទ្រង់ត្រាស់សំដៅយកភិក្ខុរូបនោះ គឺភិក្ខុដែលតាំងចិត្តស្តាប់ធម្មទេសនានេះហើយ បង្អូរទឹកដល់រឿយៗ ។

ក្នុងបទថា **វុត្តំ ខោ បនេតំ** អធិប្បាយថា **វុត្ត** សព្ទនេះ ប្រើក្នុងអត្ថផ្សេងៗ គឺប្រើក្នុងអត្ថថា កោរសក់ ដូចក្នុងប្រយោគជាដើមថា **កាបដិកោ ឆាម មាណវោ ទហរោ វុត្តសិរោ** មាណពកំលោះម្នាក់ ឈ្មោះកាបទិកៈ មានក្បាលកោរ ១ ។

ប្រើក្នុងអត្ថថា ដាំបណ្តុះ ដូចក្នុងប្រយោគជាដើមថា **យថា សារទិកំ វីជំ ខេត្តេ វុត្តំ វិរូហតិ** ពូជក្នុងសរទកាល ( រដូវរំហើយ ) ដែលគេព្រោះក្នុងស្រែ រមែងលូតលាស់ យ៉ាងណាមិញ ១ ។

ប្រើក្នុងអត្ថថា ពោល ដូចក្នុងប្រយោគជាដើមថា **វុត្តមិទំ ភគវតា វុត្តមិទំ អរហតា** ពាក្យនេះ ព្រះមានព្រះភាគ ជាព្រះអរហន្តពោលទុកហើយ ១ ។

តែក្នុងទីនេះ អ្នកសិក្សាគប្បីឃើញថា ប្រើក្នុងអត្ថថា ពោល ។ ពាក្យថា **វុត្តំ ខោ បនេតំ** នោះ មានអធិប្បាយដូច្នេះថា **កថិតំ ខោ បនេតំ** ប្រែថា ព្រះមានព្រះភាគ ទ្រង់បានត្រាស់ពាក្យនេះទុកហើយថា ... ។

បទថា **អាមិសញ្ញតរំ** សេចក្តីថា អាមិស គឺបច្ច័យណាមួយ បណ្តាអាមិស គឺបច្ច័យ ៤ អធិប្បាយថា អាមិស គឺបច្ច័យណាមួយ ។

បទថា **យទិទំ** ជានិបាត មានរូបដូច្នោះនោះឯងក្នុងគ្រប់លិង្គ វិភត្តិ និងគ្រប់វចនៈ អ្នកសិក្សាគប្បីជ្រាបប្រើឲ្យត្រូវតាមអត្ថក្នុងលិង្គ វិភត្តិ និងវចនៈនោះៗ ។ តែក្នុងទីនេះ បទថា **យទិទំ** នោះ មានអត្ថស្មើ **យោ អយំ** ។ មានពាក្យអធិប្បាយទុកថា ឈ្មោះថា បិណ្ឌបាតនោះ បិណ្ឌបាតនេះជាអាមិសមួយដែរ ។

បទថា **យន្នូនាហំ** បានដល់ **សាធុ វតាហំ** ( ប្រែថា ល្អណាស់ហ្ន៎អាត្មាអញ ... ) ។

បទថា **ឃរំ** សេចក្តីថា សូម្បីបណ្តាយឲ្យថ្ងៃ និងយប់កន្លងទៅ ដូចបុគ្គលដែលខណៈនេះឲ្យកន្លងទៅក្នុងឥឡូវនេះ ។

បទថា **វីតិនាមេយ្យំ** ប្រែថា គប្បី... ឲ្យអស់ទៅ គឺគប្បីឲ្យកន្លងហួសទៅ ។

បទថា **សោ តំ បិណ្ឌបាតំ** សេចក្តីថា ភិក្ខុនោះ មិនឆាន់បិណ្ឌបាតនោះ តាមបែបអ្នកស្រុក ព្រមទាំងទេវលោក គប្បីទទួលទុកដោយសិរសាគឺដែលសេសសល់អំពីព្រះសុគតសោយហើយ បំណាងនូវភាពជាធម្មទាយាទពិចារណាដល់ឧបមាដោយបុគ្គល ដែលត្រូវភ្លើងឆេះក្បាលហើយ គប្បីបណ្តាយឲ្យយប់ និងថ្ងៃកន្លងទៅយ៉ាងនោះ ដោយការឃ្លាន និងការខ្សោយកម្លាំងនោះឯង ។

ក្នុងវារៈនេះថា **អថ ទុតិយស្ស** មានសេចក្តីសង្ខេបដូចតទៅនេះ បើភិក្ខុ

នោះ កាលគិតថា ល្អណាស់ អញ ។បេ។ គប្បីញ៉ាំងយប់ និងថ្ងៃឲ្យកន្លង ទៅ ក៏គប្បីគិតយ៉ាងនេះ ដោយការដែលបព្វជិត នឹងស្វែងរកបិណ្ឌបាតក្នុង ភូមិស្រុក ដែលដេរដាសដោយសត្វកាច គឺបញ្ចកាមគុណ ជាការលំបាក ដូចគ្មានឹងការស្វែងរកភេសជ្ជៈក្នុងព្រៃ ដែលស៊ុមទ្រុមទៅដោយសត្វកាច តែ បិណ្ឌបាតនេះ រួចផុតដោយឥតសេសសល់ ចាកទោស ក្នុងការស្វែងរកដូច ពោលមកនេះ និងបិណ្ឌបាតដែលជាសំណល់របស់ព្រះសុគត ព្រោះដូច្នោះ ទើបហាក់ដូចជាខត្តិយកុមារ ដែលជាឧភតោសុជាតិ ( គឺមានកំណើតល្អ ទាំង ខាងមាតា និងបិតា ) ។

ម្យ៉ាងទៀត បិណ្ឌបាតជារបស់ភិក្ខុមិនគួរឆាន់ ព្រោះហេតុ ៥ ប្រការ គឺជារបស់មិនគួរឆាន់ ព្រោះបុគ្គល គឺអ្នកប្រគេន មានសភាពគួរតិះដៀល គឺ ជាបិណ្ឌបាតរបស់អលជ្ជីបុគ្គល ១ ជារបស់មិនគួរឆាន់ ព្រោះបិណ្ឌបាតកើត ឡើងមិនបរិសុទ្ធ គឺកើតឡើងដោយការចាត់ចែងរបស់ភិក្ខុនី និងព្រោះការ សរសើរគុណដែលមិនមានក្នុងខ្លួន ១ ជារបស់មិនគួរឆាន់ ដើម្បីអនុគ្រោះ ម្ចាស់របស់ គឺភិក្ខុជាម្ចាស់បិណ្ឌបាតកំពុងស្រេកឃ្លាន ១ ភិក្ខុជាម្ចាស់របស់ បិណ្ឌបាតនោះឆ្អែតហើយ តែបិណ្ឌបាតជារបស់មិនគួរឆាន់ ដើម្បីអនុគ្រោះ ដល់អន្តេវាសិករបស់លោកនោះឯងជាដើម ព្រោះអន្តេវាសិក ឬជនដទៃៗ ដែលអាស្រ័យបិណ្ឌបាតនោះ កំពុងស្រេកឃ្លាន ១ សូម្បីជនទាំងនោះឆ្អែត ស្កប់ស្កល់ហើយ តែបិណ្ឌបាតក៏នៅតែជារបស់មិនគួរឆាន់ ព្រោះការមិនមាន សទ្ធា គឺភិក្ខុជាម្ចាស់របស់បិណ្ឌបាត មិនមានសទ្ធា ១ ។

បិណ្ឌបាតនេះក៏ផុតហើយដោយឥតសេសសល់អំពីហេតុទាំង ៥ ប្រការនោះ សេចក្តីពិត ព្រះមានព្រះភាគទ្រង់ជាកំពូលរបស់លជ្ជីបុគ្គលទាំងឡាយ បិណ្ឌបាតមានការកើតឡើងដោយបរិសុទ្ធ ហើយព្រះមានព្រះភាគ ក៏ទ្រង់ឆ្អែតស្កប់ស្កល់ហើយ ទាំងបុគ្គលដទៃដែលទទួលចំពោះក្នុងបិណ្ឌបាតក៏មិនមានជនពួកណាជាអ្នកមានសទ្ធាក្នុងលោក ព្រះមានព្រះភាគ ក៏ជាកំពូលរបស់ជនទាំងនោះ ដូច្នេះហើយ ភិក្ខុនោះ កាលគិតយ៉ាងនេះហើយ ទើបឆាន់បិណ្ឌបាតហើយ បណ្តោយឲ្យយប់ និងថ្ងៃកន្លងទៅ ។

ដោយហេតុផលដូចពោលមក មានប្រមាណប៉ុណ្ណោះ ភិក្ខុណាមិនឆាន់ ( បិណ្ឌបាតដែលជាសំណល់ព្រះសុគត ) បំពេញសមណធម៌ ភិក្ខុនោះឈ្មោះថា មិនឆាន់បិណ្ឌបាតដែលគួរឆាន់នោះឯង ឯភិក្ខុណា បានឆាន់ហើយបំពេញសមណធម៌ ភិក្ខុនោះ ឈ្មោះថា ឆាន់បិណ្ឌបាតដែលគួរឆាន់ដោយពិត ។ ការប្លែកគ្នាក្នុងបិណ្ឌបាតមិនមាន តែមានការប្លែកគ្នាក្នុងបុគ្គល ព្រោះដូច្នោះ កាលសម្តែងការប្លែកគ្នានោះ ទើបព្រះមានព្រះភាគត្រាស់ថា **កិញ្ចាបិ សោ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **កិញ្ចាបិ** ជានិបាត ប្រើក្នុងអត្ថថា ព្រមទទួល និងប្រើក្នុងអត្ថថា សរសើរ ។

សួរថា ព្រមទទួលនូវអ្វី ឆ្លើយថា នូវការឆាន់ដែលមិនមានទោសនោះរបស់ភិក្ខុនោះ ។ សួរថា សរសើរនូវអ្វី ឆ្លើយថា នូវការឆាន់ហើយបំពេញសមណធម៌ ។

មានពាក្យពោលអធិប្បាយទុកដូច្នេះថា បើភិក្ខុនោះ ឆាន់បិណ្ឌបាតដែលគួរបំពេញសោត កាលពោលដោយពិតហើយ ភិក្ខុអង្គដំបូងនោះឯង របស់តថាគត សេចក្តីថា ភិក្ខុអង្គដំបូងជាអ្នកបដិសេធបិណ្ឌបាតនោះហើយ បំពេញសមណធម៌នោះឯងរបស់តថាគត មើលទៅហាក់ដូចជាបុគ្គលក្សៀវក្លាជាងបណ្តាសាវ័ក ២ រូប របស់តថាគតដែលជាអ្នកក្សៀវក្លា និងហាក់ដូចជាបណ្ឌិតជាង ក្នុងបណ្តាសាវ័ក ២ រូបដែលជាសាវ័ករបស់តថាគត ឈ្មោះថាជាអ្នកគួរបូជាជាង និងគួរសរសើរជាង មានពាក្យអធិប្បាយថា គួរបូជា និងគួរសរសើរក្រៃលែងជាងភិក្ខុអង្គទី ២ ។

ឥឡូវនេះ កាលនឹងលើកហេតុឡើងមកពង្រីកនោះ ទើបព្រះមានព្រះភាគត្រាស់បទថា **តំ កិស្ស ហេតុ** ដូច្នេះជាដើម ។

ពាក្យនោះមានអធិប្បាយថា ក្នុងសេចក្តីនោះ អ្នកទាំងឡាយមានចម្ងល់ថា ព្រោះហេតុអ្វី ទើបភិក្ខុនោះជាអ្នកគួរបូជាជាង គួរសរសើរជាងរបស់ព្រះមានព្រះភាគ ។

ចម្លើយ គឺ **តញ្ហិ តស្ស** សេចក្តីថា ព្រោះការហាមបិណ្ឌបាតនោះប្រព្រឹត្តទៅដើម្បីការប្រាថ្នាតិច ។បេ។ ដើម្បីការប្រារព្ធសេចក្តីព្យាយាមអស់កាលយូរសម្រាប់ភិក្ខុនោះ ។

សេចក្តីនេះប្រព្រឹត្តទៅដូចម្តេច គឺភិក្ខុនោះ បើសម័យតមក នឹងកើតការចង់បាន ការប្រាថ្នាលាមក ឬការប្រាថ្នាច្រើន ក្នុងបច្ច័យទាំងឡាយ លំដាប់នោះ ភិក្ខុអង្គដទៃពិចារណាឃើញយ៉ាងនោះ នឹងរារាំងលោកបាន ដោយតម្ពក់

គឺការហាមបិណ្ឌបាតនេះថា នៃលោក លោកបដិសេធបិណ្ឌបាត ដែលជារបស់សំណល់ របស់ព្រះសុគត ហើយក៏កើតសេចក្តីប្រាថ្នាដូច្នេះឡើងបានឬ នេះជាន័យក្នុងការហាម ការមិនជុសខាត់កិលេសដែលកើតហើយ កាលបើដូច្នេះ ការបដិសេធបិណ្ឌបាតនោះ នឹងប្រព្រឹត្តទៅដើម្បីការប្រាថ្នាតិច ការសន្តោស និងការជុសខាត់កិលេស សម្រាប់លោកជាមុន ។ ក្នុងបទថា **សុភរតាយ** ដើម្បីភាពជាបុគ្គលចិញ្ចឹមងាយនេះ មានការពណ៌នាដូចតទៅនេះថា

ភិក្ខុរូបខ្លះក្នុងធម្មវិន័យនេះ ជាអ្នកចិញ្ចឹមក្រ ទំនុកបម្រុងលំបាក ទាំងដល់ខ្លួនឯង និងដល់ឧបដ្ឋាក ឯភិក្ខុរូបខ្លះ ជាអ្នកចិញ្ចឹមងាយ ទំនុកបម្រុងងាយ ទាំងដល់ខ្លួនឯង ទាំងដល់ឧបដ្ឋាក ។

សេចក្តីនេះដូចម្តេច អធិប្បាយថា ភិក្ខុរូបណាបានអាហារ មានរសជូរជាដើម ហើយនៅតែស្វែងរកអាហារដទៃ មានអាហារដែលមានរសមិនជូរជាដើម ចោលទ្រព្យរបស់ដែលបានក្នុងផ្ទះរបស់បុគ្គលមួយ ទុកក្នុងផ្ទះរបស់បុគ្គលមួយទៀត ត្រាច់ចារិកទៅរហូតអស់កាលសម្រាប់បិណ្ឌបាត ហើយមានបាត្រទទេ ត្រឡប់ចូលវត្ត ហើយដេក ភិក្ខុរូបនេះ រាប់ថា ជាអ្នកចិញ្ចឹមក្រសម្រាប់ខ្លួនឯង ឯភិក្ខុរូបណា សូម្បីទាយកប្រគេនបាយស្រូវសាលី សាច់ និងបាយជាដើម រហូតពេញបាត្រហើយ ក៏គង់សម្តែងទឹកមុខក្រញូវ និងការមិនពេញចិត្តក្រៃលែងទៅជាងនោះ កាលនឹងមើលងាយបិណ្ឌបាតនោះចំពោះមុខមនុស្សទាំងនោះថា ពួកអ្នកប្រគេនរបស់អ្វី ដូច្នេះ ទើបឲ្យដល់អនុ-

បសម្បន្ន មានសាមណេរ និងគ្រហស្ថជាដើម ភិក្ខុរូបនេះ ចាត់ថា ជាអ្នកចិញ្ចឹមក្រ សម្រាប់ឧបដ្ឋាកទាំងឡាយ ពួកអ្នកស្រុកឃើញលោក ក៏នាំគ្នាចៀសចេញ គឺនាំគ្នាពួនអំពីចម្ងាយនោះឯង ដោយនឹកតិះដៀលថា ភិក្ខុចិញ្ចឹមក្រ ពួកយើងនឹងមិនអាចចិញ្ចឹមលោកបាន ។

ឯភិក្ខុណា បានអាហារណាមួយ ជារបស់ប្រភេទល្អក្តី ប្រភេទថោកទាបក្តី មានចិត្តសន្តោស ឆាន់អាហារនោះហើយ ត្រឡប់ទៅវត្តធ្វើការងាររបស់ខ្លួន ភិក្ខុរូបនេះ ចាត់ថា ជាអ្នកចិញ្ចឹមងាយសម្រាប់ខ្លួន ។ ហើយភិក្ខុរូបណាមិនបានមើលងាយទានរបស់អ្នកដទៃ ទោះតិច ឬច្រើន ទោះល្អ ឬថោកជយក៏ដោយ មានចិត្តត្រេកអរ ទឹកមុខញញឹមញញែមស្រស់ថ្លា ឆាន់ចំពោះមុខមនុស្សទាំងនោះ ហើយទើបទៅ ភិក្ខុរូបនេះ ចាត់ថា ជាអ្នកចិញ្ចឹមងាយសម្រាប់អ្នកឧបដ្ឋាក ពួកអ្នកស្រុកកាលឃើញភិក្ខុរូបនោះហើយ ក៏នាំគ្នាត្រេកអរក្រៃលែងថា លោកម្ចាស់របស់ពួកយើង ជាអ្នកចិញ្ចឹមងាយ សន្តោសដោយអាហារបន្តិចបន្តួច ពួកយើងនឹងចិញ្ចឹមលោក កាលចុះសម្រុងហើយក៏នាំគ្នាទំនុកបម្រុងថែទាំ ។ ក្នុងព្រឹត្តិកម្មនោះ បើសម័យតមក លោកនឹងកើតការគិតឡើងក្នុងទំនង និងជាអ្នកចិញ្ចឹមលំបាក ទាំងដល់ខ្លួនឯង ឬឧបដ្ឋាកទាំងឡាយសោត គ្រានោះ ភិក្ខុរូបដទៃពិចារណាឃើញយ៉ាងនេះ ក៏នឹងជួយការពារលោកទុកដោយកង្វេរ គឺការបដិសេធបិណ្ឌបាតនេះថា នែលោកម្ចាស់ លោកម្ចាស់បដិសេធបិណ្ឌបាត ដែលជារបស់ព្រះសុគតហើយ ម្តេចមកកើតការគិតដូច្នេះឡើង ។ កាលបើយ៉ាងនេះ ការបដិសេធបិណ្ឌបាត នឹងប្រព្រឹត្ត

ទៅដើម្បីភាពជាអ្នកចិញ្ចឹមងាយសម្រាប់លោក ។

ម្យ៉ាងទៀត បើលោកកើតសេចក្ដីខ្ជិលច្រអូសឡើង ភិក្ខុអង្គដទៃក៏នឹងជួយការពារទុកដោយតម្កក់នោះដូចគ្នាថា នៃលោកម្ចាស់ លោកបដិសេធបិណ្ឌបាតដែលសល់អំពីព្រះសុគតហើយ គ្រានោះ សូម្បីត្រូវសេចក្ដីឃ្លាននិងការខ្សោយកម្លាំងគ្របសង្កត់ ក៏គង់បំពេញសមណធម៌បាន ហេតុអ្វី ទើបថ្ងៃនេះបែរមករកការខ្ជិលច្រអូសទៅវិញ កាលបើយ៉ាងនេះ ការបដិសេធបិណ្ឌបាត នឹងប្រព្រឹត្តទៅដើម្បីការប្រារព្ធសេចក្ដីព្យាយាមសម្រាប់លោក ការបដិសេធបិណ្ឌបាតនេះរបស់ភិក្ខុនោះ នឹងប្រព្រឹត្តទៅដើម្បីការប្រាថ្នាតិច ។បេ។ ដើម្បីប្រារព្ធសេចក្ដីព្យាយាម អស់កាលដ៏យូរដូចពោលមកនេះ ។

គុណ ៥ គឺការប្រាថ្នាតិច ១ សន្ដោស ១ ការជុសខាត់កិលេស ១ ភាពជាអ្នកចិញ្ចឹមងាយ ១ ការប្រារព្ធព្យាយាម ១ នៃភិក្ខុនោះបរិបូណ៌យ៉ាងនេះហើយ ក៏នឹងជួយឲ្យកថាវត្ថុ ១០ បរិបូណ៌ដូចម្ដេច អធិប្បាយថា ក្នុងចំនួនគុណធម៌ទាំង ៥ នោះ កថាវត្ថុ ៣ ប្រការ គឺភាពជាអ្នកប្រាថ្នាតិច ការសន្ដោស និងការប្រារព្ធព្យាយាមក្នុងព្រះបាលីនោះឯងរួមចូលគ្នា បានទៅជា-សល្លេខធម៌ ។ ព្រោះថា សល្លេខធម៌នេះ ជា ឈ្មោះរបស់កថាវត្ថុដូចគ្នាគ្រប់ប្រការ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលអានន្ទ កថាណាផូរផង់ ជាទីសប្បាយ ដល់ការពិចារណា តាមដំណើរចិត្តប្រព្រឹត្តទៅដើម្បីនឿយណាយ ដោយចំណែកមួយ ដើម្បីប្រាសចាករាគៈ ដើម្បីរំលត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីព្រះនិព្វាន គឺអប្បិច្ឆ-

កថា ( និយាយពីសេចក្តីប្រាថ្នាតិច ) ... ។

សេចក្តីពិស្តារដូចពោលមកនេះ គុណ ៥ ប្រការបរិបូណ៌ ក៏នឹងជួយឲ្យកថាវត្ថុ ១០ បរិបូណ៌បានយ៉ាងនេះ ។

កថាវត្ថុ ១០ បរិបូណ៌ក៏នឹងជួយឲ្យសិក្ខា ៣ បរិបូណ៌ សេចក្តីនេះដូចម្តេច អធិប្បាយថា ក្នុងកថាវត្ថុទាំង ១០ នោះ កថា ៤ គឺអប្បិច្ឆកថា ពោលអំពីការប្រាថ្នាតិច សន្តោសកថា ពោលអំពីការសន្តោស អសំសគ្គកថា ពោលអំពីការមិនច្រឡូកច្រឡំដោយពួកគណៈ សីលកថា ពោលអំពីសីល សង្គ្រោះចូលក្នុងអធិសីលសិក្ខាប៉ុណ្ណោះ កថា ៣ គឺបវិវេកកថា កថាពោលអំពីការស្ងាត់ វីរិយារម្ភកថា ពោលអំពីការប្រារព្ធសេចក្តីព្យាយាម សមាធិកថា ពោលអំពីសមាធិ សង្គ្រោះចូលក្នុងអធិចិត្តសិក្ខា កថា ៣ គឺបញ្ញាកថា ពោលអំពីបញ្ញា វិមុត្តិកថា ពោលអំពីវិមុត្តិ វិមុត្តិញាណទស្សនកថា ពោលអំពីវិមុត្តិញាណទស្សនៈ សង្គ្រោះចូលក្នុងអធិប្បញ្ញាសិក្ខា កថាវត្ថុ ១០ បរិបូណ៌នឹងជួយឲ្យសិក្ខា ៣ បរិបូណ៌យ៉ាងនេះ ។ សិក្ខា ៣ បរិបូណ៌ នឹងជួយឲ្យកងនៃអសេក្ខធម៌ ៤ យ៉ាងបរិបូណ៌ ។

បរិបូណ៌ដូចម្តេច អធិប្បាយថា អធិសីលសិក្ខាបរិបូណ៌ ក៏ជាពួកសីលដែលជាអសេក្ខៈនោះឯង អធិចិត្តសិក្ខាបរិបូណ៌ ក៏ជាពួកសមាធិ ដែលជាអសេក្ខៈ អធិប្បញ្ញាសិក្ខាបរិបូណ៌ ក៏នឹងជាពួកនៃបញ្ញាវិមុត្តិ និងវិមុត្តិញាណទស្សនៈដែលជាអសេក្ខៈនោះឯង ។

រួមសេចក្តីថា សិក្ខា ៣ បរិបូណ៌ នឹងជួយឲ្យពួកអសេក្ខធម៌ ៥ បរិបូណ៌

យ៉ាងនេះ ។ ពួកនៃអសេក្ខធម៌ ៥ បរិបូណ៌ ក៏នឹងជួយឲ្យអមតនិព្វាន បរិបូណ៌ ប្រៀបដូចដុំពពកក្រាស់មហិមា ប្រមូលផ្តុំជាទឹកភ្លៀងធ្លាក់ចុះលើកំពូលភ្នំ ហូរចុះមកពេញញកភ្នំ ជ្រោះ អូរ ។ ញកភ្នំ ជ្រោះ អូរទាំងនោះពេញហើយ ក៏ហូរមកពេញប្រឡាយ ប្រឡាយពេញហើយ ក៏ហូរមកពេញបឹង បឹងពេញហើយ ក៏ហូរមកពេញស្ទឹងតូច ស្ទឹងតូចពេញហើយ ក៏ហូរមកពេញស្ទឹងធំ ស្ទឹងធំពេញហើយ ក៏ហូរមកពេញសមុទ្រសាគរ យ៉ាងណាគុណ ៥ នេះ របស់បុគ្គលនោះ ក៏ដូច្នោះដូចគ្នា គឺបរិបូណ៌ហើយ នឹងជួយឲ្យគុណធម៌ផ្តើមតាំងអំពីកថាវត្ថុ ១០ រហូតដល់អមតនិព្វានឲ្យបរិបូណ៌ ភិក្ខុនេះបដិបត្តិបដិបទានៃធម្មទាយាទហើយ នឹងបានជាធម្មទាយាទយ៉ាងកំពូលដោយប្រការដូចពោលមកនេះ ព្រះមានព្រះភាគទ្រង់ឃើញប្រយោជន៍យ៉ាងនេះឯង ទើបបានត្រាស់ទុកថា **តំ កិស្ស ហេតុ តញ្ហិ តស្ស ភិក្ខវេ ភិក្ខុនោ** ដូច្នេះជាដើម ប្រែថា ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ការមិនឆាន់បង្ហាន់បិណ្ឌបាតនោះ អាចធ្វើឲ្យភិក្ខុនោះ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច ... ។

ព្រះមានព្រះភាគ កាលទ្រង់លើកហេតុដែលធ្វើឲ្យភិក្ខុនោះ ជាអ្នកគួរបូជា និងគួរសរសើរជាង អធិប្បាយប្រកបសេចក្តីយ៉ាងនេះ ឥឡូវនេះកាលទ្រង់សន្អត់ភិក្ខុទាំងនោះ ដើម្បីឲ្យមានសភាពយ៉ាងនោះ ទើបត្រាស់ថា **តស្មាតិហ មេ ភិក្ខវេ** ដូច្នេះជាដើម ។

ត្រាស់ដូចម្តេច ត្រាស់ថា ព្រោះហេតុដែលភិក្ខុឆាន់បិណ្ឌបាតនោះហើយ

បំពេញសមណធម៌ ជាអ្នកឆ្ងាយចាកគុណធម៌ ដែលជាឫសគល់ទាំង ៥ ប្រការនេះ ឯភិក្ខុដែលមិនធាន់ ហើយបំពេញសមណធម៌ នឹងជាអ្នកមានចំណែកនៃគុណធម៌ទាំងនោះដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកធម៌របស់ថាគតជាមត៌ក កុំយកអាមិសជាមត៌កឡើយ ។

បទថា **ឥទមវោច ភគវា** សេចក្ដីថា ព្រះមានព្រះភាគបានត្រាស់ពាក្យនេះ គឺឧបទេសនៃព្រះសូត្រថា តាំងអំពីចុងនិទានរហូតដល់កុំយកអាមិសជាមត៌ក ។

បទថា **ឥទំ វត្វាន សុគតោ** សេចក្ដីថា កាលត្រាស់ឧបទេសនៃព្រះសូត្រនេះហើយ ទើបព្រះមានព្រះភាគ បានទទួលការថ្វាយព្រះនាមថា ព្រះសុគតនោះឯង ព្រោះទ្រង់យាងទៅដោយបដិបទាដ៏ស្អាត ។

បទថា **ឧដ្ឋាយាសនា វិហារំ បាវិសិ** សេចក្ដីថា ស្ដេចក្រោកឡើងចាកបវរពុទ្ធាសនៈដែលគេក្រាលថ្វាយហើយ យាងទៅកាន់វិហារ គឺមហាគន្ធកុដិរបស់ព្រះអង្គ ។

សួរថា ក្នុងកាលបរិសទ្យមិនទាន់បែកខ្ញែកគ្នាត្រឡប់ទៅឡើយ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ក្រោកឡើងចាកពុទ្ធាសនៈចូលទៅកាន់វិហារ ឆ្លើយថា ដើម្បីទ្រង់លើកសរសើរព្រះធម៌ បានឮមកថា ព្រះពុទ្ធទាំងឡាយកាលទ្រង់យាងទៅកាន់វិហារ ក្នុងកាលទេសនាមិនទាន់ចប់ ក៏ទ្រង់ចូលទៅដោយហេតុ ២ ប្រការ គឺដើម្បីទ្រង់សរសើរបុគ្គល ១ ដើម្បីទ្រង់សរសើរព្រះធម៌ ១ ។

កាលទ្រង់ចូលទៅដើម្បីសរសើរបុគ្គល ទ្រង់ត្រិះរិះយ៉ាងនេះថា ពួកភិក្ខុដែលទទួលយកធម៌ រៀនយកឧទ្ទេសនេះ ដែលតថាគតសម្តែងដោយសង្ខេបហើយ តែនៅមិនទាន់បានចែកឲ្យពិស្តារ និងនាំគ្នាចូលទៅសាកសួរព្រះអានន្ទ ឬព្រះមហាកច្ចាយនៈ លោកទាំង ២ នោះ ក៏នឹងអធិប្បាយប្រហាក់ប្រហែលនឹងញាណរបស់តថាគត បន្ទាប់អំពីនោះ ពួកភិក្ខុដែលទទួលយកធម៌ នឹងត្រឡប់មកសួរតថាគតទៀត តថាគតក៏នឹងសរសើរអ្នកទាំង ២ ពួកនោះដល់ពួកភិក្ខុដែលទទួលយកធម៌នោះ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អានន្ទអធិប្បាយល្អហើយ កច្ចាយនៈក៏អធិប្បាយល្អហើយ សេចក្តីនេះ សូម្បីពួកអ្នកទាំងឡាយ គប្បីមកសួរតថាគតសោត តថាគតក៏នឹងអធិប្បាយសេចក្តីនោះ ដូចគ្នានោះឯង បន្ទាប់អំពីនោះ ភិក្ខុទាំងឡាយក៏នឹងកើតសេចក្តីគោរពក្នុងអ្នកទាំងពីរ ហើយនាំគ្នាចូលទៅរក សូម្បីអ្នកទាំងពីរក៏នឹងណែនាំភិក្ខុទាំងឡាយក្នុងអត្ថ និងធម៌ ភិក្ខុទាំងនោះ ដែលអ្នកទាំងពីរនោះណែនាំហើយ ក៏នឹងនាំគ្នាបំពេញសិក្ខា ៣ ធ្វើនូវទីបំផុតទុក្ខបាន ។

កាលទ្រង់ចូលទៅដើម្បីសរសើរព្រះធម៌ ទ្រង់ព្រះតម្រិះដូចដែលទ្រង់ព្រះតម្រិះក្នុងទីនោះឯងថា កាលតថាគតចូលទៅកាន់វិហារហើយ សារីបុត្រនៅក្នុងចំណោមបរិសទ្យនោះឯង នឹងសម្តែងធម៌តិះដៀលអាមិសទាយាទ នឹងសរសើរធម្មទាយាទដូចគ្នា ទេសនានេះដែលយើងទាំងពីរសម្តែងហើយយ៉ាងនេះ តាមមតិដែលប្រព្រឹត្តទៅក្នុងគន្លងតែមួយ និងជាទេសនាដ៏កំពូល និងជាគរុទេសនាហាក់បីដូចឆត្រថ្ម និងទូកដែលចតត្រង់កំពង់ហើយ ព្រោះអត្ថ

ថា ធ្វូនឱយ: ៤ បាន និងដូចជារថដែលទឹមដោយសេះអាជានេយ្យ ៤ ព្រោះអត្ថថា ជាហេតុឲ្យទៅកាន់ស្ថានសួគ៌ ។

ម្យ៉ាងទៀត ប្រៀបដូចកាលព្រះរាជាទ្រង់ចេញព្រះរាជបញ្ញត្តិក្នុងទីប្រជុំថា បុគ្គលដែលធ្វើខុសយ៉ាងនេះ ត្រូវពិន័យប៉ុណ្ណេះ ហើយទ្រង់ក្រោកចាកព្រះរាជអាសនៈ ឡើងកាន់ប្រាសាទ សេនាបតីដែលអង្គុយនៅក្នុងទីនោះ នឹងថែរក្សាការណ៍ឲ្យប្រព្រឹត្តទៅតាមព្រះបញ្ញត្តិនោះ យ៉ាងណា ទេសនាដែលតថាគតសម្តែងហើយ ក៏ដូច្នោះដូចគ្នា សារីបុត្រអង្គុយនៅត្រង់ទីប្រជុំនេះឯងនឹងសម្តែងសរសើរ ។ ទេសនាដែលតថាគត និងសារីបុត្រសម្តែងហើយតាមមតិរបស់យើងទាំងពីរ នឹងរុងរឿងមានកម្លាំង ដូចព្រះអាទិត្យក្នុងវេលាថ្ងៃត្រង់ ដូច្នោះ ។

ដើម្បីទ្រង់សរសើរធម៌ក្នុងទីនេះយ៉ាងនេះ ទើបព្រះមានព្រះភាគ ទ្រង់ក្រោកឡើងចាកពុទ្ធាសនៈ ចូលទៅកាន់វិហារ ។

ម្យ៉ាងទៀត ក្នុងឋានៈដូច្នេះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់បាត់ព្រះអង្គអំពីពុទ្ធាសនៈ ដែលប្រថាប់គង់នោះឯង ទ្រង់ចូលទៅកាន់វិហារដោយការយាងទៅដោយអំណាចចិត្ត ព្រោះបើព្រះមានព្រះភាគគប្បីយាងទៅដោយការទៅដោយព្រះកាយសោត បរិសទ្យទាំងអស់ដែលប្រជុំគ្នាក្នុងទីនោះក៏គង់នាំគ្នាហែហមព្រះមានព្រះភាគ ។ បរិសទ្យដែលជួបជុំគ្នានោះបែកខ្ញែកម្តងហើយ ក៏លំបាកដើម្បីប្រជុំគ្នាបានវិញ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគទ្រង់យាងទៅដោយអំណាចចិត្តនោះឯង ។

[ ២៣ ] កាលព្រះមានព្រះភាគយាងចូលទៅកាន់វិហារ ដោយអាការយ៉ាងនេះហើយ ព្រះសារីបុត្រគង់នៅក្នុងទីនោះឯង បំណងនឹងសរសើរធម៌នោះឲ្យស្រេបនឹងព្រះបំណងរបស់ព្រះមានព្រះភាគ ទើបបានពោលពាក្យនេះទុក ។ បណ្ដាបទទាំងនោះ បទថា **អាយស្មា** ជាពាក្យហៅបុគ្គលជាទីស្រឡាញ់ ។

បទថា **សារិបុត្តោ** ជានាមរបស់ព្រះថេរៈនោះឯង នាមនោះបានមកអំពីខាងមាតា មិនមែនបានមកអំពីខាងបិតាឡើយ ព្រោះព្រះថេរៈនោះជាកូនរបស់ព្រាហ្មណី ឈ្មោះរូបសារី ដូច្នោះ ទើបឈ្មោះថា សារីបុត្រ ។

បទថា **អចិរបក្កន្តស្ស** ប្រែថា ចៀសទៅមិនបានយូរ ។

ក្នុងបទថា **អាវុសោ ភិក្ខវេ** នេះ មានវិនិច្ឆ័យដូច្នេះ ។ ព្រះមានព្រះភាគទាំងឡាយ កាលទ្រង់ហៅសាវ័ក ក៏ទ្រង់ហៅថា **ភិក្ខវេ** ឯសាវ័កទាំង-ឡាយគិតថា យើងទាំងឡាយ សូមកុំស្មើនឹងព្រះពុទ្ធទាំងឡាយឡើយ ដូច្នេះហើយ ក៏ពោលថា **អាវុសោ** ជាមុនហើយ ទើបពោលថា **ភិក្ខវេ** ឯក្រោយម្យ៉ាងទៀត ភិក្ខុសង្ឃដែលព្រះសម្ពុទ្ធទាំងឡាយត្រាស់ហៅហើយ ក៏ទូលទទួលថា **ភទន្តេ** សង្ឃដែលសាវ័កទាំងឡាយហៅ ក៏ឆ្លើយទទួលថា **អាវុសោ** ។

បទថា **កិត្តាវតា** ក្នុងបទថា **កិត្តាវតា នុ ខោ អាវុសោ** នេះ ជាពាក្យសម្ដែងការកំណត់ ប្រែថា ដោយហេតុប៉ុន្មាន **នុ** អក្ខរៈ ប្រើក្នុងអត្ថនៃពាក្យសួរ **ខោ** អក្ខរៈ ត្រឹមតែជានិបាត ។

បទថា **សត្ថុ បវិវិត្តស្ស វិហរតោ** សេចក្ដីថា កាលព្រះសាស្ដាប្រថាប់

នៅដោយវិវេក ៣ គឺកាយវិវេក ចិត្តវិវេក និងឧបធិវិវេក ។

បទថា **វិវេកន្តានុសិក្ខន្តិ** សេចក្តីថា ព្រះសារីបុត្តសួរដល់អត្ថនេះថា ភិក្ខុមិនសិក្សាតាមនូវវិវេកទាំង៣ វិវេកណាមួយ ជាធម្មទាយាទបានដែរឬទេ។ សូម្បីសុក្កបក្ខ គឺ ចំណែកដែលល្អក៏ន័យនេះ ។ កាលព្រះថេរៈពោលយ៉ាងនេះហើយ ភិក្ខុទាំងឡាយបំណងនឹងស្តាប់អត្ថនោះ ទើបបានពោលថា **ទូរតោបិ ខោ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ទូរតោបិ** សេចក្តីថា អំពីខាងក្រៅដែនខ្លះ អំពីខាងក្រៅជនបទខ្លះ អធិប្បាយថា ចាកទីឆ្ងាយរាប់បាន ១០០ យោជន៍ខ្លះ ។ បទថា **សន្តិកេ** ប្រែថា ក្នុងទីជិត ។ បទថា **អញ្ញាតុំ** ប្រែថា ដើម្បីដឹង គឺដើម្បីយល់ ។ បទថា **អាយស្មន្តំយេវ សារិបុត្តំ បដិភាតុ** សេចក្តីថា សូមជាកិច្ចរបស់សារីបុត្រចុះ អធិប្បាយថា សូមឲ្យព្រះសារីបុត្រជួយបំភ្លឺ គឺពង្រីកអត្ថឲ្យជាចំណែករបស់ខ្លួនផងចុះ ។

ក្នុងសេចក្តីនេះ មានពាក្យអធិប្បាយដូចតទៅនេះថា ការពង្រីកសេចក្តីជាកិច្ចរបស់ព្រះសារីបុត្រ ឯការស្តាប់ ជាកិច្ចរបស់ពួកខ្ញុំ ពាក្យអធិប្បាយយ៉ាងនេះ សមនឹងលក្ខណៈរបស់សត្វ ។ ចំណែកអាចារ្យពួកខ្លះពោលថា បទថា **បដិភាតុ** គឺ **ឧិស្សតុ** ប្រែថា សម្តែង ។ អាចារ្យពួកខ្លះពោលថា **ឧបដ្ឋាតុ** ប្រែថា ចូរប្រាកដ ។

បទថា **ធារិស្សន្តិ** នឹងទ្រទ្រង់ចាំទុក បានដល់ នឹងរៀន ។

លំដាប់នោះ ព្រះថេរៈបំណងនឹងសម្ដែងធម៌ដល់ភិក្ខុទាំងឡាយនោះ ទើបពោលពាក្យថា **តេនហិ** ដូច្នេះជាដើម ។

ក្នុងបទថា **តេនហិ** នេះ មានអធិប្បាយថា បទថា **តេន** ជាតតិយាវិភត្តិ ។ **ហិ** អក្ខរៈ ជានិបាត ។ មានពាក្យអធិប្បាយថា ព្រោះហេតុដែលលោកទាំងឡាយបំណងនឹងស្ដាប់ នឹងពោលឲ្យជាការៈរបស់ខ្ញុំ ដូច្នោះ សូមលោកទាំងឡាយស្ដាប់ចុះ ។ ពួកភិក្ខុទទួលពាក្យរបស់ព្រះថេរៈហើយ ។ ព្រោះហេតុនោះ ទើបលោកពោលថា **ឯវមាវុសោ ។បេ។ បច្ចស្សោសុំ** ដូច្នេះ ។

[ ២៤ ] លំដាប់នោះ ព្រះសារីបុត្រកាលសម្ដែងអត្ថដែលព្រះមានព្រះភាគ ទ្រង់តិះដៀលភាពជាអាមិសទាយាទ ត្រាស់ទុកដោយអាការដូចគ្នានោះឯងថា សូម្បីលោកទាំងឡាយ ក៏គប្បីនឹងត្រូវតិះដៀលដោយភាពជាអាមិសទាយាទនោះ ដូច្នេះ ដោយអាការ ៣ យ៉ាងដល់ភិក្ខុទាំងនោះ ទើបបានពោលពាក្យនេះថា **ឥធាវុសោ ។បេ។ សាវកា វិវេកំ នានុសិក្ខន្តិ** ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះថេរៈបានពោលទុកហើយថា ព្រះមានព្រះភាគ កាលទ្រង់តិះដៀលបដិបទារបស់បុគ្គលជាអាមិសទាយាទឯណា សូម្បីលោកទាំងឡាយ ក៏គប្បីត្រូវតិះដៀលដោយបដិបទារបស់បុគ្គលជាអាមិសទាយាទនោះ ។ ព្រះថេរៈបានសួរសំណួរណាដោយខ្លួនឯងថា **កិត្តាវតា នុ ខោ ។បេ។ នានុសិក្ខន្តិ ។** អត្ថនៃពាក្យសួរនោះបែបពិស្ដារ ឈ្មោះថាព្រះថេរៈបានចែកទុកល្អហើយ ។

តែអត្ថនោះ មិនបានពឹងផ្អែកដល់ព្រះមានព្រះភាគ ត្រូវតិះដៀលផងដែរ

ឡើយ ។ ព្រោះព្រះពុទ្ធតម្រាស់ដែលត្រាស់ទុកហើយថា **អហម្បិ តេន អាទិស្សោ ភវិស្សាមិ** ប្រែថា សូម្បីតថាគតក៏នឹងត្រូវតិះដៀលដោយភាពជាអាមិសទាយាទនោះផងដែរ ជាព្រះតម្រាស់ដែលត្រឹមត្រូវហើយរបស់ព្រះមានព្រះភាគអង្គឯង ដែលបំណងសង្គ្រោះសាវក មិនមែនជាពាក្យរបស់សាវក ។ សូម្បីក្នុងចំណែកល្អ គឺសុក្កបក្ខក៏ន័យនេះ ។ ក្នុងវគ្គនេះ មានយោជនា គឺការប្រកបសេចក្ដីតាមលំដាប់នៃអនុសន្ធិមានប្រមាណប៉ុណ្ណេះ ។

ឯការពន្រឹកសេចក្ដីក្នុងរឿងនេះ ដូចតទៅនេះ បទថា **ឥធ** ប្រែថា ក្នុងសាសនានេះ ។

បទថា **សត្ថុ បវិវិត្តស្ស** សេចក្ដីថា កាលព្រះសាស្ដាទ្រង់ស្ងាត់ហើយយ៉ាងពិតដោយវិវេក ៣ ។

បទថា **វិវេកំ នានុសិក្ខន្តិ** សេចក្ដីថា មិនតាមសិក្សា គឺមិនបំពេញឲ្យបរិបូណ៌នូវកាយវិវេក ។ បើព្រះថេរៈគប្បីពោលអត្ថដល់វិវេកទាំង ៣ សោតពាក្យសួរក៏គង់មិនមានជាពិសេស ព្រោះថា វិវេកក្នុងពាក្យថា **វិវេកំ នានុ-សិក្ខន្តិ** នេះជាចំណែកនៃពាក្យព្យាករហើយ ព្រោះដូច្នោះ ទើបលោកសម្ដែងកាយវិវេកដោយបទនេះថា ( **វិវេកំ នានុសិក្ខន្តិ** ) សម្ដែងចិត្តវិវេកដោយបទថា **យេសញ្ច ធម្មានំ** និងសម្ដែងឧបធិវិវេកដោយបទថា **ពាហុល្លិកា** ដូច្នេះជាដើម ។ ក្នុងវគ្គនេះគប្បីជ្រាបដោយសង្ខេបដូចពណ៌នាមក ដូច្នេះ ។

ដោយបទថា **យេសញ្ច ធម្មានំ** ព្រះថេរៈពោលយកអកុសលធម៌ មានលោភៈជាដើម ដែលពោលទុកខាងមុខ ដោយន័យជាដើមថា នៃអាវុសោ

បណ្ដាអកុសលធម៌ទាំងនោះ លោភៈជាបាប ។

បទថា **ឧប្បជហន្តិ** បានដល់ មិនលះបង់ អធិប្បាយថា មិនបំពេញឲ្យបរិបូណ៌នូវចិត្តវិវេក ។

បទថា **ពាហុល្លិកា** សេចក្ដីថា បដិបត្តិដើម្បីភាពជាអ្នកងប់ជ្រប់ដោយបច្ច័យ មានចីវរជាដើម ។ ភិក្ខុទាំងនោះឈ្មោះថា **សាថិលិកា** ព្រោះរាប់អានសាសនាបែបធូរថយ ។

ក្នុងបទថា **ឱក្កមនេ បុព្វង្គមា** នេះ អធិប្បាយថា នីវរណៈ ៥ ហៅថា ឱក្កមនៈ ព្រោះជាហេតុឲ្យថោកទាប ភិក្ខុទាំងនោះរាប់ថា ជាប្រធាន ( អ្នកនាំ ) ដោយការធ្វើនីវរណៈ ៥ ឲ្យបរិបូណ៌ ។

បទថា **បវិវេកេ** គឺក្នុងឧបធិវិវេក បានដល់ ក្នុងព្រះនិព្វាន ។

បទថា **និក្ខិត្តធុរា** សេចក្ដីថា មានធុរៈដាក់ចុះហើយ គឺមិនមានការផ្ដើមសេចក្ដីព្យាយាមដើម្បីសម្រេចនិព្វាន ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះដែលលោកពោលទុកហើយថា មិនបំពេញឧបធិវិវេកឲ្យបរិបូណ៌ ។ ព្រះសារីបុត្តត្ថេរកាលពោលដោយមិនកំណត់ពិតប្រាកដ ដោយពាក្យមានប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ កាលនឹងកំណត់ទេសនាឲ្យពិតប្រាកដ ទើបពោលពាក្យជាដើមថា **តត្រាវុសោ** ដូច្នេះជាដើម ។

សួរថា ព្រោះហេតុអ្វី កាលព្រះថេរៈមិនកំណត់ពិតប្រាកដយ៉ាងនេះថា សាវកទាំងឡាយ រមែងត្រូវតិះដៀលដោយហេតុ ៣ ភិក្ខុទាំងនោះ រមែងនាំគ្នាសើរើរឿងនោះព្រះថេរៈពោលថា អ្នកដទៃមិនបានពោលថា ពួកយើង តែ

កាលព្រះថេរៈពោលកំណត់ពិតប្រាកដយ៉ាងនេះថា **ថេរា** គឺ ព្រះថេរៈ **នវា** គឺភិក្ខុថ្មី **មជ្ឈិមា** គឺភិក្ខុជាកណ្តាល ភិក្ខុទាំងនោះនាំគ្នាធ្វើការអើពើថា រឿងនេះព្រះថេរៈពោលចំពោះពួកយើង ។

ឆ្លើយថា ឧបមាដូចកាលពួករាជអមាត្យប្រាប់ប្រជាជនថា ត្រូវជួយគ្នាសម្អាតផ្លូវក្នុងក្រុង មហាជនសង្ស័យថា នរណានឹងត្រូវធ្វើការសម្អាត ហើយមិនមានបុគ្គលណាមួយចាប់ផ្តើមធ្វើការសម្អាត លុះតែវាយស្គរប្រកាសថា មហាជនត្រូវធ្វើការសម្អាតទ្វារផ្ទះរៀងៗ ខ្លួន អ្នកស្រុកទាំងអស់ ក៏នាំគ្នាធ្វើការសម្អាត និងតុបតែងលម្អឲ្យស្រស់ស្អាត ដោយប្រើវេលាត្រឹមមួយសន្ទុះយ៉ាងណា ឧបមេយ្យក៏គប្បីជ្រាបដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **តត្រ** បានដល់ **តេសុ** យោគជា **សាវកេសុ** ប្រែថា បណ្តាសាវកទាំងនោះ ។

ភិក្ខុទាំងឡាយដែលហៅថា ជាព្រះថេរៈ ព្រោះសំដៅយកភិក្ខុដែលមានវស្សា ១០ ឡើងទៅ ។

## អត្ថរបស់ ឋាន សព្ទ

បទថា **តីហិ ឋានេហិ** បានដល់ ដោយហេតុ ៣ យ៉ាង ។

**ឋាន** សព្ទនេះ ប្រើក្នុងអត្ថថា តំណែង ទិសដៅ ទីតាំងនៅ ទីស្ថិតនៅ ខណៈ និងហេតុ ។

**ឋាន** សព្ទ ប្រើក្នុងអត្ថថា តំណែង ដូចក្នុងប្រយោគជាដើមថា **កឹ បនាយស្មា ឆេវានមិច្ឆោ កម្មំ កត្វា ឥមំ ឋានំ បត្តោ** សក្កទេវរាជ

ស្តេចទេវតានេះ ធ្វើកម្មអ្វីទុក ទើបបានទទួលតំណែងនេះ ។

**ឋាន** សព្ទ ប្រើក្នុងអត្ថថា ទិសដៅ ដូចក្នុងប្រយោគជាដើមថា **ឋាន-កុសលោ ហោតិ អក្ខណវេធី** បុគ្គលឈ្លាសក្នុងទិសដៅ ជាអ្នកបាញ់ទាន់ផ្លេកបន្ទោរ ។

**ឋាន** សព្ទ ប្រើក្នុងអត្ថថា ខណៈ ដូចក្នុងប្រយោគជាដើមថា **ឋាន-សោវេតំ តថាគតំ បដិភាតិ** ពាក្យនេះជាក់ច្បាស់ចំពោះព្រះមានព្រះភាគដោយខណៈ គឺដោយឆាប់រហ័ស ។

**ឋាន** សព្ទ ប្រើក្នុងអត្ថថា ហេតុ ដូចក្នុងប្រយោគជាដើមថា **ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ** ស្គាល់ ហេតុដែលប្រព្រឹត្តទៅ ដោយការប្រព្រឹត្តទៅបានផង ស្គាល់ហេតុដែលប្រព្រឹត្តទៅមិនបានផង ។

តែក្នុងទីនេះ ប្រើក្នុងអត្ថថា ហេតុប៉ុណ្ណោះ អធិប្បាយថា ហេតុដែលហៅថា ឋានៈ ព្រោះជាទីតាំងនៅនៃផល ដោយមានការប្រព្រឹត្តទៅទាក់ទងនឹងផលនោះ ដោយហេតុទី ១ នេះ ព្រះថេរៈរមែងសម្តែងថា បទថា **គារយ្ហា** ក្នុងបទថា **ថេរា ភិក្ខូ គារយ្ហា** នេះ ប្រែថា គប្បីត្រូវតិះដៀល ។ ព្រះថេរៈទាំងឡាយនឹងត្រូវនិន្ទាយ៉ាងនេះថា ឈ្មោះថា ព្រះថេរៈហើយ មិនទាន់ចូលទៅកាន់សេនាសនៈដែលជាជួរព្រៃ គឺដែលស្ងាត់ក្នុងព្រៃ មិនព្រមលះបង់សេនាសនៈជិតស្រុក ត្រាច់ប្រឡូកប្រឡំដោយពួកគណៈ មិនបំពេញកាយវិវេកឡើយក្នុងវេលាដែលជានវកភិក្ខុ និងមជ្ឈិមភិក្ខុ លោកទាំងនេះ ប្រព្រឹត្តដូចម្តេចមកហើយហ្ន៎ គឺព្រះថេរៈទាំងឡាយ រមែងបានពាក្យតិះដៀលនេះឯង ។

សូម្បីក្នុងបទថា **ឧតិយេន** នេះ ព្រះថេរៈទាំងឡាយ នឹងត្រូវនិន្ទាយ៉ាង នេះថា ភិក្ខុទាំងនេះដល់នូវភាពជាព្រះថេរៈ តែមិនព្រមលះធម៌ មានលោភៈ ជាដើមដែលព្រះសាស្ដាត្រាស់ឲ្យលះ អន្តយក្នុងទីសមគួរនាចំណែកម្ខាង ក៏ មិនបាននូវភាពជាអប្បនាស្ងប់ម្ងាប់នៃចិត្ត សូម្បីមួយផ្ទាត់ម្រាមដៃ ក្នុងវេលា ដែលជានវកភិក្ខុ និងមជ្ឈិមភិក្ខុ លោកទាំងនេះ ( ប្រព្រឹត្ត ) ដូចម្ដេចមក ហើយហ្ន៎ គឺព្រះថេរៈទាំងឡាយរមែងបានទទួលពាក្យនិន្ទានេះ ។ គួរធ្វើការ ប្រកបសេចក្ដីដូចពណ៌នាមកយ៉ាងនេះ ។

សូម្បីក្នុងបទថា **តតិយេន** ( ដោយហេតុទី ៣ ) នេះ ព្រះថេរៈរមែង សម្ដែងថា អាវុសោ ព្រះថេរៈទាំងឡាយ នឹងត្រូវនិន្ទាយ៉ាងនេះថា ភិក្ខុទាំងនេះ ដល់នូវភាពជាព្រះថេរៈ តែក៏មិនញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបច្ច័យតាម មានតាមបាន មករវល់ប្រដាប់តាក់តែងចីវរ បាត្រ សេនាសនៈ និងកាយ ស្អុយ មិនព្រមបំពេញឧបធិវិវេក ក្នុងវេលាដែលជានវកភិក្ខុ និងមជ្ឈិមភិក្ខុ លោកទាំងនេះដូចម្ដេចមកហើយហ្ន៎ ព្រះថេរៈទាំងឡាយរមែងបានទទួលពាក្យ និន្ទានេះឯង ។ អ្នកសិក្សាគប្បីជ្រាបការប្រកបសេចក្ដីដូចពណ៌នាមកនេះ ។

ក្នុងវារៈជាមជ្ឈិមភិក្ខុ និងនវភិក្ខុក៏ន័យនេះ ។

ឯសេចក្ដីប្លែកគ្នាមានដូចតទៅនេះថា

ភិក្ខុទាំងឡាយ ដែលឈ្មោះថា **មជ្ឈិម** ព្រះថេរៈពោលសំដៅយកភិក្ខុ ដែលមានវស្សា ៥ រហូតដល់ភិក្ខុដែលមានវស្សា ៩ ដូច្នេះ ។ ភិក្ខុទាំង- ឡាយ ដែលឈ្មោះថា **នវ** ព្រះថេរៈពោលថា បានដល់ ភិក្ខុមានវស្សា ៥

ចុះមក ដូច្នេះ ។ ដូចជា វេលាជាព្រះថេរៈនោះ លោកពោលថា ភិក្ខុទាំង-ឡាយដែលជាថេរៈ ក្នុងវេលាដែលជានវកភិក្ខុ និងមជ្ឈិមភិក្ខុបានដូចម្តេចមកហើយ យ៉ាងណា ក្នុងវេលានេះក៏ដូច្នោះ គឺភិក្ខុជាមជ្ឈិម និងភិក្ខុថ្មី គប្បីប្រកបអធិប្បាយថា ក្នុងកាលជាភិក្ខុថ្មីបានដូចម្តេចមកហើយ ក្នុងកាលជាព្រះថេរៈនឹងបានដូចម្តេច ក្នុងកាលជាមជ្ឈិមភិក្ខុ និងជាព្រះថេរៈនឹងដូចម្តេចហ្ន៎ ។ ឯអត្ថក្នុងសុក្កបក្ខក៏គប្បីជ្រាបតាមន័យ ដែលផ្ទុយគ្នានឹងដែលពោលមកហើយក្នុងកណ្ហបក្ខនេះ ។ ឯក្នុងទីនេះមានសេចក្តីសង្ខេបដូចតទៅនេះថា

[ ២៥ ] ម្យ៉ាងទៀត ព្រះថេរៈទាំងឡាយ រមែងជាអ្នកគួរសរសើរ គឺរមែងបានទទួលការសរសើរដោយហេតុទី ១ ថា ភិក្ខុទាំងនេះ ទោះជាព្រះថេរៈក៏គង់នៅក្នុងសេនាសនៈដែលជាដងព្រៃ ក្នុងព្រៃដែលឆ្ងាយគ្នា រហូតរាប់យោជន៍ សូម្បីដល់វេលាដែលគួរនឹងចូលទៅជិតសេនាសនៈស្រុក ក៏មិនចូលទៅ ទោះមានរាងកាយជរាយ៉ាងនេះ ក៏គង់តស៊ូប្រារព្ធព្យាយាមធ្វើឲ្យបុគ្គលអ្នកប្រគេនបច្ច័យកើតការជ្រះថ្លា ក្នុងកាលដែលជានវកភិក្ខុ និងមជ្ឈិម-ភិក្ខុបានដូចម្តេចមកហើយ ដូច្នេះ លោកទាំងឡាយរមែងលះអកុសលធម៌មានលោភៈជាដើម បំពេញចិត្តវិវេកឲ្យបរិបូណ៌ ។

ដោយហេតុទី ២ នេះ ភិក្ខុទាំងឡាយ ដែលជាថេរៈ រមែងជាអ្នកគួរសរសើរ គឺរមែងបានទទួលការសរសើរថា ភិក្ខុនេះដល់នូវភាពជាព្រះថេរៈធំក្នុងវ័យ ដូច្នេះ ជាពេលគួរអន្តុយឲ្យសទ្ធិវិហារិក និងអន្តេវាសិកចោមរោមបានហើយ ឆាន់ស្រេចហើយ ក៏ចូលបន្ទប់បំពេញសមណធម៌ ពេលល្ងាច

ទើបចេញមក ចូលទៅពេលល្ងាចហើយ ពេលព្រឹក ទើបចេញមក ធ្វើបរិកម្មកសិណឲ្យសមាបត្តិកើត សម្រេចមគ្គផល បំពេញចិត្តវិវេកឲ្យបរិបូណ៌ដោយប្រការទាំងពួង ។

ដោយហេតុទី ៣ នេះ ព្រះថេរៈរមែងជាបុគ្គលគួរសរសើរ គឺរមែងបានទទួលការសរសើរថា ក្នុងកាលដែលព្រះថេរៈគួរប្រើចីវរស្រោល ដែលមានសម្ផស្សស្រួល ដូចសំពត់ធម្មតា សំពត់ធ្វើដោយសម្បកឈើ និងសំពត់ព្រៃជាដើម ព្រះមហាថេរៈក៏នៅតែស្លៀកដណ្តប់សំពត់បង្សុកូល ។ លោករាប់អានសាសនាយ៉ាងតឹងរ៉ឹង ប្រាសចាកនីវរណៈ និងផលសមាបត្តិ បំពេញឧបធិវិវេកឲ្យបរិបូណ៌ ( ក្នុងឥឡូវនេះ ក៏នៅតែបដិបត្តិបានបែបនេះ ) ក្នុងកាលដែលជានវកភិក្ខុ និងមជ្ឈិមភិក្ខុបានជា ( បដិបត្តិ ) ដូចម្តេចមកហើយ ។ ក្នុងវារៈដែលជាមជ្ឈិមភិក្ខុក៏មានន័យនេះ ។

[ ២៦ ] សួរថា ក្នុងបទថា **តត្រាវុសោ** មានអនុសន្ធិដូចម្តេច ។

ឆ្លើយថា ព្រះសារីបុត្តត្ថេរកាលតិះដៀលបដិបទារបស់បុគ្គល ជាអ្នកយកអាមិសជាមត៌កដោយអាការ ៩ យ៉ាង សរសើរបដិបទារបស់បុគ្គលដែលទទួលយកធម៌ជាមត៌កដោយអាការ ៩ យ៉ាង ញុំាងទេសនាឲ្យចប់សព្វគ្រប់ដោយអាការ ១៨ យ៉ាងនេះហើយ ដើម្បីសម្តែងដល់ធម៌ដែលគួរលះ ដែលលោកបានពោលទុកយ៉ាងនេះថា ព្រះសាស្តាត្រាស់ការលះធម៌ពួកណា ធម៌ពួកនោះ ភិក្ខុមិនទាន់លះបាន ដល់ភិក្ខុទាំងនោះដោយសរុបថា បានដល់ ធម៌ទាំងនេះ ទើបបានពោលពាក្យនេះថា **តត្រាវុសោ លោភោ ច** ដូច្នេះជាដើម

នេះ គឺអនុសន្ធិ ( ក្នុង ២ បទនោះ ) ។ ម្យ៉ាងទៀត ធម៌ទាំងឡាយ លោកបានពោលទុកដោយអមហើយខាងដើមនោះឯង ។ ឯអាមិសក៏បានពោលទុកហើយ ទាំងដោយអម ទាំងដោយត្រង់ ។

ឥឡូវនេះ កាលពោលធម៌ដោយត្រង់ គឺលោកុត្តរមគ្គ ទើបព្រះថេរៈបានពោលពាក្យនេះទុក ហើយក្នុងពាក្យនេះក៏មានអនុសន្ធិដូច្នេះ

បទថា **តត្រ** ជាបទសម្តែងដោយទេសនា ដែលកន្លងមកហើយ ។ មានពាក្យអធិប្បាយថា ក្នុងទេសនាដែលព្រះមានព្រះភាគត្រាស់ទុកដោយន័យជាដើមថា កាលព្រះសាស្តាទ្រង់នៅយ៉ាងស្ងាត់ ពួកសាវ័កបែរជាមិនសិក្សាតាមនូវវិវេក ។ ដោយពាក្យថា លោភៈជាបាបធម៌ ទោសៈជាបាបធម៌ ព្រះថេរៈរមែងសម្តែងថា ធម៌ទាំង ២ ប្រការនេះជាបាប គឺថោកទាប ដូច្នោះទើបធម៌នេះត្រូវលះបង់ ។

ក្នុងបណ្តាលោភៈ និងទោសៈទាំង ២ នោះ លោភៈមានលក្ខណៈចង់បាន ទោសៈមានលក្ខណៈប្រទូស្តចិត្ត ។

ក្នុងចំនួនលោភៈ និងទោសៈនោះ លោភៈមានដល់កិក្ខុដែលជាអាមិសទាយាទ ព្រោះការបានបច្ច័យទាំងឡាយ ។ ឯទោសៈមានព្រោះមិនមានលាភ គឺត្រូវការវត្ថុដែលមិនទាន់បាន ឬមានព្រោះទោសៈ គឺកាលមិនបាន ក៏នាំការចង្អៀតចង្អល់មកឲ្យ ។

លោភៈ មានព្រោះទេយ្យធម៌ ( របស់ធ្វើបុណ្យ ) ។ ឯទោសៈ មានព្រោះបុគ្គលដែលមិនប្រគេន ឬក្នុងបុគ្គលដែលប្រគេនរបស់មិនត្រូវចិត្ត ។

ព្រោះលោភៈ ទើបធ្វើឲ្យ ( អកុសល ) ធម៌ ដែលមានតណ្ហា ៩ យ៉ាង ជាមូលបរិបូណ៌ ។ ព្រោះទោសៈ ទើបធ្វើឲ្យមច្ឆរិយៈ ៥ យ៉ាងបរិបូណ៌ ។

ឥឡូវនេះ កាលសម្តែងឧបាយជាគ្រឿងលះលោភៈ និងទោសៈទាំងនោះ ទើបព្រះសារីបុត្តត្ថេរពោលថា **លោភស្ស ច ទោសស្ស ច បហានាយ** ដូច្នេះជាដើម ។ ពាក្យរបស់ព្រះថេរៈនោះ អធិប្បាយថា ជាមជ្ឈិមប្បដិបទា ដើម្បីលះលោភៈ និងទោសៈ ដែលជាបាបនោះ មាន ។ ពាក្យនេះ ព្រះថេរៈពោលសំដៅដល់មគ្គ ។ ព្រោះថា មគ្គមិនចូលជិត គឺមិនចូលទៅជិតអន្តធម៌ទាំង ២ គឺលោភៈ ជាអន្តធម៌ ១ ទោសៈជាអន្តធម៌ ១ ផុតហើយដោយឥតសេសសល់ អំពីអន្តធម៌ទាំង ២ នេះ ព្រោះដូច្នោះ ទើបហៅថា មជ្ឈិមប្បដិបទា ។ ដែលឈ្មោះថា **មជ្ឈិមា** ព្រោះនៅក្នុងចន្លោះអន្តធម៌ទាំង ២ នោះ ដែលឈ្មោះថា **បដិបទា** ព្រោះបុគ្គលដែលត្រូវការនិព្វានគប្បីបដិបត្តិ ។

ម្យ៉ាងទៀត កាមសុខល្លិកានុយោគ ជាអន្តធម៌ ១ អត្តកិលមថានុយោគក៏ជាអន្តធម៌ ១ សស្សតទិដ្ឋិក៏ជាអន្តធម៌ ១ ឧច្ឆេទទិដ្ឋិក៏ជាអន្តធម៌ ១ ព្រោះហេតុនោះ បណ្ឌិតគប្បីឲ្យពិស្តារដោយន័យដំបូងនោះចុះ ។

ព្រះសារីបុត្តត្ថេរ រមែងសរសើរបដិបទានោះឯង ដោយពាក្យថា **ចក្ខុករណី** ជាដើម ព្រោះថា បដិបទានោះ រមែងប្រព្រឹត្តទៅព្រម ដើម្បីការឃើញសច្ចៈទាំងឡាយ ដោយអត្ថថា ជាប្រធានក្នុងការឃើញ ព្រោះហេតុនោះ ទើបឈ្មោះថា **ចក្ខុករណី** រមែងប្រព្រឹត្តទៅព្រមដើម្បីដឹងនូវសច្ចៈ

ទាំងឡាយ ដោយអត្ថថា ជាហេតុឲ្យដឹងច្បាស់ ព្រោះហេតុនោះ ទើបឈ្មោះថា **ញាណករណី** ។

ម្យ៉ាងទៀត ឈ្មោះថា រមែងប្រព្រឹត្តទៅព្រមដើម្បីសេចក្តីស្ងប់ ព្រោះធ្វើឲ្យកិលេសទាំងឡាយ មានរាគៈជាដើមស្ងប់ ឈ្មោះថា រមែងប្រព្រឹត្តទៅព្រមដើម្បីអភិញ្ញា គឺការដឹងក្រៃលែង ព្រោះហេតុឲ្យឃើញថា សច្ចៈទាំង ៤ ជាធម៌ដែលគួរដឹងក្រៃលែង ។

មគ្គ ឈ្មោះថា សម្ពោធ គឺការត្រាស់ដឹង មជ្ឈិមប្បដិបទា ឈ្មោះថា ប្រព្រឹត្តទៅដើម្បីសម្ពោធ ព្រោះប្រព្រឹត្តទៅព្រមដើម្បីប្រយោជន៍ដល់មគ្គនោះ សេចក្តីពិត មគ្គនោះឯង រមែងប្រព្រឹត្តទៅព្រមដើម្បីប្រយោជន៍ដល់មគ្គ ។

ធម្មជាត ឈ្មោះថា ព្រះនិព្វាន ព្រោះធ្វើកិច្ចដែលមគ្គត្រូវធ្វើ តែបដិបទា លោកពោលថា ឈ្មោះថា ប្រព្រឹត្តទៅព្រមដើម្បីព្រះនិព្វាន ព្រោះប្រព្រឹត្តទៅព្រមដើម្បីធ្វើឲ្យជាក់ច្បាស់ គឺធ្វើឲ្យប្រចក្សនូវព្រះនិព្វាននោះ ទើបលោកពោលថា ប្រព្រឹត្តទៅព្រមដើម្បីព្រះនិព្វាន ។ អត្ថសំខាន់ក្នុងរឿងនេះមានប្រមាណប៉ុណ្ណេះ ។ ការពណ៌នាដទៃក្រៅអំពីនេះ ធ្វើឲ្យវែងឆ្ងាយទៅ ។

ឥឡូវនេះ ព្រះថេរៈ បំណងនឹងសម្តែងមជ្ឈិមប្បដិបទានោះដោយសរុប ទើបសួរថា **កតមា ច សា** ដូច្នេះហើយ វិសជ្ជនាដោយន័យជាដើមថា **អយមេវ** ។

បណ្តាបទទាំងនោះ បទថា **អយមេវ** ប្រែថា នេះប៉ុណ្ណោះ ជាពាក្យអវធារណៈ គឺហាមពាក្យដទៃ ព្រះថេរៈពោលពាក្យនេះទុកដើម្បីការបដិសេធ

មគ្គ គឺផ្លូវទៅកាន់និព្វានដទៃ ដើម្បីបានសម្តែងថា មគ្គនោះ ជារបស់មានទូទៅដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវករបស់ព្រះពុទ្ធ ។ សេចក្តីនេះសមដូចព្រះពុទ្ធតម្រាស់ថា ផ្លូវនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃទស្សនៈ ផ្លូវដទៃមិនមានទេ ។

មគ្គនេះ ឈ្មោះថា **អរិយ** ព្រោះធ្វើកិលេសឲ្យនៅឆ្ងាយខ្លះ ព្រោះប្រព្រឹត្តទៅព្រមដើម្បីលះសត្រូវ គឺកិលេសខ្លះ ព្រោះជាមគ្គដែលព្រះអរិយៈសម្តែងទុកខ្លះ ព្រោះប្រព្រឹត្តទៅព្រមដើម្បីឲ្យបានភាពជាព្រះអរិយៈខ្លះ ។ មគ្គឈ្មោះថា មានអង្គ ៨ ព្រោះប្រកបដោយអង្គ ៨ ដែលផុតចាកអង្គមិនមាន ប្រៀបដូចគ្រឿងតន្ត្រីប្រកបដោយអង្គ ៥ ដូច្នោះ ។ ដែលឈ្មោះថា មគ្គ ព្រោះអត្ថថា សម្លាប់កិលេសទាំងឡាយខ្លះ ដើរទៅកាន់និព្វានខ្លះ ដែលបុគ្គលត្រូវការនិព្វាន ស្វែងរកខ្លះ ដែលបុគ្គលត្រូវការនិព្វានទាំងនោះដើរទៅខ្លះ គឺបដិបត្តិខ្លះ ។

បទថា **សេយ្យថីទំ** ជានិបាត និបាត គឺ **សេយ្យថីទំ** នោះ មានអត្ថដូចគ្នានឹង **កតមោ សោ** ប្រែថា មគ្គនោះ គឺអ្វីខ្លះ ឬមានអត្ថដូចគ្នានឹង **កតមានិ តានិ អដ្ឋង្គានិ** ប្រែថា អង្គ ៨ នោះ គឺអ្វីខ្លះ ។

ពិតហើយ អង្គតែមួយ ក៏គឺមគ្គនោះឯង ។ សមដូចពាក្យដែលលោកពោលទុកថា សម្មាទិដ្ឋិជាមគ្គផង ជាហេតុផង ។ បុរាណាចារ្យទាំងឡាយក៏ពោលទុកថា សម្មាទិដ្ឋិ ជាផ្លូវ ជាហេតុឲ្យឃើញ សម្មាសង្កប្ប ជាផ្លូវ ជាហេតុឲ្យជាក់ចិត្ត ។បេ។ សម្មាសមាធិ ជាផ្លូវ ជាហេតុ មិនឲ្យរាយមាយ ។

មា៉ងទៀត ក្នុងបណ្តាអដ្ឋមគ្គទាំងឡាយ មានសម្មាទដ្ឋិជាដើមនេះ សម្មា-ទិដ្ឋិ មានការឃើញប្រពៃជាលក្ខណៈ សម្មាសង្កប្ប មានការត្រិះរិះដោយប្រពៃជាលក្ខណៈ សម្មាវាចា មានការហួងហែងជាលក្ខណៈ សម្មាកម្មន្តៈ មានការតាំងឡើងព្រមដោយធម៌ជាលក្ខណៈ សម្មាអាជីវៈ មានការផូរផង់ដោយប្រពៃជាលក្ខណៈ សម្មាវាយាមៈ មានការផ្គងចិត្តដោយប្រពៃជាលក្ខណៈ សម្មាសតិ មានការប្រុកដដោយប្រពៃជាលក្ខណៈ សម្មាសមាធិ មានការតាំងមាំនៃចិត្តដោយប្រពៃជាលក្ខណៈ សូម្បីវិគ្គហមគ្គទាំងនោះ ក៏គប្បីជ្រាបដោយន័យនោះដូចគ្នាថា ដែលឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះឃើញដោយប្រពៃក្នុងចំនួនមគ្គទាំងនោះ ។

សម្មាទិដ្ឋិ កាលកើតឡើងរមែងលះមិច្ឆាទិដ្ឋិ និងកិលេសដែលជាសត្រូវចំពោះសម្មាទិដ្ឋិនោះ និងអវិជ្ជាបាន ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ឃើញសម្បយុត្តធម៌ទាំងឡាយ និងឃើញសម្បយុត្តធម៌ទាំងនោះដោយមិនវង្វេង មិនមែនឃើញដោយភាពជាអារម្មណ៍ ព្រោះដូច្នោះ ទើបឈ្មោះថា **សម្មាទិដ្ឋិ** ។

សម្មាសង្កប្ប កាលកើតឡើង រមែងលះបាននូវមិច្ឆាសង្កប្ប និងកិលេស ដែលជាសត្រូវចំពោះសម្មាសង្កប្បនោះ ធ្វើនិព្វានឲ្យជាអារម្មណ៍ និងដាំបណ្តុះសម្បយុត្តធម៌ទាំងឡាយទុកក្នុងចិត្តដោយប្រពៃ ព្រោះហេតុនោះ ទើបហៅថា **សម្មាសង្កប្ប** ។

សម្មាវាចា កាលកើតឡើង រមែងលះបាននូវមិច្ឆាវាចា និងកិលេសដែលជាសត្រូវចំពោះសម្មាវាចានោះ ធ្វើនិព្វានឲ្យជាអារម្មណ៍ រក្សាសម្ប-

យុត្តធម៌ទាំងឡាយដោយប្រពៃ ព្រោះដូច្នោះ ទើបហៅថា **សម្មាវាចា** ។

សម្មាកម្មន្តៈ កាលកើតឡើង រមែងលះបាននូវមិច្ឆាកម្មន្តៈ និងកិលេសដែលជាសត្រូវចំពោះសម្មាកម្មន្តៈនោះ ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ និងញុំាងសម្បយុត្តធម៌ទាំងឡាយឲ្យតាំងឡើងដោយប្រពៃ ព្រោះដូច្នោះ ទើបហៅថា **សម្មាកម្មន្ត** ។

សម្មាអាជីវៈ កាលកើតឡើង រមែងលះបាននូវមិច្ឆាអាជីវៈ និងកិលេសដែលជាសត្រូវចំពោះសម្មាអាជីវៈនោះ ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ និងរមែងញុំាងសម្បយុត្តធម៌ទាំងឡាយ ឲ្យផូរផង់ដោយប្រពៃ ព្រោះដូច្នោះ ទើបហៅថា **សម្មាអាជីវ** ។

សម្មាវាយាមៈ កាលកើតឡើង រមែងលះបាននូវមិច្ឆាវាយាមៈ និងធម៌ដែលជាសត្រូវចំពោះសម្មាវាយាមៈនោះ និងធម៌ដែលខ្ជិលច្រអូស ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ និងរមែងទទួលទុកដោយប្រពៃនូវសម្បយុត្តធម៌ទាំង-ឡាយ ព្រោះដូច្នោះ ទើបហៅថា **សម្មាវាយាម** ។

សម្មាសតិ កាលកើតឡើង រមែងលះបាននូវមិច្ឆាសតិ និងកិលេសដែលជាសត្រូវចំពោះសម្មាសតិនោះ រមែងធ្វើនិព្វានឲ្យជាអារម្មណ៍ និងរមែងញុំាងសម្បយុត្តធម៌ទាំងឡាយ ឲ្យប្រាកដដោយប្រពៃ ព្រោះហេតុនោះ ទើបហៅថា **សម្មាសតិ** ។

សម្មាសមាធិ កាលកើតឡើងរមែងលះបាននូវមិច្ឆាសមាធិ និងកិលេសដែលជាសត្រូវចំពោះសម្មាសមាធិ និងការរាយមាយនោះ ធ្វើព្រះនិព្វានឲ្យជា

អារម្មណ៍ និងរមែងតាំងសម្បយុត្តធម៌ទាំងឡាយទុកដោយប្រពៃ ព្រោះដូច្នោះទើបហៅថា **សម្មាសមាធិ** ។

ឥឡូវនេះ ព្រះថេរៈ កាលពោលត្រូវបដិបទានោះ កាលពោលត្រូវទើបពោលថា **អយំ ខោ សា អាវុសោ** ដូច្នោះជាដើម ពាក្យដែលពោលនោះមានអធិប្បាយថា ធម៌មានអង្គ ៨ នោះឯណា ដែលព្រះមានព្រះភាគត្រាស់រួមលោកុត្តរធម៌ទាំង ៤ ចូលជាមួយគ្នាថា អាវុសោ មគ្គមានអង្គ ៨ នេះឯង គឺមជ្ឈិមប្បដិបទានោះ រមែងប្រព្រឹត្តទៅព្រម ។បេ។ ដើម្បីព្រះនិព្វាន ។

កាលសម្តែងលោភៈ ទោសៈ និងឧបាយជាគ្រឿងលះបង់លោភៈ និងទោសៈនោះ ក្នុងចំនួនធម៌ទាំងឡាយដែលត្រូវលះយ៉ាងនេះហើយ ឥឡូវនេះព្រះសារីបុត្តត្ថេរ កាលសម្តែងធម៌ដែលត្រូវលះដទៃទៀត និងឧបាយជាគ្រឿងលះធម៌ទាំងនោះ ទើបពោលពាក្យថា **តត្រាវុសោ កោធោ ច** ដូច្នេះជាដើមបណ្តាធម៌ដែលត្រូវលះទាំងនោះ

**កោធៈ** មានការក្តៅក្រហាយ ឬ មានការកាចជាលក្ខណៈ មានការចងអាឃាតជាកិច្ច មានការប្រទូស្តជាអាការប្រាកដ ។

**ឧបនាហៈ** មានការចងក្រោធទុក ជាលក្ខណៈ មិនព្រមលះបង់ការចងពៀរជាកិច្ច មានក្រោធជាប់រឿយៗ ជាអាការប្រាកដ សមដូចពាក្យដែលបុរាណាចារ្យពោលទុកយ៉ាងនេះថា កោធៈកើតមុន ទើបឧបនាហៈកើតតាមក្រោយជាដើម ។

**មក្ខៈ** មានការលុបគុណអ្នកដទៃជាលក្ខណៈ មានការធ្វើគុណអ្នកដទៃនោះ ឲ្យវិនាសជាកិច្ច មានការបិទបាំងគុណរបស់អ្នកដទៃជាអាការប្រាកដ ។

**បលាសៈ** មានការប្រកាន់នូវភាពជាគូប្រជែង គឺ វាយឫកស្មើ ជាលក្ខណៈ មានការធ្វើគុណរបស់ខ្លួនឲ្យស្មើនឹងគុណរបស់អ្នកដទៃជាកិច្ច មានការប្រមាណ គឺ វាយតម្លៃ ប្រៀបធៀប គុណរបស់អ្នកដទៃ ជាអាការប្រាកដ ។

**ឥស្សា** មានការច្រណែនចំពោះសម្បត្តិអ្នកដទៃ ឬអត់ធន់មិនបានចំពោះសម្បត្តិរបស់អ្នកដទៃនោះជាលក្ខណៈ មានការមិនត្រេកអរក្រៃលែងក្នុងសម្បត្តិរបស់អ្នកដទៃនោះជាកិច្ច មានការបែរមុខគេចចេញអំពីសម្បត្តិរបស់អ្នកដទៃនោះជាអាការប្រាកដ ។

**មច្ឆេរៈ** មានការលាក់នូវសម្បត្តិរបស់ខ្លួនជាលក្ខណៈ មានការមិនសប្បាយចិត្ត កាលសម្បត្តិរបស់ខ្លួន មានអ្នកដទៃប្រើប្រាស់ផងជាកិច្ច មានការកំណាញ់ស្វិតស្វាញជាអាការប្រាកដ ។

**មាយា** មានការបិទបាំងបាបដែលខ្លួនឯងធ្វើហើយជាលក្ខណៈ មានការលាក់នូវបាបដែលខ្លួនឯងធ្វើហើយនោះជាកិច្ច មានការបិទបាំងបាបដែលខ្លួនឯងធ្វើហើយនោះជាអាការប្រាកដ ។

**សាឋេយ្យ** មានការបួលចិត្តអួតគុណដែលខ្លួនឯងមិនមាន ជាលក្ខណៈ មានការប្រមូលមកនូវគុណដែលខ្លួនឯងមិនមានទាំងនោះជាកិច្ច មានការធ្វើគុណដែលខ្លួនឯងមិនមានទាំងនោះឲ្យប្រាកដចេញមក សូម្បីដោយអាការតាម

ផ្លូវកាយជាអាការប្រាកដ ។

**ថម្ភៈ** មានការរឹងត្អឹងជាលក្ខណៈ មានការប្រព្រឹត្តមិនកោតក្រែងជាកិច្ច មានការមិនទន់ភ្លន់ជាអាការប្រាកដ ។

**សារម្ភៈ** មានការធ្វើសេចក្តីល្អឲ្យនៅខាងលើជាលក្ខណៈ មានការសម្តែងខ្លួនជាសត្រូវចំពោះអ្នកដទៃជាកិច្ច មានការមិនគោរពជាអាការប្រាកដ ។

**មានះ** មានការលើកតម្កើងខ្លួនជាលក្ខណៈ មានការប្រកាន់ខ្លួន ថាជាអញជាកិច្ច មានការក្រអឺតក្រអោងជាអាការប្រាកដ ។

**អតិមានះ** មានការលើកតម្កើងខ្លួនក្រៃលែងជាលក្ខណៈ មានការប្រកាន់ខ្លួនថាជាអញ យ៉ាងមាំ ជាកិច្ច មានការវាយឫកខ្ពស់ក្រៃលែង ជាអាការប្រាកដ ។

**មទៈ** មានការស្រវឹងជាលក្ខណៈ មានការប្រកាន់ដោយការស្រវឹងជាកិច្ច មានការខុសប្រក្រតី ដូចមនុស្សឆ្កួតជាអាការប្រាកដ ។

**បមាទៈ** មានការបណ្តោយចិត្តទៅក្នុងបញ្ចកាមគុណជាលក្ខណៈ មានការបណ្តាលឲ្យចិត្តប្រហែសធ្វេសច្រើនឡើងជាកិច្ច មិនមានស្មារតីជាអាការប្រាកដ ។

អ្នកសិក្សាគប្បីជ្រាបដល់លក្ខណៈជាដើមនៃធម៌ទាំងនេះ ដូចពោលមកនេះចុះ ក្នុងទីនេះជាការពោលដោយសង្ខេប ឯសេចក្តីពិស្តារ អ្នកសិក្សាគប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងគម្ពីរវិភង្គនោះឯងថា **តត្ថ កតមោ កោធោ** ដូច្នេះជាដើម ។

ម្យ៉ាងទៀត ក្នុងធម៌ដែលត្រូវលះទាំងនេះ គប្បីជ្រាបដោយពិសេសទៅទៀត ដូចតទៅនេះថា

ភិក្ខុដែលជាអាមិសទាយាទ រមែងក្រោធនឹងអ្នកដទៃដែលបានលាភ ព្រោះខ្លួនឯងមិនបាន ការក្រោធដែលកើតឡើងមួយគ្រា នៃភិក្ខុដែលជាអាមិស-ទាយាទនោះ ឈ្មោះថា កោធៈតែម្យ៉ាង កោធៈដែលកើតឡើងមកច្រើនជាងមុនឡើងទៅ ឈ្មោះថា ឧបនាហៈ ។

ភិក្ខុដែលជាអាមិសទាយាទនោះឯង កាលក្រោធហើយផង ចងក្រោធទុកផង រមែងលុបគុណរបស់បុគ្គលដទៃដែលមានលាភ និងប្រកាន់ជាគូប្រណាំងប្រជែងថា សូម្បីអាត្មាអញ ក៏ត្រូវតែធ្វើដូច្នោះឲ្យបាន នេះជាមក្ខៈ គឺការលុបគុណ និងបលាសៈ គឺការវាយស្មើនៃភិក្ខុដែលជាអាមិសទាយាទនោះ ។

ភិក្ខុដែលជាអាមិសទាយាទនោះ មានប្រក្រតីលុបគុណ មានប្រក្រតីវាយស្មើដូចពោលមកហើយនេះ រមែងច្រណែន រមែងប្រទូស្តក្នុងលាភ និងសក្ការៈជាដើមនៃបុគ្គលដែលមានលាភនោះថា ភិក្ខុនេះមានប្រយោជន៍អ្វីដោយវត្ថុនេះ នេះជាឥស្សា គឺការច្រណែន ។

បើលោកមានសម្បត្តិឯណាមួយ រមែងអត់ធន់មិនបាន ដែលសម្បត្តិនោះមានអ្នកដទៃនោះរួមប្រើប្រាស់ នេះជាមច្ឆរៈ គឺការកំណាញ់នៃភិក្ខុដែលជាអាមិសទាយាទនោះ ។

ព្រោះលាភជាហេតុពិតៗ លោករមែងបិទបាំងទោសដែលមានរបស់ខ្លួន

នេះជាមាយារបស់ភិក្ខុ ដែលជាអាមិសទាយាទនោះ ។

លោករមែងអួតគុណដែលមិនមានពិត នេះជាសាថេយ្យ គឺការអួតអាង នៃភិក្ខុដែលជាអាមិសទាយាទនោះ ។

លោកបដិបត្តិយ៉ាងនេះ បើបានលាភតាមបំណង រមែងជាអ្នករឹងត្អឹង មានចិត្តមិនទន់ភ្លន់ ព្រោះលោកនោះ ជាបុគ្គលដែលបុគ្គលណាមួយមិនអាច នឹងពោលបានថា លោកមិនគួរធ្វើកម្មនេះយ៉ាងនេះ នេះជាថម្ភៈ គឺការរឹងត្អឹង របស់លោក ។

មានបុគ្គលណា ពោលពាក្យណាមួយនឹងលោកថា លោកមិនគួរធ្វើកម្ម យ៉ាងនេះ លោកជាអ្នកមានចិត្តប្រាថ្នាពាក្យពោលនោះ ធ្វើមុខក្រញូវ ចង ចិញ្ចើម ពោលកំហែងអ្នកដទៃថា លោកជាអ្វីនឹងខ្ញុំ នេះជាសារម្ភៈ គឺការ ប្រណាំងវាសនារបស់ភិក្ខុដែលជាអាមិសទាយាទនោះ ។

បន្ទាប់អំពីនោះទៅ ព្រោះថម្ភៈ គឺការរឹងត្អឹង លោកនឹងសម្គាល់ខ្លួនថា អញនេះឯងល្អជាងអ្នកដទៃ ជាអ្នកប្រកាន់ខ្លួនព្រោះសារម្ភៈ លោកត្រឡប់ មើលងាយអ្នកដទៃថា ពួកនេះជានរណា ជាអ្នកប្រកាន់ខ្លួន នេះជាមានះ និង អតិមានះនៃភិក្ខុដែលជាអាមិសទាយាទនោះ ។

ព្រោះមានះ និងអតិមានះទាំងនេះ លោករមែងកើតការស្រវឹង មានការ ស្រវឹងក្នុងជាតិ គឺកំណើត និងត្រកូលជាដើម លោកស្រវឹងហើយ រមែង ប្រមាទ គឺមិនមានសតិ ក្នុងវត្ថុទាំងឡាយ បែកប្រភេទចេញទៅ មានកាម- គុណជាដើម នេះជាមទៈ គឺការស្រវឹង និងបមាទៈ គឺការមិនមានស្មារតីនៃ

ភិក្ខុដែលជាអាមិសទាយាទនោះ ។

រួមសេចក្តីថា ដោយហេតុដូចពោលមកនេះ លោករមែងមិនផុតចាកភាពជាអាមិសទាយាទទៅបាន អ្នកសិក្សាគប្បីជ្រាបធម៌ដែលត្រូវលះ ក្នុងភាពជាអាមិសទាយាទដោយធម៌ដែលជាបាបទាំងនេះ និងដោយធម៌ពួកដទៃបែបនេះជាមុន ។ ឯឧបាយជាហេតុលះ ពោលដោយបាលី និងអត្ថហើយ ក៏មិនមានអ្វីពិសេសឡើយក្នុងធម៌គ្រប់ប្រការ ។

ដើម្បីការជាក់ច្បាស់នៃការប្រមូលការដឹង អ្នកសិក្សាគួរជ្រាបការផ្សេងគ្នា លំដាប់ និងវិធីនៃការចម្រើន ក្នុងឧបាយជាគ្រឿងលះបង់ដូចតទៅនេះថា

បណ្តាការផ្សេងគ្នា លំដាប់ និងវិធីនៃការចម្រើនទាំងនេះ នឹងអធិប្បាយដល់ការផ្សេងគ្នាជាមុន ។ មជ្ឈិមប្បដិទានេះ បានដល់ មគ្គ ដែលគ្រាខ្លះក៏មានអង្គ ៨ គ្រាខ្លះក៏មានអង្គ ៧ ព្រោះថា មគ្គនេះ កាលកើតឡើងដោយអំណាចបឋមជ្ឈានដែលជាលោកុត្តរ រមែងមានអង្គ ៨ ដែលកើតឡើងដោយអំណាចឈានដ៏សេស រមែងមានអង្គ ៧ តែក្នុងទីនេះ ជាការអធិប្បាយភាពជាន់ខ្ពស់បំផុត ទើបលោកពោលថា មគ្គមានអង្គ ៨ ។ អង្គមគ្គដែលកើតលើសអំពីនោះទៅមិនមាន អ្នកសិក្សាគប្បីជ្រាបការផ្សេងគ្នាក្នុងទីនេះមានប្រមាណប៉ុណ្ណោះ ។

ព្រោះសម្មាទិដ្ឋិប្រសើរបំផុត ក្នុងបណ្តាកុសលធម៌ទាំងពួង ដូចដែលលោកពោលថា បុគ្គលអ្នកឈ្លាសទាំងឡាយពោលថា បញ្ញានេះឯងប្រសើរបំផុត ។ សម្មាទិដ្ឋិនោះក៏ជាប្រធាន គឺអ្នកនាំ ក្នុងវារៈនៃការធ្វើកុសល

ដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ឯសម្មាទិដ្ឋិជាធម្មជាត ដល់មុន តើដូចម្ដេច បុគ្គលដឹងជាក់ច្បាស់នូវ នូវមិច្ឆាទិដ្ឋិ ថាជាមិច្ឆាទិដ្ឋិ ដឹងច្បាស់នូវសម្មាទិដ្ឋិ ថាជាសម្មាទិដ្ឋិ ដូច្នេះ និងសម្ដែងថា ម្នាលភិក្ខុទាំងឡាយ វិជ្ជាជាប្រធាននៃកុសលធម៌ទាំងឡាយ ក្នុងសមាបត្តិ ដូច្នេះ ។

ម្យ៉ាងទៀត អង្គមគ្គដ៏សេសទាំងឡាយ ដែលកើតឡើង ព្រោះមានសម្មាទិដ្ឋិនោះកើតមុន ដូចព្រះមានព្រះភាគត្រាស់ថា បុគ្គលដែលមានសម្មាទិដ្ឋិ រមែងមានសម្មាសង្កប្ប ។បេ។ បុគ្គលមានសម្មាសតិ រមែងមានសម្មាសមាធិ ។ ដូច្នោះ ទើបអង្គទាំងនេះ លោកពោលទុកដោយលំដាប់នេះ អ្នកសិក្សាគប្បីជ្រាបលំដាប់ ( នៃអង្គមគ្គ ) ក្នុងឧបាយជាគ្រឿងលះនេះ យ៉ាងនេះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា វិធីនៃការចម្រើន ( សមថៈ និងវិបស្សនា ) ដូច្នេះ ព្រះយោគាវចរអង្គខ្លះ ចម្រើនវិបស្សនាមានសមថៈជាអ្នកនាំមុខ អង្គខ្លះចម្រើនសមថៈមានវិបស្សនាជាអ្នកនាំមុខ សួរថា ចម្រើនដូចម្ដេច ឆ្លើយថា ចម្រើនយ៉ាងនេះ គឺព្រះយោគាវចរអង្គខ្លះ ក្នុងសាសនានេះ ធ្វើសមថៈ ឧបចារសមាធិ ឬអប្បនាសមាធិឲ្យកើតឡើង នេះជាសមថៈ បន្ទាប់មក ព្រះយោគាវចរនោះ ពិចារណាឃើញនូវសមាធិនោះ និងធម៌ដែលសម្បយុត្ត ដោយសមាធិនោះ ដោយការៈទាំងឡាយ មានភាពជារបស់មិនទៀងជាដើម នេះជាវិបស្សនាយ៉ាងនេះ សមថៈកើតមុន វិបស្សនាកើតឯក្រោយយ៉ាងនេះ

ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ចម្រើនវិបស្សនា មានសមថៈជាអ្នកនាំមុខ ។

កាលលោកចម្រើនវិបស្សនា មានសមថៈជាអ្នកនាំមុខ មគ្គរមែងកើតលោកសេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ រមែងលះសំយោជនៈទាំង-ឡាយបាន អនុស័យទាំងឡាយរមែងអស់ទៅយ៉ាងនេះ ព្រះយោគាវចរឈ្មោះថា ចម្រើនវិបស្សនា មានសមថៈជាអ្នកនាំមុខ ។

តែព្រះយោគាវចររូបខ្លះ ក្នុងសាសនានេះ មិនញុំាងសមថៈ មានប្រការដូចពោលហើយឲ្យកើតឡើង ពិចារណាឃើញឧបាទានក្ខន្ធ ៥ ដោយសភាវៈមានភាពជារបស់មិនទៀងជាដើម នេះជាវិបស្សនា ។ ឯកគ្គតានៃចិត្តកើតឡើងអំពីអារម្មណ៍ គឺការលះបង់ធម៌ដែលកើតឡើង ក្នុងវិបស្សនានោះ ព្រោះការបរិបូណ៌នៃវិបស្សនារបស់លោក នេះជាសមថៈយ៉ាងនេះ វិបស្សនាកើតមុន សមថៈកើតឯក្រោយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ចម្រើនសមថៈ មានវិបស្សនានាំមុខ កាលលោកចម្រើនសមថៈ មានវិបស្សនានាំមុខ មគ្គរមែងកើត លោកសេព ចម្រើន ធ្វើឲ្យច្រើន នូវមគ្គនោះ កាលលោកសេពមគ្គនោះ ។បេ។ អនុស័យទាំងឡាយ រមែងអស់ទៅយ៉ាងនេះឯង ព្រះយោគាវចរឈ្មោះថា ចម្រើនសមថៈ មានវិបស្សនានាំមុខ ចម្រើនវិបស្សនា មានសមថៈនាំមុខ កាលលោកចម្រើនវិបស្សនា មានសមថៈនាំមុខក្តី ចម្រើនសមថៈ មានវិបស្សនានាំមុខក្តី ក្នុងខណៈនៃ

លោកុត្តរមគ្គហើយ សមថៈនិងវិបស្សនា រមែងប្រព្រឹត្តទៅជាគូគ្នា គឺមិនបែកចេញអំពីគ្នា អ្នកសិក្សាគប្បីជ្រាបន័យនៃការចម្រើនសមថៈ និងវិបស្សនាក្នុងទីនេះ យ៉ាងនេះឯង ។

**ធម្មទាយាទសូត្រ ចប់**

**សូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ភយភេរវសូត្រទី ៤

[២៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ជាណុស្សោណិព្រាហ្មណ៍ ចូលសំដៅទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររឭក លួមឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

[ ២៨ ] លុះជាណុស្សោណិព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន កុលបុត្រទាំងឡាយណា ដែលចេញចាកផ្ទះ ហើយចូលកាន់ផ្នួសដោយសទ្ធាចំពោះព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន ទ្រង់ណែនាំកុលបុត្រទាំងនោះ ព្រះគោតមដ៏ចម្រើន ទ្រង់មានឧបការៈច្រើនដល់កុលបុត្រទាំងនោះ ព្រះគោតមដ៏ចម្រើន ទ្រង់ឲ្យកុលបុត្រទាំងនោះសិក្សា ( នូវសិក្ខា មានអធិសីលសិក្ខាជាដើម ) ឯប្រជុំជនទាំងនោះ ក៏យកតម្រាប់តាមព្រះគោតមដ៏ចម្រើនមែនឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ សេចក្តីនេះយ៉ាងហ្នឹងហើយ ម្នាលព្រាហ្មណ៍ សេចក្តីនេះយ៉ាងហ្នឹងហើយ ម្នាលព្រាហ្មណ៍ កុលបុត្រទាំងឡាយណា ដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួសដោយសទ្ធាចំពោះតថាគត តថាគតជាអ្នកណែនាំកុលបុត្រទាំងនោះ តថាគតជាអ្នកមានឧបការៈច្រើនដល់កុលបុត្រទាំងនោះ តថាគតជាអ្នកឲ្យ

កុលបុត្រទាំងនោះសិក្សា ( នូវសិក្ខា មានអធិសីលសិក្ខាជាដើម ) ឯប្រជុំជននោះក៏យកតម្រាប់តាមតថាគតមែន ។

[ ២៩ ] បពិត្រព្រះគោតមដ៏ចម្រើន សេនាសនៈដ៏ស្ងាត់តាំងនៅក្នុងព្រៃជិត ឬព្រៃឆ្ងាយ ជាទីដែលបុគ្គលធន់ទ្រាំនៅបានដោយកម្រ វិវេកបុគ្គលធ្វើបានដោយកម្រ ត្រេកអរបានដោយកម្រ ព្រៃទាំងនោះ ហាក់ដូចជាដឹកនាំចិត្តនៃភិក្ខុ ដែលមិនបានសមាធិក្នុងទីស្ងាត់ មែនឬទេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ សេចក្ដីនេះយ៉ាងហ្នឹងហើយ ម្នាលព្រាហ្មណ៍ សេចក្ដីនេះយ៉ាងហ្នឹងហើយ ម្នាលព្រាហ្មណ៍ ព្រោះថា សេនាសនៈស្ងាត់តាំងនៅក្នុងព្រៃជិត ឬព្រៃឆ្ងាយ ជាទីដែលបុគ្គលធន់ទ្រាំនៅបានដោយកម្រ វិវេក បុគ្គលធ្វើបានដោយកម្រ ត្រេកអរដោយកម្រ ព្រៃ ( ទាំងនោះ ) ហាក់ដូចជាដឹកនាំចិត្តនៃភិក្ខុដែលមិនបានសមាធិក្នុងទីស្ងាត់មែន ។

[ ៣០ ] ម្នាលព្រាហ្មណ៍ សូម្បីតែតថាគតនៅជាពោធិសត្វនៅឡើយក្នុងកាលមុនដែលមិនទាន់បានត្រាស់ដឹងនូវសម្ពោធិញ្ញាណ មានសេចក្ដីត្រិះរិះដូច្នេះថា សេនាសនៈស្ងាត់តាំងនៅក្នុងព្រៃជិត ឬព្រៃឆ្ងាយនេះឯង ជាទីដែលបុគ្គលធន់ទ្រាំនៅបានដោយកម្រ វិវេក បុគ្គលធ្វើបានដោយកម្រ ត្រេកអរបានដោយកម្រ ព្រៃ ( ទាំងនោះ ) ហាក់ដូចជាដឹកនាំចិត្តនៃភិក្ខុដែលមិនបានសមាធិក្នុងទីស្ងាត់ ។

[ ៣១ ] ម្នាលព្រាហ្មណ៍ តថាគតនោះឯង មានសេចក្ដីត្រិះរិះដូច្នេះថា សមណព្រាហ្មណ៍ណាមួយ ដែលមានកាយកម្មមិនបរិសុទ្ធ សេពនូវសេនា-

សទ្ទះស្ងាត់ តាំងនៅក្នុងព្រៃជិត ឬព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យ គួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួនដែលមានកាយកម្មមិនបរិសុទ្ធនោះឯង ។ ចំណែកតថាគត មិនមែនជាមានកាយកម្មមិនបរិសុទ្ធ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត ឬព្រៃឆ្ងាយដូច្នោះទេ តថាគតជាអ្នកមានកាយកម្មបរិសុទ្ធមែន ។ ព្រះអរិយៈទាំងឡាយណា ដែលមានកាយកម្មបរិសុទ្ធ រមែងសេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងឡាយនោះ តថាគតជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញនូវកាយកម្មដ៏បរិសុទ្ធនុ៎ះក្នុងខ្លួនហើយ ទើបតថាគតបានដល់នូវសួស្តីច្រើន គួរនឹងនៅក្នុងព្រៃបាន ។

[ ៣២ ] ម្នាលព្រាហ្មណ៍ តថាគតឯងមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ដែលមានវចីកម្មមិនបរិសុទ្ធ ។បេ។ ដែលមានមនោកម្មមិនបរិសុទ្ធ មានអាជីវៈមិនបរិសុទ្ធ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងហៅអកុសលដែលគួរភ័យ គួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលមានអាជីវៈមិនបរិសុទ្ធនោះឯង ។ ឯតថាគតមិនមែនជាមានអាជីវៈមិនបរិសុទ្ធ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយដូច្នោះទេ តថាគតជាអ្នកមានអាជីវៈបរិសុទ្ធមែន ។ ពួកព្រះអរិយៈណា ដែលមានអាជីវៈបរិសុទ្ធ រមែងសេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ

បណ្ដាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតពិចារណាឃើញ នូវអាជីវៈដ៏បរិសុទ្ធនុ៎ះ ក្នុងខ្លួនហើយ ទើបតថាគតបានដល់នូវសួស្ដីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

[ ៣៣ ] ម្នាលព្រាហ្មណ៍ តថាគតឯងមានសេចក្ដីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ដែលមានអភិជ្ឈាជាប្រក្រតី មានសេចក្ដីត្រេកត្រអាលដ៏ក្លៀវក្លា ក្នុងកាមទាំងឡាយ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចម្រើន ទាំងនោះតែងហៅអកុសលធម៌ដែលគួរភ័យ គួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលមានអភិជ្ឈាជាប្រក្រតី មានសេចក្ដីត្រេកត្រអាលដ៏ក្លៀវក្លាក្នុងកាមទាំងឡាយនោះឯង ។ ឯតថាគតនឹងមានអភិជ្ឈាជាប្រក្រតី មានសេចក្ដីត្រេកត្រអាលដ៏ក្លៀវក្លា ក្នុងកាមទាំងឡាយ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ ដូច្នោះក៏ទេ តថាគតមិនមានអភិជ្ឈាជាប្រក្រតីមែន ។ ពួកព្រះអរិយៈណា ដែលមិនមានអភិជ្ឈាជាប្រក្រតី សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ បណ្ដាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញនូវធម៌ដែលមិនមែនជាអភិជ្ឈានុ៎ះ ក្នុងខ្លួនហើយ ទើបតថាគតបានដល់នូវសួស្ដីដ៏ដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

[ ៣៤ ] ម្នាលព្រាហ្មណ៍ តថាគតឯង មានសេចក្ដីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ មានចិត្តព្យាបាទ មានចិត្តគិតប្រទូស្ត សេពនូវ

សេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យ គួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលមានចិត្តព្យាបាទ និងចិត្តគិតប្រទូស្តនោះឯង ។ ឯតថាគតនឹងជាអ្នកមានចិត្តព្យាបាទ មានចិត្តគិតនឹងប្រទូស្ត សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ ដូច្នោះក៏ទេ តថាគតជាអ្នកមានចិត្តប្រកបដោយមេត្តា ។ ព្រះអរិយៈទាំងឡាយណា ដែលមានចិត្តប្រកបដោយមេត្តា រមែងសេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញនូវចិត្ត ប្រកបដោយមេត្តានុ៎ះ ក្នុងខ្លួនហើយ ទើបដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

[ ៣៥ ] ម្នាលព្រាហ្មណ៍ តថាគតឯង មានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ដែលថីនមិទ្ធៈ ( សេចក្តីប្រអូសចិត្ត និងប្រអូសកាយ ) គ្របសង្កត់ហើយ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យ គួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលថីនមិទ្ធៈគ្របសង្កត់នោះឯង ។ ឯតថាគតមិនមែនជាអ្នក ដែលថីនមិទ្ធៈគ្របសង្កត់ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយដូច្នោះទេ តថាគតជាអ្នកមានថីនមិទ្ធៈទៅប្រាសហើយ ។ ព្រះអរិយៈទាំងឡាយណា មានថីនមិទ្ធៈទៅប្រាសហើយ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ

បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញ នូវថីនមិទ្ធៈទៅប្រាសហើយក្នុងខ្លួន ទើបដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

[ ៣៦ ] ម្នាលព្រាហ្មណ៍ តថាគតឯង មានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ដែលមានចិត្តរវើរវាយ មានចិត្តមិនស្ងប់រម្ងាប់ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ ពួកសមណ-ព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យ គួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលមានចិត្តរវើរវាយ មានចិត្តមិនស្ងប់រម្ងាប់នោះឯង ។ ឯតថាគត នឹងមានចិត្តរវើរវាយ មានចិត្តមិនស្ងប់រម្ងាប់ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយដូច្នោះក៏ទេ តថាគតជាអ្នកមានចិត្តស្ងប់រម្ងាប់ ។ ព្រះអរិយៈទាំងឡាយណា មានចិត្តស្ងប់រម្ងាប់ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញ នូវចិត្តស្ងប់រម្ងាប់នោះក្នុងខ្លួនហើយ ទើបដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

[ ៣៧ ] ម្នាលព្រាហ្មណ៍ តថាគតឯងមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ដែលមានសេចក្តីសង្ស័យមិនដាច់ស្រេច សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ ពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងហៅអកុសលធម៌ ដែលគួរភ័យ គួរខ្លាច ព្រោះហេតុ

នៃទោសរបស់ខ្លួន ដែលមានសេចក្តីសង្ស័យ មិនដាច់ស្រេចនោះឯង ។ ឯតថាគតនឹងមានសេចក្តីសង្ស័យ មិនដាច់ស្រេច សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ ដូច្នោះក៏ទេ តថាគតជាអ្នកកន្លងផុតចាកសេចក្តីសង្ស័យ មិនដាច់ស្រេចបាន ។ ព្រះអរិយៈទាំងឡាយណា ដែលកន្លងផុតសេចក្តីសង្ស័យមិនដាច់ស្រេច សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញនូវចិត្ត ដែលកន្លងផុតសេចក្តីសង្ស័យមិនដាច់ស្រេចនុ៎ះ ក្នុងខ្លួនហើយ ទើបដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

[ ៣៨ ] ម្នាលព្រាហ្មណ៍ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ជាអ្នកលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ សមណ-ព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងហៅអកុសលធម៌ ដែលគួរភ័យ គួរខ្លាចព្រោះហេតុនៃទោសរបស់ខ្លួន ដែលលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃសេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ ដូច្នោះក៏ទេ តថាគតជាអ្នកមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃទេ ។ ព្រះអរិយៈទាំងឡាយណា ជាអ្នកមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃសេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគត

បានពិចារណាឃើញនូវសេចក្តីមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ទុំះក្នុងខ្លួនហើយ ទើបដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

[៣៩] ម្នាលព្រាហ្មណ៍ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណ-ព្រាហ្មណ៍ណាមួយ ជាអ្នកតក់ស្លុត ប្រកបដោយជាតិជាអ្នកខ្លាច សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យ គួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលមានសេចក្តីតក់ស្លុត នឹងការប្រកបដោយជាតិជាអ្នកខ្លាចនោះឯង ។ ឯតថាគតនឹងមានសេចក្តីតក់ស្លុត ប្រកបដោយជាតិជាអ្នកខ្លាច សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយដូច្នោះក៏ទេ តថាគតជាអ្នកប្រាសចាកសេចក្តីព្រឺព្រួចរោមហើយ ។ ព្រះអរិយៈទាំងឡាយណាប្រាសចាកសេចក្តីព្រឺព្រួចរោមហើយ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតពិចារណាឃើញនូវការប្រាសចាកសេចក្តីព្រឺព្រួចរោមទុំះ ក្នុងខ្លួនហើយ ទើបដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

[៤០] ម្នាលព្រាហ្មណ៍ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណ-ព្រាហ្មណ៍ណាមួយ ដែលត្រូវការចង់បានលាភសក្ការៈ និងសេចក្តីសរសើរ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ សមណ-ព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យ គួរខ្លាច

ព្រោះហេតុនៃទោសរបស់ខ្លួន ដែលត្រូវការចង់បានលាភសក្ការៈ និងសេចក្តីសរសើរនោះឯង ។ ឯតថាគតនឹងត្រូវការចង់បានលាភសក្ការៈ និងសេចក្តីសរសើរ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ ដូច្នោះក៏ទេ តថាគតជាអ្នកមានសេចក្តីប្រាថ្នាតិច ។ ព្រះអរិយៈទាំងឡាយណា ដែលមានសេចក្តីប្រាថ្នាតិច សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញសេចក្តីប្រាថ្នាតិចនុ៎ះ ក្នុងខ្លួនហើយ ទើបដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

[៤១] ម្នាលព្រាហ្មណ៍ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយជាអ្នកខ្ជិលច្រអូស មិនព្យាយាម សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យ គួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលមានសេចក្តីខ្ជិលច្រអូស និងគ្មានព្យាយាមនោះឯង ។ ឯតថាគតនឹងជាអ្នកខ្ជិលច្រអូស មិនមានព្យាយាម សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ ដូច្នោះក៏ទេ តថាគតជាអ្នកមានព្យាយាមប្រារព្ធហើយ ។ ព្រះអរិយៈទាំងឡាយណា ដែលមានព្យាយាមប្រារព្ធហើយ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញនូវសេចក្តីព្យាយាម ដែលប្រារព្ធហើយនុ៎ះ ក្នុងខ្លួនហើយ ទើប

ដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

[៤២] ម្នាលព្រាហ្មណ៍ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ជាអ្នកភ្លេចស្មារតី មិនដឹងខ្លួន ( ប្រាសចាកបញ្ញា ) សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ ពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងហៅអកុសលធម៌ដែលគួរភ័យ គួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលភ្លេចស្មារតី មិនដឹងខ្លួននោះឯង ។ ឯតថាគតនឹងជាអ្នកភ្លេចស្មារតី មិនដឹងខ្លួន សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយដូច្នេះក៏ទេ តថាគតជាអ្នកមានស្មារតីតម្កល់មាំ ។ ព្រះអរិយៈទាំងឡាយណា ជាអ្នកមានស្មារតីតម្កល់មាំ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញនូវការតម្កល់ស្មារតីមាំនុ៎ះ ក្នុងខ្លួនហើយ ទើបដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

[៤៣] ម្នាលព្រាហ្មណ៍ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ មានចិត្តមិនតម្កល់មាំ ( ប្រាសចាកឧបចារសមាធិ និងអប្បនាសមាធិ ) មានចិត្តវិលវល់ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ ពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងហៅអកុសលធម៌ ដែលគួរភ័យ គួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលមានចិត្តមិនតម្កល់មាំ និងចិត្តវិលវល់នោះឯង ។ ឯតថាគតនឹងមានចិត្ត

មិនតម្កល់មាំ មានចិត្តវិលវល់ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយដូច្នោះក៏ទេ តថាគតជាអ្នកមានសមាធិបរិបូណ៌ ។ ព្រះអរិយៈទាំងឡាយណា ដែលមានសមាធិបរិបូណ៌ សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញសមាធិសម្បទាន៌ុះ ក្នុងខ្លួនហើយ ទើបដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

[៤៤] ម្នាលព្រាហ្មណ៍ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណព្រាហ្មណ៍ណាមួយ ជាអ្នកអាប់ឥតប្រាជ្ញា ល្ងង់លេលា សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ ពួកសមណព្រាហ្មណ៍ ដ៏ចម្រើនទាំងនោះ តែងហៅអកុសលធម៌ ដែលគួរភ័យ គួរខ្លាច ព្រោះហេតុនៃទោសរបស់ខ្លួន ដែលអាប់ឥតប្រាជ្ញា ល្ងង់លេលានោះឯង ។ ឯតថាគតនឹងជាអ្នកអាប់ឥតប្រាជ្ញា ល្ងង់លេលា សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយដូច្នោះក៏ទេ តថាគតជាអ្នកបរិបូណ៌ដោយប្រាជ្ញា ។ ព្រះអរិយៈទាំងឡាយណា ដែលបរិបូណ៌ដោយប្រាជ្ញា សេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ បណ្តាព្រះអរិយៈទាំងនោះ តថាគតក៏ជាព្រះអរិយៈមួយដែរ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញបញ្ញាសម្បទាន៌ុះក្នុងខ្លួនហើយ ទើបដល់នូវសួស្តីដោយច្រើន គួរនឹងនៅក្នុងព្រៃបាន ។

**បរិយាយ ១៦ ចប់**

[ ៤៥ ] ម្នាលព្រាហ្មណ៍ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា រាត្រីទាំង-ឡាយណា ដែលគេដឹងច្បាស់ ដែលគេកំណត់ដឹងថា ជាតិថីទី ១៤ ទី ១៥ ទី ៨ នៃបក្ខ បើដូច្នេះ អាត្មាអញគួរនៅក្នុងអារាមចេតិយ វនចេតិយ រុក្ខ-ចេតិយទាំងឡាយដែលគួរភ័យ គួរភ្ញឹក គួរឲ្យព្រឺព្រួចរោម ក្នុងរាត្រីទាំងឡាយមានសភាពដូច្នោះ ។ ធ្វើម្តេចតថាគតគប្បីឃើញភ័យ និងសេចក្តីស្ញើបនោះបាន ។ ម្នាលព្រាហ្មណ៍ លុះសម័យមកខាងក្រោយ រាត្រីទាំងឡាយណាដែលគេដឹងច្បាស់ ដែលគេកំណត់ដឹងថា ជាតិថីទី ១៤ ទី ១៥ ទី ៨ នៃបក្ខតថាគតក៏នៅក្នុងអារាមចេតិយ វនចេតិយ រុក្ខចេតិយទាំងឡាយ ដែលគួរស្បើម គួរខ្លាច គួរឲ្យព្រឺព្រួចរោម ក្នុងរាត្រីទាំងឡាយមានសភាពដូច្នោះម្នាលព្រាហ្មណ៍ កាលតថាគតនៅក្នុងទីនោះ ម្រឹគក៏មកខ្លះ ក្ងោកក៏ជាន់មែកឈើស្ងួតឲ្យធ្លាក់ចុះខ្លះ ខ្យល់ក៏បក់ផាត់ស្លឹកឈើ និងសំរាមមកខ្លះ ។ ម្នាលព្រាហ្មណ៍ តថាគតក៏មានសេចក្តីត្រិះរិះដូច្នេះថា ភ័យ និងសេចក្តីភ្ញឹកនោះមកដល់ ( តថាគត ) មែនហើយតើ ។ ម្នាលព្រាហ្មណ៍ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញជាអ្នកប្រាថ្នានូវភ័យ ដោយចំណែកមួយឬអ្វីហ្ន៎ ភ័យនិងសេចក្តីស្ញើបនោះមកដល់អាត្មាអញ ដែលសម្រេចឥរិយាបថណាៗ អាត្មាអញនឹងមិនផ្លាស់ឥរិយាបថនោះៗ ដោយពិត ត្រូវតែបន្ទោបង់នូវភ័យ និងសេចក្តីស្ញើបនោះចេញ ។ ម្នាលព្រាហ្មណ៍ តថាគតកំពុងចង្ក្រម ក៏ស្រាប់តែមានភ័យ និងសេចក្តីស្ញើបនោះមកដល់ ។ ម្នាលព្រាហ្មណ៍ តថាគតក៏មិនឈរ មិនអង្គុយ មិនដេកសោះ ខំចង្ក្រមដរាបទាល់តែបន្ទោបង់ភ័យ និង

សេចក្តីស្ញើបនោះបាន ។ ម្នាលព្រាហ្មណ៍ កាលតថាគតកំពុងឈរ ក៏ស្រាប់តែមានភ័យ និងសេចក្តីស្ញើបនោះមកដល់ ។ ម្នាលព្រាហ្មណ៍ តថាគតក៏មិនចង្រ្កម មិនអង្គុយ មិនដេក ប្រឹងឈរជាបទាល់តែបន្ទោបង់នូវភ័យ និងសេចក្តីស្ញើបនោះបាន ។ ម្នាលព្រាហ្មណ៍ កាលតថាគតកំពុងអង្គុយ ក៏ស្រាប់តែមានភ័យ និងសេចក្តីស្ញើបនោះមកដល់ ។ ម្នាលព្រាហ្មណ៍ តថាគតក៏មិនដេក មិនឈរ មិនចង្រ្កមសោះ ប្រឹងអង្គុយជាបទាល់តែបន្ទោបង់ភ័យ និងសេចក្តីស្ញើបនោះបាន ។ ម្នាលព្រាហ្មណ៍ កាលតថាគតកំពុងដេក ក៏ស្រាប់តែមានភ័យ និងសេចក្តីស្ញើបនោះមកដល់ ។ ម្នាលព្រាហ្មណ៍ តថាគតក៏មិនអង្គុយ មិនឈរ មិនចង្រ្កមសោះ ប្រឹងដេកជាបទាល់តែបន្ទោបង់ភ័យ និងសេចក្តីស្ញើបនោះបាន ។

[ ៤៦ ] ម្នាលព្រាហ្មណ៍ មានសមណព្រាហ្មណ៍មួយពួក សម្គាល់យប់ថាជាថ្ងៃ សម្គាល់ថ្ងៃថាជាយប់ តថាគតពោលថា ការសម្គាល់នេះ របស់ពួកសមណព្រាហ្មណ៍ទាំងនោះ ជាការនៅវង្វេងកាន់ស្មារតីនៅឡើយ ។ ម្នាលព្រាហ្មណ៍ ចំណែកខាងតថាគតដឹងច្បាស់នូវយប់ ថាជាយប់មែន ដឹងច្បាស់នូវថ្ងៃ ថាជាថ្ងៃមែន ។ ម្នាលព្រាហ្មណ៍ ដំណើរនោះមានទំនងគួរឲ្យអ្នកផងនិយាយថា សត្វដែលមានសភាពមិនវង្វេង កើតហើយក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ដំណើរនោះ មានទំនងគួរឲ្យអ្នកផងនិយាយ

ឲ្យតថាគតថា សត្វដែលមានសភាពមិនវង្វេង កើតឡើងហើយក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។

[ ៤៧ ] ម្នាលព្រាហ្មណ៍ តថាគតបានផ្ដើមសេចក្ដីព្យាយាម មិនបន្ធូរបន្ថយឡើយ ទាំងស្មារតីតថាគតក៏ប្រុងប្រយ័ត្ន មិនឲ្យមានភ្លាត់ កាយសោតក៏ស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ ចិត្តក៏នឹងល្អ ជាចិត្តមានអារម្មណ៍មូលតែមួយ ។ ម្នាលព្រាហ្មណ៍ តថាគតឯង លុះប្រាកដជាស្ងាត់ចាកកាមទាំងឡាយ ប្រាកដជាស្ងាត់ចាកធម៌ទាំងឡាយ ជាអកុសលហើយ ក៏ចូលបឋមជ្ឈាន ដែលប្រកបដោយវិតក្ក វិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ជាអារម្មណ៍ លុះរម្ងាប់វិតក្កវិចារៈហើយ ក៏បានចូលដល់ទុតិយជ្ឈាន ជាទីផូរផង់ ប្រព្រឹត្តទៅខាងក្នុង ក៏ញុំាងចិត្តជាសមាធិឲ្យចម្រើនឡើង គ្មានវិតក្កវិចារៈទេ មានតែបីតិ និងសុខដែលកើតអំពីសមាធិ លុះលះបង់បីតិចេញហើយ តថាគត ជាបុគ្គលព្រងើយ មានសតិ និងសេចក្ដីដឹងច្បាស់ តថាគតសោយសុខដោយនាមកាយផង អរិយបុគ្គលទាំងឡាយ តែងសរសើរនូវបុគ្គលដែលបានតតិយជ្ឈាននោះណា ថាជាបុគ្គលមានចិត្តព្រងើយ ជាអ្នកមានស្មារតី មានប្រក្រតីនៅជាសុខ តថាគតក៏បានដល់នូវតតិយជ្ឈាននោះហើយ ព្រោះលះបង់នូវសេចក្ដីសុខផង ព្រោះលះបង់នូវសេចក្ដីទុក្ខផង ព្រោះរំលត់នូវសោមនស្ស និងទោមនស្សអំពីមុនផង តថាគតបានចូលដល់

ចតុត្ថជ្ឈាន ឥតទុក្ខ ឥតសុខ មានសតិដ៏ស្អាត ដោយឧបេក្ខា ។

[ ៤៨ ] កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ យ៉ាងនេះហើយ តថាគតក៏បានបង្អោនចិត្តទៅក្នុងបុព្វេនិវាសានុស្សតិញ្ញាណ ( ប្រាជ្ញាជាគ្រឿងរឭកជាតិ ដែលអាស្រ័យនៅពីមុន ) ។ តថាគតនោះ រឭកជាតិដែលបានអាស្រ័យនៅអំពីមុន ជាអនេកជាតិ រឭកជាតិបានដូចម្តេច គឺរឭកបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិក៏បាន រឭកបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្បក៏បាន ដូច្នេះថា តថាគតបានកើតក្នុងភពឯនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានសោយសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ តថាគតច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯនោះ ដែលទៅកើតក្នុងភពនោះ តថាគត ក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានសោយសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ តថាគតលុះច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងភពនេះ ។ តថាគតរឭកតាមនូវជាតិដែលអាស្រ័យនៅពីមុនបានច្រើនជាតិ ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេសយ៉ាងនេះ ។ ម្នាលព្រាហ្មណ៍ បឋមវិជ្ជានេះឯង ដែលតថាគតបានត្រាស់ដឹងក្នុងយាមជាដំបូងនៃរាត្រី លុះដល់សេចក្តីល្ងង់ខ្លាត់បាត់ទៅ សេចក្តី

បេះដឹងក៏កើតឡើង ងងឹតខ្វាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគត ដែលកំពុងអន្ទុយប្រុងស្មារតី មិនប្រហែសធ្វេស ទំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្ដុង ( ឥតមានទឹកនាដល់កាយ និងជីវិតឡើយ ) ដូចជាបណ្ឌិតទាំងឡាយ ដែលបាននូវបឋមវិជ្ជានុ៎ះដូច្នោះដែរ ។

[៤៩] កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្ដីសៅហ្មង ជាចិត្តទន់ភ្លន់សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ តថាគតក៏បង្អោនចិត្តទៅក្នុងចុតូបបាតញ្ញាណ ( ញាណដែលនាំឲ្យបានត្រាស់ដឹងនូវចុតិ និងបដិសន្ធិ ) នៃសត្វទាំងឡាយ ។ តថាគតមើលឃើញនូវសត្វទាំងឡាយ ដែលច្យុត និងចាប់បដិសន្ធិ ទាបថោក និងឧត្ដម មានសណ្ឋានល្អ និងអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធក្រៃលែងជាងចក្ខុរបស់មនុស្សសាមញ្ញ ក៏ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មថា ឱហ្ន៎ សត្វទាំងអម្បាលនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ ប្រកាន់មាំនូវកម្មជាមិច្ឆាទិដ្ឋិ សត្វទាំងនោះលុះដល់រំលាងខន្ធបន្ទាប់អំពីមរណៈ ក៏ទៅកើតឯអបាយ[១] ទុគ្គតិ[២] វិនិបាត[៣] នរក[៤] អើហ្ន៎ ចំណែកខាងសត្វទាំងអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិន

១- កំណើតសត្វតិរច្ឆាន ។ ២- ប្រេតវិស័យ ។ ៣- អសុរកាយដែលមានមហិទ្ធិឫទ្ធិ ដូចរាហូអសុរិន្ទជាដើម ។ ៤- លោកដែលគ្មានសេចក្ដីចម្រើន មានប្រការច្រើន មានអវិចីនរកជាដើម ។

តិះដៀលនូវពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ ប្រកាន់មាំនូវកម្មជាសម្មាទិដ្ឋិ សត្វទាំងអម្បាលនោះ លុះដល់រំលាងខន្ធបន្ទាប់អំពីមរណៈ ក៏ទៅកើតឯឋានសុគតិ[១] និងសួគ៌[២] ទេវលោក ។ តថាគតមើលឃើញ នូវសត្វទាំងឡាយដែលច្យុត និងចាប់បដិសន្ធិ ទាបថោក និងឧត្តម មានសណ្ឋានល្អ និងអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិ ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ ក្រៃលែងជាងចក្ខុរបស់មនុស្សសាមញ្ញ ក៏ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ ។ ម្នាលព្រាហ្មណ៍ វិជ្ជាទី ២ នេះឯងហើយដែលតថាគតបានត្រាស់ដឹងក្នុងយាមជាកណ្តាលនៃរាត្រី លុះដល់សេចក្តីល្ងង់ខ្ចាត់បាត់ទៅ សេចក្តីចេះដឹងក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគត ដែលកំពុងប្រុងស្មារតី មិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្ងួន ( ឥតមានទឹកនាដល់កាយ និងជីវិតឡើយ ) ដូចជាបណ្ឌិតទាំងឡាយ ដែលបាននូវវិជ្ជា ទី ២ នុ៎ះដូច្នោះដែរ ។

[ ៥០ ] កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ភ្លន់ សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ តថាគតក៏មិនបង្អោនទៅ ក្នុងអាសវក្ខយញ្ញាណ ( ញាណជាហេតុឲ្យបានអស់ទៅនូវអាសវៈ ) ។ តថាគតដឹងប្រាកដតាមពិតថា នេះជាទុក្ខ ដឹងប្រាកដតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងប្រាកដតាមពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា នេះជាឧបាយឲ្យដល់នូវសេចក្តី

---

១- សង្គ្រោះយកគតិរបស់មនុស្សចូលផង ។ ២- ចំពោះយកគតិនៃទេវតាតែម្យ៉ាង ។

រលត់ទុក្ខ ដឹងប្រាកដតាមពិតថា ធម៌ប៉ុណ្ណេះជាអាសវៈ ដឹងប្រាកដតាមពិតថា ធម៌នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងប្រាកដតាមពិតថា នេះជាសេចក្តីរលត់នៃអាសវៈ ដឹងប្រាកដតាមពិតថា នេះជាឧបាយឲ្យបានដល់នូវសេចក្តីរលត់នៃអាសវៈ ។ កាលដែលតថាគតដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តនៃតថាគតក៏ផុតចាកគ្រឿងត្រាំ គឺកាមផង ចិត្តនៃតថាគតក៏ផុតចាកគ្រឿងត្រាំ គឺភពផង ចិត្តនៃតថាគតក៏ផុតចាកគ្រឿងត្រាំ គឺអវិជ្ជាផង ( កាលបើចិត្តតថាគតបានរួចផុតស្រឡះហើយ ) ប្រាជ្ញាក៏កើតប្រាកដដល់តថាគតថា អញរួចស្រឡះចាកអាសវធម៌ហើយ ចិត្តរបស់អញផុតស្រឡះហើយ តថាគតដឹងច្បាស់ថា កំណើតរបស់អញអស់ហើយ ព្រហ្មចរិយធម៌អញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អញក៏បានធ្វើស្រេចហើយ នឹងមានកិច្ចដទៃក្រៅពីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលព្រាហ្មណ៍ វិជ្ជាទី ៣ នេះឯង ដែលតថាគតបានត្រាស់ដឹងក្នុងយាមជាទីបំផុតនៃរាត្រី លុះដល់សេចក្តីល្ងង់ខ្លៅខ្ចាត់បាត់ទៅ សេចក្តីចេះដឹង ក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគត ដែលកំពុងអន្ទុយប្រុងស្មារតី មិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្ងួន ( ឥតមាននឹកនាដល់កាយ និងជីវិតឡើយ ) ដូចជាបណ្ឌិតទាំងឡាយ ដែលបាននូវវិជ្ជាទី ៣ ទុំះដូច្នោះដែរ ។

[ ៥១ ] ម្នាលព្រាហ្មណ៍ ឯសមណព្រាហ្មណ៍ទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ថ្ងៃនេះឯង ព្រះសមណគោតម ប្រហែលជាមិនទាន់ប្រាសចាក

រាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈទេដឹង ព្រោះហេតុនោះ បានជាលោកសេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ ។ ម្នាលព្រាហ្មណ៍ ជំណើរនុ៎ះ អ្នកកុំគប្បីឃើញយ៉ាងនេះឡើយ ។ ម្នាលព្រាហ្មណ៍ តថាគតបានពិចារណាឃើញនូវអំណាចនៃប្រយោជន៍ ២ ប្រការ គឺពិចារណាឃើញនូវការនៅជាសុខក្នុងបច្ចុប្បន្នចំពោះខ្លួន ១ អនុគ្រោះដល់ប្រជុំជនមានក្នុងខាងក្រោយ ១ បានជាសេពនូវសេនាសនៈស្ងាត់ តាំងនៅក្នុងព្រៃជិត និងព្រៃឆ្ងាយ ។

[ ៥២ ] ជាណុស្សោណិព្រាហ្មណ៍ក្រាបបង្គំទូលថា ឱហ្ន៎ ព្រះគោតមដ៏ចម្រើន ព្រះអង្គមានសេចក្តីអនុគ្រោះ ដល់ប្រជុំជនខាងក្រោយមែន ព្រោះព្រះអង្គបានជាព្រះអរហន្តសម្មាសម្ពុទ្ធហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ( ភ្លឺច្បាស់ណាស់ ) ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬក៏ដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះ ដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាគេទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ដោយគិតថា បុរសអ្នកមានចក្ខុទាំងឡាយរមែងឃើញនូវរូបបាន ។ ខ្ញុំព្រះអង្គនោះសូមដល់នូវព្រះគោតមដ៏ចម្រើនផងព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក ចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសកដល់សរណគមន៍ស្មើដោយជីវិត ។

**កយកេរវសូត្រទី ៤ ចប់**

# អដ្ឋកថា

## ភយភេរវសូត្រ

[ ២៧ ] ភយភេរវសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។

ក្នុងភយភេរវសូត្រនេះ មានការពណ៌នាតាមលំដាប់បទដូច្នេះ សព្ទថា **អថ** ជានិបាត ប្រើក្នុងអត្ថថា **អវិច្ឆេទន** គឺមិនដាច់ខ្សែជាប់តមក សព្ទថា **ខោ** ជានិបាតដូចគ្នា ប្រើក្នុងអត្ថថា **អវធារណ** ហាមអត្ថដទៃ អធិប្បាយថា ព្រះមានព្រះភាគ ប្រថាប់នៅក្នុងក្រុងសាវត្ថី មិនដាច់រយៈឡើយ ពាក្យថា **ជាណុស្សោណិ** នោះ មិនមែនឈ្មោះដែលមាតាបិតារបស់ព្រាហ្មណ៍នោះដាក់ឲ្យទេ តែជាឈ្មោះដែលបានមកអំពីមុខតំណែង ។ បានឮមកថា តំណែងជាណុស្សោណីនោះ ជាតំណែងបុរោហិត ។ ព្រះរាជាបានព្រះរាជទានតំណែងបុរោហិតនោះឲ្យដល់ព្រាហ្មណ៍នោះ ដូច្នោះ ទើបមនុស្សទាំងឡាយ ហៅថា **ជាណុស្សោណិ** ។

បុគ្គលដែលឈ្មោះថា **ព្រាហ្មណ៍** ព្រោះមានអត្ថថា បន្ទឹសំឡេងថា ព្រហ្ម អធិប្បាយថា បានដល់ ស្វាធ្យាយមន្ត ។ ពាក្យថា **ព្រាហ្មណ** នោះ ជាភាសាហៅបុគ្គលដែលជាព្រាហ្មណ៍ដោយកំណើត ។ ឯព្រះអរិយៈទាំង-ឡាយ លោកក៏ហៅថា **ព្រាហ្មណ** ព្រោះបន្សាត់បាបបានហើយ ។

បទថា **យេន** ក្នុងបទថា **យេន ភគវា តេនុបសង្កមិ** ជាតតិយាវិភត្តិ ប្រើក្នុងអត្ថនៃសត្តមីវិភត្តិ ។ ព្រោះដូច្នោះ គប្បីឃើញអត្ថក្នុងពាក្យនេះយ៉ាងនេះថា **យត្ថ ភគវា ឧបសង្កមិ** ប្រែថា ព្រះមានព្រះភាគប្រថាប់នៅក្នុងទី

ណា ជាណុស្សោណិព្រាហ្មណ៍ ក៏ចូលទៅគាល់ហើយក្នុងទីនោះ ។ ម្យ៉ាងទៀត គប្បីឃើញអត្ថក្នុងពាក្យនេះយ៉ាងនេះថា ព្រះមានព្រះភាគ ដែលទេវតានិងមនុស្សទាំងឡាយគប្បីចូលទៅគាល់ ដោយហេតុណា ជាណុស្សោណិ-ព្រាហ្មណ៍ ក៏ចូលទៅគាល់ហើយដោយហេតុនោះ ។

សួរថា ព្រះមានព្រះភាគ ដែលទេវតា និងមនុស្សទាំងឡាយ គប្បីចូលទៅគាល់ដូចម្តេច ឆ្លើយថា ដោយបំណងនឹងសម្រេចគុណវិសេសច្រើនប្រការ ឧបមាដូចដើមឈើធំ ដែលមានផ្លែជានិច្ច សត្វបក្សីចូលទៅទំ ដោយបំណងនឹងចឹកស៊ីផ្លែដែលមានរសឆ្ងាញ់ ដូច្នោះ ។

បទថា **ឧបសង្កមិ** មានអធិប្បាយថា ទៅហើយ ។ បទកិរិយាថា **ឧបសង្កមិត្វា** ជាបទសម្តែងដល់ការចូលទៅគាល់បានដល់ទីបំផុតហើយ ។ ម្យ៉ាងទៀត អធិប្បាយថា ចូលទៅជិតជាងនោះ គឺទីជិតនៃព្រះមានព្រះភាគ ដូច្នេះក៏បាន ។

បទថា **ភគវតា សទ្ធឹ សម្មោទិ** សេចក្តីថា ព្រះមានព្រះភាគត្រាស់សួរដល់សុខទុក្ខជាដើម ឈ្មោះថា ទ្រង់ស្និទ្ធស្នាលជាមួយព្រាហ្មណ៍នោះ យ៉ាងណា សូម្បីព្រាហ្មណ៍នោះ ក៏មានចិត្តរីករាយជាមួយព្រះមានព្រះភាគ គឺដល់នូវការរីករាយចិត្ត បានដល់ ជាគ្នាឯងជាមួយព្រះមានព្រះភាគ ប្រៀបដូចទឹកត្រជាក់ និងទឹកក្តៅលាយចូលគ្នា ដូច្នោះ ។

ម្យ៉ាងទៀត ព្រាហ្មណ៍នោះត្រេកអរដោយពាក្យណា មានពាក្យថា យន្តគឺព្រះវរកាយរបស់ព្រះគោតមដ៏ចម្រើន ល្មមអត់ធន់បានដែរឬ ព្រះគោតមដ៏

ចម្រើន ល្មមញ៉ាំងយន្ត គឺព្រះវរកាយឲ្យប្រព្រឹត្តទៅបានដែរឬ ព្រះគោតមដ៏ចម្រើន និងពួកសាវ័ករបស់ព្រះគោតម ជាអ្នកមានអាពាធតិច មានរោគតិច ឈរ ដើរ បានស្រួល រឹងមាំ មានការនៅជាផាសុកដែរឬ ពាក្យនោះឈ្មោះថា **សម្មោទនីយ** គឺជាហេតុឲ្យកើតការត្រេកអរ ព្រោះឲ្យកើតការត្រេកអរយ៉ាងល្អ ពោលគឺ បីតិ និងបាមោជ្ជ និងព្រោះជាពាក្យសម្ដីសមគួរ ដើម្បីការត្រេកអរ ឈ្មោះថា **សារាណីយ** គឺជាហេតុឲ្យរឭកដល់គ្នានឹងគ្នា ព្រោះជាពាក្យសម្ដីដែលសមគួរនឹងឲ្យអ្នកស្ដាប់រឭកដល់អស់កាលយូរ គឺឲ្យប្រព្រឹត្តទៅមិនវៀរ ព្រោះជាពាក្យសម្ដីដែលអ្នកនិយាយខ្លួនឯង ក៏ត្រូវរឭកដល់ដែរ ឈ្មោះថា **សម្មោទនីយ** ព្រោះកាលស្ដាប់ក៏ជាសុខ ឈ្មោះថា **សារាណីយ** ព្រោះការរឭកដល់ក៏ជាសុខ មួយប្រការទៀត ឈ្មោះថា **សម្មោទនីយ** ព្រោះមានព្យញ្ជនៈច្បាស់លាស់ ឈ្មោះថា **សារាណីយ** ព្រោះមានអត្ថប្រាកដច្បាស់ ព្រាហ្មណ៍ញ៉ាំងពាក្យសម្ដីដែលជាសម្មោទនីយ សារាណីយ ឲ្យកន្លងផុតទៅ គឺដល់ទីបំផុត បានដល់ ឲ្យចប់សព្វគ្រប់ដោយអនេកបរិយាយ ដូចពណ៌នាយ៉ាងនេះហើយ បំណងនឹងសួរដល់គោលបំណងដែលជាហេតុឲ្យខ្លួនត្រូវមក ទើបអង្គុយចុះក្នុងទីសមគួរនាចំណែកម្ខាង ។

បទថា **ឯកមន្តំ** ជាបទសម្ដែងភាវនបុំសកៈ គឺកិរិយាវិសេស ដូចឧទាហរណ៍ក្នុងប្រយោគជាដើមថា **វិសមំ ចន្ទិមសុរិយា បរិវត្តន្តិ** ព្រះចន្ទនិងព្រះអាទិត្យគោចរមិនស្មើគ្នា ដូច្នេះ ព្រោះដូច្នោះ គប្បីឃើញអត្ថក្នុងសេចក្ដីនេះ យ៉ាងនេះថា ព្រាហ្មណ៍នោះ អង្គុយដូចដែលអ្នកដទៃអង្គុយក្នុងទី

សមគ្គរ ។ម្យ៉ាងទៀត បទថា **ឯកមន្តំ** នេះ ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថនៃ សត្តមីវិភត្តិ ។

# ទោសនៃការអង្គុយ ៦ យ៉ាង

បទថា **និសីទិ** ប្រែថា ចូលទៅអង្គុយជិត ។ ព្រោះថា បុគ្គលដែលជាបណ្ឌិត ចូលទៅរកបុគ្គលដែលតាំងនៅក្នុងឋានៈជាគ្រូហើយ រមែងអង្គុយចុះក្នុងទីសមគ្គរ ក្នុងចំណែកម្ខាង ព្រោះជាអ្នកឈ្លាសក្នុងទីអង្គុយ ហើយព្រាហ្មណ៍នោះក៏ជាបណ្ឌិតម្នាក់ ក្នុងចំនួនបណ្ឌិតទាំងនោះ ។ ព្រោះដូច្នោះ ទើបអង្គុយក្នុងទីសមគ្គរ នាចំណែកម្ខាង ។

សួរថា បុគ្គលអង្គុយដូចម្ដេច ទើបឈ្មោះថា អង្គុយក្នុងទីសមគ្គរនាចំណែកម្ខាង ឆ្លើយថា អង្គុយវៀរទោសនៃការអង្គុយ ៦ យ៉ាង ។

សួរថា ទោសនៃការអង្គុយ ៦ យ៉ាង មានអ្វីខ្លះ ឆ្លើយថា មានដូច្នេះគឺ **អតិទូរំ** អង្គុយឆ្ងាយពេក ១ **អច្ចាសន្នំ** អង្គុយជិតពេក ១ **ឧបរិវាតំ** អង្គុយក្នុងទីលើខ្យល់ ១ **ឧន្នតប្បទេសំ** អង្គុយក្នុងទីខ្ពស់ ១ **អតិសម្មុខំ** អង្គុយចំពីមុខ ១ **អតិបច្ឆា** អង្គុយខាងក្រោយពេក ១ ។

អធិប្បាយថា បុគ្គលដែលអង្គុយក្នុងទីឆ្ងាយពេក បើបំណងនឹងនិយាយគ្នា ក៏ត្រូវនិយាយដោយសំឡេងខ្លាំង ។ អង្គុយជិតពេក ក៏នឹងជ្រៀតបៀតលោក អង្គុយក្នុងទីលើខ្យល់ នឹងបៀតបៀនលោកដោយក្លិនខ្លួន អង្គុយក្នុងទីខ្ពស់ ក៏ជាការសម្ដែងការមិនគោរព អង្គុយចំពីមុខពេក បើបំណងនឹងមើលមុខគ្នា ក៏នឹងត្រូវមើលចំភ្នែកគ្នា បើអង្គុយខាងក្រោយពេក បើបំណងនឹង

សម្លឹងមើល ក៏ត្រូវអើតកដើម្បីមើល ព្រោះហេតុនោះ ទើបព្រាហ្មណ៍នោះ អន្ទ្រយវៀរទោសនៃការអន្ទ្រយ ៦ យ៉ាងនេះចេញ ព្រោះហេតុនោះ ទើបលោកពោលថា ព្រាហ្មណ៍អន្ទ្រយក្នុងទីសមគួរ នាចំណែកម្ខាង ។

[ ២៨ ] បទថា **យេមេ** កាត់បទជា **យេ ឥមេ** ប្រែថា កុលបុត្រទាំងនេះ ។

បទថា **កុលបុត្តា** បានដល់ កុលបុត្រ ២ ពួក គឺ កុលបុត្រដោយកំណើត ១ កុលបុត្រដោយអាចារៈ ១ ។ ក្នុងកុលបុត្រ ២ ពួកនោះ កុល-បុត្រដែលកើតក្នុងត្រកូលខ្ពស់ ដែលមានទីមកយ៉ាងនេះថា សម័យនោះឯងកុលបុត្រឈ្មោះរដ្ឋបាល ជាកូនប្រុសរបស់អគ្គកុលិកសេដ្ឋី ក្នុងថុល្លកោដ្ឋិត-គ្រាមនោះឯង នេះឈ្មោះថា កុលបុត្រដោយកំណើត ។ ចំណែកកុលបុត្រដែលកើតក្នុងត្រកូលណាក៏ដោយ ជាបុគ្គលដល់ព្រមដោយអាចារៈ ដែលមានទីមកយ៉ាងនេះថា កុលបុត្រពួកណា ចេញអំពីផ្ទះ បួសជាអនាគារិកដោយសទ្ធា ដូច្នេះ ឈ្មោះថា កុលបុត្រដោយអាចារៈ ។ តែក្នុងទីនេះ លោកបំណងយកកុលបុត្រដោយហេតុទាំង ២ យ៉ាងនោះ ។

បទថា **សទ្ធា** ប្រែថា ដោយសទ្ធា ។

បទថា **អគារស្មា** ប្រែថា ចាកផ្ទះ ។

បទថា **អនគារិយំ** បានដល់ បព្វជ្ជា និងឧបសម្បទា ។ ព្រោះថាបព្វជ្ជាក៏ឈ្មោះថា **អនគារិយា** ព្រោះក្នុងបព្វជ្ជានេះ មិនមានការងារដែលឧបការៈដល់ការគ្រប់គ្រងផ្ទះ អធិប្បាយថា ក្នុងបណ្ដាបព្វជ្ជានេះ មិនមាន

កសិកម្ម និងគោរក្ខកម្មជាដើម ដែលឧបការៈដល់ការគ្រប់គ្រងផ្ទះ ។ ឯភិក្ខុ ឈ្មោះថា **អនាគារ** ព្រោះលោកមិនមានផ្ទះ ។ ភាវៈនៃការមិនមានផ្ទះ ឈ្មោះថា **អនគារិយ ។**

បទថា **បព្វជិតា** ប្រែថា ចូលដល់ អធិប្បាយថា ចូលដល់បព្វជ្ជា និងភិក្ខុភាវៈ ពោល គឺការងារដែលមិនឧបការៈដល់ការគ្រប់គ្រងផ្ទះ ដោយប្រការទាំងពួង ដូចពណ៌នាមក ដូច្នេះ ។

បទថា **បុព្វង្គមោ** ប្រែថា ជាអ្នកទៅខាងមុខ គឺជាអ្នកនាំ ។

បទថា **ពហុការោ** ប្រែថា ជាអ្នកមានឧបការៈច្រើន ព្រោះធ្វើប្រយោជន៍ឲ្យ ។ បទថា **ភវន្តំ គោតមោ សមាទបេតា** សេចក្តីថា ព្រះគោតមដ៏ចម្រើន ញុំាងកុលបុត្រទាំងនោះឲ្យទទួល គឺឲ្យសិក្សានូវសិក្ខាផ្សេងៗ មានអធិសីលជាដើម ។ បទថា **សា ជនតា** ប្រែថា ពួកជននោះ ។

បទថា **ទិដ្ឋានុគតឹ អាបជ្ជតិ** ប្រែថា យកជាគំរូ ។ អធិប្បាយថា ព្រះគោតមដ៏ចម្រើន មានទិដ្ឋិយ៉ាងណា មានការពេញចិត្តយ៉ាងណា មានការគាប់ចិត្តយ៉ាងណា សូម្បីកុលបុត្រទាំងនោះ ក៏មានទិដ្ឋិយ៉ាងនោះ មានការពេញចិត្តយ៉ាងនោះ ។

សួរថា ព្រោះហេតុអ្វី ទើបព្រាហ្មណ៍ពោលយ៉ាងនោះ ឆ្លើយថា បានឮថា កាលមុន ព្រាហ្មណ៍នេះឃើញកុលបុត្រជាច្រើននៅត្រង់កណ្តាលផ្ទះ បានទទួលការទំនុកបម្រុងដោយបញ្ចកាមគុណ ហាក់បីដូចជាទេវបុត្រ បានទទួលការគ្រប់គ្រងរក្សាយ៉ាងល្អ ទាំងខាងក្នុងផ្ទះ ខាងក្រៅផ្ទះ សម័យក្រោយមក

ក៏បានឃើញកុលបុត្រទាំងនោះ ស្តាប់ព្រះធម្មទេសនាដ៏ពីរោះនៃព្រះមានព្រះភាគ ហើយចេញចាកផ្ទះ បួសដោយសទ្ធា ត្រឡប់មកជាអ្នកសន្តោស ក្នុងរឿងរបស់បរិភោគ និងគ្រឿងស្លៀកដណ្តប់យ៉ាងកំពូល មិនមានបុគ្គលណាគ្រប់គ្រងការពារដូចពីមុន ក៏មិនមានការភ័យខ្លាច សប្បាយ ត្រេកអរ រីករាយក្នុងសេនាសនៈព្រៃ កាលព្រាហ្មណ៍ឃើញហើយ ក៏គិតបានមួយរំពេចថា ការនៅយ៉ាងនេះនៃកុលបុត្រទាំងនេះ រាប់ថា ជាការនៅដោយផាសុក ហើយការនៅយ៉ាងផាសុកនេះ កើតព្រោះអាស្រ័យបុគ្គលណា ក៏បានទទួលចម្លើយថា ព្រោះអាស្រ័យព្រះគោតម ទើបជ្រះថ្លាក្នុងព្រះមានព្រះភាគ កាលប្រកាសការជ្រះថ្លានោះ ទើបព្រាហ្មណ៍បានមកកាន់សម្នាក់ព្រះមានព្រះភាគ ដូច្នោះទើបព្រាហ្មណ៍ពោលដូចដែលពោលមកហើយនេះ ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ព្រមទទួល និងទ្រង់អនុមោទនាវាចា នៃព្រាហ្មណ៍នោះ ទើបត្រាស់ពាក្យជាដើមថា **ឯវមេតំ ព្រាហ្មណ** ម្នាលព្រាហ្មណ៍ សេចក្តីនុ៎ះយ៉ាងនោះឯង ។

បទថា **ឯវមេតំ ព្រាហ្មណ** មានអធិប្បាយដូច្នេះថា

បទថា **ឯវំ** នេះ ជានិបាត ប្រើក្នុងអត្ថថា ទទួលរង និងអនុមោទនាវាចា ( របស់អ្នកដទៃ ) ។ បទថា **មមំ ឧទ្ទិស្ស** ប្រែថា ឧទ្ទិសតថាគត ។

ដោយបទថា **សទ្ធា** ព្រះមានព្រះភាគត្រាស់សំដៅយកហេតុផ្សេងៗ មានជាដើមថា ដោយសទ្ធានោះឯង មិនមែនបួសព្រោះជំពាក់បំណុល មិនមែនព្រោះការខ្លាច ព្រោះថា ព្រះមានព្រះភាគ ទ្រង់ជាប្រធាននៃកុលបុត្រដែលមាន

សភាពដូច្នេះប៉ុណ្ណោះ មិនមែនកុលបុត្រពួកដទៃទៀយ ។

[ ២៩ ] បទថា **ទុរភិសម្ភវានិ ហិ** សេចក្តីថា ទ្រាំបានដោយកម្រ គឺអត់ធន់បានលំបាក អធិប្បាយថា ភិក្ខុដែលមានសក្តិតូច មិនអាចនៅអាស្រ័យបាន ។

បទថា **អរញ្ញវនបត្ថានិ** បានដល់ ព្រៃជិត និងព្រៃឆ្ងាយ ។

ក្នុងបទថា **អរញ្ញវនបត្ថានិ** នោះ មានអធិប្បាយថា ពោលក្នុងអភិធម្មហើយ ទីលំនៅចាប់ពីសសរខឿនចេញទៅ លោកហៅថា ព្រៃក៏ពិត ទោះយ៉ាងនោះ ក៏គប្បីជ្រាបថា សេនាសនៈណាដែលឲ្យសម្រេចជាអរញ្ញិកធុតង្គបាន លោកពោលទុកថា ក្នុងទីប្រមាណ ៥០០ ជួរធ្នូ លោកបំណងយកសេនាសនៈនេះប៉ុណ្ណោះ ។

បទថា **វនបត្ថំ** បានដល់ ទីលំនៅហួសចុងស្រុកទៅ មិនមានមនុស្សទៅមករឿយៗ ជាទីដែលមិនមានការភ្ជួររាស់ ។ សេចក្តីនេះ សមដូចពាក្យដែលលោកពោកទុកដូច្នេះថា

**វនបត្ថំ** ជាឈ្មោះរបស់សេនាសនៈដែលនៅឆ្ងាយ ។ ពាក្យថា **វនបត្ថំ** ជាឈ្មោះរបស់ដងព្រៃ ។ ពាក្យថា **វនបត្ថំ** ជាឈ្មោះរបស់ទីលំនៅដែលគួរខ្លាច ។ ពាក្យថា **វនបត្ថំ** ជាឈ្មោះរបស់លំនៅដែលធ្វើឲ្យមានការព្រឺរោម ។ ពាក្យថា **វនបត្ថំ** ជាឈ្មោះរបស់លំនៅចុងដែន ។ ពាក្យថា **វនបត្ថំ** មិនមែនជាឈ្មោះរបស់សេនាសនៈដែលមានមនុស្ស ទៅមកញឹកញាប់ឡើយ ។

ក្នុងទីនេះ ក្រៅអំពីអត្ថនេះតែម្យ៉ាងថា ទីលំនៅចុងដែន គប្បីយល់ថា ព្រៃ

ជាទីលំនៅចុងដែន តាមអត្ថដ៏សេស ។ បទថា **បន្តានិ** បានដល់ ទីលំនៅចុងដែន គឺទីកន្លែងឆ្ងាយខ្លាំង ។ បទថា **ទុក្ករំ បវិវេកំ** សេចក្តីថា កាយ-វិវេក ជាវត្ថុដែលធ្វើបានលំបាក ។ បទថា **ទុរភិរមំ** ប្រែថា កម្រនឹងត្រេកអរ ។ បទថា **ឯកត្តេ** ប្រែថា ក្នុងភាពជាបុគ្គលម្នាក់ គឺនៅម្នាក់ឯង ។

សួរថា ព្រះពុទ្ធតម្រាស់ដែលត្រាស់មកនេះ សម្តែងដល់អ្វី ឆ្លើយថា សម្តែងដល់បំពេញកាយវិវេកបានហើយ ការញុំាងចិត្តឲ្យត្រេកអរក្នុងវិវេកនោះ ក៏ជារបស់ដែលធ្វើបានលំបាក ព្រោះសត្វលោកនេះ តែងត្រេកអរក្នុងការនៅជួបជុំគ្នា ។

បទថា **ហរន្តិ មញ្ញេ** សេចក្តីថា ហាក់ដូចជានាំទៅ គឺដូចជាអូសទាញទៅ ។ បទថា **មនោ** ប្រែថា នូវចិត្ត ។

បទថា **សមាធឹ អលភមានស្ស** សេចក្តីថា របស់ភិក្ខុដែលមិនបានឧបចារសមាធិ ឬអប្បនាសមាធិ ។

សួរថា ព្រះពុទ្ធតម្រាស់ដែលត្រាស់មកនេះ សម្តែងដល់អ្វី ឆ្លើយថា សម្តែងដល់ ព្រៃ ហាក់ដូចជាធ្វើចិត្តរបស់ភិក្ខុនេះឲ្យរាយមាយ ដោយសំឡេងទាំងឡាយ មានសំឡេងស្មៅ សំឡេងស្លឹកឈើ និងសំឡេងសត្វជាដើម និងរូបទាំងអារម្មណ៍ដែលគួរខ្លាចផ្សេងៗ ។ ពាក្យទាំងអស់ដែលពោលមកនេះ ព្រាហ្មណ៍ដែលកើតការត្រេកអរនឹងការនៅព្រៃនៃកុលបុត្រទាំងឡាយ ដែលបួសដោយសទ្ធាពោលទុកហើយ ។

# កាយកម្មកថា

[ ៣០ ] គ្រានោះ ព្រះមានព្រះភាគ កាលទ្រង់ទទួល និងអនុមោទនា-វាចារបស់ព្រាហ្មណ៍នោះ ដោយព្រះតម្រាស់ជាដើមថា **ឯវមេតំ ព្រាហ្មណ** តាមន័យដំបូងនោះឯងហើយ ទើបបានត្រាស់ពាក្យជាដើមថា **មយ្ហំបិ ខោ** ដើម្បីទ្រង់សម្ដែងថា សេនាសនៈប្រភេទនោះ ក៏ជាសេនាសនៈដែលនៅបាន លំបាក សម្រាប់ព្រះអង្គឯង ព្រោះសេនាសនៈប្រភេទនោះ ជាលំនៅលំបាក សម្រាប់ភិក្ខុទាំងឡាយដែលត្រូវអារម្មណ៍ចោមរោម ព្រោះហេតុ ១៦ យ៉ាង តែមិនជាទីនៅលំបាកសម្រាប់ពួកភិក្ខុ ដែលប្រកបដោយការសង្កត់សង្កិន អារម្មណ៍បាន ព្រោះហេតុទាំងនោះហើយ ព្រះអង្គឯងនឹងជាព្រះពោធិសត្វ ក៏ ទ្រង់នៅក្នុងឋានៈដូច្នោះ ។

បទថា **បុព្វេវ សម្ពោធា** សេចក្ដីថា ក្នុងកាលមុនអំពីការត្រាស់ដឹង អធិប្បាយថា ក្នុងវេលាដទៃ ក្រៅអំពីវេលាដែលអរិយមគ្គកើតឡើងនោះ ឯង ។ បទថា **អនភិសម្ពុទ្ធស្ស** បានដល់ មិនទាន់បានត្រាស់ដឹងអរិយសច្ច ៤ ។ បទថា **ពោធិសត្តស្សេវ សតោ** ប្រែថា សត្វដែលនឹងត្រាស់ដឹង គឺ សត្វដែលគួរសម្រេចព្រះសម្មាសម្ពោធិញ្ញាណ ម្យ៉ាងទៀត ដោយអត្ថថា សត្វដែលជាប់ជំពាក់ គឺជាប់ក្នុងពោធិញ្ញាណ ។

ព្រោះថា ចាប់ផ្ដើមតាំងអំពីអភិនីហារសម្រេចដោយសមោធានធម៌ ៨ ប្រការ ទៀបបាទមូលនៃព្រះមានព្រះភាគ ទ្រង់ព្រះនាមថា ទីបង្ករ ព្រះតថាគត ដែលជាព្រះពោធិសត្វ ឬជាសត្វដែលជាប់ជំពាក់ថា ពោធិញ្ញាណនេះ អញ ត្រូវត្រាស់ដឹងឲ្យបាន មិនលះបង់សេចក្ដីព្យាយាម ដើម្បីសម្រេចពោធិញ្ញាណ

នោះមកហើយ ព្រោះដូច្នោះ ទើបហៅថា ពោធិសត្វ ។

[ ៣១ ] បទថា **តស្ស មយ្ហំ** សេចក្ដីថា សម្រាប់តថាគតនោះ គឺបុគ្គលជាព្រះពោធិសត្វយ៉ាងនេះនោះឯង ។

បទថា **យេ ខោ កេចិ សមណា វា ព្រាហ្មណា វា** សេចក្ដីថា សមណៈ ឬព្រាហ្មណ៍ពួកណាមួយ គឺលោកដែលចូលដល់បព្វជ្ជា ឬក៏បុគ្គលដែលមានប្រក្រតីពោលថា **ភោ** ប្រែថា ចម្រើន ។

បទថា **អបរិសុទ្ធកាយកម្មន្តា** ប្រែថា ប្រកបដោយកាយកម្មដែលមិនបរិសុទ្ធ មានបាណាតិបាតជាដើម ។

បទថា **អបរិសុទ្ធកាយកម្មន្តសន្ទោសហេតុ** សេចក្ដីថា ព្រោះហេតុនៃទោសរបស់ខ្លួន ពោល គឺកាយកម្មដែលមិនបរិសុទ្ធ អធិប្បាយថា ព្រោះហេតុនៃកាយកម្មដែលមិនស្អាត ។ បទថា **ហវេ** ជានិបាត ប្រើក្នុងអត្ថថា ដោយចំណែកមួយ ។ បទថា **អកុសលំ** បានដល់ វត្ថុមានទោស និងមិនផុតអំពីភ័យ ។ បទថា **ភយភេរវំ** ប្រែថា ភ័យ និងវត្ថុដែលគួរខ្លាច ។ បទថា **ភយភេរវំ** នេះ ជាឈ្មោះហៅការខ្លាចនៃចិត្ត និងអារម្មណ៍ដែលគួរខ្លាច ។

បណ្ដាភ័យ និងវត្ថុដែលគួរខ្លាចទាំង ២ យ៉ាង ភ័យ គប្បីជ្រាបថា ជាអកុសល ព្រោះមានអត្ថថា មានទោស វត្ថុដែលគួរខ្លាច គប្បីជ្រាបថា ជាអកុសល ព្រោះមានអត្ថថា មិនផុតអំពីភ័យ ។

បទថា **អវ្ហាយន្តិ** ប្រែថា រមែងហៅមក ។

សួរថា រមែងហៅមកដូចម្ដេច ឆ្លើយថា សមណព្រាហ្មណ៍ទាំងនោះ

កាលធ្វើបាបកម្ម មានបាណាតិបាតជាដើម ហើយគិតបានថា អញធ្វើមិនត្រូវហើយ បើបុគ្គលដែលអញធ្វើខុសចំពោះគេ គេស្គាល់អញថាជាអ្នកធ្វើសោត ក៏នឹងត្រូវតាមមកសងសឹកអញ ក្នុងកាលឥឡូវនេះឯង ទើបលបចូលទៅក្នុងព្រៃ អង្គុយពួនទៅក្នុងចន្លោះដើមឈើ ឬគុម្ពឈើ លុះបុគ្គលនោះបានឮសំឡេងស្មៅ ឬសំឡេងស្លឹកឈើ សូម្បីសំឡេងតិចតួច ក៏ភ័យខ្លាច ដោយគិតថា ស្រេចហើយអាត្មាអញ ពេលនេះ បុគ្គលនោះ សោយអារម្មណ៍ហាក់ដូចជាត្រូវគេចាប់សម្លាប់ ដូច្នោះ កាលបើដូច្នោះ សមណព្រាហ្មណ៍ទាំងនោះឈ្មោះថា ជង្ហោយហៅ គឺហៅរកភ័យ និងអារម្មណ៍ដែលគួរខ្លាចនោះចូលមករកខ្លួន ។

បទថា **ន ខោ បនាហំ ។បេ។ បដិសេវាមិ** សេចក្តីថា អាត្មាអញជាអ្នកមានកាយកម្មមិនបរិសុទ្ធ ទើបនៅអាស្រ័យសេនាសនៈស្ងាត់ ដែលជាព្រៃជិត និងជាព្រៃឆ្ងាយបាន ។

បទថា **យេ** ក្នុងពាក្យថា **យេហិ វោ** ត្រឹមតែជានិបាត ព្រះពុទ្ធទាំងឡាយនិងសាវកនៃព្រះពុទ្ធទាំងឡាយ លោកហៅថា ព្រះអរិយៈ ។

បទថា **បរិសុទ្ធកាយកម្មន្តា** សេចក្តីថា ព្រះអរិយៈទាំងឡាយ មានសភាពដូច្នេះ ។

បទថា **អហំ តេសំ អញ្ញតរោ** សេចក្តីថា សូម្បីតថាគតក៏ជាបុគ្គលម្នាក់គឺជាបុគ្គលម្នាក់ ក្នុងបណ្តាព្រះអរិយៈទាំងនោះ ។ សេចក្តីពិតព្រះពោធិសត្វមិនថាជាគ្រហស្ថ មិនថាជាបព្វជិត រមែងជាអ្នកមានកាយកម្មបរិសុទ្ធទាំងអស់ ។

បទថា **ភិយ្យោ** ជានិបាត ប្រើក្នុងអត្ថថា យ៉ាងក្រៃលែង ។

បទថា **បល្លោមំ** ប្រែថា ភាពជាអ្នកមានរោមស្រប អធិប្បាយថា ផុតភ័យ គឺសុវត្ថិភាព ។

បទថា **អាបាទិ** ប្រែថា ដល់ហើយ អធិប្បាយថា ដល់នូវសួស្តីច្រើន ឬសួស្តីដោយអាការច្រើនយ៉ាង ។ ពីរបទថា **អរញ្ញេ វិហារាយ** ប្រែថា ដើម្បីប្រយោជន៍ដល់ការនៅក្នុងព្រៃ ។

**កាយកម្មកថា ចប់**

## វចីកម្មកថាជាដើម

[ ៣២ ] គ្រប់បទមានន័យដូច្នេះ តែដែលប្លែកគ្នាមានដូចតទៅនេះ នឹងពោលក្នុងវារៈវចីកម្មមុន ។ បទថា **អបរិសុទ្ធវចីកម្មន្តា** សេចក្តីថា ប្រកបដោយវចីកម្មដែលមិនបរិសុទ្ធ មានមុសាវាទជាដើម ។

សួរថា សមណព្រាហ្មណ៍ដែលមានវចីកម្មមិនបរិសុទ្ធទាំងនោះ តើហៅរកភ័យ និងអារម្មណ៍គួរខ្លាចមកបានដូចម្តេច ឆ្លើយថា សមណព្រាហ្មណ៍ទាំងនោះ កាលកាត់ប្រយោជន៍របស់អ្នកដទៃ ដោយការនិយាយកុហក បំបែកមិត្រដោយពាក្យញុះញង់ ក៏បំបែកសេចក្តីស្រឡាញ់របស់អ្នកដទៃ ដោយពាក្យគ្រោតគ្រាតក្នុងកណ្តាលបរិសទ្យ ធ្វើឲ្យការងាររបស់អ្នកដទៃខូចបង់ទៅ ដោយវាចាដែលឥតប្រយោជន៍ ហើយគិតបានថា អញធ្វើមិនត្រឹមត្រូវហើយ បើបុគ្គលដែលអញធ្វើខុសចំពោះ ដឹងថា អញជាអ្នកធ្វើ ក៏គង់នឹងតាមមក

សងសឹកអាត្មាអញដូច្នេះឯង ទើបលបចូលព្រៃ ទៅអង្គុយក្នុងចន្លោះដើមឈើ ឬគុម្ពឈើ លុះបុគ្គលនោះបានឮសំឡេងស្មៅ ឬសំឡេងស្លឹកឈើត្រឹមតែតិចតួច ក៏ភ័យខ្លាច ដោយគិតថា ស្រេចហើយអញគ្រានេះ បុគ្គលនោះសោយអារម្មណ៍ហាក់ដូចមានអ្នកដទៃមកឡោមព័ទ្ធ និងហាក់ដូចជាត្រូវគេចាប់សម្លាប់ ដូច្នោះ ។ សមណព្រាហ្មណ៍ទាំងនោះ ឈ្មោះថា ទទួលគឺហៅរកភ័យ និងអារម្មណ៍ដែលគួរខ្លាចនោះឲ្យចូលមករកខ្លួន ។

នឹងពោលក្នុងវារៈមនោកម្ម ។ បទថា **អបរិសុទ្ធមនោកម្មន្តា** សេចក្តីថា ប្រកបដោយមនោកម្មដែលមិនបរិសុទ្ធ មានអភិជ្ឈាជាដើម ។

សួរថា សមណព្រាហ្មណ៍ ដែលមានមនោកម្មមិនបរិសុទ្ធទាំងនោះ តើដង្ហោយហៅរកភ័យ និងអារម្មណ៍ដែលគួរខ្លាចដូចម្តេច ឆ្លើយថា សមណ-ព្រាហ្មណ៍ទាំងនោះ កាលកើតសេចក្តីលោភប្រភេទដែលដាច់ការប្រព្រឹត្តតាមធម៌ បានដល់ អភិជ្ឈា ( សម្លឹងចង់បានរបស់អ្នកដទៃ ) ក្នុងវត្ថុដែលអ្នកដទៃរក្សាគ្រប់គ្រងហើយ ទឹងក្រោធអ្នកដទៃ និងឲ្យអ្នកដទៃប្រកាន់ទស្សនៈដែលខុសទៅ ហើយគិតបានថា អញធ្វើមិនត្រឹមត្រូវហើយ ។បេ។ ឈ្មោះថាដង្ហោយហៅ គឺហៅរកភ័យ និងអារម្មណ៍ដែលគួរខ្លាចនោះចូលមករកខ្លួន ។

នឹងពោលក្នុងវារៈអាជីវៈ ។ បទថា **អបរិសុទ្ធាជីវា** សេចក្តីថា ប្រកបដោយអាជីវៈដែលមិនបរិសុទ្ធ ចែកប្រភេទជាអនេសនា ២១ យ៉ាង មានធ្វើជាពេទ្យរក្សារោគ ជាទូតបញ្ជូនដំណឹង និងលក់ដូរជាដើម ។

សួរថា សមណព្រាហ្មណ៍ដែលមានអាជីវៈមិនបរិសុទ្ធទាំងនោះ តើហៅ

រកភ័យ និងអារម្មណ៍ដែលគួរខ្លាចមកបានដូចម្ដេច ឆ្លើយថា សមណព្រាហ្មណ៍ទាំងនោះ កាលចិញ្ចឹមជីវិតយ៉ាងនោះ បានឮដំណឹងថា ពួកភិក្ខុទ្រទ្រង់ព្រះត្រៃបិដក ដែលធ្វើកិច្ចជម្រះព្រះសាសនាឲ្យបរិសុទ្ធ កំពុងចេញទៅ ជម្រះមន្ទិលព្រះសាសនា ថ្ងៃនេះ ឬស្អែកនេះ ក៏នឹងធ្វើដំណើរមកដល់ទីនេះ បានឮយ៉ាងនោះហើយ ទើបគេចចូលទៅព្រៃ អង្គុយលាក់ខ្លួនត្រង់ចន្លោះដើមឈើ ឬគុម្ពឈើ ។បេ។ មានការភ័យខ្លាច លោកសោយអារម្មណ៍ហាក់ដូចជាភិក្ខុទាំងនោះមកព័ទ្ធចាប់ និងដូចត្រូវចាប់ផ្សឹក ឲ្យស្លៀកសំពត់ស ។ ពាក្យដ៏សេសក៏ដូចគ្នាដែលពោលមកហើយនោះឯង ។

[ ៣៣ ] ក្នុងបទថា **ឥតោ បរំ អភិជ្ឈាលុ** ជាដើម អធិប្បាយថា អភិជ្ឈា និងព្យាបាទ សង្គ្រោះចូលក្នុងមនោកម្មក៏ពិត ទោះយ៉ាងនោះ គប្បីជ្រាបថា លោកពោលដដែលទុកទៀត ដោយអំណាចនីវរណៈ ។

បណ្ដាបទទាំងនោះ បទថា **អភិជ្ឈាលុ** បានដល់ បុគ្គលមានប្រក្រតីសម្លឹងដល់ទ្រព្យរបស់អ្នកដទៃ ។ បទថា **កាមេសុ តិព្វសារាគោ** បានដល់ បុគ្គលមានកិលេស មានរាគៈយ៉ាងខ្លាំងក្លាក្នុងវត្ថុកាមទាំងឡាយ ។

សួរថា សមណព្រាហ្មណ៍ដែលមានកិលេស គឺរាគៈខ្លាំងក្លាទាំងនោះ តើហៅរកភ័យ និងអារម្មណ៍ដែលគួរខ្លាចមកបានដូចម្ដេច ឆ្លើយថា សមណព្រាហ្មណ៍ទាំងនោះ មិនបានពិចារណាអារម្មណ៍ឲ្យល្អិតល្អន់ កាលលោកមិនបានធ្វើការពិចារណាអារម្មណ៍ឲ្យល្អិតល្អន់ នៅក្នុងព្រៃ វត្ថុដែលឃើញក្នុងពេលថ្ងៃ រមែងប្រាកដជាភ័យ និងជារបស់គួរខ្លាចក្នុងពេលយប់ លោកមាន

ចិត្តជាអកុសល រមែងស្រៀវខ្លាចដោយភ័យ និងវត្ថុដែលគួរខ្លាច សូម្បីត្រឹមតិចតួច គឺឃើញខ្សែ ឬវល្លិ ក៏សម្គាល់ថាជាពស់ ឃើញជន្ទត់ ក៏សម្គាល់ថាជាយក្ខ ឃើញដីទួល ឬភ្នំ សម្គាល់ថា ជាដំរី ហាក់ដូចជាត្រូវសត្វកាចមានពស់ជាដើមបៀតបៀន ដូច្នោះ ។ ពាក្យដ៏សេសក៏ដូចគ្នាដែលពោលមកហើយនោះឯង ។

បទថា **ព្យាបន្នចិត្តា** ប្រែថា មានចិត្តវិបត្តិទៅ ព្រោះលះសភាពប្រក្រតីចោល ។ សេចក្តីពិត ចិត្តដែលជាប់ជំពាក់ជាមួយកិលេស រមែងលះសភាពប្រក្រតី ត្រឡប់ក្លាយជាចិត្តអប្បអន់ទៅ ដូចបាយ និងម្ហូបចាស់ ដែលផ្អូមដូច្នោះ ។

[ ៣៤ ] បទថា **បទុដ្ឋមនសង្កប្បា** ប្រែថា មានចិត្តគិតទៅក្នុងផ្លូវមិនល្អ អធិប្បាយថា ប្រកបដោយការត្រិះរិះនៃចិត្តដែលមិនល្អ គឺធ្វើអ្នកដទៃឲ្យខូចប្រយោជន៍ ។

សួរថា សមណព្រាហ្មណ៍ដែលមានចិត្តវិបត្តិ គិតទៅក្នុងផ្លូវដែលមិនល្អទាំងនោះ តើហៅរកសេចក្តីខ្លាច និងអារម្មណ៍ដែលគួរខ្លាចបានដូចម្តេច ឆ្លើយថា រាប់តាំងអំពីនេះទៅ ការហៅរកសេចក្តីខ្លាច និងអារម្មណ៍ដែលគួរខ្លាចគប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងវារៈដែលពោលដោយ **អភិជ្ឈាលុ** នោះឯង ។ តែក្នុងទីណាដែលមានការប្លែកគ្នា ខ្ញុំនឹងអធិប្បាយ ពោលទុកក្នុងទីនោះ ។

ក្នុងព្រះតម្រាស់នេះថា **ន ខោ បនាហំ ព្យាបន្នចិត្តោ** ព្រះមានព្រះភាគ

ទ្រង់សម្តែងថា តថាគតមានចិត្តប្រកបទៅដោយមេត្តា មានចិត្តគិតប្រយោជន៍ ជាធម្មតា ព្រះពោធិសត្វទាំងឡាយរមែងមានសភាពដូច្នេះទាំងអស់ បណ្ឌិត គប្បីពណ៌នាគុណរបស់ព្រះពោធិសត្វ ដោយអំណាចនៃការផ្ទុយគ្នានឹងទោស ដែលពោលទុកក្នុងបទទាំងអស់នេះ ។

[ ៣៥ ] បទថា **ថីនមិទ្ធបរិយុដ្ឋិតា** ប្រែថា ដែលថីនៈ គឺការពិការ របស់ចិត្ត និងមិទ្ធៈ គឺការពិការរបស់គំនរនាមដ៏សេស ( វេទនា សញ្ញា និង សង្ខារ ) ចោមរោមហើយ អធិប្បាយថា គ្របសង្កត់ គឺគ្រប់គ្រង ។ សមណព្រាហ្មណ៍ដែលត្រូវថីនមិទ្ធៈចោមរោមហើយ រមែងដេកលក់ ។

[ ៣៦ ] បទថា **ឧទ្ធតា** ប្រែថា មានប្រក្រតីរាយមាយ គឺមានចិត្តបម្រះ នទៀល អធិប្បាយថា ចិត្តរមែងបម្រះនទៀលទៅអំពីឯកគ្គតារម្មណ៍ដោយ ឧទ្ធច្ចៈ ដូចសំពត់ គឺទង់បក់បោកជង់ទង់ព្រោះខ្យល់ដូច្នោះ ។

បទថា **អវូបសន្តចិត្តា** ប្រែថា មានចិត្តមានអារម្មណ៍មិនរលត់ ( មិន ស្ងប់ ) ក្នុងទីនេះ ប្រារព្ធដល់កុក្កុច្ចៈ គឺការក្តៅក្រហាយក៏បាន ។

[ ៣៧ ] ក្នុងព្រះពុទ្ធវចនៈនេះថា **កង្ខី វិចិកិច្ឆី** ជាបទតែមួយនោះឯង ព្រោះនីវរណៈទី ៥ ព្រះមានព្រះភាគត្រាស់ហៅថា **កង្ខា** ព្រោះសង្ស័យក្នុង អារម្មណ៍ថា អារម្មណ៍នេះដូច្នេះឬហ្ន៎ ត្រាស់ហៅថា **វិចិកិច្ឆា** ព្រោះមិនអាច សម្រេចបានថា អារម្មណ៍នេះ យ៉ាងនេះ ដូច្នេះ ។ សមណព្រាហ្មណ៍ដែល ប្រកបដោយកង្ខា និងវិចិកិច្ឆានោះ ព្រះមានព្រះភាគត្រាស់ថា **កង្ខី វិចិកិច្ឆី** គឺបុគ្គលមានសេចក្តីសង្ស័យ មិនអាចកាត់សម្រេចអារម្មណ៍បាន ។

[ ៣៨ ] បទថា **អត្តុក្កំសកា បរវម្ភី** សេចក្ដីថា សមណព្រាហ្មណ៍ពួកណា លើកតម្កើងខ្លួនឡើង បានដល់ លើកខ្លួនខ្ពស់ និងសង្កត់សង្កិន គឺមើលងាយ បានដល់ តិះដៀលអ្នកដទៃ ដោយអត្ថថា ដាក់អ្នកដទៃឲ្យទាបជាងខ្លួន ពីរបទនោះ គឺ **អត្តុក្កំសកា បរវម្ភី** ត្រឹមតែជាពាក្យហៅសមណ-ព្រាហ្មណ៍ទាំងនោះ ។

សួរថា សមណព្រាហ្មណ៍ដែលលើកខ្លួន សង្កត់សង្កិនអ្នកដទៃនោះ តើហៅរកភ័យ និងអារម្មណ៍ដែលគួរខ្លាចមកបានដូចម្ដេច ឆ្លើយថា ការហៅរកភ័យរបស់សមណព្រាហ្មណ៍ដែលលើកខ្លួន សង្កត់សង្កិនអ្នកដទៃនោះ បណ្ឌិតគប្បីឲ្យពិស្ដារដូចគ្នានឹងកាយកម្មថា សមណព្រាហ្មណ៍លើកខ្លួន សង្កត់សង្កិនអ្នកដទៃទាំងនោះ ត្រូវអ្នកដទៃតាមចាប់ទោសថា បានឮថា លោកឈ្មោះនោះ និងឈ្មោះនោះលើកខ្លួន តិះដៀលពួកយើង ធ្វើឲ្យដូចជាទាសៈ ចូរចាប់ខ្លួនឲ្យបាន ដូច្នេះ លោកគេចទៅចូលព្រៃ ហើយអង្គុយពួនក្នុងចន្លោះដើមឈើនិងគុម្ពឈើ ។

[ ៣៩ ] បទថា **ឆម្ភី** ប្រែថា ប្រកបដោយការភ័យខ្លាច ដែលធ្វើឲ្យកាយបសាទស្រៀវខ្លាច និងព្រឺរោម ។

បទថា **ភិរុកជាតិកា** ប្រែថា ច្រើនទៅដោយការខ្លាច អធិប្បាយថា មិនក្លាហាន ដូចក្មេងអ្នកស្រុកដែលកំសាក ដូច្នោះ ។

[ ៤០ ] ក្នុងបទថា **លាភសក្ការសិលោកោ** នេះ មានអធិប្បាយថា ដែលឈ្មោះថា លាភ ព្រោះអត្ថថា ដែលបុគ្គលរមែងបាន ពាក្យថា លាភនោះ

ជាឈ្មោះហៅបច្ច័យ ៤ ។

បទថា **សក្ការោ** ប្រែថា សក្ការៈដែលល្អ ។ អធិប្បាយថា បច្ច័យទាំងឡាយដែលគេតាក់តែងឲ្យប្រណីត ប្រណីត និងល្អ ហៅថា សក្ការៈ ដែលបានដល់ ការដែលអ្នកដទៃធ្វើសេចក្ដីគោរពខ្ពួន ឬបូជាដោយគ្រឿងបូជា មានផ្កាជាដើម ។

បទថា **សិលោកោ** ប្រែថា ការពោលសរសើរគុណ លាភ ១ សក្ការៈ ១ ការពោលសរសើរ ១ នោះ ឈ្មោះថា លាភសក្ការៈ និងសិលោកៈ ។

បទថា **ឆិកាមយមានា** ប្រែថា ប្រាថ្នា ។

ការហៅរកភ័យ និងអារម្មណ៍ដែលគួរខ្លាច ដូចដែលពោលក្នុងវគ្គអភិជ្ឈាលុនោះឯង ។ ចំណែកក្នុងទីនេះ បុរាណាចារ្យទាំងឡាយ បានពោលដល់បិយគាមិកភិក្ខុដែលជាឧទាហរណ៍ក្នុងរឿងនោះថា

## រឿង បិយគាមិកភិក្ខុ

បានឮមកថា ភិក្ខុមួយអង្គ ឈ្មោះបិយគាមិកៈ ឃើញលាភរបស់ពួកភិក្ខុដែលសមាទានធុតង្គ ហើយគិតថា អញនឹងសមាទានធុតង្គ ធ្វើលាភឲ្យកើតឡើងផងដែរ ដូច្នេះហើយ សមាទានសោសានិកង្គធុតង្គ គឺការនៅក្នុងស្មសានជាវត្ត ហើយក៏នៅក្នុងព្រៃខ្មោច ។

តមកថ្ងៃមួយ គោចាស់មួយក្បាលដែលម្ចាស់ឈប់ប្រើការហើយ ដោះលែងចោល នៅពេលថ្ងៃក៏ត្រាច់ដើររកស៊ី លុះដល់ពេលយប់ ក៏ចូលទៅក្នុងព្រៃខ្មោចនោះ បានឈរបេះរោម ស៊កក្បាលចូលក្នុងគុម្ពផ្កា ។ បិយគាមិកភិក្ខុ

ចេញអំពីទីចង្ក្រមទៅក្នុងពេលយប់ បានឮសំឡេងត្រដោករបស់គោនោះប៉ះខ្ទប់គ្នាហើយ ក៏យល់ថា សក្កទេវរាជ គង់ជ្រាបអញថា ភិក្ខុរូបនេះត្រូវការលាភ ទើបមកនៅក្នុងព្រៃខ្មោច ដូច្នេះហើយ មកដើម្បីប្រទូស្តអញពិត ។ ទើបលោកឈរផ្គងអញ្ជលីខាងមុខគោចាស់ អង្វររហូតមួយយប់ទល់ភ្លឺថា បពិត្រសក្កទេវរាជ បុគ្គលដ៏ជាសប្បុរស សូមព្រះអង្គលើកទោសឲ្យអាត្មាមួយយប់នេះចុះ ហើយតាំងអំពីស្អែកនេះទៅ អាត្មានឹងមិនធ្វើយ៉ាងនេះទៀតឡើយ លុះព្រះអាទិត្យរះឡើង លោកក៏បានឃើញគោចាស់នោះ ទើបយកដំបងដេញវាយទៅ ព្រមទាំងដេញថា ឯងធ្វើឲ្យអញខ្លាចអស់មួយយប់ទៅហើយ ។

[ ៤១ ] បទថា **កុសីតា** ប្រែថា ធ្លាក់នៅក្នុងអំណាចការខ្ជិលច្រអូស ។ បទថា **ហីនវីរិយា** សេចក្តីថា វិនាស គឺវៀរ បានដល់ ប្រាសចាកការព្យាយាម អធិប្បាយថា មិនមានសេចក្តីព្យាយាម ។ ក្នុងបុគ្គល ២ ពួកនោះ បុគ្គលដែលខ្ជិលច្រអូស រមែងវៀរចាកការផ្តើមសេចក្តីព្យាយាមផ្លូវកាយ បុគ្គលដែលដាច់នូវការព្យាយាម រមែងវៀរចាកការផ្តើមសេចក្តីព្យាយាមផ្លូវចិត្ត ជនទាំង ២ ពួកនោះ រមែងមិនអាចធ្វើត្រឹមតែការកំណត់អារម្មណ៍បាន ។ ពាក្យទាំងអស់ថា **តេសំ អវវត្ថិតារម្មណានំ** មានអត្ថដូចគ្នាដែលពោលមកអំពីមុនហើយ ។

[ ៤២ ] បទថា **មុដ្ឋស្សតី** ប្រែថា មិនមានស្មារតី ។

បទថា **អសម្បជានា** ប្រែថា ប្រាសចាកបញ្ញា ក៏ព្រោះព្រះពុទ្ធតម្រាស់

ថា តថាគតជាអ្នកមានសតិតាំងមាំហើយ ក្នុងអត្ថដែលផ្ទុយគ្នានឹងពាក្យនេះ ថា **មុដ្ឋស្សតី** ព្រះតម្រាស់ថា **អសម្បជានា** នេះ ទើបជាបទពង្រីកសតិប៉ុណ្ណោះ ចំណែកបញ្ញាក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ទុកដើម្បីសម្ដែងដល់សតិដែលខ្សោយកម្លាំង ។ ព្រោះថា សតិមាន ២ យ៉ាង គឺសតិដែលប្រកបដោយបញ្ញា ១ សតិដែលមិនប្រកបដោយបញ្ញា ១ ក្នុងសតិទាំង ២ នោះ សតិប្រកបដោយបញ្ញា រមែងមានកម្លាំង សតិដែលមិនប្រកបដោយបញ្ញា រមែងខ្សោយកម្លាំង ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **អសម្បជានា** ( មិនមានបញ្ញា ) ដើម្បីសម្ដែងអត្ថនេះថា សូម្បីក្នុងវេលាដែលភិក្ខុទាំងនោះមានសតិ ក៏នៅតែមានឈ្មោះថា មិនមានស្មារតីនោះឯង ព្រោះមិនមានបញ្ញា ព្រោះថា សតិដែលខ្សោយកម្លាំង ធ្វើកិច្ចនៃសតិមិនបាន ។ ភិក្ខុទាំងនោះមិនមានស្មារតី បាត់បង់សម្បជញ្ញៈ គឺបញ្ញាដូចពោលមកនេះ រមែងមិនអាចធ្វើត្រឹមតែការកំណត់អារម្មណ៍បានឡើយ ។ ពាក្យដ៏សេសទាំងអស់មានអត្ថដូចបានពោលហើយ ។

[ ៤៣ ] បទថា **អសមាហិតា** ប្រែថា វៀរចាកឧបចារសមាធិ និងអប្បនាសមាធិ ។

បទថា **វិព្ភន្តចិត្តា** ប្រែថា មានចិត្តរសាត់ចេញក្រៅផ្លូវ គឺចិត្តត្រាច់ទៅក្នុងអារម្មណ៍ផ្សេងៗ ព្រោះវៀរចាកសមាធិ បានដល់ ព្រោះលោកទាំងនោះមិនមានសមាធិ ព្រោះឧទ្ធច្ចៈបានឱកាស ប្រៀបដូចស្វាក្នុងព្រៃ លោតមកតាមមែកឈើក្នុងព្រៃ ដូច្នោះ ភិក្ខុទាំងនោះ ជាអ្នកមិនគង់នៅក្នុងអារម្មណ៍សូម្បី

តែម៉្យាង គឺមានចិត្តវិលទៅផ្សេងៗ តាមន័យដែលពោលហើយ ក្នុងវគ្គខាងដើមយ៉ាងនេះ ព្រោះឧទ្ធច្ចៈ រមែងមិនអាចធ្វើត្រឹមតែការកំណត់អារម្មណ៍បានឡើយ ។ ពាក្យដ៏សេសទាំងអស់ មានអត្ថដូចគ្នានឹងអត្ថដែលពោលមកហើយខាងដើម ។

[ ៤៤ ] បទថា **ទុប្បញ្ញា** នេះ ជាពាក្យសម្រាប់ហៅបុគ្គលដែលមិនមានបញ្ញា តែបញ្ញាដែលឈ្មោះថា ថោកទាបមិនមាន ។

បទថា **ឯឡមូគា** ប្រែថា មានមាត់ពេញទៅដោយទឹកមាត់ លោកផ្លាស់ **ខ** អក្ខរៈ ឲ្យជា **គ** អក្ខរៈ ទើបសម្រេចរូបជា **ឯឡមូគា** អធិប្បាយថា មានមាត់ទឹកមាត់ហូរចេញ ។ ព្រោះថា កាលបុគ្គលមានបញ្ញាថោកថយនិយាយ ទឹកមាត់នឹងហូរចេញមកអំពីមាត់ ទឹកមាត់ លោកហៅថា **ឯឡ** ។ ដូចលោកពោលទុកថា **បស្សេឡមូគំ ឧរគំ ទុជ្ជិវ្ហំ** អ្នកចូរមើលពស់មានទឹកមាត់ហូរចេញ កំពុងលៀនអណ្តាតបែកជា ២ ។ ព្រោះដូច្នោះ ទើបភិក្ខុអ្នកមានបញ្ញាថោកថយទាំងនោះ ព្រះមានព្រះភាគត្រាស់ហៅថា **ឯឡមូគា** បាឋៈថា **ឯឡមុខា** ដូច្នេះក៏មាន ។ អាចារ្យពួកខ្លះពោលថា **ឯឡមុក្ខា** ក៏មាន តែអាចារ្យមួយពួកទៀតប្រែជាពោលថា **ឯមុខា** ដូច្នេះក៏មាន ។ តែទោះជាយ៉ាងណា ក្នុងបទទាំងអស់មានអត្ថថា **ឯឡមុខា** មានទឹកមាត់ហូរមិនដាច់ ។

សួរថា ភិក្ខុអ្នកមានបញ្ញាគ្រោតគ្រាតទាំងនោះ រមែងហៅរកភ័យ និងអារម្មណ៍ដែលគួរខ្លាចបានដូចម្តេច ឆ្លើយថា ភិក្ខុមានបញ្ញាថោកទាប មានទឹកមាត់ហូរចេញទាំងនោះ មិនអាចធ្វើត្រឹមតែការកំណត់អារម្មណ៍ កាល

លោកកំណត់អារម្មណ៍មិនបាននៅក្នុងព្រៃ វត្ថុដែលឃើញក្នុងវេលាថ្ងៃ លុះវេលាយប់ក៏ប្រាកដជាភ័យ និងអារម្មណ៍ដែលគួរខ្លាច លោកមានចិត្តផ្តេសផ្តាស រមែងស្រៀវខ្លាចដោយអារម្មណ៍ត្រឹមតែតូចតាច ឃើញខ្សែ ឬវល្លិហើយ រមែងសម្គាល់ថា ជាពស់ ឃើញជន្លត់ រមែងសម្គាល់ថា ជាយក្ខ ឃើញទីទួល ឬភ្នំ រមែងសម្គាល់ថា ជាដំរី រមែងភ័យខ្លាច ហាក់ដូចត្រូវសត្វសាហាវ មានពស់ជាដើមប្រទូស្ត ដូច្នោះ ។ ភិក្ខុអ្នកមានបញ្ញាថោកទាបទាំងនោះ ឈ្មោះថា ហៅ គឺហៅរកភ័យ និងអារម្មណ៍ដែលគួរខ្លាចនោះឲ្យចូលមករកខ្លួនដូចពណ៌នាមក ដូច្នេះ ។

ក្នុងបទថា **បញ្ញាសម្បន្នោហមស្មិ** នេះ មានអធិប្បាយថា បុគ្គលដល់ព្រម គឺបុគ្គលប្រកបដោយបញ្ញា ។ តែមិនមែនដោយវិបស្សនាបញ្ញា មិនមែនដោយមគ្គប្បញ្ញា ដោយពិតហើយ ប្រកបព្រមដោយបញ្ញា និងគ្រឿងកំណត់អារម្មណ៍ ព្រោះហេតុទាំង ១៦ នេះ ។ ពាក្យដ៏សេសមានអត្ថ ដូចពោលហើយក្នុងបទទាំងអស់ ដូច្នេះ ។

**បរិយាយ ១៦ ចប់**

## អធិប្បាយ សេនាសនៈគួរភ័យខ្លាច

[ ៤៥ ] បទថា **តស្ស មយ្ហំ** មានអនុសន្ធិដូចម្តេច ។

បានឮថា ព្រះពោធិសត្វកំណត់អារម្មណ៍ទាំង ១៦ នេះ កាលមើលមិនឃើញការខ្លាច និងអារម្មណ៍ដែលគួរខ្លាច ទើបបានធ្វើការត្រិះរិះថា ការខ្លាច

និងអារម្មណ៍ដែលគួរខ្លាចនោះ លោកត្រិះរិះថា ធម្មតាការខ្លាច និងអារម្មណ៍ដែលគួរខ្លាច រមែងប្រាកដក្នុងសេនាសនៈយ៉ាងនេះ ក្នុងរាត្រីយ៉ាងនេះ ណ្ហើយចុះ អញនឹងពិនិត្យមើលការខ្លាច និងអារម្មណ៍ដែលគួរខ្លាចនោះ ក្នុងសេនា-សនៈយ៉ាងនោះ ក្នុងរាត្រីយ៉ាងនោះ ទើបបានស្វែងរកភ័យ និងអារម្មណ៍ដែលគួរខ្លាច ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងអត្ថនេះដល់ព្រាហ្មណ៍ ទើបបានត្រាស់ពាក្យថា **តស្ស មយ្ហំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **យា តា** នោះ ជាពាក្យលើកឡើងនូវរាត្រីតែម្យ៉ាងសម្តែង ។ សព្ទថា **អភិ** ក្នុងបទថា **អភិញ្ញាតា** នេះ ជាឧបសគ្គចុះក្នុងអត្ថថា លក្ខណៈ គឺការកំណត់ ព្រោះដូច្នោះ ក្នុងបទថា **អភិញ្ញាតា** គប្បីជ្រាបថា រាត្រីទាំងឡាយ លោកកំណត់ដោយលក្ខណៈទាំងឡាយជាដើមយ៉ាងនេះថា ព្រះចន្ទពេញវង់ ព្រះចន្ទលិច ។

ចំណែកសព្ទថា **អភិ** ក្នុងបទថា **អភិលក្ខិតា** ត្រឹមតែជាឧបសគ្គប៉ុណ្ណោះ ព្រោះដូច្នោះ ទើបមានអត្ថថា **អភិលក្ខិតា** គឺ **លក្ខណីយា** នោះឯង ។ ពន្យល់សេចក្តីថា រាត្រីទាំងឡាយដែលបណ្ឌិតគប្បីកំណត់ អធិប្បាយថា គប្បីកំណត់ដោយល្អ គឺគប្បីកំណត់ឲ្យមាំ ដើម្បីធ្វើកិច្ច មានការសមាទានឧបោសថ ការស្តាប់ធម៌ និងការបូជាសក្ការៈជាដើម ។

ដែលឈ្មោះថា **ចាតុទ្ទសី** បានដល់ រាត្រីមួយដែលធ្វើឲ្យគ្រប់ ១៤ ថ្ងៃ ចាប់ផ្តើមពីថ្ងៃដំបូងនៃបក្ខ ។ **បញ្ចទសី** និង **អដ្ឋមី** ក៏មានអត្ថយ៉ាងនោះ ។ បទថា **បក្ខស្ស** បានដល់ នៃសុក្កបក្ខ និងកណ្ហបក្ខ ព្រោះរួមរាត្រីទាំងនោះ

ចូលមួយបក្ខ ៣ រាត្រី ទើបជា ៦ រាត្រី ដូច្នោះ ទើបគួរប្រកបពាក្យថា បក្ខ ទុកក្នុងគ្រប់បទថា **បក្ខស្ស ចាតុទ្ទសី** តិថីទី ១៤ នៃបក្ខ **បក្ខស្ស បញ្ចទសី** តិថីទី ១៥ នៃបក្ខ **បក្ខស្ស អដ្ឋមី** តិថីទី ៨ នៃបក្ខ ។

សួរថា បើយ៉ាងនោះ ព្រោះហេតុអ្វី ទើបលោកមិនចាត់តិថីទី ៥ ចូលផង ឆ្លើយថា ព្រោះតិថីទី ៥ មិនមានសព្វកាល សេចក្តីថា ក្នុងវគ្គមុនៗ កាលព្រះមានព្រះភាគ ទ្រង់មិនទាន់កើតឡើងក្តី ទ្រង់កើតឡើងហើយមិនទាន់បរិនិព្វានក្តី តិថីទី ៥ លោកមិនបានកំណត់ទុកឡើយ លុះព្រះមានព្រះភាគទ្រង់រលត់ខន្ធបរិនិព្វានហើយ ទើបព្រះធម្មសង្គាហកត្ថេរទាំងឡាយ នាំគ្នាគិតថា ការស្តាប់ធម៌ យូរៗ មានម្តង ។ បន្ទាប់អំពីនោះ ទើបសន្មតកំណត់តិថីទី ៥ ឲ្យជាថ្ងៃធម្មសវនៈ ។ តាំងអំពីនោះមក ទើបតិថីទី ៥ ក្លាយជាថ្ងៃដែលលោកកំណត់ទុកហើយ ព្រោះហេតុដែលតិថីទី ៥ មិនមានសព្វកាលយ៉ាងនេះឯង ទើបលោកមិនសង្គ្រោះទុកក្នុងទីនេះ ។

បទថា **តថារូបាសុ** ក៏គឺ **តថាវិធាសុ** ប្រែថា យ៉ាងនោះ ។

បទថា **អារាមចេតិយានិ** សេចក្តីថា ទីកដីដែលគួររីករាយទាំងឡាយ ដូចជា សួនផ្កា សួនផ្លែឈើជាដើមនោះឯង ឈ្មោះថា **អារាមចេតិយ** ព្រោះថា ទីទាំងនោះ ហៅថា ចេតិយ ដោយអត្ថថា ជាទីកោតក្រែង អធិប្បាយថា ព្រោះជាទីកន្លែងដែលគប្បីបូជា ។

បទថា **វនចេតិយានិ** សេចក្តីថា ព្រៃទាំងឡាយ ដូចជាព្រៃសម្រាប់នាំគ្រឿងបូជាទៅបូជា ព្រៃសុភគវន្ត និងព្រៃដែលមានខ្មួមទេវតាជាដើម នោះឯង

ឈ្មោះថា **វនចេតិយ** ។

បទថា **រុក្ខចេតិយានិ** សេចក្តីថា ដើមឈើដែលគួរបូជាតាមច្រកទ្វារចូលស្រុក និងនិគមជាដើមនោះឯង ឈ្មោះថា **រុក្ខចេតិយ** ។

ព្រោះសត្វលោកសម្គាល់ថា ទេវតាចូលនៅខ្លះ មានការសម្គាល់ក្នុងទីទាំងនោះឯងថា ជាទិព្វខ្លះ គប្បីនាំគ្នាធ្វើការគោរព គឺបូជាចំពោះព្រៃ និងដើមឈើទាំងឡាយ ដូច្នោះ ទើបព្រៃ និងដើមឈើទាំងអស់នោះ គេនាំគ្នាហៅថា **ចេតិយ** ។

បទថា **ភឹសនកានិ** ប្រែថា ឲ្យកើតការខ្លាច គឺញុំាងការខ្លាចឲ្យកើតដល់អ្នកឃើញផង ដល់អ្នកបានឮផង ។

បទថា **សលោមហំសានិ** ប្រព្រឹត្តទៅជាមួយនឹងការព្រឺរោមព្រឺស្បែក ព្រោះកាលបុគ្គលណាមួយចូលទៅ ក៏កើតការព្រឺរោមព្រឺស្បែក ។

បទថា **អប្បេវ នាម បស្សេយ្យំ** សេចក្តីថា ធ្វើម្តេចហ្ន៎ អញគប្បីបានជួបភ័យ និងអារម្មណ៍គួរខ្លាចនោះខ្លះ ។

បទថា **អបរេន សមយេន** សេចក្តីថា ដោយកាលដទៃអំពីកាលដែលគិតទុកហើយ យ៉ាងនេះថា តថាគតនោះ មានការគិតដូច្នេះថា ធ្វើម្តេចហ្ន៎ អញ ... ។

បទថា **តត្ថ ច មេ ព្រាហ្មណ វិហរតោ** ប្រែថា ម្នាលព្រាហ្មណ៍ កាលតថាគតនៅក្នុងទីទាំងនោះ សេចក្តីថា បណ្តាសេនាសនៈទាំងនោះ សេនាសនៈណាមួយ ដែលជាទីអាស្រ័យរបស់យក្ខ ដែលមនុស្សទាំងឡាយ

គួរស្បើម និងនាំគ្រឿងយញ្ញចូលទៅបូជា មានទីដីដេរដាសដោយគ្រឿងបូជា និងគ្រឿងយញ្ញទាំងឡាយ ដូចជា ផ្កា ផ្សែងក្រអូប សាច់ ឈាម ខ្លាញ់រាវ ខ្លាញ់ខាប់ រាវ សួត សុក និងមេរ័យជាដើម ហាក់ដូចជាទីដែលប្រមូលប្រជុំគ្នា របស់ពួកយក្ខ អារក្ខ និងបិសាច កាលមនុស្សទាំងឡាយមកឃើញ ក្នុងពេលថ្ងៃ បេះដូងហាក់ស្ទើរបែកស្លាប់ ។ ព្រះមានព្រះភាគទ្រង់សំដៅយកទីនោះ ទើបត្រាស់ថា **តត្ថ ច មេ ព្រាហ្មណ វិហរតោ ។**

បទថា **មិគោ វា អាគច្ឆតិ** សេចក្តីថា ម្រឹគដែលចែកប្រភេទជាក្តាន់ រមាស ខ្លាដំបង និងជ្រូកព្រៃជាដើម ដើរលោតស៊ែន្ទង ឬទាត់ក្រួចកជើងគ្នាមក ពាក្យថា **មិគោ** ក្នុងទីនេះ ជាឈ្មោះសត្វជើង ៤ គ្រប់ប្រភេទ ។ តែក្នុងទីខ្លះ **មិគ** លោកពោលថា បានដល់ ចចកខ្វាក់ក៏មាន ដូចដែលសត្វក្អែកពោលបញ្ជោរចចកខ្វាក់ថា

ករបស់អ្នកដូចកនៃគោឧសភៈ ការមើតពត់របស់អ្នក ដូចជាការមើតពត់នៃសត្វសីហៈ ដូច្នោះ បពិត្រមិគរាជ ខ្ញុំសូមថ្វាយបង្គំអ្នក ធ្វើម្តេចយើងនឹងបាននូវសាច់តិចតួច ។

បទថា **មោរោ វា កដ្ឋំ ចាតេតិ** សេចក្តីថា ក្អែកធ្វើឲ្យមែកឈើស្ងួតធ្លាក់អំពីដើមឈើ ដោយសព្ទថា **មោរ** ក្នុងពាក្យនេះ លោកសំដៅយកបក្សីគ្រប់ជំពូក ព្រោះហេតុនោះ ទើបលោកពោលថា បានដល់ **យោ កោចិ បក្ខី** បក្សីណាមួយក៏ដោយ ។ម្យ៉ាងទៀត ដោយ **វា** សព្ទ ក្នុងពាក្យថា **មោរោ វា** លោកបកស្រាយថា បានដល់ បក្សីប្រភេទដទៃ ឬបក្សីណាមួយ ។

សូម្បីក្នុង **មិគ** សព្ទ ដែលជាសព្ទដំបូង ក៏មានន័យដូច្នេះ ។

បទថា **វាតោ វា បណ្ណកសដំ ឃរេតិ** សេចក្ដីថា ខ្យល់បក់ស្លឹកឈើដែលជាសំរាម ។

បទថា **ឃតំ នូន តំ ភយភេរវំ អាគច្ឆតិ** សេចក្ដីថា វត្ថុណាវមែងមក គឺប្រាកដ វត្ថុនោះចាត់ជាភ័យ និងអារម្មណ៍ដែលគួរខ្លាចពិតប្រាកដ និងតាំងអំពីឥឡូវនេះទៅ អារម្មណ៍នោះឯង គប្បីជ្រាបថា ជាភ័យ និងអារម្មណ៍ដែលគួរខ្លាច ព្រោះមានភ័យទាំងតូចធំ និងមានប្រមាណក្រៃលែងជាអារម្មណ៍ ទើបអារម្មណ៍ ឈ្មោះថា ភ័យ និងវត្ថុដែលគួរខ្លាច ប្រៀបដូចរូបដែលមានសុខជាអារម្មណ៍ ក៏ឈ្មោះថា ជាសុខដែរ ដូច្នោះ ។

បទថា **កិន្នុខោ អហំ អញ្ញទត្ថុ ភយប្បដិកង្ខី វិហរាមិ** សេចក្ដីថា តថាគតកំពុងសង្ស័យ គឺប្រាថ្នានូវហេតុណាថា ជាភ័យដោយចំណែកមួយនោះឯងពិត ទើបនៅ ។

បទថា **យថាភូតស្ស យថាភូតស្ស** សេចក្ដីថា នៅ គឺប្រព្រឹត្តទៅ ឬដល់ព្រមដោយឥរិយាបថណាមួយ ។

បទថា **មេ** គឺក្នុងសម្នាក់របស់តថាគត ។

បទថា **តថាភូតោ តថាភូតោ វា** សេចក្ដីថា នៅ គឺប្រព្រឹត្តទៅ ឬដល់ព្រមដោយឥរិយាបថនោះឯង ។

បទថា **សោ ខោ អហំ ។បេ។ បដិវិនេមិ** សេចក្ដីថា បានឮថា កាលព្រះពោធិសត្វកំពុងចង្ក្រម កាលអារម្មណ៍ គឺភ័យ និងវត្ថុដែលគួរខ្លាច មាន

ប្រភេទដូចស្នែងម្រឹគ និងសំឡេងក្រចកជើងជាដើមមកប្រាកដ អង្គព្រះមហាសត្វក៏មិនប្រថាប់ឈរ មិនប្រថាប់អង្គុយ មិនចូលផ្ទំ ។ ផ្ទុយមកវិញ ទ្រង់បែរជាចង្ក្រមតទៅ ពិចារណាទៅ ពិនិត្យពិគ្រោះ រហូតមិនឃើញថា ជាភ័យនិងវត្ថុដែលគួរខ្លាច វាត្រឹមតែជាសូរស្នែងម្រឹគ និងសំឡេងក្រចកជើងជាដើមប៉ុណ្ណោះ ។ កាលជ្រាបអារម្មណ៍នោះថា វាឈ្មោះនេះ មិនមែនជាភ័យ និងវត្ថុដែលខ្លាច ដូច្នេះហើយ បន្ទាប់អំពីនោះទៅ ទើបទ្រង់ឈប់ប្រថាប់ឈរប្រថាប់គង់ ឬទ្រង់ចូលផ្ទំ ។

កាលទ្រង់សម្តែងអត្ថយ៉ាងនេះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **សោ ខោ អហំ** ដូច្នេះជាដើម ។ គ្រប់ៗ បេយ្យាលក៏មានន័យនេះ ។

តទៅនេះគប្បីជ្រាបថា ព្រះមានព្រះភាគ ត្រាស់ឥរិយាបថទុកតាមលំដាប់ដែលជិតគ្នា ទ្រង់មិនបានត្រាស់ទុកតាមលំដាប់ឥរិយាបថឡើយ អធិប្បាយថា ព្រះមានព្រះភាគត្រាស់តាមលំដាប់ដែលជិតគ្នានៃឥរិយាបថនោះៗ ដូច្នេះថា កាលតថាគតកំពុងចង្ក្រម កាលភ័យ និងអារម្មណ៍ដែលគួរខ្លាចមកប្រាកដ តថាគតមិនឈប់ឈរ មិនអង្គុយ មិនដេក កាលតថាគតឈរ ភ័យ និងអារម្មណ៍ដែលគួរខ្លាចមកប្រាកដ តថាគតក៏មិនដើរចង្ក្រម ។

[ ៤៦ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងភាពដែលព្រះអង្គមិនមានភ័យ និងអារម្មណ៍ដែលគួរខ្លាចយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងការដែលព្រះអង្គនៅប្រថាប់ដោយមិនវង្វេង ក្នុងឋានៈជាទីតាំងនៃការវង្វេងរបស់បុគ្គលដែលបានឈានទាំងឡាយ ទើបត្រាស់បទថា **សន្តិ ខោ បន**

**ព្រាហ្មណា** ដូច្នេះជាដើម ។

បណ្ដាបទទាំងនេះ បទថា **សន្តិ** ស្មើគ្នានឹង **អត្ថិ** ប្រែថា មាន គឺ **សំវិជ្ជន្តិ** ប្រែថា មានព្រម បានដល់ **ឧបលព្ភន្តិ** បានយ៉ាងពិតប្រាកដ ។

បទថា **រត្តិំយេវ សមានំ** ប្រែថា វេលាដែលជាកណ្ដាលយប់ ។

បទថា **ទិវាតិ សញ្ជានន្តិ** ប្រែថា សម្គាល់ថា ពេលនេះជាពេលថ្ងៃ ។

បទថា **ទិវាយេវ សមានំ** ប្រែថា ជាពេលថ្ងៃ ។

បទថា **រត្តីតិ សញ្ជានន្តិ** ប្រែថា សម្គាល់ថា វេលានេះជាវេលាយប់ ។

សួរថា ព្រោះហេតុអ្វី បុគ្គលណាបានឈានយ៉ាងនេះ ទើបមានការសម្គាល់យ៉ាងនេះ ឆ្លើយថា ព្រោះមិនមានការឈ្លាសក្នុងការចេញចាកឈាន ឬព្រោះសំឡេងបក្សីយំ ។

សួរថា សេចក្ដីនេះដូចម្ដេច ឆ្លើយថា បុគ្គលដែលបានឱទាតកសិណពួកខ្លះក្នុងលោកនេះ កើតមនសិការឡើងថា អញធ្វើបរិកម្មក្នុងពេលថ្ងៃ ចូលឈានក្នុងពេលថ្ងៃហើយ ចេញក្នុងពេលថ្ងៃនោះឯង តែលោកមិនឈ្លាសក្នុងការកំណត់វេលាដើម្បីចេញ ទើបលោកចូលឈានហួសពេលថ្ងៃទៅ ចេញក្នុងពេលយប់ ដោយអំណាចការផ្សាយទៅនៃឱទាតកសិណៗ របស់លោកផូរផង់ ភ្លឺច្បាស់ លោកក៏សម្គាល់ពេលយប់នោះឯងថា ជាពេលថ្ងៃ ព្រោះកើតមនសិការថា នឹងចេញក្នុងពេលថ្ងៃ និងព្រោះការផ្សាយទៅនៃឱទាតកសិណផូរផង់ ភ្លឺច្បាស់ ។ តែបុគ្គលណាម្នាក់បាននីលកសិណ កើតមនសិការថា អញធ្វើបរិកម្មក្នុងពេលយប់ ចូលក្នុងពេលយប់ហើយ នឹងចេញ

ក្នុងពេលយប់នោះឯង តែលោកមិនឈ្លាសក្នុងការកំណត់វេលាដើម្បីចេញ ទើបលោកចូលឈាន កន្លងពេលយប់ទៅ ចេញក្នុងពេលថ្ងៃ តែដោយអំណាចការផ្សាយទៅនៃនីលកសិណ ទើបកសិណរបស់លោកមិនផូរផង់ មិនភ្លឺច្បាស់ លោកក៏សម្គាល់វេលាដែលជាពេលថ្ងៃនោះឯងថា ជាពេលយប់ ព្រោះកើតមនសិការថា នឹងចេញក្នុងពេលយប់ និងព្រោះការផ្សាយទៅនៃនីលកសិណមិនផូរផង់ មិនភ្លឺច្បាស់ ព្រោះមិនមានការឈ្លាសក្នុងការចេញចាកឈានយ៉ាងនេះ ទើបបុគ្គលដែលបានឈាន មានការសម្គាល់ដូចពណ៌នាមក ដូច្នេះ ។

ឯពោលដោយសំឡេងបក្សីយំ គឺបុគ្គលបានឈានពួកខ្លះក្នុងលោកនេះ អង្គុយខាងក្នុងសេនាសនៈ ក្នុងទីនោះ សត្វព្រៃទាំងឡាយ មានបក្សី និងក្អែកជាដើម ដែលតែងយំក្នុងពេលថ្ងៃ សម្គាល់ថា ជាពេលថ្ងៃ ព្រោះពន្លឺព្រះចន្ទ ទើបបញ្ចេញសំឡេងយំក្នុងពេលយប់ ឬបញ្ចេញសំឡេងយំព្រោះហេតុដទៃៗ លោកបានឮសំឡេងយំរបស់សត្វព្រៃទាំងនោះហើយ សម្គាល់វេលាដែលជាពេលយប់នោះឯង ថាជាពេលថ្ងៃ ។ តែបុគ្គលអ្នកបានឈានខ្លះក្នុងលោកនេះ អង្គុយនៅក្នុងគុហាភ្នំ ដែលបិទបាំងដោយព្រៃក្រាស់ ដែលនៅជ្រៅក្នុងញកភ្នំ ក្នុងវេលាដែលមានពន្លឺបាត់បង់ទៅក្នុងគ្រាដែលភ្លៀងធ្លាក់ជោកជាំអស់ ៧ ថ្ងៃ ពេលនោះ សត្វព្រៃទាំងឡាយ មានសត្វដែលយំក្នុងពេលយប់ និងទីទុយជាដើម ទំក្នុងទីងងឹតៗ នោះ សូម្បីក្នុងវេលាថ្ងៃហើយ រមែងបញ្ចេញសំឡេងយំ ដោយសម្គាល់ថា ជាវេលាយប់ ឬដោយហេតុដទៃ ។

បុគ្គលដែលបានឈានទោះ បានឮសំឡេងរបស់សត្វព្រៃទាំងឡាយនោះ តែង សម្គាល់វេលាដែលជាពេលថ្ងៃពិតៗ ថាជាពេលយប់ ។ ព្រោះសំឡេងបក្សី យំ ដូចពណ៌នាមកយ៉ាងនេះ ទើបបុគ្គលដែលបានឈាន មានការសម្គាល់ យ៉ាងនេះឯង ។

បទថា **ឥធមហំ** សេចក្តីថា តថាគតរមែងពោលវត្ថុនេះ គឺការកំណត់ យ៉ាងនេះ ។

បទថា **សម្មោហវិហារស្មឹ វទាមិ** អធិប្បាយថា តថាគតរមែងពោល ថា ជាការនៅដែលទាក់ទង គឺរាប់ថា នៅខាងក្នុង ការនៅដោយវង្វេង បាន ដល់ ពោលថា ជាការនៅដោយវង្វេងណាមួយ ។

បទថា **អហំ ខោ បន ព្រាហ្មណ ។បេ។ សញ្ជានាមិ** សេចក្តីថា ការ កំណត់វេលាយប់ និងថ្ងៃរបស់ព្រះពោធិសត្វប្រាកដហើយ សូម្បីក្នុងវេលា ដែលភ្លៀងធ្លាក់ជោកជាំអស់ ៧ ថ្ងៃ សូម្បីព្រះចន្ទ និងព្រះអាទិត្យមិនមានពន្លឺ ព្រះពោធិសត្វក៏រមែងដឹងបានឯងថា រយៈពេលប៉ុណ្ណោះ ដល់វេលាអាហារព្រឹក រយៈពេលប៉ុណ្ណោះ ជាបច្ឆាភត្ត រយៈពេលប៉ុណ្ណោះដល់បឋមយាម រយៈពេល ប៉ុណ្ណោះដល់មជ្ឈិមយាម ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ទុកហើយ យ៉ាងនោះ ហើយក៏មិនគួរអស្ចារ្យឡើយ ដែលព្រះពោធិសត្វមានបារមីបាន បំពេញមកហើយ ដឹងយ៉ាងនេះ ។

សូម្បីពួកព្រះអរិយសាវក ដែលតាំងនៅក្នុងបទេសញ្ញាណ គឺញាណជា គ្រឿងកំណត់កាល ក៏ប្រាកដថា កំណត់វេលាពេលយប់ និងពេលថ្ងៃបាន ។

មានរឿងពោលមកថា ព្រះគោទត្តត្ថេរក្នុងកល្យាណីមហាវិហារ ទទួលកត្តក្នុងវេលា ២ អង្គុលី ហើយឆាន់ក្នុងវេលា ២ អង្គុលីនោះឯង កាលព្រះអាទិត្យមិនទាន់រះ ក៏ចូលសេនាសនៈអំពីព្រឹក ចេញមកក្នុងវេលា ( ដូចគ្នា ) នោះថ្ងៃមួយ ពួកញោមវត្តគិតគ្នាថា ពួកយើងនឹងជួបលោកបាន ក្នុងវេលាដែលលោកចេញមកពេលស្អែកនេះ ទើបរៀបចំកត្ត ហើយអង្គុយចាំ ក្នុងទីជិតបង្គោលប្រាប់វេលា ( បង្គោលវាស់ស្រមោលថ្ងៃ ) ។ ព្រះថេរៈចេញមកក្នុងវេលា ២ អង្គុលីដូចដើម ។ បានឮមកថា តាំងពីពេលនោះមក សូម្បីព្រះអាទិត្យ មិនប្រាកដខ្លួន ពួកញោមវត្តក៏វាយស្គរតាមសញ្ញាដែលព្រះថេរៈចេញមក ។

សូម្បីក្នុងធជាគរវិហារ ព្រះកាលិទេវត្ថេរ វាយជួងប្រាប់យាមខាងក្នុងវស្សា ការវាយជួងប្រាប់យាម ជាកិច្ចវត្តប្រចាំថ្ងៃរបស់ព្រះថេរៈ តែព្រះថេរៈមិនព្រមប្រើនាឡិកាដែលជាគ្រឿងយន្ត ចំណែកភិក្ខុពួកដទៃប្រើ ។ ក្នុងកាលតមក កាលបឋមយាមកន្លងទៅ ព្រះថេរៈកាន់ដំបងគោះជួង កំពុងឈរ ឬគោះបាន ២ ដងប៉ុណ្ណោះគ្រឿងយន្ត ក៏វាយម៉ោងដែរ ។ កាលបើយ៉ាងនេះទើបព្រះថេរៈបំពេញសមណធម៌ ក្នុងយាមទាំង ៣ ហើយចូលទៅកាន់ស្រុកអំពីព្រលឹមទទួលបិណ្ឌបាត ត្រឡប់មកវត្ត ក្នុងវេលាឆាន់ក៏កាន់បាត្រទៅកាន់ទីសម្រាកពេលថ្ងៃ បំពេញសមណធម៌ ។ ភិក្ខុទាំងឡាយឃើញបង្គោលប្រាប់ពេលហើយ បានបញ្ជូនភិក្ខុទៅដើម្បីនិមន្តព្រះថេរៈមក ភិក្ខុនោះបានជួបព្រះថេរៈខណៈកំពុងចេញមកពីទីសម្រាកពេលថ្ងៃខ្លះ ក្នុងរវាងផ្លូវខ្លះ ។

សូម្បីសាវកដែលតាំងនៅក្នុងបទេសញ្ញាណ រមែងកំណត់ពេលថា ជាពេលយប់ និងពេលថ្ងៃបានយ៉ាងនេះ នឹងពោលថ្វីដល់បណ្តាព្រះពោធិសត្វនោះ ។

ក្នុងបទថា **យំ ខោ តំ ។បេ។ វទេយ្យ** នេះ អ្នកសិក្សាគប្បីជ្រាបបទសម្ពន្ធយ៉ាងនេះថា ម្នាលព្រាហ្មណ៍ បុគ្គលណាម្នាក់ កាលនឹងពោលវាចាណាថា សត្វដែលមានការមិនវង្វេងជាធម្មតា កើតឡើងក្នុងលោក ។បេ។ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ទើបឈ្មោះថា ពោលដោយប្រពៃ គឺជាអ្នកពោលយ៉ាងត្រឹមត្រូវ ពោលមិនឃ្លៀងឃ្លាត បុគ្គលនោះកាលពោលពាក្យនោះចំពោះតថាគតប៉ុណ្ណោះ ទើបឈ្មោះថា ពោលដោយប្រពៃ គឺជាអ្នកពោលយ៉ាងត្រឹមត្រូវ ពោលមិនឃ្លៀងឃ្លាត ។

បណ្តាបទទាំងនោះ បទថា **អសម្មោហធម្មោ** ប្រែថា មានការមិនវង្វេងជាសភាវៈ ។ បទថា **លោកេ** បានដល់ ក្នុងមនុស្សលោក ។

បទថា **ពហុជនហិតាយ** ប្រែថា ដើម្បីប្រយោជន៍ដល់ជនដ៏ច្រើន អធិប្បាយថា សត្វនោះជាអ្នកដឹកនាំក្នុងប្រយោជន៍ក្នុងបច្ចុប្បន្នផង ក្នុងសម្បរាយភពផង ដោយការដល់ព្រមនៃបញ្ញា ។

បទថា **ពហុជនសុខាយ** ប្រែថា ដើម្បីសេចក្តីសុខដល់ជនដ៏ច្រើន អធិប្បាយថា សត្វនោះ ជាអ្នកឲ្យសម្បត្តិ ដែលជាឧបករណ៍នៃសេចក្តីសុខ ដោយការដល់ព្រមនៃចាគៈ គឺការលះបង់ ។

បទថា **លោកានុកម្បាយ** ប្រែថា ដើម្បីប្រយោជន៍អនុគ្រោះលោក អធិប្បាយថា សត្វនោះជាអ្នករក្សា ជាអ្នកគ្រប់គ្រងលោក ដូចមាតាបិតាគ្រប់

គ្រងបុត្រ ដោយការដល់ព្រមនៃមេត្តាករុណា ។

ដោយសព្ទថា **ទេវមនុស្ស** ក្នុងពាក្យថា **អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ** នេះ អ្នកសិក្សាគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់សំដៅយកចំពោះពួកវេនេយ្យសត្វ ដែលជាភព្វបុគ្គល គឺបុគ្គលដែលគួរត្រាស់ដឹង ហើយសម្ដែងការកើតឡើងរបស់ព្រះអង្គ ក៏ដើម្បីឲ្យវេនេយ្យសត្វទាំងនោះបានសម្រេចមគ្គ ផល និព្វាន ។ ព្រោះកាលព្រះមានព្រះភាគត្រាស់ថា **អត្ថាយ** រមែងសំដៅដល់បរមត្ថប្រយោជន៍ គឺដើម្បីព្រះនិព្វាន កាលព្រះមានព្រះភាគត្រាស់ថា **ហិតាយ** រមែងសំដៅដល់ប្រយោជន៍ក្នុងមគ្គ ជាគ្រឿងឲ្យសម្រេចនិព្វាននោះ ។ ព្រោះដែលឈ្មោះថា ប្រយោជន៍ដែលក្រៃលែងទៅជាងមគ្គ ជាគ្រឿងឲ្យសម្រេចនិព្វានមិនមានឡើយ ។ កាលព្រះមានព្រះភាគត្រាស់ថា **សុខាយ** រមែងសំដៅដល់សេចក្ដីសុខ ដែលកើតអំពីផលសមាបត្តិ ព្រោះថា មិនមានសេចក្ដីសុខដទៃ ដែលក្រៃលែងជាងសេចក្ដីសុខកើតអំពីផលសមាបត្តិនោះឡើយ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា សមាធិនេះ ជាសុខក្នុងបច្ចុប្បន្ន និងឲ្យផលជាសុខតទៅមុខ ។

## អធិប្បាយ បុព្វភាគបដិបទា

[ ៤៧ ] ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការនៅដោយមិនវង្វេង គឺអសម្មោហវិហាររបស់ព្រះអង្គ ដែលមានការបានសម្រេចគុណនៃពុទ្ធជាទីបំផុត ដូចពណ៌នាមកដូច្នេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងបដិបទាជាហេតុ

ឲ្យសម្រេចការនៅដោយមិនវង្វេង ដែលដល់ទីបំផុតហើយនោះ តាំងអំពីពេលចាប់ផ្តើម ទើបត្រាស់ពាក្យថា **អារទ្ធំ ខោ បន មេ ព្រាហ្មណ** ដូច្នេះជាដើម ។

ឯអាចារ្យពួកខ្លះពោលថា ព្រាហ្មណ៍បានស្តាប់ការនៅ ដោយមិនវង្វេងនេះហើយ មានគំនិតយ៉ាងនេះថា ព្រះសមណគោតមសម្រេចការនៅដោយមិនវង្វេងនេះ ដោយបដិបទាអ្វីហ្ន៎ ព្រះមានព្រះភាគទ្រង់ជ្រាបគំនិតរបស់ព្រាហ្មណ៍នោះហើយ កាលទ្រង់សម្តែងថា តថាគតបានសម្រេចការនៅដោយមិនវង្វេងដ៏ឧត្តមនេះ ដោយបដិបទានេះ ទើបត្រាស់យ៉ាងនេះ ។

បណ្តាបទទាំងនោះ បទថា **អារទ្ធំ ខោ បន មេ ព្រាហ្មណ វីរិយំ អហោសិ** អធិប្បាយថា ម្នាលព្រាហ្មណ៍ ការនៅដោយមិនវង្វេងដ៏ឧត្តមនេះ មិនមែនតថាគតខ្ជិលច្រអូស ភ្លេចសតិ មានកាយសោប់សល់ ឬមានចិត្តរាយមាយ បានសម្រេចមកឡើយ ដោយពិត តថាគតបានប្រារព្ធព្យាយាម ដើម្បីសម្រេចការនៅដោយមិនវង្វេងនោះ គឺតថាគតអង្គុយត្រង់គល់ពោធិ៍ បានប្រារព្ធ ផ្តងនូវសេចក្តីព្យាយាមមានអង្គ ៤ ឲ្យប្រព្រឹត្តទៅមិនធូរថយ ។ ក៏ព្រោះប្រារព្ធហើយនោះឯង សេចក្តីព្យាយាមប្រកបដោយអង្គ ៤ នោះនៃតថាគត ទើបមិនធូរថយ ។

បទថា **ឧបដ្ឋិតា សតិ អប្បមុដ្ឋា** សេចក្តីថា ហើយមិនមែនត្រឹមតែសេចក្តីព្យាយាមតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីសតិរបស់តថាគតក៏តាំងមាំដោយភាវៈ ដែលបែរមុខឆ្ពោះទៅកាន់អារម្មណ៍ និងព្រោះតាំងមាំហើយនោះឯង

ទើបសតិមិនវង្វេង ។

បទថា **បស្សទ្ធោ កាយោ អសារទ្ធោ** សេចក្តីថា ព្រោះមានកាយ និង ចិត្តស្ងប់ សូម្បីកាយរបស់តថាគតក៏ស្ងប់ដែរ ។ ក្នុងបទនោះ អធិប្បាយថា ព្រោះកាលនាមកាយស្ងប់ រូបកាយក៏រមែងស្ងប់ដូចគ្នា ដូច្នោះ ទើបព្រះមាន ព្រះភាគត្រាស់សរុបថា កាយស្ងប់ ដោយមិនបានត្រាស់ចែកថា នាមកាយ រូបកាយ ។

បទថា **អសារទ្ធោ** សេចក្តីថា ព្រោះស្ងប់ហើយនោះឯង ទើបកាយនោះ ឈ្មោះថា មិនរសាប់រសល់ អធិប្បាយថា ប្រាសចាកការក្រវល់ក្រវាយ ។

បទថា **សមាហិតំ ចិត្តំ ឯកគ្គំ** សេចក្តីថា សូម្បីចិត្តដែលតថាគតតាំង ចិត្តទុកដោយប្រពៃហើយ ក៏ហាក់ដូចជាតាំងទុកដោយល្អ និងព្រោះតាំងទុក ដោយប្រពៃហើយនោះឯង ទើបមានឈ្មោះថា មានអារម្មណ៍មួយជាឯកគ្គតា មិនញាប់ញ័រ មិនកម្រើក ។ ព្រះមានព្រះភាគត្រាស់បដិបទាដែលជាចំណែក ខាងដើមនៃឈានទុក ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់សម្តែងគុណវិសេស ផ្តើមពីបឋមជ្ឈាន រហូតដល់វិជ្ជា ៣ ជាទីបំផុត ដែលព្រះអង្គទ្រង់បានដល់ហើយ ដោយបដិបទា នេះ ទើបត្រាស់ពាក្យថា **សោ ខោ អហំ** ដូច្នេះជាដើម ។ ក្នុងព្រះតម្រាស់ នោះ ពាក្យណាដែលត្រូវពោលក្នុងវគ្គនេះថា **វិវិច្ចេវ កាមេហិ ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហាសឹ** ពាក្យទាំងអស់នោះបានពោលទុកហើយ ក្នុង វារៈពោលដោយបឋវីកសិណ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ សេចក្តីពិត មានការ

ប្រែកគ្នាមួយកន្លែងប៉ុណ្ណោះ ដូច្នេះ គឺក្នុងគម្ពីរវិសុទ្ធិមគ្គនោះ បទកិរិយាមកថា **ឧបសម្បជ្ជ វិហរតិ** តែក្នុងទីនេះមកថា **វិហាសឹ** ។

សួរថា ព្រះមានព្រះភាគទ្រង់ធ្វើដូចម្ដេច ទើបចូលឈានទាំងនេះបាន ឆ្លើយថា ទ្រង់ចម្រើនកម្មដ្ឋាន ។

សួរថា កម្មដ្ឋានមួយណា ឆ្លើយថា អានាបានស្សតិកម្មដ្ឋាន ។

ឈានទាំង ៤ នេះ សម្រាប់បុគ្គលខ្លះ មានឯកគ្គតានៃចិត្តជាផល សម្រាប់បុគ្គលខ្លះ ជាបាទនៃការចម្រើនវិបស្សនា សម្រាប់បុគ្គលខ្លះ ជាបាទនៃការបានអភិញ្ញា សម្រាប់បុគ្គលខ្លះជាបាទនៃការចូលនិរោធ គឺព្រះនិព្វាន សម្រាប់បុគ្គលខ្លះ មានការឈានចុះកាន់ភពជាផល ។

បណ្ដាបុគ្គលទាំងនោះ សម្រាប់ព្រះខីណាស្រព ឈាន ៤ មានឯកគ្គតានៃចិត្តជាផល ព្រោះថា ព្រះខីណាស្រពទាំងនោះ ធ្វើបរិកម្មកសិណយ៉ាងនេះថា អញនឹងចូលឈាន មានចិត្តជាឯកគ្គតានៅជាសុខអស់មួយថ្ងៃ ដូច្នេះហើយ ធ្វើសមាបត្តិ ៨ ឲ្យកើតឡើង ។

សម្រាប់ព្រះសេក្ខៈ និងបុថុជ្ជនគិតថា អញចេញចាកសមាបត្តិហើយ មានចិត្តជាសមាធិ នឹងឃើញច្បាស់ ដូច្នេះហើយ ធ្វើវិបស្សនាឲ្យកើតឡើង យ៉ាងនេះ ឈានរមែងឈ្មោះថា ជាបាទនៃការចម្រើនវិបស្សនា ។

ចំណែកឈានលាភីបុគ្គលពួកណា ធ្វើសមាបត្តិ ៨ ឲ្យកើតបានហើយ ចូលឈានដែលជាបាទនៃអភិញ្ញា ចេញអំពីសមាបត្តិហើយ ប្រាថ្នាអភិញ្ញា ដែលមានន័យដូចព្រះមានព្រះភាគត្រាស់ទុកហើយថា ជាបុគ្គលម្នាក់ ធ្វើឲ្យជា

បុគ្គលច្រើនទាក់បាន ដូច្នេះហើយ ធ្វើអភិញ្ញាឲ្យកើតឡើង សម្រាប់ឈាន-លាភីបុគ្គលទាំងនោះ ឈានរមែងជាបាទនៃអភិញ្ញា ។

ចំណែកព្រះអរិយបុគ្គលពួកណា ធ្វើសមាបត្តិ ៨ ឲ្យកើតបានហើយ ចូលនិរោធសមាបត្តិ បានគិតថា អញនឹងសម្រេចនិរោធ គឺនិព្វានក្នុងបច្ចុប្បន្ន នៅជាសុខ ដោយមិនមានចិត្តសង្ខារអស់ ៧ ថ្ងៃ ដូច្នេះហើយ ធ្វើសមាបត្តិឲ្យកើតឡើង ឈានរបស់ព្រះអរិយបុគ្គលទាំងនោះ រមែងឈ្មោះថា ជាបាទនៃការចូលនិរោធ ។

ចំណែកឈានលាភីបុគ្គលពួកណា ធ្វើសមាបត្តិ ៨ ឲ្យកើតបានហើយ គិតថា អញនឹងជាអ្នកមានឈាន មិនសាបសូន្យ កើតក្នុងព្រហ្មលោក ដូច្នេះ រមែងធ្វើសមាបត្តិឲ្យកើតឡើង ឈានរបស់បុគ្គលទាំងនោះ រមែងមានការឈានចុះកាន់ភពជាផល ។

ចតុត្ថជ្ឈាននេះ ដែលព្រះមានព្រះភាគធ្វើឲ្យកើតហើយ ត្រង់មណ្ឌលពោធិព្រឹក្ស ចតុត្ថជ្ឈាននោះរបស់ព្រះមានព្រះភាគអង្គនោះ បានជាបាទនៃការចម្រើនវិបស្សនា ជាបាទនៃការចម្រើនអភិញ្ញា និងឲ្យសម្រេចកិច្ចគ្រប់យ៉ាង ទើបគប្បីជ្រាបថា ញុំាងគុណដែលជាលោកិយ និងលោកុត្តរ ឲ្យកើតបានគ្រប់យ៉ាង ។ ចតុត្ថជ្ឈាននោះ បាននាំគុណពួកណាមកឲ្យ ព្រះមានព្រះភាគកាលទ្រង់សម្តែងត្រឹមតែចំណែកខ្លះ គឺឯកទេសនៃគុណទាំងនោះ ទើបត្រាស់បទថា **សោ ឯវំ សមាហិតេ ចិត្តេ** ដូច្នេះជាដើម ។

# បុព្វេនិវាសានុស្សតិញ្ញាណជាដើម

[ ៤៨ ] *វិជ្ជា ២ ក្នុងព្រះសូត្រនោះ គឺបុព្វេនិវាសានុស្សតិញ្ញាណ និង ចុតូបបាតញ្ញាណ មានការពណ៌នាទៅតាមលំដាប់បទ និងវិធីចម្រើន បាន ពោលទុកហើយយ៉ាងពិស្តារ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ពិតហើយ ក្នុងវិសុទ្ធិមគ្គ និងក្នុងទីនេះ មានសេចក្តីប្លែកគ្នាមួយកន្លែងប៉ុណ្ណោះ ដូច្នេះ គឺក្នុងវិសុទ្ធិមគ្គ លោកពោលបទកិរិយាទុកថា* **សោ ឯវំ សមាហិតេ ចិត្តេ ។បេ។ អភិ-និន្នាមេតិ** *តែក្នុងទីនេះ ព្រះមានព្រះភាគត្រាស់បទកិរិយាទុកថា* **អភិនិន្នា-មេសឹ** *។ និងវារៈពោលដោយអប្បនាយ៉ាងនេះថា* **អយំ ខោ មេ ព្រាហ្មណ** *ក៏មិនបានមកក្នុងគម្ពីរវិសុទ្ធិមគ្គនោះ ។*

*បណ្តាបទទាំងនោះ បទថា* **សោ** *គឺ* **សោ អហំ** *ប្រែថា តថាគតនោះ ។*

*បទថា* **អភិនិន្នាមេសឹ** *ប្រែថា នាំទៅចំពោះ ។ ព្រោះព្រះតម្រាស់ថា* **អភិនិន្នាមេសឹ** *ក្នុងពាក្យថា* **សោ** *នេះ ទើបគប្បីជ្រាបអត្ថយ៉ាងនេះថា* **សោ អហំ** *ប្រែថា តថាគតនោះ ។*

*ព្រោះបុព្វេនិវាសានុស្សតិញ្ញាណនេះ មកហើយដោយអំណាចនៃព្រះមាន ព្រះភាគ ដូច្នោះ ទើបគប្បីជ្រាបការប្រកបសេចក្តីយ៉ាងនេះ ក្នុងពាក្យនេះថា តថាគតនោះចុតិចាកភពនោះហើយ មកកើតក្នុងភពនេះ ។ ក្នុងពាក្យនេះ គប្បីជ្រាបអធិប្បាយបន្ថែមទៀតថា ពាក្យថា តថាគតនោះ ចុតិចាកភពនោះ ហើយ ជាការពិចារណារបស់ព្រះពោធិសត្វ ដែលពិចារណាថយក្រោយ ព្រោះដូច្នោះ គប្បីជ្រាបថា ក្នុងពាក្យថា* **ឥធូបបន្នោ** *ព្រះមានព្រះភាគត្រាស់ សំដៅយកតុសិតភពថា តថាគតកើតក្នុងតុសិតភពនោះ មុននឹងមកកើតក្នុង*

ភពនេះ ។

បទថា **តត្រាបាសឹ ឯវំ នាមោ** សេចក្តីថា ក្នុងតុសិតភពនោះ តថាគត បានជាទេវបុត្រឈ្មោះថា **សេតកេតុ** ។ បទថា **ឯវំគោត្តោ** គឺមានគោត្រដូច គ្នានឹងទេវតាទាំងនោះ ។ បទថា **ឯវំវណ្ណោ** គឺមានពណ៌សម្បុរផូរផង់ដូច មាស ។ បទថា **ឯវមាហារោ** គឺមានទិព្វសុធាហារ ។

បទថា **ឯវំ សុខទុក្ខប្បដិសំវេទី** សេចក្តីថា ជាអ្នកមានប្រក្រតីសោយ ទិព្វសុខយ៉ាងនេះ ចំណែកទុក្ខ មានត្រឹមតែទុក្ខប្រចាំសង្ខារប៉ុណ្ណោះ ។

បទថា **ឯវមាយុបរិយន្តោ** សេចក្តីថា មានអាយុ ៥៧ កោដិ ៦ លាន ឆ្នាំ ។ បទថា **សោ តតោ ចុតោ** សេចក្តីថា តថាគតចុតិអំពីភពនោះ គឺ តុសិតភព ។

បទថា **ឥធូបបន្នោ** សេចក្តីថា កើតឡើងក្នុងភពនេះ គឺក្នុងព្រះភគ៌ព្រះ នាងមហាសិរិមាយាទេវី ។

បទថា **មេ** ក្នុងពាក្យថា **អយំ ខោ មេ ព្រាហ្មណ** ជាដើម គឺ **មយា**។

បទថា **វិជ្ជា** សេចក្តីថា ដែលឈ្មោះថា វិជ្ជា ព្រោះអត្ថថា ធ្វើឲ្យដឹង ច្បាស់ ។ សួរថា វិជ្ជាធ្វើឲ្យដឹងច្បាស់នូវអ្វី ឆ្លើយថា នូវខន្ធ គឺភពដែល ធ្លាប់នៅអាស្រ័យក្នុងភពមុន ។

បទថា **អវិជ្ជា** សេចក្តីថា ព្រោះអត្ថថា មិនធ្វើឲ្យដឹងច្បាស់នូវខន្ធ ដែលអាស្រ័យនៅក្នុងជាតិមុន អវិជ្ជា ទើបព្រះមានព្រះភាគត្រាស់ថា មោហៈ ដែលបិទបាំងខន្ធដែលអាស្រ័យនៅក្នុងជាតិមុននោះ ។

បទថា **តមោ** សេចក្តីថា មោហៈនោះឯង ព្រះមានព្រះភាគត្រាស់ហៅថា **តម** គឺងងឹត ព្រោះអត្ថថា បិទបាំង ។

បទថា **អាលោកោ** សេចក្តីថា វិជ្ជានោះឯង ព្រះមានព្រះភាគត្រាស់ហៅថា អាលោក គឺពន្លឺ ព្រោះអត្ថថា ធ្វើឲ្យភ្លឺ ។

ក្នុងព្រះតម្រាស់ដែលត្រាស់មកនេះ មានអត្ថដូច្នេះថា **វិជ្ជា អធិគតា** ប្រែថា វិជ្ជាតថាគតបានសម្រេចហើយ ។ ពាក្យដ៏សេស ជាពាក្យពោលសរសើរ ។

ម្យ៉ាងទៀត ក្នុងព្រះតម្រាស់វារៈនេះ មានការប្រកបសេចក្តីដូច្នេះថា វិជ្ជានេះឯង តថាគតបានសម្រេចហើយ កាលតថាគតនោះបានសម្រេចវិជ្ជាហើយ ទើបអវិជ្ជាត្រូវកម្ចាត់ អធិប្បាយថា វិនាសទៅ ។

សួរថា ព្រោះហេតុអ្វី ទើបអវិជ្ជាវិនាសទៅ ឆ្លើយថា ព្រោះវិជ្ជាកើតឡើង ។ សូម្បីក្នុងបទក្រៅអំពីនេះក៏ន័យនេះ ។

បទថា **យថា** ក្នុងបទថា **យថាតំ** ប្រើក្នុងអត្ថថា ឧបមា ។

បទថា **តំ** ជានិបាត ។ បុគ្គលឈ្មោះថា មិនប្រមាទ ព្រោះការមិននៅប្រាសចាកសតិ ឈ្មោះថា មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដោយធម៌ជាគ្រឿងធ្វើកិលេសឲ្យក្តៅក្រហាយទូទៅ គឺវីរិយៈ ឈ្មោះថា មានខ្លួន គឺចិត្តបញ្ជូនទៅហើយ ព្រោះមិនមានការជាប់ជំពាក់ក្នុងរាងកាយ និងជីវិត ។

បទថា **បហិតត្តស្ស** សេចក្តីថា មានខ្លួនបញ្ជូនទៅហើយ ។ មានអធិប្បាយបន្ថែមដូច្នេះថា កាលព្រះយោគាវចរ ជាបុគ្គលមិនប្រមាទ មាន

ព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានខ្ជួនបញ្ជូនទៅ អវិជ្ជាគប្បីត្រូវកម្ចាត់ វិជ្ជាគប្បីកើតឡើង ងងឹតគប្បីត្រូវកម្ចាត់ ពន្លឺគប្បីកើតឡើង យ៉ាងណា សម្រាប់តថាគតក៏ដូច្នោះដូចគ្នា អវិជ្ជាត្រូវកម្ចាត់ហើយ វិជ្ជាក៏កើតឡើង ងងឹតត្រូវកម្ចាត់ហើយ ពន្លឺក៏កើតឡើង តថាគតបានផលដែលសមគួរដល់ការបំពេញព្យាយាមនោះ ។

[ ៤៩ ] ក្នុងកថាពោលអំពីចុតូបបាតញ្ញាណ គប្បីជ្រាបអធិប្បាយដូច្នេះ ព្រោះហេតុដែលក្នុងទីនេះ បាលីមកហើយ ដោយអំណាចព្រះមានព្រះភាគ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **បស្សាមិ បជានាមិ** ប្រែថា តថាគតឃើញ ដឹង ។ ការប្លែកគ្នាមានប៉ុណ្ណេះ ។ ពាក្យដ៏សេសមានន័យដូចបានពោលហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

ក្នុងកថានេះ បទថា **វិជ្ជា** បានដល់ វិជ្ជា គឺទិព្វចក្ខុញ្ញាណ ។

បទថា **អវិជ្ជា** បានដល់ អវិជ្ជាដែលបិទបាំងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ពាក្យដ៏សេសដូចគ្នាដែលពោលមកហើយនោះឯង ។

ព្រោះហេតុដែលព្រះមហាសត្វទាំងឡាយ បានបំពេញបារមីមកហើយ ទើបមិនមានការចាំបាច់ធ្វើបរិកម្ម ព្រោះថា លោកទាំងនោះ លុះបង្អោនចិត្តទៅប៉ុណ្ណោះ ក៏នឹងរឭកដល់ខន្ធដែលអាស្រ័យនៅក្នុងកាលមុន បានសន្ទឹកសន្ធាប់ និងឃើញសត្វទាំងឡាយដោយទិព្វចក្ខុ ដូច្នោះ វិធីចម្រើនវិជ្ជាទាំងនោះ ផ្តើមតាំងអំពីធ្វើបរិកម្មដែលពោលទុកហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះ ទើបមិនចាំបាច់ត្រូវនាំមកសម្តែងទុកក្នុងទីនេះ ។

[ ៥០ ] ក្នុងវិជ្ជាទី ៣ គប្បីជ្រាបអធិប្បាយដូច្នេះ ក្នុងបទថា **សោ ឯវំ សមាហិតេ ចិត្តេ** តថាគតនោះ កាលចិត្តតាំងមាំយ៉ាងនេះហើយ ចិត្តដែលតាំងមាំនោះ គប្បីជ្រាបថា គឺចតុត្ថជ្ឈានដែលជាបាទសម្រាប់ចម្រើនវិបស្សនា ។

បទថា **អាសវានំ ខយញ្ញាណាយ** សេចក្តីថា ដើម្បីប្រយោជន៍ដល់អរហត្តមគ្គញ្ញាណ ។ ពិតហើយ អរហត្តមគ្គ លោកហៅថា ធម៌ជាទីអស់ទៅនៃអាសវៈទាំងឡាយ ព្រោះធ្វើអាសវៈឲ្យវិនាស ហើយញាណនេះរមែងមានក្នុងអរហត្តមគ្គនោះ ព្រោះទាក់ទងក្នុងអរហត្តមគ្គនោះ ។

ពីរបទថា **ចិត្តំ អភិនិន្នាមេសឹ** គឺបង្អោនចិត្តដែលសម្បយុត្តដោយវិបស្សនាទៅ ។

ក្នុងបទថា **សោ ឥទំ ទុក្ខំ** ជាដើម អ្នកសិក្សាគប្បីជ្រាបអត្ថយ៉ាងនេះថា តថាគតបានជ្រាប គឺដឹង បានដល់ ចាក់ធ្លុះនូវទុក្ខសច្ចទាំងអស់ថា ទុក្ខមានចំនួនប៉ុណ្ណេះ មិនមានក្រៃលែងទៅជាងនេះ តាមសេចក្តីពិត ដោយការចាក់ធ្លុះលក្ខណៈដែលពិត បានជ្រាប គឺបានដឹង បានដល់ ចាក់ធ្លុះនូវតណ្ហាដែលញ៉ាំងទុក្ខនោះឲ្យកើតថា នេះជាទុក្ខសមុទយៈ បានជ្រាប គឺបានដឹង បានដល់ ចាក់ធ្លុះនូវទុក្ខ និងសមុទយៈទាំង ២ មកដល់ហើយរលត់ទៅ បានដល់និព្វាន ជាទីកន្លែងដែលទុក្ខ និងសមុទយៈទាំង ២ នោះមិនប្រព្រឹត្តទៅថា នេះជាទុក្ខនិរោធ បានជ្រាប គឺបានដឹង បានដល់ ចាក់ធ្លុះនូវអរិយមគ្គដែលឲ្យសម្រេចនិព្វាននោះថា នេះជាទុក្ខនិរោធគាមិនីបដិបទាតាមសេចក្តីពិតថា ដោយការចាក់ធ្លុះលក្ខណៈដែលពិត ។

កាលទ្រង់សម្តែងសច្ចៈទាំងឡាយដោយសរុបយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងសច្ចៈទាំងឡាយដោយអម ដោយអំណាចកិលេស ទើបព្រះមានព្រះភាគត្រាស់ថា **ឥមេ អាសវា** ដូច្នេះជាដើម ។

បទថា **តស្ស មេ ឯវំ ជានតោ ឯវំ បស្សតោ** ប្រែថា កាលតថាគតនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ។ ដោយពាក្យនេះ ព្រះមានព្រះភាគត្រាស់ដល់មគ្គដែលដល់ទីបំផុត ព្រមទាំងវិបស្សនា ។

បទថា **កាមាសវា** ប្រែថា ចាកកាមាសវៈ ។ ដោយបទថា រួចផុតហើយនេះ ព្រះមានព្រះភាគទ្រង់សម្តែងខណៈនៃផល ។ ព្រោះថា ចិត្តកំពុងរួចផុតក្នុងខណៈនៃមគ្គ ។ ចាត់ថា រួចផុតហើយក្នុងខណៈនៃផល ។ ដោយពាក្យថា កាលរួចផុតហើយ ក៏ដឹងថា រួចផុតហើយនេះ ព្រះមានព្រះភាគទ្រង់សម្តែងបច្ចវេក្ខណញ្ញាណ ។ ដោយពាក្យថា ជាតិអស់ហើយ ដូច្នេះជាដើម ព្រះមានព្រះភាគទ្រង់សម្តែងភូមិរបស់បច្ចវេក្ខណញ្ញាណនោះ ព្រោះថា ព្រះមានព្រះភាគទ្រង់ពិចារណាដោយញាណនោះ ទើបទ្រង់ជ្រាបថា ជាតិអស់ហើយ ដូច្នេះជាដើម ។

សួរថា ជាតិណារបស់ព្រះមានព្រះភាគអស់ហើយ ព្រះមានព្រះភាគទ្រង់ជ្រាបជាតិនោះបានដូចម្តេច ឆ្លើយថា មិនមែនអតីតជាតិរបស់ព្រះអង្គអស់ទៅ ព្រោះអតីតជាតិនោះអស់ទៅហើយមុននោះឯង មិនមែនអនាគតជាតិរបស់ព្រះអង្គអស់ទៅ ព្រោះព្រះអង្គមិនមានសេចក្តីព្យាយាមក្នុងអនាគត មិនមែនជាតិបច្ចុប្បន្នអស់ទៅ ព្រោះជាតិបច្ចុប្បន្ននៅមាន ។ តែជាតិណាដែល

បែកប្រភេទ ជាការកើតរបស់ខន្ធ ១ ក្នុងឯកវោការភព ខន្ធ ៤ ក្នុងចតុវោ-ការភព និងខន្ធ ៥ ក្នុងបញ្ចវោការភព នឹងគប្បីកើតឡើងបាន ព្រោះមិនទាន់បានធ្វើអរិយមគ្គឲ្យកើត ជាតិនោះឯង ឈ្មោះថា អស់ទៅហើយ ព្រោះដល់នូវភាពជាសភាវៈ ដែលមានការមិនកើតឡើងជាធម្មតា ព្រោះបានធ្វើអរិយមគ្គឲ្យកើតមានហើយ ។

ព្រះមានព្រះភាគ ទ្រង់ជ្រាបជាតិនោះ ដោយទ្រង់ពិចារណាកិលេសដែលលះបានហើយ ដោយមគ្គភាវនា ហើយទ្រង់ជ្រាបថា កាលកិលេសមិនមាន ការធ្វើ ទោះមាន ក៏មិនញ៉ាំងឲ្យកើតបដិសន្ធិតទៅទៀតឡើយ ដូច្នេះ ។

បទថា **វុសិតំ** ប្រែថា នៅហើយ គឺនៅចប់ហើយ អធិប្បាយថា ធ្វើហើយ គឺប្រព្រឹត្តហើយ បានដល់ សម្រេចហើយ ។

បទថា **ព្រហ្មចរិយំ** បានដល់ មគ្គព្រហ្មចរិយៈ ។ ព្រះសេក្ខៈ ៧ ពួករួមទាំងកល្យាណបុថុជ្ជន ឈ្មោះថា កំពុងប្រព្រឹត្តព្រហ្មចរិយៈ ព្រះខីណាស្រពជាអ្នកមានការប្រព្រឹត្តព្រហ្មចរិយៈចប់ហើយ ព្រោះដូច្នោះ ព្រះមានព្រះភាគទ្រង់ពិចារណាដល់ការនៅប្រព្រឹត្តព្រហ្មចរិយធម៌នៃព្រះអង្គ ទើបទ្រង់ជ្រាបថាព្រហ្មចរិយៈរបស់តថាគតចប់ហើយ ។

បទថា **កតំ ករណីយំ** សេចក្តីថា កិច្ចទាំង១៦យ៉ាង គឺបរិញ្ញា(ការកំណត់ដឹង) បហាន(ការលះ) សច្ឆិកិរិយា(ការធ្វើឲ្យជាក់ច្បាស់) និងភាវនា(ការធ្វើឲ្យកើតមានដោយមគ្គ ៤) ក្នុងសច្ចៈ ៤ ដែលតថាគតឲ្យសម្រេចហើយ ។ ព្រោះថា ព្រះសេក្ខៈ ៧ ពួក រួមទាំងកល្យាណបុថុជ្ជនកំពុងធ្វើកិច្ចនោះ ឯព្រះ

ទីណាស្រេច មានកិច្ចដែលគួរធ្វើនោះ ធ្វើស្រេចហើយ ព្រោះដូច្នោះ ព្រះមានព្រះភាគទ្រង់ពិចារណាដល់កិច្ច ដែលគួរធ្វើរបស់ព្រះអង្គ ទើបទ្រង់ជ្រាបថា កិច្ចដែលគួរធ្វើ តថាគតបានធ្វើស្រេចហើយ ។

បទថា **នាបរំ ឥត្ថត្តាយ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ជ្រាបថា ឥឡូវនេះ កិច្ចដោយការធ្វើមគ្គឲ្យកើតមាន ដើម្បីភាពជាយ៉ាងនេះទៀត គឺដើម្បីកិច្ច ១៦ យ៉ាង ឬដើម្បីការអស់កិលេសយ៉ាងនេះទៀតរបស់តថាគតមិនមាន ។

ម្យ៉ាងទៀត បទថា **ឥត្ថត្តាយ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ជ្រាបថា ខន្ធសន្តាន គឺការបន្តនៃខន្ធដទៃចាកភាពជាយ៉ាងនេះ គឺចាកប្រការយ៉ាងនេះបានដល់ ចាកការបន្តនៃខន្ធដែលប្រព្រឹត្តទៅក្នុងឥឡូវនេះរបស់តថាគតមិនមាន តែខន្ធទាំង ៥ នេះ ដែលតថាគតកំណត់ដឹងដោយប្រពៃហើយ តាំងនៅដូចដើមឈើដែលមានឫសដាច់ដូច្នោះ ព្រោះវិញ្ញាណដួងចុងក្រោយរលត់ទៅ ខន្ធទាំង ៥ នោះ ក៏នឹងរលត់ ដូចភ្លើងដែលអស់កំញម ដូច្នោះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការសម្រេចញាណ ជាទីអស់ទៅនៃអាសវៈទាំងឡាយនោះ ដែលព្រះអង្គទ្រង់កំណត់ហើយ ដោយបច្ចវេក្ខណញ្ញាណយ៉ាងនេះដល់ព្រាហ្មណ៍ ទើបត្រាស់បទថា **អយំ ខោ មេ ព្រាហ្មណ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **វិជ្ជា** បានដល់ វិជ្ជាក្នុងអរហត្តមគ្គញាណ ។

បទថា **អវិជ្ជា** បានដល់ អវិជ្ជា ដែលបិទបាំងសច្ចៈ ៤ ។ ពាក្យដ៏

សេសមានន័យដូចពោលហើយនោះឯង ។

ព្រះមានព្រះភាគ ទ្រង់ប្រកាសសង្គ្រោះគុណនៃភាពជាសព្វញ្ញូទាំងអស់ ដោយវិជ្ជា ៣ យ៉ាងនេះ គឺទ្រង់សង្គ្រោះអតីតំសញ្ញាណ ដោយបុព្វេនិវាសា-នុស្សតិញ្ញាណ ទ្រង់សង្គ្រោះបច្ចុប្បន្នំសញ្ញាណ និងអនាគតំសញ្ញាណ ដោយទិព្វចក្ខុញ្ញាណ ហើយទ្រង់សង្គ្រោះលោកុត្តរគុណទាំងអស់ ដោយអាសវក្ខ-យញ្ញាណ ដោយព្រះតម្រាស់ដូចពោលមកនេះ ឈ្មោះថា ទ្រង់បានសម្តែងការនៅដោយមិនវង្វេងរបស់ព្រះអង្គដល់ព្រាហ្មណ៍ ។

## ប្រយោជន៍នៃការនៅព្រៃ ២ យ៉ាង

[ ៥១ ] បានឮថា កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រាហ្មណ៍គិតថា ព្រះសមណគោតមទ្រង់ប្ដេជ្ញាជាព្រះសព្វញ្ញូ តែក្នុងថ្ងៃនេះ ព្រះអង្គក៏ទ្រង់មិនព្រមលះបង់ការនៅក្នុងព្រៃ កិច្ចដែលគួរធ្វើណាមួយដទៃរបស់ព្រះអង្គនៅមានឬហ្ន៎ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបអធ្យាស្រ័យនៃព្រាហ្មណ៍នោះហើយ បានត្រាស់បទថា **សិយា ខោ បន តេ** ដូច្នេះជាដើម ដើម្បី អនុលោមតាមអធ្យាស្រ័យ ។

បណ្ដាបទទាំងនោះ បទថា **សិយា ខោ បន តេ ព្រាហ្មណ ឯវមស្ស** សេចក្ដីថា ម្នាលព្រាហ្មណ៍ គ្រាខ្លះ អ្នកគប្បីមានការគិតយ៉ាងនេះ ។

បទថា **ន ខោ បនេតំ ព្រាហ្មណ ឯវំ ទដ្ឋព្វំ** សេចក្ដីថា ម្នាលព្រាហ្មណ៍ កាលបើយ៉ាងនេះ អ្នកមិនគប្បីឃើញយ៉ាងនេះថា ការនៅក្នុងសេនាសនៈដ៏ស្ងាត់របស់តថាគត ព្រោះហេតុ មានរាគៈមិនទាន់អស់ជាដើម ។

ព្រះមានព្រះភាគ កាលទ្រង់បដិសេធវត្ថុដែលមិនមែនដូចពោលមកនេះ ក្នុងការនៅក្នុងសេនាសនៈដ៏ស្ងាត់យ៉ាងនេះហើយ កាលទ្រង់សម្ដែងដល់ហេតុ ទើបត្រាស់ពាក្យថា **ទ្វេ ខោ អហំ** ដូច្នេះជាដើម ។ ប្រយោជន៍នោះឯង ក្នុងពាក្យថា **អត្ថវសេ** នោះ ឈ្មោះថា អំណាចនៃប្រយោជន៍ ព្រោះដូច្នោះ ក្នុងពាក្យថា **ទ្វេ ខោ អហំ ព្រាហ្មណ អត្ថវសេ** ទើបមានពាក្យអធិប្បាយថា ម្នាលព្រាហ្មណ៍ តថាគតឃើញនូវប្រយោជន៍ ២ យ៉ាង គឺហេតុ ២ យ៉ាង ។

ក្នុងបទថា **អត្តនោ ច ទិដ្ឋធម្មសុខវិហារំ** គឺការនៅជាសុខក្នុងបច្ចុប្បន្នរបស់ខ្លួន អត្តភាពដែលឃើញប្រចក្សនេះ ឈ្មោះថា ទិដ្ឋធម៌ ការនៅដោយឥរិយាបថទាំង ៤ ជាផាសុក ឈ្មោះថា **សុខវិហារ** គប្បីជ្រាបអធិប្បាយនេះថា ព្រោះបុគ្គលម្នាក់មានឥរិយាបថដទៃៗ ដោយហោច ការបន្ទោបង់ឧច្ចារ-បស្សាវៈងាយស្រួលសប្បាយ ព្រោះដូច្នោះ ការនៅជាសុខរបស់អត្តភាពដែលឃើញប្រចក្ស ទើបឈ្មោះថា **ទិដ្ឋធម្មសុខវិហារ** ។

បទថា **បច្ឆិមំ ជនតំ អនុកម្បមានោ** ប្រែថា អនុគ្រោះពពួកជន ឯក្រោយ គប្បីជ្រាបអធិប្បាយដូច្នេះ ព្រះមានព្រះភាគ ទ្រង់អនុគ្រោះពួកជនឯក្រោយ ដោយការនៅព្រៃដូចម្ដេច អធិប្បាយថា កុលបុត្រទាំងឡាយដែលបួសដោយសទ្ធា ឃើញការនៅព្រៃរបស់ព្រះមានព្រះភាគ ហើយនាំគ្នាគិតថា សូម្បីតែព្រះមានព្រះភាគ ដែលមិនមានទុក្ខសច្ចត្រូវកំណត់ដឹង មិនមានសមុទយសច្ចដែលត្រូវលះ មិនមានមគ្គសច្ចដែលត្រូវធ្វើឲ្យកើត មិនមាននិរោធសច្ចដែលត្រូវធ្វើឲ្យជាក់ច្បាស់ ក៏មិនព្រមលះបង់សេនាសនៈព្រៃឡើយ

នឹងពោលថ្វីដល់ពួកយើងទាំងឡាយ ដូច្នេះហើយ នាំគ្នាសម្គាល់សេទាសទៈ ព្រៃ ថាខ្ទុនគួរនៅនោះឯង ។

ដោយអាការយ៉ាងនេះ ពួកកិក្ខុទាំងនោះក៏នឹងធ្វើទុក្ខឲ្យអស់ទៅដោយធាប់រួសរាន់ ព្រះមានព្រះភាគ ទ្រង់ឈ្មោះថា អនុគ្រោះពួកជនជំនាន់ក្រោយយ៉ាងនេះឯង ។ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងអត្ថនេះ ទើបត្រាស់ថា **បច្ឆិមញ្ច ជនតំ អនុកម្បមានោ** ដូច្នេះ ។

## អត្ថរបស់អភិកន្តសព្ទ

[ ៥២ ] ព្រាហ្មណ៍បានស្ដាប់ព្រះតម្រាស់នោះហើយ មានចិត្តត្រេកអរ ទើបបាន ពោលពាក្យថា **អនុកម្បិតរូបា** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **អនុកម្បិតរូបា** ប្រែថា ជាប្រភេទដែលព្រះគោតមដ៏ចម្រើនអនុគ្រោះហើយ គឺជាបុគ្គលដែលព្រះគោតមដ៏ចម្រើនឧបការៈហើយជាសការ: ។ បទថា **ជនតា** ប្រែថា ពពួកជន ។

បទថា **យថាតំ អរហតា សម្មាសម្ពុទ្ធេន** សេចក្ដីថា ពួកជនឯក្រោយក៏ព្រះគោតមដ៏ចម្រើនអនុគ្រោះហើយ ដូចបុគ្គលដែលព្រះអរហន្តសម្មាសម្ពុទ្ធគប្បីអនុគ្រោះ ។

ព្រាហ្មណ៍កាលពោលយ៉ាងនេះហើយ កាលនឹងសម្ដែងនូវការសរសើរព្រះធម្មទេសនានោះរបស់ព្រះមានព្រះភាគទៀត ទើបបានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះតម្រាស់របស់ព្រះអង្គពីរោះក្រៃពេក ព្រះតម្រាស់របស់ព្រះអង្គចាប់ចិត្តពន់ពេក ។

ក្នុងបទថា **អភិក្កន្តំ ភោ គោតម** ជាដើមនោះ **អភិក្កន្ត** សព្ទនេះ ប្រើក្នុងអត្ថថា **១យ** អស់ទៅ សូន្យទៅ កន្លងទៅ **សុន្ទរ** ល្អ **អភិរូប** ស្អាត និង **អព្ភនុមោទន** សរសើរ ត្រេកអរ ។

**អភិក្កន្ត** សព្ទ ដែលប្រើក្នុងអត្ថថា **១យ** ដូចក្នុងប្រយោគជាដើមថា **អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ** បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រីបឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ ។

ប្រើក្នុងអត្ថថា **សុន្ទរ** ដូចក្នុងប្រយោគជាដើមថា **អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច** បណ្ដាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះ ចាត់ថា ល្អជាងផង ប្រសើរជាងផង ។

ប្រើក្នុងអត្ថថា **អភិរូប** ដូចក្នុងប្រយោគជាដើមថា **កោ មេ វន្ទតិ បាទានិ ឥទ្ធិយា យសសា ជលំ អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា** អ្នកណាហ្ន៎ រុងរឿង ដោយឫទ្ធិ និងយស មានសម្បុរល្អ ញុំាងទិសទាំងពួងឲ្យភ្លឺ មកថ្វាយបង្គំបាទានៃតថាគត ។

ប្រើក្នុងអត្ថថា **អព្ភនុមោទនា** ដូចក្នុងប្រយោគជាដើមថា **អភិក្កន្តំ ភន្តេ** បពិត្រគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គច្បាស់ណាស់ ។

ក្នុងទីនេះ **អភិក្កន្ត** សព្ទ ប្រើក្នុងអត្ថនៃ **អព្ភនុមោទន** គឺសរសើរត្រេកអរដូចគ្នា ។ ព្រោះហេតុដែល **អភិក្កន្ត** សព្ទ ប្រើក្នុងអត្ថនៃ **អព្ភ-នុមោទន** ដូច្នោះ ទើបគួរជ្រាបថា បទថា **អភិក្កន្តំ ភោ គោតម** លោក

អធិប្បាយថា បានដល់ **សាធុ សាធុ ភោ គោតម** បពិត្រព្រះគោតមដ៏ចម្រើន ព្រះតម្រាស់ព្រះអង្គ ល្អហើយ ប្រពៃហើយ ព្រះអង្គ ។

អ្នកប្រាជ្ញបានពោលគាថាពន្ធនេះទុកថា

អ្នកប្រាជ្ញធ្វើការពោលដដែលៗ ក្នុងពាក្យពោលសម្តែង **ភយេ** គឺការខ្លាច **កោធេ** គឺសេចក្តីក្រោធ **បសំសាយំ** គឺការសរសើរ **តុរិតេ** ការប្រញាប់ប្រញាល់ **កោតុហលេ** គឺការភ្ញាក់ផ្អើល **អច្ឆរេ** គឺការអស្ចារ្យ **ហាសេ** គឺការសប្បាយរីករាយ **សោកេ** គឺសេចក្តីសោក និង **បសាទេ** គឺសេចក្តីជ្រះថ្លា ។

ដោយលក្ខណៈដូចពោលមកនេះ **អភិក្កន្ត** សព្ទនេះ គប្បីជ្រាបថា ព្រាហ្មណ៍ពោលទុកដល់ ២ ដងក្នុងទីនេះ ក៏ដោយអំណាចការជ្រះថ្លា និងការសរសើរ ។

ម្យ៉ាងទៀត បទថា **អភិក្កន្តំ** ប្រែថា គួរសរសើរក្រៃលែង និងគួរប្រាថ្នាក្រៃលែង អធិប្បាយថា គួរពេញចិត្តក្រៃលែង គឺល្អក្រៃលែង ។ ក្នុង **អភិ-កន្ត** សព្ទទាំង ២ នោះ ព្រាហ្មណ៍សរសើរទេសនា ដោយ **អភិក្កន្ត** សព្ទម្យ៉ាង ប្រកាសសេចក្តីជ្រះថ្លារបស់ខ្លួន ដោយ **អភិក្កន្ត** សព្ទម្យ៉ាង ។

ក្នុងអត្ថទាំង ២ នេះ មានអធិប្បាយដូច្នេះថា ព្រះធម្មទេសនារបស់ព្រះគោតមដ៏ចម្រើន គួរចាប់ចិត្តពន់ពេក ការជ្រះថ្លារបស់ខ្ញុំព្រះអង្គអាស្រ័យធម្មទេសនារបស់ព្រះគោតមដ៏ចម្រើន គួរពេញចិត្តក្រៃពេក បើមិនដូច្នោះទេ ព្រាហ្មណ៍នេះបំណងប្រើអត្ថទាំង ២ ក្នុងការសរសើរព្រះតម្រាស់របស់ព្រះ

មានព្រះភាគ គឺសរសើរថា ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើន រាប់ថា ចាប់ចិត្តពន់ពេក ព្រោះញុំាំងទោសឲ្យវិនាសទៅ រាប់ថា ចាប់ចិត្តពន់ពេក ព្រោះឲ្យសម្រេចគុណ ម្យ៉ាងទៀត អ្នកសិក្សាគប្បីប្រកបបទថា **ភោ គោ គោតមស្ស វចនំ អភិក្កន្តំ** ចូលជាមួយបទទាំងឡាយ មានជាដើម យ៉ាងនេះថា

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើន រាប់ថា ពីរោះពន់ពេក ព្រោះថាធ្វើឲ្យកើតសទ្ធា រាប់ថា ចាប់ចិត្តក្រៃពេក ព្រោះធ្វើឲ្យកើតបញ្ញា ។

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើន រាប់ថា ពីរោះពន់ពេក ព្រោះដល់ព្រមដោយអត្ថ រាប់ថា ចាប់ចិត្តពន់ពេក ព្រោះដល់ព្រមដោយព្យញ្ជនៈ ។

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើន រាប់ថា ពីរោះពន់ពេក ព្រោះមានបទងាយ រាប់ថា ចាប់ចិត្តពន់ពេក ព្រោះមានអត្ថជ្រាលជ្រៅ ។

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើន រាប់ថា ពីរោះពន់ពេក ព្រោះស្តាប់ហើយ ពីរោះត្រចៀក រាប់ថា ចាប់ចិត្តពន់ពេក ព្រោះស្តាប់ហើយយល់ច្បាស់ក្នុងចិត្ត ។

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើន រាប់ថា ពីរោះពន់ពេក ព្រោះមិនលើកខ្លួន រាប់ថា ចាប់ចិត្តពន់ពេក ព្រោះមិនបន្តុះបង្អាប់អ្នកដទៃ ។

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើន រាប់ថា ពីរោះពន់ពេក ព្រោះត្រជាក់ដោយព្រះករុណា រាប់ថា ចាប់ចិត្តពន់ពេក ព្រោះផូរផង់ដោយព្រះបញ្ញា ។

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើន រាប់ថា ពីរោះពន់ពេក ព្រោះជាទីរីករាយតាមគន្ធន រាប់ថា ចាប់ចិត្តពន់ពេក ព្រោះអត់ធន់ចំពោះការដែលត្រូវវាយដំ ។

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើន រាប់ថា ពីរោះពន់ពេក ព្រោះកំពុងស្តាប់ក៏ជាសុខ រាប់ថា ចាប់ចិត្តពន់ពេក ព្រោះពិចារណាក៏ជាប្រយោជន៍ ។

បន្ទាប់អំពីនោះ ព្រាហ្មណ៍បានសរសើរព្រះធម្មទេសនានោះឯង ដោយឧបមា ៤ យ៉ាង ។

បណ្តាបទទាំងនោះ បទថា **និក្កុជ្ជិតំ** បានដល់ ភាជនៈដែលផ្កាប់មាត់ចុះក្រោម ឬដែលមានមាត់នៅខាងក្រោម ។

បទថា **ឧក្កុជ្ជេយ្យ** បានដល់ ផ្ងារមាត់ឡើង ។ បទថា **បដិច្ឆន្នំ** បានដល់ ដែលគេបិទដោយស្មៅ និងស្លឹកឈើជាដើម ។ បទថា **វិវរេយ្យ** ប្រែថា បើក ។ បទថា **មូឡ្ហស្ស** បានដល់ អ្នកវង្វេងទិស ។

បទថា **មគ្គំ អាចិក្ខេយ្យ** សេចក្តីថា ចាប់ដៃហើយប្រាប់ថា នេះផ្លូវ ។

បទថា **អន្ធការេ** គឺក្នុងកាពងងឹតមានអង្គ ៤ គឺងងឹតព្រោះថ្ងៃ ១៤ រោច ព្រោះជាវេលាកណ្តាលយប់ ព្រោះព្រៃក្រាស់ ព្រោះពពកក្រាស់បិទបាំង ។

អត្ថរបស់បទដែលជ្រាលជ្រៅ មានប្រមាណប៉ុណ្ណេះ ។

ឯពាក្យអធិប្បាយប្រកបអត្ថ មានដូច្នេះថា ព្រះគោតមដ៏ចម្រើន ជាអ្នកញុំាងខ្ញុំព្រះអង្គដែលបែរមុខចេញអំពីព្រះសទ្ធម្ម ធ្លាក់ចូលទៅក្នុងអសទ្ធម្ម ឲ្យផុតចាកអសទ្ធម្ម ដូចបុគ្គលណាម្នាក់ ផ្ងារវត្ថុដែលផ្កាប់ឡើងដូច្នោះ បើក

សាសនាដែលត្រូវបិទបាំងដោយព្រៃស្តុក គឺមិច្ឆាទិដ្ឋិ ចាប់តាំងអំពីសាសនា របស់ព្រះមានព្រះភាគព្រះនាមថាកស្សបអន្តរធានទៅ ដូចបុគ្គលណាម្នាក់ បើករបស់ដែលត្រូវបិទបាំងចេញ ដូច្នោះ ជាអ្នកប្រាប់ផ្លូវសួគ៌ និងនិព្វានដល់ ខ្ញុំព្រះអង្គ ដែលដើរវង្វេងផ្លូវ ទៅកាន់ផ្លូវទាប គឺផ្លូវដែលខុស ដូចបុគ្គលណា ម្នាក់ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ដូច្នោះ ឈ្មោះថា ទ្រង់បានប្រកាសធម៌ហើយ ដោយអនេកបរិយាយដល់ខ្ញុំព្រះអង្គ ព្រោះទ្រង់ប្រកាសហើយ ដោយបរិយាយ ទាំងនេះ ដោយទ្រង់បញ្ចេញពន្លឺ គឺព្រះធម្មទេសនា កម្ចាត់បង់នូវភាពងងឹត គឺមោហៈ ដែលបិទបាំងព្រះរតនត្រ័យនោះដល់ខ្ញុំព្រះអង្គ ដែលជាអ្នកលិច លង់ទៅក្នុងងងឹត គឺមោហៈ មើលមិនឃើញរូបព្រះរតនត្រ័យ មានព្រះពុទ្ធ ជាដើម ដូចបុគ្គលណាម្នាក់ ទ្រោលភ្លើងក្នុងទីងងឹត ដូច្នោះ ។

កាលព្រាហ្មណ៍សរសើរព្រះធម្មទេសនាយ៉ាងនេះហើយ មានចិត្តជ្រះថ្លា ក្នុងព្រះរតនត្រ័យ ព្រោះទេសនានេះ កាលទ្រង់ធ្វើអាការរបស់បុគ្គលដែល ជ្រះថ្លា ទើបពោលពាក្យថា **ឯសាហំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឯសាហំ** កាត់បទជា **ឯសោ អហំ** ប្រែថា ខ្ញុំព្រះអង្គនោះ ។

ត្រើនបទថា **ភវន្តំ គោតមំ សរណំ គច្ឆាមិ** សេចក្តីថា ខ្ញុំព្រះអង្គសូម ដល់ សូមគប់រក សូមសេព សូមចូលទៅអង្គុយជិតព្រះគោតមដ៏ចម្រើន ដោយបំណងនេះថា សូមព្រះគោតមដ៏ចម្រើន ជាទីរឭក ជាទីពឹង ជាអ្នក ទម្លាយសេចក្តីទុក្ខ និងជាអ្នកសាងប្រយោជន៍សុខឲ្យដល់ខ្ញុំព្រះអង្គផងចុះ ។

ម្យ៉ាងទៀត សេចក្តីថា ខ្ញុំព្រះអង្គដឹង គឺជ្រាបយ៉ាងនេះ ។ ព្រោះថា ធាតុពួកណា ប្រែថា ទៅ ធាតុទាំងនោះរមែងប្រែថា ដឹងបានផងដែរ ។ ព្រោះដូច្នោះ បទថា **គច្ឆាមិ** នេះ ទើបព្រះអដ្ឋកថាចារ្យពោលអត្ថទុកដូច្នេះថា **ជានាមិ ពុជ្ឈាមិ** ប្រែថា កំពុងដឹង កំពុងជ្រាប ។

ក្នុងបទថា **ធម្មញ្ច ភិក្ខុសង្ឃញ្ច** នេះ គប្បីជ្រាបអធិប្បាយដូចតទៅថា

ដែលឈ្មោះថា ធម៌ ព្រោះអត្ថថា ទ្រទ្រង់ទុកនូវបុគ្គលទាំងឡាយដែលបានសម្រេចអរិយមគ្គ អ្នកធ្វើឲ្យជាក់ច្បាស់នូវនិរោធហើយ និងអ្នកបដិបត្តិតាមពាក្យដែលព្រះពុទ្ធទ្រង់ប្រៀនប្រដៅជានិច្ចកាល មិនឲ្យធ្លាក់ទៅក្នុងអបាយ ៤ ។ ធម៌នោះ កាលពោលដោយអត្ថ ក៏បានដល់អរិយមគ្គ និងនិព្វាន សមដូចព្រះតម្រាស់ដែលព្រះពុទ្ធត្រាស់ទុកដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាសង្ខតៈ មានប៉ុនណា អរិយមគ្គមានអង្គ ៨ តថាគតពោលថា ជាកំពូលនៃធម៌ដែលជាសង្ខតៈទាំងនោះ សេចក្តីពិស្តារដូចពោលមកដូច្នេះ ។ មិនមែនតែអរិយមគ្គ និងនិព្វានតែម្យ៉ាងប៉ុណ្ណោះទេ ដែលឈ្មោះថា ធម៌ ។ ដោយពិតនោះ សូម្បីបរិយត្តិធម៌ ព្រមទាំងអរិយផលទាំងឡាយ ក៏ឈ្មោះថា ធម៌ សមដូចពាក្យដែលទេវបុត្រពោលទុកក្នុងឆត្តមាណវកវិមានវត្ថុថា

អ្នកចូរដល់នូវធម៌ ដែលប្រាសចាករាគៈ មិនរំភើប មិនមានសោក ជាសភាវធម៌ដែលបច្ច័យប្រជុំតាក់តែងមិនបាន ជាធម៌មិនគួរខ្ពើម ជាធម៌ដ៏ពីរោះ ដ៏ល្អិត ដែលលោកចែកត្រឹមត្រូវហើយ ដើម្បីជាសរណៈចុះ ។

ក្នុងគាថានេះគប្បីជ្រាបវិនិច្ឆ័យដូច្នេះថា បទថា ជាធម៌ប្រាសចាករាគៈ គឺ

ទេវបុត្រពោលដល់ មគ្គ ។ ពាក្យថា ជាធម៌មិនរំភើប មិនមានសោក គឺទេវបុត្រពោលដល់ផល ។ ពាក្យថា ជាធម៌ដែលបច្ច័យប្រជុំតាក់តែងមិនបាន គឺទេវបុត្រពោលដល់និព្វាន ។ ពាក្យថា ជាធម៌មិនគួរខ្ពើម ជាធម៌ដ៏ពីរោះ ដែលព្រះពុទ្ធទ្រង់ជំនាញហើយផង ទ្រង់បានចែកទុកល្អហើយផងនេះ គឺទេវ-បុត្រពោលដល់ព្រះធម្មក្ខន្ធទាំងអស់ ដែលទ្រង់ចែកទុកក្នុងព្រះត្រៃបិដក ។

ដែលឈ្មោះថា សង្ឃ ព្រោះអត្ថថា រួមគ្នាដោយគ្រឿងរួម គឺទិដ្ឋិ និងសីល ។ សង្ឃនោះ កាលពោលដោយអត្ថ គឺពួកព្រះអរិយបុគ្គល ៨ ពួក ។ សមដូចពាក្យដែលទេវបុត្រពោលទុកក្នុងវិមានវត្ថុនោះឯងថា

អ្នកប្រាជ្ញទាំងឡាយ បានពោលនូវទាន ដែលបុគ្គលឲ្យហើយ ចំពោះគូបុរសដ៏ស្អាត ៤ គូណា ថាជាទានមានផលច្រើន គូនៃបុរសនោះ ចាត់ជាបុគ្គល ៨ ពួក ជាអ្នកឃើញនូវធម៌ អ្នកចូរដល់នូវព្រះសង្ឃនេះ ជាសរណៈចុះ ។

ពួកនៃសង្ឃទាំងឡាយ ឈ្មោះថា ភិក្ខុសង្ឃ ។ ព្រាហ្មណ៍បានប្រកាសការដល់សរណៈទាំង ៣ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

## សរណគមនកថា

ឥឡូវនេះ ដើម្បីភាពជាអ្នកឈ្លាសក្នុងសរណគមន៍ទាំងនោះ ទើបគួរជ្រាបវិធីនេះ គឺសរណៈ ការដល់សរណៈ អ្នកដល់សរណៈ ប្រភេទនៃការដល់សរណៈ ផលនៃការដល់សរណៈ សង្កិលេស គឺការសៅហ្មង និងភេទ គឺការបែកធ្លាយនៃសរណៈ ។

សួរថា វិធីនេះមានអត្ថដូចម្តេចខ្លះ ឆ្លើយថា គួរជ្រាបអត្ថ ដោយអត្ថចំពោះបទមុន ។ ដែលឈ្មោះថា សរណៈ ព្រោះអត្ថថា បៀតបៀន អធិប្បាយថា រមែងកម្ចាត់ គឺធ្វើការភ័យ ការខ្វាច សេចក្តីទុក្ខ កិលេសដែលជាហេតុឲ្យទៅកាន់ទុគ្គតិរបស់បុគ្គលដែលដល់នូវសរណៈ ឲ្យវិនាសទៅ ដោយការដល់នូវសរណៈនោះឯង ។ ពាក្យថា **សរណ** នោះ ជាឈ្មោះហៅព្រះ-រតនត្រ័យ ។

ម្យ៉ាងទៀត ដែលឈ្មោះថា **ពុទ្ធ** ព្រោះអត្ថថា កម្ចាត់បង់នូវភ័យរបស់សត្វទាំងឡាយ ដោយធ្វើសត្វទាំងឡាយ ឲ្យប្រព្រឹត្តទៅក្នុងប្រយោជន៍ និងត្រឡប់អំពីវត្ថុដែលមិនមែនប្រយោជន៍ ។

ដែលឈ្មោះថា **ធម៌** ព្រោះធ្វើសត្វទាំងឡាយ ឲ្យឆ្លងចាកកន្តារ គឺភព និងព្រោះឲ្យការស្រោលចិត្តដល់សត្វទាំងឡាយ ។

ដែលឈ្មោះថា **សង្ឃ** ព្រោះធ្វើសក្ការៈទាំងឡាយ សូម្បីជារបស់មានតម្លៃតិច ឲ្យទទួលផលដ៏បរិបូណ៌ ព្រោះដូច្នោះ ទើបព្រះរតនត្រ័យ ឈ្មោះថា សរណៈដោយបរិយាយនេះឯង ។

ចិត្តុប្បាទដែលមានកិលេសកម្ចាត់ហើយ ដោយភាពជាអ្នកគោរពជ្រះថ្លាក្នុងសរណៈនោះ ដែលប្រព្រឹត្តទៅដោយអាការ មានការគោរពជ្រះថ្លាក្នុងព្រះរតនត្រ័យនោះជាខាងមុខ ឈ្មោះថា សរណគមន៍ ។

សត្វដែលដល់ព្រមដោយសរណគមន៍នោះ ឈ្មោះថា ដល់សរណៈ ។ អធិប្បាយថា រមែងចូលដល់រតនៈទាំង ៣ នេះ ថាជាសរណៈ គឺទីពឹង

ទីពឹង ថាជាបរាយនៈ ធម៌នាំទៅកាន់ត្រើយ ដោយចិត្តប្បាទដែលមានប្រការដូចពោលហើយ ។ អ្នកសិក្សាគប្បីជ្រាបសរណៈ ការដល់សរណៈ និងអ្នកដល់សរណៈទាំង ៣ យ៉ាងនេះ ។

ឯក្នុងប្រភេទនៃការដល់សរណៈ ( ការដល់សរណៈមានប៉ុន្មានប្រភេទ ) គប្បីជ្រាបអធិប្បាយតទៅ ។ ការដល់សរណៈមាន ២ គឺការដល់សរណៈដែលជាលោកុត្តរ ១ ការដល់សរណៈដែលជាលោកិយ ១ ។ ក្នុងបទ ២ យ៉ាងនោះ ការដល់សរណៈដែលជាលោកុត្តរនៃបុគ្គលដែលឃើញសច្ចៈហើយ កាលពោលដោយអារម្មណ៍ រមែងមាននិព្វានជាអារម្មណ៍ កាលពោលដោយកិច្ច រមែងសម្រេចបានក្នុងព្រះរតនត្រ័យទាំងអស់ ព្រោះកាត់ផ្តាច់កិលេសជាហេតុជំទាស់ដល់ការដល់នូវសរណៈបាន ក្នុងខណៈនៃមគ្គ ។ ការដល់សរណៈដែលជាលោកិយនៃបុថុជ្ជន កាលពោលដោយអារម្មណ៍ រមែងមានព្រះពុទ្ធគុណជាដើមជាអារម្មណ៍ សម្រេចបានដោយការសង្កត់កិលេសដែលជាហេតុជំទាស់ការដល់សរណៈបាន ។ ការដល់សរណៈនោះ កាលពោលដោយអត្ថ បានដល់ ការបានសទ្ធាក្នុងព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម និងសម្មាទិដ្ឋិ ដែលមានសទ្ធាជាបាទ លោកហៅថា **ទិដ្ឋុជុកម្ម** គឺការធ្វើទិដ្ឋិឲ្យត្រង់ ក្នុងបុញ្ញកិរិយាវត្ថុ ១០ ។

ការដល់សរណៈបែបនេះ មាន ៤ យ៉ាង គឺការដល់ដោយប្រគល់កាយ ១ ដោយការមានព្រះរតនត្រ័យនោះជាគ្រឿងនាំផ្លូវ ១ ដោយភាពជាសិស្ស ១ ដោយការឧទ្ទិសដៃ គឺការប្រណម្យដៃធ្វើសេចក្តីគោរព ១ ។

ក្នុង ៤ យ៉ាងនោះ ដែលឈ្មោះថា ការប្រគល់កាយ បានដល់ ការលះបង់ខ្លួនដល់ព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម ( ដោយការពោលយ៉ាងនេះថា ) តាំងអំពីថ្ងៃនេះជាដើមទៅ ខ្ញុំព្រះអង្គសូមប្រគល់ខ្លួនថ្វាយដល់ព្រះពុទ្ធ ដល់ព្រះធម៌ និងព្រះសង្ឃ ។

ដែលបានឈ្មោះថា ការមានរតនត្រ័យនោះជាគ្រឿងនាំផ្លូវ បានដល់ ការមានព្រះរតនត្រ័យនោះជាទីទៅខាងមុខ ដោយការពោលយ៉ាងនេះថា តាំងពីថ្ងៃនេះជាដើមទៅ សូមលោកម្ចាស់ទាំងឡាយ ចាំទុកនូវខ្ញុំថា ខ្ញុំសូមមានព្រះពុទ្ធជាអ្នកនាំផ្លូវ សូមមានព្រះធម៌ជាអ្នកនាំផ្លូវ សូមមានព្រះសង្ឃជាអ្នកនាំផ្លូវ ។

ដែលឈ្មោះថា ការឧទ្ទិសដៃ បានដល់ ធ្វើការនមស្ការយ៉ាងខ្ពង់ខ្ពស់ក្នុងព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម ដោយការពោលយ៉ាងនេះថា ចាប់អំពីថ្ងៃនេះជាដើមទៅ សូមលោកម្ចាស់ទាំងឡាយ ចាំទុកនូវខ្ញុំថា ខ្ញុំសូមធ្វើការក្រាបថ្វាយបង្គំ ការក្រោកទទួល ការផ្គងអញ្ជលី ការធ្វើការនមស្ការចំពោះព្រះរតនត្រ័យ មានព្រះពុទ្ធជាដើមនោះឯង ។

បុគ្គលកាលធ្វើអាការឯណាមួយ ក្នុងបណ្តាអាការទាំង ៤ យ៉ាងនេះ ចាត់ថា បានទទួលការដល់សរណៈហើយនោះឯង ។

ម្យ៉ាងទៀត គប្បីជ្រាបការប្រគល់កាយ ដោយការពោលយ៉ាងនេះថា ខ្ញុំសូមលះបង់ខ្លួនដល់ព្រះមានព្រះភាគ ដល់ព្រះធម៌ ដល់ព្រះសង្ឃ ខ្ញុំសូមលះជីវិតដល់ព្រះមានព្រះភាគ ដល់ព្រះធម៌ ដល់ព្រះសង្ឃ ខ្ញុំលះបង់ខ្លួនហើយនោះឯងដល់ព្រះមានព្រះភាគ ដល់ព្រះធម៌ ដល់ព្រះសង្ឃ ខ្ញុំលះបង់ជីវិត

ហើយនោះឯងដល់ព្រះមានព្រះភាគ ដល់ព្រះធម៌ និងដល់ព្រះសង្ឃ ខ្ញុំសូមដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ថាជាសរណៈ ដោយសូមយកជីវិតជាទុន សូមព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាទីពឹង ទីរឭក ជាទីអាស្រ័យ ជាទីជ្រកកោនរបស់ខ្ញុំ ។

គប្បីឃើញការចូលដល់ភាពជាសិស្ស ដូចការចូលដល់ភាពជាសិស្សក្នុងការដល់សរណៈរបស់ព្រះមហាកស្សប ដោយការពោលយ៉ាងនេះថា អើហ្ន៎ ប្រសិនបើអាត្មាអញជួបនឹងបុគ្គលដែលជាគ្រូ ក៏សូមឲ្យជួបតែនឹងព្រះមានព្រះភាគ អើហ្ន៎ ប្រសិនបើអាត្មាអញ បានជួបនឹងបុគ្គលដែលមានគតិល្អ ក៏សូមឲ្យជួបតែនឹងព្រះមានព្រះភាគ អើហ្ន៎ ប្រសិនបើអាត្មាអញ បានជួបនឹងបុគ្គលដែលត្រាស់ដឹងធម៌ ក៏សូមឲ្យជួបតែនឹងព្រះមានព្រះភាគ ។

គប្បីជ្រាបការដែលមានព្រះរតនត្រ័យនោះជាគ្រឿងនាំផ្លូវ ដូចការដល់សរណៈរបស់ជនទាំងឡាយ មានអាឡវកយក្ខជាដើម ដោយពោលយ៉ាងនេះថា

ខ្ញុំនឹងចេញពីស្រុកមួយ ទៅស្រុកមួយ ចេញពីបុរីមួយ ទៅបុរីមួយ នមស្ការនូវព្រះពុទ្ធផង ព្រះធម៌ដ៏ប្រសើរផង ។

គប្បីឃើញការផ្គងអញ្ជលីសំពះយ៉ាងនេះថា កាលនោះឯង ព្រហ្មាយុក៏ក្រោកអំពីអាសនៈ ធ្វើនូវសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ក្រាបទៀបព្រះបាទានៃព្រះមានព្រះភាគដោយក្បាល ជប់ព្រះបាទានៃព្រះមានព្រះភាគដោយមាត់ផង ប្របាច់ដោយដៃផង បន្លឺឈ្មោះរបស់ខ្លួនថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះថា ព្រហ្មាយុព្រាហ្មណ៍ បពិត្រព្រះគោតមដ៏ចម្រើន

ខ្ញុំព្រះអង្គ ឈ្មោះព្រហ្មាយុព្រាហ្មណ៍ ។

ការប្រណម្យដែសំពះនោះមាន ៤ យ៉ាង គឺព្រោះជាញាតិ ព្រោះភ័យ ព្រោះជាអាចារ្យ និងព្រោះជាទក្ខិណេយ្យបុគ្គល ការផ្គងអញ្ជលី ៤ យ៉ាងនោះ ការដល់សរណៈមានដោយការផ្គងអញ្ជលី ព្រោះជាទក្ខិណេយ្យបុគ្គល មិនមែនដោយហេតុ ៣ យ៉ាងក្រៅអំពីនេះឡើយ ។

ព្រោះថា សរណៈដែលបុគ្គលទទួលបាន ដោយបុគ្គលដ៏ប្រសើរបំផុត និងអស់សការៈទៅ ដោយអំណាចបុគ្គលដ៏ប្រសើរបំផុតដូចគ្នា ។ ព្រោះដូច្នោះ បុគ្គលណាមានផៅពង្សជាសក្យៈ ឬជាកោលិយៈក្តី ថ្វាយបង្គំព្រះពុទ្ធ ដោយសម្គាល់ថា ព្រះពុទ្ធអង្គជាព្រះញាតិរបស់យើងទាំងឡាយ បុគ្គលនោះមិនទាន់ឈ្មោះថា បានទទួលសរណៈឡើយ ។ ឬបុគ្គលណាថ្វាយបង្គំព្រះពុទ្ធ ដោយសេចក្តីភ័យខ្លាចថា ព្រះសមណគោតមដែលព្រះរាជាបូជាហើយ មានអានុភាពច្រើន កាលអញមិនថ្វាយបង្គំ គប្បីធ្វើសេចក្តីវិនាសឲ្យដល់អញបាន បុគ្គលនោះ ក៏មិនទាន់ឈ្មោះថា បានទទួលសរណៈដូចគ្នា ។ បុគ្គលណារឭកដល់ពាក្យប្រៀនប្រដៅណាមួយ ដែលបានរៀនក្នុងសម្នាក់ព្រះមានព្រះភាគ កាលព្រះអង្គនៅជាព្រះពោធិសត្វ ឬក្នុងពុទ្ធកាល បានរៀនពាក្យប្រៀនប្រដៅទំនងនេះថា

កុលបុត្រដែលចែកភោគៈទាំងឡាយជា ៤ ចំណែក គឺបរិភោគភោគៈទាំងឡាយ ១ ចំណែក ប្រកបការងារ ២ ចំណែក ទាំងតម្កល់ទុកចំណែកទី ៤ ដោយក្រែងមានអន្តរាយទាំងឡាយ ( ទៅខាងមុខ ) ។

កើតការជ្រះថ្លា ថ្វាយបង្គំ ដោយរឭកថា ព្រះអង្គជាអាចារ្យរបស់យើង បុគ្គលនោះក៏ឈ្មោះថា មិនទាន់បានទទួលសរណៈដូចគ្នា ។

ឯបុគ្គលណាថ្វាយបង្គំ ដោយសម្គាល់ថា ព្រះពុទ្ធទ្រង់ជាអគ្គទក្ខិណេយ្យបុគ្គលក្នុងលោក បុគ្គលនោះឯង ឈ្មោះថា បានទទួលសរណៈហើយ ។ ឧបាសក ឬឧបាសិកាដែលបានទទួលសរណៈយ៉ាងនេះហើយ កាលថ្វាយបង្គំញាតិដែលបួសក្នុងសម្នាក់តិរ្ថិយ ដោយការរឭកថា លោកម្ចាស់នេះជាញាតិរបស់អញ ដូច្នេះ ការដល់សរណៈក៏មិនអស់សការៈទៅ គឺមិនបែកធ្លាយសរណៈ នឹងពោលថ្វីដល់បុគ្គល ឬឧបាសិកាដែលថ្វាយបង្គំញាតិដែលមិនទាន់បួសនោះ ។

សម្រាប់ឧបាសក ឬឧបាសិកា ដែលថ្វាយបង្គំព្រះរាជាក៏ដូចគ្នា គឺថ្វាយបង្គំដោយអំណាចភ័យថា ព្រះរាជាអង្គនេះ ជាអ្នកដែលអ្នកដែនបូជាហើយ កាលអញមិនថ្វាយបង្គំ ក៏ធ្វើសេចក្ដីវិនាសដល់អញបាន ដូច្នេះ ការដល់សរណៈក៏មិនអស់សការៈទៅ ដូចកាលបុគ្គល សូម្បីថ្វាយបង្គំតិរ្ថិយ ដែលឲ្យការសិក្សាសិប្បៈឯណាមួយ ដោយគិតថា បុគ្គលនេះជាគ្រូរបស់អញ ការដល់សរណៈក៏មិនអស់សការៈទៅ ដូច្នោះ អ្នកសិក្សាគប្បីជ្រាបប្រភេទនៃការដល់សរណៈយ៉ាងនេះឯង ។

ការដល់សរណៈដែលជាលោកុត្តរក្នុងទីនេះ មានសមញ្ញផល ៤ ជាវិបាកផល មានការអស់ទៅនៃទុក្ខទាំងពួង ជាអានិសង្សផល សមដូចព្រះតម្រាស់ដែលព្រះសម្ពុទ្ធត្រាស់ដូច្នេះថា

លុះតែបុគ្គលណា យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ឃើញច្បាស់នូវអរិយសច្ចទាំង ៤ គឺទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ និរោធសច្ចកន្លងទុក្ខ ១ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វានដែលជាទីរម្ងាប់ទុក្ខ ១ ដោយប្រាជ្ញាដ៏ប្រពៃ នេះឯងជាទីពឹងដ៏ក្សេម នេះឯងជាទីពឹងដ៏ឧត្តម បុគ្គលអាស្រ័យទីពឹងនេះ រមែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

ម្យ៉ាងទៀត គប្បីជ្រាបអានិសង្ស គឺផលនៃការដល់សរណៈនោះ ដោយអំណាចនៃហេតុ មានការមិនចូលទៅប្រកាន់ ដោយភាពជារបស់ទៀងជាដើម សមដូចព្រះតម្រាស់ដែលព្រះពុទ្ធត្រាស់ដូច្នេះថា

ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់ថា ការណ៍នុ៎ះឥតហេតុឥតបច្ច័យទេ ត្រង់ដែលបុគ្គលបរិបូណ៌ដោយទិដ្ឋិ ប្រកាន់នូវសង្ខារនីមួយថាទៀង ថាជាសុខ ថាជារបស់ខ្លួន គប្បីផ្តាច់បង់នូវមាតាចាកជីវិត គប្បីផ្តាច់បង់នូវបិតាចាកជីវិត ។បេ។ គប្បីញុំាងព្រះលោហិតព្រះតថាគតឲ្យពុរពង គប្បីបំបែកសង្ឃ គប្បីឧទ្ទិស ( ងាកចិត្តទៅរក ) សាស្តាដទៃ ការណ៍នុ៎ះមិនសមហេតុឡើយ ។

ឯការដល់សរណៈដែលជាលោកិយ រមែងមានភពសម្បត្តិ និងភោគ-សម្បត្តិជាផលដូចគ្នា សមដូចព្រះតម្រាស់ដែលព្រះសម្ពុទ្ធត្រាស់ដូច្នេះថា

ជនទាំងឡាយណាមួយ បានដល់នូវព្រះពុទ្ធ ជាទីរឭក ជនទាំងនោះនឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សហើយនឹងទៅបំពេញក្នុងពួកទេវតាមិនខាន ។

សូម្បីរឿងដទៃលោកក៏ពោលទុក ។ គ្រានោះឯង សក្កទេវរាជ មួយអន្លើដោយទេវតា ៨ ម៉ឺន បានចូលទៅរកព្រះមហាមោគ្គល្លាន ។ ព្រះមហាមោគ្គល្លានបានពោលនឹងសក្កទេវរាជដែលឈរក្នុងទីសមគួរ នាចំណែកម្ខាងដូច្នេះថា បពិត្រទេវានមិន្ទ ការដល់នូវព្រះពុទ្ធជាទីពឹងប្រពៃណាស់ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះពុទ្ធជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ ទេវលោកយ៉ាងនេះឯង សត្វទាំងនោះ រមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាង គឺអាយុជាទិព្វ ១ ពណ៌សម្បុរជាទិព្វ ១ សេចក្តីសុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ។ ក្នុងការដល់ព្រះធម៌ និងព្រះសង្ឃថាជាសរណៈ ក៏ន័យនេះ ។ ន័យម្យ៉ាងទៀត គប្បីជ្រាបផលដែលសម្គាល់របស់ការដល់សរណៈ ដោយអំណាចនៃសូត្រ មានវេលាមសូត្រជាដើម ។ គប្បីជ្រាបផលនៃការដល់សរណៈយ៉ាងនេះ ។

ក្នុងការដល់សរណៈ ២ យ៉ាងនោះ ការដល់សរណៈដែលជាលោកិយរមែងសៅហ្មងដោយហេតុទាំងឡាយ មានការមិនដឹង ការសង្ស័យ និងការដឹងខុសជាដើម ក្នុងព្រះរតនត្រ័យ ជាការដល់សរណៈ ដែលមិនមានការរុងរឿងច្រើន មិនទូលំទូលាយច្រើន ។ ឯការដល់សរណៈដែលជាលោកុត្តរមិនមានការសៅហ្មងឡើយ ។

ការដល់សរណៈដែលជាលោកិយ មានការអស់សការៈ គឺដាច់ត្រៃ

សរណៈ ២ យ៉ាង គឺការបែកធ្លាយមានទោស ១ ការបែកធ្លាយមិនមានទោស ១ ក្នុងការអស់សភាវៈទាំង ២ យ៉ាងនោះ ការអស់សភាវៈមានទោស រមែងមានដោយហេតុទាំងឡាយ មានការចូលសាសនាដទៃជាដើម ការអស់សភាវៈបែបនោះ មានផលមិនគួរប្រាថ្នា ។ ការអស់សភាវៈមិនមានទោស ព្រោះធ្វើកាលកិរិយា ការអស់សភាវៈបែបនោះ មិនមានផល ព្រោះមិនមានវិបាក ។ តែការដល់សរណៈបែបលោកុត្តរ មិនមានការអស់សភាវៈឡើយ ។ ពិតហើយ ព្រះអរិយសាវក ស្លាប់ហើយទៅកើតក្នុងភពដទៃ ក៏មិនលើកតម្កើងបុគ្គលដទៃថាជាសាស្តា ។ គប្បីជ្រាបការសៅហ្មង និងការអស់សភាវៈ គឺដាច់ការដល់សរណៈដូចពណ៌នាមក ដូច្នេះ ។

បទថា **ឧបាសកំ មំ ភវំ គោតមោ ធារេតុ** សេចក្តីថា សូមព្រះគោតមដ៏ចម្រើនចាំទុក អធិប្បាយថា សូមស្គាល់ខ្ញុំព្រះអង្គយ៉ាងនេះថា បុគ្គលនេះជាឧបាសក ។

ក្នុងទីនេះ ដើម្បីភាពជាអ្នកឈ្លាសក្នុងវិធីប្រគល់ខ្លួនជាឧបាសក ទើបគួរជ្រាបបកិណ្ណកៈនេះថា ឧបាសក គឺបុគ្គលណា ព្រោះហេតុអ្វី ទើបឈ្មោះថាឧបាសក ឧបាសកនោះមានសីលដូចម្តេច មានអាជីវៈដូចម្តេច មានវិបត្តិដូចម្តេច មានសម្បត្តិដូចម្តេច ។

ក្នុងបកិណ្ណកៈទាំងនោះ ពាក្យថា ឧបាសក គឺអ្វី បានដល់ គ្រហស្ថណាម្នាក់ដែលដល់សរណៈ ។ សមដូចព្រះតម្រាស់ ដែលព្រះសម្ពុទ្ធត្រាស់ទុកដូច្នេះថា ម្នាលមហានាម បុគ្គលជាអ្នកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះ

ធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ព្រោះហេតុឯណា ម្នាលមហានាម បុគ្គលដែលឈ្មោះថា ឧបាសក ព្រោះហេតុនេះឯង ។

ពាក្យថា ព្រោះហេតុដូចម្តេច ទើបហៅថាឧបាសក បានដល់ ព្រោះចូលទៅអង្គុយជិតព្រះរតនត្រ័យ ។ ពិតហើយ បុគ្គលនោះឈ្មោះថា ឧបាសក ព្រោះចូលទៅអង្គុយជិតព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

ពាក្យថា ឧបាសកនោះ មានសីលដូចម្តេច បានដល់ ចេតនាជាគ្រឿងវៀរចាក ៥ យ៉ាង ។ សមដូចព្រះសម្ពុទ្ធត្រាស់ទុកយ៉ាងនេះថា ម្នាលមហានាម ឧបាសកជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ដោយហេតុឯណា ម្នាលមហានាម ឧបាសកបរិបូណ៌ដោយសីល ដោយហេតុនេះឯង ។

ពាក្យថា មានអាជីពដូចម្តេច បានដល់ ការលះជំនួញខុស ៥ យ៉ាង ហើយចិញ្ចឹមជីវិតដោយសម្មាអាជីវៈ សមដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ទុកដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ជំនួញ ៥ យ៉ាងនេះ ឧបាសកមិនគួរធ្វើឡើយ ជំនួញ ៥ យ៉ាង តើដូចម្តេច គឺការជួញគ្រឿងសស្ត្រាវុធ ១ ការជួញមនុស្ស ១ ការជួញ ( សត្វដែលគេសម្លាប់យក ) សាច់ ១ ការជួញគ្រឿងស្រវឹង ១ ការជួញថ្នាំពិស ១ ម្នាលភិក្ខុទាំងឡាយ ជំនួញ ៥ ប្រការនេះឯង ឧបាសកមិនគួរធ្វើឡើយ ។

ពាក្យថា មានវិបត្តិដូចម្តេច បានដល់ វិបត្តិនៃសីល និងអាជីវៈរបស់

ឧបាសកនោះឯងឯណា នេះជាវិបត្តិរបស់ឧបាសកនោះ ។ ម្យ៉ាងទៀត ឧបាសកនោះជាមនុស្សចណ្ឌាល និងសៅហ្មងដោយមន្ទិលផ្សេងៗ ដោយវិបត្តិឯណា វិបត្តិនោះក៏គប្បីជ្រាបថា ជាវិបត្តិរបស់ឧបាសកនោះៗ ។ ភាពជាបុគ្គលចណ្ឌាលនោះ កាលពោលដោយអត្ថ ក៏បានដល់ធម៌ ៥ ប្រការ មានភាពជាអ្នកមិនមានសទ្ធាជាដើម ។ ដូចព្រះពុទ្ធតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា ឧបាសកចណ្ឌាលផង ឈ្មោះថា មលឧបាសកផង បដិកិដ្ឋឧបាសកផង ធម៌ ៥ យ៉ាង តើដូចម្តេច គឺឧបាសកជាអ្នកមិនមានសទ្ធា ១ ជាអ្នកទ្រុស្តសីល ១ ប្រកាន់មង្គលភ្ញាក់ផ្អើល ១ ជឿតែមង្គល មិនជឿកម្ម ១ ស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅពុទ្ធសាសនានេះ ហើយធ្វើបុណ្យទីងទក្ខិណេយ្យបុគ្គលនោះ ១ ។

ពាក្យថា មានសម្បត្តិដូចម្តេច បានដល់ ការដល់ព្រមដោយសីល និងការដល់ព្រមដោយអាជីវៈរបស់ឧបាសកនោះ ឈ្មោះថា សម្បត្តិ ។ ម្យ៉ាងទៀត ធម៌ ៥ ប្រការ មានសទ្ធាក្នុងព្រះរតនត្រ័យជាដើមរបស់ឧបាសកទាំងនោះឯណា ធម៌ ៥ ប្រការនោះ ឈ្មោះថា សម្បត្តិ ដូចព្រះសុគតត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា រតនឧបាសកផង ឈ្មោះថា បទុមឧបាសកផង ឈ្មោះថា បុណ្ឌរីកឧបាសកផង ធម៌ ៥ យ៉ាង តើដូចម្តេច គឺឧបាសកជាអ្នកមានសទ្ធា ១ ជាអ្នកមានសីល ១ ជាអ្នកមិនប្រកាន់មង្គលភ្ញាក់ផ្អើល ១ ជឿតែកម្ម មិនជឿមង្គល ១ មិនស្វែងរកទក្ខិណេយ្យខាងបុគ្គលក្រៅពុទ្ធសាសនា ធ្វើបុណ្យតែខាងក្នុងពុទ្ធ-

សាសនានេះ ១ ។

# អត្ថនៃអគ្គសព្ទ

អគ្គ សព្ទ ក្នុងពាក្យថា **អជ្ជតគ្គេ** នេះ រមែងប្រើក្នុងអត្ថថា ខាងដើម ខាងចុង ចំណែក និងប្រសើរបំផុត ។ ឯអគ្គ **សព្ទ** ប្រើក្នុងអត្ថថា

**ខាងដើម** ដូចក្នុងប្រយោគជាដើមថា **អជ្ជតគ្គេ សម្ម ទោវារិក អាវរាមិ ទ្វារំ និគណ្ឋានំ** ម្នាលអ្នករក្សាទ្វារជាសម្លាញ់ ពីថ្ងៃនេះជាដើមរៀងទៅ ខ្ញុំបិទទ្វារចំពោះពួកនិគ្រន្ថ ។

**ខាងចុង** ដូចក្នុងប្រយោគជាដើមថា **តេនេវ អង្គុលគ្គេន តំ អង្គុលគ្គំ បរាមសេយ្យ ឧច្ឆុគ្គំ វេឡគ្គំ** បុគ្គលស្ទាបអង្រ្គែលចុងអំពៅ ចុងឫស្សី ដោយម្រាមដៃនោះឯង ។

**ចំណែក** ដូចក្នុងប្រយោគជាដើមថា **អម្ពិលគ្គំ វា មធុរគ្គំ វា តិត្តកគ្គំ វា អនុជានាមិ ភិក្ខវេ វិហារគ្គេន វា បរិវេណគ្គេន វា ភាជេតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរំលែកអំពីចំណែករបស់ដែលមានរសជូរ ដែលមានរសផ្អែម ឬរបស់ដែលមានរសល្វីង តាមចំណែកវិហារ ឬតាមចំណែកបរិវេណ ។

**ប្រសើរបំផុត** ដូចក្នុងប្រយោគជាដើមថា **យាវតា ភិក្ខវេ សត្តា អបទា វា ។បេ។ តថាគតោ តេសំ អគ្គមក្ខាយតិ** ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលជាសត្វមិនមានជើងក្តី ។បេ។ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរជាងពួកសត្វទាំងនោះ ។

ក្នុងទីនេះ **អគ្គ** សព្ទនេះ គប្បីឃើញថា ចុះក្នុងអគ្គថា ខាងដើម ព្រោះដូច្នោះ ក្នុងបទថា **អជ្ជតគ្គេ** នេះ គប្បីឃើញអត្ថយ៉ាងនេះថា ផ្ដើមតាំងអំពីថ្ងៃនេះជាដើមទៅ ។

បទថា **អជ្ជតំ** បានដល់ **អជ្ជភាវំ** ប្រែថា ការមានក្នុងថ្ងៃនេះ ។ បាលីថា **អជ្ជទគ្គេ** ដូច្នេះក៏មាន ។ **ទ** អក្ខរៈ ជាអាគម ធ្វើកិច្ចភ្ជាប់បទវាង **អជ្ជ** និង **អគ្គេ** ប្រែថា តាំងអំពីថ្ងៃនេះ ។

បទថា **បាណុបេតំ** ប្រែថា ចូលដល់ដោយជីវិត អធិប្បាយថា ព្រះគោតមដ៏ចម្រើន សូមចាំ គឺសូមទ្រង់ជ្រាបខ្ញុំព្រះអង្គ ជាឧបាសក គឺវេយ្យាវច្ចករ ដល់សរណៈដោយត្រៃសរណគមន៍ មិនមានសាស្តាដទៃក្រៅអំពីព្រះគោតម រហូតអស់ជីវិតរបស់ខ្ញុំព្រះអង្គប្រព្រឹត្តទៅ ព្រោះថា ខ្ញុំព្រះអង្គសូម្បីបុគ្គលណាម្នាក់ប្រើកាំបិតដ៏មុតថ្លា កាត់ក្បាលរបស់ខ្ញុំព្រះអង្គចោល ក៏នឹងមិនពោលលាព្រះពុទ្ធថា ព្រះពុទ្ធមិនមែនព្រះពុទ្ធ ព្រះធម៌មិនមែនព្រះធម៌ ព្រះសង្ឃមិនមែនព្រះសង្ឃឡើយ ។ ព្រាហ្មណ៍កាលដល់សរណៈ ដោយការប្រគល់កាយថ្វាយខ្លួនយ៉ាងនេះហើយ បវារណាដោយបច្ច័យ ៤ ក្រោកឡើងអំពីទីអង្គុយនោះ ថ្វាយបង្គំព្រះមានព្រះភាគ ហើយដើរប្រទក្សិណ ៣ ជុំចៀសចេញទៅ ។l៚

**ភយភេរវសូត្រ ចប់**

**សូត្រទី ៤ ចប់**

# សុត្តន្តបិដក

## អនង្គណសូត្រទី ៥

[ ៥៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះសារីបុត្រដ៏មានអាយុ ហៅភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលអាវុសោដ៏មានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលថេរវាចារបស់ព្រះសារីបុត្រដ៏មានអាយុថា ព្រះថេរៈដ៏មានអាយុ ដូច្នេះ ។

[ ៥៤ ] ព្រះសារីបុត្រដ៏មានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ បុគ្គល ៤ ពួកនេះ តែងមាននៅក្នុងលោក ។ បុគ្គល ៤ ពួកតើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ នៅមានអង្គណៈ[១] ក៏មិនដឹងច្បាស់តាមពិតថា អាត្មាអញមានអង្គណៈក្នុងខ្លួន ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកមួយទៀតក្នុងលោកនេះ នៅមានអង្គណៈ តែដឹងច្បាស់តាមពិតថា អាត្មាអញនៅមានអង្គណៈក្នុងខ្លួន ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ មិនមានអង្គណៈ ក៏មិនដឹងច្បាស់តាមពិតថា អាត្មាអញមិនមានអង្គណៈក្នុងខ្លួន ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកមួយទៀតក្នុងលោកនេះ មិនមានអង្គណៈ តែងដឹងច្បាស់តាមពិតថា អាត្មាអញមិនមានអង្គណៈក្នុងខ្លួន ១ ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណា នៅមានអង្គណៈ តែមិនដឹងច្បាស់តាមពិតថា អាត្មាអញមានអង្គណៈក្នុងខ្លួន បណ្តា

---

១- បានដល់ កិលេសដ៏ក្តៅក្រហាយ មានប្រការផ្សេងៗ ។

បុគ្គលដែលមានអង្គណៈទាំង ២ ពួកនេះ បុគ្គលនេះប្រាកដថាជាបុរសថោកទាប ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណានៅមានអង្គណៈ តែដឹងច្បាស់តាមពិតថា អាត្មាអញនៅមានអង្គណៈក្នុងខ្លួន បណ្តាបុគ្គលដែលមានអង្គណៈទាំង ២ ពួកនេះ បុគ្គលនេះប្រាកដថាជាបុរសដ៏ប្រសើរ ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាមិនមានអង្គណៈ តែមិនដឹងច្បាស់តាមពិតថា អាត្មាអញមិនមានអង្គណៈក្នុងខ្លួន បណ្តាបុគ្គលដែលមិនមានអង្គណៈទាំង ២ ពួកនេះ បុគ្គលនេះប្រាកដថាជាបុរសថោកទាប ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាមិនមានអង្គណៈ តែដឹងច្បាស់តាមពិតថា អាត្មាអញមិនមានអង្គណៈក្នុងខ្លួន បណ្តាបុគ្គលដែលមិនមានអង្គណៈទាំង ២ ពួកនេះ បុគ្គលប្រាកដថាជាបុរសដ៏ប្រសើរ ។

[ ៥៥ ] កាលបើព្រះសារីបុត្រមានថេរវាចាយ៉ាងនេះហើយ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏បានពោលពាក្យនេះ នឹងព្រះសារីបុត្រដ៏មានអាយុថា ម្នាលអាវុសោសារីបុត្រ ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាមានបុគ្គលដែលមានអង្គណៈទាំង ២ ពួកនេះ ហើយបុគ្គលម្នាក់ ប្រាកដថាជាបុរសថោកទាប បុគ្គលម្នាក់ទៀតប្រាកដថាជាបុរសប្រសើរវិញ ម្នាលអាវុសោសារីបុត្រ ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាមានបុគ្គលដែលមិនមានអង្គណៈទាំង ២ ពួកនេះ ហើយបុគ្គលម្នាក់ប្រាកដថាជាបុរសថោកទាប បុគ្គលម្នាក់ ( ទៀត ) ប្រាកដថាជាបុរសប្រសើរវិញ ។ ព្រះសារីបុត្រមាន

ថេរវាចាថា ម្នាលអាវុសោ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណានៅមានអង្គណៈ តែមិនដឹងច្បាស់តាមពិតថា អាត្មាអញមានអង្គណៈក្នុងខ្លួន អង្គណៈនេះក៏មានប្រាកដដល់បុគ្គលនោះ បុគ្គលនោះនឹងមិនញ៉ាំងឆន្ទៈឲ្យកើតឡើង មិនសង្វាត មិនប្រារព្ធព្យាយាម ដើម្បីលះបង់នូវអង្គណៈនោះចេញ ។ បុគ្គលនោះមុខជានឹងធ្វើមរណកាលទៅទាំងរាគៈ ទោសៈ មោហៈ អង្គណៈ ទាំងចិត្តដ៏សៅហ្មង ។ ម្នាលអាវុសោ ដូចជាភាជន៍សំរឹទ្ធិ ដែលគេទើបយកមកអំពីផ្សារ ឬអំពីត្រកូលជាងលោហៈ ជាភាជន៍ប្រឡាក់ដោយធូលី និងស្នឹម បុគ្គលជាម្ចាស់ទាំងឡាយ មិនបានប្រើប្រាស់នូវភាជន៍នោះផង មិនបានដុសខាត់ផង ថែមទាំងដាក់ភាជន៍នោះទៅក្នុងផ្លូវធូលី ម្នាលអាវុសោ ក៏កាលបើដូច្នេះ ភាជន៍សំរឹទ្ធិនោះដល់សម័យជាខាងក្រោយមករឹតតែសៅហ្មង មានស្នឹមចាប់ដែរឬ។ ព្រះមហាមោគ្គល្លានក៏ទទួលថា អើអាវុសោ។ ព្រះសារីបុត្រមានថេរវាចាតទៅទៀតថា ម្នាលអាវុសោ បុគ្គលណានៅមានអង្គណៈ មិនដឹងច្បាស់តាមពិតថា អាត្មាអញមានអង្គណៈក្នុងខ្លួន អង្គណៈនេះក៏មានប្រាកដដល់បុគ្គលនោះ បុគ្គលនោះនឹងមិនញ៉ាំងឆន្ទៈឲ្យកើតឡើង មិនសង្វាត មិនប្រារព្ធព្យាយាមដើម្បីលះបង់អង្គណៈនោះចេញ ក៏ដូច្នោះដែរ ។ បុគ្គលនោះ មុខជានឹងធ្វើមរណកាលទៅទាំងរាគៈ ទោសៈ មោហៈ ទាំងអង្គណៈ ទាំងចិត្តដ៏សៅហ្មង ។ ម្នាលអាវុសោ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណានៅមានអង្គណៈ តែដឹងច្បាស់តាមពិតថា អាត្មាអញមានអង្គណៈក្នុងខ្លួន អង្គណៈនេះក៏មានប្រាកដដល់បុគ្គលនោះ តែបុគ្គលនោះ មុខជានឹងញ៉ាំងឆន្ទៈ

ឲ្យកើតឡើង មុខជានឹងសង្វាត ប្រារព្ធព្យាយាម ដើម្បីលះបង់នូវអង្គណៈនោះចេញ ។ បុគ្គលនោះ មុខជាមិនមានរាគៈ ទោសៈ មោហៈ មិនមានអង្គណៈ មិនមានចិត្តសៅហ្មង ហើយធ្វើមរណកាលទៅ ។ ម្នាលអាវុសោ ដូចជាភាជន៍សំរិទ្ធិដែលគេយកមកអំពីផ្សារ ឬអំពីត្រកូលជាងលោហៈ ជាភាជន៍ប្រឡាក់ដោយធូលី និងស្នឹម បុគ្គលជាម្ចាស់ទាំងឡាយ ក៏បានប្រើប្រាស់ភាជនៈនោះផង បានដុសខាត់ផង ថែមទាំងមិនទុកដាក់ភាជន៍នោះ ក្នុងផ្លូវធូលី ម្នាលអាវុសោ ក៏កាលបើដូច្នេះ ភាជន៍សំរិទ្ធិនោះ លុះដល់សម័យជាខាងក្រោយ នឹងបរិសុទ្ធផូរផង់ដែរឬ ។ ព្រះមហាមោគ្គល្លានក៏ទទួលថា អើ អាវុសោ ។ ព្រះសារីបុត្រមានថេរវាចាតទៅទៀតថា ម្នាលអាវុសោ បុគ្គលណានៅមានអង្គណៈ ដឹងច្បាស់តាមពិតថា អាត្មាអញមានអង្គណៈក្នុងខ្លួន អង្គណៈនេះក៏មានប្រាកដដល់បុគ្គលនោះ បុគ្គលនោះមុខជានឹងញ៉ាំងឆន្ទៈឲ្យកើតឡើង មុខជានឹងសង្វាត ប្រារព្ធព្យាយាម ដើម្បីលះបង់អង្គណៈនោះចេញ ក៏ដូច្នោះដែរ ។ បុគ្គលនោះមុខជាមិនមានរាគៈ ទោសៈ មោហៈ មិនមានអង្គណៈ មិនមានចិត្តសៅហ្មង ហើយធ្វើមរណកាលទៅ ។ ម្នាលអាវុសោ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាមិនមានអង្គណៈ មិនដឹងច្បាស់តាមពិតថា អាត្មាអញមិនមានអង្គណៈក្នុងខ្លួន អង្គណៈនេះក៏ត្រឡប់ទៅជាមានប្រាកដដល់បុគ្គលនោះវិញ បុគ្គលនោះមុខជានឹងធ្វើទុកក្នុងចិត្តនូវសុភនិមិត្ត លុះធ្វើទុកក្នុងចិត្តនូវសុភនិមិត្តនោះហើយ រាគៈមុខជានឹងតាមកម្ចាត់ចិត្តមិនខាន ។ បុគ្គលនោះ មុខជានឹងធ្វើមរណកាលទៅទាំងរាគៈ

ទោសៈ មោហៈ ទាំងអង្គណៈ ទាំងចិត្តដ៏សៅហ្មង ។ ម្នាលអាវុសោ ដូចជាកាជន៍សំរឹទ្ធិដែលគេនាំយកមកអំពីផ្សារ ឬអំពីត្រកូលជាងលោហៈ ជាកាជន៍ដ៏បរិសុទ្ធផូរផង់ តែបុគ្គលជាម្ចាស់ទាំងឡាយ មិនបានប្រើប្រាស់កាជន៍នោះផង មិនបានដុសខាត់ផង ថែមទាំងទុកកាជន៍នោះ ក្នុងផ្លូវធូលីទៀត ម្នាលអាវុសោ ក៏កាលបើដូច្នេះ កាជន៍សំរឹទ្ធិនោះ លុះដល់សម័យខាងក្រោយ ទៅជាសៅហ្មង មានស្នឹមចាប់ដែរឬ ។ ព្រះមហាមោគ្គល្លាន ក៏ទទួលថា អើ អាវុសោ ។ ព្រះសារីបុត្រមានថេរវាចាតទៅទៀតថា ម្នាលអាវុសោ បុគ្គលណាមិនមានអង្គណៈ មិនដឹងច្បាស់ តាមពិតថា អាត្មាអញមិនមានអង្គណៈក្នុងខ្លួន អង្គណៈនេះក៏ត្រឡប់ទៅជាមានប្រាកដ ដល់បុគ្គលនោះវិញ បុគ្គលនោះមុខជានឹងធ្វើទុកក្នុងចិត្តនូវសុភនិមិត្ត លុះធ្វើទុកក្នុងចិត្តនូវសុភនិមិត្តនោះហើយ រាគៈមុខជានឹងតាមកម្ចាត់ចិត្តមិនខាន ។ បុគ្គលនោះ មុខជានឹងធ្វើមរណកាលទៅទាំងរាគៈ ទោសៈ មោហៈ ទាំងអង្គណៈ ទាំងចិត្តសៅហ្មងក៏យ៉ាងនោះឯង ។ ម្នាលអាវុសោ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាមិនមានអង្គណៈ តែដឹងច្បាស់តាមពិតថា អាត្មាអញមិនមានអង្គណៈក្នុងខ្លួន អង្គណៈនេះក៏ត្រឡប់ទៅជាមានប្រាកដ ដល់បុគ្គលនោះវិញ បុគ្គលនោះមុខជានឹងធ្វើទុកក្នុងចិត្តនូវសុភនិមិត្ត លុះធ្វើទុកក្នុងចិត្តនូវសុភនិមិត្តនោះហើយ រាគៈមុខជានឹងមិនតាមកម្ចាត់ចិត្តបានឡើយ ។ បុគ្គលនោះ មុខជាមិនមានរាគៈ ទោសៈ មោហៈ មិនមានអង្គណៈ មានចិត្តមិនសៅហ្មងហើយធ្វើនូវមរណកាលទៅ ។ ម្នាលអាវុសោ ដូចកាជន៍សំរឹទ្ធិ ដែលគេនាំ

យកមកអំពីផ្សារ ឬអំពីត្រកូលជាងលោហៈ ជាភាជន៍ដ៏បរិសុទ្ធផូរផង់ បុគ្គលជាម្ចាស់ទាំងឡាយ បានប្រើប្រាស់នូវភាជន៍នោះផង បានដុសខាត់ផង ថែមទាំងមិនទុកភាជន៍ក្នុងផ្លូវធូលីផង ម្នាលអាវុសោ ក៏កាលបើដូច្នេះ ភាជន៍សំរិទ្ធិនោះ លុះសម័យខាងក្រោយមក ទៅជាភាជន៍ដ៏បរិសុទ្ធ ផូរផង់ក្រៃលែងដែរឬ ។ ព្រះមាហាមោគ្គល្លានក៏ទទួលថា អើ អាវុសោ ។ ព្រះសារីបុត្រមានថេរវាចាតទៅទៀតថា ម្នាលអាវុសោ បុគ្គលណា មិនមានអង្គណៈ ដឹងច្បាស់តាមពិតថា អាត្មាអញមិនមានអង្គណៈក្នុងខ្លួន អង្គណៈនេះក៏មានប្រាកដដល់បុគ្គលនោះ មុខជាបុគ្គលនោះ មិនបានធ្វើទុកក្នុងចិត្តចំពោះសុភនិមិត្ត លុះមិនធ្វើទុកក្នុងចិត្ត នូវសុភនិមិត្តនោះហើយ រាគៈមុខជានឹងមិនតាមកម្ចាត់ចិត្ត ក៏ដូច្នោះដែរ ។ បុគ្គលនោះ មុខជាមិនមានរាគៈទោសៈ មោហៈ មិនមានអង្គណៈ មិនមានចិត្តសៅហ្មង ធ្វើមរណកាលទៅ ។ ម្នាលអាវុសោ មោគ្គល្លាន ហេតុបច្ច័យនេះឯង ដែលនាំឲ្យមានបុគ្គលមានអង្គណៈទាំង ២ ពួកនេះ ហើយបុគ្គលពួកមួយ ប្រាកដថាជាបុរសថោកទាប បុគ្គលពួកមួយទៀត ប្រាកដថាជាបុរសប្រសើរ ម្នាលអាវុសោមោគ្គល្លាន ហេតុបច្ច័យនេះឯង ដែលនាំឲ្យមានបុគ្គល ដែលមិនមានអង្គណៈទាំងពីរពួកនេះ ហើយបុគ្គលពួកមួយ ប្រាកដថាជាបុរសថោកទាប បុគ្គលពួកមួយទៀត ប្រាកដថាជាបុរសប្រសើរ ។

[ ៥៦ ] ព្រះមហាមោគ្គល្លានដ៏មានអាយុសួរថា ម្នាលអាវុសោ ពាក្យដែលលោកហៅថា អង្គណៈ អង្គណៈ ដូច្នេះ ម្នាលអាវុសោ ចុះពាក្យថា

អង្គណៈនេះ ជាឈ្មោះនៃវត្ថុអ្វី ។ ព្រះសារីបុត្រឆ្លើយថា ម្នាលអាវុសោ ពាក្យថា អង្គណៈនេះ ជាឈ្មោះនៃអកុសលដ៏លាមក ដែលគ្របសង្កត់ចិត្ត ដោយអំណាចនៃសេចក្តីប្រាថ្នា ។

[ ៥៧ ] ម្នាលអាវុសោ ហេតុនេះតែមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើងដល់ភិក្ខុពួកខ្លះក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ អាត្មាអញត្រូវអាបត្តិមែនហើយ តែពួកភិក្ខុមិនដឹងថា អាត្មាអញត្រូវអាបត្តិទេ ។ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ពាក្យថា ពួកភិក្ខុដឹងភិក្ខុនោះថា ជាអ្នកត្រូវអាបត្តិហើយ ។ ភិក្ខុនោះ ក៏ខឹងមិនត្រេកអរ ដោយហេតុដូច្នេះថា ពួកភិក្ខុដឹងថា អាត្មាអញជាអ្នកត្រូវអាបត្តិហើយ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំង ២ នេះឯង ឈ្មោះថា អង្គណៈដែរ ។

[ ៥៨ ] ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើងដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញត្រូវអាបត្តិមែនហើយ ពួកភិក្ខុចោទអាត្មាអញ ក្នុងទីស្ងាត់ចុះ សូមកុំចោទក្នុងកណ្តាលជំនុំសង្ឃឡើយ ។ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដត្រង់ពាក្យថា ពួកភិក្ខុចោទភិក្ខុនោះក្នុងកណ្តាលជំនុំសង្ឃ មិនចោទក្នុងទីស្ងាត់ ។ ភិក្ខុនោះ ខឹងមិនត្រេកអរដោយហេតុដូច្នេះថា ពួកភិក្ខុចោទអាត្មាអញ ក្នុងកណ្តាលជំនុំសង្ឃ មិនបានចោទក្នុងទីស្ងាត់ ។ ម្នាលអាវុសោ សេចក្តីខឹងឯណាក្តី សេចក្តីមិនត្រេកអរឯណាក្តី ទាំងពីរនេះឯង ឈ្មោះថា

អន្តរណៈដែរ ។

[ ៥៩ ] ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះ យ៉ាងនេះថា អាត្មាអញត្រូវអាបត្តិមែនហើយ បុគ្គលស្មើគ្នាគួរចោទអាត្មាអញ បុគ្គលមិនស្មើគ្នា មិនគួរចោទអាត្មាអញទេ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា បុគ្គលមិនស្មើគ្នា ចោទភិក្ខុនោះ បុគ្គលស្មើគ្នា មិនចោទភិក្ខុនោះឡើយ ។ ភិក្ខុនោះខឹងមិនត្រេកអរ ដោយហេតុដូច្នេះថា បុគ្គលមិនស្មើគ្នាចោទអាត្មាអញ បុគ្គលស្មើគ្នាមិនចោទអាត្មាអញឡើយ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯងឈ្មោះថាអង្គណៈដែរ ។

[ ៦០ ] ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើងដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ ព្រះសាស្តាគប្បីសួរអាត្មាអញរឿយៗ ហើយទើបសំដែងធម៌ដល់ពួកភិក្ខុ ព្រះសាស្តា កុំគប្បីសួរភិក្ខុឯទៀតរឿយៗ ហើយសំដែងធម៌ដល់ពួកភិក្ខុឡើយ ។ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា ព្រះសាស្តាសួរភិក្ខុឯទៀតរឿយៗ ហើយសំដែងធម៌ដល់ពួកភិក្ខុ ព្រះសាស្តាមិនសួរភិក្ខុនោះរឿយៗ ហើយសំដែងធម៌ដល់ពួកភិក្ខុឡើយ ។ ភិក្ខុនោះខឹងមិនត្រេកអរ ដោយហេតុដូច្នេះថា ព្រះសាស្តាសួរតែភិក្ខុឯទៀតរឿយៗ ហើយសំដែងធម៌ដល់ពួកភិក្ខុ ព្រះសាស្តាមិនសួរអាត្មាអញរឿយៗ ហើយសំដែងធម៌ដល់ពួកភិក្ខុ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំង

ពីរនេះឯង ឈ្មោះថាអង្គណៈដែរ ។

[ ៦១ ] ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើងដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះយ៉ាងនេះថា ធ្វើម្តេចហ្ន៎ ពួកភិក្ខុគប្បីចោមរោមអាត្មាអញ ចូលទៅកាន់ស្រុក ដើម្បីភត្ត ពួកភិក្ខុកុំគប្បីចោមរោមភិក្ខុឯទៀត ចូលទៅកាន់ស្រុក ដើម្បីភត្តឡើយ ។ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា ពួកភិក្ខុគប្បីចោមរោមភិក្ខុឯទៀតរឿយៗ ចូលទៅកាន់ស្រុក ដើម្បីភត្ត ពួកភិក្ខុមិនគប្បីចោមរោមភិក្ខុនោះរឿយៗ ចូលទៅកាន់ស្រុក ដើម្បីភត្ត ។ ភិក្ខុនោះខឹងមិនត្រេកអរដោយហេតុដូច្នេះថា ពួកភិក្ខុចោមរោមភិក្ខុឯទៀតរឿយៗ ចូលទៅកាន់ស្រុក ដើម្បីភត្ត ពួកភិក្ខុមិនចោមរោមអាត្មាអញរឿយៗ ចូលទៅកាន់ស្រុក ដើម្បីភត្ត ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។

[ ៦២ ] ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎អាត្មាអញគប្បីបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ចង្ហាន់បិណ្ឌបាតដ៏ប្រសើរក្នុងរោងភត្ត ភិក្ខុឯទៀតកុំគប្បីបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ចង្ហាន់បិណ្ឌបាតដ៏ប្រសើរក្នុងរោងភត្តឡើយ ។ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា ភិក្ខុឯទៀត គប្បីបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ចង្ហាន់បិណ្ឌបាតដ៏ប្រសើរក្នុងរោងភត្ត ភិក្ខុនោះមិនគប្បីបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ

ចង្ហាន់បិណ្ឌបាតដ៏ប្រសើរក្នុងរោងភត្ត ។ ភិក្ខុនោះខឹងមិនត្រេកអរដោយហេតុដូច្នេះថា ភិក្ខុឯទៀត បានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ចង្ហាន់បិណ្ឌបាតដ៏ប្រសើរ ក្នុងរោងភត្ត អាត្មាអញមិនបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ចង្ហាន់បិណ្ឌបាតដ៏ប្រសើរ ក្នុងរោងភត្តឡើយ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។

[ ៦៣ ] ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើងដល់ភិក្ខុពួកខ្លះក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ អាត្មាអញឆាន់ហើយបានអនុមោទនាក្នុងរោងភត្ត ភិក្ខុឯទៀតឆាន់ហើយ មិនគប្បីអនុ-មោទនាក្នុងរោងភត្តឡើយ ។ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដត្រង់ថា ភិក្ខុឯទៀតឆាន់ហើយ គប្បីអនុមោទនាក្នុងរោងភត្ត ភិក្ខុនោះឆាន់ហើយមិនគប្បីបានអនុមោទនាក្នុងរោងភត្តឡើយ ។ ភិក្ខុនោះខឹងមិនត្រេកអរដោយហេតុដូច្នេះថា ភិក្ខុឯទៀតឆាន់ហើយបានអនុមោទនាក្នុងរោងភត្ត អាត្មាអញឆាន់ហើយ មិនបានអនុមោទនា ក្នុងរោងភត្តឡើយ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។

[ ៦៤ ] ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើងដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញគប្បីសម្តែងធម៌ ដល់ពួកភិក្ខុដែលឋិតនៅក្នុងអារាម ភិក្ខុឯទៀត មិនគប្បី

សម្តែងធម៌ ដល់ពួកភិក្ខុដែលឋិតនៅក្នុងអារាមឡើយ ។ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា ភិក្ខុឯទៀតសម្តែងធម៌ដល់ពួកភិក្ខុដែលឋិតនៅក្នុងអារាម ភិក្ខុនោះមិនគប្បីសម្តែងធម៌ ដល់ពួកភិក្ខុដែលឋិតនៅក្នុងអារាមឡើយ ។ ភិក្ខុនោះខឹង មិនត្រេកអរ ដោយហេតុថា ភិក្ខុឯទៀត បានសម្តែងធម៌ដល់ពួកភិក្ខុដែលឋិតនៅក្នុងអារាម អាត្មាអញមិនបានសម្តែងធម៌ ដល់ពួកភិក្ខុដែលឋិតនៅក្នុងអារាម ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។

[ ៦៥ ] ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ អាត្មាអញគប្បីសម្តែងធម៌ដល់ពួកភិក្ខុនីដែលឋិតនៅក្នុងអារាម ។បេ។ គប្បីសម្តែងធម៌ដល់ពួកឧបាសក ។បេ។ គប្បីសម្តែងធម៌ដល់ពួកឧបាសិកា ភិក្ខុឯទៀតមិនគប្បីសម្តែងធម៌ដល់ពួកឧបាសិកាដែលមកកាន់អារាម ។ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា ភិក្ខុឯទៀត គប្បីសម្តែងធម៌ដល់ពួកឧបាសិកាដែលមកកាន់អារាម ភិក្ខុនោះមិនគប្បីបានសម្តែងធម៌ ដល់ពួកឧបាសិកាដែលមកកាន់អារាម ។ ភិក្ខុនោះខឹងមិនត្រេកអរ ដោយហេតុដូច្នេះថា ភិក្ខុឯទៀតបានសម្តែងធម៌ដល់ពួកឧបាសិកាដែលមកកាន់អារាម អាត្មាអញមិនបានសម្តែងធម៌ ដល់ពួកឧបាសិកាដែលមកកាន់អារាម ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។

[ ៦៦ ] ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ ពួកភិក្ខុគប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាអាត្មាអញ ពួកភិក្ខុមិនគប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុឯទៀតឡើយ ។ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា ពួកភិក្ខុគប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុឯទៀត ពួកភិក្ខុមិនគប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុនោះឡើយ ។ ភិក្ខុនោះខឹងមិនត្រេកអរដោយហេតុដូច្នេះថា ពួកភិក្ខុធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុឯទៀតពួកភិក្ខុមិនធ្វើសក្ការៈ គោរព រាប់អាន បូជាអាត្មាអញ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯងឈ្មោះថា អង្គណៈដែរ ។

[ ៦៧ ] ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ ពួកភិក្ខុនី ។បេ។ ពួកឧបាសក ។បេ។ ពួកឧបាសិកា គប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាអាត្មាអញ ពួកឧបាសិកាមិនគប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុឯទៀតហើយ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា ពួកឧបាសិកាគប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុឯទៀត ពួកឧបាសិកាមិនគប្បីធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុនោះ ។ ភិក្ខុនោះ ខឹងមិនត្រេកអរដោយហេតុដូច្នេះថា ពួកឧបាសិកាធ្វើសក្ការៈ គោរព រាប់អាន បូជាតែភិក្ខុឯទៀត ពួកឧបាសិកាមិនធ្វើសក្ការៈ គោរព រាប់អាន បូជាអាត្មាអញ

ឡើយ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈ ។

[ ៦៨ ] ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ អាត្មាអញគប្បីបានចីវរដ៏ប្រសើរ ភិក្ខុឯទៀត កុំគប្បីបានចីវរដ៏ប្រសើរឡើយ ។ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា ភិក្ខុឯទៀតគប្បីបានចីវរដ៏ប្រសើរ ភិក្ខុនោះមិនគប្បីបានចីវរដ៏ប្រសើរ ។ ភិក្ខុនោះខឹងមិនត្រេកអរ ដោយហេតុដូច្នេះថា ភិក្ខុឯទៀតបានចីវរដ៏ប្រសើរ អាត្មាអញមិនបានចីវរដ៏ប្រសើរ ។ ម្នាលអាវុសោ សេចក្តីខឹងណាក្តី សេចក្តីមិនត្រេកអរណាក្តី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។

[ ៦៩ ] ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា សេចក្តីប្រាថ្នាកើតឡើង ដល់ភិក្ខុពួកខ្លះ ក្នុងសាសនានេះ យ៉ាងនេះថា ឱហ្ន៎ អាត្មាអញគប្បីបានចង្ហាន់បិណ្ឌបាតដ៏ប្រសើរ ។បេ។ សេនាសនៈដ៏ប្រសើរ ។បេ។ គិលានប្បច្ចយភេសជ្ជបរិក្ខារដ៏ប្រសើរ ភិក្ខុឯទៀត កុំគប្បីបាននូវគិលានប្បច្ចយភេសជ្ជបរិក្ខារដ៏ប្រសើរឡើយ ។ ម្នាលអាវុសោ ហេតុនេះតែងមានជាប្រាកដ ត្រង់ថា ភិក្ខុឯទៀតគប្បីបាននូវគិលានប្បច្ចយភេសជ្ជបរិក្ខារដ៏ប្រសើរ ភិក្ខុនោះ មិនគប្បីបាននូវគិលានប្បច្ចយភេសជ្ជបរិក្ខារដ៏ប្រសើរឡើយ ។ ភិក្ខុនោះខឹងមិនត្រេកអរ ដោយហេតុដូច្នេះថា ភិក្ខុឯទៀត បាននូវគិលានប្បច្ចយភេសជ្ជបរិក្ខារដ៏ប្រសើរ អាត្មាអញ មិនបាននូវគិលានប្បច្ចយភេសជ្ជ-

បរិក្ខារដ៏ប្រសើរឡើយ ។ ម្នាលអាវុសោ សេចក្ដីខឹងណាក្ដី សេចក្ដីមិនត្រេកអរណាក្ដី ទាំងពីរនេះឯង ឈ្មោះថា អង្គណៈដែរ ។ ម្នាលអាវុសោ ពាក្យថា អង្គណៈនេះ ជាឈ្មោះ អកុសលដ៏លាមក ដែលគ្របសង្កត់ចិត្ត ដោយអំណាចដោយសេចក្ដីប្រាថ្នានេះឯង ។

[ ៧០ ] ម្នាលអាវុសោ អកុសលដ៏លាមក ដែលគ្របសង្កត់ចិត្តដោយអំណាចសេចក្ដីប្រាថ្នាទាំងនេះ ភិក្ខុណានីមួយ មិនលះបង់ចោលហើយ អ្នកផងឃើញច្បាស់ផង ឮច្បាស់ផង ។ បើទុកជាភិក្ខុនោះប្រព្រឹត្តអារញ្ញិកធុតង្គ មានសេនាសនៈស្ងាត់ ប្រព្រឹត្តបិណ្ឌបាតិកធុតង្គ សបទានចារិកធុតង្គ បង្សុកូលិកធុតង្គ ទ្រទ្រង់ចីវរសៅហ្មង ក៏គង់តែពួកសព្រហ្មចារីមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាភិក្ខុនោះឡើយ ។ ដំណើរនេះ ព្រោះហេតុអ្វី ។ ព្រោះថា អកុសលដ៏លាមកដែលគ្របសង្កត់ចិត្ត ដោយអំណាចសេចក្ដីប្រាថ្នាទាំងនោះ លោកមានអាយុនោះ មិនលះបង់ចោល អ្នកផងឃើញច្បាស់ផង ឮច្បាស់ផង ។ ម្នាលអាវុសោ ដូចជាភាជន៍សំរឹទ្ធិ ដែលគេយកមកអំពីផ្សារ ឬអំពីត្រកូលជាងលោហៈ ជាភាជន៍បរិសុទ្ធផូរផង់ ។ បុគ្គលជាម្ចាស់ទាំងឡាយ យកសាកសពពស់ ឬសាកសពឆ្កែ ឬសាកសពមនុស្សដាក់ពេញក្នុងភាជន៍នោះ ហើយគ្របដោយភាជន៍សំរឹទ្ធិដទៃ ហើយដើរទៅក្នុងចន្លោះផ្សារ ។ អ្នកផងឃើញភាជន៍នោះហើយ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ភាជន៍នេះហាក់ដូចជាទីពេញចិត្តក្រៃលែង អ្នកឯងនាំទៅធ្វើអ្វីអេះ ។ លុះអ្នកផងក្រោកឡើងហើយ បើកភាជន៍នោះមើល សេចក្ដីមិនគាប់ចិត្តក្ដី

សេចក្តីខ្ពើមរអើមក្តី សេចក្តីធុញទ្រាន់ក្តីក៏តាំងឡើងប្រាកដដល់គេ ក្នុងខណៈដែលបានឃើញ សូម្បីបុគ្គលដែលស្រេកឃ្លានហើយ ក៏មិនគួរប្រាថ្នានឹងបរិភោគឡើយ នឹងបាច់និយាយថ្វីដល់ពួកជន ដែលបរិភោគឆ្អែតហើយ ម្នាលអាវុសោ អកុសលដ៏លាមកដែលគ្របសង្កត់ចិត្ត ដោយអំណាចសេចក្តីប្រាថ្នាយ៉ាងនេះ ដែលភិក្ខុណានីមួយ មិនទាន់លះបោលហើយ អ្នកផងឃើញច្បាស់ផង ឮច្បាស់ផងក៏យ៉ាងនោះឯង ។ បើទុកជាភិក្ខុនោះ ប្រព្រឹត្តអារញ្ញិកធុតង្គ មានសេនសនៈស្ងាត់ ប្រព្រឹត្តបិណ្ឌបាតិកធុតង្គ សបទានចារិកធុតង្គ បង្សុកូលិកធុតង្គ ទ្រទ្រង់ចីវរសៅហ្មង ក៏គង់តែពួកសព្រហ្មចារី មិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាភិក្ខុនោះឡើយ ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះថា អកុសលដ៏លាមក ដែលគ្របសង្កត់ចិត្ត ដោយអំណាចសេចក្តីប្រាថ្នានោះ លោកដ៏មានអាយុនោះ មិនទាន់លះបោល អ្នកផងឃើញច្បាស់ផង ឮច្បាស់ផង ។

[ ៧១ ] ម្នាលអាវុសោ អកុសលដ៏លាមក ដែលគ្របសង្កត់ចិត្តដោយអំណាចនៃសេចក្តីប្រាថ្នាទាំងនេះ ដែលភិក្ខុណានីមួយ លះបោលហើយ អ្នកផងឃើញច្បាស់ផង ឮច្បាស់ផង ។ បើទុកជាភិក្ខុនោះ ជាអ្នកនៅក្នុងស្រុកត្រេកអរនឹងការនិមន្ត ទ្រទ្រង់នូវគហបតិចីវរ ក៏គង់តែពួកសព្រហ្មចារី តែងធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុនោះ ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះថា អកុសលដ៏លាមកដែលគ្របសង្កត់ចិត្ត ដោយអំណាចសេចក្តីប្រាថ្នាទាំងនោះ លោកមានអាយុនោះលះបោលហើយ អ្នកផងឃើញច្បាស់ផង ឮ

ច្បាស់ផង ។ ម្នាលអាវុសោ ដូចជាភាជន៍សំរឹទ្ធិ ដែលគេយកមកអំពីផ្សារ ឬអំពីត្រកូលជាងលោហៈ ជាភាជន៍បរិសុទ្ធផូរផង់ ។ បុគ្គលជាម្ចាស់ទាំងឡាយ យកបាយស្រូវសាលីដែលប្រាសចាកពណ៌ខ្មៅ មានសម្ល និងម្ហូបគ្រៀមច្រើនមុខដាក់ពេញក្នុងភាជន៍នោះ ហើយគ្របដោយភាជន៍សំរឹទ្ធិដទៃ ហើយដើរទៅក្នុងចន្លោះផ្សារ ។ ជនឃើញភាជន៍នោះហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ភាជន៍នេះហាក់ដូចជាទីពេញចិត្តក្រៃលែង អ្នកឯងនាំទៅធ្វើអ្វីអេះ ។ លុះជននោះស្ទុះទៅបើកភាជន៍នោះមើល សេចក្តីគាប់ចិត្ត ក្តី សេចក្តីមិនខ្ពើមអើមក្តី សេចក្តីមិនធុញទ្រាន់ក្តី ក៏តាំងឡើងប្រាកដដល់ជននោះ ក្នុងខណៈដែលបានឃើញ សូម្បីតែពួកជនដែលបរិភោគឆ្អែតហើយ ក៏គួរចង់បរិភោគទៀត នឹងបាច់និយាយទៅថ្វី ដល់ពួកជនដែលស្រេកឃ្លាននោះ ម្នាលអាវុសោ អកុសលដ៏លាមកដែលគ្របសង្កត់ចិត្ត ដោយអំណាចនៃសេចក្តីប្រាថ្នាទាំងនេះ ដែលភិក្ខុណានីមួយលះចោលហើយ អ្នកផងឃើញច្បាស់ផង ឮច្បាស់ផង ក៏យ៉ាងនោះឯង ។ បើទុកជាភិក្ខុនោះ ជាអ្នកនៅក្នុងស្រុក ត្រេកអរនឹងការនិមន្ត ទ្រទ្រង់នូវគហបតិចីវរ ក៏គង់តែពួកសព្រហ្មចារី តែងធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុនោះ ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះថា អកុសលដ៏លាមក ដែលគ្របសង្កត់ចិត្ត ដោយអំណាចសេចក្តីប្រាថ្នាទាំងនោះ លោកមានអាយុនោះលះចោលហើយ អ្នកផងឃើញច្បាស់ផង ឮច្បាស់ផង ។

[៧២] កាលបើព្រះសារីបុត្រ មានថេរវាចាយ៉ាងនេះហើយ ព្រះមហា-

មោគ្គល្លានមានអាយុ ក៏បាននិយាយពាក្យនេះទៅនឹងព្រះសារីបុត្រមានអាយុថា ម្នាលអាវុសោសារីបុត្រ ខ្ញុំសូមទាញយកពាក្យឧបមាមកសំដែងឥឡូវនេះ ។ ព្រះសារីបុត្រតបថា ម្នាលអាវុសោមោគ្គល្លាន ចូរលោកទាញយកពាក្យឧបមាមកសំដែងចុះ ។ ព្រះមហាមោគ្គល្លានមានអាយុ មានថេរវាចាតទៅថា ម្នាលអាវុសោ សម័យមួយ ខ្ញុំនៅក្នុងក្រុងរាជគ្រឹះ ដែលមានភ្នំព័ទ្ធជុំវិញដូចក្រោល ។ ម្នាលអាវុសោ កាលនោះ ខ្ញុំស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរ ចូលទៅក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាតក្នុងបុព្វណ្ហសម័យ ។ សម័យនោះឯង សមីតិមាណព ជាកូនជាងរថ កំពុងចាំងខ្នងកង់រថ ។ ទើបអាជីវក ( ម្នាក់ ) ឈ្មោះបណ្ឌុបុត្រ ជាកូនជាងរថជាន់ចាស់ ចូលមកឈរជិតសមីតិមាណពនោះដែរ ។ ម្នាលអាវុសោ លំដាប់នោះ អាជីវកឈ្មោះបណ្ឌុបុត្រ ជាកូនជាងរថជាន់ចាស់ មានសេចក្ដីត្រិះរិះក្នុងចិត្តកើតឡើងយ៉ាងនេះថា ឱហ្ន៎ សមីតិមាណព ជាកូនជាងរថនេះ ចាំងឈើកោងនេះផង ឈើវៀចនេះផង ឈើប្រកបដោយទោសនេះផង ដើម្បីធ្វើខ្នងកង់នេះ ខ្នងកង់នេះឯង ត្រឡប់ទៅជាខ្នងកង់មិនកោង មិនវៀច មិនប្រកបដោយទោស ជាខ្នងកង់ដ៏បរិសុទ្ធ នៅតែខ្លឹមសុទ្ធ ។ ម្នាលអាវុសោ អាជីវកឈ្មោះបណ្ឌុបុត្រ ជាកូនជាងរថជាន់ចាស់ មានសេចក្ដីត្រិះរិះក្នុងចិត្តយ៉ាងណាៗ ក៏សមីតិ-មាណពជាកូនជាងរថ ចាំងឈើកោងនោះផង ឈើវៀចនោះផង ឈើប្រកបដោយទោសនោះផង ដើម្បីធ្វើខ្នងកង់រថនោះ យ៉ាងនោះៗ ដែរ ។ ម្នាលអាវុសោ លំដាប់នោះ អាជីវក ឈ្មោះបណ្ឌុបុត្រ ជាកូនជាងរថជាន់ចាស់

មានចិត្តរីករាយ ហើយបញ្ចេញវាចាគួរជាទីរីករាយថា សមីតិមាណពនេះ ហាក់ជាដឹងចិត្តដោយចិត្ត ហើយទើបចាំង ( នូវឈើ ) ។ ម្នាលអាវុសោ ពួកបុគ្គលណាដែលមិនមានសទ្ធា ត្រូវការតែនឹងចិញ្ចឹមជីវិត ចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួស ដោយមិនមានសទ្ធា ជាអ្នកអួតអាង ជាអ្នកមានមាយា ជាអ្នកបោកប្រាស ជាអ្នកមានចិត្តរាយមាយ លើកកម្ពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានសម្ដីផ្ដេសផ្ដាស មិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន មិនប្រកបក្នុងការភ្ញាក់រឭក មិនបានក្រឡេកមើល ក្នុងធម៌របស់សមណៈ ( ផ្នួស ) មិនមានសេចក្ដីគោរពដ៏ក្លៀវក្លា ក្នុងសិក្ខា ជាអ្នកល្មោភ មានសេចក្ដីព្យាយាមធូរថយ ជាប្រធានខាងការប្រព្រឹត្តជ្រោកជ្រាក ដាក់ចោលនូវធុរៈក្នុងវិវេក ខ្ជិលច្រអូស មានព្យាយាមថោកថយ មានសតិភ្លេចភ្លាំង មិនមានសម្បជញ្ញៈ មិនបានតាំងចិត្តមាំ មានចិត្តវិលទៅរកខុស ជាមនុស្សអាប់ឥតប្រាជ្ញា ជាមនុស្សខ្លៅ ព្រះសារីបុត្រដ៏មានអាយុ ហាក់ដូចជាដឹងចិត្តរបស់ជនទាំងឡាយនោះ ដោយចិត្ត ហើយ ទើបទូន្មានតាមធម្មបរិយាយនេះឯង ។ ចំណែកខាងពួកកុលបុត្រណាមានសទ្ធាចេញចាកផ្ទះ ចូលទៅកាន់ផ្នួសមិនមែនជាអ្នកអួតអាង មិនមានមាយា មិនមែនជាអ្នកបោកប្រាស់ មិនមានចិត្តរាយមាយ មិនលើកកម្ពស់ មិនមានចិត្តឃ្លេងឃ្លោង មិនមានមាត់រឹង មិនមានសម្ដីផ្ដេសផ្ដាស គ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន ប្រកបរឿយៗ ក្នុងការភ្ញាក់រឭក មានការក្រឡេកមើលក្នុងសមណធម៌ មានសេចក្ដីគោរព

កៀវក្លាក្នុងសិក្ខា មិនល្មោភ មិនប្រព្រឹត្តធូរ ដាក់ធុរៈចោលក្នុងការប្រព្រឹត្ត ជ្រោកជ្រាក ជាប្រធានក្នុងវិវេកធម៌ មានព្យាយាមតឹង មានចិត្តបញ្ជូនទៅកាន់ ( ព្រះនិព្វាន ) មានសតិខ្ជាប់ខ្ជួន មានសម្បជញ្ញៈ មានសមាធិ មានចិត្ត នឹងនៅក្នុងអារម្មណ៍តែមួយ មានប្រាជ្ញាមិនមែនជាមនុស្សខ្លៅ លុះកុលបុត្រ ទាំងនោះ បានស្តាប់ធម្មបរិយាយនេះ របស់ព្រះសារីបុត្រដ៏មានអាយុហើយ ក៏ហាក់ដូចបានក្រេបផឹក បានលេបដោយពាក្យសម្តីនឹងចិត្តដូច្នេះថា ឱហ្ន៎ ព្រះ សារីបុត្រជាសព្រហ្មចារីបុគ្គល រមែង ( ញុំាងពួកយើង ) ឲ្យឃ្លាតចាក អកុសល ហើយឲ្យតាំងនៅក្នុងកុសលដោយប្រពៃបាន ។ ម្នាលអាវុសោ ដូចជាស្រី ឬប្រុស ជំទង់ ឬកំលោះ កំពុងចូលចិត្តនឹងការប្រដាប់កាយ កក់ សិសៈរួចហើយ បាននូវកម្រងផ្កាឧប្បល ឬកម្រងផ្កាម្លិះ និងកម្រងផ្កាវិជ្ជុល ក៏ទទួលយកដោយដៃទាំងពីរ ហើយតម្កល់លើសិរសាជាអវយវៈដ៏ខ្ពង់ខ្ពស់ ម្នាលអាវុសោ ពួកកុលបុត្រណាមានសទ្ធា ចេញចាកផ្ទះចូលទៅកាន់ផ្នួស មិនមែនជាអ្នកអួតអាង មិនមានមាយា មិនមែនជាអ្នកបោកប្រាស មិនមាន ចិត្តរាយមាយ មិនលើកកម្ពស់ មិនមានចិត្តឃ្លេងឃ្លោង មិនមានមាត់រឹង មិនមានសម្តីផ្តេសផ្តាស គ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុង ភោជន ប្រកបរឿយៗ ក្នុងការភ្ញាក់រឭក មានការក្រឡេកមើលក្នុងសមណធម៌ មានសេចក្តីគោរពកៀវក្លាក្នុងសិក្ខា ជាអ្នកមិនល្មោភ មិនប្រព្រឹត្តធូរ ជាអ្នក ដាក់ធុរៈចោលក្នុងការប្រព្រឹត្តជ្រោកជ្រាក ជាប្រធានក្នុងវិវេកធម៌ មានព្យា- យាមតឹង មានចិត្តបញ្ជូនទៅកាន់ ( ព្រះនិព្វាន ) មានសតិខ្ជាប់ខ្ជួន មាន

សម្បជញ្ញៈ មានសមាធិ មានចិត្តនឹងនៅក្នុងអារម្មណ៍តែមួយ ជាអ្នកមានប្រាជ្ញា មិនមែនជាមនុស្សខ្លៅ កុលបុត្រទាំងនោះ បានស្តាប់ធម្មបរិយាយនេះរបស់ព្រះសារីបុត្រដ៏មានអាយុហើយ ក៏ហាក់ដូចជាបានក្រេបផឹក បានលេបដោយពាក្យសម្តីនឹងចិត្តដូច្នេះថា ឱហ្ន៎ ព្រះសារីបុត្រ ជាសព្រហ្មចារីបុគ្គលរមែង ( ញ៉ាំងពួកយើង ) ឲ្យឃ្លាតចាកអកុសល ហើយឲ្យតម្កល់នៅក្នុងកុសលដោយប្រពៃ ដូចសេចក្តីឧបមានោះឯង ។ ព្រះមហានាគទាំងពីរអង្គនោះ រីករាយចំពោះភាសិតរបស់គ្នាទៅវិញទៅមក ដោយប្រការយ៉ាងនេះឯង ។

អនង្គណសូត្រជាគម្រប់ ៥ ចប់

# អដ្ឋកថា

## អនង្គណសូត្រ

[ ៥៣ ] អនង្គណសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ... ព្រះសារីបុត្រដមានអាយុ ... ។

ការពន្យល់សេចក្ដីចំពោះបទដែលលំបាក ក្នុងព្រះសូត្រនេះ និងក្នុងព្រះសូត្រគ្រប់សូត្រ ក៏ដូចក្នុងព្រះសូត្រនេះ ព្រោះដូច្នោះ បន្ទាប់អំពីនេះទៅ ខ្ញុំនឹងមិនពោលបទទាំងអស់ទេ គ្រាន់តែធ្វើការពន្យល់បទដែលមិនធ្លាប់ពន្យល់សេចក្ដីមកអំពីមុនប៉ុណ្ណោះ ។

[ ៥៤ ] បទថា **ចត្តារោ** ជាការកំណត់រាប់ ។ បទថា **បុគ្គលា** បានដល់ សត្វ បុគ្គល និងបុរស ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ បុគ្គលមិនគួរប្រកាន់ថា ព្រះមហាថេរៈ គឺព្រះសារីបុត្រ មានប្រក្រតីពោលនិយមបុគ្គល គឺនិយមបក្ខពួក ព្រោះលោកប្រសើរបំផុតក្នុងបណ្ដាសាវកដែលជាពុទ្ធបុត្រទាំងឡាយ លោកទេសនាមិនជំទាស់នឹងព្រះធម្មទេសនារបស់ព្រះមានព្រះភាគឡើយ ។

### ទេសនា ២

ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ មាន ២ យ៉ាង គឺសម្មតិទេសនា ១ បរមត្ថទេសនា ១ ។

ក្នុងចំនួនទេសនាទាំង ២ យ៉ាងនោះ សម្មតិទេសនា មានអត្ថយ៉ាងនេះថា បុគ្គល សត្វ ស្រី ប្រុស ក្សត្រ ព្រាហ្មណ៍ ទេវតា មារជាដើម ។

ឯបរមត្ថទេសនា មានអត្ថយ៉ាងនេះថា អនិច្ចំ ទុក្ខំ អនត្តា ខន្ធ ធាតុ

អាយតនៈ សតិប្បដ្ឋានជាដើម ។

ក្នុងចំនួនទេសនាទាំង ២ នោះ ព្រះមានព្រះភាគទ្រង់សម្ដែងសម្មតិ-ទេសនាដល់ពុទ្ធវេនេយ្យ បុគ្គលដែលស្ដាប់ព្រះធម្មទេសនា ពោលដោយរឿងសន្មតហើយ យល់អត្ថ យល់សេចក្ដី ជ្រួតជ្រាប អាចលះមោហៈ សម្រេចគុណវិសេសបាន ឯបុគ្គលពួកណាស្ដាប់ធម្មទេសនា ពោលដោយរឿងបរមត្ថហើយ យល់អត្ថ យល់សេចក្ដី ជ្រួតជ្រាប អាចលះមោហៈ សម្រេចគុណវិសេសបាន ព្រះអង្គក៏ទ្រង់សម្ដែងបរមត្ថទេសនាឲ្យបុគ្គលនោះស្ដាប់ ។

ក្នុងការសម្ដែងព្រះធម្មទេសនាទាំង ២ យ៉ាងនោះ មានការប្រៀបធៀបដូចតទៅនេះ ។ ឧបមាដូចអាចារ្យដែលបរិយាយត្រៃវេទ ចេះភាសាទឹកដីរបស់ខ្លួន កាលនិយាយភាសាទមិឡ អ្នករៀនពួកណាយល់អត្ថ ក៏ប្រាប់បុគ្គលទាំងនោះដោយភាសាទមិឡ តែបើអ្នករៀនពួកណា យល់អត្ថភាសាណាមួយ ក្នុងចំនួនភាសាទាំងឡាយ មានអន្ធកភាសាជាដើម ក៏នឹងប្រាប់បុគ្គលទាំងនោះ ដោយភាសានោះ ។ កាលបើដូច្នោះ មាណព គឺអ្នករៀនទាំងនោះបានអាស្រ័យអាចារ្យអ្នកឈ្លាស មុតស្រួច និងរៀនសិប្បៈបានរហ័សនោះឯង យ៉ាងណា ។

ក្នុងការឧបមេយ្យនោះក៏ដូច្នោះ ព្រះមានព្រះភាគ គប្បីជ្រាបថា ដូចជាអាចារ្យ ព្រះត្រៃបិដកដែលនៅក្នុងភាវៈ ដែលនឹងត្រូវប្រៀនប្រដៅដូចត្រៃវេទ ព្រះបញ្ញាដែលឈ្លាសក្នុងសម្មតិ និងបរមត្ថ ដូចគ្នានឹងការឈ្លាសក្នុងភាសាផ្សេងៗ វេនេយ្យសត្វដែលអាចចាក់ធ្លុះដោយសម្មតិទេសនា និងបរមត្ថទេសនា

ដូចមាណពអ្នកពោលភាសាផ្សេងៗ ព្រះធម្មទេសនាពោលដោយសម្មតិ និងបរមត្ថរបស់ព្រះមានព្រះភាគ ដូចការប្រាប់ត្រៃវេទ ដោយភាសាទមិឡជាដើមរបស់អាចារ្យ ។

ក្នុងការដែលព្រះមានព្រះភាគ ទ្រង់សម្តែងសម្មតិទេសនា និងបរមត្ថ-ទេសនានេះ បុរាណាចារ្យបានពោលទុកថា

ព្រះសម្មាសម្ពុទ្ធ ប្រសើរជាងគ្រូទាំងឡាយ បានត្រាស់សច្ចៈ ២ យ៉ាង គឺសម្មតិសច្ច ១ បរមត្ថសច្ច ១ មិនមានសច្ចៈទី ៣ ព្រះពុទ្ធតម្រាស់ទាក់ទងនឹងសម្មតិ ឈ្មោះថាជាសច្ចៈ ព្រោះជាលោកសម្មតិ ឯព្រះពុទ្ធតម្រាស់ទាក់ទងនឹងបរមត្ថ ឈ្មោះថាជាសច្ចៈ ព្រោះហេតុដែលជាការពិតនៃធម៌ទាំងឡាយ ព្រោះដូច្នោះ សម្រាប់ព្រះលោកនាថសាស្តា ទ្រង់ឈ្លាស ក្នុងវោហារទេសនា ត្រាស់ដល់សម្មតិ ទើបមុសាវាទមិនកើតឡើង ដូច្នេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ បានត្រាស់បុគ្គលកថា ដោយហេតុ ៨ ប្រការ គឺដើម្បីទ្រង់សម្តែងដល់ហិរិ និងឱត្តប្បៈ ១ ដើម្បីទ្រង់សម្តែងដល់ភាពដែលសត្វមានកម្មជារបស់ខ្លួន ១ ដើម្បីទ្រង់សម្តែងដល់ការធ្វើរបស់បុគ្គលដោយចំពោះខ្លួន ១ ដើម្បីទ្រង់សម្តែងដល់អនន្តរិយកម្ម ១ ដើម្បីទ្រង់សម្តែងដល់ព្រហ្មវិហារធម៌ ១ ដើម្បីទ្រង់សម្តែងដល់បុព្វេនិវាសានុស្សតិញ្ញាណ ១ ដើម្បីទ្រង់សម្តែងដល់ទក្ខិណាវិសុទ្ធិ ១ ដើម្បីមិនលះបោលនូវការសន្មតរបស់លោក ១ ។

កាលព្រះអង្គត្រាស់ថា ខន្ធ ធាតុ អាយតនៈទាំងឡាយ ខ្មាសបាប ខ្លាច

បាប មហាជននឹងមិនយល់ នាំគ្នានិយាយគ្នាថា នេះអ្វីហ្ន៎ ខន្ធ ធាតុ អាយតនៈទាំងឡាយខ្មាសបាប ក្រែងខ្លាចចំពោះបាបដែរឬ ដូច្នេះ តែលុះព្រះអង្គត្រាស់ថា បុរស ក្សត្រ ព្រាហ្មណ៍ ទេវតា មារ ខ្មាសបាប ខ្លាចចំពោះបាប ដូច្នេះ មហាជននឹងយល់ មិនជជែកជំទាស់ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់បុគ្គលកថា ដើម្បីសម្តែងដល់ហិរិ និងឱត្តប្បៈ ។

កាលទ្រង់ត្រាស់ថា ខន្ធ ធាតុ អាយតនៈទាំងឡាយ ជាអ្នកមានកម្មជារបស់ខ្លួនដូច្នេះ ក៏ន័យដូចគ្នានោះឯង ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់បុគ្គលកថា ដើម្បីទ្រង់សម្តែងដល់ភាពដែលសត្វមានកម្មជារបស់ខ្លួន ។

សូម្បីក្នុងព្រះតម្រាស់ដែលត្រាស់ថា មហាវិហារ មានវេឡុវ័នជាដើម ខន្ធ ធាតុ អាយតនៈទាំងឡាយជាអ្នកសាងទុក ដូច្នេះ ក៏ន័យដូចគ្នានោះឯង ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់បុគ្គលកថា ដើម្បីសម្តែងដល់ការធ្វើរបស់បុគ្គលដោយចំពោះខ្លួន ។

ក្នុងព្រះតម្រាស់ដែលត្រាស់ថា ខន្ធ ធាតុ អាយតនៈទាំងឡាយ ផ្តាច់ជីវិតមាតា បិតា ព្រះអរហន្ត ធ្វើលោហិតុប្បាទកម្ម បំបែកសង្ឃឲ្យបែកគ្នា ដូច្នេះ ក៏ន័យនោះឯង ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់បុគ្គលកថា ដើម្បីសម្តែងដល់អនន្តរិយកម្ម ។

សូម្បីក្នុងព្រះតម្រាស់ដែលត្រាស់ថា ខន្ធ ធាតុ អាយតនៈទាំងឡាយ រមែងមេត្តា ដូច្នេះ ក៏ន័យដូចគ្នានោះឯង ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់បុគ្គលកថា ដើម្បីទ្រង់សម្តែងព្រហ្មវិហារធម៌ ។

សូម្បីក្នុងព្រះតម្រាស់ដែលត្រាស់ថា ខន្ធ ធាតុ អាយតនៈទាំងឡាយ វព្ទកជាតិដែលធ្លាប់អាស្រ័យអំពីមុនរបស់យើងបាន ដូច្នេះ ក៏ន័យដូចគ្នានោះឯង ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់បុគ្គលកថា ដើម្បីសម្តែងដល់ការវព្ទកជាតិ ដែលរស់នៅអំពីមុនបាន ។

សូម្បីក្នុងព្រះតម្រាស់ដែលត្រាស់ថា ខន្ធ ធាតុ អាយតនៈទាំងឡាយ ទទួលទាន ដូច្នេះ មហាជននឹងមិនយល់ នាំគ្នាប្រកែកជំទាស់ថា នេះអ្វីហ្ន៎ ខន្ធ ធាតុ អាយតនៈទាំងឡាយ ទទួលទានដែរឬហ្ន៎ ដូច្នេះ តែកាលត្រាស់ថា បុគ្គលអ្នកមានសីល មានកល្យាណធម៌ទទួលទាន ដូច្នេះ មហាជនក៏យល់ មិនជំទាស់ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់បុគ្គលកថា ដើម្បីសម្តែងដល់ការបរិសុទ្ធនៃទក្ខិណាទាន ។

ព្រោះថា ធម្មតាព្រះមានព្រះភាគទាំងឡាយ ទ្រង់មិនលះចោលលោក-សម្មតិ ទ្រង់តាំងនៅក្នុងវាចារបស់សត្វលោក ក្នុងភាសារបស់អ្នកស្រុក ក្នុងការបរបាររបស់សត្វលោកនោះឯងសម្តែងធម៌ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់បុគ្គលកថា ដើម្បីមិនលះបង់លោកសម្មតិ ។

ដូច្នោះ ព្រះថេរៈអង្គនេះ កាលមិនឲ្យជំទាស់នឹងព្រះធម្មទេសនារបស់ព្រះមានព្រះភាគ ទើបបានតាំងនៅក្នុងសន្មតរបស់លោក ហើយពោលពាក្យជាដើមថា នៃលោកដ៏មានអាយុទាំងឡាយ បុគ្គល ៤ ពួកនេះ ដូច្នេះ ព្រោះជាអ្នកឈ្លាសក្នុងលោកវោហារ ព្រោះដូច្នោះ បុគ្គលក្នុងទីនេះ សូមជ្រាបតាមសន្មតទាំងអស់ មិនបានសំដៅដល់បរមត្ថឡើយ ។

បទថា **សន្តោ សំវិជ្ជមានោ** ប្រែថា នៅមាន ឬរកបាន គឺល្មមមាន រកជួបតាមចំនួនរបស់លោក ។ ពាក្យថា ក្នុងលោក គឺក្នុងសត្វលោក ។

ក្នុងទីខ្លះ កិលេស ព្រះសាស្តាត្រាស់ថា អង្គណៈ គឺដូចជាទីទួល ក្នុងបទថា **សង្គណោវ សមានោ** ជាដើម ។ ដូចទ្រង់ត្រាស់ថា បណ្តាកិលេសដូចជាទីទួលនោះ កិលេសដូចជាទីទួលដូចម្តេច គឺកិលេសដូចជាទីទួល បានដល់ រាគៈ កិលេសដូចជាទីទួល បានដល់ ទោសៈ កិលេសដូចទីទួល បានដល់ មោហៈ គឺកិលេសដូចជាទីទួល ក្នុងទីខ្លះ សំដៅយកមន្ទិលឯណាមួយ ឬកក់ ដូចដែលត្រាស់ថា ព្យាយាមដើម្បីលះមន្ទិល គឺកក់នោះឯង តែក្នុងទីខ្លះ សំដៅដល់ទីប្រភេទនោះ គឺទីទួល ទីនោះ គប្បីជ្រាបតាមពាក្យដែលចរចាគ្នា ដូចជាទួលពោធិ៍ ទួលចេតិយជាដើម ។ តែក្នុងព្រះសូត្រនេះ ព្រះសារីបុត្រ សម្តែងដល់កិលេសដែលក្តៅក្រហាយច្រើនប្រការថា កិលេសដូចជាទីទួល ។

ពិតហើយ ព្រះសារីបុត្រពោលថា លោកដ៏មានអាយុ ពាក្យថា អង្គណៈ នេះ ជាឈ្មោះអកុសលធម៌ថោកទាប មានការប្រាថ្នាជាអារម្មណ៍ ។ ជាអ្នកប្រព្រឹត្តទៅព្រមដោយកិលេសដូចជាទីទួល ឈ្មោះថា មានកិលេសដូចជាទីទួល ។ បទថា **សង្គណោវ សមានោ** បុគ្គលមានកិលេសដូចជាទីទួលនោះឯង មាន ។

បទថា **អត្ថិ មេ អជ្ឈត្តំ អង្គណំ** ប្រែថា បុគ្គលខ្លះមិនដឹងតាមសេចក្តីពិតថា កិលេសដូចជាទីទួលរបស់អញមាននៅខាងក្នុង សេចក្តីថា មិនដឹងថា កិលេសមាននៅខាងក្នុងខ្លួន គឺក្នុងចិត្តសន្តានរបស់ខ្លួន គឺមិនដឹងដោយពិត

យ៉ាងនេះថា ធម្មតាកិលេសទាំងនេះ គ្រោតគ្រាត ខ្លាំងក្លា គួរលះបង់ មិនគួរយកទុក ដូចជាព្រួញលាបថ្នាំពិស ដូច្នោះ ។

ឯបុគ្គលណា ដឹងថា មានផង ដឹងយ៉ាងនេះផង បុគ្គលនោះ ព្រះសារីបុត្រហៅថា ដឹងតាមការពិតថា កិលេសដូចជាទីទួលខាងក្នុងខ្លួនរបស់អញមាន ។ តែកិលេសដែលដកបានដោយមគ្គ មិនទាន់កើតឡើងដល់បុគ្គលណា ព្រោះសង្កត់សង្កិនបានដោយវិធីណាមួយក៏ដោយ បុគ្គលនេះ ព្រះសារីបុត្របំណាងយកថា ជាអ្នកមិនមានកិលេសដូចជាទីទួលក្នុងព្រះសូត្រនេះ ។

បទថា **នត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ នប្បជានាតិ** ប្រែថា មិនដឹងតាមការពិតថា កិលេសដូចជាទីទួលខាងក្នុងរបស់អញមិនមាន សេចក្តីថា មិនដឹងថា កិលេសរបស់អញមិនមាន ព្រោះសង្កត់សង្កិនដោយវិធីណាមួយ មិនមែនមិនមានព្រោះដកបានដោយមគ្គ គឺមិនយល់ដោយពិតយ៉ាងនេះថា កិលេសទាំងនោះកាលកើតឡើង នឹងធ្វើសេចក្តីវិនាសយ៉ាងធំក្រៃលែង ព្រោះថា ជាកិលេសគ្រោតគ្រាត ខ្លាំងក្លា គួរលះបង់ មិនគួរទុក ដូចជាព្រួញលាបថ្នាំពិស ដូច្នោះ ។

ចំណែកបុគ្គលណាដឹងថា មិនមានព្រោះហេតុនេះផង ដឹងយ៉ាងនេះផង បុគ្គលនោះ ព្រះសារីបុត្រហៅថា ដឹងតាមពិតថា កិលេសដូចទីទួលខាងក្នុងរបស់អញមិនមាន ដូច្នេះ ។

បទថា **តត្រ** ស្មើគ្នានឹង **តេសុ** យោគជា **ចតូសុ បុគ្គលេសុ** ក្នុងបុគ្គល ៤ ពួកនោះ ឬយោគជា **ទ្វីសុ សង្គណេសុ** ក្នុងបុគ្គលដែលមានកិលេសដូចទី

ទួលទាំង ២ នោះ ។

បទថា **យ្វាយំ** កាត់បទជា **យោ អយំ** ប្រែថា បុគ្គលនេះ បាឋៈជា **យាយំ** ដូច្នេះក៏មាន ។

[ ៥៥ ] ព្រះមហាមោគ្គល្លានសាកសួរដល់ហេតុតែម្យ៉ាងប៉ុណ្ណោះឯង តែប្រើក្នុងពាក្យសួរ ដោយពាក្យទាំងគូថា លោកម្ចាស់សារីបុត្រដ៏មានអាយុ អ្វីហ្ន៎ជាហេតុ ជាបច្ច័យ ដូច្នេះ ។

គប្បីជ្រាបការសម្ពន្ធគ្នា ក្នុងបទថា **យេនិមេសំ** ជាដើមយ៉ាងនេះថា បណ្ដាបុគ្គលទាំង ២ ប្រភេទនោះ បុគ្គលម្នាក់លោកហៅថា ជាបុគ្គលប្រសើរ បុគ្គលម្នាក់ទៀតលោកហៅថា ជាបុគ្គលថោកទាប ព្រោះហេតុអ្វី ព្រោះបច្ច័យអ្វី ហេតុនោះ គឺអ្វី បច្ច័យនោះ គឺអ្វី ។

ក្នុងរឿងហេតុ និងបច្ច័យទាំង ២ យ៉ាងនោះ សូម្បីពាក្យថា ការដឹង និងការមិនដឹងទាំងគូនេះឯង ដែលព្រះសារីបុត្រពោលថា មិនដឹងផង ដឹងផង ជាហេតុផង ជាបច្ច័យផងក៏ពិត ទោះយ៉ាងនោះ ព្រះថេរៈបានពោលត្រួតថា នៃអាវុសោ ក្នុងចំនួនបុគ្គល ២ ប្រភេទនោះ ដូច្នេះជាដើម ដើម្បីសម្ដែងហេតុនោះឲ្យប្រាកដជាងមុន ព្រោះខ្លួនមានបដិភាណមុតស្រួច ។

បណ្ដាបទទាំងនោះ បទថា **តស្សេតំ ចាដិកង្ខំ** ប្រែថា បុគ្គលនោះសង្ឃឹមបានហេតុនោះ ដូច្នេះ អធិប្បាយថា បុគ្គលនោះ គប្បីសង្ឃឹមបានទូវហេតុនោះ គឺគប្បីប្រមាណបានថា បុគ្គលនោះនឹងជួបហេតុនេះឯង មិនមែនហេតុដទៃឡើយ ដោយអត្ថថា ជាវត្ថុដែលមានពិតប្រាកដ ។

ព្រះសារីបុត្រ ពោលសំដៅយក ការមិនញុំាងឆន្ទៈឲ្យកើតឡើងជាដើម ដែលលោកបានពោលទុក ដោយន័យជាដើមថា បុគ្គលនោះ មិនញុំាងឆន្ទៈឲ្យកើតឡើង ។

សូម្បីក្នុងចំនួនអត្ថទាំងនោះ អត្ថថា បុគ្គលនឹងឲ្យឆន្ទៈកើតឡើង គឺបុគ្គលនោះ កាលមិនដឹង ក៏នឹងមិនឲ្យការពេញចិត្តចង់ធ្វើកើតឡើង ដើម្បីលះកិលេសដូចទីទួលនោះ ។

បទថា **ន វាយមិស្សតិ** ប្រែថា នឹងមិនព្យាយាម គឺនឹងមិនធ្វើការព្យាយាមឲ្យមានកម្លាំងច្រើនទៅជាងនោះឡើយ ។

បទថា **ន វីរិយំ អារភិស្សតិ** គឺមិនប្រារព្ធសេចក្ដីព្យាយាម សេចក្ដីថា មិនប្រារព្ធសេចក្ដីព្យាយាម ដែលជាហេតុមានកម្លាំង អធិប្បាយថា មិនញុំាងសេចក្ដីព្យាយាមឲ្យប្រព្រឹត្តទៅ ។

បទថា **សង្គណោ** គឺមានកិលេសដូចទីទួល ដោយទួលទាំងឡាយមានរាគៈនេះជាដើម ។

បទថា **សង្កិលិដ្ឋចិត្តោ** ប្រែថា ជាអ្នកមានចិត្តសៅហ្មងហើយ គឺជាអ្នកមានចិត្តសៅហ្មង បានដល់ មានចិត្តល្អក់កករដ៏ច្រើន ព្រោះទួល គឺកិលេសទាំងនោះឯង បានដល់ ជាអ្នកមានចិត្តត្រូវកិលេស ដូចទីទួលទាំងនោះបៀតបៀន មានចិត្តត្រូវកិលេស ដូចទីទួលទាំងនោះ ជុតរោលនោះឯង ។

បទថា **កាលំ ករិស្សតិ** គឺនឹងស្លាប់ ។

បទថា **សេយ្យថាបិ** គឺ **សេយ្យថា នាម** សេចក្ដីថា ប្រៀបដូចជា ។

បទថា **កំសថាតិ** គឺភាជនៈដែលធ្វើដោយសំរឹទ្ធ ។ បទថា **អាភតា** គឺយកមក ។ បទថា **អាបណា វា កម្មារកុលា វា** គឺពនផ្សារ ឬស្រុករបស់ជាងលោហៈ ដែលធ្វើថាសសំរឹទ្ធ ។ បទថា **រជេន** គឺត្រូវល្អងធូលីដែលចរមក មានធូលីដីជាដើមហើយមកជាប់ ។ បទថា **មលេន** គឺត្រូវមន្ទិលលោហៈកើតជាមួយនឹងថាសសំរឹទ្ធនោះឯង ។ បទថា **បរិយោនទ្ធា** គឺចោមរោមទូទៅ ។ បទថា **ន ច បរិយោទបេយ្យុំ** គឺមិនបានធ្វើការសម្អាត ដោយវិធីលាង និងដុសខាត់ជាដើម ។

បទថា **រជាបថេ** គឺក្នុងទីដែលមានល្អងធូលី ។ ម្យ៉ាងទៀត បាឋៈ គឺបាលីក្នុងព្រះត្រៃបិដកក៏យ៉ាងនោះដូចគ្នា ។ អធិប្បាយថា ទុកដាក់ក្នុងទីដែលល្អងធូលីហុយមកដល់ គឺក្នុងទីដែលល្អងធូលីបាចសាច ឬទុកក្រោមគ្រែក្តីជង្រុកស្រូវក្តី ឬខាងក្នុងភាជនៈ ដែលហាក់ដូចជាយកល្អងធូលីរោយដាក់ ។

ក្នុងបទថា **សង្កិលិដ្ឋតរា អស្ស មលគ្គហិតា** នេះ មានអធិប្បាយថា មានតែការសៅហ្មងឡើងជាងមុន ព្រោះទុកដាក់ក្នុងទីផ្លូវដែលមានល្អងធូលី គឺត្រូវមន្ទិលចាប់ច្រើនជាងមុន ព្រោះមិនបានប្រើ និងមិនបានធ្វើការសម្អាត មិនមែនឬ ។

បទថា **សង្កិលិដ្ឋតរា អស្ស មលគ្គហិតា** មានតែសៅហ្មង មានមន្ទិលចោមរោមច្រើនមិនមែនឬ នេះជាពាក្យសាកសួរ ។ ព្រោះដូច្នោះ គប្បីជ្រាបអធិប្បាយពាក្យសាកសួរនោះដូច្នេះថា អាវុសោ ថាសសំរឹទ្ធមួយនោះដែលគេធ្វើយ៉ាងនេះ ក្នុងកាលជាខាងក្រោយ នឹងសៅហ្មងច្រើនជាងមុន នឹង

មានមន្ទិលចាប់ច្រើនជាងមុន រហូតលំបាកនឹងដឹងបាន ឬមិនដឹងថា ជាថាសដី ឬជាថាសសំរឹទ្ធ ។ ព្រះថេរៈកាលទទួលពាក្យនេះ ទើបពោលថា យ៉ាងនោះឯង អាវុសោ ។

ព្រះធម្មសេនាសបតី កាលបញ្ចាក់ឧបមេយ្យម្យ៉ាងទៀត ទើបពោលពាក្យជាដើមទុកថា **ឯវមេវ ខោ ។**

ក្នុងពាក្យនោះ គួរជ្រាបការប្រៀបធៀបពាក្យឧបមាពាក្យឧបមេយ្យដូចតទៅនេះថា

បុគ្គលដែលនៅមានកិលេសដូចទីទួល ប្រៀបដូចថាសសំរឹទ្ធដែលសៅហ្មង កាលបុគ្គលនោះបានបួស ក៏ត្រឡប់បានបួសក្នុងសម្នាក់របស់បុគ្គលដែលខ្វល់ខ្វាយក្នុងអនេសនៈទាំងឡាយ មានវេជ្ជកម្មជាដើម ប្រៀបដូចការចោលថាសសំរឹទ្ធដែលមានមន្ទិលស្រាប់ហើយ ក្នុងទីដែលមានល្អងធូលី ព្រោះមិនបានប្រើប្រាស់ជាដើម ។ ការធ្វើអនេសនៈ មានវេជ្ជកម្មជាដើមនៃបុគ្គលនោះជាអ្នកត្រាប់តាមអាចារ្យ និងឧបជ្ឈាយ៍តាមលំដាប់ មរណភាពទាំងដែលនៅមានកិលេសដូចទីទួលរបស់បុគ្គល ដែលតាំងនៅក្នុងវីតិក្កមទោស គឺការធ្វើអនេសនា គឺការធ្វើវេជ្ជកម្មជាដើម គឺធ្វើគ្រូពេទ្យដូចអាចារ្យ ប្រៀបដូចការៈរបស់ថាសដែលសៅហ្មងហើយ រឹងរឹតតែសៅហ្មងក្រៃលែងឡើង ។

ម្យ៉ាងទៀត មរណភាពទាំងមានកិលេស ដូចទីទួលនៃបុគ្គលដែលតាំងនៅក្នុងវីតិក្កមទោសនេះតាមលំដាប់ គឺការត្រូវអាបត្តិទុក្កដ និងទុព្ភាសិត ។ ម្យ៉ាងទៀត មរណភាពទាំងដែលនៅមានកិលេស ដូចទីទួលរបស់បុគ្គលតាំង

នៅក្នុងវីតិក្កមទោសនេះតាមលំដាប់ គឺការត្រូវអាបត្តិបាចិត្តិយៈ និងថុល្លច្ច័យ ការត្រូវអាបត្តិសង្ឃាទិសេស ការត្រូវអាបត្តិបារាជិក និងការធ្វើអនន្តរិយកម្ម មានការសម្លាប់មាតាជាដើម ។ តែក្នុងសេចក្ដីនេះថា នឹងជាអ្នកមានចិត្ត សៅហ្មងមរណកាល មិនគួរឃើញអធិប្បាយយ៉ាងនេះថា នឹងមរណកាលដោយ អកុសលចិត្ត ។ ព្រោះសត្វគ្រប់គ្នា ស្លាប់ដោយបកតិចិត្ត គឺដោយភវង្គចិត្ត នោះឯង តែបុគ្គលនេះ មិនទាន់ជម្រះចិត្តសន្តានឲ្យស្អាតជាមុនហើយ ទើប ស្លាប់ ដូច្នេះឯង គប្បីជ្រាបអធិប្បាយថា ព្រះសារីបុត្រពោលអត្ថយ៉ាងនេះ សំដៅយកអធិប្បាយនេះ ។

ក្នុងទុតិយវារៈមានវិនិច្ឆ័យដូច្នេះ បទថា **បរិយោទបេយ្យុំ** គឺការដុសដូត សេចក្ដីថា ធ្វើឲ្យស្អាត គឺឲ្យដូចជាកញ្ចក់ ដោយការលាង ការដុស ការដូត ដោយផេះជាដើម ។

បទថា **ឆ ច ឆំ រជាបថេ** គឺមិនគួរទុកក្នុងផ្លូវនៃធូលី សេចក្ដីថា មិន គួរទុកក្នុងទីដូចពោលមកមុននោះឡើយ តែគួរទុកក្នុងជន្ទាប់ ឬហឹប ឬខ្ចប់ ហើយព្យួរទុកត្រង់ឈើសម្រាប់ព្យួរវត្ថុ គឺដៃកែវ ។ ពាក្យដ៏សេស គួរកាន់ យកតាមគន្លងរបស់ន័យ ដែលបានពោលមកហើយនោះចុះ ។

តែក្នុងទុតិយវារៈនេះ គួរជ្រាបការប្រៀបធៀបរវាងការឧបមា និងឧប- មេយ្យដូចតទៅនេះថា កព្វបុគ្គលដែលនៅមានកិលេសដូចជាទីទួល ប្រៀប ដូចជាសសរីទ្ធដែលសៅហ្មង កាលបុគ្គលនោះបានបួសក្នុងសម្នាក់បុគ្គលមាន សីលជាទីស្រឡាញ់ ដូចធ្វើការប្រើប្រាស់ថាសសរីទ្ធ ដែលសៅហ្មងជាដើម

ហើយទុកដាក់ក្នុងទីដែលស្អាត ។ អាចារ្យ និងឧបជ្ឈាយ៍ពួកណាជាសរ់តឿន ប្រៀនប្រដៅដល់បុគ្គលនោះ ឃើញការប្រមាទត្រឹមបន្តិចបន្តួច ក៏ធ្វើទណ្ឌកម្ម ហើយឲ្យត្រងត្រាប់រឿយៗ មរណភាពខណៈដែលមិនមានកិលេសដូចទីទួល នៃបុគ្គលនោះ ដែលបដិបត្តិតាមអាចារ្យ និងឧបជ្ឈាយ៍នោះ តាំងនៅក្នុង គុណធម៌នេះ គឺការប្រព្រឹត្តបដិបត្តិប្រពៃតាមលំដាប់ ដូចភាវៈនៃថាសសំរឹទ្ធ ដែលសៅហ្មង តែស្អាតបរិសុទ្ធក្នុងកាលខាងក្រោយ ។

ម្យ៉ាងទៀត មរណភាពខណៈ ដែលមិនមានកិលេសដូចទីទួលរបស់ បុគ្គលនោះ ដែលតាំងនៅក្នុងការដាស់តឿនឲ្យនៅក្នុងសីលដ៏បរិសុទ្ធ ការរៀន យកព្រះពុទ្ធវចនៈល្មមសមគួរសម្រាប់ខ្លួន ហើយសមាទានធុតង្គ ទទួលយក ព្រះកម្មដ្ឋានដែលឧបការៈដល់ខ្លួន លះបង់ការនៅក្នុងសេនាសនៈជិតស្រុក ហើយនៅក្នុងសេនាសនៈដែលស្ងាត់នេះតាមលំដាប់ ប្រៀបធៀបនឹងភាវៈនៃ ថាសសំរឹទ្ធដែលសៅហ្មង តែស្អាតបរិសុទ្ធក្នុងកាលខាងក្រោយ ។

ម្យ៉ាងទៀត មរណភាពខណៈ ដែលមិនមានកិលេសដូចជាទីទួលក្នុង វារៈចុងក្រោយនោះឯង ( បរិនិព្វាន ) នៃលោកដែលតាំងនៅក្នុងការធ្វើ បរិកម្មកសិណ ហើយសង្កត់សង្កិនកិលេសបាន ដោយការញុំាងសមាបត្តិ ទាំង ៨ ឲ្យកើតឡើង ការចេញចាកឈានដែលជាបាទរបស់វិបស្សនា រារាំង កិលេសបានដោយតទង្គប្បហាន គឺការលះកិលេសណាមួយបានដោយអង្គ នោះ ដូចជា លះសុភារម្មណ៍បានដោយការពិចារណាអសុភជាដើម ទើប សម្រេចសោតាបត្តិផលដោយវិបស្សនា ។បេ។ ការធ្វើអរហត្តឲ្យជាក់ច្បាស់

ដល់ខ្លួន ប្រៀបដូចភាវៈនៃថាសដែលសៅហ្មង តែស្អាតបរិសុទ្ធក្នុងកាលជាខាងក្រោយ ។

ក្នុងតតិយវារៈមានវិនិច្ឆ័យដូចតទៅនេះ បទថា **សុភនិមិត្តំ** បានដល់អារម្មណ៍ដែលគួរប្រាថ្នា ជាទីតាំងនៃរាគៈ ។

បទថា **មនសិ ករិស្សតិ** សេចក្តីថា កាលសុភនិមិត្តនោះមាន បុគ្គលនោះក៏រឭកដល់និមិត្តនោះ ។ បទថា **តស្ស សុភនិមិត្តស្ស មនសិការា** ប្រែថា ការដាក់ចិត្តដល់សុភនិមិត្តរបស់បុគ្គលនោះ បានដល់ ព្រោះហេតុនៃការដាក់ចិត្តដល់សុភនិមិត្តនៃបុគ្គលនោះ ។

បទថា **អនុទ្ធំសេស្សតិ** ប្រែថា តាមបៀតបៀន គឺនឹងបៀតបៀន បានដល់ នឹងគ្របសង្កត់ចិត្តរបស់បុគ្គលនោះ ។ អធិប្បាយថា រាគៈ គប្បីជ្រាបថា កាលកើតឡើងក៏កាត់ផ្តាច់ការបដិបត្តិកុសល ជាអកុសលជវនឯង តាមកម្ចាត់កុសលចិត្ត ស្ថិតនៅ ។ ពាក្យដ៏សេសគួរកាន់យកតាមគន្លងរបស់ន័យដែលបានពោលមកហើយនោះចុះ ។

តែក្នុងតតិយវារៈនេះ គួរជ្រាបការប្រៀបធៀបរវាងឧបមេយ្យដូចតទៅនេះ បុគ្គលដែលមិនមានកិលេសដូចទីទួល មានកិលេសតិចតាមប្រក្រតី ដូចជាថាសសំរឹទ្ធដែលស្អាត ។ ការដែលបុគ្គលនោះបានបួស ក៏បានបួសក្នុងសម្នាក់នៃបុគ្គលដែលខ្វល់ខ្វាយក្នុងអនេសនា មានវេជ្ជកម្មជាដើម ដូចគ្នានឹងការមិនធ្វើការប្រើប្រាស់ជាដើម នូវថាសសំរឹទ្ធដែលស្អាតហើយ ទុកដាក់ក្នុងទីដែលមានធូលីវិញ ។ បន្ទាប់អំពីនេះ គ្រប់ពាក្យដូចគ្នានឹងបឋមវារៈទាំងអស់ ។

ក្នុងចតុត្ថវារៈ មានវិនិច្ឆ័យដូចតទៅនេះ បទថា **សុភនិមិត្តំ ន មនសិការិស្សតិ** ប្រែថា មិនដាក់ចិត្តក្នុងសុភនិមិត្ត សេចក្ដីថា មិនរឭកដល់និមិត្តនោះ ព្រោះមិនមានការប្រាសចាកសតិក្នុងនិមិត្តនោះ ។ ពាក្យដ៏សេស គប្បីជ្រាបតាមគន្លងនៃទុតិយវារៈចុះ ។ ពាក្យមានជាដើមថា **អយំ ខោ អាវុសោ** បុគ្គលនេះឯង មានន័យដូចដែលបានពោលទុកក្នុងពាក្យជាដើមថា **យោនោ ឆុខោ** នោះឯង ។

[ ៥៦ ] ឥឡូវនេះ ព្រះសារីបុត្រ ត្រូវព្រះមហាមោគ្គល្លានបំណងឲ្យលោកអធិប្បាយកិលេសដូចទីទួលនោះឲ្យច្បាស់លាស់ ដោយប្រការផ្សេងៗ សួរហើយ ដោយន័យជាដើមថា ពាក្យដែលលោកហៅថា អង្គណៈ អង្គណៈ ជាឈ្មោះនៃវត្ថុអ្វី ដូច្នេះ កាលនឹងឆ្លើយសំណួរនោះ បានពោលពាក្យថា នៃអាវុសោ ពាក្យថា **អង្គណា** នេះ ជាឈ្មោះរបស់អកុសលធម៌ដែលថោកទាប ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឥច្ឆាវចរានំ** ប្រែថា ជាដែនរបស់ឥច្ឆា មានអត្ថថា អកុសលជាទីត្រាច់ទៅនៃការចង់បាន សេចក្ដីក្រោធ និងការអាក់អន់ចិត្តច្រើនប្រការ ដែលចូលចុះ គឺប្រព្រឹត្តទៅ ដោយអំណាចការចង់បាន ។

[ ៥៧ ] បទថា **យំ ឥធេកច្ចស្ស** ប្រែថា ហេតុដែលឲ្យការចង់បានកើតឡើង ដល់ភិក្ខុរូបខ្លះក្នុងសាសនានេះ អធិប្បាយថា ការចង់បាននេះ គប្បីកើតឡើងដល់ភិក្ខុរូបខ្លះ ដោយហេតុយ៉ាងណា ហេតុនោះ ក៏ជាហេតុនៃការចង់បាននោះ មាន គឺគង់មាន បានដល់ គង់រកបាន ។

បទថា **អាបន្នោ អស្សំ** ស្មើគ្នានឹង **អាបន្នោ ភវេយ្យំ** ប្រែថា គប្បីជាអ្នកត្រូវអាបត្តិហើយ ។

ប្រយោគថា **ន ច ភិក្ខូ ជានេយ្យុំ** ស្មើគ្នានឹង **ភិក្ខូ ច មំ ន ជានេយ្យុំ** ប្រែថា សូមកុំឲ្យភិក្ខុទាំងឡាយដឹងអាត្មាអញថាត្រូវអាបត្តិ ។

ក្នុងរឿងដែលមិនឲ្យភិក្ខុទាំងឡាយដឹងនេះ មានអ្វីជាហេតុ មានភាពដែលលោកជាអ្នកមានសេចក្តីត្រូវការលាភជាហេតុ ។

អធិប្បាយថា ភិក្ខុដែលត្រូវការលាភតាមប្រក្រតីហើយ ក៏ជាអ្នកធ្វើបុណ្យទុក និងជាបុគ្គលដែលមនុស្សទាំងឡាយនាំគ្នាធ្វើសក្ការៈ គោរព រាប់អាន ទើបគិតយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិហើយ ព្រះថេរៈទាំងឡាយដឹងបុគ្គលនោះ នឹងប្រាប់ដល់ភិក្ខុដែលជាមជ្ឈិមទាំងឡាយ ភិក្ខុមជ្ឈិមទាំងឡាយនឹងប្រាប់ដល់នវភិក្ខុ នវភិក្ខុទាំងឡាយ នឹងប្រាប់ដល់មនុស្សទាំងឡាយ មានអ្នកយាមវិហារជាដើម ( អ្នកស៊ីដែល ) មនុស្សយាមវិហារទាំងនោះ នឹងប្រាប់ដល់ភិក្ខុនីទាំងឡាយដែលមកទទួលឱវាទបរិសទ្យទាំង ៤ ក៏នឹងដឹងទៅតាមលំដាប់យ៉ាងនេះ កាលបើយ៉ាងនេះ អន្តរាយនៃលាភក៏នឹងមានដល់អាត្មាអញ គួរខ្មាសអៀនពិតហ្ន៎ សូម្បីអញក៏ត្រូវអាបត្តិពិតហើយ សូមភិក្ខុទាំង-ឡាយកុំដឹងអញឡើយ ។

បទថា **យំ តំ ភិក្ខុំ ភិក្ខូ ជានេយ្យុំ** ប្រែថា ពួកភិក្ខុដឹងភិក្ខុនោះថាជាអ្នកត្រូវអាបត្តិហើយ សេចក្តីថា ព្រោះឲ្យភិក្ខុដទៃដឹងរឿងភិក្ខុនោះមានពិត គឺមាននោះឯង មិនមែនមិនមាន ព្រោះព្រះថេរៈទាំងឡាយដឹងហើយ ក៏នឹង

ប្រាប់ដល់មជ្ឈិមភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ លោកក៏នឹងជាអ្នកប្រាកដក្នុងបរិសទ្យទាំង ៤ ដោយន័យដែលបានពោលមកហើយ កាលលោកប្រាកដយ៉ាងនេះហើយ នឹងជាអ្នកអប្បយស ចូលទៅស្រុករាប់រយ ជូតជើងត្រង់ធរណីទ្វាររាប់រយកន្លែង ក៏នឹងចេញមកដោយបាត្រទទេ ។ បន្ទាប់អំពីនោះទៅ ភិក្ខុទាំងឡាយ ក៏ដឹងអាត្មាអញថា ជាអ្នកត្រូវអាបត្តិ ។ ម្យ៉ាងទៀត លោកកាលគិតថា អញត្រូវភិក្ខុទាំងនោះ ធ្វើឲ្យវិនាសទៅហើយ ដោយអាការយ៉ាងនេះ ក៏ជាអ្នកអាក់អន់ព្រោះហេតុយ៉ាងនេះ ។

[ ៥៨ ] បទថា **អប្បតីតោ** ប្រែថា ជាអ្នកអាក់អន់ចិត្ត គឺលោកជាអ្នកក្រោធអាក់អន់ បានដល់ ត្រូវសេចក្តីក្រោធគ្របសង្កត់ និងជាអ្នកទោមនស្ស គឺត្រូវសេចក្តីមិនត្រេកអរគ្របសង្កត់ព្រោះហេតុការណ៍នេះ ។ ក្នុងបទថា **យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ** ប្រែថា នែអាវុសោ សេចក្តីខឹងឯណាក្តី សេចក្តីមិនត្រេកអរឯណាក្តី ទាំង ២ នេះឯង ឈ្មោះថា អង្គណៈ គួរជ្រាបអធិប្បាយយ៉ាងនេះថា នែអាវុសោ ការខឹងក្រោធ គប្បីសង្គ្រោះចូលក្នុងសង្ខារក្ខន្ធផង ការតូចចិត្តសង្គ្រោះចូលក្នុងវេទនាខន្ធផង ទាំងគូនេះ ឈ្មោះថា អង្គណៈ ពាក្យនេះលោកពោលដោយអំណាច នៃបុគ្គលដែលមានសភាពដូច្នោះ តែការលោកលោកពោលដោយអំណាចជាចំណែកខាងដើម នៃកិលេសដូចទីទួលនេះ ។ ឯមោហៈ ក៏ជាការកាន់យកហើយដូចគ្នា ដោយអំណាចនៃការប្រកបចូលគ្នា ( នឹងលោកៈ ) ហើយ ។

[ ៥៩ ] បទថា **អនុរហោ មំ** ប្រែថា គួរចោទអាត្មាអញក្នុងទីកំបាំង មានអត្ថថា ភិក្ខុជួបនឹងអន្តជំបូង ( ដែលត្រូវអាបត្តិ ) ប្រាថ្នាឲ្យភិក្ខុទាំង-ឡាយនាំខ្លួនចូលទៅកាន់សេនាសនៈខាងចុងវិហារបិទទ្វារ ហើយសឹមចោទ ។

បទថា **ឋានំ ខោ បនេតំ** ប្រែថា សេចក្ដីនេះជាហេតុ ដោយអត្ថថា ហេតុនេះមាន គឺភិក្ខុទាំងឡាយដែលជាអ្នកឈ្លាស បានទទួលណែនាំ ហើយគួរយកភិក្ខុនោះទៅកាន់កណ្ដាលបរិសទ្យ ៤ ហើយចោទដោយន័យថា លោកម្ចាស់ធ្វើវេជ្ជកម្មក្នុងទីឈ្មោះនោះ ។ ឯពាក្យថា លោកនឹងជាអ្នកប្រាកដក្នុងបរិសទ្យ ៤ នឹងប្រាកដយ៉ាងនេះផង ត្រូវសេចក្ដីវិនាសយសគ្របសង្កត់ ហើយផង ទាំងអស់ដូចគ្នានឹងសេចក្ដីក្នុងវគ្គខាងដើមនោះឯង ។

បទថា **សប្បដិបុគ្គលោ** ប្រែថា បុគ្គលស្មើគ្នា គឺបុគ្គលផ្ទុយគ្នាក្នុងការប្រៀបធៀប ។ បទថា **សមានោ** គឺត្រូវអាបត្តិដូចគ្នា ។

បទថា **បដិបុគ្គលោ** គឺបុគ្គលជាអ្នកចោទ ។ ភិក្ខុនេះត្រូវឲ្យចោទដោយភិក្ខុដែលត្រូវអាបត្តិដូចគ្នា ព្រោះថា លោកយល់ថា អាចនឹងពោលជំទាស់បានថា លោកខ្លួនឯងក៏ត្រូវអាបត្តិនេះ ជាបឋមលោកត្រូវសម្ដែងអាបត្តិនោះខាងក្រោយ សឹមចោទខ្ញុំ ម្យ៉ាងទៀត បុគ្គលស្មើគ្នាដោយជាតិជាដើម ឈ្មោះថា បុគ្គលស្មើគ្នា ។ អធិប្បាយថា ភិក្ខុនេះត្រូវឲ្យចោទដោយភិក្ខុស្មើគ្នា ដោយគុណសម្បត្តិទាំងឡាយជាដើមយ៉ាងនេះ គឺដោយជាតិ ដោយត្រកូល ដោយភាពជាពហុស្សូត ដោយភាពឈ្លាស និងធុតង្គរបស់ខ្លួន ដោយយល់ថា ភិក្ខុបែបនោះ ចោទ នឹងមិនវិនាសច្រើន ។

បុគ្គលផ្សុយគ្នា ( គឺអ្នកចោទ ) ដែលមិនគួរគ្នា ឈ្មោះថា បុគ្គលដែលមិនស្មើគ្នា ក្នុងពាក្យនេះថា មិនមែនបុគ្គលដែលមិនស្មើគ្នា អធិប្បាយថា បុគ្គលដែលជាគូសត្រូវ ជាគូបដិបក្ខ ឈ្មោះថា មិនគួរជាអ្នកចោទ ព្រោះមិនស្មើគ្នាដោយអាបត្តិទាំងនេះជាដើម ។

បទថា **ឥតិ សោ កុបិតោ** ប្រែថា ព្រោះហេតុយ៉ាងនេះ បុគ្គលនោះនឹងជាអ្នកមិនត្រេកអរ មានអត្ថថា ព្រោះហេតុយ៉ាងនេះ បុគ្គលនោះនឹងជាអ្នកអាក់អន់យ៉ាងនេះ ព្រោះការចោទរបស់បុគ្គលដែលមិនស្មើគ្នានេះ ។

[ ៦០ ] ក្នុងចតុត្ថវារៈដែលពោលដោយឥច្ឆាវចរទី ៤ មានវិនិច្ឆ័យដូចតទៅនេះ សព្ទថា **អហោ វត** ប្រែថា ឱហ្ន៎ ប្រាកដក្នុងពាក្យតិះដៀលក៏មានដូចក្នុងពាក្យថា **អហោ វត រេ អម្ហាកំ បណ្ឌិតក អហោ វត រេ អម្ហាកំ ពហុស្សុតក អហោ វត រេ អម្ហាកំ តេវិជ្ជក** ឱ អាចក្រៃ អ្នកប្រាជ្ញយើង ឱ អាចក្រៃ អ្នកពហុស្សូតយើង ឱ អាចក្រៃ អ្នកត្រៃវិជ្ជាយើង ។ ប្រាកដក្នុងការត្រេកអរក៏មាន ដូចពាក្យថា **អហោ វត មំ ឧហារំយេវ សមានំ រជ្ជេ អភិសិញ្ចេយ្យុំ** គួរ ត្រេកអរហ្ន៎ មនុស្សទាំងឡាយ ត្រូវអភិសេកអាត្មាអញដែលនៅកំលោះ ទុកក្នុងរាជសម្បត្តិ ។ ក្នុងទីនេះ ប្រាកដក្នុងអត្ថថា ត្រេកអរប៉ុណ្ណោះ ។

បទថា **បុច្ឆិត្វា បុច្ឆិត្វា** ប្រែថា ត្រាស់សួរហើយ គឺត្រាស់សួរហើយសួរទៀត ។ ភិក្ខុត្រូវការលោកនេះ ចង់ឲ្យព្រះមានព្រះភាគទ្រង់សាកសួរខ្លួនតែត្រូវការឲ្យសួរបញ្ហានោះដោយវាចា ដើម្បីឲ្យស្រេបតាម មិនមែនត្រាស់

សួរដល់មគ្គ ផល ឬវិបស្សនា ធ្វើឲ្យមានឱកាស ។ ព្រោះថា ភិក្ខុរូបនេះ ឃើញព្រះមានព្រះភាគ ទ្រង់សាកសួរព្រះមហាថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើម ក្នុងកណ្តាលបរិសទ្យយ៉ាងនេះថា សារីបុត្រ មោគ្គល្លាន កស្សប រាហុល អ្នកយល់សេចក្តីនោះដូចម្តេច គឺចក្ខុទៀង ឬមិនទៀង ហើយទ្រង់សម្តែងធម៌ ឃើញពួកមនុស្សពោលសរសើរគុណរបស់ព្រះថេរៈទាំងនោះថា ព្រះថេរៈជាបណ្ឌិតទាំងឡាយ ព្រះសាស្តាទ្រង់ពេញព្រះទ័យដូច្នេះ និងឃើញពួកទាយកបង្អោនលាភសក្ការៈទៅប្រគេនព្រះថេរៈទាំងនោះ ព្រោះដូច្នោះ កាលលោកប្រាថ្នាលាភសក្ការៈនោះ កាលគិតយ៉ាងនេះហើយ ចេញទៅឈរចំពោះមុខព្រះមានព្រះភាគ ដូចកំណាត់ឈើដែលដាក់ ។

បទថា **សោ កុបិតោ** ប្រែថា មិនត្រេកអរហើយ សេចក្តីថា ខាងក្រោយ ព្រះមានព្រះភាគមិនដាក់ព្រះទ័យនឹងលោកឡើយ តែត្រាស់សួរព្រះថេរៈដទៃ ហើយទ្រង់សម្តែងធម៌ ព្រោះដូច្នោះ ទើបលោកអាក់អន់ដល់ព្រះមានព្រះភាគផង ព្រះថេរៈផង ។

សួរថា អាក់អន់នឹងព្រះមានព្រះភាគដូចម្តេច ឆ្លើយថា អាក់អន់នឹងព្រះមានព្រះភាគយ៉ាងនេះថា អាត្មាអញ តាំងអំពីបួស មិនស្គាល់ការចេញទៅខាងក្រៅបរិវេណព្រះគន្ធកុដិ គ្រប់ពេល មិនធ្លាប់ឆ្ងាយ ដូចគ្នានឹងស្រមោល សូម្បីតែត្រាស់សួរអាត្មាអញ ហើយទ្រង់សម្តែងធម៌ទេសនាក៏មិនមាន ទ្រង់សួរព្រះថេរៈដែលឃើញត្រឹមតែមួយភ្លែតប៉ុណ្ណោះ រួចក៏ទ្រង់សម្តែងធម៌ ។

សួរថា អាក់អន់នឹងព្រះថេរៈដូចម្តេច ឆ្លើយថា អាក់អន់នឹងព្រះថេរៈ

យ៉ាងនេះថា ភិក្ខុចាស់រូបនេះ អង្គុយចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគ ដូចគ្នានឹងជន្លត់ឈើ កាលណាហ្ន៎ ព្រះថេរៈដែលជាធម្មកម្មិក ( ធ្វើការទាក់ទងនឹងធម៌ ) នឹងឲ្យភិក្ខុចាស់រូបនេះ ដល់នូវឋានៈនៃអកព្វបុគ្គល ហើយបណ្តេញចេញអំពីពួកគណៈ ព្រោះថា បើមិនមានភិក្ខុរូបនេះក្នុងវិហារនេះសោត ព្រះមានព្រះភាគ ទ្រង់នឹងចរចាជាមួយអញពិតប្រាកដ ។

[ ៦១ ] បទថា **បុរក្ខត្វា បុរក្ខត្វា** ប្រែថា ធ្វើទុកខាងមុខ ធ្វើទុកខាងមុខ គឺធ្វើទុកខាងមុខ មានពាក្យអធិប្បាយថា ហែហមខាងមុខ និងខាងក្រោយ ។ សូម្បីភិក្ខុរូបនេះ ក៏ជាអ្នកចង់បានលាភដូចគ្នា ។ ព្រោះថា ភិក្ខុរូបនេះឃើញភិក្ខុទាំងឡាយ ដែលជាពហុស្សូតចូលស្រុក មួយអន្លើដោយភិក្ខុជាបរិវារ កំពុងថ្វាយបង្គំព្រះចេតិយ និងឃើញឧបាសកទាំងឡាយជ្រះថ្លាព្រោះឃើញគុណធម៌របស់លោកទាំងនោះ សម្តែងអាការរបស់អ្នកជ្រះថ្លាដូច្នោះ ទើបលោកត្រូវការយ៉ាងនេះ ។

បទថា **កុបិតោ** ប្រែថា មិនត្រេកអរហើយ សេចក្តីថា ភិក្ខុរូបនេះអាក់អន់ព្រោះហេតុ ២ ស្ថាន គឺអាក់អន់ចំពោះភិក្ខុទាំងឡាយផង ព្រះថេរៈផង ។

សួរថា ក្រោធខឹងភិក្ខុទាំងឡាយដូចម្តេច ឆ្លើយថា ក្រោធខឹងនឹងភិក្ខុទាំងឡាយយ៉ាងនេះថា ភិក្ខុទាំងនេះ កាន់យកចំពោះចីវរ ឬបិណ្ឌបាតដែលកើតឡើងដល់អញនោះ បរិភោគ តែបុគ្គលមកខាងក្រោយ ទទួលបាត្រចីវររបស់អញក៏មាន ។

សួរថា អាក់អន់នឹងព្រះថេរៈដូចម្តេច ឆ្លើយថា អាក់អន់នឹងព្រះថេរៈថា

ព្រះថេរៈកញ្ចាស់នេះ ប្រាកដខ្ជួនក្នុងទីនោះៗ កាលណាហ្ន៎ ព្រះធម្មកម្មិកនឹង ទាញលោកចេញទៅ បើមិនមានព្រះថេរៈកញ្ចាស់នេះទេ ភិក្ខុទាំងឡាយនឹង ចោមរោមអញតែម្នាក់ប៉ុណ្ណោះ ។

[ ៦២ ] បទថា **ភត្តគ្គេ** ប្រែថា រោងឆាន់ គឺទីកន្លែងសម្រាប់ឆាន់ ។

បទថា **អគ្គាសនំ** ប្រែថា ទីអង្គុយជាន់ខ្ពស់ គឺទីអង្គុយសម្រាប់ព្រះ-សង្ឃត្ថេរ ។ បទថា **អគ្គោទកំ** ប្រែថា ទឹកដ៏ប្រសើរ គឺទក្ខិណោទក ( ទឹក ដែលប្រគេនដោយសេចក្ដីគោរព ) ។

បទថា **អគ្គបិណ្ឌំ** ប្រែថា បិណ្ឌបាតដ៏ប្រសើរ គឺបិណ្ឌបាតសម្រាប់ ព្រះសង្ឃត្ថេរ ។ ម្យ៉ាងទៀត ក្នុងទីគ្រប់អន្លើ ពាក្យថា **អគ្គ** នេះ ជាពាក្យ ប្រើហៅវត្ថុដែលប្រណីត ។

បណ្ដាការប្រាថ្នាទាំង ២ យ៉ាងនេះ ការប្រាថ្នាថា អាត្មាអញប៉ុណ្ណោះគួរ បានដូច្នេះ មិនមានទោសធ្ងន់ប៉ុន្មានទេ ។ តែការប្រាថ្នាថា ភិក្ខុដទៃមិនគួរ បាន ដូច្នេះ មានទោសធ្ងន់ ។

ភិក្ខុដែលត្រូវការលោករូបនេះ ជាបុគ្គលគួរជ្រះថ្លា ដោយការគ្រងចីវរ ជាដើម ជួនកាលក៏បួស ជួនកាលក៏សឹក ព្រោះហេតុនោះ ក្នុងកាលខាង ក្រោយ លោកមិនបានអាសនៈជាដើមដែលខ្លួនធ្លាប់អង្គុយមកហើយក្នុងកាល មុន ទើបគិតយ៉ាងនេះថា ភិក្ខុនោះមិនគួរបាន ។ ភិក្ខុរូបនោះ កាលអគ្គ-អាសនៈជាដើមត្រូវបានព្រះថេរៈទាំងឡាយ សម្រាប់មជ្ឈិមភិក្ខុ និងនវកភិក្ខុ ដទៃក៏ទំនងដូចគ្នានោះ ជួនកាលក៏បានទីអង្គុយធម្មតា សាមញ្ញ ឬអាសនៈ

ទាបជាងអាសនៈទាំងអស់ ឬមិនបានសោះ ។

បទថា **កុបិតោ** គឺភិក្ខុរូបនោះឯង អាក់អន់ ព្រោះហេតុ ២ ស្ថាន គឺ អាក់អន់មនុស្សទាំងឡាយផង ព្រះថេរៈទាំងឡាយផង ។

សួរថា អាក់អន់នឹងមនុស្សទាំងឡាយដូចម្តេច ឆ្លើយថា អាក់អន់នឹងមនុស្សទាំងឡាយយ៉ាងនេះថា មនុស្សទាំងនេះអាស្រ័យអញ ទើបបានភិក្ខុទាំងឡាយមកក្នុងការងារមង្គលជាដើម ក្នុងកាលមុន មនុស្សទាំងនោះនាំគ្នាពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់មេត្តានាំភិក្ខុចំនួនប៉ុណ្ណេះ ទៅធ្វើសេចក្តីអនុគ្រោះដល់យើងខ្ញុំចុះ តែឥឡូវនេះ បាននាំព្រះថេរៈកញ្ចាស់ដោយគ្រាន់តែបានឃើញមួយភ្លែតទៅ ណ្ហើយចុះ រឿងនេះ តទៅកាលកិច្ចរបស់មនុស្សទាំងនេះកើតឡើង អញនឹងដឹង ។

សួរថា អាន់អន់នឹងព្រះថេរៈដូចម្តេច ឆ្លើយថា អាក់អន់នឹងព្រះថេរៈយ៉ាងនេះថា បើធម្មតា មិនមានព្រះថេរៈនេះសោត មនុស្សទាំងឡាយនឹងនិមន្តចំពោះអញប៉ុណ្ណោះ ។

[ ៦៣ ] បទថា **អនុមោទេយ្យំ** ប្រែថា អនុមោទនា គឺគួរធ្វើអនុមោទនា ។ សូម្បីភិក្ខុរូបនេះ ជាអ្នកត្រូវការលាភ ដឹងការអនុមោទនាបន្តិចបន្តួច បែបធម្មតាៗ ។ លោកគិតប្រាថ្នាយ៉ាងនេះថា ក្នុងទីអនុមោទនាមេផ្ទះនឹងនាំគ្នាមកច្រើន បុគ្គលទាំងនោះ ចាំអាត្មាអញបានហើយ តទៅនឹងថ្វាយកត្តាហារ ជាថាសៗ ។

បទថា **ឋានំ** សេចក្តីថា ការអនុមោទនាជាភារៈនៃភិក្ខុទាំងឡាយជា

ពហុស្សូត ព្រោះដូច្នោះ ទើបលោកអធិប្បាយទុកថា ភិក្ខុជាពហុស្សូតគួរអនុមោទនា ។ បទថា **កុបិតោ** ដោយអត្ថថា ភិក្ខុរូបនេះឯង ក្រោធអាក់អន់ ព្រោះហេតុ ៣ ស្ថាន គឺក្រោធអាក់អន់នឹងមនុស្សទាំងឡាយ ១ ក្រោធអាក់អន់នឹងព្រះថេរៈ ១ ក្រោធអាក់អន់នឹងព្រះធម្មកឋិក ១ ។

សួរថា អាក់អន់នឹងមនុស្សទាំងឡាយដូចម្ដេច ឆ្លើយថា អាក់អន់នឹងមនុស្សទាំងឡាយយ៉ាងនេះថា កាលមុន មនុស្សទាំងនេះ ចូលមករកអញតែម្នាក់ ហើយនិមន្តថា សូមនិមន្តព្រះនាគត្ថេររបស់យើងទាំងឡាយអនុមោទនា សូមនិមន្តលោកម្ចាស់សុមនត្ថេររបស់យើងទាំងឡាយអនុមោទនា តែថ្ងៃនេះមិននិយាយដូច្នោះ ។

សួរថា អាក់អន់នឹងព្រះថេរៈដូចម្ដេច ឆ្លើយថា អាក់អន់នឹងព្រះថេរៈនេះថា ព្រះសង្ឃត្ថេររូបនេះមិនពោលថា អ្នកទាំងឡាយ ចូរនាំគ្នាទៅរកព្រះនាគត្ថេរ ព្រះសុមនត្ថេរ ដែលជាភិក្ខុប្រចាំត្រកូលរបស់អ្នកទាំងឡាយ លោកនឹងអនុមោទនា ។

សួរថា អាក់អន់នឹងព្រះធម្មកឋិកដូចម្ដេច ឆ្លើយថា អាក់អន់នឹងព្រះធម្មកឋិកយ៉ាងនេះថា គ្រាន់តែព្រះថេរៈពោលចប់ប៉ុណ្ណោះ ហាក់ដូចជារុករានដូចមាន់ត្រូវវាយ បុគ្គលនឹងត្រូវអូសទាញភិក្ខុរូបនេះចេញទៅក៏មិនមាន ព្រោះថា បើមិនមានភិក្ខុរូបនេះ អញតែម្នាក់ប៉ុណ្ណោះត្រូវអនុមោទនា ។

[ ៦៤ ] បទថា **អារាមគតានំ** ប្រែថា អ្នកមកកាន់អារាម គឺអ្នកប្រជុំគ្នានៅក្នុងវិហារ ។

ភិក្ខុរូបនេះ អ្នកមានសេចក្តីត្រូវការលោក ចេះធម្មកថា បន្តិចបន្តួច បែបធម្មតាៗ លោកឃើញភិក្ខុទាំងឡាយ ជាអ្នកអង្គុយប្រជុំគ្នាស្តាប់ធម៌ អស់រាត្រីជានិច្ច មានចម្ងាយ ២-៣ រយយោជន៍ក្នុងទីដូច្នោះ នាំគ្នាពេញចិត្តនោះឯង ឬឃើញភិក្ខុកំលោះក្តី សាមណេរក្តី កំពុងឲ្យសាធុការដោយសំឡេងខ្លាំងថា សាធុ សាធុ ឧបាសក ឧបាសិកាទាំងឡាយ នាំគ្នាសួរភិក្ខុទាំងឡាយដែលទៅក្នុងស្រុកក្នុងថ្ងៃទី ២ បន្ទាប់អំពីនោះថា បពិត្រលោកម្ចាស់ ភិក្ខុពួកណាសម្តែងធម៌ ភិក្ខុទាំងនោះពោលថា អង្គនោះៗ មនុស្សទាំងឡាយបានឮដូច្នោះហើយ ជ្រះថ្លា នាំគ្នាធ្វើសក្ការៈដល់ព្រះធម្មកថិកច្រើន ។ ភិក្ខុនោះកាលប្រាថ្នាលាភនោះ តែងគិតយ៉ាងនេះ ។

បទថា **ឋានំ** សេចក្តីថា ការសម្តែងធម៌ទេសនា ជាការៈរបស់ភិក្ខុទាំងឡាយ ដែលជាពហូសូត ជាអ្នកឈ្លាសក្នុងការវិនិច្ឆ័យ ព្រោះហេតុនោះ ទើបមានពាក្យអធិប្បាយថា ភិក្ខុដែលជាពហូសូតគួរសម្តែងធម៌ ។

បទថា **កុបិតោ** ( អាក់អន់ហើយ ) សេចក្តីថា កាលមិនបានឱកាស ពោលត្រឹមតែគាថាដែលប្រកបដោយ ៤ បទ ក៏ក្រោធអាក់អន់ខ្លួនឯង ដែលជាបុគ្គលល្ងង់ថា ព្រោះអញល្ងង់ខ្លៅ ខ្សោយបញ្ញា ពេលណានឹងបានសម្តែងធម៌ ។

[ ៦៥ ] បទថា **ភិក្ខុនីនំ** សេចក្តីថា ដល់ភិក្ខុនីទាំងឡាយដែលមកកាន់អារាម ហើយប្រជុំគ្នាដើម្បីឱវាទ ដើម្បីឧទ្ទេស ដើម្បីការសាកសួរ ឬដើម្បីធ្វើការបូជា ។

សូម្បីភិក្ខុដែលត្រូវការលាភរូបនេះ មានការគិតយ៉ាងនេះថា ភិក្ខុនីទាំងនេះ ចេញបួសពីត្រកូលធំ កាលពួកនាងចូលទៅអន្តរយក្នុងត្រកូលទាំង-ឡាយ មនុស្សទាំងឡាយនឹងនាំគ្នាសួរថា អ្នកនាងម្ចាស់ទាំងឡាយ នាំគ្នាទទួលឱវាទក្តី ឧទ្ទេសក្តី បរិបុច្ឆាក្តី ក្នុងសម្នាក់របស់អ្នកណា ការសាកសួរនោះ ភិក្ខុនីទាំងឡាយនឹងប្រាប់ថា លោកម្ចាស់ឈ្មោះនោះ ជាពហូសូត អ្នកទាំងឡាយ ចូរប្រគេនទេយ្យធម៌ ធ្វើសក្ការៈដល់លោក ព្រោះហេតុនោះ ទើបសេចក្តីត្រូវការយ៉ាងនេះ កើតឡើងដល់លោក ។

បទថា **ឋានំ** សេចក្តីថា ជាធម្មតាកិច្ចវត្ត មានការឲ្យឱវាទជាដើមជាភារៈនៃភិក្ខុទាំងឡាយ ដែលជាពហូសូត ព្រោះដូច្នោះ ទើបលោកពោលអធិប្បាយទុកថា ភិក្ខុដែលជាពហូសូតគួរសម្តែង ។

បទថា **កុបិតោ** អធិប្បាយថា ភិក្ខុនេះ ក្រោធអាក់អន់ ព្រោះហេតុ ២ ស្ថាន គឺក្រោធអាក់អន់នឹងភិក្ខុនីទាំងនេះថា ភិក្ខុនីទាំងនោះ ពីមុនអាស្រ័យអញ ទើបបានឧបោសថ និងបវារណាជាដើម តែឥឡូវនេះ ភិក្ខុនីទាំងនោះបានទៅកាន់សម្នាក់របស់ព្រះថេរៈកញ្ចាស់ ដែលគ្រាន់តែឃើញមួយស្របក់ និងក្រោធអាក់អន់ព្រះធម្មកថិកថា ព្រះធម្មកថិកអង្គនេះ បានឲ្យឱវាទដល់ភិក្ខុនីទាំងនោះ លឿនរហ័សដូចគ្នា ។

បទថា **ឧបាសកានំ** ប្រែថា ដល់ឧបាសកទាំងឡាយ អធិប្បាយថា ធម្មតាឧបាសកទាំងឡាយដែលទៅវត្ត ជាឧបាសកធំ លះបង់ការងារហើយឧបាសកទាំងនោះប្រគល់ការងារឲ្យកូន ប្អូន ហើយត្រាច់ទៅស្តាប់ធម៌ ។ ភិក្ខុ

រូបនេះត្រូវការសម្ដែងធម៌ដល់ឧបាសកទាំងនោះ ព្រោះហេតុអ្វី ព្រោះមនុស្សទាំងនេះជ្រះថ្លាក្នុងភិក្ខុទាំងនេះហើយ នឹងប្រាប់ឲ្យឧបាសិកាទាំងឡាយជ្រាបផងដែរ តទៅនឹងដេរដាសដោយឧបាសិកាទាំងឡាយ នាំគ្នានាំលាភ និងសក្ការៈមកប្រគេនអញតែម្នាក់ ព្រោះដូច្នោះ គួរប្រកបបឋានៈចូលជាមួយអ្នកដទៃជាពហុស្សូតផងដែរ ។

បទថា **កុបិតោ** មានអត្ថថា ភិក្ខុរូបនេះ ក្រោធអាក់អន់ព្រោះហេតុ ២ ស្ថាន គឺក្រោធអាក់អន់នឹងឧបាសកទាំងឡាយថា ឧបាសកទាំងនោះស្ដាប់ធម៌ក្នុងទីដទៃ មិនមកវត្តអញ ដោយការតាំងចិត្តថា ពួកគាត់នឹងស្ដាប់ធម៌ក្នុងសម្នាក់របស់ភិក្ខុប្រចាំត្រកូលរបស់ពួកគាត់ សេចក្ដីនោះ ណ្ហើយចុះ តទៅយើងនឹងដឹងក្នុងកាលដែលពួកគាត់មានកិច្ចកើតឡើង និងក្រោធអាក់អន់នឹងព្រះធម្មកថិកថា លោករូបនេះ សម្ដែងធម៌ឲ្យមនុស្សទាំងនេះស្ដាប់ ។

បទថា **ឧបាសិកានំ** សេចក្ដីថា ធម្មតាឧបាសិកាទាំងឡាយដែលមកវត្តបានប្រជុំគ្នាដើម្បីក្រាលអាសនៈ និងធ្វើការបូជាជាដើម ឬដើម្បីស្ដាប់ធម៌ក្នុងថ្ងៃឧបោសថ ។ ពាក្យដ៏សេស ក្រៅអំពីបានអធិប្បាយហើយ មានន័យដូចបានពោលហើយ ក្នុងវគ្គនៃឧបាសកនោះឯង ។

[ ៦៦-៦៧ ] បទថា **សក្កច្ចំ** គឺគួរធ្វើដោយគោរពផង ដោយធ្វើឲ្យល្អផង ។ ពាក្យថា គួរសក្ការៈនេះ លោកប្រាថ្នាការដែលនឹងធ្វើក្នុងខ្លួនដោយគោរព និងដោយល្អ ។

បទថា **គរុករេយ្យុំ** ប្រែថា គួរធ្ងន់ គួរធ្វើឲ្យធ្ងន់ ។ ដោយពាក្យថា គួរ

ធ្ងន់នេះ លោកប្រាថ្នាឲ្យភិក្ខុទាំងឡាយ តាំងខ្លួនលោកទុកក្នុងឋានៈជាគ្រូ ។

បទថា **មានេយ្យោ** ប្រែថា គួររាប់អាន គឺគួរស្រឡាញ់ ។

បទថា **បូជេយ្យោ** ប្រែថា គួរបូជា សេចក្ដីថា លោកប្រាថ្នាការបូជាដោយបច្ច័យថា មនុស្សទាំងឡាយ កាលធ្វើសក្ការៈគោរពរាប់អានអញក៏ត្រូវ បូជាអញផង ដោយបច្ច័យទាំងឡាយយ៉ាងនេះ ។

បទថា **ឋានំ** សេចក្ដីថា ភិក្ខុជាពហុស្សូត និងជាអ្នកមានសីល មានប្រការដូចដែលពោលមកហើយថា ជាទីស្រឡាញ់ ជាទីគោរព ជាទីរាប់អានសមគួរនឹងវិធីនេះ ព្រោះដូច្នោះ ទើបលោកអធិប្បាយទុកថា ភិក្ខុទាំងឡាយគួរធ្វើបែបនេះ គឺធ្វើយ៉ាងនេះ ។

បទថា **កុបិតោ** សេចក្ដីថា ភិក្ខុរូបនេះក្រោធអាក់អន់ព្រោះហេតុ ២ ស្ថាន គឺក្រោធអាក់អន់ភិក្ខុទាំងឡាយថា ភិក្ខុទាំងនេះធ្វើសក្ការៈភិក្ខុនោះ និងក្រោធអាក់អន់ជាមួយព្រះថេរៈថា កាលមិនមានព្រះថេរៈរូបនេះ ភិក្ខុទាំង-ឡាយ នឹងត្រូវធ្វើសក្ការៈអញតែម្នាក់ប៉ុណ្ណោះ ។ ក្នុងវារៈដទៃ ៣ វារៈទៀតបន្ទាប់អំពីនេះ ក៏មានន័យនេះ ។

[ ៦៨ ] បទថា **បណីតានំ ចីវរានំ** បានដល់ សំពត់ចីវរដែលមានតម្លៃថ្លៃសាច់ម៉ដ្ឋ មានសម្ផស្សទន់ល្អ មានសំពត់ធម្មតា សំពត់សម្បកឈើសំពត់ សូត្រដែលសម្លាប់ហើយ និងសំពត់សូត្រធម្មតាជាដើម ។

ការប្រាថ្នាថា អញប៉ុណ្ណោះគួរមានលាភ មិនឈ្មោះថា មានទោសច្រើនក្នុងទីនេះឡើយ តែមានទោសច្រើន គឺសេចក្ដីត្រូវការថា សូមកុំឲ្យអ្នកដទៃ

មានលាភ ។

[ ៦៩ ] បទថា **បណីតានំ បិណ្ឌបាតានំ** គឺបិណ្ឌបាតដែលល្អបំផុតដល់ព្រម ដោយរសសប្បិ រសប្រេង និងរសសាច់ជាដើម ។

បទថា **បណីតានំ សេនាសនានំ** គឺសេនាសនៈ មានគ្រែ និងតាំងជាដើម ដែលមានតម្លៃច្រើនសែន ។ បទថា **បណីតានំ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារានំ** គឺថ្នាំជាន់ខ្ពស់ មានសប្បិ ប្រេង ទឹកឃ្មុំ ទឹកអំពៅជាដើម ។ គ្រប់វារៈគួរប្រកបហេតុ ជាឋានៈចូលជាមួយដោយភាពជាពហូសូត និងបុគ្គលមានបុណ្យទាំងឡាយ ។

បទថា **កុបិតោ** បានដល់ ក្រោធអាក់អន់ព្រោះហេតុ ២ ស្ថាន គឺអាក់អន់នឹងមនុស្សទាំងឡាយថា ដែលឈ្មោះថា មនុស្សទាំងនេះមិនមានការអប់រំសន្សំបុព្វបារមីសោះ អញនៅរួមមកអស់កាលដ៏យូរ សូម្បីដើរទៅតាមលំដាប់ផ្ទះ ដើម្បីត្រូវការសំពត់បង្សុកូល ឬដើម្បីត្រូវការបិណ្ឌបាតក្តី ព្រោះហេតុនៃសប្បិ និងប្រេងក្តី មនុស្សទាំងនេះក៏មិនប្រគេនបច្ច័យ ៤ ដែលប្រណីតណាមួយ សូម្បីតែមួយថ្ងៃ តែលុះឃើញព្រះថេរៈចាស់ ដែលជាអាគន្តុកៈមកប៉ុណ្ណោះ ក៏នាំគ្នាប្រគេនវត្ថុដែលលោកត្រូវការ និងអាក់អន់ព្រះថេរៈយ៉ាងនេះថា ព្រះថេរៈកញ្ចាស់នេះ ត្រាច់បង្ហាញខ្លួនឲ្យមនុស្សទាំងនោះឃើញ កាលណាហ្ន៎ កិក្ខុដែលជាធម្មកម្មិក នឹងអូសទាញលោកចេញទៅ បើមិនមានព្រះថេរៈចាស់នេះ អញតែម្នាក់ប៉ុណ្ណោះត្រូវមានលាភ ។

បទថា **ឥមេសំ ខោ អាវុសោ** ប្រែថា ទាំងនេះឯង ដោយអត្ថថា

អកុសលធម៌ទាំងនេះជាដែនរបស់ឥច្ឆា ដែលបានពោលអំពីខាងដើម ដោយវារៈ ១៩ វារៈ ។

[ ៧០ ] បទថា **ឧិស្សន្តិ ចេវ សុយ្យន្តិ ច** ប្រែថា កំពុងឃើញ និងកំពុងបានឮ ដោយអត្ថថា បាបអកុសលដែលជាឥច្ឆាវចរ គឺជាដែនរបស់ឥច្ឆា មិនមែនឃើញបានដោយចក្ខុ មិនមែនបានឮដោយសោតៈ ។ តែកាលបានឃើញ កាយកម្មនៃបុគ្គលដែលមិនទាន់លះបាបអកុសលដែលជាជាឥច្ឆា-វចរមិនទាន់បាន ដែលប្រព្រឹត្តទៅហើយដោយអំណាចនៃអកុសលដែលជាឥច្ឆាវចរ ក៏ដូចគ្នានឹងបានឃើញហើយ កាលបានឮវចីកម្មនៃបុគ្គលដែលមិនទាន់លះបាននូវបាបអកុសលដែលជាឥច្ឆាវចរ ដែលប្រព្រឹត្តទៅដោយអំណាចកុសលដែលជាឥច្ឆាវចរក៏ដូចគ្នា នឹងបានឮហើយ ព្រោះជាអារម្មណ៍របស់មនោវិញ្ញាណ ព្រោះដូច្នោះ ទើបព្រះសារីបុត្របានពោលទុកថា កំពុងឃើញនិងកំពុងបានឮ អធិប្បាយថា ឃើញអស់កាលដែលនៅប្រចក្ស បានឮក្នុងវេលាដែលកន្លងមកហើយថា ភិក្ខុរូបនោះ ក៏ដូចរូបនេះ ។

បទថា **កិញ្ចាបិ** ជាដើម ជាការពោលសរសើរ និងការនិន្ទា ។ ដោយពាក្យនោះ លោកសរសើរការនៅព្រៃជាវត្ត និងនិន្ទាការលះបាបអកុសលដែលជាឥច្ឆាវចរមិនទាន់បាន ។

ក្នុងពាក្យនោះ មានការប្រកបអត្ថដូច្នេះថា ភិក្ខុនោះសូម្បីហាមសេនាសនៈចុងស្រុក នៅក្នុងព្រៃជាប្រចាំ នៅក្នុងសេនាសនៈដែលស្ងប់ត្រង់ជាយដែន ក៏ពិត តែបាបអកុសលដែលជាឥច្ឆាវចរទាំងនេះ គឺប្រមាណប៉ុណ្ណោះ លោកមិន

ទាន់លះបាន សូម្បីលោកបដិសេធលាភដ៏ប្រណីត កាន់បិណ្ឌបាតជាប្រចាំក្តី វៀរការទៅបិណ្ឌបាត មិនជាផ្លូវទៅតាមលំដាប់ប្រកជាប្រក្រតីក្តី បដិសេធចីវរដែលអ្នកស្រុកប្រគេន ប្រើប្រាស់តែចីវរបង្សុកូលជាប្រចាំក្តី ក៏ពិត ( តែលោកក៏មិនទាន់លះបាបអកុសលដែលជាឥច្ឆាវចរទាំងនេះបាន ) ។

ចំណែកពាក្យថា សៅហ្មង ក្នុងពាក្យថា **លូខចីវរធរោ** នេះ គប្បីជ្រាបថា សៅហ្មងព្រោះហេតុ ៣ ប្រការ គឺសៅហ្មងព្រោះសស្ត្រា ១ សៅហ្មងព្រោះអំបោះ ១ សៅហ្មងព្រោះពណ៌ជ្រលក់ ១ ។

ក្នុងចំនួន ៣ យ៉ាងនេះ សំពត់កាត់ឲ្យដាច់ ជាចម្រៀកតូចធំដោយសស្ត្រា ឈ្មោះថា សៅហ្មងព្រោះសស្ត្រា សំពត់នោះនឹងថយតម្លៃ ។

សំពត់ដែលត្បាញដោយអំបោះគ្រោតគ្រាត និងវែង ឈ្មោះថា សៅហ្មងព្រោះអំបោះ សំពត់នោះ មិនគួរប៉ះពាល់ សម្ផស្សរឹង ។

សំពត់ដែលជ្រលក់ដោយពណ៌ គឺទឹកអម្ចត់ ឈ្មោះថា សៅហ្មងព្រោះពណ៌ជ្រលក់ សំពត់នោះនឹងខូចពណ៌ មានពណ៌មិនស្អាត ។

ភិក្ខុនោះទោះគ្រងចីវរ សៅហ្មងព្រោះសស្ត្រា សៅហ្មងព្រោះអំបោះ ឬសៅហ្មងព្រោះពណ៌ជ្រលក់ក៏ពិត តែអកុសលដែលជាឥច្ឆាវចរទាំងនេះលោកមិនទាន់លះបាន បុគ្គលកំពុងឃើញ និងបានឮ ដោយពិតហើយ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈជាមួយគ្នា ដែលជាបញ្ញាជន នឹងមិនធ្វើសក្ការបូជាលោកឡើយ ។

បទថា **តំ** ក្នុងបទថា **តំ កិស្ស ហេតុ** នេះ គ្រាន់តែជានិបាត ។

បទថា **កិស្ស ហេតុ** គឺ **កឹ ការណា** ប្រែថា ព្រោះហេតុអ្វី មានពាក្យអធិប្បាយទុកថា ព្រោះថា អំពើទាំងនោះរបស់លោក កំពុងឃើញច្បាស់ផង ឮច្បាស់ផង គឺព្រោះអកុសលធម៌ដ៏លាមកទាំងនោះរបស់លោក កំពុងឃើញ និងបានឮ ។ ព្រោះអកុសលធម៌ទាំងនេះ ដែលជាឥច្ឆាវចរ លោកមិនទាន់លះបាន ដែលពោលមកនេះ ជាពាក្យអធិប្បាយថា ព្រោះហេតុអ្វីនេះ ។

តទៅនេះព្រះសារីបុត្រ កាលនឹងអធិប្បាយអត្ថនោះឲ្យប្រាកដ ដោយការឧបមា ទើបពោលពាក្យថា **សេយ្យថាបិ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **កុណបំ** ប្រែថា សាកសព បានដល់សាកសពសត្វដែលស្លាប់ហើយ ខ្មោចរបស់ពស់ ឈ្មោះថា សាកសពពស់ ។ ( សាកសពឆ្កែ និងសាកសពមនុស្ស ) ក្រៅអំពីនេះក៏ដូចគ្នា ។

សាកសពទាំង ៣ នេះឯង គប្បីជ្រាបថា ព្រះសារីបុត្រពោលទុកហើយក្នុងពាក្យឧបមានេះ ព្រោះជារបស់បដិកូល និងគួរខ្ពើមរអើមពន់ពេក ។ សេចក្ដីពិត សាកសពរបស់សត្វដទៃ មានសត្វចិញ្ចឹម និងជ្រូកជាដើម មនុស្សទាំងឡាយ ចម្អិនជាមួយគ្រឿងក្ដៅជាដើមទទួលទានក៏មាន តែសាកសពរបស់ឆ្កែ និងមនុស្សទាំងនេះ សូម្បីនៅស្រស់ មនុស្សទាំងឡាយក៏គន់រអើម នឹងពោលថ្វីដល់សាកសពដែលកន្លងកាលវេលាទៅហើយ ដែលស្អុយហើយ មិនចាំបាច់ពោលដល់ឡើយ ។

បទថា **រចយិត្វា** គឺបន្ថែមចូលទៅ ដោយអត្ថថា ដាក់ឲ្យពេញ ។ មានពាក្យអធិប្បាយទុកថា យកសាកសពនោះដាក់ក្នុងថាសសំរឹទ្ធ ។

បទថា **អញ្ញោស្នា** ប្រែថា ដោយថាសសរឹទ្ធដទៃ ។

បទថា **បដិកុជ្ជិត្វា** ប្រែថា គ្រប គឺបិទ ។

បទថា **អន្តរាបណំ** ប្រែថា ចន្លោះផ្សារ គឺទីប្រជុំជនដែលមានមហាជនកុះករក្នុងផ្សារ ។

បទថា **បដិបជ្ជេយ្យុំ** ប្រែថា គប្បីធ្វើដំណើរទៅ គឺគប្បីដើរទៅ ។

បទថា **ជញ្ញជញ្ញំ វិយ** ប្រែថា ហាក់ដូចជាគួរដឹង គួរចាប់ចិត្ត សេចក្តីថា ហាក់ដូចជាទាក់ចិត្ត គឺហាក់ដូចពេញចិត្តពេញថ្លើម ។ មា៉្យងទៀត មានពាក្យអធិប្បាយថា ដូចស្រីក្រមុំនាំគ្រឿងបណ្ណាការមក ។ សេចក្តីពិត ស្រីក្រមុំ គេហៅថា **ជននី** ។ បណ្ណាការដែលស្រីក្រមុំនោះកំពុងនាំមក ជាវត្ថុដែលគួរដឹង ទើបលោកបានពោលត្រួតទុកក្នុងពាក្យទាំងគូ ដោយអំណាចនៃការអើពើខ្លះ ដោយអំណាចនៃការសរសើរខ្លះ ។ បាឋៈថា **ជញ្ញំ ជញ្ញំ វិយ** ដូច្នេះក៏មាន ។ បទថា **អចាបុរិត្វា** ប្រែថា មិនបិទ គឺបើក ។

ពាក្យថា **តស្ស សហ ឧស្សនេន អមនាបតា ច សណ្ឋហេយ្យ** ប្រែថា ការដែលបុគ្គលនោះមិនពេញចិត្តព្រមគ្នានឹងការបានឃើញ គប្បីតាំងឡើងប្រាកដ សេចក្តីថា ការដែលបុគ្គលនោះ មិនពេញចិត្តព្រមនឹងការបានឃើញសាកសពនោះឯង ក៏តាំងឡើងប្រាកដ ។ ពាក្យថា **អមនាបតា** ភាពជាវត្ថុមិនគួរពេញចិត្តនេះ ជាឈ្មោះរបស់ចិត្ត និងចេតសិកដែលកើតឡើងហើយថានេះជាវត្ថុដែលមិនគួរពេញចិត្ត ។ ក្នុងការបដិកូល និងគួរខ្ពើមក៏មានន័យនេះ ។

បទថា **ជិឃច្ឆិតានម្បិ** ប្រែថា សូម្បីបុគ្គលឃ្លានហើយ គឺសូម្បីបុគ្គល

ឃ្លានខ្លាំងហើយ ។ ពាក្យថា **ន ភោត្តុកម្យតា អស្ស** ប្រែថា ត្រូវការនឹងបរិភោគគង់ មិនមាន សេចក្ដីថា មិនមានបំណងនឹងបរិភោគ ។

ក្នុងពាក្យថា **បគេវ សុហិតានំ** ប្រែថា នឹងពោលថ្វីដល់អ្នកឆ្អែតហើយ អធិប្បាយថា សម្រាប់បុគ្គលអ្នកឃ្លាន ក៏គង់មិនមានការចង់បរិភោគទៅហើយ ។ ក្នុងរឿងនោះ មានការប្រៀបធៀបការឧបមាដូចតទៅនេះ គឺបព្វជ្ជាភេទរបស់បុគ្គលនេះ ដូចគ្នានឹងថាសសំរិទ្ធដែលស្អាត កាលលះឥច្ឆាវចរមិនទាន់បាន ដូចគ្នានឹងការដាក់សាកសពទុក ការលាក់បាំងឥច្ឆាវចរទុក ដោយការនៅព្រៃជាប្រចាំជាដើម ដូចការយកថាសសំរិទ្ធដទៃគ្របទុក ការមិនធ្វើសក្ការៈជាដើមរបស់សព្រហ្មចារីទាំងឡាយ ព្រោះឃើញឥច្ឆាវចររបស់លោក ដោយមិនអើពើដល់ធុតង្គ មានអារញ្ញិកង្គធុតង្គជាដើម ដូចការមិនពេញចិត្តរបស់បុគ្គល ព្រោះបើកថាសសំរិទ្ធហើយ ឃើញសាកសព ។

[ ៧១ ] ឯក្នុងធម៌ចំណែកស គប្បីជ្រាបអធិប្បាយដូច្នេះ ពាក្យថា **ករិស្សាមិ** ជាដើម ជាពាក្យលើកស្ទួយផង ជាពាក្យសរសើរផង ដោយពាក្យថា **ករិស្សាមិ** នេះ ព្រះសារីបុត្រសរសើរការនៅព្រៃជាប្រចាំ លើកតម្កើងការលះឥច្ឆាវចរ ។ បទថា **នេមន្តនិកោ** ប្រែថា អ្នកទទួលនិមន្តន៍ គឺបដិគ្គាហកៈដែលទទួលនិមន្តន៍ ។ បទថា **វិចិតកាឡកំ** ប្រែថា សស្អាត គឺប្រាសចាកខ្មៅលាយឡំ ។

ក្នុងពាក្យថា ម្ហូបច្រើនយ៉ាង សម្លច្រើនយ៉ាងនេះ វត្ថុដែលនាំទៅបានដោយដៃ ហៅថា **សូបះ** ពាក្យថា **ព្យញ្ជនំ** គឺសម្ភឧត្តរិភង្គ ។ ដោយពាក្យ

ទាំង ២ នោះ លោកបានពោលពាក្យអធិប្បាយទុកថា សូបៈច្រើនយ៉ាង មាន សូបៈ គឺត្រី សាច់ និងសណ្តែកបាយជាដើម ព្យញ្ជនៈច្រើនប្រភេទ មាន ព្យញ្ជនៈសាច់ច្រើនប្រភេទជាដើម ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យ ដែលពោលហើយនោះ ។ និងគួរជ្រាបអត្ថាធិប្បាយ ក្នុងការប្រៀបធៀប ពាក្យឧបមេយ្យ និងពាក្យឧបមាតទៅ ការលះឥច្ឆាវចរបាន ដូចការរៀបចំ បាយអង្ករស្រូវសាលីដាក់ក្នុងថាសសំរឹទ្ធ ការបិទ គឺការលាក់ឥច្ឆាវចរ ដោយ ការនៅវត្តចុងស្រុកជាដើម ដែលជាសមុដ្ឋាននៃការប្រាថ្នាតិច ដូចការគ្រប ដោយថាសសំរឹទ្ធដទៃ គួរជ្រាបការធ្វើសក្ការៈជាដើមរបស់សព្រហ្មចារី ព្រោះ មិនត្រេកអរការនៅវត្តខាងក្នុងស្រុកជាដើម ហើយលះឥច្ឆាវចរបាន ដូចការ ពេញចិត្តរបស់បុគ្គល ព្រោះបានបើកថាសសំរឹទ្ធឃើញបាយស្រូវសាលីចម្អិន យ៉ាងល្អ ។

[ ៧២ ] ពាក្យថា **ឧបមា មំ អាវុសោ សារីបុត្ត បដិភាតិ** បពិត្រព្រះ សារីបុត្រ ឧបមានេះជាក់ច្បាស់ដល់ខ្ញុំ សេចក្តីថា បពិត្រព្រះសារីបុត្រ ឧបមាប្រាកដដល់ខ្ញុំ អធិប្បាយថា ខ្ញុំបំណងពោលឧបមាមួយប្រគេន ។

បទថា **បដិភាតុ តំ** ប្រែថា សូមជាក់ច្បាស់ដល់លោកម្ចាស់ចុះ គឺចូរ ជាក់ច្បាស់ បានដល់ ប្រាកដដល់លោកម្ចាស់ចុះ អធិប្បាយថា និមន្តពោល ចុះ ។ បទថា **ឥធ** ក្នុងបទថា **ឯកមិធាហំ** ត្រឹមតែជានិបាត ។ មាន ពាក្យអធិប្បាយទុកថា សម័យមួយ ខ្ញុំ ។

បទថា **ឯកំ** នេះ ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថរបស់សត្តមីវិភត្តិ ។ បទ

ថា **រាជគហា** ក្នុងបទថា **រាជគហេ វិហរាមិ គិរិព្វជេ** នេះ ជាឈ្មោះរបស់នគរនោះ ។ នគររាជគ្រឹះ បុគ្គលហៅថា **គិរិព្វជ** ព្រោះតាំងនៅដូចក្រោល ព្រោះមានភ្នំព័ទ្ធជុំវិញ ។ ព្រះមហាមោគ្គល្លានពោលថា ខ្ញុំនៅក្នុងនគរនោះ គឺអាស្រ័យនគរនោះ ។

បទថា **អថាខ្វាហំ** កាត់បទជា **អថ ខោ អហំ** ប្រែថា កាលនោះឯងខ្ញុំ ហើយពាក្យថា **អថ** ក្នុងពាក្យថា **អថខ្វាហំ** នេះ ជានិបាត ប្រើក្នុងពាក្យផ្ដើមដែលពោលរឿងដទៃ ។ សព្ទថា **ខោ** ក៏ជានិបាត ប្រើក្នុងអត្ថត្រឹមតែញ៉ាំងបទឲ្យពេញ ។

បទថា **បុព្វណ្ហសមយំ** ប្រែថា ក្នុងវេលាព្រឹក អធិប្បាយថា វេលាចំណែកខាងដើមរបស់ថ្ងៃ គឺក្នុងពេលព្រឹក ។

ម្យ៉ាងទៀត ពេលខាងដើមនៃថ្ងៃ ឈ្មោះថា បុព្វណ្ហសម័យ អធិប្បាយថា មួយជួរខណៈក្នុងពេលព្រឹក ។ ដោយអាការយ៉ាងនេះ នឹងបានទុតិយាវិភត្តិក្នុងអច្ចន្តសំយោគ ។

បទថា **និវាសេត្វា** ប្រែថា ស្លៀកហើយ គឺគ្រងសំពត់ហើយ ពាក្យថាស្លៀកហើយនោះ គប្បីជ្រាបដោយអំណាចនៃការផ្លាស់ប្ដូរសំពត់ក្នុងវត្តនោះឯង ។ ម្យ៉ាងទៀត គប្បីជ្រាបដោយអំណាចនៃការឈរស្លៀក ដើម្បីនឹងចូលស្រុក មិនមែនពោលអំពីមុននេះថា លោកមិនបានស្លៀកនោះឡើយ ។

បទថា **បត្តចីវរមាទាយ** ប្រែថា កាន់យកបាត្រ និងចីវរ ដោយអត្ថថា ដៃកាន់បាត្រ រាងកាយគ្រងចីវរ ។ បទថា **បិណ្ឌាយ** ប្រែថា ដើម្បីបិណ្ឌបាត

សេចក្តីថា ដើម្បីបិណ្ឌបាត ។ បទថា **សមិតិ** ជាឈ្មោះបុត្ររបស់ជាងរថម្នាក់ ។ បទថា **យានការបុត្តោ** ប្រែថា កូនរបស់ជាងយាន គឺកូនរបស់ជាងរថ ។ បទថា **បណ្ឌុបុត្តោ** បានដល់ កូនរបស់អ្នកបួសត្រងោល ។

បទថា **អាជីវកោ** បានដល់ អ្នកបួសអាក្រាត ។

បទថា **បុរាណយានការបុត្តោ** ប្រែថា កូនរបស់ជាងរថអំពីបុរាណ បានដល់ កូនរបស់ត្រកូលជាងយានបុរាណ ។

បទថា **បច្ចុបដ្ឋិតោ** ប្រែថា ប្រាកដខ្លួន គឺ ចូលទៅឈរមើល ។ កោងម្ខាង ឈ្មោះថា **វង្គំ** ។ វៀចដូចជានពស់លូន ឈ្មោះថា **ជិម្ហំ** ។

បទថា **ទោសំ** ប្រែថា ទោស បានដល់ ក្រមរ និងកំញម ដែលរដិបរដុបជាដើម ។

បទថា **យថា យថា** ជានិបាត ប្រើក្នុងអត្ថបញ្ជាក់ដល់កាលវេលា មានពាក្យអធិប្បាយថា កាលណាមួយ គឺក្នុងកាលណាមួយ ។

បទថា **តថា តថា** នេះ ក៏មានអត្ថចង្អុលដល់កាលដូចគ្នា ។ មានពាក្យអធិប្បាយទុកថា ក្នុងកាលនោះៗ ។ អាជីវកនោះ គិតដោយអនុលោមតាមដែលបានសិក្សាមកអំពីបុគ្គលម្នាក់ទៀត គឺនាយសមិតិចាំងត្រង់ទីអាជីវកគិតនោះឯង ក្នុងខណៈដែលគាត់គិត ។

បទថា **អត្តមនោ** ប្រែថា ពេញចិត្ត គឺត្រូវចិត្តខ្លួន បានដល់ សប្បាយចិត្ត ដោយអត្ថថា មានបីតិ និងសោមនស្សជាប់ចិត្ត ។

បទថា **អត្តមនវាចំ និច្ឆារេសិ** ប្រែថា បន្លឺវាចាសម្តែងការពេញចិត្ត គឺ

បន្ទឹវាចា បានដល់ ពោល អធិប្បាយថា បញ្ចេញវាចាដោយការត្រេកអរ ឬ វាចាដែលគួរដល់ការពេញចិត្ត ។

ពាក្យថា **ហទយា ហទយំ មញ្ញេ អញ្ញាយ** ប្រែថា ហាក់ដូចដឹងចិត្តដោយចិត្ត សេចក្ដីថា ហាក់ដូចជាដឹងចិត្តយើងដោយចិត្តគេ ។

បទថា **អស្សទ្ធា** គឺប្រាសចាកការជឿក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ បទថា **ជីវិកត្ថា** ប្រែថា ជាអ្នកចិញ្ចឹមជីវិត គឺត្រូវភ័យ មានបំណុលជាដើមគ្របសង្កត់ មិនអាចតាំងជីវិតខាងក្រៅបាន ទើបត្រូវចិញ្ចឹមជីវិតក្នុងសាសនានេះ ។ បទថា **ន សទ្ធា** គឺមិនបានបួសដោយសទ្ធា ។

បទថា **សឋា មាយាវិនោ** ប្រែថា ជាបុគ្គលអួតមានមាយា គឺប្រកបដោយមាយាសាថេយ្យ ។

បទថា **កេដុភិនោ** ប្រែថា ជាអ្នកបោកបញ្ឆោត គឺជាអ្នកបានសិក្សាល្បិចកលទុច្ចរិតមកហើយ មានពាក្យអធិប្បាយថា ជាអ្នកសម្រេចការអួតអាងតាមកម្លាំង ។ អធិប្បាយថា ការអួត លោកហៅថា **កេរាដិយ** ( ល្បិចកោង ) ព្រោះធ្វើព្រមគ្នាទៅជាមួយការសម្ដែងគុណតម្លៃនៃវត្ថុមិនពិត ដោយការសម្ដែងគុណវិសេសដែលមិនមានពិត ។

បទថា **ឧន្នឡា** ប្រែថា ប្រកាន់ខ្លួន គឺលើកខ្លួនឡើង មានពាក្យអធិប្បាយថា លើកមានះទទេឡើង ។

បទថា **ចបលា** ប្រែថា ឃ្លេងឃ្លោង គឺប្រកបដោយការឃ្លេងឃ្លោងមានការតាក់តែងបាត្រ និងចីវរជាដើម ។

បទថា **មុខរា** ប្រែថា មាត់រឹង គឺមាត់រឹង អធិប្បាយថា មានវាចារឹង ។

បទថា **វិកិណ្ណវាចា** ប្រែថា មានសម្តីផ្តេសផ្តាស គឺមានវាចាមិនសង្រួម បានដល់ និយាយអស់មួយថ្ងៃ ក៏មានតែពាក្យឥតប្រយោជន៍ ។

បទថា **ឥន្ទ្រិយេសុ អគុត្តទ្វារា** ប្រែថា មានទ្វារមិនបានគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ គឺមានទ្វារសម្រាប់ធ្វើកម្មមិនបានរវាំងប្រយ័ត្នហើយ ក្នុងឥន្ទ្រិយទាំង ៦ ។

បទថា **ភោជនេ អមត្តញ្ញុនោ** ប្រែថា មិនស្គាល់ប្រមាណក្នុងការបរិភោគ គឺមិនដឹងប្រមាណក្នុងការបរិភោគ ដែលល្មមឲ្យរាងកាយប្រព្រឹត្តទៅបាន គឺភាពជាបុគ្គលមានការសមគួរ ក្នុងការស្វែងរកការទទួល និងបរិភោគដែលគួរដឹង ។

បទថា **ជាគរិយំ អននុយុត្តា** ប្រែថា មិនប្រកបព្យាយាមជាគ្រឿងភ្ញាក់រឭក គឺមិនប្រកបព្យាយាមដែលធ្វើឲ្យខ្លួនភ្ញាក់រឭក ។

បទថា **សាមញ្ញេ អនបេក្ខវន្តោ** ប្រែថា មិនសម្លឹងមើលសមណភាវៈ មានអធិប្បាយថា មិនសម្លឹងមើលសមណធម៌ គឺវៀរចាកការប្រតិបត្តិធម៌សមគួរដល់ធម៌ ។

បទថា **សិក្ខាយ ន តិព្វគារវា** ប្រែថា មិនគោរពយ៉ាងខ្លាំងក្លាក្នុងសិក្ខា គឺ មិនមានការគោរពច្រើនក្នុងសិក្ខាបទទាំងឡាយ បានដល់ ច្រើនទៅដោយការត្រូវអាបត្តិ ។

បទថា **ពាហុលិកា** ប្រែថា ល្មោភក្នុងបច្ច័យជាដើម ខ្ញុំបានពោលទុក

ហើយក្នុងអដ្ឋកថាធម្មទាយាទសូត្រ ។ បទថា **កុសីតា** ប្រែថា ខ្ជិលច្រអូស ជាដើម ខ្ញុំបានពោលទុកហើយក្នុង អដ្ឋកថាភយភេរវសូត្រ ។

បទថា **ធម្មបរិយាយេន** ប្រែថា ដោយធម្មបរិយាយ គឺដោយធម្ម-ទេសនា ។ បទថា **សទ្ធា អគារស្មា** ប្រែថា មានសទ្ធាចេញបួសចាកផ្ទះជាដើម មានអត្ថថា តាមប្រក្រតី អ្នកបួសដោយសទ្ធា ឈ្មោះថា ជាអ្នកមានសទ្ធាចេញចាកផ្ទះ បួសជាអនាគារិយបុគ្គល គឺបុគ្គលមិនមានផ្ទះ ។

ពាក្យថា **បិវន្តិ មញ្ញេ យសន្តិ មញ្ញេ** ប្រែថា គង់នឹងផឹក គង់នឹងបរិភោគ ដោយអត្ថថា ហាក់ដូចបានក្រេបផឹក ហាក់ដូចបានលេប គឺកាលបន្លឺវាចា ដោយការពេញចិត្ត ក៏ដូចគ្នានឹងផឹកដោយវាចា កាលអនុមោទនាក្រៃលែងឡើង ក៏ហាក់ដូចជាបរិភោគដោយចិត្ត ។

បទថា **សាធុ វត** គឺ សាធុ លោកម្ចាស់ ។

បទថា **សព្រហ្មចារី** ជាវស្សៈក៏បាន ជាទីឃៈក៏បាន បើជាវស្សៈ ខាងមុខមាន **សារីបុត្ត** បើជាទីឃៈ ខាងមុខមាន **សព្រហ្មចារី** កាលណាខាងមុខមាន **សារីបុត្ត** កាលនោះនឹងមានអត្ថថា នៃសព្រហ្មចារី ព្រះសារីបុត្រឲ្យយើងទាំងឡាយចេញចាកអកុសលហើយ ។ កាលណាមានសព្រហ្មចារីនៅខាងមុខ កាលនោះមានអត្ថថា ព្រះសារីបុត្រ ឲ្យសព្រហ្មចារីទាំងឡាយចេញចាកអកុសល ហើយតាំងនៅក្នុងធម៌ ។

បទថា **ទហរោ** គឺនៅកំលោះ ។ បទថា **យុវា** គឺនៅក្នុងវ័យកំលោះក្រមុំ ។ បទថា **មណ្ឌនកជាតិកោ** ប្រែថា មានជាតិជាអ្នកចូលចិត្តតែង

ខ្លួន សេចក្តីថា មានសភាពចូលចិត្តគ្រឿងតែងខ្លួន គឺមានប្រក្រតីតែងខ្លួន ។

បណ្តាជនទាំង ២ ប្រភេទនោះ ជនដែលដល់នូវភាពជំទង់ តែនៅមិនទាន់កំលោះក្រមុំ ដូចបុគ្គលកំលោះក្រមុំ តែបុគ្គលខ្លះដល់នូវភាពជាកំលោះក្រមុំ ក៏មិនចូលចិត្តតែងខ្លួន ដូចបុគ្គលដែលមានការស្ងប់ជាសភាវៈ ឬត្រូវការខ្ជិលប្រអូស ឬការវិនាសគ្របសង្កត់ ឯក្នុងទីនេះ បំណងយកបុគ្គលទាំងជំទង់ ទាំងកំលោះ ក្រមុំ និងចូលចិត្តតែងខ្លួន ព្រោះដូច្នោះ ទើបព្រះមហាមោគ្គល្លានពោលយ៉ាងនេះ ។ ពាក្យថា ប្រកាន់ខ្លួនជាដើម លោកពោលទុកព្រោះជាលោកសម្មតិ ។

បទថា **ឥតិហ តេ ស្មិគ្នានីង ឯវំ តេ** ប្រែថា ដោយប្រការដូចពោលមកហើយនោះ លោកទាំង ២ នោះ ... ។

បទថា **ឧភោមហានាគា** ប្រែថា មហានាគទាំងគូ សំដៅដល់បុគ្គលជាធំក្រៃលែងទាំង ២ អង្គ ។ ព្រោះថា អគ្គសាវកទាំង ២ អង្គនេះ ពុទ្ធបរិសទ្យ ទាំងឡាយហៅថា **មហានាគ** ។

ក្នុងពាក្យថា **មហានាគ** នោះ មានអត្ថវចនៈដូច្នេះ បុគ្គលមិនលំអៀងដោយអគតិទាំងឡាយ មានឆន្ទាគតិជាដើម ឈ្មោះថា **នាគ** ។

បុគ្គលមិនត្រឡប់មកកាន់កិលេស ដែលលះបានដោយមគ្គនោះហើយ ឈ្មោះថា **នាគ** ។ បុគ្គលមិនធ្វើបាប មានប្រការផ្សេងៗ ឈ្មោះថា **នាគ** ។

នេះជាអត្ថដោយសង្ខេបក្នុងពាក្យថា **នាគ** ។ ឯសេចក្តីពិស្តារ គប្បីជ្រាបតាមន័យដែលបានពោលទុក ក្នុងមហានិទ្ទេសនោះឯង ។ មួយាងទៀត

គប្បីជ្រាបអត្ថក្នុងកថានេះ យ៉ាងនេះថា

បុគ្គលមិនធ្វើបាបណាទុកក្នុងលោក រលាស់កិលេសជាគ្រឿងប្រកបសត្វទុកក្នុងភពគ្រប់យ៉ាង និងគ្រឿងចងទាំងឡាយបាន មិនជាប់ជំពាក់ក្នុងភពទាំងពួង ជាអ្នករួចផុតហើយ ជាតាទិបុគ្គល លោកហៅថា នាគ ព្រោះមានសភាពយ៉ាងនោះ ។

នាគធំ ឈ្មោះថា **មហានាគ** អធិប្បាយថា មហានាគនោះគួរបូជាជាង និងគួរសរសើរជាងនាគដែលជាខីណាស្រពដទៃ ។

បទថា **អញ្ញមញ្ញស្ស** ប្រែថា ដល់គ្នានិងគ្នា សេចក្តីថា មួយអង្គសរសើរមួយអង្គទៀត ។

បទថា **សមនុមោទឹសុ** ប្រែថា អនុមោទនាព្រម កាត់បទជា **សមំ អនុមោទឹសុ** ប្រែថា អនុមោទនាស្មើៗ គ្នា ។ ក្នុងពាក្យអនុមោទនានោះ ព្រះធម្មសេនាបតីពោលថា ព្រះមហាមោគ្គល្លានអនុមោទនា ដោយឧបមានេះថា បពិត្រលោកម្ចាស់ សេចក្តីនោះជាក់ច្បាស់ណាស់ ។ ព្រោះហេតុនោះ ទើបលោកពោលថា ព្រះថេរៈទាំង ២ អនុមោទនាពាក្យសុភាសិតដល់គ្នានឹងគ្នា ។

**អដ្ឋកថា អនង្គណសូត្រ ចប់**

**សូត្រទី ៥ ចប់**

# សុត្តន្តបិដក

## អាកង្ខេយ្យសូត្រទី ៦

[ ៧៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគមានព្រះពុទ្ធដីកាដូច្នេះថា ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយចូរជាអ្នកមានសីលបរិបូណ៌ មានបាតិមោក្ខបរិបូណ៌ សង្រួមក្នុងបាតិមោក្ខសំវរៈ ចូរជាអ្នកមានអាចារៈ និងគោចរដ៏បរិបូណ៌ ឃើញភ័យក្នុងទោសត្រឹមតែបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។

[ ៧៤ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីជាទីស្រឡាញ់ផង ជាទីពេញចិត្តផង ជាទីគោរពផង ជាទីសរសើរផង របស់ពួកសព្រហ្មចារីដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ប្រកបក្នុងការរម្ងាប់នូវចិត្តព្ធដ៏ខាងក្នុង មានឈានមិនសាបសូន្យ ប្រកបដោយវិបស្សនា ហើយចម្រើននូវសុញ្ញាគារស្ថាន[១] ។

[ ៧៥ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីបានចីវរបិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ប្រកបក្នុងការរម្ងាប់នូវចិត្តព្ធដ៏ខាងក្នុង មានឈានមិនបានសាបសូន្យ ប្រកបដោយវិបស្សនា ហើយចម្រើននូវសុញ្ញាគារស្ថាន ។

---

១- ភិក្ខុរៀនកម្មដ្ឋាន ហើយចូលទៅកាន់ផ្ទះស្ងាត់ អង្គុយនៅទាំងយប់ទាំងថ្ងៃ ។

[ ៧៦ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញប្រើប្រាស់នូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ របស់ពួកទេវតា និងមនុស្សណា ការបូជាទាំងនោះ របស់ពួកទេវតា និងមនុស្សនោះ សូមឲ្យមានផលច្រើន មានអានិសង្សច្រើនដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ប្រកបក្នុងការរម្ងាប់នូវចិត្តព្វដ៏ខាងក្នុង មានឈានមិនបានសាបសូន្យ ប្រកបដោយវិបស្សនា ចម្រើននូវសុញ្ញាគារស្ថាន ។

[៧៧] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា ពួកញាតិ និងសាលោហិតរបស់អាត្មាអញណា ដែលធ្វើមរណកាលទៅកាន់លោកខាងមុខហើយ មានចិត្តជ្រះថ្លា រឭកឃើញ ( អាត្មាអញ ) ការនឹករឭករបស់ញាតិ និងសាលោហិតទាំងនោះ សូមឲ្យមានផលច្រើន មានអានិសង្សច្រើន ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ប្រកបក្នុងការរម្ងាប់នូវចិត្តព្វដ៏ខាងក្នុង មានឈានមិនបានសាបសូន្យ ប្រកបដោយវិបស្សនាចម្រើននូវសុញ្ញាគារស្ថាន ។

[ ៧៨ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីគ្របសង្កត់នូវសេចក្តីអផ្សុក[១] និងសេចក្តីត្រេកអរ[២] សេចក្តីអផ្សុកកុំគប្បីគ្របសង្កត់អាត្មាអញឡើយ អាត្មាអញគប្បីគ្របសង្កត់រឿយៗ នូវសេចក្តីអផ្សុក ដែលកើតឡើងដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។បេ។ ចម្រើននូវសុញ្ញាគារស្ថាន ។

[៧៩] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីគ្របសង្កត់

---

១- សេចក្តីអផ្សុកក្នុងអកុសលធម៌ ឬក្នុងសេនាសនៈដ៏ស្ងាត់ ។

២- បានដល់ តម្រេកក្នុងបញ្ចពិធកាមគុណ ។

សង្កត់នូវសេចក្ដីខ្មាស ចំពោះអារម្មណ៍ដែលគួរស្ញើប ឯសេចក្ដីខ្មាសចំពោះអារម្មណ៍ដែលគួរស្ញើប កុំគប្បីគ្របសង្កត់អាត្មាអញឡើយ អាត្មាអញគប្បីគ្របសង្កត់រឿយៗ នូវសេចក្ដីខ្មាស ចំពោះអារម្មណ៍ដែលគួរស្ញើប ដែលកើតឡើង ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។បេ។ ហើយចម្រើននូវសុញ្ញាគារស្ថាន ។

[ ៨០ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយមិនខុសវេលាកំណត់នូវឈានទាំង ៤ ដែលកើតក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។បេ។ ចម្រើននូវសុញ្ញាគារស្ថាន ។

[ ៨១ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា វិមោក្ខធម៌ដ៏ស្ងប់រម្ងាប់ទាំងឡាយណា ជាអរូបជ្ឈាន កន្លងហួសនូវរូបាវចរជ្ឈាន សូមឲ្យអាត្មាអញបាននូវវិមោក្ខធម៌ទាំងនោះ ដោយនាមកាយ ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។បេ។ ចម្រើននូវសុញ្ញាគារស្ថាន ។

[ ៨២ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញជាសោតាបន្នបុគ្គល ព្រោះអស់ទៅនៃសំយោជនធម៌ ៣ ប្រការ មានកិរិយាមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀងទាត់ មានកិរិយាត្រាស់ដឹង ប្រព្រឹត្តទៅខាងមុខ ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។បេ។ ចម្រើននូវសុញ្ញាគារស្ថាន ។

[ ៨៣ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញបានជាសកទាគាមិបុគ្គល ព្រោះអស់ទៅនៃសំយោជនធម៌ទាំងឡាយ ៣ ប្រការ ព្រោះរាគៈ ទោសៈ មោហៈស្រាលស្តើង មកកាន់លោកនេះម្ដងទៀត ហើយ

ធ្វើនូវទីបំផុតនៃទុក្ខ ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ប្រកបរឿយៗ នូវការរម្ងាប់ចិត្តព្ធដ៏ខាងក្នុង មានឈានមិនបានសាបសូន្យ ប្រកបដោយវិបស្សនា ចម្រើននូវសុញ្ញាគារស្ថាន ។

[ ៨៤ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញបានជាឱបបាតិកបុគ្គល ( អនាគាមី ) ព្រោះអស់ទៅនៃសំយោជនធម៌ទាំងឡាយ ៥ ប្រការ ជាចំណែកខាងក្រោម បរិព្វានក្នុងព្រហ្មលោកនោះ មានកិរិយាមិនត្រឡប់ចាកលោកនោះ ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។បេ។ ចម្រើននូវសុញ្ញាគារស្ថាន ។

[ ៨៥ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញបាននូវឥទ្ធិវិធញ្ញាណច្រើនប្រការ គឺអាត្មាអញម្នាក់ឯង និម្មិតខ្លួនឲ្យបានទៅជាមនុស្សច្រើននាក់ក៏បាន ច្រើននាក់និម្មិតខ្លួនឲ្យបានទៅជាមនុស្សម្នាក់ក៏បាន ដើរទៅក្នុងទីណាក៏ចេះតែបាន ឥតមានទើសទាល់ គឺនៅក្នុងទីកំបាំង ដើរទៅក្នុងទីវាលក៏បាន នៅខាងក្នុងចេញទៅខាងក្រៅក៏បាន នៅខាងក្នុងជញ្ជាំងចេញទៅខាងក្រៅជញ្ជាំងក៏បាន នៅខាងក្នុងកំពែងចេញទៅខាងក្រៅកំពែងក៏បាន នៅខាងក្នុងភ្នំ ចេញទៅខាងក្រៅភ្នំក៏បាន ឥតទើសទាល់ឡើយ ដូចជាគេដើរព្ធដ៏ទីវាល អាត្មាអញងើបមុជៗ ក្នុងផែនដី ដូចជាគេងើបមុជក្នុងទឹកក៏បាន អាត្មាអញដើរលើទឹកមិនបែកធ្លាយ ដូចជាគេដើរលើផែនដីក៏បាន អាត្មាអញគប្បីទៅ ទាំងភ្នែនព្ធដ៏អាកាស ដូចជាសត្វបក្សីសកុណៈក៏បាន អាត្មាអញយកដៃទៅស្ទាបអង្អែល ចាប់ពាល់ ( មណ្ឌល ) ព្រះចន្ទ្រ និង

ព្រះអាទិត្យទាំងពីរនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើន យ៉ាងនេះក៏បាន ធ្វើអំណាចកាយឲ្យប្រព្រឹត្តទៅ រហូតដល់ព្រហ្មលោកនាយក៏បាន ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។បេ។ ចម្រើននូវសុញ្ញាគារស្ថាន ។

[ ៨៦ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញមានសោតធាតុ ជាទិព្វដ៏បរិសុទ្ធ កន្លងហួសនូវសោតធាតុ របស់មនុស្សធម្មតា ឮនូវសំឡេងពីរប្រការ គឺសំឡេងទិព្វ ១ សំឡេងរបស់មនុស្ស ១ ដែលជាសំឡេងឆ្ងាយក៏បាន ជិតក៏បាន ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។បេ។ ចម្រើនសុញ្ញាគារស្ថាន ។

[ ៨៧ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញកំណត់ដឹងចិត្តរបស់សត្វដទៃ បុគ្គលដទៃ ដោយចិត្តរបស់ខ្លួន គឺចិត្តប្រកបដោយរាគៈក្តី អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តប្រាសចាករាគៈក្តី ក៏អាត្មាអញគប្បីដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ចិត្តប្រកបដោយទោសៈក្តី គប្បីដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តប្រាសចាកទោសៈក្តី គប្បីដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ចិត្តប្រកបដោយមោហៈក្តី គប្បីដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តប្រាសចាកមោហៈក្តី គប្បីដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ចិត្តរួញរាក្តី គប្បីដឹងច្បាស់ថា ចិត្តរួញរា ចិត្តរាយមាយក្តី គប្បីដឹងច្បាស់ថា ចិត្តរាយមាយ ចិត្តជាមហគ្គតៈ គឺរូបាវចរ និងអរូបាវចរក្តី គប្បីដឹងច្បាស់ថា ចិត្តជាមហគ្គតៈ ចិត្តមិនមែនជាមហគ្គតៈក្តី គប្បីដឹងច្បាស់ថា ចិត្តមិនមែនជាមហគ្គតៈ ចិត្តជាសឧត្តរៈ គឺ

លោកិយចិត្តក្តី គប្បីដឹងច្បាស់ថា ចិត្តជាសឧត្តរៈ ចិត្តជាអនុត្តរៈ គឺលោកុត្តរ-ចិត្តក្តី គប្បីដឹងច្បាស់ថា ចិត្តជាអនុត្តរៈ ចិត្តតាំងមាំក្តី គប្បីដឹងច្បាស់ថា ចិត្តតាំងមាំ ចិត្តមិនតាំងមាំក្តី គប្បីដឹងច្បាស់ថា ចិត្តមិនតាំងមាំ ចិត្តរួចចាកកិលេសក្តី គប្បីដឹងច្បាស់ថា ចិត្តរួចចាកកិលេស ចិត្តមិនទាន់រួចចាកកិលេសក្តី គប្បីដឹងច្បាស់ថា ចិត្តមិនទាន់រួចចាកកិលេស ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។បេ។ ចម្រើននូវសុញ្ញាគារស្ថាន ។

[ ៨៨ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញរឭកឃើញនូវបុព្វេនិវាស ( ជាតិដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន ) គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១០០០ ជាតិខ្លះ ១០០០០០ ជាតិខ្លះ សំវដ្តកប្បដ៏ច្រើនខ្លះ វិវដ្តកប្បដ៏ច្រើនខ្លះ សំវដ្តវិវដ្តកប្បដ៏ច្រើនខ្លះ ថាអាត្មាអញកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ អាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ទៅកើតក្នុងទីនោះ លុះអាត្មាអញទៅកើតក្នុងទីនោះហើយ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងទីនេះ អាត្មាអញសូមឲ្យរឭកតាមនូវជាតិ ដែលអាស្រ័យនៅក្នុងកាលមុន បានច្រើនប្រការ ព្រមទាំងអាការៈ

ព្រមទាំងឧទ្ទេសយ៉ាងនេះ ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ។បេ។ ចម្រើននូវសុញ្ញាគារស្ថាន ។

[៨៩] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញមានទិព្វ-ចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ សូមឲ្យដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅ តាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាសត្វតិះដៀលនូវពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវកម្មជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ក៏ទៅកាន់កំណើតតិរច្ឆាន ប្រេត អសុរកាយ នរក អើហ្ន៎ ចំណែកខាងសត្វទាំងនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាសត្វមិនតិះដៀលពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ ប្រកាន់នូវកម្មជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ក៏ទៅកាន់មនុស្សសុគតិ និងឋានសួគ៌ទេវលោក អាត្មាអញសូមឲ្យមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ឃើញនូវសត្វទាំងឡាយដែលច្យុត ដែលកើត ថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ( មួយទៀត ) អាត្មាអញ សូមឲ្យដឹងច្បាស់នូវសត្វទាំង-ឡាយដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការយ៉ាងនេះ ដូច្នេះ គួរធ្វើ

សីលឲ្យបរិបូណ៌ ប្រកបរឿយៗ ក្នុងការរម្ងាប់នូវចិត្តពង្រីខាងក្នុង មានឈាន មិនបានសាបសូន្យ ប្រកបដោយវិបស្សនា ចម្រើននូវសុញ្ញាគារស្ថាន ។

[ ៩០ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញបាន ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ[១] មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវធម៌ទាំងឡាយ ដោយប្រាជ្ញារបស់ខ្លួន ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ចូលទៅសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ប្រកបរឿយៗ ក្នុងការរម្ងាប់នូវចិត្តពង្រីខាងក្នុង មានឈានមិនបានសាបសូន្យ ប្រកបដោយវិបស្សនា ចម្រើននូវសុញ្ញាគារស្ថាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរជាអ្នកមានសីលបរិបូណ៌ មានបាតិមោក្ខបរិបូណ៌ ចូរសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយត្រឹមតែបន្តិចបន្តួច ចូរសមាទានសិក្ខាក្នុងសិក្ខាបទទាំងឡាយ ។ ពាក្យណាដែលតថាគតបានពោលហើយ ( ក្នុងកាលមុន ) ពាក្យដែលតថាគតពោលនេះ ព្រោះអាស្រ័យ យកពាក្យនុ៎ះឯង ដោយប្រការដូច្នេះ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសូត្រនេះចប់ហើយ ពួកភិក្ខុទាំងនោះក៏មានចិត្តត្រេកអររីករាយនឹងភាសិត របស់ព្រះមានព្រះភាគ ដោយក្រៃលែង ។

## អាកង្ខេយ្យសូត្រទី ៦ ចប់

---

១- សមាធិប្រកបដោយអរហត្តផល ហៅថា ចេតោវិមុត្តិ បញ្ញាប្រកបដោយអរហត្តផល ហៅថា បញ្ញាវិមុត្តិ ។ ម្យ៉ាងទៀត សមាធិ បានជាហៅថា ចេតោវិមុត្តិ ព្រោះរួចចាករាគៈ បញ្ញាបានជាលោកហៅថា បញ្ញាវិមុត្តិ ព្រោះរួចចាកអវិជ្ជា ។ មួយវិញទៀត ផលនៃសមថៈ ហៅថា ចេតោវិមុត្តិ ផលនៃវិបស្សនា ហៅថា បញ្ញាវិមុត្តិ ។

# អដ្ឋកថា

## អាកង្ខេយ្យសូត្រ

[ ៧៣ ] *អាកង្ខេយ្យសូត្រ មានពាក្យផ្តើមថា* **ឯវម្មេ សុតំ** *ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ដូច្នេះ បណ្តាបទទាំងនោះ បទថា* **សម្បន្នសីលា** *សេចក្តីថា ការដល់ព្រម មាន ៣ យ៉ាង គឺការបរិបូណ៌ ការដល់ព្រម និងការផ្គុំ ។*

*បណ្តាការដល់ព្រម ៣ យ៉ាងនោះ ការដល់ព្រមដែលមកហើយថា*

**សម្បន្នំ សាលិកេទារំ សុវា ភុញ្ជន្តិ កោសិយ**
**បដិវេទេមិ តេ ព្រហ្មេ ន តេ វារេតុមុស្សហេ។**

*បពិត្រកោសិយៈ ស្រូវសាលីក្នុងស្រែបរិបូណ៌ដែរ តែពួកសេកតែងស៊ី បពិត្រ ព្រហ្ម ខ្ញុំសូមជម្រាបលោក ខ្ញុំមិនអាចហាមឃាត់សេកទាំងនោះបានឡើយ ដូច្នេះ ។*

*នេះឈ្មោះថា ការដល់ព្រម គឺការបរិបូណ៌ ។*

*ការដល់ព្រមនេះថា* **ឥមិនា ចាតិមោក្ខសំវរេន ឧបេតោ ហោតិ សមុបេតោ ឧចាគតោ សមុចាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ** *ជាអ្នកសម្រួម គឺជាអ្នកព្រមព្រៀង មូលមិត្ត ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រម ដោយការសម្រួមក្នុងបាតិមោក្ខនេះ ដូច្នេះ ឈ្មោះថា ដល់ព្រម គឺការដល់ព្រមព្រៀង ។*

*ការដល់ព្រមនេះថា* **ឥមិស្សា ភន្តេ មហាបឋវិយា ហេដ្ឋិមតលំ សម្បន្នំ សេយ្យថាបិ ខុទ្ទកមធុំ អនីលកំ ឯវមស្សាទំ** *សូមទ្រង់ព្រះ*

មេត្តាប្រោស ផ្ទៃខាងក្រោមនៃផែនដីនេះ មានឱជារសផ្អែម ដូចទឹកឃ្មុំ ដែលស្អាតបរិសុទ្ធ ឥតលាយច្រឡំដោយមេឃ្មុំ ដូច្នេះ ឈ្មោះថា ការដល់ព្រម គឺការផ្អែម ។

សូម្បីក្នុងសូត្រនេះ គួរបានដល់ការដល់ព្រម គឺការបរិបូណ៌ខ្លះ ការដល់ព្រម គឺការព្រមព្រៀងខ្លះ ព្រោះដូច្នោះ ក្នុងបទថា **សម្បន្នសីលា** គប្បីជ្រាប សេចក្តីយ៉ាងនេះថា

បទថា **សម្បន្នសីលា** សេចក្តីថា ជាអ្នកមានសីលបរិបូណ៌ដូច្នេះខ្លះ ជាអ្នកដល់ព្រមដោយសីលដូច្នេះខ្លះ ។

បទថា **សីលំ** សេចក្តីថា ដែលឈ្មោះថា **សីល** ព្រោះអត្ថដូចម្តេច ដែលឈ្មោះថា **សីល** ព្រោះអត្ថថា ជាទីទទួលទ្រ ។

អត្ថដោយពិស្តាររបស់បទថាសីលនោះ បានពោលទុកហើយ ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ។ ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គនោះ ដោយអត្ថនេះថា **បរិបុណ្ណសីលា** នេះ ក៏បានពោលការបរិបូណ៌របស់សីលទុកហើយ ព្រោះប្រាសចាកទោសរបស់សីល ដូចលោកពោលការបរិបូណ៌របស់ស្រែទុក ព្រោះប្រាសចាកទោសរបស់ស្រែ ដូច្នោះ ។

ស្រែដែលប្រកបដោយទោស ៤ យ៉ាង គឺគ្រាប់ពូជខូច ១ ការព្រោះមិនល្អ ១ ទឹកមិនល្អ ១ ដីមិនល្អ ១ រមែងជាស្រែដែលបរិបូណ៌មិនបាន ។ បណ្តាទោស ៤ យ៉ាងនោះ ពូជដែលបាក់ ឬស្អុយក្នុងចន្លោះៗ មានក្នុងស្រែណា ស្រែនោះ ឈ្មោះថា ស្រែមានពូជខូច ។

ជនទាំងឡាយ ព្រោះពូជនោះចូលក្នុងស្រែណា សន្ទូងរមែងមិនដុះឡើង ក្នុងស្រែនោះឡើយ ស្រែក៏ឈ្មោះថា ជាស្រែដែលខូច ។ អ្នកស្រែដែលមិនឈ្លាស កាលព្រោះពូជ រមែងព្រោះឲ្យធ្លាក់ទៅរងើលៗ ក្នុងស្រែណា ស្រែនោះ ឈ្មោះថា មានការព្រោះខូច ។ ព្រោះកាលព្រោះយ៉ាងនេះ សន្ទូងរមែងមិនដុះឡើងទូទៅគ្រប់កន្លែង ស្រែក៏ឈ្មោះថា ជាស្រែខូច ។

ក្នុងស្រែខ្វះ មានទឹកច្រើនពេក ឬមិនមានសោះ ស្រែនោះឈ្មោះថា ខ្វះទឹក ព្រោះថា សន្ទូងនឹងមិនដុះឡើងក្នុងស្រែនោះ ស្រែក៏ឈ្មោះថា ជាស្រែខូច ។ ដីក្នុងស្រែខ្វះ អ្នកស្រែយកនង្គ័លភ្ជួរដល់ទៅ ៤-៥ ដង ឲ្យកាន់តែជ្រៅ បន្ទាប់អំពីនោះ ដីក៏ប្រែ ស្រែនោះ ឈ្មោះថា ស្រែមានដូចខូច ។ ព្រោះថា ក្នុងស្រែដែលខូចនោះ សន្ទូងរមែងមិនដុះឡើង ស្រែក៏ឈ្មោះថា ជាស្រែខូច ។ ហើយស្រែដូច្នោះ នឹងមិនមានផលច្រើន ព្រោះថា ក្នុងស្រែនោះ សូម្បីព្រោះពូជចូលទៅច្រើន ក៏បានផលតិច ។

តែស្រែដែលឈ្មោះថា ជាស្រែបរិបូណ៌ ព្រោះប្រាសចាកទោសទាំង ៤ យ៉ាងនេះ ។ ស្រែដូច្នោះ ចាត់ជាស្រែមានផលច្រើន យ៉ាងណា សីលដែលប្រកបដោយទោស ៤ យ៉ាង គឺដាច់ ធ្លុះ ពព្រុស ពពាល ចាត់ជាសីលដែលបរិបូណ៌មិនបាន ដូច្នោះដូចគ្នា ។ សីលដូច្នោះ មិនមានអានិសង្សច្រើនឡើយ ។ តែសីល ឈ្មោះថា ជាសីលដែលបរិបូណ៌បាន ក៏ព្រោះប្រាសចាកទោស ៤ យ៉ាងនេះ ។ សីលដូច្នោះ ឈ្មោះថា ជាសីលមានអានិសង្សច្រើន ។ ដោយអត្ថនេះថា **សីលសមង្គិនោ** គឺលោកពោលអធិប្បាយថា អ្នក

ទាំងឡាយ ចូរជាអ្នកព្រមព្រៀង គឺជាអ្នកដល់នូវការដល់ព្រម បានដល់ប្រកបដោយសីលចុះ ដូច្នេះ ។

ក្នុងបទថា **សម្បន្នសីលា** នោះ ភាពជាអ្នកមានសីលដល់ព្រម រមែងមានដោយហេតុ ២ ប្រការ គឺព្រោះការឃើញទោសក្នុងការវិបត្តិនៃសីល ១ ព្រោះឃើញអានិសង្សក្នុងការដល់ព្រមនៃសីល ១ ។

គុណជាតិទាំង ២ យ៉ាងនេះ លោកបានឲ្យពិស្តារហើយក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ។

ព្រះសុមនត្ថេរ អ្នកស្រុកទីបវិហារពោលថា បានឮថា ព្រះមានព្រះភាគទ្រង់លើកឡើងនូវចតុប្បារិសុទ្ធិសីលសម្តែងដោយព្រះតម្រាស់ មានប្រមាណប៉ុណ្ណេះថា **សម្បន្នសីលា** ក្នុងបណ្តាបទទាំងនោះ ហើយទ្រង់សម្តែងសីលដែលជាប្រធាន ក្នុងបណ្តាសីលទាំងនោះយ៉ាងពិស្តារ ដោយបទនេះថា **បាតិមោក្ខសំវរសំវុតា** ដូច្នេះ ។

ឯព្រះចូឡនាគត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដក ដែលជាអន្តេវាសិករបស់ព្រះសុមនត្ថេរនោះពោលថា ព្រះមានព្រះភាគត្រាស់បាតិមោក្ខសំវរសីលទុកក្នុងបាលីបទេសដល់ទៅ ២ កន្លែង បាតិមោក្ខសំវរៈប៉ុណ្ណោះ ឈ្មោះថា សីលតែអាគតដ្ឋានដែលពោលធានាថា សីល ៣ យ៉ាងក្រៅអំពីនេះ ដែលជាសីលក៏មាន លោកកាលមិនឃើញ ទើបពោលជំទាស់ ហើយពោលតទៅថា គុណជាតិត្រឹមតែការរក្សាទ្វារទាំង ៦ ក៏ឈ្មោះថា ឥន្ទ្រិយសំវរៈ គុណជាតិត្រឹមតែការកើតឡើងនៃបច្ច័យដោយធម៌ ដោយស្មោះស្មើ ក៏ឈ្មោះថា អាជីវ-

បារិសុទ្ធិ គុណជាតិត្រឹមតែការពិចារណាបច្ច័យ ដែលខ្ជួនបានហើយថា វត្ថុនេះមាន ដូច្នេះហើយ ទើបបរិភោគ ក៏ឈ្មោះថា បច្ចយសន្និស្សិតសីល ។

តែពោលដោយត្រង់ បាតិមោក្ខសំវរៈប៉ុណ្ណោះ ឈ្មោះថា សីល បាតិ-មោក្ខសំវរសីលនោះរបស់បុគ្គលណាដាច់ហើយ បុគ្គលនោះ អ្នកណាម្នាក់មិនគួរពោលថា បុគ្គលនេះនឹងរក្សាសីលដ៏សេសទុក ដូច្នេះ ប្រៀបដូចបុរសដែលដាច់ក្បាលហើយ ក៏មិនអាចរក្សាដៃ និងជើងទុកបាន ដូច្នោះ ។ តែបាតិមោក្ខសំវរសីលនេះរបស់បុគ្គលណា មិនពព្រុស មិនពពាល បុគ្គលនោះ រមែងអាចរក្សាសីលដ៏សេស ឲ្យតាំងនៅតាមប្រក្រតីបាន ប្រៀបដូចបុរសដែលមានក្បាលមិនដាច់ ក៏អាចរក្សាជីវិតទុកបាន ដូច្នោះ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគលើកឡើងនូវបាតិមោក្ខសំវរសីលសម្តែង ដោយបទថា **សម្បន្នសីលា** ដូច្នេះហើយ ត្រាស់ពាក្យដែលជាវេវចនៈនៃពាក្យថា **សម្បន្នសីលា** នេះថា **សម្បន្នបាតិមោក្ខា** ដូច្នេះ កាលទ្រង់សម្តែងពាក្យដែលជាវេវចនៈនោះឲ្យពិស្តារ ទើបត្រាស់ពាក្យថា **បាតិមោក្ខសំវរសំវុតា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **បាតិមោក្ខសំវរសំវុតា** សេចក្តីថា ប្រកបដោយបាតិមោក្ខសំវរសីល ។ បទថា **អាចារគោចរសម្បន្នា** សេចក្តីថា សម្បូរដោយអាចារៈ និងគោចរ ។ បទថា **អណុមត្តេសុ** ប្រែថា មានប្រមាណតិចតួច ។ បទថា **វជ្ជេសុ** គឺក្នុងចំណែកអកុសលធម៌ទាំងឡាយ ។ បទថា **ភយទស្សាវី** ប្រែថា ជាអ្នកមានប្រក្រតីឃើញភ័យ ។ បទថា

**សមាទាយ** សេចក្ដីថា កាន់យកដោយល្អ ។ បទថា **សិក្ខថ សិក្ខាបទេសុ** សេចក្ដីថា ពួកអ្នកចូរកាន់យកសិក្ខាបទទាំងនោះដោយល្អ ហើយសិក្សាចុះ ។

ម្យ៉ាងទៀត ក្នុងបទថា **សមាទាយ សិក្ខថ សិក្ខាបទេសុ** នេះ មានសេចក្ដីសង្ខេបថា វត្ថុណានីមួយ មិនថាប្រព្រឹត្តទៅផ្លូវកាយ ឬផ្លូវវាចាឡើយ គួរសិក្សាក្នុងសិក្ខាបទ គឺក្នុងចំណែករបស់សិក្ខាបទ ពួកអ្នកចូរកាន់យកវត្ថុទាំងអស់នោះដោយល្អ ហើយសិក្សាចុះ ។

ឯបទទាំងឡាយ មានបទថា **ចាតិមោក្ខសំវរា** ជាដើម ទាំងអស់នោះ បានពោលទុកហើយ ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គយ៉ាងពិស្ដារ ។

[ ៧៤ ] សួរថា ពាក្យថា **អាកង្ខេយ្យ ចេ** នេះ ព្រះមានព្រះភាគទ្រង់ផ្ដើមទុក ព្រោះហេតុអ្វី ឆ្លើយថា ដើម្បីទ្រង់សម្ដែងអានិសង្សរបស់សីល ។

សូម្បីបុគ្គលដែលបួសមិនយូរ ឬបុគ្គលដែលមានបញ្ញាថោកថយ គប្បីមានការគិតយ៉ាងនេះថា ព្រះមានព្រះភាគត្រាស់ថា ពួកអ្នកចូរបំពេញសីល ពួកអ្នកចូរបំពេញសីល ដូច្នេះ អ្វីហ្ន៎ ជាអានិសង្ស អ្វីជាការប្លែកផ្សេងគ្នា អ្វីជាការចម្រើនក្នុងការបំពេញសីល ដូច្នេះ ។ ដើម្បីទ្រង់សម្ដែងអានិសង្ស ១៧ ប្រការ ដល់ភិក្ខុដែលបួសថ្មីជាដើមនោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ។ សេចក្ដីនេះដូចម្ដេច ភិក្ខុទាំងឡាយ បានស្ដាប់អានិសង្សដែលមានសភាពជាទីស្រឡាញ់ ជាទីពេញចិត្ត របស់សព្រហ្មចារីទាំងឡាយជាខាងដើម មានការអស់ទៅនៃអាសវៈជាទីបំផុតនោះហើយ នឹងបំពេញសីលឲ្យបរិបូណ៌ ដូចអ្នកជំនួញលក់ទឹកអំពៅ ដូច្នោះ ។ ធម្មតាអ្នកលក់ទឹកអំពៅ

លោកហៅថា ឈ្មួញទឹកអំពៅ ។

បានឮមកថា អ្នកជំនួញនោះ យករទេះដាក់ទឹកអំពៅ និងស្ករត្នោតជាដើមទៅឯជាយដែន ហើយឃោសនាថា ពួកអ្នកចូរទិញថ្នាំពិស និងបទ្វា ពួកអ្នកចូរទិញថ្នាំពិស និងបទ្វា ដូច្នេះ ពួកអ្នកស្រុកបានស្តាប់ពាក្យនោះ ក៏គិតថា ធម្មតាថ្នាំពិស ជារបស់ពុល បុគ្គលណាបរិភោគចូលទៅ បុគ្គលនោះក៏ត្រូវស្លាប់ សូម្បីបទ្វាដែលមុតហើយ រមែងធ្វើមនុស្សយើងឲ្យស្លាប់បាន វត្ថុទាំង ២ យ៉ាងនេះ ជារបស់ខ្លាំងក្លា នឹងមានអានិសង្សអ្វី ក្នុងការទិញនេះ ដូច្នេះហើយ ក៏បិទទ្វារផ្ទះ និងដេញក្មេងឲ្យគេចទៅ ។ អ្នកជំនួញឃើញហេតុនោះ ទើបគិតថា អ្នកស្រុកទាំងនេះ ជាអ្នកមិនឈ្លាសក្នុងការលក់ដូរ ណ្ហើយចុះ អញនឹងប្រើឧបាយ ឲ្យអ្នកស្រុកទាំងនោះទិញ ដូច្នេះ ទើបស្រែកពពាយនាយទៅថា អ្នកទាំងឡាយ ចូរទិញរបស់ផ្អែម អ្នកទាំងឡាយ ចូរទិញរបស់ល្អ អ្នកទាំងឡាយនឹងបានទឹកអំពៅ ស្ករផែនដែលមានតម្លៃល្អ ដោយមាសកល្អ អ្នកទាំងឡាយនឹងបានរបស់អន់ ដោយមាសកក្លែងក្លាយ និងកហាបណៈក្លែងក្លាយ ដូច្នេះ ពួកអ្នកស្រុកបានស្តាប់ពាក្យនោះ ត្រេកអរ នាំគ្នាទៅឲ្យតម្លៃថ្លៃ ហើយយករបស់នោះទៅ ។

ព្រះតម្រាស់របស់ព្រះមានព្រះភាគ ក្នុងពាក្យនោះថា **សម្បន្នសីលា ភិក្ខវេ វិហរថ ។បេ។ សមាទាយ សិក្ខាបទេសុ** នោះ ក៏ដូចគ្នានឹងពាក្យឃោសនារបស់ឈ្មួញថា **វិសកណ្តកំ គណ្ហថ សិក្ខថ** ដូច្នេះ ។

ព្រះមានព្រះភាគត្រាស់ថា ពួកអ្នកចូរជាអ្នកមានសីលបរិបូណ៌ចុះ ដូច្នេះ

ពួកភិក្ខុរមែងគិតថា ធម្មតាសីលនេះ ជារបស់រឹង ជាសត្រូវចំពោះការសើច និងការលេងជាដើម និងមានអានិសង្សដូចម្ដេចខ្លះហ្ន៎ ដល់ពួកភិក្ខុដែលមានសីលបរិបូណ៌ ដូច្នេះ ក៏ដូចគ្នានឹងពួកអ្នកស្រុក មានការគិតថា ថ្នាំពិស និងបន្លា ជារបស់គ្រោតគ្រាត មានអានិសង្សអ្វី ក្នុងការទិញថ្នាំពិសជាដើម ដូច្នោះ កាលបើដូច្នោះ គប្បីជ្រាបព្រះតម្រាស់ខាងដើមរបស់ព្រះមានព្រះភាគថា **អាកង្ខេយ្យ ចេ** ដូច្នេះ ជាប្រយោជន៍ដល់ការប្រកាសអានិសង្ស ១៧ ប្រការ ដែលមានភាពជាទីស្រឡាញ់ពេញចិត្តជាដើម មានការអស់ទៅនៃអាសវៈជាទីបំផុត ដូចពាក្យផ្ដើមរបស់ឈ្មួញនោះថា អ្នកចូរទិញយករបស់ធ្លាញ់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាកង្ខេយ្យ ចេ** សេចក្ដីថា បើអ្នកគប្បីសង្ឃឹម គឺបើអ្នកគប្បីប្រាថ្នា ។

បទថា **បិយោ ច អស្សំ** សេចក្ដីថា អាត្មាអញ គប្បីជាអ្នកដែលបុគ្គលដទៃគប្បីសម្លឹងមើលដោយភ្នែកជាទីស្រឡាញ់ អធិប្បាយថា អាត្មាអញគប្បីជាអ្នកញុំាងនូវហេតុនៃការកើតឡើងរបស់សេចក្ដីស្រឡាញ់ ដូច្នេះ ។

បទថា **មនាបោ** សេចក្ដីថា អាត្មាអញ គប្បីជាអ្នកត្រេកអររបស់ជនទាំងនោះ ។ ម្យ៉ាងទៀត អធិប្បាយថា អាត្មាអញ គប្បីជាអ្នកត្រូវចិត្តរបស់ជនទាំងនោះ គឺគប្បីឲ្យជនទាំងនោះផ្សាយមេត្តាចិត្តទៅ ។

បទថា **គរុ** សេចក្ដីថា អាត្មាអញ គប្បីជាទីធ្ងន់ចិត្តរបស់ជនទាំងនោះដូចគ្នានឹងឆត្រថ្ម ។ បទថា **ភាវនីយោ** សេចក្ដីថា អាត្មាអញ គប្បីជាអ្នក

ដែលជនទាំងនោះ គប្បីសរសើរយ៉ាងនេះថា លោកម្ចាស់រូបនេះ កាលដឹង ក៏ដឹងពិត កាលឃើញ ក៏ឃើញពិត ដូច្នេះ ។

បទថា **សីលេស្វេវស្ស បរិបូរការី** សេចក្ដីថា គប្បីជាអ្នកធ្វើឲ្យបរិបូណ៌ ក្នុងចតុប្បារិសុទ្ធិសីលនោះឯង អធិប្បាយថា គប្បីប្រកបដោយអាការដែល ធ្វើឲ្យបរិបូណ៌ មិនខ្វះខាត ។

បទថា **អជ្ឈត្តំ ចេតោសមថមនុយុត្តោ** សេចក្ដីថា ជាអ្នកប្រកបក្នុងការ ទូន្មានចិត្តរបស់ខ្លួន ។ ព្រោះពាក្យថា **អជ្ឈត្តំ** ឬ **អត្តនោ** ក្នុងពាក្យថា **អជ្ឈត្តំ ចេតោសមថមនុយុត្តោ** នេះ តែមួយដូចគ្នា គឺមានអត្ថដូចគ្នា ផ្សេង គ្នាតែព្យញ្ជនៈប៉ុណ្ណោះ ។

បទថា **សមថំ** នេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ដោយបទ ឧបសគ្គនេះថា **អនុ** ក៏ជាការសម្រេចក្នុងការប្រកបសេចក្ដីបាន ។

បទថា **អនិរាកតជ្ឈានោ** សេចក្ដីថា បុគ្គលមានឈានណាមួយ នាំ ចេញទៅខាងក្រៅមិនបាន ឬមានឈានដែលធម្មជាតណាមួយ ធ្វើឲ្យវិនាស មិនបានហើយ សេចក្ដីពិត ឈ្មោះថា **និរាករណ** នេះ ប្រើក្នុងអត្ថថា នាំ ចេញទៅ និងធ្វើឲ្យវិនាស ក៏គប្បីឃើញការប្រកបរបស់និរាករណៈនោះ ដូច ក្នុងប្រយោគជាដើមថា បុគ្គលគួរកម្ចាត់កាពរឹងត្អឹងចេញ ហើយគប្បីជាអ្នក ប្រព្រឹត្តឱនលំទោន ដូច្នេះ ។

បទថា **វិបស្សនាយ សមន្នាគតោ** សេចក្ដីថា ជាអ្នកប្រកបដោយ អនុបស្សនា ៧ យ៉ាង ។ ធម្មតាអនុបស្សនា ៧ យ៉ាង គឺអនិច្ចានុបស្សនា

ទុក្ខានុបស្សនា អនត្តានុបស្សនា និព្វិទានុបស្សនា វិរាគានុបស្សនា និរោធា-នុបស្សនា បដិនិស្សគ្គានុបស្សនា ។ អនុបស្សនាទាំងនេះ បានឲ្យពិស្តារហើយ ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ។ បទថា **ព្រូហេតា សុញ្ញា-គារានំ** សេចក្តីថា ជាអ្នកញុំាំងសុញ្ញាគារឲ្យចម្រើន ។

ក្នុងបទថា **ព្រូហេតា សុញ្ញាគារានំ** នេះ ភិក្ខុរៀនយកកម្មដ្ឋាន ដោយអំណាចសមថៈ និងវិបស្សនា ហើយចូលទៅកាន់ផ្ទះស្ងាត់ អស់ថ្ងៃ និងយប់ គប្បីជ្រាបថា ជាអ្នកចម្រើនសុញ្ញាគារ ឯភិក្ខុធ្វើសេចក្តីព្យាយាមក្នុងប្រាសាទមួយជាន់ជាដើម មិនគប្បីឃើញថា ជាអ្នកចម្រើនសុញ្ញាគារឡើយ ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ទេសនានេះ ព្រះមានព្រះភាគ ទ្រង់ផ្តើមដោយអំណាចការលើកអធិសីលសិក្ខានោះ សម្តែងមុនក៏ដោយ ក៏គប្បីជ្រាបថា ជាទេសនាដែលទាក់ទងក្នុងត្រៃសិក្ខាដោយលំដាប់ ព្រោះរួមសមថៈនិងវិបស្សនាចូលជាមួយគ្នា ព្រោះសមថៈ និងវិបស្សនា មានសីលជាបទដ្ឋាន ដូចគ្នានឹងការទេសនាធម៌ ដែលជាសត្រូវរបស់តណ្ហា ទោះព្រះមានព្រះភាគ ទ្រង់ផ្តើមដោយអំណាចការលើកតណ្ហាឡើងសម្តែងមុន ក៏គប្បីជ្រាបថា ជាទេសនាដែលរាប់ចូលក្នុងតិកៈនៃធម៌ជាគ្រឿងយឺតយូរដោយលំដាប់ ព្រោះរួមមានៈ ទិដ្ឋិ ចូលជាមួយគ្នា ព្រោះមានៈ និងទិដ្ឋិ មានតណ្ហាជាបទដ្ឋាន ។

ក្នុងបណ្តាពាក្យទាំងនោះ ដោយពាក្យមានប្រមាណប៉ុណ្ណេះថា **សីលេ-ស្វេវស្ស បរិបូរិការី** ឈ្មោះថា ទ្រង់ត្រាស់អធិសីលសិក្ខា ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះថា **អជ្ឈត្តំ ចេតោសមថមនុយុត្តា អនិរាកតជ្ឈានោ** ឈ្មោះថា ទ្រង់ត្រាស់អធិចិត្តសិក្ខា ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះថា **វិបស្សនាយ សមន្នាគតោ** ឈ្មោះថា ត្រាស់អធិបញ្ញាសិក្ខា ។

ដោយបទថា **ព្រូហេតា សុញ្ញាគារានំ** នេះ ឈ្មោះថា ទ្រង់ត្រាស់រួមយកសិក្ខាទាំង ២ យ៉ាង គឺអធិចិត្តសិក្ខា ក្នុងការចម្រើនសុញ្ញាគារ ដោយអំណាចសមថៈ អធិបញ្ញាសិក្ខា ដោយអំណាចវិបស្សនា ។

ក្នុងទីនេះ ដោយបទទាំងនេះថា **អជ្ឈត្តំ ចេតោសមថមនុយុត្តា អនិរាកតជ្ឈានោ** ទ្រង់ត្រាស់ដល់ភាពដែលចិត្តជាឯកគ្គតាថា តាមរក្សាសីលទុកបាននោះឯង ។ ដោយបទថា **វិបស្សនាយ** នេះ ទ្រង់ត្រាស់ការកំណត់សង្ខារថា អនុរក្សសីលបាន ។

សួរថា ការដែលចិត្តជាឯកគ្គតា នឹងអនុរក្សសីលបានដូចម្ដេច ឆ្លើយថា បុគ្គលណាមិនមានចិត្តជាឯកគ្គតា បុគ្គលនោះកាលព្យាធិកើតឡើង រមែងក្ដៅក្រហាយ ។ បុគ្គលនោះត្រូវព្យាធិរុកកួន បៀតបៀន ក្រវល់ក្រវាយ សូម្បីត្រូវឲ្យសីលដាច់ ទើបធ្វើព្យាធិនោះឲ្យស្ងប់ទៅបាន ឯបុគ្គលណាមានចិត្តជាឯកគ្គតានោះ រមែងសង្កត់ព្យាធិបាន ចូលសមាបត្តិ ក្នុងខណៈដែលចូលសមាបត្តិ ទុក្ខរមែងប្រាសទៅ សេចក្ដីសុខដែលមានកម្លាំងច្រើនជាង រមែងកើតឡើង ។ ភាពដែលចិត្តជាឯកគ្គតា រមែងអនុរក្សសីលបាន ដោយប្រការយ៉ាងនេះ ។

សួរថា ការកំណត់សង្ខារ រមែងតាមអនុរក្សសីលបានដូចម្ដេច ឆ្លើយថា បុគ្គលណាមិនមានការកំណត់សង្ខារថា បុគ្គលនោះ រមែងមានការស្រឡាញ់យ៉ាងខ្លាំងក្លា ក្នុងអត្តភាពថា រូបរបស់អញ វិញ្ញាណរបស់អញ ដូច្នេះ ។ បុគ្គលនោះ កាលជួបនូវទុព្ភិក្ខភ័យ និងព្យាធិភ័យបែបនោះជាដើម រមែងទម្លាយសីល ហើយរក្សាអត្តភាព ។ ឯបុគ្គលណា មានការកំណត់សង្ខារ បុគ្គលនោះរមែងមិនមានការស្រឡាញ់យ៉ាងខ្លាំងក្លា ឬការស្នេហាក្នុងអត្តភាព កាលជួបនូវទុព្ភិក្ខភ័យ និងព្យាធិភ័យ ដែលមានសភាពបែបនោះជាដើម សូម្បីពោះវៀនធំចេញមកខាងក្រៅ ទោះបុគ្គលនោះស្គមស្គាំង ស្លេកស្លាំង ឬដាច់ជាកំណាត់ៗ រាប់រយកំណាត់ រាប់ពាន់កំណាត់ ក៏មិនទម្លាយសីល ហើយរក្សាអត្តភាពឡើយ ។ ការកំណត់សង្ខារ រមែងអនុរក្សសីលបាន យ៉ាងនេះ ។

ដោយបទថា **ព្រហ្មា សុញ្ញាគារានំ** នេះ ព្រះអង្គទ្រង់សម្ដែងការបន្ថែមនូវការចម្រើន និងធ្វើដោយជាប់តនូវហេតុទាំង ២ យ៉ាងនោះ ។

ព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ព្រោះភិក្ខុដែលសង្ឃឹមគុណធម៌ទាំង ៤ ប្រការនេះ គឺយើងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរពរាប់អាននៃសព្រហ្មចារីទាំងឡាយ មិនមានកិច្ចដែលត្រូវធ្វើអ្វីដទៃឡើយ តែគប្បីជាអ្នកប្រកបដោយគុណ មានសីលជាដើមដោយពិត ព្រោះថា ភិក្ខុដែលប្រកបដោយគុណ មានសីលជាដើម ដូច្នេះ រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព រាប់អានរបស់សព្រហ្មចារីទាំងឡាយ សមដូចព្រះតម្រាស់ដែល

ព្រះមានព្រះភាគត្រាស់ថា

ជនតែងធ្វើបុគ្គលដែលបរិបូណ៌ ដោយសីល និងការឃើញត្រូវ ស្ថិតនៅក្នុងធម៌ ពោលសច្ចធម៌ ជាប្រក្រតីធ្វើកម្ម ជារបស់ខ្លួននោះ ឲ្យជាទីស្រឡាញ់ ដូច្នេះ ។

[ ៧៥ ] ព្រោះហេតុនោះ ព្រះមានព្រះភាគកាលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីបំណងថា អញគប្បីជាទីស្រឡាញ់ ។បេ។ ជាទីពេញចិត្តរបស់សព្រហ្មចារីទាំងឡាយ ដូច្នេះ អ្នកគប្បីធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ។បេ។ អ្នកគប្បីចម្រើនការនៅក្នុងផ្ទះស្ងាត់ ដូច្នេះហើយ ឥឡូវនេះ ព្រោះហេតុដែលភិក្ខុប្រាថ្នាបច្ច័យ មានលាភជាដើម គប្បីធ្វើកិច្ចនេះតែម្យ៉ាង មិនគប្បីធ្វើកិច្ចដទៃណាមួយអំពីនេះ ដូច្នោះ ទើបបានត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីបំណងថា អញគប្បីជាអ្នកមានលាភដូច្នេះជាដើម ។

ក្នុងទីនេះ កុំគប្បីយល់ថា ព្រះមានព្រះភាគ ត្រាស់ការបំពេញសីលជាដើម ដែលមានលាភជានិមិត្ត ព្រោះព្រះមានព្រះភាគ ជាអ្នកបដិសេធការស្វែងរកលាភ មិនត្រាស់ព្រះវាចាដែលអាស្រ័យដល់លាភ ទ្រង់ឱវាទដល់ពួកសាវ័ក ។ ទ្រង់នឹងត្រាស់ការបំពេញគុណ មានសីលជាដើម ដែលមានលាភជានិមិត្តបានដូចម្តេច ។

តែពាក្យនោះ ព្រះអង្គត្រាស់ដោយអំណាចអធ្យាស្រ័យរបស់បុគ្គល អធិប្បាយថា ភិក្ខុពួកណា មានអធ្យាស្រ័យយ៉ាងនេះថា បើអញមិនត្រូវ

លំបាកដោយបច្ច័យ ៤ សោត អញអាចដើម្បីបំពេញសីលជាដើមឲ្យបរិបូណ៌បាន ដូច្នេះ ។ ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ដោយអំណាចអធ្យាស្រ័យរបស់ជនទាំងឡាយនោះ ។

ម្យ៉ាងទៀត ឈ្មោះថា បច្ច័យ ៤ នេះ ជាអានិសង្សដែលពិតរបស់សីល ។ ពិតហើយ បុគ្គលដែលជាបណ្ឌិតទាំងឡាយ នាំទ្រព្យដែលខ្លួនរក្សាក្នុងជង្រុកជាដើមចេញមក ទាំងបុត្រជាដើមក៏មិនឲ្យ ទាំងខ្លួនឯងក៏មិនបានប្រើប្រាស់ តែប្រគេនដល់អ្នកមានសីល ពាក្យដូចពោលមកនេះលោកពោល ដើម្បីសម្តែងអានិសង្សពិតរបស់សីល ។

[ ៧៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៣ តទៅ បទថា **យេសាហំ** កាត់បទជា **យេសំ អហំ** ។ បទថា **តេសន្តេ ការា** សេចក្តីថា សក្ការៈ គឺការប្រគេនបច្ច័យទាំងនោះ ទេវតាក្តី មនុស្សក្តី បានធ្វើហើយដល់អញ សេចក្តីពិត ទេវតាទាំងឡាយ រមែងប្រគេនបច្ច័យដល់បុគ្គលដែលប្រកបដោយគុណមានសីលជាដើម មិនមែនមានចំពោះបុគ្គលតែម្យ៉ាងនោះទេ ។ ដូចសក្កទេវរាជ បានប្រគេនដល់ព្រះមហាកស្សបជាដើម ។

ពាក្យទាំង ២ នេះថា **មហប្ផលា មហានិសំសា** ដោយអត្ថហើយមានអត្ថតែម្យ៉ាងដូចគ្នា ផ្សេងគ្នាត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ សក្ការៈដែលឈ្មោះថា មានផលច្រើន ព្រោះឲ្យលោកិយសុខដ៏ច្រើន ឈ្មោះថា មានអានិសង្សច្រើន ព្រោះជាបច្ច័យរបស់លោកុត្តរសុខដ៏ធំកន្លង ។ សេចក្តីពិត បាយមួយវែកក្តី បណ្ណសាលាត្រង់ផែនដី បណ្តោយប្រមាណ ៥ ហត្ថក្តី ដែលបុគ្គលឲ្យ

ដល់អ្នកប្រកបដោយគុណ មានសីលជាដើម រមែងរក្សាបុគ្គលនោះមិនឲ្យធ្លាក់ទៅកាន់ទុគ្គតិ វិនិបាត ច្រើនសែនកប្ប ។ ក្នុងទីបំផុត គង់ជាបច្ច័យនៃការរលត់ដោយជុំវិញ ដោយអមតធាតុ ។ ក្នុងរឿងនេះ មានរឿងជាដើមថា អញបានប្រគេនទឹកដោះ និងបាយជាដើម ឬមានបេតវត្ថុ និងវិមានវត្ថុទាំងអស់ ជាគ្រឿងសាធកៈ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគសម្តែងថា ភិក្ខុបើប្រាថ្នាការឲ្យសក្ការៈ ដែលបុគ្គលឲ្យបច្ច័យដល់ខ្លួននោះ មានផលច្រើន គប្បីជាអ្នកប្រកបដោយគុណ មានសីលជាដើមនោះឯង ។

[ ៧៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៤ តទៅ ពពួកជនដែលជាប់ទាក់ទងខាងខ្សែស្រឡាយឪពុកក្មេក ម្តាយក្មេក ឈ្មោះថា ញាតិ បិតា និងជីតាជាដើម ដែលជាប់ទាក់ទងដោយខ្សែស្រឡាយជាមួយគ្នា ឈ្មោះថា ញាតិសាលោហិត ។

បុគ្គលដែលដល់ការលះលោកទៅហើយ ឈ្មោះថា បេត ។

បទថា **កាលកតា** ប្រែថា ស្លាប់ហើយ ។

បទថា **តេសន្តំ** សេចក្តីថា ភាពដែលជនទាំងនោះ មានចិត្តជ្រះថ្លាក្នុងអាត្មាអញ ឬកាលរឭកដល់អញ ដោយចិត្តជ្រះថ្លានោះនៃជនទាំងនោះ ។ សេចក្តីពិត មាតា ឬបិតារបស់ភិក្ខុរូបណាស្លាប់ទៅហើយ មានចិត្តជ្រះថ្លា រមែងរឭកដល់ភិក្ខុនោះថា ព្រះថេរៈជាអ្នកមានសីល មានកល្យាណធម៌នោះ ជាញាតិរបស់ពួកយើង ដូច្នេះ ការជ្រះថ្លានៃចិត្តនោះរបស់បុគ្គលនោះក្តី ហេតុគ្រាន់តែការរឭកដល់នោះក្តី មានផលច្រើន មានអានិសង្សច្រើន ។

ហេតុគ្រាន់តែការរឭកដល់នោះឯង ជាធម្មជាតដែលអាចញុំាងពួកសត្វឲ្យឆ្លងចាកទុគ្គតិអស់សែនកប្ប និងឲ្យដល់អមតមហានិព្វានក្នុងទីបំផុតនោះឯង ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុណាបរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយបញ្ញា បរិបូណ៌ដោយវិមុត្តិ បរិបូណ៌ដោយវិមុត្តិញាណទស្សនៈ ជាអ្នកទូន្មានពន្យល់ឲ្យដឹង សម្តែងបញ្ជាក់ឲ្យឃើញងាយ ណែនាំ ធ្វើឲ្យអង់អាច ធ្វើឲ្យរីករាយ ( ក្នុងកុសលធម៌ ) អាចសម្តែងនូវព្រះសទ្ធម្មបាន ម្នាលភិក្ខុទាំង-ឡាយ តថាគតពោលនូវការជួបប្រទះនូវភិក្ខុនោះថា មានឧបការៈច្រើន ... ដូច្នេះ ។ ព្រោះដូច្នោះ ទើបទ្រង់សម្តែងថា ភិក្ខុសូម្បីប្រាថ្នានូវការជ្រះថ្លានៃចិត្តក្នុងខ្លួន និងការរឭកដល់ខ្លួន ញាតិ និងសាលោហិតទាំងឡាយ និងឲ្យមានផលច្រើន គប្បីជាអ្នកប្រកបដោយគុណ មានសីលនោះឯងជាដើម ។

[ ៧៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៥ តទៅ បទថា **អរតិរតិសហោ អស្សំ** សេចក្តីថា អាត្មាអញ គប្បីជាអ្នកអត់ធន់ចំពោះការមិនត្រេកអរ និងការត្រេកអរ គឺគប្បីជាអ្នកត្រូវសេចក្តីប្រទូស្តជាដើមគ្របសង្កត់ ។

ក្នុងបទថា **អរតិរតិសហោ** នេះ ការនឿយណាយក្នុងធម៌ដែលជាកុសលដ៏ក្រៃលែង និងក្នុងសេនាសនៈដ៏ស្ងាត់ ឈ្មោះថា **អរតិ** ការត្រេកអរក្នុងកាមគុណ ៥ ឈ្មោះថា **រតិ** ។

បទថា **ឆ ច មំ អរតិ សហេយ្យ** សេចក្តីថា ការមិនត្រេកអរ គប្បីគ្របសង្កត់ គឺញុំាញី បានដល់ លិចលង់អញមិនបាន ។

បទថា **ឧប្បន្នំ** ការកើតហើយ គឺកើតឡើងហើយ ។

ព្រោះថា ភិក្ខុដែលប្រកបដោយគុណ មានសីលជាដើម រមែងអត់ធន់ គឺគ្របសង្កត់ បានដល់ ញាំញីនូវការមិនត្រេកអរ និងការត្រេកអរបាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងទុកថា ភិក្ខុសូម្បីប្រាថ្នាឲ្យខ្លួនដូច្នោះ គប្បីជាអ្នកប្រកបដោយគុណ មានសីលជាដើម ។

[ ៧៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៦ តទៅ ការភ័យខ្លាចរបស់ចិត្តក្តី អារម្មណ៍ក្តី ឈ្មោះថា ភ័យ អារម្មណ៍នោះឯង ឈ្មោះថា ភេរវៈ គឺការខ្លាច ពាក្យដ៏សេស មានន័យដូចពោលហើយក្នុងវារៈទី ៥ ។

សេចក្តីពិត ភិក្ខុដែលប្រកបដោយគុណ មានសីលជាដើម រមែងអត់ធន់ គឺរមែងគ្របសង្កត់ បានដល់ រមែងញាំញីការខ្លាច ហើយការខ្លាចតាំងនៅ ដូចព្រះមហាទត្តត្ថេរ អ្នកស្រុកអរិយកោដិយវិហារ ។

## រឿង ព្រះមហាទត្តត្ថេរ

បានឮថា ព្រះថេរៈដើរទៅក្នុងផ្លូវ បានជួបដងព្រៃ ដែលជាទីតាំងនៃការជ្រះថ្លាមួយកន្លែង ទើបគិតថា ថ្ងៃនេះ អញនឹងបំពេញសមណធម៌ក្នុងទីនេះ ហើយសឹមទៅ ដូច្នេះហើយ ទើបចេញទៅអំពីផ្លូវ ក្រាលសំពត់សង្ឃាដី ហើយអង្គុយពត់ភ្នែនក្បែរគល់ឈើមួយកន្លែង ។

កូនរបស់រុក្ខទេវតា មិនអាចតាំងនៅក្នុងការៈរបស់ខ្លួនបាន ដោយតេជះនៃសីលរបស់ព្រះថេរៈ ទើបស្រែករំពងឡើង ។ សូម្បីទេវតាខ្លួនឯងក៏អង្រួនដើមឈើគ្រប់ដើម ព្រះថេរៈអង្គុយមិនកម្រើក ទើបទេវតានោះបង្ហាយផ្សែង

ឲ្យហុយទ្រលោមឡើង សូម្បីយ៉ាងនោះក៏មិនអាចធ្វើព្រះថេរៈកម្រើកបាន ។

បន្ទាប់អំពីនោះ ទើបទេវតាក្លែងភេទជាឧបាសក ដើរមកថ្វាយបង្គំព្រះថេរៈ ហើយបានឈរនៅក្នុងទីមួយកន្លែង ព្រះថេរៈសួរថា អ្នកណាអេះ ទើបពោលថា បពិត្រលោកម្ចាស់ ខ្ញុំជាទេវតាដែលស្ថិតនៅត្រង់ដើមឈើនេះ ព្រះថេរៈសួរថា អ្នកបានធ្វើវត្ថុប្លែកៗ នោះឬ ទេវតាឆ្លើយថា មែនហើយលោកម្ចាស់ ។ ទេវតានោះ ត្រូវព្រះថេរៈសួរថា ព្រោះហេតុអ្វី ទើបអ្នកធ្វើ ក៏ឆ្លើយថា បពិត្រលោកម្ចាស់ ដោយតេជះនៃសីលរបស់លោកម្ចាស់នោះឯង ពួកកូនៗ របស់ខ្ញុំ មិនអាចតាំងនៅតាមភាវៈរបស់ខ្លួនបាន ទើបបាននាំគ្នាបន្លឺសំឡេងទ្រហឹង ខ្ញុំនោះបានធ្វើយ៉ាងនេះ បំណងដើម្បីឲ្យលោកម្ចាស់ចៀសចេញទៅ ។ ព្រះថេរៈសួរថា បើដូច្នោះ ហេតុអ្វី ទើបអ្នកបំណងឲ្យអាត្មាគេចទៅ ទេវតាឆ្លើយថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំនៅទីនេះឡើយ ខ្ញុំមិនមានសេចក្តីសុខទេ ដូច្នេះ ទើបព្រះថេរៈពោលថា ហេតុអ្វី អ្នកមិនប្រាប់អាត្មាជាមុន តែឥឡូវនេះ អ្នកកុំពោលប្តីឡើយ អាត្មាគិតថា ខ្មាសចំពោះពាក្យដែលមនុស្សនិយាយថា ព្រះអរិយកោដិយមហាទត្តៈ គេចចេញទៅព្រោះខ្លាចអមនុស្ស ដូច្នោះ អាត្មានៅក្នុងទីនេះឯង ត្រឹមតែមួយថ្ងៃ អ្នកចូរនៅក្នុងទីណាមួយសិនចុះ ។

ព្រះមានព្រះភាគទ្រង់សម្តែងថា ភិក្ខុដែលប្រកបដោយគុណ មានសីលជាដើម រមែងជាអ្នកអត់ធន់ចំពោះភ័យដែលគួរខ្លាចបាន ដូច្នោះ ភិក្ខុប្រាថ្នាឲ្យជាបុគ្គលដូច្នេះ គប្បីជាអ្នកប្រកបដោយគុណ មានសីលជាដើម ដូច្នេះ ។

[ ៨០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៧ តទៅ ចិត្តដែលបរិសុទ្ធផូរផង់ ទ្រង់ត្រាស់ហៅថា **អភិចិត្ត** ក្នុងពាក្យថា **អាភិចេតសិកានំ** ។ មួយវិញទៀត ចិត្តដ៏ក្រៃលែង ទ្រង់ត្រាស់ហៅថា **អភិចិត្ត** ឈានទាំងឡាយដែលកើតឡើងក្នុងអភិចិត្ត ឈ្មោះថា **អាភិចេតសិក** មួយវិញទៀត ឈានទាំងឡាយដែលអាស្រ័យអភិចិត្ត ដូច្នោះ ទើបឈានទាំងឡាយនោះ ឈ្មោះថា **អាភិចេតសិក** ។

បទថា **ទិដ្ឋធម្មសុខវិហារានំ** សេចក្តីថា នូវការនៅជាសុខក្នុងទិដ្ឋធម៌ ។ អត្តភាពដែលឃើញបានដោយប្រចក្ស ហៅថា ទិដ្ឋធម៌ អធិប្បាយថា ជាការនៅជាផាសុកក្នុងទិដ្ឋធម៌នោះ ។

បទថា **ទិដ្ឋធម្មសុខវិហារានំ** ជាឈ្មោះរបស់រូបាវចរជ្ឈាន ។ សេចក្តីពិត ជនទាំងឡាយអន្ទ័យសម្ងំឈាននោះយ៉ាងស៊ប់ រមែងជួបនេក្ខម្មសុខដែលមិនសៅហ្មងក្នុងអត្តភាពនេះ ព្រោះដូច្នោះ ទើបជនទាំងនោះ លោកហៅថា ជាអ្នកមានប្រក្រតីនៅជាសុខក្នុងទិដ្ឋធម៌ ។

បទថា **និកាមលាភី** សេចក្តីថា ជាអ្នកបានតាមបំណង គឺជាអ្នកបានតាមប្រាថ្នារបស់ខ្លួន អធិប្បាយថា រមែងជាអ្នកអាចចូលឈានបាន ក្នុងខណៈដែលខ្លួនប្រាថ្នា ។

បទថា **អកិច្ឆលាភី** អធិប្បាយថា ជាអ្នកអាចដើម្បីសង្កត់ធម៌ដែលជាសត្រូវហើយ ចូលឈានបានដោយស្រួល ។

បទថា **អកសិរលាភី** សេចក្តីថា ជាអ្នកបានដោយមិនលំបាក គឺយ៉ាង

ងាយស្រួល អធិប្បាយថា ជាអ្នកអាចចេញបានក្នុងវេលា តាមដែលកំណត់ទុកនោះឯង ។ សេចក្តីពិត ភិក្ខុរបខ្លះជាអ្នកបានឈាន តែមិនអាចចូលឈានបាន ក្នុងខណៈដែលខ្លួនត្រូវការ ។ ភិក្ខុរបខ្លះអាចចូលក្នុងខណៈដែលខ្លួនប្រាថ្នាបាន តែសង្កត់ធម៌ដែលជាសត្រូវចំពោះវសីបានលំបាក ។ អង្គខ្លះតែងចូលបានក្នុងខណៈដែលខ្លួនត្រូវការ និងសង្កត់ធម៌ដែលជាសត្រូវចំពោះវសីបានដោយមិនលំបាក តែមិនអាចដើម្បីនឹងចេញ ក្នុងខណៈដែលខ្លួនកំណត់ទុកបាន ដូចនាឡិកាយន្ត ។ បុគ្គលណាប្រាថ្នានូវការដល់ព្រមទាំង ៣ យ៉ាងនេះ បុគ្គលនោះ គប្បីជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយពិត ។

[ ៨១ ] កាលព្រះមានព្រះភាគត្រាស់ឈាន ដែលជាបាទរបស់អភិញ្ញាយ៉ាងនេះហើយ ក៏មកដល់វារៈនៃអភិញ្ញាដោយពិត តែទោះជាដូច្នោះ ព្រះមានព្រះភាគក៏ទ្រង់មិនបានកាន់យកអភិញ្ញានោះ ដើម្បីរម្លេសម្តែងធម៌ទាំងអស់នោះ ព្រោះថា មិនមែនត្រឹមតែឈានដែលជាបាទរបស់អភិញ្ញា និងអភិញ្ញាតែម្យ៉ាងប៉ុណ្ណោះ ដែលជាអានិសង្សរបស់សីល ដោយពិតនោះ អរូបជ្ឈានទាំង ៤ និងអរិយមគ្គទាំង ៣ ខាងដើម ក៏ជាអានិសង្សរបស់សីលដូចគ្នាដូច្នោះ ទើបត្រាស់ពាក្យជាដើមថា **អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ យេ តេ សន្តា** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្តា** សេចក្តីថា វិមោក្ខទាំងឡាយ ឈ្មោះថា ជាធម្មជាតស្ងប់ស៊ប់ ព្រោះមានអង្គស្ងប់ និងព្រោះមានអារម្មណ៍ស្ងប់ ។

បទថា **វិមោក្ខា** សេចក្តីថា វិមោក្ខទាំងឡាយ ឈ្មោះថា ស្ងប់ ព្រោះ

រូបផុតចាកធម៌ដែលជាសត្រូវ និងព្រោះបង្អោនទៅក្នុងអារម្មណ៍ ។

បទថា **អតិក្កម្ម រូបេ** សេចក្តីថា ឈានកន្លងបង់នូវរូបាវចរជ្ឈាន ក្តាប់បទថា **វិមោក្ខ** ឈ្មោះថា ស្ងប់បាន ព្រោះឈានកន្លងរូបាវចរជ្ឈាន ដូច្នេះ ។ សេចក្តីពិត កាលនឹងពោលដោយប្រការដទៃ វិមោក្ខទាំងឡាយឈានកន្លងរូបាវចរជ្ឈានហើយ ក៏មិនគប្បីប្រាកដជាធ្វើអ្វី ។

បទថា **អារុប្បា** សេចក្តីថា វៀរចាករូបទាំងដោយអារម្មណ៍ និងដោយវិបាក ។

បទថា **កាយេន ផុសិត្វា** សេចក្តីថា ពាល់ត្រូវនាមកាយ អធិប្បាយថា សម្រេច បានដល់ ពាល់ត្រូវហើយ ។

ពាក្យដ៏សេស មានអត្ថជាក់ច្បាស់ហើយ មានពាក្យអធិប្បាយដែលលោកពោលថា ភិក្ខុរូបណា បំណងនឹងពាល់ត្រូវវិមោក្ខហើយ សូម្បីភិក្ខុនោះគប្បីធ្វើឲ្យជាអ្នកបរិបូណ៌ក្នុងសីលទាំងឡាយពិត ដូច្នេះឯង ។

[ ៨២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៩ តទៅ បទថា **តិណ្ណំ សំយោជនានំ** សេចក្តីថា នៃគ្រឿងចង ៣ យ៉ាង គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ។ សេចក្តីពិត គ្រឿងចងទាំងនោះ រមែងប្រកបខន្ធ គតិ និងភពជាដើម ចូលជាមួយខន្ធ គតិ និងភពជាដើម ។ម្យ៉ាងទៀត រមែងប្រកបកម្មចូលជាមួយផល ដូច្នោះ ទើបគ្រឿងចងទាំងនោះ លោកហៅថា **សំយោជន** អធិប្បាយថា គ្រឿងចង ។

បទថា **បរិក្ខយា** ប្រែថា ព្រោះការអស់ទៅជុំវិញ ។

បទថា **សោតាបន្នោ** បានដល់ បុគ្គលដល់ក្រសែ ។ ពាក្យថា **សោតា** នោះ ជាឈ្មោះរបស់មគ្គ ។ ពាក្យថា **សោតាបន្នោ** ជាឈ្មោះរបស់បុគ្គលដែលដល់ព្រមដោយមគ្គនោះ ។

ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្ត គេតែងពោលថា សោតៈៗ ដូច្នេះ ម្នាលសារីបុត្ត ចុះសោតៈ តើដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯងជាសោតៈ ផ្លូវដ៏ប្រសើរ ប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ គឺសេចក្តីឃើញត្រូវ ១ ការត្រិះរិះត្រូវ ១ ។បេ។ ការតម្កល់ចិត្តនឹងត្រូវ ១ ។

ម្នាលសារីបុត្ត គេតែងពោលថា បុគ្គលជាសោតាបន្ន សោតាបន្ន ដូច្នេះ ម្នាលសារីបុត្ត ចុះបុគ្គលជាសោតាបន្ន តើដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា ប្រកបដោយផ្លូវដ៏ប្រសើរ ប្រកបដោយអង្គ ៨ ហៅថា បុគ្គលជាសោតាបន្ន លោកដ៏មានអាយុនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ ដូច្នេះ ។

តែក្នុងទីនេះ ផលបានឈ្មោះតាមមគ្គ ដូច្នោះ បុគ្គលដែលតាំងនៅក្នុងផល គប្បីជ្រាបថា ជាព្រះសោតាបន្ន ។

បទថា **អវិនិបាតធម្មោ** មានវិគ្គហៈថា ធម៌ដែលឈ្មោះថា វិនិបាត ព្រោះអត្ថថា រមែងញុំាងសត្វឲ្យធ្លាក់ទៅក្នុងទីអាក្រក់ ដែលឈ្មោះថា អវិនិ-បាតធម៌ ព្រោះជាធម៌ដែលមិនញុំាងសត្វឲ្យធ្លាក់ទៅក្នុងទីអាក្រក់ អធិប្បាយថា ជាធម៌ដែលមិនញុំាងខ្លួនឲ្យធ្លាក់ទៅក្នុងអបាយទាំងឡាយជាសភាវៈ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះធម៌ដែលមានការញុំាងសត្វឲ្យធ្លាក់ទៅក្នុងអបាយទាំងនោះ លោកលះបានហើយ ។

បញ្ញាគ្រឿងត្រាស់ដឹង ជាទីទៅខាងមុខ គឺជាគតិរបស់ព្រះសោតាបន្ននោះ ដូច្នោះ ។ ទើបលោកឈ្មោះថា មានបញ្ញាជាគ្រឿងត្រាស់ដឹង ជាទីទៅខាងមុខ អធិប្បាយថា ជាអ្នកសម្រេចមគ្គ ៣ ខាងលើពិតប្រាកដ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះលោកបានសោតាបត្តិមគ្គហើយ ។

បទថា **សីលេសុ** សេចក្ដីថា ភិក្ខុជាអ្នកបំណងនឹងឲ្យខ្លួនមានសភាពយ៉ាងនេះ គប្បីជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយចុះ ។

[ ៨៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ១០ តទៅ សំយោជនៈ ៣ ដែលព្រះយោគាវចរលះបានដោយសោតាបត្តិមគ្គ លោកក៏ពោលទុកដើម្បីប្រយោជន៍ដល់ការពណ៌នាសកទាគាមិមគ្គ ។

បទថា **រាគទោសមោហានំ តនុត្តា** សេចក្ដីថា ព្រោះភាវៈដែលរាគៈទោសៈ មោហៈទាំងនោះ ជាសភាពស្រាលស្ដើង អធិប្បាយថា ព្រោះធ្វើរាគៈ ទោសៈ មោហៈទាំងនោះឲ្យស្រាលស្ដើង ។

ក្នុងពាក្យនោះ គប្បីជ្រាបសេចក្ដីដែលរាគៈជាដើមនោះ ជាធម្មជាតិស្រាលស្ដើងដោយហេតុ ២ ប្រការ គឺព្រោះកើតឡើងជាគ្រា និងព្រោះបរិយុដ្ឋានកិលេសមានកម្លាំងខ្សោយ ។ សេចក្ដីពិត កិលេសទាំងឡាយ រមែងមិនកើតឡើងដល់ព្រះសកទាគាមីរឿយៗ ដូចកើតឡើងដល់មហាជន ដែលត្រាច់ទៅក្នុងវដ្ដៈ ។ រមែងកើតឡើងជាឱកាសៗ ក្នុងគ្រាខ្លះ ដូចពន្លកនៃពូជក្នុង

ស្រែ ដែលដាំឆ្ងាយៗ ពីគ្នា បើកើតឡើង រមែងមិនកើតឡើងញាំញី ជ្រួត ជ្រាប បិទបាំង និងការធ្វើការងងឹតអន្ធការ ដូចកើតដល់មហាជន ដែលវិល វល់ក្នុងវដ្តៈឡើយ រមែងកើតឡើងស្រាលៗ គឺជាធម្មជាតស្រាលកើតឡើង ដូចស្រទាប់នៃពពកដែលស្រាលស្តើងតាមលំដាប់ និងដូចសត្វល្អិតបបោស អង្អែលផ្កា ( មិនធ្វើឲ្យជាំ ) ដូច្នោះ ។

ក្នុងរឿងនោះ ព្រះថេរៈពួកខ្លះបានពោលថា កិលេសទាំងឡាយយូរៗ ទើបកើតឡើងដល់ព្រះសកទាគាមីក៏ពិត ទោះជាយ៉ាងនោះ ក៏កើតឡើងយ៉ាង ក្រាស់ ព្រោះលោកនៅមានបុត្រធីតា ។ តែពាក្យនោះមិនជាប្រមាណ ព្រោះ បុត្រធីតា ជួនកាលក៏កើតមានដល់មាតាបិតា ដោយហេតុត្រឹមតែការស្ទាប អង្អែលអវយវៈ ដូច្នោះ គប្បីជ្រាបកិលេសរបស់ព្រះសកទាគាមីនោះ ជា ធម្មជាតស្រាលស្តើង ដោយហេតុ ២ យ៉ាងប៉ុណ្ណោះ គឺព្រោះការកើតឡើង ម្តងម្កាល និងព្រោះបរិយុដ្ឋានកិលេសរបស់លោកស្រាលស្តើងថយចុះ ។

បទថា **សកទាគាមី** សេចក្តីថា បុគ្គលមានការត្រឡប់មកកាន់លោក នេះត្រឹមតែម្តងប៉ុណ្ណោះ ដោយអំណាចបដិសន្ធិ ។

បុគ្គលណា ចម្រើនសកទាគាមិមគ្គក្នុងលោកនេះហើយ បរិនិព្វានក្នុង លោកនេះ សូម្បីបុគ្គលនោះ លោកក៏មិនចាត់ទុកក្នុងទីនេះ ។ ទោះបុគ្គល ណា ចម្រើនមគ្គក្នុងលោកនេះហើយ កើតឡើងក្នុងទេវលោក ហើយបរិនិព្វាន ក្នុងទេវលោកនោះ បុគ្គលនោះក៏មិនចាត់ចូលក្នុងទីនេះ ។ បុគ្គលណាចម្រើន មគ្គក្នុងទេវលោក ហើយត្រឡប់មកកើត ហើយបរិនិព្វានក្នុងលោកនេះ អ្នក

នោះក៏មិនបាត់ចូលក្នុងទីនេះ ។ បុគ្គលណា ចម្រើនមគ្គក្នុងលោកនេះហើយ កើតឡើងក្នុងទេវលោក តាំងនៅក្នុងទេវលោក រហូតអស់អាយុ ហើយកើតក្នុងទេវលោកនោះទៀត ហើយបរិនិព្វាន បុគ្គលនេះឯង គប្បីជ្រាបថា លោកកាន់យកក្នុងទីនេះ ។

បទថា **ឱក្កស្សន្តំ ករេយ្យំ** សេចក្តីថា អាត្មាអញគប្បីធ្វើការកំណត់វដ្តទុក្ខ ។ បទថា **សីលេសេ្វវ** សេចក្តីថា ភិក្ខុ ទោះជាអ្នកបំណងនឹងឲ្យខ្លួនជាបុគ្គលដូច្នេះ គប្បីជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយចុះ ។

[ ៨៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ១១ តទៅ បទថា **បញ្ចន្នំ** ជាការកំណត់ដោយការរាប់ ។ បទថា **ឱរម្ភាគិយានំ** សេចក្តីថា ខាងក្រោមលោកហៅថា **ឱរ** បានដល់ ចំណែកខាងក្រោម អធិប្បាយថា មានការកើតឡើងក្នុងកាមាវចរលោកជាបច្ច័យ ។

បទថា **សំយោជនានំ** បានដល់ កិលេសជាគ្រឿងចង កិលេសជាគ្រឿងចងទាំងនោះ គប្បីជ្រាបថា បានដល់ សំយោជនៈដែលលោកពោលទុកក្នុងកាលមុន ( គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ) មួយអន្លើដោយសំយោជនៈ គឺកាមរាគៈ និងព្យាបាទ ។ សេចក្តីពិត សំយោជនៈទាំងនោះ បុគ្គលណាលះមិនទាន់បាន សូម្បីបុគ្គលនោះកើតក្នុងភវគ្គព្រហ្មក៏ពិត ទោះជាយ៉ាងនោះ បុគ្គលនោះ ក៏រមែងកើតក្នុងកាមាវចរទៀត ព្រោះអស់អាយុ អ្នកនេះគប្បីជ្រាបថា មានឧបមាដូចត្រីជាប់សន្ទូច និងមានឧបមាដូចបក្សីត្រូវអំបោះចងទុកត្រង់ជើង ។ ដូច្នោះ ក្នុងអធិការនេះ គប្បីជ្រាបថា លោកពោល

ពាក្យនេះទុក ដើម្បីប្រយោជន៍ដល់ការពណ៌នាព្រះអរិយបុគ្គល ដែលលោកពោលទុកអំពីដំបូង ។

បទថា **ឱបបាតិកោ** ជាបទពោលជំទាស់កំណើតដ៏សេស ។

បណ្ដាបទទាំងនោះ បទថា **បរិនិព្វាយិ** សេចក្ដីថា បរិនិព្វានក្នុងព្រហ្មលោកនោះឯង ។ បទថា **អនាវត្តិធម្មោ តស្មា លោកា** សេចក្ដីថា មានការមិនត្រឡប់មកអំពីព្រហ្មលោកនោះ ដោយអំណាចបដិសន្ធិទៀតជាសភាវៈ ។ បទថា **សីលេសុ** សេចក្ដីថា ភិក្ខុជាអ្នកបំណងបានជាបុគ្គលដូច្នេះ គប្បីជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយចុះ ។

[ ៨៥ ] កាលព្រះមានព្រះភាគ ត្រាស់អនាគាមិមគ្គយ៉ាងនេះហើយ សូម្បីមកដល់វារៈនៃមគ្គទី ៤ ក៏ពិត សូម្បីយ៉ាងនោះ ព្រះមានព្រះភាគក៏ទ្រង់មិនកាន់យកអរហត្តមគ្គនោះ ព្រោះមិនត្រឹមតែអភិញ្ញា គឺការអស់ទៅនៃអាសវៈ ជាអានិសង្សនៃសីលតែម្យ៉ាង ដែលពិតនោះ អភិញ្ញា ៥ ប្រការដែលជាលោកិយ ( ក៏ជាអានិសង្សនៃសីលដូចគ្នា ) ដូច្នោះ ដើម្បីទ្រង់សម្ដែងអភិញ្ញាទាំងនោះ និងព្រោះកាលទ្រង់ត្រាស់ដល់ការអស់ទៅនៃអាសវៈទេសនាក៏ជាការចប់ កាលបើដូច្នេះ ការពោលនេះ ក៏ឈ្មោះថា ពោលដល់អភិញ្ញាសុទ្ធ ព្រោះមិនបានពោលដល់គុណរបស់អភិញ្ញាទាំងនោះ ដូច្នោះ ដើម្បីទ្រង់សម្ដែងអភិញ្ញាយ៉ាងបរិបូណ៌ និងព្រោះការធ្វើឫទ្ធិរមែងសម្រេចដល់បុគ្គល ដែលតាំងនៅក្នុងអនាគាមិមគ្គដោយងាយ ។ ហើយព្រះអនាគាមីរមែងជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីល និងក្នុងសមាធិ ព្រោះលោកដកកាមរាគៈ

និងព្យាបាទដែលជាសត្រូវរបស់សមាធិបានហើយ ដូច្នោះ ដើម្បីទ្រង់សំដែងលោកិយអភិញ្ញាទាំងឡាយ ក្នុងឋានៈដ៏គួរ ទើបទ្រង់ត្រាស់ពាក្យជាដើមយ៉ាងនេះថា **អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ អនេកវិហិតំ** នេះឯងជាអនុសន្ធិ ។ ការពណ៌នាបាលីនៃលោកិយអភិញ្ញាទាំង ៥ ដែលមកហើយដោយន័យជាដើមថា **អនេកវិហិតំ ឥទ្ធិវិធំ** ក្នុងបាលីនោះ លោកពោលទុកហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ព្រមទាំងវិធីឲ្យអភិញ្ញាកើតឡើង ។

[ ៩០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអភិញ្ញាទី ៦ តទៅ បទថា **អាសវានំ ខយា** សេចក្តីថា ព្រោះការអស់ទៅនៃកិលេសគ្រប់យ៉ាងដោយអរហត្តមគ្គ ។

បទថា **អនាសវំ** សេចក្តីថា វៀរចាកអាសវៈ ក្នុងពាក្យថា **ចេតោវិមុត្តិ បញ្ញាវិមុត្តិ** នេះ សមាធិដែលសម្បយុត្តដោយអរហត្តផល លោកពោលដោយបទថា **ចេតោ** បញ្ញាដែលសហគតៈដោយអរហត្តមគ្គនោះ លោកពោលទុកដោយពាក្យថា បញ្ញា ។

ក្នុងសមាធិ និងបញ្ញានោះ សមាធិគប្បីជ្រាបថា ឈ្មោះថា ចេតោវិមុត្តិ ព្រោះផុតចាករាគៈ បញ្ញា គប្បីជ្រាបថា ឈ្មោះថា បញ្ញាវិមុត្តិ ព្រោះរួចផុតចាកអវិជ្ជា ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សមាធិឯណាគប្បីមាន សមាធិនោះគប្បីជាសមាធិន្ទ្រិយ ម្នាលភិក្ខុទាំងឡាយ បញ្ញាណាគប្បីមាន បញ្ញានោះ គប្បីជាបញ្ញិន្ទ្រិយ ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ចេតោវិមុត្តិ ព្រោះរួចផុតចាករាគៈ ឈ្មោះថា បញ្ញាវិមុត្តិ ព្រោះរួចផុត អវិជ្ជាយ៉ាងនេះឯង ។

ម្យ៉ាងទៀត ក្នុងអធិការនេះ ផលនៃសមថៈ គប្បីជ្រាបថា ជាចេតោវិមុត្តិ ផលរបស់វិបស្សនា គប្បីជ្រាបថា ជាបញ្ញាវិមុត្តិ ។

បទថា **ទិដ្ឋេវ ធម្មេ** បានដល់ ក្នុងអត្តភាពនេះឯង ។

បទថា **សយំ អភិញ្ញា សច្ឆិកត្វា** សេចក្ដីថា ធ្វើឲ្យប្រចក្សដោយបញ្ញាខ្លួនឯង អធិប្បាយថា ដឹងដោយមិនមានអ្នកដទៃជាបច្ច័យ ។

បទថា **ឧបសម្បជ្ជ វិហរេយ្យំ** សេចក្ដីថា អាត្មាអញគប្បីសម្រេច គឺឲ្យដល់ព្រម ។

បទថា **សីលេស្វេវ** សេចក្ដីថា ភិក្ខុទោះបំណងនឹងឲ្យអាសវៈទាំងនោះដល់នូវការរលត់យ៉ាងនេះ សម្រេចចេតោវិមុត្តិ និងបញ្ញាវិមុត្តិ គប្បីជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយចុះ ។

ព្រះមានព្រះភាគ កាលត្រាស់ពណ៌នាអានិសង្សនៃសីល រហូតដល់ព្រះអរហត្តយ៉ាងនេះហើយ កាលទ្រង់សង្គ្រោះសម្ដែងអានិសង្សនៃសីលទាំងអស់នោះ ទើបត្រាស់ពាក្យចុងក្រោយថា **សម្បន្នសីលា ភិក្ខវេ ។បេ។ ឥធមេតំ បដិច្ច វុត្តំ** ដូច្នេះ ពាក្យចុងក្រោយនោះ មានសេចក្ដីសង្ខេបដូចតទៅនេះថា

បទថា **សម្បន្នសីលា ភិក្ខវេ វិហរថ ។បេ។ សិក្ខាបទេសូតិ ឥតិ យន្តំ វុត្តំ** សេចក្ដីថា ពាក្យណា តថាគតពោលទុកហើយយ៉ាងនេះក្នុងកាលមុន ពាក្យទាំងអស់នោះ តថាគតពោលសំដៅដល់ភិក្ខុដែលសម្បូរដោយសីលជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើររបស់សព្រហ្មចារី ជាអ្នកបានបច្ច័យ ជាអ្នកធ្វើទាយកឲ្យមានផលច្រើន ជាអ្នកធ្វើចេតនា គឺការ

វព្រកបុព្វញ្ញាតិឲ្យមានផលច្រើន ជាអ្នកអត់ធន់ចំពោះភ័យ និងការខ្លាច ជាអ្នកបានរូបាវចរជ្ឈាន និងអរូបាវចរជ្ឈាន ជាអ្នកធ្វើឲ្យជាក់ច្បាស់នូវគុណទាំងនេះ គឺសាមញ្ញផល ៣ ខាងក្រោម លោកិយអភិញ្ញា ៥ អាសវក្ខយញ្ញាណ ដោយអភិញ្ញាដោយខ្លួនឯង ។

ព្រះមានព្រះភាគបានត្រាស់ពាក្យនេះហើយ ភិក្ខុទាំងឡាយនោះ ក៏មានចិត្តត្រេកអរ រីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ដូច្នេះឯង ។ល។

**អាកង្ខេយ្យសូត្រ ចប់**

**សូត្រទី ៦ ចប់**

# សុត្តន្តបិដក

## វត្ថូបមសូត្រទី ៧

[ ៩១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងជេតវនារាម ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ដូច្នេះ ។ ពួកភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ដូច្នេះ ។

[ ៩២ ] ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ដូចជាសំពត់ដែលសៅហ្មង មានមន្ទិលកាន់ ជាងជ្រលក់យកសំពត់នោះដាក់ក្នុងគ្រឿងជ្រលក់ណាៗ ដែលមានពណ៌ខៀវក្តី លឿងក្តី ក្រហមក្តី ហង្សបាទក្តី សំពត់នោះក៏នៅតែមានពណ៌មិនល្អ មានពណ៌មិនស្អាត ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា សំពត់នោះមិនស្អាត ម្នាលភិក្ខុទាំងឡាយ កាលបើចិត្តសៅហ្មងហើយ ទុគ្គតិនឹងមានប្រាកដ ដូចសេចក្តីឧបមានោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសំពត់ស្អាតផូរផង់ ជាងជ្រលក់យកសំពត់នោះដាក់ក្នុងគ្រឿងជ្រលក់ណាៗ ដែលមានពណ៌ខៀវក្តី លឿងក្តី ក្រហមក្តី ហង្សបាទក្តី សំពត់នោះក៏នៅជាមានពណ៌ល្អ មានពណ៌ស្អាត ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា សំពត់នោះស្អាត ម្នាលភិក្ខុទាំងឡាយ កាលបើចិត្តមិនសៅហ្មងហើយ សុគតិនឹងមានប្រាកដ ដូចសេចក្តីឧបមានោះដែរ ។

[៩៣] ម្នាលភិក្ខុទាំងឡាយ ពួកឧបក្កិលេស គឺសេចក្តីសៅហ្មងនៃចិត្ត តើដូចម្តេច ។ គឺអភិជ្ឈាវិសមលោភៈ ជាឧបក្កិលេសនៃចិត្ត ១ ព្យាបាទ ជាឧបក្កិលេសនៃចិត្ត ១ កោធៈជាឧបក្កិលេសនៃចិត្ត ១ ឧបនាហៈ ( ការចងកំហឹងទុក ) ជាឧបក្កិលេសនៃចិត្ត ១ មក្ខៈ ( ការលុបគុណរបស់លោកអ្នកមានគុណ ) ជាឧបក្កិលេសនៃចិត្ត ១ បលាសៈ ( ការកាន់យកឫកប្រៀបផ្ទឹម ឬប្រណាំងវាស្នា ) ជាឧបក្កិលេសនៃចិត្ត ១ ឥស្សា ( សេចក្តីច្រណែន ) ជាឧបក្កិលេសនៃចិត្ត ១ មច្ឆរិយៈ ( សេចក្តីកំណាញ់ ) ជាឧបក្កិលេសនៃចិត្ត ១ មាយា ( ការប្រព្រឹត្តលាក់ពុតបិទបាំងទោស ) ជាឧបក្កិលេសនៃចិត្ត ១ សាឋេយ្យៈជាឧបក្កិលេសនៃចិត្ត ១ ថម្ភៈ[១] ( សេចក្តីរឹងត្អឹង ) ជាឧបក្កិលេសនៃចិត្ត ១ សារម្ភៈ[២] ( ការប្រណាំងប្រជែង ) ជាឧបក្កិលេសនៃចិត្ត ១ មានះ ( សេចក្តីប្រកាន់ខ្លួន ) ជាឧបក្កិលេសនៃចិត្ត ១ អតិមានះ ( សេចក្តីប្រកាន់ខ្លួនខ្លាំងពេក ) ជាឧបក្កិលេសនៃចិត្ត ១ មទៈ

---

១- ក្នុងអដ្ឋកថាព្រះអភិធម្មថា សេចក្តីរឹងត្អឹងរបស់ចិត្ត ប្រៀបដូចសំពត់សាជកដែលរឹងដោយបាយម៉ាន បុគ្គលដែលប្រកបដោយថម្ភៈនោះ រមែងជាអ្នកគ្មានសភាពរាបទាប ជាអ្នកព្រហើនប៉ោងឡើង ប្រៀបដូចពស់ថ្លាន់ដែលលេបផ្សៀងនង្គ័ល ឬប្រៀបដូចថ្លោកស្បែកដែលពេញដោយខ្យល់ កាលបើឃើញចេតិយ ឬបុគ្គលចាស់ជាងខ្លួន ក៏មិនធ្វើសេចក្តីឱនលំទោន ។ ២- សារម្ភៈមានលក្ខណៈ ធ្វើអំពើឲ្យលើសលុបជាងគេ ចែកជាពីរផ្នែក ជាអកុសលក៏មាន ជាកុសលក៏មាន ចំណែកខាងគ្រហស្ថ កាលបើឃើញគេធ្វើគ្រឿងប្រដាប់កាយជាដើម ក៏ប្រឹងឲ្យច្រើនជាងគេជាទ្វេគុណ ចំណែកអ្នកបួស កាលបើឃើញគេរៀនធម៌បានប៉ុន្មានៗ ក៏ខំប្រឹងរៀនឲ្យបានច្រើនជាងគេជាទ្វេគុណ ម្យ៉ាងទៀត ចំណែកគ្រហស្ថ កាលបើឃើញគេធ្វើសលាកភត្ត ១ ខ្លួនក៏ចង់ធ្វើឲ្យបានពីរ ឬបី ចំណែកអ្នកបួស កាលធ្វើឃើញគេរៀនបានគម្ពីរនិកាយ ១ ខ្លួនក៏ចង់រៀនឲ្យបាននិកាយពីរ តែក្នុងទីនេះ សំដៅយកតែអកុសល ។

( សេចក្ដីស្រវឹង ) ជាឧបក្កិលេសនៃចិត្ត ១ បមាទៈ ( ការប្រហែសធ្វេស ឬ បណ្ដោយចិត្ត ទៅក្នុងកាមគុណ ) ជាឧបក្កិលេសនៃចិត្ត ១ ។

[៩៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង លុះដឹងច្បាស់ថា អភិជ្ឈាវិសមលោភៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវអភិជ្ឈាវិសមលោភៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា ព្យាបាទ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវព្យាបាទ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា កោធៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវកោធៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា ឧបនាហៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះបង់នូវឧបនាហៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា មក្ខៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវមក្ខៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា បលាសៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវបឡាសៈ ជា ឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា ឥស្សា ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវឥស្សា ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា មច្ឆរិយៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវមច្ឆរិយៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា មាយា ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវមាយា ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា សាឋេយ្យៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវសាឋេយ្យៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់

ថា ថម្ភៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវថម្ភៈ ជាឧបក្កិ-
លេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា សារម្ភៈ ជាឧបក្កិលេសចិត្ត
ដូច្នេះហើយ ក៏រមែងលះនូវសារម្ភៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះ
ដឹងច្បាស់ថា មានះ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវមានះ
ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា អតិមានះ ជាឧបក្កិលេស
នៃចិត្តដូច្នេះហើយ ក៏រមែងលះនូវអតិមានះ ជាឧបក្កិលេសនៃចិត្តចេញបាន ។
លុះដឹងច្បាស់ថា មទៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ ក៏រមែងលះនូវមទៈ
ជាឧបក្កិលេសនៃចិត្តចេញបាន ។ លុះដឹងច្បាស់ថា បមាទៈ ជាឧបក្កិលេស
នៃចិត្តដូច្នេះហើយ ក៏រមែងលះនូវបមាទៈ ជាឧបក្កិលេសនៃចិត្តចេញបាន ។

[៩៥] ម្នាលភិក្ខុទាំងឡាយ កាលណា បើភិក្ខុដឹងច្បាស់ថា អភិជ្ឈាវិ-
សមលោភៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ បានលះអភិជ្ឈាវិសមលោភៈ
ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា ព្យាបាទ ជាឧបក្កិលេសនៃចិត្តដូច្នេះ
ហើយបានលះព្យាបាទ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា កោធៈ ជា
ឧបក្កិលេសនៃចិត្តដូច្នេះហើយ បានលះកោធៈ ជាឧបក្កិលេសនៃចិត្ត ។
ដឹងច្បាស់ថា ឧបនាហៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ បានលះឧបនាហៈ
ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា មក្ខៈ ជាឧបក្កិលេសនៃចិត្តដូច្នេះ
ហើយ បានលះមក្ខៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា បលាសៈ ជា
ឧបក្កិលេសនៃចិត្តដូច្នេះហើយ បានលះបលាសៈ ជាឧបក្កិលេសនៃចិត្ត ។
ដឹងច្បាស់ថា ឥស្សា ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ បានលះឥស្សា ជា

ឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា មច្ឆរិយៈ ជាឧបក្កិលេសនៃចិត្តដូច្នេះ ហើយ បានលះមច្ឆរិយៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា មាយា ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ បានលះមាយា ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា សាឋេយ្យៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ បានលះសាឋេយ្យៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា ថម្ភៈ ជាឧបក្កិលេសនៃចិត្តដូច្នេះ ហើយ បានលះថម្ភៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា សារម្ភៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ បានលះសារម្ភៈ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា មានះ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ បានលះមានះ ជាឧបក្កិ-លេសនៃចិត្ត ។ ដឹងច្បាស់ថា អតិមានះ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ បានលះអតិមានះ ជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា មទៈ ជាឧបក្កិ-លេសនៃចិត្តដូច្នេះហើយ បានលះមទៈជាឧបក្កិលេសនៃចិត្ត ។ ដឹងច្បាស់ថា បមាទៈ ជាឧបក្កិលេសនៃចិត្តដូច្នេះហើយ បានលះបមាទៈ ជាឧបក្កិលេសនៃចិត្ត ។ ភិក្ខុនោះរមែងជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះពុទ្ធដូច្នេះថា ព្រះមានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ គឺសេចក្ដីចេះដឹង និងកិរិយាដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថី អ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតា និង

មនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិល ត្រឡប់មកកាន់កពថ្មីទៀតៗ រមែងជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ ញ័រក្នុងព្រះធម៌ថា ព្រះបរិយត្តិធម៌ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែង ហើយដោយល្អ ព្រះលោកុត្តរធម៌ ជាធម៌ដែលព្រះអរិយបុគ្គលទាំងពួងដឹង ពិត ឃើញពិត ដោយបច្ចវេក្ខណញ្ញាណ ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌ដែលព្រះអរិយបុគ្គល គប្បីបង្អោនចូល មកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ មាន ឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ៗ រមែងជាអ្នក ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះសង្ឃថា ពួកសាវកនៃព្រះ មានព្រះភាគប្រតិបត្តិប្រពៃ ពួកសាវកនៃព្រះមានព្រះភាគប្រតិបត្តិត្រង់ ពួក សាវកនៃព្រះមានព្រះភាគ ប្រតិបត្តិដើម្បីព្រះនិព្វាន ពួកសាវកនៃព្រះមាន ព្រះភាគប្រតិបត្តិសមគួរ គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា បុរស បុគ្គលណា បើរាប់ជាគូ បាន ៤ គូ បើរាប់រៀងទៅបាន ៨ ពួកសាវករបស់ ព្រះមានព្រះភាគនេះ គួរទទួលនូវចតុប្បច្ច័យដែលបុគ្គលនាំមកអំពីចម្ងាយ បូជា គួរទទួលនូវអាគន្តុកទាន គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ៗ កាលណាបើភិក្ខុ នោះលះបោលហើយ ខ្ជាក់បោលហើយ ជម្រុះបោលហើយ លះលែងបោល ហើយ រលាស់បោលហើយ ( នូវឧបក្កិលេសទាំងនោះ ) ដោយឱធិ[១] គឺ

---

១- ឱធិ ប្រែថា ចំណែក ឬជួរ ។

មគ្គខាងក្រោមទាំង ៣ ។ ភិក្ខុនោះរមែងបាននូវសេចក្តីត្រេកអរក្នុងអត្ថ បាននូវសេចក្តីត្រេកអរក្នុងធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ ដោយគិតថា អាត្មាអញជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះពុទ្ធ ដូច្នេះ កាលបើភិក្ខុនោះមានចិត្តរីករាយហើយ បីតិក៏កើត កាលបើភិក្ខុមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះភិក្ខុមានកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបើភិក្ខុមានសេចក្តីសុខហើយ ចិត្តក៏តម្កល់នៅល្អ ។ ក្នុងព្រះធម៌ ។បេ។ រមែងបាននូវសេចក្តីត្រេកអរក្នុងអត្ថ បាននូវសេចក្តីត្រេកអរក្នុងធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ ដោយគិតថា អាត្មាអញជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះសង្ឃ ដូច្នេះ កាលបើភិក្ខុនោះមានចិត្តរីករាយហើយ បីតិក៏កើត កាលបើភិក្ខុមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះភិក្ខុមានកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបើភិក្ខុមានសេចក្តីសុខហើយ ចិត្តក៏បានតម្កល់នៅល្អ ។ រមែងបាននូវសេចក្តីត្រេកអរក្នុងអត្ថ បាននូវសេចក្តីត្រេកអរក្នុងធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ ដោយគិតថា អាត្មាអញបានលះបោលហើយ ខ្ជាក់ចោលហើយ ជម្រុះចោលហើយ លះលែងចោលហើយ រលាស់ចោលហើយ នូវឧបក្កិលេសទាំងនោះ ដោយឱធិ គឺមគ្គខាងក្រោមទាំង ៣ ដូច្នេះ កាលបើភិក្ខុមានចិត្តរីករាយហើយ បីតិក៏កើត កាលបើភិក្ខុមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះភិក្ខុមានកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបើភិក្ខុមានសេចក្តី

សុខហើយ ចិត្តក៏រមែងតម្កល់នៅល្អ ។

[ ៩៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯងមានសីលយ៉ាងនេះ មានធម៌យ៉ាងនេះ មានប្រាជ្ញាយ៉ាងនេះ រមែងបរិភោគនូវបាយនៃស្រូវសាលីដែលប្រាសចាកពណ៌ខ្មៅ មានសម្លច្រើនមុខ មានម្ហូបគ្រៀមច្រើនមុខ ការបរិភោគនោះមិនមានអន្តរាយដល់ភិក្ខុនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសំពត់ដែលសៅហ្មង មានមន្ទិលកាន់ហើយ ទៅជាសំពត់ស្អាតផូរផង់ ព្រោះអាស្រ័យទឹកថ្លា ម្យ៉ាងទៀត មាសដែលបរិសុទ្ធស្អាតផូរផង់ ព្រោះអាស្រ័យមាត់បាវ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសីលយ៉ាងនេះ មានធម៌យ៉ាងនេះ មានប្រាជ្ញាយ៉ាងនេះ បរិភោគនូវបិណ្ឌបាតនៃស្រូវសាលី ដែលប្រាសចាកពណ៌ខ្មៅ មានសម្លច្រើនមុខ មានម្ហូបគ្រៀមច្រើនមុខ ការបរិភោគនោះ មិនមានអន្តរាយដល់ភិក្ខុនោះ យ៉ាងនោះដែរ ។

[ ៩៧ ] ភិក្ខុនោះរមែងមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា ។ រមែងមានចិត្តប្រកបដោយមេត្តា ជាចិត្តធំទូលាយ ដល់នូវភាវៈជាធំ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម និងទិសទទឹង[១] ផ្សាយទៅកាន់ទិសទាំងពួង ដោយប្រការទាំងពួង ក្នុងទីទាំងពួង ។ មានចិត្តប្រកបដោយករុណា ។បេ។ មានចិត្តប្រកបដោយមុទិតា ។បេ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទី ៣

---

១- ទិសអាគ្នេយ៍ ១ ទិសនិរតី ១ ទិសពាយព្យ ១ ទិសឦសាន ១ ។

ទី ៤ ក៏ដូចគ្នា ។ មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តធំទូលាយ ដល់នូវភាវៈធំរកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម និងទិសទទឹង ផ្សាយទៅកាន់លោកទាំងពួង ដោយប្រការទាំងពួង ក្នុងទីទាំងពួង ។ ភិក្ខុនោះរមែងដឹងច្បាស់ថា ទុក្ខសច្ចនេះនៅមាន សមុទយសច្ចដែលគួរលះបង់នៅមាន មគ្គសច្ចដ៏ប្រសើរក៏នៅមាន និរោធសច្ចជាគ្រឿងរលាស់ចេញនូវសញ្ញានេះតទៅក៏នៅមាន ។ កាលភិក្ខុនោះដឹងយ៉ាងនេះហើយ ឃើញយ៉ាងនេះហើយ ចិត្តរមែងរួចចាកកាមាសវៈផង ចិត្តរមែងរួចចាកភវាសវៈផង ចិត្តរមែងរួចចាកអវិជ្ជាសវៈផង កាលបើចិត្តរួចស្រឡះហើយ ប្រាជ្ញាក៏កើតឡើងថា ចិត្តរួចស្រឡះហើយ ដូច្នេះ ភិក្ខុនោះក៏ដឹងច្បាស់ថា ជាតិ ( របស់អាត្មាអញ ) អស់ហើយ មគ្គព្រហ្មចារ្យ ( របស់អាត្មាអញ ) បាននៅរួចហើយ សោឡសកិច្ចដែលអាត្មាអញធ្វើ ក៏បានធ្វើហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា ជាអ្នកលាងជម្រះដោយគ្រឿងសម្រាប់លាងជម្រះ ( នូវកិលេស ) ខាងក្នុង ។

[ ៩៨ ] សម័យនោះឯង មានព្រាហ្មណ៍ម្នាក់ឈ្មោះសុន្ទរិកភារទ្វាជៈអង្គុយនៅជិតព្រះមានព្រះភាគ ។ លំដាប់នោះឯង សុន្ទរិកភារទ្វាជព្រាហ្មណ៍ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា ចុះព្រះគោតមដ៏ចម្រើន ធ្លាប់ស្តេចទៅកាន់ស្ទឹងពាហុកា ដើម្បីលាងជម្រះដែរឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ប្រយោជន៍អ្វីដោយស្ទឹងពាហុកា ស្ទឹងពាហុកា

នោះនឹងធ្វើអ្វីឲ្យ ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថា ស្ទឹងពាហុកា មានជនច្រើនគ្នាសន្មតហើយ ថាជាស្ទឹងបរិសុទ្ធ បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថា ស្ទឹងពាហុកា មានជនច្រើនគ្នាសន្មត ហើយ ថាជាបុណ្យ ម្យ៉ាងទៀត ជនច្រើនគ្នាតែងបណ្តែតបាបកម្ម ដែលគេធ្វើហើយ ចោលទៅក្នុងស្ទឹងពាហុកា ( នេះដែរ ) ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សម្តែងដោយបទគាថាទាំងឡាយ ចំពោះសុន្ទរិកភារទ្វាជ-ព្រាហ្មណ៍ថា

ជនពាល មានបាបកម្មអាក្រក់ ( ក្នុងសន្តាន ) បើទុកជា ចូលទៅកាន់ស្ទឹងពាហុកាក្តី កាន់កំពង់ឈ្មោះអធិកក្កៈក្តី កាន់កំពង់ឈ្មោះគយាក្តី[១] កាន់ស្ទឹងឈ្មោះសុន្ទរិកាក្តី កាន់ស្ទឹងឈ្មោះសរស្សតីក្តី កាន់កំពង់ឈ្មោះបយាគក្តី ឬក៏កាន់ស្ទឹងឈ្មោះពាហុមតីក្តី អស់កាលជានិច្ច ក៏នៅតែមិនស្អាតឡើយ ព្រោះថា ស្ទឹងឈ្មោះសុន្ទិកានឹងធ្វើអ្វីឲ្យ កំពង់ឈ្មោះបយាគៈនឹងធ្វើអ្វីឲ្យ ស្ទឹងឈ្មោះពាហុកានឹងធ្វើអ្វីឲ្យ ។ ព្រោះថា ស្ទឹងឈ្មោះសុន្ទរិកាជាដើម មិនដែលលាងជម្រះសត្វមានពៀរ មានបាបកម្មដ៏ក្លៀវក្លា ដែលខ្លួនធ្វើហើយ មានកម្មដ៏លាមកនោះ ឲ្យស្អាតបានឡើយ ផគ្គុណឫក្សតែងមានសព្វៗ កាល ដល់បុគ្គលដែលបរិសុទ្ធ ឧបោសថតែងមានសព្វៗ កាល ដល់

---

១- កំពង់មានសណ្ឋានដូចបឹងមូល ។

បុគ្គលដែលបរិសុទ្ធ ការកាន់យកនូវវត្ត តែងសម្រេចសព្វៗ កាល ដល់បុគ្គលដែលបរិសុទ្ធ មានកម្មដ៏ស្អាត ។ ម្នាល ព្រាហ្មណ៍ អ្នកចូរលាងជម្រះខ្លួនក្នុងសាសនាតថាគតនេះវិញ អ្នកចូរធ្វើសេចក្តីក្សេមក្សាន្តចំពោះពួកសត្វទាំងពួងចុះ បើអ្នក មិននិយាយកុហក បើអ្នកមិនបៀតបៀនសត្វ បើអ្នកមិនកាន់ យកនូវទ្រព្យដែលគេមិនបានឲ្យ មានចិត្តជឿហើយ មិនមាន សេចក្តីកំណាញ់ អ្នកចាំបាច់ទៅកាន់កំពង់ទឹកធ្វើអ្វីទៀត អ្នក ផឹកទឹក ( ឬងូត ) តែក្នុងកំពង់ទឹករបស់អ្នកឯង ( បាន ហើយ ) ។

[ ៩៩ ] កាលបើព្រះមានព្រះភាគ មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ទើបសុន្ទរិកភារទ្វាជព្រាហ្មណ៍ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រ ព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេក- បរិយាយយ៉ាងនេះ ហាក់ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬក៏ដូចជាគេបើក បង្ហាញរបស់ដែលកំបាំង ពុំនោះ ដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះ សោត ដូចជាគេកាន់ប្រទីបទ្រោលបំភ្លឺ ក្នុងទីងងឹតដោយគិតថា មនុស្សមាន ភ្នែក តែងមើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតម ដ៏ចម្រើនផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរឭក ខ្ញុំព្រះអង្គសូម បាន នូវបព្វជ្ជា សូមបាននូវឧបសម្បទា ក្នុងសំណាក់នៃព្រះគោតមដ៏ចម្រើន ។

សុន្ទរិកភារទ្វាជព្រាហ្មណ៍ក៏បានបព្វជ្ជា បានឧបសម្បទាក្នុងសំណាក់នៃព្រះមានព្រះភាគ ។ ភារទ្វាជភិក្ខុដ៏មានអាយុ ដែលបានឧបសម្បទា មិនទាន់អស់កាលយូរប៉ុន្មាន ជាភិក្ខុម្នាក់ឯង ចៀសចេញ ( ចាកពួក ) ជាអ្នកមិនប្រមាទ មានព្យាយាម ដុតបំផ្លាញកិលេស មានចិត្តស្ទុះទៅកាន់ ( ព្រះនិព្វាន ) ពួកកុលបុត្រដែលចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ( ភារទ្វាជភិក្ខុ ) ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចារ្យ ដោយប្រាជ្ញារបស់ខ្លួនដោយខ្លួនឯងក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ មិនយូរប៉ុន្មាន ក៏បានដឹងច្បាស់ថា ជាតិកំណើតរបស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌ អញក៏បាននៅរួចហើយ កិច្ចដែលត្រូវធ្វើអញបានធ្វើហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ភារទ្វាជភិក្ខុដ៏មានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

**វត្ថូបមសូត្រជាគម្រប់ ៧ ចប់**

# អដ្ឋកថា

# វត្ថូបមសូត្រ

[ ៩១-៩២ ] វត្ថូបមសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ។

បណ្ដាបទទាំងនោះ បទនេះថា **ភិក្ខវេ យថា វត្ថំ** ក្នុងបទថា **សេយ្យថាបិ ភិក្ខវេ វត្ថំ** ជាបទឧបមា ។ ព្រះមានព្រះភាគ កាលទ្រង់ឧបមាក្នុងកន្លែងខ្លះ ទ្រង់សម្ដែងឧបមាជាមុននោះឯង ទើបទ្រង់សម្ដែងឧបមេយ្យ គឺការប្រៀបសេចក្ដីក្នុងកាលជាក្រោយ ក្នុងទីខ្លះទ្រង់សម្ដែងឧបមេយ្យមុនហើយ ទើបទ្រង់សម្ដែងឧបមាជាក្រោយ ក្នុងកន្លែងខ្លះ ទ្រង់នាំឧបមាសម្ដែងប្រកបឧបមេយ្យ ក្នុងទីខ្លះ ទ្រង់នាំឧបមេយ្យសម្ដែងប្រកបឧបមា ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះ កាលទ្រង់សម្ដែងទេវទូតសូត្រទាំងមូលឲ្យជាឧបមាមុន ហើយសម្ដែងឧបមេយ្យក្នុងកាលខាងក្រោយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មានផ្ទះ ២ ខ្នង ប្រកបដោយទ្វារ មានបុរសភ្នែកភ្លឺម្នាក់ ឈរចំកណ្ដាល គប្បីឃើញពួកមនុស្ស ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់សម្ដែងឧបមេយ្យ ដែលជាឥទ្ធិវិធទាំងអស់មុនហើយ សម្ដែងឧបមាក្នុងកាលខាងក្រោយ ទើបត្រាស់ដោយន័យជាដើមថា ភិក្ខុនោះដើរទម្លុះទៅខាងក្រៅជញ្ជាំង ខាងក្រៅកំពែង ខាងក្រៅភ្នំ មិនទើសទាក់ ដូចជាដើរទៅក្នុងទីវាលក៏បាន ដូច្នោះ ។

កាលទ្រង់យកឧបមាមកដោយជុំវិញ គឺសម្ដែងប្រកបជាមួយឧបមេយ្យ ទើបបានត្រាស់ចូឡសារោបមសូត្រទាំងមូល ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ដូច្នោះ ។

ម្យ៉ាងទៀត កាលទ្រង់យកឧបមេយ្យមកសម្តែងប្រកបនឹងឧបមា ទើបត្រាស់សូត្រទាំងឡាយ មានអលគទ្ទូបមសូត្រ និងមហាសារោបមសូត្រទាំងមូល ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានមោឃបុរសពួកខ្លះ រៀនធម៌ គឺសុត្តៈ ។បេ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសអ្នកត្រូវការដោយពស់វែក ដូច្នោះ ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់សម្តែងពាក្យឧបមាមុនក្នុងទីនេះហើយ ទ្រង់សម្តែងឧបមេយ្យក្នុងកាលជាក្រោយ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគសម្តែងយ៉ាងនេះ ឆ្លើយថា ព្រោះអជ្ឈាស្រ័យរបស់បុគ្គល ឬព្រោះទ្រង់ពង្រីកទេសនា ។

ពិតហើយ បុគ្គលណាយល់ឧបមេយ្យ ដែលព្រះអង្គត្រាស់សម្តែងឧបមាមុនបានដោយងាយ ព្រះមានព្រះភាគទ្រង់រមែងសម្តែងឧបមាមុនដល់កុលបុត្រទាំងនោះ ។ គ្រប់បទទាំងអស់ក៏ន័យនេះ ។ ម្យ៉ាងទៀត ព្រោះទ្រង់ត្រាស់ដឹងធម្មជាតណាដោយល្អ ទើបព្រះមានព្រះភាគ ឈ្មោះថា ទ្រង់ជំនាញក្នុងការពង្រីកទេសនាធម្មជាតុនោះ ដែលទ្រង់ចាក់ធ្លុះដោយល្អហើយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគអង្គនោះ ទ្រង់ជាធម្មិស្សរធម្មរាជា ជំនាញក្នុងការពង្រីកព្រះធម្មទេសនា ព្រះអង្គរមែងសម្តែងធម៌បានតាមដែលទ្រង់ប្រាថ្នាដោយប្រការដូចពោលមកនេះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌យ៉ាងនេះ គឺព្រោះអជ្ឈាស្រ័យរបស់បុគ្គលផង ព្រោះទ្រង់ពង្រីកទេសនានោះផង ។

បណ្តាបទទាំងនោះ បទថា **វត្ថំ** បានដល់ សំពត់ស្អាតតាមប្រក្រតី ។

បទថា **សង្កិលិដ្ឋំ មលគ្គហិតំ** សេចក្តីថា ឈ្មោះថា សៅហ្មងហើយ ព្រោះគ្រឿងសៅហ្មង មានល្អងធូលីជាដើម ដែលហុយមកជាប់ និងឈ្មោះថា ដែលមន្ទិលកាន់ហើយ ព្រោះត្រូវមន្ទិល មានក្អែលជាដើមប្រឡាក់ហើយ ។ **រង្គជាត** ក្នុងបទថា **រង្គជាតេ** នេះ បានដល់ ទឹកជ្រលក់នោះឯង ។ បទថា **ឧបសំហរេយ្យ** ប្រែថា គប្បីបង្អោនចូលទៅ ។

បទថា **យទិ នីលកាយ** លោកពោលអធិប្បាយទុកថា ដើម្បីឲ្យមានពណ៌ខៀវ ។ គ្រប់បទទាំងអស់ក៏ន័យនេះ ។ ពិតហើយ ជាងជ្រលក់ កាលនាំសំពត់ទៅជ្រលក់ ដើម្បីឲ្យមានពណ៌ខៀវ ក៏នឹងនាំសំពត់ទៅត្រាំក្នុងទឹកជ្រលក់ពណ៌ខៀវ មានពណ៌ខ្មៅដូចសរីទ្ធ និងពណ៌ខៀវស្លឹកឈើជាដើម កាលនាំសំពត់ទៅជ្រលក់ ដើម្បីឲ្យចេញជាពណ៌លឿង ក៏ត្រូវនាំសំពត់ទៅត្រាំក្នុងទឹកជ្រលក់ពណ៌លឿង ដូចជាផ្កាកណិការ កាលនាំសំពត់ទៅជ្រលក់ ដើម្បីឲ្យជាពណ៌ក្រហម ក៏នឹងនាំសំពត់ទៅត្រាំក្នុងទឹក ជ្រលក់ពណ៌ក្រហម ដូចជាផ្កាចប្បា កាលនាំសំពត់ទៅជ្រលក់ ដើម្បីឲ្យមានពណ៌ហង្សបាទ ក៏នាំសំពត់ទៅត្រាំក្នុងទឹកជ្រលក់ពណ៌ហង្សបាទ ដូចជាផ្កាកណវីរៈ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **យទិ នីលកាយ ។បេ។ យទិ មញ្ជេដ្ឋ-កាយ** ដូច្នេះ ។ បទថា **ទុរត្តវណ្ណោមេវស្ស** បានដល់ គប្បីជាសំពត់មានពណ៌ ដែលជ្រលក់ហើយមិនល្អនោះឯង ។

បទថា **អបរិសុទ្ធវណ្ណោមេវស្ស** សេចក្តីថា សូម្បីពណ៌ខៀវរបស់សំពត់នោះ ក៏មិនបរិសុទ្ធ សូម្បីពណ៌ដ៏សេស ក៏មិនបរិសុទ្ធដូចគ្នា ។ សេចក្តីពិត

សំពត់ដូច្នោះ សូម្បីគេត្រាំចូលទៅក្នុងថ្នាំងទឹកជ្រលក់ពណ៌ខៀវ ក៏មិនជាពណ៌ខៀវសុទ្ធ សូម្បីត្រាំចូលទៅក្នុងថ្នាំងទឹកជ្រលក់ដ៏សេស ក៏មិនមែនជាពណ៌សុទ្ធ មានពណ៌លឿងសុទ្ធជាដើម រមែងមានពណ៌ខៀវស្មោក ពណ៌ស្មោកខ្ទុយដ៏រក្រៀម ពណ៌ផ្កាកណិការក្រៀម និងពណ៌ផ្កាច្បាក្រៀម និងពណ៌ផ្កាកណវីរៈ(ផ្កាយីថោ) ក្រៀមប៉ុណ្ណោះ ។

បទថា **តំ កិស្ស ហេតុ** សេចក្ដីថា សំពត់នោះមានសភាពដូច្នេះ ព្រោះហេតុអ្វី គឺព្រោះមានអ្វីជាហេតុ ម្យ៉ាងទៀត ទឹកជ្រលក់ធ្វើសំពត់នោះឲ្យមានសភាពដូច្នេះ គឺមានពណ៌មិនស្អាត មិនបរិសុទ្ធ ព្រោះហេតុអ្វី ក៏ព្រោះការដែលសំពត់នោះមិនស្អាតនោះឯងជាហេតុក្នុងសេចក្ដីនេះ មិនមែនហេតុដទៃឡើយ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **អបរិសុទ្ធត្តា ភិក្ខវេ វត្ថស្ស** ដូច្នេះ ពាក្យថា **ឯវមេវ** ជាពាក្យឧបមេយ្យ ។

ពីរបទថា **ចិត្តេ សង្កិលិដ្ឋេ** សេចក្ដីថា កាលចិត្តសៅហ្មងហើយ ។

បើមានពាក្យសួរជ្រៀតចូលមកថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ធ្វើពាក្យឧបមាទុកដោយសំពត់ដែលសៅហ្មងហើយ ។

ឆ្លើយថា ដើម្បីទ្រង់សម្ដែងថា ការព្យាយាមមានផលច្រើន ។ ប្រៀបដូចសំពត់ដែលសៅហ្មងព្រោះមន្ទិលដែលហុយមកជាប់ កាលបោកចេញម្ដងរមែងសស្អាត ព្រោះតាមប្រក្រតីជារបស់សស្អាតហើយ ការព្យាយាមក្នុងការបោកសំពត់នោះ នឹងឥតផល ដូចការព្យាយាមធ្វើរោមចៀមដែលខ្មៅពីធម្ម-ជាតិ ឲ្យសស្អាតមិនបាន យ៉ាងណា ។ សូម្បីចិត្តដែលសៅហ្មងព្រោះកិលេស

ទាំងឡាយដែលចរមក ក៏ដូច្នោះ គឺតាមប្រក្រតី ចិត្តនោះរមែងជាធម្មជាតស្អាតនោះឯង ក្នុងវារៈបដិសន្ធិចិត្ត និងភវង្គចិត្ត ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចិត្តនេះជាធម្មជាតបភស្សរៈ ចិត្តនោះឯងសៅហ្មងទៅ ព្រោះឧបក្កិលេសដែលចរមក ចិត្តនោះកាលបានទទួលការជម្រះឲ្យបរិសុទ្ធ បុគ្គលក៏អាចធ្វើឲ្យបភស្សរៈ គឺថាស្អាតឡើងទៀតបាន ការព្យាយាមក្នុងការជម្រះចិត្តនោះ រមែងមិនឥតផលឡើយ ។ ព្រះមានព្រះភាគ បណ្ឌិតគប្បីជ្រាបថា ទ្រង់ធ្វើឧបមាដោយសំពត់ដែលសៅហ្មងដើម្បីទ្រង់សម្តែងថា ការព្យាយាមមានផលច្រើន ដោយប្រការដូច្នេះ ។

បទថា **ទុគ្គតិ បាដិកង្ខា** សេចក្តីថា កាលបើចិត្តដូច្នេះ ទុគ្គតិ បុគ្គលគប្បីសង្ឃឹមបាន លោកអធិប្បាយថា ទុគ្គតិជាគតិដែលបុគ្គលនោះគប្បីសង្ឃឹមបានយ៉ាងនេះថា បុគ្គលនេះនឹងដល់ទុគ្គតិពិតប្រាកដ មិនដល់គតិដទៃឡើយ ដូច្នេះ ។ គឺទុគ្គតិជាគតិដែលបុគ្គលនោះមានចំណែករួមយ៉ាងនេះ ។ ឈ្មោះថា ទុគ្គតិនេះ មាន ២ យ៉ាង គឺបដិបត្តិទុគ្គតិ និងគតិទុគ្គតិ ។ បដិបត្តិទុគ្គតិ មាន ២ យ៉ាង គឺអាគារិយបដិបត្តិទុគ្គតិ និងអនាគារិយបដិបត្តិទុគ្គតិ ។ អធិប្បាយថា គ្រហស្ថមានចិត្តសៅហ្មង រមែងសម្លាប់សត្វខ្លះ រមែងលួចទ្រព្យខ្លះ រមែងប្រព្រឹត្តអកុសលកម្មបថទាំង ១០ ខ្លះ នេះឈ្មោះថា **អាគារិយបដិបត្តិទុគ្គតិ** របស់គ្រហស្ថនោះ ។ គ្រហស្ថនោះ តាំងនៅក្នុងអត្តភាពនោះហើយ កាលបែកកាយស្លាប់ទៅ រមែងទៅកាន់នរកខ្លះ កំណើតសត្វតិរច្ឆានខ្លះ បេតវិស័យខ្លះ នេះឈ្មោះថា **គតិទុគ្គតិ** របស់គ្រហស្ថនោះ ។

ឯបព្វជិត បួសក្នុងសាសនានេះហើយ មានចិត្តសៅហ្មង ទទួលបម្រើអ្នកដទៃ ធ្វើខ្លួនជាគ្រូពេទ្យ ព្យាយាមបំបែកសង្ឃ ទម្លាយចេតិយដ្ឋាន បំពុះជីវិតដោយការឲ្យឫស្សីជាដើម ប្រព្រឹត្តអនាចារ និងត្រាច់ទៅកាន់អគោចរដ្ឋានទាំងអស់នេះ ឈ្មោះថា **អនាគារិយបដិបត្តិទុគ្គតិ** របស់បព្វជិតនោះ ។ បព្វជិតនោះតាំងនៅក្នុងអត្តភាពនោះហើយ កាលកាយបែកធ្លាយ រមែងទៅកាន់នរកខ្លះ កំណើតសត្វតិរច្ឆានខ្លះ បេតវិស័យខ្លះ ឈ្មោះថា សមណយក្ខ សមណប្រេត មានកាយឆេះទ្រលោម ដោយសំពត់សង្ឃាដីជាដើម ដែលត្រូវភ្លើងឆេះហើយ បន្លឺសំឡេងថ្ងូចថ្ងូរត្រាច់ទៅ នេះឈ្មោះថា **គតិទុគ្គតិ** របស់បព្វជិតនោះ ។

បទថា **សេយ្យថាបិ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់ផ្ដើមសម្ដែងធម៌ចំណែកស គឺសុគតិ ។ អត្ថនៃធម៌ចំណែកសនោះ គប្បីជ្រាបដោយធម៌ដែលផ្ទុយគ្នា ដែលពោលទុកហើយ ក្នុងធម៌ចំណែកខ្មៅ គឺទុគ្គតិ ដូច្នេះ ។ម្យ៉ាងទៀត ឈ្មោះថា សុគតិក្នុងទីនេះ មាន ២ យ៉ាង គឺបដិបត្តិសុគតិ និងគតិសុគតិ ។ បដិបត្តិសុគតិក៏មាន ២ យ៉ាង គឺអាគារិយបដិបត្តិសុគតិ និងអនាគារិយបដិបត្តិសុគតិ អធិប្បាយថា គ្រហស្ថមានចិត្តបរិសុទ្ធ រមែងវៀរចាកការសម្លាប់សត្វខ្លះ ការលួចទ្រព្យខ្លះ បំពេញកុសលកម្មបថទាំង ១០ ខ្លះ នេះឈ្មោះថា **អាគារិយបដិបត្តិសុគតិ** របស់គ្រហស្ថនោះ ។ គ្រហស្ថនោះតាំងនៅក្នុងអត្តភាពនោះហើយ កាលកាយបែកធ្លាយស្លាប់ទៅ រមែងចូលដល់ភាពជាធំក្រៃលែងក្នុងពពួកមនុស្សខ្លះ ភាពជាធំក្រៃលែងក្នុងពពួក

ទេវតាខ្លះ នេះឈ្មោះថា **គតិសុគតិ** របស់គ្រហស្ថនោះ ។ ឯបព្វជិតបួស ក្នុងសាសនានេះ មានចិត្តបរិសុទ្ធ រក្សាបារិសុទ្ធិសីល ៤ បរិសុទ្ធ សមាទាន ធុតង្គ ១៣ រៀនយកកម្មដ្ឋានដែលសមដល់ខ្លួន ក្នុងអារម្មណ៍ ៣៨ ជាអ្នក នៅក្នុងសេនាសនៈស្ងាត់ ធ្វើបរិកម្មកសិណ ឲ្យកើតឈានសមាបត្តិ បាន សម្រេចសោតាបត្តិមគ្គ ។បេ។ បានសម្រេចអនាគាមិមគ្គ នេះឈ្មោះថា **អនាគារិយបដិបត្តិសុគតិ** របស់បព្វជិតនោះ ។ បព្វជិតនោះ តាំងនៅក្នុង អត្តភាពនោះហើយ កាលកាយបែកធ្លាយ រមែងកើតក្នុងត្រកូលធំ ៣ ក្នុង មនុស្សលោកខ្លះ ក្នុងទេវតាជាន់កាមាវចរ ៦ ជាន់ខ្លះ ក្នុងភពនៃព្រហ្ម ១០ ភពខ្លះ ក្នុងជាន់សុទ្ធាវាស ៥ ជាន់ខ្លះ ក្នុងអរូបភព ៤ ជាន់ខ្លះ នេះឈ្មោះ ថា **គតិសុគតិ** របស់បព្វជិតនោះ ។

[ ៩៣ ] ព្រះមានព្រះភាគ កាលត្រាស់ថា សម័យចិត្តសៅហ្មង ទុគ្គតិ ជាទីសង្ឃឹមបាន សម័យចិត្តមិនសៅហ្មង សុគតិជាទីសង្ឃឹមបាន យ៉ាងនេះ ហើយ ឥឡូវនេះ កាលទ្រង់សម្តែងឧបក្កិលេសទាំងឡាយ ដែលជាហេតុឲ្យ ចិត្តសៅហ្មង ទើបត្រាស់ពាក្យថា ម្នាលភិក្ខុទាំងឡាយ ឧបក្កិលេសនៃចិត្ត តើដូចម្តេច គឺអភិជ្ឈាវិសមលោភៈដូច្នេះជាដើម ។ បណ្តាឧបក្កិលេសទាំង នោះ ការស្រឡាញ់ ការពេញចិត្ត ក្នុងភណ្ឌៈរបស់ខ្លួន ឈ្មោះថា អភិជ្ឈា ការស្រឡាញ់ ការពេញចិត្តក្នុងភណ្ឌៈរបស់អ្នកដទៃ ឈ្មោះថា វិសមលោភៈ។ ម្យ៉ាងទៀត ការស្រឡាញ់ពេញចិត្តក្នុងភណ្ឌៈរបស់ខ្លួន ឬរបស់អ្នកដទៃ សូម លើកទុក ការស្រឡាញ់ ការពេញចិត្តក្នុងឋានៈដែលត្រូវ ដែលគួរ ឈ្មោះ

ថា អភិជ្ឈា ការស្រឡាញ់ ការពេញចិត្តក្នុងឋានៈដែលមិនត្រូវ មិនគួរ ឈ្មោះថា វិសមលោភៈ ។

ចំណែកព្រះថេរៈពោលទុកថា លោភៈគ្រប់យ៉ាង ដែលមិនបានឈ្មោះថា វិសមៈមិនមាន ព្រោះព្រះបាលីថា ពួកអ្នកធ្វើការបែងចែកធ្វើអ្វី ទោះជាអារម្មណ៍ដែលសមគ្គី មិនសមគ្គី រាគៈជាវិសមៈ ទោសៈក៏ជាវិសមៈ មោហៈក៏ជាវិសមៈ ដូចគ្នា ព្រោះដូច្នោះ លោភៈនេះឯង ឈ្មោះថា អភិជ្ឈា ព្រោះអត្ថថា សម្លឹងរំពៃ ឈ្មោះថា វិសមៈ ព្រោះអត្ថថា មិនស្មើ មិនប្រពៃតាមធម៌ ពាក្យថា អភិជ្ឈា និងវិសមៈនេះ មានអត្ថតែមួយដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ។ អភិជ្ឈាវិសមលោភៈនេះកើតឡើងហើយ រមែងប្រទូស្តចិត្ត គឺមិនឲ្យចិត្តផូរផង់ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ជាគ្រឿងសៅហ្មងនៃចិត្ត ដូច្នេះ ។ អភិជ្ឈាវិសមលោភៈនេះយ៉ាងណា ព្យាបាទដែលកើតអំពីអាឃាតវត្ថុ ៩ យ៉ាង សេចក្តីក្រោធដែលកើតអំពីអាឃាតវត្ថុ ១០ យ៉ាង ការត្រូវក្រោធដែលគ្របសង្កត់ចិត្តរឿយៗ ក៏ដូច្នោះ ការលុបគុណដែលធ្វើវត្ថុដែលគេធ្វើល្អហើយ គឺគុណឲ្យវិនាសទៅ មិនថាជាគ្រហស្ថ ឬបព្វជិតឡើយ អធិប្បាយថា ឯគ្រហស្ថ កាលដើមឡើយ ជាបុគ្គលខ្វះខាត អ្នកមានករុណាខ្លះ បានលើកបុគ្គលនោះទុកក្នុងឋានៈខ្ពង់ខ្ពស់ តមក បែរជាពោលថា លោកធ្វើអ្វីឲ្យខ្ញុំ ឈ្មោះថា ទម្លាយសេចក្តីល្អដែលអ្នកដទៃ មានករុណានោះ ធ្វើទុកហើយឲ្យវិនាសទៅ ឯបព្វជិត ចាប់ពីសម័យដែលនៅជាសាមណេរតូច អាចារ្យ ឬឧបជ្ឈាយ៍ណាមួយ អនុគ្រោះដោយបច្ច័យ ៤

ដោយឧទ្ទេស និងបរិបុច្ឆា ឲ្យត្រេងត្រាប់ បានជាអ្នកឈ្លាសក្នុងបករណ៍ជាដើម ដោយធម្មកថា សម័យតមក ព្រះរាជា និងរាជអាមាត្យជាដើម ធ្វើសក្ការៈ គោរពហើយ លោកត្រឡប់ជាមិនមានការកោតក្រែងក្នុងអាចារ្យ និងឧបជ្ឈាយ៍ ត្រាច់ទៅ អាចារ្យជាដើមពោលថា ភិក្ខុនេះ កាលគេនៅក្មេង យើងទាំងឡាយ ជួយអនុគ្រោះ និងផ្គូងផ្គើមឲ្យបោះជំហានយ៉ាងនេះ តែឥឡូវនេះលោកមិនគួរឲ្យស្រឡាញ់សោះ ក៏ពោលឆ្លើយឆ្លងថា លោកម្ចាស់ធ្វើអ្វីឲ្យខ្ញុំដូច្នេះ ឈ្មោះថា ទម្លាយសេចក្ដីល្អដែលឧបជ្ឈាយ៍ និងអាចារ្យទាំងនោះធ្វើហើយឲ្យវិនាសទៅ ការលុបគុណដែលធ្វើហើយឲ្យវិនាសទៅរបស់បព្វជិតនោះ តែងកើតឡើងធ្វើឲ្យចិត្តប្រទូស្ត គឺមិនឲ្យចិត្តផូរផង់ ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា ធម៌ជាគ្រឿងសៅហ្មងនៃចិត្ត ដូច្នេះ ។ ការលុបគុណនេះ យ៉ាងណា ការវាយស្មើ គឺការចាប់គូប្រណាំងប្រជែងក៏ដូច្នោះកើតឡើង រាលដាលទៅ អាងដល់បុគ្គលជាពហូស្សុត ដោយន័យជាដើមថាលោកជាពហូស្សុត ដូច្នេះ មានគតិមិនពិតប្រាកដ ហើយលោក និងខ្ញុំ មានអ្វីពិសេស ។ ការប្រណែន បានដល់ ការទឹកតិះដៀលសក្ការៈជាដើមរបស់អ្នកដទៃ ការកំណាញ់ បានដល់ ការអត់ធន់មិនបាននូវសម្បត្តិរបស់ខ្លួន មានអ្នកដទៃរួមប្រើប្រាស់ ។ មាយា បានដល់ កិរិយាដែលជាការប្រព្រឹត្តបោកបញ្ឆោត ។ ការអួតអាង កើតឡើងធ្វើឲ្យជាបុគ្គលនិយាយពន្ទើស ។ ពិតហើយ បុគ្គលនិយាយពន្ទើស រមែងដូចជាត្រី ឈ្មោះអានន្ទ ។

បានឮថា ត្រីឈ្មោះអានន្ទ ចូលចិត្តយកកន្ទុយ បង្អួតត្រីដទៃ យកក្បាល

បន្តួតពស់ ឲ្យត្រី និងពស់ទាំងនោះដឹងថា ពួកគេជាពួកតែមួយនឹងខ្លួន ។ បុគ្គលនិយាយអួត ក៏ដូច្នោះដូចគ្នា ចូលទៅរកអ្នកព្រះសូត្រ ឬអ្នកអភិធម្មណាមួយ រមែងពោលនឹងលោកនោះៗ យ៉ាងនេះថា ខ្ញុំប្រព្រឹត្តប្រយោជន៍ដើម្បីលោកទាំងឡាយ លោកទាំងឡាយត្រូវអនុគ្រោះខ្ញុំ ខ្ញុំមិនលះបង់ពួកលោកទេ ដូច្នេះ ។ កាលបើយ៉ាងនេះ អ្នកចេះព្រះសូត្រ និងអ្នកចេះអភិធម្មទាំងនោះ ក៏សម្គាល់លោកថា បុគ្គលនេះ មានការគោរពកោតក្រែងក្នុងយើងទាំងឡាយ ការអួតនេះឯងរបស់បុគ្គលនោះ កាលកើតឡើងដោយធ្វើឲ្យជាបុគ្គលនិយាយពន្ទើស រមែងកើតឡើងប្រទូស្តចិត្ត គឺធ្វើឲ្យចិត្តមិនផូរផង់ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ជាគ្រឿងសៅហ្មងនៃចិត្តដូច្នេះ ។ ការអួតអាងនេះ យ៉ាងណា សូម្បីការរឹងត្អឹងក៏ដូច្នេះ ជាកិលេសធ្វើមិនឲ្យប្រព្រឹត្តឱនលំទោន ងើបក្បាល ព្រោះជាអ្នករឹងត្អឹង ប្រៀបដូចស្នប់ដែលពេញដោយខ្យល់ ។ ការប្រណាំងវាសនា មានការធ្វើក្រៃលែងជាងនោះ ការប្រណាំងវាសនានោះ បែកបាន ២ ប្រភេទ គឺខាងអកុសល និងខាងកុសល ក្នុងបណ្តាការប្រណាំងវាសនា ២ ប្រភេទនោះ សម្រាប់គ្រហស្ថ ការប្រណាំងវាសនាកើតឡើង ព្រោះបានឃើញគ្រឿងប្រដាប់ជាដើមដែលអ្នកដទៃធ្វើហើយ ហើយធ្វើឲ្យទ្វេគុណឡើងទៅជាងនោះ ចាត់ជាអកុសល ហើយសម្រាប់បព្វជិត ខណៈដែលបព្វជិតដទៃសូធ្យរៀន ឬពោលធម៌មានប្រមាណប៉ុនណា ការប្រណាំងវាសនាដែលកើតឡើង ដោយការធ្វើឲ្យជាទ្វេគុណច្រើនទៅជាងនោះ ដោយអំណាចនៃមានះ ចាត់ជាអកុសល ។ ឯគ្រហស្ថ ការ

ប្រណាំងវាសនាកើតឡើង ព្រោះបានឃើញអ្នកដទៃប្រគេនសលាកភត្តមួយសម្រាប់ ហើយខ្លួន បំណងនឹងប្រគេន ២-៣ សម្រាប់ ចាត់ជាកុសល ។ ហើយសម្រាប់បព្វជិត កាលបានដឹងថា ភិក្ខុដទៃរៀនបានមួយនិកាយហើយ ការប្រណាំងវាសនាកើតឡើង ដោយមិនអាស្រ័យមានះ តែព្រោះបានឃើញភិក្ខុដទៃនោះរៀនបានមួយនិកាយ ហើយបំណងនឹងគ្របសង្កត់ការខ្វិលប្រអូសរបស់ខ្លួនតែម្យ៉ាង រៀនបាន ២ និកាយ ចាត់ជាកុសល ។ តែក្នុងទីនេះលោកបំណងយកការប្រណាំងវាសនាដែលជាអកុសល ។ ព្រោះថា ការប្រណាំងវាសនាជាអកុសលនេះ រមែងកើតឡើងប្រទូស្តចិត្ត គឺមិនឲ្យចិត្តផូរផង់ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ជាគ្រឿងសៅហ្មងនៃចិត្ត ។ ម្យ៉ាងទៀត ការប្រណាំងវាសនានេះ យ៉ាងណា ការប្រកាន់ខ្លួន ក៏យ៉ាងនោះ ប្រព្រឹត្តទៅដោយអំណាចការលើកតម្កើងខ្លួននៃចិត្ត ព្រោះអាស្រ័យជាតិកំណើតជាដើម មានះ ដែលប្រព្រឹត្តទៅដោយអំណាចការតម្កើងខ្លួនក្រៃលែងនៃចិត្ត ឈ្មោះថា អតិមានះ អាការដែលទទួលយកដោយការស្រវឹង ឈ្មោះថា មទៈ មទៈកើតឡើង ដោយអំណាចការបណ្តោយចិត្តទៅក្នុងកាមគុណទាំងឡាយ ឈ្មោះថា បមាទៈ បមាទៈកើតឡើង រមែងប្រទូស្តចិត្ត គឺមិនឲ្យចិត្តផូរផង់ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ជាគ្រឿងសៅហ្មងនៃចិត្ត ។

សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគ កាលទ្រង់សម្តែងឧបក្កិលេសទើបទ្រង់សម្តែងលោភៈទុកជាលំដាប់ដំបូង ឆ្លើយថា ព្រោះលោភៈនោះកើត

ឡើងមុនកិលេសដទៃ ។

ពិតហើយ កាលសត្វទាំងពួងកើតឡើងក្នុងភពណាមួយ ដោយហោច សូម្បីក្នុងសុទ្ធាវាសភូមិ លោកៈរមែងកើតឡើងមុនគេ ដោយអំណាចការត្រេកអរក្នុងភព បន្ទាប់អំពីនោះ ឧបក្កិលេសក្រៅអំពីនេះ មានព្យាបាទជាដើម តែងកើតតាមសមគួរដល់បច្ច័យ ព្រោះអាស្រ័យបច្ច័យដែលគួរដល់ខ្លួន និង មិនមែនដល់ឧបក្កិលេសរបស់ចិត្ត ១៦ យ៉ាងនេះប៉ុណ្ណោះទេដែលកើតឡើង តែគប្បីជ្រាបថា ដោយន័យនេះ រមែងឈ្មោះថា សង្គ្រោះយកកិលេសទាំងអស់នោះឯង ។

[ ៩៤ ] ព្រះមានព្រះភាគ កាលទ្រង់សម្ដែងកិលេសជាគ្រឿងសៅហ្មង ដោយពាក្យអធិប្បាយ មានប្រមាណប៉ុណ្ណោះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងការផូរផង់ ទើបត្រាស់បទថា **ស ខោ សោ ភិក្ខវេ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឥតិ វិទិត្វា** ប្រែថា ដឹងយ៉ាងនេះ ។

បទថា **បជហាតិ** សេចក្ដីថា លះដោយអរិយមគ្គ ដោយអំណាចនៃសមុច្ឆេទប្បហាន ។

ក្នុងបទថា **បជហាតិ** នោះ គប្បីជ្រាបការលះ មាន ២ យ៉ាង គឺលះតាមលំដាប់កិលេស និងលះតាមលំដាប់មគ្គ ។ និងអធិប្បាយការលះតាមលំដាប់កិលេសមុន កិលេសទាំង ៦ នេះ គឺអភិជ្ឈាវិសមលោភៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ រមែងលះបានដោយអរហត្តមគ្គ ។ កិលេស ៤ គឺព្យាបាទ កោធៈ ឧបនាហៈ បមាទៈ រមែងលះដោយអនាគាមិមគ្គ ។

កិលេស ៦ គឺមក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ រមែង លះដោយសោតាបត្តិមគ្គ ។ ចំណែកការលះតាមលំដាប់មគ្គ អធិប្បាយដូចតទៅនេះ

កិលេសទាំង ៦ នេះ គឺមក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ រមែងលះដោយសោតាបត្តិមគ្គ ។ កិលេសទាំង ៤ នេះ គឺ ព្យាបាទ កោធៈ ឧបនាហៈ បមាទៈ រមែងលះដោយអនាគាមិមគ្គ ។ កិលេស ទាំង ៦ នេះ គឺអភិជ្ឈាវិសមលោភៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ រមែង លះដោយអរហត្តមគ្គ ។ តែក្នុងទីនេះ កិលេសទាំងនេះ នឹងត្រូវសម្លាប់ដោយ សោតាបត្តិមគ្គ ឬត្រូវសម្លាប់ដោយមគ្គដ៏សេសក៏ដោយ សូម្បីយ៉ាងនោះគប្បី ជ្រាបថា ព្រះមានព្រះភាគត្រាស់ពាក្យថា បុគ្គលរមែងលះអភិជ្ឈាវិសមលោភៈ ដែលជាគ្រឿងសៅហ្មងនៃចិត្ត ដូច្នេះជាដើម ទ្រង់សំដៅយកការលះដោយ អនាគាមិមគ្គនោះឯង នេះជាការកើត ( នៃផល ) ដែលមកហើយតាមមគ្គ ដែលបន្ទាប់ក្នុងទីនេះ ។ ព្រោះព្រះមានព្រះភាគទ្រង់សម្តែងមគ្គទី ៤ ទុកក្នុង ខាងលើបំផុតហើយ ទើបការកើតនៃផលនោះ ត្រូវឧបក្កិលេស មានវិសម-លោភៈជាដើមដ៏សេសអំពីឧបក្កិលេស ដែលលះបានដោយតតិយមគ្គ រមែង លះបានដោយមគ្គទី ៤ នោះ ។ កិលេសដ៏សេស រមែងលះបានដោយមគ្គទី ៤ នេះដូចគ្នា ។ ព្រោះថា ឧបក្កិលេស មានមក្ខៈជាដើមពួកណា រមែងលះ បានដោយសោតាបត្តិមគ្គ ឧបក្កិលេសទាំងនោះ រមែងលះបានជាសមុច្ឆេទ ហើយ ដោយអនាគាមិមគ្គនោះឯង ព្រោះចិត្តដែលជាសមុដ្ឋាននៃឧបក្កិលេស

មានមគ្គៈជាដើមនោះ មិនទាន់លះបានជាសមុច្ឆេទ ( ដោយសោតាបត្តិមគ្គ ) ។ តែក្នុងអធិការនេះ អាចារ្យពួកខ្លះពណ៌នាការលះបានដោយបឋមមគ្គនោះឯង ។ ពាក្យនោះមិនសមជាមួយនឹងពាក្យដើម និងពាក្យចុង ។ អាចារ្យពួកខ្លះពណ៌នាវិក្ខម្ភនប្បហានទុកក្នុងអធិការនេះ ។ ពាក្យនោះ ត្រឹមតែជាបំណងរបស់អាចារ្យពួកនោះប៉ុណ្ណោះ ។

[ ៩៥ ] បទថា **យតោ** ក្នុងបទថា **យតោ ខោ ភិក្ខវេ** នេះ ប្រែថា ក្នុងកាលណា ។ ដោយបទថា **បហីនោ ហោតិ** ព្រះមានព្រះភាគត្រាស់សំដៅយកការលះក្នុងខណៈនៃអនាគាមិមគ្គ ។

បទថា **សោ ពុទ្ធេ អវេច្ចប្បសាទេន** នេះ គប្បីប្រកបចូលជាមួយបទតែមួយបទយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលណា ភិក្ខុលះវិសមលោភៈបានក្នុងកាលនោះ លោករមែងប្រកបដោយការជ្រះថ្លា មិនញាប់ញ័រក្នុងព្រះពុទ្ធ ។ ពិតហើយ ភិក្ខុរូបនេះ មានសេចក្តីជ្រះថ្លាដែលជាលោកុត្តរ មកហើយដោយអនាគាមិមគ្គ សម័យតមក កាលភិក្ខុនេះរឭកដល់ព្រះគុណរបស់ព្រះមានព្រះភាគ របស់ព្រះធម៌ និងព្រះសង្ឃ ការជ្រះថ្លាដែលជាលោកិយ តែងកើតឡើងបាន ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេចក្តីជ្រះថ្លា ជាលោកិយផង លោកុត្តរផង ទាំងអស់នោះរបស់ភិក្ខុនោះ ទើបត្រាស់ពាក្យថា **ពុទ្ធេ អវេច្ចប្បសាទេន** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អវេច្ចប្បសាទេន** សេចក្តីថា ដោយការជ្រះថ្លា ឈ្មោះថា មិនញាប់ញ័រ គឺមិនឃ្លេងឃ្លោង ព្រោះដឹងពុទ្ធគុណ ធម្ម-

គុណ និងសង្ឃគុណតាមសេចក្ដីពិត ។ កាលភិក្ខុនោះរឭកដល់សេចក្ដីជ្រះថ្លា ដែលមិនញាប់ញ័រនោះ កើតឡើងហើយដោយវិធីណា ឥឡូវនេះ កាលទ្រង់សម្ដែងវិធីនោះ ទើបទ្រង់ញ៉ាំងឋានៈទីតាំងនៃអនុស្សតិ ៣ ឲ្យពិស្ដារដោយន័យថា **ឥតិបិ សោ ភគវា** ដូច្នេះជាដើម ។ ការពណ៌នាអត្ថនៃទីតាំងអនុស្សតិទាំងនោះ ព្រះពុទ្ធឃោសាចារ្យពោលទុកហើយយ៉ាងល្អិតល្អន់ ក្នុងអនុស្សតិកថា ក្នុងវិសុទ្ធិមគ្គ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសេចក្ដីជ្រះថ្លា ដែលជាលោកិយផងលោកុត្តរផងរបស់ព្រះអនាគាមីនោះ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងការលះកិលេស និងអានិសង្ស មានសោមនស្សជាដើម ដែលប្រកបដោយសេចក្ដីជ្រះថ្លា ដែលមិនញាប់ញ័រ ដែលកើតឡើងដល់ព្រះអនាគាមីជាអ្នកពិចារណា ទើបត្រាស់ពាក្យថា **យថោធិ ខោ បនស្ស** ដូច្នេះជាដើម ។ ពាក្យនោះមានអធិប្បាយថា ពិតហើយ សោមនស្សដ៏ខ្លាំងក្លា រមែងកើតឡើងដល់ព្រះអនាគាមី ជាអ្នកពិចារណាដល់ការលះកិលេសរបស់ខ្លួនថា កិលេសទាំងនេះ អាត្មាអញលះបានហើយ ប្រៀបដូចសោមនស្សដ៏ខ្លាំងក្លា កើតដល់ព្រះរាជា ដែលទ្រង់បង្ក្រាបអន្តរាយ គឺចោរ ដែលបោះជំរំនៅត្រង់បរិវេណជាយដែនឲ្យស្ងប់ហើយ យាងត្រឡប់មកប្រថាប់ពិចារណាព្រះរាជកិច្ចនោះនៅក្នុងមហានគរនោះ ដូច្នោះ ។ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសោមនស្សនោះ ទើបត្រាស់ពាក្យថា **យថោធិ ខោ បនស្ស** ដូច្នេះជាដើម ។ ពាក្យនោះមានអធិប្បាយថា ព្រះអនាគាមីនេះ ពិចារណាយ៉ាងនេះថា ព្រះ-

អរិយសាវកជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លាដែលមិនញាប់ញ័រ ក្នុងព្រះពុទ្ធ ។បេ។ ព្រះធម៌ ។បេ។ ព្រះសង្ឃជាបុញ្ញក្ខេត្តដ៏កំពូលរបស់សត្វលោក កិលេស ដែលព្រះអនាគាមីលះហើយ រលាស់ចោលហើយតាមចំណែក បានដល់ លះ ហើយ តាមអំណាចចំណែករៀងៗ ខ្លួននោះឯង កិលេសនោះៗ ដែលព្រះ អនាគាមីនោះខ្ជាក់ចោលហើយ បន្សាត់បង់ហើយ លះបានហើយ រលាស់ ចោលហើយ ។

បទថា **សកសកឱធិសោឧ** ចំណែកមាន ២ គឺចំណែកនៃកិលេស និង ចំណែកនៃមគ្គ ។ បណ្ដាចំណែក ២ នោះ ពោលដោយអំណាចចំណែកនៃ កិលេសមុន កិលេសពួកណា ដែលបុគ្គលគប្បីសម្លាប់ដោយមគ្គណា កិលេស ទាំងនោះមិនលាយឡំនឹងកិលេស ដែលមគ្គដទៃគប្បីសម្លាប់ គឺព្រះអនាគាមី លះបានហើយ ដោយចំណែករបស់ខ្លួននោះឯង ។ ពោលដោយចំណែកនៃ មគ្គ កិលេសពួកណាដែលបុគ្គលគប្បីលះដោយមគ្គណា កិលេសទាំងនោះ ឯង រមែងលះដោយមគ្គនោះ ។ កិលេសនោះៗ ឈ្មោះថា លោកលះ ហើយ រលាស់ចោលហើយនោះឯង ដោយអំណាចចំណែករបស់ខ្លួន ដោយ ប្រការដូច្នេះ ភ្ជាប់សេចក្ដីថា លោកពិចារណាដល់កិលេសដែលលះបានហើយ ជាអ្នកបានសោមនស្ស លោករមែងបានការដឹងអត្ថ ( ផល ) ក្រៃលែងទៅ ជាងនោះថា អញជាអ្នកប្រកបដោយការជ្រះថ្លា ដែលមិនញាប់ញ័រ ក្នុងព្រះ ពុទ្ធ ។ បាឋៈថា **យទោធិ ខោ** ដូច្នេះក៏មាន ។ ដោយអំណាចបាឋៈនោះ មានអត្ថដូច្នេះ ព្រោះហេតុដែលកិលេស ឈ្មោះថា ភិក្ខុនោះលះបានហើយ

រលាស់បានហើយ ។

បណ្ដាបទទាំងនោះ បទថា **យតោ** ជាតតិយាវិភត្តិ អធិប្បាយថា **យស្មា** ប្រែថា ព្រោះហេតុណា ។ មគ្គ ៣ ខាងក្រោមលោកហៅថា **ឱធិ** ព្រោះហេតុអ្វី ព្រោះមគ្គ ៣ ខាងក្រោមនោះ ធ្វើកិលេសឲ្យជាចំណែក គឺឲ្យជាកោដ្ឋាស ហើយរមែងលះកិលេសបាន វៀរកិលេសដែលគប្បីលះដោយមគ្គខាងលើៗ ដូច្នោះ មគ្គ ៣ ខាងក្រោម ទើបលោកហៅថា **ឱធិ** ដូច្នេះ ។ ឯអរហត្តមគ្គ រមែងលះកិលេសគ្រប់យ៉ាង មិនឲ្យសេសសល់ ព្រោះដូច្នោះ ទើបលោកពោលថា **អនោធិ** ដូច្នេះ ។ មា្យងទៀត ភិក្ខុរូបនេះ លះបង់កិលេសបានហើយ ដោយមគ្គ ៣ ខាងក្រោម ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **យតោធិ ខោ បន ចត្តំ ហោតិ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ខោ បន** ត្រឹមតែជានិបាត ។ ឯអត្ថនេះជាអត្ថរួម ។ ព្រោះកិលេសឈ្មោះថា ឱធិ ឈ្មោះថា ភិក្ខុរូបនោះលះហើយ រលាស់ចោលហើយ ដូច្នោះ ទើបគួរពង្រីកសេចក្ដីតាមព្រះបាលីថា ភិក្ខុរូបនោះពិចារណាដល់កិលេសដែលលះបានហើយនោះ រមែងបានសោមនស្ស លោករមែងបានការដឹងច្បាស់នូវអត្ថ គឺផលក្រៃលែងឡើងជាងនោះ ថាអញជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លា ដែលមិនញាប់ញ័រក្នុងព្រះពុទ្ធ ។

បណ្ដាបទទាំងនោះ បទថា **ចត្តំ** នេះ លោកពោលដោយអំណាចការលះភាវៈរបស់ខ្លួន ។ ឯបទថា **វន្តំ** នេះ លោកពោលទុកដោយអំណាចការសម្ដែងភាវៈ គឺការមិនប្រកាន់ ។

បទថា **មុត្តំ** នេះ លោកពោលដោយអំណាចការដោះចាកសន្តតិ ។

បទថា **បហីនំ** នេះ លោកពោលដោយអំណាចការសម្តែងថា កិលេស ដែលផុតបានហើយ មិនតាំងនៅក្នុងទីណាមួយ ។

បទថា **បដិនិស្សដ្ឋំ** នេះ លោកពោលដោយអំណាចការសម្តែងការលះ កិលេស ដែលធ្លាប់ប្រកាន់ក្នុងកាលមុន ឬដោយអំណាចការសម្តែងភាវៈនៃ កិលេសដែលខ្ជូនលោស់ចោលហើយចំពោះមុខ លោកអធិប្បាយថា ដោយ អំណាចការសម្តែងភាវៈនៃកិលេសដែលខ្ជូនគ្របសង្កត់ ដោយកម្លាំងនៃការនា លោស់ចោលហើយ ដូច្នោះ ។ ក្នុងពាក្យថា **លភតិ អត្ថវេទំ លភតិ ធម្មវេទំ** នេះ អធិប្បាយថា ការជ្រះថ្លាដែលមិនញាប់ញ័រក្នុងព្រះរតនត្រ័យ មានព្រះពុទ្ធជាដើមនោះឯង ឈ្មោះថា អត្ថ ព្រោះបុគ្គលគប្បីដើរ អធិប្បាយ ថា គប្បីចូលទៅឲ្យដល់ ។ ឈ្មោះថា ធម៌ ព្រោះជាសភាវៈទ្រទ្រង់ទុក អធិប្បាយថា មិនឲ្យធ្លាក់ចុះ ។

បទថា **វេទ** សំដៅយកគម្ពីរខ្លះ សំដៅយកញាណខ្លះ សំដៅយក សោមនស្សខ្លះ គម្ពីរលោកហៅថា **វេទ** ដូចក្នុងប្រយោគជាដើមថា **តិណ្ណំ វាទានំ ចារគូ** ជាអ្នកដល់នូវត្រើយនៃត្រៃវេទ ៣ ដូច្នេះ ។ ញាណ លោក ហៅថា វេទ ដូចប្រយោគជាដើមថា **យំ ព្រាហ្មណំ វេទគុំ អភិជញ្ញា អកិញ្ចនំ កាមភវេ អសត្តំ** ព្រាហ្មណ៍ណាដែលជាអ្នកដល់នូវវេទ អ្នកមិន មានកង្វល់ មិនជាប់នៅក្នុងកាមភព ដូច្នេះ ។

សោមនស្សលោកហៅថា **វេទ** ដូចក្នុងប្រយោគជាដើមថា **យេ វេទ-**

**ជាតា វិចរន្តិ លោកេ** ជនពួកណា កើតសេចក្ដីត្រេកអរ រមែងអន្ទោលទៅក្នុងលោក ដូច្នេះ ។ តែក្នុងទីនេះ លោកបំណងយកសោមនស្ស និងញាណដែលប្រកបដោយសោមនស្ស ព្រោះដូច្នោះ ក្នុងពាក្យនេះ គប្បីជ្រាបអត្ថយ៉ាងនេះថា

បទថា **លភតិ អត្ថវេទំ លភតិ ធម្មវេទំ** សេចក្ដីថា រមែងបានសោមនស្សដែលមានសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងអារម្មណ៍ និងញាណដែលសម្រេចដោយសោមនស្ស ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថក្នុងសេចក្ដីនេះយ៉ាងនេះថា

បទថា **អត្ថវេទំ** សេចក្ដីថា រមែងបាននូវការដឹងនូវវេទ មានប្រការដូចពោលនោះឯង ដែលកើតឡើងហើយ ដល់លោកដែលពិចារណានូវការជ្រះថ្លា ដែលមិនញាប់ញ័រ ។

បទថា **ធម្មវេទំ** សេចក្ដីថា រមែងបាននូវការដឹងនូវវេទ មានប្រការដូចពោលហើយនោះឯង ដែលកើតឡើងហើយដល់លោកដែលពិចារណានូវការលះកិលេស ដោយជាចំណែក ព្រោះហេតុនៃសេចក្ដីជ្រះថ្លា ដែលមិនញាប់ញ័រ ។ សមដូចពាក្យដែលលោកពោលទុកថា ញាណក្នុងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា ញាណក្នុងផលនៃហេតុ ឈ្មោះថា អត្ថប្បដិសម្ភិទា ដូច្នេះ ។

បទថា **ធម្មូបសញ្ហិតំ ចាមោជ្ជំ** សេចក្ដីថា រមែងបានបាមោជ្ជដែលកើតឡើងហើយដល់បុគ្គលដែលពិចារណានូវអត្ថ និងធម៌នោះឯង ហើយការដឹងនូវវេទដែលជាអានិសង្សកើតមកអំពីការដឹងអត្ថ និងធម៌នោះ ។ ពិតហើយ

បាមោជ្ជនោះ លោកពោលថា ប្រកបដោយធម៌ដែលប្រព្រឹត្តទៅដោយអាការពិចារណាដោយលក្ខណៈដែលមិនមានទោស ។

បទថា **បមុទិតស្ស បីតិ ជាយតិ** សេចក្តីថា បីតិដែលមិនលាយឡំដោយអាមិស រមែងកើតដល់លោកដែលរីករាយដោយបាមោជ្ជនេះ ។

បទថា **បីតិមនស្ស** សេចក្តីថា បុគ្គលមានចិត្តឆ្អែតដោយបីតិនោះ ។

បទថា **កាយោ បស្សម្ភតិ** សេចក្តីថា សូម្បីកាយក៏ឈ្មោះថា ស្ងប់រម្ងាប់ គឺមានការក្រវល់ក្រវាយស្ងប់រម្ងាប់ហើយ ។

បទថា **បស្សទ្ធកាយោ សុខំ** សេចក្តីថា បុគ្គលមានការក្រវល់ក្រវាយតាមកាយស្ងប់ហើយយ៉ាងនេះ រមែងសោយសុខផ្លូវចិត្ត ។

បទថា **ចិត្តំ សមាធិយតិ** សេចក្តីថា ចិត្តរមែងតាំងមាំដោយប្រពៃ គឺតាំងនៅមិនញាប់ញ័រ ហាក់ដូចដល់អប្បនា ។

[ ៩៦ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងអានិសង្ស មានសោមនស្សជាដើម ដែលកើតឡើងដល់ភិក្ខុរូបនោះ ពិចារណានូវការលះកិលេសដែលប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ប្រកាសអាការដែលប្រព្រឹត្តទៅហើយនៃការពិចារណារបស់ភិក្ខុនោះ ដោយពាក្យថា **យតោធិ ខោ បន មេ** ដូច្នេះហើយ សម្តែងពលានុភាពនៃអនាគាមិមគ្គនោះឯង ទើបត្រាស់បទថា **ស ខោ សោ ភិក្ខវេ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឯវំ សីលោ** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងសីលក្ខន្ធដែលប្រកបដោយអនាគាមិមគ្គរបស់ភិក្ខុនោះៗ ។

បទថា **ឯវំ ធម្មោ ឯវំ បញ្ញោ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សំដែងសមាធិក្ខន្ធ និងបញ្ញាខន្ធដែលប្រកបដោយអនាគាមិមគ្គនោះឯង ។

បទថា **សាលីនំ** សេចក្តីថា នៃស្រូវសាលីប្រភេទផ្សេងៗ មានស្រូវសាលីក្រហម និងស្រូវសាលីក្រអូបជាដើម ។ បទថា **បិណ្ឌបាតំ** បានដល់បាយ ។ បទថា **វិចិតកាលកំ** សេចក្តីថា នាំចំណែកដែលខ្មៅចេញ ។

បទថា **នេវស្ស តំ ហោតិ អន្តរាយ** សេចក្តីថា ការឆាន់បិណ្ឌបាតមានប្រការដូចពោលនោះរបស់ភិក្ខុបែបនោះ រមែងមិនជាការអន្តរាយដល់មគ្គឬផល ។ ពិតហើយ ការឆាន់នោះរបស់បុគ្គលណាសម្រេចគុណធម៌ ហើយនឹងធ្វើអន្តរាយអ្វីបាន សូម្បីលោកមិនទាន់បានសម្រេចអរហត្តមគ្គ និងអរហត្តផល តែគង់ចម្រើនវិបស្សនាដើម្បីសម្រេចមគ្គផលនោះ ការឆាន់នោះ ក៏មិនចាត់ជាអន្តរាយឡើយ គឺមិនអាចធ្វើអន្តរាយបាន ។ ព្រោះហេតុអ្វី ព្រោះលោកមានចិត្តបរិសុទ្ធដោយមគ្គដែលប្រមូល សីល ធម្មៈ និងបញ្ញា មានប្រការដូចបានពោលហើយ ព្រោះក្នុងសេចក្តីដែលមានហេតុនេះឯង ដូច្នោះកាលទ្រង់សំដែងឧបមាដ៏សមគួរដល់ហេតុនោះ ទើបត្រាស់ពាក្យថា **សេយ្យថាបិ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អច្ឆំ** សេចក្តីថា ថ្លាស្អាត ព្រោះប្រាសចាកមន្ទិល ផូរផង់ហើយ ព្រោះបកស្រះ ។

បទថា **ឧក្កាមុខំ** សេចក្តីថា បាវរបស់ជាងមាស ព្រោះក្នុងទីនេះបាវរបស់ជាងមាសហៅថា **ឧក្កា** ។ តែក្នុងទីដទៃ សូម្បីប្រទីបជាដើម លោកក៏

ហៅថា **ឧក្កា** ដែរ ។ ពិតហើយ ប្រទីបលោកហៅថា **ឧក្កា** គឺគប់ភ្លើង ក្នុងអាគតដ្ឋានថា **ឧក្កា ធារិយមានាសុ** ដូច្នេះ បាវ លោកហៅថា **ឧក្កា** ក្នុងអាគតដ្ឋានថា **ឧក្កំ ពន្ធេយ្យ ឧក្កំ ពន្ធិត្វា ឧក្កាមុខំ អាលិម្បេយ្យ** ជាងមាសគប្បីធ្វើបាវ កាលធ្វើស្រេចហើយ គប្បីបូកមាត់បាវ ដូច្នេះ ចង្ក្រានជាងមាស លោកហៅថា **ឧក្កា** ក្នុងអាគតដ្ឋានថា **កម្មារានំ យថា ឧក្កា អន្តោ ឈាយតិ នោ ពហិ** ដូចចង្ក្រាននៃជាងមាសឆេះនៅខាងក្នុង មិនរាលមកខាងក្រៅ ។ កម្លាំងខ្យល់លោកហៅថា **ឧក្កា** ក្នុងអាគតដ្ឋានថា **ឯវំ វិចារោ ឧក្កាចារោ ភវិស្សតិ** កម្លាំងខ្យល់ គឺ **ឧក្កាចារ** នឹងមានផលយ៉ាងនេះ ដូច្នេះ ។ តែក្នុងទីនេះ និងក្នុងទីដទៃដែលមានលក្ខណៈដូចគ្នានេះ បាវរបស់ជាងមាស គប្បីជ្រាបថា **ឧក្កា** ក្នុងអាគតដ្ឋានថា **សណ្ឌាសេន ជាតរូបំ គហេត្វា ឧក្កាមុខេ បក្ខិបតិ** ជាងមាសយកដង្កាប់មាសស៊ិកចូលទៅក្នុងមាត់បាវ ដូច្នេះ ។ ក្នុងសេចក្តីនោះ មានការប្រៀបដល់ឧបមាដូចតទៅនេះ ។ ចិត្តរបស់ភិក្ខុនេះ ក្នុងវេលាដែលនៅជាបុថុជ្ជន ប្រឡាក់ប្រឡូសដោយមន្ទិល មានរាគៈជាដើម គប្បីឃើញដូចសំពត់ដែលស្មោកគ្រោក ដូចមាសដែលសៅហ្មង ដូច្នោះ អនាគាមិមគ្គ គប្បីឃើញដូចទឹកដ៏ស្អាត និងដូចមាត់បាវ ដូច្នោះ ។ ការដែលភិក្ខុរូបនោះមានចិត្តបរិសុទ្ធ ព្រោះអាស្រ័យអនាគាមិមគ្គដែលប្រមូលទុកនូវសីល ធម្មៈ និងបញ្ញា មានប្រការដូចពោលហើយ គប្បីឃើញដូចសំពត់សស្អាត និងមាសបរិសុទ្ធ ព្រោះអាស្រ័យទឹក និងមាត់បាវ ដូច្នោះ ដូច្នេះឯង ។

[ ៩៧ ] បទថា **សោ មេត្តាសហគតេន ចេតសា** សេចក្តីថា ព្រះធម្មទេសនាមកហើយតាមអនុសន្ធិ ។ ពិតហើយ អនុសន្ធិមាន ៣ គឺបុច្ឆានុសន្ធិ អជ្ឈាសយានុសន្ធិ និងយថានុសន្ធិ ។ ក្នុងអនុសន្ធិ ៣ នោះ គប្បីជ្រាបបុច្ឆានុសន្ធិ ដោយអំណាចព្រះសូត្រ ដែលទ្រង់វិសជ្ជនាហើយដល់ភិក្ខុទាំងឡាយ ដែលទូលសួរយ៉ាងនេះថា លុះព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ មានភិក្ខុមួយរូបបានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន បើបរិក្ខារខាងក្រៅមិនមាន គឺវិនាសទៅ សេចក្តីតក់ស្លុតមានឬទេ ព្រះមានព្រះភាគទ្រង់តបថា ម្នាលភិក្ខុ មាន ដូច្នេះ ។ គប្បីជ្រាបអជ្ឈាសយានុសន្ធិដោយអំណាចសូត្រ ដែលព្រះមានព្រះភាគទ្រង់ជ្រាបអធ្យាស្រ័យរបស់អ្នកដទៃហើយ ត្រាស់ទុកយ៉ាងនេះថា ម្នាលព្រាហ្មណ៍ ចំណែកសមណព្រាហ្មណ៍ទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ថ្ងៃនេះឯង ព្រះសមណគោតមប្រហែលជាមិនទាន់ប្រាសចាករាគៈ ដូច្នេះ ។ ឯយថានុសន្ធិគប្បីជ្រាបដោយអំណាចសូត្រទាំងឡាយ ដែលជាទីមកនៃទេសនាជាន់ខ្ពស់តាមលំដាប់ ដោយអំណាចធម៌ដែលសមគួរ និងជាបដិបក្ខ ចំពោះធម៌ដែលជាហេតុឲ្យទេសនាកើតឡើងក្នុងពេលដំបូង ។

ដូចក្នុងអាកង្ខេយ្យសូត្រ ទេសនាដល់រឿងសីលធម៌ជាដើម ជាទេសនាជាន់ទាប អភិញ្ញា ៦ មក ជាទេសនាជាន់ខ្ពស់ ក្នុងកកចូបមសូត្រ ទេសនាពោលដោយការមិនអត់ធន់កើតឡើង ជាទេសនាជាន់ទាប ឱវាទឧបមាដោយរណារមក ជាទេសនាជាន់ខ្ពស់ ។ ក្នុងអលគទ្ទូបមសូត្រ ទេសនាពោល

ដោយការសម្តែងទិដ្ឋិកើតឡើង ជាទេសនាជាន់ទាប ការប្រកាសសុញ្ញតាមក ជាទេសនាជាន់ខ្ពស់ ។ ក្នុងចូឡអស្សបុរសូត្រ ទេសនាពោលដោយការមិនអត់ធន់កើតឡើង ជាទេសនាជាន់ទាប ព្រហ្មវិហារមកជាទេសនាជាន់ខ្ពស់ ។ ក្នុងកោសម្ពិកសូត្រ ទេសនាពោលដោយការឈ្លោះគ្នាកើតឡើង ជាទេសនាជាន់ទាប សារាណីយធម៌មកជាទេសនាជាន់ខ្ពស់ ។ សូម្បីក្នុងវត្ថូបមសូត្រនេះ ការសម្តែងរឿងកិលេសកើតជាទេសនាជាន់ទាប ព្រហ្មវិហារមក ជាទេសនាជាន់ខ្ពស់ ។ ព្រោះហេតុនោះ ទើបលោកពោលថា **យថានុសន្ធិវសេន ទេសនា អាគតា** ដូច្នេះ ។ ឯក្នុងព្រហ្មវិហារធម៌ លោកពោលការពណ៌នាតាមលំដាប់បទ និងន័យនៃការចម្រើនទាំងអស់ទុកក្នុងគម្ពីរវិសុទ្ធិមគ្គដោយគ្រប់គ្រាន់ ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការចម្រើនព្រហ្មវិហារនៃព្រះអនាគាមីនោះ ជាបដិបក្ខចំពោះឧបក្កិលេស មានអភិជ្ឈាជាដើម ឈ្មោះថា បានបទដ្ឋានហើយ ព្រោះកម្ចាត់ធម៌ដែលជាសត្រូវ ដោយលះកាមរាគៈ ព្យាបាទ ដោយប្រការទាំងពួងនោះឯង យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងវិបស្សនា ដើម្បីភាពជាព្រះអរហន្តនៃព្រះអនាគាមីនោះហើយ ទ្រង់សម្តែងការសម្រេចព្រះអរហត្តរបស់លោក ទើបត្រាស់ពាក្យថា **សោ អត្ថិ ឥទំ** ដូច្នេះជាដើម ។ ពាក្យនេះមានអត្ថថា ព្រះអនាគាមីនោះបានចម្រើនព្រហ្មវិហារយ៉ាងនេះហើយ ចេញចាកព្រហ្មវិហារណាមួយ ក្នុងបណ្តាព្រហ្មវិហារទាំងនោះហើយ កំណត់ធម៌ គឺព្រហ្មវិហារទាំងនោះឯង ថាជានាម និងកំណត់ធម៌ គឺភូតរូប និងឧបាទាយរូប ថាជារូប ដោយន័យជាដើមថា

ហទយវត្ថុជាទីអាស្រ័យរបស់ព្រហ្មវិហារធម៌ទាំងនោះ ភូតរូបជាទីអាស្រ័យរបស់ហទយវត្ថុ ដូច្នេះហើយ រមែងដឹងច្បាស់ថា សេចក្តីនេះនៅមានដូច្នេះ ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ព្រះអនាគាមីនេះធ្វើការកំណត់ទុក្ខសច្ចហើយ បន្ទាប់អំពីនោះ កាលលោកចាក់ធ្លុះទុក្ខសមុទយៈ រមែងដឹងច្បាស់ថា របស់ដែលអាក្រក់មាន ដូច្នេះ ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ លោកឈ្មោះថា កំណត់សមុទយៈហើយ បន្ទាប់អំពីនោះ លោកកាលជ្រើសរើសឧបាយជាគ្រឿងលះសមុទយសច្ចនោះ រមែងដឹងច្បាស់ថា វត្ថុដែលប្រសើរមាន ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រះអនាគាមីនេះឈ្មោះថា កំណត់មគ្គសច្ចហើយ ។ បន្ទាប់អំពីនោះ កាលលោកពិចារណាឋានៈដែលគប្បីសម្រេចដោយមគ្គនោះ រមែងដឹងច្បាស់ថា វិធីរលាស់សញ្ញានេះឲ្យក្រៃលែងឡើងទៅនៅមាន អធិប្បាយថា រមែងដឹងច្បាស់យ៉ាងនេះថា ព្រះនិព្វានជាគ្រឿងរលាស់នូវព្រហ្មវិហារសញ្ញានេះ ដែលអាត្មាអញសម្រេចហើយដ៏ក្រៃលែងមាន ដូច្នេះ ដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រះអនាគាមីនេះ ឈ្មោះថា ធ្វើការកំណត់និរោធសច្ចហើយ ។

បទថា **ឯវំ ជានតោ ឯវំ បស្សតោ** សេចក្តីថា កាលព្រះអនាគាមីនោះកំពុងដឹងនូវសច្ចៈ ៤ ដោយអាការ ៤ យ៉ាងនេះ ដោយវិបស្សនាបញ្ញា ឃើញយ៉ាងនេះដោយមគ្គប្បញ្ញា ចិត្តរមែងរួចផុតចាកអាសវៈ ដោយន័យដូចពោលទុកហើយ ក្នុងភយភេរវសូត្រ ។

បទថា **ឥត្ថត្តាយាតិ បជានាតិ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ញុំាង

ទេសនាឲ្យចប់ហូតដល់ព្រះអរហត្តយ៉ាងនេះហើយ ឥឡូវនេះ ព្រោះព្រាហ្មណ៍ មានការឃើញថា ការបរិសុទ្ធមានព្រោះការងូតទឹក អង្គុយនៅក្នុងបរិសទ្យ នោះឯង ព្រះមានព្រះភាគទ្រង់ជ្រាបហើយថា ព្រាហ្មណ៍នោះឯងបានស្តាប់ ការពណ៌នា ដល់នូវការបរិសុទ្ធ ព្រោះការងូតទឹកដែលតថាគតកំពុងពោល បួសហើយ នឹងសម្រេចអរហត្តដូច្នេះ ដូច្នោះ ដើម្បីបំណាងនឹងដាស់តឿន ព្រាហ្មណ៍នោះ ទើបត្រាស់អនុសន្ធិចែកចំពោះថា **អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ សិនាតោ អន្តរេន សិនានេន** ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោល ថា ងូតហើយដោយការងូតខាងក្នុង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អន្តរេន សិនានេន** សេចក្តីថា ដោយការ ងូត គឺការចេញចាកកិលេស ដែលមានក្នុងខាងក្នុង ។

[ ៩៨ ] បទថា **សុន្ទរិកភារទ្វាជោ** បានដល់ ព្រាហ្មណ៍នោះ ឈ្មោះថា ភារទ្វាជៈ ដោយអំណាចគោត្ររបស់ខ្លួន ។ ព្រាហ្មណ៍នោះមានការយល់ ឃើញដូច្នេះថា បុគ្គលដែលងូតទឹកក្នុងស្ទឹងសុន្ទរិកា រមែងលះបាបបាន ព្រោះ ដូច្នោះ ទើបត្រូវហៅថា សុន្ទរិកភារទ្វាជៈ ដូច្នេះ ។ ព្រាហ្មណ៍នោះបានស្តាប់ ព្រះតម្រាស់នៃព្រះមានព្រះភាគនោះហើយ គិតថា សូម្បីពួកយើង រមែង សរសើរការបរិសុទ្ធ ព្រោះការងូតទឹក ចំណែកព្រះគោតម ក៏រមែងសរសើរ ការបរិសុទ្ធ ព្រោះការងូតទឹកនោះដូចគ្នា ឥឡូវនេះ ព្រះសមណគោតមនេះ មានការពេញចិត្តដូចគ្នានឹងពួកយើង ដូច្នេះ ។ លំដាប់នោះ ព្រាហ្មណ៍ សម្គាល់ព្រះមានព្រះភាគថា ហាក់ដូចជាទ្រង់ទៅកាន់ស្ទឹងពាហុកា បន្សាត់

បាបក្នុងស្ទឹងនោះហើយ យាងមក ទើបក្រាបទូលថា ព្រះគោតមដ៏ចម្រើន ទ្រង់រមែងទៅកាន់ស្ទឹងពាហុកាដើម្បីស្រង់ទឹកឬ ព្រះមានព្រះភាគមិនត្រាស់ថា ទៅ ឬមិនទៅ តែទ្រង់មានបំណងនឹងដកទិដ្ឋិរបស់ព្រាហ្មណ៍នោះ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ ប្រយោជន៍អ្វីដោយទឹកស្ទឹងពាហុកា ទឹកស្ទឹងពាហុកានឹងធ្វើអ្វីបាន ដូច្នេះ ។ ពាក្យនោះមានអត្ថថា ប្រយោជន៍អ្វីដោយស្ទឹងពាហុកា ស្ទឹងពាហុកានោះនឹងធ្វើអ្វីបាន ស្ទឹងពាហុកានោះ មិនអាចញុំាងប្រយោជន៍ណាមួយឲ្យបានទេ តថាគតនឹងទៅត្រង់ស្ទឹងនោះធ្វើអ្វី លំដាប់នោះ ព្រាហ្មណ៍កាលសរសើរសេចក្តីនោះ ទើបពោលពាក្យថា **លោក្ខសម្មតា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **លោក្ខសម្មតា** សេចក្តីថា ស្ទឹងពាហុកាដែលសត្វលោកសន្មតថា ជាដែនផុតចាកបាប អធិប្បាយថា ដែលសត្វលោករមែងសន្មតយ៉ាងនេះថា រមែងឲ្យផុតចាកបាប គឺការរួចផុត បានដល់ សេចក្តីបរិសុទ្ធ ។ បាឋៈថា **លោក្យសម្មតា** ដូច្នេះក៏មាន ។ បាឋៈនោះមានអត្ថថា ដែលសត្វលោករមែងទទួលយ៉ាងនេះថា រមែងឲ្យដល់លោកដែលប្រសើរបំផុត ។

បទថា **បុញ្ញសម្មតា** បានដល់ សត្វលោក រមែងយល់ថា ជាបុណ្យដូច្នេះ ។ បទថា **បវាហេតិ** សេចក្តីថា បន្សាត់ទៅ គឺធ្វើឲ្យស្អាត ។

បទថា **គាថាហិ អជ្ឈភាសិ** សេចក្តីថា បានត្រាស់ដោយព្រះគាថាទាំងឡាយ ពិតហើយ គាថាទាំងឡាយ កាលព្រះមានព្រះភាគត្រាស់ រមែងត្រាស់ដល់បុគ្គលដែលចូលចិត្តគាថា ដើម្បីទ្រង់សម្តែងអត្ថនោះប៉ុណ្ណោះ ឬដើម្បី

សម្តែងអត្ថដែលសំខាន់ ។ តែក្នុងទីនេះ គាថាទាំងនោះគប្បីជ្រាបថា ត្រាស់ដើម្បីសម្តែងអត្ថទាំង ២ ។

ពិតហើយ បទថា **ពាហុកំ** នេះឯង ជាបទសម្តែងសេចក្តីនោះក្នុងទីនេះ បទដ៏សេស ជាបទសម្តែងអត្ថដែលសំខាន់ ដូចសុន្ទរិកភារទ្វាជព្រាហ្មណ៍ រមែងទៅកាន់ស្ទឹងពាហុកា ដើម្បីបណ្តែតបាបដោយការងូតទឹក យ៉ាងណា សត្វលោកក៏រមែងទៅកាន់ទីដែលមានកំពង់ទឹក មានកំពង់អធិកក្កាជាដើម ដើម្បីបណ្តែតបាប ដោយការងូតទឹក ដូច្នោះ ។ បណ្តាសត្វលោកទាំងនោះ ជនពួកណានៅជិតទីទាំងនោះ ជនទាំងនោះ រមែងងូតទឹកមួយថ្ងៃ ៣ ដង ជនពួកណានៅឆ្ងាយ ជនទាំងនោះរមែងងូតទឹកមួយថ្ងៃ ២ ដង ១ ដង រៀរថ្ងៃមួយៗ តាមលំដាប់យ៉ាងនេះ រហូតដល់មួយឆ្នាំ ១ ដង ។ ចំណែកជនពួកណាមិនអាចទៅបានសោះ ជនទាំងនោះ ក៏ប្រើឲ្យអ្នកដទៃយកធ្លាំងជងទឹកអំពីទីនោះមកងូត ។ ពាក្យទាំងអស់នេះមិនមានប្រយោជន៍ ។ ព្រោះដូច្នោះ ដើម្បីទ្រង់សម្តែងអត្ថ នេះ ទើបព្រះមានព្រះភាគត្រាស់ថា **អធិកក្កាធីធិបិ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អធិកក្កំ** ព្រះមានព្រះភាគត្រាស់សំដៅយកកំពង់ទឹកមួយកន្លែង ដែលមានឈ្មោះយ៉ាងនោះ ដោយអំណាចជាឧបករណ៍ក្នុងការងូត ។ បទថា **គយា** ព្រះមានព្រះភាគ ត្រាស់ដល់កំពង់ទឹកមានសណ្ឋានដូច ស្រះមូលនោះឯង ។

សូម្បីបទថា **បយាគា** នេះ ព្រះមានព្រះភាគត្រាស់សំដៅដល់កំពង់ទឹក

មួយរបស់ស្ទឹងគង្គា ដែលជាទីកន្លែងត្រង់មុខជណ្តើរប្រាសាទរបស់ព្រះបាទ មហាបនាទៈ ដែលលិចចុះទៅក្នុងស្ទឹងគង្គាហើយ ។ ចំណែកស្ទឹងទាំងនេះ គឺពាហុកា សុន្ទរិកា សរស្សតី ពាហុមតី ជាស្ទឹង ៤ ខ្សែ ។

បទថា **ពាលោ** បានដល់ អ្នកមានបញ្ញាថោកទាប ។ បទថា **បក្ខន្ទោ** ប្រែថា ចូលទៅ ។ បទថា **ន សុជ្ឈតិ** ប្រែថា មិនសម្រេចដល់ការបរិសុទ្ធ ចាកកិលេស ។ បុគ្គលរមែងបណ្តែតបានតែក្អែលតែម្យ៉ាងប៉ុណ្ណោះ ។

បទថា **កឹ សុន្ទរិកា ករិស្សតិ** សេចក្តីថា ស្ទឹងសុន្ទរិកា នឹងធ្វើអ្វីបាន ដោយការជម្រះកិលេស អធិប្បាយថា មិនអាចនឹងធ្វើអ្វីបានឡើយ ។ ក្នុង កំពង់ទឹកបយាគា និងស្ទឹងពាហុកាក៏មានន័យនេះ ។ ដោយបទទាំង ៣ នេះ លោកពោលទុកហើយ ឈ្មោះថា លោកពោល ៤ បទក្រៅអំពីនេះទុកផងដូច គ្នា ដោយលក្ខណហារន័យ ។ ព្រោះដូច្នោះ គប្បីជ្រាបថា ស្ទឹងអធិកក្កាជា ដើម ក៏ធ្វើអ្វីមិនបាន ដូចគ្នានឹងស្ទឹងសុន្ទរិកា ស្ទឹងបយាគា និងស្ទឹងពាហុកា ធ្វើអ្វីមិនបាន ដូច្នោះ ។

បទថា **វេរី** ប្រែថា បុគ្គលប្រកបដោយពៀរ ៥ មានបាណាតិបាតជា ដើម ។ បទថា **កតកិព្វិសំ** គឺជាអ្នកបានធ្វើកម្មដែលគ្រោតគ្រាតទុកហើយ ។ បទថា **ន ហិ នំ សោធយេ** លោកពោលអធិប្បាយទុកថា ស្ទឹងសុន្ទរិកា កំពង់បយាគា ឬស្ទឹងពាហុកា ក៏ធ្វើបុគ្គលឲ្យបរិសុទ្ធមិនបាន ។

បទថា **ចាបកម្មិនំ** សេចក្តីថា ប្រកបដោយកម្មដែលជាបាប គឺកម្មដែល ថោកទាប ជាកម្មប្រកបដោយពៀរ ឬប្រកបដោយអំពើលាមក លោកពោល

អធិប្បាយទុកថា ប្រកបដោយបាប សូម្បីតិចតួច ដែលមិនទាន់ដល់ភាពជាទោស គឺពៀរ ។ បទថា **សុទ្ធស្ស** ប្រែថា អស់កិលេស ។

បទថា **សទា ផគ្គុ** បានដល់ បុណ្យនក្ខត្តឫក្សប្រចាំខែផល្គុណដែលមានជាប្រចាំ ។ បានឮថា ព្រាហ្មណ៍នោះ មានទិដ្ឋិយ៉ាងនេះថា ក្នុងខែផល្គុណ បុគ្គលណាងូតទឹកក្នុងថ្ងៃខាងខ្នើត ខែផល្គុណ បុគ្គលនោះ រមែងជម្រះបាបដែលខ្លួនធ្វើពេញមួយឆ្នាំបាន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលជំទាស់ទិដ្ឋិរបស់ព្រាហ្មណ៍នោះ ទើបត្រាស់ថា សម្រាប់បុគ្គលបរិសុទ្ធហើយ ខែផល្គុណ មានគ្រប់កាល សម្រាប់បុគ្គលអស់កិលេសហើយ នក្ខត្តឫក្សប្រចាំខែផល្គុណ មានប្រចាំ អន្លង់ទឹកនេះនឹងជម្រះលាងអ្វីបាន ដូច្នេះ ។

បទថា **ឧបោសថោ សទា** សេចក្តីថា បុគ្គលដែលបរិសុទ្ធហើយ សូម្បីមិនបានសមាទានអដ្ឋឧបោសថ ក្នុងថ្ងៃ ១៤ កើត ១៥ កើតរបស់ឧបោសថ ក៏រមែងមានជានិច្ចនោះឯង ។

បទថា **សុទ្ធស្ស សុចិកម្មស្ស** ប្រែថា ឈ្មោះថា បុគ្គលស្អាតហើយ ព្រោះជាអ្នកអស់កិលេស និងជាបុគ្គលប្រកបដោយកាយកម្មជាដើមដ៏ស្អាត។

បទថា **សទា សម្បជ្ជតេ វតំ** សេចក្តីថា សូម្បីការសមាទានវត្តដែលប្រកបដោយកុសលរបស់បុគ្គលយ៉ាងនេះ រមែងដល់ព្រមជាប្រចាំនោះឯង ។

បទថា **ឥធេវ សិនាហិ** លោកពោលអធិប្បាយទុកថា ព្រះមានព្រះភាគត្រាស់ថា អ្នកចូរងូតទឹកក្នុងសាសនារបស់តថាគតនេះឯង ។ លោកពោលអធិប្បាយទៀតថា បើអ្នកប្រាថ្នានឹងលាងមន្ទិល គឺកិលេសខាងក្នុងសោត ចូរ

ងូតដោយទឹក គឺមគ្គមានអង្គ ៨ ក្នុងសាសនានៃតថាគតនេះនោះឯង ព្រោះថា ក្នុងទីដទៃ ទឹក គឺមគ្គមានអង្គ ៨ ដូច្នេះ មិនមាន ដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការបរិសុទ្ធក្នុងទ្វារទាំង ៣ ដោយអំណាចទេសនា ដែលសមគួរដល់ព្រាហ្មណ៍នោះ ទើបត្រាស់ពាក្យថា **សព្វភូតេសុ ករោហិ ខេមតំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ខេមតំ** បានដល់ ការមិនមានភ័យ គឺភាពជាប្រយោជន៍ អធិប្បាយថា បានដល់ មេត្តា ។ ដោយបទនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងការបរិសុទ្ធតាមមនោទ្វារដល់ព្រាហ្មណ៍នោះ ។

ដោយបទថា **សចេ មុសា ន ភណសិ** នេះ ព្រះមានព្រះភាគ ទ្រង់សម្តែងការស្អាតតាមវចីទ្វារ ។ ដោយបទទាំងនេះថា **សចេ បាណំ ន ហឹសសិ សចេ អទិន្នំ នាទិយសិ** ឈ្មោះថា ព្រះមានព្រះភាគ ទ្រង់សម្តែងការបរិសុទ្ធតាមកាយទ្វារ ។

ដោយបទទាំងនេះថា **សទ្ទហានោ អមច្ឆរី** ព្រះមានព្រះភាគ ទ្រង់ប្រកបព្រាហ្មណ៍នោះ ដែលមានទ្វារបរិសុទ្ធហើយយ៉ាងនេះ ទុកក្នុងសទ្ធាសម្បទា និងចាគសម្បទា ។ ឯបាលីថា **កឹ កាហសិ គយំ គន្ត្វា ឧទបានោបិ តេ គយា** ជាពាក់កណ្តាលគាថា ។ គប្បីប្រកបអត្ថយ៉ាងនេះថា បើអ្នកធ្វើការឲ្យអភ័យក្នុងសត្វទាំងពួង មិននិយាយកុហក មិនសម្លាប់សត្វ មិនលួចទ្រព្យ មានការជឿ មិនកំណាញ់ អ្នកទៅកាន់ស្ទឹងគយា នឹងធ្វើអ្វីបាន សូម្បីស្ទឹងគយាក៏គ្រាន់តែជាអណ្តូងទឹកសម្រាប់អ្នក ព្រោះថា កាលអ្នកងូតទឹកក្នុងស្ទឹង

គយាក្តី ក្នុងអណ្តូងទឹកក្តី ការបរិសុទ្ធចាកកិលេស នឹងមានក៏ដោយការបដិបត្តិ នេះប៉ុណ្ណោះ ឯការបរិសុទ្ធចាកមន្ទិលតាមរាងកាយ មានដូចគ្នា ក្នុងទីទាំង ២ កន្លែង ។ បណ្ឌិតគប្បីជ្រាបអត្ថថា ព្រោះថា ស្ទឹងគយាដែលសត្វលោក ស្គាល់ច្រើនជាងក្នុងលោក ដូច្នោះ ព្រះមានព្រះភាគ ត្រូវព្រាហ្មណ៍នោះទូល សួរថា ព្រះគោតមដ៏ចម្រើន ទ្រង់ទៅកាន់ស្ទឹងពាហុកាឬ មិនត្រាស់ថា អ្នក ទៅកាន់ស្ទឹងពាហុកា នឹងធ្វើអ្វីបាន តែត្រាស់ថា អ្នកទៅកាន់ស្ទឹងគយា នឹង ធ្វើអ្វីបាន ដូច្នេះ ។

[ ៩៩ ] ពាក្យជាដើមយ៉ាងនេះថា **ឯវំ វុត្តេ** រាប់ថា ជាក់ច្បាស់ហើយ ព្រោះ លោកពោលទុកហើយ ក្នុងភយភេរវសូត្រ ។

ក្នុងបទជាដើមថា **ឯកោ វូបកដ្ឋោ** គប្បីជ្រាបអធិប្បាយដូច្នេះ ព្រាហ្មណ៍ ឈ្មោះថា ជាបុគ្គលម្នាក់ឯងដោយកាយវិវេក ឈ្មោះថា ចៀសចេញហើយ ចាកការប្រឡូកប្រឡំ គឺនីវរណៈ ដោយចិត្តវិវេក ឈ្មោះថា មិនប្រមាទ ដោយការមិនលះបង់សតិក្នុងកម្មដ្ឋាន ឈ្មោះថា មានសេចក្តីព្យាយាម ដោយ ការព្យាយាមដុតកិលេស ពោល គឺសេចក្តីព្យាយាមតាមកាយ និងការព្យា-យាមតាមផ្លូវចិត្ត ឈ្មោះថា អស់អាល័យក្នុងខ្លួនហើយ ព្រោះមិនមានការ ជាប់ជំពាក់ក្នុងកាយ និងជីវិត ឈ្មោះថា នៅដោយឥរិយាបថឯណាមួយ ក្នុងបណ្តាឥរិយាបថ ៤ ។ បទថា **ន ចិរស្សេវ** លោកពោលសំដៅដល់ បព្វជ្ជា ។ បទថា **កុលបុត្តា** បានដល់ កុលបុត្រមាន ២ ពួក គឺកុលបុត្រ ដោយជាតិ និងកុលបុត្រដោយអាចារៈ ។ ព្រាហ្មណ៍នេះជាកុលបុត្រដោយ

ប្រការទាំង ២ ។ បទថា **អគារស្មា** ប្រែថា ចាកផ្ទះ ។

ក្នុងបទថា **អនគារិយំ** គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ការងារដែលជាហេតុកពូនទ្រព្យសម្បត្តិ មានកសិកម្ម និងគោរក្ខកម្មជាដើម ដែលជាប្រយោជន៍ដល់ការគ្រប់គ្រងផ្ទះ លោកហៅថា **អគារិយ** ។ ការងារដែលឧបការៈដល់ការគ្រប់គ្រងផ្ទះក្នុងបព្វជ្ជានេះ មិនមាន ហេតុនោះ ទើបបព្វជ្ជានេះ ឈ្មោះថា **អនគារិយំ** ។ ពាក្យថា **អនគារិយំ** នោះ ជាឈ្មោះនៃការបួស ។

បទថា **បព្វជន្តិ** ប្រែថា ចូលទៅជិត គឺចូលទៅរក ។

បទថា **តទនុត្តរំ** កាត់បទជា **តំ អនុត្តរំ** ប្រែថា ផលដ៏ប្រសើរនោះ។

បទថា **ព្រហ្មចរិយ បរិយោសានំ** បានដល់ ទីបំផុតនៃមគ្គព្រហ្មចរិយៈ លោកពោលអធិប្បាយទុកថា បានដល់ អរហត្តផល ដូច្នេះ ។ ពិតហើយ ពួកកុលបុត្របួស ក៏ដើម្បីប្រយោជន៍ដល់អរហត្តផលនោះ ។

បទថា **ទិដ្ឋេវ ធម្មេ** ប្រែថា ក្នុងអត្តភាពនោះឯង ។

បទថា **សយំ អភិញ្ញា សច្ឆិកត្វា** សេចក្តីថា ធ្វើឲ្យប្រចក្សដោយបញ្ញាដោយខ្លួនឯងនោះឯង អធិប្បាយថា ដឹងដោយមិនមានអ្នកដទៃជាបច្ច័យដូច្នេះ ។ បទថា **ឧបសម្បជ្ជ វិហាសិ** សេចក្តីថា សម្រេច គឺឲ្យសម្រេច ។ សុន្ទរិកភារទ្វាជភិក្ខុ កាលនៅដោយអាការយ៉ាងនោះ ក៏បានជ្រាបច្បាស់ថា ជាតិអស់ហើយ ។បេ។ ដូច្នេះ ព្រះអានន្ទត្ថេរសម្តែងដល់ភូមិនៃបច្ចវេក្ខណញ្ញាណ របស់លោកដោយពាក្យនោះ ។

សួរថា ជាតិណារបស់លោកអស់ទៅហើយ ហើយដឹងជាតិដែលអស់

ទៅនោះ ដូចម្ដេច ខ្ញុំនឹងឆ្លើយដូចតទៅថា

សេចក្ដីនោះបានពោលហើយ ក្នុងកយកេរវសូត្រក៏ពិត ។ តែទោះជាយ៉ាងនោះ ក្នុងទីនេះ ខ្ញុំនឹងពោលសេចក្ដីនោះដដែលទៀត ដោយសង្ខេបដើម្បីសម្ដែងន័យក្នុងការអធិប្បាយប្រកបសេចក្ដី ដោយបឋមបុរស ។ ជាតិដែលជាអតីតរបស់សុន្ទរិកភារទ្វាជភិក្ខុនោះ មិនឈ្មោះថា អស់ទៅហើយមុន ក្នុងទីនេះ ព្រោះជាតិនោះអស់ទៅហើយក្នុងកាលមុននោះឯង ។ ជាតិដែលជាអនាគតក៏មិនឈ្មោះថា អស់ទៅ ព្រោះលោកមិនមានការព្យាយាម ក្នុងជាតិដែលជាអនាគតនោះ ។ ជាតិដែលជាបច្ចុប្បន្ន ក៏មិនឈ្មោះថា អស់ទៅព្រោះជាតិបច្ចុប្បន្ននៅមាន ។ ជាតិណាចែកប្រភេទជាខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ក្នុងឯកវោការភព ចតុវោការភព និងបញ្ចវោការភព គប្បីកើតឡើងព្រោះមិនទាន់បានចម្រើនមគ្គឲ្យកើតមាន ជាតិនោះ ឈ្មោះថា អស់ទៅហើយព្រោះដល់នូវភាពជាជាតិដែលមានការមិនកើតឡើងជាធម្មតា ព្រោះលោកបានចម្រើនមគ្គឲ្យកើតឡើងហើយ ។ សុន្ទរិកភារទ្វាជភិក្ខុនោះ ពិចារណាដល់កិលេសដែលមគ្គភាវនាលះបានហើយ ដឹងថា កាលមិនមានកិលេស កម្មមាន ក៏រមែងមិនឲ្យបដិសន្ធិតទៅ ឈ្មោះថា រមែងដឹងជាតិដែលអស់ទៅនោះ ។

បទថា **វុសិតំ** សេចក្ដីថា នៅហើយ គឺនៅចប់ហើយ អធិប្បាយថា ធ្វើហើយ ប្រព្រឹត្តហើយ ឲ្យចប់ហើយ ។ បទថា **ព្រហ្មចរិយំ** បានដល់ មគ្គព្រហ្មចរិយៈ ។ បទថា **កតំ ករណីយំ** សេចក្ដីថា កិច្ចទាំង ១៦ គឺ បរិញ្ញាកិច្ច បហានកិច្ច សច្ឆិកិរិយាកិច្ច និងភាវនាកិច្ច ដែលលោកឲ្យសម្រេច

ហើយ ដោយមគ្គ ៤ ក្នុងសច្ចៈទាំង ៤ ។

បទថា **ឆាបរំ ឥត្ថត្តាយ** សេចក្តីថា ការចម្រើនមគ្គដើម្បីភាពជាយ៉ាង នេះទៀត គឺដើម្បីកិច្ច ១៦ យ៉ាង ឬដើម្បីការអស់កិលេសទាំងនេះមិនមាន ក្នុងឥឡូវនេះ ។

ម្យ៉ាងទៀត បទថា **ឥត្ថត្តាយ** សេចក្តីថា ការបន្តនៃខន្ធដទៃចាកសភាព យ៉ាងនេះ គឺចាកខន្ធសន្តានដែលប្រព្រឹត្តទៅក្នុងឥឡូវនេះ យ៉ាងនេះមិនមាន។ សុន្ទរិកភារទ្វាជភិក្ខុនោះ បានដឹងហើយថា ខន្ធទាំង ៥ នេះ លោកកំណត់ ដឹងហើយ តាំងនៅ ប្រៀបដូចដើមឈើដែលត្រូវកាត់ឫសហើយ ដូច្នោះ ។

បទថា **អញ្ញតរោ** គឺមានអត្ថស្មើគ្នានឹង **ឯកោ** ប្រែថា មួយ ។

បទថា **អរហតំ** គឺ **អរហន្តានំ** ។ អធិប្បាយថា លោកជាព្រះអរហន្ត មួយអង្គ ក្នុងបណ្តាព្រះអរហន្តដែលជាសាវ័ករបស់ព្រះមានព្រះភាគ ដូច្នេះ ។

**វត្ថូបមសូត្រ ចប់**

**សូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សល្លេខសូត្រទី ៨

[ ១០០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមហាចុន្ទមានអាយុ ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមហាចុន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ទិដ្ឋិទាំងឡាយច្រើនប្រការណា ដែលជាទិដ្ឋិប្រកបដោយអត្តវាទខ្លះ ប្រកបដោយលោកវាទខ្លះ កើតឡើងក្នុងលោក បពិត្រព្រះអង្គដ៏ចម្រើន កាលបើភិក្ខុធ្វើទុកក្នុងចិត្តជាដំបូង តើលះទិដ្ឋិទាំងនុ៎ះ ដោយឧបាយយ៉ាងនេះ បោលទិដ្ឋិទាំងនុ៎ះ ដោយឧបាយយ៉ាងនេះដែរឬទេ ។

[ ១០១ ] ព្រះអង្គត្រាស់ថា ម្នាលចុន្ទ ទិដ្ឋិទាំងឡាយមានច្រើនប្រការណា ដែលជាទិដ្ឋិប្រកបដោយអត្តវាទខ្លះ ប្រកបដោយលោកវាទខ្លះ កើតឡើងក្នុងលោក ក៏ទិដ្ឋិទាំងឡាយនោះ កើតក្នុងបញ្ចក្ខន្ធណា ដេកសម្ងំនៅក្នុងបញ្ចក្ខន្ធណា ផុសផុលឡើងក្នុងបញ្ចក្ខន្ធណា កាលបើភិក្ខុឃើញច្បាស់នូវបញ្ចក្ខន្ធនុ៎ះ តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នេះមិនមែនរបស់អញ នេះមិនមែនអញ នេះមិនមែនខ្លួនរបស់អញដូច្នេះ ការលះបង់នូវទិដ្ឋិទាំងឡាយនេះ គង់មានដោយឧបាយយ៉ាងនេះបាន ការរលាស់បោលនូវទិដ្ឋិទាំងឡាយនោះ គង់មានដោយឧបាយយ៉ាងនេះបាន ។

[១០២] ម្នាលចុន្ទ ហេតុនេះតែងមានជាប្រាកដ គឺភិក្ខុពួកខ្លះក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ចូលបឋមជ្ឈានប្រកបដោយវិតក្កវិចារៈ មានបីតិ និងសុខដែលកើតអំពីវិវេក ភិក្ខុនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញនៅដោយសេចក្ដីជូរចត់ ដូច្នេះ ម្នាលចុន្ទ តែតថាគត មិនទាន់ឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាសេចក្ដីជូរចត់ ក្នុងវិន័យរបស់ព្រះអរិយៈទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនោះ ថាជាការនៅសប្បាយក្នុងបច្ចុប្បន្ន ក្នុងវិន័យរបស់ព្រះអរិយៈ ( ប៉ុណ្ណោះ ) ។ ម្នាលចុន្ទ ហេតុនេះតែងមានជាប្រាកដ គឺភិក្ខុពួកខ្លះក្នុងសាសនានេះ ចូលទុតិយជ្ឈាន ដែលកើតក្នុងសន្ដាននៃខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារៈ មានតែបីតិ និងសុខ កើតអំពីសមាធិ ព្រោះស្ងប់រម្ងាប់វិតក្ក និងវិចារៈ ភិក្ខុនោះមានសេចក្ដីសម្គាល់ថា អាត្មាអញនៅដោយសេចក្ដីជូរចត់ដូច្នេះ ម្នាលចុន្ទ តែថាតថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាសេចក្ដីជូរចត់ ក្នុងអរិយវិន័យទេគ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាការនៅសប្បាយក្នុងបច្ចុប្បន្ន ក្នុងអរិយវិន័យប៉ុណ្ណោះ ។ ម្នាលចុន្ទ ហេតុនេះតែងមានជាប្រាកដ គឺភិក្ខុពួកខ្លះក្នុងសាសនានេះ មានចិត្តព្រងើយកន្តើយ ព្រោះនឿយណាយចាកបីតិ តែមានស្មារតី និងដឹងខ្លួនទទួលសេចក្ដីសុខដោយនាមកាយ ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គលប្រកបដោយតតិយជ្ឈាននោះថា បុគ្គលប្រកបដោយតតិយជ្ឈាន មានចិត្តព្រងើយកន្តើយ មានស្មារតីនៅជាសុខ ដូច្នេះ ដោយតតិយជ្ឈានណា ( ភិក្ខុនោះ ) ក៏បាន

ចូលតតិយជ្ឈានទោះ ភិក្ខុនោះមានសេចក្តីសម្គាល់ថា អាត្មាអញនៅដោយសេចក្តីផូរផង់ដូច្នេះ ម្នាលចុន្ទ តែតថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាសេចក្តីផូរផង់ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាការនៅសប្បាយក្នុងបច្ចុប្បន្ន ក្នុងអរិយវិន័យប៉ុណ្ណោះ ។ ម្នាលចុន្ទ ហេតុនេះតែងមានជាប្រាកដ គឺភិក្ខុពួកខ្លះក្នុងសាសនានេះចូលចតុត្ថជ្ឈាន មានសតិដ៏បរិសុទ្ធដោយឧបេក្ខា មិនទុក្ខ មិនសុខ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង វិនាសទៅនៃសោមនស្ស និងទោមនស្សទាំងឡាយក្នុងកាលមុនផង ភិក្ខុនោះមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញ នៅដោយសេចក្តីផូរផង់ដូច្នេះ ម្នាលចុន្ទ តែថាតថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាសេចក្តីផូរផង់ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាការនៅសប្បាយក្នុងបច្ចុប្បន្ន ក្នុងអរិយវិន័យប៉ុណ្ណោះ ។

[១០៣] ម្នាលចុន្ទ ហេតុនេះតែងមានជាប្រាកដ គឺភិក្ខុពួកខ្លះក្នុងសាសនានេះ ចូលអាកាសានញ្ចាយតនៈ ដោយគិតថា អាកាសមិនមានទីបំផុត ព្រោះកន្លងនូវពួករូបសញ្ញា វិនាសទៅនៃពួកបដិឃសញ្ញា មិនកំណត់ក្នុងចិត្តនូវពួកនានត្តសញ្ញាដោយសព្វគ្រប់ ភិក្ខុនោះមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញនៅដោយសេចក្តីផូរផង់ដូច្នេះ ម្នាលចុន្ទ តែថាតថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាសេចក្តីផូរផង់ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាគ្រឿងនៅដ៏ស្ងប់ស្ងាត់ក្នុងបច្ចុប្បន្ន ក្នុងអរិយវិន័យប៉ុណ្ណោះ ។ ម្នាលចុន្ទ ហេតុនេះតែងមានជាប្រាកដ គឺ ភិក្ខុពួកខ្លះក្នុងសាសនានេះ កន្លងហួស

អាកាសានញ្ចាយតនៈដោយសព្វគ្រប់ ហើយចូលវិញ្ញានញ្ចាយតនៈ ដោយគិតថា វិញ្ញាណមិនមានទីបំផុត ភិក្ខុនោះ ក៏មានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញនៅដោយសេចក្តីផូរផង់ដូច្នេះ ម្នាលចុន្ទ តែថា តថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាសេចក្តីផូរផង់ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាគ្រឿងនៅដ៏ស្ងប់រម្ងាប់ ក្នុងអរិយវិន័យប៉ុណ្ណោះ ។ ម្នាលចុន្ទ ហេតុនេះ តែងមានជាប្រាកដ គឺភិក្ខុពួកខ្លះក្នុងសាសនានេះ កន្លងហួសនូវវិញ្ញាណញ្ចាយតនៈដោយសព្វគ្រប់ ហើយចូលអកិញ្ចញ្ញាយតនៈ ដោយគិតថា វត្ថុតិចតួចមិនមាន ភិក្ខុនោះក៏មានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញនៅដោយសេចក្តីផូរផង់ដូច្នេះ ម្នាលចុន្ទ តែថា តថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាសេចក្តីផូរផង់ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាគ្រឿងនៅដ៏ស្ងប់រម្ងាប់ ក្នុងអរិយវិន័យប៉ុណ្ណោះ ។ ម្នាលចុន្ទ ហេតុនេះតែងមានជាប្រាកដ គឺភិក្ខុពួកខ្លះក្នុងសាសនានេះ កន្លងហួសនូវអាកិញ្ចញ្ញាយតនៈដោយសព្វគ្រប់ ហើយចូលនេវសញ្ញានាសញ្ញាយតនៈ ភិក្ខុនោះក៏មានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញនៅដោយសេចក្តីផូរផង់ដូច្នេះ ម្នាលចុន្ទ តែថា តថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាសេចក្តីផូរផង់ ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះ ថាជាគ្រឿងនៅដ៏ស្ងប់រម្ងាប់ ក្នុងអរិយវិន័យប៉ុណ្ណោះ ។

[ ១០៤ ] ម្នាលចុន្ទ អ្នកត្រូវធ្វើសេចក្តីផូរផង់ ក្នុងវត្ថុមានការមិនបៀតបៀនជាដើមនេះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយ

ដទៃ នឹងជាអ្នកបៀតបៀនក្នុងវត្ថុណា ពួកយើងនឹងជាអ្នកមិនបៀតបៀនក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្លូវផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងជាអ្នកបំបាត់ជីវិតសត្វ ក្នុងវត្ថុណា ពួកយើងនឹងជាអ្នកវៀរចាកកិរិយាបំបាត់ជីវិតក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើសេចក្ដីផ្លូវផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងកាន់យកនូវរបស់គេមិនបានឲ្យ ក្នុងវត្ថុណា ពួកយើងនឹងវៀរចាកការកាន់យកនូវរបស់ដែលគេមិនបានឲ្យក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្លូវផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងប្រព្រឹត្តនូវធម៌មិនប្រសើរ ក្នុងវត្ថុណា ពួកយើងនឹងប្រព្រឹត្តនូវធម៌ដ៏ប្រសើរក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្លូវផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងនិយាយពាក្យកុហកក្នុងវត្ថុណា ពួកយើងនឹងវៀរការនិយាយពាក្យកុហកក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្លូវផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានសម្ដីញុះញង់ក្នុងវត្ថុណា ពួកយើងនឹងវៀរចាកសម្ដីញុះញង់ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្លូវផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានសម្ដីទ្រគោះក្នុងវត្ថុណា ពួកយើងនឹងវៀរសម្ដីទ្រគោះក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្លូវផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងពោលពាក្យឥតប្រយោជន៍ក្នុងវត្ថុណា ពួកយើងនឹងវៀរចាក ការពោលពាក្យឥតប្រយោជន៍ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្លូវផង់យ៉ាងនេះថា ជនទាំងឡាយដទៃមានសេចក្ដីគយគន់ ( ចង់បានទ្រព្យអ្នកដទៃ ) ក្នុងវត្ថុណា ពួកយើងនឹងមិនមានសេចក្ដីគយគន់ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្លូវផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានចិត្ត

គុំកួន ក្នុងវត្ថុណា ពួកយើងនឹងមិនមានចិត្តគុំកួនក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផ្ចង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងជាមិច្ឆាទិដ្ឋិក្នុងវត្ថុណា យើងទាំងឡាយនឹងជាសម្មាទិដ្ឋិក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផ្ចង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានតម្រិះខុសក្នុងវត្ថុណា ពួកយើងនឹងមានតម្រិះត្រូវក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផ្ចង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានសម្តីខុស ក្នុងវត្ថុណា ពួកយើងនឹងមានសម្តីត្រូវក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផ្ចង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានការងារខុស ក្នុងវត្ថុណា ពួកយើងនឹងមានការងារត្រូវក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផ្ចង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងចិញ្ចឹមជីវិតខុសក្នុងវត្ថុណា ពួកយើងនឹងចិញ្ចឹមជីវិតត្រូវក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផ្ចង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានព្យាយាមខុសក្នុងវត្ថុណា ពួកយើងនឹងមានព្យាយាមត្រូវក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផ្ចង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានសេចក្តីរឭកខុស ក្នុងវត្ថុណា ពួកយើងនឹងមានសេចក្តីរឭកត្រូវក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផ្ចង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានសមាធិខុសក្នុងវត្ថុណា ពួកយើងនឹងមានសមាធិត្រូវក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផ្ចង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានញាណខុសក្នុងវត្ថុណា ពួកយើងនឹងមានញាណត្រូវក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផ្ចង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានវិមុត្តិខុសក្នុងវត្ថុណា ពួកយើងនឹងមានវិមុត្តិត្រូវក្នុងវត្ថុនុ៎ះ ។ ពួកអ្នក

ត្រូវធ្វើនូវសេចក្ដីផ្សេងយ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានបីនមិទ្ធៈគ្របសង្កត់ក្នុងវត្ថុណា ពួកយើងនឹងមានបីនមិទ្ធៈទៅប្រាសហើយក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សេងយ៉ាងនេះថា ជនទាំងឡាយដទៃ នឹងប្រកបដោយសេចក្ដីរាយមាយ ក្នុងវត្ថុណា ពួកយើងនឹងមិនមានសេចក្ដីរាយមាយក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សេងយ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានសេចក្ដីសង្ស័យ ក្នុងវត្ថុណា ពួកយើងនឹងមានសេចក្ដីសង្ស័យកន្លងផុតហើយក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សេងយ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានសេចក្ដីក្រេវក្រោធក្នុងវត្ថុណា ពួកយើងនឹងមិនមានសេចក្ដីក្រេវក្រោធក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សេងយ៉ាងនេះថា ជនទាំងឡាយដទៃនឹងចងសេចក្ដីក្រេវក្រោធទុកក្នុងវត្ថុណា ពួកយើងនឹងមិនចងសេចក្ដីក្រេវក្រោធទុកក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សេងយ៉ាងនេះថា ជនទាំង-ឡាយដទៃនឹងលុបលាងគុណគេក្នុងវត្ថុណា ពួកយើងនឹងមិនលុបលាងគុណគេក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សេងយ៉ាងនេះថា ជនទាំងឡាយដទៃ នឹងតម្កើងឫកស្មើក្នុងវត្ថុណា ពួកយើងនឹងមិនតម្កើងឫកស្មើក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សេងយ៉ាងនេះថា ជនទាំងឡាយដទៃ នឹងប្រណែនក្នុងវត្ថុណា ពួកយើងនឹងមិនប្រណែនក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សេងយ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានសេចក្ដីកំណាញ់ ក្នុងវត្ថុណា ពួកយើងនឹងមិនមានសេចក្ដីកំណាញ់ ក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្ដីផ្សេងយ៉ាងនេះថា ជនទាំងឡាយដទៃ នឹងអួតអាងក្នុងវត្ថុណា ពួកយើងនឹង

មិនអួតអាងក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានមាយាក្នុងវត្តណា ពួកយើងនឹងមិនមានមាយាក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងរឹងត្អឹងក្នុងវត្តណា ពួកយើងនឹងមិនរឹងត្អឹងក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានសេចក្តីមើលងាយគេក្នុងវត្តណា ពួកយើងនឹងមិនមានសេចក្តីមើលងាយគេក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងជាអ្នកដែលគេប្រដៅក្រក្នុងវត្តណា ពួកយើងនឹងជាអ្នកដែលគេប្រដៅងាយក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមានមិត្តអាក្រក់ក្នុងវត្តណា ពួកយើងនឹងមានមិត្តល្អក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងប្រហែសធ្វេសក្នុងវត្តណា ពួកយើងនឹងមិនប្រហែសធ្វេសក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមិនមានសទ្ធាក្នុងវត្តណា ពួកយើងនឹងមានសទ្ធាក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមិនខ្មាសបាបក្នុងវត្តណា ពួកយើងនឹងមានចិត្តខ្មាសបាបក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមិនខ្លាចបាបក្នុងវត្តណា ពួកយើងនឹងខ្លាចបាបក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមិនរៀនសូត្រក្នុងវត្តណា ពួកយើងនឹងរៀនសូត្រច្រើនក្នុងវត្តនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ

នឹងខ្ជិលច្រអូសក្នុងវត្ថុណា ពួកយើងនឹងមានព្យាយាមប្រឹងប្រែងក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផ្សពផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានសេចក្តីភ្លេចភ្លាំង ក្នុងវត្ថុណា ពួកយើងនឹងប្រុងស្មារតីក្នុងវត្ថុនោះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផ្សពផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងអាប់ឥតប្រាជ្ញាក្នុងវត្ថុណា ពួកយើងនឹងមានប្រាជ្ញាក្នុងវត្ថុនុ៎ះ ។ ពួកអ្នកត្រូវធ្វើនូវសេចក្តីផ្សពផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកប្រកាន់មាំ ជាអ្នកដែលគេឲ្យលះបង់ ( លទ្ធិ ) បានដោយក្រក្នុងវត្ថុណា ពួកយើងនឹងមិនប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកមិនប្រកាន់មាំ នឹងជាអ្នកដែលគេឲ្យលះបង់ ( លទ្ធិ ) បានដោយងាយ ។

[ ១០៥ ] ម្នាលចុន្ទ តថាគតពោលចំពោះនៃការកើតឡើងនៃចិត្តក្នុងកុសលធម៌ទាំងឡាយ ថាមានឧបការៈច្រើន នឹងពោលទៅថ្វីក្នុងការតាក់តែងដោយកាយ ឬដោយវាចា ។ ម្នាលចុន្ទ ព្រោះហេតុនោះ អ្នកត្រូវញ៉ាំងចិត្តឲ្យកើតឡើងយ៉ាងនេះថា ជនទាំងឡាយដទៃ នឹងបៀតបៀនក្នុងវត្ថុណា ពួកយើងនឹងមិនបៀតបៀនក្នុងវត្ថុនុ៎ះ ។ អ្នកត្រូវញ៉ាំងចិត្តឲ្យកើតឡើងយ៉ាងនេះថា ជនទាំងឡាយដទៃ នឹងបំបាត់ជីវិតសត្វ ក្នុងវត្ថុណា ពួកយើងនឹងវៀរចាកការបំបាត់ជីវិតសត្វក្នុងវត្ថុនុ៎ះ។បេ។ អ្នកត្រូវញ៉ាំងចិត្តឲ្យកើតឡើងយ៉ាងនេះថា ជនទាំងឡាយដទៃ នឹងប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកប្រកាន់មាំ ជាអ្នកដែលគេឲ្យលះបង់ ( លទ្ធិ ) បានដោយក្រក្នុងវត្ថុណា ពួកយើងនឹងមិនប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកមិនប្រកាន់មាំ ជាអ្នក

ដែលគេឲ្យលះបង់ ( លទ្ធិ ) បានដោយងាយក្នុងវត្ថុនុ៎ះ ។

[ ១០៦ ] ម្នាលចុន្ទ ដូចជាផ្លូវមិនស្មើ មានផ្លូវស្មើដទៃ សម្រាប់ចៀសវាងផ្លូវមិនស្មើនោះ ម្នាលចុន្ទ ពុំនោះសោត ដូចកំពង់មិនស្មើ មានកំពង់ស្មើឯទៀត សម្រាប់ចៀសវាងកំពង់មិនស្មើនោះ មានឧបមាយ៉ាងណា ម្នាលចុន្ទ បុរសបុគ្គលជាអ្នកបៀតបៀន រមែងមានការមិនបៀតបៀន សម្រាប់ចៀសវាងចេញ មានឧបមេយ្យយ៉ាងនោះ ។ បុរសបុគ្គលអ្នកសម្លាប់សត្វ មានចេតនាវៀរចាកការសម្លាប់សត្វសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកកាន់យកទ្រព្យ ដែលគេមិនបានឲ្យ មានចេតនាវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យសម្រាប់ចៀសវាង ។ បុរសបុគ្គល អ្នកប្រព្រឹត្តធម៌មិនប្រសើរ មានការប្រព្រឹត្តធម៌ដ៏ប្រសើរសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកនិយាយពាក្យកុហក មានចេតនាវៀរចាកពាក្យកុហក សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសម្ដីញុះញង់ មានចេតនាវៀរចាកសម្ដីញុះញង់សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសម្ដីទ្រគោះ មានចេតនាវៀរចាកសម្ដីទ្រគោះសម្រាប់ចៀសវាង ។ បុរសបុគ្គល អ្នកពោលពាក្យឥតប្រយោជន៍ មានចេតនាការពោលពាក្យឥតប្រយោជន៍សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានចិត្តរំពៃចង់បានទ្រព្យរបស់គេ មានការមិនរំពៃចង់បានទ្រព្យរបស់គេសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានចិត្តចង់ឲ្យគេវិនាស មានការមិនចង់ឲ្យគេវិនាសសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសេចក្ដីយល់ឃើញខុស មានការយល់ឃើញត្រូវ សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមាន

តម្រិះខុស មានតម្រិះត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសម្ដីខុស មានសម្ដីត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានការងារខុស មានការងារត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលមានការចិញ្ចឹមជីវិតខុស មានការចិញ្ចឹមជីវិតត្រូវ សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសេចក្ដីព្យាយាមខុស មានសេចក្ដីព្យាយាមត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសេចក្ដីរឭកខុស មានសេចក្ដីរឭកត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសមាធិខុស មានសមាធិត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានញាណខុស មានញាណត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានវិមុត្តិខុស មានវិមុត្តិត្រូវសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានថីនមិទ្ធៈគ្របសង្កត់ មានការប្រាសចាកថីនមិទ្ធៈសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានចិត្តរាយមាយ មានចិត្តមិនរាយមាយ សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសេចក្ដីសង្ស័យ មានការកន្លងសេចក្ដីសង្ស័យសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានសេចក្ដីក្រេវក្រោធ មានសេចក្ដីមិនក្រេវក្រោធសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកចងសេចក្ដីក្រោធទុក មានការមិនចងសេចក្ដីក្រោធទុកសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកលុបគុណគេ មានការមិនលុបគុណគេសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកប្រណាំងវាស្នា មានការមិនប្រណាំងវាសនា សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកច្រណែន មានការមិនច្រណែនសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកកំណាញ់ មានសេចក្ដីមិនកំណាញ់សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នក

អួតអាង មានការមិនអួតអាងសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកលាក់ពុត មានការមិនលាក់ពុតសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នករឹងត្អឹង មានសេចក្តីមិនរឹងត្អឹងសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមើលងាយគេ មានសេចក្តីមិនមើលងាយគេ សម្រាប់ចៀសវាង ។ បុរសបុគ្គលដែលគេប្រដៅបានដោយក្រ មានការប្រដៅបានងាយសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានមិត្តអាក្រក់ មានភាវៈជាអ្នកមានមិត្តល្អសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកធ្វេសប្រហែស មានសេចក្តីមិនធ្វេសប្រហែសសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមិនជឿ មានការជឿសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមិនខ្មាសបាប មានសេចក្តីខ្មាសបាបសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមិនខ្លាចបាប មានសេចក្តីខ្លាចបាបសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នករៀនសូត្រតិច មានការរៀនសូត្រច្រើនសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកខ្ជិលច្រអូស មានការប្រារព្ធព្យាយាមសម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកមានស្មារតីភ្លេចភ្លាំង មានភាវៈជាអ្នកមានស្មារតីតម្កល់ខ្ជាប់សម្រាប់ចៀសវាង ។ បុរសបុគ្គលអ្នកអាប់ឥតប្រាជ្ញា មានការបរិបូណ៌ដោយប្រាជ្ញាសម្រាប់ចៀសវាង ។ បុរសបុគ្គលជាអ្នកមានសេចក្តីប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ប្រកាន់មាំ នឹងជាអ្នកដែលគេឲ្យលះបង់ទិដ្ឋិបានដោយក្រ មានភាវៈជាអ្នកមិនបានប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន មិនបានប្រកាន់មាំ នឹងជាអ្នកដែលគេឲ្យលះបង់ទិដ្ឋិបានដោយងាយ សម្រាប់ចៀសវាង ។

[ ១០៧ ] ម្នាលចុន្ទ ធម៌ទាំងឡាយណានីមួយជាអកុសល ធម៌ទាំងអស់

នោះ តែងញុំាងសត្វឲ្យធ្លាក់ទៅកាន់ទីទាប ធម៌ទាំងឡាយណានីមួយជាកុសល ធម៌ទាំងអស់នោះ តែងញុំាងសត្វឲ្យឡើងទៅទីខ្ពស់ មានឧបមាយ៉ាងណា ម្នាលចុន្ទ បុរសបុគ្គលអ្នកបៀតបៀន មានការមិនបៀតបៀនសម្រាប់ញុំាងខ្លួនឲ្យបានខ្ពស់ ក៏មានឧបមេយ្យយ៉ាងនោះ បុរសបុគ្គលអ្នកសម្លាប់សត្វ មានកិច្ចវៀរចាកការសម្លាប់សត្វ សម្រាប់ញុំាងខ្លួនឲ្យបានខ្ពស់ ។ បុរសបុគ្គលអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យ ។បេ។ បុរសបុគ្គលអ្នកប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ប្រកាន់មាំ នឹងជាអ្នកដែលគេឲ្យលះបង់ទិដ្ឋិដោយក្រ មានការមិនប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន មិនបានប្រកាន់មាំ នឹងជាអ្នកដែលគេឲ្យលះបង់ទិដ្ឋិបានដោយងាយ សម្រាប់ញុំាងខ្លួនឲ្យបានខ្ពស់ ។

[ ១០៨ ] ម្នាលចុន្ទ បុគ្គលណាមុជចុះក្នុងភក់ គឺកាមគុណដោយខ្លួនឯងហើយ បុគ្គលនោះឯង នឹងជួយស្រង់បុគ្គលដទៃដែលមុជចុះក្នុងភក់ គឺកាមគុណដូចគ្នា ហេតុដូច្នេះនេះ មិនដែលមានទេ ។ ម្នាលចុន្ទ លុះតែបុគ្គលណា មិនមុជចុះក្នុងភក់ គឺកាមគុណដោយខ្លួនឯងទេ បុគ្គលនោះឯង ទើបជួយស្រង់បុគ្គលដទៃដែលមុជចុះក្នុងភក់ គឺកាមគុណ ហេតុដូច្នេះនេះ ទើបមាន ។ ម្នាលចុន្ទ បុគ្គលណាមិនទាន់បានប្រដៅចិត្ត មិនទាន់បានទូន្មានចិត្ត មិនទាន់រំលត់កិលេសដោយខ្លួនឯង បុគ្គលនោះឯង នឹងប្រដៅ នឹងទូន្មាន នឹងញុំាងបុគ្គលដទៃឲ្យរំលត់កិលេស ហេតុដូច្នេះនេះ មិនដែលមានទេ ។ ម្នាលចុន្ទ បុគ្គលណាបានប្រដៅ បានទូន្មាន បានរំលត់កិលេសដោយខ្លួនឯង បុគ្គល

នោះឯង ទឹងប្រជៅ ទឹងទូន្មាន ទឹងញ៉ាំងបុគ្គលដទៃឲ្យរំលត់កិលេស ហេតុដូច្នេះនេះ ទើបមាន ។ ម្នាលចុន្ទ ដូចយ៉ាងបុរសបុគ្គលអ្នកបៀតបៀន មានការមិនបៀតបៀនសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកសម្លាប់សត្វ មានចេតនាវៀរចាកការសម្លាប់សត្វសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យ មានចេតនាវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកប្រព្រឹត្តធម៌មិនប្រសើរ មានការប្រព្រឹត្តធម៌ដ៏ប្រសើរសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកនិយាយពាក្យកុហក មានចេតនាវៀរចាកពាក្យកុហកសម្រាប់រំលត់។ បុរសបុគ្គលអ្នកមានសម្តីញុះញង់ មានចេតនាវៀរចាកសម្តីញុះញង់ សម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានសម្តីទ្រគោះ មានចេតនាវៀរចាកសម្តីទ្រគោះសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកនិយាយពាក្យឥតប្រយោជន៍ មានចេតនាវៀរចាកការនិយាយពាក្យឥតប្រ-យោជន៍សម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានចិត្តរំពៃចង់បានទ្រព្យរបស់គេ មានចិត្តមិនរំពៃចង់បានទ្រព្យរបស់គេសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានចិត្តចង់ឲ្យគេវិនាស មានការមិនចង់ឲ្យគេវិនាសសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកយល់ខុស មានសេចក្តីយល់ត្រូវសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានតម្រិះខុស មានតម្រិះត្រូវសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានសម្តីខុស មានសម្តីត្រូវសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានការងារខុស មានការងារត្រូវសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកចិញ្ចឹមជីវិតខុស មានការចិញ្ចឹមជីវិតត្រូវសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានសេចក្តីព្យាយាមខុស

មានសេចក្តីព្យាយាមត្រូវសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានសេចក្តីរឭកខុស មានសេចក្តីរឭកត្រូវសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានសមាធិខុស មានសមាធិត្រូវសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានញាណខុស មានញាណត្រូវ សម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានវិមុត្តិខុស មានវិមុត្តិត្រូវសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានថីនមិទ្ធៈគ្របសង្កត់ មានការប្រាសចាកថីនមិទ្ធៈសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានចិត្តរាយមាយ មានការមិនមានចិត្តរាយមាយសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានសេចក្តីសង្ស័យ មានការកន្លងសេចក្តីសង្ស័យសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានសេចក្តីក្រេវក្រោធ មានសេចក្តីមិនក្រេវក្រោធសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកចងសេចក្តីក្រោធទុក មានការមិនចងសេចក្តីក្រោធទុកសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកលុបគុណគេ មានការមិនលុបគុណគេសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកប្រណាំងវាសនា មានការមិនប្រណាំងវាសនាសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកច្រណែន មានការមិនច្រណែនសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកកំណាញ់ មានសេចក្តីមិនកំណាញ់សម្រាប់រំលត់ ។ បុរសបុគ្គលអ្នកអួតអាង មានការមិនអួតអាងសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកលាក់ពុត មានការមិនលាក់ពុតសម្រាប់រំលត់ ។ បុរសបុគ្គលអ្នករឹងត្អឹង មានសេចក្តីមិនរឹងត្អឹងសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមើលងាយគេ មានសេចក្តីមិនមើលងាយគេ សម្រាប់រំលត់ ។ បុរសបុគ្គលដែលគេប្រដៅបានដោយក្រ មានការប្រដៅបានដោយងាយសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមានមិត្រអាក្រក់ មានមិត្រ

លួសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកធ្វេសប្រហែស មានសេចក្តីមិនធ្វេសប្រហែសសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមិនជឿ មានការជឿសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមិនខ្មាសបាប មានសេចក្តីខ្មាសបាបសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកមិនខ្លាចបាប មានសេចក្តីខ្លាចបាបសម្រាប់រំលត់ ។ បុរសបុគ្គលអ្នករៀនសូត្រតិច មានការរៀនសូត្រច្រើនសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកខ្ជិលច្រអូស មានការប្រារព្ធព្យាយាមសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកស្មារតីភ្លេចភ្លាំង មានស្មារតីតម្កល់ខ្ជាប់សម្រាប់រំលត់ ។ បុរសបុគ្គលអាប់ឥតប្រាជ្ញា មានការបរិបូណ៌ដោយប្រាជ្ញាសម្រាប់រំលត់ ។ បុរសបុគ្គលអ្នកប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ប្រកាន់មាំ និងមានលទ្ធិដែលគេឲ្យលះបង់បានដោយក្រ មានសេចក្តីមិនប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន មិនបានប្រកាន់មាំ និងមានលទ្ធិដែលគេឲ្យលះបង់បានដោយងាយសម្រាប់រំលត់ ។

[ ១០៩ ] ម្នាលចុន្ទ តថាគតបានសម្តែងនូវហេតុនៃសេចក្តីជូរផង់ហើយ បានសម្តែងនូវហេតុនៃការកើតឡើងនៃចិត្តហើយ បានសម្តែងនូវហេតុនៃការចៀសវាង ( នូវបាបធម៌មានការបៀតបៀនជាដើម ) ហើយ បានសម្តែងនូវហេតុនៃការកើតក្នុងជាន់ខ្ពស់ហើយ បានសម្តែងនូវហេតុជាគ្រឿងរំលត់ហើយ ដោយប្រការដូច្នោះឯង ។ ម្នាលចុន្ទ កិច្ចណាដែលសាស្តា ជាអ្នកស្វែងរកនូវប្រយោជន៍ ជាអ្នកអនុគ្រោះ គប្បីធ្វើដល់សាវកទាំងឡាយ កិច្ចនោះតថាគតអាស្រ័យសេចក្តីអនុគ្រោះ បានធ្វើហើយដល់អ្នកទាំងឡាយ ។ ម្នាល

ចុន្ទ ពួកអ្នកចូរពិចារណានូវរុក្ខមូលសេនាសនៈ នឹងផ្ទះស្ងាត់ទុំះចុះ ម្នាលចុន្ទ ពួកអ្នកកុំប្រមាទឡើយ កុំជាបុគ្គលមានសេចក្តីក្តៅក្រហាយ ស្តាយក្រោយឡើយ ។ នេះជាពាក្យប្រៀនប្រដៅរបស់យើង ដល់អ្នកទាំងឡាយ ។ លុះព្រះមានជោគ បានទ្រង់សម្តែងព្រះសូត្រនេះចប់ហើយ ព្រះមហាចុន្ទដ៏មានអាយុក៏មានចិត្តត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

បទ[១] ៤៤ ព្រះមានព្រះភាគ បានត្រាស់សម្តែងហើយ
សន្ធិ[២] ៥ ព្រះមានព្រះភាគ ក៏បានសម្តែងហើយ សូត្រ
( នេះ ) ឈ្មោះសល្លេខៈ ព្រោះមានសេចក្តីជ្រាលជ្រៅ
ឧបមាដូចសាគរ ។

## សល្លេខសូត្រទី ៨ ចប់

---

១- បានដល់ ពួកធម៌ មានអាការ ៤៤ គឺមានការមិនបៀតបៀនជាដើម មានភាពជាអ្នកលះបង់ទិដ្ឋិបានដោយងាយជាទីបំផុត ។ ២- បានដល់ ហេតុជាតំណនៃធម៌ ៥ យ៉ាង គឺសេចក្តីផូរផង់ ១ ការកើតឡើងនៃចិត្ត ១ ការចៀសវាង ១ ការកើតក្នុងជាន់ខ្ពស់ ១ ការរំលត់កិលេស ១ ។

# អដ្ឋកថា

## សល្លេខសូត្រ

[ ១០០ ] *សល្លេខសូត្រមានពាក្យផ្តើមថា* **ឯវម្មេ សុតំ** *ខ្ញុំអានន្ទ បាន ស្តាប់មកហើយយ៉ាងនេះ ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **មហាចុន្ទ** *ជាឈ្មោះរបស់ព្រះថេរៈអង្គ នោះ ។ បទថា* **សាយណ្ហសមយំ** *ប្រែថា ក្នុងសាយណ្ហសម័យ គឺក្នុង វេលាល្ងាច ។*

*ទីកំបាំង គឺទីពួនអំពីសត្វ និងសង្ខារទាំងឡាយនោះៗ ឈ្មោះថា ទីពួន ក្នុងបទថា* **បដិសល្លានា វុដ្ឋិតោ** *ប្រែថា ចេញអំពីទីពួនសម្ងំនេះ មានពាក្យ អធិប្បាយទុកថា បានដល់ ភាពឯកោ គឺការស្ងាត់ ។ បុគ្គលដែលចេញអំពី ទីនោះ ឈ្មោះថា ជាអ្នកចេញអំពីទីពួនសម្ងំ ។ តែព្រះចុន្ទត្ថេរ ព្រោះចេញ អំពីផលសមាបត្តិ ដែលខ្ពង់ខ្ពស់ជាងការពួនសម្ងំធម្មតា ព្រោះដូច្នោះ ទើប ព្រះអានន្ទបានពោលថា ចេញអំពីទីពួនសម្ងំហើយ ។*

*បទថា* **ភគវន្តំ អភិវាទេត្វា** *ប្រែថា កាលថ្វាយបង្គំព្រះមានព្រះភាគ ហើយ សេចក្តីថា កាលថ្វាយបង្គំព្រះមានព្រះភាគដោយគោរពដោយសិរសា គឺត្បូង ប្រកបជាមួយការផ្គងឡើងនូវម្រាមទាំង ១០ ប្រណម្យហើយ ឬ កាលថ្វាយបង្គំព្រះមានព្រះភាគហើយ ព្រះអង្គទ្រង់បន្ទឺព្រះតម្រាស់យ៉ាងនេះថា ម្នាលចុន្ទ ចូរនៅជាសុខចុះ ។*

## ពុទ្ធនិយាម

*បានឮថា ព្រះមានព្រះភាគ កាលមានអ្នកថ្វាយបង្គំ ទ្រង់បង្ហើបព្រះសូរង*

ដែលដូចគ្នានឹងស្គរមាសឡើងហើយ ទ្រង់បន្លឺព្រះសូរសៀង ដូចសំឡេងព្រហ្មដែលពីរោះត្រចៀក ជាទីជាប់ចិត្ត ដូចគ្នានឹងស្រោចស្រពដោយទឹកអម្រឹត ត្រាស់ប្រាប់ពួកឈ្មោះបុគ្គលនោះៗ ថា ចូរជាសុខចុះ ដូច្នេះ នេះជាទំនៀមរបស់ព្រះពុទ្ធទាំងឡាយ ។

ក្នុងរឿងនោះ មានព្រះសូត្រដែលមកជាទីអាងបានដូចតទៅនេះ គឺសក្កបញ្ហសូត្រថា កាលបញ្ចសិខទេវបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សក្កទេវរាជជាធំជាងពួកទេវតា ព្រមទាំងអមាត្យ ព្រមទាំងបរិសទ្យ សូមក្រាបថ្វាយបង្គំនូវព្រះបាទទាំងគូ របស់ព្រះមានព្រះភាគដោយត្បូង ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលបញ្ចសិខ: សូមឲ្យសក្កទេវរាជ ជាធំជាងពួកទេវតា ព្រមទាំងអមាត្យ ព្រមទាំងបរិសទ្យ បានសេចក្តីសុខ តាមសេចក្តីប្រាថ្នាចុះ ព្រោះពួកទេវតា និងមនុស្ស អសុរ នាគ គន្ធព្វ និងសត្វដទៃៗ ជាច្រើនពួក តែងប្រាថ្នាសេចក្តីសុខ ដូច្នេះ កាលបើយ៉ាងនេះ ព្រះតថាគតទាំងឡាយ ទ្រង់ថ្វាយព្រះពរទេវតា ដែលមានសភាពបែបនោះ ដែលជាអ្នកមានសក្តិធំ គួរបូជាដូចពោលមកហើយ ។

បទថា **យា ឥមា** សេចក្តីថា ព្រះពុទ្ធបានពោលដល់ទិដ្ឋិដែលត្រូវពោលដល់ក្នុងឥឡូវនេះ ដូចធ្វើឲ្យនៅចំពោះមុខ ។

បទថា **អនេកវិហិតា** ប្រែថា មានច្រើនយ៉ាង បានដល់ មានច្រើនប្រការ ។ បទថា **ទិដ្ឋិយោ** ប្រែថា ទិដ្ឋិទាំងឡាយ បានដល់ មិច្ឆាទិដ្ឋិ ។

បទថា **លោកេ ឧប្បជ្ជន្តិ** ប្រែថា កើតឡើងក្នុងលោក សេចក្តីថា

ប្រាកដក្នុងពពួកសត្វលោក ។

បទថា **អត្តវាទប្បដិសំយុត្តា** ប្រែថា ប្រកបដោយអត្តវាទ សេចក្តីថា មិច្ឆាទិដ្ឋិទាំងនេះ ដែលប្រកបដោយអត្តវាទប្រព្រឹត្តទៅហើយ ដោយន័យជាដើមថា រមែងតាមឃើញរូប ដោយភាពជាអត្តា មាន ២០ យ៉ាង ។

បទថា **លោកវាទបដិសំយុត្តា** ប្រែថា ប្រកបដោយលោកវាទ និយាយ ប្រារព្ធលោក សេចក្តីថា ប្រព្រឹត្តទៅហើយដោយន័យជាដើមថា អត្តា និងលោកទៀង ។

## មិច្ឆាទិដ្ឋិ ៨ យ៉ាង

មិច្ឆាទិដ្ឋិប្រារព្ធអត្តា និងលោកនោះ មាន ៨ ប្រការ ប្រព្រឹត្តទៅហើយ យ៉ាងនេះថា អត្តា និងលោកទៀង ១ អត្តា និងលោកមិនទៀង ១ អត្តា និងលោកទៀងខ្លះ មិនទៀងខ្លះ ១ អត្តា និងលោកទៀងក៏មិនមែន មិនទៀងក៏មិនមែន ១ អត្តា និងលោកមានទីបំផុត ១ អត្តា និងលោកមិនមានទីបំផុត ១ អត្តា និងលោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ១ អត្តា និងលោកមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ១ ។

ក្នុងពាក្យជាដើមថា **អាទិមេវ** ប្រែថា ជាដើមនេះប៉ុណ្ណោះ មានអធិប្បាយយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុមនសិការធម៌ខាងដើមតែម្យ៉ាង គឺសូម្បីមិនសម្រេចសោតាបត្តិមគ្គ មនសិការចំពោះធម៌ខាងដើមប៉ុណ្ណោះ ដែលលាយដោយវិបស្សនា មានការលះ និងការលោសបោលនូវទិដ្ឋិទាំងនេះយ៉ាងនេះ គឺទិដ្ឋិទាំងនេះ ដោយឧបាយប៉ុណ្ណោះប៉ុណ្ណោះ បានដូចម្តេច ព្រះ

ថេរៈ សូម្បីខ្លួនលោកមិនមានមានះក្រៃលែង តែក៏គប្បីជ្រាបថា ហាក់ដូចជាមានះក្រៃលែង សួរបញ្ហានេះដើម្បីមានះក្រៃលែង សម្រាប់ភិក្ខុទាំងឡាយដែលមានមានះក្រៃលែង ។

ចំណែកអាចារ្យពួកដទៃពោលថា អន្តេវាសិកទាំងឡាយរបស់ព្រះថេរៈមានការយល់យ៉ាងនេះថា ការលះទិដ្ឋិទាំងឡាយបានជាសមុច្ឆេទ មានដោយមនសិការធម៌ខាងដើមប៉ុណ្ណោះក៏មាន ដែលមានការយល់ថា មាន ព្រោះមានសមាបត្តិជាវិហារធម៌ គឺមានធម៌ជាគ្រឿងជុសខាត់ជាវិហារធម៌ក៏មាន លោកទូលសួរព្រះមានព្រះភាគដើម្បីប្រយោជន៍ដល់អន្តេវាសិកទាំងនោះ ។

[ ១០១ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងឧបាយសម្រាប់លះទិដ្ឋិទាំងនោះដល់លោក ទើបបានត្រាស់ពាក្យថា **យា ឥមា** ដូច្នេះជាដើមណា ក្នុងពាក្យទាំងនោះមានសេចក្តីពិស្តារថា មានពាក្យថា **យត្ថ ចេតា ទិដ្ឋិយោ ឧប្បជ្ជន្តិ** ប្រែថា ទិដ្ឋិទាំងនោះកើតឡើងក្នុងទីណា ដូច្នេះជាដើម ព្រះអង្គត្រាស់សំដៅយកបញ្ចក្ខន្ធ អធិប្បាយថា ទិដ្ឋិទាំងនោះកើតឡើងក្នុងបញ្ចក្ខន្ធទាំងនោះ ដូចដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលរូបមាន ព្រោះប្រកាន់មាំនូវរូប ទិដ្ឋិកើតឡើងយ៉ាងនេះថា អញ គឺអត្តា និងលោក លះលោកនេះទៅហើយ ក៏គង់មាន ព្រោះថា អត្តានោះ លោកនោះជារបស់ទៀង ស្ថិតស្ថេរ ជាប់តគ្នាទៅ មានការមិនប្រែប្រួលទៅជាធម្មតា ។ តែព្រះអង្គត្រាស់ជាឯកវចនៈថា **យត្ថ ច** ប្រែថា ក្នុងអារម្មណ៍ណា ដោយអំណាចនៃអារម្មណ៍ មានអធិប្បាយថា ទិដ្ឋិទាំងឡាយកើតឡើងក្នុងអារម្មណ៍

ណា ។ មួយវិញទៀត ក្នុងពាក្យថា **យត្ថ** ជាដើមនេះ គួរជ្រាបដល់ទិដ្ឋិទាំងនេះ ធ្វើកិច្ចផ្សេងៗ គ្នាយ៉ាងនេះ គឺកើតឡើង ១ នៅដេកត្រាំ ១ ផ្សាយឡើង ១ អធិប្បាយថា ទិដ្ឋិទាំងនេះមានការធ្វើកិច្ចផ្សេងគ្នា ដូច្នេះ គឺទិដ្ឋិទាំងឡាយដោយជាតិរបស់វា ដែលមិនទាន់កើតឡើង ។

កាលកើតឡើង ទ្រង់ត្រាស់ហៅថា កំពុងកើតឡើង ដែលសេពរហូតថ្មីករឿយៗ មានកម្លាំង កម្ចាត់មិនទាន់បាន ទ្រង់ត្រាស់ហៅថា ដេកត្រាំ ចំណែកដែលជួប គឺកន្លងចេញមកតាមកាយទ្វារ និងវចីទ្វារ ទ្រង់ត្រាស់ហៅថា ផ្សាយឡើង ។

ក្នុងពាក្យទាំងឡាយ មានពាក្យថា **នេតំ មម** ប្រែថា វត្ថុនេះមិនមែនរបស់អញជាដើម គួរជ្រាបអធិប្បាយរបស់បទទាំងនេះមុនថា អារម្មណ៍ដែលចែកប្រភេទជាបញ្ចក្ខន្ធនេះ មិនមែនរបស់អញ សូម្បីអញក៏មិនមែនរបស់នុ៎ះ សូម្បីរបស់នុ៎ះក៏មិនមែនអត្តារបស់អញ ភិក្ខុឃើញបញ្ចក្ខន្ធនោះតាមសេចក្តីពិតដោយបញ្ញាដ៏ប្រពៃយ៉ាងនេះ មានការលះបង់នូវទិដ្ឋិនោះបាន ។

តែព្រោះក្នុងការប្រកាន់ ៣ យ៉ាងនេះ កាលប្រកាន់ ប្រកាន់ដោយអំណាចតណ្ហាថា នុ៎ះរបស់អញ ក៏ឈ្មោះថា ប្រកាន់ដោយតណ្ហាជាគ្រឿងយឺតយូរ ញែកប្រភេទចេញជាតណ្ហាវិចរិត ១០៨ ប្រការ កាលប្រកាន់ប្រកាន់ដោយអំណាចមានះថា នុ៎ះជាអញ ឈ្មោះថា ប្រកាន់មានះដែលជាគ្រឿងយឺតយូរ ចែកជាប្រភេទ ៩ ប្រការ និងកាលប្រកាន់ ដោយការប្រកាន់ ដោយអំណាចទិដ្ឋិថា នុ៎ះមិនមែនអត្តារបស់អញ ឈ្មោះថា ប្រកាន់

ទិដ្ឋិជាគ្រឿងយឺតយូរ ចែកចេញជា ៦២ ប្រការ ព្រោះដូច្នោះ ព្រះមានព្រះភាគកាលត្រាស់ថា នុ៎ះមិនមែនរបស់អញ ក៏ឈ្មោះថា ទ្រង់បដិសេធគ្រឿងយឺតយូរ ចែកប្រភេទតាមដែលពោលហើយ កាលត្រាស់ថា នុ៎ះមិនមែនអញ ក៏ឈ្មោះថា ទ្រង់បដិសេធមានះ ជាគ្រឿងយឺតយូរ កាលត្រាស់ថា នុ៎ះមិនមែនអត្តារបស់អញ ក៏ឈ្មោះថា ទ្រង់បដិសេធទិដ្ឋិជាគ្រឿងយឺតយូរ ។ ម្យ៉ាងទៀត ក្នុងរឿងតណ្ហា មានះ ទិដ្ឋិ ទាំង ៣ យ៉ាងនេះ តណ្ហា និងមានះ គប្បីជ្រាបថា តាំងនៅក្នុងពួកជាមួយគ្នានឹងទិដ្ឋិនោះឯង ។

បទថា **ឯវមេតំ** ប្រែថា ឃើញវត្ថុនោះយ៉ាងនេះ គឺឃើញបញ្ចក្ខន្ធនោះដោយអាការជាដើមថា នុ៎ះមិនមែនរបស់អញយ៉ាងនេះ ។

បទថា **យថាភូតំ** ប្រែថា តាមសេចក្តីពិត គឺតាមសភាវៈ មានពាក្យអធិប្បាយថា តាមដែលមាន អធិប្បាយថា សេចក្តីពិត ខន្ធបញ្ចកៈ មានដោយអាការយ៉ាងនោះឯង តែខន្ធបញ្ចកៈដែលប្រកាន់ដោយន័យជាដើមថា របស់អញ រមែងមិនមាន ដោយអាការយ៉ាងនោះឯង ។

បទថា **សម្មប្បញ្ញាយ** ប្រែថា ឃើញដោយបញ្ញាដ៏ប្រពៃ សេចក្តីថា ឃើញដោយល្អ ដោយវិបស្សនាបញ្ញា មានសោតាបត្តិមគ្គប្បញ្ញាជាបរិយោសាន ។

បទថា **ឯវមេតាសំ** ប្រែថា លះទិដ្ឋិទាំងនេះយ៉ាងនេះ បានដល់ លះទិដ្ឋិទាំងនេះដោយឧបាយនេះ ។ ពាក្យថា ការលះការលះបង់ចោលទាំងពួងនេះ ជាឈ្មោះនៃការលះកិលេសបានដោយសមុច្ឆេទនោះឯង ។

[ ១០២ ] ព្រះមានព្រះភាគ ដែលព្រះមហាចុន្ទត្ថេរសួរបញ្ហា ដោយអំណាចនៃបុគ្គលដែលមានមានះក្រៃលែងថា ការលះទិដ្ឋិទាំងឡាយ មានដោយមនសិការធម៌ខាងដើមប៉ុណ្ណោះ ឬមិនមានហ្ន៎ ។ កាលទ្រង់សម្តែងការលះទិដ្ឋិដោយសោតាបត្តិមគ្គហើយ ឥឡូវនេះ កាលទ្រង់ចែកឈាននៃបុគ្គលមានមានះក្រៃលែងដោយព្រះអង្គឯង ទើបបានត្រាស់ពាក្យថា ហេតុជាទីតាំងដូច្នេះជាដើម ។ បុគ្គលមានមានះក្រៃលែង កើតឡើងដោយសម្គាល់ថា បានសម្រេចហើយ ក្នុងធម៌ដែលខ្លួនមិនបានសម្រេច ឈ្មោះថា បុគ្គលមានមានះក្រៃលែង ក្នុងពាក្យថា **អធិមានិកានំ** នោះ ។ តែអធិមានះ ( មានះក្រៃលែង ) នេះ កាលកើតឡើង មិនកើតឡើងដល់ពាលបុថុជ្ជនដែលរវូកដល់លោកានុវត្តរឿយៗ ឡើយ និងមិនកើតឡើងដល់អរិយសាវកទាំងឡាយ អធិប្បាយថា អធិមានះថា អញជាព្រះសកទាគាមី ក៏មិនកើតដល់ព្រះសោតាបន្ន អធិមានះថា អញជាព្រះអនាគាមី នឹងមិនកើតឡើងដល់ព្រះសកទាគាមី អធិមានះថា អញជាព្រះអរហន្ត មិនកើតឡើងដល់ព្រះអនាគាមី តែកើតចំពោះការកបុគ្គលប៉ុណ្ណោះ បុគ្គលសង្កត់កិលេសបានដោយអំណាចសមថៈ ឬដោយអំណាចវិបស្សនា បុគ្គលប្រារព្ធវិបស្សនា ហើយព្យាយាមប្រឹងប្រែងជានិច្ច ។ សេចក្តីពិត ការកបុគ្គលនោះ កាលមិនឃើញការផ្សាយឡើងនៃកិលេសដែលសង្កត់ទុកដោយសមថៈ ឬដែលសង្កត់ទុកបានដោយវិបស្សនា អធិមានះថា អញជាព្រះសោតាបន្នខ្លះ អញជាព្រះសកទាគាមីខ្លះ អញជាព្រះអនាគាមីខ្លះ អញជាព្រះអរហន្តខ្លះ នឹងកើតឡើងដូចគ្នានឹងព្រះ

ថេរៈទាំងឡាយ ដែលព្រះធម្មទិន្នត្ថេរអាស្រ័យនៅត្រង់ តលង្គរតិស្សបព៌ត បានដាស់តឿនហើយ ។

## រឿង ព្រះធម្មទិន្នត្ថេរ

បានឮថា ភិក្ខុច្រើនរូបបានតាំងខ្លួននៅក្នុងឱវាទរបស់ព្រះថេរៈ ដែលឧបសម្បទាហើយ មិនយូរឡើយ ក៏នាំគ្នាសម្រេចគុណវិសេស ភិក្ខុសង្ឃអ្នកស្រុកតិស្សមហាវិហារបានជ្រាបព្រឹត្តិកម្មនោះហើយ ដាក់ការយល់ឃើញថា ព្រះថេរៈប្រកបក្នុងរឿងដែលប្រព្រឹត្តទៅមិនបាន លោកទាំងឡាយ ចូរនាំព្រះថេរៈមក ហើយបានបញ្ជូនភិក្ខុច្រើនរូបទៅ ។ ភិក្ខុទាំងនោះ ទៅដល់ហើយបានប្រាប់ថា បពិត្រលោកម្ចាស់ធម្មទិន្ន ភិក្ខុសង្ឃហៅរកលោកម្ចាស់ ។ លោកពោលថា លោកទាំងឡាយគួរស្វែងរកខ្លួន ឬអ្នកដទៃ ។ ភិក្ខុទាំង-ឡាយប្រាប់ថា បពិត្រលោកសប្បុរស យើងទាំងឡាយស្វែងរកខ្លួន ។ ព្រះថេរៈនោះបានឲ្យកម្មដ្ឋានដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះបានសម្រេចអរហត្តទាំងអស់គ្រប់រូប ។ ទើបភិក្ខុសង្ឃបញ្ជូនភិក្ខុពួកដទៃទៅទៀត ភិក្ខុដែលសង្ឃបញ្ជូនទៅយ៉ាងនេះអស់វារៈ ៣ ដង ក៏បានសម្រេចអរហត្តដូចគ្នាទាំងអស់ហើយនៅជាមួយព្រះថេរៈនោះ ។ បន្ទាប់អំពីនោះមក ភិក្ខុសង្ឃឃើញថា ភិក្ខុដែលទៅហើយ មិនត្រឡប់មក ទើបបញ្ជូនភិក្ខុដែលជាថេរៈចាស់មួយរូបទៅទៀត ព្រះថេរៈចាស់នោះកាលទៅដល់ហើយ បានពោលថា បពិត្រលោកម្ចាស់ធម្មទិន្ន ភិក្ខុសង្ឃសម្នាក់តិស្សមហាវិហារបញ្ជូនភិក្ខុមកឯសម្នាក់របស់លោកម្ចាស់ អស់វារៈ ៣ ដង តែលោកម្ចាស់មិនធ្វើការគោរពអាណត្តិសង្ឃ

មិនមកតាមពាក្យសង្ឃ ។ ព្រះថេរៈឆ្លើយថា សេចក្តីនេះដូចម្តេច ហើយឲ្យព្រះថេរៈចាស់នោះទទួលយកបាត្រ និងចីវរ ដោយមិនចាំបាច់ចូលបណ្ណ-សាលា ហើយចេញទៅមួយរំពេចនោះឯង ។ លោកបានគេចចេញទៅកាន់ហត្ថិនវិហារ ក្នុងចន្លោះផ្លូវ ។ ក្នុងហត្ថិនវិហារនោះ មានមហាថេរៈមួយរូបមានវស្សា ៦០ កន្លងហើយ ប្តេជ្ញាខ្លួនជាព្រះអរហន្ត ដោយមានះដ៏ក្រៃលែង ព្រះថេរៈចូលទៅរកលោក ថ្វាយបង្គំ ធ្វើបដិសណ្ឋារៈ ហើយបានសាកសួរដល់គុណធម៌ដែលបានសម្រេច ។ ព្រះថេរៈពោលថា អើ ធម្មទិន្ន កិច្ចដែលបព្វជិតគប្បីធ្វើ ខ្ញុំបានធ្វើស្រេចយូរហើយ ឥឡូវនេះ ខ្ញុំក៏មានវស្សា ៦០ ថ្វាយហើយ ។ ធម្មទិន្នភិក្ខុសាកសួរថា លោកម្ចាស់ញ៉ាំងឫទ្ធិបានខ្លះឬទេ លោកឆ្លើយថា បាន ធម្មទិន្នភិក្ខុប្រាប់ថា សាធុ លោកម្ចាស់ សូមនិម្មិតដំរីកំពុងដើរមកត្រង់ចំពោះមុខចុះ ព្រះថេរៈទទួលនិមន្តន៍ហើយ បាននិម្មិតដំរីធំដែលប្រកបដោយគជលក្ខណៈ ៧ ប្រការ ចុះប្រេងដ៏ក្លាហាន លើកកន្ទុយសិកប្រមោយចូលក្នុងមាត់ ស្ទុះមកចំពោះមុខ ហាក់ដូចជាយកភ្លុកទាំង ២ ចាក់ទម្លុះ លោកឃើញដំរីនិម្មិតនោះដែលខ្លួននិម្មិតឯង ខ្លាច ផ្តើមនឹងគេចទៅក្នុងវេលានោះឯង លោកក៏ដឹងខ្លួនថា អាត្មាអញ មិនទាន់បានជាព្រះអរហន្តទើបអង្គុយប្រណាំងទៀបបាទមូលរបស់ព្រះធម្មទិន្ន ហើយពោលថា សូមលោកម្ចាស់ ជាទីពឹងរបស់ខ្ញុំចុះ ព្រះធម្មទិន្នបាននិយាយលួងចិត្តព្រះថេរៈថា បពិត្រលោកម្ចាស់ លោកម្ចាស់កុំសោយសោក កុំទោមនស្សឡើយ មានះដ៏ក្រៃលែងកើតឡើងចំពោះការកបុគ្គលទាំងឡាយប៉ុណ្ណោះហើយបានឲ្យកម្មដ្ឋាន

ដល់ព្រះថេរៈៗ តាំងនៅក្នុងឱវាទរបស់លោកហើយ បានសម្រេចព្រះអរហត្ត ។

សូម្បីព្រះថេរៈមួយរូបទៀត ដែលនៅត្រង់ចិត្តលតាបព៌តក៏ដូចគ្នា ។ ព្រះធម្មទិន្នចូលទៅរក ហើយសួរយ៉ាងនោះដូចគ្នា ។ ទាំងលោកក៏បានព្យាករយ៉ាងនោះដូចគ្នា ។ បន្ទាប់អំពីនោះ ព្រះធម្មទិន្នក៏បានពោលនឹងលោកថា លោកម្ចាស់សម្តែងឫទ្ធិបានខ្លះឬទេ ព្រះថេរៈទទួលពាក្យថា បាន ។ ព្រះធម្មទិន្នប្រាប់លោកថា បពិត្រលោកម្ចាស់ ល្អហើយ សូមលោកម្ចាស់និម្មិតស្រះបោក្ខរណីមួយចុះ ព្រះថេរៈបាននិម្មិតតាមសំណូមពរ ព្រះធម្មទិន្នប្រាប់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់និម្មិតឡើងនូវគុម្ពឈូកក្នុងស្រះនេះផងចុះ ។ ព្រះថេរៈបាននិម្មិតគុម្ពឈូកឡើង ។ ព្រះធម្មទិន្នសំណូមពរថា សូមលោកម្ចាស់និម្មិតសរីរៈស្ត្រីម្នាក់ឈរច្រៀងរាំ ដោយសំឡេងដ៏ពីរោះនៅលើផ្កាឈូកនោះចុះ ។ ព្រះថេរៈក៏និម្មិតស្រីនោះ ។ ទើបព្រះធម្មទិន្នប្រាប់ថា សូមលោកម្ចាស់សម្លឹងពិនិត្យស្រីនោះរឿយៗ ហើយលោកក៏ចូលប្រាសាទទៅ កាលព្រះថេរៈសម្លឹងស្រីដែលនិម្មិតឡើងនោះ កិលេសដែលសង្កត់ទុកអស់កាល ៦០ ឆ្នាំ ក៏កម្រើកឡើងក្នុងកាលនោះ លោកដឹងខ្លួន ទើបសូមរៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះធម្មទិន្ន បានសម្រេចអរហត្តដូចព្រះថេរៈរូបមុន ។

ឯព្រះធម្មទិន្ន ក៏បានទៅកាន់តិស្សមហាវិហារតាមលំដាប់ និងក្នុងវេលានោះ ព្រះថេរៈទាំងឡាយ បោសលានព្រះចេតិយ ហើយអង្គុយចម្រើនកម្មដ្ឋាន ញ៉ាំងបីតិ មានព្រះពុទ្ធជាអារម្មណ៍ឲ្យកើតឡើង ។ បានឮថា ការធ្វើ

យ៉ាងនេះ ជាកិច្ចវត្តរបស់ភិក្ខុទាំងនោះ ។ ព្រោះហេតុនោះ ទើបមិនមានព្រះថេរៈសូម្បីតែមួយរូប ក្នុងបណ្ដាព្រះថេរៈទាំងនោះ និយាយជាមួយនឹងព្រះធម្មទិន្នត្ថេរថា សូមលោកម្ចាស់ដាក់បាត្រ និងចីវរទុកត្រង់នេះ ។ តែដឹងថា នេះជាព្រះធម្មទិន្ន ទើបនាំគ្នាសួរបញ្ហានឹងលោក លោកឆ្លើយដោះប្រស្នាដែលសួរបាន ដូចគ្នានឹងដាវដ៏មុត កាត់ទងឈូកឲ្យដាច់ដោយស្រួល ដូច្នោះហើយ យកម្រាមជើងសង្កត់មហាប្រឹថពី ហើយនិយាយថា បពិត្រលោកដ៏ចម្រើន មហាប្រឹថពីនោះ សូម្បីមិនមានចិត្ត ក៏គង់ដឹងគុណតម្លៃរបស់ធម្មទិន្ន តែលោកទាំងឡាយមិនដឹង ទើបពោលគាថានេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ផែនដីនេះ មិនមានចិត្ត គង់ស្គាល់គុណតូចធំ ចំណែកលោកម្ចាស់ទាំងឡាយមានចិត្ត តែមិនស្គាល់គុណតូចធំ ។

ក្នុងវេលានោះឯង លោកក៏បានហោះឡើងទៅលើអាកាស ទៅកាន់តលង្គតិស្សបព៌តនោះឯង ។

[ ១០៣ ] អធិមានះ រមែងកើតឡើងដល់ការកបុគ្គល ដូចដែលពោលមកហើយនេះប៉ុណ្ណោះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់ចែកឈាន ដោយអំណាចនៃភិក្ខុទាំងឡាយ ដែលមានសភាពដូច្នោះ ទើបត្រាស់ពាក្យថា **ឋានំ ខោ បន** ជាដើម ។

បទថា **ឋានំ ខោ បន** នោះ មានអធិប្បាយថា ហេតុនេះមាន មិនមែនមិនមាន គឺភិក្ខុរបស់ក្នុងសាសនានេះស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលបឋមជ្ឈានដែលជាសាធារណៈដល់បរិព្វាជក ក្រៅសាសនាទាំងឡាយ ។

តែពាក្យណាពោលថា **តស្ស ឯវមស្ស សល្លេខេន វិហរាមិ** ប្រែថា លោកគប្បីមានការយល់យ៉ាងនេះថា អាត្មាអញ នៅដោយសល្លេខធម៌ គឺធម៌ជាគ្រឿងជុសខាត់កិលេស សេចក្ដីថា បដិបទាណា រមែងជុសខាត់កិលេសបាន អាត្មាអញនៅដោយបដិបទានោះ ពាក្យនោះមិនត្រឹមត្រូវ ។ ព្រោះថា ឈានរបស់ភិក្ខុដែលមានមានះក្រៃលែង មិនជាសល្លេខធម៌ ឬសល្លេខបដិបទាឡើយ ។

ព្រោះហេតុអ្វី ព្រោះមិនជាបាទរបស់វិបស្សនា អធិប្បាយថា លោកចូលឈាន កាលចេញចាកឈានហើយ ក៏មិនពិចារណាសង្ខារទាំងឡាយ ។ ឯឈានក៏ធ្វើត្រឹមតែឲ្យចិត្តរបស់លោកជាឯកគ្គតាប៉ុណ្ណោះ ។ លោកក៏ជាអ្នកនៅសប្បាយក្នុងបច្ចុប្បន្ន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងអត្ថនោះ ទើបបានត្រាស់ថា ម្នាលចុន្ទ ឈានធម៌ទាំងនោះ តថាគតមិនហៅថា ជាសល្លេខធម៌ក្នុងវិន័យរបស់ព្រះអរិយៈឡើយ តែឈានធម៌ទាំងនោះ តថាគតហៅថា ទិដ្ឋធម្មសុខវិហារធម៌ ក្នុងអរិយវិន័យ ។

បទថា **ឯតេ** ប្រែថា ទាំងនោះ ក្នុងព្រះពុទ្ធវចនៈនោះ គប្បីជ្រាបថា ជាពហុវចនៈ ដោយអំណាចនៃឈាន មានពាក្យអធិប្បាយថា **ឯតេ** យោគជា **បឋមជ្ឈានធម្មា** ប្រែថា ធម៌ គឺបឋមជ្ឈានទាំងនោះម្យ៉ាងទៀត ជាពហុវចនៈ ដោយអំណាចនៃសមាបត្តិ អធិប្បាយថា បឋមជ្ឈាន សូម្បីឈានមួយ តែប្រព្រឹត្តទៅដោយការចូលរឿយៗ ក៏ដល់នូវភាពជារបស់ច្រើនបាន ។ ម្យ៉ាងទៀត ជាពហុវចនៈ ដោយអំណាចនៃអារម្មណ៍ អធិប្បាយថា បឋមជ្ឈាន

សូម្បីតែមួយក៏ដល់នូវភាពជារបស់ច្រើនបាន ដោយការប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំងឡាយ មានបឋវីកសិណជាដើម ក្នុងទុតិយជ្ឈាន តតិយជ្ឈាន និងចតុត្ថជ្ឈានក៏ន័យនេះ ។

តែក្នុងអរូបជ្ឈានទាំងឡាយ ពាក្យថា ទាំងនោះ គប្បីជ្រាបថា ជាពហុវចនៈ ដោយអំណាចនៃហេតុទាំង ២ ក្នុងឈានមុន ចតុត្ថជ្ឈាននោះឯង ព្រោះមិនមានការផ្សេងគ្នានៃអារម្មណ៍ ។ ព្រោះហេតុនៃអង្គផង អារម្មណ៍ផងរបស់អរូបជ្ឈានទាំងនោះស្ងប់ អធិប្បាយថា រលត់ឥតមានសេសសល់ផង ល្អិតផង ព្រោះដូច្នោះ អង្គក្តី អារម្មណ៍ទាំងនោះក្តី គប្បីជ្រាបថា ទ្រង់ត្រាស់ទុកយ៉ាងនេះថា ឈានធម៌ទាំងនោះ ជាធម៌ស្ងប់ ជាវិហារធម៌ ( សន្តវិហារធម៌ ) ។ នេះជាការពង្រីកទូទៅរបស់អរូបជ្ឈានទាំង ៤ នោះ ។ ឯការពង្រីកសេចក្តីពិសេស គួរពោលតាមទំនងបទជាដើមថា ព្រោះកន្លងរូបសញ្ញាទៅដោយអាការទាំងពួង ។ ការពង្រីកសេចក្តីនោះ បានពោលអធិប្បាយទុកគ្រប់យ៉ាង ក្នុងគម្ពីរវិសុទ្ធិមគ្គហើយ ដូច្នេះ ។

[ ១០៤ ] ព្រោះហេតុដែលវិហារធម៌ គឺឈានរបស់ភិក្ខុដែលមានអធិមានះ មិនជាសល្លេខវិហារធម៌ ព្រោះមិនជាបាទរបស់វិបស្សនា ព្រោះថាលោកចូលឈាន កាលចេញចាកឈានហើយ មិនបានពិចារណាសង្ខារទាំងឡាយឡើយ តែទិដ្ឋធម្មសុខវិហារធម៌របស់លោក ត្រឹមតែធ្វើឲ្យចិត្តជាឯកគ្គតាយ៉ាងនេះ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងអត្ថនោះ ទើបទ្រង់ចែករូបជ្ឈាន និងអរូបជ្ឈានទុកតទៅនេះ កាលទ្រង់សម្តែងរឿងនោះ

និងសល្លេខធម៌នោះ ដោយអាការ ៤៤ យ៉ាង ទើបត្រាស់ពាក្យថា **ឥធ ខោ បន ភោ** ដូច្នេះជាដើម ។

ហេតុអ្វីធម៌ទាំងឡាយ មានអវិហិង្សាជាដើមប៉ុណ្ណោះ ក្រៅពីសមាបត្តិទាំង ៨ យ៉ាង ទើបព្រះមានព្រះភាគត្រាស់ជាសល្លេខធម៌ ។

ព្រោះធម៌ទាំងឡាយ មានអវិហិង្សាជាដើមជាបាទរបស់វិបស្សនា ដែលជាលោកុត្តរបាន ។

ដែលពិតនោះ សមាបត្តិទាំង ៨ របស់បុគ្គលទាំងឡាយខាងក្រៅពុទ្ធសាសនា ជាបាទរបស់វដ្ដៈប៉ុណ្ណោះ ។ តែក្នុងពុទ្ធសាសនា សូម្បីសរណគមន៍ ក៏គប្បីជ្រាបថា ជាបាទរបស់លោកុត្តរធម៌បាន តាមព្រះសូត្រនេះ ដោយចំពោះ នឹងពោលទៅថ្វីដល់ធម៌ទាំងឡាយ មានអវិហិង្សាជាដើមនោះ ។

មយ៉ាងទៀត ទានដែលបុគ្គលឲ្យដល់បុគ្គល ដែលដល់ព្រះរតនត្រ័យជាសរណៈក្នុងពុទ្ធសាសនា មានផលច្រើនជាងទានដែលឲ្យដល់បុគ្គលខាងក្រៅសាសនាដែលបានសមាបត្តិ ៨ សូម្បីមានអភិញ្ញា ៥ ក៏ដោយ ។ ព្រោះថាក្នុងទក្ខិណាវិភង្គសូត្រ ព្រះមានព្រះភាគទ្រង់សំដៅយកសេចក្ដីនេះ ទើបបានត្រាស់ថា ទក្ខិណាមានផលគុណដោយសែនកោដិ ទាយកគប្បីសង្ឃឹមបាន ព្រោះឲ្យទានដល់បុគ្គលក្រៅសាសនា ដែលប្រាសចាកការត្រេកអរក្នុងកាមទាំងឡាយ តែទក្ខិណាមានផលរាប់មិនបាន ប្រមាណមិនកើត ទាយកគប្បីសង្ឃឹមបាន ព្រោះឲ្យទានដល់អ្នកបដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល នឹងពោលទៅថ្វីដល់ព្រះសោតាបន្ន ។

សេចក្ដីពិត បុគ្គលបដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ក្នុងទក្ខិណាវិភង្គសូត្រ ព្រះអង្គទ្រង់បំណងយកតាំងអំពីការដល់សរណៈជាដើមទៅ នេះជាការប្រកបសេចក្ដីតាមព្រះបាលីក្នុងព្រះសូត្រនេះប៉ុណ្ណេះ ។

ឯក្នុងការពណ៌នាសេចក្ដីតាមលំដាប់បទសេចក្ដីដូច្នេះ បទថា **ឥធ** នេះជាពាក្យសម្ដែងរឿង មានការមិនបៀតបៀនជាដើម ។ ពាក្យថា **ខោ បន** ត្រឹមតែជានិបាត ។ ពាក្យថា **វោ** ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃតតិយាវិភត្តិ ។

ក្នុងពាក្យថា **ឥធ** ជាដើមនេះ មានអត្ថដោយសង្ខេបដូច្នេះ ម្នាលចុន្ទ អ្នកទាំងឡាយគួរធ្វើការជុសខាត់កិលេស ( សល្លេខ ) ក្នុងរឿងការបៀតបៀនជាដើមនេះ ដែលតថាគតពោលដោយន័យជាដើមថា បុគ្គលដទៃនឹងជាអ្នកបៀតបៀនគ្នា ។ ព្រះមានព្រះភាគ កាលត្រាស់ដោយសង្ខេបយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ពង្រីកសេចក្ដីឲ្យពិស្ដារ ទើបត្រាស់ពាក្យជាដើមថា បុគ្គលពួកដទៃនឹងជាអ្នកបៀតបៀនគ្នា តែយើងទាំងឡាយ ជាអ្នកមិនបៀតបៀនគ្នា ព្រោះរឿងនេះ អ្នកទាំងឡាយ គួរបំពេញសល្លេខធម៌ដូចដែលពោលមកនេះ ។

ក្នុងចំនួនពាក្យទាំងនោះ ពាក្យថា **បរេ** ប្រែថា បុគ្គលដទៃ បានដល់បុគ្គលណាក៏ដោយ ដែលប្រកបសល្លេខធម៌នេះរឿយៗ ។

ពាក្យថា **វិហឹសកា ភវិស្សន្តិ** ប្រែថា នឹងជាអ្នកបៀតបៀនគ្នា សេចក្ដីថា នឹងជាអ្នកបៀតបៀនសត្វទាំងឡាយ ដោយគ្រឿងបៀតបៀនទាំងឡាយមានបាតដៃ ឬដុំដីជាដើម ។

ពាក្យថា **មយមេត្ថ អវិហិំសកា ភវិស្សាម** ( យើងទាំងឡាយ ) នឹងជាអ្នកមិនបៀតបៀនគ្នាក្នុងរឿងនេះ ។ សេចក្ដីថា ឯយើងទាំងឡាយ នឹងជាអ្នកមិនបៀតបៀនគ្នា ព្រោះរឿងដែលជាហេតុឲ្យអ្នកដទៃបៀតបៀនគ្នាយ៉ាងនេះប៉ុណ្ណោះ គឺយើងទាំងឡាយ នឹងនៅជាមួយគ្នា ដោយមិនឲ្យកើតការបៀតបៀនគ្នាឡើយ ។

បទថា **ឥតិ សល្លេខោ ករណីយោ** ប្រែថា ព្រោះហេតុយ៉ាងនេះ ការជុសខាត់កិលេសជាវត្ថុដែលគួរធ្វើ សេចក្ដីថា អ្នកទាំងឡាយគួរធ្វើសល្លេខ-ធម៌យ៉ាងនេះ ។ ការមិនបៀតបៀនគ្នានោះឯង គប្បីជ្រាបថា ជាសល្លេខធម៌ក្នុងទីនេះ ។ ព្រោះថា ការមិនបៀតបៀនគ្នា នឹងជុសខាត់កិលេស គឺកាត់ការបៀតបៀនគ្នាបាន ព្រោះដូច្នោះ ទើបត្រាស់ថា **សល្លេខ** ។ គ្រប់បទ ក៏ន័យនេះ ។ តែមានការប្លែកគ្នាយ៉ាងនេះ គឺទិដ្ឋិក្នុងពាក្យថា **បរេ មិច្ឆាទិដ្ឋី** ប្រែថា អ្នកដទៃនឹងជាអ្នកមានការធ្វើខុស នេះគប្បីជ្រាបថា ព្រះអង្គត្រាស់ទិដ្ឋិ ដោយទ្រង់សង្គ្រោះយកមិច្ឆាទិដ្ឋិចុងក្រោយរបស់កម្មបថ ( អកុសលកម្មបថ ១០ ) របស់មិច្ឆត្តចូលជាមួយគ្នា ។ម្យ៉ាងទៀត សម្មាទិដ្ឋិក្នុងឋានៈ ដែលត្រាស់ថា យើងទាំងឡាយ នឹងជាអ្នកមានការយល់ត្រូវក្នុងរឿងនេះ និងកម្មបថ ក្នុងពាក្យថា យើងទាំងឡាយ នឹងជាអ្នកវៀរចាកបាណាតិបាត ក្នុងរឿងនេះជាដើម នេះនឹងមានជាក់ច្បាស់ ក្នុងសម្មាទិដ្ឋិសូត្រដោយពិស្ដារ ឯមិច្ឆាទិដ្ឋិក្នុងមិច្ឆត្តជាដើម នឹងជាក់ច្បាស់ក្នុង **ទ្វេធាវិតក្កសូត្រ** ( ខាងមុខ ) ។

តែអត្ថដែលពោលតទៅនេះ ជាការសង្ខេបក្នុងកម្មបថ និងមិច្ឆត្តនេះ ។

ជនពួកណា ញុំាងសត្វមានជីវិតឲ្យធ្លាក់កន្លងទៅ ព្រោះហេតុនោះ ជនទាំងនោះ ឈ្មោះថា **ចាណាតិបាតី** អធិប្បាយថា ជាអ្នកសម្លាប់សត្វមានជីវិត ។

ជនពួកណាកាន់យកវត្ថុដែលគេមិនបានឲ្យ ព្រោះហេតុនោះ ជនទាំងនោះ ឈ្មោះថា **អទិន្នាទាយី** អធិប្បាយថា អ្នកលួចរបស់អ្នកដទៃ ។

ជនពួកណា ប្រព្រឹត្តធម៌មិនប្រសើរ គឺធម៌ខ្មៅ បានដល់ អាក្រក់ ព្រោះហេតុនោះ ជនទាំងនោះ ឈ្មោះថា **អព្រហ្មចារី** អធិប្បាយថា ជាអ្នកសេពមេថុនធម្ម ឯជនពួកណា ប្រព្រឹត្តធម៌ប្រសើរ គឺបដិបទាប្រសើរបំផុត ព្រោះហេតុនោះ ជនទាំងនោះឈ្មោះថា **ព្រហ្មចារី** អធិប្បាយថា ជាអ្នកវៀរមេថុនធម្ម ។ ព្រហ្មចរិយៈគប្បីជ្រាបថា ជាសល្លេខធម៌ ក្នុងពាក្យថា យើងទាំងឡាយ នឹងជាអ្នកប្រព្រឹត្តព្រហ្មចរិយៈ ព្រោះហេតុនេះ ។ ព្រោះថា ព្រហ្មចរិយៈ គឺការប្រព្រឹត្តធម៌ដ៏ប្រសើរ រមែងជុសខាត់កម្ចាត់អព្រហ្មចរិយៈបាន ។ ជនពួកណាពោលកុហក ព្រោះហេតុនោះ ជនទាំងនោះ ឈ្មោះថា **មុសាវាទី** អធិប្បាយថា ជាអ្នកពោលវាចាទទេ គឺឡេះឡោះ ដែលបៀតបៀនប្រយោជន៍របស់អ្នកដទៃ ។

ពួកជនណា ឈ្មោះថា មានបិសុណាវាចា ព្រោះមានវាចាញុះញង់ ។

ពួកជនដែល ឈ្មោះថា មានផរុសវាចា ព្រោះមានវាចាគ្រោតគ្រាតបៀតបៀនវត្ថុជាទីស្រឡាញ់របស់អ្នកដទៃ ។

ជនពួកណានិយាយរោយរាយ គឺឥតប្រយោជន៍ ព្រោះហេតុនោះ ជន

ទាំងនោះ ឈ្មោះថា **សម្ផប្បលាបី** ។

ជនពួកណា រមែងសម្លឹងរំពៃ ព្រោះហេតុនោះ ជនទាំងនោះ ឈ្មោះថា មានអភិជ្ឈាជាប្រក្រតី អធិប្បាយថា ជាអ្នកចង់បានទ្រព្យរបស់អ្នកដទៃ ។

ពួកជនដែលឈ្មោះថា មានចិត្តព្យាបាទ ព្រោះមានចិត្តព្យាបាទ គឺជាចិត្តកាច ។

ពួកជនដែលឈ្មោះថា មានការយល់ឃើញខុស ព្រោះការឃើញខុស គឺលាមក បានដល់ ដែលអ្នកប្រាជ្ញតិះដៀល អធិប្បាយថា ប្រកបដោយនត្ថិកទិដ្ឋិ មានជាដើមថា ទានដែលឲ្យហើយមិនមានផល ដែលទាក់ទងក្នុងអកុសលកម្មបថ និងទិដ្ឋិដែលមិននាំសត្វចេញចាកវដ្ដៈ ដែលទាក់ទងក្នុងមិច្ឆត្ត គឺការយល់ខុស ។

តែពួកជនដែលឈ្មោះថា មានការឃើញត្រូវ ព្រោះមានការឃើញប្រពៃ គឺស្អាត បានដល់ បុគ្គលដែលអ្នកប្រាជ្ញសរសើរ អធិប្បាយថា ប្រកបដោយការឃើញថា សត្វមានកម្មជារបស់ខ្លួន ថាទានដែលឲ្យហើយមានផល ដែលទាក់ទងក្នុងកុសលកម្មបថ និងការឃើញក្នុងមគ្គ ដែលទាក់ទងដោយសម្មត្តការយល់ត្រូវ ។

បទថា **មិច្ឆាសង្កប្បា** បានដល់ ការត្រិះរិះក្នុងអកុសលដែលមិនប្រព្រឹត្តទៅតាមសេចក្ដីពិត និងមិនមានគ្រឿងនាំសត្វចេញចាកវដ្ដៈ ។

ក្នុងមិច្ឆាវាចាជាដើម ក៏មានន័យនេះ ។ តែមានការប្លែកគ្នាដូច្នេះថា

សេចក្ដីថា ធម្មតាមិច្ឆាសតិ ដូចគ្នានឹងមិច្ឆាសង្កប្បជាដើម មិនជាធម៌

ណាមួយដោយចំពោះ គឺមិនមានធម៌ណាមួយ ។ តែពាក្យថា មិច្ឆាសតិនេះ ជាឈ្មោះរបស់ខន្ធ ដែលជាអកុសលក្ខន្ធទាំង ៤ ដែលប្រព្រឹត្តទៅហើយ សម្រាប់បុគ្គលដែលគិតដល់អតីត ។ សូម្បីពាក្យណាដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អនុស្សតិនោះមាន មិនមែនមិនមាន ដែលបានដល់អនុស្សតិរបស់បុគ្គល ដែលតាមរឭកដល់ការបានបុត្រ តាមរឭកដល់ការបានលាភ ឬតាមរឭកដល់ការបានយស ។ សូម្បីពាក្យនោះ គប្បីជ្រាបថា ព្រះអង្គត្រាស់សំដៅយកការកើតឡើងដោយសតិបដិរូបរបស់អ្នកគិតដល់រឿងនោះៗ ។

មោហៈដែលកើតឡើងដោយអំណាចការគិតដល់ឧបាយ ក្នុងការធ្វើបាបទាំងឡាយ និងដោយអាការនៃការធ្វើអាក្រក់ និងពិចារណាថា អញធ្វើល្អហើយ គប្បីជ្រាបថា ជាមិច្ឆាញាណ ក្នុងពាក្យថា **មិច្ឆាញាណី** គឺបុគ្គលមានការដឹងខុសនេះ ។

បុគ្គលទាំងឡាយដែលប្រកបដោយមិច្ឆាញាណនោះ ឈ្មោះថា **មិច្ឆា-ញាណី** ឯបច្ចវេក្ខណញ្ញាណចែកប្រភេទជា ៧៩ យ៉ាង ព្រះអង្គត្រាស់ហៅថា **សម្មាញាណ** ក្នុងបទថា **សម្មាញាណី** គឺបុគ្គលមានការដឹងត្រូវនេះ ។ បុគ្គលទាំងឡាយដែលប្រកបដោយសម្មាញាណនោះ ឈ្មោះថា **សម្មាញាណី** ពាក្យថា **មិច្ឆាវិមុត្តី** ជាអ្នកមានការរួចផុតខុស គឺមិនទាន់រួចផុតឡើយ តែមានការសម្គាល់យ៉ាងនេះថា យើងទាំងឡាយរួចផុតហើយ ឬមានការសម្គាល់ថា ការមិនរួចផុត ថាជាការរួចផុត ។

ក្នុងមិច្ឆាវិមុត្តិនោះ មានអត្ថដូច្នេះ ពពួកជនឈ្មោះថា **មិច្ឆាវិមុត្តី** ព្រោះមានការរួចផុតខុស គឺអាក្រក់ បានដល់ វិបរិត ។ ម្យ៉ាងទៀត ពាក្យថា **មិច្ឆាវិមុត្តី** នេះ ជាឈ្មោះរបស់ខន្ធដែលជាអកុសល ដែលប្រព្រឹត្តទៅដោយអាការដូចពោលមកហើយ ។ ឯធម៌ដ៏សេសដែលសម្បយុត្តដោយផល វៀរអង្គទាំង ៨ មានសម្មាទិដ្ឋិជាដើម គប្បីជ្រាបថា វិមុត្តិ ។ វិមុត្តិនោះ គប្បីជ្រាបថា ជាសល្លេខធម៌ ព្រោះកម្ចាត់មិច្ឆាវិមុត្តិ ហើយស្ថិតនៅ ។

ព្រះមានព្រះភាគ កាលទ្រង់ឲ្យភិក្ខុទាំងឡាយប្រកបក្នុងសម្មាវិមុត្តិនោះ ទើបត្រាស់ពាក្យជាដើមថា យើងទាំងឡាយ នឹងជាអ្នកមានសម្មាវិមុត្តិ ក្នុងរឿងនេះ អ្នកទាំងឡាយ គួរបំពេញសល្លេខធម៌យ៉ាងនេះ អកុសលទាំង ៣ បន្ទាប់អំពីនេះទៅ ព្រះអង្គត្រាស់ដោយអំណាចនៃនីវរណៈ តែព្រោះព្រះមានព្រះភាគត្រាស់ហើយ ក្នុងកម្មបថទាំងឡាយយ៉ាងនេះថា បុគ្គលសម្លឹងរំពៃ មានចិត្តព្យាបាទ ទើបគួរជ្រាបថា ព្រះអង្គត្រាស់នីវរណៈ ២ ខាងដើមហើយ ។ ក្នុងចំនួននីវរណៈទាំង ៣ នោះ ពួកជនដែលត្រូវថីនមិទ្ធៈចោមរោមហើយ គឺគ្របសង្កត់ហើយ ដូច្នោះ ទើបឈ្មោះថា **ថីនមិទ្ធបរិយុដ្ឋិតា** គឺបុគ្គលត្រូវងងុយងោកងក់បៀតបៀនហើយ ។

ពួកជនដែលឈ្មោះថា **ឧទ្ធតា** ប្រែថា មានការរាយមាយ ព្រោះប្រកបដោយការរាយមាយ ។

ពួកជនដែលមានឈ្មោះថា **វិចិកិច្ឆា** ព្រោះកំពុងសង្ស័យ គឺមិនអាចធ្វើការសម្រេចចិត្តបាន ។

អកុសលទាំង ១០ មានការក្រោធជាដើម ទ្រង់ត្រាស់ទុកដោយអំណាចនៃឧបក្កិលេស ក្នុងចំនួនឧបក្កិលេសទាំងឡាយ មានការក្រោធទាំងនោះជាដើម ពាក្យដែលគួរពោលទាំងអស់ ខ្ញុំបានពោលទុកហើយ ក្នុងធម្មទាយាទសូត្រ និងវត្ថូបមសូត្រ ។

តែក្នុងសូត្រនេះ មានអត្ថវចនៈដូច្នេះ បទថា **កោធនា** ប្រែថា សេចក្តីក្រោធ គឺមានការក្តៅក្រហាយជាប្រក្រតី ។

បទថា **ឧបនាហី** ប្រែថា ចងសេចក្តីក្រោធ គឺ មានការក្រោធជាប្រក្រតី ម្យ៉ាងទៀត ឈ្មោះថា **ឧបនាហី** ព្រោះបុគ្គលទាំងនោះ មានការចងក្រោធទុក ។ **មក្ខី** ប្រែថា បុគ្គលលុបគុណ **បលាសី** ប្រែថា បុគ្គលវាយឫកស្មើ ក៏ដូចគ្នា ។

ពួកជនដែលឈ្មោះថា **ឥស្សុកី** ព្រោះប្រណែន ។ ពួកជនឈ្មោះថា **មច្ឆរី** ព្រោះកំណាញ់ ម្យ៉ាងទៀត ព្រោះជនទាំងនោះ មានការកំណាញ់ ។

ជនពួកណាប្រព្រឹត្តអួតអាង ជនទាំងនោះឈ្មោះថា **សឋា** ប្រែថា អ្នកអួត មានពាក្យអធិប្បាយថា មិនពោលដោយប្រពៃ ពាក្យថា **សឋា** នេះជាឈ្មោះរបស់ពួកជន ដែលប្រកបដោយហេតុធ្វើឲ្យថោកទាប ។

មាយារបស់ជនទាំងនោះមាន ដូច្នោះ ទើបជនទាំងនោះឈ្មោះថា **មាយាវី** អ្នកមានមាយា ។

ពួកជនឈ្មោះថា **ថទ្ធា** ប្រែថា រឹងត្អឹង ព្រោះប្រកបដោយការរឹងត្អឹង ។ ពួកជនឈ្មោះថា មានមានះក្រៃលែង ព្រោះប្រកបដោយការមើលងាយ ។

ឯធម៌ដែលជាចំណែកសុក្កធម៌ គប្បីជ្រាបដោយន័យនៃធម៌ដែលផ្ទុយគ្នា ដែលបានពោលទុកហើយ ។

បទថា **ឧត្តចា** សេចក្ដីថា ជាអ្នកលំបាកទូន្មាន គឺប្រដៅ យ៉ាងណាហើយ អត់ធន់មិនបាន ។ ពួកជនដែលផ្ទុយគ្នានឹងបុគ្គលប្រដៅក្រនោះ ឈ្មោះថា **សុវចា** ។ ពួកជនដែលឈ្មោះថា **បាបមិត្តា** ព្រោះមានមិត្តអាក្រក់ដូចទេវទត្តជាដើម ។

ពួកជនដែលឈ្មោះថា **កល្យាណមិត្តា** ព្រោះមានមនុស្សល្អ គឺព្រះពុទ្ធ ឬសាវកទាំងឡាយ ដូចជាព្រះសារីបុត្រជាដើមជាមិត្ត ។

ពួកជនដែលផ្ទុយគ្នានឹងបុគ្គលមិនប្រមាទហើយ ដោយអំណាចការបណ្ដោយចិត្ត ក្នុងកាយទុច្ចរិតជាដើម គប្បីជ្រាបថា **បមត្តា** ។

ទាំង ៣ យ៉ាងនេះ ព្រះអង្គត្រាស់ទុកដោយបកិណ្ណកៈ ចំណែក ៧ យ៉ាងមានភាពជាអ្នកមិនមានសទ្ធាជាដើម ព្រះអង្គត្រាស់ទុកដោយជាអស្សទ្ធម្ម ។ ក្នុងចំនួន ៧ យ៉ាងនោះ ពួកជនដែលឈ្មោះថា មិនមានសទ្ធា ព្រោះមិនមានការជឿក្នុងវត្ថុទាំង ៣ គឺព្រះរតនត្រ័យ ។ ក្នុងធម៌ដែលជាចំណែកសុក្កធម៌ គប្បីជ្រាបអធិប្បាយដូច្នេះ ជនពួកណាជាអ្នកមានសទ្ធា ដូច្នោះ ជនទាំងនោះឈ្មោះថា ជាអ្នកជឿ ឬឈ្មោះថា មានសទ្ធា ព្រោះមានការជឿ ពួកជនដែលឈ្មោះថា អហិរិកៈ ព្រោះមិនមានការខ្មាស ។

បទថា **អហិរិក** នេះ ជាឈ្មោះរបស់បុគ្គលមិនខ្មាសចំពោះការបដិបត្តិក្នុងអកុសលធម៌ ។

ពួកជនឈ្មោះថា **ហិរិមនា** ព្រោះមានការខ្មាសក្នុងចិត្ត ឬមានចិត្តប្រកប ដោយការខ្មាស ។

ជនពួកណាមិនខ្លាចចំពោះបាប ដូច្នោះ ទើបជនទាំងនោះ ឈ្មោះថា **អនោត្តប្បី** មានអធិប្បាយថា មិនខ្លាចចំពោះការប្រព្រឹត្តអកុសលធម៌ ។ តែបុគ្គលដែលផ្ទុយគ្នានឹងបុគ្គលនោះ ឈ្មោះថា **ឱត្តប្បី** គឺបុគ្គលខ្លាចបាប ។

ពួកជនដែលឈ្មោះថា **អប្បស្សុតា** ព្រោះមានការសិក្សាតិច តែការតិចមិនគួរកាន់យកថា បានដល់ ការតិចតួច ។ ត្រូវកាន់យកថា មិនមានសោះ ។ ព្រោះថា បុគ្គលមិនមានការសិក្សា គឺសុត្តៈ ។ គឺគ្មានការសិក្សា ព្រះមានព្រះភាគត្រាស់ហៅថា បុគ្គលខ្វះការសិក្សា គឺសុត្តៈ ។

តែពួកជនដែលឈ្មោះថា **ពហុស្សុតា** ព្រោះមានការសិក្សា គឺសុត្តៈច្រើន ពាក្យថា **ពហុស្សុតា** នេះ ជាឈ្មោះរបស់ពួកជនដែលចេះពុទ្ធភាសិត គឺកថា សូម្បីមួយរឿង ដោយស្ទាត់ជំនាញ ហើយបដិបត្តិសមគួរដល់ការបដិបត្តិ ។

ពួកជនដែលឈ្មោះថា **កុសីតា** ព្រោះលិចចុះកាន់ការៈដែលគួរខ្ពើម ពាក្យនេះជាឈ្មោះរបស់បុគ្គលសាបសូន្យចាកសេចក្ដីព្យាយាមហើយ ។

ពួកជនឈ្មោះថា **អារទ្ធវីរិយា** ព្រោះមានសេចក្ដីព្យាយាមដែលប្រារព្ធហើយ ពាក្យនេះជាឈ្មោះរបស់ពួកជនដែលប្រកបដោយសម្មាវាយាមៈ ។

ពួកជនដែលឈ្មោះថា **មុដ្ឋស្សតី** ព្រោះមានសតិវាយមាយហើយ មានពាក្យអធិប្បាយថា មានសតិសាបសូន្យហើយ ។

ពួកជនឈ្មោះថា **ឧបដ្ឋិតស្សតី** ព្រោះមានសតិដែលខ្លួនតាំងទុកជិតស្និទ្ធហើយ ។ ពាក្យថា **ឧបដ្ឋិតស្សតី** នេះ ជាឈ្មោះរបស់បុគ្គលបដិបត្តិទាំងឡាយ ដែលមានសតិទល់គ្នានឹងអារម្មណ៍ជានិច្ច ។

ពួកជនដែលឈ្មោះថា **ឧប្បញ្ញា** ព្រោះជាអ្នកមានបញ្ញាអាក្រក់ មានពាក្យអធិប្បាយថា មានបញ្ញាវិនាសហើយ ។ ពួកជន ឈ្មោះថា **បញ្ញា-សម្បន្នា** ព្រោះដល់ព្រមដោយបញ្ញា ។

តែបញ្ញាក្នុងទីនេះគប្បីជ្រាបថា បានដល់ វិបស្សនាបញ្ញា ព្រោះថា អង្គប្រកបវិបស្សនាមានមកគ្រប់ចំនួនក្នុងទីនេះ ព្រោះដូច្នោះ ទើបបុរាណាចារ្យរចនាទុកថា បញ្ញានេះ គឺវិបស្សនាបញ្ញាប៉ុណ្ណោះ ។ តទៅនេះ កាលទ្រង់សម្តែងទិដ្ឋិមិននាំសត្វចេញចាកវដ្តៈតែម្យ៉ាងប៉ុណ្ណោះ ដែលធ្វើអន្តរាយចំពោះគុណធម៌ដែលជាលោកុត្តរ ដោយអាការ ៣ យ៉ាង ទើបត្រាស់ពាក្យថា **សន្ទិដ្ឋិបរាមាសី** បុគ្គលអ្នកស្ទាបអង្អែលនូវទិដ្ឋិរបស់ខ្លួនជាដើម ។

ក្នុងពាក្យថា **សន្ទិដ្ឋិបរាមាសី** ជាដើមនោះ គប្បីជ្រាបអធិប្បាយដូច្នេះថា ពួកជនដែលឈ្មោះថា **សន្ទិដ្ឋិបរាមាសី** ព្រោះប្រកាន់នូវទិដ្ឋិរបស់ខ្លួន ។

ពួកជនដែលឈ្មោះថា **អធានគាហី** ព្រោះប្រកាន់ទុកមាំ ព្រោះប្រកាន់មាំ លោកហៅថា **អាធាន** សេចក្តីថា បុគ្គលប្រកាន់មាំ ។ ពួកជនឈ្មោះថា **សុប្បដិនិស្សគ្គី** ព្រោះឃើញហេតុដែលត្រឹមត្រូវហើយ ក៏លះបង់ចោលនូវលទ្ធិចាស់ ។ តែពួកជនដែលឈ្មោះថា **ទុប្បដិនិស្សគ្គី** ព្រោះលះបង់បានដោយលំបាក បានដល់ ស្អិត អធិប្បាយថា ឃើញហេតុជាច្រើន ក៏មិនអាច

លះបង់បាន ។ ពាក្យថា **ទុប្បដិនិស្សគ្គី** នេះ ជាឈ្មោះរបស់ពួកជនដែលប្រកាន់មាំក្នុងទិដ្ឋិ ដែលកើតឡើងដល់ខ្លួនថា វត្ថុនេះប៉ុណ្ណោះពិត សូម្បីព្រះពុទ្ធជាដើម ក៏ទ្រង់ចង្អុលបង្ហាញ សម្តែងហេតុឲ្យស្តាប់ ក៏មិនលោះបង់ចោលអធិប្បាយថា បុគ្គលប្រភេទនេះស្តាប់រឿងណាមួយ ជារឿងធម្មិក្តី មិនមែនធម្មិក្តី ប្រមូលរឿងទាំងអស់នោះទុកខាងក្នុងនោះឯងថា អាចារ្យរបស់យើងទាំង-ឡាយពោលទុកយ៉ាងនេះ យើងទាំងឡាយបានស្តាប់មកយ៉ាងនេះ ។ ដូចអណ្តើកលាក់អវយវៈទាំងឡាយទុកខាងក្នុងស្នូករបស់ខ្លួន គឺប្រកាន់ទិដ្ឋិនោះទុក មិនលែងចោល ដូចការត្របាក់របស់ក្រពើ ។ ឯធម៌ស គប្បីជ្រាបដោយបរិយាយផ្ទុយគ្នាដែលពោលមកហើយ ។

[ ១០៥ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងសល្លេខធម៌ដោយអាការ ៤៤ ប្រការ យ៉ាងនេះហើយ ដើម្បីទ្រង់សម្តែងថា សូម្បីការកើតឡើងនៃចិត្តក្នុងសល្លេខធម៌នោះ ក៏ជាធម៌មានឧបការៈច្រើន ទើបបានត្រាស់ពាក្យថា តថាគតពោលចំពោះការឡើងនៃចិត្ត ... ជាដើម ។

បទថា **ចិត្តុប្បាទម្បិ ខោ អហំ** ជាដើមនោះ មានអត្ថថា ម្នាលចុន្ទសូម្បីការកើតឡើងនៃចិត្តក្នុងកុសលធម៌ទាំងឡាយ តថាគតក៏ពោលថា មានឧបការៈច្រើន នឹងពោលថ្វីក្នុងរឿងការបាត់បែងធ្វើដោយកាយ និងដោយវាចា គឺ ធ្វើធម៌ទាំងនោះ និងបង្គាប់ដោយចិត្តថា អ្នកទាំងឡាយចូរនាំគ្នាធ្វើឬ ការរៀន ការសាកសួរជាដើម ដូចគ្នានឹងចិត្តដួងដំបូងដែលកើតឡើងព្រោះថា ព្រះមានព្រះភាគទ្រង់សម្តែងថា ការបាត់បែងធ្វើនោះ មានឧបការៈ

ច្រើនដោយចំណែកមួយប៉ុណ្ណោះឯង ។

សួរថា ហេតុអ្វី សូម្បីការកើតឡើងនៃចិត្តក្នុងកុសលធម៌ទាំងនោះ ទើបមានឧបការៈច្រើន ឆ្លើយថា ព្រោះធ្វើប្រយោជន៍ និងសេចក្តីសុខមកឲ្យដោយចំណែកមួយ ព្រោះជាហេតុនៃការធ្វើតាមលំដាប់ផងដែរ ។

ពិតហើយ ការកើតឡើងនៃចិត្តថា អញនឹងឲ្យទាន ដោយទំនើងខ្លួនឯង ក៏ជាហេតុនាំប្រយោជន៍ និងសេចក្តីសុខមកឲ្យ ដោយចំណែកមួយ និងទាំងជាហេតុឲ្យធ្វើតាមលំដាប់ផងដែរ ។ ព្រោះការគិតកើតឡើងយ៉ាងនេះ ( ក្នុងថ្ងៃដំបូង ) នោះឯង ក្នុងថ្ងៃទី ២ ទើបបិទផ្លូវធំ សាងបារាំធំ ហើយឲ្យទានដល់ភិក្ខុ ១០០ អង្គ ឬ ១០០០ អង្គ បានប្រាប់អ្នកផងថា សូមនិមន្តសូមបូជា សូមអង្គាសភិក្ខុសង្ឃចុះ ដូច្នេះ ការកើតឡើងនៃចិត្តថា អញនឹងប្រគេនចីវរ សេនាសនៈ និងភេសជ្ជៈដល់ព្រះសង្ឃយ៉ាងនេះ ដោយទំនើងខ្លួនឯង ក៏ជាហេតុនាំប្រយោជន៍ឧបការៈ និងសេចក្តីសុខមកឲ្យបានដោយចំណែកមួយ ហើយទាំងជាហេតុឲ្យធ្វើតាមលំដាប់ ដោយប្រការដូច្នេះ ។ ពិតហើយ ព្រោះមានចិត្តកើតឡើងយ៉ាងនេះឯង ទើបបុគ្គលចាត់ចែងត្រៀមចីវរជាដើម នាំគ្នាប្រគេន ។

ក្នុងការដល់សរណៈជាដើមក៏មានន័យនេះ អធិប្បាយថា បុគ្គលកើតគំនិតឡើងមុននោះឯងថា អាត្មាអញនឹងដល់សរណៈ ខាងក្រោយ ទើបទទួលសរណៈដោយកាយ ឬដោយវាចា ម្យ៉ាងទៀត បុគ្គលកើតការគិតឡើងនោះឯងថា អញនឹងសមាទានសីលមានអង្គ ៥ មានអង្គ ៨ ឬមានអង្គ ១០

ហើយទើបសមាទានដោយកាយ ឬដោយវាចា ។ ឯបុគ្គលបួសហើយ ក៏មានគំនិតឡើង ( មុន ) ដូចគ្នាថា អញនឹងតាំងនៅក្នុងសីល ៤ ហើយទើបញុំាងសីលដែលគួរឲ្យបរិបូណ៌ដោយកាយ និងវាចា ឲ្យបរិបូណ៌ ។ បុគ្គលកើតការគិតឡើង ( មុន ) ថា អញនឹងរៀនព្រះពុទ្ធវចនៈ ហើយទើបរៀនព្រះពុទ្ធវចនៈបាន ១ និកាយ ២ និកាយ ៣ និកាយ ៤ និកាយ ឬ ៥ និកាយ ។

គួរនាំរឿងចិត្តុប្បាទមកសម្តែងយ៉ាងនេះ ដោយអំណាចនៃការសមាទានធុតង្គ ការរៀនកម្មដ្ឋាន ការបរិកម្មកសិណ ការចូលឈាន ( ការចម្រើន ) វិបស្សនា មគ្គ ផល បច្ចេកពោធិញ្ញាណ សម្មាសម្ពោធិញ្ញាណ ព្រោះថាការកើតគំនិតឡើងថា អញនឹងជាព្រះពុទ្ធ ដោយទំនើងខ្លួនឯង ក៏ជាហេតុនាំប្រយោជន៍ និងសេចក្តីសុខមកឲ្យបាន ដោយចំណែកមួយហើយនោះ ជាហេតុឲ្យធ្វើតាមលំដាប់ផងដែរ អធិប្បាយថា ព្រោះកាលមានគំនិតឡើងយ៉ាងនេះឯង សម័យតមក ទើប ( ពោធិសត្វ ) បំពេញបារមីដោយកាយនិងវាចា អស់កាល ៤ អសង្ខេយ្យ និងមួយសែនកប្ប ហើយបានត្រាស់ដឹង ទ្រង់យាងប្រោសសត្វលោក ព្រមទាំងទេវលោក ឲ្យឆ្លងផុតឱឃសង្សារ សូម្បីកើតការគិតឡើងក្នុងកុសលធម៌គ្រប់យ៉ាង ក៏មានឧបការៈច្រើន ដូចពណ៌នាមកនេះ តែការធ្វើតាមលំដាប់ដោយកាយវាចា គប្បីជ្រាបថា មានឧបការៈក្រៃលែងនោះឯង ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងចិត្តុប្បាទទាំងនោះ ទើបត្រាស់ពាក្យថា ម្នាលចុន្ទ ព្រោះហេតុនោះឯង ជាដើម ។

ពាក្យនោះ ដោយអត្ថប្រាកដជាក់ច្បាស់ហើយ ។

[ ១០៦ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងចិត្តុប្បាទក្នុងសល្លេខធម៌ ដែលទ្រង់សម្តែងហើយដោយអាការ ៤៤ យ៉ាង ថាមានឧបការៈច្រើនយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងសល្លេខធម៌នោះឯងថា ជាផ្លូវនៃការសម្រេចប្រយោជន៍ ទើបត្រាស់ពាក្យថា **សេយ្យថាបិ** ប្រែថា យ៉ាងណាជាដើម ។ ពាក្យនោះ អធិប្បាយថា ម្នាលចុន្ទ ឧបមាដូចមានផ្លូវដែលមិនរាបស្មើ ពោរពេញទៅដោយដង្គត់ បន្លា និងថ្ម ត្រូវមានផ្លូវដទៃដែលរាបស្មើ ដូចបរិវេណដែលពង្រាបទុកល្អហើយ ដើម្បីចៀសវាង គឺដើម្បីវៀរផ្លូវដែលមិនរាបស្មើនោះ យ៉ាងណា ម្យ៉ាងទៀត មានកំពង់ទឹកដែលមិនរាបស្មើ មានដង្គត់ មានថ្ម និងរណ្តៅ បរិបូណ៌ទៅដោយអន្តរាយ មានក្រពើ និងមករជាដើម ត្រូវមានកំពង់ទឹកដែលរាបស្មើ ជម្រាលទៅតាមលំដាប់ ដូចគ្នានឹងកាំជណ្តើរ ដើម្បីចៀសវាង គឺដើម្បីវៀរកំពង់ទឹកដែលមិនរាបស្មើនោះ ដែលបុគ្គលដើរទៅហើយ តៀងចុះកាន់ស្ទឹង ឬស្រះ ហើយងូតទឹក ឬឡើងមកបានដោយស្រួល យ៉ាងណា ។ ម្នាលចុន្ទ អវិហិង្សា ក៏ដូច្នោះដូចគ្នានោះឯង ដូចគ្នានឹងផ្លូវដែលរាបស្មើ និងកំពង់ដែលរាបល្អ មានដើម្បីចៀសវាងបុគ្គលអ្នកមានវិហិង្សា ជាអ្នកប្រកបដោយការបៀតបៀន ដែលដូចគ្នានឹងកំពង់ដែលមិនរាបស្មើ ។ សេចក្តីពិត ផ្លូវដែលរាបស្មើ និងកំពង់ដែលរចនាហើយ មានដើម្បីវៀរផ្លូវដែលមិនរាបស្មើ និងកំពង់ទឹកដែលមិនរាបល្អ យ៉ាងណា អ្នកបដិបត្តិដើម្បីវៀរវិហិង្សា និងដើម្បីទំនុកបម្រុងខ្លួនដោយអវិហិង្សា ក៏ដូច្នោះ

ដូចគ្នា នឹងទាញយកមនុស្សគតិ ឬទេវតាគតិ សោយសម្បត្តិ ឬធ្វងផុតលោកបានដោយងាយ ។ គ្រប់បទគួរប្រកបដោយទំនងនេះដូចគ្នា ។

[ ១០៧ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងសល្លេខធម៌ថា ជាផ្លូវនៃការជួបនូវប្រយោជន៍យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងភាវៈដែលសល្លេខធម៌ ឲ្យដល់នូវការខ្ពង់ខ្ពស់ ទើបត្រាស់ពាក្យថា **សេយ្យថាបិ** ជាដើម ។ ពាក្យនោះមានអធិប្បាយថា ម្នាលចុន្ទ អកុសលធម៌ដែលឲ្យកើតបដិសន្ធិ ឬមិនឲ្យកើតក្តី សូម្បីកាលឲ្យបដិសន្ធិហើយ នឹងឲ្យកើតវិបាក ឬមិនឲ្យកើតក្តី ទាំងអស់នោះដោយជាតិហើយ នឹងមានឈ្មោះយ៉ាងនេះថា **អធោភាវង្គមនីយ** ប្រែថា ជាធម៌ធ្វើឲ្យដល់ការថោកទាប ព្រោះអកុសលធម៌ទាំងនោះ ក្នុងវេលាឲ្យកើតវិបាក ជាវិបាកដែលមិនគួរប្រាថ្នា មិនគួរពេញចិត្ត យ៉ាងណា ចំណែកកុសលធម៌ដែលឲ្យកើតបដិសន្ធិ ឬមិនឲ្យកើតក្តី កាលឲ្យបដិសន្ធិហើយ នឹងឲ្យកើតវិបាក ឬមិនឲ្យកើតក្តី ទាំងអស់នោះ ដោយជាតិហើយ នឹងមានឈ្មោះយ៉ាងនេះថា **ឧបរិភាវង្គមនីយ** ប្រែថា ជាធម៌ឲ្យដល់នូវភាពឧត្តម ព្រោះកុសលធម៌ទាំងនោះ ក្នុងវេលាឲ្យវិបាក ជាវិបាកដែលគួរប្រាថ្នា ពេញចិត្ត យ៉ាងណា ។ ម្នាលចុន្ទ បុរសបុគ្គលអ្នកបៀតបៀន មានការមិនបៀតបៀន សម្រាប់ញ៉ាំងខ្លួនបានខ្ពស់ ក៏មានឧបមេយ្យយ៉ាងនោះ ។ ក្នុងរឿងនោះ មានការប្រៀបធៀបរវាងឧបមា និងឧបមេយ្យដូចតទៅនេះ ។ អកុសលធម៌ទាំងអស់នោះ ជាធម៌ឲ្យដល់នូវការថោកទាប យ៉ាងណា សូម្បីវិហិង្សាតែម្យ៉ាង ដែលជាធម៌ឲ្យដល់នូវការថោកទាប សម្រាប់បុគ្គលអ្នកមាន

វិហិង្សា ក៏ដូច្នោះ ។ ចំណែកកុសលធម៌ទាំងអស់ ជាធម៌ឲ្យដល់នូវការខ្ពង់ខ្ពស់ យ៉ាងណា សូម្បីអវិហិង្សាតែម្យ៉ាង ដែលជាធម៌ឲ្យដល់នូវភាពខ្ពង់ខ្ពស់ សម្រាប់បុគ្គលដែលមិនមានវិហិង្សាក៏យ៉ាងនោះ ។ គួរប្រៀបធៀបអកុសល និងអកុសលផង កុសល និងកុសលផង ដោយឧបាយនេះឯង ។ បានឮថា ក្នុងរឿងនេះមានអធិប្បាយ ដូចតទៅនេះថា

[ ១០៨ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងសល្លេខធម៌ ថាជាធម៌ឲ្យដល់នូវទីខ្ពស់យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងថា សល្លេខធម៌ ជាធម៌អាចញ៉ាំងកិលេសនៃបុគ្គលនោះឲ្យរលត់ដោយជុំវិញ ឲ្យដល់និព្វាន ទើបត្រាស់ពាក្យថា **សោ វត ចុន្ទ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **សោ** សម្តែងដល់បុគ្គលប្រភេទដែលពោលមកហើយ ។

គួរជ្រាបដល់ការនាំយកពាក្យឧទ្ទេសនេះថា **យោ** នៃបទថា **សោ** នោះ មកភ្ជាប់គ្នាក្នុងគ្រប់បទយ៉ាងនេះថា ម្នាលចុន្ទ បុគ្គលណាមុជចុះក្នុងភក់ គឺកាមគុណដោយខ្លួនឯង បុគ្គលនោះឯង នឹងជួយស្រង់បុគ្គលដទៃ ដែលមុជចុះក្នុងភក់ គឺកាមគុណដូចគ្នា ហេតុដូច្នេះនេះ មិនមែនមានទេ ។ បុគ្គលលិចចុះក្នុងភក់ជ្រៅ ព្រះមានព្រះភាគត្រាស់ហៅថា **បលិបបលិបន្នោ** ប្រែថា បុគ្គលលិចចុះក្នុងភក់ តែមិនមែនហៅក្នុងព្រះអរិយវិន័យឡើយ ។

ក្នុងអរិយវិន័យ ទ្រង់ត្រាស់ហៅបញ្ចកាមគុណថា **បលិប** ប្រែថា ភក់ ។ ពាលបុថុជ្ជនលិចចុះក្នុងបញ្ចកាមគុណនោះ ឈ្មោះថា **បលិបន្ន** ។

ព្រោះដូច្នោះ គួរជ្រាបការប្រកបអត្ថក្នុងពាក្យនេះថា **សោ វត ចុន្ទ** ជា

ដើមនេះ ម្នាលចុន្ទ បុគ្គលខ្លះលិចចុះក្នុងភក់ជ្រៅ រហូតដល់ច្រមុះ នឹងចាប់ដៃ ឬក្បាលបុគ្គលម្នាក់ទៀត ដែលលិចចុះក្នុងភក់នោះជាមួយគ្នា ហើយទាញឡើងមក សេចក្តីនេះ ជាហេតុដែលប្រព្រឹត្តទៅមិនបាន អធិប្បាយថា ហេតុដែលបុគ្គលនឹងជួយស្រង់បុគ្គលនោះ ឲ្យឡើងទៅឈរនៅលើគោកបានដូចម្តេច បុគ្គលដែលលិចចុះក្នុងភក់ គឺបញ្ចកាមគុណខ្លួនឯង ក៏ដូច្នោះដូចគ្នា នឹងស្រង់អ្នកដទៃដែលលិចក្នុងភក់ដូចគ្នានោះឡើងមក ហេតុនោះ ទើបសេចក្តីនេះ ជាហេតុដែលប្រព្រឹត្តទៅមិនបាន ។

ក្នុងរឿងនេះ គប្បីមានពាក្យសួរថា ព្រះពុទ្ធតម្រាស់នោះ គង់មិនត្រឹមត្រូវ ព្រោះថា ជនទាំងឡាយបានស្តាប់ធម្មទេសនារបស់ភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកាទាំងឡាយដែលនៅជាបុថុជ្ជន ហើយបានសម្រេចធម៌ក៏មាន ព្រោះដូច្នោះ បុគ្គលលិចចុះក្នុងភក់ ទើបឈ្មោះថា ស្រង់អ្នកដទៃដែលលិចចុះក្នុងភក់ដូចគ្នាឡើងបាន ។

គួរវិសជ្ជនាថា ពាក្យនោះ មិនគួរឃើញយ៉ាងនោះ ។ សេចក្តីពិត ព្រះមានព្រះភាគប៉ុណ្ណោះ ទ្រង់លើកឡើងបានក្នុងរឿងដែលពោលនោះ ។ ឯព្រះធម្មកថិកទាំងឡាយ បានទទួលក៏ត្រឹមតែពាក្យសរសើរប៉ុណ្ណោះ ដូចគ្នានឹងអ្នកអានព្រះហស្តលេខា ដែលព្រះរាជាទ្រង់បញ្ជូនទៅដូច្នោះ ។ ពិតហើយ ព្រះហស្តលេខា ដែលព្រះរាជាបញ្ជូនទៅត្រង់ជនបទជាយដែន បុគ្គលទីនោះអានព្រះរាជហស្តលេខាមិនចេញ ក៏ឲ្យបុគ្គលដែលអាចអានបានអាន រួចនាំគ្នាស្តាប់អត្ថព្រះហស្តលេខានោះ បង្អោនទទួលដោយគោរពថា ជាព្រះបរម-

រាជឱង្ការ ហើយបុគ្គលទាំងនោះ មិនមានការគិតថា នេះជាបញ្ញារបស់អ្នកអាន ឯបុគ្គលអ្នកអានព្រះរាជហស្តលេខា ក៏បានទទួលត្រឹមតែការសរសើរប៉ុណ្ណោះថា អានដោយពាក្យសម្តីច្បាស់លាស់ មិនរអាក់រអួល យ៉ាងណា ។ ព្រះធម្មកឋិកទាំងឡាយ ចាប់ពីព្រះសារីបុត្រ សម្តែងធម៌បានក៏ពិត ទោះយ៉ាងនោះ លោកទាំងនោះក៏ដូច្នោះដូចគ្នា គឺដូចគ្នានឹងអ្នកអានព្រះរាជហស្តលេខា ចំណែកព្រះធម្មទេសនានោះ ក៏ជាព្រះទេសនារបស់ព្រះមានព្រះភាគនោះឯង ដូចគ្នានឹងព្រះបរមរាជឱង្ការ ។ ម្យ៉ាងទៀត ជនពួកណាស្តាប់ធម្មទេសនាហើយ បានសម្រេចធម៌ ព្រះមានព្រះភាគនោះឯង គប្បីជ្រាបថា ទ្រង់លើកបុគ្គលទាំងនោះឡើង ឲ្យផុតភក់ ។ ឯព្រះធម្មកឋិកក៏បានត្រឹមតែពាក្យសរសើរប៉ុណ្ណោះថា សម្តែងធម៌ដោយពាក្យច្បាស់លាស់ មិនរអាក់រអួល ព្រោះដូច្នោះទើបព្រះពុទ្ធតម្រាស់នេះត្រឹមត្រូវពិត ។ ឯធម៌ដែលជាចំណែកស គប្បីជ្រាបដោយបរិយាយដែលផ្ទុយគ្នា នឹងការពោលមកហើយ ។

ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនេះថា **អទន្តោ** ប្រែថា បុគ្គលមិនបានទូន្មាន **អវិនីតោ** បុគ្គលមិនទាន់បានប្រៀនប្រដៅ **អវិនិព្វុតោ** បុគ្គលរំលត់កិលេសមិនទាន់បាន បុគ្គលឈ្មោះថា មិនបានទទួលការទូន្មាន ព្រោះជាបុគ្គលមិនទាន់អស់ព្យសន៍ បុគ្គលឈ្មោះថា មិនបានទទួលការប្រៀនប្រដៅ ព្រោះមិនទាន់បានសិក្សាវិន័យ បុគ្គលឈ្មោះថា រំលត់កិលេសមិនទាន់បាន ព្រោះនៅមានកិលេសដែលរំលត់មិនទាន់បាន បុគ្គលប្រភេទនោះ នឹងទូន្មានអ្នកដទៃ គឺនឹងធ្វើឲ្យបុគ្គលនោះអស់ព្យសន៍កំណាច នឹងប្រៀនប្រដៅបុគ្គល

នោះ គឺនឹងឲ្យបុគ្គលនោះសិក្សាត្រៃសិក្ខា ឬនឹងឲ្យបុគ្គលដទៃរំលត់កិលេស គឺនឹងឲ្យកិលេសទាំងឡាយរបស់បុគ្គលនោះរលត់ទៅ សេចក្តីដែលពោលមកនេះ ជាហេតុដែលប្រព្រឹត្តទៅមិនបាន តែធម៌ដែលជាចំណែកស គប្បីជ្រាបដោយបរិយាយដែលផ្ទុយគ្នានឹងការពោលមកហើយនេះ ។

ឯអធិប្បាយក្នុងពាក្យនេះថា ម្នាលចុន្ទ អវិហិង្សាមាន ដើម្បីការរំលត់កិលេសរបស់បុរសបុគ្គលអ្នកមានវិហិង្សា ក៏ដូច្នោះដូចគ្នា គប្បីជ្រាបយ៉ាងនេះ ។ ដូចបុគ្គលមិនលិចក្នុងភក់ នឹងស្រង់អ្នកដទៃដែលលិចចុះក្នុងភក់ឡើងបាន បុគ្គលទូន្មានហើយ នឹងទូន្មានអ្នកដទៃបាន បុគ្គលបានទទួលការណែនាំហើយ នឹងណែនាំអ្នកដទៃបាន បុគ្គលរំលត់កិលេសបានហើយ នឹងឲ្យអ្នកដទៃរំលត់កិលេសបាន សេចក្តីដែលពោលមកនេះ ទើបជាហេតុដែលប្រព្រឹត្តទៅបាន ។

សួរថា ហេតុនោះ គឺអ្វី ឆ្លើយថា គឺការមិនលិចក្នុងភក់ ការទូន្មានខ្លួនហើយ ការបានទទួលពាក្យប្រៀនប្រដៅហើយ និងការរំលត់កិលេសបានហើយ យ៉ាងណា ម្នាលចុន្ទ អវិហិង្សាមាន ដើម្បីរំលត់កិលេសរបស់បុរសបុគ្គលដែលមានវិហិង្សា ដូច្នោះដូចគ្នា ។

មានពាក្យអធិប្បាយទុកដូចម្តេច។ មានពាក្យអធិប្បាយថា អវិហិង្សារបស់បុគ្គលមិនបៀតបៀនដោយខ្លួន មានដើម្បីរំលត់ការបៀតបៀនអ្នកដទៃ របស់បុគ្គលដែលមានវិហិង្សា ព្រោះថា បុគ្គលមិនបៀតបៀនខ្លួនឯង នឹងរំលត់ចេតនាជាគ្រឿងបៀតបៀនរបស់អ្នកដទៃបាន ព្រោះដូច្នោះ ទើបសេចក្តីនោះ

ជាហេតុដែលប្រព្រឹត្តទៅបាន ។

សួរថា ហេតុនោះ គឺអ្វី ឆ្លើយថា ហេតុនោះ គឺភាពជាអ្នកមិនបៀតបៀននោះឯង ។ ព្រោះថា បុគ្គលដែលសម្រេចការមិនបៀតបៀនដោយខ្លួនឯង ទើបអាចដឹកនាំអ្នកដទៃឲ្យជាយ៉ាងនោះបាន ។

ម្យ៉ាងទៀត បុគ្គលមិនលិចចុះក្នុងភក់ ទូន្មានហើយ បានទទួលការប្រៀនប្រដៅហើយ រំលត់កិលេសបានហើយដោយខ្លួនឯង នឹងលើកអ្នកដទៃដែលលិចក្នុងភក់ឡើងបាន នឹងទូន្មានបុគ្គលដែលមិនទាន់បានទូន្មាន នឹងណែនាំបុគ្គល ដែលមិនទាន់បានណែនាំ នឹងលើកបុគ្គលដែលរំលត់កិលេសមិនទាន់បាន ឲ្យរំលត់កិលេសបាន ដូច្នោះ ទើបសេចក្តីនេះ ជាហេតុប្រព្រឹត្តទៅបានយ៉ាងណា អវិហិង្សាដែលកើតឡើងដល់បុគ្គលចម្រើនមគ្គ ដើម្បីលះវិហិង្សាក៏ ដូច្នោះដូចគ្នា មានដើម្បីរំលត់វិហិង្សារបស់បុរសបុគ្គលដែលមានវិហិង្សា អធិប្បាយថា អវិហិង្សាចេតនា អាចរំលត់វិហិង្សាចេតនាបាន ដូចគ្នានឹងបុគ្គលរំលត់កិលេសបានហើយ អាចញុំាងអ្នករំលត់កិលេសមិនទាន់បាន ឲ្យរំលត់បាន ដូច្នោះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងអត្ថដូចពណ៌នាមកយ៉ាងនេះហើយ ទើបត្រាស់ថា **ឯវមេវ ខោ ចុន្ទ** ដូច្នេះជាដើម អ្នកសិក្សាគប្បីឃើញអធិប្បាយក្នុងរឿងនេះ ដូចពណ៌នាមកនេះចុះ ។ តែការប្រកបអត្ថតាមលំដាប់បទ គ្រប់ៗ បទ មិនបានធ្វើទុក ដូចក្នុងបទវិហិង្សា និងអវិហិង្សានេះឡើយ ព្រោះនឹងនាំឲ្យវែងឆ្ងាយពេក ។

[ ១០៩ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងសល្លេខធម៌នោះថា អាច

ក្នុងការរំលត់កិលេសបាន ដោយឥតសេសសល់យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់បញ្ជាក់ព្រះធម្មទេសនានោះប្រកបអ្នកស្តាប់ ក្នុងបដិបត្តិធម៌ ទើបត្រាស់ថា **ឥតិ ខោ ចុន្ទ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **សល្លេខបរិយាយោ** ប្រែថា បរិយាយនៃសល្លេខធម៌ បានដល់ ហេតុនៃសល្លេខធម៌ ។ គ្រប់បទក៏មានន័យដូច្នេះ ។ កុសលធម៌ទាំងឡាយ មានអវិហិង្សាជាដើមនោះឯង ក្នុងសល្លេខសូត្រនេះ គប្បីជ្រាបថា ឈ្មោះថា ហេតុនៃសល្លេខធម៌ ព្រោះដុសខាត់ កម្ចាត់អកុសលធម៌ មានវិហិង្សាជាដើម ឈ្មោះថា ជាហេតុនៃចិត្តុប្បាទ ព្រោះចិត្តដែលបុគ្គលគប្បីឲ្យកើតឡើង ដោយអំណាចនៃអវិហិង្សាជាដើមនោះ ឈ្មោះថា ជាហេតុនៃការចៀសចេញទៅ ព្រោះជាហេតុនៃការចៀសចេញទៅអំពីវិហិង្សាជាដើម ឈ្មោះថា ជាហេតុនៃភាពជាបុគ្គលខ្ពង់ខ្ពស់ ព្រោះញុំាងភាពខ្ពង់ខ្ពស់ឲ្យចម្រើន ឈ្មោះថា ជាហេតុនៃការញុំាងកិលេសឲ្យរលត់បាន ព្រោះញុំាងវិហិង្សាឲ្យរលត់បានជាដើម ។ បទថា **ហិតេសិនា** សេចក្តីថា ទ្រង់ជាអ្នកស្វែងរកប្រយោជន៍ ។ បទថា **អនុកម្បកេន** ប្រែថា ទ្រង់ជាអ្នកអនុគ្រោះ គឺទ្រង់មានព្រះទ័យករុណា ។

បទថា **អនុកម្បំ ឧបាទាយ** ប្រែថា ទ្រង់អាស្រ័យសេចក្តីករុណា គឺទ្រង់កំណត់សេចក្តីករុណាដោយព្រះទ័យ មានពាក្យអធិប្បាយថា ទ្រង់អាស្រ័យ គឺការអាណិតអាសូរដូច្នេះក៏មាន ។ ពាក្យថា **កតំ វោ តំ មយា** ប្រែថា កិច្ចនោះ តថាគតបានធ្វើហើយដល់អ្នកទាំងឡាយ សេចក្តីថា កិច្ច

នោះ តថាគតសម្ដែងហេតុទាំង ៥ ប្រការនេះ បានធ្វើហើយដល់អ្នកទាំង-ឡាយ អធិប្បាយថា កិច្ចមានប្រមាណប៉ុណ្ណោះឯង ជាកិច្ចរបស់សាស្ដាអ្នកអាណិតអាសូរ បានដល់ ទ្រង់សម្ដែងធម៌ដែលមិនក្លាំងក្លាត់ ( ទ្រង់បានធ្វើហើយ ) ឯតអំពីនោះទៅ ការបដិបត្តិជាកិច្ចរបស់សាវកទាំងឡាយ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលចុន្ទ ពួកអ្នកចូរពិចារណានូវរុក្ខមូល ។បេ។ នេះជាពាក្យប្រៀនប្រដៅរបស់តថាគតដល់អ្នកទាំងឡាយ ។ ក្នុងចំនួនស្ថានទី ៣ កន្លែងនោះ ដោយបទថា **រុក្ខមូល** នេះ ទ្រង់សម្ដែងដល់ទីអង្គុយ ទីដេក គឺគល់ឈើ ។ ដោយពាក្យថា **សុញ្ញាគារ** គឺផ្ទះស្ងាត់នេះ ទ្រង់សម្ដែងដល់ទីកន្លែង ដែលស្ងាត់ចាកមនុស្សម្នា ។ ម្យ៉ាងទៀតដោយពាក្យទាំង ២ នេះ ទ្រង់ប្រាប់សេនាសនៈដែលសមគួរនឹងសេចក្ដីព្យាយាម គឺទ្រង់ប្រគល់ភាពជាទាយាទឲ្យ ។ ពាក្យថា អ្នកទាំងឡាយចូរសម្លឹង ដោយអត្ថថា ចូលទៅសម្លឹងអារម្មណ៍ ៣៨ ប្រការ ដោយអារម្មណូបនិជ្ឈាន គឺការសម្លឹងអារម្មណ៍ និងសម្លឹងខន្ធ អាយតនៈជាដើម ដោយការមិនទៀងជាដើម ដោយលក្ខណូបនិជ្ឈាន គឺការសម្លឹងលក្ខណៈមានពាក្យអធិប្បាយថា ចម្រើនសមថៈ និងវិបស្សនា ។

បទថា **មា បមាទត្ថ** ប្រែថា អ្នកទាំងឡាយកុំប្រមាទ សេចក្ដីថា អ្នកទាំងឡាយកុំប្រមាទ គឺកុំក្ដៅក្រហាយក្នុងកាលឯក្រោយឡើយ អធិប្បាយថាជនពួកណា កាលមុន គឺក្នុងវេលាជាកំលោះ ក្នុងវេលាមិនមានរោគ ក្នុងវេលាជួបការសប្បាយ ៧ យ៉ាងជាដើម និងក្នុងវេលាដែលនៅមានព្រះ

សាស្តាក្នុងទីចំពោះមុខ វៀរចាកយោនិសោមនសិការ សោយសេចក្តីសុខអំពីការដេក និងសេចក្តីសុខអំពីនិទ្រា ដែលជានុយរបស់សង្កើច ជាអ្នកប្រមាទទាំងយប់ ទាំងថ្ងៃ ជនទាំងនោះ ក្រោយមក គឺក្នុងវេលាជរា វេលាមានរោគ វេលាជិតស្លាប់ វេលាវិបត្តិ និងវេលាដែលព្រះសាស្តាបរិនិព្វានរឭកដល់ការនៅដោយសេចក្តីប្រមាទ ក្នុងកាលមុននោះ និងពិចារណាឃើញបដិសន្ធិ និងការស្លាប់របស់ខ្លួនថាជាភារៈ ទើបជាអ្នកមានការក្តៅក្រហាយចំណែកអ្នកទាំងឡាយ កុំជាបុគ្គលដូចបុគ្គលប្រភេទនោះឡើយ ព្រោះដូច្នោះព្រះមានព្រះភាគ កាលទ្រង់សម្តែងអត្ថដូចពោលមកនេះ ទើបត្រាស់ថា អ្នកទាំងឡាយ កុំជាអ្នកក្តៅក្រហាយស្តាយក្រោយឡើយ ។

បទថា **អយំ វោ អម្ហាកំ អនុសាសនី** ប្រែថា នេះជាអនុសាសនី គឺពាក្យប្រៀនប្រដៅរបស់តថាគត សម្រាប់អ្នកទាំងឡាយ សេចក្តីថា នេះជាអនុសាសនី មានពាក្យអធិប្បាយថា ជាឱវាទដើម្បីអ្នកទាំងឡាយចាកសម្នាក់របស់តថាគត តថាគតពោលថា ចូរសម្លឹង គឺដុតកិលេស ចូរកុំប្រមាទដូច្នេះឯង ។ល។

**សល្លេខសូត្រ ចប់**

**សូត្រទី ៨ ចប់**

# សុត្តន្តបិដក

## សម្មាទិដ្ឋិសូត្រទី ៩

[ ១១០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អានាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះសារីបុត្រដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ ។ ភិក្ខុទាំងឡាយនោះ ទទួលតបពាក្យព្រះសារីបុត្រដ៏មានអាយុដោយពាក្យថា ម្នាលអាវុសោ ដូច្នេះ ។ ព្រះសារីបុត្រដ៏មានអាយុ បានសួរពាក្យនេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ តែងត្រាស់ថា សម្មាទិដ្ឋិៗ ដូច្នេះ ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះដោយហេតុប៉ុន្មានយ៉ាងហ្ន៎ ។ ភិក្ខុទាំងឡាយនោះ ឆ្លើយតបថា ម្នាលអាវុសោ យើងទាំងឡាយមកអំពីចម្ងាយ ដើម្បីដឹងសេចក្តីនៃភាសិតនេះ ក្នុងសំណាក់នៃព្រះសារីបុត្រដ៏មានអាយុ យើងសូមអង្វរ សូមព្រះសារីបុត្រដ៏មានអាយុ សំដែងសេចក្តីនៃភាសិតនុ៎ះឲ្យទាន ភិក្ខុទាំងឡាយបានស្តាប់ភាសិតរបស់ព្រះសារីបុត្រដ៏មានអាយុហើយ នឹងចាំទុក ។ ព្រះសារីបុត្រមានថេរវាចាថា ម្នាលអាវុសោទាំងឡាយ បើដូច្នោះ ចូរលោកទាំងឡាយប្រុងស្តាប់ចុះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ ខ្ញុំនឹងសំដែងឥឡូវនេះ ។ ពួកភិក្ខុទាំងនោះទទួលស្តាប់ព្រះសារីបុត្រដ៏មានអាយុ ដោយពាក្យថា ករុណា អាវុសោ ។

[ ១១១ ] ព្រះសារីបុត្រដ៏មានអាយុ ក៏បានសំដែងសេចក្តីនេះថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវ័ក ដឹងច្បាស់នូវអកុសលផង

ដឹងច្បាស់នូវអកុសលមូលផង ដឹងច្បាស់នូវកុសលផង ដឹងច្បាស់នូវកុសលមូលផង ម្នាលអាវុសោទាំងឡាយ ព្រះអរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ក្នុងកាលនោះ ដោយហេតុប៉ុណ្ណេះឯង ។ ម្នាលអាវុសោ អកុសល តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ បាណាតិបាតជាអកុសល ១ អទិន្នាទានជាអកុសល ១ កាមេសុមិច្ឆាចារជាអកុសល ១ មុសាវាទជាអកុសល ១ បិសុណាវាចាជាអកុសល ១ ផរុសវាចាជាអកុសល ១ សម្ផប្បលាបៈជាអកុសល ១ អភិជ្ឈាជាអកុសល ១ ព្យាបាទជាអកុសល ១ មិច្ឆាទិដ្ឋិជាអកុសល ១ ម្នាលអាវុសោទាំងឡាយ នេះហៅថាអកុសល ។ ម្នាលអាវុសោទាំងឡាយ អកុសលមូល តើដូចម្តេច ។ លោភៈជាអកុសលមូល ១ ទោសៈជាអកុសលមូល ១ មោហៈជាអកុសលមូល ១ ម្នាលអាវុសោ នេះហៅថា អកុសលមូល ។ ម្នាលអាវុសោទាំងឡាយ កុសល តើដូចម្តេច ។ចេតនាវៀរចាកបាណាតិបាតជាកុសល ១ ចេតនាវៀរចាកអទិន្នាទានជាកុសល ១ ចេតនាវៀរចាកកាមេសុមិច្ឆាចារជាកុសល ១ ចេតនាវៀរចាកមុសាវាទជាកុសល ១ ចេតនាវៀរចាកបិសុណាវាចាជាកុសល ១ ចេតនាវៀរចាកផរុសវាចាជាកុសល ១ ចេតនាវៀរចាកសម្ផប្បលាបៈជាកុសល ១ ការមិនមានអភិជ្ឈាជាកុសល ១ ការមិនមានព្យាបាទជាកុសល ១ សម្មាទិដ្ឋិជាកុសល ១ ម្នាលអាវុសោទាំងឡាយ នេះហៅថាកុសល ។ ម្នាលអាវុសោទាំងឡាយ កុសលមូល តើដូចម្តេច ។ អលោភៈ

ជាកុសលមូល ១ អទោសៈជាកុសលមូល ១ អមោហៈជាកុសលមូល ១ ម្នាលអាវុសោទាំងឡាយ នេះហៅថា កុសលមូល ។ ម្នាលអាវុសោទាំង-ឡាយ កាលណាអរិយសាវក ដឹងច្បាស់នូវអកុសលយ៉ាងនេះ ដឹងច្បាស់នូវអកុសលមូលយ៉ាងនេះ ដឹងច្បាស់នូវកុសលយ៉ាងនេះ ដឹងច្បាស់នូវកុសលមូលយ៉ាងនេះ អរិយសាវកនោះលះបង់រាគានុស័យ បន្ទោបង់នូវបដិឃានុស័យ ដកចេញនូវមានានុស័យប្រហែលនឹងទិដ្ឋិថា អាត្មាអញមានដូច្នេះហើយ លះបង់នូវអវិជ្ជា ញុំាងវិជ្ជាឲ្យកើត ធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ន ដោយសព្វគ្រប់បាន ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ។

[ ១១២ ] ភិក្ខុទាំងឡាយនោះ ត្រេកអរអនុមោទនា ចំពោះភាសិតរបស់ព្រះសារីបុត្រដ៏មានអាយុ ដោយពាក្យថា ម្នាលអាវុសោ ប្រពៃហើយ ទើបសួរប្រស្នាតទៅទៀតនឹងព្រះសារីបុត្រដ៏មានអាយុថា ម្នាលអាវុសោ អរិយ-សាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយបរិយាយដទៃទៀតមានដែរឬ ។

[ ១១៣ ] ព្រះសារីបុត្រដ៏មានអាយុ បានឆ្លើយថា ម្នាលអាវុសោទាំង-ឡាយ មានដែរ ហើយបាននិយាយ ( តទៅថា ) ម្នាលអាវុសោទាំងឡាយ

កាលណាអរិយសាវ័ក ស្គាល់ច្បាស់នូវអាហារ គឺបច្ច័យផង ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃអាហារផង ស្គាល់ច្បាស់នូវសេចក្តីរលត់អាហារផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់អាហារផង ម្នាលអាវុសោទាំងឡាយ អរិយសាវ័កជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ អាហារ តើដូចម្តេច សេចក្តីកើតឡើងនៃអាហារ តើដូចម្តេច សេចក្តីរលត់នៃអាហារ តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់អាហារ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ អាហារ ៤ យ៉ាងនេះ តែងប្រព្រឹត្តទៅដើម្បីឋិតនៅ ដល់ពួកសត្វដែលជាភូតផង ដើម្បីអនុគ្រោះដល់ពួកសត្វដែលជាសម្ភវេសីផង ។ អាហារទាំង ៤ យ៉ាង តើដូចម្តេច ។ គឺអាហារធ្វើជាពំនូតគ្រោតគ្រាត ឬល្អិត ( ជាទី ១ ) ការពាល់ត្រូវ ( មានចក្ខុសម្ផស្សជាដើម ) ជាអាហារទី ២ ការត្រិះរិះក្នុងចិត្ត ជាអាហារទី ៣ វិញ្ញាណ ( នាំមកនូវបដិសន្ធិនៃនាមរូប ) ជាអាហារទី ៤ ។ សេចក្តីកើតឡើងនៃអាហារ ព្រោះសេចក្តីកើតឡើងនៃតណ្ហា សេចក្តីរលត់អាហារ ព្រោះសេចក្តីរលត់នៃតណ្ហា បានដល់មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាសេចក្តីប្រតិបត្តិជាដំណើរទៅ ដើម្បីរលត់អាហារ គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្ប ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក

ស្គាល់ច្បាស់នូវអាហារយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃអាហារយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីរំលត់អាហារយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់អាហារយ៉ាងនេះ កាលណាអរិយសាវកនោះ លះបង់នូវរាគានុស័យ បន្ទោបង់នូវបដិឃានុស័យ ដកចេញនូវមានានុស័យ ប្រហែលនឹងទិដ្ឋិថា អាត្មាអញមានដូច្នេះ លះបង់អវិជ្ជាហើយញុំាងវិជ្ជាឲ្យកើតឡើង ធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នដោយសព្វគ្រប់ ក្នុងកាលនោះ ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ។

[ ១១៤ ] ពួកភិក្ខុទាំងនោះ ត្រេកអរអនុមោទនាភាសិត របស់ព្រះសារីបុត្រដ៏មានអាយុថា អាវុសោប្រពៃហើយ ទើបសួរប្រស្នាតទៅទៀតនឹងព្រះសារីបុត្រដ៏មានអាយុថា ម្នាលអាវុសោ បរិយាយដទៃនៅមានទៀតដែរឬ ។បេ។

[១១៥] ព្រះសារីបុត្រដ៏មានអាយុឆ្លើយតបថា ម្នាលអាវុសោទាំងឡាយមានដែរ ហើយបាននិយាយថា ម្នាលអាវុសោទាំងឡាយ កាលណា អរិយសាវកដឹងច្បាស់នូវទុក្ខផង ដឹងច្បាស់នូវហេតុជាទីកើតឡើងនៃទុក្ខផង ដឹងច្បាស់នូវសេចក្តីរំលត់ទុក្ខផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ទុក្ខផង ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមក

កាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ។ ម្នាលអាវុសោទាំងឡាយ សេចក្តីទុក្ខ តើដូចម្តេច គឺ ជាតិក៏ជាទុក្ខ ជរាក៏ជាទុក្ខ មរណៈក៏ជាទុក្ខ សេចក្តីសោកខ្សឹកខ្សួល លំបាកកាយ ទោមនស្ស ចង្អៀតចង្អល់ចិត្ត ក៏ជាទុក្ខ ការប្រកបដោយរបស់មិនជាទីស្រឡាញ់ទាំងឡាយ ក៏ជាទុក្ខ ការព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ទាំងឡាយ ក៏ជាទុក្ខ ប្រាថ្នានូវរបស់ណាមិនបានរបស់នោះ ក៏ជាទុក្ខ ដោយសង្ខេប ឧបាទានក្ខន្ធទាំង ៥ ក៏ជាទុក្ខ ម្នាលអាវុសោទាំងឡាយ នេះហៅថាទុក្ខ ។ ម្នាលអាវុសោទាំងឡាយ ហេតុជាទីកើតឡើងនៃទុក្ខ តើដូចម្តេច តណ្ហាដែលជាធម្មជាតនាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីរីករាយ និងសេចក្តីត្រេកត្រអាល ជាធម្មជាតត្រេកអរចំពោះក្នុងអារម្មណ៍នោះៗ គឺកាមតណ្ហា ភវតណ្ហា វិភវតណ្ហា ម្នាលអាវុសោទាំងឡាយ នេះហៅថា ហេតុជាទីកើតឡើងនៃទុក្ខ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីរំលត់ទុក្ខ តើដូចម្តេច សេចក្តីអស់ទៅ និងសេចក្តីរំលត់ដោយមិនសល់ណា នៃតណ្ហានោះឯង គឺការលះបង់ រលាស់ចោល ជម្រុះចោល ឥតមានអាល័យ ម្នាលអាវុសោទាំងឡាយ នេះហៅថា ទុក្ខនិរោធ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីប្រតិបត្តិជាដំណើរដើម្បីរំលត់ទុក្ខ តើដូចម្តេច អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក ដឹងច្បាស់នូវទុក្ខយ៉ាងនេះ ដឹងច្បាស់នូវទុក្ខសមុទយៈទាំងនេះ ដឹងច្បាស់នូវទុក្ខនិរោធយ៉ាងនេះ ដឹងច្បាស់នូវទុក្ខនិរោធគាមិនីបដិបទាយ៉ាងនេះ អរិយសាវកនោះ

លះបោលអនុស័យ គឺ រាគៈ បន្ទោបង់អនុស័យ គឺ បដិឃៈ ដកចេញនូវអនុស័យ គឺ មានះប្រហែលនឹងទិដ្ឋិថា អាត្មាអញមានដូច្នេះ លះបង់នូវអវិជ្ជាញុំាងវិជ្ជាឲ្យកើតឡើងដោយសព្វគ្រប់ ហើយធ្វើនូវទីបំផុតនៃទុក្ខបានក្នុងបច្ចុប្បន្ននេះ ក្នុងកាលនោះ ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ។

[ ១១៦ ] ភិក្ខុទាំងឡាយនោះ ត្រេកអរអនុមោទនា ចំពោះភាសិតរបស់ព្រះសារីបុត្រដ៏មានអាយុថា អាវុសោ ប្រពៃហើយ ទើបសួរប្រស្នាតទៅទៀត នឹងព្រះសារីបុត្រដ៏មានអាយុថា ម្នាលអាវុសោ អរិយសាវកជាសម្មាទិដ្ឋិ មានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយបរិយាយដទៃទៀតមានដែរឬ ។

[ ១១៧ ] ព្រះសារីបុត្រដ៏មានអាយុឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ បរិយាយដទៃនៅមានទៀតដូច្នេះ ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក ស្គាល់ច្បាស់នូវជរា និងមរណៈផង ស្គាល់ច្បាស់នូវហេតុជាទីកើតឡើងនៃជរា និងមរណៈផង ស្គាល់ច្បាស់នូវសេចក្ដីរំលត់ជរា និងមរណៈផង ស្គាល់ច្បាស់នូវសេចក្ដីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ជរា និងមរណៈផង ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោ

ទាំងឡាយ ជរា និងមរណៈ តើដូចម្តេច សេចក្តីកើតឡើងនៃជរា និងមរណៈ តើដូចម្តេច សេចក្តីរំលត់ទៅនៃជរា និងមរណៈ តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ជរា និងមរណៈ តើដូចម្តេច ។ សេចក្តីគ្រាំគ្រាណា គឺសេចក្តីទ្រុឌទ្រោម ធ្មេញបាក់ សក់ស្កូវ ស្បែកយុរយារ ថយអាយុ ចាស់ទុំឥន្ទ្រិយ របស់ពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ នេះហៅថា ជរា ។ សេចក្តីឃ្លាតណាចាកសត្តនិកាយនោះៗ គឺច្យុត បែកធ្លាយ អន្តរធាន មច្ចុ មរណៈ កាលកិរិយា ការបែកធ្លាយនៃខន្ធទាំងឡាយ ការដាក់ចោលនូវសាកសព ការផ្តាច់នូវជីវិតិន្ទ្រិយ នៃពួកសត្វនោះៗ នុ៎ះហៅថា មរណៈ ។ ម្នាលអាវុសោទាំងឡាយ ជរានេះឯង មរណៈនេះឯង ហៅថា ជរាមរណៈ ដោយប្រការដូច្នេះឯង ។ សេចក្តីកើតឡើងនៃជរា និងមរណៈ ព្រោះសេចក្តីកើតឡើងនៃជាតិ សេចក្តីរំលត់ជរា និងមរណៈ ព្រោះសេចក្តីរំលត់ជាតិ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ជារា និងមរណៈ អរិយមគ្គនោះ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ម្នាលអាវុសោទាំងឡាយកាលណាអរិយសាវ័ក ដឹងច្បាស់នូវជរា និងមរណៈយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃជរា និងមរណៈយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរំលត់ជរា និងមរណៈយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់នៃជរា និងមរណៈយ៉ាងនេះ អរិយសាវ័កនោះ លះបោលនូវអនុស័យ គឺរាគៈដោយសព្វគ្រប់ ក្នុងកាលនោះ ។បេ។ ម្នាលអាវុសោទាំងឡាយ អរិយសាវ័កជាសម្មាទិដ្ឋិ មានទិដ្ឋិត្រង់ ប្រកប

ដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ។

[១១៨] ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយឯទៀតនៅមានដែរឬ ។ ព្រះសារីបុត្រដ៏មានអាយុឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ មានដែរ ដូច្នេះហើយ និយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវកស្គាល់នូវជាតិផង ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃជាតិផង ស្គាល់ច្បាស់នូវសេចក្តីរំលត់ជាតិផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ជាតិផង ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ ជាតិ តើដូចម្តេច សេចក្តីកើតឡើងនៃជាតិ តើដូចម្តេច សេចក្តីរំលត់ជាតិ តើដូចម្តេច សេចក្តីប្រតិបត្តិជាដំណើរដើម្បីរំលត់ជាតិ តើដូចម្តេច ។ កំណើតណា គឺសេចក្តីកើតគ្រប់គ្រាន់ ចាប់បដិសន្ធិ កកើតទ្រើសឡើង កើតបានជាគ្រោងខន្ធឡើង ការបានចំពោះនូវអាយតនៈទាំងឡាយរបស់ពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ ម្នាលអាវុសោទាំងឡាយ នេះហៅថា ជាតិ ។ សេចក្តីកើតឡើងនៃជាតិ ព្រោះសេចក្តីកើតឡើងនៃភព សេចក្តីរំលត់ជាតិ ព្រោះសេចក្តីរំលត់ភព អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ឈ្មោះថា ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ជាតិ អរិយមគ្គនោះ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណា

អរិយសាវកដឹងច្បាស់នូវជាតិយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃជាតិយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរំលត់ជាតិយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ជាតិយ៉ាងនេះ អរិយសាវកនោះ លះបោលអនុស័យ គឺរាគៈ ដោយសព្វគ្រប់ ក្នុងកាលនោះ ។បេ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ។

[ ១១៩ ] ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយឯទៀតនៅមានដែរឬ ។បេ។ ព្រះសារីបុត្រដ៏មានអាយុឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ នៅមានដែរដូច្នេះ ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវកដឹងច្បាស់នូវភពផង ដឹងច្បាស់នូវសេចក្តីកើតឡើងនៃភពផង ដឹងច្បាស់នូវសេចក្តីរំលត់ភពផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ភពផង ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មា-ទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ ភព តើដូចម្តេច សេចក្តីប្រជុំកើតឡើងនៃភព តើដូចម្តេច សេចក្តីរំលត់ភព តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ភព តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភពទាំងឡាយនេះមាន ៣ យ៉ាង គឺកាមភព ១ រូបភព ១ អរូបភព ១ ។ សេចក្តីកើតឡើងនៃភព

ព្រោះសេចក្តីកើតឡើងនៃឧបាទាន សេចក្តីរំលត់ភព ព្រោះសេចក្តីរំលត់ឧបាទាន អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ភព អរិយមគ្គនោះ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវកដឹងច្បាស់នូវភពយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃភពយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរំលត់ភពយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ភពយ៉ាងនេះ អរិយសាវកនោះ លះបោលអនុស័យ គឺរាគៈដោយសព្វគ្រប់ ។បេ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។

[ ១២០ ] ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយឯទៀតនៅមានដែរឬ ។បេ។ ព្រះសារីបុត្រដ៏មានអាយុឆ្លើយតបថា ម្នាលអាវុសោទាំង-ឡាយ នៅមានដែរ ដូច្នេះហើយ និយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក ដឹងច្បាស់នូវឧបាទានផង ដឹងច្បាស់នូវសេចក្តីកើតឡើងនៃឧបាទានផង ដឹងច្បាស់នូវសេចក្តីរំលត់ឧបាទាន ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ឧបាទានផង ម្នាលអាវុសោទាំងឡាយ អរិយ-សាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ ឧបាទានដូចម្តេច សេចក្តីកើត

ឡើងនៃឧបាទាន តើដូចម្តេច សេចក្តីរំលត់ឧបាទាន តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ឧបាទាន តើដូចម្តេច ។ ម្នាលអាវុសោទាំង-ឡាយ ឧបាទាននេះ មាន ៤ គឺកាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វ-តុបាទាន ១ អត្តវាទុបាទាន ១ ។ សេចក្តីកើតឡើងនៃឧបាទាន ព្រោះសេចក្តីកើតឡើងនៃតណ្ហា សេចក្តីរំលត់ឧបាទាន ព្រោះសេចក្តីរំលត់តណ្ហា អរិយ-មគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ឧបាទាន អរិយមគ្គនោះ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណា អរិយសាវក ដឹងច្បាស់នូវឧបាទានយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃឧបាទានយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរំលត់ឧបាទានយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ឧបាទានយ៉ាងនេះ អរិយសាវកនោះ លះបោលនូវអនុស័យ គឺរាគៈ ដោយប្រការទាំងពួង ។បេ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។

[១២១] ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយឯទៀតនៅមានដែរឬ ។បេ។ ព្រះសារីបុត្រដ៏មានអាយុឆ្លើយតបថា ម្នាលអាវុសោទាំង-ឡាយ នៅមានដែរ ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណា អរិយសាវកដឹងច្បាស់នូវតណ្ហាផង ដឹងច្បាស់នូវសេចក្តីកើតឡើងនៃតណ្ហាផង ដឹងច្បាស់នូវសេចក្តីរំលត់តណ្ហាផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជា

ដំណើរដើម្បីរំលត់តណ្ហាផង ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ តណ្ហា តើដូចម្តេច សេចក្តីកើតឡើងនៃតណ្ហា តើដូចម្តេច សេចក្តីរំលត់តណ្ហា តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់តណ្ហា តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ពួកតណ្ហានេះ មាន ៦ គឺសេចក្តីប្រាថ្នាក្នុងរូប ១ ប្រាថ្នាក្នុងសំឡេង ១ ប្រាថ្នាក្នុងក្លិន ១ ប្រាថ្នាក្នុងរស ១ ប្រាថ្នាក្នុងការពាល់ត្រូវ ១ ប្រាថ្នាក្នុងធម្មារម្មណ៍ គឺអារម្មណ៍ដែលខ្លួនធ្លាប់សន្សំទុកមកក្នុងចិត្ត ១ ។ សេចក្តីកើតឡើងនៃតណ្ហា ព្រោះសេចក្តីកើតឡើងនៃវេទនា សេចក្តីរំលត់តណ្ហា ព្រោះសេចក្តីរំលត់វេទនា អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់តណ្ហា អរិយមគ្គនោះ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវកដឹងច្បាស់នូវតណ្ហាយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃតណ្ហាយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរំលត់តណ្ហាយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់តណ្ហាយ៉ាងនេះ អរិយសាវកនោះ លះបោលអនុស័យ គឺរាគៈដោយសព្វគ្រប់ ។បេ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។

[១២២] ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយឯទៀតនៅមានដែរឬ ។បេ។ ព្រះសារីបុត្រមានអាយុឆ្លើយតបថា ម្នាលអាវុសោទាំង-ឡាយ នៅមានដែរ ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក ដឹងនូវវេទនាផង ដឹងច្បាស់នូវសេចក្តីកើតឡើងនៃវេទនាផង ដឹងច្បាស់នូវសេចក្តីរំលត់វេទនាផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់វេទនាផង ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ វេទនា តើដូចម្តេច សេចក្តីកើតឡើងនៃវេទនា តើដូចម្តេច សេចក្តីរំលត់នៃវេទនា តើដូចម្តេច សេចក្តីប្រតិបត្តិជាដំណើររលត់វេទនា តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ពួកវេទនានេះ មាន ៦ គឺ វេទនាកើតអំពីការពាល់ត្រូវដោយភ្នែក ១ វេទនាកើតអំពីការពាល់ត្រូវដោយត្រចៀក ១ វេទនាកើតអំពីការពាល់ត្រូវដោយច្រមុះ ១ វេទនាកើតអំពីការពាល់ត្រូវដោយអណ្តាត ១ វេទនាកើតអំពីការពាល់ត្រូវដោយកាយ ១ វេទនាកើតអំពីការពាល់ត្រូវដោយចិត្ត ១ ។ សេចក្តីកើតឡើងនៃវេទនា ព្រោះសេចក្តីកើតឡើងនៃផស្សៈ សេចក្តីរំលត់វេទនា ព្រោះសេចក្តីរំលត់ផស្សៈ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់វេទនា អរិយមគ្គនោះ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក ដឹងច្បាស់នូវវេទនាយ៉ាងនេះ ដឹង

ច្បាស់នូវសេចក្តីកើតឡើងនៃវេទនាយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរំលត់វេទនា យ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់វេទនាយ៉ាងនេះ អរិយសាវកនោះ លះបោលអនុស័យ គឺរាគៈដោយសព្វគ្រប់ ។បេ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។

[១២៣] ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយឯទៀតនៅមានដែរឬ ។បេ។ ព្រះសារីបុត្រមានអាយុឆ្លើយតបថា ម្នាលអាវុសោទាំង-ឡាយ នៅមានដែរ ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណា អរិយសាវកដឹងច្បាស់នូវផស្សៈផង ដឹងច្បាស់នូវសេចក្តីកើតឡើងនៃផស្សៈផង ដឹងច្បាស់នូវសេចក្តីរំលត់ផស្សៈផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ផស្សៈផង ក្នុងកាលណាហើយ ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ ផស្សៈ តើដូចម្តេច សេចក្តីកើតឡើងនៃផស្សៈ តើដូចម្តេច សេចក្តីរំលត់ផស្សៈ តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើររំលត់ផស្សៈ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ពួកផស្សៈនេះ មាន ៦ គឺចក្ខុសម្ផស្ស ១ សោតសម្ផស្ស ១ ឃានសម្ផស្ស ១ ជិវ្ហា-សម្ផស្ស ១ កាយសម្ផស្ស ១ មនោសម្ផស្ស ១ ។ សេចក្តីកើតឡើងនៃ

ផស្សៈ ព្រោះសេចក្តីកើតឡើងនៃអាយតនៈ ៦ សេចក្តីរំលត់ផស្សៈ ព្រោះសេចក្តីរំលត់អាយតនៈ ៦ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់ផស្សៈ អរិយមគ្គនោះ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវ័កដឹងច្បាស់នូវផស្សៈយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃផស្សៈយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរំលត់ផស្សៈយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិជាដំណើរដើម្បីរំលត់ផស្សៈយ៉ាងនេះ អរិយសាវ័កនោះ លះចោលអនុស័យគឺរាគៈដោយសព្វគ្រប់ ។បេ។ ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ ក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។

[ ១២៤ ] ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយឯទៀតនៅមានដែរឬ ។បេ។ ព្រះសារីបុត្រមានអាយុឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ នៅមានដែរ ដូច្នេះហើយ និយាយ ( តទៅទៀត ) ថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវ័ក ដឹងច្បាស់នូវអាយតនៈ ៦ ផង ដឹងច្បាស់នូវសេចក្តីកើតឡើងនៃអាយតនៈ ៦ ផង ដឹងច្បាស់នូវសេចក្តីរំលត់អាយតនៈ ៦ ផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់អាយតនៈ ៦ ផង ម្នាលអាវុសោទាំងឡាយ អរិយសាវ័កជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយ

មកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ អាយតនៈ ៦ តើដូចម្តេច សេចក្តីកើតឡើងនៃអាយតនៈ ៦ តើដូចម្តេច សេចក្តីរំលត់អាយតនៈ ៦ តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់អាយតនៈ ៦ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ អាយតនៈនេះ មាន ៦ គឺចក្ខាយតនៈ១ សោតាយតនៈ១ ឃានាយតនៈ១ ជិវ្ហាយតនៈ១ កាយាយតនៈ១ មនាយតនៈ១ ។ ការកើតឡើងនៃអាយតនៈ ៦ បាន ព្រោះសេចក្តីកើតឡើងនៃនាមរូប សេចក្តីរំលត់អាយតនៈ ៦ បាន ព្រោះសេចក្តីរំលត់នាមរូប អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់អាយតនៈ ៦ អរិយមគ្គនោះ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណា អរិយសាវក ដឹងច្បាស់នូវអាយតនៈ ៦ យ៉ាងនេះ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃអាយតនៈ ៦ យ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរំលត់អាយតនៈ ៦ យ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់អាយតនៈ ៦ យ៉ាងនេះ អរិយសាវកនោះ លះបោលអនុស័យ គឺរាគៈដោយសព្វគ្រប់ ។បេ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។

[ ១២៥ ] ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយឯទៀត នៅមានដែរឬ ។បេ។ ព្រះសារីបុត្រមានអាយុឆ្លើយតបថា ម្នាលអាវុសោ

ទាំងឡាយ នៅមានដែរ ដូច្នេះហើយ និយាយថា ម្នាលអាវុសោទាំងឡាយ កាលណា អរិយសាវក ដឹងច្បាស់នូវនាមរូបផង ដឹងច្បាស់នូវសេចក្តីកើតឡើងនៃនាមរូបផង ដឹងច្បាស់នូវសេចក្តីរលត់នាមរូបផង ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់នាមរូបផង ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ នាមរូប តើដូចម្តេច សេចក្តីកើតឡើងនៃនាមរូប តើដូចម្តេច សេចក្តីរលត់នាមរូប តើដូចម្តេច សេចក្តីប្រតិបត្តិជាដំណើរដើម្បីរលត់នាមរូប តើដូចម្តេច ។ វេទនា ១ សញ្ញា ១ ចេតនា ១ ផស្សៈ ១ មនសិការ ១ នេះហៅថា នាម ។ មហាភូតទាំង ៤ និងរូបដែលអាស្រ័យមហាភូតរូបទាំង ៤ នេះ ហៅថា រូប ។ ម្នាលអាវុសោ នាមនេះ និងរូបនេះ ហៅថា នាមរូប ដោយប្រការដូច្នេះ ។ សេចក្តីកើតឡើងនៃនាមរូប ព្រោះសេចក្តីកើតឡើងនៃវិញ្ញាណ សេចក្តីរលត់នាមរូប ព្រោះសេចក្តីរលត់វិញ្ញាណ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់នាមរូប អរិយមគ្គនោះ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវកដឹងច្បាស់នូវនាមរូបយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃនាមរូបយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់នាមរូបយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរលត់នាមរូបយ៉ាងនេះ អរិយសាវកនោះ លះបង់អនុស័យ គឺ

ភាគៈដោយសព្វគ្រប់ ។បេ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មា-ទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ បានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។

[ ១២៦ ] ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយឯទៀត នៅមានតទៅទៀតដែរឬ ។បេ។ ព្រះសារីបុត្រឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ នៅមានដែរ ដូច្នេះហើយ និយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក ស្គាល់ច្បាស់នូវវិញ្ញាណផង ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃវិញ្ញាណផង ស្គាល់ច្បាស់នូវសេចក្តីរំលត់វិញ្ញាណផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់វិញ្ញាណផង ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ បានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ វិញ្ញាណ តើដូចម្តេច សេចក្តីកើតឡើងនៃវិញ្ញាណ តើដូចម្តេច សេចក្តីរំលត់វិញ្ញាណ តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់វិញ្ញាណ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ពួកវិញ្ញាណនេះ មាន ៦ គឺ ចក្ខុវិញ្ញាណ ១ សោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោវិញ្ញាណ ១ ។ សេចក្តីកើតឡើងនៃវិញ្ញាណ ព្រោះសេចក្តីកើតនៃសង្ខារ សេចក្តីរំលត់វិញ្ញាណ ព្រោះសេចក្តីរំលត់សង្ខារ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់វិញ្ញាណ អរិយមគ្គនោះ

គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណា អរិយសាវក ស្គាល់ច្បាស់នូវវិញ្ញាណយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃវិញ្ញាណយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីរំលត់វិញ្ញាណយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់វិញ្ញាណយ៉ាងនេះ អរិយសាវកនោះ លះចោលអនុស័យ គឺរាគៈដោយសព្វគ្រប់ ។បេ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។

[ ១២៧ ] ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយឯទៀតនៅមានដែរឬ ។បេ។ ព្រះសារីបុត្រឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ បរិយាយឯទៀតនៅមាន ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវកស្គាល់ច្បាស់នូវសង្ខារផង ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃសង្ខារផង ស្គាល់ច្បាស់នូវសេចក្តីរំលត់សង្ខារផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់សង្ខារផង ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ សង្ខារទាំងឡាយតើដូចម្តេច សេចក្តីកើតឡើងនៃសង្ខារ តើដូចម្តេច សេចក្តីរំលត់សង្ខារ តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់សង្ខារ តើដូចម្តេច ។ ម្នាលអាវុសោ

ទាំងឡាយ សង្ខារនេះ មាន ៣ គឺកាយសង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ សេចក្ដីកើតឡើងនៃសង្ខារ ព្រោះសេចក្ដីកើតឡើងនៃអវិជ្ជា សេចក្ដីរំលត់សង្ខារ ព្រោះសេចក្ដីរំលត់អវិជ្ជា អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្ដីប្រតិបត្តិ ជាដំណើរដើម្បីរំលត់សង្ខារ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវកស្គាល់ច្បាស់នូវសង្ខារយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្ដីកើតឡើងនៃសង្ខារយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្ដីរំលត់សង្ខារយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្ដីប្រតិបត្តិ ជាដំណើរដើម្បីរំលត់សង្ខារយ៉ាងនេះ អរិយសាវកនោះ លះបោលអនុស័យ គឺរាគៈ ដោយសព្វគ្រប់ បន្ទោបង់អនុស័យ គឺបដិឃៈ ដកចេញនូវអនុស័យ គឺមានះ ប្រហែលនឹងទិដ្ឋិថា អាត្មាអញមានដូច្នេះ ហើយលះបង់នូវអវិជ្ជា ញុំាងវិជ្ជាឲ្យកើតឡើង ហើយធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្ននេះបាន ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ បានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។

[ ១២៨ ] ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោ បរិយាយឯទៀត នៅមានដែរឬ ។បេ។ ព្រះសារីបុត្រឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ នៅមានដែរ ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណា អរិយសាវកស្គាល់ច្បាស់នូវអវិជ្ជាផង ស្គាល់ច្បាស់នូវសេចក្ដីកើតឡើងនៃអវិជ្ជាផង ស្គាល់ច្បាស់នូវសេចក្ដីរំលត់អវិជ្ជាផង ស្គាល់ច្បាស់នូវសេចក្ដីប្រតិបត្តិ

ជាដំណើរដើម្បីរំលត់អវិជ្ជាផង ម្នាលអាវុសោទាំងឡាយ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ បានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ អវិជ្ជាតើដូចម្តេច សេចក្តីកើតឡើងនៃអវិជ្ជា តើដូចម្តេច សេចក្តីរំលត់អវិជ្ជា តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់អវិជ្ជា តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ សេចក្តីមិនដឹងទុក្ខ ១ សេចក្តីមិនដឹងហេតុឲ្យកើតទុក្ខ ១ សេចក្តីមិនដឹងព្រះនិព្វានជាគ្រឿងរំលត់ទុក្ខ ១ សេចក្តីមិនដឹងបដិបទា ជាដំណើរដើម្បីរំលត់ទុក្ខ ១ ម្នាលអាវុសោ នេះឯង ហៅថា អវិជ្ជា ។ សេចក្តីកើតឡើងនៃអវិជ្ជា ព្រោះសេចក្តីកើតឡើងនៃអាសវៈ សេចក្តីរំលត់អវិជ្ជា ព្រោះសេចក្តីរំលត់អាសវៈ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់អវិជ្ជា គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលអាវុសោទាំងឡាយ កាលណាអរិយ-សាវក ស្គាល់ច្បាស់នូវអវិជ្ជាយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃអវិជ្ជាយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីរំលត់អវិជ្ជាយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់អវិជ្ជាយ៉ាងនេះ អរិយសាវកនោះលះបោលអនុស័យ គឺរាគៈ បន្ទោបង់អនុស័យ គឺបដិឃៈ ដកចេញនូវអនុស័យ គឺមានះ ប្រហែលនឹងទិដ្ឋិថា អាត្មាអញមានដូច្នេះ លះបង់នូវអវិជ្ជា ញុំាងវិជ្ជាឲ្យកើតឡើង ហើយធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្ននេះបាន ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តី

ជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ មកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។

[ ១២៩ ] ភិក្ខុទាំងអម្បាលនោះ ត្រេកអរអនុមោទនាចំពោះភាសិតរបស់ព្រះសារីបុត្រដ៏មានអាយុថា ម្នាលអាវុសោ ប្រពៃហើយ បានសួរប្រស្នានឹងព្រះសារីបុត្រដ៏មានអាយុតទៅទៀតថា ម្នាលអាវុសោ អរិយសាវក ជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ បានមកកាន់ព្រះសទ្ធម្មនេះ ដោយបរិយាយដទៃទៅមានដែរឬ ។

[ ១៣០ ] ព្រះសារីបុត្រឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ បរិយាយឯទៀតនៅមាន ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ កាលណាអរិយសាវក ស្គាល់ច្បាស់នូវអាសវៈផង ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃអាសវៈផង ស្គាល់ច្បាស់នូវសេចក្តីរំលត់អាសវៈផង ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់អាសវៈផង ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ បានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណោះឯង ក្នុងកាលនោះ ។ ម្នាលអាវុសោទាំងឡាយ អាសវៈ តើដូចម្តេច សេចក្តីកើតឡើងនៃអាសវៈ តើដូចម្តេច សេចក្តីរំលត់អាសវៈ តើដូចម្តេច សេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់អាសវៈ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ អាសវៈនេះ មាន ៣ គឺកាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ សេចក្តីកើតឡើងនៃអាសវៈ ព្រោះសេចក្តីកើតឡើងនៃអវិជ្ជា សេចក្តីរំលត់

អាសវៈ ព្រោះសេចក្តីរំលត់អវិជ្ជា អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ជាសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់អាសវៈ អរិយមគ្គនោះ គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្ប ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មា-វាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។ ម្នាលអាវុសោទាំងឡាយ កាលណា អរិយសាវកស្គាល់ច្បាស់នូវអាសវៈយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីកើតឡើងនៃអាសវៈយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីរំលត់អាសវៈយ៉ាងនេះ ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិ ជាដំណើរដើម្បីរំលត់អាសវៈយ៉ាងនេះ អរិយសាវកនោះ លះបោលអនុស័យ គឺរាគៈ ដោយសព្វគ្រប់ បន្ទោបង់អនុស័យ គឺបដិឃៈ ដកចេញនូវអនុស័យ គឺមានះ ប្រហែលនឹងទិដ្ឋិថា អាត្មាអញមានដូច្នេះ លះបង់នូវអវិជ្ជា ញ៉ាំងវិជ្ជាឲ្យកើត ហើយធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ននេះបាន ម្នាលអាវុសោទាំងឡាយ អរិយសាវកជាសម្មាទិដ្ឋិ ជាអ្នកមានទិដ្ឋិត្រង់ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ បានមកកាន់ព្រះសទ្ធម្មនេះ ដោយហេតុប៉ុណ្ណេះឯង ក្នុងកាលនោះ ។ លុះព្រះសារីបុត្រដ៏មានអាយុ ពោលពាក្យនេះហើយ ភិក្ខុទាំងអម្បាលនោះ មានចិត្តត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះសារីបុត្រដ៏មានអាយុ ។

## សម្មាទិដ្ឋិសូត្រទី ៩ ចប់

ធម្មជាតណា ក្នុងពាក្យដែលលោកពោលថា **កតមំ បញ្ចាវុសោ**( ម្នាលអាវុសោ តើដូចម្ដេច )មាន ៦ បទ គឺទុក្ខ ជរា មរណៈ ឧបាទាន សឡាយតនៈ នាមរូប វិញ្ញាណ ។ ធម្មជាតណា ក្នុងពាក្យដែលលោកពោលថា **កតមា បញ្ចាវុសោ** ( ម្នាលអាវុសោ តើដូចម្ដេច ) មាន ៤ គឺជាតិ តណ្ហា វេទនា ជាគម្រប់ ៤ នឹងអវិជ្ជា ។ សភាវៈណា ក្នុងពាក្យដែលលោកពោលថា **កតមំ បញ្ចាវុសោ** ( ម្នាលអាវុសោ តើដូចម្ដេច ) មាន ៥ បទ គឺ អាហារ ភព ផស្សៈ សង្ខារ ជាគម្រប់ ៥ នឹងអាសវៈ ។ ធម្មជាតនោះលោកពោលថា មាន **កតមំ** ( តើដូចម្ដេច ) ៦ លើក មាន **កតមាណិ ច** ( តើដូចម្ដេច ) ៤ លើក លោកពោលថា មាន **កតមោ** ( តើដូចម្ដេច ) ៥ លើក រួមបទនៃសង្ខារធម៌ទាំងអស់ ត្រូវជា ១៥ ។

# អដ្ឋកថា

## សម្មាទិដ្ឋិសូត្រ

[ ១១០ ] *សម្មាទិដ្ឋិសូត្រ មានពាក្យផ្ដើមថា* **ឯវំមេ សុតំ** *ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាទិដ្ឋិសូត្រដូចតទៅនេះ*

*ពាក្យសួរដែលព្រះថេរៈ ឈ្មោះសារីបុត្រពោលទុកយ៉ាងនេះថា បពិត្រលោកម្ចាស់ ដែលហៅថា សម្មាទិដ្ឋិដោយហេតុមានប្រមាណប៉ុនណា ដូច្នេះ ឬថា អកុសលដូចម្ដេច ដូច្នេះគ្រប់ប្រការ ជាកថេតុកម្យតាបុច្ឆា គឺសួរដើម្បីឆ្លើយឯងប៉ុណ្ណោះ ។*

*ព្រោះថា ក្នុងពាក្យសួរទាំងនោះ មនុស្សទាំងឡាយយល់ក្នុងសម្មាទិដ្ឋិនោះក៏មាន មិនយល់ក៏មាន ជាបុគ្គលក្រៅសាសនាក៏មាន ក្នុងសាសនាក៏មាន ពោលថា សម្មាទិដ្ឋិ ដោយអំណាចដែលបានស្ដាប់តាមគ្នាមកជាដើមក៏មាន ដោយបានប្រចក្សដោយខ្លួនឯងមកក៏មាន ដូច្នោះ ទើបព្រះសារីបុត្របានពោលសំដៅយកពាក្យសួររបស់បុគ្គលជាច្រើនរូប បញ្ចូលក់ដល់ទៅ ២ ដងថា បពិត្រលោកម្ចាស់ ដែលហៅថា សម្មាទិដ្ឋិ ... ដែលពិតក្នុងរឿងនេះ មានអធិប្បាយដូចតទៅនេះ សូម្បីអាចារ្យដទៃក៏ហៅថា សម្មាទិដ្ឋិ ។*

*ព្រះសារីបុត្រនោះ កាលពោលយ៉ាងនេះ បានពោលថា ដោយហេតុមានប្រមាណប៉ុនណា ទើបអរិយសាវក ឈ្មោះថា មានការឃើញត្រឹមត្រូវ ដូច្នេះ សំដៅដល់អត្ថ និងលក្ខណៈរបស់សម្មាទិដ្ឋិនោះ ។*

*បណ្ដាបទទាំងនោះ បទថា* **សម្មាទិដ្ឋិ** *សេចក្ដីថា ឈ្មោះថា ជាបុគ្គលប្រកបដោយការឃើញល្អផង ប្រសើរផង ។*

កាលណា សព្ទថា **សម្មាទិដ្ឋិ** នេះ ប្រើក្នុងធម្មៈប៉ុណ្ណោះ កាលនោះ គប្បីជ្រាបអត្ថរបស់សព្ទនោះយ៉ាងនេះថា ទិដ្ឋិល្អផង ប្រសើរផង ឈ្មោះថា សម្មាទិដ្ឋិ ។ សម្មាទិដ្ឋិនេះមាន ២ យ៉ាង គឺលោកិយសម្មាទិដ្ឋិ ១ លោកុត្តរសម្មាទិដ្ឋិ ១ ។

ក្នុងចំនួនសម្មាទិដ្ឋិ ២ យ៉ាងនោះ កម្មស្សកតាញាណ និងសច្ចានុលោមិកញ្ញាណ ( ប្រាជ្ញាប្រព្រឹត្តទៅដោយសមគួរដល់ការកំណត់ដឹងអរិយសច្ច ) ឈ្មោះថា លោកិយសម្មាទិដ្ឋិ ។ ចំណែកបញ្ញាដែលសម្បយុត្តដោយអរិយមគ្គ អរិយផល ឈ្មោះថា លោកុត្តរសម្មាទិដ្ឋិ ។ តែបុគ្គលដែលមានសម្មាទិដ្ឋិមាន ៣ ប្រភេទ គឺបុថុជ្ជន ១ សេក្ខបុគ្គល ១ អសេក្ខបុគ្គល ១ ។

ក្នុងបុគ្គល ៣ ប្រភេទនោះ បុថុជ្ជនមាន ២ ប្រភេទ គឺពាហិរកជន ១ សាសនិកជន ១ ក្នុងបុគ្គល ២ ប្រភេទនោះ ពាហិរកបុថុជ្ជន ជាកម្មវាទី គឺជឿនូវកម្មផល ឈ្មោះថា ជាសម្មាទិដ្ឋិបុគ្គល ដោយការឃើញថា សត្វមានកម្មជារបស់ខ្លួន មិនមែនដោយការឃើញថ្នាក់សច្ចានុលោមិកញ្ញាណទេ ឯសាសនិកជន ឈ្មោះថា មានការយល់ត្រូវ ជាសម្មាទិដ្ឋិបុគ្គល ដោយការឃើញទាំង ២ យ៉ាង គឺកម្មស្សកតា និងអនុលោមិកញ្ញាណ ព្រោះនៅស្អាប់អន្លែលការឃើញអត្តា លះសក្កាយទិដ្ឋិមិនទាន់បាន ។ សេក្ខបុគ្គល ឈ្មោះថា មានការឃើញប្រពៃ ព្រោះមានការឃើញប្រពៃដោយពិតប្រាកដ ។ ឯអសេក្ខបុគ្គល ឈ្មោះថា មានការឃើញប្រពៃ ព្រោះមិនចាំបាច់សិក្សា ។ តែក្នុងទីនេះ បំណងយកបុគ្គលប្រកបដោយសម្មាទិដ្ឋិ ដែលជាលោកុត្តរកុសល

ដែលពិតប្រាកដ គឺជាគ្រឿងនាំសត្វចេញចាកទុក្ខថា បុគ្គលមានការឃើញប្រពៃ ។ ព្រោះហេតុនោះឯង ទើបព្រះសារីបុត្រពោលថា ជាបុគ្គលប្រកបដោយការជ្រះថ្លាក្នុងធម៌ មិនឃ្លៀងឃ្លាត បានមកកាន់ព្រះសទ្ធម្មនេះហើយ ។

អធិប្បាយថា សម្មាទិដ្ឋិជាលោកុត្តរកុសលប៉ុណ្ណោះ ជាការឃើញដ៏ត្រង់ ព្រោះទៅតាមការត្រង់ មិនធ្លាក់ចូលក្នុងអន្តធម៌ទាំង ២ យ៉ាង ឬកាត់ផ្តាច់នូវការវៀចវេរគ្រប់យ៉ាង មានការវៀចវេរតាមផ្លូវកាយជាដើម ហើយទៅត្រង់ និងបុគ្គលប្រកបដោយទិដ្ឋិនោះឯង ឈ្មោះថា ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនឃ្លៀងឃ្លាត គឺដោយការជ្រះថ្លា មិនញាប់ញ័រ ក្នុងនវលោកុត្តរធម៌ ។ អរិយសាវក កាលប្រាសចាកការប្រកាន់មាំ ដោយទិដ្ឋិគ្រប់យ៉ាង លះកិលេសទាំងអស់បាន ចេញទៅចាកសង្សារ គឺជាតិ ចប់នូវការបដិបត្តិ លោកហៅថា អ្នកបានមកកាន់ព្រះសទ្ធម្ម ពោល គឺព្រះនិព្វាន ដែលឈមចុះកាន់អមតធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសហើយ ដោយអរិយមគ្គ ។

[ ១១១ ] បទថា **យតោ ខោ** នេះ ជាពាក្យកំណត់កាលវេលា អធិប្បាយថា ក្នុងកាលណា ។

បទថា **អកុសលមូលញ្ច បជានាតិ** សេចក្តីថា ស្គាល់ច្បាស់អកុសល ពោល គឺអកុសលកម្មបថ ១០ ប្រការ គឺកាលចាក់ធ្លុះថា វត្ថុនេះជាទុក្ខ ដោយអំណាចនៃកិច្ចញ្ញាណ ឈ្មោះថា ដឹងច្បាស់អកុសល ព្រោះការដឹងច្បាស់ ដែលមាននិរោធជាអារម្មណ៍ ។

បទថា **អកុសលញ្ច បជានាតិ** សេចក្តីថា ដឹងច្បាស់នូវឫសគល់នៃអកុសលដែលជាឫសគល់ ជាបច្ច័យរបស់អកុសលនោះ គឺកាលចាក់ធ្លុះថា នេះជាហេតុឲ្យកើតទុក្ខ ដោយប្រការនោះឯង ឈ្មោះថា ដឹងច្បាស់នូវឫសគល់របស់អកុសល ។ សូម្បីក្នុងពាក្យនេះថា កុសល និងឫសគល់របស់កុសល ក៏មានន័យដូច្នេះ ។

គ្រប់វារៈបន្តអំពីវារៈនេះទៅ ក៏ដូចគ្នាក្នុងវារៈនេះ គួរជ្រាបការដឹងច្បាស់នូវវត្ថុ ដោយអំណាចនៃកិច្ចញ្ញាណនោះឯង ។

បទថា **ឯត្តាវតាបិ** សេចក្តីថា ដោយហេតុមានប្រមាណប៉ុណ្ណេះ គឺសូម្បីដោយការដឹងច្បាស់អកុសលជាដើមនេះ ។

បទថា **សម្មាទិដ្ឋិ ហោតិ** សេចក្តីថា ជាអ្នកប្រកបដោយលោកុត្តរ-សម្មាទិដ្ឋិ មានប្រការដូចពោលមកហើយ ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះថា អរិយសាវកនោះ មានការឃើញត្រង់ ។បេ។ បានមកកាន់ព្រះសទ្ធម្មនេះហើយ ឈ្មោះថា ព្រះសារីបុត្របញ្ចប់ ការសម្តែងដោយការសង្ខេបហើយ ។ ការសម្តែងរបស់លោកនេះសូម្បីសង្ខេប តែក៏គួរជ្រាបដល់ការចាក់ធ្លុះ ដោយមនសិការ ដោយប្រពៃដោយអំណាចសេចក្តីពិស្តារនោះឯង សម្រាប់កិក្ខុទាំងនេះ ។ ឯក្នុងទុតិយ-វារៈ ដល់នូវការសម្តែង ទោះសង្ខេបក៏គួរជ្រាបដល់ការចាក់ធ្លុះ ដោយមនសិការ ដោយប្រពៃ យ៉ាងពិស្តារថា បានប្រព្រឹត្តទៅហើយ ដោយពិស្តារនោះឯង ។

ភិក្ខុទាំងឡាយ បាននិយាយគ្នាថា បណ្តាការសម្តែងទាំង ២ យ៉ាងនោះ ដោយការសម្តែងយ៉ាងសង្ខេប ព្រះសារីបុត្របានពោលដល់មគ្គខាងក្រោម ទាំង ២ យ៉ាង ដោយការសម្តែងយ៉ាងពិស្តារ ព្រះសារីបុត្របានពោលដល់ មគ្គជាន់ខ្ពស់ ២ យ៉ាង ។

ក្នុងទីបំផុតនៃការសម្តែងយ៉ាងពិស្តារ ភិក្ខុទាំងឡាយ សម្គាល់ឃើញពាក្យ ជាដើមថា ព្រោះលះរាគានុស័យបាន ដោយប្រការទាំងពួង តែព្រះថេរៈ បានពោលថា មគ្គទាំង ៤ បានពោលហើយ ដោយភាពជាពួក ដោយការ សម្តែងយ៉ាងសង្ខេបក៏មាន ដោយការសម្តែងយ៉ាងពិស្តារក៏មាន ។

មួយវិញទៀត ការសម្តែងដោយសង្ខេបផង ដោយពិស្តារផងនេះ ជាការ សម្តែង ដែលខ្ញុំបានធ្វើការពិចារណាដោយល្អិតល្អន់ ជាក់ច្បាស់ហើយក្នុងទី នេះ ការសម្តែងនោះគប្បីជ្រាបតាមន័យដែលបានពោលហើយ ក្នុងគ្រប់វារៈ ហោង ។ ព្រោះថា បន្ទាប់អំពីនេះទៅ ខ្ញុំនឹងធ្វើត្រឹមតែការពង្រីកសេចក្តី ចំពោះបទដែលលំបាក ដែលមិនទាន់បានអធិប្បាយប៉ុណ្ណោះ ។

# អធិប្បាយ

## អកុសលកម្មបថ ១០

គប្បីជ្រាបវិនិច្ឆ័យក្នុងការសម្តែងដោយពិស្តារទូវបឋមវារៈ ក្នុងចំនួនវារៈ ទាំងនោះដូច្នេះ ក្នុងពាក្យទាំងឡាយ មានពាក្យថា អាវុសោ បាណាតិបាត នោះឯង ជាអកុសលជាដើម ។ អកុសលគប្បីជ្រាបបានពីការប្រព្រឹត្តទៅ ដោយការមិនឈ្លាស ។ អកុសលធម៌នោះ គប្បីជ្រាបដោយការផ្ទុយគ្នានឹង

កុសលដែលត្រូវពោលខាងមុខ ឬដោយលក្ខណៈ គប្បីជ្រាបថា ជាវត្ថុដែលមានទោស និងមានវិបាកជាទុក្ខ ជាវត្ថុដែលសៅហ្មង នេះជាការពង្រីកបទទូទៅ ក្នុងអកុសលវារៈប្រមាណប៉ុណ្ណេះ ។

ឯក្នុងបទចំពោះ គឺមិនទូទៅ គប្បីជ្រាបវិនិច្ឆ័យថា ការញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ឈ្មោះថា បាណាតិបាត បានដល់ ការសម្លាប់សត្វមានជីវិត អធិប្បាយថា ការទម្លាយសត្វមានជីវិត ។ ពាក្យថា **បាណ** ក្នុងពាក្យថា **បាណាតិបាតោ** នេះ ដោយវោហារ បានដល់ សត្វ តែដោយបរមត្ថបានដល់ ជីវិតិន្ទ្រិយ ។

ឯចេតនាដែលសម្លាប់របស់បុគ្គល ដែលមានការសម្គាល់ក្នុងសត្វមានជីវិតនោះថា ជាសត្វមានជីវិត ដែលជាសមុដ្ឋាននៃសេចក្តីព្យាយាម ដែលនឹងចូលទៅកាត់ជីវិតិន្ទ្រិយ ដែលប្រព្រឹត្តទៅតាមកាយទ្វារ ឬវចីទ្វារ ទ្វារណាមួយ ឈ្មោះថា **បាណាតិបាត** ។

បាណាតិបាតនោះ គប្បីជ្រាបថា មានទោសតិច ព្រោះសត្វមានសរីរៈតូច ក្នុងចំនួនសត្វមានជីវិតទាំងឡាយ មានតិរច្ឆានជាដើម ដែលប្រាសចាកគុណ តែគប្បីជ្រាបថា មានទោសច្រើន ព្រោះសត្វមានជីវិត មានសរីរៈធំ ។

ព្រោះហេតុអ្វី ព្រោះមានប្រយោគធំ គឺព្យាយាមខ្លាំង ។

កាលមានប្រយោគស្មើគ្នា បាណាតិបាត គប្បីជ្រាបថា មានទោសច្រើន ព្រោះវត្ថុធំ ( សរីរៈធំ ) ។ ក្នុងពួកសត្វដែលមានគុណ មានមនុស្សជាដើម ព្រោះសត្វមានគុណតិច បាណាតិបាតក៏គប្បីជ្រាបថា មានទោសតិច ក្នុង

សត្វមានគុណច្រើន គប្បីជ្រាបថា មានទោសច្រើន ។ តែកាលសរីរៈ និង គុណ មានការស្មើគ្នា បាណាតិបាតគប្បីជ្រាបថា មានទោសតិច ព្រោះកិលេស និងការព្យាយាមទន់ខ្សោយ គប្បីជ្រាបថា មានទោសច្រើន ព្រោះកិលេស និងការព្យាយាមខ្លាំងក្លា ។

បាណាតិបាតនោះ មានអង្គប្រកប ៥ គឺសត្វមានជីវិត ១ ដឹងថាសត្វមានជីវិត ១ ចិត្តគិតនឹងសម្លាប់ ១ ព្យាយាមសម្លាប់ ១ សត្វស្លាប់ព្រោះព្យាយាមនោះ ១ ។

ប្រយោគនៃការសម្លាប់មាន ៦ គឺសាហត្ថិកប្បយោគ គឺសម្លាប់ដោយខ្លួនឯង ១ អាណត្តិកប្បយោគ គឺប្រើឲ្យអ្នកដទៃសម្លាប់ ១ និស្សគ្គិយប្បយោគ គឺសម្លាប់ដោយសាស្ត្រាវុធ ដែលគប់ ឬគ្រវែងចេញទៅ ១ ថាវរប្បយោគ គឺសម្លាប់ដោយឧបករណ៍ដាក់នៅមួយកន្លែង ១ វិជ្ជាមយប្បយោគ គឺសម្លាប់ដោយវិជ្ជា ១ ឥទ្ធិមយប្បយោគ គឺសម្លាប់ដោយឫទ្ធិ ១ ។

តែកាលអធិប្បាយបយោគនេះឲ្យពិស្តារក្នុងបឋមវារៈនេះ ក៏នឹងវែងឆ្ងាយពេក ព្រោះដូច្នោះ សុំមិនអធិប្បាយបយោគនោះ និងបយោគដទៃឲ្យពិស្តារឡើយ ចំណែកលោកអ្នកមានសេចក្តីត្រូវការ គប្បីពិនិត្យមើលក្នុងសមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យឯណោះផងចុះ ។

ការកាន់យកទ្រព្យដែលគេមិនបានឲ្យ ឈ្មោះថា **អទិន្នាទាន** ការលួចទ្រព្យរបស់អ្នកដទៃ ឈ្មោះថា **ថេយ្យ** អធិប្បាយថា ជាកិរិយារបស់ចោរ ។

បទថា **អទិន្នំ** បានដល់ របស់ដែលអ្នកដទៃហួងហែង ដែលម្ចាស់

ទ្រព្យអាចប្រើបានតាមដែលត្រូវការ មិនទទួលទណ្ឌ: និងមិនត្រូវមានពាក្យតិះដៀល ។

ឯចេតនាដែលលួចរបស់បុគ្គល ដែលមានការសម្គាល់ក្នុងរបស់អ្នកដទៃហួងហែងនោះថា ជារបស់ដែលគេហួងហែង ជាសមុដ្ឋាននៃសេចក្តីព្យាយាមដែលនឹងកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យនោះ ឈ្មោះថា **អទិន្នាទាន។**

អទិន្នាទាននោះ មានទោសតិច ព្រោះទ្រព្យអ្នកដទៃអន់ថយ ឈ្មោះថាមានទោសច្រើន ព្រោះទ្រព្យអ្នកដទៃប្រណីត ។

ព្រោះហេតុអ្វី ព្រោះថា ជាទ្រព្យប្រណីត ។

កាលមានការស្មើគ្នានៃវត្ថុ ឈ្មោះថា មានទោសច្រើន ព្រោះទ្រព្យដែលមាននោះជារបស់បុគ្គលអ្នកមានគុណក្រៃលែង ។ អទិន្នាទាននោះ ឈ្មោះថាមានទោសតិច ព្រោះទ្រព្យរបស់បុគ្គលដែលមានគុណធម៌ទាបជាងនោះ ព្រោះប្រៀបធៀបនឹងបុគ្គលមានគុណធម៌ច្រើននោះ ។

អទិន្នាទាននោះ មានអង្គប្រកប ៥ ប្រការ គឺរបស់ដែលអ្នកដទៃហួងហែង ១ ការដឹងថាទ្រព្យដែលអ្នកដទៃហួងហែង ១ ចិត្តគិតនឹងលួច ១ ព្យាយាមនឹងលួច ១ លួចបានមកដោយព្យាយាមនោះ ១ ។

ប្រយោគរបស់អទិន្នាទានមាន ៦ យ៉ាង មានសាហត្ថិកប្បយោគជាដើម ប្រយោគទាំងនោះឯងប្រព្រឹត្តទៅហើយ ដោយអំណាចនៃអវហារ គឺថេយ្យាវហារ គឺលួចដូចជាចោរ ១ បសយ្ហាវហារ គឺលួចដោយការចោទ ១ បដិច្ឆន្នាវហារ គឺលួចដោយការបិទបាំង ១ បរិកប្បាវហារ គឺលួចដោយការ

កំណត់ទ្រព្យ ឬពេលវេលា ១ កុសាវហារ គឺលួចដោយការប្តូរស្លាក ១ សេចក្តីដូចពោលមកហើយនេះ ជាការពោលដោយសង្ខេបក្នុងអវហារនេះ ឯសេចក្តីពិស្តារបានពោលហើយ ក្នុងអដ្ឋកថា ឈ្មោះសមន្តប្បាសាទិកា ។

បទថា **កាមេសុ** ក្នុងបទថា **កាមេសុមិច្ឆាចារា** នេះ បានដល់ មេថុនសមាចារ ។ ការប្រព្រឹត្តលាមក ដែលបណ្ឌិតតិះដៀលដោយចំណែកមួយ ឈ្មោះថា **មិច្ឆាចារ** ។

តែដោយលក្ខណៈ ចេតនាដែលប្រព្រឹត្តកន្លងអគមនីយដ្ឋាន គឺបុគ្គលដែលមិនគួរប៉ះពាល់ ដែលប្រព្រឹត្តទៅតាមកាយទ្វារ ដោយការបំណងចំពោះអសទ្ធម្ម ឈ្មោះថា **កាមេសុមិច្ឆាចារ** ។

ជាបឋម ស្រីដែលឈ្មោះថា ជាអគមនីយដ្ឋាន គឺស្ត្រីដែលបុរសមិនគួរប៉ះពាល់ សម្រាប់បុរសក្នុងកាមេសុមិច្ឆាចារនេះ បានដល់ ស្រី ២០ ពួក គឺស្រីដែលមានម្តាយរក្សាជាដើម ។

ស្រី ១០ ពួក គឺស្រីដែលមាតារក្សា ១ ដែលបិតារក្សា ១ ដែលមាតានិងបិតារក្សា ១ ដែលបងប្រុសប្អូនប្រុសរក្សា ១ ដែលបងស្រីប្អូនស្រីរក្សា ១ ដែលញាតិរក្សា ១ ដែលគោត្ររក្សា ១ ដែលធម៌រក្សា ១ ដែលប្រុសថែរក្សាទុកតាំងពីនៅក្នុងផ្ទៃ ១ ស្រីដែលស្តេចហួងហែងដោយអាជ្ញា ១ ។

និងភរិយា ១០ ពួកទៀត មានស្រីដែលលោះមកដោយទ្រព្យជាដើម គឺភរិយាដែលលោះមកដោយទ្រព្យ ១ ដែលនៅជាមួយគ្នាព្រោះការពេញចិត្ត ១ ដែលនៅជាមួយគ្នាព្រោះបុរសឲ្យភោគៈ ១ ដែលនៅជាមួយគ្នាព្រោះបុរសឲ្យ

សំពត់ ១ ដែលអ្នកគ្រប់គ្រងពេញចិត្តចាប់ដៃផ្តុំឲ្យ ១ ដែលបុរសលើកទ្រនូលចុះអំពីក្បាល ១ ដែលជាកិរិយាផង ជាទាសៈផង ១ ដែលជាកិរិយាផង កូនឈ្នួលផង ១ ដែលជាឈ្លើយសឹក ១ ដែលនៅជាមួយគ្នាត្រឹមមួយរយៈ ១ ។

ឯបុរសដទៃក្រៅអំពីស្វាមីរបស់ខ្លួន ឈ្មោះថា **អគមនីយដ្ឋាន** សម្រាប់ស្រី ១២ ពួក គឺ ២ ពួក មានស្រីដែលប្រុសថែរក្សាទុកតាំងពីនៅក្នុងផ្ទៃ ១ និងស្រីដែលស្តេចហួងហែងដោយអាជ្ញា ១ រួមនឹងកិរិយា ១០ មានកិរិយាដែលលោះមកដោយទ្រព្យជាដើម ។

ម្យ៉ាងទៀត មិច្ឆាចារនេះ ឈ្មោះថា មានទោសតិច ព្រោះអគមនីយដ្ឋានប្រាសចាកគុណធម៌ មានសីលជាដើម ឈ្មោះថា មានទោសច្រើន ព្រោះដល់ព្រមដោយគុណធម៌ មានសីលជាដើម ។

កាមេសុមិច្ឆាចារនោះ មានអង្គប្រកប ៤ គឺជាអគមនីយបុគ្គល ១ ចិត្តគិតនឹងសេពក្នុងអគមនីយបុគ្គលនោះ ១ ការប្រកបការសេព ១ ញ៉ាំងមគ្គនិងមគ្គឲ្យដល់គ្នា ១ ប្រយោគមានតែម្យ៉ាង គឺសាហត្ថិប្បយោគប៉ុណ្ណោះ ។

កាយប្បយោគ និងវចីបយោគ ដែលបំផ្លាញអ្នកដទៃរបស់បុគ្គលបំណងនឹងពោលឲ្យខុស ឈ្មោះថា **មុសា** ។ ចេតនារបស់បុគ្គលដែលពោលឲ្យខុសចំពោះអ្នកដទៃ ដោយបំណងនឹងឲ្យយល់ខុស មានកាយប្បយោគ និងវចី-បយោគជាសមុដ្ឋាន ឈ្មោះថា **មុសាវាទ** ។

ម្យ៉ាងទៀត រឿងមិនពិត មិនមែន ឈ្មោះថា **មុសា** ។ ការឲ្យអ្នកដទៃ

យល់រឿងមិនពិតនោះ ថាជារឿងពិត រឿងមែន ឈ្មោះថា **វាទ** តែពោលដោយលក្ខណៈ ចេតនារបស់អ្នកបំណងនឹងឲ្យអ្នកដទៃដឹងរឿងដែលមិនពិតថាជារឿងពិត ដែលជាសមុដ្ឋាននៃវិញ្ញត្តិយ៉ាងនោះ ឈ្មោះថា **មុសាវាទ** គឺការពោលកុហក ។

មុសាវាទនេះ ឈ្មោះថា មានទោសតិច ព្រោះប្រយោជន៍ដែលខ្លួនបំផ្លាញមានចំនួនតិច ឈ្មោះថា មានទោសច្រើន ព្រោះប្រយោជន៍ដែលខ្លួនធ្វើឲ្យខូចខាតមានចំនួនច្រើន ។

មយ៉ាងទៀត សម្រាប់គ្រហស្ថ មុសាវាទដែលប្រព្រឹត្តទៅហើយ ដោយន័យជាដើមថា មិនមាន ព្រោះមិនបំណងឲ្យរបស់ខ្លួនដល់អ្នកដទៃមានទោសតិច ដែលពោលធ្វើជាសាក្សីដើម្បីឲ្យខូចប្រយោជន៍កាគីម្ខាងទៀត មានទោសច្រើន សម្រាប់បព្វជិត មុសាវាទដែលប្រព្រឹត្តទៅហើយ ដោយន័យនៃបូរណកថា គឺនិយាយឲ្យពេញសេចក្តី ឬលេងសំនួនវោហារថា ថ្ងៃនេះ ប្រេងក្នុងស្រុកនឹងហូរជាស្ទឹង ដោយបំណងនឹងឲ្យសើច ព្រោះបានប្រេង ឬសប្បិតិចពេក មានទោសតិច តែរបស់បុគ្គលដែលពោលដោយន័យជាដើមថា វត្ថុដែលមិនបានឃើញ ថាបានឃើញ មានទោសច្រើន ។

មុសាវាទនោះ មានអង្គប្រកប ៤ យ៉ាង គឺរឿងមិនពិត ១ តាំងចិត្តពោលឲ្យខុស ១ ព្យាយាមពោល ១ អ្នកដទៃយល់អត្ថនោះ ១ ។ ប្រយោគមាន ១ គឺសាហត្ថិកប្បយោគប៉ុណ្ណោះ ។ ប្រយោគនោះគប្បីឃើញថា បានដល់ ការសម្តែងកិរិយារបស់បុគ្គលដែលពោលឲ្យខុសចំពោះអ្នកដទៃ ដោយ

កាយ ដោយរបស់ដែលជាប់ទាក់ទងដោយកាយ ឬដោយវាចា ។ បើមាន អ្នកដទៃយល់អត្ថនោះដោយកិរិយានោះ កិរិយានេះឈ្មោះថា ទាក់ទងដោយ មុសាវាទកម្ម ក្នុងខណៈនៃចេតនា ដែលមានកិរិយាជាសមុដ្ឋាននោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា បិសុណាវាចាជាដើម ។ វាចាដែលជា ហេតុឲ្យហទយៈរបស់បុគ្គល ដែលខ្លួនពោលកើតការស្រឡាញ់ខ្លួន និងស្អប់ អ្នកដទៃ ឈ្មោះថា **បិសុណាវាចា** ។

ឯវាចាដែលជាហេតុធ្វើឲ្យខ្លួនឯងខ្វះ អ្នកដទៃខ្វះ គ្រោតគ្រាត និងវាចា ដែលគ្រោតគ្រាតឯង គឺមិនពីរោះត្រចៀក ឬមិនជាទីត្រេកអររបស់អ្នកស្តាប់ នេះ ឈ្មោះថា **ផរុសវាចា** ។

វាទៈដែលជាហេតុឲ្យចរចាផ្តេសផ្តាស គឺឥតប្រយោជន៍ ឈ្មោះថា **សម្ផប្បលាប** ចេតនាដែលជាមូលដ្ឋាននៃការពោលពាក្យគ្រោតគ្រាត និង ពាក្យផ្តេសផ្តាសទាំងនោះ ក៏បានឈ្មោះថា **បិសុណាវាចា** ជាដើមនោះ ឯង ។ ក្នុងទីនេះ បំណងយកចេតនានោះឯង ។

ចេតនារបស់បុគ្គលដែលមានចិត្តសៅហ្មង ដែលជាសមុដ្ឋាននៃកាយ- ប្បយោគ និងវចីបយោគ ដើម្បីទម្លាយជនដទៃ ឬដើម្បីបំណងនឹងធ្វើខ្លួនឲ្យ ជាទីស្រឡាញ់របស់អ្នកដទៃ ឈ្មោះថា **បិសុណាវាចា** ក្នុងវចីកម្មនេះ ។ បិសុណាវាចានោះ ឈ្មោះថា មានទោសតិច ព្រោះបុគ្គលដែលត្រូវធ្វើឲ្យ បែកគ្នានោះ មានគុណធម៌តិច ឈ្មោះថា មានទោសច្រើន ព្រោះមានគុណ ធម៌ច្រើន ។

បិសុណាវាចានេះ មានអង្គប្រកប ៤ ប្រការ គឺបុគ្គលត្រូវបំបែកជាអ្នកដទៃ ១ ការបែរមុខ និងបំបែកដោយបំណងថា បុគ្គលទាំងនេះនឹងជាអ្នកបែកពីគ្នា ដោយឧបាយយ៉ាងនេះ ឬបំណងថា អញនឹងជាទីស្រឡាញ់ ជាទីស្និទ្ធស្នាលរបស់បុគ្គលនោះ ដោយឧបាយយ៉ាងនេះ រួមជាអង្គ ១ ការព្យាយាមដែលកើតអំពីការតាំងចិត្តនោះ ១ បុគ្គលនោះយល់អត្ថនោះ ១ ។

ចេតនាដែលគ្រោតគ្រាតដោយចំណែកមួយ ដែលជាសមុដ្ឋាននៃកាយប្បយោគ និងវចីបយោគ ដែលជាហេតុ កាត់ផ្តាច់នូវការស្រឡាញ់របស់អ្នកដទៃ ឈ្មោះថា **ផរុសវាចា** ដើម្បីការជាក់ច្បាស់នៃផរុសវាចានោះ មានរឿងសាធក:ដូច្នេះ

បានឮថា យុវជនម្នាក់ មិនស្តាប់បង្គាប់ពាក្យរបស់ម្តាយ ចចេសចូលទៅព្រៃ ម្តាយកាលមិនអាចឃាត់កូនឲ្យត្រឡប់បាន ទើបជេរថា សូមឲ្យមេក្របីកាចដេញវៃធបាចុះ ។ ខាងក្រោយ មេក្របីបានប្រាកដដល់បុរសនោះដូចដែលម្តាយជេរនោះឯង ។ ទើបយុវជនធ្វើសច្ចកិរិយាថា អ្នកម្តាយរបស់ខ្ញុំពោលយ៉ាងណាដោយមាត់ សូមកុំយ៉ាងនោះឡើយ តែគិតយ៉ាងណាដោយចិត្ត សូមឲ្យយ៉ាងនោះចុះ មេក្របីបានទុចងឹក់ក្នុងទីនោះឯង ដូចត្រូវចងទុក ។

វចីបយោគ សូម្បីជាហេតុកាត់បង់នូវពាក្យស្រឡាញ់ គឺពាក្យដែលអាស្រ័យដល់វត្ថុជាទីស្រឡាញ់ដូចពណ៌នាមកនេះ ក៏មិនជាផរុសវាចទេ ព្រោះជាអ្នកមានចិត្តទន់ ។ ពិតហើយ ជួនកាល ឪពុកម្តាយជេរកូនៗ យ៉ាងនេះថា សូមឲ្យពួកចោរកាត់ពួកឯងឲ្យដាច់ជាកំណាត់ៗ ទៅចុះ ទោះយ៉ាងនោះ សូម្បី

តែត្របកឈូកក៏មិនបំណងនឹងឲ្យធ្លាក់ខាងលើពួកកូនៗ នោះឡើយ ។ ជួនកាល អាចារ្យ និងឧបជ្ឈាយ៍ ជជែកជាមួយអន្តេវាសិក និងសទ្ធិវិហារិក ដែលនៅអាស្រ័យទាំងឡាយថា ពួកនេះ និយាយអ្វី ក៏មិនមានកេរ្តិ៍ខ្មាស មិនមានការខ្លាចក្រែង លោកម្ចាស់ទាំងឡាយ ចូរដេញបុគ្គលនេះចេញទៅ ។ ទោះជាដូច្នោះ អាចារ្យ និងឧបជ្ឈាយ៍ទាំងនោះ នៅតែប្រាថ្នាសម្បត្តិ គឺអាគម ( បរិយត្តិ ) និងអធិគម ( បដិវេធ ) ដល់អន្តេវាសិក និងសទ្ធិវិហារិកទាំងនោះ ។

ម្យ៉ាងទៀត វចីបយោគ មិនជាផរុសវាចា ព្រោះជាអ្នកមានចិត្តទន់ភ្លន់ យ៉ាងណា នឹងមិនជាផរុសវាចា ព្រោះបុគ្គលអ្នកនិយាយ មានវាចាទន់ផ្អែម ដូច្នោះក៏ទេ ព្រោះថា វាចារបស់បុគ្គល ដែលបំណងឲ្យបុគ្គលណាមួយស្លាប់ថា ពួកឯង ចូរឲ្យបុគ្គលនេះដេកសប្បាយចុះ ដូច្នេះ មិនមែនជាផរុសវាចា តែវាចានេះ ជាផរុសវាចានោះឯង ព្រោះបុគ្គលពោលមានចិត្តគ្រោតគ្រាត ។

ផរុសវាចានេះ ឈ្មោះថា មានទោសតិច ព្រោះបុគ្គលដែលជាផរុសវាទីពោលសំដៅដល់ ជាបុគ្គលមានគុណតិច ឈ្មោះថា មានទោសច្រើន ព្រោះមានគុណច្រើន ។

ផរុសវាចានោះ មានអង្គប្រកប ៣ ប្រការ គឺអ្នកដែលត្រូវជេរ ជាអ្នកដទៃ ១ ចិត្តអាក់អន់ ១ បានជេរ ១ ។

ការផ្តោតចិត្តដែលជាអកុសល ដែលជាសមុដ្ឋាននៃកាយប្បយោគ និងវចីបយោគ ដែលញុំាងអ្នកដទៃឲ្យយល់វាចាដែលឥតប្រយោជន៍ ឈ្មោះថា

**សម្ផប្បលាប** សម្ផប្បលាបៈនោះ ឈ្មោះថា មានទោសតិច ព្រោះបុគ្គល អ្នកពោលមានអាសេវនៈទន់ខ្សោយ ( ការស្និទ្ធស្នាលតិច ) ឈ្មោះថា មាន ទោសច្រើន ព្រោះបុគ្គលអ្នកពោល មានអាសេវនៈច្រើន ។

សម្ផប្បលាបៈនោះ មានអង្គប្រកប ២ ប្រការ គឺការបែរមុខដែលនឹង ពោលពាក្យឥតប្រយោជន៍ មានរឿងសង្គ្រាមភារតៈ និងរឿងលួចនាងសិតា គឺរឿងរាមកេរ្តិ៍ជាដើម ១ ការពោលពាក្យប្រភេទនោះ ១ ។

ចេតនា ឈ្មោះថា **អភិជ្ឈា** ព្រោះសម្លឹងរំពៃ អធិប្បាយថា រមែង ប្រព្រឹត្តទៅដើម្បីភាពជាអ្នកបែរមុខ សម្លឹងរំពៃ ចំពោះភណ្ឌៈរបស់អ្នកដទៃ ហើយបង្អោនភណ្ឌៈនោះមក អភិជ្ឈានោះ មានលក្ខណៈសម្លឹងភណ្ឌៈរបស់ អ្នកដទៃយ៉ាងនេះថា ធ្វើម្តេចហ្ន៎ ទ្រព្យនេះ គប្បីជារបស់អញ ។ អភិជ្ឈានេះ ឈ្មោះថា មានទោសតិច និងទោសច្រើន ដូចគ្នានឹងអទិន្នាទាន ។

អភិជ្ឈានោះ មានអង្គប្រកប ២ ប្រការ គឺរបស់អ្នកដទៃ ១ បង្អោន ទ្រព្យនោះមកដើម្បីខ្លួន ១ ។

អធិប្បាយថា សូម្បីកើតការលោភ ដែលមានភណ្ឌៈរបស់អ្នកដទៃជាទី តាំងឡើង កម្មបថក៏មិនទាន់ដាច់ លុះតែបង្អោនមកដើម្បីខ្លួនថា ធ្វើម្តេចហ្ន៎ របស់នេះ គប្បីជារបស់អញ ។

បាបធម៌ ឈ្មោះថា **ព្យាបាទ** ព្រោះញុំាងប្រយោជន៍ និងសេចក្តីសុខឲ្យ ដល់នូវការវិនាស ។ **ព្យាបាទ** មានលក្ខណៈប្រទូស្ត ដើម្បីសេចក្តីវិនាស របស់អ្នកដទៃ ។ ព្យាបាទនោះ ឈ្មោះថា មានទោសតិច និងមានទោស

ច្រើន ដូចគ្នានឹងផរុសវាចា ។

ព្យាបាទនោះ មានអង្គប្រកប ២ ប្រការ គឺ សត្វដទៃ ១ គិតឲ្យសត្វនោះវិនាស ១ ។

អធិប្បាយថា កើតការក្រោធដែលមានសត្វដទៃជាទីតាំងឡើង កម្មបថនៅមិនទាន់ដាច់ ដរាបណា ការក្រោធមិនទាន់គិតឲ្យសត្វនោះវិនាសថា ធ្វើម្ដេចហ្ន៎ ទើបសត្វនេះ គប្បីដាច់សូន្យ វិនាសទៅ ។

ចេតនា ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះយល់ខុស ដោយមិនមានការកាន់យកតាមសេចក្ដីពិត មិច្ឆាទិដ្ឋិនោះ មានលក្ខណៈយល់ខុស ដោយន័យជាដើមថា ទានដែលឲ្យហើយមិនមានផល ។ មិច្ឆាទិដ្ឋិនោះ ឈ្មោះថា មានទោសតិច និងមានទោសច្រើន ដូចគ្នានឹងសម្ផប្បលាបៈ ។ ម្យ៉ាងទៀត មិច្ឆាទិដ្ឋិដែលមិនពិតប្រាកដ ឈ្មោះថា មានទោសតិច ដែលពិតប្រាកដគឺទៀង ឈ្មោះថា មានទោសច្រើន ។

មិច្ឆាទិដ្ឋិនោះ មានអង្គប្រកប ២ ប្រការ គឺរឿងខុសអំពីអាការប្រកាន់ ១ ការប្រាកដឡើងនៃរឿងនោះ មិនដូចមិច្ឆាទិដ្ឋិកបុគ្គលប្រកាន់ ១ ។

ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងអកុសលកម្មបថទាំង ១០ នេះ ដោយអាការ ៥ យ៉ាង គឺដោយធម្មតោ ១ ដោយកោដ្ឋាសតោ ១ ដោយអារម្មណតោ ១ ដោយវេទនតោ ១ ដោយមូលតោ ១ ។

បណ្ដាបទទាំងនោះ បទថា **ធម្មតោ** មានអត្ថថា សេចក្ដីពិត ក្នុងចំនួនកម្មបថ ១០ យ៉ាងនេះ កម្មបថ ៧ តាមលំដាប់ គឺកាយកម្ម ៣ វចីកម្ម ៤

ជាចេតនាធម៌ដោយត្រង់ ឯកម្មបថ ៣ មានអភិជ្ឈាជាដើម ជាគួប្រកប ចេតនា ។

បទថា **កោដ្ឋាសតោ** សេចក្ដីថា កម្មបថ ៧ តាមលំដាប់ និងមិច្ឆាទិដ្ឋិ ១ ទៀត រួមជា ៨ នេះ ជាកម្មបថតែម្យ៉ាង មិនជាមូល គឺឫសគល់របស់ អកុសល ឯអភិជ្ឈា និងព្យាបាទ ជាកម្មបថផង ជាមូលផង អធិប្បាយថា ព្រោះជាឫសគល់ ទើបអភិជ្ឈាជាលោភអកុសលមូល ព្យាបាទជាទោស-អកុសលមូល ។

បទថា **អារម្មណតោ** សេចក្ដីថា បាណាតិបាត មានសង្ខារជាអារម្មណ៍ ព្រោះមានជីវិតិន្ទ្រិយជាអារម្មណ៍ អទិន្នាទានមានសត្វជាអារម្មណ៍ក៏មាន មាន សង្ខារជាអារម្មណ៍ក៏មាន មិច្ឆាចារមានសង្ខារជាអារម្មណ៍ ដោយអំណាចនៃ ផោដ្ឋព្វៈ អាចារ្យពួកខ្លះពោលថា មានសត្វជាអារម្មណ៍ក៏មាន ។ មុសាវាទ មានសត្វជាអារម្មណ៍ក៏មាន មានសង្ខារជាអារម្មណ៍ក៏មាន បិសុណាវាចាក៏ ដូចគ្នា ។ ផរុសវាចា មានសត្វជាអារម្មណ៍តែម្យ៉ាង សម្ផប្បលាបៈ មានសត្វ ជាអារម្មណ៍ក៏មាន ដោយអំណាចនៃរូបដែលបានឃើញហើយ សំឡេងដែល បានឮហើយ ក្លិន រស និងផោដ្ឋព្វៈដែលបានជ្រាបហើយ ធម្មារម្មណ៍ដែល បានដឹងហើយ អភិជ្ឈាក៏ដូចគ្នា ព្យាបាទ មានសត្វជាអារម្មណ៍តែម្យ៉ាង ឯ មិច្ឆាទិដ្ឋិ មានសង្ខារជាអារម្មណ៍ ដោយអំណាចនៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

បទថា **វេទនតោ** សេចក្ដីថា បាណាតិបាត មានវេទនាជាទុក្ខ ព្រោះថា

ព្រះរាជាទាំងឡាយឃើញចោរហើយ ដល់នូវការញញឹមបណ្តើរ បញ្ជាបណ្តើរថា ចូរយកវាទៅពិឃាតដូច្នេះក៏ពិត តែទោះជាយ៉ាងនោះ ចេតនាដែលដាក់ព្រះទ័យរបស់ព្រះរាជានោះ ជាចេតនាដែលប្រកបដោយទុក្ខ ។

អទិន្នាទាន មានវេទនា ៣ មិច្ឆាចារមានវេទនា ២ ដោយអំណាចនៃសុខវេទនា និងឧបេក្ខាវេទនា ។ តែមិនមែនមានវេទនាជាឧបេក្ខា ព្រោះចិត្តជាតួហេតុឲ្យដាក់ចិត្ត ។ មុសាវាទមានវេទនា ៣ បិសុណាវាចាក៏ដូចគ្នា ។ ផរុសវាចាមានវេទនាជាទុក្ខតែម្យ៉ាង ។ សម្ផប្បលាបៈមានវេទនា ៣ អភិជ្ឈាមានវេទនា ២ ដោយអំណាចនៃសុខវេទនា និងឧបេក្ខាវេទនា មិច្ឆាទិដ្ឋិក៏ដូចគ្នា តែព្យាបាទមានវេទនាជាទុក្ខ ។

បទថា **មូលតោ** សេចក្តីថា បាណាតិបាត មានអកុសល ២ យ៉ាងជាមូល ដោយអំណាចទោសៈ និងមោហៈ ។ អទិន្នាទាន មានអកុសល ២ យ៉ាងជាមូល ដោយអំណាចនៃទោសៈនិងមោហៈ ឬដោយអំណាចនៃលោភៈនិងមោហៈ មិច្ឆាចារ មានអកុសល ២ យ៉ាងជាមូល ដោយអំណាចលោភៈនិងមោហៈ ។ មុសាវាទ មានមូល ២ ដោយអំណាចទោសៈ និងមោហៈ ឬលោភៈ និងមោហៈ ។ បិសុណាវាចា និងសម្ផប្បលាបៈក៏ដូចគ្នានឹងមុសាវាទ ។ ផរុសវាចាមានមូល ២ ដោយអំណាចនៃទោសៈ និងមោហៈ អភិជ្ឈាមានអកុសល ១ ជាមូល ដោយអំណាចនៃមោហៈ ។ ព្យាបាទក៏ដូចគ្នានឹងអភិជ្ឈា ។ តែមិច្ឆាទិដ្ឋិមានអកុសល ២ ជាមូល ដោយអំណាចនៃលោភៈនិងមោហៈដូច្នេះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **លោភោ អកុសលមូលំ** ជាដើមដូចតទៅនេះ អកុសលធម៌ដែលឈ្មោះថា **លោភ** ព្រោះចង់បាន ។ ដែលឈ្មោះថា **ទោស** ព្រោះប្រទូស្ត ។ ដែលឈ្មោះថា **មោហ** ព្រោះវង្វេង ។

ក្នុងចំនួនអកុសលធម៌ទាំង ៣ យ៉ាងនោះ លោភៈ ឈ្មោះថា ជាអកុសលមូល ព្រោះខ្លួនឯងជាអកុសលផង ព្រោះអត្ថថា មានទោស និងមានទុក្ខជាវិបាក និងជាឫសគល់របស់អកុសលធម៌ទាំងនេះ មានបាណាតិបាតជាដើមផង ព្រោះអត្ថថា ជាសភាពនៃសម្បយុត្តធម៌របស់អកុសលណាមួយ និងព្រោះអត្ថថា ជាឧបនិស្សយប្បច្ច័យរបស់អកុសលធម៌ណាមួយ ។ សមដូចពាក្យដែលព្រះសារីបុត្របានពោលថា អាវុសោ បុគ្គលត្រេកត្រអាលច្រើនហើយ ត្រូវរាគៈគ្របសង្កត់ហើយ មានចិត្តត្រូវរាគៈរួបរឹតហើយ រមែងសម្លាប់នូវសត្វមានជីវិត ដូច្នេះជាដើម ក្នុងទោសៈ និងមោហៈ ជាអកុសលមូល ក៏មានន័យនេះដូចគ្នា ។

# អធិប្បាយ

## កុសលកម្មបថ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **បាណាតិបាតា វេរមណី កុសលំ** ប្រែថា ចេតនាវៀរចាកបាណាតិបាតជាកុសលជាដើមដូចតទៅនេះ អកុសលកម្មបថទាំងឡាយ មានបាណាតិបាតជាដើម មានអធិប្បាយដូចខ្ញុំបានពោលមកហើយនោះឯង ។

ចេតនា ឈ្មោះថា **វេរមណី** ព្រោះញ៉ាំញីនូវពៀរ អធិប្បាយថា លះនូវ

ពៀរបាន ។ ម្យ៉ាងទៀត បុគ្គលវៀរចាកពៀរបាន ព្រោះចេតនានេះជាហេតុ ព្រោះហេតុនោះ ទើបចេតនានោះ ឈ្មោះថា **វេរមណី** ដោយផ្លាស់ **វិ** អក្ខរៈ ឲ្យជា **វេ** អក្ខរៈ ។ នេះជាការពង្រីកសេចក្ដីក្នុងពាក្យថា **វេរមណី** នេះ ដោយព្យញ្ជនៈ ។ ឯការពង្រីកសេចក្ដីដោយអត្ថ គប្បីជ្រាបថា វិរតិដែលសម្បយុត្តដោយកុសលចិត្ត ឈ្មោះថា **វេរមណី** ។ វិរតិរបស់បុគ្គលដែលវៀរចាកបាណាតិបាត ដែលត្រាស់យ៉ាងនេះថា ការវៀរចាកបាណាតិបាតក្នុងសម័យនោះ ដូច្នេះ ឈ្មោះថា ជាវិរតិដែលសម្បយុត្តដោយកុសលចិត្ត ។

វិរតិនោះចែកប្រភេទចេញជា ៣ យ៉ាង គឺសម្បត្តវិរតិ ១ សមាទានវិរតិ ១ សមុច្ឆេទវិរតិ ១ ក្នុងចំនួនវិរតិទាំង ៣ នោះ វិរតិដែលកើតឡើងដល់បុគ្គលដែលមិនបានសមាទានសិក្ខាបទទាំងឡាយ តែបានពិចារណាដល់ជាតិ វ័យ និងការភ្លៀវក្លាជាដើមរបស់ខ្លួនហើយ ឃើញថា មិនសមដល់អញក្នុងការធ្វើយ៉ាងនេះ ហើយមិនកន្លងវត្ថុដែលជួបចំពោះមុខ គប្បីជ្រាបថា ជាសម្បត្តវិរតិ ដូចគ្នានឹងវិរតិរបស់ចក្កនឧបាសក ក្នុងសីហឡទ្វីប ។

## រឿង ចក្កនឧបាសក

បានឮថា ក្នុងវេលានៅជាកំលោះនោះឯង មាតារបស់ចក្កនៈកើតរោគ គ្រូពេទ្យប្រាប់ថា គួរបានសាច់ទន្សាយស្រស់មកប្រកបជាថ្នាំ ។ លំដាប់នោះ បងប្រុសរបស់ចក្កនៈប្រើថា ចូរប្អូនទៅស្រែចុះ ហើយបញ្ជូនចក្កនៈទៅ ។ ចក្កនៈបានទៅត្រង់ស្រែនោះ ។ ក្នុងវេលានោះ មានទន្សាយមួយមកស៊ីស្មៅខ្ចី ។ ទន្សាយឃើញចក្កនៈហើយ ប្រញាប់រត់គេចទៅ តែទៅជាប់នឹងវល្លិ

ទើបបន្លឺសំឡេងកិរិ កិរិ ឡើង ។ ចក្កនៈតាមសំឡេងនោះទៅ ចាប់ទន្សាយនោះបាន តាំងចិត្តថា នឹងយកមកធ្វើថ្នាំឲ្យម្តាយ តែក៏ក្នុកគិតឡើងមកថា មិនសមគួរសម្រាប់អញ ដែលទម្លាយជីវិតសត្វដទៃ ស្រោចស្រង់ជីវិតម្តាយរបស់ខ្លួន ទើបនិយាយថា ទៅចុះទន្សាយ ទៅស៊ីស្មៅ ផឹកទឹកជាមួយទន្សាយទាំងឡាយក្នុងព្រៃចុះ ហើយលែងទៅ កាលត្រឡប់ដល់ផ្ទះ ចក្កនៈត្រូវបងប្រុសសួរថា នែប្អូនប្រុស បានទន្សាយឬទេ ទើបបានប្រាប់ការប្រព្រឹត្តទៅនោះឲ្យជ្រាប វេលានោះ បងប្រុសក៏បានជេរប្រទេចចក្កនៈ ។ ចក្កនៈចូលទៅរកមាតាហើយ បានឈរតាំងសច្ចាធិដ្ឋានថា ខ្ញុំតាំងអំពីកើតមកចាំសេចក្តីបាន មិនធ្លាប់ដាក់ចិត្តសម្លាប់សត្វ បំបាត់ជីវិតឡើយ ។ វេលានោះមាតារបស់ចក្កនៈបានជាសះស្បើយអំពីរោគ ។

តែវិរតិដែលកើតឡើងដល់បុគ្គលសមាទានសិក្ខាបទមកហើយ សូម្បីលះជីវិតរបស់ខ្លួន ក្នុងវេលាសមាទានសិក្ខាបទ និងវេលាបន្ទាប់នោះទៅ ក៏មិនកន្លងល្មើសវត្ថុ គប្បីជ្រាបថា ជាសមាទានវិរតិ ដូចវិរតិរបស់ឧបាសកអ្នកភ្នំឧត្តរវឌ្ឍមានៈ ។

## រឿង ឧបាសកអ្នកភ្នំឧត្តរវឌ្ឍមានៈ

បានឮថា ឧបាសកនោះ ទទួលសិក្ខាបទក្នុងសម្នាក់របស់ព្រះបិង្គលពុទ្ធរក្ខិតត្ថេរក្នុងអម្ពរិយវិហារ ហើយទៅភ្ជួរស្រែ ។ បន្ទាប់មក គោរបស់គាត់បាត់ទៅ កាលគាត់តាមរកគោ បានឡើងភ្នំឧត្តរវឌ្ឍមានៈ ។ ពស់ធំបានរួតគាត់លើភ្នំនោះ ។ គាត់គិតថា នឹងយកកាំបិតដ៏មុតនេះកាត់ក្បាលពស់ តែ

ក៏គិតទៀតថា ការបានសមាទានសិក្ខាបទក្នុងសម្នាក់របស់គ្រូ ដែលគួររាប់អានហើយ ទម្លាយបង់មិនសមគួរឡើយ ។ លុះគិតយ៉ាងនេះអស់វារៈ ៣ ដងហើយ ក៏សម្រេចចិត្តថា អញនឹងលះបង់ជីវិត មិនព្រមលះបង់សិក្ខាបទ ហើយបានគ្រវែងកាំបិតធំ ដែលស្ពាយមកនៅលើស្មា ចូលទៅក្នុងព្រៃ ។ រំពេចនោះ ពស់ធំក៏បានរំសាយខ្លួនចេញ ហើយលូនទៅ ។

ចំណែកវិរតិដែលសម្បយុត្តដោយអរិយមគ្គ គប្បីជ្រាបថា ជាសមុច្ឆេទ-វិរតិ ដែលចាប់ផ្តើមពីកើតហើយ ព្រះអរិយបុគ្គលទាំងឡាយមិនធ្លាប់ សូម្បីតែកើតគំនិតថា អញនឹងសម្លាប់សត្វមានជីវិត ដូច្នេះ ។ តែវិរតិនេះ លោកហៅថា **កុសល** ព្រោះប្រព្រឹត្តទៅដោយការឈ្លាស ។ ម្យ៉ាងទៀត លោកហៅថា **កុសល** ព្រោះកាត់បង់នូវការទ្រុស្តសីល ដែលបានវោហារថា **កុស** ព្រោះកាត់ផ្តាច់នូវបាបអកុសលក៏មាន តែមិនបានហៅថា **កុសល** ព្រោះមិនបានសមគួរនឹងបញ្ហានេះថា អាវុសោ កុសលដូចម្តេច ។

ម្យ៉ាងទៀត កុសលកម្មបថទាំងនេះ ក៏គួរជ្រាបវិនិច្ឆ័យដោយអាការ ៥ យ៉ាង គឺដោយធម្មតោ ១ ដោយកោដ្ឋាសតោ ១ ដោយអារម្មណតោ ១ ដោយវេទនតោ ១ ដោយមូលតោ ១ ដូចនឹងអកុសលកម្មបថទាំងឡាយ ។

បណ្តាបទទាំងនោះ បទថា **ធម្មតោ** សេចក្តីថា ក្នុងចំនួនកុសលកម្មបថទាំងនេះ កម្មបថ ៧ ប្រកបតាមលំដាប់ ជាតួចេតនា តែវិរតិទាំង ៣ ខាងចុង គឺមនោកម្ម ជាធម៌សម្បយុត្តដោយចេតនា ។

បទថា **កោដ្ឋាសតោ** សេចក្តីថា កុសលធម៌ ៧ ប្រការ តាមលំដាប់

ជាកម្មបថតែម្យ៉ាង មិនជាមូលឡើយ ។ តែកុសលធម៌ ៣ ប្រការខាងចុង ជាកម្មបថផង ជាមូលផង អធិប្បាយថា អនភិជ្ឈា ដល់នូវកម្មបថហើយ ទើបឈ្មោះថា ជាអលោភកុសលមូល តែអព្យាបាទ ឈ្មោះថា ជាអទោសកុសលមូល ។ ឯសម្មាទិដ្ឋិ ឈ្មោះថា អមោហកុសលមូល ។

បទថា **អារម្មណតោ** សេចក្តីថា អារម្មណ៍ទាំងឡាយ មានបាណាតិបាតនោះឯង ជាអារម្មណ៍របស់វេរមណី គឺចេតនាវៀរចាកបាណាតិបាតទាំងនោះជាដើម ព្រោះថា វេរមណីមាន ក៏ដោយសារបានជួបនឹងវត្ថុដែលត្រូវកន្លងប៉ុណ្ណោះ ឧបមាដូចអរិយមគ្គ មានព្រះនិព្វានជាអារម្មណ៍ ទើបលះកិលេសបាន យ៉ាងណា កម្មបថទាំងនេះ ក៏គប្បីជ្រាបថា ដូច្នោះដូចគ្នា ត្រូវមានជីវិតិន្ទ្រិយជាអារម្មណ៍ជាដើម ទើបលះនូវការទ្រុស្តសីល មានបាណាតិបាតបាន ។

បទថា **វេទនតោ** សេចក្តីថា កុសលកម្មបថទាំងអស់ ជាសុខវេទនាក៏មាន ជាឧបេក្ខាវេទនាក៏មាន ព្រោះថា ដល់កុសលហើយ មិនមានទុក្ខវេទនា គឺកម្មបថខាងកុសល មិនឲ្យផលជាទុក្ខឡើយ ។

បទថា **មូលតោ** សេចក្តីថា កម្មបថ ៧ មានមូល ៣ តាមអំណាចនៃអលោភៈ អទោសៈ និងអមោហៈ សម្រាប់បុគ្គលដែលវៀរដោយចិត្តសម្បយុត្តដោយញាណ តែមានមូល ២ សម្រាប់បុគ្គលដែលវៀរដោយចិត្តប្រាសចាកបញ្ញា ។ អនភិជ្ឈាមានមូល ២ សម្រាប់បុគ្គលដែលវៀរដោយញាណសម្បយុត្តចិត្ត មានមូល ១ សម្រាប់បុគ្គលដែលវៀរដោយចិត្ត ជា

ញាណវិប្បយុត្ត តែអលោភៈខ្លួនឯងមិនជាឫសគល់របស់ខ្លួនឡើយ សូម្បីក្នុងអព្យាបាទ ក៏មានទំនងដូចគ្នានេះឯង ។

សម្មាទិដ្ឋិ មានមូល ២ ដូចគ្នាតាមអំណាចរបស់អលោភៈ និងអទោសៈ ដូច្នេះ ។

កុសលធម៌ ឈ្មោះថា **អលោភ** ក្នុងពាក្យថា **អលោភោ កុសលមូលំ** ជាដើម ព្រោះមិនលោភ ។ ពាក្យថា **អលោភោ** នេះ ជាឈ្មោះរបស់ធម៌ដែលជាចំណែកផ្ទុយគ្នានឹងលោភៈ ។ សូម្បីក្នុងអទោសៈ និងអមោហៈ ក៏មានទំនងដូចគ្នានេះឯង ។

ក្នុងចំនួនកុសលមូលទាំង ៣ យ៉ាងនោះ **អលោភ** ឈ្មោះថា **កុសលមូល** ព្រោះខ្លួនក៏ជាកុសល និងឈ្មោះថា ជាមូលរបស់កុសលធម៌ទាំងឡាយមានការវៀរចាកបាណាតិបាតទាំងនេះជាដើមផង ព្រោះអត្ថថា ជាសភាពនៃសម្បយុត្តធម៌របស់កុសលពួកខ្លះ ព្រោះអត្ថថា ជាឧបនិស្សយប្បច្ច័យរបស់កុសលធម៌ពួកខ្លះ ។ ក្នុងភាពដែលអទោសៈ និងអមោហៈជាកុសលមូល ក៏ន័យដូចគ្នានេះឯង ។

ឥឡូវនេះ ព្រះសារីបុត្រ កាលបញ្ចប់អត្ថទាំងអស់នោះ ដែលលោកបានសម្តែងហើយ ទាំងដោយសង្ខេប និងដោយពិស្តារ ទើបបានពោលអប្បនាវារៈថា **យតោ ខោ អាវុសោ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឯវំ អកុសលំ បជានាតិ** សេចក្តីថា ដឹងច្បាស់នូវអកុសល ដោយអំណាចអកុសលកម្មបថ ១០ តាមដែលបាន

សម្តែងមកហើយយ៉ាងនេះ ។ ក្នុងបទថា **ឯវំ អកុសលមូលំ** ជាដើម ក៏ដូចគ្នានេះឯង ។

ដោយហេតុមានប្រមាណប៉ុណ្ណេះ គឺដោយន័យតែមួយដូចគ្នា ឈ្មោះថា ព្រះសារីបុត្របានពោលដល់កម្មដ្ឋាន ជាហេតុនាំសត្វចេញទៅចាកភព រហូតដល់ព្រះអរហត្ត សម្រាប់បុគ្គលបំពេញកម្មដ្ឋាន មានចតុរារិយសច្ចជាអារម្មណ៍ ។

សេចក្តីនេះ លោកបានពោលដូចម្តេច លោកពោលថា សេចក្តីពិតអកុសលកម្មបថ ១០ និងកុសលកម្មបថ ១០ វៀរអភិជ្ឈា លោកពោលថា ជាទុក្ខសច្ចក្នុងកម្មបថវារៈនេះ ឯធម៌ទាំង ២ យ៉ាងនេះ គឺអភិជ្ឈា ១ លោភៈដែលជាអកុសលមូល ១ លោកពោលថា ជាសមុទយសច្ចដោយត្រង់ ។ តែកម្មបថទាំងអស់ លោកពោលថា ជាទុក្ខសច្ចដោយអម ។ កុសលមូលនិងអកុសលមូលទាំងអស់ លោកពោលថា ជាសមុទយសច្ច ។ ការមិនប្រព្រឹត្តទៅនៃកុសលមូល និងអកុសលមូលទាំង ២ លោកពោលថា ជានិរោធសច្ច ។ កាលកំណត់ដឹងទុក្ខ កាលលះសមុទយសច្ច កាលដឹងច្បាស់នូវនិរោធ អរិយមគ្គ លោកពោលថា ជាមគ្គសច្ច សច្ចៈទាំង ២ លោកបានពោលហើយដោយសរុប ដូចពណ៌នាមកនេះ ។ ចំណែកសច្ចៈ ២ យ៉ាង គឺនិរោធ និងមគ្គ គប្បីជ្រាបដោយអំណាចនៃការមិនវិលត្រឡប់ ។

បទថា **សោ សព្វសោ រាគានុសយំ បហាយ** ប្រែថា លោកលះបង់រាគានុស័យបានដោយប្រការទាំងពួង សេចក្តីថា លោកដឹងច្បាស់នូវអកុសល

ជាដើមយ៉ាងនោះ លះរាគានុស័យបានដោយអាការគ្រប់យ៉ាង ។

បទថា **បដិឃានុសយំ បដិវិនោទេត្វា** ប្រែថា បន្ទោបង់នូវបដិឃា-នុស័យ មានពាក្យដែលលោកពោលថា នាំបដិឃានុស័យចេញបានដោយប្រការទាំងពួងនោះឯង ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះថេរៈបានពោលដល់អនាគាមិមគ្គ ។

បទថា **អស្មីតិ ទិដ្ឋិមានានុសយំ សមូហនិត្វា** ប្រែថា ដកនូវទិដ្ឋិ-មានានុស័យ ថាអាត្មាអញមានចោល សេចក្តីថា ដកឡើងនូវទិដ្ឋិមានា-នុស័យ ដែលប្រព្រឹត្តទៅដោយអាការប្រកាន់រួមគ្នា ថាអញមាន ដោយធ្វើធម៌ប្រការខ្វះក្នុងខន្ធ ៥ មិនឲ្យធ្លាក់ចុះ ។

បណ្តាបទទាំងនោះ បទថា **ទិដ្ឋិមានានុសយំ** លោកអធិប្បាយថា បានដល់ មានានុស័យដែលដូចគ្នានឹងទិដ្ឋិ ។ ព្រោះថា មានានុស័យនេះដូចគ្នានឹងទិដ្ឋិ ព្រោះមានលក្ខណៈប្រព្រឹត្តទៅហើយ ថាអញមាន ព្រោះដូច្នោះទើបលោកពោលយ៉ាងនេះ ។ ម្យ៉ាងទៀត បុគ្គលបំណងនឹងយល់ក្នុងអស្មិមានៈនេះដោយពិស្តារ គួរពិនិត្យមើលក្នុងខេមកសូត្រ ក្នុងខន្ធវារវគ្គផងចុះ ។

បទថា **អវិជ្ជំ បហាយ** សេចក្តីថា ប្រហារអវិជ្ជាដែលជាឫសគល់របស់វដ្តៈ ។ បទថា **វិជ្ជំ ឧប្បាទេត្វា** សេចក្តីថា ឲ្យវិជ្ជា គឺអរហត្តមគ្គដែលកម្ចាត់បង់អវិជ្ជានោះកើតឡើង ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះសារីបុត្របានពោលដល់អរហត្តមគ្គ ។

ពាក្យថា **ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ** ប្រែថា ជាអ្នកធ្វើទីបំផុត

នៃទុក្ខក្នុងបច្ចុប្បន្ននេះឯង សេចក្តីថា ជាអ្នកធ្វើការកាត់ផ្តាច់នូវវដ្តទុក្ខ ក្នុងអត្តភាពនេះឯង ។

ព្រះសារីបុត្រញ៉ាំងទេសនាឲ្យចប់ ដោយពាក្យថា **ឯត្តាវតាបិ ខោ អាវុសោ** អធិប្បាយថា ដោយអំណាចនៃការចាក់ធ្លុះ ដោយមនសិការដូចពោលហើយ ក្នុងការសម្តែងកម្មបថនេះ ។ ពាក្យដែលនៅសេសសល់ មានន័យដូចពោលមកហើយនោះឯង ។

ព្រះសារីបុត្រ បានបញ្ចប់ទេសនា ដោយអនាគាមិមគ្គ និងអរហត្តមគ្គ ដូចបានពណ៌នាមកនេះឯង ។

**ពោលអំពី កម្មបថ ចប់**

# អធិប្បាយ អាហារវារៈ
# ភូត និងសម្ភវេសី

[ ១១២ ] ក្នុងពាក្យថា **សាធាវុសោ ខោ ។បេ។ អាគតោ ឥមា សទ្ធម្មំ** មានពាក្យអធិប្បាយថា ភិក្ខុទាំងនោះ កាលបានស្តាប់ព្រះធម៌ទេសនា ពោលដោយសច្ចៈទាំង ៤ របស់ព្រះសារីបុត្រដោយប្រធាន គឺកុសល និងអកុសល យ៉ាងនេះហើយ ទើបនាំគ្នាសរសើរភាសិតរបស់ព្រះសារីបុត្រ ដោយពាក្យនេះថា សាធុ លោកម្ចាស់ និងអនុមោទនាដោយចិត្តដែលជាសមុដ្ឋានរបស់ពាក្យនេះឯង ទទួលយកដោយវាចា ត្រេកអរដោយចិត្តនោះឯង ។

ឥឡូវនេះ ព្រោះហេតុដែលព្រះថេរៈជាអ្នកអាចសម្តែងធម្មទេសនា ដោយចតុរារិយសច្ចបាន ដូចដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រអាចពោលសម្តែងអរិយសច្ច ៤ បានដោយពិស្តារ ។ ព្រោះហេតុដែលព្រះសារីបុត្រត្រូវសម្តែងធម៌ឲ្យខ្ពស់ឡើង ទើបបានពោលថា **ឯត្តាវតាបិ ខោ អាវុសោ** ប្រែថា នែអាវុសោ មានប្រមាណប៉ុណ្ណេះឯង ព្រោះហេតុនោះ ភិក្ខុទាំងឡាយបំណងនឹងស្តាប់សច្ចទេសនាដោយន័យដទៃ ក៏បានសួរបញ្ហាខ្ពស់ឡើងទៅជាមួយព្រះសារីបុត្រ ។ ទើបភិក្ខុទាំងនោះ សួរបញ្ហាដទៃខ្ពស់ឡើងទៅដោយន័យថា បពិត្រលោកម្ចាស់ បរិយាយដទៃនៅមានទៀតឬ គឺហេតុដទៃដែលខ្ពស់ជាងបញ្ហាដែលលោកម្ចាស់សួរឯង ឆ្លើយឯងមកហើយ ។

ម្យ៉ាងទៀត មានពាក្យអធិប្បាយថា ភិក្ខុទាំងនោះ បាននាំគ្នាសួរបញ្ហាក្នុងចំណែកខាងលើជាងបញ្ហាមុនឡើងទៅ ។ ម្យ៉ាងទៀត លោកអធិប្បាយថា ភិក្ខុទាំងឡាយសួរបញ្ហាដំបូងឲ្យខ្ពស់ឡើងមួយជាន់ទៅទៀត ។

[ ១១៣ ] បន្ទាប់អំពីនោះ ព្រះថេរៈកាលព្យាករបញ្ហាឲ្យភិក្ខុទាំងនោះស្តាប់ ទើបពោលពាក្យថា **សិយា អាវុសោ** នែអាវុសោ នៅមានតទៅទៀតដូច្នេះជាដើម ។

ក្នុងចំនួនបទទាំងនោះ ពាក្យពង្រីកតទៅនេះ នឹងជាពាក្យពង្រីកសេចក្តីចំពោះបទដែលលំបាក ។

ពាក្យថា **អាហារ** បានដល់ បច្ច័យ ។ ព្រោះបច្ច័យនាំផលមកឲ្យខ្លួន

ដូច្នោះ ទើបបច្ច័យ ហៅថា **អាហារ** ។

ពួកសត្វដែលបដិសន្ធិកើតហើយ ឈ្មោះថា **ភូត** ក្នុងពាក្យទាំងឡាយ មានពាក្យថា **ភូតានំ វា សត្តានំ** ជាដើម ។

ពួកសត្វដែលស្វែងរក គឺស្វែងរកសម្ភវៈ គឺការកើត បានដល់ ការកើតឡើង ឈ្មោះថា **សម្ភវេសី** ។

បណ្តាកំណើតទាំង ៤ ប្រភេទនោះ សត្វដែលកើតក្នុងស៊ុត និងដែលកើតក្នុងតំណក់ទឹក ដរាបណាមិនទាន់ទម្លាយសម្បកស៊ុត និងស្បូនចេញមកដរាបនោះ ក៏នៅតែឈ្មោះថា **សម្ភវេសី** លុះកាលណាទម្លាយសម្បកស៊ុត និងស្បូនចេញមកខាងក្រៅហើយ ទើបឈ្មោះថា **ភូត** ។

ឯសត្វដែលកើតអំពីញើស និងឧបបាតិ ក្នុងខណៈនៃចិត្តដួងដំបូង ឈ្មោះថា **សម្ភវេសី** តាំងអំពីខណៈនៃចិត្តដួងទី ២ ទៅ ឈ្មោះថា **ភូត** ។

ម្យ៉ាងទៀត សត្វទាំងឡាយ ទោះកើតដោយឥរិយាបថណាក៏ដោយ ល្មមណា នៅមិនទាន់ផ្លាស់ឥរិយាបថដទៃចាកឥរិយាបថនោះ ដរាបនោះ ឈ្មោះថា **សម្ភវេសី** បន្ទាប់អំពីឥរិយាបថនោះទៅ ទើបឈ្មោថា **ភូត** ។

ម្យ៉ាងទៀត ពួកសត្វដែលកើតហើយ គឺកើតឡើងហើយ ឈ្មោះថា **ភូត** ។ ព្រះខីណាស្រពពួកណា ដែលជាព្រះអរិយៈហើយនោះឯង រាប់ថាមិនកើតទៀត ពាក្យថា **ភូត** នេះ ជាឈ្មោះរបស់ព្រះខីណាស្រពទាំងនោះ ។

សត្វពួកណា កំពុងស្វែងរកការកើត សត្វទាំងនោះ ឈ្មោះថា **សម្ភ-វេសី** ពាក្យថា **សម្ភវេសី** នេះ ជាឈ្មោះរបស់ព្រះសេក្ខៈ និងបុថុជ្ជន ដែល

កំពុងស្វែងរកការកើតតទៅ ព្រោះមិនទាន់លះសំយោជនៈក្នុងភពបាន ។

កាលបើដូច្នេះ ដោយពីរបទនេះ ក្នុងទីគ្រប់អន្ទើ ទើបអត្ថគ្របដណ្តប់ដល់សត្វគ្រប់ប្រភេទ ។ **វា** សព្វ ក្នុងពាក្យថា **ភូតានំ វា សត្តានំ** នេះ ជាសម្បិណ្ឌនត្ថៈ ( មានអត្ថរួម មិនប្រើជាវិកប្បត្ថ ) ។ ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបថា ស្មើគ្នានឹងអត្ថនេះថា **ភូតានំ ច សម្ភវេសីនញ្ច** ភូតផង សម្ភវេសីផង ។ បទថា **ឋិតិយា** បានដល់ ដើម្បីតាំងនៅ ។

បទថា **អនុគ្គហាយ** បានដល់ ដើម្បីអនុគ្រោះ គឺដើម្បីឧបការៈ ។

ទាំងពីរបទ គឺ **ភូតានំ វា សម្ភវេសីនំ** នោះ មានការប្លែកផ្សេងគ្នាត្រឹមតែពាក្យពោលប៉ុណ្ណោះ តែអត្ថរបស់បទទាំងពីរនោះ តែមួយដូចគ្នានោះឯង ។

បទថា **ឋិតិយា** ប្រែថា ដើម្បីតាំងនៅ គឺដើម្បីមិនឲ្យធម៌ទាំងឡាយដែលកើតឡើងហើយដល់សត្វនោះៗ ដាច់ទៅដោយប្រការជាប់តគ្នាបាន ។

បទថា **អនុគ្គហាយ** ប្រែថា ដើម្បីអនុគ្រោះ បានដល់ ដើម្បីឲ្យធម៌ដែលមិនទាន់កើត បានកើតឡើង ។

ទាំងពីរបទនេះ គួរប្រើក្នុងអត្ថទាំងគូយ៉ាងនេះថា ដើម្បីការតាំងនៅ និងដើម្បីអនុគ្រោះភូតទាំងឡាយផង ដើម្បីការតាំងនៅ និងដើម្បីអនុគ្រោះសម្ភវេសីទាំងឡាយផង ។

អាហារដែលត្រូវធ្វើឲ្យជាពំនូតៗ ហើយទំពាស៊ី ឈ្មោះថា **កពឡិង្ការាហារ** ។ ពាក្យថា **កពឡិង្ការាហារ** នេះ ជាឈ្មោះរបស់ឱជៈ មានបាយ

និងទំស្រស់ជាដើមជាទីតាំង ។

ពីរបទថា **ឱឡារិកោ វា សុខុមោ វា** សេចក្តីថា អាហារ ឈ្មោះថា **ឱឡារ** ព្រោះជាវត្ថុដែលគ្រោតគ្រាត ដោយវត្ថុ ឈ្មោះថា **សុខុម** ព្រោះជាវត្ថុដែលល្អិតដោយវត្ថុ ។

តែដោយសភាវៈ កពឡិង្ការាហារ ឈ្មោះថា ជារបស់ល្អិតនោះឯង ព្រោះជារបស់ទាក់ទងក្នុងសុខុមរូប ។ សូម្បីការដែលអាហារនោះ ជារបស់គ្រោតគ្រាត និងជារបស់ល្អិតដោយវត្ថុ ក៏ត្រូវដឹងបាន ព្រោះឧបាទាយរូប ។ សេចក្តីពិត អាហាររបស់ក្ងោក ឈ្មោះថា ជារបស់ល្អិត ព្រោះប្រៀបធៀបនឹងអាហារក្រពើ បានឮថា ពួកក្រពើលេបដុំថ្មចូលទៅ ដុំថ្មទាំងនោះ លុះធ្លាក់ដល់ពោះរបស់ក្រពើប៉ុណ្ណោះ ក៏រលួយអស់ទៅ ។ ពួកក្ងោក ស៊ីសត្វមានជីវិត ដូចជាពស់ និងខ្ទួយជាដើម ។ តែអាហាររបស់ពួកឆ្កែ ឈ្មោះថា ជារបស់ល្អិត ព្រោះប្រៀបធៀបនឹងអាហាររបស់ក្ងោក បានឮថា ឆ្កែស្រុកទាំងនោះ អង្កៀមស្នែង និងឆ្អឹងសត្វដែលចោលអស់ ៣ ឆ្នាំបាន ស្នែង និងឆ្អឹងសត្វទាំងនោះ គ្រាន់តែសើមទឹកមាត់របស់ឆ្កែប៉ុណ្ណោះ ក៏ផុយដូចគ្នានឹងមើមដំឡូង ។

អាហាររបស់ពួកដំរី ឈ្មោះថា ជារបស់ល្អិត ព្រោះប្រៀបធៀបនឹងអាហាររបស់ឆ្កែស្រុក ពួកដំរីស៊ីមែកឈើច្រើនប្រភេទ ។ អាហាររបស់សត្វទាំងឡាយ ដូចជា គោព្រៃ រមាស និងម្រឹគជាដើម ឈ្មោះថា ជារបស់ល្អិតជាងអាហារដំរី បានឮថា ពួកម្រឹគទាំងនោះ នាំគ្នាស៊ីស្លឹកឈើច្រើនប្រភេទ

ដែលមិនរឹងជាដើម ។ អាហាររបស់ពួកគោ ឈ្មោះថា ជាអាហារល្អិតជាង អាហាររបស់គោព្រៃជាដើមនោះ ពួកគោស៊ីស្មៅស្រស់ និងស្មៅក្រៀម ។ អាហាររបស់ទន្សាយ ជាអាហារល្អិតជាងអាហារគោទាំងនោះ ។ អាហាររបស់បក្សីល្អិតជាងអាហាររបស់ពួកទន្សាយ ។ អាហាររបស់ពួកអ្នកជាយដែន ល្អិតជាងអាហាររបស់ពួកបក្សី ។ អាហាររបស់ពួកមេស្រុក ល្អិតជាងអាហាររបស់អ្នកជាយដែន ។ អាហាររបស់ព្រះរាជា និងមហាមាត្យរបស់ព្រះរាជា ល្អិតជាងអាហាររបស់មេស្រុក ។ ព្រះក្រយាហាររបស់ស្តេចចក្រពត្តិ ល្អិតជាងអាហាររបស់ជនទាំងនោះ ។ អាហាររបស់ពួកភុម្មទេវតាល្អិតជាងអាហាររបស់ស្តេចចក្រពត្តិ ។ អាហាររបស់ពួកទេវតាជាន់ចាតុម្មហារាជិកា ល្អិតជាងអាហាររបស់ពួកភុម្មទេវតា អាហាររបស់ពួកទេវតាជាន់ផ្សេងៗ ក៏ពង្រីកឲ្យពិស្តារយ៉ាងនេះទៅ រហូតដល់ពួកទេវតាជាន់បរនិម្មិតវសវត្តី ។ អាហាររបស់ទេវតាជាន់ទាំងនោះ ឈ្មោះថា ជាអាហារល្អិតទាំងអស់ ។ម្យ៉ាងទៀត ក្នុងវត្ថុគ្រោតគ្រាតនេះ ឱជាក៏តិច មានកម្លាំងតិច ក្នុងវត្ថុល្អិត ឱជាមានកម្លាំងច្រើន ។ ពិតហើយ បុគ្គលហុតបបរពេញមួយបាត្រមួយអន្ទាំស្វាប៉ុណ្ណោះក៏ឃ្លាន ចង់ទំពាស៊ីរបស់ណាមួយទៀតនោះឯង ។ ឯបុគ្គលហុតសប្បិត្រឹមតែមួយទូកដៃ ក៏មិនចង់បរិភោគ គឺមិនឃ្លានអស់មួយថ្ងៃ ។ ក្នុងចំនួនវត្ថុ និងឱជា ២ យ៉ាងនោះ វត្ថុបន្ទោបង់សេចក្តីក្រវល់ក្រវាយ គឺការឃ្លានបាន តែមិនអាចរក្សាជីវិតបានឡើយ ។ ឯឱជារក្សាជីវិតបាន តែមិនអាចបន្ទោបង់សេចក្តីក្រវល់ក្រវាយ គឺការឃ្លានបានឡើយ ។ ទាំង ២

យ៉ាងនោះរួមចូលគ្នាហើយ បន្ទាបង់ការក្រវល់ក្រវាយ គឺការឃ្លានបានផង រក្សាជីវិតបានផង ដូច្នេះឯង ។

បទថា **ផស្សោ ទុតិយោ** សេចក្តីថា ផស្សៈទាំង ៦ មានចក្ខុសម្ផស្ស ជាដើម គប្បីជ្រាបថា ជាអាហារបែបទី ២ ក្នុងចំនួនអាហារ ៤ យ៉ាងនោះ ។

ឯន័យនេះ ជាន័យនៃទេសនាប៉ុណ្ណោះ ព្រោះដូច្នោះ ដោយហេតុនេះ ទើបមិនគួរស្វែងរកពាក្យនេះថា អាហារទី ២ និងទី ៣ ក្នុងអាហារវារៈនេះ ។

ចេតនានោះឯង លោកហៅថា **មនោសញ្ចេតនា** ។

ចិត្តដូងណាមួយ ឈ្មោះថា **វិញ្ញាណ** ។

ក្នុងរឿងនេះ ព្រះសារីបុត្របានពោលថា បើមានពាក្យសួរថា សត្វ មានជីវិតតាំងនៅបាន ព្រោះបច្ច័យ មានជីវិតតាំងនៅបាន ព្រោះអាហារ បើ ដូច្នោះ ហេតុអ្វី កាលបច្ច័យរបស់សត្វទាំងឡាយដទៃមាន ទើបទ្រង់ត្រាស់ តែអាហារ ៤ យ៉ាងប៉ុណ្ណោះ ។

ខ្ញុំនឹងឆ្លើយថា ព្រះអង្គត្រាស់ ព្រោះជាបច្ច័យពិសេសនៃសន្តតិជាខាង ក្នុង អធិប្បាយថា កពឡិង្ការាហារ ជាបច្ច័យពិសេសរបស់រូបកាយនៃសត្វ ទាំងឡាយ ដែលមានកពឡិង្ការាហារជាកិច្ចា ផស្សាហារជាបច្ច័យពិសេសនៃ វេទនាក្នុងពពួកនាម មនោសញ្ចេតនាហារ ជាបច្ច័យពិសេសរបស់វិញ្ញាណ វិញ្ញាណជាបច្ច័យពិសេសរបស់នាមរូប ។ ដូចព្រះមានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រាងកាយនេះ អាស្រ័យអាហារ ទើបជីវិតស្ថិតនៅបាន មិនមានអាហារ ជីវិតស្ថិតនៅមិនបានឡើយ យ៉ាងណា ។ ដូចជាវេទនា កើត

មាន ព្រោះផស្សៈជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ នាមរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដូច្នោះ ។

សួរថា ក្នុងបញ្ហាវារៈនេះ អាហារណានាំអ្វីមកឲ្យ ឆ្លើយថា កពឡិង្ការាហារ នាំរូប មានឱជាជាគម្រប់ ៨ មកឲ្យ គឺអវិនិព្ភោគរូបមកឲ្យ ផស្សាហារ នាំវេទនា ៣ មកឲ្យ មនោសញ្ចេតនាហារ នាំភព ៣ មកឲ្យ វិញ្ញាណាហារ នាំនាមរូបក្នុងបដិសន្ធិមកឲ្យ ។

សួរថា នាំមកឲ្យដូចម្ដេច ឆ្លើយថា នាំមកឲ្យយ៉ាងនេះ ជាបឋម កពឡិង្ការាហារគ្រាន់តែដាក់ក្នុងមាត់ប៉ុណ្ណោះ ក៏ញ៉ាំងរូប ៨ ឲ្យតាំងឡើង ។ ឯដុំបាយតែមួយពំនូតដែលធ្មេញទំពាឲ្យល្អិតលេបចូលទៅ ក៏ញ៉ាំងរូប ១ កលាបៈ ៨ រូបប៉ុណ្ណោះ ។ កពឡិង្ការាហារ មានឱជាជាគម្រប់ ៨ មកឲ្យយ៉ាងនេះ ។ ឯផស្សាហារ គឺផស្សៈដែលឲ្យកើតសុខវេទនា កាលកើតឡើង នាំសុខវេទនាមកឲ្យ ។ ផស្សៈដែលនាំទុក្ខវេទនាក៏ដូច្នោះ គឺនាំទុក្ខមកឲ្យ ដែលឲ្យកើតអទុក្ខមសុខវេទនា ក៏នាំអទុក្ខមសុខមកឲ្យ ។ ផស្សាហារ នាំវេទនាទាំង ៣ មកឲ្យដោយប្រការទាំងពួង ដូចពណ៌នាមកនេះ ។

មនោសញ្ចេតនាហារ គឺកម្ម ដែលឲ្យចូលដល់កាមភព នាំកាមភពមកឲ្យ ។ ដែលឲ្យចូលដល់រូបភព និងអរូបភព ក៏នាំរូបភព និងអរូបភពមកឲ្យ ។ មនោសញ្ចេតនាហារ នាំភពទាំង ៣ មកឲ្យយ៉ាងនេះ ដោយប្រការទាំងពួង ។

តែវិញ្ញាណាហារលោកពោលថា នាំខន្ធទាំង ៣ ដែលសម្បយុត្តដោយ

វិញ្ញាណនោះ និងរូប ៣០ ដែលកើតឡើង ដោយអំណាចសន្តតិ ៣ មកឲ្យ ដោយន័យរបស់បច្ច័យ មានសហជាតប្បច្ច័យជាដើម ក្នុងបដិសន្ធិក្ខណៈ ។ វិញ្ញាណាហារ នាំនាមរូបក្នុងបដិសន្ធិក្ខណៈមកឲ្យយ៉ាងនេះ ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងអាហារវារៈនេះ កុសលចេតនា និងអកុសលចេតនា ដែលនៅមានអាសវៈនោះឯង លោកពោលថា មនោសញ្ចេតនាហារ នាំភព ទាំង ៣ មកឲ្យ បដិសន្ធិវិញ្ញាណនោះឯង លោកពោលថា វិញ្ញាណ នាំនាម រូបក្នុងបដិសន្ធិក្ខណៈមកឲ្យ ។ តែអាហារ ៣ យ៉ាងនេះ គប្បីជ្រាបថា ជាអាហារ ដោយមិនប្លែកគ្នា ព្រោះនាំមកនូវធម៌ដែលសម្បយុត្តដោយវិញ្ញាណ នោះ និងធម៌ដែលជាសមុដ្ឋាននៃវិញ្ញាណនោះ ។

ក្នុងចំនួនអាហារ ៤ យ៉ាងនោះ កពឡិង្ការាហារ កាលគាំទ្រជីវិត រមែង ឲ្យសម្រេចកិច្ច គឺការនាំរូបមក ។ ផស្សៈ កាលពាល់ត្រូវនោះឯង រមែងឲ្យ សម្រេចកិច្ច គឺនាំវេទនាមក ។ មនោសញ្ចេតនា កាលប្រមូលមកនោះឯង រមែងឲ្យសម្រេចកិច្ច គឺការនាំភពមក ។ វិញ្ញាណ កាលដឹងនោះឯង រមែង ឲ្យសម្រេចកិច្ច គឺការនាំរូបក្នុងបដិសន្ធិក្ខណៈមក ។

សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា សេចក្តីពិត កពឡិង្ការាហារ កាលឧបត្ថម្ភជីវិតនោះឯង មានការធ្វើសត្វទាំងឡាយឲ្យតាំងនៅ ដោយឲ្យ កាយតាំងនៅ ព្រោះថា រាងកាយនេះ សូម្បីកម្មតាក់តែងឲ្យកើតកពឡិង្កា- រាហារ ក៏ឧបការៈទុក ទើបតាំងនៅបាន រហូតដល់អាយុក្ខ័យ ១០ ឆ្នាំក្តី ២០ ឆ្នាំក្តី ដូចទារកដែលមាតាឲ្យកើតហើយ មេដោះឲ្យបៅជាដើម ចិញ្ចឹមមើលថែ

ទើបតាំងនៅបានយូរ ដូច្នេះ ដូចផ្ទះដែលប្រើបង់បាញ់ទល់ ដូច្នោះ ។

ដូចលោកពោលទុកថា សូមថ្វាយព្រះពរមហារាជ កាលផ្ទះទៀបរលំ មនុស្សទាំងឡាយ យកឈើដទៃមកទល់ ផ្ទះនោះ ត្រូវឈើដទៃទល់ ក៏តាំងនៅបាន កាលបើដូច្នេះ ផ្ទះនោះនឹងមិនរលំ យ៉ាងណា សូមថ្វាយព្រះពរមហារាជ រាងកាយនេះ ក៏ដូច្នោះដូចគ្នានោះឯង តាំងនៅបាន ព្រោះអាហារ អាស្រ័យអាហារ ទើបតាំងនៅបាន ។ កពឡិង្ការាហារ កាលឧបការៈរាងកាយយ៉ាងនេះ រមែងឈ្មោះថា ឲ្យសម្រេចកិច្ចរបស់អាហារ គឺនាំរូបមក និងកាលឲ្យសម្រេចអាហារកិច្ចយ៉ាងនេះ កពឡិង្ការាហារក៏ឈ្មោះថា ជាបច្ច័យរបស់រូបសន្តតិ ២ យ៉ាង គឺជាបច្ច័យរបស់រូប ដែលមានអាហារជាសមុដ្ឋានផង រូបដែលតណ្ហា និងទិដ្ឋិកាន់យកហើយផង ។ កពឡិង្ការាហារ ជាវត្ថុដែលតាមរក្សាកម្មជរូប និងជាអ្នកឲ្យកំណើតដល់រូប ដែលមានអាហារជាសមុដ្ឋាន តាំងនៅបាន ។

ឯផស្សៈ កាលពាល់ត្រូវអារម្មណ៍ ដែលជាទីតាំងនៃសេចក្តីសុខជាដើមនោះឯង ឈ្មោះថា មានដើម្បីការតាំងនៅនៃសត្វទាំងឡាយ ដោយការវិលទៅនៃសុខវេទនាជាដើម ។

មនោសញ្ចេតនា កាលប្រមូលមក ដោយអំណាចនៃកុសលកម្ម និងអកុសលកម្មនោះឯង ឈ្មោះថា មានដើម្បីការតាំងនៅនៃសត្វទាំងឡាយ ដោយការញ៉ាំងឫសគល់នៃភពឲ្យសម្រេច ។

វិញ្ញាណ កាលដឹងនោះឯង ឈ្មោះថា មានដើម្បីការតាំងនៅនៃសត្វ

ទាំងឡាយ ដោយការប្រព្រឹត្តទៅនៃនាមរូប ។

ក្នុងអាហារទាំង ៤ យ៉ាងនេះ ដែលឲ្យសម្រេចអាហារកិច្ច ដោយអំណាចនៃការឧបត្ថម្ភជាដើម គួរឃើញភ័យ ៤ ប្រការយ៉ាងនេះ គឺក្នុងកពឡិង្ការាហារ បានដល់ ភ័យ គឺការស្រឡាញ់ គឺចង់បានក្នុងផស្សាហារ បានដល់ ភ័យ គឺការជាប់ជំពាក់នោះឯង ក្នុងមនោសញ្ចេតនាហារ បានដល់ ភ័យ គឺការប្រមូលមក គឺសន្សំនោះឯង ក្នុងវិញ្ញាណាហារ បានដល់ ភ័យ គឺការធ្លាក់ចុះចំពោះ គឺបដិសន្ធិនោះឯង ។

សួរថា ភ័យព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា សត្វទាំងឡាយធ្វើភ័យ គឺការប្រាថ្នាក្នុងកពឡិង្ការាហារ បែរមុខចំពោះការរងាជាដើម ធ្វើការងារមានការរាប់ដោយមេដៃជាដើមដើម្បីអាហារ រមែងចូលដល់ទុក្ខមិនមែនតិច ។ និងបុគ្គលពួកខ្លះទៀត សូម្បីបួសក្នុងសាសនានេះ ក៏ស្វែងរកអាហារ ដោយការស្វែងរកមិនសមគួរ មានវេជ្ជកម្មជាដើម ជាបុគ្គលត្រូវនិន្ទាក្នុងបច្ចុប្បន្ននេះ ។ ក្នុងសម្បរាយភព ក៏ជាសមណប្រេត ដោយន័យដែលបានពោលមកហើយ ក្នុងលក្ខណសំយុត្ត មានជាដើមថា សូម្បីសង្ឃាដីរបស់អ្នក ត្រូវភ្លើងឆេះសន្ធោសន្ធៅហើយ ការប្រាថ្នាក្នុងកពឡិង្ការាហារនោះឯង គប្បីជ្រាបថា ជាភ័យ ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ។

ជនទាំងឡាយ មានអស្សាទក្នុងផស្សៈ កាលជួបផស្សៈ ក៏បៀតបៀនទ្រព្យទាំងឡាយ មានប្រពន្ធជាដើមរបស់អ្នកដទៃ ដែលគេរក្សាគ្រប់គ្រង ម្ចាស់ទ្រព្យចាប់បុគ្គលនោះ ព្រមដោយភស្តុតាង កាប់ឲ្យដាច់ជាកំណាត់ៗ

បោះចោលត្រង់គំនរសំរាម ឬប្រគល់ខ្លួនដល់ព្រះរាជា ។ បន្ទាប់អំពីនោះ ព្រះរាជាក៏ត្រាស់ឲ្យពួកបុគ្គលនោះ ធ្វើកម្មករណៈប្រភេទផ្សេងៗ គឺដាក់ទោស ។ និងព្រោះកាយបែកធ្លាយទៅ ពួកបុគ្គលនោះ ជាទីសង្ស័យមបាន ទទួលនូវភ័យ គឺទុគ្គតិ ។ កម្មដែលមានអស្សាទក្នុងផស្សៈជាមូល ជាហេតុឲ្យជួបនូវភ័យក្នុងបច្ចុប្បន្នផង សម្បរាយកពនោះឯងផង ដោយប្រការនេះ ។ ព្រោះហេតុនេះ ការជាប់ជំពាក់ក្នុងផស្សាហារនេះឯង គប្បីជ្រាបថា ជាភ័យ ។ តែភ័យក្នុងភពទាំង ៣ ដែលមានកុសល និងអកុសលកម្មនោះជាមូល នឹងមកទាំងអស់ ព្រោះការប្រមូលមកនូវកុសលកម្ម និងអកុសលកម្មនោះឯង ព្រោះហេតុនេះ ការប្រមូលមកនូវមនោសញ្ចេតនាហារនោះឯង គប្បីជ្រាបថា ជាភ័យ ។

ឯបដិសន្ធិវិញ្ញាណ ក៏ទទួលយកបដិសន្ធិនាមរូបនោះឯង កើតឡើងក្នុងទីដែលបដិសន្ធិ កាលបដិសន្ធិវិញ្ញាណនោះកើតឡើងហើយ ភ័យគ្រប់យ៉ាង ក៏ឈ្មោះថា កើតឡើងដូចគ្នា ព្រោះមានបដិសន្ធិនោះជាឫសគល់ ព្រោះហេតុដូចពណ៌នាមកនេះឯង បដិសន្ធិគប្បីជ្រាបថា ជាភ័យក្នុងវិញ្ញាណាហារដូច្នេះឯង ។

តែក្នុងពួកអាហារទាំង ៤ យ៉ាងនេះ ក៏ជាភ័យយ៉ាងនេះ ដើម្បីឲ្យគ្របសង្កត់ការប្រាថ្នាក្នុងកពឡិង្ការាហារ ទើបព្រះមានព្រះភាគ ទ្រង់សម្តែងការប្រៀបធៀបដោយសាច់កូន ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ប្តីប្រពន្ធទាំង ២ នោះ យ៉ាងណា ។

ដើម្បីឲ្យគ្របសង្កត់ការប្រាថ្នាក្នុងផស្សាហារ ទើបទ្រង់សម្តែងការប្រៀបធៀបដោយមេគោ ដែលពន្លាត់ស្បែក ដោយន័យជាដើមថា ម្នាលភិក្ខុទាំង-ឡាយ មេគោដែលពន្លាត់ស្បែកហើយ ... យ៉ាងណា ។

ដើម្បីឲ្យគ្របសង្កត់ការប្រាថ្នាក្នុងមនោសញ្ចេតនាហារ ទើបទ្រង់សម្តែងការប្រៀបធៀបដោយរណ្តៅរងើកភ្លើង ដោយន័យជាដើមថា ម្នាលភិក្ខុទាំង-ឡាយ រណ្តៅរងើកភ្លើង ... យ៉ាងណា ។

ដើម្បីឲ្យគ្របសង្កត់ការប្រាថ្នាក្នុងវិញ្ញាណាហារ ទើបទ្រង់សម្តែងការប្រៀបធៀបចាក់នឹងលំពែង ៣០០ ដើម ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ... នូវចោរដែលប្រព្រឹត្តអាក្រក់ យ៉ាងណា ។

នេះជាការប្រកបអត្ថដោយសង្ខេប ដោយអធិប្បាយឲ្យជាក់ច្បាស់ ក្នុងអាហារវារៈនេះ ។

បានឮថា ប្តីប្រពន្ធ នាំគ្នាពបុត្រ ដើរផ្លូវកន្តារ ១០០ យោជន៍ ដោយស្បៀងតិចតួច កាលដើរទៅបាន ៥០ យោជន៍ ស្បៀងអស់ ។

ជនទាំង ២ សោប់សោល់ ព្រោះការស្រេកឃ្លាន នាំគ្នាអង្គុយក្រោមម្លប់ឈើដែលគ្មានស្លឹក បន្ទាប់អំពីនោះ បុរសជាស្វាមីបាននិយាយនឹងភរិយាថា នែនាង អស់រយៈ ៥០ យោជន៍ជុំវិញនេះ មិនមានស្រុក ឬនិគមឡើយ ព្រោះដូច្នោះ ឥឡូវនេះ អញមិនអាចនឹងធ្វើការជាច្រើន ដែលបុរសគប្បីធ្វើបាន មានការធ្វើស្រែ និងចិញ្ចឹមគោជាដើមបានឡើយ ណ្ហើយចុះ ចូរនាងសម្លាប់អញ ហើយបរិភោគសាច់មួយចំណែក មួយចំណែកទៀត យកធ្វើជា

ស្បៀង ធ្វើដំណើរឆ្លងផ្លូវកន្តារ ទៅជាមួយកូនចុះ ។

ឯនាងជាភរិយា បានពោលនឹងស្វាមីថា បពិត្រអ្នក ឥឡូវនេះ ប្អូនមិនអាចនឹងធ្វើការងារដែលស្រីត្រូវធ្វើ មានការរវៃអំបោះជាដើមជាច្រើនបានឡើយ ណ្ហើយចុះ សូមអ្នកសម្លាប់ប្អូន ស៊ីសាច់មួយចំណែក មួយចំណែកទៀត យកធ្វើជាស្បៀង ធ្វើដំណើរឆ្លងផ្លូវកន្តារ ទៅជាមួយកូនចុះ ។

ឯបុរសជាស្វាមី បានពោលនឹងភរិយាទៀតថា នែនាង ព្រោះមេផ្ទះស្លាប់ ការស្លាប់នឹងប្រាកដដល់យើងឪកូន ព្រោះកូនតូច បើគ្មានមាតាហើយ ធ្វើម្តេចមានជីវិតអាចនៅបាន តែបើយើងទាំង ២ នៅមានជីវិត ក៏នឹងបានកូនទៀត ណ្ហើយចុះ ឥឡូវនេះ យើងសម្លាប់កូនយកសាច់ស៊ី ឆ្លងផ្លូវកន្តារទៅចុះ ។

លំដាប់នោះ ម្តាយបានពោលនឹងកូនថា នែកូន ចូរទៅរកឪពុករបស់កូនចុះ ។ កូនក៏បានទៅរកឪពុក ។ បន្ទាប់អំពីនោះ ឪពុករបស់កូនពោលថា អញបានសោយទុក្ខមកមិនមែនតិច ព្រោះការធ្វើស្រែចិញ្ចឹមគោ ដោយសង្ឃឹមថា នឹងចិញ្ចឹមកូន ទើបអញមិនអាចសម្លាប់កូនបាន នាងនោះឯង ចូរសម្លាប់កូនរបស់នាង ដូច្នេះហើយ បានប្រាប់កូនថា នែកូន ចូរទៅរកម៉ែរបស់កូនចុះ កូនក៏ទៅរកម៉ែ សូម្បីម៉ែរបស់កូននោះ ក៏បានពោលថា ខ្ញុំកាលចង់បានកូន បានសោយទុក្ខទារុណមិនមែនតិច ដោយការប្រព្រឹត្តខ្លួនដូចជាគោ ប្រព្រឹត្តខ្លួនដូចជាឆ្កែ និងអង្វរសូមចំពោះទេវតាជាដើម មិនទាន់ពោលដល់ការពពោះ ទើបខ្ញុំមិនអាចសម្លាប់កូនបាន ហើយបានប្រាប់ថា នែ

កូន ចូរទៅរកឪពុកចុះ ។ កូននោះ កាលដើរទៅដើរមក ក្នុងចន្លោះឪពុកម្តាយទាំង ២ នោះ ក៏បានស្លាប់ឯង ។

ពីរនាក់ប្តីប្រពន្ធនោះ ឃើញកូនរបស់ខ្លួនស្លាប់ នាំគ្នាសោកសង្រេង យកសាច់កូនមកស៊ី ហើយចៀសចេញទៅ តាមន័យដែលបានពោលហើយខាងដើម ជនទាំងពីរនោះ មិនបានយកសាច់កូនស៊ី ជាអាហារដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីទ្រទ្រង់នូវគ្រឿងប្រដាប់ មិនមែនដើម្បីតាក់តែងស្អិតស្អាង តែដើម្បីឆ្លងឲ្យផុតផ្លូវកន្តារតែម្យ៉ាងប៉ុណ្ណោះឯង ព្រោះជារបស់បដិកូល ដោយហេតុ ៩ ប្រការ ។

សួរថា បដិកូលដោយហេតុ ៩ ប្រការដូចម្តេច ឆ្លើយថា ព្រោះជាសាច់ដែលកើតអំពីខ្លួន ១ ព្រោះជាសាច់របស់ញាតិ ១ ព្រោះជាសាច់របស់កូន ១ ព្រោះជាសាច់របស់កូនជាទីស្រឡាញ់ ១ ព្រោះជាសាច់ក្មេងតូច ១ ព្រោះជាសាច់ឆៅ ១ ព្រោះជាសាច់ដែលមិនមែនជាចំណី ១ ព្រោះមិនបានដាក់អំបិល ១ ព្រោះមិនបានអាំង ១ ។

ព្រោះដូច្នោះ ភិក្ខុណា ឃើញកពឡិង្ការាហារដូចជាសាច់កូនយ៉ាងនេះ លោកគ្របសង្កត់នូវការប្រាថ្នា ក្នុងកពឡិង្ការាហារនោះបាន នេះជាការប្រកបសេចក្តីក្នុងការឧបមាដោយសាច់កូន ជាបឋម ។

ឯក្នុងការប្រៀបធៀបដោយមេគោដែលពន្លាត់ស្បែក គប្បីជ្រាបដូចតទៅ មេគោនោះ គេពន្លាត់ស្បែកអំពីក រហូតដល់ក្រចកអស់ ហើយលែងទៅ គោត្រូវសត្វមានជីវិតខាំស៊ី នៅក្នុងទីដែលខ្លួនអាស្រ័យនៅ ។ មានតែរៀង

ទុក្ខប៉ុណ្ណោះ យ៉ាងណា សូម្បីផស្សៈក៏ដូច្នោះដូចគ្នា អាស្រ័យវត្ថុ ឬអារម្មណ៍ណាមួយ ស្ថិតនៅ នឹងមានតែរឿងទុក្ខដែលបានសោយហើយប៉ុណ្ណោះ ដែលកើតអំពីវត្ថុ និងអារម្មណ៍នោះ ។

ព្រោះដូច្នោះ ភិក្ខុណាឃើញផស្សាហារ ដូចគ្នានឹងមេគោដែលគេពន្លាត់ស្បែកយ៉ាងនេះ ភិក្ខុនោះនឹងគ្របសង្កត់ការប្រាថ្នាក្នុងផស្សាហារនោះបាន ។ នេះជាការប្រកបក្នុងការឧបមា ដូចមេគោដែលគេពន្លាត់ស្បែក ។

តែក្នុងការប្រៀបធៀប ដោយរណ្ដៅរងើកភ្លើង គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ភពទាំង ៣ ដូចគ្នានឹងរណ្ដៅរងើកភ្លើង ព្រោះអត្ថថា ក្ដៅធំច្រើន មនោសញ្ចេតនា ដូចគ្នានឹងបុរស ២ នាក់ នាំគ្នាចាប់ដើមដៃ អូសទម្លាក់ចូលទៅក្នុងរណ្ដៅរងើកភ្លើងនោះ ព្រោះអត្ថថា ទាញទម្លាក់ចូលទៅក្នុងភពទាំងឡាយ ព្រោះដូច្នោះ ភិក្ខុណាឃើញមនោសញ្ចេតនាហារថា ដូចគ្នានឹងរណ្ដៅរងើកយ៉ាងនេះ ភិក្ខុនោះ នឹងគ្របសង្កត់ការប្រាថ្នាក្នុងមនោសញ្ចេតនាហារបាន នេះជាការប្រកបសេចក្ដី ក្នុងការប្រៀបធៀបដោយរណ្ដៅរងើកភ្លើង ។

ក្នុងការប្រៀបធៀប ការត្រូវចាក់ដោយលំពែង ៣០០ លំពែង គប្បីជ្រាបអធិប្បាយដូចតទៅនេះ ក្នុងវេលាព្រឹកបុរសម្នាក់ឈឺចាប់ ព្រោះលំពែង ១០០ លំពែងណា ។ ចំនួនលំពែងនោះចាក់រាងកាយរបស់បុរសនោះ ឲ្យធ្លុះរហូត ១០០ កន្លែង ធ្លុះទៅមិនឈប់នៅក្នុងចន្លោះ ហើយក្នុងកាលតមក ក៏ដកចេញទៅ លំពែង ២០០ ដើមដទៃទៀតក៏យ៉ាងនោះ កាលបើដូច្នោះ ទូ

ទាំងរាងកាយ ទើបសុសសព្វអស់ ព្រោះលំពែងច្រើនដើម ដែលចាក់ទម្លុះទៅមិនចំឱកាសដែលលំពែង ១០០ ដើមពីមុននោះចាក់ទម្លុះទៅហើយ ។ ទុក្ខរបស់បុរសនោះកើតឡើងព្រោះមុខដំបៅ សូម្បីមួយកន្លែង ក៏មិនអាចនឹងប្រមាណស្រាប់ហើយ នឹងពោលទៅថ្វីដល់ទុក្ខដែលកើតឡើង ព្រោះស្នាមលំពែង ៣០០ កន្លែង ។

បណ្ដាហេតុការណ៍ទាំងនោះ បដិសន្ធិ ដូចគ្នានឹងវេលាដែលលំពែងពាល់ត្រូវ ការកើតឡើងនៃខន្ធ ដូចគ្នានឹងការកើតព្រោះមុខរបួស ការកើតឡើងនៃទុក្ខច្រើនប្រការ មានវដ្តៈជាមូល មានព្រោះខន្ធទាំងឡាយ ដែលកើតហើយ ដូចការកើតឡើងនៃទុក្ខវេទនា ព្រោះមុខរបួសទាំងឡាយ ។

ម្យ៉ាងទៀត បដិសន្ធិវិញ្ញាណ ដូចបុរសដែលប្រព្រឹត្តអាក្រក់ នាមរូបមានព្រោះវិញ្ញាណជាបច្ច័យ ដូចមុខដំបៅដែលកើតឡើងដល់បុរសនោះ ព្រោះត្រូវលំពែងទាំងឡាយទម្លុះហើយ ។ គប្បីឃើញការកើតឡើងនៃទុក្ខ មានប្រការផ្សេងៗ សម្រាប់វិញ្ញាណ ព្រោះមាននាមរូបជាបច្ច័យ ដោយអំណាចនៃកម្មករណៈ ៣២ ប្រការ និងរោគ ៩៨ ប្រភេទជាដើម ដូចការកើតឡើងនៃទុក្ខដ៏ទម្ងន់ដល់បុរសនោះ ព្រោះមានមុខដំបៅជាបច្ច័យ ។

ព្រោះដូច្នោះ ភិក្ខុណាឃើញវិញ្ញាណាហារថា ដូចគ្នានឹងការចាក់ទម្លុះដោយលំពែង ៣០០ យ៉ាងនេះ ភិក្ខុនោះ នឹងគ្របសង្កត់ការប្រាថ្នាក្នុងវិញ្ញាណាហារបាន នេះជាការប្រកបសេចក្ដីក្នុងការប្រៀបធៀប ដោយការចាក់ដោយលំពែង ៣០០ ។

លោកកាលគ្របសង្កត់ការប្រាថ្នា ក្នុងអាហារទាំងនេះយ៉ាងនេះថា ឈ្មោះថា រមែងកំណត់ដឹងអាហារទាំង ៤ យ៉ាង ។ កាលកំណត់ដឹងអាហារទាំងនោះហើយ វត្ថុដែលកំណត់ដឹងទាំងអស់ ក៏ឈ្មោះថា កំណត់ដឹងដូចគ្នា ។

សមដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើកំណត់ដឹងកវឡិង្កាហារហើយ ក៏ឈ្មោះថា បានកំណត់ដឹងរាគៈ ដែលប្រព្រឹត្តទៅក្នុងកាមគុណទាំង ៥ ដែរ កាលបើកំណត់ដឹងរាគៈ ដែលប្រព្រឹត្តទៅក្នុងកាមគុណទាំង ៥ ហើយ អរិយសាវកដែលប្រកបដោយសំយោជនៈណាហើយ ត្រូវត្រឡប់មកកាន់លោកនេះម្ដងទៀត សំយោជនៈនោះមិនមានទេ ។

ម្នាលភិក្ខុទាំងឡាយ កាលបើកំណត់ដឹងផស្សាហារហើយ ក៏ឈ្មោះថា បានកំណត់ដឹងនូវវេទនាទាំងបីដែរ កាលបើកំណត់ដឹងនូវវេទនាទាំងបីហើយ តថាគតពោលថា កិច្ចណាមួយ ដែលអរិយសាវកត្រូវធ្វើតទៅទៀត មិនមានឡើយ ។

ម្នាលភិក្ខុទាំងឡាយ កាលបើកំណត់ដឹងនូវមនោសញ្ចេតនាហារហើយ ក៏ឈ្មោះថា បានកំណត់ដឹងនូវតណ្ហាបីដែរ កាលបើកំណត់ដឹងនូវតណ្ហាទាំងបីហើយ តថាគតពោលថា កិច្ចណាមួយ ដែលអរិយសាវក ត្រូវធ្វើតទៅទៀត មិនមានឡើយ ។

ម្នាលភិក្ខុទាំងឡាយ កាលបើកំណត់ដឹងវិញ្ញាណាហារហើយ ក៏ឈ្មោះថា បានកំណត់ដឹងនូវនាម និងរូបដែរ កាលបើកំណត់ដឹងនូវនាម និងរូបហើយ តថាគតពោលថា កិច្ចណាមួយ ដែលអរិយសាវក ត្រូវធ្វើតទៅទៀត

មិនមានឡើយ ។

បទថា **តណ្ហាសមុទយា អាហារសមុទយោ** មានអត្ថថា ព្រោះតណ្ហាមុនកើតឡើង សមុទយៈ គឺការកើតឡើងនៃអាហារទាំងឡាយ ដែលមានមកអំពីបដិសន្ធិ រមែងមានឡើង ។

សួរថា មានដូចម្តេច ឆ្លើយថា មានយ៉ាងនេះ គឺក្នុងខណៈនៃបដិសន្ធិមានឱជាកើតឡើងហើយខាងក្នុងរូប ៣០ ដែលកើតឡើងដោយអំណាចនៃសន្តតិ ៣ នេះ គឺកពឡិង្ការាហារដែលជាឧបាទិន្នក ( មានចិត្តគ្រប់គ្រង ) កើតឡើងហើយ ព្រោះតណ្ហាជាបច្ច័យ ។ ឯផស្សាហារ មនោសញ្ចេតនាហារ និងវិញ្ញាណាហារ ជាឧបាទិន្នកទាំងនេះ គឺផស្សៈ និងចេតនាដែលសម្បយុត្តដោយបដិសន្ធិចិត្ត និងវិញ្ញាណ គឺតួចិត្តកើតឡើងហើយ ព្រោះមានតណ្ហាជាបច្ច័យ ដូច្នេះឯង ។

គប្បីជ្រាបការកើតឡើងនៃអាហារទាំងឡាយ ដែលមានមកអំពីបដិសន្ធិ ព្រោះបុរិមតណ្ហាកើតឡើង ដូចពណ៌នាមកនេះជាបឋម ។

តែព្រោះហេតុដែលអាហារវារៈនេះ ព្រះសារីបុត្រពោលដល់អាហារដែលលាយឡំគ្នា ជាអាហារផង ជាឧបាទិន្នកផង និងដែលជាអនុបាទិន្នកផង ដូច្នោះ ទើបគួរជ្រាបការកើតឡើងនៃអាហារ ព្រោះតណ្ហាកើតឡើងយ៉ាងនេះ សម្រាប់អាហារទាំងឡាយ ដែលជាអនុបាទិន្នកដូចតទៅនេះ

សេចក្តីពិត ឱជៈ មាននៅក្នុងរូបទាំងឡាយដែលតាំងឡើងអំពីលោភសហគតចិត្ត ៨ ដួងនេះ គឺកពឡិង្ការាហារដែលជាអនុបាទិន្នក ដែលកើត

ឡើងហើយ ព្រោះតណ្ហាដែលកើតឡើងព្រមគ្នាជាបច្ច័យ ចំណែកផស្សៈ ១ចេតនាដែលសម្បយុត្តដោយចិត្តដែលសហគតៈដោយលោភៈ ១ វិញ្ញាណគឺតួចិត្តខ្លួនឯង ១ រួមទាំង ៣ យ៉ាងនេះ បានដល់ ផស្សាហារ មនោ-សញ្ចេតនាហារ និងវិញ្ញាណាហារដែលជាអនុបាទិន្នកកើតឡើងហើយ ព្រោះមានតណ្ហាជាបច្ច័យ ដូច្នេះឯង ។

ពីរបទថា **តណ្ហានិរោធា អាហារនិរោធោ** សេចក្តីថា ការរលត់នៃអាហាររមែងប្រាកដ ព្រោះការរលត់នៃតណ្ហា ដែលជាបច្ច័យរបស់អាហារទាំងឡាយ ជាឧបាទិន្នកផង ជាអនុបាទិន្នកផង ដូច្នេះ ។

ពាក្យដ៏សេស មានន័យដូចដែលបានពោលហើយនោះឯង ។

ក្នុងអាហារវារៈនេះ ព្រះសារីបុត្របានពោលដល់សច្ចៈទាំង ៤ ដោយសរុបហើយ ។ គ្រប់វារៈក្រៅអំពីនេះ លោកក៏បានពោលដូចក្នុងអាហារវារៈនេះ ព្រោះហេតុនោះឯង អ្នកសិក្សាមិនវង្វេង គួរលើកសច្ចៈទាំងឡាយឡើងក្នុងគ្រប់វារៈ ។ ការប្រមូលទេសនាក្នុងគ្រប់វារៈថា **ឯត្តាវតាបិ ខោ អាវុសោ** នេះ គួរប្រកបដោយអំណាចនៃធម៌ដែលសម្តែងហើយ ក្នុងវារៈនោះ នេះជាការប្រកបអត្ថនោះក្នុងវារៈនេះ ជាបឋម ។

បទថា **ឯត្តាវតាបិ** នេះ សេចក្តីថា ដោយទេសនារឿងអាហារនេះ មានអធិប្បាយថា សូម្បីដោយអំណាចនៃការចាក់ធ្លុះ ដោយមនសិការដែលពោលមកហើយ ក្នុងបទទាំងអស់ក៏ទំនង គឺមានន័យដូច្នេះ ។

**អធិប្បាយអាហារវារៈ ចប់**

## អធិប្បាយ សច្ចវារៈ

[ ១១៤ ] ឥឡូវនេះ ភិក្ខុទាំងនោះ កាលនាំគ្នាសរសើរនូវអនុមោទនាកាសិតរបស់ព្រះថេរៈនោះ ដោយន័យដែលបានពោលមកហើយខាងដើមថា **សាធាវុសោ** ហើយបានសួរបញ្ហាខ្ពស់ឡើងទៅទៀត ព្រះថេរៈក៏បានដោះស្រាយប្រស្នា ដោយទំនងដទៃដល់ភិក្ខុទាំងនោះ ។ គ្រប់វារៈក្រៅអំពីវារៈនេះ ក៏មានន័យដូច្នេះ ។

[ ១១៥ ] ព្រោះដូច្នោះ បន្ទាប់អំពីនេះទៅ ខ្ញុំនឹងពង្រីកសេចក្ដីរបស់បរិយាយដែលព្រះថេរៈបានដោះស្រាយហើយ មិនអាស្រ័យដល់ពាក្យបែបនេះ ។ តែការសម្ដែងដោយសង្ខេបនូវវារៈនេះ ព្រះថេរៈបានសម្ដែងទុក្ខសច្ចថា **ទុក្ខ** ក្នុងពាក្យថា **ទុក្ខញ្ច បជាធាតិ** ។ ឯក្នុងការសម្ដែងដោយពិស្ដារពាក្យដែលត្រូវពោលទាំងអស់ បានពោលហើយក្នុងសច្ចនិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

### អធិប្បាយសច្ចវារៈ ចប់

## អធិប្បាយ ជរាមរណវារៈ

[ ១១៧ ] បន្ទាប់អំពីនេះទៅ ជាទេសនាពោលដោយបដិច្ចសមុប្បាទ ។ ក្នុងចំនួនវារៈទាំងនោះ ជាបឋមគប្បីជ្រាបវិនិច្ឆ័យក្នុងជរាមរណវារៈដូច្នេះ

បទថា **តេសំ តេសំ** នេះ ជាការសម្ដែងទូទៅដល់សត្វជាច្រើនដោយសង្ខេប ។ ព្រោះថា កាលពោលអស់មួយថ្ងៃយ៉ាងនេះថា ការចាស់របស់ទេវទត្តភិក្ខុយ៉ាងណា ការចាស់របស់សោមទត្តយ៉ាងណា ... ដូច្នេះ សត្វទាំង

ឡាយនឹងមិនដល់នូវការគ្រប់គ្រង គឺមិនគ្របដណ្តប់ទៅដល់សត្វទាំងអស់ តែដោយបទទាំង ២ នេះ ( **តេសំ តេសំ** ) សត្វណាមិនត្រូវគ្របដណ្តប់ទៅមិនមាន ។ ព្រោះដូច្នោះ ទើបខ្ញុំពោលថា បទនេះជាការសម្តែងទូទៅ ដល់សត្វចំនួនច្រើនដោយសង្ខេប ។

បទទាំង ២ ថា **តម្ហិ តម្ហិ** នេះ ជាការសម្តែងទូទៅដល់ពួកសត្វចំនួនច្រើន ដោយអំណាចនៃការកើតក្នុងគតិ ។

បទថា **សត្តនិកាយេ** ជាការសម្តែងសរុបដល់សត្វដែលបានសម្តែងហើយ ដោយសាធារណនិទ្ទេស ។

បទថា **ជរា** ក្នុងបទទាំងឡាយ មានបទថា **ជរា ជីរណតា** ជាដើម ជាការសម្តែងដល់សភាវធម៌ ។

បទថា **ជីរណតា** ជាការសម្តែងដល់អាការ ។

បទទាំងឡាយ មាន **ខណ្ឌិច្ចំ** ជាដើម ជាការសម្តែងដល់កិច្ចរបស់ជរា ព្រោះកន្លងកាលវេលាទៅ ។

ពីរបទខាងក្រោយ ជាការសម្តែងដល់កិច្ចតាមប្រក្រតី ។ ព្រោះថា ជរានេះ ព្រះសារីបុត្រសម្តែងដោយសភាវៈ ដោយបទថា **ជរា** ព្រោះដូច្នោះ ទើបបទនេះ ជាបទសម្តែងដល់សភាវៈនៃជរានោះ ។

ដោយបទថា **ជីរណតា** នេះ ព្រះថេរៈបានសម្តែងដោយអាការ ព្រោះដូច្នោះ ទើបបទនេះ ជាបទសម្តែងដល់អាការរបស់ជរានោះ ។

ដោយបទថា **ខណ្ឌិច្ចំ** នេះ ព្រះថេរៈបានសម្តែងដោយកិច្ច គឺការធ្វើ

ភាវៈនៃធ្មេញ និងក្រចកដែលបាក់ជាចំណែកៗ ព្រោះកន្លងកាលវេលាទៅ ។

ដោយបទថា **ខាណ្ឌិច្ចំ** នេះ ព្រះថេរៈបានសម្ដែងដោយកិច្ច គឺការធ្វើភាវៈដែលសក់ និងរោមស្កូវ ។ ដោយបទថា **វលិត្តចតា** នេះ ព្រះថេរៈបានសម្ដែងដោយកិច្ច គឺការធ្វើឲ្យសាច់ និងស្បែកជ្រីវជ្រួញ ។ ដោយហេតុនោះ សព្ទទាំង ៣ មាន **ខណ្ឌិច្ចំ** ជាដើមនេះ ទើបជាសព្ទសម្ដែងដល់កិច្ចនៃជរានោះ ព្រោះកន្លងកាលវេលាទៅដោយសព្ទទាំង ៣ នោះ ព្រះថេរៈបានសម្ដែងដល់ជរាដែលប្រាកដ គឺជាវត្ថុដែលប្រាកដដោយអំណាចឃើញនូវការវិការទាំងនេះបាន ។

ឧបមាថា ផ្លូវរបស់ទឹកប្រាកដឲ្យឃើញបាន ព្រោះក្ដួចយកស្មៅ និងដើមឈើជាដើមឲ្យរាបទៅ ឬផ្លូវរបស់ភ្លើងប្រាកដឲ្យឃើញបាន ព្រោះស្មៅ និងដើមឈើជាដើមឆេះ ។ ផ្លូវទឹកជាដើមនោះ ក៏មិនមែនទឹកជាដើមនោះឡើយ គឺមយ៉ាង យ៉ាងណា ដំណើររបស់ជរា ក៏ដូច្នោះដូចគ្នា ជាធម្មជាតប្រាកដឲ្យឃើញក្នុងអវយវៈទាំងឡាយ មានធ្មេញជាដើម ដោយអំណាចនៃការវិការទាំងឡាយ មានការបាក់ជាដើម បុគ្គលទោះបិទភ្នែកហើយ ក៏ប៉ះពាល់បាន ។ ដំណើររបស់ជរានោះ ដោយអំណាចនៃការវិការទាំងឡាយ មានការបាក់ជាដើម ក៏មិនមែនជរា ។ ព្រោះជរា ជាធម្មជាតដឹងមិនបាន ដោយចក្ខុឡើយ ( ដឹងបានដោយបញ្ញា ) ។

តែដោយបទទាំងនេះថា **អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ** ព្រះថេរៈបានសម្ដែងជរាតាមប្រក្រតី ព្រោះការអស់ទៅនៃអាយុ ជាវត្ថុដែលដឹង

បាន អំពីការធ្លិននៃឥន្ទ្រិយ មានចក្ខុជាដើម ព្រោះការឈានកន្លងកាលវេលាប៉ុណ្ណោះ ព្រោះលោកជាអ្នកឈ្លាសក្រៃលែង ។

ព្រោះដូច្នោះ អាការ ២ ខាងក្រោយនេះ គប្បីជ្រាបថា ជាការសម្តែងអាការតាមប្រក្រតីរបស់ជរានោះ ។

បណ្តាអាយុ និងឥន្ទ្រិយទាំង ២ យ៉ាងនោះ ព្រោះអាយុរបស់បុគ្គលដែលដល់នូវការចាស់ រមែងអស់ទៅច្រើន ព្រោះដូច្នោះ ទើបលោកពោលជរា ដោយជិតចំពោះផល គឺសេចក្តីស្លាប់ថា បានដល់ ការអស់ទៅនៃអាយុគឺអាយុច្រើន ។

តែព្រោះកាលនៅជាកំលោះ ឥន្ទ្រិយទាំងឡាយ មានភ្នែកជាដើមនៅស្រស់ថ្លា អាចទទួលយកអារម្មណ៍ ( មានរូបជាដើម ) របស់ខ្លួន ដែលល្អិតបានដោយងាយ កាលចូលដល់ជរាហើយ នឹងធ្លិនល្អក់ មិនស្រស់ថ្លាអារម្មណ៍របស់ខ្លួន ទោះគ្រោតគ្រាត ក៏មិនអាចនឹងទទួលបាន ដូច្នោះ ទើបជរា ព្រះថេរៈពោលដោយការជិតចំពោះផលថា ការចាស់នៃឥន្ទ្រិយទាំង-ឡាយ ។ ម្យ៉ាងទៀត ជរានេះ គឺជរាទាំងអស់ដែលសម្តែងមកហើយយ៉ាងនេះមាន ២ យ៉ាង គឺបាកដជរា ជរាដែលប្រាកដ ១ បដិច្ឆន្នជរា ជរាដែលកំបាំង ១ ។ ក្នុងចំនួនជរាទាំង ២ យ៉ាងនោះ ការចាស់ក្នុងរូបធម៌ទាំងឡាយ ឈ្មោះថា **បាកដជរា** ព្រោះសម្តែងការវិការ មានការបាក់ជាដើមក្នុងអវយវៈទាំង-ឡាយ មានធ្មេញជាដើមឲ្យឃើញ ឯក្នុងអរូបធម៌ ឈ្មោះថា **បដិច្ឆន្នជរា** ព្រោះមិនបង្ហាញការវិការដូច្នោះ ឲ្យឃើញឡើយ ។

មានដក ២ យ៉ាងទៀត គឺអវីចិដក គឺដកមិនមានគន្លងឲ្យឃើញ ១ សវីចិដក ដកមានគន្លងឲ្យឃើញ ១ ក្នុងចំនួនដក ២ យ៉ាងនោះ ដករបស់កែវមណី មាស ប្រាក់ កែវពពាល ព្រះចន្ទ ព្រះអាទិត្យជាដើម គប្បីជ្រាបថា ឈ្មោះថា **អវីចិដកា** អធិប្បាយថា ឈ្មោះថា ដកមិនមានរវាងចន្លោះដែលអាចឲ្យឃើញបាន ព្រោះការបែកផ្សេងគ្នារបស់ពណ៌ជាដើមក្នុងចន្លោះៗដឹងបានលំបាក ដូចការបែកផ្សេងគ្នានៃពណ៌ជាដើម ក្នុងចន្លោះៗ របស់សត្វមានបាណ ក្នុងវ័យមន្ទទសកៈ គឺ ១០ ឆ្នាំក្នុងយុវវ័យជាដើម និងដូចការផ្សេងគ្នានៃពណ៌ជាដើម ក្នុងចន្លោះៗ របស់វត្ថុដែលមិនមានបាណ ក្នុងផ្លៃឈើ និងក្នុងស្លឹកឈើជាដើម ។ តែដកក្នុងវត្ថុដទៃក្រៅអំពីនោះ តាមដែលពោលមកហើយ ឈ្មោះថា **សវីចិដកា** ព្រោះការផ្សេងគ្នានៃពណ៌ជាដើមក្នុងចន្លោះៗ ជាវត្ថុដែលគប្បីដឹងបានងាយ ។

បន្ទាប់អំពីនេះទៅ បទថា **តេសំ តេសំ** ជាដើម គប្បីជ្រាបដោយន័យដែលបានពោលមកហើយនោះឯង ។

បទថា **ចុតិ** ក្នុងពាក្យទាំងឡាយ មានពាក្យថា **ចុតិ ចវនតា** ជាដើម ព្រះថេរៈពោលទោសដោយអំណាចនៃសត្វដែលឃ្លាតទៅ ។

ពាក្យថា **ចុតិ** នេះ ជាពាក្យទូទៅសម្រាប់ខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ។

ពាក្យថា **ចវនតា** ជាពាក្យសម្ដែងដល់លក្ខណៈរបស់ខន្ធ ដោយការឃ្លាតចាកការៈ ។ ពាក្យថា **ភេទោ** ជាពាក្យសម្ដែងដល់ការបែកធ្លាយ និងការកើតឡើងនៃខន្ធទាំងឡាយដែលចុតិ ។ ពាក្យថា **អន្តរធានំ** ជាពាក្យ

សម្តែងដល់ការៈនៃការឃ្លាតចាកស្ថាន ដោយបរិយាយឯណាមួយនៃចុតិក្ខន្ធទាំងឡាយ ដែលបែកធ្លាយទៅ ដូចក្អមដែលបែកហើយ ដូច្នោះ ។ ការស្លាប់ពោល គឺមច្ចុ ឈ្មោះថា **មច្ចុមរណា** ។

ដោយសព្ទថា **មច្ចុមរណំ** នោះ ព្រះថេរៈបដិសេធសមុច្ឆេទមរណៈជាដើម ។ មច្ចុរាជដែលធ្វើនូវទីបំផុត ឈ្មោះថា **កាល** ការធ្វើកាលនោះ ឈ្មោះថា **កាលកិរិយា** ដោយពាក្យថា **កាលកិរិយា** នេះ ព្រះថេរៈសម្តែងដល់ការស្លាប់តាមសន្មតរបស់សត្វលោក ។ តទៅនេះ ដើម្បីសម្តែងដល់ការស្លាប់ដោយបរមត្ថ ទើបព្រះថេរៈពោលពាក្យថា **ខន្ធានំ ភេទោ** ជាដើម ។

សេចក្តីពិត ដោយបរមត្ថ ខន្ធទាំងឡាយប៉ុណ្ណោះបែកធ្លាយ មិនមែនសត្វណាមួយស្លាប់ឡើយ កាលខន្ធទាំងឡាយកំពុងបែកធ្លាយ សត្វក៏ឈ្មោះថា កំពុងស្លាប់ កាលបែកធ្លាយហើយ ក៏មានវោហារថា ស្លាប់ហើយ ។

ក្នុងជរាមរណវារៈនេះ ការបែកធ្លាយនៃខន្ធទាំងឡាយ មានដោយចតុវោការភព ការដាក់ចុះនូវសាកសព មានដោយឯកវោការភព ការបែកធ្លាយនៃខន្ធទាំងឡាយ គប្បីជ្រាបដោយចតុវោការភព ការដាក់ចុះនូវសាកសព គប្បីជ្រាបដោយអំណាចនៃភពទាំង ២ ដ៏សេស គឺឯកវោការភព និងបញ្ចវោការភព ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសាកសព ពោល គឺរូបកាយកើតឡើងចំពោះក្នុងភពទាំង ២ នេះ ។

ម្យ៉ាងទៀត ព្រោះខន្ធទាំងឡាយក្នុងទេវលោក និងព្រហ្មលោក មានចាតុម្មហារាជិកាជាដើម បែកធ្លាយទៅតែម្យ៉ាង ក៏មិនមានសល់សាកសព ដូច្នោះ ការបែកធ្លាយនៃខន្ធទាំងឡាយ គប្បីជ្រាបដោយអំណាចនៃខន្ធទាំង-ឡាយក្នុងទេវលោក និងព្រហ្មលោក មានចាតុម្មហារាជិកាជាដើមនោះ ។ ឯការដាក់ចុះនូវសាកសព មាននៅក្នុងសត្វទាំងឡាយ មានមនុស្សជាដើម ។ ការស្លាប់ដោយហេតុ ដែលដាក់នូវសាកសព ព្រះថេរៈពោលថា ការដាក់ចុះនូវសាកសព ។ គប្បីជ្រាបវិនិច្ឆ័យយ៉ាងនេះថា ជរាក្តី មរណៈក្តី គប្បីជ្រាបដូចពណ៌នាមកនេះ ។ ពាក្យថា **ឥទំ វុច្ចតាវុសោ** សេចក្តីថា ជរា និងមរណៈទាំង ២ យ៉ាងនេះ ព្រះថេរៈពោលរួមគ្នាថា ជរាមរណៈ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ដូច្នេះ ។

**អធិប្បាយ ជរាមរណវារៈ ចប់**

## អធិប្បាយ ជាតិវារៈ

[ ១១៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យទាំងឡាយថា **ជាតិ សញ្ជាតិ** ជាដើម ក្នុងជាតិវារៈដូចតទៅនេះ

ឈ្មោះថា **ជាតិ** ព្រោះអត្ថថា ផ្តើមកើត ។ ជាតិនោះប្រកបហើយដោយអំណាចនៃអាយតនៈមិនទាន់បរិបូណ៌ ។

ឈ្មោះថា **សញ្ជាតិ** ព្រោះអត្ថថា កើតគ្រប់ហើយ ។ សញ្ជាតិនោះប្រកបហើយ ដោយអំណាចអាយតនៈបរិបូណ៌ហើយ ។

ឈ្មោះថា **ឱក្កន្តិ** ព្រោះអត្ថថា ឈានចុះ គឺឈានចុះកាន់គភ៌ ។ ឱក្កន្តិនោះប្រកបដោយអណ្ឌជកំណើត និងជលាពុជកំណើត ។ អធិប្បាយថា សត្វទាំងនោះឈានចុះ គឺបដិសន្ធិ ដូចឈានចូលទៅកាន់សម្បកស៊ុត និងស្បូន ដូច្នោះ ។

ឈ្មោះថា **អភិនិព្វត្តិ** ព្រោះអត្ថថា ផុសកើត ។ អភិនិព្វត្តិនោះប្រកបដោយសំសេទជកំណើត និងឱបបាតិកកំណើត អធិប្បាយថា សត្វទាំងនោះកើតប្រាកដឡើងតែម្តង ។ នេះជាទេសនាតាមវោហារជាបឋម ។ តទៅនេះទើបជាទេសនាដោយបរមត្ថ អធិប្បាយថា ដោយបរមត្ថ ខន្ធទាំងឡាយប៉ុណ្ណោះឯងប្រាកដឡើង មិនមែនសត្វប្រាកដឡើយ ។

បណ្តាបទទាំងនោះ បទថា **ខន្ធានំ** គប្បីជ្រាបថា សំដៅយក ខន្ធ ១ ក្នុងឯកវោការភព ខន្ធ ៤ ក្នុងចតុវោការភព និងខន្ធ ៥ ក៏មានខ្លះក្នុងបញ្ចវោការភព ។

ការឧប្បត្តិ ឈ្មោះថា **ធាតុភាវោ** ។ គប្បីជ្រាបការសង្គ្រោះដោយអាយតនៈដែលកំពុងកើតឡើង ក្នុងភពនោះៗ ចូលក្នុងពាក្យថា **អាយតនានំ** នេះ ។ ការប្រាកដឡើងក្នុងសន្តតិនោះឯង ឈ្មោះថា **បដិលាភោ** អធិប្បាយថា អាយតនៈទាំងនោះ ដែលប្រាកដនោះឯង រមែងឈ្មោះថា សត្វទាំងឡាយត្រូវឡប់បានហើយ ។

ដោយបទនេះថា **អយំ វុច្ចតាវុសោ ជាតិ** ព្រះថេរៈពោលបញ្ចប់ជាតិដែលបានសម្តែងមកហើយ ដោយវោហារផង ដោយបរមត្ថផង ដូច្នេះឯង ។

អ្នកសិក្សាគប្បីជ្រាបកម្មភព ដែលជាបច្ច័យនៃជាតិ ក្នុងពាក្យថា **ភវ-សមុទយា** នេះ ។ ពាក្យដ៏សេស មានន័យដូចដែលពោលហើយនោះឯង ។

អធិប្បាយ ជាតិវារៈ ចប់

## អធិប្បាយ ភវវារៈ

[ ១១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភវវារៈដូចតទៅនេះ កម្មភព និងឧបបត្តិភព ឈ្មោះថា **កាមភព** ។ បណ្ដាភពទាំង ២ យ៉ាងនោះ កម្មដែលជាហេតុឲ្យចូលដល់កាមភពនោះឯង ឈ្មោះថា **កម្មភព** ។

អធិប្បាយថា កម្មនោះឯង លោកពោលថា **ភព** ដោយការពោលដល់ផល ដូចពាក្យទាំងឡាយជាដើមថា ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ ជាហេតុនាំមកនូវសេចក្ដីសុខ ការសន្សំនូវបាប ជាហេតុនាំមកនូវសេចក្ដីទុក្ខ ដូច្នេះ ព្រោះកម្មភពនោះ ជាហេតុនៃឧបបត្តិភព ។ ខន្ធបញ្ចកៈដែលតណ្ហា និងទិដ្ឋិប្រកាន់មាំហើយ កើតឡើងហើយដោយកម្មនោះ ឈ្មោះថា **ឧបបត្តិ-ភព** ។ ព្រោះថា ខន្ធបញ្ចកៈនោះ លោកពោលថា **ភព** ព្រោះតាំងវិគ្គហៈថា ជាទីកើតនៃបដិសន្ធិចិត្ត ។

កាលបើដូច្នេះ ទាំង ២ យ៉ាងនេះ គឺកម្មភព ១ ឧបបត្តិភព ១ លោកពោលថា ជាកាមភពដោយប្រការទាំងពួង ។ ក្នុង **រូបភព** និង **អរូបភព** ក៏ទំនងនេះ ។ តែឧបាទានក្នុងពាក្យថា **ឧបាទានសមុទយា** នេះ ជាបច្ច័យនៃកម្មភពដែលជាកុសល ។ ដោយឧបនិស្សយប្បច្ច័យនោះឯង ។ ឧបាទាន

ជាបច្ច័យនៃកម្មកពដែលជាអកុសល ដោយឧបនិស្សយប្បច្ច័យខ្លះ ដោយសហជាតប្បច្ច័យជាដើមខ្លះ ជាបច្ច័យរបស់ឧបបត្តិកព របស់កម្មកពដែលជាកុសលផង អកុសលទាំងអស់ផង ដោយឧបនិស្សយប្បច្ច័យខ្លះ ។ ពាក្យដ៏សេសមាន ន័យដូចពោលមកហើយនោះឯង ដូច្នេះ ។

**អធិប្បាយ ភវវារៈ ចប់**

## អធិប្បាយ ឧបាទានវារៈ

[ ១២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យទាំងឡាយ មានពាក្យថា **កាមុ-បាទានំ** ក្នុងឧបាទានវារៈ ជាដើមដូចតទៅនេះ

កិលេសជាតិ ឈ្មោះថា **កាមុបាទាន** ព្រោះអត្ថវិគ្គហៈថា ជាហេតុប្រកាន់មាំនូវវត្ថុកាម ឬព្រោះប្រកាន់វត្ថុកាមនោះឯង ។ម៉្យាងទៀត កាមនោះផងជាឧបាទានផង ព្រោះដូច្នោះ ទើបឈ្មោះថា **កាមុបាទាន** ។

ការប្រកាន់មាំ លោកហៅថា **ឧបាទាន** ។ ព្រោះថា **ឧប** សព្ទ ក្នុងពាក្យថា **ឧបាទានំ** នេះ មានអត្ថថា **មាំ** ដូច **ឧប** សព្ទ ក្នុងពាក្យទាំងឡាយថា **ឧបាយាស** និង **ឧបកដ្ឋ** ។

ពាក្យថា **កាមុបាទាន** នេះ ជាឈ្មោះរបស់រាគៈ ដែលប្រព្រឹត្តទៅក្នុងកាមគុណ ។ នេះជាការសង្ខេបក្នុងកាមុបាទាននេះ ។

តែដោយពិស្តារ កាមុបាទាននេះ គប្បីជ្រាបដោយន័យដែលត្រាស់ទុកហើយថា បណ្ដាឧបាទានទាំងនោះ តើកាមុបាទានដូចម្ដេច បានដល់ ការពេញ

ចិត្តដោយអំណាចការប្រាថ្នាក្នុងកាមទាំងឡាយ ។ ទិដ្ឋុបាទានក៏យ៉ាងនោះ គឺទិដ្ឋិនោះផង ជាឧបាទានផង ព្រោះដូច្នោះ ទើបឈ្មោះថា **ទិដ្ឋុបាទាន** ។ ម្យ៉ាងទៀត កិលេសជាតិ ឈ្មោះថា **ទិដ្ឋុបាទាន** ព្រោះប្រកាន់មាំនូវទិដ្ឋិ ឬឈ្មោះថា **ទិដ្ឋុបាទាន** ព្រោះវិគ្គហៈថា ជាហេតុឲ្យប្រកាន់មាំក្នុងទិដ្ឋិ អធិប្បាយថា កិលេសជាតិណា រមែងប្រកាន់មាំនូវមូលទិដ្ឋិ ក្នុងពាក្យទាំងឡាយជាដើមថា អត្តាក្តី លោកក្តីជារបស់ទៀង ព្រោះដូច្នោះ ទើបកិលេសជាតិនោះឈ្មោះយ៉ាងនោះ គឺឈ្មោះថា **ទិដ្ឋុបាទាន** ។ ដូចពាក្យជាដើមថា អត្តានិងលោកជារបស់ទៀង វត្ថុនេះប៉ុណ្ណោះជារបស់ពិត វត្ថុដទៃជាមោឃៈ ។ ពាក្យថា **ទិដ្ឋុបាទាន** នេះ ជាឈ្មោះរបស់ទិដ្ឋិទាំងអស់ វៀរតែសីលព្វតុបាទាន និងអត្តវាទុបាទានប៉ុណ្ណោះ នេះជាការសង្ខេបក្នុងទិដ្ឋុបាទាននេះ ។ តែដោយពិស្តារ ទិដ្ឋុបាទាននេះ គប្បីជ្រាបដោយន័យ ដែលត្រាស់ហើយនោះឯងថា បណ្តាឧបាទានទាំងនោះ ទិដ្ឋុបាទាន តើដូចម្តេច ទិដ្ឋុបាទាន គឺទានដែលបុគ្គលឲ្យហើយ មិនមានផល ។

បណ្តាឧបាទានទាំងនោះ ឈ្មោះថា **សីលព្វតុបាទាន** ព្រោះជាហេតុប្រកាន់មាំនូវសីល និងវត្ត ព្រោះសីល និងវត្តនោះប្រកាន់មាំឯងផង ព្រោះសីល និងវត្តនោះ ជាឧបាទានផង ។

អធិប្បាយថា ការប្រកាន់មាំដោយខ្លួនឯងនោះឯង ដោយការជឿមាំថា សីល និងវត្តទាំងឡាយ មានសីលរបស់គោ និងវត្តរបស់គោជាដើម ជារបស់បរិសុទ្ធិដោយអាការយ៉ាងនេះ ព្រោះដូច្នោះ ទើបមានឈ្មោះយ៉ាងនោះ

គឺឈ្មោះថា **សីលព្វតុបាទាន** ។ នេះជាអត្ថសង្ខេបក្នុងសីលព្វតុបាទាននេះ ។

តែដោយពិស្តារ សីលព្វតុបាទាននេះ គប្បីជ្រាបដោយន័យដែលត្រាស់ហើយថា បណ្ដាឧបាទានទាំងនោះ សីលព្វតុបាទាន តើដូចម្ដេច គឺសេចក្តីបរិសុទ្ធដោយសីលរបស់សមណព្រាហ្មណ៍ទាំងឡាយខាងក្រៅសាសនានេះ ។

ឈ្មោះថា **វាទ** ព្រោះជាហេតុពោលក្នុងឥឡូវនេះ ។

ឈ្មោះថា **ឧបាទាន** ព្រោះជាហេតុប្រកាន់មាំ ។

សួរថា ពោល ឬប្រកាន់មាំដូចម្ដេច ឆ្លើយថា ពោល ឬ ប្រកាន់មាំនូវអត្តា( អាត្ម័ន ) ។ ការប្រកាន់មាំនូវវាទៈរបស់ខ្លួន ឈ្មោះថា **អត្តវាទុ-បាទាន** ។ ម្យ៉ាងទៀត ឈ្មោះថា **អត្តវាទុបាទាន** ព្រោះជាហេតុប្រកាន់មាំត្រឹមតែវាទៈនៃខ្លួនប៉ុណ្ណោះថាជាអត្តា ។ ពាក្យថា **អត្តវាទុបាទាន** នេះ ជាឈ្មោះសក្កាយទិដ្ឋិ ២០ ។ នេះជាសេចក្តីសង្ខេបក្នុងអត្តវាទុបាទាននេះ ។

ឯដោយពិស្តារ អត្តវាទុបាទាននេះ គប្បីជ្រាបដោយន័យដែលត្រាស់មកហើយថា បណ្ដាឧបាទាននោះ អត្តវាទុបាទាន តើដូចម្ដេច អត្តវាទុបាទាន គឺបុថុជ្ជនក្នុងសាសនានេះ មិនបានស្ដាប់ហើយ មិនឃើញព្រះអរិយៈទាំងឡាយដូច្នេះ ។ តណ្ហា ក្នុងពាក្យថា **តណ្ហាសមុទយា** នេះ ជាបច្ច័យនៃកាមុបាទានដោយឧបនិស្សយប្បច្ច័យ ឬដោយអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ នត្ថិប្បច្ច័យនិងអាសេវនប្បច្ច័យ តែជាបច្ច័យនៃឧបាទានដ៏សេស គឺដោយសហជាតប្បច្ច័យជាដើមក៏មាន ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ដូច្នេះ ។

**អធិប្បាយ ឧបាទានវារៈ ចប់**

# អធិប្បាយ តណ្ហាវារៈ

## តណ្ហា ១០៨

[ ១២១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតណ្ហាវារៈដូច្នេះ តណ្ហាដែលប្រព្រឹត្ត ទៅហើយ ដោយជវនវិថី មានឈ្មោះតាមអារម្មណ៍ ដូចគ្នានឹងបិតា គឺអ្នក ឲ្យកើតថា រូបតណ្ហា ។បេ។ ធម្មតណ្ហា ដូចគ្នានឹងបុគ្គលមានឈ្មោះតាមបិតា ក្នុងពាក្យទាំងឡាយ ដូចពាក្យថា សេដ្ឋីបុត្រ ព្រាហ្មណបុត្រជាដើម ។

ក្នុងតណ្ហាវារៈនេះ តណ្ហាមាន ៣ ប្រការយ៉ាងនេះ តណ្ហាដែលមានរូប ជាអារម្មណ៍ គឺតណ្ហាក្នុងរូប ព្រោះដូច្នោះ ទើបឈ្មោះថា **រូបតណ្ហា** រូបតណ្ហា នោះ កាលត្រេកអរ ប្រព្រឹត្តទៅដោយភាពជាកាមរាគៈ ឈ្មោះថា **កាម-តណ្ហា** ។ កាលត្រេកអរ ប្រព្រឹត្តទៅយ៉ាងនេះថា រូបទៀង គឺស្ថិតស្ថេរ បានដល់ ជាប់តគ្នាទៅ ដោយភាពជារាគៈ ដែលកើតរួមជាមួយសស្សតទិដ្ឋិ ឈ្មោះថា **ភវតណ្ហា** ។

កាលត្រេកអរ ប្រព្រឹត្តទៅយ៉ាងនេះថា រូបដាច់សូន្យ គឺបាត់ទៅ បាន ដល់ លះលោកនេះទៅហើយ នឹងមិនមាន ដោយភាពជារាគៈកើតរួមជាមួយ ឧច្ឆេទទិដ្ឋិ ឈ្មោះថា **វិភវតណ្ហា** ។

សទ្ទតណ្ហាជាដើម ក៏ដូចគ្នានឹងរូបតណ្ហានោះឯង ទើបរួមជាតណ្ហាវិបរិត ១៨ ប្រការ ។ តណ្ហាវិបរិតទាំងនោះចែកជា ១៨ ក្នុងអាយតនៈទាំងឡាយ មានរូបខាងក្នុងជាដើម និងចែកជា ១៨ ក្នុងអាយតនៈទាំងឡាយ មានរូប ខាងក្រៅជាដើម ទើបរួមជា ៣៦ ប្រការ ។ ចែកជាអតីត ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ ដោយប្រការយ៉ាងនោះ ទើបជាតណ្ហាវិបរិត ១០៨ ប្រការ ។

ម្យ៉ាងទៀត តណ្ហាវិចរិត ១៨ ប្រការ អាស្រ័យរូបដែលប្រព្រឹត្តទៅខាងក្នុងជាដើមយ៉ាងនេះថា ព្រោះអាស្រ័យរូបខាងក្នុង មានតណ្ហាថា អញមាន ព្រោះរូបនេះ ថាកាលអញមាន អញក៏ជាទីប្រាថ្នា ដូច្នោះ ទើបរួមជាតណ្ហា ៣៦ ចែកជាអតីត ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ ដោយប្រការ យ៉ាងនេះ រួមជាតណ្ហាវិចរិត ១០៨ ដូចពណ៌នាមកនេះឯង ។

កាលធ្វើការសង្គ្រោះទៀត តណ្ហាក៏មាន ៦ ពួកប៉ុណ្ណោះ ក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ដោយអត្ថដែលលោកសម្តែងយ៉ាងនេះថា តណ្ហាមាន ៣ យ៉ាងប៉ុណ្ណោះ មានកាមតណ្ហាជាដើម អ្នកប្រាជ្ញគប្បីជ្រាបតណ្ហាដោយការសង្គ្រោះអត្ថដែលពិស្តារចូលគ្នាទៀត អំពីការពិស្តារដែលសម្តែងមកហើយ ដូច្នេះ ។

វេទនាដែលជាវិបាក ព្រះថេរៈបំណងយកហើយថា វេទនាក្នុងពាក្យថា **វេទនាសមុទយា** នេះ ។

បើមានពាក្យសួរថា វេទនានោះជាបច្ច័យនៃតណ្ហាក្នុងទ្វារ ៦ ដូចម្តេច ឆ្លើយថា ជាបច្ច័យព្រោះវេទនា ជាវត្ថុដែលគួរត្រេកអរ អធិប្បាយថា កាលសត្វទាំងឡាយប្រកាន់មាំក្នុងវេទនា ថាជារបស់អញ ដោយការពេញចិត្តក្នុងសុខវេទនា បុគ្គលនោះ នឹងជាអ្នកញុំាងការចង់បានក្នុងវេទនាឲ្យកើតឡើងហើយ ត្រេកអរហើយ ដោយតម្រេកក្នុងវេទនា ប្រាថ្នារូបដែលបានឃើញហើយនោះឯង កាលបានរូបនោះហើយ ក៏ពេញចិត្ត ទាំងធ្វើសក្ការៈ ដល់ជាងគំនូរជាដើមដែលឲ្យអារម្មណ៍ ។

ក្នុងសោតទ្វារជាដើម ក៏ដូចគ្នា សត្វទាំងឡាយ រមែងប្រាថ្នាសំឡេងជាដើមដែលជាទីប្រាថ្នានោះឯង កាលបានហើយ ក៏ពេញចិត្តក្នុងសំឡេងជាដើមនោះ ទាំងធ្វើសក្ការៈដល់អ្នកដេញពិណ ជាងធ្វើទឹកក្រអូប ជាងតម្បាញ និងអ្នកសម្តែងសិប្បៈច្រើនប្រភេទជាដើម សួរថា សេចក្តីនេះដូចអ្វី ឆ្លើយថា ដូចម្តាយស្រឡាញ់កូន ធ្វើសក្ការៈដល់មេដោះ គឺឲ្យមេដោះផឹក និងបរិភោគសប្បិ និងទឹកដោះដ៏ឆ្ងាញ់ជាដើម ព្រោះស្នេហាក្នុងកូន ។ ពាក្យដ៏សេសមានន័យដូចដែលពោលហើយនោះឯង ។

**អធិប្បាយ តណ្ហាវារៈ ចប់**

# អធិប្បាយ វេទនាវារៈ

[ ១២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវេទនាវារៈដូចតទៅនេះ ពួកវេទនាឈ្មោះថា **វេទនាកាយ** ។

ពាក្យថា **ចក្ខុសម្ផស្សជា វេទនា ។បេ។ មនោសម្ផស្សជា វេទនា** នេះជាឈ្មោះរបស់វេទនាដែលជាកុសលផង អកុសលផង និងអព្យាកតៈដែលប្រព្រឹត្តទៅហើយក្នុងចក្ខុទ្វារជាដើមតាមវត្ថុ គឺទីតាំង ដូចម៉ែ ដូចគ្នានឹងឈ្មោះរបស់កូន តាមម៉ែក្នុងពាក្យទាំងឡាយថា **សារីបុត្ត មន្តានីបុត្ត** យ៉ាងនេះជាដើម ព្រោះមកហើយក្នុងគម្ពីរវិភង្គយ៉ាងនេះថា វេទនាដែលកើតអំពីចក្ខុ-សម្ផស្ស ដែលជាកុសលក៏មាន អកុសលក៏មាន អព្យាកតៈក៏មាន ក្នុងពាក្យថា **ចក្ខុសម្ផស្សជា វេទនា** នេះជាដើម មានអត្ថវចនៈថា វេទនាដែលកើត

ឡើងព្រោះចក្ខុសម្ផស្សជាហេតុ ឈ្មោះថា **ចក្ខុសម្ផស្សជាវេទនា** ។ គ្រប់ទ្វារទាំងអស់ មានសោតៈជាដើមក៏មានទំនងនេះ ។ នេះជាកថា ដែលពោលដោយការសង្គ្រោះចូលគ្នាគ្រប់យ៉ាង ក្នុងវេទនាការៈនេះ ។

តែវេទនាគប្បីជ្រាបដោយវេទនា ដែលសម្បយុត្តដោយធម៌ទាំងនេះ គឺក្នុងចក្ខុទ្វារដោយវិបាក មានចក្ខុវិញ្ញាណ ២ ដួង មនោធាតុ ២ ដួង មនោវិញ្ញាណធាតុ ៣ ដួង ។ ក្នុងសោតទ្វារជាដើម ក៏ទំនងនេះ ។ ឯមនោទ្វារគប្បីយល់ថា ជាវេទនាដែលសម្បយុត្តដោយមនោវិញ្ញាណធាតុ ។

ក្នុងពាក្យថា **ផស្សសមុទយា** នេះ គប្បីជ្រាបវិនិច្ឆ័យថា ក្នុងទ្វារទាំង ៥ វេទនាអាស្រ័យវត្ថុទាំង ៥ មានការកើតឡើង ព្រោះចក្ខុសម្ផស្សដែលកើតឡើងរួមគ្នាជាដើមកើតឡើង ។ ទើបចក្ខុសម្ផស្សជាដើម ជាបច្ច័យរបស់វេទនាដ៏សេសទាំងឡាយ ដោយជាឧបនិស្សយប្បច្ច័យជាដើម វេទនាក្នុងតទាលម្ពណក្ខណៈក្នុងមនោទ្វារ និងវេទនាក្នុងបដិសន្ធិក្ខណៈ ភវង្គក្ខណៈ និងចុតិក្ខណៈដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ មានការកើតឡើង ព្រោះការកើតឡើងនៃមនោសម្ផស្សដែលកើតឡើងរួមគ្នា ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

**អធិប្បាយ វេទនាការៈ ចប់**

## អធិប្បាយ ផស្សការៈ

[ ១២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងផស្សការៈតទៅនេះថា ផស្សៈក្នុងចក្ខុ

ឈ្មោះថា **ចក្ខុសម្ផស្ស** ។ គ្រប់ទ្វារក៏មានទំនងដូច្នេះ ។ និងដោយពាក្យមានប្រមាណប៉ុណ្ណេះថា **ចក្ខុសម្ផស្សោ ។បេ។ កាយសម្ផស្សោ** ឈ្មោះថា ព្រះថេរៈបានពោលដល់សម្ផស្សទាំង ១០ មានវត្ថុ ៥ ដែលជាកុសលវិបាកផង អកុសលវិបាកផង ។

ដោយពាក្យថា **មនោសម្ផស្សោ** នេះ ឈ្មោះថា ព្រះថេរៈបានពោលដល់ផស្សៈដែលសម្បយុត្តដោយលោកិយវិបាកដ៏សេស ២២ យ៉ាង ។

បទថា **សឡាយតនសមុទយា** សេចក្ដីថា ព្រោះអាយតនៈ ៦ មានចក្ខុជាដើមកើតឡើង ផស្សៈទាំង ៦ យ៉ាងនេះ ក៏មានការកើតឡើងដែរ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

**អធិប្បាយ ផស្សវារៈ ចប់**

## អធិប្បាយ សឡាយតនវារៈ

[ ១២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសឡាយតនវារៈដូចតទៅថា អាយតនៈទាំងអស់ ដែលគួរពោលក្នុងពាក្យទាំងឡាយថា **ចក្ខាយតនំ** ជាដើម មានន័យដូចបានពោលមកហើយ ក្នុងខន្ធនិទ្ទេស និងអាយតននិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

តែក្នុងពាក្យថា **នាមរូបសមុទយា** នេះ អ្នកសិក្សាគប្បីជ្រាបការកើតឡើងនៃសឡាយតនៈ ព្រោះនាមរូបកើតដោយន័យដែលបានពោលទុកហើយក្នុងនិទ្ទេសនៃបដិច្ចសមុប្បាទ ក្នុងគម្ពីរវិសុទ្ធិមគ្គ ដោយអំណាចនៃអាយតនៈ

ដែលមានរូប និងនាម និងនាមផង រូបផងជាបច្ច័យ ពាក្យដ៏សេស មាន ប្រការដូចពោលមកហើយនោះឯង ។

អធិប្បាយ សឡាយតនវារៈ ចប់

# អធិប្បាយ នាមរូបវារៈ

[ ១២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនាមរូបវារៈដូចតទៅនេះថា នាមមាន ការបង្អោនទៅជាលក្ខណៈ ។ រូបមានការបែកធ្លាយទៅជាលក្ខណៈ ។ តែ ក្នុងវារៈនៃវិត្ថារន័យ ( ន័យដោយពិស្តារ ) របស់នាមរូបនោះ គប្បីជ្រាបថា វេទនា បានដល់ វេទនាខន្ធ សញ្ញា បានដល់ សញ្ញាខន្ធ ចេតនា ផស្សៈ មនសិការ បានដល់ សង្ខារក្ខន្ធ ។ ទោះបីមានធម៌ដទៃដែលសង្គ្រោះចូល ដោយសង្ខារក្ខន្ធក៏ពិត តែធម៌ ៣ យ៉ាងនេះ មាននៅក្នុងចិត្តដែលមានកម្លាំង ខ្សោយគ្រប់ដួង ព្រោះដូច្នោះ ក្នុងនាមរូបវារៈនេះ ព្រះថេរៈក៏បានសម្តែង សង្ខារក្ខន្ធ ដោយអំណាចនៃធម៌ទាំង ៣ យ៉ាងនេះឯង ។

ពាក្យថា **ចត្តារិ** ក្នុងពាក្យថា **ចត្តារិ មហាភូតានិ** នេះ ជាការ កំណត់ការរាប់ ។ ពាក្យថា **មហាភូតានិ** នេះ ជាឈ្មោះរបស់ដី ទឹក ភ្លើង ខ្យល់ តែហេតុដែលហៅវត្ថុទាំង ៤ នោះ ថាជាមហាភូត និងន័យនៃការ វិនិច្ឆ័យដទៃ ក្នុងនាមរូបទាំងអស់នេះ បានពោលទុកហើយក្នុងនិទ្ទេសនៃ រូបក្ខន្ធ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ឯពាក្យថា **ចតុន្នំ** ក្នុងពាក្យថា **ចតុន្នញ្ច មហាភូតានំ ឧបាទាយ** ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ មានអធិប្បាយ

ថា អាស្រ័យមហាភូតទាំង ៤ ។

បទថា **ឧបាទាយ** សេចក្តីថា ចូលទៅប្រកាន់ទុក គឺចាប់ទុក ។ អាចារ្យពួកខ្លះពោលថា **និស្សាយ** ប្រែថា អាស្រ័យក៏មាន ។

សព្ទថា **វត្តមានំ** នេះ ជាបាឋសេស គឺលើស ។ ម្យ៉ាងទៀត ពាក្យថា **វត្តមានំ** នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថថា ប្រជុំ ព្រោះហេតុនោះ គប្បីជ្រាបអធិប្បាយនេះថា រូបដែលអាស្រ័យការប្រជុំមហាភូតរូបទាំង ៤ ប្រព្រឹត្តទៅ ។

កាលបើយ៉ាងនេះ ក្នុងទីគ្រប់កន្លែង មហាភូតរូប ៤ មានបឋវីជាដើម និងរូប ២៣ យ៉ាង ដែលអាស្រ័យមហាភូត ៤ ប្រព្រឹត្តទៅ ដែលត្រាស់ទុកក្នុងព្រះបាលីនោះឯង ក្នុងគម្ពីរអភិធម្ម ដោយចែកប្រភេទជាចក្ខាយតនៈជាដើម ទាំងអស់នេះ គប្បីជ្រាបថា ឈ្មោះថា **រូប** ។

ក្នុងពាក្យថា **វិញ្ញាណសមុទយា** នេះ វិញ្ញាណណាជាបច្ច័យរបស់នាមផង របស់រូបផង របស់នាម និងរូបផង ព្រោះដូច្នោះ ដោយអំណាចនៃនាម នៃរូប និងនាមផង រូបផង ដែលមានវិញ្ញាណជាបច្ច័យនោះ អ្នកសិក្សាគប្បីជ្រាបការកើតឡើងនៃនាមរូប ព្រោះវិញ្ញាណកើតឡើង តាមន័យដែលបានពោលមកហើយ ក្នុងនិទ្ទេសនៃបដិច្ចសមុប្បាទ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។ ពាក្យដ៏សេស មានន័យដូចពោលមកនោះឯង ដូច្នេះឯង ។

**អធិប្បាយ នាមរូបវារៈ ចប់**

## អធិប្បាយ វិញ្ញាណវារៈ

[ ១២៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិញ្ញាណវារៈដូច្នេះ វិញ្ញាណអាស្រ័យចក្ខុ ឈ្មោះថា **ចក្ខុវិញ្ញាណ** ម្យ៉ាងទៀត វិញ្ញាណដែលកើតឡើងហើយអំពីចក្ខុ ព្រោះដូច្នោះ ទើបឈ្មោះថា **ចក្ខុវិញ្ញាណ** ។ **សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ** និង **កាយវិញ្ញាណ** ក៏យ៉ាងនោះដូចគ្នា ។ តែវិញ្ញាណនេះ បានដល់ មនោនោះឯង ព្រោះដូច្នោះ ទើបឈ្មោះថា **មនោវិញ្ញាណ** ។ ពាក្យថា **មនោវិញ្ញាណ** នេះ ជាឈ្មោះរបស់វិបាកចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ វៀរទ្វិបញ្ចវិញ្ញាណ ។

តែក្នុងពាក្យថា **សង្ខារសមុទយា** នេះ អ្នកសិក្សាគប្បីជ្រាបការកើតឡើងនៃវិញ្ញាណ ព្រោះសង្ខារកើត តាមន័យដែលបានពោលហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។ ដោយវិញ្ញាណដែលមានសង្ខារជាបច្ច័យ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ដូច្នេះ ។

អធិប្បាយ វិញ្ញាណវារៈ ចប់

## អធិប្បាយ សង្ខារវារៈ

[ ១២៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសង្ខារវារៈដូចតទៅនេះថា សង្ខារមានការតាក់តែងជាលក្ខណៈ តែក្នុងវារៈនៃវិត្ថារន័យរបស់សង្ខារនោះ សង្ខារដែលប្រព្រឹត្តទៅហើយផ្លូវកាយ ឈ្មោះថា **កាយសង្ខារ** ។

ពាក្យថា **កាយសង្ខារ** នេះ ជាឈ្មោះរបស់កាយសញ្ចេតនា ២០ គឺកាមាវចរកុសល ៨ ដួង និងកាមាវចរអកុសល ១២ ដួង ដែលប្រព្រឹត្តទៅ

ហើយ ដោយការកម្រើកក្នុងកាយទ្វារ ។

ពាក្យថា **វចីសង្ខារ** នេះ ជាឈ្មោះរបស់វចីសញ្ចេតនា ២០ ដួងដូចគ្នា ដែលប្រព្រឹត្តទៅហើយ ដោយការកម្រើកវាចាក្នុងវចីទ្វារ ។

សង្ខារដែលប្រព្រឹត្តទៅហើយតាមផ្លូវចិត្ត ឈ្មោះថា **ចិត្តសង្ខារ** ពាក្យថា **ចិត្តសង្ខារ** នេះ ជាឈ្មោះនៃមនោសញ្ចេតនា ១៩ ដែលជាលោកិយកុសល និងលោកិយអកុសល ដែលប្រព្រឹត្តទៅហើយ គឺកើតឡើងដល់បុគ្គលដែលអង្គុយគិតក្នុងទីកំបាំង ដោយមិនបានធ្វើការកម្រើកកាយ និងវាចា ក្នុងពាក្យថា **អវិជ្ជាសមុទយា** នេះ គប្បីជ្រាបវិនិច្ឆ័យថា អវិជ្ជានៃសង្ខារដែលជាកុសលដោយឧបនិស្សយប្បច្ច័យខ្លះ របស់សង្ខារដែលជាអកុសលដោយសហជាតប្បច្ច័យជាដើមខ្លះ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ដូច្នេះ ។

អធិប្បាយ សង្ខារវារៈ ចប់

## អធិប្បាយ អវិជ្ជាវារៈ

[ ១២៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអវិជ្ជាវារៈដូច្នេះថា ការមិនដឹងក្នុងទុក្ខសច្ច ឈ្មោះថា ការមិនដឹងក្នុងទុក្ខ ។ ពាក្យថា **ទុក្ខេ អញ្ញាណំ** នេះ ជាឈ្មោះរបស់មោហៈ ។ ក្នុងពាក្យទាំងឡាយ មានពាក្យថា **សមុទយេ អញ្ញាណំ** ជាដើមក៏មានន័យដូច្នេះ ។

ក្នុងចំនួនសច្ចៈទាំង ៤ នោះ ការមិនដឹងក្នុងទុក្ខ គប្បីជ្រាបបានដោយ

ហេតុ ៤ ប្រការ គឺដោយការឈមចុះខាងក្នុង ១ ដោយស្ថាន ១ ដោយអារម្មណ៍ ១ ដោយការបិទបាំង ១ ។ ពិតហើយ ការមិនដឹងទុក្ខនោះ ឈ្មោះថា ឈមចុះខាងក្នុងទុក្ខ ព្រោះទាក់ទងក្នុងទុក្ខសច្ច ទុក្ខសច្ច ឈ្មោះថា ជាទីតាំង ព្រោះជានិស្សយប្បច្ច័យនៃការមិនដឹងទុក្ខនោះ ឈ្មោះថា ជាអារម្មណ៍ ព្រោះជាអារម្មណប្បច្ច័យនៃការមិនដឹងទុក្ខនោះ ទុក្ខសច្ច រមែងបិទបាំងការមិនដឹងទុក្ខនោះផងដែរ ។

ក្នុងអធិការនៃអវិជ្ជាវារៈ ការមិនដឹងក្នុងសមុទយៈ គប្បីដឹងបានដោយហេតុ ៣ ប្រការ គឺដោយទីតាំង ១ ដោយអារម្មណ៍ ១ ដោយការបិទបាំង ១ ព្រោះសមុទយៈនោះ រារាំងនូវការចាក់ធ្លុះលក្ខណៈតាមសេចក្តីពិត និងព្រោះមិនប្រគល់ឲ្យនូវការប្រព្រឹត្តទៅនៃញាណ ។ ការមិនដឹងក្នុងនិរោធ និងបដិបទា គប្បីជ្រាបបានដោយហេតុ ១ ប៉ុណ្ណោះ គឺដោយការបិទបាំង ។ ការមិនដឹងដែលបិទបាំងនិរោធ និងបដិបទានោះឯង គប្បីជ្រាបបាន ព្រោះឃាត់នូវការចាក់ធ្លុះលក្ខណៈតាមការពិតនៃនិរោធសច្ច និងបដិបទាទាំងនោះ និងព្រោះការមិនប្រគល់ឲ្យនូវការមិនប្រព្រឹត្តទៅនៃញាណ ក្នុងសច្ចៈទាំង ២ នោះ ។ តែការមិនដឹងសច្ចៈទាំង ២ នោះ មិនជាការឈមចុះខាងក្នុងសច្ចៈទាំង ២ នោះ ព្រោះមិនទាក់ទងក្នុងសច្ចៈទាំង ២ នោះ សច្ចៈទាំង ២ នោះក៏មិនជាទីតាំងនៃការមិនដឹងសច្ចៈទាំង ២ នោះ ព្រោះមិនជាធម៌កើតរួមគ្នា និងមិនជាអារម្មណ៍ ព្រោះមិនប្រារព្ធសច្ចៈទាំង ២ ប្រព្រឹត្តទៅ ។

អធិប្បាយថា សច្ចៈ ២ ខាងក្រោយ ឃើញបានលំបាក ព្រោះជ្រាល

ជ្រៅ តែក្នុងរឿងនេះ ការមិនដឹង មិនមែនខ្វាក់ងងឹត ទើបប្រព្រឹត្តទៅ ។ ឯសច្ចៈ ២ ខាងដើមជ្រាលជ្រៅព្រោះលក្ខណៈនៃសភាវៈ ឃើញបានលំបាកដោយអត្ថថា ជាសត្រូវគ្នា ទើបប្រព្រឹត្តទៅដោយការដល់នូវវិបល្លាសក្នុងសច្ចៈទាំង ២ នោះ ។

ម្យ៉ាងទៀត ដោយពាក្យមានប្រមាណប៉ុណ្ណេះថា **ទុក្ខេ** ព្រះថេរៈបានសម្តែងអវិជ្ជា ដោយការសង្គ្រោះចូលគ្នា ទាំងដោយឋាន ដោយអារម្មណ៍ និងដោយកិច្ច ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះថា **ទុក្ខសមុទយេ** លោកសម្តែងដោយឋាន គឺទីតាំង ដោយអារម្មណ៍ និងដោយកិច្ច ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះថា **ទុក្ខនិរោធេ ទុក្ខនិរោធគាមិនិយា បដិបទាយ** លោកសម្តែងដោយកិច្ច ។ តែដោយមិនផ្សេងគ្នា អវិជ្ជាគប្បីជ្រាបថា លោកសម្តែងដោយសភាវៈ ដោយពាក្យថា **អញ្ញាណំ** នេះ ។

កាមាសវៈ ភវាសវៈ ក្នុងពាក្យថា **អាសវសមុទយា** នេះ ជាបច្ច័យនៃអវិជ្ជា ដោយអំណាចនៃសហជាតប្បច្ច័យជាដើម ។ អវិជ្ជាសវៈគប្បីជ្រាបថា អវិជ្ជាដែលកើតឡើងមុន ដោយឧបនិស្សយប្បច្ច័យនោះឯង ឈ្មោះថា អវិជ្ជាសវៈ ក្នុងពាក្យថា **អាសវសមុទយា** នេះ ។ អវិជ្ជាសវៈនោះ ជាឧបនិស្សយប្បច្ច័យនៃអវិជ្ជាដែលកើតឡើងក្នុងកាលបន្ទាប់មក ។ ពាក្យដ៏សេសមានន័យដូចពណ៌នាមកហើយ ដូច្នេះ ។

**អធិប្បាយ អវិជ្ជាវារៈ ចប់**

# អធិប្បាយ អាសវវារៈ

[ ១៣០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាសវវារៈដូច្នេះ **អវិជ្ជា** ក្នុងពាក្យថា **អវិជ្ជាសមុទយា** នេះ ជាបច្ច័យដោយសហជាតប្បច្ច័យជាដើមនៃកាមាសវៈ និងភវាសវៈ និងជាបច្ច័យនៃអវិជ្ជាសវៈ ដោយឧបនិស្សយប្បច្ច័យនោះឯង តែក្នុងពាក្យថា **អវិជ្ជាសមុទយា** នេះ អវិជ្ជាដែលកើតឡើងក្នុងកាលបន្ទាប់ៗមក គប្បីជ្រាបថាជា **អវិជ្ជាសវៈ ។** អវិជ្ជានោះឯង ដែលកើតឡើងក្នុងកាលមុន ជាឧបនិស្សយប្បច្ច័យដល់អវិជ្ជាសវៈដែលកើតឡើងក្នុងកាលក្រោយៗ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ដូច្នេះ ។

វារៈនេះ លោកពោលហើយ ដោយការសម្តែងបច្ច័យនៃអវិជ្ជានេះ ដែលជាប្រធាន ក្នុងបទបដិច្ចសមុប្បាទទាំងឡាយ ។ ដោយវារៈដែលលោកពោលយ៉ាងនេះ ជាការសម្រេចនូវភាពដែលសង្សារ មានទីបំផុតខាងដើម ដែលពុំមានបុគ្គលណាដឹងបាន ។

សួរថា ដឹងមិនបានដូចម្តេច ឆ្លើយថា ដឹងមិនបានយ៉ាងនេះ ព្រោះថា ការកើតឡើងនៃអវិជ្ជាមាន ព្រោះការកើតឡើងនៃអាសវៈ ការកើតឡើងនៃអាសវៈក៏មាន ព្រោះការកើតឡើងនៃអវិជ្ជា អាសវៈជាបច្ច័យនៃអវិជ្ជា សូម្បីអវិជ្ជាក៏ជាបច្ច័យនៃអាសវៈ ព្រោះអធិប្បាយដូចដែលពោលមកហើយនេះ ទើបទីបំផុតខាងដើមមិនប្រាកដ ភាវៈដែលសង្សារដែលមានខាងដើមមិនមានបុគ្គលណាដឹងហើយ ឈ្មោះថា សម្រេចហើយ ព្រោះខាងដើមនៃអវិជ្ជានោះមិនប្រាកដ ។

វារៈទាំងអស់នេះ គឺកម្មបថវារៈ ១ អាហារវារៈ ១ ទុក្ខវារៈ ១ ជរា-

មរណវារៈ ១ ជាតិវារៈ ១ ភវវារៈ ១ ឧបាទានវារៈ ១ តណ្ហាវារៈ ១ វេទនាវារៈ ១ ផស្សវារៈ ១ សឡាយតនវារៈ ១ នាមរូបវារៈ ១ វិញ្ញាណវារៈ ១ សង្ខារវារៈ ១ អវិជ្ជាវារៈ ១ អាសវវារៈ ១ រួមជា ១៦ វារៈ ព្រះថេរៈបានពោលហើយ ក្នុងព្រះសូត្រនេះ ដូចពណ៌នាមកនេះ

ព្រោះក្នុងចំនួនវារៈទាំង ១៦ នោះ វារៈនីមួយៗ លោកសម្ដែងជា ២ យ៉ាង ដោយសង្ខេប និងដោយពិស្ដារ ទើបជា ៣២ ស្ថាន ដោយហេតុដូច្នេះ ទើបក្នុងព្រះសូត្រនេះ ឈ្មោះថា ព្រះថេរៈបានពោលសច្ចៈ ៤ យ៉ាង ក្នុងស្ថានទាំង ៣២ នេះ ។

ព្រះថេរៈបានពោលអរហត្តក្នុងទី ១៦ ស្ថាន ដែលពោលហើយដោយពិស្ដារ ក្នុងបណ្ដាយ៉ាងសង្ខេប និងយ៉ាងពិស្ដារនោះឯង ។ តែតាមមតិរបស់ព្រះថេរៈបានពោលដល់សច្ចៈទាំង ៤ និងមគ្គទាំង ៤ ក្នុងស្ថាន ៣២ ប៉ុណ្ណោះ ព្រោះហេតុដូចពោលមកហើយនេះឯង ក្នុងព្រះពុទ្ធវចនៈដែលព្រះធម្មសង្គាហកាចារ្យ បានរួបរួមទុកក្នុងនិកាយធំទាំង ៥ និកាយ ទូទៅទាំងអស់ ទើបមិនមានសូត្រដែលប្រកាសសច្ចៈ ៤ យ៉ាង ដល់ទៅ ៣២ ដង និងប្រកាសអរហត្តដល់ទៅ ៣២ ដង ក្រៅអំពីសម្មាទិដ្ឋិសូត្រនេះឯង ។

ពាក្យថា **ឥទមវោចាយស្មា សារិបុត្តោ** មានអត្ថថា ព្រះសារីបុត្របានពោលសម្មាទិដ្ឋិសូត្រនេះ លម្អទៅដោយហេតុ ៦៤ យ៉ាង គឺដោយការបរិយាយអរិយសច្ចបួន ៣២ យ៉ាង និងបរិយាយអរហត្ត ៣២ យ៉ាង ។

ភិក្ខុទាំងនោះពេញចិត្ត បាននាំគ្នាសរសើរភាសិត របស់ព្រះសារីបុត្រ ដូច្នេះឯង ។ល។

## សម្មាទិដ្ឋិសូត្រ ចប់

## សូត្រទី ៩ ចប់

# សុត្តន្តបិដក

## សតិប្បដ្ឋានសូត្រទី ១០

[ ១៣១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅកម្មាសធម្មនិគម[១] របស់អ្នកកុរុ ក្នុងដែនកុរុ ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំង-ឡាយ ដូច្នេះ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ដូច្នេះ ។

[ ១៣២ ] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិប្បដ្ឋានទាំង ៤ ជាផ្លូវមូលតែមួយ[២] ( ប្រព្រឹត្តទៅ ) ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីលះបង់នូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់នូវទុក្ខ និងទោមនស្ស ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ នេះហៅថា សតិ-ប្បដ្ឋាន ៤ ។ សតិប្បដ្ឋាន ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន ជាអ្នកមានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់នូវអភិជ្ឈា និងទោម-នស្សក្នុងលោកចេញ ។ ភិក្ខុពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់

---

១- ហៅថា កម្មាសទម្មនិគមខ្លះ ។ ២- មើលអដ្ឋកថាខាងក្រោម ។

នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។ ភិក្ខុពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។

[ ១៣៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ទៅនៅព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែនតាំងកាយឲ្យត្រង់ តម្កល់សតិឲ្យមានមុខឆ្ពោះទៅរក ( កម្មដ្ឋាន ) ។ ភិក្ខុនោះមានសតិ ដកដង្ហើមចេញ មានសតិដកដង្ហើមចូល ។ កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ។ កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។ កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី ។ ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងនូវកាយ គឺខ្យល់ទាំងពួង សឹមដកដង្ហើមចេញ ។ ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងនូវកាយ គឺខ្យល់ទាំងពួង សឹមដកដង្ហើមចូល ។ ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ គឺ

ដង្ហើមចេញ និងដង្ហើមចូល សឹមដកដង្ហើមចេញ ។ ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ សឹមដកដង្ហើមចូល ។ ម្នាលភិក្ខុទាំងឡាយ ជាងក្រឡឹង ឬកូនជាងរបស់ជាងក្រឡឹងដែលប៉ិនប្រសប់ កាលទាញខ្សែក្រឡឹងវែងក៏ដឹងច្បាស់ថា អាត្មាអញទាញខ្សែក្រឡឹងវែង ។ កាលទាញខ្សែក្រឡឹងខ្លី ក៏ដឹងច្បាស់ថា អាត្មាអញទាញខ្សែក្រឡឹងខ្លី មានឧបមាដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ។ កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។ កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី មានឧបមេយ្យដូច្នោះឯង ។ ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងនូវកាយ គឺខ្យល់ទាំងពួង សឹមដកដង្ហើមចេញ ។ ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងនូវកាយ គឺខ្យល់ទាំងពួង សឹមដកដង្ហើមចូល ។ ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ សឹមដកដង្ហើមចេញ ។ ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ សឹមដកដង្ហើមចូល ។ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង គឺកាយរបស់ខ្លួន ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្រៅ គឺកាយរបស់បុគ្គលដទៃ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយទាំងខាងក្នុងទាំងខាងក្រៅ គឺកាយរបស់ខ្លួន និងកាយរបស់បុគ្គលដទៃ ជាប្រក្រតី គ្រប់ឥរិយាបថ

ទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលប្រជុំកើតឡើងក្នុងកាយ គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលសូន្យទៅក្នុងកាយ គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលប្រជុំកើតឡើង និងធម៌ដែលសូន្យទៅក្នុងកាយ គ្រប់ឥរិយាបថទាំង ៤ ក្តី មួយទៀត ស្មារតីជាគ្រឿងកំណត់នូវកាយរបស់ភិក្ខុនោះក៏ផ្ចង់ឡើងចំពោះថា កាយនេះមាន ( ប៉ុន្តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម ) ល្មមតែកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ភិក្ខុនោះមានចិត្តមិនអាស្រ័យ ( តណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ ) គ្រប់ឥរិយាបថទាំង ៤ មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

## អានាបានបព្វៈ ។

[ ១៣៤ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទោះដើរក្តី ក៏ដឹងច្បាស់ថា អាត្មាអញដើរ ទោះឈរក្តី ក៏ដឹងច្បាស់ថា អាត្មាអញឈរ ទោះអង្គុយក្តី ក៏ដឹងច្បាស់ថា អាត្មាអញអង្គុយ ទោះដេកក្តី ក៏ដឹងច្បាស់ថា អាត្មាអញដេក ។ ម្យ៉ាងទៀត កាយរបស់ភិក្ខុនោះ តម្កល់នៅដោយអាការយ៉ាងណាៗ ក៏ដឹងច្បាស់នូវកាយ ដោយអាការយ៉ាងនោះៗ ។ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយខាងក្នុង ( ដោយការកំណត់នូវឥរិយាបថទាំង ៤ របស់ខ្លួន ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ដូច្នេះ ។បេ។ ម្នាលភិក្ខុទាំង

ឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

## ឥរិយាបថបព្វៈ ។

[ ១៣៥ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុធ្វើនូវសម្បជញ្ញៈ គឺសេចក្តីដឹងខ្លួន ជាប្រក្រតី ក្នុងការដើរទៅមុខ និងថយក្រោយ ធ្វើសេចក្តីដឹងខ្លួន ជាប្រក្រតី ក្នុងការប្រឡេកមើលទៅមុខ និងក្រឡេកមើលទៅទិសផ្សេងៗ ធ្វើសេចក្តីដឹងខ្លួនជាប្រក្រតីក្នុងការបត់ដៃជើង និងលាដៃជើង ធ្វើនូវសេចក្តីដឹងខ្លួន ជាប្រក្រតី ក្នុងការទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរ ធ្វើនូវសេចក្តីដឹងខ្លួនជាប្រក្រតី ក្នុងការបរិភោគភោជន និងផឹកទឹក ទំពាស៊ីខាទនិយវត្ថុ ទទួលរស ធ្វើនូវសេចក្តីដឹងខ្លួនជាប្រក្រតី ក្នុងការបន្ទោបង់នូវឧច្ចារៈ និងបស្សាវៈ ធ្វើនូវសេចក្តីដឹងខ្លួនជាប្រក្រតី ក្នុងការដើរ ឈរ អង្គុយ ដេក ភ្ញាក់ឡើង និយាយ និងភាពស្ងៀម ជាប្រក្រតី ។ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយខាងក្នុង ( ដោយការកំណត់នូវសម្បជញ្ញៈទាំង ៤ ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ដូច្នេះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

## សម្បជញ្ញបព្វៈ ។

[១៣៦] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ ( ក្នុងសាសនានេះ )

ពិចារណាឃើញនូវកាយនេះឯង ខាងលើតាំងពីបាតជើងឡើងទៅ ខាងក្រោមតាំងពីចុងសក់ចុះមក ដែលបិទបាំងដោយស្បែក ពេញដោយវត្ថុមិនស្អាតមានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយនេះ មានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃទាំងឡាយ ឆ្អឹងទាំងឡាយ ខួរក្នុងឆ្អឹង ទាច បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ទឹកប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ។ ម្នាលភិក្ខុទាំងឡាយ ( ធម្មតា ) ថង់ដែលមានមាត់ទាំងពីរខាង ពេញដោយធញ្ញជាតិមានប្រការផ្សេងៗ ធញ្ញ-ជាតិទាំងនោះ គឺស្រូវខ្សាយស ស្រូវខ្សាយក្រហម សណ្តែកបាយ សណ្តែករាជមាស ល្ង អង្ករ ។ បុរសមានចក្ខុ គប្បីស្រាយនូវមាត់ថង់នោះ ហើយពិចារណាឃើញច្បាស់ដូច្នេះថា នេះស្រូវខ្សាយស នេះស្រូវខ្សាយក្រហម នេះសណ្តែកបាយ នេះសណ្តែករាជមាស នេះល្ង នេះអង្ករ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយនេះឯង ខាងលើតាំងពីបាតជើងឡើងទៅ ខាងក្រោមតាំងពីចុងសក់ចុះមក ដែលបិទបាំងទៅដោយស្បែក ពេញទៅដោយវត្ថុមិនស្អាតមានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយនេះ មានសក់ រោម ។បេ។ ទឹករំអិល ទឹកមូត្រ មានឧបមេយ្យដូច្នោះឯង ។ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង ( ដោយការកំណត់នូវអាការ មានសក់ជាដើម ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ដូច្នេះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុង

កាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

បដិកូលបព្វៈ ។

[ ១៣៧ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញនូវកាយនេះឯង ដែលស្ថិតនៅហើយ យ៉ាងណា ដែលតម្កល់នៅហើយ យ៉ាងណា ដោយកំណត់ថា ជាធាតុ ដូច្នេះថា ក្នុងកាយនេះ មានបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ។ ម្នាលភិក្ខុទាំងឡាយ ធម្មតាបុរសអ្នកសម្លាប់គោក្តី អន្តេវាសិកនៃបុរសអ្នកសម្លាប់គោក្តី ដែលប៉ិនប្រសប់ សម្លាប់គោហើយ វែកញែកជាចំណែក អង្គុយនៅទៀបផ្លូវធំមានមុម ៤ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយនេះឯង ដែលស្ថិតនៅហើយ យ៉ាងណា ដែលតម្កល់នៅហើយ យ៉ាងណា ដោយកំណត់ថាជាធាតុ ដូច្នេះថា ក្នុងកាយនេះ មានបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ មានឧបមេយ្យដូច្នោះឯង ។ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ជាខាងក្នុង ដោយ ( ការកំណត់នូវធាតុទាំង ៤ ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ដូច្នេះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ធាតុបព្វៈ ។

[ ១៣៨ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីឃើញសរីរៈស្លាប់ ដែលគេបោលក្នុងព្រៃស្មសាន ទោះស្លាប់ហើយអស់ ១ ថ្ងៃក្តី ស្លាប់ហើយ

អស់ ២ ថ្ងៃក្តី ស្លាប់ហើយអស់ ៣ ថ្ងៃក្តី ដែលកំពុងហើមមានពណ៌ខៀវ ( ដោយច្រើន ) មានខ្ទុះហូរចេញ ( តាមទ្វារទាំង ៩ ) ដូចម្តេចមិញ ។ ភិក្ខុនោះ ក៏បង្អោនសរីរៈស្លាប់នោះ មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពជារបស់គួរខ្ពើមយ៉ាងនេះ គង់នឹងក្លាយទៅជាឧទ្ធុមាតកអសុភ ជាដើមយ៉ាងនេះ នឹងកន្លងចាកឧទ្ធុមាតកអសុភជាដើមនោះពុំបានឡើយ ។ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង ( ដោយការកំណត់ ) នូវអសុភ មានអសុភកំពុងហើមជាដើម ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ដូច្នេះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ ដែលគេចោលក្នុងព្រៃស្មសាន ដែលក្អែកកំពុងចឹកស៊ីក្តី ដែលពួកត្មាតកំពុងជញ្ជែងស៊ីក្តី ដែលពួកត្រដក់កំពុងចឹកស៊ីក្តី ដែលពួកស្វានកំពុងកកេរស៊ីក្តី ដែលពួកចចកកំពុងខាំស៊ីក្តី ដែលពួកបាណកជាតិផ្សេងៗ កំពុងស៊ីក្តី ។ ភិក្ខុនោះ ( ក៏បង្អោនសរីរៈស្លាប់នោះ ) មកប្រៀបធៀបនឹងកាយនេះឯងថា សូម្បីកាយនេះឯងសោត ក៏គង់នឹងមានសភាពជារបស់គួរខ្ពើមយ៉ាងនោះ គង់នឹងក្លាយទៅជាយ៉ាងនោះ នឹងកន្លងនូវភាពយ៉ាងនោះ ពុំបានឡើយ ។ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង ( ដោយការកំណត់នូវអសុភ មានអសុភដែលកំពុងហើមជាដើម ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ នេះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវ

កាយក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។ ម្នាល ភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីឃើញសរីរៈស្លាប់ ដែលគេចោលក្នុងព្រៃស្មសាន មានតែរាងឆ្អឹង ព្រមទាំងសាច់ និងឈាម មានសរសៃជាគ្រឿងចង យ៉ាងណាមិញ ។បេ។ នៅតែរាងឆ្អឹង ឥតមានសាច់ តែនៅប្រឡាក់ទៅដោយឈាមមានសរសៃជាគ្រឿងចង ។បេ។ នៅមានតែរាងឆ្អឹង ឥតមានសាច់ និងឈាម មានតែសរសៃជាគ្រឿងចង ។បេ។ នៅតែរាងឆ្អឹងទទេមិនមានសរសៃចងរួតរឹត ខ្ចាត់ខ្ចាយរាត់រាយទៅ ក្នុងទិសតូច និងទិសធំ គឺឆ្អឹងដៃទៅដោយឡែក ឆ្អឹងជើងទៅដោយឡែក ឆ្អឹងស្មងទៅដោយឡែក ឆ្អឹងភ្លៅទៅដោយឡែក ឆ្អឹងចង្កេះទៅដោយឡែក ឆ្អឹងខ្នងទៅដោយឡែក ឆ្អឹងជំនីរទៅដោយឡែក ឆ្អឹងទ្រូងទៅដោយឡែក ឆ្អឹងដើមដៃទៅដោយឡែក ឆ្អឹងស្មាទៅដោយឡែក ឆ្អឹងកទៅដោយឡែក ឆ្អឹងចង្កាទៅដោយឡែក ឆ្អឹងធ្មេញទៅដោយឡែក ឆ្អឹងក្បាលទៅឡែក ។ ភិក្ខុនោះ ( ក៏បង្អោនសរីរៈស្លាប់នោះ ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពជារបស់គួរខ្ពើមយ៉ាងនេះ គង់នឹងមានប្រភេទ ( ក្លាយទៅ ) ជាយ៉ាងនោះ នឹងកន្លងចាកសភាពយ៉ាងនោះពុំបានឡើយ ។ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង ( ដោយការកំណត់នូវអសុភ មានឧទ្ធុមាតកាសុភជាដើម ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះក្តី ។បេ។ ម្នាល ភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត

ភិក្ខុគប្បីឃើញសរីរៈស្លាប់ ដែលគេចោលក្នុងព្រៃស្មសាន នៅសល់តែរាងឆ្អឹងទទេ មានពណ៌ស ដូចជាពណ៌នៃស័ង្ខ យ៉ាងណាមិញ ... ។ សល់តែរាងឆ្អឹង រោយរាយជាពំនូកៗ កន្លងទៅ ១ ឆ្នាំហើយ ... ។ នៅសល់តែរាងឆ្អឹងទទេ ពុកផុយខ្ទេចខ្ទី ជាលម្អិតតូចលម្អិតធំ ។ ភិក្ខុនោះ ( បង្អោនសរីរៈស្លាប់នោះ ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះសោតក៏គង់នឹងមានសភាពជារបស់គួរខ្ពើមយ៉ាងនោះ គង់នឹងមានប្រភេទ ក្លាយទៅជាយ៉ាងនោះ នឹងកន្លងចាកសភាពយ៉ាងនោះ ពុំបានឡើយ ។ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង ( ដោយការកំណត់នូវអសុភដែលសត្វកំពុងចឹកស៊ីជាដើម ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ដូច្នេះក្តី ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ជាខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវសមុទយធម៌ក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញនូវវយធម៌ក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវសមុទយធម៌ និងវយធម៌ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពុំនោះសោត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថាកាយនេះមានមែន ( តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម ) គ្រាន់តែជាទីកំណត់ ដើម្បីឲ្យកើតប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុនោះមានចិត្តមិនអាស្រ័យ ( តណ្ហានិស្ស័យ និងទិដ្ឋិ-

និស្ស័យ ) ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

## នវសីវថិកាបព្វៈ
## កាយានុបស្សនាសតិប្បដ្ឋាន ចប់

[ ១៣៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលទទួលសុខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា កាលទទួលទុក្ខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា កាលទទួលអទុក្ខមសុខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា ដូច្នេះ ។ កាលទទួលសុខវេទនា ប្រកបដោយអាមិស គឺបញ្ចកាមគុណក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខ-វេទនា ប្រកបដោយអាមិស កាលទទួលសុខវេទនា មិនប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា មិនប្រកបដោយអាមិស ។ កាលទទួលទុក្ខវេទនា ប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនាប្រកបដោយអាមិស កាលទទួលទុក្ខវេទនា មិនប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា មិនប្រកបដោយអាមិស ។ កាលទទួលអទុក្ខមសុខវេទនា ប្រកបដោយអាមិស

ក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា ប្រកបដោយអាមិស កាលទទួលអទុក្ខមសុខវេទនា មិនប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា មិនប្រកបដោយអាមិស ដូច្នេះ ។ ភិក្ខុពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយជាខាងក្នុង ជាប្រក្រតី ( ដោយការកំណត់នូវវេទនា មានសុខវេទនាជាដើម ) គ្រប់ឥរិយាបថទាំង ៤ ដូច្នេះក្តី ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយជាខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយជាខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងវេទនាទាំងឡាយ គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយ គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងវេទនាទាំង-ឡាយ គ្រប់ឥរិយាបថទាំង ៤ ក្តី ពុំនោះសោត ស្មារតី ( ជាគ្រឿងកំណត់នូវវេទនា ) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា វេទនាមានមែន ( តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម ) គ្រាន់តែជាទីកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុនោះមានចិត្តមិនអាស្រ័យ ( ដោយតណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ ជា

ប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

## វេទនានុបស្សនាសតិប្បដ្ឋាន ។

[១៤០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗនូវចិត្តក្នុងចិត្ត ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះចិត្តប្រកបដោយរាគៈ ( គឺលោភមូល ៨ ប្រការ ) ក៏ ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ទោះប្រាសចាករាគៈ ( គឺលោកិយ-កុសលចិត្ត និងអព្យាកតចិត្ត ) ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ។ ទោះចិត្តប្រកបដោយទោសៈ ( គឺទោសមូលពីរប្រការ ) ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ទោះចិត្តប្រាសចាកទោសៈ ( គឺលោកិយកុសលចិត្ត និងអព្យាកតចិត្ត ) ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ។ ទោះចិត្តប្រកបដោយមោហៈ ( គឺមោហមូលពីរប្រការ ) ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ទោះចិត្តប្រាសចាកមោហៈ ( គឺលោកិយកុសលចិត្ត និងអព្យាកត-ចិត្ត ) ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ។ ទោះចិត្តរួញរា ( គឺចិត្តដែលថីនមិទ្ធៈគ្របសង្កត់ ) ក៏ដឹងច្បាស់ថា ចិត្តរួញរា ទោះចិត្តរាយមាយ ( ឧទ្ធច្ចសហគតចិត្ត ) ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ។ ទោះចិត្តដល់នូវភាវៈប្រសើរ ( គឺជារូបាវចរចិត្ត និងអរូបាវចរចិត្ត ) ក៏ដឹងច្បាស់ថា ចិត្តដល់នូវភាវៈប្រសើរ ទោះចិត្តមិនដល់នូវភាវៈប្រសើរ ( គឺកាមាវចរចិត្ត ) ក៏ដឹងច្បាស់ថា ចិត្តមិនដល់នូវភាវៈប្រសើរ ។ ទោះចិត្តនៅមានចិត្តដទៃប្រសើរ

ជាង ( គឺកាមាវចរចិត្ត ) ក៏ដឹងច្បាស់ថា ចិត្តនៅមានចិត្តដទៃប្រសើរជាង ទោះចិត្តមិនមានចិត្តដទៃប្រសើរជាង ( គឺរូបាវចរចិត្ត និងអរូបាវចរចិត្ត ) ក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃប្រសើរជាង ។ ទោះចិត្តតម្កល់នៅមាំ ( គឺអប្បនាសមាធិ និងឧបចារសមាធិ ) ក៏ដឹងច្បាស់ថា ចិត្តតម្កល់នៅមាំ ទោះចិត្តមិនតម្កល់នៅមាំ ( គឺប្រាសចាកសមាធិទាំង ២ ) ក៏ដឹងច្បាស់ថា ចិត្តមិនតម្កល់នៅមាំ ។ ទោះចិត្តរួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះ ទោះចិត្តមិនទាន់រួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ ។ ភិក្ខុពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តជាខាងក្នុង ( ដោយការកំណត់នូវចិត្តប្រកបដោយរាគៈជាដើម ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចា-រណាឃើញរឿយៗ នូវចិត្តក្នុងចិត្តជាខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តជាខាងក្នុង និងខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងចិត្តជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលសូន្យទៅក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលជាទីប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពុំនោះសោត ស្មារតី ( ជាគ្រឿងកំណត់នូវចិត្តដែលប្រកបដោយរាគៈជាដើម ) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ចិត្តមានមែន ( តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម ) គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា

ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ភិក្ខុនោះ មានចិត្តមិនអាស្រ័យ ( តណ្ហា-និស្ស័យ និងទិដ្ឋិនិស្ស័យ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្ត ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

## ចិត្តានុបស្សនាសតិប្បដ្ឋាន ។

[ ១៤១ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គឺនីវរណៈទាំង ៥ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គឺនីវរណៈទាំង ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះកាមច្ឆន្ទៈមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះកាមច្ឆន្ទៈមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះកាមច្ឆន្ទៈដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវកាមច្ឆន្ទៈដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កាមច្ឆន្ទៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះព្យាបាទមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមាននៅក្នុងសន្តានចិត្តរបស់

អាត្មាអញ ទោះព្យាបាទមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះព្យាបាទដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវព្យាបាទដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ព្យាបាទដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះថីនមិទ្ធៈមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះថីនមិទ្ធៈមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះថីនមិទ្ធៈដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវថីនមិទ្ធៈដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ថីនមិទ្ធៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះឧទ្ធច្ចកុក្កុច្ចៈដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះឧទ្ធច្ចកុក្កុច្ចៈ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈ មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ឧទ្ធច្ចកុក្កុច្ចៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយ

ហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះវិចិកិច្ឆាមាននៅក្នុងសន្តាន ចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆាមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះ វិចិកិច្ឆាមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆាមាននៅក្នុង សន្តានចិត្តរបស់អាត្មាអញ ។ ទោះវិចិកិច្ឆា មិនទាន់កើតឡើង ហើយកើត ឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវ វិចិកិច្ឆាដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង វិចិកិច្ឆាដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹង ច្បាស់នូវហេតុនោះផង ។ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំង-ឡាយជាខាងក្នុង ( ដោយការកំណត់នូវនីវរណធម៌ ៥ យ៉ាង ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថ ទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលជាទីប្រជុំកើតឡើង ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញ រឿយៗ នូវធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថ ទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលជាទីប្រជុំកើតឡើង ទាំង ធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពុំនោះសោត ស្មារតី ( ជាគ្រឿងកំណត់នូវនីវរណធម៌ ៥ យ៉ាង ) របស់ ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌មានមែន ( តែមិនមែនសត្វ មិនមែន

បុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម ) គ្រាន់តែជាទីកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ភិក្ខុមានចិត្តមិនអាស្រ័យ ( ដោយតណ្ហា និងទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺនីវរណធម៌ទាំង ៥ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

## នីវរណបព្វៈ ។

[ ១៤២ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធទាំង ៥ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធទាំង ៥ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ( ពិចារណាឃើញរឿយៗ ដូច្នេះថា ) រូបមានប្រមាណប៉ុណ្ណោះ ធម៌ដែលជាដែនកើតឡើងនៃរូបមានប្រមាណប៉ុណ្ណោះ ធម៌ដែលជាដែនរលត់ទៅនៃរូបមានប្រមាណប៉ុណ្ណោះ វេទនាមានប្រមាណប៉ុណ្ណោះ ធម៌ដែលជាដែនកើតឡើងនៃវេទនាមានប្រមាណប៉ុណ្ណោះ ធម៌ដែលជាដែនរលត់ទៅនៃវេទនាមានប្រមាណប៉ុណ្ណោះ សញ្ញាមានប្រមាណប៉ុណ្ណោះ ធម៌ដែលជាដែនកើតឡើងនៃសញ្ញាមានប្រមាណប៉ុណ្ណោះ ធម៌ដែលជាដែនរលត់ទៅនៃសញ្ញាមានប្រមាណប៉ុណ្ណោះ សង្ខារទាំងឡាយមានប្រមាណ

ប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃសង្ខារទាំងឡាយ មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនរលត់ទៅនៃសង្ខារទាំងឡាយមានប្រមាណប៉ុណ្ណេះ វិញ្ញាណ មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃវិញ្ញាណ មានប្រមាណ ប៉ុណ្ណេះ ធម៌ដែលជាដែនរលត់ទៅនៃវិញ្ញាណមានប្រមាណប៉ុណ្ណេះ ។ ភិក្ខុ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង ( ដោយការ កំណត់នូវឧបាទានក្ខន្ធទាំង ៥ ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្រៅជាប្រក្រតី គ្រប់ ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជា ខាងក្នុង និងខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណា ឃើញរឿយៗ នូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលសូន្យទៅក្នុង ធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ដែលជាទីប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជា ប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពុំនោះសោត ស្មារតី ( ជាគ្រឿងកំណត់ នូវឧបាទានក្ខន្ធ ) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌មានមែន ( តែ មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុស ) គ្រាន់តែជាទី កំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ភិក្ខុមានចិត្តមិន អាស្រ័យ ( ដោយតណ្ហា និងទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិន ប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណា

ឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធទាំង ៥ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

**ខន្ធបព្វៈ ។**

[ ១៤៣ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ៦ ទាំងខាងក្នុង និងខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ៦ ទាំងខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវចក្ខុប្រសាទផង ដឹងច្បាស់នូវរូបារម្មណ៍ទាំងឡាយផង មួយវិញទៀត សំយោជនធម៌ណាដែលអាស្រ័យនូវភ្នែក និងរូបទាំងពីរនោះ ហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនធម៌នោះផង ។ សំយោជនធម៌ដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កាលលះបង់បាននូវសំយោជនធម៌ដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សំយោជនធម៌ដែលលះបង់បានហើយ មិនកើតឡើងទៅទៀតដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុដឹងច្បាស់នូវសោតប្រសាទផង ដឹងច្បាស់នូវសទ្ទារម្មណ៍ទាំងឡាយផង...។ ដឹងច្បាស់នូវឃានប្រសាទផង ដឹងច្បាស់នូវគន្ធារម្មណ៍ទាំងឡាយផង ... ។ ដឹងច្បាស់នូវជិវ្ហាប្រសាទផង ដឹងច្បាស់នូវរសារម្មណ៍

ទាំងឡាយផង ... ។ ដឹងច្បាស់នូវកាយប្រសាទផង ដឹងច្បាស់នូវផោដ្ឋព្វា-រម្មណ៍ទាំងឡាយផង ... ។ ដឹងច្បាស់នូវចិត្តផង ដឹងច្បាស់នូវធម្មារម្មណ៍ទាំងឡាយផង មួយទៀត សំយោជនធម៌ណា ដែលអាស្រ័យនូវចិត្ត និងធម្មារម្មណ៍ទាំងពីរនោះ ហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនធម៌នោះផង ។ សំយោជនធម៌ដែលមិនទាន់កើតឡើង ក៏កើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវសំយោជនធម៌ ដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សំយោជនធម៌ដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាចំណែកខាងក្នុង ( ដោយការកំណត់នូវអាយតនៈខាងក្នុង ) ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាចំណែកខាងក្រៅក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាចំណែកខាងក្នុង និងខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវសមុទយធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថ ទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវវយធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយា-បថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវសមុទយធម៌ និងវយធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពុំនោះសោត ស្មារតី ( ជាគ្រឿងកំណត់នូវអាយតនៈ ) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌ទាំងឡាយមានមែន ( តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែន

ប្រុសជាដើម ) គ្រាន់តែជាទីកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ ( តណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ៦ ទាំងខាងក្នុងខាងក្រៅជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

## អាយតនបព្វៈ ។

[ ១៨៤ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គ ( អង្គធម៌ជាគ្រឿងត្រាស់ដឹង ) ៧ ប្រការជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គ ៧ ប្រការ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះសតិសម្ពោជ្ឈង្គ ដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះសតិសម្ពោជ្ឈង្គដែលមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ មិនមានក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះសតិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង កើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការចម្រើនឡើងបរិបូណ៌នៃសតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ

ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ទោះធម្មវិចយសម្ពោជ្ឈង្គដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន ... ។ ទោះវីរិយសម្ពោជ្ឈង្គ ដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន ... ។ ទោះបីតិសម្ពោជ្ឈង្គដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន ... ។ ទោះបស្សទ្ធិសម្ពោជ្ឈង្គដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន ... ។ ទោះសមាធិសម្ពោជ្ឈង្គ ដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន ... ។ ទោះឧបេក្ខាសម្ពោជ្ឈង្គដែលមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះឧបេក្ខាសម្ពោជ្ឈង្គដែលមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះឧបេក្ខាសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង កើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការចម្រើនពេញបរិបូណ៌នៃឧបេក្ខាសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាចំណែកខាងក្នុង ជាប្រក្រតី ( ដោយការកំណត់នូវសម្ពោជ្ឈង្គទាំង ៧ ) គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាចំណែកខាងក្រៅ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាចំណែកខាងក្នុង និងខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវសមុទយធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវវយធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយា-

បថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវសមុទយធម៌ និងវយធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពុំនោះសោត ស្មារតី ( ជាគ្រឿងកំណត់នូវសម្ពោជ្ឈង្គទាំង ៧ ) របស់ភិក្ខុនោះក៏ផ្ចង់ឡើងចំពោះថា ធម៌មានមែន ( តែមិនមែនសត្វ-បុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម ) គ្រាន់តែជាទីកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ភិក្ខុមានចិត្តមិនអាស្រ័យ ( តណ្ហា និងទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គទាំង ៧ ប្រការជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

## ពោជ្ឈង្គបព្វៈ ។

[ ១៤៥ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចទាំង ៤ គ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ច ៤ គ្រប់ឥរិយាបថទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទុក្ខសមុទយៈ ដឹងច្បាស់តាមពិតថា នេះជាទុក្ខនិរោធ ដឹងច្បាស់តាមពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាចំណែកខាងក្នុង ( ដោយការកំណត់នូវអរិយសច្ចទាំង

៤ ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាចំណែកខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាចំណែកខាងក្នុងខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវសមុទយ-ធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវវយធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវសមុទយធម៌ និងវយធម៌ ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពុំនោះសោត ស្មារតី ( ជាគ្រឿងកំណត់នូវអរិយសច្ចទាំង ៤ ) របស់ភិក្ខុនោះក៏ផ្ចង់ឡើងចំពោះថា ធម៌មានមែន ( តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម ) គ្រាន់តែជាគ្រឿងកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ភិក្ខុមានចិត្តមិនអាស្រ័យ ( តណ្ហា និងទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចទាំង ៤ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

**សច្ចបព្វៈ**

**ភាណវារៈ ជាបឋម ចប់**

[១៨៦] ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខអរិយសច្ចតើដូចម្តេច ។ ជាតិក៏ជាទុក្ខ ជរាក៏ជាទុក្ខ មរណៈក៏ជាទុក្ខ សោកៈ បរិទេវៈ គឺសេចក្តីខ្សឹកខ្សួល ទុក្ខៈ

គឺសេចក្តីលំបាកកាយ ទោមនស្សៈ គឺសេចក្តីអាក់អន់តូចចិត្ត ឧបាយាសៈ គឺសេចក្តីចង្អៀតចង្អល់ចិត្ត ក៏សុទ្ធតែជាទុក្ខ អប្បិយេហិសម្បយោគៈ គឺដំណើរជួបប្រសព្វដោយសត្វ និងសង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់ ក៏ជាទុក្ខ បិយេហិវិប្បយោគៈ គឺសេចក្តីព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយដែលជាទីស្រឡាញ់ក៏ជាទុក្ខ យម្បិច្ឆំនលភតិតម្បិ គឺបុគ្គលចង់បាននូវរបស់ណាហើយ មិនបាននូវរបស់នោះក៏ជាទុក្ខ បើពោលដោយសេចក្តីបង្រួញ ឧបាទានក្ខន្ធទាំង ៥ មានរូបក្ខន្ធជាដើមក៏ជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ជាតិ ។ កិរិយាកើតជាដំបូង កិរិយាកើតព្រម ការចុះចាប់ផ្ទៃ ការវិលត្រឡប់មកកើត កិរិយាកើតប្រាកដនៃខន្ធទាំងឡាយ ការបាននូវអាយតនៈទាំងឡាយណា របស់សត្វទាំងឡាយនោះៗ ក្នុងសត្តនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ជាតិ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ជរា ។ ជរា គឺសេចក្តីគ្រាំគ្រា ឬការប្រែប្រួល ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវយុរយារ កិរិយាថយទៅនៃអាយុ កិរិយាទ្រុឌទ្រោមទៅនៃឥន្ទ្រិយទាំងឡាយណា របស់សត្វទាំងឡាយនោះៗ ក្នុងសត្តនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ជរា ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា មរណៈ ។ ភាវៈនៃចិត្តដែលឃ្លាតចេញ អាការនៃចិត្តដែលឃ្លាតទៅ កិរិយាបែកធ្លាយទៅ កិរិយាបាត់បង់ទៅ សេចក្តីវិនាសនៃជីវិត សេចក្តីស្លាប់ កាលកិរិយា សេចក្តីបែកធ្លាយនៃខន្ធទាំងឡាយ កិរិយាដាក់ចុះនៃសាកសព កិរិយាផ្តាច់បង់នូវជីវិតិន្ទ្រិយណា របស់សត្វទាំង-

ឡាយនោះៗ ចាកសត្តនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា មរណៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សោកៈ ។ ម្នាលភិក្ខុទាំងឡាយ សោកៈ គឺសេចក្តីស្តាយស្រណោះ សេចក្តីស្រងេះស្រងោចសេចក្តីសោយសោក សេចក្តីរីងស្ងួតក្នុងចិត្ត សេចក្តីក្រៀមក្រំក្នុងចិត្តណារបស់សត្វដែលប្រកបដោយសេចក្តីវិនាសណាមួយ ដែលសេចក្តីទុក្ខណាមួយពាល់ត្រូវ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សោកៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា បរិទេវៈ ។ ម្នាលភិក្ខុទាំងឡាយ ការៈទួញរក ( បិយជន មានកូនជាដើម ) ការៈទួញរៀបរាប់ ( សរសើរគុណ ) កិរិយាយំអណ្តឺតអណ្តក កិរិយាយំបម្រះនទៀល ការៈនៃកិរិយាយំអណ្តឺតអណ្តក ការៈនៃកិរិយាយំបម្រះនទៀលណា របស់សត្វដែលប្រកបដោយសេចក្តីវិនាសណាមួយ ដែលសេចក្តីទុក្ខណាមួយពាល់ត្រូវ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា បរិទេវៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទុក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីលំបាកកាយ សេចក្តីមិនសប្បាយកាយ សេចក្តីលំបាកដែលកើតអំពីកាយសម្ផស្ស ការទទួលវេទនាមិនស្រួលណា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទោមនស្សៈ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីលំបាកក្នុងចិត្ត សេចក្តីមិនសប្បាយក្នុងចិត្ត សេចក្តីលំបាកដែលកើតអំពីមនោសម្ផស្ស ការសោយអារម្មណ៍មិនស្រួលណា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទោមនស្សៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា

ឧបាយាសៈ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីតានតឹងក្នុងចិត្ត សេចក្តីចង្អៀតចង្អល់ក្នុងចិត្ត ភាវៈនៃសេចក្តីតានតឹងក្នុងចិត្ត ភាវៈនៃសេចក្តីចង្អៀតចង្អល់ចិត្តណា របស់សត្វដែលប្រកបដោយសេចក្តីវិនាសណាមួយ ដែលសេចក្តីទុក្ខណាមួយពាល់ត្រូវ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ឧបាយាសៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា អប្បិយេហិសម្បយោគទុក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយណា ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្តក្នុងលោកនេះ មានដល់ជននោះ ពុំនោះសោត ពួកជនណាដែលប្រាថ្នានូវសេចក្តីមិនចម្រើន ប្រាថ្នានូវអំពើឥតប្រយោជន៍ ប្រាថ្នានូវសេចក្តីមិនសប្បាយ ប្រាថ្នានូវសេចក្តីមិនក្សេមក្សាន្តចាកយោគៈដល់សត្វនោះ ការបានជួបគ្នា ការជួបជុំគ្នា ការប្រជុំគ្នា ការនៅប្រឡូកប្រឡំគ្នាណា ដោយអារម្មណ៍នឹងជនទាំងឡាយនោះ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា អប្បិយេហិសម្បយោគទុក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា បិយេហិវិប្បយោគទុក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយណា ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្តក្នុងលោកនេះ មានដល់ជននោះ ពុំនោះសោត ពួកជនណា ទោះមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី មិត្តក្តី អាមាត្យក្តី ញាតិសាលោហិតក្តី ដែលជាអ្នកប្រាថ្នាសេចក្តីចម្រើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីសប្បាយ ប្រាថ្នាសេចក្តីក្សេមក្សាន្តចាកយោគៈ មានដល់ជននោះ

ការមិនបានជួបគ្នា ការមិនបានជួបជុំគ្នា ការមិនបានប្រជុំគ្នា ការមិនបាននៅប្រឡូកប្រឡំណា ដោយអារម្មណ៍នឹងជនទាំងឡាយនោះ ម្នាលភិក្ខុទាំងឡាយនេះ តថាគតហៅថា បរិយេហិវិប្បយោគទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានជាតិជាធម្មតា តែងមានសេចក្ដីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើម្ដេចហ្ន៎ ឲ្យយើងទាំងឡាយកុំគប្បីមានជាតិជាធម្មតា ពុំនោះសោត ធ្វើម្ដេចហ្ន៎ ជាតិ កុំគប្បីមកដល់យើងឡើយ សេចក្ដីនេះ ពួកសត្វក៏មិនបានសម្រេចតាមប្រាថ្នាឡើយ នេះឯងតថាគតហៅថា យម្បិច្ឆំ ន លភតិ តម្បិទុក្ខ: ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្ដីគ្រាំគ្រា ឬប្រែប្រួលជាធម្មតា ... ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្ដីឈឺថ្កាត់ជាធម្មតា .... ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្ដីស្លាប់ជាធម្មតា .... ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ សេចក្ដីអាក់អន់តូចចិត្ត សេចក្ដីខ្ចាចផ្សាចិត្ត ជាធម្មតា តែងមានសេចក្ដីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើម្ដេចហ្ន៎ ឲ្យយើងទាំងឡាយ កុំគប្បីមានសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ សេចក្ដីអាក់អន់តូចចិត្ត សេចក្ដីខ្ចាចផ្សាចិត្តឡើយ មួយទៀត ធ្វើម្ដេចហ្ន៎ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ សេចក្ដីអាក់អន់តូចចិត្ត សេចក្ដីខ្ចាចផ្សាចិត្ត កុំគប្បីមកដល់យើងឡើយ សេចក្ដីនេះ ពួកសត្វក៏មិនបានសម្រេចតាមប្រាថ្នា នេះឯង តថាគតហៅថា យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ

ចុះដូចម្តេច ឧបាទានក្ខន្ធទាំង ៥ ដោយបង្រួញ ដែលថាជាទុក្ខ ឧបាទានក្ខន្ធទាំង ៥ នោះ គឺអ្វីខ្លះ គឺរូបជាឧបាទានក្ខន្ធ ១ វេទនាជាឧបាទានក្ខន្ធ ១ សញ្ញាជាឧបាទានក្ខន្ធ ១ សង្ខារជាឧបាទានក្ខន្ធ ១ វិញ្ញាណជាឧបាទានក្ខន្ធ ១ ម្នាលភិក្ខុទាំងឡាយ ទាំងនេះ តថាគតហៅថា ឧបាទានក្ខន្ធទាំង ៥ ដោយសេចក្តី បំព្រួមដែលថាជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខអរិយសច្ច ។

[ ១៤៧ ] ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទុក្ខសមុទយអរិយសច្ច ។ តណ្ហាណា ជាធម្មជាតិនាំសត្វ ឲ្យកើតទៀត ប្រកបដោយតម្រេករីករាយ ជាធម្មជាតិនាំសត្វ ឲ្យត្រេកត្រអាលក្នុងភពនោះៗ ឬក្នុងអារម្មណ៍នោះៗ តណ្ហានោះ តើគឺអ្វីខ្លះ គឺកាមតណ្ហា ( សេចក្តីប្រាថ្នាក្នុងកាមគុណ ) ១ ភវតណ្ហា ( សេចក្តីប្រាថ្នាក្នុងរូបភព និងអរូបភព ) ១ វិភវតណ្ហា ( សេចក្តីប្រាថ្នាក្នុងភពសូន្យ ) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហានោះ កាលដែលកើតឡើង តើកើតឡើងក្នុងទីណា កាលដែលជាប់នៅ តើជាប់នៅក្នុងទីណា ។ អារម្មណ៍ណាដែលមានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងអារម្មណ៍នោះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងអារម្មណ៍នោះ ។ អារម្មណ៍អ្វីមួយដែលមានសភាវៈ គួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក ។ ភ្នែកមានសភាវៈ គួរស្រឡាញ់ មានសភាវៈ គួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងភ្នែកនោះ កាលដែលជាប់នៅក៏ជាប់នៅ

ក្នុងភ្នែកនោះ ។ ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងត្រចៀកជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងត្រចៀកជាដើមនោះ ។ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ដែលមានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងរូបជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងរូបជាដើមនុ៎ះ ។ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងតែក្នុងចក្ខុវិញ្ញាណជាដើមនោះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងចក្ខុវិញ្ញាណជាដើមនោះ ។ ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងចក្ខុ-សម្ផស្សជាដើមនោះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងចក្ខុសម្ផស្សជាដើមនុ៎ះ ។ វេទនាដែលកើតអំពីចក្ខុសម្ផស្ស វេទនាដែលកើតអំពីសោតសម្ផស្ស វេទនាដែលកើតអំពីឃានសម្ផស្ស វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស វេទនាដែលកើតអំពីកាយសម្ផស្ស វេទនាដែលកើតអំពីមនោសម្ផស្ស មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងតែក្នុងវេទនា ដែលកើតអំពីចក្ខុសម្ផស្សជាដើមនុ៎ះ កាល

ដែលជាប់នៅ ក៏ជាប់នៅក្នុងវេទនា ដែលកើតអំពីចក្ខុសម្ផស្សជាដើមនុ៎ះ ។ រូបសញ្ញា ( សេចក្តីសម្គាល់ក្នុងរូប ) សទ្ទសញ្ញា ( សេចក្តីសម្គាល់ក្នុងសំឡេង ) គន្ធសញ្ញា ( សេចក្តីសម្គាល់ក្នុងក្លិន ) រសសញ្ញា ( សេចក្តីសម្គាល់ក្នុងរស ) ផោដ្ឋព្វសញ្ញា ( សេចក្តីសម្គាល់ក្នុងផោដ្ឋព្វៈ ) ធម្មសញ្ញា ( សេចក្តីសម្គាល់ក្នុងធម្មារម្មណ៍ ) មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងតែក្នុងរូបសញ្ញាជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងរូបសញ្ញាជាដើមនុ៎ះ ។ រូបសញ្ចេតនា ( ការគិតសន្សំនូវរូបារម្មណ៍ ) សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងការគិតសន្សំនូវរូបារម្មណ៍ជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងរូបារម្មណ៍ជាដើមនុ៎ះ ។ រូបតណ្ហា ( សេចក្តីស្រេកឃ្លានក្នុងរូបារម្មណ៍ ) សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងរូបារម្មណ៍ជាដើមនោះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងរូបជាដើមនុ៎ះ ។ រូបវិតក្ក ( សេចក្តីត្រិះរិះក្នុងរូបារម្មណ៍ ) សទ្ទវិតក្ក គន្ធវិតក្ក រសវិតក្ក ផោដ្ឋព្វវិតក ធម្មវិតក្ក មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងសេចក្តីត្រិះរិះក្នុងរូបជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុង

សេចក្តីត្រិះរិះ ក្នុងរូបជាដើមនុ៎ះ ។ រូបវិចារៈ ( សភាពពិចារណានូវរូបារម្មណ៍ ) សទ្ទវិចារៈ គន្ធវិចារៈ រសវិចារៈ ផោដ្ឋព្វវិចារៈ ធម្មវិចារៈ មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងសេចក្តីពិចារណានូវរូបជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងរូបជាដើមនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខសមុទយអរិយសច្ច ។

[១៤៨] ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទុក្ខនិរោធអរិយសច្ច ។ កិរិយាប្រាសចាកតម្រេក រំលត់មិនមានសេសសល់ដោយអរិយមគ្គ កិរិយាលះបង់ កិរិយារលាស់ចេញ ការរួចស្រឡះ ការមិនអាល័យនូវតណ្ហានុ៎ះ ( ឈ្មោះថា ជាទុក្ខនិរោធអរិយសច្ច ) ។ ម្នាលភិក្ខុទាំងឡាយ តណ្ហានុ៎ះឯង ដែលបុគ្គលលះបង់ តើលះបង់ក្នុងទីណា កាលដែលរលត់ទៅ តើរលត់ទៅក្នុងទីណា ។ អារម្មណ៍ណាដែលមានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងអារម្មណ៍នុ៎ះ កាលរលត់ ក៏រលត់ក្នុងអារម្មណ៍នុ៎ះ ។ អារម្មណ៍ដូចម្តេចដែលមានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក ។ ភ្នែកមានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងភ្នែកនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងភ្នែកនុ៎ះ ។ ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏

លះបង់ក្នុងត្រចៀកជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងត្រចៀកជាដើមនុ៎ះ ។ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ធម្មារម្មណ៍ មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ ដែលបុគ្គលលះបង់ ក៏លះបង់ក្នុងរូបារម្មណ៍ជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងរូបារម្មណ៍ជាដើមនុ៎ះ ។ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ក៏លះបង់ ក្នុងចក្ខុវិញ្ញាណជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងចក្ខុវិញ្ញាណជាដើមនុ៎ះ ។ ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងចក្ខុសម្ផស្សជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងចក្ខុសម្ផស្សជាដើមនុ៎ះ ។ វេទនាដែលកើតអំពីចក្ខុសម្ផស្ស វេទនាដែលកើតអំពីសោតសម្ផស្ស វេទនាដែលកើតអំពីឃានសម្ផស្ស វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស វេទនាដែលកើតអំពីកាយសម្ផស្ស វេទនាដែលកើតអំពីមនោសម្ផស្ស មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងវេទនាដែលកើតអំពីចក្ខុសម្ផស្សជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងវេទនា ដែលកើតអំពីចក្ខុសម្ផស្សជាដើមនុ៎ះ ។ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា មាន

សភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងរូបសញ្ញាជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងរូបសញ្ញាជាដើមនុ៎ះ ។ រូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងរូបសញ្ចេតនាជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងរូបសញ្ចេតនាជាដើមនុ៎ះ ។ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងរូបតណ្ហាជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងរូបតណ្ហាជាដើមនុ៎ះ ។ រូបវិតក្ក សទ្ទវិតក្ក គន្ធវិតក្ក រសវិតក្ក ផោដ្ឋព្វវិតក្ក ធម្មវិតក្ក មានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងរូបវិតក្កជាដើមនុ៎ះ កាលរលត់ទៅក៏រលត់ទៅក្នុងរូបវិតក្កជាដើមនុ៎ះ ។ រូបវិចារៈ សទ្ទវិចារៈ គន្ធវិចារៈ រសវិចារៈ ផោដ្ឋព្វវិចារៈ ធម្មវិចារៈ មានសភាវៈគួរស្រឡាញ់ មានសភាៈវគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងរូបវិចារៈជាដើមនុ៎ះ កាលរលត់ទៅ ក៏រលត់ទៅក្នុងរូបវិចារៈជាដើមនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខនិរោធអរិយសច្ច ។

[១៨៩] ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទុក្ខនិរោធគាមិនី-

បដិបទាអរិយសច្ច ។ អរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះ គឺសម្មាទិដ្ឋិ ( ប្រាជ្ញាយល់ត្រូវ ) ១ សម្មាសង្កប្ប ( ប្រាជ្ញាត្រិះរិះត្រូវ ) ១ សម្មាវាចា ( សម្តីត្រូវ ) ១ សម្មាកម្មន្តៈ ( ការងារត្រូវ ) ១ សម្មាអាជីវៈ ( ចិញ្ចឹមជីវិតត្រូវ ) ១ សម្មាវាយាមៈ ( ការព្យាយាមត្រូវ ) ១ សម្មាសតិ ( ការតម្កល់ស្មារតីត្រូវ ) ១ សម្មាសមាធិ ( ការតាំងចិត្តត្រូវ ) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សម្មាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាជាគ្រឿងដឹងក្នុងកងទុក្ខណា ប្រាជ្ញាជាគ្រឿងដឹងក្នុងតណ្ហាជាដែនឲ្យកើតនៃកងទុក្ខណា ប្រាជ្ញាជាគ្រឿងដឹងក្នុងធម៌ជាទីរលត់នៃកងទុក្ខណា ប្រាជ្ញាជាគ្រឿងដឹងក្នុងដំណើរជាទីទៅកាន់ទីរលត់ទុក្ខណា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ហៅថា សម្មាសង្កប្ប ។ សេចក្តីត្រិះរិះក្នុងកិរិយាចេញចាកកាម ១ សេចក្តីត្រិះរិះក្នុងកិរិយាមិនព្យាបាទ ១ សេចក្តីត្រិះរិះក្នុងការមិនបៀតបៀន ១ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាសង្កប្ប ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សម្មាវាចា ។ ចេតនាវៀរចាកមុសាវាទ ១ ចេតនាវៀរចាកបិសុណាវាចា ១ ចេតនាវៀរចាកផរុសវាចា ១ ចេតនាវៀរចាកសម្ផប្បលាបៈ ១ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាវាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សម្មាកម្មន្តៈ ។ ចេតនាវៀរចាកបាណាតិបាត ១ ចេតនាវៀរចាកអទិន្នាទាន ១ ចេតនាវៀរចាកកាមេសុមិច្ឆាចារ ១ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាកម្មន្តៈ ។ ម្នាលភិក្ខុទាំងឡាយ

ចុះដូចម្ដេច ហៅថា សម្មាអាជីវៈ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ លះបង់នូវមិច្ឆាអាជីវៈ គឺការចិញ្ចឹមជីវិតខុស ហើយប្រព្រឹត្តចិញ្ចឹមជីវិតដោយសម្មាអាជីវៈ គឺការចិញ្ចឹមជីវិតត្រូវ ម្នាលភិក្ខុទាំងឡាយនេះតថាគតហៅថា សម្មាអាជីវៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច ហៅថា សម្មាវាយាមៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាំងឆន្ទៈឲ្យកើត ធ្វើនូវព្យាយាម ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីធ្វើអកុសលធម៌ទាំងឡាយដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ធ្វើឆន្ទៈឲ្យកើត ធ្វើព្យាយាម ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយ ( ឲ្យសាបសូន្យទៅ ) ញុំាំងឆន្ទៈឲ្យកើត ទំព្យាយាម ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីធ្វើកុសលធម៌ទាំងឡាយដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ញុំាំងឆន្ទៈឲ្យកើត ទំព្យាយាម ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីធ្វើកុសលធម៌ទាំងឡាយដែលកើតឡើងហើយ ឲ្យឋិតនៅយូរអង្វែង មិនឲ្យសាបសូន្យឲ្យចម្រើនឡើង ឲ្យធំទូលាយ ឲ្យចម្រើនពេញបរិបូណ៌ ។ ម្នាលភិក្ខុទាំង-ឡាយ នេះតថាគត ហៅថា សម្មាវាយាមៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច ហៅថា សម្មាសតិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានសេចក្ដីដឹងខ្លួន និងមានសតិបន្ទោបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។ ភិក្ខុពិចារណាឃើញ

ឃើញៗ នូវវេទនាក្នុងវេទនាទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន និងមានសតិបន្ទោបង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ ។ ពិចារណាឃើញៗ នូវចិត្តក្នុងចិត្ត ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសេចក្តីដឹងខ្លួន និងមានសតិបន្ទោបង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកចេញ ។ ពិចារណាឃើញៗ នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសេចក្តីដឹងខ្លួន មានសតិបន្ទោបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ម្នាលភិក្ខុទាំងឡាយ នេះតថាគត ហៅថា សម្មាសតិ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ហៅថា សម្មាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ក៏ចូលបឋមជ្ឈាន ដែលប្រកបដោយវិតក្កវិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ លុះភិក្ខុនោះចូលទៅជិត រម្ងាប់នូវវិតក្កវិចារៈរួចហើយ ក៏បានចូលដល់ទុតិយជ្ឈាន ជាទីជ្រះថ្លាប្រព្រឹត្តទៅខាងក្នុង ក៏ញុំាងចិត្តជាសមាធិឲ្យចម្រើនឡើង មិនមានវិតក្ក និងវិចារៈទេ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិប៉ុណ្ណោះ លុះលះបង់បីតិចេញហើយ ភិក្ខុនោះជាបុគ្គលមានចិត្តព្រងើយ មានសតិ និងសម្បជញ្ញៈ សោយសេចក្តីសុខដោយនាមកាយផង ព្រះអរិយបុគ្គលទាំងឡាយ តែងហៅនូវភិក្ខុដែលបានតតិយជ្ឈាននោះថា ជាអ្នកមានចិត្ត

ព្រះនិយកន្ទើយ ជាអ្នកមានសតិ ជាអ្នកនៅជាសុខ ភិក្ខុនោះក៏បានដល់តតិ-យជ្ឈាន លុះលះបង់នូវសេចក្តីសុខ និងសេចក្តីទុក្ខរួចហើយ ក៏រំលត់នូវសោមនស្ស និងទោមនស្សអំពីមុន ចូលកាន់ចតុត្ថជ្ឈាន ឥតទុក្ខ ឥតសុខ មានសតិដ៏ស្អាត ចំពោះត្រង់ឧបេក្ខា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា សម្មាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា ទុក្ខនិរោធគាមិនី-បដិបទាអរិយសច្ច ។

[ ១៥០ ] ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង ( ដោយការកំណត់នូវអរិយសច្ចទាំង ៤ ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាខាងក្នុងខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវសភាវៈដែលកើតឡើងនៃសច្ចៈទាំង ៤ គួរតាមពិត ក្នុងសច្ចធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចា-រណាឃើញរឿយៗ នូវសភាវៈសូន្យទៅនៃសច្ចៈទាំង ៤ គួរតាមពិត ក្នុងសច្ចធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពិចារណាឃើញរឿយៗ នូវសភាវៈដែលកើតឡើង និងសូន្យទៅនៃសច្ចៈទាំង ៤ គួរតាមពិត ក្នុងសច្ចធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី ពុំនោះសោតស្មារតី ( ជាគ្រឿងកំណត់នូវសច្ចៈទាំង ៤ ) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌មានមែន ( តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិន

មែនប្រុសជាដើម ) គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ភិក្ខុនោះមានចិត្តមិនអាស្រ័យ ( តណ្ហា និងទិដ្ឋិ ) ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចទាំង ៤ យ៉ាងនេះឯង ។

[ ១៥១ ] ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ អស់ ៧ ឆ្នាំ តាមលំដាប់នៃវិធីចម្រើនដែលតថាគតបានពោលហើយយ៉ាងនេះ ។ បណ្តាផលទាំងឡាយ ២ ផលណាមួយ ក៏គង់នឹងបានចម្រេចដល់បុគ្គលនោះ តាមសេចក្តីប្រាថ្នាដោយពិត គឺថា នឹងបានសម្រេចនូវភាវៈជាព្រះអរហន្ត ក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាវៈជាអនាគាមិបុគ្គលពុំខានឡើយ ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់ ៧ ឆ្នាំឡើយ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយបានចម្រើនសតិប្បដ្ឋានទាំង ៤ នេះអស់ ៦ ឆ្នាំ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ តាមលំដាប់វិធីចម្រើន ដែលតថាគតបានពោលហើយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កុំថា ដល់ទៅអស់មួយឆ្នាំឡើយ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នេះ អស់ ៧ ខែ តាមលំដាប់វិធីចម្រើន ដែលតថាគតបានពោលហើយយ៉ាងនេះ បណ្តាផលទាំងឡាយ ២ ផលណាមួយ ក៏គង់នឹងបានសម្រេចដល់បុគ្គលនោះ តាមសេចក្តីប្រាថ្នាដោយពិត គឺថា នឹងបានសម្រេចនូវភាវៈ ជាព្រះអរហន្តក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមាន

ឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវការៈ ជាអនាគាមិបុគ្គល ពុំខានឡើយ ម្នាលភិក្ខុទាំងឡាយ កុំថា ដល់ទៅអស់ ៧ ខែឡើយ ម្នាល ភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយបានចម្រើនសតិប្បដ្ឋានទាំង ៤ នេះ អស់ ៦ ខែ ៥ ខែ ៤ ខែ ៣ ខែ ២ ខែ ១ ខែ កន្លះខែ តាមលំដាប់វិធីចម្រើន ដែលតថាគតបានពោលហើយយ៉ាងនេះ .... ម្នាលភិក្ខុទាំងឡាយ កុំថា ដល់ ទៅអស់កន្លះខែឡើយ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីបុគ្គលណាមួយ បាន ចម្រើនសតិប្បដ្ឋានទាំង ៤ នេះ អស់ ៧ ថ្ងៃ តាមលំដាប់វិធីចម្រើន ដែល តថាគតបានពោលហើយយ៉ាងនេះ បណ្តាផលទាំងឡាយ ២ ផលណាមួយ ក៏គង់នឹងបានសម្រេចដល់បុគ្គលនោះ តាមសេចក្តីប្រាថ្នាដោយពិត គឺថា នឹង បានសម្រេចនូវការៈជាព្រះអរហន្ត ក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើ មានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវការៈ ជាព្រះ អនាគាមិបុគ្គលពុំខានឡើយ ។

[១៥២] ម្នាលភិក្ខុទាំងឡាយ ផ្លូវ គឺសតិប្បដ្ឋានទាំង ៤ នេះឯង ជាផ្លូវ មូលតែមួយ ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធដោយវិសេសនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់នូវទុក្ខ និង ទោមនស្ស ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឲ្យ ជាក់ច្បាស់នូវព្រះនិព្វាន ។ ពាក្យណា ដែលតថាគតបានពោលហើយថា ( សាសានារបស់តថាគត ជាគុណសម្រាប់ស្រោចស្រង់សត្វ ) ដូច្នេះ ពាក្យ នោះ តថាគតពោលហើយ ព្រោះអាស្រ័យនូវផ្លូវដ៏ប្រសើរ គឺសតិប្បដ្ឋានទាំង

៤ នេះឯង ។ លុះព្រះមានព្រះភាគបានសម្តែងសតិប្បដ្ឋានសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគ ។

## សតិប្បដ្ឋានសូត្រទី ១០ ចប់

## មូលបរិយាយវគ្គទី ១ ចប់

## បញ្ជីរឿងក្នុងមូលបរិយាយវគ្គនោះគឺ

អ្នកទាំងឡាយ ចូរស្តាប់ ( នូវពាក្យដែលសម្តែងអំពីព្រះនិព្វាន ) ជាធម្មជាតមិនចាស់ មិនស្លាប់ ជាទីលុះដល់អមតៈ ជាគ្រឿងសម្តែងនូវមគ្គ ផល បន្ទោបង់នូវសេចក្តីទុក្ខ ធ្វើនូវទីកំបាំងធំ ដែលមានប្រយោជន៍ និងសេចក្តីចម្រើន នាំមកនូវបីតីជាច្រើន មានប្រការផ្សេងៗ ជាទីញ៉ាំងភ្លើង និងជ័រទាំង ៣ ប្រការឲ្យរីងស្ងួត ដូចជាស្រះមានទឹកពេញបៀប ( ដែលព្រះអាទិត្យឲ្យរីងស្ងួត ) ក្នុងរដូវក្តៅ ។ សូត្រដ៏ប្រសើរក្នុងមជ្ឈិមកាយទាំងឡាយ ជាគ្រឿងបន្ទោបង់ និងរម្ងាប់នូវព្យាធិ មានអត្ថរសដ៏ឆ្ងាញ់ ទន់ភ្លន់ និងញ៉ាំងសេចក្តីរីករាយសប្បាយ ឲ្យកើតឡើងដល់ពួកទេវតា ជាសូត្រដែលព្រះគន្ថរចនាចារ្យ តម្កល់ទុកហើយផង ជាសូត្រដែលពួកសក្យបុត្រតម្កល់ទុក ដើម្បីញ៉ាំងពួកមនុស្សឲ្យត្រេកអរចំពោះសូត្រ និងព្យាករណ៍នោះផង អ្នកទាំងឡាយចូរមានចិត្តតែមួយ គឺ

មានចិត្តនឹងនួន តាំងសោតប្រសាទ ស្តាប់នូវសូត្រដ៏ប្រសើរនោះ ដែលមានវគ្គដ៏ប្រសើរ ៥៣ និង ១៥០ ទាំងវេយ្យាករណ៍ ២ ប្រការ និងពាក្យតិចតួចដទៃៗ ទៀត ក្នុងបឋមវគ្គទាំងអស់ ដែលមិនស្មើគ្នាតាមលំដាប់ដូច្នេះ គឺមូលបរិយាយសូត្រ ១ សព្វាសវសំវរសូត្រ ១ ធម្មទាយាទសូត្រ ១ ភយភេរវសូត្រ ១ អនង្គណសូត្រ ១ អាកង្ខេយ្យសូត្រ ១ វត្ថូបមសូត្រ ១ សល្លេខសូត្រ ១ សម្មាទិដ្ឋិសូត្រ ១ សតិប្បដ្ឋានសូត្រ ១ បឋវគ្គដ៏ប្រសើរទាំងនោះ ចប់តែប៉ុណ្ណេះហើយ ។

# អដ្ឋកថា

# សតិប្បដ្ឋានសូត្រ

## ការមកនៃពាក្យថា កុរុ

[ ១៣១ ] សតិប្បដ្ឋានសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ខ្ញុំបាន ស្ដាប់មកហើយយ៉ាងនេះ បណ្ដាបទទាំងនោះ បទថា **កុរូសុ វិហរតិ** សេចក្ដីថា ជនបទមួយកន្លែង ជាលំនៅរបស់រាជកុមារ ដែលនៅក្នុងជនបទ ឈ្មោះថា **កុរុ** អ្នកស្រុកហៅថា **កុរូ** ដោយ **រុឡ្ហិ** សព្ទ ( សព្ទក្លាយ ) ព្រះមានព្រះភាគទ្រង់ប្រថាប់ត្រង់កុរុជនបទនោះ ។

ព្រះអដ្ឋកថាចារ្យទាំងឡាយ ពោលថា ក្នុងវជ្ជសម័យរបស់ព្រះបាទមន្ធាតុរាជ មនុស្សក្នុងទ្វីប ៣ បានឮល្បីថា ដែលឈ្មោះថា ជម្ពូទ្វីប ជាទឹកដីដែលកើតឡើងរបស់អគ្គបុគ្គល មានព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងស្ដេចចក្រពត្តិទាំងឡាយ ជាទីអភិរមឧត្ដមភាព ទើបបាននាំគ្នាមកមួយអន្លើជាមួយស្ដេចចក្រពត្តិ ឈ្មោះមន្ធាតុរាជដែលទ្រទ្រង់នូវចក្រកែវ ហើយទ្រង់យាងទៅកាន់ទ្វីបទាំង ៤ ។

បន្ទាប់អំពីនោះមក ព្រះរាជាបានត្រាស់សួរបរិនាយកកែវថា នៅមានទៀតដែរឬទេ ក្នុងទីកន្លែងដែលជារមណីយដ្ឋានក្រៃលែងជាងមនុស្សលោក ។

បរិនាយកកែវបានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុអ្វី ទើបទ្រង់ត្រាស់យ៉ាងនេះ ព្រះអង្គមិនបានទតឃើញអានុភាពរបស់ព្រះចន្ទ ព្រះអាទិត្យទេឬ ទីកន្លែងដែលព្រះចន្ទ និងព្រះអាទិត្យទាំងនេះ ជារមណីយដ្ឋានក្រៃលែង

ជាន់មនុស្សលោកនេះពិត ។

ទើបព្រះរាជាទ្រង់បញ្ជូនចក្រកែវទៅមុន ហើយទ្រង់យាងទៅក្នុងទីនោះ ។ ស្តេចចាតុម្មហារាជបានជ្រាបថា ព្រះបាទមន្ធាតុរាជយាងមកហើយ ទ្រង់ត្រិះរិះថា ព្រះរាជាទ្រង់មានឫទ្ធិច្រើន អញមិនអាចនឹងតតាំងបានដោយការច្បាំងឡើយ ទើបប្រគល់រាជសម្បត្តិរបស់ខ្លួនថ្វាយ ព្រះអង្គទទួលរាជ-សម្បត្តិនោះហើយ បានត្រាស់សួរទៀតថា មានទៀតដែរឬ ស្ថានទីដែលជារមណីយដ្ឋានក្រៃលែងជាងនេះ ។

ស្តេចចាតុម្មហារាជ បានក្រាបទូលតាវត្តិង្សពិភពដល់ព្រះអង្គថា បពិត្រព្រះអង្គ តាវត្តិង្សភព ជាស្ថានក្រៃលែងជាងនេះ ។ លើតាវត្តិង្សភពនោះមហារាជទាំង ៤ នេះ ជាអ្នករក្សាការ គឺជាអ្នកបម្រើរបស់សក្កទេវរាជនោះប្រថាប់ឈរត្រង់ខ្លោងទ្វារ សក្កទេវរាជទ្រង់មានឫទ្ធិច្រើន ទ្រង់មានអានុភាពច្រើន ព្រះអង្គទ្រង់មានទេវស្ថានសម្រាប់ប្រើប្រាស់ទាំងនេះ គឺវេជយន្តប្រា-សាទកម្ពស់ ១០០០ យោជន៍ សុធម្មាទេវសភាកម្ពស់ ៥០០ យោជន៍ វេជយន្តរថកម្ពស់ ១៥០ យោជន៍ ដំរីឯរាវ័ណកម្ពស់ប៉ុណ្ណោះដែរ សួននន្ទនវ័ន សួនចិត្តលតាវ័ន សួនបារុសកវ័ន សួនមិសកវ័ន ប្រដាប់ដោយទិព្វព្រឹក្សាចំនួន ១ ពាន់ដើម ដើមឈើសួគ៌ ឈ្មោះបារិច្ឆត្តក គឺរលួសផ្អុងកម្ពស់ ១០០ យោជន៍ ខាងក្រោមដើមបារិច្ឆត្តកនោះ មានព្រះទីន័ងបណ្ឌុកម្ពលសិលាអាសនៈមានពណ៌ដូចផ្កាសិរមាន់ បណ្តោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្ពស់ ១៥ យោជន៍ ដែលទន់ល្វតល្វន់ កាលសក្កទេវរាជទ្រង់ប្រថាប់គង់

ព្រះវរកាយលិចពាក់កណ្ដាល ។ កាលទ្រង់ព្រះសណ្ដាប់ពាក្យក្រាបទូលនោះ ហើយ ព្រះរាជាមានព្រះរាជបំណងនឹងយាងទៅក្នុងតាវត្តិង្សពិភពនោះ ទើប ទ្រង់បោះចក្រកែវទៅ ។ ចក្រកែវនោះប្រតិស្ឋានទៅលើអាកាស ព្រមដោយ ចតុរង្គសេនា ។ បន្ទាប់មក ចក្រកែវក៏ធ្លាក់ចុះត្រង់កណ្ដាលទេវលោកទាំង ២ ប្រតិស្ឋានទៅត្រង់ផែនដី ព្រមដោយចតុរង្គសេនា មានបរិនាយកកែវជា ប្រធាន ព្រះរាជាបានយាងទៅកាន់តាវត្តិង្សភព មួយព្រះអង្គឯងប៉ុណ្ណោះ ។

សក្កទេវរាជបានដឹងថា ព្រះបាទមន្ធាតុយាងមកប៉ុណ្ណោះ ក៏ទ្រង់ស្វាគមន៍ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គយាងមក នេះជារាជសម្បត្តិ របស់ព្រះអង្គឯង សូមទ្រង់គ្រប់គ្រងចុះព្រះអង្គ ទូលព្រះបង្គំសូមបែងរាជ-សម្បត្តិចេញជា ២ ចំណែក ព្រមដោយទេពអប្សរ ថ្វាយមួយចំណែក ព្រះ រាជាគ្រាន់តែទ្រង់ប្រថាប់ត្រង់តាវត្តិង្សពិភពប៉ុណ្ណោះ ភាពជាមនុស្សក៏បាត់ទៅ ភាពជាទេវតាក៏ប្រាកដឡើងជំនួស ។ ឮថា ព្រះអង្គប្រថាប់គង់លើព្រះទីន័ង បណ្ឌុកម្ពលសិលាអាសនៈ រួមជាមួយសក្កទេវរាជ ដោយហេតុត្រឹមតែប៉ប្រិច ព្រះនេត្រ[១] ទើបប្រាកដផ្សេងគ្នា ។ ពួកទេវតា កាលមិនសង្កេតព្រះអង្គ ក៏មិនឃើញភាពផ្សេងគ្នា រវាងស្ដេចសក្កៈ និងព្រះអង្គ ។ ព្រះអង្គកាលទ្រង់ សោយទិព្វសម្បត្តិក្នុងតាវត្តិង្សភពនោះ ទ្រង់គ្រងរាជសម្បត្តិ រហូតសក្ក-ទេវរាជកើតឡើង ហើយចុតិទៅអស់ ៣៦ អង្គ ក៏ទ្រង់មិនឆ្អែតដោយកាមគុណ

---

១- សក្កទេវរាជ និងព្រះបាទមន្ធាតុ មានរូបរាងដូចគ្នា ប្លែកត្រង់តែងតែព្រះបាទមន្ធាតុចេះ ប៉ប្រិចភ្នែក ឯព្រះឥន្ទ្រមិនប៉ប្រិចភ្នែកឡើយ ។

ឡើយ កាលទ្រង់ធ្លាក់ចាកទេវលោកនោះហើយ ក៏ទ្រង់តាំងនៅត្រង់ព្រះរាជ-ឧទ្យានរបស់ព្រះអង្គ មានព្រះវរកាយត្រូវខ្យល់ និងកម្ដៅថ្ងៃប៉ះពាល់ សោយទិវង្គតទៅ ។ កាលចក្រកែវប្រតិស្ឋានត្រង់ផែនដី បរិនាយកកែវ ក៏ប្រថាប់ស្នាមព្រះបាទរបស់ព្រះបាទមន្ធាតុលើជំពារមាស ហើយប្រគល់ថ្វាយរាជ-សម្បត្តិថា នេះជារាជសម្បត្តិរបស់ព្រះបាទមន្ធាតុ ។ មនុស្សដែលមកអំពីទ្វីបទាំង ៣ នោះ មិនអាចទៅវិញបាន បាននាំគ្នាចូលទៅរកបរិនាយកកែវ ហើយពោលថា បពិត្រព្រះអង្គ ពួកខ្ញុំមកដោយព្រះបរមរាជានុភាព ឥឡូវនេះ មិនអាចទៅវិញបាន សូមព្រះអង្គឲ្យទីលំនៅដល់ពួកខ្ញុំផងចុះ ។ បរិនាយកកែវប្រគល់ជនបទ ឲ្យដល់ជនទាំងនោះ ដើម្បីប្រយោជន៍ដល់ការនៅ ម្នាក់មួយកន្លែង ។

ក្នុងចំនួនជនទាំងនោះ ទឹកដីដែលមានមនុស្សមកអំពីបុព្វវិទេហទ្វីបនៅអាស្រ័យ បានឈ្មោះថា **វិទេហរដ្ឋ** តាមឈ្មោះចាស់នោះឯង ។ ទឹកដីដែលមានមនុស្សមកអំពីអាមរគោយានទ្វីបនៅអាស្រ័យ បានឈ្មោះថា **អបរន្តជនបទ** ។ ទឹកដីដែលមានមនុស្សមកអំពីឧត្តរកុរុទ្វីបនៅអាស្រ័យ បានឈ្មោះថា **កុរុរដ្ឋ** ។ តែមនុស្សទាំងឡាយហៅដោយពហុវចនៈ ដោយសំដៅដល់ស្រុកនិងនិគមជាច្រើន ព្រោះហេតុដូចពោលមកហើយនេះ ទើបព្រះអានន្ទពោលថា ប្រថាប់នៅត្រង់ដែនកុរុទាំងឡាយ ( ដែលជាពហុវចនៈ ) ដូច្នេះ ។

## ការមករបស់ពាក្យថា កម្មាសធម្ម

ក្នុងបទថា **កម្មាសធម្មំ** ក្នុងបណ្ដាបទថា **កម្មាសធម្មំ ឈាម កុរូនំ**

**ឆិគមោ** នេះ អាចារ្យពួកខ្លះ ពោលអធិប្បាយសេចក្តី ដោយផ្លាស់ ឆ អក្ខរៈ ជា **ឩ** អក្ខរៈ ។ ស្ថានទីដែលឈ្មោះថា **កម្មាសធម្ម** ព្រោះជាទីត្រូវ ទូន្មានមនុស្សជើងពពាល ។ ព្រះបាទបោរិសាទ ជាអ្នកមានព្រះបាទាពពាល ទើបហៅថា **កម្មាស** ( ស្តេចពពាល ) ។

បានឮថា ដំបៅត្រង់ព្រះបាទដែលត្រូវជន្លត់ជង់ ដុះឡើងស្រដៀងគ្នានឹង ដើមឈើដែលមានធ្នូត ព្រោះដូច្នោះ ទើបប្រាកដថា មានព្រះបាទាពពាល ។ ក្នុងឱកាសនោះ ព្រះអង្គត្រូវទូន្មាន ហើយត្រូវហាមឃាត់ អំពីភាពជាមនុស្ស ស៊ីមនុស្ស ។ សួរថា បុគ្គលណាទូន្មាន ឆ្លើយថា ព្រះពោធិសត្វ ។

សួរថា ក្នុងជាតកអ្វី ឆ្លើយថា ព្រះថេរៈមួយពួកអះអាងថា ក្នុងសុត-សោមជាតក ។ តែព្រះថេរៈទាំងនេះប្រាប់ថា មកក្នុងជយទិសជាតក ។ ពិត ហើយ ព្រះមហាសត្វ ទ្រង់បានទូន្មានព្រះបាទបោរិសាទដែលជាអ្នកមានព្រះ បាទាពពាល ។ ដូចដែលលោកពោលថា

ក្នុងកាលមួយ តថាគតជាព្រះបរមឱរសាធិរាជ របស់ព្រះបាទជយទិស ជាព្រះរាជាធិបតីនៃបញ្ចាលរដ្ឋ បានលះបង់ជីវិតដើម្បីដោះព្រះរាជបិតាហើយ ម្យ៉ាងទៀត តថាគតបានឲ្យព្រះបាទបោរិសាទ ដែលជាអ្នកមានព្រះបាទា ពពាលជ្រះថ្លាហើយ ដូច្នេះ ។

តែអាចារ្យខ្លះអធិប្បាយដោយ ឆ អក្ខរៈតែម្យ៉ាង ។ ដូចបានឮមកថា អ្នកកុរុរដ្ឋ មានទំនៀមប្រចាំកុរុរដ្ឋ កាលណាកើតការស្នាមពពាលឡើង ក្នុង ទំនៀមនោះ ព្រោះដូច្នោះ ទើបការពពាលនោះ ត្រូវហៅថា **កម្មាសធម្ម**

ព្រោះមានធម៌ គឺការពពាលកើតឡើង ។

សួរថា ហេតុអ្វី ទើបមិនពោលឈ្មោះនិគមដែលនៅអាស្រ័យគ្នាកន្លែងនេះទុកដោយសត្តមីវិភត្តិ ក្នុងពាក្យថា **កម្មាសធម្មំ** នោះ ។

ឆ្លើយថា ព្រោះព្រះមានព្រះភាគ មិនមានឱកាសដែលនឹងប្រថាប់ ។

បានឮថា មិនមានវិហារណាមួយ ដែលជាឱកាសឲ្យព្រះមានព្រះភាគគង់ក្នុងនិគមនោះឡើយ ។ តែឆ្ងាយចេញអំពីនិគមទៅ មានដងព្រៃធំ ក្នុងភូមិភាគមួយកន្លែងសម្បូរដោយទឹក ជារមណីយដ្ឋាន ។ ព្រះមានព្រះភាគទ្រង់ប្រថាប់ត្រង់ដងព្រៃធំនោះ ទ្រង់យកនិគមនោះ ជាគោចរគ្រាម គឺស្រុកទទួលបិណ្ឌបាត ព្រោះដូច្នោះ គួរយល់អត្ថក្នុងរឿងនេះថា ព្រះមានព្រះភាគទ្រង់គង់នៅត្រង់ស្រុកកុរុ ទ្រង់យកនិគមរបស់អ្នកដែនកុរុ ដែលឈ្មោះថា កម្មាសធម្មជាគោចរគ្រាម ។

## ពោលអំពី ឧទ្ទេសវារកថា

[ ១៣២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ឯកាយនោ អយំ ភិក្ខវេ មគ្គោ** ដូច្នេះ សួរថា ហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ព្រះសូត្រនេះក្នុងដែនកុរុរដ្ឋនោះ ឆ្លើយថា ព្រោះអ្នកកុរុអាចក្នុងការទទួលយកព្រះធម្មទេសនាដែលជ្រាលជ្រៅបាន ។

បានឮថា ភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកាទាំងឡាយ អ្នកកុរុរដ្ឋ ជាអ្នកមានរាងកាយ និងចិត្តសមគួរជានិច្ច ដោយអំណាចនៃបច្ច័យ គឺឧតុជាទីសប្បាយ ព្រោះរដ្ឋនោះសម្បូរដោយបច្ច័យ គឺឧតុ ។ មនុស្សទាំងនោះ មាន

កម្លាំងបញ្ញាដែលសមគួរនៃចិត្ត និងរាងកាយអនុគ្រោះហើយ ជាអ្នកអាចទទួលស្តាប់ពាក្យដែលជ្រាលជ្រៅបាន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគកាលទ្រង់សម្លឹងឃើញថា មនុស្សទាំងនោះអាចទទួលស្តាប់ព្រះធម្មទេសនាដ៏ជ្រាលជ្រៅនេះបាន ទើបត្រាស់សតិប្បដ្ឋានសូត្រ ដែលមានអត្ថជ្រាលជ្រៅនេះ ដោយលើកព្រះកម្មដ្ឋានចុះក្នុងអរហត្ត ក្នុងឋានៈ ២១ យ៉ាង ។

ឧបមាដូចបុរសបានប្រអប់មាស ហើយដាក់ផ្កាច្រើនប្រភេទក្នុងនោះ ឬបានប្រអប់មាស ហើយរក្សារតនៈទាំង ៧ ក្នុងនោះ យ៉ាងណា ព្រះមានព្រះភាគក៏ដូច្នោះ កាលទ្រង់បានអ្នកដែនកុរុរដ្ឋជាបរិស័ទ ទើបទ្រង់សម្តែងព្រះធម្មទេសនាដ៏ជ្រាលជ្រៅ ដោយហេតុនោះឯង ទើបក្នុងមជ្ឈិមនិកាយ មូលបណ្ណាសកៈនេះ ទ្រង់សម្តែងព្រះសូត្រដែលមានអត្ថជ្រាលជ្រៅទុកមួយសូត្រ ក្នុងទីឃនិកាយ ទ្រង់បានសម្តែងទុក មួយសូត្រទៀត គឺមហានិទានសូត្រ ១ មហាសតិប្បដ្ឋានសូត្រ ១ ក្នុងមជ្ឈិមនិកាយនេះ ទ្រង់សម្តែងព្រះសូត្រមួយទៀត គឺសារោបមសូត្រ ១ រុក្ខូបមសូត្រ ១ រដ្ឋបាលសូត្រ ១ មាគន្ទិយសូត្រ ១ អានញ្ជសប្បាយសូត្រ ១ ។

ម្យ៉ាងទៀត ក្នុងជនបទនោះតាមប្រក្រតីហើយ បរិស័ទទាំង ៤ នាំគ្នាប្រកបរឿយៗ ក្នុងសតិប្បដ្ឋានភាវនា ដោយហោចសូម្បីពួកទាសកម្មករ និងបរិវារជន ក៏និយាយគ្នាទាក់ទងនឹងសតិប្បដ្ឋាននោះ សូម្បីតែត្រង់កំពង់ទឹក និងទីកន្លែងការអំបោះជាដើម ដែលឈ្មោះថា ការនិយាយគ្នាក្នុងរឿងឥតប្រយោជន៍ប្រព្រឹត្តទៅមិនមានឡើយ ។

បើស្រីណាមួយ គេសួរថា នែនាង នាងមនសិការសតិប្បដ្ឋានការនាមួយណា ហើយឆ្លើយថា មិនបានមនសិការមួយណាឡើយ ។ មនុស្សទាំងឡាយ នឹងតិះដៀលនាងថា ជីវិតរបស់នាងឥតប្រយោជន៍ នាងនឹងមានជីវិតដូចគ្នានឹងមនុស្សស្លាប់ហើយ ។ ទើបបានឲ្យឱវាទនាងថា ឥឡូវនេះ នាងកុំធ្វើយ៉ាងនេះ ហើយឲ្យរៀនយកសតិប្បដ្ឋានណាមួយ ។ តែបើស្រីណាពោលថា ខ្ញុំមនសិការសតិប្បដ្ឋានឈ្មោះនោះ ។ មនុស្សទាំងឡាយ នឹងនាំគ្នាឲ្យសាធុការថា សាធុ សាធុ ហើយសរសើរដោយពាក្យទាំងឡាយថា ជីវិតរបស់នាង ជាជីវិតដែលល្អហើយ នាងឈ្មោះថា ជាមនុស្សសម្បូរហើយ ព្រះសម្មាសម្ពុទ្ធទ្រង់កើតឡើងមក ដើម្បីប្រយោជន៍ដល់នាងជាដើម ។ ក្នុងរឿងនេះមិនចំពោះតែមនុស្សជាតិតែម្យ៉ាងប៉ុណ្ណោះទេ ដែលនាំគ្នាប្រកបមនសិការសតិប្បដ្ឋាន សូម្បីតែពួកសត្វតិរច្ឆាន ដែលអាស្រ័យមនុស្សទាំងនោះក៏មនសិការសតិប្បដ្ឋានដែរ ។ ក្នុងការធ្វើមនសិការសតិប្បដ្ឋានរបស់សត្វនោះ មានរឿងដូចតទៅនេះ

## សេកចម្រើនសតិប្បដ្ឋាន

បានឮមកថា អ្នករបាំម្នាក់ បានចាប់កូនសេកមកបង្ហាត់ នាងអាស្រ័យសម្នាក់ភិក្ខុនី វេលាទៅក៏ទៅ ហើយភ្លេចកូនសេក ទើបពួកសាមណេរីចាប់មកចិញ្ចឹម ។ ឲ្យឈ្មោះសេកនោះថា ពុទ្ធរក្ខិត ។ ថ្ងៃមួយ ព្រះថេរីឃើញសេកនោះនៅខាងមុខ ទើបហៅថា ពុទ្ធរក្ខិត ។ សេកឆ្លើយថា មានរឿងអ្វីអ្នកនាងម្ចាស់ ។ ព្រះថេរីសួរថា មានមនសិការភាវនាអ្វីខ្លះទេ សេកឆ្លើយថា

មិនមានទេ អ្នកនាងម្ចាស់ ។

ព្រះថេរីពោលថា នែសេក ធម្មតាអ្នកនៅក្នុងសម្នាក់បព្វជិត មិនគួរជាអ្នករស់នៅដោយបណ្តោយអត្តភាពចោលទទេឡើយ គួរប្រកបមនសិការអ្វីមួយ ហើយប្រាប់ថា អ្វីដទៃឯងមិនអាចធ្វើបាន ចូរស្វាធ្យាយ គឺបរិកម្មថា **អដ្ឋិ អដ្ឋិ** ឆ្អឹង ឆ្អឹង ។ សេកតាំងនៅក្នុងឱវាទរបស់ព្រះថេរី ហើរស្វាធ្យាយថា **អដ្ឋិ អដ្ឋិ** ឆ្អឹង ឆ្អឹង ។ ថ្ងៃមួយ នៅពេលព្រឹក សេកទំត្រង់ចុងសសរអាំងថ្ងៃ បក្សីមួយ បានចាបដោយក្រចកយកទៅ ។ សេកនោះ បន្លឺសំឡេង **កិរិ កិរី** ។ សាមណេរីទាំងឡាយ បានឮសំឡេង ទើបពោលថា អ្នកនាងម្ចាស់ ពុទ្ធរក្ខិត ត្រូវបក្សីចាបទៅ នាងទៅជួយឲ្យបក្សីនោះលែង ហើយនាំគ្នាកាន់យកដុំដីជាដើមដេញតាមទៅ ឲ្យបក្សីនោះលែងទាល់តែបាន ។ ព្រះថេរីសួរសេកដែលខ្លួនជួយនាំមកទំខាងមុខថា ពុទ្ធរក្ខិត ពេលបក្សីចាបយកទៅ ឯងគិតដូចម្តេច ។

សេកឆ្លើយថា បពិត្រអ្នកនាងម្ចាស់ ខ្ញុំមិនបានគិតដទៃ ខ្ញុំគិតដល់គំនរឆ្អឹងប៉ុណ្ណោះ យ៉ាងនេះថា គំនរឆ្អឹងនោះឯង ចាបយកគំនរឆ្អឹងទៅ គំនរឆ្អឹងដេរដាសទៅ មិនថា ក្នុងទីណាឡើយ ។

ភិក្ខុនីពោលថា សាធុ សាធុ ពុទ្ធរក្ខិត ការធ្វើមនសិការយ៉ាងនោះចាត់ជាបច្ច័យដល់ការអស់ទៅនៃភពរបស់ឯងក្នុងអនាគត ។

សូម្បីសត្វតិរច្ឆាន ក្នុងជនបទនោះ ក៏ប្រកបមនសិការក្នុងសតិប្បដ្ឋានដូចពោលមកហើយនេះ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់ញ៉ាំងការ

ចម្រើនក្នុងសតិប្បដ្ឋាននោះឯង ឲ្យកើតឡើងដល់បុគ្គលទាំងនោះ ទើបបាន ត្រាស់ព្រះសូត្រនេះ ។

បណ្តាបទទាំងនោះ បទថា **ឯកាយនោ** ប្រែថា ផ្លូវមូលតែមួយ ។ ព្រោះថា ផ្លូវមានឈ្មោះច្រើនយ៉ាង គឺ **មគ្គ បន្ថ បថ បជ្ជ អញ្ជស វដុម អាយន ណាវា ឧត្តរសេតុ កុល្ល ភិសិ** និង **សង្កម** ។

ក្នុងសតិប្បដ្ឋានសូត្រនេះ ទ្រង់ត្រាស់ផ្លូវនេះ ដោយឈ្មោះថា **អាយន** ព្រោះដូច្នោះ ក្នុងពាក្យថា **ឯកាយនោ អយំ ភិក្ខវេ មគ្គោ** ម្នាលភិក្ខុទាំង-ឡាយ ផ្លូវនេះជាផ្លូវមូលតែមួយ នេះគួរយល់អត្ថយ៉ាងនេះថា ម្នាលភិក្ខុទាំង-ឡាយ ផ្លូវនេះជាផ្លូវមូលតែមួយ មិនមែនជាផ្លូវពីរឡើយ ។

ម្យ៉ាងទៀត ផ្លូវ ឈ្មោះថា **ឯកាយន** ព្រោះបុគ្គលម្នាក់ឯងប៉ុណ្ណោះគប្បីទៅ ។ ពាក្យថា បុគ្គលម្នាក់ឯង គឺគួរលះការច្រឡូកច្រឡំដោយពួកគណៈ រលាស់ខ្លួនចេញទៅកាន់ទីស្ងាត់ ដើរទៅ គឺបដិបត្តិម្នាក់ឯង ឬឈ្មោះថា **អាយន** ព្រោះជាហេតុដើរទៅ គឺទៅអំពីសង្សារ ដល់ព្រះនិព្វាន ។

ផ្លូវដើររបស់បុគ្គលឯក ឈ្មោះថា **ឯកាយន** ពាក្យថា ជាបុគ្គលឯក បានដល់ បុគ្គលប្រសើរបំផុត ។ បុគ្គលដែលប្រសើរបំផុតជាងសព្វសត្វ គឺ ព្រះមានព្រះភាគ ព្រោះដូច្នោះ ទើបមានអធិប្បាយថា បានដល់ ផ្លូវដើររបស់ ព្រះមានព្រះភាគ ។

សេចក្តីពិត សូម្បីអ្នកដទៃក៏ដើរទៅតាមផ្លូវនោះបាន សូម្បីយ៉ាងនោះ ផ្លូវនោះ ក៏ឈ្មោះថា ជាផ្លូវដើររបស់ព្រះមានព្រះភាគ ព្រោះព្រះអង្គទ្រង់សាង

ឡើង ។ ដូចលោកពោលទុកថា នៃព្រាហ្មណ៍ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ជាអ្នកបង្កើតផ្លូវដែលមិនទាន់កើតឡើង ដូច្នេះជាដើម ។

ម្យ៉ាងទៀត ឈ្មោះថា **អយន** ព្រោះទៅ គឺដំណើរទៅ អធិប្បាយថា ប្រព្រឹត្តទៅ ។ មានអធិប្បាយថា ទៅក្នុងទីតែមួយ គឺប្រព្រឹត្តទៅក្នុងធម្មវិន័យ គឺសាសនានេះប៉ុណ្ណោះ មិនមែនទៅក្នុងទីដទៃ ។ ដូចដែលត្រាស់ថា ម្នាលសុភទ្ទ អរិយមគ្គមានអង្គ ៨ មានក្នុងព្រះធម្មវិន័យនេះឯង ។ សេចក្តីពិតអត្ថទាំង ២ នេះ ផ្សេងគ្នាត្រឹមតែទេសនាប៉ុណ្ណោះ តែក៏មានអត្ថដូចគ្នា ។

ម្យ៉ាងទៀត ឈ្មោះថា **ឯកាយន** ព្រោះទៅកាន់គោលដៅតែមួយ អធិប្បាយថា ខាងដើម សូម្បីទៅដោយន័យនៃការនាំដែលជាបដិបទាផ្សេងគ្នា តែខាងក្រោយ ក៏ដល់ព្រះនិព្វានដូចគ្នានោះឯង ដូចដែលសហម្បតីព្រហ្មបានពោលថា

បុគ្គលឃើញនូវទីបំផុតនៃការអស់នៃជាតិ មានសេចក្តីអនុគ្រោះដោយប្រយោជន៍ រមែងដឹងច្បាស់នូវផ្លូវមូលតែមួយ ជនទាំងឡាយបានឆ្លងហើយក្នុងកាលមុនក្តី នឹងឆ្លង ( ក្នុងអនាគត ) ក្តី កំពុងឆ្លងក្នុងកាលឥឡូវនេះក្តី នូវឱឃៈបាន ដោយផ្លូវនុ៎ះឯង ។

តែអាចារ្យពួកខ្លះពោលថា ឈ្មោះថា **ឯកាយន** ព្រោះទៅដល់និព្វានតែម្តង តាមន័យនៃសេចក្តីថា មិនទៅដល់ត្រើយ ( គឺព្រះនិព្វាន ) ដល់ទៅ ២ ដង ពាក្យនោះ មិនត្រឹមត្រូវ ។ ព្រោះថា អត្ថយ៉ាងនេះ ព្យញ្ជនៈគួរយ៉ាងនេះថា **សកឹ អយនោ** ( មិនមែន **ឯកាយនោ** ) ។ តែពោលប្រកបសេចក្តី

យ៉ាងនេះថា ផ្លូវនោះ មានផ្លូវទៅតែមយ៉ាង គឺមានគតិ បានដល់ មានការប្រព្រឹត្តទៅតែមយ៉ាង ដូច្នេះ ព្យញ្ជនៈក៏ប្រើបាន ។ តែអត្ថមិនមែនបានទាំង ២ យ៉ាង ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះក្នុងទីនេះ ទ្រង់បំណងយកមគ្គដែលជាបុព្វភាគ អធិប្បាយថា ក្នុងទីនេះ ព្រះអង្គទ្រង់បំណងយកមគ្គ ជាទីតាំងសតិ គឺសតិប្បដ្ឋានដែលជាចំណែកខាងដើម ប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង ៤ មានកាយជាដើម មិនមែនមគ្គដែលជាលោកុត្តរ ។ ហើយមគ្គជាចំណែកខាងដើមនោះ ក៏ទៅបានមិនមែនម្ដងផង មានការទៅមិនមែនតែមយ៉ាងផង ។ មយ៉ាងទៀត កាលអំពីមុន ក្នុងបទនេះ ព្រះមហាថេរៈទាំងឡាយ មានការសន្ទនាគ្នាមកហើយដូចគ្នា ។ គឺព្រះតិបិដកចូឡនាគត្ថេរ បានពោលថា ជាផ្លូវសតិប្បដ្ឋានដែលជាបុព្វភាគ ។ តែអាចារ្យរបស់លោក គឺព្រះតិបិដក-ចូឡសុមនត្ថេរបានពោលថា ជាផ្លូវលាយឡំគ្នាទៅ ( ទាំងជាលោកិយ និងលោកុត្តរ ) ។ ព្រះតិបិដកចូឡនាគត្ថេរពោលថា ជាផ្លូវខាងដើម ណាលោកម្ចាស់ ។ ព្រះតិបិដកចូឡសុមនត្ថេរជំទាស់ថា ជាផ្លូវលាយឡំគ្នាទៅ ណាលោកម្ចាស់ ។

កាលអាចារ្យពោលត្រួតហើយ ត្រួតទៀត សិស្សក៏នៅស្ងៀម មិនជំទាស់ ។ ទាំង ២ អង្គក្រោកឡើងដោយមិនវិនិច្ឆ័យវែកញែកបញ្ហាឡើយ ។ ក្រោយមក ព្រះថេរៈដែលជាអាចារ្យទៅកាន់បន្ទប់ផ្លូតទឹក គិតថា អញពោលថា ជាផ្លូវលាយឡំគ្នាទៅ តែលោកម្ចាស់ចូឡនាគអះអាងថា ជាផ្លូវខាងដើម

ក្នុងបញ្ហានេះ នឹងមានវិនិច្ឆ័យដូចម្តេចហ្ន៎ ទើបស្វាធ្យាយព្រះសូត្រតាំងពីដើមទៅ កំណត់សេចក្តីត្រង់នេះថា **យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិប្បដ្ឋានេ ឯវំ ភាវេយ្យ សត្ត វស្សានិ** ប្រែថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាម្នាក់ ចម្រើនសតិប្បដ្ឋានទាំង ៤ នេះ យ៉ាងនេះអស់ ៧ ឆ្នាំដូច្នេះ លោកក៏ដឹងថា ធម្មតាលោកុត្តរមគ្គ កាលកើតឡើងហើយ នឹងឈប់តាំងនៅអស់ ៧ ឆ្នាំមិនមាន មគ្គដែលលាយឡំគ្នាទៅ ដែលអញពោលហើយនោះមិនមាន ឯមគ្គដែលជាបុព្វភាគ ដែលលោកម្ចាស់ចូឡនាគសម្តែងហើយ ទើបត្រឹមត្រូវ ហើយបានទៅកាន់ទីសម្រាប់ប្រកាស ក្នុងថ្ងៃធម្មស្សវនៈ ៨ កើត ៨ រោច ។

បានឮថា ព្រះថេរៈក្នុងកាលមុន ចូលចិត្តស្តាប់ធម៌ ។ លុះបានឮសំឡេងប៉ុណ្ណោះ ក៏គិតថា អញនឹងស្តាប់មុន អញនឹងស្តាប់មុន ហើយអង្គុយចុះស្តាប់ព្រមគ្នានោះឯង ។ ថ្ងៃនោះក៏ជាវារៈរបស់ចូឡនាគត្ថេរ ។ កាលលោកអង្គុយលើធម្មាសនៈ ចាប់ផ្លិតហើយ ពោលអារម្ភបទ គឺបុព្វកថា ព្រះថេរៈដែលឈរនៅក្រោយអាសនៈ មានការគិតថា អញនឹងអង្គុយក្នុងទីកំបាំង មិនពោលអ្វីឡើយ ។ ព្រោះថា ព្រះថេរៈក្នុងកាលមុនជាអ្នកស្តាប់ និងមិនលើកការពេញចិត្តរបស់ខ្លួនឡើងជាធំតែម្យ៉ាងទេ ដូចបុគ្គលចងបាច់អំពៅទុកដូច្នោះ កាន់យកហេតុផលតែម្យ៉ាង ។ វលាស់ចោលវត្ថុដែលមិនមានហេតុផល ។ ព្រោះដូច្នោះ ទើបព្រះថេរៈពោលថា លោកម្ចាស់ចូឡនាគ ។

ព្រះចូឡនាគសង្ស័យថា ស្តាប់ទៅដូចជាសំឡេងរបស់លោកអាចារ្យ

បានឈប់សម្តែងធម៌ ហើយឆ្លើយថា មានការអ្វី លោកម្ចាស់ ព្រះថេរៈពោលថា លោកម្ចាស់ ចូឡនាគ មគ្គលាយឡំគ្នា ដែលខ្ញុំពោលនោះ មិនមាន តែមគ្គ គឺសតិប្បដ្ឋានដែលជាបុព្វភាគ ដែលលោកម្ចាស់ពោលនោះមាន ។ ព្រះថេរៈចូឡនាគគិតថា អាចារ្យរបស់អញរៀនបរិយត្តិ រហូតដល់ចាំព្រះត្រៃបិដក បានជាសុតពុទ្ធ បញ្ហានេះ គង់ល្អក់កករសម្រាប់ភិក្ខុដែលមានសភាពបែបនេះ ភិក្ខុដែលជាអ្នកស្រករក្រោយ ក្នុងអនាគត នឹងពិភាល់ក្នុងបញ្ហានេះពិតប្រាកដ អញនឹងយកព្រះសូត្រមកស្រាយបញ្ហានេះ មិនឲ្យជាប់ជំពាក់បាន ។

ក្នុងគម្ពីរបដិសម្ភិទាមគ្គ បុព្វភាគសតិប្បដ្ឋានមគ្គ លោកហៅថា **ឯកាយនមគ្គ** ។ ព្រះថេរៈបាននាំយកព្រះសូត្រមកតាំងទុកថា

ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ បទ ៤ គឺអរិយសច្ចប្រសើរជាងសច្ចៈទាំងឡាយ វិរាគធម៌ ប្រសើរជាងធម៌ទាំងឡាយ មួយទៀត ព្រះតថាគត មានចក្ខុប្រសើរជាងសត្វទ្វេបាទទាំងឡាយ ផ្លូវនេះឯងប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃទស្សនៈ ផ្លូវដទៃមិនមានទេ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរដើរទៅកាន់ផ្លូវនោះ ផ្លូវនេះជាផ្លូវញ៉ាំងមារឲ្យវង្វេង អ្នកទាំងឡាយ ដើរទៅកាន់ផ្លូវនេះហើយ អាចនឹងធ្វើឲ្យផុតទុក្ខបាន ។

ផ្លូវ ឈ្មោះថា មគ្គ ព្រោះអត្ថដូចម្តេច ព្រោះអត្ថថា ជាហេតុឲ្យដល់ព្រះនិព្វាន និងព្រោះអត្ថថា អ្នកត្រូវការព្រះនិព្វានដែលត្រូវដើរទៅ ។

បទថា **សត្តានំ វិសុទ្ធិយា** ប្រែថា ដើម្បីប្រយោជន៍ដល់សេចក្តីបរិសុទ្ធ

នៃសត្វទាំងឡាយ ដែលមានចិត្តសៅហ្មងហើយ ព្រោះមន្ទិលទាំងឡាយ មានរាគៈជាដើម និងព្រោះឧបក្កិលេសទាំងឡាយ មានអភិជ្ឈាវិសមលោភៈ ជាដើម ។

ពិតហើយ សត្វទាំងនេះ គឺព្រះសម្មាសម្ពុទ្ធជាច្រើនអង្គ តាំងអំពីព្រះពុទ្ធ ព្រះនាមថា តណ្ហង្ករ មេធង្ករ សរណង្ករ ទីបង្ករ ដែលទ្រង់បានឧប្បត្តិហើយ ក្នុងកប្បជាមួយគ្នានោះឯង មុនអំពីកប្បនេះទៅ ៤ អសង្ខេយ្យ និងមួយសែន កប្ប រហូតដល់ព្រះសក្យមុនីជាបំផុតក្តី ព្រះបច្ចេកពុទ្ធច្រើនរយព្រះអង្គក្តី ព្រះអរិយសាវក ហួសនឹងគណនារាប់ក្តី ទ្រង់បានបណ្តេត និងបន្សាត់មន្ទិល របស់ចិត្តទាំងអស់ហើយ ទ្រង់សម្រេច និងត្រាស់ដឹងសេចក្តីបរិសុទ្ធដ៏កំពូល ក៏ដោយផ្លូវនេះ ។ តែដោយអំណាចនៃមន្ទិលរបស់រូប មិនមានការបញ្ញត្តការ សៅហ្មង និងការផូរផង់ឡើយ ។ ពិតហើយ ព្រះមហាឥសី គឺព្រះពុទ្ធ មិន បានត្រាស់ថា មាណព គឺមនុស្សទាំងឡាយសៅហ្មង ព្រោះរូបសៅហ្មង បរិសុទ្ធ ព្រោះរូបបរិសុទ្ធ តែព្រះមហាឥសី បានត្រាស់យ៉ាងនេះថា មាណព ទាំងឡាយសៅហ្មង ព្រោះចិត្តសៅហ្មង បរិសុទ្ធ ព្រោះចិត្តបរិសុទ្ធ ។

ដូចទ្រង់បានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានធម៌ ជា គ្រឿងសៅហ្មងនៃចិត្ត រមែងជ្រោកជ្រាក ពួកសត្វដែលមានធម៌ ជាគ្រឿង ផូរផង់នៃចិត្ត រមែងបរិសុទ្ធ ។ ហើយការផូរផង់របស់ចិត្តនោះមាន ព្រោះផ្លូវ គឺសតិប្បដ្ឋាននេះ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា ដើម្បីសេចក្តីបរិសុទ្ធ នៃសត្វទាំងឡាយ ។

បទថា **សោកបរិទេវានំ សមតិក្កមាយ** ប្រែថា ដើម្បីរម្ងាប់នូវសោក និងបរិទេវៈទាំងឡាយ សេចក្ដីថា ដើម្បីរម្ងាប់ អធិប្បាយថា ដើម្បីលះសេចក្ដីសោក និងការខ្សឹកខ្សួលទាំងឡាយ ។

ព្រោះថា មគ្គនេះ បុគ្គលអប់រំហើយ ប្រព្រឹត្តទៅដើម្បីរម្ងាប់នូវសេចក្ដីសោករបស់បុគ្គលទាំងឡាយបាន ដូចសន្តតិមហាមាត្យជាដើម និងរម្ងាប់ការខ្សឹកខ្សួលរបស់បុគ្គលទាំងឡាយបាន ដូចបដាចារាថេរីជាដើម ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **សោកបរិទេវានំ សមតិក្កមាយ** ដើម្បីឈានកន្លងនូវសោក និងបរិទេវៈទាំងឡាយ ។

សេចក្ដីពិត សន្តតិមហាមាត្យ បានស្ដាប់ព្រះគាថាបទនេះថា

កិលេសជាតណា ( ដែលកើត ) ក្នុងកាលមុន អ្នកចូរញុំាងកិលេសជាតនោះ ឲ្យរីងស្ងួត កិលេសជាតជាគ្រឿងកង្វល់ កុំមានដល់អ្នកក្នុងកាលជាខាងក្រោយឡើយ បើអ្នកមិនកាន់យកក្នុងខន្ធជាកណ្ដាលទេ អ្នកនឹងជាបុគ្គលស្ងប់ ត្រាច់ទៅ ដូច្នេះ ។

ហើយបានសម្រេចអរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយ ។

ព្រះនាងបដាចារាថេរីបានស្ដាប់ព្រះគាថានេះថា កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយ មិនមានដើម្បីជាទីពឹង បិតាក៏មិនមាន ទាំងផៅពង្សក៏មិនមានដើម្បីជាទីពឹងឡើយ សេចក្ដីទីពឹងក្នុងញាតិទាំងឡាយក៏មិនមាន ដូច្នេះ ។

ហើយបានតាំងនៅក្នុងសោតាបត្តិផលពិតនោះឯង ។ តែដែលបានឈ្មោះ

ថា ការនោះហើយ នឹងមិនទាក់ទងជាមួយធម៌ណាក្នុងកាយ វេទនា ចិត្ត ធម៌ កើតមិនមាន ព្រោះដូច្នោះ លោកទាំង ២ នោះ ក៏ត្រូវជ្រាបដោយការឈាន កន្លងនូវសោកបរិទេវៈទៅបាន ព្រោះផ្លូវនេះដូចគ្នា ។

បទថា **ទុក្ខទោមនស្សានំ អត្ថង្គមាយ** ប្រែថា ដើម្បីរម្ងាប់បង់នូវទុក្ខទោមនស្សទាំងឡាយ ដោយអត្ថថា ដើម្បីរម្ងាប់ អធិប្បាយថា ដើម្បីរំលត់ទុក្ខទាំង ២ យ៉ាងនេះ គឺទុក្ខតាមកាយ ១ ទោមនស្សផ្លូវចិត្ត ១ ។ ព្រោះថា មគ្គនេះ បុគ្គលអប់រំហើយ នឹងប្រព្រឹត្តទៅដើម្បីរំលត់ទុក្ខនៃបុគ្គលទាំងឡាយ ដូចទុក្ខរបស់ព្រះតិស្សត្ថេរជាដើម និងដើម្បីរំលត់ទោមនស្សនៃបុគ្គលទាំង-ឡាយ ដូចជាទោមនស្សរបស់ព្រះឥន្ទ្រជាដើម ។ ក្នុងរឿងនេះ មានការសម្តែងអត្ថ ដូច្នេះ

## រឿង ព្រះតិស្សត្ថេរ

បានឮមកថា ក្នុងនគរសាវត្ថី បុត្ររបស់កុដុម្ពិកៈ ឈ្មោះតិស្សៈ លះបង់នូវប្រាក់ ៤០ កោដិចេញបួស ហើយនៅក្នុងព្រៃ ជាអ្នកមិនមានផ្ទះ ។ ភរិយារបស់ប្អូនប្រុសរបស់លោក បញ្ជូនចោរ ៥០០ នាក់ទៅ ដោយប្រាប់ថា ពួកអ្នកចូរផ្តាច់ជីវិតភិក្ខុរូបនោះ ពួកចោរនាំគ្នាទៅអង្គុយព័ទ្ធព្រះថេរៈ ។

ព្រះថេរៈពោលថា ឧបាសក នាំគ្នាមកធ្វើអ្វី ចោរឆ្លើយថា ខ្ញុំនឹងផ្តាច់ជីវិតលោកម្ចាស់ ព្រះថេរៈពោលថា នៃឧបាសក អ្នកទាំងឡាយចូរយកអាត្មាជារបស់ធានាហើយ ឲ្យជីវិតអាត្មាត្រឹមតែមួយយប់ចុះ ។

ចោរសួរថា បពិត្រសមណៈ បុគ្គលណានឹងជាអ្នកធានាឲ្យលោកម្ចាស់

នៅក្នុងទីនេះ ។

ព្រះថេរៈលើកដុំថ្មមួយដុំធំ មកវាយឆ្អឹងស្មងទាំង ២ ឲ្យបាក់ ហើយប្រាប់ថា នែឧបាសក អ្នកជានានេះ សមគួរឬទេ ។

ពួកចោរនាំគ្នាចៀសចេញទៅ បង្កាត់ភ្លើងដេក ត្រង់ដើមផ្លូវចង្ក្រមរបស់លោក ។ កាលព្រះថេរៈសង្កត់នូវទុក្ខវេទនា ហើយពិចារណាសីល ព្រោះអាស្រ័យសីលបរិសុទ្ធ ទើបបីតិបាមោជ្ជកើតឡើង ។ បន្ទាប់អំពីនោះ លោកក៏ចម្រើនវិបស្សនា បំពេញសមណធម៌អស់រាត្រីទាំង ៣ យាម វេលាព្រឹកឡើង ក៏បានសម្រេចអរហត្ត ហើយបន្លឺឧទាននេះថា

ខ្ញុំវាយជើងទាំង ២ ដើម្បីជាអ្នកធានាដល់អ្នកទាំងឡាយ ខ្ញុំខ្ពើមឆ្អើមការស្លាប់ទាំងដែលនៅមានរាគៈ កាលគិតយ៉ាងនេះហើយ ខ្ញុំក៏ឃើញច្បាស់តាមសេចក្ដីពិត កាលដល់ថ្ងៃរះឡើង ទើបបានសម្រេចអរហត្ត ។

## រឿងភិក្ខុ ៣០ អង្គ

ភិក្ខុ ៣០ រូបដទៃទៀត រៀនយកកម្មដ្ឋានក្នុងសម្នាក់របស់ព្រះមានព្រះភាគ ហើយចាំវស្សាត្រង់អរញ្ញវិហារ ដាក់កតិកាគ្នាថា លោកម្ចាស់ទាំងឡាយ យើងទាំងឡាយត្រូវបំពេញសមណធម៌អស់រាត្រីទាំង ៣ យាម មិនគួរទៅមករកគ្នា ដូច្នេះហើយ ទើបនាំគ្នានៅក្នុងទីនោះ ។ កាលលោកទាំងនោះបំពេញសមណធម៌ហើយ វេលាជិតភ្លឺ ក៏ស្រោកឯក់ ខ្លាធំមួយមកពាំយកភិក្ខុមួយរូបទៅ មិនមាននរណាស្រែកឡើយថា ខ្លាខាំខ្ញុំ ដូច្នេះឡើយ កាលភិក្ខុត្រូវខ្លាពាំទៅស៊ីអស់ ១៥ រូបយ៉ាងនេះ ក្នុងថ្ងៃឧបោសថ ទើបសួរគ្នាថា ភិក្ខុ

ក្រៅអំពីនេះទៅណាអស់ហ្ន៎ លុះដឹងរឿងហើយក៏ពោលកតិកាគ្នាជាថ្មីថា ពីថ្ងៃនេះទៅ អ្នកណាត្រូវខ្លាចាប់ គួរប្រាប់គ្នាថា ខ្លាចាប់ខ្ញុំហើយ ដូច្នេះហើយ ក៏នៅតទៅទៀត ក្រោយមក ខ្លាធំបានចាប់ភិក្ខុកំលោះមួយរូប ដូចកាលមុននោះឯង ។ លោកបានប្រាប់ថា លោកម្ចាស់ ខ្លាធំ ។ ភិក្ខុទាំងឡាយនាំគ្នាកាន់ឈើប្រត់ និងគប់ភ្លើង ដេញតាមទៅ ដោយតាំងចិត្តថា នឹងឲ្យខ្លាលែង ។ ខ្លាធំបានឡើងទៅត្រង់ញកភ្នំដែលដាច់ ដែលភិក្ខុឡើងទៅមិនបាន ក៏ចាប់ផ្តើមស៊ីភិក្ខុនោះ តាំងអំពីម្រាមជើងឡើងទៅ ។ ភិក្ខុក្រៅអំពីនោះបាននាំគ្នាពោលថា នែលោកជាសប្បុរស ឥឡូវនេះ ពួកខ្ញុំជួយអ្វីលោកម្ចាស់មិនបានទេ ធម្មតាគុណវិសេសរបស់ភិក្ខុទាំងឡាយ នឹងប្រាកដឲ្យឃើញក្នុងស្ថានការណ៍ដូច្នេះឯង ។ លោកដេកនៅជិតមាត់ខ្លាធំនោះឯង គ្របសង្កត់ទុក្ខវេទនានោះ ចម្រើនវិបស្សនា ក្នុងវេលាខ្លាធំស៊ីដល់កជើង ក៏បានជាព្រះសោតា វេលាស៊ីដល់ជង្គង់ ក៏បានជាព្រះសកទាគាមី វេលាស៊ីដល់ពោះ ក៏បានជាព្រះអនាគាមី ខណៈស៊ីមិនទាន់ដល់បេះដូងនោះឯង ក៏សម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទា បានបន្លឺឧទាននេះថា

ខ្ញុំមានសីល បរិបូណ៌ដោយវត្ត មានសមាធិ មានបញ្ញា ភ្លេចខ្លួនមួយសន្ទុះ មិនបានប្រយ័ត្ន ខ្លាធំចាប់ខ្ញុំទុកក្នុងក្រញាំក្រចក នាំចូលមកត្រង់ភ្នំដើម្បីស៊ីខ្ញុំពិត កាយរបស់ខ្ញុំដែលមិនមានចិត្ត ជាអាហារខ្លា កាលខ្ញុំត្រឡប់បានកម្មដ្ឋាន មរណស្សតិនឹងចម្រើន ។

# រឿង ទីបមល្លត្ថេរ

ភិក្ខុមួយរូបទៀត ឈ្មោះថា ទីបមល្លត្ថេរ កាលនៅជាគ្រហស្ថ កាន់យក សំពត់ត្រង់គំនរសំរាម ៣ គំនរមកកាន់តម្ពបណ្ណិទ្វីប គាល់ព្រះរាជា ហើយ បានទទួលព្រះរាជានុគ្រោះ ។ ថ្ងៃមួយ ដើរទៅតាមទ្វារសាលាភិលញ្ជកាសនៈ បានស្តាប់ **ឆត្តុម្ហាកវត្ត** ថា ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំង-ឡាយទេ អ្នកទាំងឡាយ ចូរលះបង់នូវរូបនោះចេញ រូបនោះ បើអ្នកទាំង-ឡាយលះបង់ហើយ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ។ ហើយគិតថា រូបមិនមែនរបស់ខ្លួនឡើយ វេទនាក៏មិនមែនរបស់ខ្លួន ។ បុរស នោះធ្វើ **ឆត្តុម្ហាកវត្ត** នោះឲ្យដូចជាកដីរ ចេញទៅកាន់មហាវិហារ សូម បព្វជ្ជា បព្វជ្ជាឧបសម្បទា ទន្ទេញមាតិកាទាំង ២ បានស្ទាត់ហើយ នាំភិក្ខុ ៣០ រូប ទៅកាន់ទួលឈ្មោះថា **គវរាលិយ** បំពេញសមណធម៌ ។ កាល ជើងហើម ក៏ដើរចង្ក្រមដោយក្បាលជង្គង់ ។ ក្នុងយប់នោះ ព្រានម្រឹគម្នាក់ ស្មានថា លោកជាម្រឹគ ទើបពួយលោកដោយលំពែងចុះទៅ លោកឲ្យបុរស នោះយកលំពែងចេញ ហើយយករមូរស្មៅញុកមុខរបួសឲ្យពេញ ព្យួរខ្លួន អង្គុយលើដុំថ្ម កាន់យកឱកាស ចម្រើនវិបស្សនា សម្រេចអរហត្ត ព្រម ដោយបដិសម្ភិទា ព្យាករដល់ភិក្ខុដែលមកព្រោះសំឡេងក្អករបស់លោក ហើយបានបន្លឺឧទាននេះថា

ព្រះពុទ្ធ ជាបុគ្គលប្រសើរបំផុត ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ រូប នេះ មិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយ ចូរលះបង់វាចេញ សង្ខារទាំង ឡាយមិនទៀងហ្ន៎ មានការកើតឡើង និងវិនាសទៅជាធម្មតា កាលកើតឡើង

ហើយ ក៏រលត់ទៅ ការរម្ងាប់នៃសង្ខារទាំងនោះ ជាសុខ ។

គ្រានោះ ភិក្ខុទាំងឡាយ បានពោលនឹងលោកថា លោកម្ចាស់ដ៏ចម្រើន បើព្រះសម្មាសម្ពុទ្ធ ទ្រង់មិនប្រឈួនហើយសោត ព្រះអង្គនឹងត្រូវលាព្រះហស្ត ធ្វងសមុទ្រ មកស្ទាបសីសៈរបស់លោកដោយពិត ។

ដោយហេតុមានប្រមាណប៉ុណ្ណេះ ផ្លូវនេះ រមែងប្រព្រឹត្តទៅដើម្បីរំលត់ ទុក្ខរបស់សត្វទាំងឡាយ ដូចរបស់ព្រះតិស្សត្ថេរជាដើម ។

## រឿង ព្រះឥន្ទ្រចុតិ

សក្កទេវរាជ កាលទ្រង់ឃើញបុព្វនិមិត្ត ៥ យ៉ាងរបស់ព្រះអង្គហើយ ទ្រង់ត្រូវមរណភ័យគំរាម កើតស្លុតព្រះទ័យ ទើបចូលទៅគាល់ព្រះមានព្រះ ភាគ ទ្រង់សួរបញ្ហាក្នុងអវសាននៃការវិសជ្ជនាបញ្ហា ទ្រង់ក៏បានសម្រេច សោតាបត្តិផល ព្រមដោយទេវតា ៨ ម៉ឺនអង្គ ទ្រង់ចុតិហើយ បានឧប្បត្តិក ឡើងជាថ្មី ជាប្រក្រតីដូចដើមទៀត ។

## រឿង សុព្រហ្មទេវបុត្រ

សូម្បីសុព្រហ្មទេវបុត្រ មានទេពអប្សរមួយពាន់ជាបរិវារ សោយសួគ៌ សម្បត្តិ បណ្ដាទេពអប្សរសួគ៌មួយពាន់នោះ ទេពអប្សរ ៥០០ នាក់កំពុង បេះផ្កាអំពីដើមស្ដែងៗ ក៏ចុតិ ហើយកើតក្នុងនរក ។ ទេវបុត្រពិចារណាថា ស្រីទេពអប្សរទាំងនេះ ហេតុអ្វី ទើបយឺតយូរ ក៏បានឃើញថា នាងទាំងនោះ កើតក្នុងនរកហើយ ទ្រង់រំពឹងមើលថា អាយុរបស់អញ នៅសល់ប៉ុន្មានណាហ្ន៎ លុះទ្រង់ជ្រាបព្រះជន្មាយុរបស់ព្រះអង្គ នឹងអស់ទៅដូចគ្នា ទ្រង់ឃើញថា ទ្រង់

កើតក្នុងនរកនោះឯង ទើបស្ទុតព្រះទ័យ ទ្រង់ទោមនស្សពន់ប្រមាណ ទ្រង់ត្រិះរិះថា ព្រះសាស្តា នឹងកម្ចាត់ទោមនស្សរបស់អាត្មាអញនេះបាន អ្នកដទៃកម្ចាត់មិនបានឡើយ ហើយទ្រង់បាននាំទេពអប្សរ ៥០០ ដែលនៅសេសសល់ទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរបញ្ហាថា

កាលបើកិច្ច គឺសេចក្តីទុក្ខទាំងឡាយ មិនទាន់កើតឡើងក្តី ឬកើតឡើងហើយក្តី ចិត្ត ( របស់ខ្ញុំព្រះអង្គ ) នេះ តក់ស្លុតជានិច្ច ចិត្ត ( របស់ខ្ញុំព្រះអង្គ ) នេះ រន្ធត់ជានិច្ច បើចិត្តដែលមិនតក់ស្លុតមាន ខ្ញុំព្រះអង្គសូមសួរឲ្យព្រះអង្គប្រាប់នូវចិត្តនោះ ដល់ខ្ញុំព្រះអង្គ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់បានត្រាស់នឹងទេវបុត្រនោះថា

តថាគត មិនឃើញសួស្តីរបស់ពួកសត្វ ក្រៅអំពីពោជ្ឈង្គ និងតបោ-គុណទេ ក្រៅអំពីការសង្រួមនូវឥន្ទ្រិយទេ ក្រៅអំពីការលះបង់នូវកិលេសទាំងអស់ទេ ។

ក្នុងវេលាចប់ព្រះធម្មទេសនា ទេវបុត្រតាំងនៅក្នុងសោតាបត្តិផល ព្រមដោយទេពអប្សរ ៥០០ ទ្រង់ធ្វើទិព្វសម្បត្តិនោះឲ្យមានស្ថេរភាព ហើយបានយាងទៅកាន់ទេវលោកវិញ ។

ផ្លូវនេះ បុគ្គលចម្រើនហើយ គប្បីយល់ថា ប្រព្រឹត្តទៅដើម្បីរំលត់ទោមនស្សនៃសត្វទាំងឡាយ ដូចទោមនស្សរបស់សក្កទេវរាជជាដើម ដែលពណ៌នាមកនេះ ។

អរិយមគ្គមានអង្គ ៨ នោះ លោកហៅថា **ញាយ** ក្នុងពាក្យថា

**ញាយស្ស អធិគមាយ** ប្រែថា ដើម្បីសម្រេច អធិប្បាយថា ដើម្បីដល់អរិយមគ្គ ។ ព្រោះថា មគ្គសតិប្បដ្ឋានដែលជាលោកិយក្នុងចំណែកខាងដើមនេះ ដែលបុគ្គលចម្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីសម្រេចលោកុត្តរមគ្គ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ញាយស្ស អធិគមាយ** ។

បទថា **និព្វានស្ស សច្ឆិកិរិយាយ** ប្រែថា ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន សេចក្តីថា ដើម្បីធ្វើឲ្យជាក់ច្បាស់ លោកអធិប្បាយថា ដើម្បីប្រចក្សដោយខ្លួនឯងនូវអមតធម៌ ដែលបានឈ្មោះថា ព្រះនិព្វាន ព្រោះវៀរចាកតណ្ហាដែលជាគ្រឿងរួបរឹត ព្រោះថា មគ្គនេះ ដែលបុគ្គលអប់រំហើយ ឲ្យសម្រេចការធ្វើ ឲ្យជាក់ច្បាស់នូវព្រះនិព្វានតាមលំដាប់ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **និព្វានស្ស សច្ឆិកិរិយាយ** ។

បណ្តាពាក្យទាំងនោះ កាលព្រះអង្គត្រាស់ថា ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ពាក្យថា ឈានកន្លងបង់នូវសោកជាដើម ក៏ឈ្មោះថាសម្រេចអត្ថទៅផងក៏ពិត តែមិនទាន់ប្រាកដដល់អ្នកដទៃក្រៅអំពីអ្នកឈ្លាសក្នុងយុត្តិរបស់សាសនា ។ ព្រះមានព្រះភាគ ទ្រង់មិនបានធ្វើឲ្យបុគ្គលជាអ្នកឈ្លាសក្នុងយុត្តិរបស់សាសនាមុនហើយ ទើបទ្រង់សម្តែងធម៌ខាងក្រោយ ។ តែទ្រង់ឲ្យយល់ក្នុងផល ដែលត្រូវការនោះៗ ដោយសូត្រនោះៗ ប៉ុណ្ណោះ ព្រោះដូច្នោះ ក្នុងសតិប្បដ្ឋានសូត្រនេះ ទ្រង់សម្តែងផលដែលត្រូវការនូវឯកាយនមគ្គ ឲ្យសម្រេចបានឲ្យប្រាកដ ទើបបានត្រាស់ថា **សោកបរិទេវានំ សមតិក្កមាយ** ដើម្បីឈានកន្លងសោក និងបរិទេវៈទាំងឡាយ ដូច្នេះជាដើម ។

ម្យ៉ាងទៀត ព្រោះការបរិសុទ្ធនៃសត្វទាំងឡាយ នឹងប្រព្រឹត្តទៅព្រម ក៏ដោយឯកាយនមគ្គ ការបរិសុទ្ធមាន ព្រោះឈានកន្លងសោកបរិទេវៈ ការឈានកន្លងសោកបរិទេវៈមាន ព្រោះទុក្ខទោមនស្សរលត់ទៅ ការរលត់ទុក្ខ-ទោមនស្សមាន ព្រោះបានសម្រេចញាយធម៌ ការសម្រេចញាយធម៌មាន ព្រោះការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដូច្នោះ កាលទ្រង់សម្តែងលំដាប់នេះហើយ ទើបពោលថា **សត្តានំ វិសុទ្ធិយា** ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំង-ឡាយ ហើយបានត្រាស់ពាក្យជាដើមនេះថា **សោកបរិទេវានំ សមតិ-ក្កមាយ** ដើម្បីរម្ងាប់សោកបរិទេវៈ ។

ម្យ៉ាងទៀត បទថា **សត្តានំ វិសុទ្ធិយា** ជាដើមនេះ ជាពាក្យពោលសរសើរឯកាយនមគ្គ ដូចដែលព្រះមានព្រះភាគត្រាស់សរសើរទេសនា ៦ ពួក មួយពួក ៦ ប្រការ ដោយបទ ៨ ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌ មានលម្អបទដើម មានលម្អបទកណ្តាល មានលម្អបទចុងប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវធម៌ ដែលមានចំនួនប្រាំមួយឆក្កៈ ។ ហើយបានត្រាស់សរសើរអរិយវង្សទេសនាដោយ ៩ បទថា ម្នាលភិក្ខុទាំងឡាយ អរិយវង្ស ៤ យ៉ាងនេះ ជាច្បាប់ទម្លាប់ ដឹងអស់រាត្រីដ៏វែង ជាបវេណី ជាច្បាប់ចាស់ មិនច្រឡូកច្រឡំ មិនដែលច្រឡូកច្រឡំ មិនរាត់រាយ ដែលសមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកប្រាជ្ញ មិនអាចតិះដៀលបាន ។ ទ្រង់ក៏បានត្រាស់សរសើរឯកាយនមគ្គនេះទុកដោយ ៧ បទ

មានបទថា ដើម្បីការបរិសុទ្ធនៃសត្វទាំងឡាយ ដូច្នោះជាដើម ។

បើសួរថា ព្រោះហេតុអ្វី ឆ្លើយថា ដើម្បីឲ្យកើតឧស្សាហ៍ដល់ភិក្ខុទាំងនោះ ព្រោះថា ភិក្ខុទាំងនោះ កាលបានស្តាប់ការត្រាស់សរសើរ នឹងកើតឧស្សាហ៍ឡើងថា ផ្លូវនេះ នឹងនាំឧបទ្រពទាំង ៤ ចេញទៅ គឺសេចក្តីសោកដែលជាគ្រឿងដុតចិត្ត ១ សេចក្តីខ្សឹកខ្សួលដែលជាការសោកសង្រេងផ្លូវវាចា ១ សេចក្តីទុក្ខដែលជាការមិនមានផាសុកផ្លូវកាយ ១ ឧបាយាសៈដែលជាការមិនជូរស្បើយក្នុងចិត្ត ១ នឹងនាំគុណវិសេស ៣ យ៉ាងមកឲ្យ គឺវិសុទ្ធិការបរិសុទ្ធ ១ ញាយធម៌ដែលគួរដឹង ១ និព្វានការរំលត់កិលេស ១ ដូច្នេះហើយ នឹងសម្គាល់ព្រះធម្មទេសនានេះថា ត្រូវរៀន ត្រូវទន្ទេញ ត្រូវចងចាំ ត្រូវបង្រៀន នឹងសម្គាល់ផ្លូវនេះថា ត្រូវចម្រើន ។ ព្រះមានព្រះភាគ កាលបានត្រាស់សរសើរឯកាយនមគ្គ ដើម្បីឲ្យភិក្ខុទាំងនោះកើតឧស្សាហ៍ដោយប្រការដូចពណ៌នាមកនេះ ដូចគ្នានឹងអ្នកជំនួញសំពត់រោមសត្វ ពោលសរសើរគុណភាពសំពត់រោមសត្វ ដូច្នោះជាដើម ។

សេចក្តីពិស្តារថា កាលឈ្មួញសំពត់រោមសត្វពណ៌លឿង(បណ្ឌុកម្ពល) តម្លៃមួយសែន ឃោសនាថា សូមអញ្ជើញទទួលសំពត់រោមសត្វ មនុស្សទាំងឡាយគង់មិនជ្រាបមុនថា ជាសំពត់កម្ពលប្រភេទនោះ ។ ព្រោះថា ទោះជាកេសកម្ពល និងវាឡកម្ពលជាដើម ដែលមានក្លិនស្អុយ សាច់គ្រោតគ្រាតគេក៏ហៅថា សំពត់កម្ពលដូចគ្នា ។ តែកាលឈ្មួញឃោសនាថា សំពត់កម្ពលក្រហមមកពីដែនគន្ធាររដ្ឋ សាច់ម៉ដ្ឋ កក់ក្តៅ ជណ្តប់សប្បាយ ។

កាលនោះ មនុស្សដែលមានទ្រព្យគ្រប់គ្រាន់ ក៏នឹងទទួលទិញ ឯបុគ្គលដែលមិនមានទ្រព្យគ្រប់គ្រាន់ ក៏ចង់មើល យ៉ាងណា ។ កាលព្រះអង្គត្រាស់ថា ផ្លូវមួយនេះ ជាផ្លូវឯក ក៏មិនទាន់ជាក់ច្បាស់ថា ជាផ្លូវនោះដូច្នោះដូចគ្នា ។ ព្រោះថា ផ្លូវដែលនឹងនាំចេញចាកទុក្ខច្រើនប្រការ គេក៏ហៅថាផ្លូវដូចគ្នា ។ តែកាលទ្រង់ត្រាស់ពាក្យជាដើមថា **សត្តានំ វិសុទ្ធិយា** ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ភិក្ខុទាំងឡាយ ក៏កើតឧស្សាហ៍ថា បានឮថា ផ្លូវនេះ នាំឧបទ្រវទាំង ៤ ចេញទៅ នាំគុណវិសេស ៣ ប្រការមក នឹងសម្គាល់ព្រះធម្មទេសនានេះថា ត្រូវរៀន ត្រូវទន្ទេញ ត្រូវចងចាំ ត្រូវបង្រៀន និងសម្គាល់ផ្លូវនេះថា ត្រូវចម្រើន ដូច្នោះ ព្រះមានព្រះភាគកាលត្រាស់សរសើរ ទើបត្រាស់ថា **សត្តានំ វិសុទ្ធិយា** ។

ក្នុងរឿងនេះ គួរនាំការប្រៀបធៀប និងអ្នកលក់មាសជម្ពូនទៈពណ៌ក្រហម ឈ្មួញកែវមណីដែលមានទឹកល្អ ឈ្មួញកែវមុក្តាហារ និងឈ្មួញកែវពពាលដែលឆ្នៃហើយជាដើមមក ដូចគ្នានឹងការប្រៀបធៀបជាមួយឈ្មួញលក់សំពត់បណ្ឌុកម្ពលតម្លៃមួយសែន ដូច្នោះ ។

សព្ទថា **យទិទំ** ជានិបាត មានអត្ថស្មើគ្នានឹង **យេ ឥមេ** ។ សព្ទថា **ចត្តារោ** ជាការកំណត់រាប់ ។ ដោយសព្ទនោះ ព្រះអង្គទ្រង់សម្តែងដល់ការកំណត់ចំនួនសតិប្បដ្ឋានថា មិនលើសមិនខ្វះជាងនោះ ។

បទថា **សតិប្បដ្ឋាន** បានដល់ សតិប្បដ្ឋាន ៣ យ៉ាង គឺអារម្មណ៍នៃសតិ ១ ការដែលព្រះសាស្តាទ្រង់មិនសោមនស្ស មិនទោមនស្ស ក្នុងកាល

សាវ័កទាំងឡាយបដិបត្តិក្នុងសតិប្បដ្ឋាន ៣ យ៉ាង ១ សតិ ១ ។

អធិប្បាយថា អារម្មណ៍នៃសតិលោកហៅថា **សតិប្បដ្ឋាន** ដូចក្នុងពុទ្ធ-វចនៈទាំងឡាយជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេចក្តីកើតឡើង និងសូន្យទៅនៃសតិប្បដ្ឋាន ៤ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីកើតឡើងនៃកាយដូចម្តេច សេចក្តីកើតឡើងនៃកាយ ព្រោះកើតឡើងនៃអាហារ ។បេ។

ម្យ៉ាងទៀត អារម្មណ៍របស់សតិ លោកហៅថា **សតិប្បដ្ឋាន** ដូចក្នុងពាក្យទាំងឡាយថា **កាយ** ឈ្មោះថា **ឧបដ្ឋាន** មិនឈ្មោះថា **សតិ** ទេ ឯសតិ ឈ្មោះថា **ឧបដ្ឋាន** ផង ឈ្មោះថា **សតិ** ផង ដូច្នេះជាដើមក៏មាន ។

សតិប្បដ្ឋាននោះមានអត្ថថា ឈ្មោះថា **បដ្ឋាន** ព្រោះជាទីតាំង ។ អ្វីតាំង សតិតាំង ។ ទីតាំងនៃសតិ ឈ្មោះថា **សតិប្បដ្ឋាន** ។ ម្យ៉ាងទៀត ស្ថានទីដែលជាទីចត គឺប្រធាន ដូច្នោះ ទើបឈ្មោះថា **បដ្ឋាន** ។ ស្ថានទីជាទីចតនៃសតិនោះ ឈ្មោះថា **សតិប្បដ្ឋាន** ដូចគ្នានឹងទីឈររបស់ដំរី និងទីឈររបស់សេះជាដើម ដូច្នោះ ។

សតិប្បដ្ឋាន ៣ យ៉ាង គឺការដែលព្រះសាស្តាទ្រង់មិនសោមនស្ស និងទោមនស្ស ព្រោះសាវ័កទាំងឡាយបដិបត្តិក្នុងសតិប្បដ្ឋាន ៣ យ៉ាង លោកហៅថា សតិប្បដ្ឋាន ដូចក្នុងព្រះពុទ្ធវចនៈនេះថា ឯសតិប្បដ្ឋាន ៣ ប្រការជាធម៌ដែលសាស្តាដ៏ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយទើបគួរប្រៀនប្រដៅនូវគណៈបាន ដូច្នេះ ។ សេចក្តីនោះមានអត្ថថា ឈ្មោះថា

**បដ្ឋាន** ព្រោះគួរឲ្យផ្ដើមតាំងទុក អធិប្បាយថា ព្រោះគួរឲ្យប្រព្រឹត្តទៅ ។

សួរថា ព្រោះគួរឲ្យអ្វីតាំង ឆ្លើយថា គួរឲ្យសតិតាំង ការតាំងសតិឈ្មោះថា **សតិប្បដ្ឋាន** ដូច្នេះ ។

សតិនោះឯង លោកហៅថា **សតិប្បដ្ឋាន** ក្នុងពាក្យទាំងឡាយថា សតិប្បដ្ឋានដែលអប់រំហើយ ធ្វើឲ្យច្រើនហើយ ក្នុងពោជ្ឈង្គ ៧ ប្រការ បរិបូណ៌បានជាដើម ។ ក្នុងសេចក្ដីនោះ មានអត្ថថា ឈ្មោះថា **បដ្ឋាន** ព្រោះតាំងទុក អធិប្បាយថា ចូលទៅតាំងទុក គឺឈានចុះ បន្សាត់ទៅ ប្រព្រឹត្តទៅ ។ **បដ្ឋាន** គឺសតិនោះឯង ទើបឈ្មោះថា **សតិប្បដ្ឋាន ។**

ម្យ៉ាងទៀត ឈ្មោះថា **សតិ** ព្រោះអត្ថថា រឭក ឈ្មោះថា **បដ្ឋាន** ព្រោះអត្ថថា ចូលទៅតាំងទុក ។ សតិផង ការតាំងទុកផង ដូច្នោះ ទើបឈ្មោះថា **សតិប្បដ្ឋាន** ដោយប្រការដូច្នេះក៏មាន ។ ក្នុងសតិប្បដ្ឋានសូត្រនេះ លោកបំណងយកសតិប្បដ្ឋានប្រការនេះឯង ។

សួរថា បើយ៉ាងនោះ ហេតុអ្វី ទើបពាក្យថា សតិប្បដ្ឋានជាពហុវចនៈ ឆ្លើយថា ព្រោះសតិមានច្រើន ។

សេចក្ដីពិត ពោលដោយប្រភេទនៃអារម្មណ៍ សតិនោះមានច្រើន ។

កាលបើដូច្នោះ ហេតុអ្វី ទើបពាក្យថា មគ្គ មានច្រើនដូចគ្នា តែជាឯកវចនៈ ឆ្លើយថា ព្រោះមានតែមួយ ដោយអត្ថថា ត្រូវដើរទៅ ។

ពិតហើយ សតិទាំងនោះ សូម្បីមាន ៤ តែក៏ដល់នូវភាពតែមួយដូចគ្នា ដោយអត្ថថា ត្រូវដើរទៅ ។ សមដូចពាក្យលោកពោលថា ផ្លូវ ឈ្មោះថា

**មគ្គ** ព្រោះអត្ថដូចម្ដេច ព្រោះអត្ថថា ជាគ្រឿងទៅកាន់និព្វាន និងព្រោះអត្ថថា អ្នកត្រូវការនិព្វាន ត្រូវដើរទៅ ។

សតិទាំង ៤ យ៉ាងនោះ កាលញុំាងកិច្ចឲ្យសម្រេចក្នុងអារម្មណ៍ទាំង-ឡាយ មានកាយជាដើម រហូតដល់និព្វាន ក្នុងកាលខាងក្រោយ បុគ្គលប្រាថ្នានិព្វានក៏ដើរទៅតាំងអំពីនោះ ព្រោះហេតុដូចពោលមកហើយនោះ ទើបលោកពោលថា សតិទាំង ៤ យ៉ាង ជាផ្លូវឯក ។

កាលបើដូច្នេះ ទើបមានទេសនា ដែលមានការបន្តគ្នាមកតាមលំដាប់ ដោយការបន្តពាក្យគ្នាមក ដូចក្នុងព្រះពុទ្ធវចនៈទាំងឡាយជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវមគ្គ ជាគ្រឿងញុំាញីនូវមារ និងសេនារបស់មារ ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្ដាប់ធម៌នោះចុះ ម្នាលភិក្ខុទាំងឡាយ ចុះមគ្គដែលជាគ្រឿងញុំាញីមារ និងសេនានៃមារ តើដូចម្ដេច គឺពោជ្ឈង្គ ៧ នេះឯង ។ ផ្លូវសម្រាប់ញុំាញីនូវមារក្ដី ពោជ្ឈង្គ ៧ ក្ដី មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ យ៉ាងណា ឯកាយនមគ្គ និងសតិ-ប្បដ្ឋាន ៤ ក៏ដូច្នោះ ដោយអត្ថក៏ដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ព្រោះដូច្នោះ គួរយល់ថា មគ្គ ជាឯកវចនៈ ព្រោះតែមួយដូចគ្នា ដោយអត្ថថា ត្រូវដើរទៅ ឯក្នុងសតិប្បដ្ឋាន គួរយល់ថា ជាពហុវចនៈ ព្រោះសតិមានច្រើន ដោយប្រភេទនៃអារម្មណ៍ ។

សួរថា ហេតុដូចម្ដេច ទើបព្រះមានព្រះភាគត្រាស់សតិប្បដ្ឋាន ៤ យ៉ាងប៉ុណ្ណោះ មិនលើសមិនខ្វះ ឆ្លើយថា ព្រោះទ្រង់អនុគ្រោះដល់វេនេយ្យសត្វ ។

អធិប្បាយថា បណ្តាវេនេយ្យសត្វទាំងឡាយ សត្វដែលមានតណ្ហាចរិត ទិដ្ឋិចរិត សមថយានិក និងវិបស្សនាយានិក ចែកជាមួយពួកមាន ២ តាមការទន់ខ្សោយ និងការចាស់ក្លាបញ្ញា បុគ្គលដែលជាតណ្ហាចរិត មានបញ្ញាទន់ខ្សោយ មានកាយានុបស្សនាសតិប្បដ្ឋាន មានអារម្មណ៍គ្រោតគ្រាត ជាផ្លូវនៃសេចក្តីបរិសុទ្ធ ។ តែបុគ្គលតណ្ហាចរិត មានបញ្ញាចាស់ក្លា មានវេទនានុបស្សនាសតិប្បដ្ឋានដែលល្អិត ជាផ្លូវនៃសេចក្តីបរិសុទ្ធ ។ បុគ្គលមានទិដ្ឋិចរិត បញ្ញាទន់ខ្ចី មានចិត្តានុបស្សនាសតិប្បដ្ឋាន ដែលមានអារម្មណ៍ចែកចេញមិនច្រើនពេក ជាផ្លូវនៃសេចក្តីបរិសុទ្ធ ។ បុគ្គលមានទិដ្ឋិចរិត បញ្ញាចាស់ក្លា មានធម្មានុបស្សនាសតិប្បដ្ឋាន ដែលមានអារម្មណ៍ចែកប្រភេទចេញទៅច្រើន ជាផ្លូវនៃសេចក្តីបរិសុទ្ធ ។ សតិប្បដ្ឋានទី ១ មាននិមិត្តគប្បីដឹងបានមិនលំបាក ជាផ្លូវនៃសេចក្តីបរិសុទ្ធរបស់សមថយានិកបុគ្គលប្រភេទបញ្ញាទន់ សតិប្បដ្ឋានទី ២ ជាផ្លូវនៃវិសុទ្ធិសមថយានិកបុគ្គលប្រភេទបញ្ញាចាស់ក្លា ព្រោះលោកតាំងនៅបានមិនមាំ ទាំងក្នុងអារម្មណ៍ដែលគ្រោតគ្រាត ។ សតិប្បដ្ឋានទី ៣ មានអារម្មណ៍ចែកប្រភេទចេញទៅ មិនច្រើនពេក ជាផ្លូវនៃសេចក្តីបរិសុទ្ធរបស់វិបស្សនាយានិក បុគ្គលប្រភេទបញ្ញាទន់ខ្សោយ ។ សតិប្បដ្ឋានទី ៤ មានអារម្មណ៍ចែកប្រភេទចេញទៅច្រើន ជាផ្លូវនៃសេចក្តីបរិសុទ្ធរបស់វិបស្សនាយានិកបុគ្គល ប្រភេទបញ្ញាចាស់ក្លា ទើបសតិប្បដ្ឋានត្រាស់ ៤ យ៉ាងប៉ុណ្ណោះ មិនច្រើន មិនតិច ដោយប្រការដូចពណ៌នាមកនេះដូច្នេះ ។

ម្យ៉ាងទៀត ដើម្បីលះវិបល្លាស គឺការស្អាត ការសុខ ការទៀង និង អត្តាជាដើម ។ សេចក្ដីពិត កាយជារបស់មិនស្អាត តែសត្វទាំងឡាយ ស្ថិតនៅដោយវិបរិត សម្គាល់ខុសក្នុងកាយនោះ ថាស្អាត សតិប្បដ្ឋានទី ១ ត្រាស់សម្រាប់សត្វទាំងនោះ ដើម្បីឲ្យលះសុភវិបល្លាសនោះ ដោយការឃើញថា មិនស្អាតក្នុងកាយនោះ ។ និងក្នុងវេទនាជាដើម សូម្បីសត្វទាំង-ឡាយប្រកាន់ថា ជាសុខ ទៀង ជាអត្តា ក៏មានន័យនេះ គឺវេទនាជាទុក្ខ ចិត្តមិនទៀង ធម៌ទាំងឡាយជាអនត្តា តែសត្វទាំងនោះ ស្ថិតនៅដោយវិបរិត សម្គាល់ខុសក្នុងវេទនា ចិត្ត និងធម៌ទាំងនោះ ថាជាសុខ ទៀង និងជាអត្តា ត្រាស់សតិប្បដ្ឋាន ៣ ដ៏សេសសម្រាប់សត្វទាំងនោះ ដើម្បីឲ្យលះវិបល្លាសដ៏សេសទាំងនោះ ដោយការឃើញវេទនាទាំងនោះ ថាជាទុក្ខជាដើមដូច្នេះ ។

កាលបើដូច្នេះ សតិប្បដ្ឋានក៏គួរយល់ថា ទ្រង់ត្រាស់ ៤ យ៉ាងប៉ុណ្ណោះ មិនច្រើន មិនតិច ដើម្បីឲ្យលះសុភវិបល្លាស សុខវិបល្លាស និច្ចវិបល្លាស និងអត្តវិបល្លាស ។ និងមិនមែនគ្រាន់តែត្រាស់ដើម្បីឲ្យលះវិបល្លាសតែម្យ៉ាងប៉ុណ្ណោះទេ តែគួរយល់ថា ត្រាស់ ៤ យ៉ាងប៉ុណ្ណោះ ដើម្បីឲ្យលះឱឃៈ ៤ យោគៈ ៤ អាសវៈ ៤ គន្ថៈ ៤ ឧបាទាន ៤ អគតិ ៤ ផងដែរ ដើម្បីឲ្យកំណត់ដឹងអាហារទាំង ៤ ផង ។ នេះជាន័យតាមបករណៈ ។

ឯក្នុងអដ្ឋកថា លោកពោលប៉ុណ្ណោះឯងថា ដោយរឭក និងដោយការប្រមូលចុះកាន់ចំណុចតែមួយដូចគ្នាហើយ សតិប្បដ្ឋានក៏មានតែម្យ៉ាងប៉ុណ្ណោះ តែដោយអារម្មណ៍ មាន ៤ យ៉ាង ។ ឧបមាដូចក្នុងព្រះនគរដែលមានទ្វារ ៤

បុគ្គលមកអំពីទិសខាងកើត កាន់យកទ្រព្យដែលមានក្នុងទិសខាងកើត ហើយចូលព្រះនគរ តាមទ្វារទិសខាងកើតនោះឯង បុគ្គលមកអំពីទិសខាងត្បូង ទិសខាងលិច ទិសខាងជើង កាន់យកទ្រព្យដែលមានក្នុងទិសខាងជើង ហើយចូលកាន់ព្រះនគរតាមទ្វារទិសខាងជើងនោះឯង យ៉ាងណា ការឧបមេយ្យដែលឲ្យឧបមាដល់ព្រមនេះ ក៏គួរជ្រាបដូច្នោះ ។

សេចក្ដីពិត ព្រះនិព្វាន ដូចព្រះនគរ លោកុត្តរមគ្គប្រកបដោយអង្គ ៨ ដូចទ្វារព្រះនគរ កាយជាដើម ដូចទិសខាងកើតជាដើម ។

ព្រះយោគាវចរទាំងឡាយ កាលមកដោយអំណាច កាយានុបស្សនា ចម្រើនកាយានុបស្សនាសតិប្បដ្ឋាន ដោយវិធី ១៤ យ៉ាងហើយ ក៏ទៅកាន់ទីរួមគ្នា គឺព្រះនិព្វាននោះឯង ដោយអរិយមគ្គដែលកើតឡើង ដោយអានុភាពនៃកាយានុបស្សនា ដូចមនុស្សទាំងឡាយដែលមកអំពីទិសខាងកើតកាន់យកទ្រព្យ ដែលមានក្នុងទិសខាងកើត ហើយក៏ចូលដល់ព្រះនគរ ដូចគ្នានឹងទ្វារទិសខាងកើតបាន ដូច្នោះ ។

ព្រះយោគាវចរ កាលដើរមកតាមទ្វារវេទនានុបស្សនា ចម្រើនវេទនានុបស្សនាសតិប្បដ្ឋានដោយវិធី ៩ យ៉ាង ក៏ទៅកាន់ទីតែមួយ គឺព្រះនិព្វាននោះឯង ដោយអរិយមគ្គកើតឡើង ដោយអានុភាពរបស់វេទនានុបស្សនា-សតិប្បដ្ឋាន ដូចបុគ្គលមកអំពីទិសខាងត្បូង កាន់យកទ្រព្យដែលមានក្នុងទិសខាងត្បូង ចូលដល់ព្រះនគរដូចគ្នា តាមទ្វារទិសខាងត្បូង ដូច្នោះ ។

ព្រះយោគាវចរទាំងឡាយ កាលដើរមកតាមទ្វារចិត្តានុបស្សនា ចម្រើន

ចិត្តានុបស្សនាសតិប្បដ្ឋាន ដោយវិធី ១៦ យ៉ាង ទៅកាន់ទីជាមួយគ្នា គឺព្រះនិព្វាននោះឯង ដោយអរិយមគ្គដែលកើតឡើង ដោយអានុភាពរបស់ចិត្តានុ-បស្សនាសតិប្បដ្ឋាន ដូចបុគ្គលមកអំពីទិសខាងលិច កាន់យកទ្រព្យដែលមានក្នុងទិសខាងលិច ក៏ចូលដល់ព្រះនគរដូចគ្នា តាមទ្វារទិសខាងលិច ដូច្នោះ ។

ព្រះយោគាវចរទាំងឡាយ កាលដើរមកតាមទ្វារធម្មានុបស្សនា ចម្រើនធម្មានុបស្សនាសតិប្បដ្ឋាន ដោយវិធី ៥ យ៉ាង ហើយទៅកាន់ទីដូចគ្នា គឺព្រះនិព្វាននោះឯង ដោយអរិយមគ្គដែលកើតឡើង ដោយអានុភាពរបស់ធម្មានុបស្សនាសតិប្បដ្ឋាន ដូចគ្នានឹងបុគ្គលមកអំពីទិសខាងជើង កាន់យកទ្រព្យដែលមានក្នុងទិសខាងជើង ក៏ចូលដល់ព្រះនគរដូចគ្នា តាមទ្វារទិសខាងជើងបាន ដូច្នោះ ។

សតិប្បដ្ឋាន គប្បីជ្រាបថា ត្រាស់តែម្យ៉ាងប៉ុណ្ណោះ ដោយការរឭក និងដោយការរួមចុះកាន់គោលដៅតែមួយ គប្បីជ្រាបថា ត្រាស់ ៤ យ៉ាងនោះឯង ដោយអារម្មណ៍ ដោយប្រការដូច្នេះ ។

បទថា **កតមេ ចត្តារោ** ប្រែថា សតិប្បដ្ឋាន ៤ គឺអ្វី ជាកថេតុកម្យ-តាបុច្ឆា គឺសួរដើម្បីឆ្លើយឯង ។

បទថា **ឥធ** បានដល់ **ឥមស្មឹ យោគ សាសនេ** ប្រែថា ក្នុងសាសនានេះ ។ ពាក្យថា **ភិក្ខវេ** នេះ ជាពាក្យហៅបុគ្គលដែលទទួលធម៌ ។ ពាក្យថា **ភិក្ខុ** ជាពាក្យសម្តែងដល់បុគ្គល អ្នកញុំាងបដិបត្តិឲ្យដល់ព្រម ម្យ៉ាងទៀត ទេវតា និងមនុស្សដទៃ ក៏ញុំាងបដិបទាឲ្យដល់ព្រមបានដូចគ្នា ។

តែព្រះអង្គត្រាស់ហៅថា **ភិក្ខុ** ព្រោះជាបុគ្គលប្រសើរ និងព្រោះទ្រង់សម្ដែងដល់ភិក្ខុភាវៈដោយបដិបទា ព្រោះថា កាលភិក្ខុទាំងឡាយបដិបត្តិតាមអនុសាសនី របស់ព្រះមានព្រះភាគហើយ ភិក្ខុទាំងឡាយ ក៏នឹងជាបុគ្គលប្រសើរបំផុត ព្រោះដូចជាភាជនៈទទួលទ្រអនុសាសនីគ្រប់ប្រការ ។ ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ថា **ភិក្ខុ** ព្រោះជាបុគ្គលប្រសើរបំផុត ។

ទ្រង់ប្រារព្ធដល់ភិក្ខុនោះហើយ ទេវតា និងមនុស្សដ៏សេស ក៏ឈ្មោះថាទ្រង់ប្រារព្ធដល់ហើយដូចគ្នា ដូចបរិស័ទដ៏សេស ត្រូវប្រារព្ធដល់ដោយ **រាជសព្ទ** ក្នុងកិច្ចទាំងឡាយ មានទ្រង់ព្រះរាជដំណើរជាដើម ។

បុគ្គលណាបដិបត្តិក្នុងបដិបទានេះ បុគ្គលនោះ ក៏ឈ្មោះថា **ភិក្ខុ** ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ថា **ភិក្ខុ** ព្រោះទ្រង់សម្ដែងដល់ភិក្ខុភាវៈ ដោយបដិបទា ។ អ្នកបដិបត្តិ ទោះជាទេវតាក្ដី មនុស្សក្ដី ដល់នូវការរាប់ថា ជាភិក្ខុទាំងអស់ ដូចព្រះតម្រាស់ថា

បើបុគ្គលណាមានខ្លួនប្រដាប់ស្អិតស្អាងហើយ ( ដោយគ្រឿងអម្ពរ ) តែគប្បីប្រព្រឹត្តធម៌ស្មើ អ្នកស្ងប់រម្ងាប់ ទូន្មាន ( ឥន្ទ្រិយ ) ជាបុគ្គលទៀង ( ចំពោះមគ្គផល ) អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញាក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះ ហៅថា ព្រាហ្មណ៍ក៏បាន ថាសមណៈក៏បាន ថាភិក្ខុក៏បាន ។

## អធិប្បាយ ពាក្យថា កាយ

បទថា **កាយេ** បានដល់ ក្នុងរូបកាយ ។ សេចក្ដីពិត រូបកាយ ទ្រង់

បំណងថា កាយក្នុងព្រះសូត្រនេះ ដូចជា កាយដំរី និងកាយសេះជាដើម ព្រោះអត្ថថា ជាទីប្រជុំរបស់អវយវៈតូចធំ និងរបស់របរធម៌ទាំងឡាយ មានសក់ជាដើម ។

**រូបកាយ** ឈ្មោះថា **កាយ** ព្រោះអត្ថថា ជាទីប្រជុំនៃអវយវៈតូចធំទាំងឡាយ យ៉ាងណា ឈ្មោះថា **កាយ** ព្រោះអត្ថថា ជាទីមកដល់នៃវត្ថុដែលគួរខ្ពើមទាំងឡាយ ដូច្នោះ ។

ព្រោះថា រូបកាយនោះ ជាទីមកដល់នៃវត្ថុដែលគួរខ្ពើមទាំងឡាយ គឺវត្ថុដែលគួរអើមក្រែពេក ព្រោះដូច្នោះ ទើបឈ្មោះថា **កាយ** ។

បទថា **អាយោ** បានដល់ ដែនកើតរបស់ដែលគួរខ្ពើម ក្នុងបទថា **កាយោ** នេះ មានអត្ថដូច្នេះ ឈ្មោះថា **អាយ** ព្រោះជាដែនកើត សួរថា អ្វីកើត ឆ្លើយថា អវយវៈទាំងឡាយ មានសក់ជាដើម ដែលគួរខ្ពើមកើត ឈ្មោះថា **កាយ** ព្រោះជាដែនកើតនៃវត្ថុដែលគួរខ្ពើមទាំងឡាយ ដោយប្រការដូច្នេះ ។

បទថា **កាយានុបស្សី** បានដល់ បុគ្គលពិចារណាឃើញកាយរឿយៗជាប្រក្រតី ឬដែលពិចារណាឃើញរឿយៗ នូវកាយ ។

គួរជ្រាបថា ព្រះមានព្រះភាគត្រាស់ហើយថា **កាយេ** តែទ្រង់ធ្វើ **កាយ** សព្ទជាលើកទី ២ ទៀតថា **កាយានុបស្សី** ដើម្បីទ្រង់សម្តែងញែកឃនសញ្ញាចេញ ទៅដោយការកំណត់ ដោយចតុធាតុវវដ្ឋានកម្មដ្ឋាន ដោយមិនឲ្យលាយឡំគ្នា ព្រះយោគាវចរមិនមែនជាអ្នកពិចារណាឃើញវេទនាក្នុងកាយ

ឬពិចារណាឃើញចិត្ត និងធម៌ក្នុងកាយ ដោយពិតនោះ ជាអ្នកពិចារណាឃើញកាយក្នុងកាយនោះឯង ព្រោះដូច្នោះ ដោយបទថា **កាយានុបស្សី** នោះ ឈ្មោះថា ព្រះមានព្រះភាគទ្រង់សម្តែងដល់ការកំណត់ ដោយមិនឲ្យលាយឡំគ្នា ដោយការសម្តែង ព្រោះអាការ គឺការពិចារណាឃើញកាយក្នុងវត្ថុពោល គឺកាយនោះឯង ។

ម្យ៉ាងទៀត មិនមែនជាអ្នកពិចារណាឃើញធម៌យ៉ាងឯក ក្រៅអំពីអវយវៈតូចធំក្នុងកាយផង មិនមែនជាអ្នកពិចារណាឃើញបុរស ឬស្ត្រី ក្រៅអំពីសក់ រោមជាដើមផង ក្នុងកាយឡើយ ។

ក្នុងពាក្យថា **កាយេ កាយានុបស្សី** នេះ មិនមែនពិចារណាឃើញធម៌យ៉ាងឯក ក្រៅអំពីមហាភូតរូប និងឧបាទាយរូប សូម្បីក្នុងកាយ ពោល គឺទីប្រជុំមហាភូតរូប និងឧបាទាយរូប មានសក់ រោមជាដើម ដោយពិតហើយ ក៏ជាអ្នកពិចារណាឃើញទីប្រជុំនៃអង្គអវយវៈ ដូចបុគ្គលមើលឃើញគ្រឿងប្រកបរបស់រថ ដូច្នោះ ជាអ្នកពិចារណាឃើញទីប្រជុំនៃសក់ រោមជាដើម ដូចបុគ្គលឃើញចំណែកផ្សេងៗ នៃទីក្រុង ដូច្នោះ នឹងជាអ្នកពិចារណាឃើញទីប្រជុំនៃមហាភូតរូប និងឧបាទាយរូបនោះឯង ដូចបុគ្គលសកស្រទបចេកអំពីដើមចេក ដូច្នោះ ដូចបុគ្គលលាតបាតដៃទទេយ៉ាងនោះឯង ព្រោះដូច្នោះ ដោយទ្រង់សម្តែងវត្ថុ ពោល គឺកាយ ដោយអំណាចនៃទីប្រជុំ ដោយប្រការផ្សេងៗ នោះឯង ឈ្មោះថា ទ្រង់សម្តែងកាយបែកឃនសញ្ញាចេញហើយ ព្រោះថា ក្នុងពាក្យថា **កាយេ កាយានុបស្សី** នេះ មិនឃើញជាកាយស្ត្រី

ជាបុរស ឬជាធម៌ដទៃណាមួយ ក្រៅអំពីការប្រជុំនៃធម៌តាមដែលពោលហើយ ។ តែសត្វទាំងឡាយធ្វើការជឿខុសយ៉ាងនោះៗ ក្នុងការៈត្រឹមតែការប្រជុំនៃធម៌ តាមដែលពោលហើយប៉ុណ្ណោះ ព្រោះដូច្នោះ ទើបបុរាណាចារ្យពោលថា

វត្ថុណា ដែលបុគ្គលកំពុងឃើញ វត្ថុនោះ មិនមែនវត្ថុដែលបុគ្គលនោះឃើញហើយទេ វត្ថុណាដែលបុគ្គលនោះឃើញហើយ វត្ថុនោះ មិនមែនវត្ថុដែលបុគ្គលនោះ កំពុងឃើញទេ កាលមិនឃើញតាមសេចក្តីពិត ទើបវង្វេងកាលវង្វេង រមែងមិនរួចផុត អធិប្បាយថា ដើម្បីសម្តែងដល់ការបែកឃនសញ្ញាចេញទៅជាដើម ។

ដោយ **អាធិ** សព្ទ ក្នុងពាក្យថា **ឃនវិនិព្ភោគាធិ ធស្សនដ្ឋំ** នេះ ក៏គួរជ្រាបអធិប្បាយដូចតទៅនេះថា

សេចក្តីពិត ព្រះយោគាវចរនេះ ពិចារណាឃើញកាយតែម្យ៉ាងប៉ុណ្ណោះ មិនមែនពិចារណាឃើញធម៌ដទៃឡើយ ។

សួរថា មានអធិប្បាយដូចម្តេច ឆ្លើយថា មានអធិប្បាយថា មនុស្សទូទៅមើលឃើញថ្ងៃបណ្តើរកូនដែលមិនមែនជាទឹក ថាជាទឹក យ៉ាងណា ព្រះយោគាវចរមិនមែនយ៉ាងនោះឡើយ គឺមិនឃើញកាយនេះ ដែលជារបស់មិនទៀង ជាទុក្ខ ជាអនត្តា និងមិនស្អាត ថាជារបស់ទៀង ជាសុខ ជាអត្តា និងជារបស់ស្អាត ដោយពិតហើយ ពិចារណាឃើញត្រឹមតែកាយ គឺពិចារណាឃើញថា ជាទីប្រជុំនៃកាយដែលមិនទៀង ជាទុក្ខ ជាអនត្តា និងជារបស់មិន

ស្អាតប៉ុណ្ណោះ ។

ម្យ៉ាងទៀត គួរជ្រាបអត្ថយ៉ាងនេះថា កាយនេះ មានខ្យល់ដង្ហើមចេញ-ចូលជាខាងដើម មានឆ្អឹងដែលក្លាយជាផង់ធូលីទៅក្នុងទីបំផុត ព្រះមានព្រះភាគត្រាស់ហើយដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះទៅកាន់ព្រៃក្តី ។បេ។ ភិក្ខុនោះ មានសតិដកដង្ហើមចេញ និងកាយណាដែលព្រះសារីបុត្រពោលមកក្នុងបដិសម្ភិទាមគ្គថា ព្រះយោគាវចររូបខ្លះក្នុងសាសនានេះ ពិចារណាឃើញកាយ គឺដី កាយ គឺទឹក កាយ គឺភ្លើង កាយ គឺខ្យល់ កាយ គឺសក់ កាយ គឺរោម កាយ គឺសម្បុរថ្ងៃ កាយ គឺស្បែក កាយ គឺសាច់ កាយ គឺឈាម កាយ គឺសរសៃ កាយ គឺឆ្អឹង កាយ គឺខួរក្នុងឆ្អឹង ថាជារបស់មិនទៀង ព្រោះពិចារណាឃើញកាយទាំងអស់នោះ ក្នុងកាយនេះឯង ទើបព្រះយោគាវចរ ឈ្មោះថា ពិចារណាឃើញកាយក្នុងកាយ ។

ម្យ៉ាងទៀត គួរជ្រាបអត្ថយ៉ាងនេះថា ពិចារណាឃើញកាយ ពោល គឺទីប្រជុំរូបធម៌ មានសក់ជាដើម ក្នុងកាយផ្សេងៗ ព្រោះមិនឃើញវត្ថុណាមួយក្នុងកាយដែលត្រូវប្រកាន់យ៉ាងនេះថា អញ ឬរបស់អញ តែព្រោះពិចារណាឃើញការប្រជុំនៃរូបធម៌ផ្សេងៗ នោះឯង មានសក់ និងរោមជាដើម ។

ម្យ៉ាងទៀត គួរយល់អត្ថយ៉ាងនេះថា ជាអ្នកពិចារណាឃើញកាយក្នុងកាយ ព្រោះពិចារណាឃើញកាយ ពោល គឺប្រជុំអាការ មានអនិច្ចលក្ខណៈជាដើម ទូទៅគ្រប់យ៉ាងក្នុងកាយនេះ មានន័យដូចដែលពោលមកហើយ ក្នុងបដិសម្ភិទាមគ្គ ដោយន័យថា ពិចារណាឃើញដោយភាពជារបស់មិនទៀង

មិនមែនឃើញដោយភាពជារបស់ទៀងឡើយជាដើម ។

ពិតហើយ ភិក្ខុអ្នកបដិបត្តិ **កាយេកាយានុបស្សនាបដិបទា** នេះ គប្បីជ្រាបថា ពិចារណាឃើញកាយនេះ ដោយអំណាចនៃអនុបស្សនា ៧ ប្រការ មានអនិច្ចានុបស្សនាជាដើម គឺពិចារណាឃើញដោយភាពជារបស់មិនទៀង មិនមែនពិចារណាឃើញ ដោយភាពជារបស់ទៀង និងពិចារណាឃើញដោយភាពជាទុក្ខ មិនមែនពិចារណាឃើញដោយភាពជាសុខ ពិចារណាឃើញដោយភាពជាអនត្តា មិនមែនពិចារណាឃើញថាជាអត្តា នឿយណាយមិនមែនត្រេកអរ និងប្រាសចាកតម្រេក មិនមែនត្រេកអរ និងរំលត់តណ្ហា មិនមែនឲ្យកើតតណ្ហា រលាស់ចេញ មិនមែនប្រកាន់មាំ កាលលោកពិចារណាឃើញកាយនោះ ដោយការមិនទៀង ក៏នឹងលះនិច្ចសញ្ញាបាន កាលពិចារណាឃើញដោយភាពជាទុក្ខ ក៏នឹងលះសុខសញ្ញាបាន កាលពិចារណាឃើញថាជាអនត្តា ក៏លះអត្តសញ្ញាបាន កាលនឿយណាយ ក៏នឹងលះនន្ទិធម៌ គឺការត្រេកអរបាន កាលប្រាសចាកតម្រេក ក៏នឹងលះរាគៈបាន កាលរំលត់ក៏នឹងលះសមុទយៈបាន កាលរលាស់ចេញបាន ក៏នឹងលះការប្រកាន់មាំបាន ។

បទថា **វិហរតិ** បានដល់ ដំណើរទៅ ។ ក្នុងបទថា **អាតាបី** គប្បីជ្រាបវិគ្គហៈដូច្នេះ ឈ្មោះថា **អាតាប** ព្រោះ អត្ថថា រមែងដុតបំផ្លាញកិលេសក្នុងភព ៣ ។ ពាក្យថា **អាតាប** នេះ ជា ឈ្មោះរបស់វិរិយៈ ។ **អាតាប** នៃភិក្ខុនោះមាន ហេតុនោះ ទើបភិក្ខុនោះ ឈ្មោះថា **អាតាបី** ។

បទថា **សម្បជានោ** បានដល់ ប្រកបដោយបញ្ញា ពោល គឺសម្ប-

ជញ្ញៈ ។ បទថា **សតិមា** គឺប្រកបដោយសតិ ដែលប្រើកំណត់កាយ ។

ធម្មតា អនុបស្សនានេះ នឹងមិនមានដល់បុគ្គលដែលប្រាសចាកសតិឡើយ ព្រោះព្រះយោគាវចរប្រើសតិកំណត់អារម្មណ៍ហើយ ទើបពិចារណាឃើញកាយជាដើម ដោយបញ្ញា ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលដល់សតិ ថាមានប្រយោជន៍ក្នុងធម៌ទាំងពួង ព្រោះដូច្នោះ ក្នុងព្រះសូត្រនេះ ទើបទ្រង់ត្រាស់ថា **កាយេ កាយានុបស្សី វិហរតិ** ប្រែថា ពិចារណាឃើញកាយក្នុងកាយ ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ទ្រង់ត្រាស់កាយានុបស្សនាសតិប្បដ្ឋាន-កម្មដ្ឋាន ។

មួយ៉ាងទៀត ព្រោះបុគ្គលមិនមានសេចក្តីព្យាយាម ការរួញរាខាងក្នុងរមែងធ្វើអន្តរាយឲ្យបាន បុគ្គលដែលមិនមានសម្បជញ្ញៈ រមែងជាអ្នកភ្លេចស្មារតី ក្នុងការកំណត់ឧបាយ និងក្នុងការវៀរនូវវត្ថុដែលមិនមែនឧបាយ គឺជាបុគ្គលមិនអាចក្នុងការកំណត់ឧបាយ និងក្នុងការលះបង់ចោលនូវវត្ថុដែលមិនមែនឧបាយ ហើយកម្មដ្ឋាននោះ នឹងមិនសម្រេចដល់លោកដោយវិធីនោះ ដូច្នោះគប្បីជ្រាបថា កាលទ្រង់សម្តែងធម៌ទាំងឡាយ ដែលមានអានុភាពជាហេតុសម្រេចនៃកម្មដ្ឋាននោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះថា **អាតាបី** មានសេចក្តីព្យាយាម **សម្បជានោ** មានសម្បជញ្ញៈ **សតិមា** មានសតិ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងកាយានុបស្សនាសតិប្បដ្ឋាន និងវិធីប្រកបកាយានុបស្សនាសតិប្បដ្ឋាននោះដោយប្រការយ៉ាងនេះហើយ ឥឡូវនេះ

កាលទ្រង់សម្ដែងអង្គនៃការលះកិលេស ទើបបានត្រាស់ថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ដើម្បីកម្ចាត់បង់អភិជ្ឈា និងទោមនស្សក្នុងលោក ។

បណ្ដាបទទាំងនោះ បទថា **វិនេយ្យ** បានដល់ ប្រាសចេញទៅដោយការប្រាសព្រាត់ទៅដោយអង្គនោះ ឬដោយការប្រាសចេញទៅដោយការសង្កត់សង្កិន ។

បទថា **លោកេ** បានដល់ ក្នុងកាយនោះឯង ។ សេចក្ដីពិត កាយ ទ្រង់បំណាងយកថា ជាលោកក្នុងទីនេះ ព្រោះអត្ថថា បែកធ្លាយ តែព្រោះហេតុដែលលោកមិនមែនលះអភិជ្ឈា និងទោមនស្សបានចំពោះត្រឹមតែក្នុងកាយប៉ុណ្ណោះ សូម្បីក្នុងវេទនាជាដើមក៏លះបានដូចគ្នា ដូច្នោះទើបលោកពោលក្នុងគម្ពីរវិភង្គថា **លោក** គឺឧបាទានក្ខន្ធទាំង ៥ ។

ម្យ៉ាងទៀត ព្រោះធម៌ទាំងនោះ ត្រូវរាប់ថា ជាលោក ពាក្យថា **លោក** នោះ ទើបលោកពោលដោយអត្ថុទ្ធារន័យ គឺដោយការពង្រីកសេចក្ដី ឯពាក្យណា ដែលលោកពោលថា ក្នុងធម៌ទាំងនោះ ធម៌ណាជាលោក កាយនោះឯងជាលោក ។ នេះឯងជាអធិប្បាយក្នុងពាក្យនេះ ។ គប្បីឃើញការសម្ពន្ធសេចក្ដីយ៉ាងនេះថា បណ្ដេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកនោះចេញបាន ព្រោះហេតុក្នុងសូត្រនេះ កាមច្ឆន្ទៈសង្គ្រោះចូលនឹងសព្ទថា **អភិជ្ឈា** ព្យាបាទសង្គ្រោះចូលនឹងសព្ទថា **ទោមនស្ស** ដូច្នោះ គប្បីជ្រាបថា ការលះនីវរណៈ គឺព្រះមានព្រះភាគត្រាស់ហើយ ដោយការសម្ដែងធម៌ ២ យ៉ាងដែលមានកម្លាំងទាក់ទងនឹងការលះនីវរណៈ តែដោយពិស្ដារហើយ ក្នុងសូត្រ

នេះ ព្រះមានព្រះភាគត្រាស់ការលះនូវការត្រេកអរ ដែលមានកាយសម្បត្តិជាមូល ដោយការកម្ចាត់អភិជ្ឈា និងការមិនត្រេកអរ ដែលមានកាយវិបត្តិជាមូលទៀត ដោយការកម្ចាត់ទោមនស្ស ម្យ៉ាងទៀត ត្រាស់ការលះនូវការត្រេកអរក្នុងកាយ ដោយការកម្ចាត់អភិជ្ឈាផង ការមិនត្រេកអរក្នុងការចម្រើនកាយភាវនា ដោយការកម្ចាត់ទោមនស្សផង ត្រាស់ការលះនូវការបន្ថែមនូវភាពស្អាត និងសេចក្តីសុខជាដើមដែលមិនមានពិតក្នុងកាយ ដោយការកម្ចាត់បង់អភិជ្ឈា និងការនាំចេញនូវការមិនស្អាត និងភាពជាទុក្ខ ដែលមានពិតក្នុងកាយ ដោយការកម្ចាត់បង់ទោមនស្ស ។

ដោយពាក្យថា **វិនេយ្យ លោកេ អភិជ្ឈា ទោមនស្សំ** នេះ ឈ្មោះថា ព្រះមានព្រះភាគ ទ្រង់សម្តែងអានុភាពនៃការបំពេញព្យាយាម និងភាពជាអ្នកអាចក្នុងការបំពេញសេចក្តីព្យាយាម របស់ព្រះយោគាវចរមកហើយ ។ សេចក្តីពិត អានុភាពរបស់សេចក្តីព្យាយាមនោះ បានដល់ ការដែលព្រះយោគាវចរជាអ្នករួចផុតទៅចាកសេចក្តីត្រេកអរ និងការមិនត្រេកអរ ជាអ្នកសង្កត់នូវការត្រេកអរ និងមិនត្រេកអរបាន និងជាអ្នកវៀរចាកការបន្ថែមវត្ថុដែលមិនពិតចូលទៅ និងនាំវត្ថុដែលពិតចេញមក ។ ព្រះយោគាវចរនេះ កាលរួចផុតចាកសេចក្តីត្រេកអរ និងការមិនត្រេកអរ សង្កត់បាននូវការត្រេកអរ និងមិនត្រេកអរ មិនបន្ថែមវត្ថុដែលមិនពិតចូលទៅ និងមិននាំវត្ថុដែលពិតចេញមក រមែងឈ្មោះថា ជាអ្នកអាចក្នុងការបំពេញព្យាយាម ដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបថា ទ្រង់ត្រាស់កម្មដ្ឋានដោយអនុបស្សនា ( ការ

ពិចារណារឿយៗ ) ក្នុងបទថា **កាយេ កាយានុបស្សី** នេះ ត្រាស់ការបរិហារកាយសម្រាប់បុគ្គលបំពេញកម្មដ្ឋានដោយការសម្រាក ដូចដែលបានពោលហើយក្នុងបទថា **វិហរតិ** ។ ក្នុងបទថា **អាតាបី** ជាដើម ទ្រង់ត្រាស់សម្មប្បធានដោយ **អាតាប** គឺព្យាយាមជាហេតុដុតនូវកិលេស ត្រាស់កម្មដ្ឋានដែលឲ្យសម្រេចប្រយោជន៍គ្រប់យ៉ាង ឬឧបាយសម្រាប់បរិហារកម្ម-ដ្ឋាន ដោយសតិសម្បជញ្ញៈ ។ ម្យ៉ាងទៀត ត្រាស់សមថៈដែលបានពោលមកហើយ ដោយអំណាចកាយានុបស្សនាដោយសតិ ។ ត្រាស់វិបស្សនាដោយសម្បជញ្ញៈ ។ ត្រាស់កម្លាំងនៃភាវនា ដោយការកម្ចាត់បង់អភិជ្ឈានិងទោមនស្ស ។

ក្នុងគម្ពីរវិភង្គ ព្រះអង្គត្រាស់បទថា **អនុបស្សី** សេចក្តីថា បណ្តាធម៌ទាំងនោះ អនុបស្សនា គឺអ្វី ។ គឺបញ្ញា ការដឹងទូទៅ ។បេ។ សម្មាទិដ្ឋិនេះហៅថា អនុបស្សនា ។ ភិក្ខុចូលដល់ ចូលដល់រៀបរយហើយ ចូលមកដល់ហើយ ចូលមកដល់រៀបរយហើយ ចូលទៅដល់ហើយ ដល់ព្រមហើយប្រកបហើយដោយអនុបស្សនានេះ ព្រោះហេតុនោះ ទើបត្រាស់ហៅថា **អនុបស្សី** គឺអ្នកពិចារណាឃើញរឿយៗ ។

បទថា **វិហរតិ** សេចក្តីថា រមែងផ្លាស់ប្តូរប្រព្រឹត្តទៅ រក្សាទុក ដំណើរទៅឯង ឲ្យរាងកាយដំណើរទៅ នាំទៅ សម្រាក ដោយហេតុនោះ ទើបត្រាស់ថា **វិហរតិ** ។

បទថា **អាតាបី** សេចក្តីថា បណ្តាធម៌ទាំងនោះ **អាតាប** គឺអ្វី ។ គឺ

ការប្រារព្ធសេចក្ដីព្យាយាមក្នុងចិត្ត ។បេ។ ការព្យាយាមប្រពៃ នេះហៅថា **អាតាប** ភិក្ខុដែលជាអ្នកចូលដល់ហើយ ។បេ។ ប្រកបព្រមហើយដោយអាតាបៈនេះ ដោយហេតុនោះ ទើបត្រាស់ហៅថា **អាតាបី** ។

បទថា **សម្បជានោ** សេចក្ដីថា បណ្ដាធម៌ទាំងនោះ **សម្បជញ្ញ** គឺអ្វី ។ គឺបញ្ញា ការដឹងទូទៅ ។បេ។ សម្មាទិដ្ឋិ នេះហៅថា **សម្បជញ្ញ** ។ ភិក្ខុជាអ្នកចូលដល់ហើយ ។បេ។ ប្រកបព្រមហើយដោយសម្បជញ្ញៈនេះ ដោយហេតុនោះ ទើបត្រាស់ហៅថា **សម្បជានោ** ។

បទថា **សតិមា** សេចក្ដីថា បណ្ដាធម៌ទាំងនោះ **សតិ** គឺអ្វី ។ សតិ គឺការរឭកបាន អនុស្សតិ គឺការរឭកដល់រឿយៗ ។បេ។ សម្មាសតិ គឺការរឭកត្រូវ នេះហៅថា **សតិ** ។ ភិក្ខុជាអ្នកចូលដល់ហើយ ។បេ។ ប្រកបព្រមហើយដោយសតិនេះ ដោយហេតុនោះ ទើបត្រាស់ហៅថា អ្នកមានសតិ ។

បទថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** សេចក្ដីថា បណ្ដាធម៌ទាំងនោះ **លោក** គឺអ្វី ។ កាយនោះឯង ឈ្មោះថា **លោក** លោក គឺឧបាទានក្ខន្ធ ៥ នេះ ហៅថា **លោក** ។

បណ្ដាបទទាំងនោះ **អភិជ្ឈា** គឺអ្វី ។ គឺការត្រេកអរ ការត្រេកអរខ្លាំងក្លា ការរីករាយ ការបណ្ដោយតាមការភ្លើតភ្លើន តម្រេកដោយការភ្លើតភ្លើន តម្រេកខ្លាំងក្លានៃចិត្ត នេះហៅថា **អភិជ្ឈា** ។

បណ្ដាធម៌ទាំងនោះ **ទោមនស្ស** គឺអ្វី គឺការមិនត្រេកអរផ្លូវចិត្ត សេចក្ដីទុក្ខផ្លូវចិត្ត ការមិនត្រេកអរ ទុក្ខវេទនាកើតអំពីមនោសម្ផស្សផ្លូវចិត្ត នេះហៅ

ថា **ទោមនស្សំ** ។

អភិជ្ឈាក្តី ទោមនស្សក្នុងលោកក្តី គឺកាយនេះ ឈ្មោះថា ត្រូវកម្ចាត់ហើយ ត្រូវកម្ចាត់ចេញទៅហើយ ស្ងប់ហើយ ស្ងាត់ហើយ រម្ងាប់ហើយ ដល់នូវការរំលត់ហើយ ដល់នូវការតាំងនៅមិនបានហើយ ដល់នូវការរលត់សូន្យទៅ មិនត្រេកអរហើយ អស់បដិភាណហើយ ស្គាំងស្គមហើយ ក្រៀមស្ងួតហើយ ធ្វើឲ្យវិនាសអស់ហើយ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា កម្ចាត់អភិជ្ឈា និងទោមនស្សក្នុងលោក គឺកាយបាន អត្ថនៃបទទាំងនោះ ខ្ញុំបានពោលហើយ ដូចពណ៌នាមកនេះ អ្នកសិក្សាគប្បីជ្រាបន័យនៃអដ្ឋកថានេះ មួយអន្លើដោយអត្ថនោះ ដោយការប្រៀបធៀបគ្នាចុះ ។

នេះជាកថាពណ៌នាសេចក្តីនៃឧទ្ទេស នៃកាយានុបស្សនាសតិប្បដ្ឋាន ។

## អធិប្បាយ វេទនានុបស្សនា

ឥឡូវនេះ អ្នកសិក្សាគប្បីជ្រាបប្រយោជន៍ក្នុងការពោលវេទនាជាដើម ក្នុងពាក្យមានយ៉ាងនេះថា **វេទនាសុ វេទនានុបស្សី វិហរតិ** ដែលមាននៅក្នុងពាក្យនេះថា **វេទនាសុ ... ចិត្តេ ... ធម្មេសុ ធម្មានុបស្សី វិហរតិ ។បេ។ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ដោយន័យដូចបានពោលហើយក្នុងកាយានុបស្សនា ។

ក្នុងពាក្យថា **វេទនាសុ វេទនានុបស្សី វិហរតិ ចិត្តេ ចិត្តានុបស្សី ធម្មេសុ ធម្មានុបស្សី** នេះ ពាក្យថា **វេទនា** បានដល់ វេទនា ៣ ហើយ វេទនានោះ ជាលោកិយតែម្យ៉ាង សូម្បីចិត្តក៏ដូចគ្នា គឺជាលោកិយ ។ ធម៌ក៏

ដូច្នោះដូចគ្នា ។ ការចែកវេទនាទាំងនោះជាដើម នឹងប្រាកដក្នុងនិទ្ទេសវារៈ តែក្នុងទីនេះ គប្បីជ្រាបការចែកវេទនាសុទ្ធៗ ថា វេទនាត្រូវពិចារណាឃើញយ៉ាងណា ព្រះយោគាវចរ កាលពិចារណាឃើញយ៉ាងនោះ ក៏ឈ្មោះថា ពិចារណាឃើញវេទនាក្នុងវេទនា ។ ក្នុងចិត្តានុបស្សនា និងធម្មានុបស្សនា ក៏ន័យនេះដូចគ្នា ។

សួរថា វេទនាគួរពិចារណាឃើញដូចម្តេច ឆ្លើយថា ជាបឋម សុខវេទនា គួរពិចារណាឲ្យឃើញថាជាទុក្ខ ទុក្ខវេទនាគួរពិចារណាឲ្យឃើញដូចជាព្រួញ អទុក្ខមសុខវេទនា គួរពិចារណាឲ្យឃើញជារបស់មិនទៀង ដូចព្រះតម្រាស់ថា

អ្នកឯណា បានឃើញសុខវេទនា ថាជាទុក្ខវេទនាវិញ បានឃើញទុក្ខវេទនា ថាជាកូនសរ បានឃើញអទុក្ខមសុខវេទនានោះ ថាជាសភាវៈមិនទៀងទៅវិញ បើភិក្ខុបានឃើញដោយប្រពៃ កំណត់ដឹងនូវវេទនាទាំងឡាយ ភិក្ខុនោះ លុះកំណត់ដឹងនូវវេទនាទាំងឡាយ ក្នុងបច្ចុប្បន្ននេះហើយ ជាអ្នកមិនមានអាសវៈ ស្ថិតនៅក្នុងធម៌ ជាអ្នកដល់នូវវេទ លុះទម្លាយរាងកាយទៅ មិនគួររាប់ថា ( ជាអ្នកមានភពទៀតឡើយ ) ។

វេទនាគ្រប់យ៉ាងនេះ គួរពិចារណាឲ្យឃើញថាជាទុក្ខ ។ ព្រះមានព្រះភាគបានត្រាស់ថា អារម្មណ៍ឯណានីមួយ ដែលបុគ្គលបានសោយហើយ អារម្មណ៍នោះ ក៏ជាទុក្ខ ។

ម្យ៉ាងទៀត សុខវេទនា ក៏គួរពិចារណាឲ្យឃើញថាជាទុក្ខ ។ ដូចព្រះ

តម្រាស់ថា សុខវេទនា មានកិរិយាស្ថិតនៅដដែលជាសុខ មានការប្រែប្រួលទៅវិញជាទុក្ខ ព្រោះដូច្នោះ គួរពង្រីកឲ្យពិស្តារគ្រប់អន្ទើ ។

ម្យ៉ាងទៀត វេទនាគួរពិចារណាឲ្យឃើញដោយអនុបស្សនាទាំង ៧ មានអនិច្ចានុបស្សនាជាដើម ។ ពាក្យដ៏សេស នឹងមានប្រាកដក្នុងនិទ្ទេសវារៈនោះឯង ។

បណ្តាចិត្ត និងធម៌ ចិត្តក៏គួរពិចារណាឲ្យឃើញដោយការចែកចេញទៅជាចិត្ត មានរាគៈជាដើមដែលមកហើយ ក្នុងនិទ្ទេសវារៈនៃអនិច្ចានុបស្សនាជាដើម ដែលចែកចេញផ្សេងៗ គ្នា មានអារម្មណ៍ អធិបតី សហជាតធម៌ ភូមិ កម្ម វិបាក និងកិរិយាជាដើម ។ ធម៌ ក៏គួរពិចារណាឲ្យឃើញដោយវិសេសលក្ខណៈ និងសាមញ្ញលក្ខណៈ ។ ដោយសុញ្ញតធម៌ ដោយអនុបស្សនាទាំង ៧ មានអនិច្ចានុបស្សនាជាដើម និងដោយចែកចេញជាសន្តធម៌គឺធម៌ដែលស្ងប់ និងអសន្តធម៌ជាដើម ដែលមកហើយក្នុងនិទ្ទេសវារៈ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនេះឯង ។

ក្នុងការលះអភិជ្ឈា និងទោមនស្សជាដើមនេះ បុគ្គលណា លះអភិជ្ឈា និងទោមនស្សក្នុងលោក ពោល គឺកាយបានហើយ បុគ្គលនោះ ក៏លះអភិជ្ឈា និងទោមនស្សក្នុងលោក គឺវេទនាជាដើមបាននោះឯងក៏ពិត សូម្បីដូច្នោះ ទ្រង់ក៏បានត្រាស់គ្រប់ៗ និទ្ទេសវារៈ ដោយបុគ្គលប្លែកផ្សេងគ្នា និងដោយសតិប្បដ្ឋានភាវនាដែលប្រាកដឡើងក្នុងខណៈចិត្តផ្សេងគ្នា ។ ម្យ៉ាងទៀត គប្បីជ្រាបថា ដោយហេតុដែលអភិជ្ឈា និងទោមនស្សដែលលះបានក្នុងវារៈមួយ

ហើយ ក៏ឈ្មោះថា លះបានក្នុងវារៈដ៏សេសនោះឯង ដើម្បីទ្រង់សម្តែងការលះអភិជ្ឈា និងទោមនស្សក្នុងវារៈនោះ ទើបត្រាស់យ៉ាងនេះ ដូច្នេះឯង ។

**ពោលអំពីឧទ្ទេសវារកថា ចប់**

# កាយានុបស្សនា

## អានាបានបព្វៈ

[ ១៣៣ ] ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់មានពុទ្ធបំណងឲ្យសត្វទាំងឡាយ សម្រេចគុណវិសេសច្រើនប្រការ ដោយធម្មទេសនា ពោលដោយសតិប្បដ្ឋាន ទើបទ្រង់ចែកសម្មាសមាធិមួយនោះឯងចេញជា ៤ តាមអារម្មណ៍ ដោយន័យថា សតិប្បដ្ឋានមាន ៤ យ៉ាង ។ ៤ យ៉ាង គឺអ្វីខ្លះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ពិចារណាឃើញកាយក្នុងកាយជាដើម ដូច្នេះហើយ តទៅ កាលទ្រង់យកសតិប្បដ្ឋានមួយមកចែកទៀត ទើបទ្រង់ប្រារព្ធដើម្បីត្រាស់និទ្ទេសវារៈ ដោយន័យជាដើមថា **កថញ្ច ភិក្ខវេ** ប្រែថា ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះដូចម្តេច ឧបមាដូចជាជាងផែងដ៏ឈ្លាសបំណាងនឹងធ្វើគ្រឿងប្រើប្រាស់ មានកន្ទេលផែងចម្រៀកធំ កន្ទេលផែងចម្រៀកតូច ប្រអប់ ហឹប និងស្មុគជាដើម បានឫស្សីធំមួយដើមមកពុះជា ៤ ចម្រៀក យកតែមួយចម្រៀកមកបិតឲ្យជាបន្ទោះ ហើយត្បាញគ្រឿងប្រើប្រាស់ ដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **កថញ្ច** ជាដើម ជាពាក្យសួរ ដោយទ្រង់

បំណាងធ្វើយឲ្យពិស្តារដោយព្រះអង្គឯង ។ ក្នុងបទនេះ មានអធិប្បាយដោយសង្ខេបដូចតទៅនេះ ម្នាលភិក្ខុទាំងឡាយ ដោយប្រការដូចម្តេច ទើបភិក្ខុពិចារណាឃើញកាយក្នុងកាយ ។ ក្នុងន័យនេះនឹងមានគ្រប់វារៈនៃសំណួរ ។

បទថា **ឥធ ភិក្ខវេ ភិក្ខុ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ។ ព្រោះថា **ឥធ** សព្ទនេះ ក្នុងពាក្យថា **ឥធ ភិក្ខវេ ភិក្ខុ** នេះ សំដៅដល់សាសនា ដែលជាទីពំនាក់អាស្រ័យរបស់បុគ្គល ដែលឲ្យកើតកាយានុបស្សនាគ្រប់ប្រការ និងបដិសេធសាសនាដទៃថាមិនមែនយ៉ាងនោះ។ សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សមណៈទាំងឡាយមានតែក្នុងសាសនានេះ ។បេ។ វាទៈ ( គឺទិដ្ឋិ ៦២ ) របស់សាសនាដទៃសូន្យចាកសមណៈទាំងឡាយដទៃ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា ភិក្ខុក្នុងសាសនានេះ ។

ពាក្យថា **អារញ្ញគតោ វា ។បេ។ សុញ្ញាគារគតោ វា** នេះ ជាពាក្យសម្តែងដល់ការកំណត់សេនាសនៈដ៏សមគួរ ដោយការបំពេញសតិប្បដ្ឋាន ។

ព្រោះថា ចិត្តនៃភិក្ខុនេះ ដែលរសាត់ទៅក្នុងរូបារម្មណ៍ជាដើមមកយូរហើយ មិនបំណាងចូលគន្លងកម្មដ្ឋានឡើយ រត់ចេញទៅក្រៅផ្លូវនោះឯង ដូចរទេះដែលទឹមដោយគោកំណាច ដូច្នោះ ព្រោះហេតុនោះ ទើបឧបមាដូចអ្នកចិញ្ចឹមគោ កាលបំណាងនឹងហ្វឹកកូនគោពុតដែលបៅដោះអំពីមេគោពុត ទើបជំឡើងមក កាលបំបែកគោនោះអំពីមេ បោះបង្គោលមួយធំ ក្នុងទីសមគួរ ហើយយកខ្សែលាមត្រង់បង្គោលនោះ ។ កាលកូនគោរបស់បុរសនោះ ចង់

ទៅខាងនោះខាងនេះ ក៏មិនអាចគេចទៅបាន ក៏ត្រូវឈរជិត ឬដេកជិតបង្គោលនោះឯង យ៉ាងណា ភិក្ខុរូបនេះឯងក៏ដូច្នោះដូចគ្នា កាលបំណងទូន្មានចិត្តកាចរបស់ខ្លួន ដែលចម្រើនឡើងពីការផឹករស មានរូបារម្មណ៍ជាដើមមកយូរហើយ កាលត្រូវឃាំងចាករូបារម្មណ៍ជាដើម ចូលទៅកាន់ព្រៃក្តី រុក្ខមូលក្តី ផ្ទះស្ងាត់ក្តី យកខ្សែ គឺសតិនោះចងចិត្តត្រង់បង្គោល គឺអារម្មណ៍របស់សតិប្បដ្ឋាននោះ ។ ចិត្តរបស់បុគ្គលនោះ ទោះបម្រះទៅខាងនោះ ខាងនេះ កាលមិនបានអារម្មណ៍ដែលធ្លាប់ស្និទ្ធស្នាលមកអំពីមុន មិនអាចទម្លាយខ្សែ គឺសតិឲ្យដាច់ ហើយចៀសទៅ ក៏សុបសៅ និងស្ងៀមនៅក្នុងអារម្មណ៍នោះឯង ដោយឧបចារសមាធិ ដោយហេតុនោះ ទើបបុរាណាចារ្យពោលថា

ព្រះយោគាវចរជាអ្នកបំពេញព្យាយាម ត្រូវយកសតិចងចិត្តរបស់ខ្លួនត្រង់អារម្មណ៍ គឺកម្មដ្ឋានឲ្យមាំ ដូចគ្នានឹងមនុស្សក្នុងលោកនេះ កាលទូន្មានគោ ត្រូវចងគោដែលត្រូវទូន្មានត្រង់បង្គោល ដូច្នោះ ។

សេនាសនៈនោះជាសេនាសនៈ ដែលសមគួរនឹងបំពេញកម្មដ្ឋានសម្រាប់លោក ដោយប្រការដូចពណ៌នាមកនេះ ។ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា **អរញ្ញគតោ វា ។បេ។ សុញ្ញាគារគតោ វា** នេះ ចង្អុលបង្ហាញដល់ការកំណត់សេនាសនៈដែលសមគួរនឹងការបំពេញសតិប្បដ្ឋាន ។

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះយោគាវចរមិនទាន់លះសេនាសនៈចុងស្រុក ដែលអឺងកងដោយសំឡេងស្ត្រី សំឡេងបុរស សំឡេងដំរី សំឡេងសេះជាដើមបាន នឹងញ៉ាំងអានាបានស្សតិកម្មដ្ឋាន ដែលជាកំពូលនៃកាយានុ-

បស្សនាជាហេតុជិតនៃការសម្រេចគុណវិសេសនិងទិដ្ឋធម្មសុខវិហារធម៌របស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវកគ្រប់ៗ អង្គនេះឲ្យបរិបូណ៌ មិនមែនរបស់ដែលធ្វើបានងាយ ព្រោះឈានមានសំឡេងជាគ្រឿងរកាំង គឺជាឧបសគ្គ ។ តែក្នុងព្រៃដែលមិនមានភូមិ ស្រុក ការកំណត់យកកម្មដ្ឋាននេះហើយញុំាងឈានទី ៤ មានអានាបានស្សតិជាអារម្មណ៍ ធ្វើឈាននោះឯងឲ្យជាបាទរបស់វិបស្សនា ពិចារណាសង្ខារហើយ បានសម្រេចអរហត្ត ដែលជាផលជាន់ខ្ពស់ ជាវត្ថុដែលព្រះយោគាវចរធ្វើបានងាយ ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេនាសនៈ ដែលសមគួរដល់ព្រះយោគាវចរនោះទើបត្រាស់ថា **អរញ្ញគតោ វា** ដូច្នេះជាដើម ។

ព្រោះថា ព្រះមានព្រះភាគ ទ្រង់ដូចជាអាចារ្យដឹងទឹកដី គឺអ្នកធរណីវិទ្យា ។ កាលទ្រង់ពិចារណាឃើញសេនាសនៈដែលសមគួរដល់យោគាវចរយ៉ាងនេះហើយ ទើបទ្រង់ចង្អុលបង្ហាញថា គួរបំពេញកម្មដ្ឋាន ក្នុងទីនេះ បន្ទាប់អំពីនោះទៅ ព្រះយោគីបំពេញកម្មដ្ឋាន កាលបានសម្រេចអរហត្តតាមលំដាប់ហើយ ទ្រង់បានទទួលសក្ការៈយ៉ាងច្រើន ដោយពាក្យសរសើរថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹងប្រពៃដោយព្រះអង្គឯងពិតៗ ហ្ន៎ ដូចអាចារ្យដែលចេះមើលទឹកដី មើលទីសាងព្រះនគរ ពិចារណាមើលសព្វគ្រប់ហើយ ចង្អុលប្រាប់ថា អ្នកទាំងឡាយ ចូរសាងនគរក្នុងទីនេះ កាលនគរសាងស្រេចដោយសួស្តីហើយ នឹងបានព្រះរាជទានសក្ការៈច្រើន អំពីរាជត្រកូល ដូច្នោះ ។

តែភិក្ខុរូបនេះ លោកពោលថា ដូចគ្នានឹងខ្លាធំ អធិប្បាយថា ខ្លាធំអាស្រ័យគុម្ពស្មៅ ឬគុម្ពោតព្រៃ ចូលទៅក្នុងព្រៃ ពួនចាប់ពពួកម្រឹគ មានក្របីព្រៃ ម្រឹគស្មាន់ និងជ្រូកព្រៃជាដើមស៊ី យ៉ាងណា ភិក្ខុនេះក៏ដូច្នោះដូចគ្នា បំពេញកម្មដ្ឋានរឿយៗ ក្នុងព្រៃជាដើម នឹងសម្រេចអរិយមគ្គ ៤ និងអរិយផល ៤ តាមលំដាប់ ព្រោះដូច្នោះ ទើបបុរាណាចារ្យពោលថា ភិក្ខុជាពុទ្ធបុត្រ បំពេញវិបស្សនា ប្រកបសេចក្តីព្យាយាមនេះ ចូលទៅកាន់ព្រៃហើយសម្រេចអរហត្តផល ដូចខ្លាធំពួនចាប់ម្រឹគស៊ី ដូច្នោះ ។

ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេនាសនៈព្រៃដែលជាទីកដីសមគួរដល់ការពួនសម្ងំ ក្នុងការប្រកបព្យាយាមដល់ភិក្ខុនោះ ទើបត្រាស់ថា **អរញ្ញគតោ វា** ដូច្នេះជាដើម ។

បន្តអំពីនេះទៅ ពាក្យណាដែលខ្ញុំត្រូវពោលក្នុងអានាបានបព្វៈនេះ ពាក្យនោះខ្ញុំបានពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គនោះហើយ ។

កាលព្រះយោគាវចរនោះ សិក្សាដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនេះ ដែលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ភិក្ខុសិក្សាថា កាលខ្យល់ដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អញដកដង្ហើមចេញវែង ឈានទាំង ៤ កើតឡើងព្រោះនិមិត្ត គឺអស្សាសៈ និងបស្សាសៈ ។

លោកចេញចាកឈានហើយ កំណត់ខ្យល់ដង្ហើមចេញ-ចូល ឬកំណត់អង្គឈាន ក្នុងចំនួនអស្សាសបស្សាសៈ និងអង្គឈានទាំង ២ យ៉ាងនោះ ។ បើជាអ្នកកំណត់អស្សាសបស្សាសៈជាអារម្មណ៍ ក៏កំណត់រូបយ៉ាងនេះថា

អស្សាសបស្សាសៈអាស្រ័យអ្វី ក៏បានដឹងថា អាស្រ័យនឹងវត្ថុ **ករជកាយ** ឈ្មោះថា វត្ថុ **មហាភូតរូប ៤** និង **ឧបាទាយរូប** ២៤ ឈ្មោះថា ករជកាយ ។

បន្ទាប់មក កំណត់នាមរូបយ៉ាងនេះថា នាមមានក្នុងអារម្មណ៍នោះ មានផស្សៈជាគម្រប់ ៥ កាលស្វែងរកបច្ច័យរបស់នាមរូបនោះ នឹងឃើញបដិច្ច-សមុប្បាទ មានអវិជ្ជាជាដើម ឆ្លងសេចក្តីសង្ស័យបានថា នេះត្រឹមតែជាបច្ច័យ និងធម៌ដែលអាស្រ័យបច្ច័យកើតឡើងប៉ុណ្ណោះ មិនមានសត្វ ឬបុគ្គលដទៃផ្សេងក្រៅអំពីអស្សាសបស្សាសៈនោះឡើយ លើកឡើងនូវនាមរូប ព្រមទាំងបច្ច័យកាន់ត្រៃលក្ខណ៍ ចម្រើនវិបស្សនា ចាក់ធ្លុះអរហត្តតាមលំដាប់ នេះជាឱកាសនៃការចេញទៅចាកទុក្ខ រហូតដល់អរហត្តរបស់ភិក្ខុមួយរូប ។

ឯបុគ្គលកំណត់ឈានជាអារម្មណ៍ កំណត់នាមរូបថា អង្គឈានទាំង-ឡាយនេះ អាស្រ័យនឹងអ្វី ក៏បានដឹងថា អាស្រ័យនឹងវត្ថុ ករជកាយឈ្មោះថា វត្ថុ អង្គឈានជានាម ករជកាយជារូប កាលស្វែងរកបច្ច័យរបស់នាមរូបនោះ នឹងឃើញបច្ចយាការ មានអវិជ្ជាជាដើម ឆ្លងចាកសេចក្តីសង្ស័យបានថា នេះត្រឹមតែជាបច្ច័យ និងធម៌ដែលអាស្រ័យបច្ច័យកើតឡើងប៉ុណ្ណោះ មិនមានសត្វ ឬបុគ្គលដទៃដោយឡែកអំពីនាមរូបនោះ លើកឡើងនូវនាមរូបព្រមទាំងបច្ច័យកាន់ត្រៃលក្ខណ៍ ចម្រើនវិបស្សនា សម្រេចអរហត្តតាមលំដាប់ នេះជាឱកាសនៃការចេញទៅចាកទុក្ខ រហូតដល់អរហត្តរបស់ភិក្ខុមួយអង្គ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្ដីថា ភិក្ខុពិចារណាឃើញកាយក្នុងកាយ គឺខ្យល់ដង្ហើមចេញ-ចូលរបស់ខ្លួនយ៉ាងនេះក្ដី ។

បទថា **ពហិទ្ធា វា** សេចក្ដីថា ពិចារណាឃើញកាយក្នុងកាយ គឺខ្យល់ដង្ហើមចេញ-ចូលរបស់អ្នកដទៃក្ដី ។

បទថា **អជ្ឈត្តពហិទ្ធា វា** សេចក្ដីថា ក្នុងកាយ គឺខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូលរបស់ខ្លួន និងរបស់អ្នកដទៃតាមកាលវេលាយ៉ាងនេះ ។

ដោយបទថា **អជ្ឈត្តពហិទ្ធា វា** នេះ ទ្រង់ត្រាស់ដល់កាលវេលាដែលខ្យល់ ដង្ហើមនោះចេញៗ ចូលៗ ដោយមិនផ្អាកកម្មដ្ឋានដែលជំនាញ ។ តែទាំង ២ យ៉ាងនេះ នឹងមានក្នុងវេលាជាមួយគ្នាមិនបាន ។

បទថា **សមុទយធម្មានុបស្សី វា** សេចក្ដីថា ឧបមាដូចស្នប់របស់ជាងមាស អាស្រ័យដងស្នប់ និងការព្យាយាមដែលកើតទាំង ២ យ៉ាងនោះ ទើបខ្យល់ប្រព្រឹត្តទៅមកបាន យ៉ាងណា កាយ គឺអស្សាសបស្សាសៈនៃភិក្ខុក៏ដូច្នោះ អាស្រ័យករជកាយ ក្ដាងប្រមុះ និងចិត្ត ទើបសញ្ចរទៅមកបាន ។ ធម៌ទាំងឡាយមានកាយជាដើមជាសមុទយៈ ភិក្ខុកាលពិចារណាធម៌ទាំងនោះ ហៅថា ពិចារណាឃើញធម៌ គឺការកើតឡើងក្នុងកាយ ។

បទថា **វយធម្មានុបស្សី វា** សេចក្ដីថា កាលកាយបែកធ្លាយ ក្ដាងប្រមុះបិទជិត និងចិត្តរលត់ ឈ្មោះថា **កាយ** គឺអស្សាសៈ និងបស្សាសៈ សញ្ចរមិនបាន ដូចគ្នានឹងស្នប់ កាលនាំចេញទៅហើយ កាលដងស្នប់បាក់ និងកាលមិនមានសេចក្ដីព្យាយាមដែលកើតអំពីស្នប់ និងដងស្នប់នោះ ខ្យល់

នោះ នឹងមិនដើរ ដូច្នោះ ខ្យល់ដង្ហើមចេញ-ចូល រលត់ទៅ ព្រោះកាយជាដើមបែកធ្លាយទៅ កាលភិក្ខុពិចារណាឃើញយ៉ាងនេះ ទើបទ្រង់ត្រាស់ហៅថា ពិចារណាឃើញធម៌ គឺការរលត់ទៅក្នុងកាយ ។

បទថា **សមុទយវយធម្មានុបស្សី** សេចក្ដីថា ពិចារណាឃើញការកើតតាមកាលវេលា ការរលត់ទៅតាមកាលវេលា ។

បទថា **អត្ថិ កាយោតិ វា បនស្ស** សេចក្ដីថា **សតិ** ឈ្មោះថាលោកចូលទៅតាំងទុកយ៉ាងនេះថា កាយមាន តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុស មិនមែនអត្តា មិនមែនវត្ថុដែលទាក់ទងដោយអត្តា មិនមែនអញ មិនមែនរបស់អញ មិនមែនបុគ្គលណា មិនមែនរបស់បុគ្គលណា ។

ពាក្យថា **យាវទេវ** នេះ ជាពាក្យកំណត់ចង្អុលបង្ហាញនូវប្រយោជន៍ ពាក្យអធិប្បាយថា សតិដែលចូលទៅតាំងទុកនោះ មិនមែនដើម្បីប្រយោជន៍ដទៃ ដោយពិតនោះ ដើម្បីត្រឹមតែការដឹងប៉ុណ្ណោះ គឺដើម្បីប្រយោជន៍ដល់ញាណដែលក្រៃលែងឡើងទៅ ជាប្រមាណតៗ ទៅ និងដើម្បីសតិជាប្រមាណ អធិប្បាយថា ដើម្បីឲ្យសតិ និងសម្បជញ្ញៈចម្រើនឡើង ។

បទថា **អនិស្សិតោ ច វិហរតិ** សេចក្ដីថា ជាអ្នកមិនអាស្រ័យអ្វីមួយដោយអំណាចនៃតណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ ។

ពាក្យថា **ន ច កិញ្ចិ លោកេ ឧបាទិយតិ** សេចក្ដីថា លោកមិនប្រកាន់អ្វី គឺរូប ។បេ។ ឬវិញ្ញាណក្នុងលោកថា នេះជាអត្តា ឬវត្ថុដែលទាក់ទងដោយ

អត្តារបស់ខ្លួន ។

**ចិ** អក្ខរៈ ក្នុងពាក្យថា **ឃរំចិ** ប្រើក្នុងអត្ថថា រួមយកអត្ថខាងមុខមកទុក ។ មួយាងទៀត ដោយបទនេះ ព្រះមានព្រះភាគទ្រង់សម្តែងធម៌ទេសនាពោលដោយអានាបានបព្វៈ ប្រគល់ឲ្យសាវកទាំងឡាយ ដូច្នេះ ។

បណ្តាសច្ចៈទាំងនោះ សតិដែលកំណត់អស្សាសៈ និងបស្សាសៈ ជាទុក្ខសច្ច តណ្ហាដែលមានអំពីមុន ដែលជាសមុដ្ឋានរបស់សតិនោះ ជាទុក្ខសមុទយៈ ការមិនប្រព្រឹត្តទៅនៃសតិ និងតណ្ហាទាំង ២ យ៉ាងនោះ ជានិរោធ អរិយមគ្គដែលមានការកំណត់ដឹងទុក្ខ មានការលះសមុទយៈ មាននិរោធជាអារម្មណ៍ ជាមគ្គសច្ច ។

លោកខ្វល់ខ្វាយដោយអំណាចសច្ចៈទាំង ៤ យ៉ាងនេះហើយ នឹងសម្រេចការរលត់ គឺព្រះនិព្វាន ដូច្នោះ ទើបសេចក្តីនេះជាឱកាសនៃការចេញទៅអំពីទុក្ខ រហូតដល់អរហត្តរបស់ភិក្ខុដែលមិនប្រកាន់មាំ ដោយអំណាចអស្សាសៈ និងបស្សាសៈមួយអន្ត ។

**អានាបានបព្វៈ ចប់**

## អធិប្បាយ ឥរិយាបថបព្វៈ

[ ១៣៤ ] ព្រះមានព្រះភាគ កាលទ្រង់ចែកការពិចារណាមើលកាយដោយអស្សាសៈ និងបស្សាសៈយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយឥរិយាបថ ទើបត្រាស់ពាក្យថា **បុន ច បរំ** ជាដើម ។

នឹងវិនិច្ឆ័យក្នុងបទទាំងនោះដូច្នេះ ឆ្កែស្រុក និងឆ្កែចចក កាលដើរទៅ

ក៏ដឹងដោយពិតថា អញកំពុងដើរ ។ ការដឹងនោះ ព្រះមានព្រះភាគ ទ្រង់មិនបានត្រាស់សំដៅយកការដឹងបែបនោះ ។ ព្រោះការដឹងបែបនេះ លះសត្តូបលទ្ធិ គឺការប្រកាន់មាំថា ជាសត្វមិនបាន ។ ដកអត្តសញ្ញាក៏មិនបាន ។ មិនជាកម្មដ្ឋាន ឬសតិប្បដ្ឋានភាវនាឡើយ ។

តែការដឹងរបស់ភិក្ខុនេះ លះសត្តូបលទ្ធិបាន ដកសត្តសញ្ញាបាន ជាកម្មដ្ឋាន ឬជាសតិប្បដ្ឋានភាវនា ។ សេចក្តីពិត ការដឹងនេះ ទ្រង់ត្រាស់សំដៅយកការដឹងខ្លួនយ៉ាងនេះថា អ្នកណាដើរ ការដើររបស់អ្នកណា ដើរបានព្រោះហេតុអ្វី ក្នុងការឈរ ក៏មានន័យដូចគ្នា ។

បណ្តាពាក្យទាំងនោះ ពាក្យថា អ្នកណាដើរ សេចក្តីថា មិនមែនសត្វណា ឬមនុស្សណាដើរឡើយ ។ ពាក្យថា ការដើររបស់អ្នកណា សេចក្តីថា មិនមានការដើររបស់អ្នកណាឡើយ ។ ពាក្យថា ដើរបានព្រោះហេតុអ្វី សេចក្តីថា ដើរទៅបាន ដោយការផ្សាយរបស់វាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត ។ ព្រោះដូច្នោះ ភិក្ខុនេះ ដឹងច្បាស់នូវឥរិយាបថយ៉ាងនេះ ចិត្តកើតឡើងថា អញនឹងដើរ ចិត្តនោះឲ្យវាយោធាតុកើត និងឲ្យការកម្រើកនៃវាយោកើត ។ ការរំកិលកាយទាំងមូលទៅខាងមុខ ដោយការផ្សាយរបស់វាយោធាតុ ដែលកើតអំពីកិរិយានៃចិត្ត ហៅថា ការដើរ ។ ក្នុងការឈរជាដើម ក៏មានន័យនេះដូចគ្នា ។

ក្នុងបណ្តាការឈរជាដើមនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ចិត្តកើតឡើងថា អញនឹងឈរ ចិត្តនោះនឹងឲ្យវាយោកើត នឹងឲ្យការកម្រើកនៃវាយោកើត ។

ភាវៈដែលកាយទាំងអស់ តាំងអំពីទីបំផុត គឺពីក្បាលដល់ចុងជើង តឹងឡើង ដោយការផ្សាយរបស់វាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត ហៅថា ការឈរ ។

ចិត្តកើតឡើងថា អញនឹងអង្គុយ ចិត្តនោះ នឹងឲ្យវាយោកើត នឹងឲ្យការកម្រើកនៃវាយោកើត ការបត់កាយខាងក្រោមចុះ ការតឹងនៃកាយខាងលើតាំងឡើង ដោយការផ្សាយរបស់វាយោធាតុ ដែលកើតអំពីកិរិយានៃចិត្ត ហៅថា ការអង្គុយ ។

ចិត្តកើតឡើងថា អញនឹងដេក ចិត្តនឹងឲ្យវាយោនោះកើត នឹងឲ្យការកម្រើកនៃវាយោកើត ។ ការសណ្ដូកកាងកាយទាំងអស់ចេញទៅតាមទទឹង ដោយការផ្សាយនៃវាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត ហៅថា ការដេក ។ អាការរបស់បុគ្គលដែលឃើញយ៉ាងនេះ ហៅថា សត្វដើរ សត្វឈរ ។

សួរថា មានសត្វណាដើរ ឬឈរឬ ឆ្លើយថា មិនមាន ។

តែដូចពាក្យដែលហៅថា រទេះទៅ រទេះឈប់ ។ ក៏មិនមានអ្វី ដែលឈ្មោះថា រទេះទៅ ឬឈប់ ។ តែកាលសារថីអ្នកឈ្លាស ទឹមគោ ៤ ដេញទៅ ក៏មានត្រឹមតែការហៅថា រទេះទៅ រទេះឈប់ យ៉ាងណា កាយដូចរទេះ ព្រោះអត្ថថា មិនដឹង ខ្យល់ដែលកើតអំពីចិត្ត ដូចគោ ចិត្ត ដូចសារថី កាលចិត្តកើតឡើងថា អញនឹងដើរ វាយោធាតុដែលនឹងឲ្យកើតវិញ្ញត្តិក៏នឹងកើតឡើង ការដើរជាដើមនឹងប្រព្រឹត្តទៅដោយការផ្សាយពង្រីករបស់វាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត នឹងមានត្រឹមតែការសន្មត ហៅថា

សត្វដើរ សត្វឈរ ខ្ញុំដើរ ខ្ញុំឈរដូច្នោះ ដូចគ្នា ។

ទូករសាត់ទៅបាន ព្រោះកម្លាំងរបស់ខ្យល់ ព្រួញរត់ទៅបាន ព្រោះកម្លាំងរបស់ខ្សែ យ៉ាងណា រាងកាយនេះ ក៏យ៉ាងនោះ ដើរទៅបាន ព្រោះខ្យល់ខាងក្នុងបក់ឲ្យកម្រើក ។ កាយយន្តនេះ ដែលនាយជាង គឺតណ្ហាប្រកបទុក ដើរ ឈរ អង្គុយ បានដោយអំណាចខ្សែទាញ គឺចិត្ត ដូចតុក្កតាយន្តកម្រើកបាន ដោយអំណាចនៃខ្សែទាញ ក្នុងរឿងនេះ មិនមានសត្វក្រៅអំពីហេតុបច្ច័យ ដែលឈរក្តី ដើរក្តី ដោយអានុភាពរបស់ខ្លួនឡើយ ។

ព្រោះដូច្នោះ ព្រះយោគាវចរនោះកំណត់ដឹងនូវឥរិយាបថដើររបស់ខ្លួន ដែលប្រព្រឹត្តទៅដោយហេតុ និងបច្ច័យប៉ុណ្ណោះ យ៉ាងនេះ គប្បីជ្រាបចុះថា បុគ្គលនោះ កាលដើរ ក៏ដឹងច្បាស់ថា អញដើរ កាលឈរ អង្គុយ ដេក ក៏ដឹងច្បាស់ថា អញឈរ អង្គុយ ដេក ។

ពាក្យថា **យថា យថា វា បនស្ស កាយោ បណិហិតោ ហោតិ តថា តថា នំ បជានាតិ** ប្រែថា លោករមែងដឹងច្បាស់កាយនោះតាមដែលខ្លួនតាំងនៅហើយ នេះជាពាក្យដែលប្រមូលឥរិយាបថគ្រប់យ៉ាង ។

មានអធិប្បាយដូចតទៅនេះថា កាយរបស់លោកតាំងនៅហើយ ដោយអាការណាៗ លោកក៏ដឹងច្បាស់នូវកាយនោះដោយអាការនោះៗ គឺដឹងច្បាស់កាយដែលតាំងនៅ ដោយអាការដែលដើរថា កំពុងដើរ ដឹងច្បាស់កាយដែលតាំងនៅ ដោយអាការដែលឈរ អង្គុយ ឬដេក ថាកំពុងដេកជាដើម ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ឬលោកពិចារណាឃើញកាយក្នុង

កាយ ដោយការពិចារណាឥរិយាបថទាំង ៤ របស់ខ្លួនយ៉ាងនោះ ។

បទថា **ពហិទ្ធា វា** សេចក្តីថា ឬដោយកំណត់ឥរិយាបថ ៤ របស់អ្នកដទៃ ។ បទថា **អជ្ឈត្តពហិទ្ធា វា** សេចក្តីថា ពិចារណាឃើញកាយក្នុងកាយ ដោយការកំណត់ឥរិយាបថ ៤ របស់ខ្លួន ឬរបស់អ្នកដទៃតាមកាលវេលា ។

ឯក្នុងបទថា **សមុទយធម្មានុបស្សី វា** ជាដើម អ្នកសិក្សាគួរនាំយកការកើតឡើង និងការរលត់ទៅនៃរូបក្ខន្ធ ដោយអាការ ៥ យ៉ាងមក ដោយន័យជាដើមថា ព្រោះអវិជ្ជាកើត ទើបរូបក្ខន្ធកើត ។

សេចក្តីពិត ពាក្យថា **សមុទយធម្មានុបស្សី វា** នេះ ក្នុងឥរិយាបថ-បព្វៈ នេះ ទ្រង់ត្រាស់សំដៅយកពាក្យនោះ ។ ពាក្យថា **អត្ថិ កាយោតិ វា បនស្ស** ជាដើម ក៏ដូចគ្នាដែលពោលមកហើយនោះឯង ។

តែក្នុងឥរិយាបថបព្វៈនេះ សតិដែលកំណត់ឥរិយាបថទាំង ៤ ជាទុក្ខសច្ច បុរិមតណ្ហាដែលជាសមុដ្ឋានរបស់សតិ ជាសមុទយសច្ច ការមិនប្រព្រឹត្តទៅនៃសតិ និងតណ្ហាទាំង ២ យ៉ាងនោះ ជានិរោធសច្ច អរិយមគ្គដែលកំណត់ដឹងទុក្ខ ដែលលះសមុទយៈ មាននិរោធជាអារម្មណ៍ ជាមគ្គសច្ច ។

ព្រះយោគាវចរ ខ្វល់ខ្វាយដោយអំណាចសច្ចៈទាំង ៤ យ៉ាងនេះហើយ នឹងសម្រេចការរលត់ គឺព្រះនិព្វាន ពាក្យដូចពណ៌នាមកនេះ ជាឱកាសនៃការនាំចេញចាកទុក្ខ រហូតដល់ព្រះអរហត្តរបស់ភិក្ខុដែលកំណត់ឥរិយាបថ ៤ មួយរូបនោះឯង ។

**អធិប្បាយ ឥរិយាបថបព្វៈ ចប់**

# អធិប្បាយ សម្បជញ្ញបព្វៈ

[ ១៣៥ ] ព្រះមានព្រះភាគ កាលទ្រង់ចែកការពិចារណាឃើញកាយក្នុងកាយ ដោយឥរិយាបថយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយសម្បជញ្ញៈ ៤ ទើបត្រាស់ពាក្យជាដើមថា **បុន ចបរំ** ។

ជាបឋម បណ្តាពាក្យទាំងនោះ ក្នុងពាក្យថា **អភិក្កន្តេ បដិក្កន្តេ** នេះ ការដើរទៅ ទ្រង់ត្រាស់ហៅថា **អភិក្កន្ត** ការដើរថយ ទ្រង់ត្រាស់ហៅថា **បដិក្កន្ត** ។ ទាំង ២ យ៉ាង បានក្នុងឥរិយាបថទាំង ៤ ។

យើងនឹងពោលក្នុងការដើរជាមុន កាលបង្អោនកាយទៅខាងមុខ ក៏ឈ្មោះថា ឈានទៅ កាលបង្អោនត្រឡប់ ឈ្មោះថា ឈានថយ ។ ក្នុងការឈរ អ្នកឈរនោះឯង កាលបង្អោនកាយទៅខាងមុខ ឈ្មោះថា ឈានទៅ កាលបង្អោនកាយមកខាងក្រោយ ឈ្មោះថា ថយក្រោយ ។ ក្នុងការអង្គុយ អ្នកអង្គុយនោះឯង កាលបង្អោនខ្លួនទៅខាងមុខចំពោះមុខអាសនៈ ឈ្មោះថា ឈានទៅ កាលបង្អោនកាយខាងក្រោយទៅក្រោយ ឈ្មោះថា ថយក្រោយ ។ ការដេក ក៏មានន័យនេះដូចគ្នា ។

បទថា **សម្បជានការី ហោតិ** សេចក្តីថា ជាអ្នកប្រកបកិច្ចគ្រប់យ៉ាងដោយសម្បជញ្ញៈជាប្រក្រតី ឬជាអ្នកធ្វើការដឹងខ្លួននោះឯងជាប្រក្រតី ព្រោះថា លោកធ្វើការដឹងខ្លួននោះឯង ក្នុងការឈានទៅខាងមុខជាដើម មិនថាក្នុងឥរិយាបថណាមួយ ក៏មិនវៀរសម្បជញ្ញៈ ។

សម្បជញ្ញៈ ក្នុងពាក្យថា **សម្បជានការី** នោះ មាន ៤ យ៉ាង គឺ សាត្ថកសម្បជញ្ញៈ ១ សប្បាយសម្បជញ្ញៈ ១ គោចរសម្បជញ្ញៈ ១

អសម្មោហសម្បជញ្ញៈ ១ ។

បណ្ដាសម្បជញ្ញៈទាំង ៤ យ៉ាងនោះ ការមិនទៅតាមអំណាចការគិតដែលកើតឡើងនោះឯង ក្នុងកាលគិតនឹងឈានទៅ កំណត់ប្រយោជន៍ និងមិនប្រយោជន៍ជាមុនថា ការទៅទីនោះ នឹងមានប្រយោជន៍ដល់អញ ឬមិនមានហើយ កាន់យកតែប្រយោជន៍ ឈ្មោះថា **សាត្ថកសម្បជញ្ញៈ** ។

បណ្ដាអត្ថៈ និងអនត្ថៈ គឺប្រយោជន៍ និងមិនប្រយោជន៍ ទាំង ២ យ៉ាងនោះ ការចម្រើនតាមផ្លូវធម៌ ដោយបានឃើញព្រះចេតិយ បានឃើញដើមពោធិ៍ បានឃើញព្រះសង្ឃ បានឃើញព្រះថេរៈ និងបានឃើញអសុភារម្មណ៍ជាដើម ឈ្មោះថា អត្ថៈ ។ ព្រោះថា សូម្បីបានឃើញព្រះចេតិយ ហើយញុំាងបីតិឲ្យកើត មានព្រះពុទ្ធជាអារម្មណ៍ឡើងបាន និងព្រោះបានឃើញព្រះសង្ឃ ក៏ឲ្យកើតបីតិ មានព្រះសង្ឃជាអារម្មណ៍ឡើងបាន ហើយកាលពិចារណាអារម្មណ៍នោះឯង ដោយការអស់ទៅ និងការសូន្យទៅ ក៏សម្រេចអរហត្ត ។ បានឃើញព្រះថេរៈហើយ តាំងនៅក្នុងឱវាទរបស់លោក បានឃើញអសុភារម្មណ៍ហើយ ញុំាងបឋមជ្ឈានឲ្យកើតក្នុងអសុភារម្មណ៍នោះបាន កាលពិចារណាអសុភារម្មណ៍នោះឯង ដោយការអស់ទៅ និងការសូន្យទៅ ក៏សម្រេចអរហត្ត ។ ព្រោះដូច្នោះ ការឃើញវត្ថុទាំងនោះ ទើបឈ្មោះថា មានប្រយោជន៍ តែអាចារ្យពួកខ្លះពោលថា ការចម្រើនខាងអាមិស ក៏ឈ្មោះថា ជាប្រយោជន៍ដូចគ្នា ព្រោះអាស្រ័យប្រយោជន៍នោះហើយ បានបដិបត្តិធម៌ ដើម្បីអនុគ្រោះព្រហ្មចរិយៈ ។

ឯការកំណត់សប្បាយ និងអសប្បាយ ក្នុងការដើរនោះហើយ កំណត់យកសប្បាយ ឈ្មោះថា **សប្បាយសម្បជញ្ញៈ ។**

បានដល់ អ្វី បានដល់ ការឃើញព្រះចេតិយ ឈ្មោះថា មានប្រយោជន៍ បើបរិស័ទប្រជុំគ្នា ក្នុងចម្ងាយ ១០ ឬ ១២ យោជន៍ ដើម្បីបូជាមហាចេតិយជាការធំ ស្ត្រីខ្លះ បុរសខ្លះ តាក់តែងខ្លួនដោយគ្រឿងប្រដាប់តាមគួរដល់សម្បត្តិរបស់ខ្លួនតាមឋានានុរូប ដើរត្រេសង់ទៅ ដូចគ្នានឹងរូបចិត្រកម្ម គឺរូបគំនូរសោត លោកក៏កើតការចង់បានក្នុងឥដ្ឋារម្មណ៍នោះ និងកើតការអាក់អន់ព្រោះអនិដ្ឋារម្មណ៍ និងកើតការវង្វេង ព្រោះការមើលមិនសមគួរ ។ នឹងត្រូវអាបត្តិកាយសំសគ្គៈ ឬមានអន្តរាយដល់ជីវិត នឹងព្រហ្មចរិយៈ ។ ទីដូចពណ៌នាមកនេះ ឈ្មោះថា ជាអសប្បាយ ។ ការឃើញព្រះសង្ឃដែលជាសប្បាយ ឈ្មោះថា មានប្រយោជន៍ ព្រោះមិនមានអន្តរាយ មានប្រការដូចដែលពោលមកហើយ ។

តែកាលមនុស្សនាំគ្នាសាងបារាំធំខាងក្នុងស្រុក ហើយស្តាប់ធម្មទេសនារហូតរាត្រី ការជួបជុំរបស់មហាជន នឹងអន្តរាយរមែងមាន ក៏នឹងមានដោយប្រការដូចពោលហើយនោះឯង ។ ទីដូចពោលមកនេះ ជាអសប្បាយ តែជាសប្បាយបាន ព្រោះមិនមានអន្តរាយ ក្នុងការឃើញព្រះថេរៈទាំងឡាយដែលមានបរិស័ទច្រើន ក៏មានន័យនេះដូចគ្នា ។ សូម្បីការឃើញអសុភារម្មណ៍ ក៏ឈ្មោះថា មានប្រយោជន៍ ។ មានរឿងដូច្នេះ ជាការសម្តែងអត្ថនោះ ។

# រឿង ភិក្ខុកំលោះ

បានឮមកថា ភិក្ខុកំលោះមួយរូប នាំសាមណេរទៅរកឈើស្ងួន សាមណេរចៀងចេញអំពីផ្លូវ ដើរខាងមុខទៅ ឃើញអសុភារម្មណ៍ ហើយញ៉ាំងបឋមជ្ឈានឲ្យកើតឡើង ធ្វើបឋមជ្ឈាននោះឯងឲ្យជាបាទ ពិចារណាសង្ខារធ្វើផលទាំង ៣ ឲ្យជាក់ច្បាស់ហើយ បានឈរកំណត់កម្មដ្ឋាន ដើម្បីផលប្រយោជន៍ដល់មគ្គខាងលើ ។ ភិក្ខុកំលោះ កាលមិនឃើញសាមណេរនោះទើបស្រែកហៅថា សាមណេរ ។ សាមណេរនោះគិតថា តាំងអំពីបួសហើយអញមិនធ្លាប់ឲ្យភិក្ខុហៅដល់ ២ ដងឡើយ អញនឹងឲ្យគុណវិសេសខាងលើកើតឡើងក្នុងថ្ងៃដទៃចុះ ដូច្នេះហើយ ទើបឲ្យពាក្យឆ្លើយថា ករុណាលោកម្ចាស់ សាមណេរនោះដែលភិក្ខុកំលោះប្រាប់ថា មកចុះសាមណេរ ត្រឹមមួយមាត់ប៉ុណ្ណោះក៏មក ហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់និមន្តទៅតាមផ្លូវនេះសិន ហើយឈរបែរមុខទៅទិសខាងកើតមួយសន្ទុះ ក្នុងឱកាសដែលខ្ញុំឈរ ។ លោកបានធ្វើតាមនោះ ហើយបានសម្រេចគុណវិសេសដែលសាមណេរនោះបានសម្រេចហើយ ។ អសុភារម្មណ៍មួយ បានកើតប្រយោជន៍ដល់ជន ២ នាក់ ដូចពណ៌នាមកនេះ ។

អសុភារម្មណ៍នេះ មានប្រយោជន៍ដូចពណ៌នាមកនេះ តែអសុភារម្មណ៍គឺស្រី ជាអសប្បាយរបស់បុរស និងអសុភារម្មណ៍ គឺបុរស ជាអសប្បាយរបស់ស្ត្រី ។ អសុភារម្មណ៍ដែលជាសភាគគ្នាប៉ុណ្ណោះ ទើបជាសប្បាយព្រោះដូច្នោះ ការកំណត់សប្បាយប៉ុណ្ណោះ ឈ្មោះថា **សប្បាយសម្បជញ្ញ ។**

តែការរៀនយកគោចរ ពោល គឺកម្មដ្ឋាន ដែលជាទីពេញចិត្តរបស់ខ្លួន

ក្នុងចំនួនកម្មដ្ឋានទាំង ៣៨ ប្រការ ហើយទទួលយកកម្មដ្ឋាននោះ ដើរទៅក្នុងទីគោចរ ដើម្បីកិច្ចាចារ ឈ្មោះថា **គោចរសម្បជញ្ញ** សម្រាប់បុគ្គលមានសប្បាយ មានប្រយោជន៍ដែលកំណត់ហើយយ៉ាងនេះ ។

ដើម្បីឲ្យជាក់ច្បាស់នៃគោចរសម្បជញ្ញៈនោះ អ្នកសិក្សាគួរជ្រាប សម្បជញ្ញៈ ៤ ពួក ដូចតទៅនេះ គឺ ភិក្ខុរូបខ្លះក្នុងសាសនានេះ នាំទៅមិននាំមក មិននាំទៅនាំមក រូបខ្លះមិននាំទៅមិននាំមក ភិក្ខុរូបខ្លះ នាំទៅផងនាំមកផង ។

បណ្ដាភិក្ខុទាំង ៤ រូបនោះ ភិក្ខុរូបណាជម្រះចិត្តឲ្យផូរផង់ចាកនីវរណធម៌ ដោយការចង្រ្កម ដោយការអង្គុយអស់មួយថ្ងៃ រហូតបឋមយាមនៃរាត្រី ក៏ដូច្នោះ ក្នុងមជ្ឈិមយាមសិង ក្នុងបច្ឆិមយាមក៏ឲ្យវេលាកន្លងទៅ ដោយការអង្គុយ ការចង្រ្កម នឹងពេលទៅថ្ងៃដល់ធ្វើវត្តត្រង់លានព្រះចេតិយ លានពោធិព្រឹក្ស និងស្រោចពោធិព្រឹក្ស តាំងទឹកផឹក ទឹកប្រើប្រាស់ សមាទានបដិបត្តិវត្ត ក្នុងគម្ពីរខន្ធកៈគ្រប់យ៉ាង មានអាចរិយវត្ត និងឧបជ្ឈាយវត្តជាដើម លោកនាំធុរៈទាក់ទងនឹងរាងកាយហើយ ចូលទៅកាន់ទីអង្គុយ ទីដេក និងអង្គុយពត់ក្អែន ២-៣ ឥរិយាបថ ល្មមឲ្យកក់ក្ដៅហើយ បដិបត្តិកម្មដ្ឋានក្រោកឡើងក្នុងពេលកិច្ចាចារ កាន់យកបាត្រ និងចីវរចេញទៅអំពីសេនាសនៈ មនសិការកម្មដ្ឋាន ដោយមាតិកាកម្មដ្ឋាននោះឯង ដើរទៅកាន់លានចេតិយ ហើយ បើមានកម្មដ្ឋាន មានពុទ្ធានុស្សតិជាអារម្មណ៍សោត ក៏មិនបោះបង់កម្មដ្ឋាននោះចោល ចូលទៅកាន់លានព្រះចេតិយ ។ បើមានកម្មដ្ឋានដទៃសោត គួរផ្អាកកម្មដ្ឋាននោះសិន ដូចយកដៃចាប់វត្ថុត្រង់ជើងជណ្ដើរ ហើយ

កំណត់បីតិ មានព្រះពុទ្ធជាអារម្មណ៍ ឡើងទៅកាន់លានព្រះចេតិយ បើលានព្រះចេតិយធំ គួរធ្វើប្រទក្សិណ ៣ ជុំ ហើយថ្វាយបង្គំទាំង ៤ ទិស បើលានព្រះចេតិយតូច គួរធ្វើប្រទក្សិណយ៉ាងនោះដូចគ្នា ហើយថ្វាយបង្គំទាំង ៨ ទិស កាលថ្វាយបង្គំចេតិយស្រេចហើយ ទៅដល់លានពោធិព្រឹក្សហើយ គួរវន្ទាពោធិព្រឹក្ស សម្តែងការកោតក្រែង ដូចនៅចំពោះព្រះភក្ត្រព្រះមានព្រះភាគ ។ ថ្វាយបង្គំព្រះចេតិយ និងដើមពោធិ៍យ៉ាងនេះហើយ ទៅកាន់ទីដែលខ្លួនដាក់កម្មដ្ឋាន ទទួលយកកម្មដ្ឋានដែលដាក់ ដូចគ្នានឹងយកដៃចាប់យកវត្ថុដែលខ្លួនរក្សាទុក ដូច្នោះហើយ ដណ្តប់ចីវរក្នុងទីជិតស្រុក ដោយមានកម្មដ្ឋានសញ្ញានោះឯង ចូលទៅដើម្បីបិណ្ឌបាត ។

កាលមនុស្សទាំងឡាយឃើញលោកហើយ ប្រាប់គ្នាថា លោកម្ចាស់របស់ពួកយើងមកហើយ នាំគ្នាទទួលលោក ទទួលយកបាត្រហើយ ឲ្យអង្គុយលើរោងឆាន់ ឬលើផ្ទះ ប្រគេនបបរ លាងជើង លាបដោយប្រេង រហូតស្រេចភត្តកិច្ច នាំគ្នាអង្គុយខាងមុខ ខ្លះក៏សួរបញ្ហា ខ្លះក៏ត្រូវការស្តាប់ធម៌ ។ តែបើបុគ្គលទាំងនោះឲ្យពោលធម្មកថា ព្រះអដ្ឋកថាចារ្យពោលថា ដែលឈ្មោះថា ធម្មកថាគួរសម្តែងនោះឯង ដើម្បីអនុគ្រោះមហាជន ។ ព្រោះឈ្មោះថាធម្មកថាដទៃទៅអំពីកម្មដ្ឋាន មិនមាន ព្រោះដូច្នោះ កាលលោកសម្តែងធម៌ដោយមានកម្មដ្ឋានសញ្ញានោះឯង ឆាន់អាហារដោយមានកម្មដ្ឋានសញ្ញានោះឯង ធ្វើអនុមោទនាហើយ កាលទាយកឲ្យត្រឡប់ ក៏ឲ្យតាមបុគ្គលចូលទៅហើយ ត្រឡប់ក្នុងទីនោះឯង ហើយទើបធ្វើដំណើរតទៅ ។ កាលសាមណេរ

និងភិក្ខុកំលោះចេញទៅមុន ធាន់ស្រេចហើយ ឃើញលោក ទើបនាំគ្នាទៅទទួលយកបាត្រ និងចីវររបស់លោក ។

បានឮថា ភិក្ខុជាថេរៈមើលមុខឃើញថា មិនមែនឧបជ្ឈាយាចារ្យរបស់ខ្លួនហើយ ធ្វើអាគន្តុកវត្ត តែធ្វើតាមកំណត់ដែលមកជួបគ្នាប៉ុណ្ណោះ ។ ភិក្ខុទាំងនោះសួរលោកថា បុគ្គលនេះ ជាអ្វីនឹងលោកម្ចាស់ ទាក់ទងគ្នាខាងខ្សែស្រឡាយញោមស្រី ឬខាងញោមប្រុស លោកក៏ឆ្លើយថា ពួកលោកម្ចាស់ឃើញអ្វី ទើបសួរ សាមណេរ និងភិក្ខុកំលោះទាំងនោះប្រាប់ថា មនុស្សទាំងនេះ មានការស្រឡាញ់ ការរាប់អានច្រើន ក្នុងលោកម្ចាស់ ។

ព្រះថេរៈឆ្លើយថា នែលោកម្ចាស់ វត្ថុណាដែលញោមស្រី ញោមប្រុសរបស់ខ្ញុំធ្វើបានលំបាក បុគ្គលទាំងនោះ ធ្វើវត្ថុនោះឲ្យខ្ញុំ សូម្បីបាត្រ និងចីវររបស់ខ្ញុំ ក៏ជារបស់ជនទាំងនោះប្រគេនដូចគ្នា ដោយអានុភាពរបស់បុគ្គលទាំងនោះ កាលមានភ័យ ខ្ញុំក៏មិនស្គាល់ភ័យឡើយ កាលមានការឃ្លាន ខ្ញុំក៏មិនស្គាល់ឃ្លានឡើយ ឈ្មោះថា ពួកជនអ្នកមានឧបការៈដល់ខ្ញុំយ៉ាងនេះមិនមាន លោកពោលដល់គុណរបស់ជនទាំងនោះយ៉ាងនេះដើរទៅ ភិក្ខុនេះលោកហៅថា នាំទៅ មិននាំត្រឡប់ ។

តែនឹងពោលថ្វី កាលភិក្ខុណា ធ្វើវត្តបដិបត្តិ មានប្រការដូចពោលមកហើយ តេជះដែលកើតអំពីកម្មនឹងសម្តែងចេញ នឹងលែងចោលអនុបាទិន្នកសង្ខារ ទាញយកឧបាទិន្នកសង្ខារ ញើសក៏ហូរចេញអំពីរាងកាយ មិនឡើងកាន់វិថីរបស់កម្មដ្ឋាន ។ នឹងពោលទៅថ្វីដល់ភិក្ខុនោះ ទោះបីកាន់យកបាត្រ

និងចីវរស្រួតទៅថ្វាយបង្គំព្រះចេតិយ ចូលស្រុកដើម្បីបបរ និងបាយ ក្នុងវេលាដែលគោទាំងឡាយចេញទៅរកស៊ីនោះឯង បានបបរហើយ ទៅកាន់អាសនៈសាលា ហើយឆាន់ ។ ខាងក្រោយ ដោយហេតុត្រឹមតែការឆាន់បបរ ២-៣ គ្រួករបស់លោកប៉ុណ្ណោះ តេជះ គឺការក្តៅដែលកើតអំពីកម្ម នឹងលែងឧបាទិន្នកសង្ខារ ទាញយកអនុបាទិន្នកសង្ខារ ។ លោកនឹងរំលត់សេចក្តីក្រវល់ក្រវាយដែលកើតអំពីតេជោធាតុ ដូចងូតទឹក ១០០ ក្អម ឆាន់បបរដោយមានកម្មដ្ឋានសញ្ញា លាងបាត្រខ្ទរមាត់ហើយ មនសិការកម្មដ្ឋាន ក្នុងចន្លោះកត្ត ត្រាច់ទៅបិណ្ឌបាត ក្នុងទីដ៏សេស ឆាន់អាហារដោយមានកម្មដ្ឋាន-សញ្ញា តាំងអំពីនោះទៅ ទទួលយកកម្មដ្ឋាន ដែលប្រាកដឡើងជាប់តគ្នាទៅហើយដើរទៅ ភិក្ខុនេះ ឈ្មោះថា មិននាំទៅ តែនាំត្រឡប់ ។ ដែលឈ្មោះថាភិក្ខុទាំងឡាយឆាន់បបរ ប្រារព្ធវិបស្សនា ហើយសម្រេចអរហត្តក្នុងព្រះពុទ្ធ-សាសនាយ៉ាងនេះ រាប់ចំនួនមិនអស់ ។ ក្នុងកោះសីហឡនោះឯង លើអាសនៈសាលា អាសនៈសម្រាប់គង់ឆាន់បបរក៏មិនមាន ភិក្ខុដែលឆាន់បបរហើយ សម្រេចអរហត្តក៏មិនមាន ។ តែភិក្ខុណា ជាអ្នកនៅដោយសេចក្តីប្រមាទជាប្រក្រតី ដាក់ចុះនូវធុរៈ ទម្លាយវត្តគ្រប់យ៉ាង មានចិត្តជាប់ជំពាក់នឹងចេតោខីលធម៌ ៥ ប្រការ មិនធ្វើសញ្ញាថា ដែលឈ្មោះថាកម្មដ្ឋាន មានចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ច្រឡូកច្រឡំដោយពួកគ្រហស្ថ ដែលមិនសមគួរ ឆាន់ហើយ មានបាត្រទទេចេញទៅ ភិក្ខុនេះ ហៅថា មិននាំទៅមិននាំត្រឡប់ ។

ឯភិក្ខុណា ដែលលោកពោលថា នាំទៅផង នាំត្រឡប់ផង ភិក្ខុនោះ គប្បីជ្រាបបានដោយគតបច្ចាគតិវត្ត របស់បុគ្គលដើរត្រឡប់ទៅត្រឡប់មក ។ ព្រោះថា កុលបុត្រទាំងឡាយដែលប្រាថ្នាប្រយោជន៍ បួសក្នុងសាសនាហើយ កាលនៅដោយទំនើង ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៥០ ឆ្នាំខ្លះ ១០០ ឆ្នាំខ្លះ នៅដោយធ្វើកតិកាវត្តគ្នាថា នៃលោកម្ចាស់ លោកទាំងឡាយ មិនមែនបួសព្រោះជំពាក់បំណុល មិនមែនបួសព្រោះភ័យ មិនមែនបួសចិញ្ចឹមជីវិត តែបំណងនឹងផុតចាកទុក្ខ ទើបបួសក្នុងសាសនានេះ ព្រោះដូច្នោះ ក្នុងខណៈដើរនោះឯង លោកម្ចាស់ទាំងឡាយ ចូរដើរសង្កត់កិលេសដែលកើតឡើង ក្នុងវេលាដើរ ក្នុងខណៈឈរ ក៏សង្កត់កិលេសដែលកើតឡើង ក្នុងវេលាឈរ ក្នុងខណៈអង្គុយ ក៏ចូរសង្កត់កិលេសដែលកើតឡើង ក្នុងវេលាអង្គុយ ក្នុងខណៈដេកនោះឯង ក៏ចូរសង្កត់កិលេសដែលកើតឡើង ក្នុងវេលាដេក ។ ភិក្ខុទាំងនោះ កាលធ្វើកតិកាវត្តយ៉ាងនេះហើយ កាលទៅបិណ្ឌបាត ក៏ដើរទៅ មនសិការកម្មដ្ឋានទៅតាមសញ្ញានោះ បើកិលេសកើតឡើងក្នុងបុគ្គលណា ក្នុងខណៈដើរ ក្នុងរវាងកន្លះឧសភៈ មួយឧសភៈ កន្លះគាវុត ឬមួយគាវុត មានដុំថ្ម ភិក្ខុនោះ នឹងសង្កត់កិលេសនោះក្នុងទីនោះឯង កាលមិនអាចសង្កត់បានយ៉ាងនោះ ក៏ឈប់ឈរ ។ បន្ទាប់អំពីនោះ ភិក្ខុរូបដទៃ ដើរតាមក្រោយលោកមក ក៏ឈប់ឈរតាមលោក ដាស់តឿនខ្លួនឯងថា ភិក្ខុនេះ ដឹងវិតក្កដែលកើតដល់អញហើយ សេចក្ដីនេះមិនសមគួរដល់អញ ហើយចម្រើនវិបស្សនា ឈានចុះកាន់អរិយភូមិក្នុងទីនោះឯង ក្នុងពាក្យថា កាលមិនអាច

យ៉ាងនោះ លោកក៏អង្គុយ បន្ទាប់អំពីនោះ ភិក្ខុដែលមកឯក្រោយលោក ក៏អង្គុយតាម ក៏មានន័យដូចគ្នា ។ សូម្បីមិនអាចឈានចុះកាន់អរិយភូមិបាន ក៏នឹងសង្កត់កិលេសនោះ ដើរមនសិការកម្មដ្ឋាននោះឯង មិនលើកជើងឡើងទាំងដែលមានចិត្តប្រាសចាកកម្មដ្ឋាន បើលើកក៏នឹងត្រឡប់ទៅកាន់ទីដើមនោះឯង ដូចមហាបុស្សទេវត្ថេរអ្នកដែនអាលិន្ទក ដូច្នោះ ។

# រឿង ព្រះមហាបុស្សទេវត្ថេរ

បានឮមកថា លោកបានបំពេញគតបច្ចាគតិកវត្ត គឺវត្តរបស់អ្នកដើរត្រឡប់ទៅត្រឡប់មកនោះឯង អស់វេលា ១៩ ឆ្នាំ បានឮថា មនុស្សទាំង-ឡាយកំពុងភ្ជួរ កំពុងសាបព្រោះ កំពុងគក់ កំពុងធ្វើការ ឃើញព្រះថេរៈដើរយ៉ាងនោះ ទើបសន្ទនាគ្នាថា ព្រះថេរៈរូបនេះ ដើរត្រឡប់ទៅត្រឡប់មកប្រហែលវង្វេងផ្លូវ ឬបើមិនដូច្នោះ ក៏គង់ភ្លេចអ្វីទេដឹង លោកមិនពិចារណាដល់ពាក្យសម្តីនោះ ធ្វើសមណធម៌ទាំងចិត្តប្រកបដោយកម្មដ្ឋាននោះឯង បានសម្រេចអរហត្តក្នុងវស្សាទី ២០ ។ ក្នុងថ្ងៃដែលលោកបានសម្រេចអរហត្តនោះឯង ទេវតាដែលស្ថិតនៅខាងចុងផ្លូវចង្ក្រមរបស់លោក បានឈរធ្វើប្រាមដៃជំនួសប្រទីប សូម្បីមហារាជទាំង ៤ សក្កទេវរាជ និងសហម្បតីព្រហ្មក៏បាននាំគ្នាមកកាន់ទីធ្វើការទំនុកបម្រុងលោក ។ ព្រះវនវាសីតិស្សមហាថេរៈឃើញពន្លឺនោះហើយ ក្នុងថ្ងៃទី ២ ទើបបានសួរព្រះមហាបុស្សទេវត្ថេរអ្នកដែនអាលិន្ទកថា កាលពីកណ្តាលយប់ ត្រង់សម្នាក់របស់លោកម្ចាស់ មានពន្លឺៗ នោះជាពន្លឺអ្វីហ្ន៎ ព្រះថេរៈកាលធ្វើការបន្ទប់ ទើបពោលពាក្យជាដើម

យ៉ាងនេះថា ធម្មតាពន្លឺ គង់ជាពន្លឺរបស់ប្រទីបខ្លះ ជាពន្លឺរបស់កែវមណីខ្លះ ។ តមក លោកឲ្យព្រះវនវាសីតិស្សត្ថេរសន្យាដើម្បីបិទបាំង លុះលោកទទួលពាក្យហើយ ទើបប្រាប់ ។ នឹងដូចព្រះមហានាគត្ថេរ អ្នកកាលវល្លិមណ្ឌប ដូច្នោះ ។

## រឿង ព្រះមហានាគត្ថេរ

បានឮថា ព្រះថេរៈរូបនោះ កាលបំពេញគតបច្ចាគតិកវត្ត បានអធិដ្ឋានចង្ក្រមតែម្យ៉ាង អស់កាល ៧ ឆ្នាំថា អញនឹងបូជាសេចក្តីព្យាយាមដ៏ធំរបស់ព្រះមានព្រះភាគជាបឋម បានបំពេញគតបច្ចាគតិកវត្ត ១៦ ឆ្នាំទៀត ទើបសម្រេចអរហត្ត លោកមានចិត្តប្រកបដោយកម្មដ្ឋាននោះឯង លើកជើងជយត្រឡប់ ក្នុងខណៈលើកជើងឡើងដោយប្រាសចាកកម្មដ្ឋាន ដើរទៅជិតស្រុកឈរយំចីវរក្នុងទីដែលនាំឲ្យមនុស្សស្រង្ស័យថា មេគោ ឬភិក្ខុហ្ន៎ ប្រើទឹកអំពីរវាងដើមជ្រៃលាងបាត្រ ហើយក៏បៀមទឹក ។ ព្រោះហេតុអ្វី ព្រោះលោកគិតថា សូមអាត្មាអញកុំបោះបង់កម្មដ្ឋាន ទោះដោយហេតុដែលពោលនឹងមនុស្សដែលប្រគេនភិក្ខា ឬមនសិការថា ចូរមានអាយុវែងចុះ ។ តែបើសួរដល់ថ្ងៃថា ថ្ងៃនេះជាថ្ងៃអ្វីលោកម្ចាស់ ឬសួរចំនួនភិក្ខុ សួរបញ្ហា ក៏ខ្ជាក់ទឹកចោលហើយ ទើបប្រាប់ បើមិនមានអ្នកសួរដល់ថ្ងៃជាដើម ពេលចេញទៅ ក៏ខ្ជាក់ទឹកចេញត្រង់ទ្វារស្រុកហើយ ទើបទៅ ដូចគ្នានឹងភិក្ខុ ៥០ រូបដែលចាំវស្សាត្រង់កលម្ពតិត្ថវិហារ ដូច្នោះ ។

# រឿងភិក្ខុ ៥០ រូប

បានឮថា ក្នុងអាសាឡ្ហបុណ្ណមី គឺថ្ងៃ ១៥ កើត ខែអាសាឍ ព្រះថេរៈទាំងនោះបានធ្វើកតិកាវត្តថា បើពួកយើងមិនទាន់សម្រេចអរហត្តហើយ នឹងមិននិយាយគ្នា ។ កាលចូលទៅបិណ្ឌបាត គ្រប់អង្គក៏បៀមទឹក ហើយទើបចូលទៅ កាលត្រូវសួរដល់ថ្ងៃជាដើម ក៏បដិបត្តិដូចដែលពោលមកហើយនោះឯង ។ មនុស្សទាំងឡាយ ឃើញស្នាមខ្ពុរទឹកក្នុងទីនោះហើយ ក៏ដឹងថាថ្ងៃនេះមានភិក្ខុមកមួយរូប ថ្ងៃនេះមកពីររូប ទើបគិតគ្នាយ៉ាងនេះថា លោកម្ចាស់ទាំងនេះមិននិយាយចំពោះជាមួយយើង ឬដូចម្ដេចហ្ន៎ ឬសូម្បីតែពួកគ្នាឯង ក៏មិនពោល បើលោកមិននិយាយគ្នា លោកនឹងវិវាទគ្នាដោយពិតណ្ហើយចុះ ពួកយើងនឹងឲ្យលោកសូមខមាទោសគ្នា ទើបនាំគ្នាទៅវត្ត មិនបានឃើញភិក្ខុក្នុងទីមួយ ២ រូប ក្នុងចំនួន ៥០ រូប ។ បន្ទាប់មក បណ្ដាមនុស្សទាំងឡាយនោះ អ្នកមានភ្នែកល្អក៏ពោលថា បាអើយ មនុស្សឈ្លោះគ្នាមិនមានឱកាសដូច្នេះ លានព្រះចេតិយ លានព្រះពោធិព្រឹក្ស ក៏បោសស្អាតរៀបរយ អំបោសក៏ទុកដាក់បានល្អ ទឹកឆាន់ ទឹកប្រើប្រាស់ក៏ទុកដាក់រៀបរយ ។ បន្ទាប់អំពីនោះ អ្នកស្រុកទាំងនោះក៏នាំគ្នាត្រឡប់ ។ ខាងក្នុងវស្សានោះឯង ភិក្ខុទាំងនោះ ក៏សម្រេចអរហត្តក្នុងថ្ងៃមហាបវារណា ទើបបវារណាដោយវិសុទ្ធិបវារណា ។

ភិក្ខុមានចិត្តប្រកបដោយកម្មដ្ឋាននោះឯង លើកឡើងនូវជើងដើរទៅ ដល់ជិតស្រុកហើយ បៀមទឹក ពិចារណាមើលផ្លូវច្រើនខែ្ស ក៏មិនមានអ្នកឈ្លោះគ្នា មិនមានអ្នកលេងសុរា និងអ្នកលេងល្បែងភ្នាល់ជាដើម ឬមិនមានដំរីកាច

សេះកាចជាដើម ហើយដើរទៅផ្លូវនោះ ដូចព្រះមហានាគត្ថេរ អ្នកដែនកាល-វល្លិមណ្ឌប និងដូចភិក្ខុដែលចាំវស្សាក្នុងកលម្ពតិត្ថវិហារដូចពណ៌នាមកនេះ ។ កាលលោកទៅបិណ្ឌបាតក្នុងស្រុកនោះ ក៏មិនដើលឿន ដូចអ្នកប្រញាប់ប្រញាល់ ព្រោះថា មិនមានធុតង្គណាមួយ ដែលមានឈ្មោះថា ធុតង្គសម្រាប់អ្នកដើរបិណ្ឌបាតរហ័សឡើយ ។ តែដើរមិនគ្រលែងកាយ ដូចរទេះដឹកទឹកពេញ ទៅដល់ទីរាបស្មើ ។ ហើយចូលទៅតាមលំដាប់ផ្ទះ ឈររង់ចាំវេលាសមគួរ ដើម្បីសង្កេតមើលថា ទាយកបំណងនឹងប្រគេន ឬមិនបំណងប្រគេន ទទួលភិក្ខាហើយ នៅក្នុងស្រុក ឬក្រៅស្រុក ឬមកកាន់វិហារនោះឯង អង្គុយក្នុងឱកាសដែលសមគួរតាមសប្បាយ ហើយមនសិការកម្មដ្ឋានកំណត់បដិកូលសញ្ញាក្នុងអាហារ ពិចារណាដោយប្រៀបធៀបនឹងប្រេងបន្តក់ភ្លៅរទេះ សំពត់រុំដំបៅ និងសាច់កូន នាំអាហារដែលប្រកបដោយអង្គ ៨ មក មិនមែនឆាន់ដើម្បីលេង មិនមែនឆាន់ដើម្បីស្រិតស្អាងរាងកាយ មិនមែនឆាន់ដើម្បីឲ្យកើតបុរិសមានះស្រវឹង ឆាន់ហើយ រៀបចំទឹកសម្រាប់ផឹក ទឹកសម្រាប់លាងស្រេចហើយ រម្ងាប់សេចក្តីលំបាកដែលកើតអំពីអាហារមួយស្របក់ ហើយទើបមនសិការកម្មដ្ឋាននោះឯង ក្នុងវេលាក្រោយឆាន់ ដូចគ្នានឹងវេលាមុនឆាន់ និងក្នុងវេលាបច្ឆិមយាម ដូចគ្នានឹងវេលាបឋមយាម ភិក្ខុរូបនេះហៅបានថា នាំទៅផង នាំត្រឡប់ផង ។

កាលលោកបំពេញគតបច្ចាគតិកវត្ត ពោល គឺការនាំទៅ និងនាំមកនេះ បើមានឧបនិស្ស័យបរិបូណ៌សោត ក៏នឹងសម្រេចអរហត្តក្នុងបឋមយាមនោះ

ឯង បើមិនសម្រេចក្នុងបឋមយាម ក៏នឹងសម្រេចក្នុងមជ្ឈិមយាម បើក្នុងមជ្ឈិមយាមមិនសម្រេចសោត តទៅក៏នឹងសម្រេចក្នុងមរណសម័យ បើក្នុងមរណសម័យមិនសម្រេចសោត តទៅក៏ជាទេវបុត្រ ហើយសម្រេច បើជាទេវបុត្រហើយក៏មិនទាន់សម្រេចសោត កាលព្រះពុទ្ធមិនទាន់កើតឡើង នឹងកើតឡើង ហើយធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ បើមិនធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណសោត តទៅនឹងជាអ្នកត្រាស់ដឹងរហ័ស គឺខិប្បាភិញ្ញាបុគ្គលចំពោះព្រះភក្ត្រនៃព្រះពុទ្ធទាំងឡាយ ដូចគ្នានឹងព្រះពាហិយទារុចីរិយត្ថេរ នឹងមានបញ្ញាច្រើន ដូចព្រះសារីបុត្តត្ថេរ នឹងមានឫទ្ធិច្រើនដូចព្រះមោគ្គល្លានត្ថេរ នឹងជាអ្នកបង្រៀនធុតង្គដូចព្រះមហាកស្សបត្ថេរ នឹងជាអ្នកមានទិព្វចក្ខុដូចព្រះអនុរុទ្ធត្ថេរ នឹងជាព្រះវិនយធរដូចព្រះឧបាលិត្ថេរ នឹងជាព្រះធម្មកថិកដូចព្រះបុណ្ណមន្តានីបុត្តត្ថេរ នឹងជាអ្នកនៅព្រៃជាប្រចាំ ដូចព្រះរេវតត្ថេរ នឹងជាពហុស្សូត ដូចព្រះអានន្ទត្ថេរ ឬនឹងជាអ្នកស្រឡាញ់ក្នុងការសិក្សាដូចព្រះរាហុលត្ថេរពុទ្ធបុត្រ ដូច្នេះ ។

ភិក្ខុអ្នកនាំទៅ និងនាំត្រឡប់ក្នុង ៤ វារៈនេះ នឹងមានគោចរសម្បជញ្ញៈដល់កំពូល គឺវិបស្សនា ដោយប្រការដូចពណ៌នាមកនេះ ។

ឯការមិនវង្វេង ក្នុងការឈានទៅខាងមុខជាដើម ឈ្មោះថា អសម្មោហសម្បជញ្ញៈ អសម្មោហសម្បជញ្ញៈនោះគប្បីជ្រាបយ៉ាងនេះ ។ ភិក្ខុទៅក្នុងសាសនានេះ កាលឈានទៅខាងមុខ ឬឈានថយក្រោយ ក៏មិនភ្លេច ដូចអន្ធបុថុជ្ជនថា អត្តាឈានទៅខាងមុខ អត្តាឲ្យកើតការឈានទៅខាងមុខ ឬ

ថា អញឈានទៅខាងមុខ អញឲ្យកើតការឈានទៅខាងមុខ ក្នុងការឈានទៅខាងមុខជាដើម កាលកើតការគិតឡើងថា អញនឹងមានស្មារតីឈានទៅខាងមុខ វាយោធាតុដែលមានចិត្តជាសមុដ្ឋាន កាលឲ្យកើតវិញ្ញត្តិឡើង នឹងកើតឡើងជាមួយចិត្តដួងនោះឯង ។ គ្រោងឆ្អឹងដែលសន្មតថា កាយនេះ នឹងឈានទៅខាងមុខតាមអំណាចនៃការផ្សាយ នៃវាយោធាតុដែលកើតអំពីកិរិយារបស់ចិត្ត ដោយប្រការយ៉ាងនេះ កាលគ្រោងឆ្អឹងនោះឯង ឈានទៅខាងមុខ ក្នុងការលើកជើងមួយឡើង ធាតុ ២ គឺបឋវីធាតុ និងអាបោធាតុថយចុះ ។ ធាតុ ២ យ៉ាងទៀតក្រៅអំពីនេះ នឹងមានកម្លាំងខ្លាំងឡើង ។ ក្នុងការឈានជើងទៅ និងការបោះជើងទៅមុខ តេជោធាតុ វាយោធាតុ ដែលប្រព្រឹត្តទៅហើយក្នុងការផ្លាស់ជើងចេញទៅ និងថយចុះ និងខ្សោយចុះ ធាតុ ២ យ៉ាងក្រៅអំពីនេះ គឺបឋវី និងអាបោ មានកម្លាំងខ្លាំងឡើង ។ ក្នុងការជាន់ និងការជាន់សឹប រូបធម៌ និងអរូបធម៌ ដែលប្រើក្នុងការលើកជើងឡើងនោះ ក៏ដូច្នោះ មិនដល់នូវការឈានទៅ ដែលប្រើក្នុងការឈានទៅក៏ទំនងដូចគ្នា មិនដល់ការផ្លាស់ជើងទៅ ដែលប្រើក្នុងការផ្លាស់ជើងទៅ ក៏មិនដល់ការដាក់ចុះ ដែលប្រើក្នុងការដាក់ជើងចុះ ក៏មិនដល់ការជាន់ ដែលប្រើក្នុងការជាន់ ក៏មិនដល់ការជាន់សឹប ។ សេចក្តីគ្រប់ប្រការ និងទី-តគ្រប់កន្លែង ប្រព្រឹត្តទៅតាមការប្រារព្ធក្នុងទីនោះឯង និងលាន់ប្រេះៗ ដូចគ្រាប់ល្ងដែលបោះចូលក្នុងខ្ទះក្តៅ ដូច្នោះ ក្នុងរឿងនោះ មិនមានបុគ្គលណាឈានទៅ ឬមិនមានការឈានទៅរបស់បុគ្គលណាមួយឡើយ ។ សេចក្តីពិតពោលដោយបរមត្ថហើយ

គឺការដើររបស់ធាតុប៉ុណ្ណោះ ការឈរ ការអង្គុយ ការដេក ក៏របស់ធាតុប៉ុណ្ណោះ មិនមែនរបស់បុគ្គលណាឡើយ ។

ព្រោះថា ក្នុងចំណែកនោះៗ ចិត្តដួងដទៃកើត ដួងដទៃរលត់ព្រមគ្នានឹងរូប គឺមិនមែនដួងជាមួយគ្នា ដូចខ្សែទឹកដែលហូរជាប់តទៅជារលក ដូច្នោះយ៉ាងនេះឯង ។

ការមិនវង្វេងក្នុងការឈានទៅខាងមុខជាដើមដូចពណ៌នាមកនេះ ឈ្មោះថា អសម្មោហសម្បជញ្ញៈ ដូច្នេះឯង ។ ចប់អត្ថាធិប្បាយពោលដោយបុគ្គលដែលធ្វើការដឹងខ្លួនក្នុងការឈានទៅខាងមុខ និងការឈានថយក្រោយ ។

ការក្រឡេកមើលទៅមុខ ឈ្មោះថា **អាលោកិត** ក្នុងពាក្យថា **អាលោកិតេ វិលោកិតេ** នេះ ការមើលទៅតាមអនុទិស ឈ្មោះថា **វិលោកិត** គឺការក្រឡេកមើលឆ្វេងស្តាំ មានឥរិយាបថដទៃទៀត ឈ្មោះថា ការឱនចុះ ការងើយឡើង ការបែរទៅមក ការមើលខាងក្រោម មើលខាងលើ មើលខាងៗ ឥរិយាបថទាំងនេះ ទ្រង់មិនកាន់យកក្នុងទីនេះ ។ តែដោយសេចក្តីសមគួរ ទ្រង់កាន់យក ២ យ៉ាងនេះប៉ុណ្ណោះ ឬដោយការសម្គាល់នេះ ទ្រង់កាន់យកទាំងអស់នោះឯង ដូច្នេះ ។

បណ្តាសម្បជញ្ញៈទាំងនោះ ការជញ្ជឹងដល់ប្រយោជន៍ មិនមើលដោយអំណាចនៃចិត្តប៉ុណ្ណោះ ក្នុងកាលកើតការគិតឡើងថា អញនឹងសម្លឹងមើល ឈ្មោះថា សាត្ថកសម្បជញ្ញៈ ។ សាត្ថកសម្បជញ្ញៈនោះ គួរជ្រាបដោយលើកយកព្រះនន្ទដែលមានកាយជាបន្ទាល់ សមដូចព្រះមានព្រះភាគបានត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ បើនទួភិក្ខុមិលមើលទៅទិសខាងកើត លុះតែប្រមូលនូវហេតុទាំងអស់ដោយចិត្ត ទើបនទួភិក្ខុមិលមើលនូវទិសខាងកើត ដោយគំនិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស នឹងមិនជាប់តាមអាត្មាអញ ដែលកំពុងរមិលមើលទិសខាងកើតយ៉ាងនេះ ។ ព្រោះហេតុនោះ ក្នុងសាសនានេះ ទើបនទួភិក្ខុ ឈ្មោះថា ជាអ្នកមានសេចក្ដីដឹងខ្លួនក្នុងការគ្រប់គ្រងទ្វារនោះ ។ ម្នាលភិក្ខុទាំងឡាយ បើនទួភិក្ខុរមិលមើលទិសខាងលិច រមិលមើលទិសខាងជើង រមិលមើលទិសខាងត្បូង ងើយមើលទៅទិសខាងលើ ឱនមើលទិសខាងក្រោម ងាកមើលទៅទិសជាលំដាប់ លុះតែប្រមូលនូវហេតុទាំងអស់ដោយចិត្ត ទើបនទួភិក្ខុងាកមើលនូវទិសជាលំដាប់ ដោយគំនិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស នឹងមិនជាប់តាមអាត្មាអញ ដែលកំពុងងាកមើលទិសជាលំដាប់ ។ ព្រោះហេតុនោះ ក្នុងសាសនានេះ ទើបនទួភិក្ខុ ឈ្មោះថា ជាអ្នកមានសេចក្ដីដឹងខ្លួន ក្នុងការគ្រប់គ្រងទ្វារយ៉ាងនេះ ។

ន័យម្យ៉ាងទៀត សូម្បីក្នុងសម្បជញ្ញបព្វៈនេះ គួរជ្រាបសាត្ថកសម្បជញ្ញៈ និងសប្បាយសម្បជញ្ញៈ ដោយការឃើញព្រះចេតិយ ដែលបានពោលមកហើយខាងដើមនោះចុះ ។

ឯការមិនលះកម្មដ្ឋាននោះឯង ឈ្មោះថា គោចរសម្បជញ្ញៈ ព្រោះដូច្នោះ បុគ្គលចម្រើនកម្មដ្ឋាន មានខន្ធ ធាតុ និងអាយតនៈជាអារម្មណ៍ គួរធ្វើការសម្លឹងមើលទៅមុខ និងសម្លឹងមើលឆ្វេងស្ដាំ ដោយអំណាចកម្មដ្ឋានរបស់ខ្លួន

ប៉ុណ្ណោះ ឬអ្នកចម្រើនកម្មដ្ឋាន មានកសិណជាអារម្មណ៍ជាដើម គួរធ្វើការមើលទៅមុខ និងក្រឡេកឆ្វេងស្តាំ ដោយអាការមានកម្មដ្ឋានសញ្ញាដូចគ្នា ។

ធម្មតាអត្តាខាងក្នុង ឈ្មោះថា ជាអ្នកសម្លឹងមើលទៅមុខ មើលឆ្វេងស្តាំ មិនមាន តែកាលកើតការគិតឡើងថា អញនឹងមើលទៅមុខ វាយោធាតុកើតអំពីចិត្ត កាលនឹងឲ្យវិញ្ញត្តិកើត ក៏នឹងកើតឡើងព្រមជាមួយចិត្តដូងនោះឯង ។

ដោយប្រការដូច្នេះ ត្របកភ្នែកខាងក្រោម ក៏ទាញទៅក្រោម ត្របកភ្នែកខាងលើក៏ទាញឡើងលើ ដោយអំណាចការផ្សាយនៃវាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត ។ មិនមានបុគ្គលណា ឈ្មោះថាបើកភ្នែកដោយគ្រឿងយន្តនោះឡើយ ។

បន្ទាប់អំពីនោះទៅ ចក្ខុវិញ្ញាណកើតឡើងឲ្យសម្រេចទស្សនកិច្ច ក៏ការដឹងខ្លួនដូចពណ៌នាមកនេះ ឈ្មោះថា **អសម្មោហសម្បជញ្ញ** ក្នុងអធិការនៃសម្បជញ្ញៈនេះ ។

ម្យ៉ាងទៀត ក្នុងរឿងសម្បជញ្ញៈនេះ គប្បីជ្រាបអសម្មោហសម្បជញ្ញៈដោយអំណាចមូលបរិញ្ញាជាអាគន្តុកៈ គឺជាភ្ញៀវ និងជាតាវកាលិក គឺប្រព្រឹត្តទៅមួងក្កាល ។ ជាបឋមគួរជ្រាបអសម្មោហសម្បជញ្ញៈ ដោយមូលបរិញ្ញា គឺការកំណត់មូលដូច្នេះ ភវង្គ ១ អាវជ្ជនៈ ១ ទស្សនៈ ១ សម្បដិច្ឆនៈ ១ សន្តីរណៈ ១ វោដ្ឋព្វនៈ ១ ទី ៧ គឺជវនៈ ១ ។

បណ្តាចិត្តទាំង ៧ នោះ ភវង្គឲ្យកិច្ច គឺជាហេតុនៃឧបបត្តិភពសម្រេចប្រព្រឹត្តទៅ ។ កិរិយាមនោធាតុកាលញុំាងភវង្គនោះឲ្យវិលត្រឡប់ហើយ នឹង

ឲ្យអាវជ្ជនកិច្ចសម្រេច ព្រោះអាវជ្ជនកិច្ចនោះរលត់ទៅ ចក្ខុវិញ្ញាណ នឹងឲ្យទស្សនកិច្ចសម្រេចប្រព្រឹត្តទៅ ព្រោះទស្សនកិច្ចនោះរលត់ទៅ វិបាកមនោធាតុនឹងឲ្យសម្បដិច្ឆន្នកិច្ចសម្រេចប្រព្រឹត្តទៅ ព្រោះសម្បដិច្ឆន្នកិច្ចនោះរលត់ទៅ មនោវិញ្ញាណធាតុដែលជាវិបាក នឹងឲ្យសន្តីរណកិច្ចសម្រេចប្រព្រឹត្តទៅ ព្រោះសន្តីរណកិច្ចនោះរលត់ទៅ មនោវិញ្ញាណធាតុដែលជាកិរិយា ឲ្យវោដ្ឋព្វនកិច្ចសម្រេចប្រព្រឹត្តទៅ ព្រោះវោដ្ឋព្វនកិច្ចនោះរលត់ទៅ ជវនស្ទុះទៅ ៧ ខណៈ បណ្តាជវនទាំង ៧ នោះ ទោះក្នុងជវនដំបូង ការមើលទៅមុខ ការក្រឡេកមើលឆ្វេងស្តាំដោយអំណាចនៃតម្រេក ការអាក់អន់ និងការវង្វេងថា នេះជាស្រី នេះជាប្រុស នឹងមិនមាន ក្នុងជវនទី ២ ក្តី ។បេ។ ក្នុងជវនទី ៧ ក្តី ក៏មិនមានដូចគ្នា ។ តែកាលវិថីចិត្តទាំងនេះបែកធ្លាយទៅហើយ ដោយអំណាចចិត្តដួងដំបូង រហូតដល់ចិត្តដួងចុងក្រោយ ដូចទាហានក្នុងរឿងចម្បាំង ការក្រឡេកមើលទៅមុខ និងការក្រឡេកមើលឆ្វេងស្តាំ ដោយអំណាចតម្រេកជាដើមថា នេះជាស្រី នេះជាប្រុស ក៏នឹងមាន ។ គប្បីជ្រាបសម្មោហសម្បជញ្ញៈ ដោយអំណាចជាមូលបរិញ្ញា ក្នុងឥរិយាបថបព្វៈនេះ ដូចពណ៌នាមកនេះប៉ុណ្ណោះ ។

កាលរូបប្រាកដក្នុងចក្ខុទ្វារហើយ បន្ទាប់អំពីភវង្គចលនៈទៅ កាលវិថីចិត្ត មានអាវជ្ជនៈជាដើមកើតឡើង ហើយរលត់ទៅដោយអំណាចធ្វើកិច្ចរបស់ខ្លួនឲ្យសម្រេចក្នុងទីបំផុត ជវនក៏កើតឡើង ជវននោះ ដូចជាបុរសដែលជាភ្ញៀវរបស់វិថីចិត្ត មានអាវជ្ជនៈជាដើមដែលកើតឡើងមុន ( មកសួរសុខទុក្ខ )

ទ្វារ គឺភ្នែក ដែលដូចគ្នានឹងផ្ទះ កាលវិថីចិត្ត មានអាវជ្ជនៈជាដើមមិនតម្រេក មិនអាក់អន់ មិនវង្វេងក្នុងចក្ខុទ្វារ ដែលដូចគ្នានឹងផ្ទះនៃអាវជ្ជនៈជាដើម ជវន នោះ ក៏មិនតម្រេក មិនអាក់អន់ មិនវង្វេងដែរ ដូចគ្នានឹងបុរសជាភ្ញៀវចូល ទៅសុំវត្ថុអ្វីមួយ ត្រង់ផ្ទះរបស់អ្នកដទៃ កាលម្ចាស់ផ្ទះអង្គុយស្ងៀម និងធ្វើ ការបង្គាប់ក៏មិនត្រឹមត្រូវ ដូច្នោះ គប្បីជ្រាបអសម្មោហសម្បជញ្ញៈ ដែលដូច ជាភ្ញៀវ ដូចពណ៌នាមកនេះ ។

ម្យ៉ាងទៀត ចិត្ត មានវោដ្ឋពនៈជាទីបំផុត ដែលកើតឡើងក្នុងចក្ខុទ្វារទាំង នេះ នឹងរលត់ទៅក្នុងទីនោះឯង ព្រមទាំងសម្បយុត្តធម៌ នឹងមិនជួបគ្នាឡើយ ព្រោះដូច្នោះ ទើបចិត្តក្រៅអំពីនេះប្រព្រឹត្តទៅមួយជួរខណៈប៉ុណ្ណោះ ។

ក្នុងសេចក្តីនោះ អ្នកសិក្សាគួរជ្រាបអសម្មោហសម្បជញ្ញៈ ដោយភាព ជារបស់មួយជួរខណៈយ៉ាងនេះថា ក្នុងផ្ទះមួយខ្នង កាលបុគ្គលស្លាប់អស់ ហើយ មនុស្សម្នាក់ដែលនៅសល់ ដែលធម្មតាក៏នឹងស្លាប់ទៅទៀតក្នុងកាល មិនយូរដូចគ្នា ឈ្មោះថា នៅមានការសប្បាយរីករាយ ក្នុងការច្រៀង និង ការរាំជាដើម ក៏មិនត្រឹមត្រូវ យ៉ាងណា កាលអាវជ្ជនចិត្តជាដើមដែលសម្ប- យុត្តក្នុងទ្វារជាមួយគ្នា រលត់ទៅក្នុងទីនោះឯង សូម្បីជវនចិត្តដែលនៅសល់ ក៏នឹងមានការបែកធ្លាយទៅជាធម្មតា ក្នុងកាលមិនយូរឡើយដូចគ្នា ឈ្មោះថា នៅមានការត្រេកអរដោយអំណាចតម្រេក ការអាក់អន់ និងការវង្វេងក៏មិន ត្រឹមត្រូវ ដូច្នោះដូចគ្នា ។

អើ ម្យ៉ាងទៀត គប្បីជ្រាបអសម្មោហសម្បជញ្ញៈនេះ ដោយការពិចា-

វណាខន្ធ ធាតុ អាយតនៈ និងបច្ច័យដូចតទៅនេះ

អធិប្បាយថា ក្នុងពាក្យថា ខន្ធជាដើមនេះ ចក្ខុក្ដី រូបក្ដី ឈ្មោះថា រូប-ក្ខន្ធ ការឃើញ ឈ្មោះថា វិញ្ញាណក្ខន្ធ ការសោយអារម្មណ៍ដែលសម្បយុត្ត ដោយវិញ្ញាណក្ខន្ធនោះ ឈ្មោះថា វេទនាខន្ធ ការចាំបាន ឈ្មោះថា សញ្ញា ខន្ធ ធម៌ មានផស្សៈជាដើម ឈ្មោះថា សង្ខារក្ខន្ធ ព្រោះខន្ធទាំងនេះ មក ប្រជុំគ្នា ការមើលទៅមុខ និងការក្រឡេកមើលឆ្វេងស្ដាំ ទើបប្រាកដ ។ កាលការមើលទៅមុខ និងការមើលឆ្វេងស្ដាំប្រាកដ ដោយអំណាចបញ្ចក្ខន្ធ នោះ តើនឹងមានបុគ្គលណាមួយ មកមើលទៅមុខ នឹងមានបុគ្គលណាមួយ ក្រឡេកមើលឆ្វេងស្ដាំនោះ ។

មួយប្រការទៀត ចក្ខុ ឈ្មោះថា ចក្ខាយតនៈ រូប ឈ្មោះថា រូបាយតនៈ ការឃើញ ឈ្មោះថា មនាយតនៈ សម្បយុត្តធម៌ទាំងឡាយ មានវេទនាជា ដើម ឈ្មោះថា ធម្មាយតនៈ ក្នុងអាយតនៈទាំង ៤ នោះ មកប្រជុំគ្នាយ៉ាង នេះឯង ទើបការមើលទៅមុខ និងការមើលឆ្វេងស្ដាំ ប្រាកដ ។ កាលការ មើលទៅមុខ និងការមើលឆ្វេងស្ដាំប្រាកដ ដោយអំណាចអាយតនៈ ៤ នោះ ហើយ នឹងមានបុគ្គលណាត្រឹមតែម្នាក់ មកមើលទៅមុខ នឹងមានបុគ្គលណា ម្នាក់មកមើលឆ្វេងស្ដាំនោះ ។ ម្យ៉ាងទៀត ចក្ខុ ឈ្មោះថា ចក្ខុធាតុ រូប ឈ្មោះថា រូបធាតុ ការឃើញ ឈ្មោះថា ចក្ខុវិញ្ញាណធាតុ វេទនាជាដើម ដែលសម្បយុត្តដោយចក្ខុវិញ្ញាណធាតុនោះ ឈ្មោះថា ធម្មធាតុ ព្រោះធាតុ ៤ នេះ មកប្រជុំគ្នាយ៉ាងនេះ ទើបការមើលទៅមុខ និងការក្រឡេកមើលឆ្វេង

ស្តាំប្រាកដ កាលការមើលទៅមុខ និងការក្រឡេកឆ្វេងស្តាំប្រាកដដោយអំណាចធាតុ ៤ នោះ មិនមានបុគ្គលណាម្នាក់ក្រឡេកមើលទៅមុខ មិនមានបុគ្គលម្នាក់ក្រឡេកមើលឆ្វេងស្តាំឡើយ ។

មួយប្រការទៀត ចក្ខុជានិស្សយប្បច្ច័យ រូបជាអារម្មណប្បច្ច័យ អាវជ្ជនៈជាអនន្តរប្បច្ច័យ សមនន្តរប្បច័យ ឧបនិស្សយប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ អាលោក គឺពន្លឺ ជាឧបនិស្សយប្បច្ច័យ វេទនាជាដើម ជាសហជាតប្បច្ច័យ ។ ព្រោះបច្ច័យទាំងនោះដូចគ្នាយ៉ាងនោះ ទើបការមើលទៅមុខ និងការមើលឆ្វេងស្តាំប្រាកដ កាលការក្រឡេកមើលទៅមុខ និងការក្រឡេកមើលឆ្វេងស្តាំប្រាកដ ដោយអំណាចបច្ច័យនោះ តើនឹងមានបុគ្គលណាម្នាក់មកមើលទៅមុខ នឹងមានបុគ្គលណាម្នាក់ក្រឡេកមើលឆ្វេងស្តាំនោះ ។ គប្បីជ្រាបអសម្មោហសម្បជញ្ញៈ ដោយការពិចារណាខន្ធ ធាតុ អាយតនៈ និងបច្ច័យ ក្នុងការមើលទៅមុខ និងការក្រឡេកមើលឆ្វេងស្តាំនេះ ដូចពណ៌នាមកនេះ ។ បទថា **សម្មិញ្ជិតេ បសារិតេ** បានដល់ ក្នុងការលាតសណ្តូក និងអង្គុញដៃ-ជើងចេញទៅ ។

បណ្តាសម្បជញ្ញៈទាំង ៤ នោះ ការមិនធ្វើការបត់អង្គុញ និងការលាតសណ្តូកដោយអំណាចចិត្ត ( ការគិត ) តែម្យ៉ាង តែពិគ្រោះមើលអត្ថៈ និងអនត្ថៈ ព្រោះមានការលាតសណ្តូក បត់អង្គុញដៃ-ជើងចេញទៅជាបច្ច័យហើយ ជ្រើសរើសយកតែប្រយោជន៍ ឈ្មោះថា សាត្ថកសម្បជញ្ញៈ ។ ក្នុងការលាតសណ្តូក និងបត់អង្គុញចេញទៅនោះ គប្បីជ្រាបការពិគ្រោះដល់អត្ថៈ

និងអនត្ថៈយ៉ាងនេះថា កាលលោកបត់អង្គុញអវយវៈយូរៗ លាតសណ្ដូក អវយវៈចេញទៅយូរៗ វេទនាកើតឡើងគ្រប់ៗ គ្រា ។ ចិត្តនឹងមិនបាន ឯកគ្គតា កម្មដ្ឋាននឹងបាត់បង់ លោកនឹងមិនបានសម្រេចគុណវិសេស ។ តែ កាលបត់អង្គុញល្មមប្រមាណ លាតសណ្ដូកចេញទៅល្មមប្រមាណ វេទនា នឹងមិនកើតឡើង ចិត្តនឹងជាឯកគ្គតា កម្មដ្ឋានក៏នឹងគួរដល់ការចម្រើន លោក នឹងបានសម្រេចគុណវិសេស ។

ឯការដែលបច្ច័យមាន ព្រះយោគាវចរ ញុំាងវិគ្រោះស្ថានទី ដែលជា សប្បាយ និងមិនជាសប្បាយ ហើយជ្រើសយកទីដែលជាសប្បាយ ឈ្មោះ ថា **សប្បាយសម្បជញ្ញ** ។ ក្នុងសប្បាយសម្បជញ្ញៈមានសេចក្ដីដូច្នេះ

បានឮមកថា ភិក្ខុកំលោះៗ នាំគ្នាសូធ្យមន្តត្រង់លានមហាចេតិយ ខាង ក្រោយភិក្ខុទាំងនោះ ភិក្ខុនីក្រមុំៗ កំពុងស្ដាប់ធម៌ ។ ក្នុងចំនួនភិក្ខុទាំងនោះ ភិក្ខុកំលោះមួយរូប លាដៃចេញទៅ ត្រូវកាយភិក្ខុនី ហើយបានក្លាយជា គ្រហស្ថទៅ ព្រោះហេតុនោះឯង ។ ភិក្ខុមួយរូបទៀត កាលសណ្ដូកជើង ចេញទៅ បានប៉ះភ្លើង ភ្លើងឆេះជើងដល់ឆ្អឹង ។ ភិក្ខុមួយរូបទៀត លាត ទៅត្រង់ដំបូក ក៏ត្រូវពស់ចឹក ។ ភិក្ខុមួយរូបទៀតលាតទៅត្រង់ដងក្លស់ ត្រូវ ពស់វែកពញាក់ចឹកលោក ។ ព្រោះដូច្នោះ កាលលាតជើង កុំលាតទៅក្នុង ទីដែលមិនជាសប្បាយ ដូច្នោះ គួរលាតទៅក្នុងទីដែលសប្បាយ ។ នេះជា សប្បាយសម្បជញ្ញៈ ក្នុងឥរិយាបថពូៈនេះ ឯគោចរសម្បជញ្ញៈ គួរសម្ដែង ដោយរឿងព្រះមហាថេរៈ ។

# រឿង ព្រះមហាថេរៈ

បានឮថា ព្រះមហាថេរៈ អង្គុយត្រង់ទីសម្រាកពេលថ្ងៃ កាលសន្ទនាជាមួយអន្តេវាសិក បានបត់ដៃចូល ហើយលាដៃដូចដើម បន្ទាប់អំពីនោះ ទើបធ្វើដូច្នោះទៀតសន្សឹមៗ ។ អន្តេវាសិកសាកសួរលោកថា បពិត្រលោកម្ចាស់ ហេតុអ្វី ទើបលោកម្ចាស់បត់ដៃចូលយ៉ាងរហ័ស ហើយត្រឡប់លាទៅដូចដើម បន្ទាប់អំពីនោះ ទើបបត់ចូលសន្សឹមៗ ទៀត ។ ព្រះថេរៈឆ្លើយថា លោកម្ចាស់ តាំងអំពីខ្ញុំផ្តើមដាក់ចិត្តក្នុងកម្មដ្ឋាន ខ្ញុំមិនធ្លាប់លះកម្មដ្ឋាន ហើយបត់ដៃចូលឡើយ តែឥឡូវនេះ ខ្ញុំនិយាយជាមួយពួកលោក បានលះកម្មដ្ឋាន ហើយទើបបត់ដៃចូល ព្រោះដូច្នោះ ទើបខ្ញុំលាតដៃចេញទៅដូចដើម ហើយបត់ដៃសន្សឹមៗ ម្តងទៀត ។ អន្តេវាសិកទាំងឡាយពោលថា សាធុ លោកម្ចាស់ ធម្មតាភិក្ខុ គួរជាបុគ្គលដែលមានសភាពយ៉ាងនេះ ។ សូម្បីក្នុងឥរិយាបថបព្វៈនេះ ការមិនលះកម្មដ្ឋាន គប្បីជ្រាបថា ឈ្មោះថា គោចរសម្បជញ្ញៈ ដោយប្រការដូច្នេះ ។

មិនមានអ្វីខាងក្នុងដែលឈ្មោះថា អត្តាជាអ្នកបត់អង្គុញ ឬលាតសណ្តូកទៅឡើយ តែការលាតអង្គុញ បត់សណ្តូក មានដោយការផ្សាយរបស់វាយោធាតុដែលកើតអំពីចិត្ត មានប្រការដូចពោលមកហើយ ដូចការកម្រើកដៃ-ជើងរបស់រូបយន្ត ដោយការទាញខ្សែ ដូច្នោះ ព្រោះដូច្នោះ ការកំណត់ដឹងដែលពោលមកនេះ គប្បីជ្រាបចុះថា ឈ្មោះថា ជា **អសម្មោហសម្បជញ្ញ** ក្នុងឥរិយាបថបព្វៈនេះ ។

ការប្រើសង្ឃាដី និងសំពត់ចីវរ ដោយការស្លៀក ការដណ្តប់ ការប្រើ

បាត្រដោយការរក្សាជាដើម ឈ្មោះថា ធារណៈ ក្នុងពាក្យថា **សង្ឃាដិបត្ត-ចីវរធារណេ** នេះ ។ ការបានអាមិសនៃភិក្ខុដែលស្លៀក និងដណ្ដប់ហើយត្រាច់ទៅបិណ្ឌបាត និងប្រយោជន៍មានប្រការ ដូចព្រះមានព្រះភាគត្រាស់ដោយន័យជាដើមថា **សីតស្ស បដិឃាតាយ** ដើម្បីការពារនូវរងា ឈ្មោះថា ប្រយោជន៍ក្នុងការទ្រទ្រង់សំពត់សង្ឃាដី និងសំពត់ចីវរនោះ អ្នកសិក្សាគួរយល់សាត្ថកសម្បជញ្ញៈ ដោយអំណាចនៃប្រយោជន៍នោះ ដូច្នេះ ។

ឯចីវរសាច់ម៉ដ្ឋ ជាសប្បាយរបស់បុគ្គលមានប្រក្រតីក្ដៅ និងមានកម្លាំងតិច តែចីវរគ្រោតគ្រាតក្រាស់ ជាសប្បាយរបស់បុគ្គលមានប្រក្រតីរងាច្រើន ខុសអំពីនេះមិនជាសប្បាយ ។ ចីវរចាស់មិនសប្បាយរបស់បុគ្គលណាឡើយ ។ ព្រោះធ្វើការកង្វល់ចិត្តដល់លោក ដោយឲ្យនូវការអំពល់ចិត្តជាដើម ។ ចីវរមួយផ្ទាំង គឺមិនបានកាត់ឲ្យជាខណ្ឌ និងសំពត់សម្បកឈើជាដើម ជាទីតាំងនៃការលោភក៏យ៉ាងនោះ ព្រោះសំពត់បែបនោះ ធ្វើអន្តរាយដល់ការនៅម្នាក់ឯងក្នុងព្រៃ ឬធ្វើអន្តរាយដល់ជីវិតក៏មាន ដោយត្រង់ សំពត់ចីវរផ្ទាំងណាដែលកើតឡើងដោយអំណាចមិច្ឆាជីវៈ មានការធ្វើនិមិត្តជាដើម និងចីវរណាកាលលោកប្រើប្រាស់ អកុសលធម៌ចម្រើនឡើង កុសលធម៌វិនាសទៅ ចីវរនោះ ជាអសប្បាយ តែចីវរដែលខុសអំពីនេះ ជាសប្បាយ ។

ក្នុងសម្បជញ្ញបព្វៈនេះ អ្នកសិក្សាគប្បីជ្រាបសប្បាយសម្បជញ្ញៈ ដោយអំណាចនៃចីវរនោះ និងគោចរសម្បជញ្ញៈ ដោយអំណាចការមិនលះកម្មដ្ឋាននោះឯង ។

មិនមានអ្វីដែលឈ្មោះថា អត្តាខាងក្នុងរបស់ភិក្ខុដែលដណ្តប់ចីវរ មានតែការដណ្តប់ចីវរ ដោយការផ្សាយរបស់វាយោធាតុ ដែលកើតអំពីកិរិយានៃចិត្ត មានប្រការដូចពោលហើយប៉ុណ្ណោះ ។ បណ្តាចីវរ និងកាយទាំង ២ យ៉ាងនោះ ចីវរក៏មិនមានការតាំងចិត្ត កាយក៏មានការតាំងចិត្ត ចីវរក៏មិនដឹងថា អញដណ្តប់កាយ កាយក៏មិនដឹងថា ចីវរដណ្តប់អញ ធាតុទាំងឡាយប៉ុណ្ណោះ គ្របដណ្តប់ធាតុ ដូចយកសំពត់ចាស់ខ្ទប់រូប គឺគម្ពីរ ព្រោះដូច្នោះបានចីវរល្អហើយ មិនគួរធ្វើការសប្បាយចិត្តឡើយ បានមិនល្អ ក៏មិនគួរអន់ចិត្ត អធិប្បាយថា បុគ្គលពួកខ្លះនាំគ្នាមកសក្ការៈបូជានាគ ដំបូក ចេតិយ និងដើមឈើជាដើម ដោយផ្កា គ្រឿងក្រអូប និងសំពត់ជាដើម ។ តែបុគ្គលខ្លះ ធ្វើវត្ថុដែលមិនមែនសក្ការៈ ដូចជា បន្ទោបង់ឧច្ចារៈ បស្សាវៈ យកកក់លាប យកកំណាត់ឈើវាយ និងសស្រ្តាប្រហារជាដើម នាគ ដំបូក និងដើមឈើជាដើម មិនធ្វើការត្រេកអរ ឬមិនត្រេកអរដោយសក្ការៈ ឬអសក្ការៈនោះ យ៉ាងណា ភិក្ខុក៏ដូច្នោះដូចគ្នា បានចីវរល្អហើយ ក៏មិនគួរធ្វើការត្រេកអរ បានចីវរមិនល្អ ក៏មិនគួរអាក់អន់ ។ ក្នុងសម្បជញ្ញបព្វៈនេះ អ្នកសិក្សាគួរជ្រាបអសម្មោហសម្បជញ្ញៈ ដោយអំណាចការពិចារណាដែលប្រព្រឹត្តទៅហើយ ដូចពណ៌នាមកនេះ ។

ក្នុងការបើបាត្រ ក៏គួរជ្រាបអសម្មោហសម្បជញ្ញៈ ដោយអំណាចប្រយោជន៍ដែលគប្បីបាន ព្រោះមានការកាន់បាត្រជាបច្ច័យ យ៉ាងនេះថា អញនឹងមិនប្រញាប់ប្រញាល់កាន់បាត្រ តែកាន់យកបាត្រដោយកម្មដ្ឋានសញ្ញា ត្រាច់ទៅ

បិណ្ឌបាត ក៏នឹងបានភិក្ខា ។

ចំណែកបាត្រធ្ងន់ មិនជាសប្បាយសម្រាប់ភិក្ខុ ដែលមានរាងកាយស្គម និងកម្លាំងតិច បាត្រដែលផ្សារដែកចូលគ្នា ៤-៥ បន្ទះ ថ្មេរមិនរៀបរយ មិនជាជាទីសប្បាយដល់បុគ្គលណាម្នាក់ឡើយ ។ ព្រោះថា បាត្រដែលលាង លំបាក មិនជាទីសប្បាយ កាលលាងបាត្រនោះឯង លោកនឹងមានកង្វល់ ។ ឯបាត្រដែលមានពណ៌ដូចកែវមណី ជាទីតាំងនៃការលោភ មិនជាសប្បាយ ដោយន័យដែលបានពោលមកហើយ ក្នុងចីវរនោះឯង ។ តែបាត្រដែលបាន មកដោយការធ្វើនិមិត្តជាដើម កាលភិក្ខុនោះប្រើប្រាស់ អកុសលធម៌នឹង ចម្រើន កុសលធម៌នឹងវិនាស បាត្រនេះជាអសប្បាយ ដោយចំណែកមួយ ប៉ុណ្ណោះ បាត្រដែលខុសអំពីនេះ ជាសប្បាយ ។ គប្បីជ្រាបសប្បាយ សម្បជញ្ញៈ ដោយអំណាចនៃបាត្រនោះ គប្បីជ្រាបគោចរសម្បជញ្ញៈ ដោយ មិនលះកម្មដ្ឋាន ។

មិនមានអ្វីដែលឈ្មោះថា អត្តាខាងក្នុងដល់ភិក្ខុដែលបីបាត្រ ធម្មតាការបី បាត្រនឹងមានដោយការផ្សាយនៃវាយោធាតុដែលកើតឡើង ព្រោះកិរិយានៃ ចិត្ត មានប្រការដូចពោលហើយ បណ្ដាដៃ និងបាត្រទាំង ២ យ៉ាងនោះ បាត្រក៏មិនមានការតាំងចិត្ត ដៃក៏មិនមានការតាំងចិត្ត បាត្រក៏មិនដឹងថា ដៃ ឱបអញ ដៃក៏មិនដឹងថា អញឱបបាត្រ ធាតុទាំងឡាយ ប៉ុណ្ណោះឱបក្រុម ធាតុ ដូចគ្នាក្នុងវេលាយកដង្កាប់កៀបបាត្រដុតក្នុងភ្លើង ព្រោះដូច្នោះ ក្នុង សម្បជញ្ញបព្វៈនេះ គប្បីជ្រាបអសម្មោហសម្បជញ្ញៈ ដោយការពិចារណាអត្ថ

ដែលប្រព្រឹត្តទៅហើយ ដូចពណ៌នាមកនេះ ។

ម្យ៉ាងទៀត ភិក្ខុណាពិចារណាឃើញចីវរ ដូចសំពត់រុំដំបៅ បាត្រដូចអំបែងដាក់ថ្នាំ និងភិក្ខាដែលបានមកក្នុងបាត្រ ដូចថ្នាំក្នុងអំបែង ភិក្ខុនេះគប្បីជ្រាបចុះថា ជាអ្នកមានប្រក្រតីធ្វើការជីងខ្លួនយ៉ាងខ្ពង់ខ្ពស់ជាប្រក្រតី ដោយអសម្មោហសម្បជញ្ញៈ ក្នុងការទ្រទ្រង់សង្ឃាដី បីបាត្រ និងដណ្តប់ចីវរ ដូចគ្នានឹងបុរសដែលមានករុណា ឃើញជនអនាថាដេកត្រង់សាលា សម្រាប់បុគ្គលអនាថា មានដៃជើងកំបុត មានខ្ទុះ និងឈាមផង ដង្កូវហូរចេញអំពីដំបៅផង មានរុយក្បាលខៀវរោមផង ទើបបានរកសំពត់ដំបៅ និងថ្នាំ និងអំបែងសម្រាប់ដាក់ថ្នាំទៅប្រគល់ឲ្យដល់ជនទាំងនោះ ក្នុងចំនួនទ្រព្យទាំងនោះ សំពត់ដែលសាច់ម៉ដ្ឋ ក៏ធ្លាក់ដល់ជនទាំងនោះ សំពត់សាច់គ្រោតគ្រាត ក៏ធ្លាក់ដល់ជនទាំងនោះ សូម្បីត្រឡោកដាក់ថ្នាំដែលមានទ្រង់ទ្រាយល្អ ក៏ធ្លាក់ដល់ជនទាំងនោះ ដែលទ្រង់ទ្រាយមិនល្អ ក៏ធ្លាក់ដល់ជនទាំងនោះ ជនទាំងនោះមិនត្រេកអរ ឬអាក់អន់ក្នុងទ្រព្យទាំងនោះ ព្រោះពួកជនទាំងនោះ ត្រូវការសំពត់គ្រាន់តែប្រើរុំដំបៅប៉ុណ្ណោះ ត្រឡោកប្រើសម្រាប់ដាក់ថ្នាំប៉ុណ្ណោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការឆាន់ជាដើមដូច្នេះ បទថា **អសិតេ** សេចក្តីថា ក្នុងការឆាន់បិណ្ឌបាត ។ បទថា **បីតេ** សេចក្តីថា ក្នុងការហុតបបរជាដើម ។ បទថា **ខាយិតេ** សេចក្តីថា ក្នុងការទំពាខជ្ជនីយាហារដែលធ្វើដោយម្សៅជាដើម ។ បទថា **សាយិតេ** សេចក្តីថា ក្នុងការផឹករបស់ផឹក មានទឹកអំពៅជាដើម ។

ក្នុងការឆាន់ជាដើមនោះ ប្រយោជន៍ទាំង ៨ យ៉ាង ដែលព្រះពុទ្ធត្រាស់ដោយន័យជាដើមថា **នេវ ទវាយ** គឺមិនមែនដើម្បីលេង ឈ្មោះថា ប្រយោជន៍ អ្នកសិក្សាគប្បីជ្រាបសាត្ថកសម្បជញ្ញៈ ដោយអំណាចនៃប្រយោជន៍នោះ ។

បុគ្គលណា មានការមិនសប្បាយ ព្រោះភោជនណា ភោជននោះ ជាអសប្បាយសម្រាប់បុគ្គលនោះ ឯភោជនណា បានមកដោយការធ្វើនិមិត្តជាដើម កាលលោកឆាន់ភោជនណា អកុសលធម៌ទាំងឡាយចម្រើនឡើង កុសលធម៌ទាំងឡាយវិនាសទៅ ភោជននោះ ជាអសប្បាយដោយចំណែកមួយប៉ុណ្ណោះ ។ តែភោជនដែលខុសអំពីនោះ ជាសប្បាយ ។

អ្នកសិក្សាគួរជ្រាបសប្បាយសម្បជញ្ញៈ ដោយអំណាចនៃភោជន ដែលជាសប្បាយនោះ និងគប្បីជ្រាបគោចរសម្បជញ្ញៈ ដោយមិនលះកម្មដ្ឋាន ។

មិនមានបុគ្គលណា ឈ្មោះថា អត្តាខាងក្នុងបុគ្គលដែលជាអ្នកបរិភោគ មានតែការទទួលបាត្រជាធម្មតា ដោយការផ្សាយនៃវាយោធាតុដែលកើតអំពីកិរិយារបស់ចិត្ត មានប្រការដូចពោលមកហើយប៉ុណ្ណោះ មានតែការលូកដៃចូលក្នុងបាត្រជាធម្មតា ដោយការផ្សាយនៃវាយោធាតុដែលកើតអំពីកិរិយានៃចិត្តប៉ុណ្ណោះ មានតែការពូតដុំបាយ ការលើកដុំបាយឡើង និងការហាមាត់ទទួល ដោយការផ្សាយរបស់វាយោធាតុ ដែលកើតអំពីកិរិយានៃចិត្តប៉ុណ្ណោះ មិនមានបុគ្គលណាយកកូនសោ និងគ្រឿងយន្តបើកថ្គាមថ្គាម មានតែការដាក់ពំនូតបាយក្នុងមាត់ ការឲ្យធ្មេញលើធ្វើកិច្ចជំនួសអង្រែ ការឲ្យធ្មេញខាងក្រោមធ្វើកិច្ចជំនួសត្បាល់ និងការឲ្យអណ្តាតធ្វើកិច្ចជំនួសដៃ ដោយការផ្សាយនៃ

វាយោធាតុ ដែលកើតអំពីកិរិយានៃចិត្តប៉ុណ្ណោះ ។

ដោយហេតុយ៉ាងនេះ ទឹកមាត់តិចតួចចេញអំពីចុងអណ្តាត ក្នុងបណ្តាចុង និងគល់នោះ ទឹកមាត់ជាច្រើនចេញអំពីគល់អណ្តាត ក៏ប្រឡាក់ប្រឡូសដុំបាយនោះ ដុំបាយនោះក៏ត្រឡប់ទៅត្រឡប់មក ដោយដៃ គឺអណ្តាត ក្នុងត្បាល់ គឺធ្មេញក្រោម ផ្សើមទៅដោយទឹក គឺខេឡៈ បុកលម្អិតដោយអង្រែ គឺធ្មេញលើ ដែលឈ្មោះថា បុគ្គលណាម្នាក់យកស្លាបព្រា ឬវែកស៊ីកចូលទៅក្នុងមាត់មិនមាន ដុំបាយចូលទៅបាន ព្រោះវាយោធាតុនោះឯង ដុំបាយដែលចូលទៅហើយ បុគ្គលណាឈ្មោះថារៀបទុក ធ្វើឲ្យដូចជាពំនូកចំបើងមិនមាន តែរៀបទុកដោយអំណាចវាយោធាតុប៉ុណ្ណោះ កាលដែលធ្លាក់រៀបរយហើយ បុគ្គលណាម្នាក់ឈ្មោះថា រៀបចង្ក្រានដុតភ្លើងស្ងោរឲ្យរលួយមិនមាន តែរលួយបានព្រោះតេជោធាតុប៉ុណ្ណោះ ដែលរលួយហើយ បុគ្គលណាម្នាក់ ឈ្មោះថា យកឈើជ្រួយ ឬឈើច្រត់កៀរទម្លាក់ទៅខាងក្រៅមិនមាន វាយោធាតុប៉ុណ្ណោះនាំចេញទៅ ដោយហេតុយ៉ាងនេះ វាយោធាតុនាំដុំបាយចូលទៅផង នាំចេញទៅផង ឲ្យឈប់ផង ឲ្យត្រឡប់ទៅមកផង ឲ្យរលួយទៅផង ឲ្យនាំសំណល់ចេញទៅផង បឋវីធាតុទ្រទ្រង់ទុកផង ឲ្យត្រឡប់ទៅផង ឲ្យរលួយផង អាបោធាតុឲ្យប្រមូលផ្តុំគ្នាផង រក្សាឲ្យនៅស្រស់ផង តេជោធាតុរំលាយដុំបាយដែលចូលទៅខាងក្នុងហើយ អាកាសធាតុជាឱកាស វិញ្ញាណធាតុគិតដល់ ដោយអាស្រ័យការប្រកបគ្នា ដោយប្រពៃក្នុងធាតុនោះៗ អ្នកសិក្សាគប្បីជ្រាបអសម្មោហសម្បជញ្ញៈ ក្នុងសម្បជញ្ញបព្វៈ ដោយ

ការពិចារណា ដែលប្រព្រឹត្តទៅហើយ ដូចពណ៌នាមកនេះ ។

ម្យ៉ាងទៀត ព្រះយោគាវចរគួរជ្រាបអសម្មោហសម្បជញ្ញៈ ក្នុងសម្បជញ្ញបព្វៈនេះ ដោយការពិចារណាដល់ភាពជាបដិកូល ១០ យ៉ាងនេះ គឺ ដោយការទៅ ១ ដោយការស្វែងរក ១ ដោយការឆាន់ ១ ដោយទីអាស្រ័យ ១ ដោយការតម្កល់នៅ ១ ដោយចំណែកដែលមិនទាន់រលួយ ១ ដោយចំណែកដែលរលួយហើយ ១ ដោយផល ១ ដោយជ្រួតជ្រាប ១ ដោយប្រឡាក់ប្រឡូស ១ ចំណែកកថាយ៉ាងពិស្តារ ក្នុងសម្បជញ្ញបព្វៈនេះ គួរកាន់យកចាកនិទ្ទេសនៃអាហារេបដិកូលសញ្ញា ក្នុងគម្ពីរវិសុទ្ធិមគ្គផងចុះ ។

បទថា **ឧច្ចារបស្សាវកម្មេ** សេចក្តីថា ក្នុងការបន្ទោបង់ឧច្ចារៈ និងបស្សាវៈ ព្រោះថា ដល់វេលានោះហើយ កាលមិនបន្ទោបង់ឧច្ចារបស្សាវៈ ញើសទឹងហូរចេញពេញរាងកាយ ភ្នែកទឹងស្រវាំង ចិត្តមិនជាឯកគ្គតា រោគផ្សេងៗ ក៏នឹងកើតឡើង តែកាលបន្ទោបង់ហើយ វត្ថុទាំងអស់នោះមិនមាន ព្រោះដូច្នោះ សេចក្តីនេះជាអធិប្បាយក្នុងបទថា **ឧច្ចារបស្សាវកម្មេ** នេះ ។ អ្នកសិក្សាគប្បីជ្រាបសាត្ថកសម្បជញ្ញៈ ដោយអំណាចនៃអត្ថនោះ ។

កាលបន្ទោបង់ឧច្ចារៈ និងបស្សាវៈក្នុងទីមិនសមគួរ នឹងត្រូវអាបត្តិ នឹងវិនាសយស នឹងមានអន្តរាយដល់ជីវិត តែលុះបន្ទោបង់ក្នុងទីសមគួរ វត្ថុទាំងនោះមិនមាន ព្រោះដូច្នោះ ការបន្ទោបង់ក្នុងទីសមគួរនេះ ទើបជាសប្បាយក្នុងឧច្ចារបស្សាវកម្មនេះ អ្នកសិក្សាគប្បីជ្រាបសប្បាយសម្បជញ្ញៈ ដោយអំណាចនៃសប្បាយនោះ ឯគោចរសម្បជញ្ញៈ គប្បីជ្រាបដោយអំណាចការ

មិនលះបង់កម្មដ្ឋាននោះឯង ។

មិនមានបុគ្គលណាឈ្មោះថា ជាអត្តាខាងក្នុង បន្ទោបង់ឧច្ចារបស្សាវៈ មានតែការបន្ទោបង់ឧច្ចារបស្សាវៈ ព្រោះការផ្សាយទៅនៃវាយោធាតុ ដែលកើតអំពីកិរិយានៃចិត្តប៉ុណ្ណោះ ឧច្ចារៈ និងបស្សាវៈដែលតាំងនៅក្នុងពោះវៀនចាស់ និងតម្រងបស្សាវៈ ត្រូវកម្លាំងខ្យល់រុញទៅ ក៏ចេញទៅឯង ដោយមិនចង់ឲ្យចេញឡើយ ដូចកាលបូសទុំហើយ ខ្ទុះ និងឈាមក៏ហូរចេញទៅឯង ដោយមិនលំបាក ព្រោះបែកធ្លាយ ហើយដូចគ្នានឹងទឹកដែលហូរចេញអំពីកាជនៈដាក់ទឹកដែលផ្អៀងហើយ ដោយមិនចង់ឲ្យហូរ ដូច្នោះ ។

ឯឧច្ចារៈ និងបស្សាវៈនេះ ដែលបន្ទោបង់ចេញទៅហើយ ឧច្ចារៈ និងបស្សាវៈនេះនៃអត្តារបស់ភិក្ខុនោះ មិនមានឡើយ របស់បុគ្គលដទៃក៏មិនមាន មានតែការបន្ទោបង់នៃរាងកាយប៉ុណ្ណោះ ។

សេចក្តីនេះប្រៀបដូចអ្វី ប្រៀបដូចចាក់ទឹកចាស់ចេញអំពីក្អម ហើយក្អមក៏មិនមានទឹកដូច្នោះឡើយ វត្ថុដទៃក៏មិនមាន មានត្រឹមតែបដិបត្តិតែម្យ៉ាងប៉ុណ្ណោះ យ៉ាងណា អ្នកសិក្សាគប្បីជ្រាបអសម្មោហសម្បជញ្ញៈ ក្នុងសម្បជញ្ញបព្វៈនេះ ដោយការពិចារណាកិរិយាអាការ ដែលប្រព្រឹត្តទៅហើយដូច្នោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការដើរជាដើមដូច្នេះ បទថា **គតេ** បានដល់ ការដើរទៅ ។ បទថា **ឋិតេ** បានដល់ ការឈរ ។ បទថា **និសិន្នេ** បានដល់ ការអង្គុយ ។ បទថា **សុត្តេ** បានដល់ ការដេកលក់ ។ បទថា **ជាគរិតេ**

បានដល់ ក្នុងការក្រាក់ ។ បទថា **ភាសិតេ** បានដល់ ក្នុងការពោល ។ បទថា **តុណ្ហីភាវេ** បានដល់ ក្នុងការមិននិយាយ ។

ព្រះអដ្ឋបានត្រាស់ឥរិយាបថវែងឆ្ងាយទុកក្នុងឋានៈនេះថា កាលដើរទៅក៏ដឹងថា អញកំពុងដើរខ្លះ ឈរហើយក៏ដឹងថា អញឈរហើយខ្លះ អង្គុយហើយ ក៏ដឹងថា អញអង្គុយហើយខ្លះ ដេកហើយ ក៏ដឹងថា អញដេកហើយខ្លះ ទ្រង់ត្រាស់ឥរិយាបថកណ្តាលៗ ក្នុងឋានៈនេះថា ក្នុងការឈានទៅខាងមុខ ក្នុងការឈានថយក្រោយ ក្នុងការមើលទៅមុខ ក្នុងការក្រឡេកមើលឆ្វេងស្តាំ ក្នុងការលាតសណ្តូក តែក្នុងបទ្ទៈនេះ ត្រាស់ឥរិយាបថបកិណ្ណកៈបន្តិចបន្តួចថា ក្នុងការដើរ ក្នុងការឈរ ក្នុងការអង្គុយ ក្នុងការលក់ ក្នុងការភ្ញាក់ ព្រោះដូច្នោះ គប្បីជ្រាបភាពជាអ្នកធ្វើការដឹងខ្លួនជាប្រក្រតី ដោយន័យដែលត្រាស់ហើយក្នុងឋានៈទាំងនេះឯង ។

ព្រះមហាសិវត្ថេរ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដកបានពោលថា បុគ្គលណាដើរទៅ ឬចង្ក្រមយូរៗ បន្ទាប់មក ទើបឈរ ពិចារណាឃើញយ៉ាងនេះថា រូបធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅហើយ ក្នុងវេលាចង្ក្រម បានរលត់ទៅហើយក្នុងវេលាចង្ក្រមនេះឯង បុគ្គលនេះឈ្មោះថា ធ្វើការដឹងខ្លួនក្នុងការដើរ ។

បុគ្គលណា កាលធ្វើការស្វាធ្យាយ ឆ្លើយបញ្ហា ឬមនសិការកម្មដ្ឋានឈរនៅយូរៗ ហើយបន្ទាប់មក ទើបអង្គុយ ពិចារណាឃើញយ៉ាងនេះថា រូបធម៌ និងអរូបធម៌ ដែលប្រព្រឹត្តទៅហើយ ក្នុងពេលឈរ បានរលត់ទៅហើយក្នុងពេលឈរនេះឯង បុគ្គលនេះ ឈ្មោះថា ធ្វើការដឹងខ្លួនក្នុងការ

ឈរ ។ បុគ្គលណា អង្គុយយូរៗ ដោយធ្វើការសាធ្យាយជាដើមនោះឯង បន្ទាប់មក ទើបដេក ពិចារណាឃើញយ៉ាងនេះ រូបធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅហើយក្នុងវេលាអង្គុយ បានរលត់ទៅហើយក្នុងវេលាអង្គុយនោះឯង អ្នកនោះ ឈ្មោះថា ធ្វើការដឹងខ្លួនក្នុងការអង្គុយ ។

បុគ្គលណា ដេកនោះឯង ធ្វើការសាធ្យាយទៅបណ្តើរ ឬមនសិការកម្មដ្ឋានទៅបណ្តើរ ឈមចុះកាន់ការលក់ បន្ទាប់មក ទើបក្រោកឡើង ពិចារណាឃើញយ៉ាងនេះថា រូបធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅហើយក្នុងវេលាដេក បានរលត់ទៅហើយក្នុងវេលាដេកនោះឯង បុគ្គលនេះ ឈ្មោះថា ធ្វើការដឹងខ្លួនក្នុងការដេកលក់ផង ក្នុងការភ្ញាក់ផង ។ ព្រោះថា ចិត្តដែលសម្រេចដោយកិរិយា មិនមានការប្រព្រឹត្តទៅ ( មិនឡើងកាន់វិថី ) ឈ្មោះថា ដេកលក់ មានការប្រព្រឹត្តទៅ ឈ្មោះថា ភ្ញាក់ ព្រោះដូច្នោះ ទើបបុគ្គលនោះ ឈ្មោះថា ធ្វើការដឹងខ្លួនក្នុងនិទ្រាផង ក្នុងការភ្ញាក់ផង ។

ឯបុគ្គលណាកាលពោល ក៏ពោលមានសតិ ដឹងខ្លួនថា ធម្មតាសំឡេងនេះ អាស្រ័យបបូរមាត់ អាស្រ័យធ្មេញ អណ្តាត ពិតាន និងបយោគរបស់ចិត្តដែលសមគួរនឹងចិត្តនោះ ហើយទើបកើតឡើងបាន ។

មយ៉ាងទៀត បុគ្គលណាធ្វើការសាធ្យាយធម៌ ប្រាប់ធម៌ ប្រែធម៌ បង្រៀនកម្មដ្ឋាន ឬវិសជ្ជនាអស់កាលដ៏យូរ បន្ទាប់មក ទើបអង្គុយស្ងៀម ពិចារណាឃើញយ៉ាងនេះថា រូបធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅ ក្នុងវេលាពោល ក៏រលត់ទៅហើយ ក្នុងវេលាពោលនោះឯង ។ បុគ្គលនោះ ឈ្មោះថា ធ្វើការ

ដឹងខ្លួនក្នុងការពោល ។

បុគ្គលណា នៅស្ងៀម មនសិការដល់ធម៌ ឬកម្មដ្ឋានយូរៗ បន្ទាប់មក ពិចារណាឃើញយ៉ាងនេះថា រូបធម៌ និងអរូបធម៌ ដែលប្រព្រឹត្តទៅក្នុងវេលាស្ងៀម ក៏បានរលត់ទៅហើយក្នុងវេលាស្ងៀមនោះឯង កាលមានការប្រព្រឹត្តទៅនៃឧបាទាយរូប បុគ្គលនោះក៏ឈ្មោះថា ពោល កាលមិនមានក៏ឈ្មោះថាជាអ្នកស្ងៀម បុគ្គលនេះ ឈ្មោះថា ធ្វើការដឹងខ្លួនក្នុងតុណ្ហីភាព ។

សម្បជញ្ញៈដែលមានអសម្មោហៈជាធុរៈ ដែលព្រះមហាថេរៈពោលហើយនេះ ព្រះអង្គទ្រង់បំណងយកក្នុងសតិប្បដ្ឋានសូត្រនេះ ។ ឯក្នុងសាមញ្ញផលសូត្រ បានសម្បជញ្ញៈគ្រប់ទាំង ៤ យ៉ាង ។ ព្រោះដូច្នោះ ក្នុងសាមញ្ញផលសូត្រនោះ អ្នកសិក្សាគប្បីជ្រាបភាពជាអ្នកធ្វើការដឹងខ្លួនជាពិសេស ដោយអំណាចសម្បជញ្ញៈដែលមិនវង្វេង ។ ក្នុងគ្រប់បទ មានបទថា **សម្បជានការី សម្បជានការី** អ្នកសិក្សាគប្បីជ្រាបអធិប្បាយដោយអំណាចសម្បជញ្ញៈ ដែលប្រកបដោយសតិដូចគ្នា ។

ឯក្នុងវិភង្គប្បករណ៍ ព្រះអង្គទ្រង់ចែកបទនេះដូចគ្នាថា ព្រះយោគាវចរ មានសតិ មានសម្បជញ្ញៈ ឈានទៅខាងមុខ មានសតិ មានសម្បជញ្ញៈ ឈានថយក្រោយ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្ដីថា ព្រះយោគាវចរ ឈ្មោះថា ពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬរបស់អ្នកដទៃ គឺកាយរបស់ខ្លួនតាមកាលដែលគួរ ឬកាយរបស់អ្នកដទៃតាមកាលដែលគួរ ដោយការកំណត់ដោយ

សម្បជញ្ញៈ ៤ ប្រការយ៉ាងនេះ ។

សូម្បីក្នុងចតុសម្បជញ្ញបព្វៈនេះ ក៏គួរនាំយកការកើត ការវិនាសនៃរូបក្ខន្ធនោះឯង ទៅប្រកបក្នុងពាក្យទាំងឡាយថា **សមុទយវយធម្មានុបស្សី វា** ជាដើម ពាក្យដ៏សេសដូចគ្នានឹងពាក្យដែលបានពោលហើយនោះឯង ។

ក្នុងទីនេះ សតិដែលកំណត់ដោយសម្បជញ្ញៈ ៤ ប្រការ ជាទុក្ខសច្ច បុរិមតណ្ហាដែលញុំាងសតិឲ្យប្រាកដ ជាសមុទយសច្ច ការមិនប្រព្រឹត្តទៅនៃសតិ និងបុរិមតណ្ហាទាំង ២ នោះ ជានិរោធសច្ច អរិយមគ្គមានប្រការដូចពោលមកហើយ ជាមគ្គសច្ច ព្រះយោគាវចរខ្វល់ខ្វាយដោយអំណាចសច្ចៈទាំង ៤ យ៉ាងនេះហើយ សម្រេចការរំលត់តណ្ហា ព្រោះដូច្នោះ ទើបជាឱកាសនៃធម៌ជាហេតុនាំចេញចាកទុក្ខ រហូតដល់អរហត្ត ដោយអំណាចនៃព្រះយោគាវចរដែលកំណត់ដោយសម្បជញ្ញៈ ៤ ប្រការមួយរូប ដូច្នេះ ។

**អធិប្បាយ សម្បជញ្ញបព្វៈ ចប់**

# អធិប្បាយ បដិក្កូលមនសិការបព្វៈ

[ ១៣៦ ] ព្រះមានព្រះភាគ កាលទ្រង់ចែកកាយានុបស្សនា ដោយអំណាចនៃសម្បជញ្ញៈ ៤ ប្រការ ដូចពណ៌នាមកនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយអំណាចមនសិការថាជារបស់បដិកូល ទើបបានត្រាស់ពាក្យថា **បុន ចបរំ** ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបដិកូលមនសិការបព្វៈដូច្នេះ ពាក្យណាដែលត្រូវ

ពោលក្នុងពាក្យថា **ឥមមេវ កាយំ** ជាដើម ពាក្យទាំងអស់នោះ បានពោលហើយក្នុងកាយគតាសតិកម្មដ្ឋាន ក្នុងគម្ពីរវិសុទ្ធិមគ្គដោយពិស្តារ ដោយអាការគ្រប់យ៉ាង ។

បទថា **ឧភតោមុខា** សេចក្តីថា ថៃមានមាត់ទាំងសងខាង គឺទាំងខាងក្រោម និងខាងលើ ។ បទថា **នានាវិហិតស្ស** ប្រែថា មានបែបផ្សេងៗ ។

ក្នុងរឿងនេះ មានការឧបមាជាការប្រៀបធៀបគ្នាដូច្នេះ កាយ គឺមហាភូតរូប ៤ គប្បីជ្រាបថា ដូចថៃមានមាត់សងខាង អាការ ៣២ មានសក់ជាដើម គប្បីជ្រាបថា ដូចធញ្ញជាតិច្រើនប្រភេទ ដែលចាក់លាយគ្នាក្នុងថៃ ព្រះយោគាវចរគប្បីជ្រាបថា ដូចបុរសភ្នែកល្អ អាការប្រាកដជាក់ច្បាស់នៃអាការ ៣២ ដល់ព្រះយោគី គប្បីជ្រាបថា ដូចវេលាដែលធញ្ញជាតិច្រើនប្រភេទប្រាកដដល់បុរសនោះ ដែលស្រាយថៃនោះហើយ ពិនិត្យមើលដូច្នោះ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរ ឈ្មោះថា ពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬក្នុងកាយរបស់អ្នកដទៃ គឺក្នុងកាយរបស់ខ្លួនតាមកាល ឬក្នុងកាយរបស់អ្នកដទៃតាមកាល ( ដែលសមគួរ ) ដោយការកំណត់ក្នុងសក់ជាដើម ។ ពាក្យបន្ទាប់អំពីនេះទៅ មានន័យដូចបានពោលមកហើយនោះឯង ។ ពិតហើយ ក្នុងបដិកូលមនសិការបព្វៈនេះ សតិដែលកំណត់អាការ ៣២ ជាទុក្ខសច្ចតែម្យ៉ាង អ្នកសិក្សាគួរធ្វើការប្រកបសេចក្តីដូចពណ៌នាមកយ៉ាងនេះហើយ ជ្រាបឱកាសនៃការចេញទៅអំពីទុក្ខ ។ ពាក្យ

ដ៏សេស ដូចគ្នានឹងពាក្យមុននោះឯង ដូច្នេះ ។

## អធិប្បាយ បដិក្កូលមនសិការបព្វៈ ចប់

# អធិប្បាយ ធាតុមនសិការបព្វៈ

[ ១៣៧ ] ព្រះមានព្រះភាគ កាលទ្រង់ចែកកាយានុបស្សនា ដោយអំណាចបដិកូលមនសិការយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយអំណាចការមនសិការដល់ធាតុ ទើបត្រាស់ពាក្យថា **បុន ចបរំ** ជាដើម ។ ក្នុងពាក្យទាំងនោះ មានការពណ៌នាព្រមនឹងពាក្យឧបមាជាការប្រៀបធៀបគ្នាដូច្នេះ ។

អ្នកសម្លាប់គោពួកខ្លះ ឬកូនសិស្សរបស់អ្នកសម្លាប់គោក្តី សម្លាប់គោហើយ ពន្លះហើយ បែងចេញជាចំណែកៗ អង្គុយលក់ត្រង់ផ្លូវបែកជា ៤ ពោល គឺត្រង់កែងផ្លូវធំ ដែលបែកជា ៤ ទិស យ៉ាងណា ភិក្ខុក៏ដូច្នោះដូចគ្នា ពិចារណាកាយ តាមដែលតាំងនៅហើយ ដោយអាការណាមួយ នៃឥរិយាបថទាំង ៤ និងតាមដែលតាំងនៅហើយ ព្រោះតាមដែលបានតាំងបណិធានទុកយ៉ាងនេះថា មាននៅក្នុងកាយនេះ គឺធាតុដី ។បេ។ ធាតុខ្យល់ ។

សួរថា មានពុទ្ធាធិប្បាយដូចម្តេច ឆ្លើយថា មានពុទ្ធាធិប្បាយថា អ្នកសម្លាប់គោ កាលកំពុងចិញ្ចឹមគោក្តី កំពុងដឹកទៅកាន់ទីសត្តឃាតក្តី កាលដឹកទៅហើយ កំពុងចងឲ្យឈរក្នុងទីនោះក្តី កំពុងសម្លាប់ក្តី កំពុងមើលគោដែលគេសម្លាប់ហើយក្តី មានសញ្ញាថា មេគោមិនទាន់បាត់ទៅដរាបណា មិនទាន់

ពន្ធះមេគោនោះបែងជាចំណែកៗ តែកាលអន្ទ្រយ៍ចែកសាច់ហើយ ក៏មាន សញ្ញាថា មេគោក៏បាត់ទៅ មានការសម្គាល់ថា សាច់នឹងប្រព្រឹត្តទៅចូលមក ជំនួស អ្នកសម្លាប់គោមិនមានការគិតយ៉ាងនេះថា អញលក់មេគោ បុគ្គល ទាំងនេះទិញមេគោ ដោយពិតហើយ អ្នកសម្លាប់គោមានការគិតយ៉ាងនេះ ប៉ុណ្ណោះថា អញលក់សាច់ ជនទាំងនេះទិញសាច់ យ៉ាងណា ក្នុងវេលា ដែលភិក្ខុរូបនេះ នៅជាពាលបុថុជ្ជនអំពីមុន ក៏ដូច្នោះដូចគ្នា ការសម្គាល់ថា សត្វ ឬបុគ្គលនៃលោក ថាជាគ្រហស្ថក្តី ជាអ្នកបួសហើយក្តី មិនទាន់ អន្តរធានទៅដរាបណា មិនទាន់បានធ្វើកាយនេះឯង តាមដែលស្ថិតនៅហើយ តាមដែលតាំងនៅហើយ ឲ្យជាការញែកចេញទៅអំពីឃនៈ ហើយឃើញ ដោយធាតុ តែកាលលោកពិចារណាឃើញថាជាធាតុ សត្តសញ្ញារបស់ លោក ក៏អន្តរធានទៅ ចិត្តតាំងនៅដោយអំណាចនៃធាតុនោះឯង ។

ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ភិក្ខុពិចារណាឃើញកាយ នេះតាមដែលស្ថិតនៅហើយ តាមដែលតាំងនៅហើយ ថាគ្រាន់តែជាធាតុក្នុង កាយនេះ មានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ម្នាលភិក្ខុទាំងឡាយ នាយគោឃាតក ជាអ្នកប៉ិនប្រសប់ក្តី ។បេ។ វាយោធាតុ យ៉ាងណា ។

អធិប្បាយថា ភិក្ខុអ្នកបំពេញព្យាយាម ដូចអ្នកសម្លាប់គោ មានសញ្ញា សម្គាល់ថាសត្វ ដូចការសម្គាល់ថា មេគោ ឥរិយាបថ ៤ ដូចផ្លូវធំបែកជា ៤ ការពិចារណាឃើញកាយថាជាធាតុ ដូចនាយគោឃាតកដែលអន្ទ្រយ៍ចែក សាច់ជាចំណែក ។ នេះគឺការពណ៌នាសេចក្តីតាមបាលីក្នុងធាតុមនសិការបព្វៈ

នេះ ។ ឯកថាពោលដោយកម្មដ្ឋាន បានឲ្យពិស្តារហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរមានប្រក្រតីពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬក្នុងកាយរបស់អ្នកដទៃ គឺមានប្រក្រតីពិចារណាឃើញកាយក្នុងកាយរបស់ខ្លួនតាមកាល ឬក្នុងកាយរបស់អ្នកដទៃតាមកាលយ៉ាងនេះ គឺដោយការកំណត់ធាតុ ៤ ពាក្យបន្តអំពីនេះទៅ មានន័យដូចពោលហើយនោះឯង ព្រោះថា ក្នុងធាតុមនសិការបព្វៈនេះ សតិដែលកំណត់ធាតុ ៤ ជាទុក្ខសច្ចតែម្យ៉ាង ។

បណ្ឌិតគប្បីជ្រាបឱកាសនៃធម៌ជាគ្រឿងនាំចេញចាកទុក្ខ តាមដែលបានអធិប្បាយសេចក្តីប្រកបមកយ៉ាងនេះឯង ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យមុននោះឯង ដូច្នេះ ។

**អធិប្បាយ ធាតុមនសិការបព្វៈ ចប់**

## អធិប្បាយ នវសីវថិកាបព្វៈ

[ ១៣៨ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងចែកកាយានុបស្សនាដោយអំណាចមនសិការដល់ធាតុយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកនវសីវថិកាបព្វៈ គឺធម៌ដែលពោលដោយព្រៃខ្មោច ៩ ទើបត្រាស់ពាក្យថា **បុន ចបរំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សេយ្យថាបិ បស្សេយ្យ** បានដល់ **យថា បស្សេយ្យ** ប្រែថា គប្បីឃើញយ៉ាងណា ។ បទថា **សរីរំ** បានដល់ រាងកាយ

របស់បុគ្គលដែលស្លាប់ហើយ ។ បទថា **សីវថិកាយ ឆឌ្ឌិតំ** សេចក្តីថា គេបោះចោលត្រង់ព្រៃស្មសាន ។ រាងកាយរបស់បុគ្គលដែលស្លាប់ហើយមួយថ្ងៃ ព្រោះដូច្នោះ ទើបឈ្មោះថា **ឯកាហមត** ។ រាងកាយរបស់បុគ្គលដែលស្លាប់ហើយពីរថ្ងៃ ព្រោះដូច្នោះ ទើបឈ្មោះ ថា **ទ្វីហមត** ។ រាងកាយរបស់បុគ្គលដែលស្លាប់ហើយបីថ្ងៃ ព្រោះដូច្នោះ ទើបឈ្មោះថា **តីហមត** ។ សពដែលហើមប៉ោងដូចស្នប់ ឈ្មោះថា **ឧទ្ធុមាតក** ព្រោះហើមប៉ោង គឺប៉ោងឡើងទៅតាមលំដាប់ ក្រោយអំពីអស់ជីវិតហើយ ។ ពណ៌ជាំខ្មៅខៀវ ហៅថា **វិនីល** ។ **វិនីលក** ក៏គឺ **វិនីល** នោះឯង ។

ម្យ៉ាងទៀត សពដែលមានពណ៌ខៀវពព្វាក់ គួរខ្ពើម ព្រោះជាវត្ថុបដិកូល ព្រោះដូច្នោះ ទើបឈ្មោះថា **វិនីលក** ។ ពាក្យថា **វិនីលក** នេះ ជាឈ្មោះរបស់សាកសពដែលមានពណ៌ក្រហម ក្នុងទីដែលមានសាច់ប៉ោង មានពណ៌ស ក្នុងទីដែលខ្ទុះហូរ តែដោយច្រើនមានពណ៌ខៀវ ក្នុងទីដែលមានពណ៌ខៀវ ដូចដណ្តប់ដោយសំណាត់ពណ៌ខៀវ ។

ម្យ៉ាងទៀត ខ្ទុះដែលហូរចេញអំពីទ្វារទាំង ៩ ក្នុងទីដែលបែកធ្លាយហើយ ឈ្មោះថា **វិបុព្វ** ក៏គឺ **វិបុព្វក** នោះឯង ។ ម្យ៉ាងទៀត ខ្ទុះដែលហូរគួរខ្ពើម ព្រោះបដិកូល ព្រោះដូច្នោះ ទើបឈ្មោះថា **វិបុព្វក** ។ សពដែលក្លាយជាខ្ទុះ គឺដល់នូវភាវៈយ៉ាងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **វិបុព្វក-ជាត** ។

បទថា **សោ ឥមមេវ កាយំ** សេចក្តីថា ភិក្ខុនោះបង្អោនកាយរបស់ខ្លួន

នេះចូលទៅប្រៀបធៀបនឹងកាយនោះដោយបញ្ញា ។

បទថា **ឧបសំហរតិ** ប្រែថា បង្អោននាំចូលទៅ ។

សួរថា បង្អោនចូលទៅដូចម្តេច ឆ្លើយថា បង្អោនចូលទៅយ៉ាងនេះថា សូម្បីកាយនេះសោត ជាធម្មតាយ៉ាងនេះ មានសភាពយ៉ាងនេះ មិនកន្លងសភាពយ៉ាងនេះបានឡើយ ។

សួរថា លោកពោលអធិប្បាយដូចម្តេច ឆ្លើយថា លោកពោលអធិប្បាយថា ព្រោះមានធម៌ទាំង ៣ យ៉ាងនេះ គឺអាយុ ភ្លើងធាតុ វិញ្ញាណ ទើបកាយនេះតាំងនៅ គឺផ្លាស់ប្តូរឥរិយាបថ មានឈរ និងដើរជាដើមបាន តែព្រោះមិនមានធម៌ទាំង ៣ នេះ ទើបរាងកាយនេះទៅជាយ៉ាងនេះជាធម្មតា គឺមានសភាពជាវត្ថុពុកផុយយ៉ាងនេះដូចគ្នា ។

បទថា **ឯវំភាវី** សេចក្តីថា កាយនេះនឹងមានសភាពយ៉ាងនេះដូចគ្នា គឺនឹងជាប្រភេទផ្សេងៗ មានរាងកាយដែលហើមប៉ោងជាដើម ។

បទថា **ឯវំ អនតីតោ** សេចក្តីថា មិនកន្លងសភាពយ៉ាងនេះ គឺភាពជារាងកាយដែលហើមប៉ោងជាដើមទៅបានឡើយ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរមានប្រក្រតីពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬក្នុងកាយរបស់អ្នកដទៃ គឺមានប្រក្រតីពិចារណាឃើញកាយរបស់ខ្លួនតាមកាល ឬក្នុងកាយរបស់អ្នកដទៃតាមកាល ដោយអាការយ៉ាងនេះ គឺដោយការកំណត់រាងកាយ មានរាងកាយដែលហើមប៉ោងជាដើម ។

បទថា **ខជ្ជមានំ** សេចក្តីថា សរីរៈដែលត្រូវសត្វទាំងឡាយ មានក្អាត និងក្អែកជាដើមចឹកស៊ី ដោយទំព្រង់អវយវៈ មានពោះជាដើម ហើយចឹកយកសាច់ពោះ សាច់បបូរមាត់ និងក្អែកជាដើមចេញមក ។

បទថា **សមំសលោហិតំ** សេចក្តីថា រាងកាយដែលប្រកបទៅដោយសាច់ និងឈាមដែលហូរជាទិច្ច ។

បទថា **និម្មំសលោហិតមក្ខិតំ** សេចក្តីថា កាលសាច់អស់ទៅហើយ ឈាមក៏មិនទាន់ស្ងួត ព្រះមានព្រះភាគទ្រង់សំដៅយកឈាមនោះ ទើបត្រាស់ថា **លោហិតមក្ខិតំ** ដូច្នេះ ។

បទថា **អញ្ញេន** បានដល់ ដោយទិសាភាគដទៃ ។

បទថា **ហត្ថដ្ឋិកំ** សេចក្តីថា ឆ្អឹងដៃទាំង ៦៤ កំណាត់ ខ្ចាត់ខ្ចាយទៅក្នុងទិសផ្សេងៗ គ្នា ។ សូម្បីឆ្អឹងជើងជាដើម ក៏មានន័យដូចគ្នានេះ ។

បទថា **តេរោវស្សិកានិ** បានដល់ ឆ្អឹងដែលកន្លងមួយឆ្នាំហើយ ។

បទថា **បូតីនិ** សេចក្តីថា ឆ្អឹងដែលនៅកណ្តាលវាល កាលត្រូវខ្យល់ កម្តៅថ្ងៃ និងភ្លៀង ទើបពុកផុយ ឆ្អឹងដែលកន្លងមួយឆ្នាំហើយ មិនទាន់ពុកផុយ តែឆ្អឹងដែលកប់នៅក្នុងដី រមែងនៅបានយូរជាង ។

បទថា **ចុណ្ណកជាតានិ** បានដល់ បែកជាលម្អិតតូចធំ ខ្ចាត់ខ្ចាយទៅ ។

ក្នុងគ្រប់បទ បណ្ឌិតគប្បីបន្ថែមពាក្យប្រកបសេចក្តីដោយអំណាចនៃកាយដែលត្រូវក្អែក និងក្អាតចឹកស៊ីជាដើម តាមន័យដែលពោលទុកហើយថា **សោ ឥមមេវ** ដូច្នេះ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្ដីថា ព្រះយោគាវចរមានប្រក្រតីពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬក្នុងកាយរបស់អ្នកដទៃ គឺមានប្រក្រតីពិចា-រណាឃើញកាយក្នុងកាយរបស់ខ្លួនតាមកាល ឬក្នុងកាយរបស់អ្នកដទៃតាមកាល ដោយអាការយ៉ាងនេះ គឺដោយការកំណត់កាយ មានកាយដែលត្រូវត្មាតក្អែកជាដើមចឹកស៊ីជាដើម រហូតដល់បែកជាលម្អិតតូចធំ ពុកផុយ ដូច្នេះ ។

ស្មសាន ៩ គប្បីប្រមូលទុកក្នុងទីត្រង់នេះ គឺស្មសានទាំងអស់ ដែលត្រាស់ដោយន័យជាដើមថា **ឯកាហមតំ វា** គឺសាកសពដែលស្លាប់ហើយមួយថ្ងៃក្ដី ១ ។

ស្មសានដែលត្រាស់ហើយថា **កាកេហិ វា ខជ្ជមានំ** សាកសពដែលត្រូវពួកក្អែកចឹកស៊ីក្ដី ១ ។

ស្មសានដែលត្រាស់ថា **អដ្ឋិសង្ខលិកំ សមំសលោហិតំ ន្ហារុសម្ពន្ធំ** សាកសពដែលមានតែពង្អឹង មានសាច់ និងឈាម មានសរសៃជាគ្រឿងចង ១ ។

ស្មសានដែលត្រាស់ថា **និម្មំសលោហិតមក្ខិតំ ន្ហារុសម្ពន្ធំ** សាកសពដែលមិនមានសាច់ តែនៅប្រឡាក់ឈាម នៅមានសរសៃជាគ្រឿងចង ១ ។

ស្មសានដែលត្រាស់ថា **អបគតមំសលោហិតំ ន្ហារុសម្ពន្ធំ** សាកសពដែលមិនមានសាច់ និងឈាមជាប់ តែមានសរសៃជាគ្រឿងចង ១ ។

ស្មសានដែលត្រាស់ជាដើមថា **អដ្ឋិកានិ អបគតសម្ពន្ធានិ** ឆ្អឹង ដែលមិនមានសរសៃជាគ្រឿងចង ១ ។

ស្មសានដែលត្រាស់ជាដើមថា **អដ្ឋិកានិ សេតានិ សង្ខវណ្ណបដិ-ភាគានិ** ឆ្អឹងសដូចពណ៌ស័ង្ខ ១ ។

ស្មសានដែលត្រាស់ជាដើមថា **បុញ្ជកិតានិ តេរោវស្សិកានិ** ឆ្អឹងដែលនៅក្នុងគំនរ កន្លងទៅមួយឆ្នាំហើយ ១ ។

ស្មសានដែលត្រាស់ជាដើមថា **បូតីនិ ចុណ្ណកជាតានិ** ឆ្អឹង ដែលបែកជាចម្រៀកតូចធំ ពុកផុយ ១ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងស្មសាន ៩ យ៉ាងទុកក្នុងទីនេះហើយ កាលនឹងចប់កាយានុបស្សនាសតិប្បដ្ឋាន ទើបត្រាស់ថា **ឯវំ ខោ ភិក្ខវេ** ដូច្នេះ ។

សតិជាគ្រឿងកំណត់ស្មសាន ៩ ក្នុងនវសិវថិកាបព្វៈនេះ ជាទុក្ខសច្ចបុរិមតណ្ហាដែលជាមូលឲ្យកើតសតិនោះ ជាសមុទយសច្ច ការមិនប្រព្រឹត្តទៅនៃទុក្ខសច្ច និងសមុទយសច្ចទាំង ២ ជានិរោធសច្ច ។ អរិយមគ្គដែលជាតួកំណត់ដឹងទុក្ខ លះសមុទយសច្ច មាននិរោធ គឺនិព្វានជាអារម្មណ៍ ជាមគ្គសច្ច ។

ព្រះយោគាវចរ រមែងសម្រេចដល់និព្វានដោយអំណាចសច្ចៈ ៤ ដូចពណ៌នាមកនេះ សរុបសេចក្តីថា ជាផ្លូវនៃធម៌ជាគ្រឿងនាំចេញ រហូតដល់អរហត្តរបស់ភិក្ខុដែលកំណត់ស្មសាន ៩ ដូច្នេះ ។

កាយានុបស្សនា ១៤ បព្វៈ គឺអានាបានបព្វៈ ១ ឥរិយាបថបព្វៈ ១ ចតុសម្បជញ្ញបព្វៈ ១ បដិកូលមនសិការបព្វៈ ១ ធាតុមនសិការបព្វៈ ១

នវសិវថិកាបព្វៈ ៩ ឈ្មោះថា ចប់ហើយ ដោយមានពាក្យប្រមាណប៉ុណ្ណេះ ។

បណ្តាបព្វៈទាំងនោះ ២ បព្វៈ គឺអានាបានបព្វៈ ១ បដិកូលមនសិការ-បព្វៈ ១ ជាអប្បនាកម្មដ្ឋាន ឯ ១២ បព្វៈដ៏សេស ជាឧបចារកម្មដ្ឋានប៉ុណ្ណោះ ព្រោះទ្រង់ត្រាស់ស្មសាន ដោយអំណាចអាទីនវានុបស្សនា ដូច្នេះ ។

**អធិប្បាយ នវសីវថិកាបព្វៈ ចប់**

**កាយានុបស្សនា ចប់**

## អធិប្បាយ វេទនានុបស្សនា

[ ១៣៩ ] ព្រះមានព្រះភាគ កាលត្រាស់កាយានុបស្សនាសតិប្បដ្ឋាន ដោយវិធី ១៤ យ៉ាង ដូចពណ៌នាមកនេះហើយ ឥឡូវនេះ ដើម្បីត្រាស់វេទនានុបស្សនា ដោយវិធី ៩ យ៉ាង ទើបត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **សុខំ វេទនំ** អធិប្បាយថា ព្រះយោគាវចរ កាលសោយសុខវេទនាដែលប្រព្រឹត្តទៅតាមកាយ ឬប្រព្រឹត្តទៅតាមផ្លូវចិត្ត រមែងដឹងច្បាស់ថា អញកំពុងសោយសុខវេទនា ដូច្នេះ ។ សេចក្តីនេះ ទោះកូនងាំដែលនៅដេកផ្ងារនៅឡើយ កាលសោយសេចក្តីសុខក្នុងវេលាបៅដោះជាដើម ក៏ដឹងច្បាស់ថា អញកំពុងសោយសុខក៏ពិត តែទោះជាដូច្នោះ ពាក្យនេះ ព្រះមានព្រះភាគមិនបានត្រាស់សំដៅយកការដឹងយ៉ាងនេះ ព្រោះថា ការដឹងបែបនេះ លះសត្តូបលទ្ធិមិនបាន ។ ដកអត្តសញ្ញាមិនបាន មិនជាកម្មដ្ឋាន

ឬមិនជាសតិប្បដ្ឋានភាវនា ។

ឯការដឹងរបស់ភិក្ខុនេះ លះសត្តូបលទ្ធិបាន ដកសត្តសញ្ញាបាន ជាកម្មដ្ឋានផង ជាសតិប្បដ្ឋានភាវនាផង ។ ការដឹងនេះ ព្រះមានព្រះភាគត្រាស់សំដៅយកការសោយ ដោយការដឹងខ្លួនយ៉ាងនេះថា អ្នកណាសោយ ការសោយរបស់អ្នកណា ព្រោះហេតុអ្វី ទើបសោយ ។

បណ្តាបទទាំងនោះ បទថា **កោ វេទយតិ** ប្រែថា អ្នកណាសោយ សេចក្តីថា មិនមែនអ្នកណាសោយ មិនមែនសត្វ ឬបុគ្គលសោយឡើយ ។

បទថា **កស្ស វេទនា** ប្រែថា ការសោយរបស់អ្នកណា សេចក្តីថា មិនមែនការសោយរបស់អ្នកណា មិនមែនការសោយរបស់សត្វ ឬបុគ្គល ។

បទថា **កឹ ការណា វេទនា** ប្រែថា ព្រោះហេតុអ្វី ទើបសោយ សេចក្តីថា ព្រោះមានវត្ថុជាអារម្មណ៍ ទើបបុគ្គលមានការសោយ ។

ព្រោះហេតុនោះ បុគ្គលនោះដឹងច្បាស់យ៉ាងនេះថា វេទនានោះឯងសោយ ដោយធ្វើវត្ថុនៃសេចក្តីសុខជាដើមនោះ ឲ្យជាអារម្មណ៍ ។ តែព្រោះសំដៅយកការប្រព្រឹត្តទៅនៃវេទនានោះ ។ ពាក្យថា **អហំ វេទយាមិ** អញសោយវេទនា ទើបត្រឹមតែជាវោហារប៉ុណ្ណោះ ។

ព្រះយោគាវចរនោះ កាលកំណត់ថា វេទនានោះឯងសោយ ដោយធ្វើវត្ថុឲ្យជាអារម្មណ៍យ៉ាងនេះ អ្នកសិក្សាគប្បីយល់ថា លោកដឹងច្បាស់ថា អញកំពុងសោយសុខវេទនា ។ ដូចព្រះថេរៈមួយអង្គ នៅត្រង់ចិត្តលតាបពិតដូច្នោះ ។

# រឿង ព្រះថេរៈនៅត្រង់ចិត្តលតាបពិត

បានឮថា ព្រះថេរៈ ក្នុងវេលាដែលលោកមិនសប្បាយ ដកដង្ហើមបណ្ដើរ ដេកបម្រះទៅមកបណ្ដើរ ។

ភិក្ខុកំលោះមួយរូបសួរលោកថា លោកម្ចាស់ ទីត្រង់ណារបស់លោកម្ចាស់ ដែលរោគចាក់ដោត ។

ព្រះថេរៈឆ្លើយថា លោកម្ចាស់ ឈ្មោះថា រោគចាក់ដោតត្រង់ទីណាមួយមិនមាន វេទនាឯណោះទេសោយ ដោយធ្វើវត្ថុឲ្យជាអារម្មណ៍ ។

ភិក្ខុកំលោះប្រាប់ថា បើដូច្នោះ លោកម្ចាស់គួរបញ្ឈប់វេទនាដែលដឹងមិនមែនឬ ព្រះថេរៈឆ្លើយថា ខ្ញុំកំពុងបញ្ឈប់ ។ ភិក្ខុកំលោះប្រាប់ថា លោកម្ចាស់ ការបញ្ឈប់ជារបស់ប្រសើរ ។ ព្រះថេរៈបានបញ្ឈប់ហើយ ។

លំដាប់នោះ ខ្យល់បានចាក់ដល់បេះដូង ។ ពោះវៀនបានចេញមកគរនៅលើគ្រែ ព្រះថេរៈបានចង្អុលឲ្យភិក្ខុកំលោះមើលថា បញ្ឈប់បែបនេះ សមគួរឬនៅ ភិក្ខុកំលោះនៅស្ងៀម ព្រះថេរៈប្រកបសេចក្ដីព្យាយាមជានិច្ច ហើយបានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ជាព្រះអរហន្តប្រភេទជីវិត-សមសីសី បរិនិព្វានហើយ ។

កាលព្រះយោគាវចរដឹងច្បាស់ថា សុខយ៉ាងណា ទុក្ខយ៉ាងនោះ ។បេ។ កាលសោយអទុក្ខមសុខវេទនា មិនអាស្រ័យអាមិស ក៏ដឹងច្បាស់ថា អញកំពុងសោយអទុក្ខមសុខវេទនា មិនអាស្រ័យអាមិស ។

ព្រះមានព្រះភាគ កាលត្រាស់ប្រាប់រូបកម្មដ្ឋាន ដោយអាការយ៉ាងនេះហើយ កាលត្រាស់ប្រាប់អរូបកម្មដ្ឋាន ទើបបានត្រាស់ដោយអំណាចនៃវេទនា ។

ព្រោះថា កម្មដ្ឋានមាន ២ យ៉ាង គឺរូបកម្មដ្ឋាន ១ អរូបកម្មដ្ឋាន ១ ។ រូប-កម្មដ្ឋាន និងអរូបកម្មដ្ឋាននេះឯង ទ្រង់ហៅថា រូបបរិគ្គហៈ គឺការកំណត់រូប អរូបបរិគ្គហៈ គឺការកំណត់អរូបក៏មាន ។ បណ្តារូបកម្មដ្ឋាន និងអរូប-កម្មដ្ឋាននោះ ព្រះមានព្រះភាគ កាលត្រាស់រូបកម្មដ្ឋាន ទើបត្រាស់ចតុធាតុ-វវដ្ឋាន គឺការកំណត់ធាតុ ៤ ដោយអំណាចនៃមនសិការដោយសង្ខេបក៏មាន ដោយអំណាចការមនសិការដោយពិស្តារក៏មាន ។ កម្មដ្ឋានទាំង ២ យ៉ាង នោះបានសម្តែងហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ដោយអាការទាំងពួងនោះឯង ។

តែព្រះមានព្រះភាគ កាលត្រាស់អរូបកម្មដ្ឋាន ដោយច្រើន ក៏នឹងត្រាស់ដោយអំណាចនៃវេទនា ។ ព្រោះថា ការផ្តោតចិត្តក្នុងអរូបកម្មដ្ឋាន មាន ៣ យ៉ាង គឺដោយអំណាចនៃផស្សៈ ១ ដោយអំណាចនៃវេទនា ១ ដោយអំណាចនៃចិត្ត ១ ។

សួរថា ផ្តោតដូចម្តេច ឆ្លើយថា ផ្តោតយ៉ាងនេះ ពិតហើយ ផស្សៈ កាលពាល់ត្រូវអារម្មណ៍នោះ ក្នុងខណៈដែលចិត្ត និងចេតសិកធ្លាក់ទៅចំពោះគ្រាដំបូង ក្នុងអារម្មណ៍ប្រាកដដល់ព្រះយោគាវចររូបខ្លះ ក្នុងរូបកម្មដ្ឋានដែលលោកកំណត់ហើយដោយសង្ខេប ឬដោយពិស្តារ ។ វេទនាកាលសោយអារម្មណ៍នោះកើតឡើង នឹងប្រាកដដល់ព្រះយោគាវចររូបខ្លះ វិញ្ញាណកាលកំណត់អារម្មណ៍នោះ គឺដឹង កើតឡើងដល់ព្រះយោគាវចរខ្លះ ។

បណ្តាផស្សៈ វេទនា វិញ្ញាណទាំងនោះ ផស្សៈប្រាកដដល់ព្រះយោគា-វចរណា មិនចំពោះផស្សៈតែម្យ៉ាងនោះនឹងកើតឡើង សូម្បីវេទនាក៏សោយ

អារម្មណ៍នោះឯង ក៏កើតឡើងជាមួយផស្សៈនោះ សូម្បីសញ្ញាដែល ចាំបាន សូម្បីចេតនាដែលតាំងចិត្ត សូម្បីវិញ្ញាណដែលដឹងច្បាស់នូវអារម្មណ៍នោះ ក៏កើតព្រមជាមួយផស្សៈនោះ ព្រោះដូច្នោះ ព្រះយោគាវចរនោះ រមែងកំណត់ចេតសិកធម៌ មានផស្សៈជាគម្រប់ ៥ នោះឯង ។

វេទនាណា ប្រាកដដល់ព្រះយោគាវចរ មិនចំពោះវេទនាតែម្យ៉ាងប៉ុណ្ណោះទេដែលកើតឡើង ផស្សៈដែលពាល់ត្រូវក៏កើតឡើងជាមួយវេទនានោះ សូម្បីសញ្ញាដែលចាំ សូម្បីចេតនាដែលតាំងចិត្ត សូម្បីវិញ្ញាណដែលដឹងច្បាស់ ក៏កើតឡើងជាមួយវេទនានោះ ព្រោះដូច្នោះ ព្រះយោគាវចរនោះ ក៏រមែងកំណត់ចេតសិកធម៌ មានផស្សៈជាគម្រប់ ៥ នោះឯង ។

សូម្បីវិញ្ញាណប្រាកដដល់ព្រះយោគាវចរណា មិនចំពោះតែវិញ្ញាណតែម្យ៉ាងទេដែលកើតឡើង សូម្បីផស្សៈដែលពាល់ត្រូវអារម្មណ៍នោះឯង ក៏កើតឡើងជាមួយវិញ្ញាណនោះ សូម្បីវេទនាដែលសោយ សូម្បីសញ្ញាដែលចាំ សូម្បីចេតនាដែលតាំងចិត្តចំពោះអារម្មណ៍នោះ ក៏កើតឡើងជាមួយវិញ្ញាណនោះ ព្រោះដូច្នោះ ព្រះយោគាវចរនោះ រមែងកំណត់ដឹងចេតសិកធម៌ មានផស្សៈជាគម្រប់ ៥ នោះឯង ។

ព្រះយោគាវចរនោះ កាលពិចារណាថា ធម៌ មានផស្សៈជាគម្រប់ ៥ នេះ នៅអាស្រ័យ ។ នឹងជ្រាបច្បាស់ថា អាស្រ័យវត្ថុ ។

ករជកាយ ឈ្មោះថា **វត្ថុ** ព្រះមានព្រះភាគត្រាស់សំដៅយកវិញ្ញាណរបស់យើងនេះ អាស្រ័យនៅក្នុងករជកាយនេះ ពាក់ព័ន្ធនៅក្នុងករជកាយនេះ ។

ដោយអត្ថ ព្រះយោគាវចរនោះ រមែងឃើញមហាភូតរូបផង ឧបាទា-យរូបផង កាលបើដូច្នេះ ក្នុងវេទនាបព្វៈនេះ ព្រះយោគាវចរឃើញត្រឹមតែនាមរូបប៉ុណ្ណោះថា ជាវត្ថុ ជារូប ចេតសិកធម៌មានផស្សៈជាគម្រប់ ៥ ជានាម ។ ក្នុងសេចក្ដីនេះ រូប បានដល់ រូបក្ខន្ធ នាម បានដល់ អរូបក្ខន្ធ ៤ ព្រោះដូច្នោះ ទើបមានត្រឹមតែបញ្ចក្ខន្ធប៉ុណ្ណោះ ព្រោះថា បញ្ចក្ខន្ធដែលផុតអំពីនាមរូប ឬនាមរូបដែលផុតទៅអំពីបញ្ចក្ខន្ធមិនមាន ។

ព្រះយោគាវចរនោះ កាលពិគ្រោះមើលថា បញ្ចក្ខន្ធទាំងនោះ មានអ្វីជាហេតុ ក៏ឃើញថា មានអវិជ្ជាជាដើមហេតុ ។ បន្ទាប់អំពីនោះ ព្រះយោគា-វចរលើកឡើងនូវបញ្ចក្ខន្ធកាន់ត្រៃលក្ខណ៍ ដោយអំណាចនាមរូប ព្រមទាំងបច្ច័យថា នេះត្រឹមតែបច្ច័យ នេះវត្ថុដែលអាស្រ័យបច្ច័យជាដើម មិនមានអ្វីដទៃដែលជាសត្វ ឬបុគ្គល មានត្រឹមតែគំនរសង្ខារសុទ្ធៗ ប៉ុណ្ណោះ រួចពិចា-រណាពិនិត្យមើល អនិច្ចំ ទុក្ខំ អនត្តា តាមលំដាប់នៃវិបស្សនា ហោករំពឹងបដិវេធថា នឹងបានសម្រេចថ្ងៃនេះ ថ្ងៃនេះ បានឧតុសប្បាយ បុគ្គលសប្បាយ ភោជនសប្បាយ ធម្មស្សវនសប្បាយ អង្គុយពត់ភ្នែនក្នុងឥរិយាបថតែមួយ ញ៉ាំងវិបស្សនាឲ្យដល់ទីបំផុត ហើយតាំងនៅក្នុងអរហត្តមគ្គ ដោយប្រការដូចពោលមកនេះ ឈ្មោះថា ទ្រង់ប្រាប់កម្មដ្ឋានដល់ជនទាំង ៣ នេះ រហូតដល់អរហត្ត ។

តែក្នុងសតិប្បដ្ឋានសូត្រនេះ ព្រះមានព្រះភាគ កាលត្រាស់ប្រាប់អរូប-កម្មដ្ឋាន ទើបត្រាស់ដោយអំណាចនៃវេទនា ។ ព្រោះថា កាលត្រាស់ដោយ

អំណាចនៃផស្សៈ ឬដោយអំណាចនៃវិញ្ញាណ កម្មដ្ឋានទឹងមិនប្រាកដ នឹងប្រាកដដូចការងងឹត ។ ឯដែលត្រាស់ប្រាប់ដោយអំណាចនៃវេទនា កម្មដ្ឋាននឹងប្រាកដ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះកម្មដ្ឋានប្រាកដ ក៏ព្រោះវេទនាកើតឡើង ។

ពិតហើយ ការកើតឡើងនៃសុខវេទនា និងទុក្ខវេទនា នឹងប្រាកដចំពោះកាលសេចក្តីសុខកើតឡើង បានដល់ សេចក្តីសុខដែលកើតឡើងធ្វើឲ្យញាប់ញ័រទូទៅពេញរាងកាយ ហូរជន់រហូតលិចលង់ហទយៈ ដូចការបានផឹកសប្បិរាប់រយដង ដូចឲ្យលាបប្រេងដែលរម្ងាស់ហើយរាប់រយដង និងដូចឲ្យរលត់ការក្តៅក្រហាយ ដោយទឹក ១០០០ ក្អម ធ្វើឲ្យបន្លឺវាចាថា សុខហ្ន៎ សុខហ្ន៎ដូច្នេះនោះឯង ហើយកាលសេចក្តីទុក្ខកើតឡើង បានដល់ សេចក្តីទុក្ខដែលកើតឡើង ធ្វើឲ្យញាប់ញ័រពេញរាងកាយ ជ្រួតជ្រាបទៅរហូតដល់ហទយៈដូចឲ្យចូលទៅកាន់អណ្តាតភ្លើងដ៏ប្រាលឆ្អៅ ដូចត្រូវស្រោចដោយទឹកទង់ដែងដែលរលាយដ៏ក្តៅ និងដូចបោះគប់ភ្លើងចូលទៅកាន់ព្រៃ ដែលមានស្មៅស្ងួតនិងដើមឈើងាប់ ហាក់ដូចជាឲ្យស្រែកឡើងថា ទុក្ខពិត ទុក្ខពិត ។ ការកើតឡើងនៃសុខវេទនា និងទុក្ខវេទនា ប្រាកដឡើងបានដោយអាការយ៉ាងនេះ ។

ឯអទុក្ខមសុខវេទនា សម្តែងឲ្យឃើញបានលំបាក ងងឹតងងល់ មិនជាក់ច្បាស់ ។ អទុក្ខមសុខវេទនានោះ នឹងប្រាកដដល់ព្រះយោគាវចរដែលប្រកាន់ដោយន័យថា អទុក្ខមសុខវេទនា មានអាការជាកណ្តាល ដោយការបោល

នូវការផាសុក និងមិនស្រាកស្រាន្ត ក្នុងកាលសុខ និងទុក្ខអស់ទៅ ។

សួរថា ប្រៀបដូចអ្វី ឆ្លើយថា ប្រៀបដូចនាយព្រានម្រឹគតាមស្នាមជើងម្រឹគ ដែលលោតឡើងលើថ្មក្នុងចន្លោះផ្លូវ ហើយគេចទៅបាន ព្រានឃើញស្នាមជើងទាំងខាងនេះ ទាំងខាងនោះរបស់ដុំថ្ម តែមិនឃើញស្នាមជើងត្រង់កណ្តាល ក៏ដឹងបានដោយន័យថា ម្រឹគនេះឡើងតាមនេះ ហើយចុះទៅតាមនោះ គង់នឹងឆ្លងទៅផ្លូវនេះ លើដុំថ្មត្រង់កណ្តាលយ៉ាងណា ការកើតឡើងនៃសុខវេទនា ក៏ដូច្នោះ ប្រាកដដូចស្នាមជើងរបស់ម្រឹគ ប្រាកដក្នុងទីដែលវាឡើងទៅ ការកើតឡើងនៃទុក្ខវេទនា នឹងប្រាកដដូចស្នាមជើងរបស់ម្រឹគ ក្នុងទីដែលវាចុះហើយ ដូច្នោះ ។ អទុក្ខមសុខវេទនា នឹងប្រាកដដល់ព្រះយោគាវចរដែលប្រកាន់ដោយន័យថា អទុក្ខមសុខវេទនា មានអាការជាកណ្តាល ដោយលះនូវផាសុក និងការមិនសុខ ក្នុងកាលសុខ និងទុក្ខបាត់ទៅ ដូចការប្រកាន់ដោយន័យថា ឆ្លងទៅត្រង់កណ្តាលនេះឯង ដោយឡើងតាមផ្លូវខាងនេះហើយ ចុះតាមផ្លូវខាងនោះ ដូច្នោះ ព្រះមានព្រះភាគ ទ្រង់បានសម្តែងសតិប្បដ្ឋាន ដោយត្រាស់រូបកម្មដ្ឋានមុន ហើយញ៉ាំងអរូបកម្មដ្ឋានឲ្យកើតឡើង ដោយអំណាចនៃវេទនាខាងក្រោយ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងទុកយ៉ាងនេះ ចំពោះក្នុងសតិប្បដ្ឋានសូត្រនេះមួយកន្លែងក៏ទេ ទ្រង់បានសម្តែងដោយត្រាស់រូបកម្មដ្ឋានមុន ហើយញ៉ាំងអរូបកម្មដ្ឋានឲ្យកើតឡើង ដោយអំណាចវេទនាខាងក្រោយ ក្នុងព្រះសូត្រច្រើនសូត្រ ច្រើនកន្លែងយ៉ាងនេះ គឺ ក្នុងចូឡតណ្ហាសង្ខយសូត្រ ក្នុង

មហាតណ្ហាសង្ខេយសូត្រ ក្នុងចូឡវេទល្លសូត្រ ក្នុងមហាវេទល្លសូត្រ ក្នុងរដ្ឋបាលសូត្រ ក្នុងមាគណ្ឌិយសូត្រ ក្នុងធាតុវិភង្គសូត្រ ក្នុងអានេញ្ជសប្បាយ-សូត្រ ក្នុងមហានិទានសូត្រ ក្នុងសក្កបញ្ហសូត្រ ក្នុងមហាសតិប្បដ្ឋានសូត្រ ក្នុងទីឃនិកាយ ក្នុងចូឡនិទានសូត្រ ក្នុងរុក្ខូបមសូត្រ ក្នុងបរិវីមង្សនសូត្រ និងក្នុងវេទនាសំយុត្តទាំងអស់ ក្នុងសំយុត្តនិកាយ និងសតិប្បដ្ឋានសូត្រនេះ ទើបព្រះមានព្រះភាគ ទ្រង់សម្តែងដោយត្រាស់ប្រាប់រូបកម្មដ្ឋានមុនហើយ ទើបទ្រង់ញ៉ាំងអរូបកម្មដ្ឋានឲ្យកើតឡើង ដោយអំណាចនៃវេទនាជាក្រោយ ដូចក្នុងព្រះសូត្រទាំងនោះ ។

បណ្តាពាក្យទាំងនោះ មានបរិយាយនៃការដឹងច្បាស់ គឺវេទនាម្យ៉ាងទៀតដូច្នេះ ពាក្យថា **សុខំ វេទនំ វេទិយាមីតិ បជានាតិ** សេចក្តីថា ព្រោះមិនមានទុក្ខវេទនាក្នុងខណៈនៃសុខវេទនា ព្រះយោគាវចរ កាលសោយសុខវេទនា ក៏ដឹងច្បាស់ថា អញកំពុងសោយសុខវេទនា វេទនាឈ្មោះថា មិនទៀង មិនស្ថិតស្ថេរ មានការប្រែប្រួលជាធម្មតា ព្រោះទុក្ខវេទនាដែលធ្លាប់សោយមកអំពីមុន ក្នុងឥឡូវនេះមិនមានហើយ និងព្រោះសុខវេទនានេះពីមុននេះ ក៏មិនមាន ព្រោះដូច្នោះ ទើបព្រះយោគាវចរ ឈ្មោះថា ដឹងច្បាស់ក្នុងសុខវេទនា និងទុក្ខវេទនានោះ ដូចពណ៌នាមកដូច្នេះ ដោយពាក្យថា **សុខំ វេទនំ វេទិយាមីតិ បជានាតិ** នោះ ។

សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលអគ្គិវេស្សនៈ សម័យណាបុគ្គលទទួលសុខវេទនា សម័យនោះ មិនទទួលទុក្ខវេទនា មិនទទួលអទុក្ខ-

មសុខវេទនាទេ ក្នុងសម័យនោះ ទទួលចំពោះតែសុខវេទនា ។ ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលទុក្ខវេទនា ។បេ។ សម័យណា បុគ្គលទទួលអទុក្ខមសុខវេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលទុក្ខវេទនាទេ សម័យនោះ ទទួលចំពោះតែអទុក្ខមសុខវេទនា ។ ម្នាលអគ្គិវេស្សនៈ សុខវេទនាជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែងកើតឡើងហើយ មានកិរិយាអស់ទៅ និងសូន្យទៅជាធម្មតា មានកិរិយាក្ស័យទៅទាំងមានកិរិយារលត់ទៅវិញជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ ទុក្ខវេទនា ។បេ។ ម្នាលអគ្គិវេស្សនៈ សូម្បីអទុក្ខមសុខវេទនាក៏ជារបស់មិនទៀង ។បេ។ មានកិរិយាក្ស័យទៅ និងរលត់ទៅជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ អរិយសាវកអ្នកបានស្តាប់ហើយ កាលឃើញយ៉ាងនេះ រមែងនឿយណាយចាកសុខវេទនាផង នឿយណាយចាកទុក្ខវេទនាផង នឿយណាយចាកអទុក្ខមសុខវេទនាផង កាលបើនឿយណាយហើយ រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តរមែងរួចចាកកិលេស កាលចិត្តរួចចាកកិលេសហើយ ញាណក៏កើតឡើងច្បាស់ថា ចិត្តរួចស្រឡះហើយ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ បាននៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើរួចស្រេចហើយ កិច្ចដទៃក្រៅពីនេះ មិនមានឡើយ ។

ក្នុងពាក្យថា **សាមិសំ វា សុខំ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

សោមនស្សវេទនាដែលអាស្រ័យផ្ទះ ៦ យ៉ាង លាយដោយអាមិស គឺបញ្ចកាមគុណ ឈ្មោះថា **សាមិសសុខវេទនា** ។

សោមនស្សវេទនាដែលអាស្រ័យនេក្ខម្មៈ ៦ យ៉ាង ឈ្មោះថា **និរាមិសសុខវេទនា** ។

ទោមនស្សវេទនាដែលអាស្រ័យផ្ទះ ៦ យ៉ាង ឈ្មោះថា **សាមិសទុក្ខវេទនា** ទោមនស្សវេទនាដែលអាស្រ័យនេក្ខម្មៈ ៦ យ៉ាង ឈ្មោះថា **និរាមិសទុក្ខវេទនា** ។

ឧបេក្ខាវេទនាដែលអាស្រ័យផ្ទះ ៦ យ៉ាង ឈ្មោះថា **សាមិសអទុក្ខមសុខវេទនា** ។

ឧបេក្ខាវេទនាដែលអាស្រ័យនេក្ខម្មៈ ៦ យ៉ាង ឈ្មោះថា **និរាមិសអទុក្ខមសុខវេទនា** ការបែកវេទនាទាំងនោះ មកច្បាស់ហើយ ក្នុងព្រះបាលីក្នុងឧបរិបណ្ណាសកៈ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរ មានប្រក្រតីពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយរបស់ខ្លួន ឬក្នុងវេទនាទាំងឡាយរបស់អ្នកដទៃ គឺក្នុងវេទនាទាំងឡាយរបស់ខ្លួនតាមកាល ឬក្នុងវេទនាទាំងឡាយរបស់អ្នកដទៃតាមកាល ។

ក្នុងបទថា **សមុទយវយធម្មានុបស្សី វា** នេះ គប្បីជ្រាបថា ព្រះយោគាវចរកាលឃើញការកើតឡើង និងការវិនាសទៅរបស់វេទនាទាំងឡាយដោយអាការ ៥ មានអវិជ្ជាកើត ទើបវេទនាកើតជាដើម ឈ្មោះថា មានប្រក្រតីពិចារណាឃើញធម៌ គឺការកើតឡើងក្នុងវេទនាទាំងឡាយ ឬមានប្រក្រតីពិចារណាឃើញធម៌ គឺការវិនាសក្នុងវេទនាទាំងឡាយ គឺមានប្រក្រតី

ពិចារណាឃើញធម៌ គឺការកើតឡើងក្នុងវេទនាទាំងឡាយតាមកាល ឬមានប្រក្រតីពិចារណាឃើញធម៌ គឺការវិនាស ក្នុងវេទនាទាំងឡាយតាមកាល ។ ពាក្យក្រៅអំពីនេះ មានន័យដូចពោលហើយ ក្នុងកាយានុបស្សនានោះឯង ។

សតិជាគ្រឿងកំណត់វេទនាក្នុងវេទនានុបស្សនានេះ ជាទុក្ខសច្ចៈតែម្យ៉ាង បណ្ឌិតគប្បីជ្រាបគន្លងនៃធម៌ជាគ្រឿងនាំចេញរបស់ភិក្ខុ ដែលកំណត់វេទនា ព្រោះអធិប្បាយប្រកបសេចក្តីដូចពោលមកនេះឯង ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យដែលពោលមកនោះឯង ។

**អធិប្បាយ វេទនានុបស្សនា ចប់**

## អធិប្បាយ ចិត្តានុបស្សនា

[ ១៤០ ] ព្រះមានព្រះភាគ កាលត្រាស់សតិប្បដ្ឋាន គឺវេទនានុបស្សនាដោយអាការ ៩ យ៉ាង យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីត្រាស់ចិត្តានុបស្សនា ដោយអាការ ១៦ យ៉ាង ទើបត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សរាគំ** បានដល់ ចិត្តដែលសហគតៈដោយលោភៈ ៨ យ៉ាង ។

បទថា **វីតរាគំ** បានដល់ កុសលចិត្ត ដែលជាលោកិយ និងអព្យាកតចិត្ត ។ ចិត្តដែលប្រាសចាករាគៈ ក្នុងចិត្តានុបស្សនានេះ មិនបានសំដៅដល់លោកុត្តរចិត្តសូម្បីតែមួយបទឡើយ ព្រោះការពិចារណា មិនមែនជាការប្រជុំធម៌ ចំណែកអកុសលចិត្ត ៤ ដួងដ៏សេស មិនចាត់ចូលក្នុងបទដំបូង និង

មិនចាត់ចូលក្នុងបទក្រោយឡើយ ។ បទថា **សទោសំ** បានដល់ ចិត្តដែលសហគតៈដោយទោមនស្ស ២ ដួង ។ បទថា **វីតទោសំ** បានដល់ កុសល-ចិត្តខាងលោកិយ និងអព្យាកតចិត្ត ។

អកុសលចិត្តដ៏សេស ១០ ដួង មិនចាត់ចូលក្នុងបទដំបូង និងមិនចាត់ចូលក្នុងបទក្រោយឡើយ ។ បទថា **សមោហំ** បានដល់ អកុសលចិត្ត ២ ដួង គឺអកុសលចិត្តដែលសហគតៈដោយវិចិកិច្ឆា ១ ដួង អកុសលចិត្តដែលសហគតៈដោយឧទ្ធច្ចៈ ១ ដួង ។

ព្រោះមោហៈរមែងកើតឡើងក្នុងអកុសលចិត្តគ្រប់ដួង ដូច្នោះ អកុសលចិត្តទាំងអស់នោះ ទើបសមគួរ គឺរាប់ចូលក្នុងចិត្តានុបស្សនានេះដោយពិតនោះឯង ។ ពិតហើយ ក្នុងចិត្តដែលជាគូគ្នានេះឯង លោកចាត់អកុសលចិត្ត ១២ ដួងចូលទុកហើយ ដូច្នេះ ។

បទថា **វីតមោហំ** បានដល់ កុសលចិត្តខាងលោកិយ និងអព្យាកត-ចិត្ត ។ បទថា **សង្ខិត្តំ** បានដល់ ចិត្តដែលធ្លាក់ទៅតាមថីនមិទ្ធៈ ចិត្តដែលធ្លាក់ទៅតាមថីនមិទ្ធៈនោះ ឈ្មោះថា ចិត្តរួញរា ។ បទថា **វិក្ខិត្តំ** បានដល់ ចិត្តដែលសហគតៈដោយឧទ្ធច្ចៈ ចិត្តដែលសហគតៈដោយឧទ្ធច្ចៈនោះ ឈ្មោះថា ចិត្តរាយមាយ ។ បទថា **មហគ្គតំ** បានដល់ រូបាវចរចិត្ត និងអរូបា-វចរចិត្ត ។ បទថា **អមហគ្គតំ** បានដល់ កាមាវចរចិត្ត ។ បទថា **សឧត្តរំ** បានដល់ កាមាវចរចិត្ត ។ បទថា **អនុត្តរំ** បានដល់ រូបាវចរចិត្ត និងអរូបាវចរចិត្ត ។

ម្យ៉ាងទៀត ក្នុងបទទាំង ២ គឺ **សឧត្តរំ អនុត្តរំ** នោះ **សឧត្តរចិត្ត** បានដល់ រូបាវចរចិត្ត **អនុត្តរចិត្ត** បានដល់ អរូបាវចរចិត្តនោះឯង ។

បទថា **សមាហិតំ** បានដល់ ចិត្តដែលមានអប្បនាសមាធិ ឬឧបចារសមាធិ ។ បទថា **អសមាហិតំ** បានដល់ ចិត្តដែលមិនមានសមាធិទាំង ២ ។ បទថា **វិមុត្តំ** បានដល់ ចិត្តដែលរួចផុតហើយដោយតទង្គវិមុត្តិ និងវិក្ខម្ភនវិមុត្តិ ។ បទថា **អវិមុត្តំ** បានដល់ ចិត្តដែលមិនមានវិមុត្តិទាំង ២ ។

ឯសមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និងនិស្សរណវិមុត្តិ មិនមានឱកាស គឺមិនបានពោលដល់ក្នុងចិត្តានុបស្សនានេះឡើយ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរ កាលកំណត់ចិត្ត ដែលប្រព្រឹត្តទៅគ្រប់ខណៈ ដោយការកំណត់ចិត្ត មានសរាគចិត្តជាដើមយ៉ាងនេះ ឈ្មោះថា មានប្រក្រតីតាមឃើញចិត្តក្នុងចិត្តរបស់ខ្លួន ឬក្នុងចិត្តរបស់អ្នកដទៃ ឈ្មោះថា មានប្រក្រតីតាមឃើញចិត្តក្នុងចិត្តរបស់ខ្លួនតាមកាល ឬក្នុងចិត្តរបស់បុគ្គលដទៃតាមកាល ។

ឯក្នុងបទថា **សមុទយវយធម្មានុបស្សី** គឺមានការតាមឃើញធម៌ គឺការកើតឡើង និងការវិនាសទៅ នេះគួរពង្រីកការកើត និងការរលត់នៃវិញ្ញាណ មួយចេញជា ៥ អាការយ៉ាងនេះ គឺព្រោះអវិជ្ជាកើត ទើបវិញ្ញាណកើត ជាដើម ។ ពាក្យក្រៅអំពីនេះ មានន័យដូចពោលហើយនោះឯង ។

សតិជាគ្រឿងកំណត់ចិត្ត ក្នុងចិត្តានុបស្សនានេះ ជាទុក្ខសច្ចៈតែម្យ៉ាង បណ្ឌិតគប្បីជ្រាបគន្លងធម៌ ដែលជាគ្រឿងនាំចេញរបស់ភិក្ខុដែលកំណត់ចិត្ត

តាមដែលបានអធិប្បាយមកយ៉ាងនេះឯង ។ ពាក្យដ៏សេស មានអត្ថដូចបានពោលមកហើយនោះឯង ។

អធិប្បាយ ចិត្តានុបស្សនា ចប់

# អធិប្បាយ ធម្មានុបស្សនា

[ ១៤១ ] កាលត្រាស់ចិត្តានុបស្សនាសតិប្បដ្ឋាន ដោយអាការ ១៦ យ៉ាង ដូចពណ៌នាមកនេះ ឥឡូវនេះ ដើម្បីទ្រង់សម្តែងធម្មានុបស្សនា ដោយអាការ ៥ យ៉ាង ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ** ដូច្នេះជាដើម ។

មួយវិញទៀត ព្រះមានព្រះភាគ ត្រាស់ការកំណត់រូបសុទ្ធៗ ដោយកាយានុបស្សនា ត្រាស់ការកំណត់នាមសុទ្ធៗ ដោយវេទនានុបស្សនា និងចិត្តានុបស្សនា ឥឡូវនេះ ដើម្បីកំណត់ទាំងរូប និងនាមរួមគ្នា ទើបត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ** ដូច្នេះជាដើម ។

មួយវិញទៀត ព្រះមានព្រះភាគត្រាស់ការកំណត់រូបក្ខន្ធ ដោយកាយានុបស្សនា ត្រាស់ការកំណត់វេទនាខន្ធ ដោយវេទនានុបស្សនា ត្រាស់ការកំណត់វិញ្ញាណក្ខន្ធ ដោយចិត្តានុបស្សនា ។ ឥឡូវនេះ ដើម្បីត្រាស់ការកំណត់វិញ្ញាណក្ខន្ធ និងសង្ខារក្ខន្ធ ទើបត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ** ដូច្នេះជាដើម ។

# នីវរណបព្វៈ

បណ្តាបទទាំងនោះ បទថា **សន្តំ** បានដល់ មាន ដោយការកើតឡើងរឿយៗ ។ បទថា **អសន្តំ** បានដល់ មិនមាន ដោយការមិនកើតឡើង ឬមិនមាន ព្រោះលះបានហើយ ។ បទថា **យថា ច** សេចក្តីថា កាមច្ឆន្ទៈរមែងកើតឡើងបានដោយហេតុណា ។ បទថា **តញ្ច បជានាតិ** បានដល់ រមែងដឹងហេតុនោះផង ។ គប្បីជ្រាប អធិប្បាយក្នុងបទទាំងអស់ដោយន័យនេះ ។

ក្នុងបទថា **យថា ច** ជាដើមនោះ គប្បីជ្រាបវិនិច្ឆ័យថា

កាមច្ឆន្ទៈរមែងកើតឡើង ព្រោះការធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយក្នុងសុភនិមិត្ត ។ ដែលឈ្មោះថា សុភនិមិត្ត បានដល់ សុភនិមិត្តដែលស្អាតខ្លះ សុភនិមិត្តដែលមានអារម្មណ៍ស្អាតខ្លះ ដែលឈ្មោះថា ការធ្វើទុកក្នុងចិត្តដោយអយោនិសោមនសិការ បានដល់ ធ្វើទុកក្នុងចិត្តដោយមិនជាឧបាយ ការធ្វើទុកក្នុងចិត្តដោយមិនត្រូវផ្លូវ គឺការធ្វើទុកក្នុងចិត្តក្នុងវត្ថុដែលមិនទៀង ថាទៀងខ្លះ ក្នុងវត្ថុដែលជាទុក្ខ ថាសុខខ្លះ ក្នុងវត្ថុដែលជាអនត្តា ថាជាអត្តាខ្លះ ក្នុងវត្ថុដែលមិនស្អាត ថាស្អាតខ្លះ កាលព្រះយោគាវចរញ៉ាំងការធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយនោះឲ្យប្រព្រឹត្តទៅក្នុងសុភនិមិត្តនោះច្រើនដង កាមច្ឆន្ទៈរមែងកើតឡើង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត សុភនិមិត្ត ការធ្វើទុកក្នុងចិត្តដោយអយោនិ-សោមនសិការ និងការធ្វើច្រើនដងក្នុងសុភនិមិត្តនោះ នេះជាអាហារ ( បច្ច័យ ) ឲ្យកាមច្ឆន្ទៈដែលមិនទាន់កើត កើតឡើងខ្លះ ឲ្យកាមច្ឆន្ទៈដែលកើតឡើងហើយ បរិបូណ៌ក្រៃលែងឡើងខ្លះ ។

ឯក្នុងអសុភនិមិត្ត ការលះរមែងមាន ដោយការធ្វើទុកក្នុងចិត្ត ដោយឧបាយ ដែលឈ្មោះថា **អសុភនិមិត្ត** បានដល់ អសុភនិមិត្តដែលមិនស្អាតខ្លះ អសុភនិមិត្តដែលមានអារម្មណ៍មិនស្អាតខ្លះ ដែលឈ្មោះថា ការធ្វើទុកក្នុងចិត្តដោយឧបាយ បានដល់ ការធ្វើទុកក្នុងចិត្តដោយឧបាយ ការធ្វើទុកក្នុងចិត្តដោយត្រូវផ្លូវ គឺការធ្វើទុកក្នុងចិត្តក្នុងវត្ថុដែលមិនទៀង ថាមិនទៀងខ្លះ ក្នុងវត្ថុដែលជាទុក្ខ ថាជាទុក្ខខ្លះ ក្នុងវត្ថុដែលជាអនត្តា ថាជាអនត្តាខ្លះ ក្នុងវត្ថុដែលមិនស្អាត ថាមិនស្អាតខ្លះ កាលព្រះយោគាវចរញ៉ាំងការធ្វើទុកក្នុងចិត្ត ដោយឲ្យយោនិសោមនសិការប្រព្រឹត្តទៅក្នុងអសុភនិមិត្តនោះច្រើនដង ក៏រមែងលះកាមច្ឆន្ទៈបាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ មានតែអសុភនិមិត្ត និងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងអសុភនិមិត្តនោះ នេះធម៌ដែលមិនមែនជាអាហារ របស់កាមច្ឆន្ទៈដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់កាមច្ឆន្ទៈ ដែលកើតហើយ ឲ្យរីងរឹតតែកើតច្រើនឡើង ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ គឺការរៀនយកនូវអសុភនិមិត្ត ១ ការបំពេញអសុភភាវនា ១ ភាពជាអ្នកគ្រប់គ្រងទ្វារទុកបាន ក្នុងឥន្ទ្រិយទាំងឡាយ ១ ភាពជាអ្នកស្គាល់ប្រមាណក្នុងភោជន ១ ភាពជាអ្នកមានកល្យាណមិត្ត ១ សន្ទនារឿងដែលជាសប្បាយ ១ ។

កាលព្រះយោគាវចររៀនយកនូវអសុភនិមិត្ត ១០ យ៉ាងក្នុងរវាងនេះ កាមច្ឆន្ទៈ ឈ្មោះថា លោកលះបង់បាន កាលលោកចម្រើនអសុភនិមិត្តក្តី រក្សា

ទ្វារក្នុងឥន្ទ្រិយទាំងឡាយក្តី ស្គាល់ប្រមាណក្នុងភោជន ដោយមានឱកាសអាចឆាន់បាន ៤-៥ ពំនូតទៀត លោកក៏ឈប់ ហើយផឹកទឹកជំនួសជាប្រចាំក្តី កាមច្ឆន្ទៈ ឈ្មោះថា លោកលះបង់បាន ដោយហេតុនោះ ទើបលោកពោលគាថាពន្ធនេះថា

នៅសល់ ៤-៥ ម៉ាត់ទៀតនឹងឆ្អែត ព្រះយោគាវចរកុំឆាន់ គួរផឹកទឹកជំនួស ព្រោះថា អាហារមានប្រមាណប៉ុណ្ណោះ ក៏គ្រប់គ្រាន់ល្មម ដែលនឹងនៅយ៉ាងផាសុក សម្រាប់ភិក្ខុ មានខ្លួនដែលបញ្ជូនទៅហើយ ។

កាលព្រះយោគាវចរសេពគប់កល្យាណមិត្ត ដែលជាអ្នកត្រេកអរ ក្នុងអសុភភាវនា ដូចព្រះតិស្សត្ថេរអ្នកចម្រើនអសុភកម្មដ្ឋាន កាមច្ឆន្ទៈដែលលោកលះបាន លោករមែងលះកាមច្ឆន្ទៈបាន ដោយការសន្ទនាដល់ទីដែលជាសប្បាយ ដែលអាស្រ័យអសុភ ១០ ក្នុងឥរិយាបថទាំងឡាយ មានឥរិយាបថឈរ និងអង្គុយជាដើម ។ ដោយហេតុនោះ ទើបលោកពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ ។ ព្រះយោគាវចររមែងដឹងច្បាស់ថា កាមច្ឆន្ទៈដែលលះបានហើយ ដោយធម៌ ៦ ប្រការនេះ រមែងកើតឡើងមិនបានតទៅទៀត ដោយអរហត្តមគ្គ ។

មយ៉ាងទៀត ព្រោះការធ្វើទុកក្នុងចិត្តដោយអយោនិសោមនសិការ ក្នុងបដិឃនិមិត្ត ព្យាបាទរមែងកើតឡើងបាន ។ ក្នុងបដិឃនិមិត្តនោះ បានដល់បដិឃនិមិត្តដែលជាបដិឃៈក្តី បដិឃនិមិត្តដែលមានបដិឃៈជាអារម្មណ៍ក្តី ។ ការធ្វើទុកក្នុងចិត្តដោយមិនមែនឧបាយ មានលក្ខណៈដូចគ្នាក្នុងទីគ្រប់អន្លើ

នោះឯង ។ កាលព្រះយោគាវចរញ៉ាំងការធ្វើទុកក្នុងចិត្ត ដោយមិនមែនឧបាយនោះ ឲ្យប្រព្រឹត្តទៅក្នុងនិមិត្តនោះច្រើនដង ព្យាបាទរមែងកើតឡើងបាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មានតែបដិឃនិមិត្ត និងការធ្វើនូវអយោនិសោមនសិការឲ្យច្រើន ក្នុងបដិឃ-និមិត្តនោះ នេះធម៌ជាអាហារ របស់ព្យាបាទដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ព្យាបាទដែលកើតឡើងហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ។ ម្នាលភិក្ខុទាំងឡាយ មានតែចេតោវិមុត្តិ និងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងមេត្តាចេតោវិមុត្តិនោះ នេះធម៌ដែលមិនមែនជាអាហាររបស់ព្យាបាទ ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ព្យាបាទដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ។

ក្នុងមេត្តាចេតោវិមុត្តិនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ កាលព្រះមានព្រះភាគត្រាស់ថា មេត្តា គួរបំពោះអប្បនាសមាធិផង ឧបចារសមាធិផង កាលត្រាស់ថា ចេតោវិមុត្តិ គួរបំពោះអប្បនាតែម្យ៉ាង ការធ្វើមេត្តាចេតោវិមុត្តិទុកក្នុងចិត្តដោយយោនិសោមនសិការ មានលក្ខណៈដូចពោលមកហើយនោះឯង កាលព្រះយោគាវចរ ញ៉ាំងការធ្វើទុកក្នុងចិត្តដោយឧបាយនោះ ឲ្យប្រព្រឹត្តទៅក្នុងមេត្តាចេតោវិមុត្តិនោះច្រើនដង លោកក៏រមែងលះព្យាបាទបាន ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មានតែមេត្តាចេតោវិមុត្តិនិងការធ្វើនូវយោនិសោមនសិការឲ្យច្រើនក្នុងមេត្តាចេតោ-វិមុត្តិនោះ នេះធម៌ដែលមិនមែនជាអាហាររបស់ព្យាបាទដែលមិនទាន់កើតឲ្យកើត

ឡើងបាន ឬរបស់ព្យាបាទដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះព្យាបាទ គឺការរៀនយកនូវមេត្តាវិមុត្តិ ១ ការបំពេញមេត្តាភាវនា ១ ការពិចារណាថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន ១ ភាពជាអ្នកច្រើនដោយការពិចារណា ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ការសន្ទនាជល់រឿងដែលជាសប្បាយ ១ ។

អធិប្បាយថា កាលព្រះយោគាវចររៀនយកនូវមេត្តា ដោយអំណាចការផ្សាយទៅចំពោះទិស និងមិនចំពោះទិសណាមួយ ព្យាបាទរបស់លោករមែងលះបាន ។

កាលព្រះយោគាវចរចម្រើនមេត្តា ផ្សាយទៅកាន់ទិសដោយចំពោះព្យាបាទ ឈ្មោះថា លោកលះបង់បានហើយ ។

កាលព្រះយោគាវចរពិចារណាឃើញថា ខ្លួន និងអ្នកដទៃ មានកម្មជារបស់ខ្លួន យ៉ាងនេះថា អ្នកក្រោធនឹងអ្នកដទៃហើយ នឹងធ្វើអ្វីបាន អ្នកនឹងអាចធ្វើគុណធម៌ មានសីលជាដើមរបស់បុគ្គលនោះឲ្យវិនាសបានឬ អ្នកមកតាមកម្មរបស់ខ្លួនហើយ ក៏នឹងទៅតាមកម្មរបស់ខ្លួននោះឯង មិនមែនឬ ឈ្មោះថា ការក្រោធអ្នកដទៃ ដូចគ្នានឹងបុគ្គលស្រវាយករងើកភ្លើងដែលប្រាសចាកអណ្តាត លំពែងដែកដ៏ក្តៅ និងលាមកជាដើម គ្រវែងបុគ្គលដទៃ សូម្បីបុគ្គលក្រោធហើយក៏នឹងធ្វើអ្វីឲ្យបាន បុគ្គលនោះនឹងអាចឲ្យគុណធម៌ មានសីលជាដើមរបស់អ្នកវិនាសបានឬ បុគ្គលមកតាមកម្មរបស់ខ្លួន ក៏នឹងទៅតាមកម្មរបស់ខ្លួនដូចគ្នា ការក្រោធនោះ ក៏នឹងធ្លាក់ស្រោចក្បាលបុគ្គលនោះ

ឯង ដូចរបស់ដែលបញ្ជូនទៅ មិនមានអ្នកណាទទួល ក៏នឹងត្រឡប់មកកាន់អ្នកបញ្ជូន និងដូចក្តាប់ធូលីបាចទៅច្រាសខ្យល់ ដូច្នោះឯង ពិចារណាឃើញថា ខ្លួនឯងក្តី អ្នកដទៃក្តី មានកម្មជារបស់ខ្លួន និងតាំងនៅក្នុងការពិចារណា សេពគប់កល្យាណមិត្ត ត្រេកអរក្នុងមេត្តាភាវនា ដូចព្រះអស្សគុត្តត្ថេរ ព្យាបាទ ឈ្មោះថា លោកលេះបង់បាន ។

លោករមែងលះបង់ព្យាបាទបាន ដោយការសន្ទនាដល់វត្ថុ ដែលជាសប្បាយ ទាក់ទងដោយមេត្តាក្នុងឥរិយាបថទាំងឡាយ មានឥរិយាបថឈរ និងអង្គុយជាដើម ។

ព្រះយោគាវចរ រមែងដឹងច្បាស់ថា ព្យាបាទដែលលះបានហើយ ដោយធម៌ ៦ ប្រការនេះ នឹងកើតឡើងមិនបានតទៅ ដោយអនាគាមិមគ្គ ។

ព្រោះធ្វើទុកក្នុងចិត្ត ដោយអយោនិសោមនសិការក្នុងធម៌ទាំងឡាយ ថីនមិទ្ធៈរមែងកើតឡើងបាន ។ ដែលឈ្មោះថា **អរតិ** បានដល់ ភាពជាអ្នកមិនត្រេកអរ ។ ដែលឈ្មោះថា **តន្ទិ** បានដល់ ភាពជាអ្នកខ្ជិល ។ ដែលឈ្មោះថា **វិជម្ភិកា** បានដល់ មឹតពត់កាយ ។ ដែលឈ្មោះថា **ភត្តសម្មទោ** បានដល់ ភាពប្រអួសដែលកើតអំពីអាហារ និងការក្រវល់ក្រវាយដែលកើតអំពីអាហារ ( ពុលបាយ ) ។ ដែលឈ្មោះថា **ចេតសោ លីនត្តំ** បានដល់ ចិត្តដែលមិនមានផាសុក គឺរួញរាចិត្ត ។ កាលព្រះយោគាវចរ ញុំាងការធ្វើទុកក្នុងចិត្តដោយអយោនិសោមនិការ ឲ្យប្រព្រឹត្តទៅក្នុងធម៌ទាំងឡាយ មានអរតិជាដើមនេះរឿយៗ ថីនមិទ្ធៈរមែងកើតឡើងបាន ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនត្រេកអរ ខ្ជិល មិតពត់កាយ ពុលបាយ រួញរាចិត្ត និង ការធ្វើទុកអយោនិសោមនសិការ ឲ្យច្រើនក្នុងសេចក្តីមិនត្រេកអរជាដើមនោះ នេះធម៌ជាអាហាររបស់ថីនមិទ្ធៈ ដែលមិនទាន់កើតឲ្យកើតឡើងបាន ឬរបស់ ថីនមិទ្ធៈដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ។

ការលះថីនមិទ្ធៈនោះ រមែងមានដោយយោនិសោមនសិការ ព្រោះធាតុ ទាំងឡាយ មានអារព្ភធាតុជាដើម ។ ដែលឈ្មោះថា **អារព្ភធាតុ** បានដល់ ការផ្តើមតាំងផ្តើម ។ ដែលឈ្មោះថា **និក្កមធាតុ** បានដល់ ការខ្នះខ្នែងដែល មានកម្លាំង ច្រើនជាងអារព្ភធាតុនោះ ព្រោះជាគ្រឿងចេញចាកកោសជ្ជៈ ។ ដែលឈ្មោះថា **បរក្កមធាតុ** បានដល់ ការប្រឹងប្រែងដែលមានកម្លាំងច្រើន ជាងនិក្កមធាតុនោះ ។ សូម្បីដូច្នោះ ព្រោះឈានទៅកាន់ឋានៈក្រៃលែង ឡើងៗ ។

កាលព្រះយោគាវចរ ញុំាងការធ្វើទុកក្នុងចិត្តដោយឧបាយ ឲ្យប្រព្រឹត្តទៅ ក្នុងសេចក្តីព្យាយាម ៣ ប្រភេទនេះរឿយៗ លោករមែងលះថីនមិទ្ធៈបាន ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មានតែការតាំងផ្តើម ការខ្នះខ្នែង ការប្រឹងប្រែង និងការធ្វើទុកយោនិសោ- មនសិការឲ្យច្រើន ក្នុងការតាំងផ្តើមជាដើមនោះ នេះធម៌មិនមែនជាអាហារ របស់ថីនមិទ្ធៈ ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ថីនមិទ្ធៈដែល កើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការរមែងប្រព្រឹត្តទៅ ដើម្បីលះថីនមិទ្ធៈ គឺការកាន់យកនិមិត្តក្នុងការបរិភោគច្រើន ១ ការផ្លាស់ប្តូរឥរិយាបថ ១ មនសិការដល់អាលោកសញ្ញា ១ ការនៅក្នុងទីវាល ១ ភាពជាអ្នកមានកល្យាណមិត្ត ១ សន្ទនាដល់រឿងដែលជាសប្បាយ ១ ។

កាលព្រះយោគាវចរឆាន់ច្រើនពេក ដូចហត្ថកព្រាហ្មណ៍ កុត្តអមិត្តកព្រាហ្មណ៍ តត្រវដកព្រាហ្មណ៍ អលង្សាដកព្រាហ្មណ៍ និងកាកមាសកព្រាហ្មណ៍ ហើយអង្គុយបំពេញសមណធម៌ ក្នុងទីសម្រាកពេលយប់ និងក្នុងទីសម្រាកពេលថ្ងៃ ថីនមិទ្ធៈរមែងមកគ្រប់សង្កត់បាន ដូចដំរីធំមកជាន់ ដូច្នោះ ។

តែសម្រាប់ភិក្ខុដែលវៀរឱកាស ដែលឆាន់បាន ៤-៥ ម៉ាត់ចេញ ហើយផឹកទឹកជំនួសជាប្រចាំ ថីនមិទ្ធៈនោះរមែងមិនមាន កាលព្រះយោគាវចរកាន់យកនិមិត្តក្នុងការឆាន់ច្រើនពេក ដូចពោលមកនេះ លោករមែងលះថីនមិទ្ធៈបាន ។

ក្នុងឥរិយាបថណា ព្រះយោគាវចរធ្លាក់នៅក្នុងអំណាចថីនមិទ្ធៈ កាលលោកផ្លាស់ឥរិយាបថដទៃអំពីឥរិយាបថនោះក្តី មនសិការដល់ពន្លឺព្រះចន្ទ ពន្លឺប្រទីប និងពន្លឺគប់ភ្លើង ក្នុងពេលរាត្រី និងពន្លឺព្រះអាទិត្យក្នុងពេលថ្ងៃក្តី នៅត្រង់ទីវាលក្តី គប់រកកល្យាណមិត្តដែលលះថីនមិទ្ធៈបានហើយ ដូចជាព្រះមហាកស្សបត្ថេរក្តី ថីនមិទ្ធៈ ឈ្មោះថា លោករមែងលះបង់បាន ។

លោករមែងលះថីនមិទ្ធៈបាន ដោយការសន្ទនាដល់រឿងដែលជាសប្បាយទាក់ទងនឹងធុតង្គ ក្នុងឥរិយាបថទាំងឡាយ មានឥរិយាបថឈរ និងអង្គុយជា

ដើម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ ៦ ប្រការ រមែង ប្រព្រឹត្តទៅដើម្បីលះថីនមិទ្ធៈ ។ ព្រះយោគាវចរ រមែងដឹងច្បាស់ថា ថីនមិទ្ធៈ ដែលលះបានហើយ ដោយធម៌ ៦ ប្រការនេះ នឹងកើតឡើងមិនបានទៀត ក្នុងអរហត្តមគ្គ ។

កាលចិត្តមិនស្ងប់ ឧទ្ធច្ចកុក្កុច្ចៈរមែងកើតឡើងបាន ដោយការមិនបាន ធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ។ អាការដែលចិត្តមិនស្ងប់ ឈ្មោះថា **អវូបសម** ដោយអត្ថ ពាក្យថា **អវូបសម** នោះ គឺឧទ្ធច្ចកុក្កុច្ចៈនោះឯង ។ កាលព្រះយោគាវចរ ញ៉ាំងអយោនិសោមនសិការឲ្យប្រព្រឹត្តទៅក្នុងអវូបសម នោះរឿយៗ ឧទ្ធច្ចកុក្កុច្ចៈ រមែងកើតឡើង ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មានតែការមិនស្ងប់ស្ងាត់ចិត្ត និងការធ្វើនូវអយោនិសោមនសិការ ឲ្យច្រើន ក្នុងការមិនស្ងប់ស្ងាត់ចិត្តនោះ នេះធម៌ជាអាហាររបស់ឧទ្ធច្ចកុក្កុច្ចៈ ដែលមិន ទាន់កើត ឲ្យកើតឡើងបាន ឬរបស់ឧទ្ធច្ចកុក្កុច្ចៈដែលកើតហើយ ឲ្យរឹងរឹតតែ កើតច្រើនឡើង ។

ការលះឧទ្ធច្ចកុក្កុច្ចៈនោះ មានដោយយោនិសោមនសិការ ព្រោះចិត្តស្ងប់ ពោល គឺសមាធិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ មានតែការស្ងប់ស្ងាត់ចិត្ត និងការធ្វើនូវយោនិសោមនសិការ ឲ្យច្រើន ក្នុងការស្ងប់ស្ងាត់ចិត្តនោះ នេះធម៌ដែលមិនមែនជាអាហាររបស់ ឧទ្ធច្ចកុក្កុច្ចៈ ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ឧទ្ធច្ចកុក្កុច្ចៈដែល

កើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ។

ម្យ៉ាងទៀត ធម៌ទាំង ៦ យ៉ាង រមែងប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ គឺ ភាពជាពហូសូត ១ ភាពជាអ្នកសាកសួរ ១ ភាពជាអ្នកដឹងប្រក្រតីក្នុងព្រះវិន័យ ១ ការសេពគប់បុគ្គលចម្រើនហើយ ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ការពោលពាក្យដែលជាទីសប្បាយ ១ ។

អធិប្បាយថា លោករៀន ១ និកាយខ្លះ ២ និកាយខ្លះ ៣ និកាយខ្លះ ៤ និកាយខ្លះ ៥ និកាយខ្លះ ដោយព្រះបាលីផង ដោយអដ្ឋកថាផង រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។ លោកជាអ្នកច្រើនទៅដោយការសាកសួរនូវរបស់ដែលជាកប្បិយ និងអកប្បិយក្តី ជាអ្នកដឹងភាពជាប្រក្រតីក្នុងវិនយប្បញ្ញត្តិ ព្រោះជាអ្នកប្រព្រឹត្តទៅក្នុងអំណាចវិន័យ ដែលខ្លួនស្ទាត់ជំនាញហើយក្តី ចូលទៅរកបុគ្គលដែលចម្រើន គឺព្រះថេរៈដែលជាធំក្តី គប់រក គឺសមាគមនឹងកល្យាណមិត្តដែលជាអ្នកទ្រទ្រង់វិន័យ ដូចព្រះឧបាលិត្ថេរក្តី រមែងលះឧទ្ធច្ច-កុក្កុច្ចៈបាន ។

ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម លោករមែងលះបាន ដោយការពោលពាក្យដែលជាសប្បាយ ទាក់ទងនឹងវត្ថុដែលជាកប្បិយ និងអកប្បិយ ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ ៦ យ៉ាង រមែងប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ ។ លោករមែងដឹងថា បណ្តាឧទ្ធច្ចកុក្កុច្ចៈដែលលះបានហើយ ដោយធម៌ទាំង ៦ យ៉ាងនេះ ឧទ្ធច្ចៈមិនមានកើតឡើង

តទៅ ព្រោះអរហត្តមគ្គ កុក្កុច្ចៈមិនមានកើតការកើតឡើងតទៅដោយអំណាចអនាគាមិមគ្គ ។

វិចិកិច្ឆា រមែងកើតឡើងបាន ដោយមិនមនសិការក្នុងធម៌ទាំងឡាយដែលជាទីតាំងនៃវិចិកិច្ឆា ។ ដែលឈ្មោះថា ធម៌ជាទីតាំងនៃវិចិកិច្ឆា ក៏បានដល់វិចិកិច្ឆានោះឯង ព្រោះជាហេតុនៃការសង្ស័យ ។ កាលអាត្មាអញញុំាងអយោនិសោមនសិការ ក្នុងវិចិកិច្ឆានោះឲ្យប្រព្រឹត្តទៅរឿយៗ វិចិកិច្ឆារមែងកើតឡើង ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយមានធម៌ទាំងឡាយ ដែលបណ្តាលឲ្យកើតវិចិកិច្ឆា និងការធ្វើទុកអយោនិសោ-មនសិការឲ្យច្រើនក្នុងធម៌នោះ នេះធម៌ជាអាហាររបស់វិចិកិច្ឆា ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់វិចិកិច្ឆាដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ។

ការលះវិចិកិច្ឆានោះ រមែងមានដោយយោនិសោមនសិការក្នុងធម៌ទាំង-ឡាយ មានកុសលជាដើម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មានពួកធម៌ជាកុសល និងអកុសល ពួកធម៌ដែលប្រកបដោយទោស និងឥតទោស ពួកធម៌ដែលថោកទាប និងថ្លៃថ្លា ពួកធម៌ជាចំណែកខ្មៅ និងស និងការធ្វើទុកយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះធម៌មិនមែនជាអាហាររបស់វិចិកិច្ឆាដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់វិចិកិច្ឆាដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ។

ម្យ៉ាងទៀត ធម៌ទាំង ៦ យ៉ាង រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា គឺ កាពជាពហុស្សូត ១ ភាពជាអ្នកសាកសួរ ១ ភាពជាអ្នកដឹងប្រក្រតីក្នុងព្រះវិន័យ ១ ភាពជាអ្នកច្រើនដោយអធិមោក្ខ ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ការពោលពាក្យដែលជាសប្បាយ ១ ។

អធិប្បាយថា លោករៀនយក ១ និកាយខ្លះ ។បេ។ ៥ និកាយខ្លះ ដោយព្រះបាលីផង ដោយអដ្ឋកថាផង រមែងលះវិចិកិច្ឆាបានដោយពហុសច្ចៈ។ បុគ្គលច្រើនដោយការសាកសួរ ដោយការប្រារព្ធព្រះរតនត្រ័យក្តី បុគ្គលមានការជំនាញក្នុងព្រះវិន័យក្តី បុគ្គលច្រើនទៅដោយអធិមោក្ខ ពោលគឺ មានសទ្ធាមាំទាំក្នុងព្រះរតនត្រ័យក្តី បុគ្គលគប់រកកល្យាណមិត្តដែលជាសទ្ធាវិមុត្តិ ដូចវក្កលិត្ថេរក្តី រមែងលះវិចិកិច្ឆាបានដោយពហុសច្ចៈ ។

ក្នុងឥរិយាបថទាំងឡាយ មានការឈរ ការអង្គុយជាដើម លោករមែងលះវិចិកិច្ឆាបានដោយពាក្យដែលជាសប្បាយ ទាក់ទងនឹងគុណរបស់ព្រះរតនត្រ័យ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ ៦ យ៉ាង រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា ព្រះយោគាវចររមែងជ្រាបច្បាស់ថា វិចិកិច្ឆាដែលលះបានដោយធម៌ទាំង ៦ យ៉ាងនេះ មិនមានការកើតឡើងតទៅទៀត ព្រោះសោតាបត្តិមគ្គ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរគប្បីពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយរបស់ខ្លួន ឬក្នុងធម៌ទាំងឡាយរបស់អ្នកដទៃ គឺក្នុងធម៌ទាំងឡាយរបស់ខ្លួនតាមកាលដ៏សមគួរ ឬរបស់អ្នកដទៃតាមកាលដ៏សមគួរ

ដោយការកំណត់នីវរណៈ ៥ យ៉ាងនេះ ។

តែក្នុងនីវរណបព្វៈនេះ ព្រះយោគាវចរនាំយកការកើតឡើង និងការសូន្យទៅដោយអយោនិសោមនសិការ ឬយោនិសោមនសិការក្នុងសុភនិមិត្តជាដើម ដោយន័យដែលបានត្រាស់ហើយ ក្នុងនីវរណៈ ៥ ។ សេចក្ដីបន្ទាប់នេះទៅ មានន័យដូចពោលមកហើយនោះឯង ។

សតិជាគ្រឿងកំណត់នីវរណៈ ក្នុងនីវរណបព្វៈនេះ ជាទុក្ខសច្ចៈតែម្យ៉ាង បណ្ឌិតគប្បីប្រកបសេចក្ដីដូចពណ៌នាមកនេះ ហើយជ្រាបគន្លងនៃធម៌ជាគ្រឿងនាំចេញចាកទុក្ខរបស់ភិក្ខុ ដែលកំណត់នីវរណៈជាអារម្មណ៍ សេចក្ដីក្នុងទីដ៏សេស ក៏ដូច្នោះដូចគ្នានោះឯង ។

**អធិប្បាយ នីវរណបព្វៈ ចប់**

## ខន្ធបព្វៈ

[ ១៤២ ] ព្រះមានព្រះភាគ កាលទ្រង់ចែកធម្មានុបស្សនាដោយនីវរណៈ ៥ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយបញ្ចក្ខន្ធ ទើបត្រាស់ពាក្យថា **បុន ចបរំ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **បញ្ចសុ ឧបាទានក្ខន្ធេសុ** សេចក្ដីថា កងនៃឧបាទាន ឈ្មោះថា **ឧបាទានក្ខន្ធ** អធិប្បាយថា ក្រុមនៃធម៌ គឺគំនរនៃធម៌ដែលជាបច្ច័យនៃឧបាទាន ឈ្មោះថា **ធម្មរាសី** សេចក្ដីសង្ខេបក្នុងបញ្ចក្ខន្ធនេះ មានប្រមាណប៉ុណ្ណេះ ។ ឯសេចក្ដីពិស្ដាររឿងខន្ធ បានពោលហើយក្នុង

គម្ពីរវិសុទ្ធិមគ្គ ។

បទថា **ឥតិ រូបំ** សេចក្តីថា ដឹងរូបដោយសភាវៈថា នេះរូប រូបមានប៉ុណ្ណេះ រូបដទៃក្រៅអំពីនេះមិនមាន ។ សូម្បីក្នុងវេទនាជាដើម ក៏ន័យនេះដូចគ្នា ។ សេចក្តីសង្ខេបក្នុងពាក្យនេះមានប៉ុណ្ណេះ ។ ឯដោយពិស្តារ រូបជាដើម លោកពោលមកហើយ ក្នុងរឿងខន្ធ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

បទថា **ឥតិ រូបស្ស សមុទយោ** សេចក្តីថា ការកើតនៃរូបដោយអាការ ៥ ដោយមានអវិជ្ជាជាទីកើតជាដើមយ៉ាងនេះ ។

បទថា **ឥតិ រូបស្ស អត្ថង្គមោ** សេចក្តីថា ការរលត់នៃរូបដោយអាការ ៥ ដោយមានការរលត់នៃអវិជ្ជាជាដើមយ៉ាងនេះ ។ សូម្បីក្នុងវេទនាជាដើម ក៏ន័យនេះដូចគ្នា ។ នេះជាសេចក្តីសង្ខេបក្នុងសេចក្តីនេះ ឯការពិស្តារពោលទុកហើយក្នុងរឿងឧទយព្វយញ្ញាណ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ មិនថារបស់ខ្លួន ឬរបស់អ្នកដទៃ មិនថាតាមកាលរបស់ខ្លួន ឬរបស់អ្នកដទៃ ដោយការកំណត់បញ្ចក្ខន្ធជាអារម្មណ៍យ៉ាងនេះ ។ ក្នុងពាក្យនេះ សមុទយធម៌ និងវយធម៌ គប្បីលើកឡើងពិចារណាលក្ខណៈ ៥០ ដែលលោកពោលទុកក្នុងខន្ធទាំងឡាយជាដើមថា ព្រោះអវិជ្ជាកើត ទើបរូបកើត ។ បន្ទាប់អំពីនេះ ក៏មានន័យដូចពោលហើយនោះឯង ។

សតិជាគ្រឿងកំណត់ខន្ធជាអារម្មណ៍ ក្នុងខន្ធបព្វៈនេះ ជាទុក្ខសច្ចៈតែម្យ៉ាង គប្បីប្រកបសេចក្តីដូចពោលមកនេះ ហើយគប្បីជ្រាបបដិបទានាំចេញចាកទុក្ខ

នៃភិក្ខុដែលកំណត់ខន្ធជាអារម្មណ៍ ។ ពាក្យដ៏សេសក៏យ៉ាងនោះ ដូចគ្នា ។

**ខន្ធបព្វៈ ចប់**

## **អាយតនបព្វៈ**

[ ១៤ ] ព្រះមានព្រះភាគ កាលទ្រង់ចែកធម្មានុបស្សនាដោយបញ្ចក្ខន្ធយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយអាយតនៈ ទើបត្រាស់ពាក្យថា **បុន ចបរំ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ** បានដល់ អាយតនៈខាងក្នុង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត និងអាយតនៈខាងក្រៅ ៦ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ។

បទថា **ចក្ខុំ ច បជានាតិ** បានដល់ ដឹងចក្ខុបសាទ ដោយលក្ខណៈនៃកិច្ចតាមសេចក្ដីពិត ។

បទថា **រូបេ ច បជានាតិ** សេចក្ដីថា ដឹងច្បាស់នូវរូប ដែលមានសមុដ្ឋាន ៤ យ៉ាងខាងក្រៅផង ដោយលក្ខណៈនៃចិត្តតាមសេចក្ដីពិតផង ។

ពាក្យថា **យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សំយោជនំ** សេចក្ដីថា ព្រោះអាស្រ័យអាយតនៈទាំង ២ យ៉ាង គឺភ្នែកផង រូបផង សំយោជនៈ ១០ យ៉ាង គឺកាមរាគសំយោជនៈ បដិឃៈ មានះ ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ភវរាគៈ ឥស្សា មច្ឆរិយៈ និងអវិជ្ជា សំយោជនៈណាមួយរមែងកើតឡើង លោកដឹងច្បាស់សំយោជនៈនោះដោយលក្ខណៈតាមការពិតផង ។

សួរថា សំយោជនៈនេះកើតឡើងបានដូចម្ដេច ឆ្លើយថា នឹងពោលក្នុងចក្ខុទ្វារមុន កាលលោកពេញចិត្ត ត្រេកអរីករាយ ក្នុងឥដ្ឋារម្មណ៍ដែលមកកាន់គន្លងចក្ខុ ដោយអំណាចនៃការពេញចិត្តក្នុងឥដ្ឋារម្មណ៍ កាមរាគ-សំយោជនៈនឹងកើតឡើង ។ កាលក្រោធក្នុងអនិដ្ឋារម្មណ៍ បដិឃសំយោជនៈនឹងកើតឡើង។ កាលសម្គាល់ថា ក្រៅអំពីអញហើយ មិនមានបុគ្គលដទៃអាចសម្ដែងអារម្មណ៍នេះឲ្យជាក់ច្បាស់បាន មានះសំយោជនៈនឹងកើតឡើង ។ កាលប្រកាន់ថា រូបារម្មណ៍នេះទៀង ស្ថិតស្ថេរ ទិដ្ឋិសំយោជនៈនឹងកើតឡើង កាលសង្ស័យថា រូបារម្មណ៍នេះជាសត្វឬហ្ន៎ ឬជារបស់សត្វ វិចិកិច្ឆា-សំយោជនៈនឹងកើតឡើង ។ កាលប្រាថ្នាភពថា ភព គឺការកើតនេះមិនមែនរកបានងាយក្នុងសម្បត្តិភពឡើយ ភវរាគសំយោជនៈនឹងកើតឡើង កាលប្រកាន់មាំនូវសីល និងវត្តថា អញសមាទានសីល និងវត្តបែបនេះហើយអាចបានសម្រេចគុណវិសេសតទៅ សីលព្វតបរាមាសសំយោជនៈនឹងកើតឡើង ។ កាលឥស្សាកើតឡើងថា ធ្វើដូចម្ដេចហ្ន៎ អ្នកដទៃកុំបានរូបារម្មណ៍នេះ ឥស្សាសំយោជនៈនឹងកើតឡើង ។ កាលកំណាញ់រូបារម្មណ៍ដែលខ្លួនបានហើយចំពោះអ្នកដទៃ មច្ឆរិយសំយោជនៈនឹងកើតឡើង កាលមិនដឹងដោយមិនដឹងធម៌ដែលកើតឡើង ព្រមជាមួយធម៌ទាំងអស់នោះ អវិជ្ជា-សំយោជនៈក៏កើតឡើង ។

បទថា **យថា ច អនុប្បន្នស្ស** សេចក្ដីថា សំយោជនៈទាំង ១០ យ៉ាងនោះ ដែលមិនទាន់បានកើត នឹងកើតឡើងដោយហេតុ គឺដោយការមិនផ្សាយ

ឡើង យ៉ាងណា លោកដឹងច្បាស់នូវហេតុនោះផង ។

បទថា **យថា ច ឧប្បន្នស្ស** សេចក្តីថា ចំណែកការលះសំយោជនៈ ទាំង ១០ យ៉ាងនោះ ដែលកើតឡើងហើយ ដោយអត្ថថា មិនទាន់លះបាន ក្តី ដោយការផ្សាយឡើងក្តី ដោយហេតុណា លោករមែងដឹងច្បាស់នូវ ហេតុនោះផង ។

បទថា **យថា ច បហីនស្ស** សេចក្តីថា សំយោជនៈ ១០ យ៉ាងនោះ ដែលលះបានហើយ ដោយតទង្គប្បហាន និងវិក្ខម្ភនប្បហាន នឹងមិនមានការ កើតឡើងតទៅ ព្រោះហេតុណា លោកក៏ដឹងហេតុនោះផង អធិប្បាយថា សំយោជនៈនោះ មិនមានការកើតឡើងតទៅ សំយោជនៈ ៥ គឺទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ឥស្សា មច្ឆរិយៈ មិនមានការកើតឡើងតទៅ ព្រោះ សោតាបត្តិមគ្គ ។

សំយោជនៈទាំងគូ គឺកាមរាគៈ និងបដិឃៈយ៉ាងគ្រោតគ្រាតនឹងមិនមាន ការកើតឡើងតទៅព្រោះសកទាគាមិមគ្គ សំយោជនៈទាំងគូ គឺកាមរាគៈ និង បដិឃៈ ដែលទៅជាមួយគ្នាយ៉ាងល្អិត មិនកើតឡើងតទៅ ព្រោះអនាគាមិមគ្គ សំយោជនៈ ៣ យ៉ាង គឺមានៈ ភវរាគៈ និងអវិជ្ជា មិនមានការកើតឡើង តទៅ ព្រោះអរហត្តមគ្គ ដោយហេតុណា លោកក៏ដឹងហេតុនោះផង ។ ក្នុង បទថា **សន្តេ** ក៏មានន័យនេះដូចគ្នា ។ មយ៉ាងទៀត ក្នុងសេចក្តីនេះ គប្បី ជ្រាបកថាពោលដោយអាយតនៈ ដោយពិស្តារតាមន័យដែលបានពោលហើយ ក្នុងអាយតននិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គនោះ ។

ព្រះយោគាវចរ ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយរបស់ខ្លួន ដោយការកំណត់អាយតនៈខាងក្នុង ឬក្នុងធម៌ទាំងឡាយរបស់អ្នកដទៃដោយការកំណត់អាយតនៈខាងក្រៅ គឺក្នុងធម៌ទាំងឡាយរបស់ខ្លួនតាមកាល ឬរបស់អ្នកដទៃតាមកាល ដោយប្រការយ៉ាងនេះ ។ ក្នុងអាយតនបព្វៈនេះ សមុទយធម៌ និងវយធម៌ គួរនាំចេញទៅដោយន័យរបស់រូបាយតនៈ ដែលត្រាស់ហើយក្នុងរូបក្ខន្ធនៃអាយតនៈ ក្នុងបណ្ដាអរូបាយតនៈទាំងឡាយដែលត្រាស់ក្នុងវិញ្ញាណក្ខន្ធនៃធម្មាយតនៈ ដែលត្រាស់ក្នុងខន្ធដ៏សេសថា ព្រោះអវិជ្ជាកើតទើបចក្ខុកើត ។ មិនគួរសំដៅដល់លោកុត្តរធម៌ ។ ពាក្យបន្ដអំពីនេះទៅមានន័យដូចពោលហើយនោះឯង ។

សតិជាគ្រឿងកំណត់អាយតនៈ ក្នុងអាយតនបព្វៈនេះ ជាទុក្ខសច្ចតែម្យ៉ាង គប្បីប្រកបសេចក្ដីដូចពោលមកនេះ ហើយជ្រាបបដិបទាដែលជាហេតុនាំចេញចាកទុក្ខនៃភិក្ខុ ដែលកំណត់អាយតនៈជាអារម្មណ៍ ។ ពាក្យដ៏សេសក៏យ៉ាងនោះដូចគ្នា ។

**អាយតនបព្វៈ ចប់**

## ពោជ្ឈង្គបព្វៈ

[ ១៨៤ ] ព្រះមានព្រះភាគ កាលទ្រង់ចែកធម្មានុបស្សនាដោយអាយតនៈដែលប្រព្រឹត្តទៅខាងក្នុង និងខាងក្រៅយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីចែកដោយពោជ្ឈង្គ ទើបត្រាស់ពាក្យថា **បុន ចបរំ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **ពោជ្ឈង្គេសុ** បានដល់ អង្គនៃបុគ្គលដែលជាប់ជំពាក់នៅក្នុងការត្រាស់ដឹង ។ បទថា **សន្តំ** បានដល់ មានដោយការត្រឡប់បាន ។ បទថា **សតិសម្ពោជ្ឈង្គំ** បានដល់ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង ពោល គឺសតិ ។

អធិប្បាយថា ព្រះយោគាវចរ រមែងដឹងព្រមក្នុងធម៌ទាំង ៧ នេះ ចាប់ផ្ដើមតាំងអំពីប្រារព្ធវិបស្សនា ព្រោះដូច្នោះ ទើបធម៌ទាំងនោះ ឈ្មោះថា **សម្ពោជ្ឈង្គ** ។ មា៉ងទៀត ព្រះយោគាវចរនោះ ភ្ញាក់ គឺក្រោកឡើងអំពីកិលេសនិទ្រា ឬចាក់ធ្លុះនូវសច្ចៈទាំងឡាយ ដោយធម្មសាមគ្គី ៧ ប្រការណា មានសតិជាដើម ធម្មសាមគ្គីនោះ ឈ្មោះថា **សម្ពោធិ** ។ ឈ្មោះថា **សម្ពោជ្ឈង្គ** ព្រោះជាអង្គនៃសម្ពោធិធម៌ ឬសម្ពោធិធម្មសាមគ្គីនោះ ដោយហេតុនោះ ទើបលោកពោលថា សម្ពោជ្ឈង្គ ពោលគឺ សតិ ។ ក្នុងសម្ពោជ្ឈង្គដ៏សេស ក៏គប្បីជ្រាបអត្ថវចនៈ ដោយន័យនេះដូចគ្នា ។

បទថា **អសន្តំ** សេចក្ដីថា មិនមានដោយការមិនត្រឡប់បាន ។ ក្នុងបទទាំងឡាយ មានបទថា **យថា ច អនុប្បន្នស្ស** ជាដើម មានវិនិច្ឆ័យដូចតទៅនេះ

លំដាប់ដំបូង សតិសម្ពោជ្ឈង្គ មានការកើតឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងឡាយ មានធម៌ទាំងឡាយដែលនាំឲ្យកើតសតិសម្ពោជ្ឈង្គ និងការធ្វើនូវយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះធម៌ជាអាហាររបស់សតិ-សម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់សតិសម្ពោជ្ឈង្គដែល

កើតឡើងហើយ ឲ្យចម្រើនបរិបូណ៌ ។ កាលសតិមាននោះឯង ធម៌ទាំង-ឡាយដែលជាទីតាំងនៃសតិសម្ពោជ្ឈង្គមាន យោនិសោមនសិការមានលក្ខណៈដូចពោលមកហើយនោះឯង កាលព្រះយោគាវចរញ៉ាំងយោនិសោ-មនសិការនោះឲ្យប្រព្រឹត្តទៅក្នុងធម៌ទាំងនោះរឿយៗ សតិសម្ពោជ្ឈង្គ រមែងកើតឡើង ។

ម្យ៉ាងទៀត ធម៌ ៤ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃសតិសម្ពោជ្ឈង្គ គឺសតិសម្បជញ្ញៈ ១ ការវៀរចាកបុគ្គលមិនមានស្មារតី ១ ការគប់រកបុគ្គលដែលមានសតិមាំទាំ ១ ភាពជាអ្នកបង្អោនទៅរកសតិនោះ ១ ។

ពិតហើយ សតិសម្ពោជ្ឈង្គកើតឡើងក្នុងទី ៧ ស្ថាន មានការឈានទៅខាងមុខជាដើម ព្រោះមានសតិសម្បជញ្ញៈ ព្រោះវៀរបុគ្គលដែលមិនមានស្មារតី ដូចជាការរក្សាអាហារទុក ព្រោះគប់រក ឬសមាគមនឹងបុគ្គលដែលមានសតិតាំងមាំ ដូចជាព្រះតិស្សទត្តត្ថេរ និងព្រះអភយត្ថេរជាដើម និងព្រោះជាអ្នកមានចិត្តបង្អោនទៅ ដើម្បីមានសតិតាំងឡើងក្នុងឥរិយាបថទាំងឡាយមានការអង្គុយ ការដេកជាដើម រមែងជាអ្នកដឹងច្បាស់ថា ការបរិបូណ៌នៃការចម្រើនសតិសម្ពោជ្ឈង្គនោះ ដែលកើតឡើងហើយដោយហេតុ ៤ យ៉ាងនេះ នឹងមានដោយអរហត្តមគ្គ ។

ឯធម្មវិចយសម្ពោជ្ឈង្គ មានការកើតឡើងយ៉ាងនេះថា ម្នាលភិក្ខុទាំង-ឡាយ មានពួកធម៌ជាកុសល ឬអកុសល ពួកធម៌ប្រកបដោយទោស ឬឥតទោស ពួកធម៌ថោកទាប ឬថ្លៃថ្លា ពួកធម៌ជាចំណែកខ្មៅ ឬស និងការធ្វើទុក

យោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះធម៌ជាអាហាររបស់ធម្មវិចយសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ធម្មវិចយសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចម្រើនបរិបូណ៌ ។

ម្យ៉ាងទៀត ធម៌ទាំង ៧ ប្រការនេះ ការសាកសួរ ១ ការធ្វើវត្ថុឲ្យស្អាតផូរផង់ ១ ការធ្វើឥន្ទ្រិយឲ្យស្មើ ១ ការវៀរបុគ្គលដែលមានបញ្ញាទុព្វល ១ ការសេពគប់នឹងបុគ្គលមានបញ្ញា ១ ការពិចារណាការប្រព្រឹត្តទៅ ដោយញាណដ៏ជ្រាលជ្រៅ ១ ការបង្អោនចិត្តទៅក្នុងធម្មវិចយៈ ១ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គ ។ ភាពជាអ្នកច្រើនដោយការសាកសួរ ទាក់ទងនឹងអត្ថនៃខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ ពល ពោជ្ឈង្គ មគ្គ អង្គឈាន សមថៈ និងវិបស្សនា ឈ្មោះថា **បរិបុច្ឆកតា** ក្នុងបណ្ដាធម៌ ៧ នោះ ។

ការធ្វើវត្ថុទាំងខាងក្នុង និងខាងក្រៅឲ្យផូរផង់ ឈ្មោះថា **វត្ថុវិសទកិរិយា** ។ ព្រោះថា កាលណាសក់ ក្រចក រោម របស់លោកវែងពេក ឬរាងកាយរបស់លោកមានរោគច្រើន ឬប្រឡាក់ប្រឡូសទៅដោយមលការៈ គឺញើស ក្អែល កាលនោះ វត្ថុដែលមានខាងក្នុងចិត្ត នឹងមិនផូរផង់ មិនបរិសុទ្ធ តែកាលណាចីវររបស់លោកចាស់សៅហ្មង មានក្លិន ឬសេនាសនៈប្រឡាក់ប្រឡូស កាលនោះ វត្ថុដែលមានខាងក្រៅមិនផូរផង់ មិនបរិសុទ្ធ ព្រោះដូច្នោះ វត្ថុខាងក្នុង លោកត្រូវធ្វើឲ្យផូរផង់ ដោយការកោរសក់ជាដើម ដោយការធ្វើរាងកាយឲ្យស្រោលសប្បាយ ដោយការជម្រះទាំងខាងលើ ខាង

ក្រោមជាដើម ដោយការអប់ ការរំងួត ។

វត្ថុខាងក្រៅ ត្រូវធ្វើឲ្យផូរផង់ ដោយការដេរ ការបោក ការជ្រលក់ និងការធ្វើគ្រឿងប្រើជាដើម ព្រោះថា សូម្បីញាណក្នុងចិត្ត និងចេតសិកដែលកើតឡើង ព្រោះវត្ថុខាងក្នុង និងខាងក្រៅនេះ ដែលមិនផូរផង់ ក៏នឹងមិនផូរផង់ទៅដែរ ដូចពន្លឺរបស់ប្រទីបដែលកើតឡើង ដោយអាស្រ័យចង្កៀងប្រឆេះ និងប្រេងដែលមិនស្អាត ដូច្នោះ សូម្បីញាណក្នុងចិត្ត និងចេតសិកទាំងឡាយដែលកើតឡើងហើយ ព្រោះវត្ថុខាងក្នុង និងខាងក្រៅដែលផូរផង់ ក៏នឹងផូរផង់ទៅផង ដូចពន្លឺនៃប្រទីប ដោយអាស្រ័យចង្កៀង ប្រឆេះ និងប្រេងដែលស្អាត ដូច្នោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ការធ្វើវត្ថុឲ្យផូរផង់ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គ។

ការធ្វើឥន្ទ្រិយ មានសទ្ធាជាដើមឲ្យស្មើគ្នា ឈ្មោះថា ការធ្វើឥន្ទ្រិយឲ្យស្មើគ្នា ។ ព្រោះថា សទ្ធិន្ទ្រិយរបស់លោកមានកម្លាំង ឥន្ទ្រិយក្រៅអំពីនេះទន់ខ្សោយ ។ បន្ទាប់អំពីនោះទៅ វីរិយិន្ទ្រិយមិនអាចធ្វើកិច្ចផ្គងបាន សតិន្ទ្រិយមិនអាចធ្វើកិច្ចប្រាកដបាន សមាធិន្ទ្រិយមិនអាចធ្វើកិច្ចមិនរាយមាយបាន បញ្ញិន្ទ្រិយមិនអាចធ្វើកិច្ចពិចារណាឃើញបាន ព្រោះដូច្នោះ ព្រះយោគាវចរគប្បីឲ្យសទ្ធិន្ទ្រិយនោះវិនាសទៅដោយពិចារណាដល់សភាវធម៌ ឬដោយមិនដាក់ចិត្តដល់ដោយទំនង កាលដាក់ដល់ សទ្ធិន្ទ្រិយនឹងមានកម្លាំង ។ ក្នុងសេចក្ដីនេះមានព្រះវក្កលិត្ថេរជាគំរូ ។ តែបើវីរិយិន្ទ្រិយមានកម្លាំង ក្រោយមក សទ្ធិន្ទ្រិយមិនអាចធ្វើកិច្ចបង្អោនចិត្តជឿបានឡើយ ឥន្ទ្រិយក្រៅអំពីនេះ

ក៏មិនអាចធ្វើកិច្ចផ្សេងក្រៅអំពីនេះបាន ព្រោះដូច្នោះ ព្រះយោគាវចរគប្បីឲ្យវីរិយិន្ទ្រិយនោះថយចុះ ដោយការចម្រើនបស្សទ្ធិជាដើម ។ ក្នុងសេចក្ដីនោះគប្បីសម្ដែងរឿងព្រះសោណត្ថេរឲ្យឃើញ ។ សូម្បីក្នុងឥន្ទ្រិយដ៏សេស ក៏គប្បីជ្រាបយ៉ាងនោះ ។ កាលឥន្ទ្រិយតែមួយមានកម្លាំង គប្បីជ្រាបថា ឥន្ទ្រិយក្រៅអំពីនេះក៏អស់សមត្ថភាពក្នុងកិច្ចរបស់ខ្លួន ។

តែក្នុងរឿងនេះ លោកសរសើរការដែលសទ្ធា និងបញ្ញាស្មើគ្នា សមាធិនិងវីរិយៈស្មើគ្នាទុកដោយពិសេស ។ ព្រោះថា បុគ្គលមានសទ្ធាខ្លាំង តែមានបញ្ញាខ្សោយ នឹងមានការជ្រះថ្លាវង្វេង គឺជ្រះថ្លាក្នុងវត្ថុដែលមិនមែនវត្ថុ បុគ្គលមានបញ្ញាខ្លាំង តែមានសទ្ធាទន់ខ្សោយ រមែងធ្លាក់ចូលទៅក្នុងផ្លូវវឹងរូស កែបានលំបាក ដូចរោគដែលស្គាល់ថ្នាំ មិនធ្វើកុសល មានទានជាដើម ដោយគិតជ្រុលទៅថា កុសលមានដោយហេតុត្រឹមចិត្តប្បាទប៉ុណ្ណោះរមែងកើតក្នុងនរក ។ តែព្រោះសទ្ធា និងបញ្ញាទាំងគូស្មើគ្នា បុគ្គលនោះនឹងជ្រះថ្លាក្នុងព្រះរតនត្រ័យនោះឯង ។ ឯសមាធិដែលមានកម្លាំងខ្លាំង តែវីរិយៈមានកម្លាំងខ្សោយ កោសជ្ជៈរមែងគ្របសង្កត់ ព្រោះសមាធិជាបក្ខពួកនៃកោសជ្ជៈ គឺការខ្ជិលច្រអូស ។ បើវីរិយៈមានកម្លាំងខ្លាំង សមាធិមានកម្លាំងខ្សោយ ឧទ្ធច្ចៈនឹងគ្របសង្កត់លោក ព្រោះវីរិយៈជាបក្ខពួកនៃឧទ្ធច្ចៈ ។ សមាធិដែលប្រកបទៅដោយវីរិយៈ នឹងមិនធ្លាក់ទៅក្នុងកោសជ្ជៈ គឺការខ្ជិលច្រអូស ។ វីរិយៈដែលប្រកបទៅដោយសមាធិ នឹងមិនធ្លាក់ទៅក្នុងឧទ្ធច្ចៈព្រោះដូច្នោះ គួរធ្វើសមាធិ និងវីរិយៈទាំងគូនេះឲ្យស្មើគ្នា ព្រោះថា អប្បនា

មានព្រោះវីរិយៈ និងសមាធិទាំងគូនោះស្មើគ្នា ។

ម្យ៉ាងទៀត សម្រាប់អ្នកផ្ដើមបំពេញសមាធិ សូម្បីសទ្ធាមានកម្លាំង ក៏ប្រើបាន ។ កាលជឿយ៉ាងនេះ នឹងសម្រេចអប្បនា ។ ក្នុងសមាធិ និងបញ្ញា សម្រាប់បុគ្គលផ្ដើមបំពេញសមាធិ ឯកគ្គតា ( សមាធិ ) មានកម្លាំងរមែងប្រើបាន ។ ព្រោះថា កាលបើយ៉ាងនេះ លោកក៏នឹងសម្រេចអប្បនា ។ សម្រាប់អ្នកផ្ដើមបំពេញវិបស្សនា បញ្ញាមានកម្លាំងរមែងប្រើបាន ។ ព្រោះថា កាលបើយ៉ាងនេះ លោកក៏ដល់នូវការចាក់ធ្លុះលក្ខណៈ គឺត្រៃលក្ខណ៍ ។ ព្រោះធម៌ទាំង ២ យ៉ាងនោះស្មើគ្នា អប្បនាក៏នឹងមាននោះឯង ។ ឯសតិមានកម្លាំងខ្លាំង ប្រើបានក្នុងទីគ្រប់អន្លើ ។ ព្រោះថា សតិនឹងរក្សាចិត្តទុកបានចាកការធ្លាក់ទៅកាន់ឧទ្ធច្ចៈ ដោយអំណាចនៃសទ្ធា វិរិយៈ និងបញ្ញា ដែលជាចំណែកនៃឧទ្ធច្ចៈ នឹងរក្សាចិត្តទុកបានអំពីការធ្លាក់ទៅកាន់កោសជ្ជៈ ដោយសមាធិដែលជាចំណែកនៃកោសជ្ជៈ ព្រោះដូច្នោះ ទើបសតិនោះចាំបាច់ក្នុងទីទាំងពួង ដូចក្នុងសម្លគ្រប់យ៉ាងមិនចោលអំបិល និងដូចរាជកិច្ចគ្រប់យ៉ាងត្រូវការបុគ្គលសម្រេចរាជការ ដោយហេតុនោះ ទើបលោកពោលថា សតិប្រើបានក្នុងទីទាំងពួង ព្រះមានព្រះភាគបានត្រាស់ហើយ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា ចិត្តមានសតិជាទីពឹងអាស្រ័យ សតិមានការរក្សាជាគ្រឿងប្រាកដ វៀរសតិហើយ ការផ្គង និងការសង្កត់ចិត្តក៏មិនមាន ។

ការវៀរឲ្យឆ្ងាយនូវបុគ្គលដែលមានបញ្ញាថោកថយ គឺបុគ្គលមានបញ្ញា

មិនឈមចុះក្នុងធម៌ មានខន្ធជាដើម ឈ្មោះថា វៀរបុគ្គលដែលមានបញ្ញាថោកថយ ។ ការសេពគប់បុគ្គលប្រកបដោយបញ្ញា ជាគ្រឿងពិចារណាឃើញការកើត និងការរលត់ ដែលកំណត់លក្ខណៈ ៥០ ឈ្មោះថា ការគប់រកបុគ្គលដែលមានបញ្ញា ។ ការពិចារណាប្រភេទនៃបញ្ញាដ៏ជ្រាលជ្រៅ ដែលប្រព្រឹត្តទៅហើយក្នុងខន្ធទាំងឡាយដែលជ្រាលជ្រៅ ឈ្មោះថា ការពិចារណាការប្រព្រឹត្តទៅនៃញាណដ៏ជ្រាលជ្រៅ ។ ការដែលចិត្តបង្អោន និងទោរទន់ទៅដើម្បីឲ្យធម្មវិចយសម្ពោជ្ឈង្គតាំងឡើងក្នុងឥរិយាបថអង្គុយ និងឥរិយាបថដេកជាដើម ឈ្មោះថា ការបង្អោនចិត្តទៅក្នុងធម្មវិចយសម្ពោជ្ឈង្គនោះ ។ លោកដឹងច្បាស់ថា ធម្មវិចយសម្ពោជ្ឈង្គនោះ ដែលកើតឡើងហើយយ៉ាងនេះ នឹងឲ្យមានការភាវនាបរិបូណ៌ដោយអរហត្តមគ្គ ។

វិរិយសម្ពោជ្ឈង្គមានការកើតឡើងយ៉ាងនេះ គឺម្នាលភិក្ខុទាំងឡាយ មានសេចក្តីតាំងផ្តើម ការខ្នះខ្នែង ការប្រឹងប្រែង និងការធ្វើទុកក្នុងចិត្តដោយឧបាយ ដោយមានយោនិសោមនសិការ ឲ្យច្រើនក្នុងសេចក្តីតាំងផ្តើមជាដើមនោះ នេះធម៌ជាអាហាររបស់វិរិយសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់វិរិយសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចម្រើនបរិបូណ៌ ។

ម្យ៉ាងទៀត ធម៌ ១១ ប្រការ គឺការពិចារណាឃើញភ័យក្នុងអបាយ ១ ការឃើញអានិសង្ស ១ ការពិចារណាឃើញផ្លូវទៅ ១ ការប្រព្រឹត្តឱនលំទោនចំពោះបិណ្ឌបាត ១ ការពិចារណាឃើញភាពជាធំ ដោយភាពជាទាយាទ ១ ការពិចារណាឃើញភាពជាធំរបស់ព្រះសាស្តា ១ ការពិចារណាឃើញភាព

ជាធំ ដោយជាតិ ១ ការពិចារណាឃើញភាពជាធំ ដោយជាសព្រហ្មចារី ១ ការវៀរបុគ្គលដែលខ្ជិលច្រអូស ១ ការគប់រកបុគ្គលដែលប្រារព្ធព្យាយាម ១ ភាពជាអ្នកមានចិត្តបង្អោនទៅក្នុងវីរិយសម្ពោជ្ឈង្គនោះ ១ រមែងប្រព្រឹត្តទៅដើម្បីការកើតនៃវីរិយសម្ពោជ្ឈង្គ ។

ក្នុងធម៌ ១១ ប្រការនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ អញមិនអាចឲ្យវីរិយសម្ពោជ្ឈង្គកើតឡើង ក្នុងវេលាសោយទុក្ខដ៏ធំកន្លង ចាប់ផ្ដើមតាំងអំពីត្រូវកម្មករណៈដោយគ្រឿងចង ៥ ប្រការ ក្នុងនរកទាំងឡាយក្ដី ក្នុងវេលាត្រូវចាប់ដោយគ្រឿងចាប់សត្វទឹក មានការបង់សំណាញ់ និងដាក់លបជាដើម និងក្នុងវេលាដែលអូសរទេះទៅជាដើមរបស់សត្វដែលត្រូវគៀន ដោយការចាក់នឹងជន្លួញ និងវាយដោយបន្ទាជាដើម ក្នុងកំណើតតិរច្ឆានក្ដី ក្នុងវេលាជួបនូវការឃ្លាន ការស្រេកអស់កាលច្រើនពាន់ឆ្នាំក្ដី មួយពុទ្ធន្តរក្ដីក្នុងបេតវិស័យ ។ ក្នុងវេលាសោយទុក្ខ មានខ្យល់ និងកម្ដៅថ្ងៃជាដើម ដោយអត្តភាពដែលមានត្រឹមតែស្បែកជណ្ដប់ឆ្អឹងប៉ុណ្ណោះ កម្ពស់ប្រមាណ ៦០ ហត្ថ និង ៨០ ហត្ថ ក្នុងពួកអសុរឈ្មោះកាឡកញ្ចិកក្ដី ម្នាលភិក្ខុទាំងឡាយ វេលានេះឯង ជាពេលដែលអ្នកត្រូវបំពេញសេចក្ដីព្យាយាម កាលអ្នកពិចារណាឃើញភ័យក្នុងអបាយ ដូចពណ៌នាមកនេះ វីរិយសម្ពោជ្ឈង្គ ក៏នឹងកើតឡើង ។

វីរិយសម្ពោជ្ឈង្គ នឹងកើតឡើងដល់អ្នកឃើញអានិសង្សនៃសេចក្ដីព្យាយាមយ៉ាងនេះថា អ្នកខ្ជិលច្រអូស មិនអាចនឹងបាននវលោកុត្តរធម៌ អ្នកប្រារព្ធសេចក្ដីព្យាយាមប៉ុណ្ណោះ ទើបអាចបាន នេះជាអានិសង្សនៃវីរិយៈ ។

វីរិយសម្ពោជ្ឈង្គ នឹងកើតឡើងដល់អ្នកពិចារណាឃើញផ្លូវយ៉ាងនេះថា អ្នកគប្បីដើរផ្លូវដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះមហាសាវករបស់ព្រះពុទ្ធទាំងឡាយ ទ្រង់ដើរទៅ និងដើរទៅហើយ ផ្លូវនោះ បុគ្គលខ្ជិលច្រអូស ដើរទៅមិនបានឡើយ ។

វីរិយសម្ពោជ្ឈង្គ រមែងកើតឡើងដល់ភិក្ខុដែលពិចារណាឃើញការកោតក្រែងនូវបិណ្ឌបាត ដូចដែលកើតឡើងដល់ព្រះមហាមិត្តត្ថេរយ៉ាងនេះថា ពួកជនដែលទំនុកបម្រុងអ្នកដោយបច្ច័យ មានបិណ្ឌបាតជាដើមទាំងនេះ មិនមែនជាញាតិរបស់អ្នកឡើយ មិនមែនជាទាសកម្មកររបស់អ្នក ទាំងបុគ្គលទាំងនោះមិនបានឲ្យបិណ្ឌបាតជាដើមដ៏ប្រណីតដល់អ្នក ដោយគិតថា ពួកយើងនឹងតាំងនៅបានព្រោះអាស្រ័យអ្នក ដោយពិតបុគ្គលទាំងនោះ បំណងសក្ការៈរបស់ខ្លួន ដើម្បីឲ្យមានផលច្រើន ទើបនាំគ្នាប្រគេន សូម្បីព្រះសាស្តាក៏ទ្រង់មិនបានឃើញយ៉ាងនេះថា ភិក្ខុនេះឆាន់បច្ច័យទាំងនេះហើយ នឹងជាអ្នកមានកាយមាំទាំច្រើន នៅយ៉ាងសប្បាយ ទ្រង់បានអនុញ្ញាតដល់អ្នក ដោយពិត ទ្រង់អនុញ្ញាតបច្ច័យទាំងនោះ ដោយទ្រង់បំណងថា ភិក្ខុនេះកាលបរិភោគបច្ច័យទាំងនេះ នឹងបំពេញសមណធម៌ ហើយផុតចាកទុក្ខ ឥឡូវនេះ អ្នកខ្ជិលច្រអូស និងមិនកោតក្រែងបិណ្ឌបាតនោះ ព្រោះដែលឈ្មោះថា ការកោតក្រែងបិណ្ឌបាតមានដល់ភិក្ខុដែលប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ ។

## រឿងព្រះមហាមិត្តត្ថេរ

បានឮថា ព្រះថេរៈអាស្រ័យនៅត្រង់ទីឈ្មោះថា កស្សកលេណៈ មាន

មហាឧបាសិកាម្នាក់ ក្នុងគោចរគ្រាមរបស់ព្រះថេរៈនោះ បានបដិបត្តិព្រះថេរៈ ដូចជាកូនប្រុស ថ្ងៃមួយ ឧបាសិកា កាលចូលព្រៃ បានប្រាប់កូនស្រីថា នែហង អង្ករចាស់នៅក្នុងទីនោះ ទឹកដោះនៅក្នុងទីនោះ សប្បិនៅក្នុងទីនោះ ទឹកអំពៅនៅក្នុងទីនោះ ក្នុងវេលាដែលលោកម្ចាស់មហាមិត្តៈជាបងប្រុសរបស់ហងមក ចូរហងដាំបាយប្រគេន មួយអន្ទើដោយសម្ល ទឹកដោះ សប្បិ និងទឹកអំពៅ ហើយហងក៏គួរបរិភោគ ឯម៉ែ ម្សិលមិញស៊ីបាយក្តាំង និងទឹកជ្រក់ ។

កូនស្រីសួរថា ថ្ងៃត្រង់ម៉ែពិសាអ្វី ឧបាសិកានោះប្រាប់ថា ហងចូរយកចុងអង្ករបបរឲ្យជូរ បន្ថែមបន្លែជ្រក់ចូលទៅ ដួសទុកឲ្យម៉ែចុះ ព្រះថេរៈដណ្តប់ចីវរ ហើយនាំបាត្រចេញ បានឮសំឡេងនោះហើយ ទូន្មានខ្លួនថា បានឮថា មហាឧបាសិកាបរិភោគបាយក្តាំង និងទឹកជ្រក់ សូម្បីពេលថ្ងៃត្រង់ ក៏បរិភោគបបរបន្ថែមទឹកជ្រក់ទៀត ។ តែប្រាប់ឲ្យចម្អិនអង្ករចាស់ជាដើមដើម្បីប្រយោជន៍ដល់អញ ឯឧបាសិកាមិនបានប្រាថ្នាស្រែ ចម្ការ កត្ត សំពត់ ព្រោះអាស្រ័យអញ តែប្រាថ្នាសម្បត្តិ ៣ ទើបប្រគេន អ្នកអាចឲ្យសម្បត្តិទាំងនោះដល់គាត់ ឬក៏មិនអាច ឯបិណ្ឌបាតនេះ ដែលអ្នកនៅមានរាគៈ ទោសៈ និងមោហៈ មិនអាចនឹងទទួលបាន ទើបទុកបាត្រក្នុងស្រោម អត់ធ្មត់ ត្រឡប់ទៅកាន់កស្សកលេណៈវិញ ទុកបាត្រក្រោមគ្រែ ពាក់ចីវរទុកលើស្នួ គិតថា បើអញមិនបានសម្រេចអរហត្ត អញនឹងមិនចេញទៅឡើយ អង្គុយធ្វើសេចក្តីព្យាយាម ហើយលោកមិនប្រមាទ ជាភិក្ខុរក្សាខ្លួនដោយសេចក្តីមិនប្រមាទ

អស់កាលដ៏យូរ ចម្រើនវិបស្សនា សម្រេចអរហត្តមុនឆាន់នោះឯង ជាព្រះខីណាស្រព ញញឹមពព្រាយចេញមក ដូចផ្កាបទុមដែលរីកដូច្នោះ ទេវតាដែលស្ថិតនៅត្រង់ដើមឈើជិតទ្វារគុហា ឃើញលោកហើយ បន្លឺឧទានថា

បពិត្របុរសជាអាជានេយ្យ ខ្ញុំសូមនមស្ការលោកម្ចាស់ បពិត្រលោកដ៏ឧត្តម ខ្ញុំសូមនមស្ការលោកម្ចាស់ បពិត្រលោកនិទ្ទុក្ខ លោកលះអាសវៈបានហើយ ទើបជាអ្នកសមគួរទទួលទក្ខិណា ។

ដូច្នោះហើយ ពោលថា បពិត្រលោកម្ចាស់ ពួកស្រីចាស់ថ្វាយភិក្ខាដល់ព្រះអរហន្ត ដូចជាលោកម្ចាស់ ដែលចូលទៅទទួលបិណ្ឌបាតហើយ នឹងផុតទុក្ខបាន ។

ព្រះថេរៈក្រោកឡើង បើកទ្វារមើលវេលា ដឹងថា នៅព្រឹកនៅឡើយ ទើបឱបបាត្រ ឃ្លុំចីវរចូលទៅកាន់ភូមិ ។ ឯកូនស្រីត្រៀមកត្ត ក៏ចេញមកអង្គុយចាំមើលត្រង់ទ្វារ ដោយបំណងថា បងប្រុសរបស់អញនឹងមកឥឡូវនេះ នឹងមកឥឡូវនេះ កាលព្រះថេរៈមកដល់ទ្វារផ្ទះ នាងក៏ទទួលបាត្រទៅដាក់បាយ លាយដោយទឹកដោះ ផ្សំដោយសប្បិ និងទឹកអំពៅទាល់តែពេញហើយនាំមកប្រគេនផ្ទាល់ដៃ ព្រះថេរៈធ្វើអនុមោទនាថា ចូរមានសេចក្តីសុខចុះ ដូច្នេះ ចៀសចេញទៅ ។ ឯកូនស្រីនោះ ក៏បានឈរសម្លឹងមើលលោករហូតភ្លឹក ។ ព្រោះពេលនោះ ឆវីវណ្ណរបស់ព្រះថេរៈផូរផង់ពន់ពេក ឥន្ទ្រិយទាំងឡាយក៏ផូរផង់ វង្វង់មុខក៏ផូរផង់ក្រៃលែង ដូចផ្លែត្នោតទុំ ដែលទើបតែជ្រុះចាកទង ដូច្នោះ ។

មហាឧបាសិកាត្រឡប់មកអំពីព្រៃ សួរថា នែហ្ន៎ បងប្រុសរបស់ហ្ន៎ មកហើយឬ នាងបាននិទានរឿងរ៉ាវទាំងអស់ឲ្យស្តាប់ ឧបាសិកាជ្រាបថា ថ្ងៃនេះ បព្វជិតកិច្ចរបស់កូនប្រុសអញដល់ទីបំផុតហើយ ទើបពោលថា នែហ្ន៎ បងប្រុសរបស់នាងគង់អភិរមមិននឿយណាយ ក្នុងព្រះពុទ្ធសាសនាឡើយ ។

វីរិយសម្ពោជ្ឈង្គ រមែងកើតដល់ភិក្ខុពិចារណាឃើញភាពជាធំនៃមត៌កឯមត៌ករបស់ព្រះសាស្តានេះ គឺអរិយទ្រព្យ ៧ ជារបស់ធំកន្លង បុគ្គលខ្ជិលប្រអូស មិនអាចទទួលមត៌កនោះបានឡើយ ដូចមាតាបិតា រមែងបណ្តេញបុត្រវិង្វូសឲ្យចេញក្រៅគំនរមត៌ក ដោយសម្គាល់ថា ឯងនេះ មិនមែនកូនរបស់អញតទៅទៀតឡើយ ព្រោះបច្ច័យ គឺការកាត់កាល់របស់មាតាបិតានោះ បុត្រវិង្វូសនោះ រមែងមិនបានមត៌ក យ៉ាងណា សូម្បីភិក្ខុដែលខ្ជិលប្រអូសក៏ដូច្នោះ នឹងមិនបានទទួលមត៌ក គឺអរិយទ្រព្យនេះ ភិក្ខុដែលប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ ទើបបានទទួលមត៌ក ។

វីរិយសម្ពោជ្ឈង្គ រមែងកើតឡើងដល់ភិក្ខុដែលពិចារណាដល់ភាពជាធំក្រៃលែងរបស់ព្រះសាស្តាយ៉ាងនេះថា ឯព្រះសាស្តារបស់អ្នកធំក្រៃលែង ព្រោះថា ក្នុងវេលាដែលព្រះសាស្តាទ្រង់ចាប់បដិសន្ធិក្នុងព្រះគភ៌ព្រះមាតាក្តី ក្នុងវេលាចេញមហាភិនេស្រ្កមណ៍ក្តី ក្នុងវេលាត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណក្តី ក្នុងវេលាសម្តែងធម្មចក្រក្តី ក្នុងវេលាសម្តែងយមកប្បាដិហារ្យក្តី ទ្រង់ចុះចាកទេវលោក និងដាក់ព្រះជន្មាយុសង្ខារក្តី លោកធាតុមួយម៉ឺនញាប់ញ័រហើយ គួរដែរឬ ដែលអ្នកបួសក្នុងសាសនារបស់ព្រះសាស្តា ដែលមាន

សភាពបែបនេះ ហើយខ្ជិលច្រអូសនោះ ។

វិរិយសម្ពោជ្ឈង្គ រមែងកើតដល់ភិក្ខុដែលពិចារណាដល់ការធំក្រៃលែង នៃជាតិកំណើតយ៉ាងនេះថា សូម្បីពោលដោយកំណើត ឥឡូវនេះ អ្នកក៏មិនមែនជាអ្នកដែលមានកំណើតថោកទាប អ្នកមកអំពីវង្សរបស់ព្រះមហាសម្មត មិនលាយឡំនឹងវណ្ណៈដទៃ ទាំងបានកើតក្នុងវង្សរបស់ព្រះបាទឱក្កាករាជ បានជាព្រះនត្តារបស់ព្រះបាទសុទ្ធោទនមហារាជ និងព្រះនាងមហាមាយាទេវី ជាប្អូនរបស់ព្រះរាហុល ដែលធម្មតាអ្នកបានជាជិនបុត្រ ដែលមានសភាពបែបនេះ គិតតែពីខ្ជិលច្រអូស មិនសមគួរឡើយ ។

វិរិយសម្ពោជ្ឈង្គ កើតឡើងដល់ភិក្ខុដែលពិចារណាដល់ភាពជាធំរបស់សព្រហ្មចារីយ៉ាងនេះថា ព្រះសារីបុត្រ ព្រះមោគ្គល្លាន និងព្រះអសីតិមហាសាវកត្រាស់ដឹងលោកុត្តរធម៌ដោយសេចក្តីព្យាយាម អ្នកនឹងដើរទៅតាមផ្លូវរបស់សព្រហ្មចារីទាំងនោះ ឬមិនដើរតាម ។

វិរិយសម្ពោជ្ឈង្គ រមែងកើតឡើងដល់ភិក្ខុដែលវៀរបុគ្គលខ្ជិលច្រអូស បោះបង់សេចក្តីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ជាបុគ្គលដូចគ្នានឹងពស់ថ្លាន់ខ្វល់ខ្វាយព្រោះតែបរិភោគចំណីរហូតពេញពោះ ដល់ភិក្ខុដែលគប់រកបុគ្គលដែលមានខ្លួនតាំងមាំ ប្រារព្ធសេចក្តីព្យាយាមផង ដល់ភិក្ខុដែលមានចិត្តបង្អោនឱន នាំទៅ ដើម្បីឲ្យកើតសេចក្តីព្យាយាម ក្នុងឥរិយាបថទាំងឡាយ មានឥរិយាបថឈរ និងអង្គុយជាដើម ។

កាលវិរិយសម្ពោជ្ឈង្គនោះកើតឡើងហើយយ៉ាងនេះ ភិក្ខុរមែងជ្រាបច្បាស់

យ៉ាងនេះថា ការចម្រើនបរិបូណ៌នៃវីរិយសម្ពោជ្ឈង្គ មានដោយអរហត្តមគ្គ ។

បីតិសម្ពោជ្ឈង្គ រមែងកើតឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងឡាយ មានធម៌ទាំងឡាយ ដែលនាំឲ្យកើតបីតិសម្ពោជ្ឈង្គ និងការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា-សិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះធម៌ជាអាហាររបស់បីតិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់បីតិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចម្រើនបរិបូណ៌ ។

ក្នុងព្រះពុទ្ធវចនៈនេះ បីតិនោះឯង ឈ្មោះថា ធម៌ជាទីតាំងនៃបីតិ-សម្ពោជ្ឈង្គ ការធ្វើទុកក្នុងចិត្តដែលឲ្យបីតិសម្ពោជ្ឈង្គនោះកើតឡើង ឈ្មោះថា ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ។

មួយ៉ាងទៀត ធម៌ ១១ ប្រការ គឺពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវតានុស្សតិ ១ ឧបសមានុស្សតិ ១ ការវៀរបុគ្គលដែលជាទោស ១ ការគប់រកបុគ្គលដែលជាគុណ ១ ការពិចារណាដល់ព្រះសូត្រ ដែលជាទីតាំងនៃសេចក្តីជ្រះថ្លា ១ ភាពជាអ្នកបង្អោនទៅក្នុងបីតិសម្ពោជ្ឈង្គនោះ ១ ។ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃបីតិសម្ពោជ្ឈង្គ ។

អធិប្បាយថា សម្រាប់ភិក្ខុដែលជាអ្នកព្យាយាម រឭកដល់ព្រះពុទ្ធគុណ បីតិសម្ពោជ្ឈង្គ រមែងកើតឡើងផ្សាយទូទៅពេញរាងកាយ រហូតដល់ឧប-ចារសមាធិ ។ សម្រាប់ភិក្ខុដែលព្យាយាមរឭកដល់ធម្មគុណ សង្ឃគុណក្តី ដែលពិចារណាដល់ចតុប្បារិសុទ្ធិសីល ដែលរក្សាមិនដាច់អស់កាលយូរក្តី

បីតិសម្ពោជ្ឈង្គ ក៏រមែងកើតឡើងបាន ។

សម្រាប់គ្រហស្ថដែលពិចារណាដល់សីល ១០ សីល ៥ ក្តី ជាអ្នកថ្វាយភោជនដ៏ប្រណីតដល់បុគ្គលដែលជាសព្រហ្មចារី ក្នុងគ្រាកើតទុព្ភិក្ខភ័យជាដើម ហើយពិចារណាដល់ការបរិច្ចាគរបស់ខ្លួនថា អញបានឲ្យយ៉ាងនេះក្តី បីតិសម្ពោជ្ឈង្គនឹងកើតឡើងបាន ។

មយ៉ាងទៀត សម្រាប់គ្រហស្ថដែលពិចារណាដល់ទាន ដែលឲ្យដល់អ្នកមានសីល ក្នុងកាលដូច្នេះក្តី ពិចារណាឃើញថា ទេវតាប្រកបដោយគុណទាំងឡាយណា ទើបដល់ភាពជាទេវតា គុណនោះ មាននៅក្នុងខ្លួនក្តី បីតិ-សម្ពោជ្ឈង្គក៏កើតឡើងបាន ។ សម្រាប់ភិក្ខុ ដែលពិចារណាឃើញកិលេសដែលសង្កត់បានហើយ ដោយសមាបត្តិថា កិលេសទាំងនេះ មិនផុយឡើងអស់ ៦០ ឆ្នាំក្តី ៧០ ឆ្នាំក្តី ចៀសវាងបុគ្គលដែលសៅហ្មង ដែលប្រាកដច្បាស់ ដោយការមិនធ្វើសេចក្តីគោរព ក្នុងកាលបានឃើញព្រះចេតិយ ពោធិ-ព្រឹក្ស និងឃើញព្រះថេរៈដែលឈ្មោះថា ដូចគ្នានឹងល្អងធូលីដែលជាប់លើជំបូល ព្រោះមិនមានការជ្រះថ្លា និងការស្រឡាញ់ក្នុងព្រះរតនត្រ័យ មានព្រះពុទ្ធអង្គជាដើមក្តី ជាអ្នកគប់រកបុគ្គលដែលផូរផង់ មានចិត្តទន់ភ្លន់ ច្រើនដោយការជ្រះថ្លាក្នុងព្រះរតនត្រ័យ មានព្រះសម្ពុទ្ធជាដើមក្តី ជាអ្នកពិចារណាដល់ព្រះសូត្រ ដែលញុំាងឲ្យកើតសេចក្តីជ្រះថ្លា សម្តែងគុណរបស់ព្រះរតនត្រ័យក្តី ជាអ្នកមានចិត្តឱនបង្អោន នាំទៅ ដើម្បីឲ្យកើតបីតិ ក្នុងឥរិយាបថឈរ និងអង្គុយជាដើមក្តី បីតិសម្ពោជ្ឈង្គ រមែងកើតឡើងបាន ។

កាលបីតិសម្ពោជ្ឈង្គនោះ កើតឡើងហើយយ៉ាងនោះ ភិក្ខុរមែងដឹងច្បាស់ថា ការចម្រើនពេញទីនៃបីតិសម្ពោជ្ឈង្គ មានដោយអរហត្តមគ្គ ។

បស្សទ្ធិសម្ពោជ្ឈង្គ រមែងកើតឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងឡាយ មានការស្ងប់ស្ងាត់កាយ ការស្ងប់ស្ងាត់ចិត្ត និងការធ្វើទុកក្នុងចិត្តដោយឧបាយ... មានការស្ងប់ស្ងាត់កាយ ការស្ងប់ស្ងាត់ចិត្ត និងការធ្វើទូវយោនិសោមនសិការឲ្យច្រើនក្នុងការស្ងប់ស្ងាត់នោះ នេះធម៌ជាអាហាររបស់បស្សទ្ធិសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់បស្សទ្ធិសម្ពោជ្ឈង្គដែលកើតហើយឲ្យចម្រើនបរិបូណ៌ ។

ម្យ៉ាងទៀត ធម៌ ៧ ប្រការ គឺការបរិភោគភោជនដែលប្រណីត ១ ការសេពសុខតាមរដូវ ១ ការសេពសុខតាមឥរិយាបថ ១ ភាពជាអ្នកមានមជ្ឈត្តប្បយោគ ១ ការវៀរបុគ្គលដែលមានកាយសោប់សេល់ ១ ការគប់រកបុគ្គលដែលមានកាយស្ងប់ ១ ភាពជាអ្នកបង្អោនទៅក្នុងបស្សទ្ធិសម្ពោជ្ឈង្គនោះ ១ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃបស្សទ្ធិសម្ពោជ្ឈង្គ ។

អធិប្បាយថា សម្រាប់ភិក្ខុអ្នកបរិភោគភោជនដែលជាសប្បាយ មានរសឆ្ងាញ់ប្រណីតក្តី អ្នកសេពឧតុដែលជាសប្បាយ ក្នុងបណ្តាឧតុរងា និងក្តៅ និងឥរិយាបថដែលជាសប្បាយ ក្នុងបណ្តាឥរិយាបថឈរជាដើមក្តី បស្សទ្ធិរមែងកើតឡើង ។

ឯភិក្ខុណា មានលក្ខណនិស្ស័យជាមហាបុរស រមែងអត់ធន់ចំពោះឧតុ និងឥរិយាបថទាំងពួងបាននោះឯង ពាក្យនេះលោកមិនបានពោលសំដៅយកភិក្ខុនោះទេ ។

សម្រាប់ភិក្ខុណា មានឧតុ និងឥរិយាបថជាសភាគ គឺជាទីសប្បាយ និង វិសភាគ គឺអសប្បាយ បស្សទ្ធិរមែងកើតឡើងដល់ភិក្ខុនោះឯង បុគ្គលសូម្បី វៀរដូវ និងឥរិយាបថដែលជាវិសភាគចេញ ហើយសេពឧតុ និងឥរិយាបថ ដែលជាសភាគ ។

ការពិចារណាឃើញថា ខ្លួន និងបុគ្គលដទៃ មានកម្មជារបស់ខ្លួន លោក ហៅថា មជ្ឈត្តប្បយោគ បស្សទ្ធិរមែងកើតឡើងបាន ព្រោះមជ្ឈត្តប្បយោគ នេះ ។ សម្រាប់ភិក្ខុដែលវៀរបុគ្គលអ្នកមានកាយសោប់សេល់ ជាអ្នកត្រាច់ បៀតបៀនអ្នកដទៃសព្វកាល ដោយដុំដី និងកំណាត់ឈើជាដើម សេពគប់ រកបុគ្គលដែលមានកាយស្ងប់ ជាអ្នកសង្រួមដៃ និងជើងក្តី ជាអ្នកមានចិត្ត បង្អោន ទោរទន់ នាំទៅដើម្បីឲ្យកើតបស្សទ្ធិ ក្នុងឥរិយាបថទាំងឡាយ មាន ឈរ និងអង្គុយជាដើមក្តី បស្សទ្ធិរមែងកើតឡើងបាន ។

កាលបស្សទ្ធិសម្ពោជ្ឈង្គនោះ កើតឡើងហើយយ៉ាងនោះ ភិក្ខុរមែងដឹង ច្បាស់ថា ការចម្រើនបរិបូណ៌ក្រៃលែងនៃបស្សទ្ធិសម្ពោជ្ឈង្គ រមែងមានដោយ អរហត្តមគ្គ ។

សមាធិសម្ពោជ្ឈង្គ រមែងកើតឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងឡាយ មានតែសមាធិនិមិត្ត អព្យគ្គនិមិត្ត និងការធ្វើទុកយោនិសោមនសិការឲ្យច្រើន ក្នុងនិមិត្តទាំងនោះ នេះធម៌ជាអាហាររបស់សមាធិសម្ពោជ្ឈង្គ ដែលមិនទាន់ កើត ឲ្យកើតឡើងបាន ឬរបស់សមាធិសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចម្រើន បរិបូណ៌ ។ ក្នុងសមាធិសម្ពោជ្ឈង្គនោះ សមថនិមិត្ត ជាសមថៈផង ឈ្មោះ

ថា អព្យគ្គនិមិត្ត ព្រោះអត្ថថា មិនរាយមាយផង ។

ម្យ៉ាងទៀត ធម៌ ១១ ប្រការ គឺការធ្វើវត្ថុឲ្យស្អាតបរិសុទ្ធ ១ ការផ្គង ឥន្ទ្រិយឲ្យប្រព្រឹត្តទៅស្មើ ១ ជាអ្នកឈ្លាសក្នុងនិមិត្ត ១ ការលើកចិត្តក្នុង សម័យដែលគួរលើក ១ ការសង្កត់ចិត្តក្នុងសម័យដែលគួរសង្កត់ ១ ការធ្វើ ចិត្តឲ្យក្មៀវក្លាក្នុងសម័យ ១ ការសម្លឹងមើលចិត្តព្រងើយៗ ក្នុងសម័យ ១ ការវៀរបុគ្គលដែលមានចិត្តមិនជាសមាធិ ១ ការគប់រកបុគ្គលដែលមានចិត្ត ជាសមាធិ ១ ការពិចារណាឈាន និងវិមោក្ខ ១ ភាពជាអ្នកបង្អោនទៅក្នុង សមាធិសម្ពោជ្ឈង្គនោះ ១ ។ រមែងប្រព្រឹត្តទៅ ដើម្បីការកើតនៃសមាធិ- សម្ពោជ្ឈង្គ ។

បណ្តាធម៌ ១១ ប្រការនោះ គួរធ្វើវត្ថុឲ្យស្អាតបរិសុទ្ធ និងការផ្គងឥន្ទ្រិយ ឲ្យប្រព្រឹត្តទៅស្មើ គប្បីជ្រាបតាមន័យដែលពោលហើយ ។ ភាពជាអ្នក ឈ្លាសក្នុងការរៀនយកកសិណនិមិត្ត ឈ្មោះថា ជាអ្នកឈ្លាសក្នុងនិមិត្ត ។

បទថា **សមយេ ចិត្តស្ស បគ្គណ្ហនតា** ប្រែថា ការផ្គងចិត្តក្នុងសម័យ ដែលគួរផ្គង អធិប្បាយថា ក្នុងសម័យណាចិត្តជាធម្មជាតរួញរា ដោយហេតុ ទាំងឡាយ មានការធ្វើធូរថយពេកជាដើម ការលើកចិត្តនោះក្នុងសម័យនោះ ដោយការញុំាងធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ និងបីតិសម្ពោជ្ឈង្គឲ្យ កើតព្រមគ្នា ។

បទថា **សមយេ ចិត្តស្ស និគ្គណ្ហនតា** ប្រែថា ការសង្កត់ចិត្តក្នុង សម័យដែលគួរសង្កត់ សេចក្តីថា ក្នុងសម័យណា ចិត្តជាធម្មជាតរាយមាយ

ដោយហេតុទាំងឡាយ មានការប្រារព្ធសេចក្ដីព្យាយាមខ្លាំងក្លាពេកជាដើម ការសង្កត់ចិត្តនោះ ក្នុងសម័យនោះ ដោយការញ៉ាំងបស្សទ្ធិសម្ពោជ្ឈង្គ សមាធិ-សម្ពោជ្ឈង្គ និងឧបេក្ខាសម្ពោជ្ឈង្គឲ្យកើតឡើងព្រមគ្នា ។

បទថា **សមយេ សម្បហំសនតា** ប្រែថា ការផ្គងចិត្តឲ្យក្លៀវក្លា ក្នុងសម័យដែលគួរផ្គងចិត្តឲ្យក្លៀវក្លា សេចក្ដីថា ក្នុងសម័យណា ចិត្តជាធម្មជាតមិនស្រស់ថ្លា ព្រោះមានបញ្ញា និងសេចក្ដីព្យាយាមតិច ឬព្រោះមិនបានសម្រេចដល់សេចក្ដីសុខ ដែលកើតអំពីការចូលទៅស្ងប់ ក្នុងសម័យនោះ ព្រះយោគាវចរ រមែងញ៉ាំងចិត្តឲ្យសង្វេគ ដោយការពិចារណាសង្វេគវត្ថុ ៨ យ៉ាង ដែលឈ្មោះថា សង្វេគវត្ថុ ៨ បានដល់ ជាតិ ជរា ព្យាធិ និងមរណៈ រួមជា ៤ ទុក្ខក្នុងអបាយជាគម្រប់ ៥ ទុក្ខដែលមានវដ្ដៈជាមូលក្នុងអតីត ទុក្ខដែលមានវដ្ដៈជាមូលក្នុងអនាគត ទុក្ខមានការស្វែងរកអាហារជាមូល ក្នុងបច្ចុប្បន្ន ។ និងឲ្យកើតការជ្រះថ្លាដោយការព្យាយាមរឭកដល់គុណព្រះរតន-ត្រ័យ ។ នេះហៅថា ការផ្គងចិត្តទុកក្លៀវក្លា ក្នុងសម័យដែលគួរផ្គងចិត្តឲ្យក្លៀវក្លា ។

ដែលឈ្មោះថា ការសម្លឹងមើលចិត្តព្រងើយៗ ក្នុងសម័យដែលគួរសម្លឹងបានដល់ ក្នុងសម័យណាចិត្ត ជាធម្មជាតមិនរួញរា មិនរាយមាយ ឆាកវេស្រស់ថ្លា ប្រព្រឹត្តទៅក្នុអារម្មណ៍យ៉ាងស្មើ ដើរទៅតាមវិថីរបស់សមថៈ ព្រោះអាស្រ័យបដិបត្តិប្រពៃក្នុងការលើក ការសង្កត់ និងការផ្គងចិត្តនោះ ឲ្យក្លៀវក្លា ប្រៀបដូចនាយសារថី មិនរវល់ក្នុងសេះដែលរត់ទៅស្មើ នេះហៅថា ការ

សម្លឹងមើលចិត្តព្រងើយៗ ក្នុងសម័យដែលគួរសម្លឹង ។

ដែលឈ្មោះថា ការវៀរបុគ្គលដែលមានចិត្តមិនជាសមាធិ បានដល់ ការវៀរឲ្យឆ្ងាយនូវបុគ្គលដែលមិនបានសម្រេចឧបចារសមាធិ ឬអប្បនាសមាធិ ដែលមានចិត្តរាយមាយ ។

ដែលឈ្មោះថា ការគប់រកបុគ្គលដែលមានចិត្តជាសមាធិ បានដល់ ការសេព ការគប់រក ការចូលទៅអង្គុយជិតបុគ្គលដែលមានចិត្តតាំងមាំ ដោយឧបចារសមាធិ ឬអប្បនាសមាធិ ។

ដែលឈ្មោះថា ភាពជាអ្នកបង្អោនទៅក្នុងសមាធិសម្ពោជ្ឈង្គនោះ បានដល់ ភាពជាបុគ្គលមានចិត្តបង្អោន ឱន នាំទៅក្នុងឥរិយាបថទាំងឡាយ មានឈរ និងអង្គុយជាដើមនោះឯង ។

កាលព្រះយោគាវចរបដិបត្តិយ៉ាងនេះ សមាធិសម្ពោជ្ឈង្គនោះកើតឡើង កាលសមាធិសម្ពោជ្ឈង្គនោះកើតឡើងយ៉ាងនោះ ព្រះយោគាវចររមែងជ្រាបច្បាស់ថា ការចម្រើនក្រៃលែងនៃសមាធិសម្ពោជ្ឈង្គ មានដោយអំណាចអរហត្តមគ្គ ។

ឧបេក្ខាសម្ពោជ្ឈង្គ រមែងកើតឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងឡាយ មានពួកធម៌ដែលនាំឲ្យកើតឧបេក្ខាសម្ពោជ្ឈង្គ និងការធ្វើនូវយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះធម៌ជាអាហាររបស់ឧបេក្ខាសម្ពោជ្ឈង្គដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ឧបេក្ខាសម្ពោជ្ឈង្គដែលកើតហើយ ឲ្យចម្រើនបរិបូណ៌ ។ ក្នុងព្រះតម្រាស់នោះ ឧបេក្ខានោះឯង ឈ្មោះ

ថា ធម៌ជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គ ។

ម្យ៉ាងទៀត ធម៌ ៥ ប្រការ គឺភាពជាអ្នកដាក់ខ្លួនជាកណ្តាលក្នុងសត្វ ១ ភាពជាអ្នកដាក់ខ្លួនជាកណ្តាលក្នុងសង្ខារ ១ ការវៀរបុគ្គលដែលជាប់ជំពាក់ក្នុងសត្វ និងសង្ខារ ១ ការគប់រកបុគ្គលដែលដាក់ខ្លួនជាកណ្តាលក្នុងសត្វ និងសង្ខារ ១ ភាពជាអ្នកបង្អោនទៅក្នុងឧបេក្ខាសម្ពោជ្ឈង្គនោះ ១ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គ ។

បណ្តាធម៌ ៥ ប្រការនោះ ព្រះយោគាវចររមែងញ៉ាំងការដាក់ខ្លួនជាកណ្តាលក្នុងសត្វឲ្យកើតឡើង ដោយអាការ ២ យ៉ាង គឺដោយការពិចារណាឃើញថា សត្វមានកម្មជារបស់ខ្លួនយ៉ាងនេះថា អ្នកមកតាមកម្មរបស់ខ្លួនហើយ ក៏នឹងទៅតាមកម្មរបស់ខ្លួន អ្នកនឹងជាប់ជំពាក់ក្នុងបុគ្គលណា និងដោយការពិចារណាឃើញថា មិនមែនសត្វយ៉ាងនេះថា ពោលដោយបរមត្ថហើយ សត្វមិនមានឡើយ តើអ្នកនឹងជាប់ជំពាក់ក្នុងបុគ្គលណា ។

រមែងញ៉ាំងការដាក់ខ្លួនជាកណ្តាលក្នុងសង្ខារឲ្យកើតឡើង ដោយអាការ ២ យ៉ាង គឺដោយពិចារណាឃើញថា មិនមានម្ចាស់យ៉ាងនេះថា ចីវរមួយផ្ទាំងនេះចូលដល់នូវការប្រែពណ៌ ការគ្រាំគ្រាតាមលំដាប់ នឹងក្លាយជាសំពត់ជូតជើង ត្រូវគេគ្រឹះបោលដោយចុងឈើច្រត់ បើចីវរនោះគប្បីមានម្ចាស់សោត ម្ចាស់ក៏មិនព្រមឲ្យចីវរនោះវិនាសទៅយ៉ាងនោះ ១ និងដោយការពិចារណាឃើញថា ជារបស់មួយជួរខណៈយ៉ាងនេះថា ចីវរនេះ មិនស្ថិតស្ថេរនៅបានមួយជួរខណៈ ១ ។

ម្យ៉ាងទៀត បណ្ឌិតគប្បីធ្វើការប្រកបសេចក្តីនោះក្នុងបាត្រជាដើម ដូចក្នុងចីវរនោះឯង ។

ក្នុងពាក្យថា **សត្តសង្ខារកេឡាយនបុគ្គលបរិវជ្ជនតា** ប្រែថា វៀរបុគ្គលដែលជាប់ជំពាក់ក្នុងសត្វ និងសង្ខារ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បុគ្គលណា ជាគ្រហស្ថ រមែងប្រកាន់បិយជនទាំងឡាយ មានបុត្រ និងធីតាជាដើមរបស់ខ្លួន ថាជារបស់អញ ឬជាបព្វជិត រមែងប្រកាន់អន្តេវាសិក សទ្ធិវិហារិក និងអ្នករួមឧបជ្ឈាយ៍ជាដើមរបស់ខ្លួនថា ជារបស់អញ រួមធ្វើការងារទាំងឡាយ មានការកោរសក់ ដេរសំពត់ បោកចីវរ ជ្រលក់ចីវរ និងអប់បាត្រជាដើមឲ្យដល់បុគ្គលទាំងនោះដោយខ្លួនឯង មិនឃើញត្រឹមតែមួយសន្ទុះក៏ត្រាច់ដើររក មិនខុសអ្វីនឹងម្រឹគដែលភ្ញាក់ផ្អើល ស្រែកសួរថា សាមណេររូបនោះទៅណា ភិក្ខុកំលោះរូបនោះទៅណា សូម្បីត្រូវអ្នកដទៃសូមថា សូមលោកម្ចាស់ បញ្ជូនភិក្ខុកំលោះ ឬសាមណេររូបនោះទៅឲ្យជួយកោរសក់ជាដើមមួយរយៈចុះ ក៏មិនព្រមឲ្យទៅ ដោយអាងថា សូម្បីពួកយើងក៏មិនព្រមប្រើឲ្យបុគ្គលនេះធ្វើការរបស់ខ្លួនឡើយ ពួកអ្នកមកយកបុគ្គលនេះទៅធ្វើការឲ្យលំបាក បុគ្គលនេះ ឈ្មោះថា ជាអ្នកជាប់ជំពាក់ក្នុងសត្វ ។

ឯបុគ្គលណា ប្រកាន់ក្នុងបាត្រ ចីវរ ថាស និងឈើច្រត់មនុស្សចាស់ជាដើម ថាជារបស់អញ មិនព្រមឲ្យអ្នកដទៃ សូម្បីគ្រាន់តែយកដៃប៉ះ បើត្រូវខ្ចី ក៏ពោលថា ពួកយើងទាំងឡាយស្រឡាញ់ទ្រព្យនេះ មិនព្រមប្រើប្រាស់ពួកយើងនឹងឲ្យពួកអ្នកបានដូចម្តេច បុគ្គលនេះ ឈ្មោះថា ជាប់ជំពាក់ក្នុង

សង្ខារ ។

ឯបុគ្គលណា ជាអ្នកមានខ្លួនជាកណ្តាល ព្រងើយក្នុងវត្ថុទាំង ២ នោះ បុគ្គលនេះ ឈ្មោះថា ដាក់ខ្លួនជាកណ្តាល ក្នុងសត្វ និងសង្ខារ ។

ឧបេក្ខាសម្ពោជ្ឈង្គនេះ រមែងកើតឡើងដល់ព្រះយោគាវចរ ដែលវៀរឆ្ងាយបុគ្គលអ្នកជាប់ជំពាក់ក្នុងសត្វ និងសង្ខារ ដែលមានសភាពបែបនេះផង ជាអ្នកគប់រកបុគ្គលដែលដាក់ខ្លួនជាកណ្តាលក្នុងសត្វ និងសង្ខារផង ជាអ្នកមានចិត្តបង្អោន ទោរទន់ នាំទៅ ដើម្បីឲ្យកើតឧបេក្ខាសម្ពោជ្ឈង្គនោះ ក្នុងឥរិយាបថទាំងឡាយ មានឈរ និងអង្គុយជាដើមផង ដូចពណ៌នាមកនេះ ។

កាលឧបេក្ខាសម្ពោជ្ឈង្គនោះកើតឡើងយ៉ាងនោះ ព្រះយោគាវចររមែងជ្រាបច្បាស់ថា ការចម្រើនបរិបូណ៌នៃឧបេក្ខាសម្ពោជ្ឈង្គ មានដោយអំណាចអរហត្តមគ្គ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរនោះ កំណត់ពោជ្ឈង្គ ៧ របស់ខ្លួន ឬរបស់អ្នកដទៃយ៉ាងនេះហើយ គឺកំណត់ពោជ្ឈង្គរបស់ខ្លួនតាមកាលផង ពោជ្ឈង្គរបស់អ្នកដទៃតាមកាលផង ជាអ្នកមានប្រក្រតីពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយយ៉ាងនេះ ។ ឯការកើតឡើង និងការរលត់ទៅក្នុងពោជ្ឈង្គបព្វៈនេះ គប្បីជ្រាបដោយអំណាចការកើត និងការរលត់របស់សម្ពោជ្ឈង្គទាំងឡាយ ។ ពាក្យដទៃក្រៅអំពីនេះ មានន័យដូចពោលមកហើយ ។

ដោយក្នុងពោជ្ឈង្គបព្វៈនេះ សតិដែលកំណត់ពោជ្ឈង្គ ជាទុក្ខសច្ចៈតែម្យ៉ាង

អ្នកសិក្សាគប្បីជ្រាបផ្លូវនៃធម៌ ជាគ្រឿងនាំចេញរបស់ភិក្ខុ អ្នកដែលកំណត់ពោជ្ឈង្គ ព្រោះការប្រកបសេចក្ដីដូចពោលមកនេះឯង ពាក្យដ៏សេស ដូចគ្នានឹងពោលមកហើយនោះឯង ។

## ពោជ្ឈង្គបព្វៈ ចប់

# សច្ចបព្វៈ

[ ១៤៥ ] កាលទ្រង់ចែកធម្មានុបស្សនាដោយអំណាចពោជ្ឈង្គ ៧ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយអំណាចសច្ចៈ ៤ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **បុន ចបរំ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ** សេចក្ដីថា ព្រះយោគាវចរ រមែងជ្រាបច្បាស់នូវធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ៣ វៀរតណ្ហា តាមសេចក្ដីពិតថា នេះទុក្ខ រមែងជ្រាបច្បាស់នូវបុរិមតណ្ហាដែលជាហេតុឲ្យទុក្ខនោះឯងកើត គឺតាំងឡើងតាមសេចក្ដីពិតថា នេះទុក្ខសមុទយៈ រមែងជ្រាបច្បាស់ព្រះនិព្វាន គឺការមិនប្រព្រឹត្តទៅរបស់ទុក្ខ និងតណ្ហាទាំង ២ តាមសេចក្ដីពិតថា នេះទុក្ខនិរោធ រមែងជ្រាបច្បាស់អរិយមគ្គដែលជាតួកំណត់ដឹងទុក្ខ លះសមុទយៈ ធ្វើនិរោធឲ្យជាក់ច្បាស់តាមសេចក្ដីពិតថា នេះទុក្ខនិរោធគាមិនីបដិបទា ។ កថាពោលដោយអរិយសច្ចដ៏សេស បានអធិប្បាយទុកឲ្យពិស្ដារហើយ ក្នុងវិសុទ្ធិមគ្គនោះឯង ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្ដីថា ព្រះយោគាវចរកំណត់សច្ចៈ ៤

របស់ខ្លួន ឬរបស់បុគ្គលដទៃហើយ គឺកំណត់សច្ចៈទាំង ៤ របស់ខ្លួនតាមកាល ឬរបស់បុគ្គលដទៃតាមកាល ជាអ្នកមានប្រក្រតីពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ ឯការកើតឡើង និងការរលត់ទៅក្នុងចតុសច្ចបព្វៈនេះ គប្បីជ្រាបដោយអំណាចការកើតឡើង និងការរលត់របស់សច្ចៈទាំង ៤ តាមសេចក្តីពិត ។ ពាក្យដទៃក្រៅអំពីនេះ មានន័យដូចពោលហើយនោះឯង ។

ក្នុងចតុសច្ចបព្វៈនេះ សតិជាគ្រឿងកំណត់សច្ចៈ ៤ ជាទុក្ខសច្ចតែម្យ៉ាង បណ្ឌិតគប្បីជ្រាបផ្លូវនៃធម៌ជាគ្រឿងនាំចេញរបស់ភិក្ខុដែលកំណត់សច្ចៈ ព្រោះការប្រកបសេចក្តីដូចពោលមកនេះឯង ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យដែលពោលមកហើយនោះឯង ។

## ចតុសច្ចបព្វៈ ចប់

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះមានព្រះភាគត្រាស់កម្មដ្ឋាន ២១ យ៉ាង គឺអានាបាន ១ ចតុឥរិយាបថ ១ ចតុសម្បជញ្ញៈ ១ ទ្វត្តឹង្សាការ ( អាការ ៣២ ) ១ ចតុធាតុវវដ្ឋាន ១ នវសីវថិកា ១ វេទនានុបស្សនា ១ ចិត្តានុបស្សនា ១ នីវរណបរិគ្គហៈ ១ ខន្ធបរិគ្គហៈ ១ អាយតនបរិគ្គហៈ ១ ពោជ្ឈង្គបរិគ្គហៈ ១ សច្ចបរិគ្គហៈ ១ ។

បណ្តាកម្មដ្ឋាន ២១ យ៉ាងនោះ អានាបាន ១ ទ្វត្តឹង្សាការ ១ នវសីវថិកា ១ រួមជាកម្មដ្ឋានដែលឲ្យដល់អប្បនា ១១ ។ ឯព្រះមហាសិវត្ថេរដែលជាអ្នកពោលគម្ពីរទីឃនិកាយ ពោលថា ព្រះមានព្រះភាគ ត្រាស់នវសីវថិកា ដោយអំណាចការពិចារណាឃើញទោស ។ ព្រោះដូច្នោះ តាមមតិរបស់ព្រះ

មហាសិវត្ថេរនោះ កម្មដ្ឋាន ២ គឺអានាបាន និងទ្វត្តឹង្សាការប៉ុណ្ណោះ ជាកម្មដ្ឋានឲ្យដល់អប្បនា កម្មដ្ឋានដ៏សេស ជាកម្មដ្ឋានដែលឲ្យដល់ឧបចារៈប៉ុណ្ណោះ ។

សួរថា ការប្រកាន់មាំកើតក្នុងកម្មដ្ឋានទាំងអស់នោះ ឬមិនកើត ឆ្លើយថា មិនកើត ព្រោះថា ការប្រកាន់មាំរមែងមិនកើតក្នុងឥរិយាបថ សម្បជញ្ញៈ នីវរណៈ និងសម្ពោជ្ឈង្គ តែកើតក្នុងកម្មដ្ឋានដ៏សេស ។

ឯព្រះមហាសិវត្ថេរពោលថា រមែងកើតការប្រកាន់មាំក្នុងកម្មដ្ឋានទាំងនោះ មានឥរិយាបថជាដើម ព្រោះថា ព្រះយោគាវចរនេះ រមែងកំណត់យ៉ាងនេះថា ឥរិយាបថ ៤ របស់អញ មាន ឬមិនមាន សម្បជញ្ញៈ ៤ របស់អញ មាន ឬមិនមាន នីវរណៈ ៥ របស់អញ មាន ឬមិនមាន ពោជ្ឈង្គ ៧ របស់អញ មាន ឬមិនមាន ព្រោះដូច្នោះ ទើបកើតការប្រកាន់មាំក្នុងកម្មដ្ឋានគ្រប់ប្រការ ។

## អានិសង្សក្នុងការចម្រើនសតិប្បដ្ឋាន

[ ១៥១ ] បទថា **យោ ហិ កោចិ ភិក្ខវេ** សេចក្តីថា បុគ្គលណាម្នាក់ជាភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ។ បទថា **ឯវំ ភាវេយ្យ** សេចក្តីថា គប្បីចម្រើនសតិប្បដ្ឋានទៅតាមលំដាប់នៃការនា ដែលព្រះមានព្រះភាគត្រាស់តាំងអំពីដំបូង ។ បទថា **ចាដិកង្ខំ** ប្រែថា គប្បីសង្ឃឹម អធិប្បាយថា មានពិត ។ បទថា **អញ្ញា** បានដល់ អរហត្តផល ។ បទថា **សតិ វា ឧបាទិសេសេ** សេចក្តីថា ឬកាលឧបាទាននៅសេសសល់ គឺមិន

ទាន់អស់ទៅ ។ បទថា **អញ្ញាតាវិនា** បានដល់ ភាពជាព្រះអនាគាមី ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងភាពដែលសាសនធម៌ ជាគ្រឿងនាំចេញដោយអំណាចរយៈពេល ៧ ឆ្នាំយ៉ាងនេះហើយ កាលទ្រង់សម្តែងរយៈពេលដែលខ្លីជាងនោះទៅទៀត ទើបត្រាស់ពាក្យថា **តិដ្ឋន្តុ ភិក្ខវេ** ដូច្នេះជាដើម ព្រោះធម៌ទាំងអស់នោះ ព្រះមានព្រះភាគត្រាស់ដោយអំណាចវេនេយ្យបុគ្គល ( មានសតិបញ្ញា ) ជាកណ្តាលប៉ុណ្ណោះ ។ ឯបុរាណាចារ្យសំដៅយកបុគ្គលដែលមានបញ្ញាចាស់ក្លា ទើបពោលថា បុគ្គលមានបញ្ញាចាស់ក្លា បានទទួលពាក្យប្រៀនប្រដៅក្នុងពេលព្រឹក ក៏នឹងសម្រេចគុណវិសេសបានក្នុងពេលល្ងាច បានទទួលពាក្យប្រៀនប្រដៅក្នុងពេលល្ងាច ក៏នឹងសម្រេចគុណវិសេសបានក្នុងពេលព្រឹក ។

[ ១៥២ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ សាសនធម៌របស់តថាគត ជាធម៌ គឺគ្រឿងនាំចេញយ៉ាងនេះ ដូចពណ៌នាមកដូច្នេះហើយ កាលទ្រង់លើកតម្កើងព្រះធម្មទេសនា ដែលទ្រង់សម្តែងហើយដោយកំពូល គឺអរហត្តក្នុងឋានៈ ២១ យ៉ាងដល់ព្រះសាវក ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះ ជាផ្លូវឯក ។បេ។ ព្រោះអាស្រ័យពាក្យដែលពោលមកហើយយ៉ាងនេះ ទើបតថាគតបានពោលសតិប្បដ្ឋានសូត្រនេះ ។ ពាក្យដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ។៚

**សតិប្បដ្ឋានសូត្រទី ១០ ចប់**

**វគ្គទី ១ ឈ្មោះ មូលបរិយាយ ចប់**

# ក្បាលទី ១៣

# សុត្តន្តនិកាយ បាលីប្រែ -២០

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ


**មូលបរិយាយសូត្រទី ១** ...... ...... ...... ....... ..... ២

**អដ្ឋកថា មូលបរិយាយសូត្រ** ( បទនមស្ការព្រះរតនត្រ័យ ) ....... ១៧

អត្ថរបស់ ឯវំ សព្ទជាដើម ...... ...... ...... ...... ...... ...... ...... ២០

ការមកនៃឈ្មោះនគរឧក្កដ្ឋា ...... ...... ...... ...... ...... ...... ...... ៣៩

ការមកនៃឈ្មោះព្រៃសុភគវន ...... ...... ...... ...... ...... ...... ៤០

អត្ថរបស់ មូល សព្ទ ...... ...... ...... ...... ...... ...... ...... ៤៣

ហេតុកើតព្រះសូត្រ ៤ យ៉ាង .... ...... ...... ...... ...... ...... ...... ៥១

អត្ថរបស់ វោ សព្ទ ...... ...... ...... ...... ...... ...... ...... ៥៧

អត្ថរបស់ សាធុ សព្ទ ...... ...... ...... ...... ...... ...... ...... ៥៩

អត្ថរបស់ បុថុជ្ជន សព្ទ ...... ...... ...... ...... ...... ...... ...... ៦៣

វិន័យ ២ យ៉ាង ...... ...... ...... ...... ...... ...... ...... ៦៧

បហាន ៥ យ៉ាង ...... ...... ...... ...... ...... ...... ...... ៦៩

ទេសនា ៤ យ៉ាង ...... ...... ...... ...... ...... ...... ...... ៧១

បឋវី ៤ ប្រការ ...... ...... ...... ...... ...... ...... ...... ៧៣

អធិប្បាយ អាបោធាតុជាដើម ... ...... ...... ...... ...... ...... ...... ៨៤

អធិប្បាយ ភូត សព្ទ ...... ...... ...... ...... ...... ...... ...... ៨៨

ទេវ ៣ យ៉ាង ...... ...... ...... ...... ...... ...... ...... ៩៣

អំពីទេវបុត្តមារ ...... ...... ...... ...... ...... ...... ...... ៩៣

អត្ថរបស់ ព្រហ្ម សព្ទ ...... ...... ...... ...... ...... ...... ...... ៩៦

អំពីសុទ្ធាវាសភូមិ ...... ...... ...... ...... ...... ...... ...... ៩៩
អធិប្បាយ ទិដ្ឋ សព្ទជាដើម ...... ...... ...... ...... ...... ...... ...... ១០០
អធិប្បាយ ឯកត្តំ នានត្តំ ...... ...... ...... ...... ...... ...... ...... ១០៣
អធិប្បាយ សេក្ខបុគ្គល ...... ...... ...... ...... ...... ...... ...... ១០៨
អត្ថរបស់ មានស សព្ទ ...... ...... ...... ...... ...... ...... ...... ១១០
អធិប្បាយ អរិយបុគ្គល ...... ...... ...... ...... ...... ...... ...... ១១៤
អធិប្បាយ ពាក្យថា តថាគត ...... ...... ...... ...... ...... ...... ១២១
អធិប្បាយ ពាក្យថា នន្ទិ ទុក្ខស្ស មូលំ ...... ...... ...... ....... ១៣៩
អត្ថរបស់ ពោធិ សព្ទ ...... ...... ...... ...... ...... ...... ...... ១៤៤
ភិក្ខុមិនត្រេកអរនឹងភាសិតរបស់ព្រះតថាគត ...... ...... ...... ...... ១៤៧

**សព្វាសវសំវរសូត្រទី២** ...... ...... ...... ...... ...... ...... ..... ១៥៦

**អដ្ឋកថាសព្វាសវសំវរសូត្រ** អធិប្បាយទីមកនៃពាក្យថាសាវត្ថីនិងជេតវន ១៧០
អាសវៈលះបានដោយទស្សនៈ ...... ...... ...... ...... ...... ....... ១៨៦
អាសវៈលះបានដោយសំវរៈ ..... ..... ...... ...... ...... ...... ....... ២០៤
អាសវៈលះបានដោយការពិចារណា ...... ...... ...... ...... ....... ២១០
អាសវៈបានដោយការអត់ធន់ ...... ...... ...... ...... ....... ២១១
អាសវៈបានដោយការវៀរ ...... ...... ...... ...... ...... ...... ២១៦
អាសវៈលះបានដោយការបន្ទោបង់ ...... ...... ...... ...... ...... ...... ២១៩
អាសវៈលះបានដោយការចម្រើន ...... ...... ...... ...... ...... ...... ២២១
វិវេក ៥ យ៉ាង ...... ...... ...... ...... ...... ...... ២២៧

**ធម្មទាយាទសូត្រទី៣** ...... ...... ...... ...... ...... ...... ........ ២៣៤

**អដ្ឋកថា ធម្មទាយាទសូត្រ** ( ហេតុកើតព្រះសូត្រ ) ...... ....... ២៤៤
មត្តិក ២ យ៉ាង ...... ...... ...... ...... ...... ...... ....... ២៤៧

បវារណា ៤ យ៉ាង ...... ...... ...... ...... ...... ...... ....... ២៥៧

អត្ថរបស់ វុត្ត សព្ទ ...... ...... ...... ...... ...... ...... ....... ២៦១

បិណ្ឌបាតដែលមិនគួរឆាន់ ៥ យ៉ាង ...... ...... ...... ...... ....... ២៦៣

អត្ថរបស់ ឋាន សព្ទ ...... ...... ...... ...... ...... ...... ....... ២៧៩

**ភយភេរវសូត្រទី៤** ........ ...... ...... ...... ...... ...... ....... ២៩៩

**អដ្ឋកថា ភយភេរវសូត្រ** ....... ...... ...... ...... ...... ...... ........ ៣១៨

ទោសនៃការអគ្គិយ ៦ យ៉ាង ...... ...... ...... ...... ...... ........ ៣២១

កុលបុត្ត ២ ពួក ....... ...... ...... ...... ...... ...... ........ ៣២២

សេនាសនៈព្រៃ ....... ...... ...... ...... ...... ...... ........ ៣២៥

កាយកម្មកថា ....... ...... ...... ...... ...... ...... ........ ៣២៧

វចីកម្មកថាជាដើម ....... ...... ...... ...... ...... ...... ........ ៣៣០

រឿងបិយគាមិកភិក្ខុ ....... ...... ...... ...... ...... ...... ........ ៣៣៦

អធិប្បាយសេនាសនៈគួរភ័យខ្លាច ...... ...... ...... ...... ...... ....... ៣៤០

អធិប្បាយបុព្វភាគបដិបទា ...... ...... ...... ...... ...... ....... ៣៥២

បុព្វេនិវាសានុស្សតិញ្ញាណជាដើម ...... ...... ...... ...... ...... ....... ៣៥៧

ប្រយោជន៍នៃការនៅព្រៃ ២ យ៉ាង ...... ...... ...... ...... ...... ....... ៣៦៥

អត្ថរបស់ អភិក្កន្ត សព្ទ ...... ...... ...... ...... ...... ...... ....... ៣៦៧

ឧបមា ៤ យ៉ាង ...... ...... ...... ...... ...... ...... ....... ៣៧១

សរណគមនកថា ...... ...... ...... ...... ...... ...... ....... ៣៧៤

**អនង្គណសូត្រទី ៥** ........ ...... ...... ...... ...... ...... ....... ៣៨៨

**អដ្ឋកថា អនង្គណសូត្រ** ( ទេសនា ២ យ៉ាង ) ...... ...... ....... ៤០៨

ហេតុដែលទ្រង់ត្រាស់បុគ្គល ៨ យ៉ាង ...... ...... ...... ...... ....... ៤១០

ភិក្ខុខឹងក្រោធ ...... ...... ...... ...... ....... ៤២៨

**អាកង្ខេយ្យសូត្រទី ៦** ........ ...... ...... ...... ...... ...... ........ ៤៥០

**អដ្ឋកថា អាកង្ខេយ្យសូត្រ** ........ ...... ...... ...... ...... ...... ........ ៤៥៨

*ទោសរបស់ស្រែ ៤ យ៉ាង* ........ ...... ...... ...... ...... ...... ........ ៤៥៩

*សីលបរិបូណ៌ដោយហេតុ ២ ប្រការ* ...... ...... ...... ...... ........ ៤៦១

*អធិប្បាយសេចក្តីប្រាថ្នា ១៣ យ៉ាង* ...... ...... ...... ...... ........ ៤៦៣

*រឿងព្រះមហាទត្តត្ថេរ* ........ ...... ...... ...... ...... ...... ........ ៤៧៤

**វត្ថូបមសូត្រទី ៧** ........ ...... ...... ...... ...... ...... ........ ៤៨៧

**អដ្ឋកថា វត្ថូបមសូត្រ** ........ ...... ...... ...... ...... ...... ........ ៤៩៩

*ទុគ្គតិ ២ យ៉ាង* ........ ...... ...... ...... ...... ...... ........ ៥០៣

*សុគតិ ២ យ៉ាង* ........ ...... ...... ...... ...... ...... ........ ៥០៤

*ឧបក្កិលេស ១៦* ........ ...... ...... ...... ...... ...... ........ ៥០៥

*ការលះឧបក្កិលេស* ........ ...... ...... ...... ...... ...... ........ ៥១០

*អត្ថរបស់ វេទ សព្ទ* ........ ...... ...... ...... ...... ...... ........ ៥១៦

**សល្លេខសូត្រទី ៨** ........ ...... ...... ...... ...... ...... ........ ៥៣៤

**អដ្ឋកថា សល្លេខសូត្រ** ( *ពុទ្ធនិយាម* ) ...... ...... ...... ...... ...... ៥៥១

*មិច្ឆាទិដ្ឋិ ៨ យ៉ាង* ........ ...... ...... ...... ...... ...... ........ ៥៥៣

*រឿងព្រះធម្មទិន្នត្ថេរ* ........ ...... ...... ...... ...... ...... ........ ៥៥៨

*បាទរបស់វិបស្សនា* ........ ...... ...... ...... ...... ...... ........ ៥៦៤

*កម្មបថ និងមិច្ឆត្ត* ........ ...... ...... ...... ...... ...... ........ ៥៦៧

*អវិហិង្សាដូចកំពង់ទឹក* ........ ...... ...... ...... ...... ...... ........ ៥៧៨

*កាមគុណដូចភក់* ........ ...... ...... ...... ...... ...... ........ ៥៨០

**សម្មាទិដ្ឋិសូត្រទី ៩** ........ ...... ...... ...... ...... ...... ........ ៥៨៨

**អដ្ឋកថា សម្មាទិដ្ឋិសូត្រ** ........ ...... ...... ...... ...... ...... ........ ៦១៣

អធិប្បាយអកុសលកម្មបថ ១០ ...... ...... ...... ...... ...... ...... ៦១៧
អាការ ៥ ក្នុងអកុសលកម្មបថ ...... ...... ...... ...... ...... ...... ៦២៨
អធិប្បាយកុសលកម្មបថ ...... ...... ...... ...... ...... ...... ៦៣១
វិរតិ ៣ ...... ...... ...... ...... ...... ...... ៦៣២
រឿងចក្កនឧបាសក ...... ...... ...... ...... ...... ...... ៦៣២
រឿងឧបាសកអ្នកក្នុងឧត្តរវឌ្ឍមាន: ...... ...... ...... ...... ...... ...... ៦៣៣
អាការ ៥ ក្នុងកុសលកម្មបថ ...... ...... ...... ...... ...... ...... ៦៣៤
ចែកកម្មបថដោយសច្ច: ...... ...... ...... ...... ...... ...... ៦៣៧
អធិប្បាយអាហារវារ: ( កូត និងសម្មាវេសី ) ...... ...... ...... ...... ៦៣៩
អធិប្បាយសច្ចវារ: ...... ...... ...... ...... ...... ...... ៦៥៩
អធិប្បាយជរាមរណវារ: ...... ...... ...... ...... ...... ...... ៦៥៩
អធិប្បាយជាតិវារ: ...... ...... ...... ...... ...... ...... ៦៦៥
អធិប្បាយភវវារ: ...... ...... ...... ...... ...... ...... ៦៦៧
អធិប្បាយឧបាទានវារ: ...... ...... ...... ...... ...... ...... ៦៦៨
អធិប្បាយតណ្ហាវារ: ( តណ្ហា ១០៨ ) ...... ...... ...... ...... ...... ៦៧១
អធិប្បាយវេទនាវារ: ...... ...... ...... ...... ...... ...... ៦៧៣
អធិប្បាយផស្សវារ: ...... ...... ...... ...... ...... ...... ៦៧៤
អធិប្បាយសឡាយតនវារ: ...... ...... ...... ...... ...... ...... ៦៧៥
អធិប្បាយនាមរូបវារ: ...... ...... ...... ...... ...... ...... ៦៧៦
អធិប្បាយវិញ្ញាណវារ: ...... ...... ...... ...... ...... ...... ៦៧៨
អធិប្បាយសង្ខារវារ: ...... ...... ...... ...... ...... ...... ៦៧៨
អធិប្បាយអវិជ្ជាវារ: ...... ...... ...... ...... ...... ...... ៦៧៩
អធិប្បាយអាសវវារ: ...... ...... ...... ...... ...... ...... ៦៨២

**សតិប្បដ្ឋានសូត្រទី ១០** ........ ...... ...... ...... ...... ...... ....... ៦៨៥

**អដ្ឋកថា សតិប្បដ្ឋានសូត្រ** ( ការមកនៃពាក្យថា កុរុ ) ...... ....... ៧២៨

ការមករបស់ពាក្យថា កម្មាសធម្ម ...... ...... ...... ...... ...... ...... ៧៣១

ពោលអំពីឧទ្ទេសវារកថា ...... ...... ...... ...... ...... ...... ៧៣៣

សេកចម្រើនសតិប្បដ្ឋាន ...... ...... ...... ...... ...... ...... ៧៣៥

រឿងព្រះតិស្សត្ថេរ ........ ...... ...... ...... ...... ...... ....... ៧៤៤

រឿងភិក្ខុ ៣០ អង្គ ........ ...... ...... ...... ...... ...... ....... ៧៤៥

រឿងព្រះទីឃមល្លត្ថេរ ........ ...... ...... ...... ...... ...... ....... ៧៤៧

រឿងព្រះឥន្ទ្រចុតិ
រឿងសុព្រហ្មទេវបុត្រចុតិ } ....... ...... ...... ...... ...... ...... ...... ៧៤៨

ហេតុដែលទ្រង់ត្រាស់សតិប្បដ្ឋានទុកត្រឹមតែ ៤ ...... ...... ...... ...... ៧៥៧

អធិប្បាយពាក្យថា កាយ ...... ...... ...... ...... ...... ...... ៧៦១

អធិប្បាយវេទនានុបស្សនា ...... ...... ...... ...... ...... ...... ៧៧២

កាយានុបស្សនា ( អានាបានបព្វៈ )...... ...... ...... ...... ...... ...... ៧៧៥

អធិប្បាយឥរិយាបថបព្វៈ ...... ...... ...... ...... ...... ...... ៧៨៣

អធិប្បាយសម្បជញ្ញបព្វៈ ...... ...... ...... ...... ...... ...... ៧៨៨

រឿងភិក្ខុកំលោះ ........ ...... ...... ...... ...... ...... ....... ៧៩១

គតបច្ចាគតិវត្ត ........ ...... ...... ...... ...... ...... ....... ៧៩២

រឿងព្រះមហាបុស្សទេវត្ថេរ ...... ...... ...... ...... ...... ...... ៧៩៧

រឿងព្រះមហានាគត្ថេរ ...... ...... ...... ...... ...... ...... ៧៩៨

រឿងភិក្ខុ ៥០ រូប ........ ...... ...... ...... ...... ...... ....... ៧៩៩

រឿងព្រះមហាថេរៈ ........ ...... ...... ...... ...... ...... ....... ៨១១

អធិប្បាយបដិកូលមនសិការបព្វៈ ...... ...... ...... ...... ...... ...... ៨២៣

អធិប្បាយនវសីវថិកាបព្វៈ ...... ...... ...... ...... ...... ...... ៨២៧
អធិប្បាយវេទនានុបស្សនា ...... ...... ...... ...... ...... ...... ៨៣៣
រឿងព្រះថេរៈនៅត្រង់ចិត្តលតាបព៌ត .. ...... ...... ...... ...... ៨៣៥
អធិប្បាយចិត្តានុបស្សនា ...... ...... ...... ...... ...... ...... ៨៤៤
អធិប្បាយធម្មានុបស្សនា ...... ...... ...... ...... ...... ...... ៨៤៧
នីវរណបព្វៈ ...... ...... ...... ...... ...... ...... ៨៤៨
ខន្ធបព្វៈ ...... ...... ...... ...... ...... ...... ៨៦០
អាយតនបព្វៈ ...... ...... ...... ...... ...... ...... ៨៦២
ពោជ្ឈង្គបព្វៈ ...... ...... ...... ...... ...... ...... ៨៦៥
រឿងព្រះមហាមិត្តត្ថេរ ...... ...... ...... ...... ...... ...... ៨៧៥
សច្ចបព្វៈ ........ ...... ...... ...... ...... ...... ....... ៨៨៩
អានិសង្សក្នុងការចម្រើនសតិប្បដ្ឋាន ...... ...... ...... ...... ...... ....... ៨៩១